# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៤៥

បាលីប្រែ ៥៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## ជាតកដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## សត្តមភាគ

## ៤៥

## បាលីប្រែ ៥៨



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤៥
# សុត្តន្តបិដក ខុទ្ទកនិកាយ
# សត្តមភាគ

*សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ឯកនិបាត ជាតក ២២
## អបណ្ណកវគ្គ

### អបណ្ណកជាតក

[១] *(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) បុគ្គលពួកខ្លះ ជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស បុគ្គលពួកខ្លះ ត្រិះរិះយកឯង រមែងប្រកាន់ហេតុទី ២ ( ហេតុខុស ) មេធាវីបុគ្គល បានដឹងនូវហេតុដែលខុស និងហេតុដែលមិនខុសនេះហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ។*

*អបណ្ណកជាតកទី ១ ចប់*

# អដ្ឋកថា

# ខុទ្ទកនិកាយ ជាតកដ្ឋកថា

# ឯកនិបាត

# ទូរេនិទាន

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បណាមគាថា

ប្រយោជន៍សម្រាប់សត្វលោកដែលគណនាមិនបាន ប្រមាណមិនកើត ដែលព្រះមហេសី ជាទីពឹងនៃសត្វលោក ទ្រង់បានបំពេញហើយ ដោយជាតិរាប់ពាន់កោដិ ខ្ញុំសូមនមស្ការ ទៀបបាទារបស់ព្រះមហេសីអង្គនោះ និងសូមធ្វើអញ្ជលីដល់ព្រះធម៌ និងសូមនមស្ការចំពោះព្រះសង្ឃ ដែលដូចជាភាជនៈទទួលនូវការគោរព និងសក្ការៈទាំងពួង ។

ដោយអានុភាពនៃបុណ្យ គឺការថ្វាយបង្គំដែលប្រព្រឹត្តទៅហើយ ក្នុងព្រះរតនត្រ័យ សូមឧបទ្រព និងអន្តរាយទាំងពួងវិនាសទៅ ។ ជាតកទាំងឡាយចាប់ផ្តើមអំពីអបណ្ណកជាតក ដែលព្រះមហេសីទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ទ្រង់ដោះសព្វសត្វឲ្យចេញចាកទុក្ខ ទ្រង់ជាលោកនាយក បានសន្សំអប់រំពោធិសម្ភារដែលមិនមានទីបំផុត អស់កាលយូរ ទ្រង់សម្តែងហើយ ដោយអាស្រ័យហេតុនោះៗ ។

ម្យ៉ាងទៀត ជាតកឯណា ដែលព្រះធម្មសង្គាហកាចារ្យបានចងក្រងរឿង

ដែលកើតឡើងនោះៗ ទុកជាពួកលើកឡើងកាន់សង្គាយនាហើយ ខ្ញុំ ( ពុទ្ធឃោសាចារ្យ ) ដែលព្រះថេរៈទាំងពីរ ជាអ្នកសម្រឹងនូវប្រយោជន៍ ប្រាថ្នានូវការតាំងនៅដ៏វែងឆ្ងាយនៃពុទ្ធវង្ស ព្រះថេរៈទាំងពីរអង្គនោះ គឺព្រះពុទ្ធមិត្តអ្នកមានប្រក្រតីនៅដោយមិនច្រឡូកច្រឡំ ដោយពួក ដោយគណៈ មានធម៌ជាគ្រឿងនៅបរិសុទ្ធ មានចិត្តស្ងប់ ជាអ្នកឈ្លាស និងភិក្ខុឈ្មោះពុទ្ធទេវៈអ្នកកើតក្នុងត្រកូលមហឹសាសៈ ជាអ្នកដឹងន័យ ជាអ្នកបរិសុទ្ធ អារាធនាហើយ ។

ខ្ញុំនឹងពោលសុភាសិតដែលពណ៌នានូវអត្ថរបស់ជាតកនោះ ដែលធ្វើបញ្ជាំងដល់អានុភាពនៃចរិយារបស់ព្រះមហាបុរស ដែលជាអចិន្តេយ្យ ដែលអាស្រ័យកថាមគ្គរបស់ព្រះថេរៈ អ្នកនៅក្នុងមហាវិហារជាគំរូ សូមសាធុជនទាំងឡាយតាំងចិត្តសិក្សាដោយល្អចុះ ។

## និទានកថា

កិច្ចពណ៌នាអត្ថប្បវត្តិនោះ កាលខ្ញុំនឹងសម្ដែងនិទាន ៣ គឺ **ទូរេនិទាន ១ អវិទូរេនិទាន ១ សន្តិកេនិទាន ១** ដើម្បីឲ្យយល់បានងាយ ព្រោះបុគ្គលនឹងបានយល់ក្នុងខណៈដែលបានអាន បានស្ដាប់ហើយ ព្រោះហេតុនោះ ខ្ញុំនឹងសម្ដែងនិទានទាំងនោះ ពណ៌នាប្រវត្តិនោះ បណ្ដានិទាននោះ គួរជ្រាបបរិច្ឆេទជាមុនសិន ។ កថាមគ្គ ដែលពោលរឿងតាំងអំពីព្រះមហាសត្វ បានតាំងសេចក្ដីប្រាថ្នាយ៉ាងពិតប្រាកដ ទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមទីបង្ករ រហូតដល់ចុតិអំពីអត្តភាពជាព្រះវេស្សន្តរ ហើយបានទៅកើតក្នុងជាន់តុសិត

ចាត់ជាទូរេនិទាន ។

កថាមគ្គ ដែលពោលតាំងអំពីចុតិចាកស្ថានសួគ៌ជាន់តុសិត រហូតដល់សម្រេចសព្វញ្ញុតញ្ញាណត្រង់មណ្ឌលពោធិព្រឹក្ស ចាត់ជាអវិទូរេនិទាន ។

ឯសន្តិកេនិទាន មានប្រាកដក្នុងទីផ្សេងៗ របស់ព្រះសាស្ដា ដែលទ្រង់ប្រថាប់នៅក្នុងទីនោះៗ ដោយប្រការដូច្នេះ ។

# ទូរេនិទាន

ក្នុងនិទានទាំងនោះ ដែលឈ្មោះថា **ទូរេនិទាន** មានដូចតទៅនេះ

បានឮថា ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប អំពីកប្បនេះ មាននគរមួយឈ្មោះអមរវតី ក្នុងនគរនោះ មានព្រាហ្មណ៍ម្នាក់ ឈ្មោះសុមេធ នៅអាស្រ័យ គាត់មានកំណើតល្អ មានគភ៌បរិសុទ្ធ ទាំងខាងម្ដាយ និងខាងឪពុក រាប់បាន ៧ តំណាត្រកូល ដែលបុគ្គលណាម្នាក់មើលងាយមិនបាន តិះដៀលមិនបានដោយជាតិត្រកូល ជាបុរសមានរូបស្អាត គួរមើល គួរជ្រះថ្លា ប្រកបដោយពណ៌សម្បុរល្អក្រៃលែង គាត់មិនធ្វើការងារដទៃឡើយ សិក្សាតែសិប្បៈរបស់ព្រាហ្មណ៍ ។ មាតា និងបិតារបស់គាត់អនិច្ចកម្មហើយ តាំងអំពីគាត់នៅជាកំលោះ ។ បន្ទាប់មក នាយឃ្លាំង នាំបញ្ជីទ្រព្យមក បើកឃ្លាំងដែលពេញដោយមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ជម្រាបដល់ទ្រព្យទាំង ៧ ជួរត្រកូលថា បពិត្រកុមារ ទ្រព្យប៉ុណ្ណេះ ជារបស់ខាងម្ដាយ ទ្រព្យប៉ុណ្ណេះ ជាទ្រព្យខាងឪពុក ទ្រព្យប៉ុណ្ណេះ ជាទ្រព្យខាងជីតា និងតាទួត ហើយប្រាប់ថា សូមលោកចាត់ចែងចុះ ។ សុមេធបណ្ឌិតគិតថា ជីតា

ជាដើមរបស់អញសន្សំទ្រព្យនេះទុកហើយ កាលទៅកាន់បរលោក ឈ្មោះថា កាន់យកទ្រព្យសូម្បីត្រឹមតែ ១ កហាបណៈទៅក៏មិនបាន តែអញនឹងធ្វើហេតុឲ្យកាន់យកទ្រព្យទៅឲ្យបាន ដូច្នេះហើយ បានក្រាបទូលដល់ព្រះរាជាឲ្យវាយស្គរ ប្រកាសក្នុងព្រះនគរ ឲ្យទានដល់មហាជនហើយ ចេញបួសជាតាបស ។ ដើម្បីឲ្យអត្ថនេះជាក់ច្បាស់ គួរពោលសុមេធកថាទុកក្នុងទីនេះផងដែរ តែសុមេធកថានេះ មកហើយ ក្នុងពុទ្ធវង្សជាប់តគ្នា តែព្រោះពោលរឿងប្រព័ន្ធជាគាថា ទើបមិនប្រាកដឲ្យជាក់ច្បាស់ពេក ព្រោះដូច្នោះ ខ្ញុំនឹងពោល មួយអន្លើដោយការសម្តែងពាក្យ ដែលប្រព័ន្ធជាគាថាបញ្ចូលក្នុងចន្លោះៗ ។

## សុមេធកថា

ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប មាននគរឈ្មោះ អមរវតី និងឈ្មោះមួយទៀតថា **អមរ** អឺងកងទៅដោយសំឡេង ១០ ដែលលោកបំណងពោលនៅក្នុងពុទ្ធវង្សថា

ក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប មាននគរឈ្មោះ អមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយ និងទឹក ទាំងមិនស្ងាត់ដោយមានសំឡេង ១០ យ៉ាង គឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧសហិ សត្តេហិ អវិវិត្តំ** សេចក្តីថា អឺងកងទៅដោយសំឡេងទាំងនេះ គឺសំឡេងដំរី សំឡេងសេះ សំឡេងរថ

សំឡេងស្គរ សំឡេងសម្ភោរ សំឡេងពិណ សំឡេងមហោស្រព សំឡេងប្រគំ សំឡេងស័ង្ខ និងសំឡេងជាគម្រប់ ១០ ថា អញ្ជើញបរិភោគ អញ្ជើញទំពា អញ្ជើញផឹក លោកកាន់យកត្រឹមតែឯកទេសមួយ នៃសំឡេងទាំងនោះ ទើបពោលគាថាទាំងនេះ ក្នុងគម្ពីរពុទ្ធវង្សថា

ទាំងជានគរគឹកកងដោយសំឡេង ដែលប្រកបដោយបាយ និងទឹក ថា ចូរស៊ី ចូរផឹក ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង ។ បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿងបរិភោគ និងឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។ វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ដូច្នេះ ។

ថ្ងៃមួយ សុមេធបណ្ឌិតនោះ ទៅក្នុងទីសម្ងំ លើផ្ទៃប្រាសាទជាន់លើ អង្គុយពត់ភ្នែន គិតថា នៃបណ្ឌិត ការកើត ឈ្មោះថា បដិសន្ធិ ជាទុក្ខ ការបែកធ្លាយនៃសរីរៈ ក្នុងទីដែលកើតហើយ ក៏ជាទុក្ខដូចគ្នា អាត្មាអញក៏មានការកើតជាធម្មតា មានការចាស់ជាធម្មតា មានជំងឺជាធម្មតា មានការស្លាប់ជាធម្មតា បុគ្គលដូចអញនេះ នឹងស្វែងរកមហានិព្វានដែលមិនកើត មិនចាស់

មិនឈឺ មិនមានទុក្ខ មានតែសេចក្តីសុខត្រជាក់ មិនស្លាប់ ជាផ្លូវតែមួយ ដែលផុតចាកភព មានប្រក្រតីនាំទៅកាន់ព្រះនិព្វាន នឹងគប្បីមានពិតប្រាកដ ដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាកពថ្មី ទៀតតែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវ សេចក្តីទុក្ខដូចគ្នា ( សេចក្តីស្លាប់ប្រកបដោយមោហៈ នាំមកនូវ ទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ ) អាត្មាអញមាន ជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញ នឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ដូច្នេះ ។

បន្ទាប់អំពីនោះ សុមេធបណ្ឌិត ក៏គិតក្រៃលែងបន្តទៀតថា ឈ្មោះថា សុខ ជាបដិបក្ខចំពោះទុក្ខ មានក្នុងលោក យ៉ាងណា កាលបើភពមាន វត្ថុ ដែលប្រាសចាកភព ជាបដិបក្ខចំពោះភពនោះ ក៏គប្បីមាន ដូច្នោះ បើក្តៅ មាន ត្រជាក់ដែលរម្ងាប់ក្តៅនោះក៏មាន យ៉ាងណា ព្រះនិព្វានដែលរម្ងាប់ភ្លើង មានរាគៈជាដើម ក៏គប្បីមាន ដូច្នោះ ធម៌ដែលមិនមានទោស ជាធម៌ស្អាត ជាបដិបក្ខចំពោះធម៌ដែលជាបាបលាមក រមែងមាន យ៉ាងណា កាលជាតិ គឺ ការកើតដ៏លាមកមាន ព្រះនិព្វាន ពោល គឺការមិនកើត ព្រោះឲ្យការកើត គ្រប់យ៉ាងអស់ទៅ ក៏គប្បីមាន យ៉ាងនោះ ព្រោះហេតុនោះ ទើបលោក ពោលថា

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើកពមាន ការប្រាសចាកកព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នាក៏មាន យ៉ាងនោះដែរ ដូច្នេះ ។

សុមេធបណ្ឌិតគិតសេចក្តីដទៃទៀតថា បុរសធ្លាក់ក្នុងគំនរលាមក ឃើញស្រះធំ ដេរដាសដោយផ្កាឈូក មានពណ៌ ៥ អំពីចម្ងាយ គួរតែស្វែងរកស្រះនោះ ដោយគិតថា អញគួរទៅកាន់ស្រះនោះ ដោយផ្លូវណាហ្ន៎ ការមិនស្វែងរកស្រះនោះ មិនជាទោសរបស់ស្រះនោះឡើយ តែជាទោសរបស់បុរសនោះប៉ុណ្ណោះ យ៉ាងណា កាលស្រះធំ គឺអមតមហានិព្វាន ជាទីជម្រះ លាងមន្ទិល គឺកិលេសមាន ការមិនស្វែងរកស្រះនោះ មិនមែនជាទោសរបស់ស្រះធំ គឺអមតនិព្វាន តែជាទោសរបស់បុរសនោះប៉ុណ្ណោះ ដូច្នោះដូចគ្នា ។ ម្យ៉ាងទៀត បុរសត្រូវចោរហ៊ុមព័ទ្ធ កាលផ្លូវសម្រាប់រត់ចេញមាន បើបុរសនោះ មិនរត់ចេញទៅ សេចក្តីនោះមិនមែនជាទោសរបស់ផ្លូវឡើយ តែជាទោសនៃបុរសនោះ យ៉ាងណា បុរសដែលត្រូវកិលេសចោមរោម ចាប់បានហើយ កាលផ្លូវដែលត្រជាក់ជាទីទៅកាន់ព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ មិនមែនជាទោសនៃផ្លូវឡើយ ជាទោសរបស់បុរសនោះប៉ុណ្ណោះយ៉ាងនោះដូចគ្នា ។ បុរសដែលត្រូវព្យាធិបៀតបៀន កាលគ្រូពេទ្យអ្នកព្យាបាលជំងឺមាន បុរសនោះមិនស្វែងរកពេទ្យនោះឲ្យព្យាបាលជំងឺ សេចក្តីនោះ មិនមែនជាកំហុសរបស់ពេទ្យឡើយ តែជាកំហុសរបស់បុរសនោះ

យ៉ាងណា បុគ្គលត្រូវព្យាធិ គឺកិលេសបៀតបៀន មិនស្វែងរកអាចារ្យអ្នកឈ្លាសក្នុងការរម្ងាប់កិលេសដែលមាន សេចក្តីនោះ ជាទោសរបស់បុរសនោះប៉ុណ្ណោះ មិនមែនជាទោសរបស់អាចារ្យដែលធ្វើនូវកិលេសឲ្យវិនាសឡើយ ព្រោះដូច្នោះ ទើបលោកពោលថា

បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេស ជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯងយ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយបៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះ មិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះ

ឯង យ៉ាងនោះដែរ ដូច្នេះ ។

សុមេធបណ្ឌិតពិចារណាសេចក្ដីដទៃទៀតថា បុគ្គលដែលចូលចិត្តតែង ខ្លួន គប្បីគ្រវាត់ចោលនូវសាកសព ដែលព្យួរត្រង់កទៅ យ៉ាងមានសេចក្ដីសុខ យ៉ាងណា សូម្បីអាត្មាអញ ក៏គួរលោសនូវរាងកាយស្អុយនេះ ដោយមិនអាល័យ ចូលទៅកាន់នគរ គឺព្រះនិព្វាន ដូច្នោះ ។ បុរស ស្ត្រីទាំងឡាយ បន្ទោបង់ឧច្ចារៈ និងបស្សាវៈ ដាក់លើផែនដី ដែលស្មោកគ្រោក ហើយមិនគិតថា អញនឹងរើសដាក់ថ្នក់ ឬយកជាយសំពត់ខ្ចប់ទៅ តែងរង្កៀស មិនមានអាល័យឡើយ បោះបង់ចោលទៅ យ៉ាងណា អញក៏គួរមិនមានអាល័យ លោសចោលនូវកាយស្អុយនេះ ទៅកាន់នគរ គឺនិព្វានដែលជាអមតៈ ដូច្នោះ នាយសំពៅមិនមានអាល័យ លះបង់សំពៅចាស់គ្រាំគ្រាទៅ យ៉ាងណា សូម្បីអញក៏លះបង់នូវកាយ ដែលជាទីហូរចេញអំពីមុខដំបៅទាំង ៩ នេះ មិនមានអាល័យ ចូលទៅកាន់និព្វានបុរី ក៏ដូច្នោះ ។ មួយវិញទៀត បុរសនាំយកកែវច្រើនប្រការ ធ្វើដំណើរទៅជាមួយចោរ គប្បីលះពួកចោរទាំងនោះ ព្រោះខ្លាចបាត់បង់នូវកែវរបស់ខ្លួន កាន់យកផ្លូវដែលផុតភ័យ យ៉ាងណា ករជកាយ គឺកាយដែលកើតអំពីធូលីនេះ ក៏ដូច្នោះ ដូចគ្នានឹងចោរប្លន់កែវ បើអញញ៉ាំងតណ្ហាឡើងក្នុងកាយនេះ កែវ គឺព្រះធម៌ដែលជាកុសល គឺអរិយមគ្គនឹងសូន្យ ព្រោះដូច្នោះ គួរអញបោះបង់នូវកាយ ដែលដូចគ្នានឹងចោរនេះចេញ ហើយចូលទៅកាន់នគរនិព្វាន ដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

បុរសបានស្រាយសាកសពដ៏គួរខ្ពើមរអើម ដែលជាប់ព្ធដ៏ក គប្បី

ជាអ្នកមានសេចក្តីសុខនៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ ។ បុរសស្ត្រីទាំងឡាយទៅបន្ទោបង់នូវករីសក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញ នឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះបោលនូវទូកចាស់ ដូច្នោះឯង ។ បុរស កាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យក៏លះបង់ ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញ នឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ដូច្នេះ ។

សុមេធបណ្ឌិត គិតអត្ថប្រកបដោយនេក្ខម្មៈនេះ ដោយឧបមាផ្សេងៗ ហើយលះនូវគំនរភោគសម្បត្តិ ដែលមិនអាចរាប់អស់ ក្នុងផ្ទះរបស់ខ្លួន ដល់

ពួកជន មានមនុស្សកំព្រា និងអ្នកដើរផ្លូវឆ្ងាយជាដើម ថ្វាយមហាទាន លះវត្ថុកាមហើយ ចេញអំពីអមរនគរម្នាក់ឯងប៉ុណ្ណោះ អាស្រ័យភ្នំឈ្មោះធម្មិកៈ ក្នុងព្រៃហិមពាន្ត ធ្វើអាស្រម និម្មិតបណ្ណសាលា និងទីចង្ក្រម ដោយកម្លាំងបុណ្យរបស់ខ្លួន ដើម្បីនឹងវៀរបង់ចាកទោស គឺនីវរណៈទាំង ៥ នាំមកនូវកម្លាំង ពោល គឺអភិញ្ញាដែលប្រកបដោយហេតុ ដែលជាគុណ ៨ យ៉ាង តាមដែលពោលដោយន័យជាដើមថា បើចិត្តមាំទាំហើយយ៉ាងនេះ ដូច្នេះហើយ លះបង់នូវសំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ហើយស្លៀកសំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ យ៉ាង បួសជាឥសី ។ កាលបួសហើយយ៉ាងនេះ ក៏លះបណ្ណសាលានោះ ដែលដេរដាសទៅដោយទោស ៨ ប្រការ ចូលទៅរកគល់ឈើ ដែលប្រកបដោយគុណ ១០ យ៉ាង លះបង់នូវបាយផ្សេងៗ បរិភោគផ្លែឈើដែលជ្រុះឯង តាំងនូវសេចក្ដីព្យាយាម ដោយអំណាចការអង្គុយ ការឈរ និងការចង្ក្រម ក្នុង ៧ ថ្ងៃនោះឯង ក៏បានសមាបត្តិ ៨ និងអភិញ្ញា ៥ ដល់នូវកម្លាំងនៃអភិញ្ញាតាមដែលប្រាថ្នានោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះទើបលោកពោលថា

> លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ។ តថាគត

និម្មិតនូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពល ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។ តថាគតផ្គងព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ដូច្នេះ ។

ក្នុងគាថានោះ បាលីថា **អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា** លោកពោលដល់បណ្ណសាលា និងទីចង្ក្រម ថាដូចសុមេធបណ្ឌិតសាងឡើង ដោយដៃខ្លួនឯង តែក្នុងគាថានេះ មានសេចក្តីដូចតទៅនេះ សក្កទេវរាជទ្រង់ឃើញថា ព្រះមហាសត្វចូលកាន់ព្រៃហិមពាន្តហើយ ថ្ងៃនេះ នឹងដល់ភ្នំឈ្មោះធម្មិកៈ ទើបហៅវិស្សកម្មទេវបុត្តមកថា នែបា សុមេធបណ្ឌិតចេញមក ដោយគិតថា អញនឹងបួស ចូរអ្នកនិម្មិតលំនៅដល់ព្រះមហាសត្វនោះ ។ វិស្សកម្មទេវបុត្តនោះ ទទួលព្រះតម្រាស់របស់ព្រះឥន្ទ្រហើយ ទើបនិម្មិតអាស្រមគួរជាទីត្រេកអរ បណ្ណសាលាយ៉ាងល្អ ទីចង្ក្រម

ដ៏គួររីករាយ តែព្រះមានព្រះភាគ ទ្រង់អាស្រ័យអាស្រមបទនោះ ដែលសម្រេចដោយអានុភាពនៃបុណ្យរបស់ព្រះអង្គ ទើបត្រាស់ថា

មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម

សាងបណ្ណសាលាក្បែរភ្នំនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុកតោ មយ្ហំ** បានដល់ តថាគតសាងអាស្រមយ៉ាងល្អហើយ ។ បទថា **បណ្ណសាលា សុមាបិតា** សេចក្ដីថា បណ្ណសាលាដែលប្រក់ដោយស្លឹក តថាគតក៏សាងល្អហើយ ។ បទថា **បញ្ចទោសវិវជ្ជិតំ** សេចក្ដីថា ឈ្មោះថា ទោសនៃទីចង្ក្រមមាន ៥ យ៉ាង គឺផ្ទៃដីមិនរាបស្មើ ១ មានដើមឈើខាងក្នុងទីចង្ក្រម ១ ដំបូលប្រក់ខាងលើស្មុគស្មាញ ១ តូចពេក ១ ធំពេក ១ ។ ពិតហើយ បុគ្គល កាលដើរចង្ក្រមលើទីចង្ក្រមដែលមានផ្ទៃដីរឹង និងមិនរាបស្មើ ជើងទាំង ២ រមែងឈឺចាប់ ឬហើម ចិត្តមិនជាឯកគ្គតា កម្មដ្ឋាននឹងវិបត្តិ តែកម្មដ្ឋានដល់ព្រមដោយអាស្រ័យការនៅសប្បាយ ក្នុងទីដែលទន់ និងរាបស្មើ ព្រោះដូច្នោះគប្បីជ្រាបថា ទីដែលមិនរាបស្មើជាទោស ១ ។ កាលដើមឈើមាននៅក្នុងទីចង្ក្រម ត្រង់កណ្ដាលក្ដី ត្រង់ខាងចុងក្ដី កាលអាស្រ័យសេចក្ដីប្រមាទ ថ្ងាស ឬក្បាលរមែងទង្គិច ព្រោះដូច្នោះ ដើមឈើក្នុងទីចង្ក្រមជាទោសទី ២ ។ កាលដើរចង្ក្រមលើទីចង្ក្រមដែលមានដំបូល ខាងលើស្មុគស្មាញដោយស្មៅ និងវល្លិជាដើម ក្នុងពេលយប់ ក៏នឹងជាន់សត្វ មានពស់ជាដើម ធ្វើឲ្យសត្វទាំងនោះស្លាប់ ឬត្រូវសត្វទាំងនោះខាំ បានទទួលការក្ដៅក្រហាយ ព្រោះ

ដូច្នោះ ការដែលទីប្រក់ស្មុគស្មាញ ទើបជាទោសទី ៣ កាលដើរចង្ក្រមលើទីចង្ក្រមតូចពេក ដែលមានកំណត់ទទឹង ១ ហត្ថ ឬកន្លះហត្ថ ក្រចកក្តីម្រាមដៃក្តី នឹងប៉ះរបស់ផ្សេងៗ ហើយបែក ទើបទីចង្ក្រមតូចពេក ជាទោសប្រការទី ៤ ។ កាលដើរចង្ក្រមលើទីចង្ក្រមដែលធំពេក ចិត្តរមែងរាយមាយមិនមានឯកគ្គតា ព្រោះដូច្នោះ ទើបទីចង្ក្រមធំពេក ជាទោសប្រការទី ៥ ។ ទីចង្ក្រមដែលមានទទឹង ១ ហត្ថកន្លះ ជាយម្ខាង ១ ហត្ថ ( រួមជា ៣ ហត្ថកន្លះ ) បណ្តោយ ៦០ ហត្ថ មានផ្ទៃដីទន់ រោយដោយដីខ្សាច់រាបស្មើ ប្រើការបាន ដូចទីចង្ក្រមរបស់ព្រះមហិន្ទត្ថេរ ដែលជាអ្នកបណ្តុះសេចក្តីជ្រះថ្លាដល់អ្នកកោះ ត្រង់ចេតិយគិរីវិហារ ក៏មានសភាពយ៉ាងនេះ ព្រោះហេតុនោះទើបលោកពោលថា តថាគតនិម្មិតនូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការដូច្នេះ ។

បទថា **អដ្ឋគុណសមុបេតំ** គឺប្រកបដោយសុខរបស់សមណៈ ៨ ប្រការ ឈ្មោះថា សុខរបស់សមណៈ ៨ ប្រការ គឺមិនមានការហួងហែងទ្រព្យមានស្រូវអង្ករជាដើម ១ ស្វែងរកតែបិណ្ឌបាតដែលមិនមានទោស ១ បរិភោគតែបិណ្ឌបាតដែលត្រជាក់ ១ មិនមានការបៀតបៀនអំពីព្រះរាជាទាំងឡាយមានបៀតបៀនដោយកាស៊ី ឬដោយការរឹបអូសយកទ្រព្យមានតម្លៃ និងកហាបណៈជាដើម ១ ប្រាសចាកតម្រេកដោយការពេញចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ ១ មិនមានភ័យក្នុងរឿងចោរ ១ មិនប្រឡូកប្រឡំជាមួយព្រះរាជានិងអមាត្យជាដើម ១ មិនទើសទាក់ក្នុងទិសទាំងបួន ១ ។ លោកអធិប្បាយ

ថា បុគ្គលដែលនៅក្នុងអាស្រមនោះអាចជួបសុខរបស់សមណៈទាំងនេះបាន យ៉ាងណា តថាគតសាងអាស្រមនោះដែលប្រកបដោយគុណ ៨ យ៉ាង ក៏ យ៉ាងនោះ ។ បទថា **អភិញ្ញាពលសមាហរឹ** សេចក្តីថា ក្រោយមក កាល តថាគតនៅក្នុងអាស្រមនោះ ធ្វើបរិកម្មក្នុងកសិណហើយ ផ្តើមចម្រើន វិបស្សនា ដោយជារបស់មិនទៀង ជាទុក្ខ ដើម្បីការកើតឡើងនៃអភិញ្ញា និងសមាបត្តិ ហើយក៏បានកម្លាំងនៃវិបស្សនា ដែលទ្រទ្រង់នូវកម្លាំង ។ អធិប្បាយថា កាលតថាគតនៅក្នុងអាស្រមនោះ អាចនាំកម្លាំងនោះមកបាន យ៉ាងណា តថាគតបានសាងអាស្រមនោះ សមគួរដល់កម្លាំងនៃវិបស្សនា នោះ ដើម្បីជាប្រយោជន៍ដល់អភិញ្ញានោះ ក៏យ៉ាងនោះ ។

ក្នុងគាថានេះថា **សាដកំ បជហឹ តត្ថ នវទោសមុបាគតំ** មានពាក្យ ដែលនឹងពោលតាមលំដាប់ដូចតទៅ បានឮថា ក្នុងកាលនោះ កាលវិស្សុកម្ម- ទេវបុត្តនិម្មិតអាស្រមដែលប្រកបដោយគូប ទីសម្ងំ និងទីចង្រ្កម ដោយផ្ទូវ កោង ដេរដាសទៅដោយដើមឈើចេញផ្លែផ្កា មានទឹក មានរសឆ្ងាញ់ គួរជា ទីត្រេកអរ ប្រាសចាកសត្វសាហាវ និងបក្សី មានសំឡេងយំ គួរខ្លាចផ្សេងៗ គួរដល់ការស្ងប់ស្ងាត់ រៀបចំក្តារក់ដែសម្រាប់ផ្អែកត្រង់ទីបំផុតសងខាងនៃទី ចង្រ្កមដែលតាក់តែងហើយ តម្កល់ផ្ទាំងថ្ម មានពណ៌ដូចសណ្តែកបាយ មាន មុខស្មើ ត្រង់កណ្តាលទីចង្រ្កម ដើម្បីអង្គុយ ។ ខាងក្នុងបណ្ណសាលា និម្មិត សម្ភារៈគ្រប់យ៉ាង ដែលប្រព្រឹត្តទៅដើម្បីឧបការៈដល់បព្វជិតយ៉ាងនេះ គឺ ជដាមណ្ឌល សំពត់សម្បកឈើ បរិក្ខារតាបស មានឈើប្រត់ចម្លាម ៣

ជាដើម ត្រង់បន្ទប់ទឹក មានតម្កល់ក្អមទឹក ស័ង្ខជងទឹក ផ្តិលជងទឹក ត្រង់រោងភ្លើង មានខ្ទះទ្រនើក និងឧសជាដើម ត្រង់ជញ្ជាំងនៃបណ្ណសាលា ចារឹកអក្សរថា បុគ្គលណាម្នាក់ មានបំណងបួស ចូរកាន់យកបរិក្ខារទាំងនេះបួសចុះ ហើយទៅកាន់ទេវលោក ។ សុមេធបណ្ឌិតទៅកាន់ព្រៃហិមពាន្ត តាមផ្លូវនៃញកភ្នំ សម្លឹងមើលទីផាសុក គួរនៅអាស្រ័យរបស់ខ្លួន ឃើញអាស្រមគួរជាទីត្រេកអរ ដែលវិស្សកម្មទេវបុត្រ និម្មិតដែលសក្កទេវរាជប្រទានឲ្យត្រង់ទីហួរនៃស្ទឹង ទើបទៅខាងចុងទីចង្ក្រម មិនបានឃើញស្នាមជើង គិតថាបព្វជិតស្វែងរកកិក្ខាក្នុងស្រុកជិត ហើយហត់នឿយនឹងមក ចូលទៅកាន់បណ្ណសាលា ហើយអង្គុយពិត ទើបរង់ចាំមួយអន្ទាំស្លា គិតថា បព្វជិតយឺតយូរពន់ពេក អញនឹងដឹង ទើបបើកទ្វារកុដិក្នុងបណ្ណសាលា ចូលទៅខាងក្នុងពិនិត្យមើលឆ្វេងស្តាំ អានអក្សរដែលចារត្រង់ជញ្ជាំង ហើយគិតថា កប្បិយ-បរិក្ខារទាំងនេះជារបស់អញ អញនឹងកាន់យកបរិក្ខារទាំងនេះបួស ទើបចោលសំពត់សាដកទាំងគូដែលខ្លួនស្លៀក និងដណ្តប់ហើយ ព្រោះហេតុនោះ ទើបលោកពោលថា តថាគតដោះសំពត់សាដក ដាក់ក្នុងបណ្ណសាលានោះ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការក្នុងអាស្រមបទនោះ ដូច្នេះ ។

បទថា **នវទោសសមុបគតំ** សេចក្តីថា តថាគតកាលដោះសំពត់សាដក ទើបដោះចោលទៅ ព្រោះឃើញទោស ៩ ប្រការ ។ ពិតហើយ សម្រាប់អ្នកបួសជាតាបស ទោស ៩ ប្រការរមែងប្រាកដក្នុងសំពត់សាដក

គឺមានតម្លៃច្រើនជាទោស ១ កើតឡើងព្រោះទាក់ទងនឹងអ្នកដទៃជាទោស ១ សៅហ្មងរហ័ស ព្រោះការប្រើប្រាស់ជាទោស ១ សៅហ្មងព្រោះការប្រើប្រាស់ ហើយត្រូវបោកគក់នឹងជ្រលក់ជាទោស ១ សម្រាប់សំពត់ដែលចាស់ហើយ ត្រូវធ្វើការជួសជុល ឬប្រើសំពត់ប៉ះ ការដែលបានទទួលដោយការស្វែងរកទៀតក៏លំបាកជាទោស ១ មិនសមនឹងការបួសជាតាបសជាទោស ១ ជារបស់ទូទៅដល់សត្រូវ មានចោរជាដើមជាទោស ១ ព្រោះត្រូវថែរក្សាកុំឲ្យសត្រូវកាន់យកទៅបាន ជាគ្រឿងប្រដាប់របស់អ្នកប្រើប្រាស់ជាទោស ១ សម្រាប់បុគ្គលដែលត្រាច់ទៅ ( ប្រកាសខ្លួន ) ជាមនុស្សប្រាថ្នាច្រើន ក្នុងវត្ថុប្រើប្រាស់ប្រចាំខ្លួនជាទោស ១ ។ បទថា **វាកចីរំ និវាសេសឹ** សេចក្តីថា ម្នាលសារីបុត្ត កាលនោះ តថាគតឃើញទោស ៩ ប្រការនេះ ទើបចោលសំពត់សាដក ស្លៀកសំពត់សម្បកឈើ គឺប្រើសំពត់សម្បកឈើដែលហែកស្មៅជំណោកទន្សាយឲ្យជាចម្រៀកតូចធំ ត្បាញចូលគ្នាធ្វើឡើង ដើម្បីជាប្រយោជន៍ប្រើប្រាស់ជាសំពត់ស្លៀក និងសំពត់ដណ្តប់ ។

បទថា **ទ្វាទសគុណមុបាគតំ** សេចក្តីថា ប្រកបដោយអានិសង្ស ១២ ប្រការ ។ ក្នុងសំពត់សម្បកឈើ មានអានិសង្ស ១២ ប្រការ គឺមានតម្លៃថោកសមគួរ ១ អាចធ្វើដោយខ្លួនឯងបាន ១ មិនឆាប់សៅហ្មងដោយការប្រើប្រាស់ សូម្បីបោក ក៏មិនយឺតយូរ ១ ចាស់ទៅព្រោះការប្រើប្រាស់ ក៏មិនចាំបាច់ដេរ ១ កាលស្វែងរកថ្មីក៏ធ្វើបានងាយ ១ សមគួរនឹងការបួសជាតាបស ១ សត្រូវមិនប្រើប្រាស់ ១ កាលប្រើប្រាស់ ក៏មិនជាទីតាំងនៃការ

តាក់តែង ១ ស្លៀកដណ្តប់កំស្រាល ១ ប្រកាសនូវការប្រាថ្នាតិចក្នុងបច្ច័យ គឺចីវរ ១ ការកើតឡើងនៃសម្បកឈើ ជារបស់បានមកដោយធម៌ និងមិនមានទោស ១ សំពត់សម្បកឈើ សូម្បីបាត់ទៅ ក៏មិនសោកស្តាយ ១ ។

បទថា **អដ្ឋទោសសមាកិណ្ណំ បជហឹ បណ្ណសាលកំ** សេចក្តីថា តថាគតលះបង់ដូចម្តេច បានឮថា សុមេធបណ្ឌិតនោះ ដោះសំពត់សាច់ល្អទាំងគូចេញ ហើយកាន់យកសំពត់សម្បកឈើ មានពណ៌ក្រហម ដូចគ្នានឹងផ្កានទោងដែលព្យួរត្រង់ខ្សែស្បៀង ហើយស្លៀកដណ្តប់សំពត់សម្បកឈើមានពណ៌ដូចមាសមួយផ្ទាំងទៀត ពីលើសំពត់សម្បកឈើនោះ ធ្វើស្បែកខ្លាទាំងក្រចក មានសណ្ឋានដូចផ្កាបុសនាគត្រង់ស្មា យកជដាមណ្ឌលពាក់ខ្ទាស់ ដោយឈើរឹងក្នុងផ្នួងសក់ មិនឲ្យកម្រើក ដាក់កុណ្ឌីទឹក មានពណ៌ដូចកែវប្រពាលក្នុងសង្រែក ដូចកម្រងកែវមុក្តា កាន់យកដងរែកដែលកោងក្នុងទី ៣ អន្ទើ ពាក់កុណ្ឌីទឹកត្រង់ចុងដងរែក តម្ពក់ និងកំប្រោង ឈើចម្លាម ៣ ជាដើម ដាក់ត្រង់ចុងម្ខាងទៀត រែកបរិក្ខារតាបសលើចង្កេះស្មា យកដៃស្តាំកាន់ឈើច្រត់ ចេញទៅអំពីបណ្ណសាលា ដើរចង្រ្កមទៅមក លើទីចង្ក្រមប្រមាណ ៦០ ហត្ថ សម្លឹងមើលភេទរបស់ខ្លួន ហើយគិតថា មនោរថរបស់អញដល់ទីបំផុតហើយ បព្វជ្ជារបស់អញ ល្អពិតហ្ន៎ ឈ្មោះថា បព្វជ្ជានេះ ធីរបុរសទាំងពួង មានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើមសរសើរហើយ គ្រឿងចងរបស់គ្រហស្ថ អញលះហើយ អាត្មាអញកំពុងចេញបួស អញបានទូវបព្វជ្ជាដ៏ឧត្តម អញនឹងធ្វើសមណធម៌ អញនឹងបានសុខដែលកើតអំពីមគ្គផល

ដូច្នេះហើយ កើតនូវឧស្សាហ៍ ដាក់អម្រែកតាបសបរិក្ខារចុះ អង្គុយលើផ្ទាំងថ្ម មានពណ៌ដូចសណ្តែកបាយ ដូចបដិមាមាសដូច្នោះ ក្នុងពេលថ្ងៃអស់ទៅ ចូលទៅកាន់បណ្ណសាលា ក្នុងពេលល្ងាច ដេកលើគ្រែដែលត្បាញដោយផ្តៅ ឲ្យខ្លួនបានទទួលអាកាសជាទីសប្បាយ ភ្ញាក់ឡើងពេលទៀបភ្លឺ ពិចារណាដល់ការមករបស់ខ្លួនថា អញឃើញទោសក្នុងឃរាវាស ហើយលះបង់នូវភោគសម្បត្តិរាប់មិនអស់ យសមិនមានទីបំផុត ចូលកាន់ព្រៃ ស្វែងរកនេក្ខម្មៈបួស ចាប់តាំងអំពីនេះទៅ អញប្រព្រឹត្តខ្លួនដោយសេចក្តីប្រមាទមិនគួរឡើយ ព្រោះរុយ គឺមិច្ឆាវិតក្ក រមែងស៊ីបុគ្គលដែលលះការស្ងប់ស្ងាត់ត្រាច់ទៅ ឥឡូវនេះ គួរអញចម្រើនសេចក្តីស្ងប់ស្ងាត់ ដ្បិតថា អញសម្លឹងឃើញការនៅគ្រប់គ្រងផ្ទះ ដោយភាពជារបស់មានតែកង្វល់ ទើបចេញមក បណ្ណសាលានេះគួរពេញចិត្ត ផ្ទៃដីដែលព័ទ្ធដោយរបងរាបស្មើ ហើយមានពណ៌ដូចផ្លែព្នៅទុំ ជញ្ជាំងពណ៌សដូចប្រាក់ ដំបូលស្លឹកឈើ មានពណ៌ដូចជើងព្រាប គ្រែផ្តៅមានពណ៌ដូចសំពត់កម្រាលដ៏ស្អាត លំនៅល្មមអាស្រ័យបានដោយផាសុកសម្បត្តិនៃផ្ទះរបស់អញក៏មិនមានការដល់ព្រមជាងនេះ ដូច្នេះ ជ្រើសរើសទោសរបស់បណ្ណសាលា ក៏បានឃើញទោស ៨ ប្រការ ។ ពិតហើយ ក្នុងការប្រើប្រាស់បណ្ណសាលា មានទោស ៨ ប្រការ គឺត្រូវស្វែងរក ដោយការធ្វើឡើងអំពីសម្ភារៈច្រើនជាទោស ១ ត្រូវជួសជុលជានិច្ចជាទោស ១ ព្រោះមានស្លឹកឈើ និងដីឥតជ្រុះចុះមក ត្រូវយករបស់ទាំងនោះទុកត្រង់ទីដើមជាទោស ១ ធម្មតាសេនាសនៈ ត្រូវបានដល់បុគ្គលដែលមានវ័យចម្រើនមុន បើ

បុគ្គលនោះចូលមក អញត្រូវក្រោកឡើងក្នុងកាលដែលមិនសមគួរ ឯកគ្គ-តាចិត្តក៏មិនមាន ព្រោះដូច្នោះ ការដែលត្រូវជាស់ឲ្យក្រោកឡើងជាទោស ១ ព្រោះកម្ចាត់នូវរងា និងក្តៅ ធ្វើឲ្យរាងកាយទន់ខ្សោយជាទោស ១ បុគ្គលចូលកាន់ផ្ទះ អាចធ្វើកម្មអាក្រក់ណាមួយបាន ព្រោះដូច្នោះ ការបិទបាំងវត្ថុដែលគួរតិះដៀលជាទោស ១ ការហួងហែង ដោយគិតថាជារបស់អញជាទោស ១ ធម្មតាការមានផ្ទះបញ្ជាក់ថា ជាអ្នកមានករិយាជាទោស ១ ជាទូទៅដល់ជនច្រើន ព្រោះជាសាធារណៈដល់សត្វ មានសុច សង្កើច និងតុកកែជាដើមជាទោស ១ ។ ព្រះមហាសត្វ ឃើញទោស ៨ ប្រការនេះហើយ ទើបលះបណ្ណសាលា ។ ព្រោះហេតុនោះ ទើបលោកពោលថា លះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការដូច្នេះ ។

បទថា **ឧបាគមី រុក្ខមូលំ គុណេ ទសហុបាគតំ** សេចក្តីថា ព្រះមហាសត្វពោលថា តថាគតឃាត់នូវទីប្រក់បាំង ចូលរកគល់ឈើដែលប្រកបដោយគុណ ១០ ប្រការ ក្នុងសេចក្តីនោះ គុណ ១០ ប្រការ គឺមានការខ្វល់ខ្វាយតិចជាគុណ ១ ត្រឹមតែចូលទៅប៉ុណ្ណោះក៏នៅបាន មិនចាំបាច់មើលថែរក្សាជាគុណ ១ ទីនោះបោសក្តី មិនបោសក្តី ក៏ប្រើប្រាស់បានយ៉ាងសប្បាយ ការមិនចាំបាច់ថែទាំច្រើនជាគុណ ១ ទីនោះ បិទបាំងនូវការនិទ្ទាមិនបាន ព្រោះកាលខ្លួនធ្វើអាក្រក់ក្នុងទីនោះ រមែងខ្មាស ព្រោះដូច្នោះ ការបិទនូវការនិទ្ទាមិនបានជាគុណ ១ គល់ឈើ ដូចនៅក្នុងទីវាល រមែងមិនញ៉ាំងរាងកាយឲ្យទន់ខ្សោយ ព្រោះដូច្នោះ ទើបរាងកាយមិនទន់ខ្សោយជាគុណ ១ មិនមានការ

ត្រូវធ្វើការហួងហែងជាគុណ ១ ឃាត់បង់បាននូវអាល័យក្នុងផ្ទះជាគុណ ១ មិនមានពាក្យដែលត្រូវពោលថា ខ្ញុំនឹងបោសជូត ចូរពួកអ្នកចេញទៅ ហើយក៏ដេញទៅ ដូចក្នុងផ្ទះដែលទូទៅដល់ជនច្រើនជាគុណ ១ បុគ្គលអ្នកនៅបានទទួលនូវបីតិជាគុណ ១ មិនអាល័យក្នុងអារម្មណ៍ ព្រោះសេនាសនៈ គឺគល់ឈើរកបានងាយ ទោះនៅទីណាក៏ដោយជាគុណ ១ ។ ព្រះមហាសត្វឃើញគុណ ១០ យ៉ាង ទើបពោលថា ចូលទៅកាន់គល់ឈើ ដូច្នេះ ។ ព្រះមហាសត្វកំណត់ហេតុមានប្រមាណប៉ុណ្ណោះហើយ ស្អែកឡើង ក៏ចូលទៅបិណ្ឌបាត ។ កាលនោះ ពួកមនុស្សក្នុងស្រុកដែលសុមេធបណ្ឌិតទៅដល់ បានប្រគេនភិក្ខា ដោយឧស្សាហ៍ធំ លោកធ្វើភត្តកិច្ចហើយ មកកាន់អាស្រមអង្គុយហើយ គិតថា អញបួស ដោយបំណងថា អញនឹងបានអាហារក៏មិនមែន ធម្មតាអាហារដែលឆ្ងាញ់នេះ រមែងញុំាងសេចក្តីស្រវឹង ដោយអំណាចមានះ និងការស្រវឹងក្នុងភាពជាបុរសឲ្យចម្រើន ទីបំផុតនៃទុក្ខ ដែលមានអាហារជាមូលមិនមាន បើដូច្នោះ អាត្មាអញគប្បីលះបង់អាហារ ដែលកើតអំពីស្រូវ ដែលគេព្រោះ និងស្ទូង បរិភោគផ្លែឈើដែលជ្រុះឯង ដូច្នេះ ។ ចាប់តាំងអំពីនោះ លោកធ្វើយ៉ាងនោះ ព្យាយាមខាងក្នុងសប្តាហ៍ ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងបានហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា

លះបង់ស្រូវ ដែលគេព្រោះ គេដាំដោយមិនសេសសល់ កាន់យក
ផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។ តថាគត

ផ្គងព្យាយាមក្នុងអាស្រមបទនោះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្រ្កម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ដូច្នេះ ។

កាលសុមេធតាបសដល់នូវអភិញ្ញាពលយ៉ាងនេះហើយ ឲ្យពេលវេលាកន្លងទៅដោយសុខ ដែលកើតអំពីសមាបត្តិ ។ ព្រះសាស្តាទ្រង់ព្រះនាមថាទីបង្ករកើតឡើងក្នុងលោកហើយ ការបដិសន្ធិ ការកើតឡើង ការត្រាស់ដឹង និងការប្រកាសធម្មចក្រ លោកធាតុ ១០០០ ញាប់ញ័រទាំងអស់ បុព្វនិមិត្ត ៣២ ប្រការ ប្រាកដឡើងហើយ ។ សុមេធបណ្ឌិតឲ្យកាលកន្លងទៅ ដោយសុខដែលកើតអំពីសមាបត្តិ មិនបានឮសំឡេងនោះឡើយ ទាំងមិនបានឃើញនិមិត្តនោះផងដែរ ព្រោះហេតុនោះ ទើបលោកពោលថា

កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមានវសីក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រីព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្កផង តថាគតជាអ្នកត្រេកស្កប់ស្កល់ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែ មិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ដូច្នេះ ។

ក្នុងកាលនោះ ព្រះសាស្តាព្រះនាមទីបង្ករ មានព្រះខីណាស្រពមួយសែនចោមរោមហើយ យាងចារិកទៅតាមលំដាប់ ដល់នគរឈ្មោះរម្មកៈ គង់នៅក្នុងសុទស្សនមហាវិហារ ពួកអ្នករម្មកនគរបានដំណឹងថា បានឮថា ព្រះពុទ្ធ

ព្រះនាមទីបង្ករ ជាធំជាងសមណៈ ទ្រង់សម្រេចអភិសម្ពោធិយ៉ាងក្រៃលែង ទ្រង់ប្រកាសធម្មចក្កដ៏បវរ ចារិកទៅដោយលំដាប់ ទ្រង់ដល់រម្មកនគរហើយ គង់នៅត្រង់សុទស្សនមហាវិហារ នាំគ្នាកាន់យកភេសជ្ជៈ មានសប្បិ និងនវនីត ជាដើម មួយអន្ទើដោយសំពត់គ្រឿងស្លៀកដណ្តប់ មានដៃកាន់គ្រឿងក្រអូប និងផ្កាជាដើម ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានក្នុងទីណា ក៏នាំគ្នាជាប់តាម ទៅក្នុងទីនោះៗ គាល់ព្រះសាស្តា ហើយថ្វាយបង្គំ បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ស្តាប់ព្រះធម៌ទេសនា ហើយទូលនិមន្តដើម្បីសោយក្នុងថ្ងៃស្អែក នាំគ្នាក្រោកអំពីអាសនៈ ហើយចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង អ្នករម្មកនគរ នាំគ្នាត្រៀមអាហារទាន តាក់តែងព្រះនគរ លម្អផ្លូវដែលជាទីយាងមករបស់ព្រះទសពល ក្នុងទីដែលមានទឹកច្រោះដាច់ ក៏យកដីបំពេញ ធ្វើផែនដីឲ្យរាបស្មើ រោយនូវខ្សាច់ដែលមានពណ៌ដូចប្រាក់ រាយនូវលាជ និងផ្កា លើកទង់ជ័យ និងទង់ជ្វាលា មួយអន្ទើដោយសំពត់ជ្រលក់ពណ៌ផ្សេងៗ បញ្ឈរដើមចេក តាំងក្អមទឹក ពេញដោយផ្កា តម្រៀបគ្នាជាជួរ ។ ក្នុងកាលនោះ សុមេធតាបសហោះអំពីអាស្រមបទរបស់ខ្លួន មកតាមអាកាស ខាងលើមនុស្សទាំងនោះ ឃើញមហាជនត្រេកអរ គិតថា មានហេតុអ្វីហ្ន៎ ដូច្នេះហើយ ទើបចុះអំពីអាកាស ឈរក្នុងទីសមគួរ នាចំណែកម្ខាង សួរថា នែអ្នកដ៏ចម្រើន ពួកអ្នកនាំគ្នាតាក់តែងផ្លូវនេះ ដើម្បីអ្នកណា ព្រោះហេតុនោះ ទើបលោកពោលថា

ពួកមហាជនក្នុងបច្ចន្តប្រទេសមានចិត្តត្រេកអរ និមន្តព្រះតថាគត

បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះតថាគតនោះ ។ សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្តត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាស ហើយសួរមនុស្ស ទាំងឡាយក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយ រីករាយពេញចិត្ត ជម្រះផ្លូវ គន្ទងប្រឡាយដើម្បីអ្នកណា ដូច្នេះ ។ ទើបពួកមនុស្សប្រាប់ថា បពិត្រសុមេធដ៏ចម្រើន លោកម្ចាស់មិនដឹង ទេឬ ព្រះទសពលទីបង្ករ ទ្រង់ដល់នូវត្រៃយសម្ពោធិញ្ញាណ ហើយប្រកាស ធម្មចក្រដ៏ប្រសើរ យាងមកដល់នគររបស់ពួកយើងហើយ ទ្រង់គង់ត្រង់ សុទស្សនមហាវិហារ ពួកយើងនិមន្តព្រះមានព្រះភាគអង្គនោះមក ទើបតាក់ តែងផ្លូវនេះ ដែលជាទីយាងមករបស់ព្រះពុទ្ធអង្គនោះ ។ សុមេធតាបសគិត ថា ត្រឹមតែពាក្យប្រកាសថា **ពុទ្ធោ** ក៏រកបានកម្រក្នុងលោក នឹងពោលទៅ ថ្វីដល់ការកើតឡើងនៃព្រះសម្ពុទ្ធ អញក៏គួររួមជាមួយមនុស្សទាំងនេះ ធ្វើផ្លូវ ដើម្បីព្រះទសពលផងដែរ ។ ទើបលោកពោលនឹងពួកមនុស្សទាំងនោះថា អ្នក និទ៌ុក្ខ ពួកអ្នកតាក់តែងផ្លូវនេះដើម្បីព្រះសម្ពុទ្ធ ចូរឲ្យឱកាសមួយចំណែកដល់ ខ្ញុំផង ខ្ញុំក៏នឹងធ្វើផ្លូវដើម្បីព្រះទសពលជាមួយពួកអ្នកដែរ ពួកជនទាំងនោះ ក៏ទទួលថា សាធុ ដឹងថា សុមេធតាបសមានឫទ្ធិ ទើបកំណត់ទីទំនេរ ដែល មានទឹកហ្រោះឲ្យ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ធ្វើត្រង់ទីនេះ ចុះ ហើយប្រគល់ឲ្យទៅ សុមេធតាបសទាញយកបីតិ ដែលមានព្រះពុទ្ធជា

អារម្មណ៍ គិតថា អញអាចតាក់តែងទីទទេនេះដោយឫទ្ធិបាន តែកាលអញតាក់តែងបែបនេះ ចិត្តក៏មិនត្រេកអរប៉ុន្មាន ថ្ងៃនេះ អញគួរធ្វើការបម្រើដោយកាយ ដូច្នេះហើយ ទើបជញ្ជូនដីមកចាក់ក្នុងទីទំនេរនោះ ។ កាលទីទំនេរនោះធ្វើមិនទាន់ស្រេច ព្រះទសពលទីបង្ករ មានព្រះខីណាស្រព ដែលបានអភិញ្ញា ៦ មានអានុភាពច្រើន ៤ សែនរូបចោមរោម កាលពួកទេវតាបូជាដោយគ្រឿងក្រអូប និងផ្កាទិព្វ កាលតន្ត្រីទិព្វកំពុងបន្លឺ កាលពួកមនុស្សបូជាដោយគ្រឿងក្រអូប និងផ្កា ទ្រង់លីលាលើផ្ទៃមនោសិលា ដោយព្រះដំណើរល្អមិនមានទីបំផុត ដូចរាជសីហ៍យាងមកកាន់ទីតាក់តែង ដែលរៀបចំហើយនោះ សុមេធតាបសបើកភ្នែកទាំងគូ សម្លឹងមើលព្រះវរកាយរបស់ព្រះទសពលដែលយាងមកតាមផ្លូវ ដែលតាក់តែងហើយ ដែលដល់នូវភាពដ៏ប្រសើរលើស ដោយព្រះរូប ប្រដាប់ដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការល្អដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការ ធៀលធ្វាត់ដោយព្រះរស្មីប្រមាណ ១ ព្យាម បញ្ចេញនូវពុទ្ធរស្មី ដែលមានពណ៌ ៦ ចេញមក ដូចផ្លេកបន្ទោរវាសនៅក្នុងអាកាស ដូចកែវមណីចែងចាំងនូវរស្មីទៅមកជាគូៗ ដូច្នោះ ទើបគិតថា ថ្ងៃនេះ អញគួរធ្វើការបរិច្ចាគជីវិតដល់ព្រះទសពល ព្រោះដូច្នោះ សូមព្រះមានព្រះភាគទ្រង់កុំជាន់ភក់ ចូរជាន់ខ្នងអញយាងទៅ មួយអន្លើដោយព្រះខីណាស្រព ៤ សែន ដូចទ្រង់ជាន់ស្ពានកែវមណីចុះ សេចក្តីនោះនឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អញអស់កាលយូរ ដូច្នោះហើយស្រាយសក់ចេញ ក្រាលស្បែកខ្លា ជដា និងសំពត់សម្បកឈើ លើភក់ដែល

មានពណ៌ខ្មៅ ដេកលើកក់ដូចស្ពានកែវមណី ព្រោះហេតុនោះ ទើបលោកពោលថា

ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្លង ប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើងដល់តថាគត ក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធដូច្នេះហើយ ក៏បាននូវសោមនស្ស ។ តថាគតឋិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសលក្នុងបុញ្ញក្ខេត្តនេះកុំឲ្យខណៈកន្លងទៅទទេឡើយ ។ ( លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា ) បើអ្នកទាំងឡាយជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជនទាំងនោះក៏ឲ្យឱកាសមួយដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះជម្រះផ្លូវបណ្តើរក្នុងឱកាសនោះ ។ កាលដែលឱកាស ( ផ្លូវ ) របស់តថាគតធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រីជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែបាននូវអភិញ្ញា ៦ ជាតាទិបុគ្គលប្រាសចាកមន្ទិល ។ ការក្រោកទទួល ( ព្រះសាស្តា ) ក៏ប្រព្រឹត្តទៅ

ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើងគគ្រឹកគគ្រេង ពួកមនុស្ស និងទេវតាក៏គ្រេកអរ ញុំាងសាធុការឲ្យប្រព្រឹត្តទៅ ។ ពួកទេវតា ឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ទេវតា និង មនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលីដើរដង្ហែព្រះតថាគត ។ ពួក ទេវតា ប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគំតូរ្យតន្ត្រី ជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតា ដែលឋិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាសអំពីទិសតូចទិសធំ ។ ពួកទេវតាដែលឋិតនៅឰដ៏ អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្វផង គ្រឿងក្រអូបដ៏ប្រសើរ ទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។ ពួកមនុស្សដែល ឋិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាក្ដុម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូចទិសធំ ។ តថាគតរំសាយ សក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញ យាងទៅចុះ សូមកុំជាន់ភក់ ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ដូច្នេះ ។

សុមេធតាបសនោះ ដេកលើភក់នោះឯង បើកភ្នែកទាំងគូ ឃើញព្រះ

ពុទ្ធសិរីរបស់ព្រះទសពលទីបង្ករ ទើបគិតថា បើអញត្រូវការដុតកិលេស ទាំងពួងឲ្យអស់ ហើយធ្វើជាសង្ឃនវក ចូលទៅកាន់រម្មកនគរបាន តែអញ មិនមានកិច្ចដោយការដុតកិលេស ដោយភេទដែលនរណាម្នាក់មិនស្គាល់ ហើយបរិនិព្វាន បើដូច្នោះ អញគប្បីដូចព្រះទសពលទីបង្ករ ត្រាស់ដឹងនូវ អភិសម្ពោធិញ្ញាណដ៏ឧត្តម ហើយឡើងកាន់ធម្មនាវា ឲ្យមហាជនឆ្លងសង្សារ សាគរបាន ហើយសឹមបរិនិព្វានឯក្រោយ សេចក្តីនេះ សមគួរដល់អញ ដូច្នេះហើយ បន្ទាប់ពីនោះ ទើបសមោធានធម៌ ៨ ប្រការ ធ្វើសេចក្តីប្រាថ្នាដ៏ធំ ដើម្បីភាពជាព្រះពុទ្ធ រួចក្រាបចុះ ព្រោះហេតុនោះ ទើបលោកពោលថា

កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្តយ៉ាង នេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយរបស់អញក្នុង ថ្ងៃនេះក៏បាន ។ តែថា ប្រយោជន៍អ្វីអាត្មាអញធ្វើឲ្យជាក់ច្បាស់នូវ ធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់ នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក ព្រមទាំងទេវលោកឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់ នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើង

ជិះលើនាគ គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ដូច្នេះ ។

កាលបុគ្គលប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នាដែលធំក្រៃលែង សម្រេចបាន ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១ ការឃើញព្រះសាស្តា ១ បព្វជ្ជា ១ ការសម្បូរដោយគុណ ១ ការធ្វើក្រៃលែងធំ ១ ឆន្ទៈ ១ ។

ពិតហើយ កាលបុគ្គលតាំងនៅក្នុងការៈនៃភាពជាមនុស្សនោះឯង ប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នារមែងសម្រេច ការប្រាថ្នារបស់នាគ គ្រុឌ ឬទេវតាមិនសម្រេចឡើយ ក្នុងការៈនៃភាពជាមនុស្ស បុគ្គលតាំងនៅក្នុងភេទបុរសប៉ុណ្ណោះ ទើបការប្រាថ្នាសម្រេច សេចក្តីប្រាថ្នារបស់ស្ត្រី ឬខ្ទើយ និងឧភតោព្យញ្ជនកៈ មិនសម្រេចឡើយ សម្រាប់បុរស ការប្រាថ្នារបស់បុគ្គលដែលសម្បូរដោយហេតុ ដែលអាចសម្រេចអហរត្តក្នុងអត្តភាពនោះប៉ុណ្ណោះ ទើបសម្រេចបាន បុរសក្រៅអំពីនេះ មិនសម្រេចឡើយ សម្រាប់បុគ្គលដែលសម្បូរដោយហេតុ ( អាចសម្រេចអរហត្តក្នុងជាតិនោះ ) កាលប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ ដែលគង់ព្រះជន្មនៅប៉ុណ្ណោះ ទើបសម្រេចបាន កាលព្រះពុទ្ធបរិនិព្វានហើយ ប្រាថ្នាត្រង់ចេតិយ ឬត្រង់គល់ពោធិ៍ មិនសម្រេចឡើយ កាលប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ ការប្រាថ្នារបស់បុគ្គលដែលតាំងនៅក្នុងភេទបព្វជិតប៉ុណ្ណោះ ទើបសម្រេច បុគ្គលដែលតាំងនៅក្នុងភេទគ្រហស្ថមិនសម្រេចឡើយ ទោះបីជាបព្វជិត ការប្រាថ្នារបស់បុគ្គលដែលបានអភិញ្ញា

៥ និងសមាបត្តិ ៨ ប៉ុណ្ណោះ ទើបសម្រេច បុគ្គលដែលវៀរចាកគុណ-សម្បត្តិនេះ មិនសម្រេចឡើយ បុគ្គលដែលសម្បូរដោយគុណហើយក្តី ការប្រាថ្នារបស់បុគ្គលដែលបានធ្វើការបរិច្ចាគជីវិតរបស់ខ្លួនដល់ព្រះពុទ្ធ ដែលជាបុគ្គលសម្បូរដោយការធ្វើដ៏ធំនេះប៉ុណ្ណោះ ទើបសម្រេច បុគ្គលក្រៅពីនេះ មិនសម្រេចឡើយ សូម្បីបុគ្គលដែលសម្បូរដោយការធ្វើដ៏ធំហើយ ត្រូវមានឆន្ទៈដ៏ធំ មានឧស្សាហ៍ មានព្យាយាម និងការស្វែងរកដ៏ធំ ដើម្បីប្រយោជន៍ដល់ធម៌ ដែលធ្វើឲ្យបានជាព្រះពុទ្ធទៀត ទើបសេចក្តីប្រាថ្នាសម្រេច បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។

ក្នុងការដែលមានឆន្ទៈជាំក្រៃលែងនោះ មានសេចក្តីឧបមាដូចតទៅនេះ បើគប្បីប្រព្រឹត្តទៅយ៉ាងនេះថា បុគ្គលណាអាចប្រើកម្លាំងដើមដៃ ឆ្លងអន្លង់នៃចក្រវាលទាំងមូល ដែលពេញដោយទឹក ហើយដល់ត្រើយបាន បុគ្គលនោះរមែងសម្រេចជាព្រះពុទ្ធបាន ឬបុគ្គលណាដើរដោយជើង អាចជាន់ផ្ទៃចក្រវាលទាំងមូល ដែលគ្របដណ្តប់ដោយគុម្ពឫស្សីដល់ត្រើយបាន បុគ្គលនោះរមែងសម្រេចភាពជាព្រះពុទ្ធបាន ឬបុគ្គលណាដោតដាវទាំងឡាយ ហើយយកជើងជាន់ឆ្លងកាត់ផ្ទៃចក្រវាលទាំងមូល ដែលដោតដោយដាវដល់កណ្តាប់ចក្រវាលបាន បុគ្គលនោះ រមែងសម្រេចភាពជាព្រះពុទ្ធបាន ឬបុគ្គលណាយកជើងដើរឆ្លងផ្ទៃចក្រវាលទាំងមូលដែលពេញដោយអណ្តាតភ្លើង ឆេះសន្ធោសន្ធៅ អាចដល់កណ្តាប់ចក្រវាលបាន បុគ្គលនោះ រមែងបានសម្រេចភាពជាព្រះពុទ្ធ បុគ្គលណាមិនសម្គាល់ហេតុទាំងនោះ ណាមួយថា ជារបស់ដែលខ្លួនធ្វើបាន

លំបាក គិតថា អញនឹងឆ្លង ឬទៅដល់ត្រើយឲ្យបាន ដូច្នេះ បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រកបដោយឆន្ទៈ ឧស្សាហ៍ ព្យាយាម និងការស្វែងរកដ៏ធំ សេចក្តីប្រាថ្នារបស់អ្នកនោះ រមែងសម្រេច បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។ សុមេធតាបស ប្រមូលសមោធានធម៌ទាំង ៨ ប្រការនេះបានហើយ ធ្វើសេចក្តីប្រាថ្នាធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ហើយក្រាបចុះ ។ ឯព្រះមានព្រះភាគព្រះនាមទីបង្ករ ទ្រង់យាងមកគង់ឈរខាងសីសៈសុមេធតាបស ទ្រង់បើកព្រះនេត្រទាំងគូ ដែលសម្បូរដោយបសាទមានពណ៌ ៥ ដូចបើកសីហបញ្ជរកែវមណី ទតសុមេធតាបសដែលកំពុងដេកលើភក់ ទ្រង់ព្រះតម្រិះថា តាបសនេះ ធ្វើសេចក្តីប្រាថ្នាធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ការប្រាថ្នារបស់បុរសនេះ សម្រេចឬហ្ន៎ ទ្រង់បញ្ជូនអនាគតំសញ្ញាណពិចារណា ទ្រង់ជ្រាបថា នៅ ៤ អសង្ខេយ្យ និង ១ សែនកប្បអំពីកប្បនេះទៀត បុរសនេះនឹងបានត្រាស់ជាព្រះពុទ្ធ ឈ្មោះថា គោតម ទ្រង់គង់ឈរនោះឯង ព្យាករហើយ ដោយព្រះតម្រាស់ក្នុងកណ្តាលបរិស័ទថា អ្នកទាំងឡាយ ចូរមើលតាបសដែលមានតបៈខ្ពង់ខ្ពស់នេះ ដែលដេកលើភក់ ភិក្ខុទាំងឡាយក្រាបទូលថា ឃើញហើយ ព្រះអង្គ ព្រះមានព្រះភាគទីបង្ករទ្រង់ត្រាស់ថា តាបសនេះ ធ្វើសេចក្តីប្រាថ្នាធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ដេកហើយ ការប្រាថ្នារបស់តាបសនេះ នឹងសម្រេចក្នុងទីបំផុត ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប បន្ទាប់អំពីកប្បនេះ នឹងបានជាព្រះពុទ្ធ ឈ្មោះគោតម ក្នុងអត្តភាពនោះ នគរឈ្មោះកបិលពស្តុ ជាទីនៅអាស្រ័យ ព្រះទេវីព្រះនាមមាយា ជាព្រះមាតា

ព្រះរាជាព្រះនាមសុទេ្ធាទនៈ ជាព្រះរាជបិតា ព្រះថេរៈឈ្មោះឧបតិស្សៈ ជាអគ្គសាវក ព្រះថេរៈឈ្មោះកោលិតៈ ជាទុតិយសាវក ពុទ្ធុបដ្ឋាកឈ្មោះអានន្ទ ព្រះថេរីឈ្មោះខេមា ជាអគ្គសាវិកា ព្រះថេរីឈ្មោះឧប្បលវណ្ណា ជាអគ្គទុតិយសាវិកា បុរសនេះ មានញាណចាស់ក្លាហើយ ចេញមហាភិនេស្ក្រមណ៍ តាំងមហាបធាន ទទួលមធុបាយាសត្រង់ដើមជ្រៃ សោយត្រង់ស្ទឹងនេរញ្ជរា ឡើងកាន់ពោធិមណ្ឌល នឹងត្រាស់ដឹងក្រោមគល់អស្សត្ថព្រឹក្ស ព្រោះហេតុនោះ ទើបលោកពោលថា

ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ។ សត្វនេះនឹងចេញចាកក្រុង ឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះអង្គុយទៀបគល់ អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ ( អង្គុយ ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់

ដឹងនូវអនុត្តរសម្មោធិញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជនិកា មាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថាព្រះគោតម អគ្គសាវកទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គ-សាវិកាពីររូប គឺនាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺចិត្តៈ ១ ហត្ថាឡវកៈ ១ ដូច្នេះ ។

សុមេធតាបស កើតសោមនស្សថា បានឮថា ការប្រាថ្នារបស់អញនឹងសម្រេច ដូច្នេះ មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះទសពលទីបង្ករហើយ នាំគ្នាត្រេកអរថា បានឮថា សុមេធតាបស ជាសពេជ្ជ ជាពន្លកនៃព្រះពុទ្ធ ពួកជនទាំងនោះ មានគំនិតយ៉ាងនេះថា ធម្មតាបុរស បើឆ្លងស្ទឹង មិនអាចឆ្លងកំពង់ដោយត្រង់បាន រមែងឆ្លងកំពង់ខាងក្រោម យ៉ាងណា ពួកយើង ក៏នឹងឆ្លងដូចគ្នា បើមិនបានមគ្គផលក្នុងសាសនារបស់ព្រះទសពលទីបង្ករ ក្នុងកាលណា ក្នុងអនាគត បុរសនេះ បានជាព្រះពុទ្ធក្នុងកាលនោះ ពួកយើង អាចធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលចំពោះមុខបុរសនេះ ដូច្នេះ នាំគ្នាតម្កល់

សេចក្ដីនូវប្រាថ្នា សូម្បីព្រះទសពលទីបង្ករ ទ្រង់សរសើរព្រះពោធិសត្វ ទ្រង់បូជាដោយផ្កា ៨ ក្ដាប់ ទ្រង់ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ឯព្រះខីណាស្រព ៤ សែន នាំគ្នាបូជាព្រះពោធិសត្វដោយគ្រឿងក្រអូប និងកម្រងផ្កា ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ ចំណែកទេវតា និងមនុស្សទាំង-ឡាយ នាំគ្នាបូជាយ៉ាងនោះឯង នមស្ការហើយ ចៀសចេញទៅ ។ ព្រះពោធិសត្វក្រោកឡើងអំពីទីដែលខ្លួនដេក ក្នុងកាលដែលមនុស្សទាំងពួងចៀសចេញទៅហើយ គិតថា អាត្មាអញនឹងពិចារណាមើលបារមីទាំងឡាយ ដូច្នេះទើបអង្គុយពត់ភ្នែនលើទីបំផុតនៃគំនរផ្កា កាលព្រះពោធិសត្វអង្គុយហើយយ៉ាងនេះ ទេវតាក្នុងមួយម៉ឺនចក្រវាល បានប្រជុំគ្នាឲ្យសាធុការថា បពិត្រលោកម្ចាស់សុមេធ ក្នុងបុរាណកាល ព្រះពោធិសត្វទាំងឡាយ អង្គុយពត់ភ្នែន ដោយគិតថា អញនឹងរាវរកបារមីទាំងឡាយ ឈ្មោះថា បុព្វនិមិត្តពួកណានឹងប្រាកដ បុព្វនិមិត្តទាំងនោះ ប្រាកដជាក់ច្បាស់ហើយក្នុងថ្ងៃនេះ អ្នកនឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ ពួកខ្ញុំក៏ដឹងសេចក្ដីនោះ និមិត្តទាំងនេះប្រាកដដល់បុគ្គលណា បុគ្គលនោះ ជាព្រះពុទ្ធដោយចំណែកមួយ ចូរអ្នកផ្គងសេចក្ដីព្យាយាមរបស់ខ្លួនឲ្យមាំ ដូច្នេះ ពោលសរសើរព្រះពោធិសត្វ ដោយពាក្យជាអនេក ព្រោះហេតុនោះ ទើបលោកពោលថា

ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាកររបស់ព្រះពុទ្ធទីបង្ករ
ទ្រង់ស្វែងរកគុណដ៏ធំឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយដោយ
គិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ

ទាំងឡាយក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយ
ម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោល
ថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុង
កាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះ ព្រះភក្រ្ត
នៃព្រះគោតមនេះ ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់
ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោយ ក៏ឈ្មោះថា ឆ្លង
ស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រី
នេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះ
ព្រះភក្រ្តនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទីបង្ករ ទ្រង់
ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើ
របស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។ សាវកទាំង-
ឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវកទាំងនោះ ក៏
ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ខ
ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះ
លោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគត
ទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។
តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយ
បាមោជ្ជ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែនក្នុងកាលនោះ ។
តថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញ

ជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសី ស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្ទាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែននៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេងឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុងខណៈនោះ វល្លិ និងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយ ដែលឋិត

នៅឰដ៏អាកាសក្តី ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំង-ឡាយ រុះរោយ ចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ មហាសមុទ្រក៏ស្រេកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺនក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យ ប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានមានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដីក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយប្រកបដោយព្រះចន្ទវិសាខ ( ក៏រុងរឿង ) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួក

សត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្ដីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយ ជាអ្នកត្រេកអរក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅទាំងសេចក្ដីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្ដីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រាគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈក៏បាត់បង់ទៅក្នុងកាលនោះ រាគ និងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោក

នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដ ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿង រាំងមិនមានឡើយ កំពែង សន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយ ទៅជាអាកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជា ព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្ត ទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ ប្រាកដ ។ ( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បី ត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ) ( ពួកសត្វពោលថា បពិត្រ សុមេធតាបស ) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹង បានត្រាស់ជាព្រះពុទ្ធប្រាកដ ដូច្នេះ ។

ព្រះពោធិសត្វ ស្តាប់ព្រះតម្រាស់របស់ព្រះទសពលទីបង្ករ និងពាក្យ របស់ទេវតាក្នុងម៉ឺនចក្រវាល កើតនូវឧស្សាហ៍ដោយប្រមាណក្រៃលែង ទើប គិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មានព្រះតម្រាស់មិនទទេឡើយ ពាក្យរបស់ ព្រះពុទ្ធទាំងឡាយ មិនមានវិបរិត ដូចដុំដីដែលចោលទៅក្នុងអាកាស ត្រូវធ្លាក់ សត្វដែលកើតហើយ ត្រូវស្លាប់ កាលអរុណជាបុព្វនិមិត្តនៃព្រះអាទិត្យរះ ឡើង រាជសីហ៍ដែលចេញអំពីគុហា ត្រូវតែបន្លឺសីហនាទ ស្រីដែលមានគភ៌

ត្រូវតែជាក់នូវការៈ ជារបស់ទៀងទាត់ មិនចាំបាច់សង្ស័យ យ៉ាងណា ធម្មតាព្រះតម្រាស់ព្រះពុទ្ធទាំងឡាយជារបស់ទៀង មិនទទេ ដូច្នោះ អញនឹងបានជាព្រះពុទ្ធពិត ដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

តថាគតលុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្កវាឡហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅឰដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញយ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់ ប្រាកដយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដ ដូច្នោះដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណាព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈដែលចេញអំពីដំណេក តែងបន្លឺសំឡេងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀង

ទាត់ប្រាកដយ៉ាងនោះដែរ ។ ការសម្រាលគភ៌នៃស្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ដូច្នេះ ។

សុមេធតាបសនោះ ធ្វើការសម្រេចចិត្តយ៉ាងនេះថា អញនឹងបានជាព្រះពុទ្ធពិត ដើម្បីនឹងពិចារណាដល់ពុទ្ធការកធម៌ កាលរាវរកធម្មធាតុទាំងអស់ ដោយលំដាប់ថា ពុទ្ធការកធម៌មានក្នុងទីណាហ្ន៎ ខាងលើ ខាងក្រោម ក្នុងទិសធំ ឬទិសតូច ដូច្នេះ បានឃើញទានបារមីជាទី ១ ដែលបុរាណពោធិសត្វទាំងឡាយបដិបត្តិជាប្រចាំ ទើបទូន្មានខ្លួនយ៉ាងនេះថា ម្នាលសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកគប្បីបំពេញទានបារមីជាបឋមឲ្យបរិបូណ៌ ដូចក្អមទឹកដែលផ្កាប់ហើយ រមែងហៀរទឹកចេញ មិនមានសេសសល់ ទឹកមិនត្រឡប់ចូលទៅទៀត យ៉ាងណា អ្នកកាលមិនសម្លឹងមើលទ្រព្យ យស បុត្ត ភរិយា ឬអវយវៈធំតូច ឲ្យវត្ថុដែលគេត្រូវការចង់បានទាំងអស់ ដល់អ្នកសូម ដែលមកដល់ ធ្វើមិនឲ្យមានចំណែកសេសសល់ ទើបនឹងបានអង្គុយត្រង់គល់ពោធិ៍ ត្រាស់ដឹងជាព្រះពុទ្ធបាន ដូច្នេះ លោកបានអធិដ្ឋានទានបារមីជាបឋមឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបុរាណ

ធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវទានបារមីជាដំបូងនេះឲ្យមាំមួន បើអ្នកចង់ល្មុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាបខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទានកុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើង ដោយគិតថា ពុទ្ធការកធម៌ មិនគប្បីមានត្រឹមប៉ុណ្ណេះឡើយ បានឃើញសីលបារមីទី ២ ទូន្មានខ្លួនថា នែសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញសីល-បារមីឲ្យបរិបូណ៌ ដូចចាមរីម្រឹគមិនសោកស្ដាយសូម្បីតែជីវិត រក្សាកន្ទុយរបស់ខ្លួនតែម្យ៉ាង យ៉ាងណា ចាប់តាំងអំពីនេះទៅ អ្នកក៏មិនសោកស្ដាយសូម្បីត្រឹមតែជីវិត រក្សាសីលតែម្យ៉ាង ទើបបានជាព្រះពុទ្ធ ដូច្នេះហើយ អធិដ្ឋានសីលបារមីទី ២ ធ្វើឲ្យរឹងមាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព

ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសីលបារមីទី ២ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយយ៉ាងនោះចុះ ដូច្នេះ ។

លំដាប់នោះ កាលសុមេធកំពុងពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនគប្បីមានត្រឹមប៉ុណ្ណោះឡើយ បានឃើញនេក្ខម្មបារមីទី ៣ គិតថា នែសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញនេក្ខម្មបារមីឲ្យពេញ ដូចបុរសនៅក្នុងគុក មិនមានប្រាថ្នាក្នុងគុកនោះឡើយ ដោយពិត បុរសនោះ រមែងមិនមានផាសុកតែម្យ៉ាង មិនចង់នៅឡើយ យ៉ាងណា សូម្បីអ្នកក៏ចូរធ្វើភពទាំងពួង ឲ្យដូចគ្នានឹងគុក ប្រាថ្នានឹងរួចផុតចាកភពទាំងពួង បែរមុខចំពោះការចេញបួស ដូច្នោះដូចគ្នា អ្នកនឹងបានជាព្រះពុទ្ធដោយអាការយ៉ាងនេះ ដូច្នេះ បានអធិដ្ឋាននេក្ខម្មបារមីទី ៣ នោះឲ្យមាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ

នេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញ៉ាំងសេចក្តីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្ម ដើម្បីរួចចាកភព យ៉ាងនោះដែរ ដូច្នេះ ។

សម័យនោះ កាលសុមេធពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យជាព្រះពុទ្ធ មិនគប្បីមានត្រឹមប៉ុណ្ណោះឡើយ បានឃើញបញ្ញាបារមីទី ៤ គិតថា នៃសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញបញ្ញាបារមីឲ្យបរិបូណ៌ កុំបីវៀរបុគ្គលណាមួយឡើយ ទោះបីជាមនុស្សអាក្រក់ មនុស្សថ្នាក់កណ្តាល និងជាន់ខ្ពស់ គប្បីចូលទៅរកបណ្ឌិតគ្រប់គ្នា ហើយសាកសួរបញ្ហា ដូចភិក្ខុបិណ្ឌបាតមិនវៀរត្រកូលណាមួយឡើយ ក្នុងបណ្តាត្រកូលផ្សេងៗ មានត្រកូលជាន់ទាបជាដើម ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ រមែងបានអាហារ ល្មមញ៉ាំងជីវិតដោយរួសរាន់ យ៉ាងណា សូម្បីអ្នកក៏ចូលទៅរកបណ្ឌិត ហើយសាកសួរ នឹងបានជាព្រះពុទ្ធ ក៏ដូច្នោះ យ៉ាងនេះហើយ អធិដ្ឋានធ្វើបញ្ញាបារមីទី ៤ ឲ្យមាំ ព្រោះហេតុនោះ ទើបលោកពោលថា

គ្រានោះ កាលសុមេធពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណោះឡើយ ក៏បានឃើញបញ្ញាបារមីទី ៤ គិតថា ម្នាលសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកគប្បីបំពេញបញ្ញា-បារមីឲ្យបរិបូណ៌ អ្នកកុំវៀរបុគ្គលណាម្នាក់ ទោះជាបុគ្គលជាន់ទាប ជាន់កណ្តាល ជាន់ខ្ពស់ គប្បីចូលទៅរកបណ្ឌិតទាំងអស់ ហើយសួរបញ្ហា ដូចភិក្ខុត្រាច់ទៅបិណ្ឌបាត មិនវៀរត្រកូលណាមួយ ក្នុងបណ្តាត្រកូលផ្សេងៗ មានត្រកូលថោកទាបជាដើម ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ រមែងបានអាហារល្មមញុំាងជីវិតឲ្យប្រព្រឹត្តទៅបាន ដោយឆាប់រួសរាន់ យ៉ាងណា ឯអ្នកចូលទៅរកបណ្ឌិត ហើយសាកសួរ នឹងបានត្រាស់ជាព្រះពុទ្ធ យ៉ាងនោះ ។ សុមេធបណ្ឌិតបានអធិដ្ឋានធ្វើបញ្ញាបារមីទី ៤ ឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុ កាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់

ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នក បើសាកសួរជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

គ្រានោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណេះឡើយ ក៏បានឃើញវីរិយបារមីទី ៥ គិតថា នែសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកគប្បីបំពេញវីរិយបារមីឲ្យបរិបូណ៌ ដូចសីហមិគរាជ ជាសត្វមានសេចក្តីព្យាយាមមាំ ក្នុងឥរិយាបថទាំង ៤ យ៉ាងណា សូម្បីអ្នកក៏ជាអ្នកមានសេចក្តីព្យាយាមមាំ មានសេចក្តីព្យាយាមមិនធូរថយ នឹងបានជាព្រះពុទ្ធ សុមេធបានអធិដ្ឋានវីរិយ-បារមីទី ៥ ធ្វើឲ្យមាំមួនហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គង ព្យាយាមឲ្យមាំមួនក្នុង

កពទាំងពួងយ៉ាងនោះចុះ លុះដល់វីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំង-ឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

លំដាប់នោះ កាលសុមេធពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណោះឡើយ បានឃើញខន្តិ-បារមីទី ៦ មានសេចក្តីត្រិះរិះថា នែសុមេធបណ្ឌិត ចាប់តាំងអំពីថ្ងៃនេះទៅ អ្នកគប្បីបំពេញខន្តិបារមីឲ្យបរិបូណ៌ គប្បីជាអ្នកអត់ធន់បាន ក្នុងការរាប់អាន និងការមើលងាយ ឧបមាដូចមនុស្សទាំងឡាយ បោលរបស់ស្អាតខ្លះ មិនស្អាតខ្លះលើផែនដី ផែនដីមិនធ្វើការពេញចិត្ត មិនធ្វើការអាក់អន់ មានតែការអត់ធន់ប៉ុណ្ណោះ យ៉ាងណា សូម្បីអ្នកកាលអត់ធន់បាន ក្នុងការរាប់អានក្តី ក្នុងការមើលងាយក្តី ទើបបានជាព្រះពុទ្ធ ដូច្នេះហើយ អធិដ្ឋានខន្តិបារមីទី ៦ ធ្វើឲ្យមាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើស

រើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្មោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណោះឡើយ ក៏បានឃើញសច្ចបារមីទី ៧ មានគំនិតយ៉ាងនេះថា នៃសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញសច្ចបារមីឲ្យបរិបូណ៌ កុំនិយាយកុហកទាំងដឹងខ្លួន ដោយចង់បាននូវទ្រព្យជាដើម សូម្បីអសនីបាតធ្លាក់ចុះលើអំបែងក្បាលរបស់អ្នក ដូចផ្កាយព្រឹកក្នុងរដូវ មិនវៀរផ្លូវគោចររបស់ខ្លួនឡើយ មិនគោចរក្នុងផ្លូវដទៃ គោចរទៅចំពោះផ្លូវរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណា អ្នកកុំលះបង់សច្ចៈ កុំធ្វើការ

ពោលកុហកជាច់ខាត អ្នកនឹងបានជាព្រះពុទ្ធ ដូច្នេះ សុមេធបណ្ឌិតបាន អធិដ្ឋានបារមីទី ៧ ឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹង ជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យ សម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ សច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះឲ្យមាំមួន កុំមានពាក្យ បែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិន ខានឡើយ ។ ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំង ទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយ យ៉ាងនោះ ដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើងទៅ ដោយ គិតថា ធម៌ដែលធ្វើភាពជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណេះឡើយ ហើយ បានឃើញអធិដ្ឋានបារមីទី ៨ រួចគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់ តាំងអំពីនេះទៅ អ្នកគប្បីបំពេញអធិដ្ឋានបារមីឲ្យពេញបរិបូរ អ្នកអធិដ្ឋានវត្ថុ ណា គប្បីជាអ្នកមិនញាប់ញ័រក្នុងអធិដ្ឋាននោះ ធម្មតាភ្នំ កាលខ្យល់គ្រប់ទិស

បក់ប៉ះ រមែងមិនរង្គើ មិនញាប់ញ័រ តាំងនៅក្នុងទីដែលខ្លួនតាំងនៅនោះឯង យ៉ាងណា អ្នកក៏ដូច្នោះ ជាអ្នកមិនញាប់ញ័រ ក្នុងការតាំងចិត្តមាំរបស់ខ្លួន នឹងបានជាព្រះពុទ្ធ ដូច្នេះ សុមេធបណ្ឌិតបានអធិដ្ឋានបារមីទី ៨ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើង ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណេះឡើយ បានឃើញមេត្តាបារមីទី ៩ គិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នក

គប្បីបំពេញមេត្តាបារមីឲ្យបរិបូណ៌ ក្នុងវត្ថុដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ គប្បីមានចិត្តតែមួយ ដូចទឹក រមែងធ្វើឲ្យត្រជាក់ ផ្សាយទៅស្មើគ្នា ទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ យ៉ាងណា អ្នកកាលជាបុគ្គលមានទឹកចិត្តតែមួយដោយមេត្តា ក្នុងសត្វទាំងពួង នឹងបានជាព្រះពុទ្ធ ដូច្នេះហើយ បានអធិដ្ឋានមេត្តាបារមីទី ៩ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើចំពោះមិត្ត និងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

បន្ទាប់មក កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើងទៀត ដោយគិត

ថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមប៉ុណ្ណោះឡើយ ទើបបាន ឃើញឧបេក្ខាបារមីទី ១០ គិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញឧបេក្ខាបារមីឲ្យបរិបូរ គប្បីដាក់ចិត្តជាកណ្តាលក្នុងសុខក្តី ក្នុងទុក្ខក្តី ដូចផែនដី កាលមនុស្សបោះចោលរបស់ស្អាតក្តី មិនស្អាតក្តី រមែងដាក់ចិត្តជាកណ្តាល យ៉ាងណា សូម្បីអ្នកក៏ដូច្នោះ កាលដាក់ចិត្តជាកណ្តាលបានក្នុងសុខ និងទុក្ខ ក៏នឹងបានត្រាស់ជាព្រះពុទ្ធ សុមេធបាន អធិដ្ឋានឧបេក្ខាបារមីទី ១០ ឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោក ពោលថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី តែងប្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីងចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះ

ដែរ ៗ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោ-
ធិញ្ញាណពុំខាន ដូច្នេះ ៗ

បន្ទាប់អំពីនោះ ទើបសុមេធបណ្ឌិតគិតថា ពុទ្ធការកធម៌ ដែលជាគ្រឿងអប់រំបន្ទុំពោធិញ្ញាណ ដែលព្រះពោធិសត្វគ្រប់អង្គ គប្បីបំពេញក្នុងលោកមានត្រឹមប៉ុណ្ណេះ វៀរបារមី ១០ ចេញ ធម៌ដទៃ មិនមាន បារមីទាំង ១០ នេះ ខាងលើ ក្នុងអាកាស ក៏មិនមាន ខាងក្រោមផែនដីក្តី ក្នុងទិសទាំង-ឡាយ មានទិសខាងកើតជាដើមក្តី ក៏មិនមាន តែតាំងនៅក្នុងហទយៈរបស់អញនេះឯង ដូច្នេះ ៗ កាលឃើញថា បារមីទាំងនោះ តាំងនៅក្នុងហទយៈហើយ ទើបអធិដ្ឋានបារមីទាំងអស់ធ្វើឲ្យមាំ ពិចារណាហើយ ពិចារណាទៀត ពិចារណាអនុលោម បដិលោម កាន់យកខាងចុង មកដល់ខាងដើម កាន់យកខាងដើម មកតាំងទុកខាងចុង កាន់យកត្រង់កណ្តាល ឲ្យដល់ទាំងសងខាង កាន់យកទីបំផុតសងខាង មកបញ្ចប់ត្រង់កណ្តាល កាន់យកបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ គឺបរិច្ចាគទ្រព្យខាងក្រៅជាទានបារមី បរិច្ចាគអវយវៈជាទានឧបបារមី បរិច្ចាគជីវិតជាទានបរមត្ថបារមី ឲ្យចប់ត្រង់កណ្តាលហើយ ពិចារណាត្រឡប់ទៅត្រឡប់មក ដូចបុគ្គលបង្វិលគ្រឿងយន្តកៀបនូវប្រេងទៅមក និងពិចារណាច្របល់ចូលគ្នា ដូចបុគ្គលកូរនូវកំពូកភ្នំសិនេរុឲ្យក្លាយជាមហាសមុទ្រក្នុងផ្ទៃចក្រវាល ដូច្នោះ កាលកំពុងពិចារណាបារមីទាំង ១០ ដោយតេជះនៃធម៌ ផែនដីធំ ដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍នេះ ហាក់បីដូចបាច់នៃដើមបបុសដែលដំរីជាន់ហើយ និងយន្ត

*កៀបអំពៅដែលកំពុងកៀប ក៏កម្រើកញាប់ញ័រ លាន់ទូទៅ ដូចជាសយន្ត របស់ជាងផ្ទាំង និងគ្រឿងយន្តកៀបប្រេង ព្រោះហេតុនោះ ទើបលោកពោលថា*

*ធម៌ទាំងឡាយណា ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមី ១០ នោះមិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះ ឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីធម៌ទាំងនេះ ដោយសភាវលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្លឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាងណា ផែនដី ក៏ញាប់ញ័រយ៉ាងនោះដែរ ដូច្នេះ ។*

*កាលមហាប្រឹថពីកម្រើក អ្នកអាស្រ័យក្នុងរម្មកនគរ មិនអាចទប់ខ្លួនឈរបាន ដូចសាលាធំត្រូវខ្យល់កំបុតត្បូងបោកបក់យ៉ាងខ្លាំងក្លា នាំគ្នាដួលចុះ ភាជនៈរបស់ស្មូនឆ្នាំង មានក្អមទឹកដែលកំពុងធ្វើប៉ះទង្គិចគ្នាជាដើម បែកជាលម្អិតតូចធំទៅ ។ មហាជនតក់ស្លុត ទើបចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គមិនដឹងសេចក្តីនោះដូចម្តេចទេថា នេះនាគធ្វើឲ្យញាប់ញ័រ ឬភូតយក្ខ និងទេវតាពួកណាមួយ ធ្វើឲ្យញាប់ញ័រ ។ មួយប្រការទៀត មហាជនទាំងអស់នេះ ត្រូវធ្វើឲ្យក្តៅក្រហាយ*

ហេតុអាក្រក់ ហេតុល្អ នឹងមានដល់លោកនេះ សូមទ្រង់ត្រាស់ប្រាប់ហេតុនោះដល់ពួកខ្ញុំព្រះអង្គចុះ ។ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យរបស់ពួកជនទាំងនោះហើយត្រាស់ថា ពួកអ្នកកុំភ័យខ្លាចឡើយ កុំគិតថ្វីឡើយ ភ័យកើតអំពីហេតុនេះមិនមានដល់ពួកអ្នកឡើយ ថ្ងៃនេះ សុមេធបណ្ឌិត តថាគតព្យាករហើយថានឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតមក្នុងអនាគត ឥឡូវនេះ សុមេធបណ្ឌិតបានពិចារណាបារមីទាំងឡាយ កាលកំពុងពិចារណា ព្រោះតេជះនៃធម៌ លោកធាតុទាំងមួយម៉ឺនញាប់ញ័រ និងលាន់ឮព្រមគ្នានោះឯង ព្រោះហេតុនោះ ទើបលោកពោលថា

បរិស័ទរបស់ព្រះពុទ្ធមានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដីក្នុងទីអង្គាសនោះ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។ ពួកមហាជនមានចិត្តរន្ធត់តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើលមានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយ ចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្ដេច នឹងមានដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្ដីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោសបន្ទោបង់សេចក្ដីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករទ្រង់ញុំាងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។

ដ្បិតតថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះនឹងបានត្រាស់
ជាព្រះពុទ្ធក្នុងលោក ( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនុ៎ះ
កំពុងពិចារណាធម៌ដែលព្រះជិនស្រី អំពីបុរាណធ្លាប់សេពមក ។
កាលសុមេធបណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិដោយឥតសេសសល់
ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោក
ព្រមទាំងទេវលោកញាប់ញ័រ ដូច្នេះ ។

មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះតថាគតហើយ ត្រេកអរ នាំគ្នា
កាន់យកផ្កា គ្រឿងក្រអូប និងគ្រឿងលាប ចេញអំពីរម្មកនគរ ចូលទៅរក
ព្រះពោធិសត្វ បូជាដោយផ្កាជាដើម ថ្វាយបង្គំ ធ្វើប្រទក្សិណ ហើយចូល
ទៅកាន់រម្មកនគរវិញ ឯព្រះពោធិសត្វ ពិចារណាបារមីទាំងអស់ ធ្វើសេចក្តី
ព្យាយាមឲ្យមាំទាំ អធិដ្ឋានហើយ ក្រោកចាកអាសនៈ ព្រោះហេតុនោះ ទើប
លោកពោលថា

ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបាន
ស្តាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមក
រកតថាគត ហើយក្រាបថ្វាយបង្គំម្តងទៀត ។ គ្រានោះ តថាគត
សមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ
ហើយក្រោកចាកអាសនៈ ដូច្នេះ ។

លំដាប់នោះ ទេវតាក្នុងម៉ឺនចក្រវាលប្រជុំគ្នា ហើយបូជាព្រះពោធិសត្វ
ដែលក្រោកចាកអាសនៈដោយផ្កា និងគ្រឿងក្រអូបដ៏ជាទិព្វ ហើយស្រែក

ប្រកាសពាក្យសរសើរដែលជាមង្គលជាដើមថា បពិត្រលោកម្ចាស់សុមេធ ថ្ងៃនេះ លោកតាំងប្រាថ្នាធំទៀបបាទមូលរបស់ព្រះទសពលទីបង្ករ សូមសេចក្ដីប្រាថ្នារបស់លោកសម្រេចដោយមិនមានអន្តរាយ ការខ្លាច ឬការតក់ស្លុត កុំបីមានដល់លោក រោគសូម្បីតែតិចតួច កុំបីកើតក្នុងរាងកាយ សូមលោកបំពេញបារមីឲ្យពេញដោយឆាប់រួសរាន់ ហើយសម្រេចសម្មាសម្ពោធិញ្ញាណ ដើមឈើដែលនឹងចេញផ្កាផ្លែ រមែងចេញផ្កាផ្លែ តាមរដូវកាលយ៉ាងណា សូម្បីលោកក៏សូមបានពាល់ត្រូវនូវពោធិញ្ញាណដ៏ឧត្តម ដោយឆាប់រួសរាន់ កុំបីកន្លងសម័យនោះឡើយ ។ ទេវតាទាំងឡាយ កាលប្រកាសយ៉ាងនេះហើយ បានត្រឡប់ទៅកាន់ទេវស្ថានរបស់ខ្លួនវិញ ឯព្រះពោធិសត្វដែលទេវតាសរសើរហើយ គិតថា អញនឹងបំពេញបារមី ១០ ក្នុងទីបំផុតនៃ ៤ អសង្ខេយ្យ និង ១ សែនកប្ប នឹងបានជាព្រះពុទ្ធ ដូច្នេះ អធិដ្ឋានធ្វើសេចក្ដីព្យាយាមឲ្យមាំទាំ ហើយហោះឡើងទៅកាន់អាកាស ទៅកាន់ព្រៃហិមពាន្តមួយរំពេច ព្រោះហេតុនោះ ទើបលោកពោលថា

ពួកទេវតា ពួកមនុស្ស ទាំងពីរពួកក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្សចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនោះបាននូវសួស្ដី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះសមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបវៀសចៀសចេញទៅ សេចក្ដីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្ដី

អន្តរាយកុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុ-
តញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗ ចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា
រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោក
ចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណយ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំង-
ឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា
បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០
យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀប
គល់ពោធិមណ្ឌ: យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោក
ចូរត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈនៃព្រះជិនស្រីយ៉ាងនោះ ។ ព្រះ
សម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាង
ណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្កឲ្យ
ប្រព្រឹត្តទៅយ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃ
ពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុង
លោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យដែលរួចផុតអំពី
រាហុ រមែងរុងរឿងដោយកម្ដៅ យ៉ាងណា លោកចូររួចចាក
លោកធម៌ ចូររុងរឿងដោយពុទ្ធសិរីយ៉ាងនោះដែរ ។ ស្ទឹងទាំង-
ឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួក
លោក ព្រមទាំងទេវលោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោក
យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា

និងមនុស្សទាំងនោះ ស្ញើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ដូច្នេះ ។

សុមេធកថា ចប់

ចំណែកអ្នកក្រុងរម្មកនគរ បានចូលទៅកាន់នគរ ហើយថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ពួកជនទាំងនោះ ឲ្យមហាជនតាំងនៅក្នុងសរណៈជាដើម ហើយទ្រង់ចេញអំពីរម្មកនគរទៅ បន្តអំពីនោះ ទ្រង់តាំងនៅដរាបដល់អស់ព្រះជន្ម ទ្រង់ធ្វើពុទ្ធកិច្ចសព្វយ៉ាងហើយ រម្ងត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុដោយលំដាប់ ពាក្យដែលគួរពោលក្នុងទីទាំងអស់នោះ គប្បីជ្រាបតាមន័យដែលលោកពោលហើយ ក្នុងគម្ពីរពុទ្ធវង្សនោះចុះ ពិតហើយ លោកពោលនៅក្នុងពុទ្ធវង្សនោះថា

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករនោះជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរដល់បុគ្គលខ្លះ ប្រទាន

វិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថ ជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូចព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានដងខ្លួនមូលក្ងំ ដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើនឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ឋិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិតហើយ ញុំាងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញុំាងពួកទេវតា ១០០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញុំាងពួកទេវតា និងមនុស្ស ៩០ កោដិ ឲ្យត្រាស់ដឹង ។ កាលណាព្រះពុទ្ធ ទ្រង់សម្តែងធម៌ក្នុងភពនៃទេវតា កាលនោះ ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។ កាលដែលព្រះជិនស្រីទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំនារទៈ ពួកព្រះខីណាស្រពប្រាសចាកមន្ទិលចំនួន ១០០ កោដិ មកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ២ ) ។ កាលព្រះមហាមុនីមានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ព្ធដ៏ភ្នំសុទស្សនៈ ( នេះជាសន្និបាតលើកទី ៣ ) ។

សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។ សាសនារបស់ព្រះទីបង្ករមានព្រះភាគ ជាគុណជាតធំទូលាយ មានជនច្រើនស្តុកស្តម្ភ សាយកាយ គឺព្រះអង្គទ្រង់ជម្រះល្អហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រពចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនា ( របស់ព្រះពុទ្ធទីបង្ករនោះ ) រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្ត-ខីណាស្រព ជាតាទិបុគ្គល ប្រាសចាកមន្ទិលសព្វកាល ។ នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មាវតី ក្សត្រិយ៍ព្រះនាមសុទេវៈ ( ជាព្រះបិតា ) ព្រះជនិកា ព្រះនាមសុមេធា ។ ព្រះជិនស្រីនៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់មាន ៣ ខ្នង គឺហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មយុរប្រាសាទ ១ ។ ពួកនារី ៣ សែននាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ ( ជាមហេសី ) ព្រះឱរសព្រះនាមឧសភក្ខន្ធ ។ ព្រះ

ជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ ( បួស ) ដោយយាន ដំរី ទ្រង់ផ្គងព្យាយាមអស់ ១០ ខែឥតខ្វះ ។ លុះព្រះមុនីមាន ព្រះហឫទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ ព្រះ មហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រី មាន ព្យាយាមធំ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទៈ ទ្រង់គង់ ទៀបគល់ប្រេស ធ្វើនូវការញុំាញុំាតិត្ថិយ ។ ព្រះសុមង្គលៈ និងព្រះ តិស្សៈ ជាអគ្គសាវក ព្រះសាគតៈជាឧបដ្ឋាករបស់ព្រះសាស្តា ទីបង្ករ ។ នាងនន្ទា និងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ ព្រះមានព្រះភាគអង្គនោះ គេហៅថាដើមល្វៀប ។ ឧបាសកឈ្មោះ តបុស្សៈ និងភល្លិកៈជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមា និងនាង សោណា ជាឧបដ្ឋាយិការបស់ព្រះសាស្តាទីបង្ករ ។ ព្រះមហាមុនី ទីបង្ករមានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើម សាលរាជព្រឹក្ស មានផ្ការីកស្គុសស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយ ទៅចម្ងាយ ១០០ យោជន៍ជុំវិញ ព្រះមហេសីនោះ មានព្រះជន្ម មួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញុំាងព្រះ សទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាក សង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវកនិព្វានទៅ ដូចគំនរ ភ្លើងដែលរុងរឿងរលត់ទៅ ដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំង ចក្ករ័តន៍ពួដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ ក៏

អន្តរធានទៅ ឱហ្ន៎! សង្ខារទាំងពួង ជារបស់សូន្យទទេ ព្រះជិនស្រី ជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់ ៣៦ យោជន៍ ( គេសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស ( សម្រាប់បញ្ចុះ ) បាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា ។ សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយកព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជៈរកទីបំផុតគ្មាន មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្របសង្កត់បាន ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះពុទ្ធទីបង្ករកន្លងមកមួយអសង្ខេយ្យ ព្រះសាស្តាព្រះនាមថា កោណ្ឌញ្ញៈកើតឡើងហើយ ការប្រជុំសាវ័ករបស់ព្រះអង្គ មាន ៣ ដង ក្នុងកាលប្រជុំលើកទី ១ មានសាវ័ក ១ សែនកោដិ ក្នុងកាលប្រជុំលើកទី ២ មាន ១ ពាន់កោដិ ក្នុងកាលប្រជុំលើកទី ៣ មាន ៩០ កោដិ កាលនោះ ព្រះពោធិសត្វជាស្តេចចក្រពត្តិ ឈ្មោះវិជិតាវី បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ១ សែនកោដិ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានជាព្រះពុទ្ធ ហើយទ្រង់សម្តែងធម៌ ព្រះពោធិសត្វស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ លះទ្រព្យសម្បត្តិចេញបួស រៀនព្រះត្រៃបិដក ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងហើយ មានឈានមិនសាបសូន្យ

ទៅកើតក្នុងព្រហ្មលោក ។

សម្រាប់ព្រះកោណ្ឌញ្ញសម្ពុទ្ធ នគរឈ្មោះរម្មវតី ក្សត្រព្រះនាមអានន្ទ ជាព្រះរាជបិតា ព្រះទេវីព្រះនាមសុជាតាជាព្រះរាជមាតា ព្រះភទ្ទៈ និងព្រះសុភទ្ទៈ ជាអគ្គសាវក ពុទ្ធុបដ្ឋាកឈ្មោះអនុរុទ្ធ ព្រះនាងតិស្សាថេរី និងព្រះនាងឧបតិស្សាថេរីជាអគ្គសាវិកា ដើមឈើដែលត្រាស់ដឹង ឈ្មោះដើមសាលកល្យាណី ( ដើមក្ងោកនាង ) ព្រះវរកាយកម្ពស់ ៨៨ ហត្ថ ប្រមាណព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងកាលតមក កន្លងទៅបានមួយអសង្ខេយ្យ ក្នុងកប្បមួយនោះឯង មានព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះមង្គលៈ ១ ព្រះសុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ១ ។

ព្រះមានព្រះភាគ ព្រះនាមមង្គលៈ មានការប្រជុំសាវក ៣ ដង ក្នុងការប្រជុំលើកទីមួយ មានភិក្ខុ ១ សែនកោដិ លើកទីពីរ ១ សែនកោដិ លើកទីបី ៩០ កោដិ ។ បានឮថា ព្រះភាតា មាតាផ្សេងរបស់ព្រះអង្គព្រះនាមអានន្ទកុមារ បានមកកាន់សម្នាក់របស់ព្រះសាស្តា ដើម្បីស្តាប់ធម៌ជាមួយនឹងបរិស័ទ ៩០ កោដិ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់ព្រះអង្គ ព្រះរាជកុមារ មួយអន្លើដោយបរិស័ទបានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ។ ព្រះសាស្តា ទ្រង់សម្លឹងមើលបុព្វចរិយារបស់កុលបុត្តទាំងនោះ ទតឃើញឧបនិស្ស័យនៃបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបទ្រង់លាព្រះហស្តខាងស្តាំត្រាស់ថា ចូរពួកអ្នកមកជាភិក្ខុចុះ ខណៈនោះឯង ជនទាំងអស់ទ្រទ្រង់

បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ បរិបូណ៌ដោយអាកប្បកិរិយា ដូចព្រះ ថេរៈមានវស្សា ៦០ ថ្វាយបង្គំព្រះសាស្តា ចោមរោមហើយ នេះជាការប្រជុំ របស់សាវកលើកទី ៣ របស់ទ្រង់ ។ ព្រះសាស្តាគ្រប់អង្គ មានរស្មីផ្សាយ ចេញអំពីព្រះកាយប្រមាណ ៨០ ហត្ថប៉ុណ្ណោះដោយជុំវិញ យ៉ាងណា តែ រស្មីរបស់ព្រះមង្គលៈ មិនមែនដូច្នោះឡើយ រស្មីផ្សាយចេញអំពីព្រះសរីរៈនៃ ព្រះមានព្រះភាគអង្គនោះ អស់ម៉ឺនលោកធាតុ តាំងនៅជានិច្ច ដើមឈើ ផែនដី ភ្នំ និងសមុទ្រជាដើម ដោយហោច សូម្បីតែឆ្នាំងបាយជាដើម ក៏ ហាក់បីដូចគ្របដណ្តប់ដោយមាស ។ មួយយ៉ាងទៀត ប្រមាណព្រះជន្មាយុរបស់ ព្រះអង្គ ៩ ម៉ឺនឆ្នាំ ។ អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះចន្ទ និងព្រះ អាទិត្យជាដើម មិនអាចបញ្ចេញពន្លឺដោយរស្មីរបស់ខ្លួន ការកំណត់ពេល យប់ និងពេលថ្ងៃមិនមាន ពេលថ្ងៃ ពួកសត្វត្រាច់ទៅ ដោយពន្លឺរបស់ព្រះ សម្ពុទ្ធប៉ុណ្ណោះ ដូចគ្នានឹងពន្លឺរបស់ព្រះអាទិត្យ សត្វលោកដឹងពេលយប់ និង ពេលថ្ងៃ ដោយអំណាចផ្ការីកក្នុងពេលល្ងាច និងបក្សីជាដើមក្នុងពេលព្រឹក ។ សួរថា ព្រះសម្ពុទ្ធទាំងឡាយអង្គដទៃ មិនមានអានុភាពនេះឬ ។ ឆ្លើយថា មិនមែនមិនមានទេ ។ ពិតហើយ ព្រះពុទ្ធទាំងនោះ កាលទ្រង់ប្រាថ្នាគប្បី ផ្សាយរស្មីទៅអស់លោកធាតុមួយម៉ឺន ឬក្រៃលែងជាងនោះក៏បាន តែព្រះរស្មី ដែលចេញអំពីព្រះសរីរៈរបស់ព្រះមានព្រះភាគមង្គលៈ បានផ្សាយទៅអស់ លោកធាតុមួយម៉ឺន អស់កាលជានិច្ច ដូចរស្មីមួយព្យាមរបស់ព្រះពុទ្ធអង្គដទៃ ដោយអំណាចការប្រាថ្នាក្នុងកាលមុន បានឮថា ក្នុងកាលដែលអន្ទោលទៅ

ជាព្រះពោធិសត្វ ទ្រង់តាំងនៅក្នុងអត្តភាពដូចព្រះវេស្សន្តរ មួយអន្លើដោយ បុត្ត និងភរិយា នៅត្រង់ភ្នំ ដូចគ្នានឹងភ្នំវង្កត គ្រានោះ មានយក្ខមួយឈ្មោះ ខរទាឋិក បានឮថា ព្រះមហាបុរស មានអធ្យាស្រ័យចូលចិត្តឲ្យទាន ទើប ចូលទៅរកដោយភេទជាព្រាហ្មណ៍ ហើយសូមទារកទាំងពីរនឹងព្រះមហាសត្វ ព្រះមហាសត្វពោលថា ម្នាលព្រាហ្មណ៍ យើងនឹងឲ្យកូនតូច ដូច្នេះហើយ ត្រេកអររីករាយ ធ្វើឲ្យផែនដីដែលមានទឹកជាទីបំផុតញាប់ញ័រ បានឲ្យទារក ទាំង ២ ហើយ ។ យក្ខឈរផ្អែកក្ដារក្បាលដៃ ក្នុងទីបំផុតនៃទីចង្ក្រម កាលព្រះ មហាសត្វកំពុងឃើញនោះឯង ទំពាស៊ីទារក ដូចទំពាឫសឈើ ទោមនស្ស សូម្បីត្រឹមមួយចម្រៀកសក់ មិនបានកើតឡើងដល់មហាបុរស ព្រោះសម្លឹង មើលយក្ខ សូម្បីឃើញមាត់របស់យក្ខកំពុងមានតំណក់ឈាមហូរមក ដូច អណ្ដាតភ្លើងក្នុងមាត់ដែលហាឡើង កាលព្រះពោធិសត្វគិតថា ទានអញឲ្យ ល្អហើយហ្ន៎ បីតិ និងសោមនស្សយ៉ាងធំ បានកើតឡើងពេញសរីរៈ បានធ្វើ សេចក្ដីប្រាថ្នាថា ដោយផលនៃទានរបស់អាត្មាអញនេះ ក្នុងអនាគត សូមរស្មី ផ្សាយចេញដោយទំនងនេះឯង ព្រោះអាស្រ័យសេចក្ដីប្រាថ្នានោះ ទើបរស្មី ផ្សាយចេញអំពីសរីរៈរបស់ព្រះសម្ពុទ្ធផ្សាយទៅ មានប្រមាណប៉ុណ្ណេះ ។ បុព្វ-ចរិយាដទៃទៀតរបស់ទ្រង់នៅមាន បានឮថា ក្នុងកាលជាព្រះពោធិសត្វ ឃើញ ចេតិយរបស់ព្រះពុទ្ធមួយអង្គ គិតថា អញគួរបរិច្ចាគជីវិតដល់ព្រះពុទ្ធអង្គនេះ ដូច្នេះហើយ ទើបរុំសរីរៈទាំងមូល ដោយទំនងធ្វើដូចជាប្រទីប យកសប្បិ ចាក់របូតពេញថាសមាសដែលមានតម្លៃមួយសែន កម្ពស់មួយហត្ថក្ដាប់ ដុត

ប្រទេះក្នុងថាសនោះ យកសីសៈទូលថាសនោះ ហើយដុតខ្លួន ធ្វើប្រទក្សិណ
ចេតិយ ឲ្យកន្ទង់ទៅអស់មួយយប់ សូម្បីព្រះមហាសត្វ ព្យាយាមយ៉ាងនេះ
ដល់ថ្ងៃរះឡើង ការក្តៅមិនមានសូម្បីត្រឹមចុងរោម ហាក់ដូចជាចូលទៅក្នុង
បន្ទប់នៃផ្កាឈូកក្រហម ពិតហើយ ធម្មតាធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌
ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងថេរគាថា ) ថា

ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំ
ហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ ដែល
បុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់
ទុគ្គតិ ដូច្នេះ ។

ព្រោះផលនៃកម្មនេះ ទើបពន្លឺចេញអំពីសរីរៈរបស់ព្រះមានព្រះភាគអង្គ
នោះ ផ្សាយទៅអស់ម៉ឺនលោកធាតុ ។

ក្នុងកាលនោះ ព្រះពោធិសត្វនៃយើង ជាព្រាហ្មណ៍ឈ្មោះសុរុចិ គិតថា
អញនឹងនិមន្តព្រះសាស្តា ដូច្នេះហើយ ទើបចូលទៅគាល់ស្តាប់ធម្មកថាដ៏ពីរោះ
ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្អែកនេះ សូមទ្រង់ទទួលភិក្ខា
ក្នុងផ្ទះរបស់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកត្រូវការដោយភិក្ខុ មាន
ប្រមាណប៉ុន្មាន ។ ព្រាហ្មណ៍ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ
ជាបរិវាររបស់ព្រះអង្គមានប៉ុន្មាន ។ ក្នុងគ្រានោះ ព្រះសាស្តាទ្រង់មានការ
ប្រជុំសាវកជាលើកដំបូងល្អម ព្រោះដូច្នោះ ទើបត្រាស់ថា មានប្រមាណមួយ

សែនកោដិ ។ ទើបព្រាហ្មណ៍ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មួយអន្លើដោយភិក្ខុសង្ឃទាំងអស់ ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្ដាទទួលហើយ ។ ព្រាហ្មណ៍កាលនិមន្តដើម្បីសោយក្នុងថ្ងៃស្អែកហើយ ទៅផ្ទះ គិតថា អញអាចថ្វាយបបរ ភត្ត និងសំពត់ជាដើមដល់ភិក្ខុសង្ឃ មានប្រមាណប៉ុណ្ណេះបាន តែទីអង្គុយនឹងគិតដូចម្ដេចហ្ន៎ ការគិតរបស់ព្រាហ្មណ៍នោះ ធ្វើឲ្យកម្ដៅកើតដល់បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជ ដែលប្រថាប់ឈរក្នុងទីបំផុតនៃទី ៨ ម៉ឺន ៤ ពាន់ យោជន៍ ។ សក្កទេវរាជត្រិះរិះថា នរណាហ្ន៎ ត្រូវការឲ្យអញឃ្លាតចាកអាសនៈនេះ ទ្រង់ប្រមើលមើលដោយទិព្វចក្ខុ ឃើញមហាបុរស ទ្រង់ព្រះតម្រិះថា សុរុចិព្រាហ្មណ៍នេះនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គិតហើយ ត្រូវការអាសនៈ អញគួរទៅក្នុងទីនោះ កាន់យកចំណែកបុណ្យខ្លះ ដូច្នេះ ទើបទ្រង់និម្មិតរាងកាយជាជាងឈើ មានដៃកាន់កាំបិត និងពូថៅ ប្រាកដខ្លួនខាងមុខរបស់មហាបុរស ពោលថា អ្នកណាមានការងារដែលត្រូវស៊ីឈ្នួលធ្វើខ្លះ ព្រះមហាបុរសឃើញហើយទើបសួរថា អ្នកនឹងធ្វើការងារអ្វី ក៏ពោលថា ឈ្មោះថា សិប្បៈដែលខ្ញុំមិនចេះមិនមាន បុគ្គលណាឲ្យខ្ញុំធ្វើការងារណា ជាផ្ទះក្ដី ជាមណ្ឌបក្ដី ខ្ញុំអាចធ្វើការងារនោះដល់បុគ្គលនោះ ។ ព្រះមហាបុរសពោលថា បើដូច្នោះ ការងាររបស់ខ្ញុំមាន មេជាងពោលថា ការងារអ្វីលោកម្ចាស់ ។

ព្រះពោធិសត្វពោលថា ខ្ញុំនិមន្តភិក្ខុមួយសែនកោដិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក អ្នកធ្វើមណ្ឌប និងទីអង្គុយដល់ភិក្ខុទាំងនោះបានដែរឬទេ មេជាងពោល

ថា ខ្ញុំធ្វើបាន បើលោកអាចឲ្យថ្ងៃឈ្នួលដល់ខ្ញុំបាន ។ ព្រះពោធិសត្វពោលថា នែអ្នក ខ្ញុំអាច ។ មេជាងទទួលថា សាធុ ខ្ញុំនឹងធ្វើ ទើបទៅពិនិត្យមើលទីទំនេរមួយកន្លែង មានប្រមាណ ១២ យោជន៍ មានផ្ទៃរាបស្មើ ដូចមណ្ឌលកសិណ មេជាងគិតថា មណ្ឌបសម្រេចដោយកែវ ៧ ប្រការ ចូរកើតឡើងក្នុងទីមានប្រមាណប៉ុណ្ណេះ ។ ក្នុងរំពេចនោះ មណ្ឌបក៏ផុសទម្លុះផែនដីឡើង សសរប្រាសាទនោះសម្រេចដោយមាស ក្អមទឹកសម្រេចដោយប្រាក់តាំងនៅ ។ ត្រង់សសរដែលសម្រេចដោយប្រាក់ មានក្អមទឹកសម្រេចដោយមាស ត្រង់សសរដែលសម្រេចដោយកែវមណី មានក្អមទឹកសម្រេចដោយកែវប្រពាល ត្រង់សសរដែលសម្រេចដោយកែវប្រពាល មានក្អមទឹកសម្រេចដោយកែវមណី ត្រង់សសរដែលសម្រេចដោយកែវ ៧ ប្រការ មានក្អមទឹកសម្រេចដោយកែវ ៧ ប្រការដូចគ្នា ។ បន្ទាប់អំពីនោះ មេជាងសម្លឹងមើលដោយគិតថា សូមបណ្តាញកណ្តឹងសំយុងតាមចន្លោះនៃមណ្ឌប មួយអន្លើដោយការសម្លឹងមើលនោះឯង បណ្តាញកណ្តឹងក៏សំយុងហើយ ។ សំឡេងដ៏ពីរោះរបស់បណ្តាញកណ្តឹងដែលព័ទ្ធជុំវិញ រេរាំទៅមក បន្លឺសំឡេងចេញ ហាក់ដូចសំឡេងដ៏ពីរោះនៃតន្ត្រី ដែលប្រកបដោយអង្គ ៥ មើលទៅមិនខុសអ្វីក្នុងកាលដែលទិព្វតន្ត្រីបន្លឺឡើយ ។ មេជាងគិតថា ក្នុងចន្លោះៗ សូមកម្រងគ្រឿងក្រអូប និងកម្រងផ្កាសំយុងចុះមក កម្រងគ្រឿងក្រអូប និងកម្រងផ្កាក៏សំយុងចុះមកហើយ ។ មេជាងគិតថា សូមអាសនៈ និងព្រះទែនសម្រាប់ភិក្ខុមួយសែនកោដិ ជ្រែកផែនដីផុសឡើងមក រំពេចនោះឯង របស់ទាំងនោះ

ក៏ផុសឡើងមក មេជាងគិតថា គ្រប់ជ្រុង សូមក្អមទឹកផុសឡើងមកមួយជ្រុង ១ ក្អមទឹកក៏ផុសឡើងមក ។ មេជាងនិម្មិតវត្ថុផ្សេងៗ មានប្រមាណប៉ុណ្ណោះស្រេចហើយ ទើបទៅកាន់សម្នាក់របស់ព្រាហ្មណ៍ ហើយពោលថា នៃលោក សូមលោកពិនិត្យមើលមណ្ឌប ហើយឲ្យថ្លៃឈ្នួលដល់ខ្ញុំ ។ មហាបុរសទៅពិនិត្យមើលមណ្ឌបហើយ ។ កាលកំពុងមើលនោះឯង រាងកាយក៏ពាល់ត្រូវដោយបីតិ ៥ ប្រការសព្វកាល ។ ពេលនោះ មហាសត្វសម្លឹងមើលមណ្ឌប ក៏គិតយ៉ាងនេះថា មណ្ឌបនេះ មនុស្សមិនអាចធ្វើបាន តែព្រោះអធ្យាស្រ័យរបស់អញ គុណរបស់អញ ភពរបស់សក្កទេវរាជក្តៅពិត បន្ទាប់អំពីនោះ សក្កទេវរាជនឹងសាងមណ្ឌបនេះឡើង ដូច្នេះ ។ ព្រះពោធិសត្វគិតថា ការថ្វាយទានត្រឹមមួយថ្ងៃប៉ុណ្ណោះ ក្នុងមណ្ឌបបែបនេះ មិនសមគួរដល់អញឡើយ អញនឹងថ្វាយទានអស់ ៧ ថ្ងៃ ។ ពិតហើយ ទានខាងក្រៅ មានប្រមាណប៉ុន្មាន ក៏មិនអាចធ្វើសេចក្តីត្រេកអរឲ្យដល់ព្រះពោធិសត្វបាន តែក្នុងកាលដែលព្រះពោធិសត្វកាត់ក្បាល ដែលប្រដាប់តាក់តែងហើយ ខ្វេះភ្នែកទាំង ២ ដែលបន្តក់ថ្នាំហើយ អារទូវសាច់បេះដូងចេញហើយ ឲ្យទៅ ព្រះពោធិសត្វមានសេចក្តីត្រេកអរក្រៃពេក ព្រោះអាស្រ័យបរិច្ចាគនេះ ។ កាលព្រះពោធិសត្វនៃយើងលះកហាបណៈ ៥ សែនរាល់ថ្ងៃ ឲ្យទានត្រង់ទ្វារទាំង ៤ និងត្រង់កណ្តាលព្រះនគរ ក្នុងរឿងសិវិរាជជាតក ទាននោះ ក៏មិនអាចឲ្យកើតនូវការត្រេកអរក្នុងបរិច្ចាគឡើយ តែក្នុងកាលណាសក្កទេវរាជបន្លំខ្លួនមកក្នុងរូបភាពជាព្រាហ្មណ៍ សុំកែវភ្នែកទាំងគូរបស់ព្រះពោធិសត្វ កាលនោះ

ព្រះពោធិសត្វខ្វះកែវក្អែកទាំងនោះ ឲ្យទៅជាទាននោះឯង ការត្រេកអរបាន កើតឡើងហើយ ចិត្តមិនបានប្រែប្រួលទៅជាដទៃ សូម្បីត្រឹមមួយចម្រៀកសក់ ។

ឈ្មោះថា បីតិ ព្រោះអាស្រ័យទានដែលឲ្យហើយ ដោយអាការយ៉ាងនេះ មិនមានដល់ព្រះពោធិសត្វឡើយ ព្រោះហេតុនោះ ទើបព្រះមហាបុរសគិតថា អញគួរថ្វាយទានដល់ភិក្ខុទាំងឡាយមួយសែនកោដិអស់វារៈ ៧ ថ្ងៃ ដូច្នេះហើយ ទើបឲ្យភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គង់ក្នុងមណ្ឌបនោះ បានថ្វាយទាន ឈ្មោះគវបានៈអស់ ៧ ថ្ងៃ ។ ដែលហៅថា គវបានៈនោះ បានដល់ កោជនដែលគេដាក់ទឹកដោះពេញឆ្នាំងធំ ហើយលើកឡើង តម្កល់លើជើងចង្ក្រាន ដាក់អង្ករបន្តិចក្នុងទឹកដោះ ដែលជាំធ្លិនហើយក្នុងឆ្នាំង ហើយផ្សំដោយរសទឹកឃ្មុំ ស្ករក្រាម សប្បិដែលស្ងោរហើយ ។ មនុស្សនេះឯងមិនអាចអង្គាសបាន សូម្បីទេវតា ក៏ត្រូវប្តូរវេនគ្នា ទើបអង្គាសបាន ។ សូម្បីទីប្រមាណ ១២ ឬ ១៣ យោជន៍ក៏មិនអាចគ្រប់គ្រាន់ សម្រាប់ភិក្ខុទាំង-ឡាយបានឡើយ តែភិក្ខុទាំងនោះ អង្គុយដោយអានុភាពរបស់ខ្លួន ។

ក្នុងថ្ងៃចុងក្រោយ ព្រះពោធិសត្វឲ្យលាងបាត្ររបស់ភិក្ខុគ្រប់រូប ហើយដាក់សប្បិ នវនីត ទឹកឃ្មុំ និងទឹកអំពៅជាដើម រហូតពេញបាត្រ ដើម្បីជាភេសជ្ជៈ មួយអន្លើដោយត្រៃចីវរ ។ សំពត់សាដកដែលជាចីវរ ដែលនវភិក្ខុក្នុងពួកសង្ឃបានទទួល មានតម្លៃមួយសែន ។ ព្រះសាស្តាកាលទ្រង់ធ្វើអនុ-មោទនា ទ្រង់ពិចារណាមើលថា បុរសនេះបានឲ្យទានដល់ម៉្លេះ នឹងបានជាអ្វី

ហ្ន៎ ទតឃើញថា នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងទីបំផុតនៃ ២ អសង្ខេយ្យក្រៃលែងដោយសែនកប្បក្នុងអនាគត ដូច្នេះហើយ ទើបត្រាស់ហៅមហាបុរសមក ហើយទ្រង់ព្យាករថា ក្នុងកាលមានប្រមាណប៉ុណ្ណេះ អ្នកនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

មហាបុរសបានស្តាប់ពាក្យព្យាករហើយ គិតថា បានឮថា អញនឹងបានជាព្រះពុទ្ធ ប្រយោជន៍អ្វីរបស់អញ ដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួស ដូច្នេះហើយ ទើបលះបង់សម្បត្តិបែបនោះ ដូចដុំទឹកមាត់ ហើយបួសក្នុងសម្នាក់របស់ព្រះសាស្តា លុះបួសហើយ រៀនព្រះពុទ្ធវចនៈ ឲ្យអភិញ្ញា និងសមាបត្តិកើតឡើងហើយ ក្នុងកាលអស់អាយុ បានទៅកើតក្នុងព្រហ្មលោក ។ ព្រះនគររបស់ព្រះមានព្រះភាគព្រះនាមមង្គលៈ មានឈ្មោះថាឧត្តរៈ ព្រះរាជមាតាក៏ទ្រង់ព្រះនាមឧត្តរា ព្រះរាជបិតា ទ្រង់ជាក្សត្រ ព្រះនាមថាឧត្តរៈ អគ្គសាវក ២ អង្គ ឈ្មោះសុទេវៈ ១ ធម្មសេនៈ ១ ឧបដ្ឋាកឈ្មោះបាលិតៈ អគ្គសាវិកា ២ អង្គ ឈ្មោះសិម្ពលី ១ អសោកា ១ ដើមឈើត្រាស់ដឹងឈ្មោះនាគព្រឹក្ស គឺដើមខ្ទឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ទ្រង់តាំងព្រះជន្មនៅអស់ ៩ ម៉ឺនឆ្នាំ ហើយបរិនិព្វាន ។ កាលព្រះមានព្រះភាគអង្គនោះបរិនិព្វានហើយ ចក្រវាលមួយម៉ឺន ងងឹតទាំងអស់ព្រមគ្នា ពួកមនុស្សទាំងឡាយ ក្នុងចក្រវាលទាំងអស់ ទ្រហោយំហើយ ។

កាលខាងក្រោយអំពីព្រះសមុទ្ទកោណ្ឌញ្ញៈមក ព្រះលោកនាយក
ព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹតក្នុងលោក ព្រះអង្គទ្រទ្រង់នូវ

គប់ភ្លើង គឺព្រះធម៌ ដូច្នេះ ។

ក្នុងកាលខាងក្រោយនៃព្រះមានព្រះភាគអង្គនោះ ដែលបរិនិព្វាន ធ្វើម៉ឺនលោកធាតុឲ្យងងឹតយ៉ាងនេះហើយ ព្រះសាស្តាទ្រង់ព្រះនាមសុមនៈ កើតឡើងហើយ សាវកសន្និបាតរបស់ទ្រង់ក៏មាន ៣ ដង ក្នុងសន្និបាតលើកទីមួយ មានភិក្ខុមួយសែនកោដិ លើកទីពីរត្រង់កាញ្ចនបព៌ត មានភិក្ខុ ៩០ សែនកោដិ លើកទីបី ៨០ សែនកោដិ ។ ក្នុងកាលនោះ ព្រះមហាសត្វ កើតជានាគរាជឈ្មោះអតុលៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ស្តេចនាគនោះបានឮថា ព្រះពុទ្ធកើតឡើងហើយ មានពួកញាតិចោមរោមហើយ ចេញចាកនាគពិភព ឲ្យធ្វើការប្រគំថ្វាយដោយទិព្វតន្ត្រីដល់ព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ និងបរិវារមួយសែនកោដិ ថ្វាយសំពត់មួយគូដល់ព្រះសាស្តា ហើយតាំងនៅក្នុងសរណៈ ព្រះសាស្តាអង្គនោះ ក៏ទ្រង់ព្យាករស្តេចនាគថា នឹងបានជាព្រះពុទ្ធក្នុងអនាគត ។ ព្រះនគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះមេខលា ព្រះរាជាព្រះនាមសុទត្តៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមសិរិមា ព្រះអគ្គសាវក ២ អង្គ ឈ្មោះសរណៈ ១ ភាវិតត្តៈ ១ ឧបដ្ឋាកនាមឧទេន អគ្គសាវិកាទាំង ២ ឈ្មោះសោណា ១ ឧបសោណា ១ ដើមនាគព្រឹក្សជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៩០ ហត្ថ ប្រមាណអាយុរបស់ទ្រង់ ៩ ម៉ឺនឆ្នាំ ដោយប្រការដូច្នេះ ។

កាលខាងក្រោយអំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក ព្រះ
នាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គឧត្តមជាង

សព្វសត្វ ដូច្នេះ ។

ក្នុងកាលខាងក្រោយនៃព្រះអង្គ ព្រះសាស្តាទ្រង់ព្រះនាមរេវតៈបានកើតឡើង សាវកសន្និបាតរបស់ទ្រង់ក៏មាន ៣ ដង ក្នុងសន្និបាតដំបូង មានសាវ័ករាប់មិនបាន ក្នុងលើកទីពីរ មានភិក្ខុមួយសែនកោដិ ក្នុងលើកទីបីក៏ដូចគ្នា ។ ក្នុងគ្រានោះ ព្រះពោធិសត្វកើតជាព្រាហ្មណ៍ ឈ្មោះអតិទេព ស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយ តាំងនៅក្នុងសរណៈ ផ្គងអញ្ជលីលើក្បាលហើយ បានស្តាប់ព្រះគុណក្នុងការលះកិលេសរបស់ព្រះសាស្តានោះ បានធ្វើការបូជាដោយសំពត់ដណ្តប់ សូម្បីទ្រង់ក៏ព្យាករថា នឹងបានត្រាស់ជាព្រះពុទ្ធ ។ ព្រះនគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះសុធញ្ញវតី ព្រះរាជបិតាក៏ជាក្សត្រព្រះនាមវិបុល ព្រះរាជមាតាព្រះនាមវិមលា អគ្គសាវ័ក ២ អង្គ ឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ១ ឧបដ្ឋាកឈ្មោះសម្ភវៈ អគ្គសាវិកា ២ អង្គ ឈ្មោះភទ្ទា ១ សុភទ្ទា ១ ដើមនាគព្រឹក្សជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨០ហត្ថ ប្រមាណព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ដោយប្រការដូច្នេះ ។

កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមសុមនៈមក មានព្រះលោកនាយកព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្ញឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ដូច្នេះ ។

ក្រោយមកទៀត ព្រះសាស្តាព្រះនាមសោភិតៈ កើតឡើងក្នុងលោក សាវកសន្និបាតរបស់ទ្រង់មាន ៣ ដង ក្នុងសន្និបាតដំបូង មានភិក្ខុ ១០០ កោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ ។ ក្នុងកាលនោះ ព្រះ

ពោធិសត្វជាព្រាហ្មណ៍ឈ្មោះអជិតៈ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ហើយ តាំងនៅក្នុងសរណៈ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់ក៏បានព្យាករថា នឹងបានជាព្រះពុទ្ធ ។ ព្រះនគររបស់ព្រះសាស្តាអង្គនោះឈ្មោះសុធម្មៈ ព្រះរាជាព្រះនាមសុធម្មៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមសុធម្មា អគ្គសាវកឈ្មោះអសមៈ ១ សុនេត្តៈ ១ ពុទ្ធុបដ្ឋាកឈ្មោះអនោមៈ អគ្គសាវិកាឈ្មោះនកុលា ១ សុជាតា ១ នាគព្រឹក្សជាឈើត្រាស់ដឹង សរីរៈកម្ពស់ ៥៨ ហត្ថ ប្រមាណព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មានព្រះលោកនាយក ព្រះនាមសោភិតៈ មានព្រះហឫទ័យតម្កល់ខ្ជាប់
មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ក្នុងកាលក្រោយមក កន្លងទៅបានមួយអសង្ខេយ្យ ក្នុងកប្បមួយ មានព្រះពុទ្ធ ៣ ព្រះអង្គកើតឡើងហើយ គឺព្រះអនោមទស្សី ១ ព្រះបទុម ១ ព្រះនារទៈ ១ ព្រះមានព្រះភាគព្រះនាមអនោមទស្សី មានសាវកសន្និបាត ៣ ដង ជំបូងមានភិក្ខុ ៨ សែន លើកទីពីរ ៧០ សែន លើកទីបី ៨៦ ពាន់កោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតជាសេនាបតីយក្ខ មានឫទ្ធិច្រើន មានអានុភាពច្រើន ជាធំជាងយក្ខមួយសែនកោដិ ។ យក្ខនោះបានឮថា ព្រះសម្ពុទ្ធកើតឡើងហើយ ទើបមក បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ។ ព្រះសាស្តាក៏ព្យាករយក្ខនោះថា នឹងបានជាព្រះពុទ្ធ

ក្នុងអនាគត ។ នគររបស់ព្រះមានព្រះភាគ អនោមទស្សីឈ្មោះចន្ទវតី ព្រះរាជាព្រះនាមយសវាជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមយសោធរា អគ្គសាវក ឈ្មោះនិសភៈ ១ អនោមៈ ១ ពុទ្ធុបដ្ឋាកឈ្មោះវរុណៈ ១ អគ្គសាវិកា ឈ្មោះសុន្ទរី ១ សុមនា ១ អជ្ជុនព្រឹក្ស គឺដើមថ្កាន់[១] ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ។

កាលជាខាងក្រោយអំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះ
នាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយស
រាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន ដូច្នេះ ។

ក្នុងកាលខាងក្រោយមកទៀត ព្រះសាស្តាព្រះនាមបទុម កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គមាន ៣ ដង ក្នុងសន្និបាតគ្រាជំបូង មានភិក្ខុ ១ សែនកោដិ គ្រាទីពីរមាន ៣ សែនរូប គ្រាទី ៣ មានភិក្ខុនៅក្នុងព្រៃមហាវ័ន មិនមែនជាស្រុក ២ សែនរូប ។ ក្នុងគ្រានោះ កាលព្រះតថាគតគង់នៅក្នុងដងព្រៃនោះ ព្រះពោធិសត្វកើតជារាជសីហ៍ ឃើញព្រះសាស្តាចូលនិរោធសមាបត្តិ មានចិត្តជ្រះថ្លា ថ្វាយបង្គំ ធ្វើប្រទក្សិណ កើតបីតិ និងសោមនស្ស បន្លឺសីហនាទ ៣ ដង អស់ ៧ ថ្ងៃ មិនបានលះបង់នូវបីតិ មានព្រះពុទ្ធជាអារម្មណ៍ ព្រោះសុខដែលកើតអំពីបីតិនោះឯង មិនចេញទៅរកស៊ី បរិច្ចាគជីវិត ចូលទៅគាល់ ហើយឈរ ។ ព្រះសាស្តាយាងចេញអំពីនិរោធសមាបត្តិ កាលកន្លងទៅបាន ៧ ថ្ងៃហើយ ទតឃើញរាជសីហ៍ ទ្រង់ព្រះ

---

១- បិដកខ្មែរពុទ្ធវង្ស ជាដើមអង្គ្រង ។

តម្រិះថា សង្ឃប្ចូរមក ដើម្បីឲ្យរាជសីហ៍ មានចិត្តជ្រះថ្លាក្នុងភិក្ខុសង្ឃ ហើយថ្វាយបង្គំ ។ រំពេចនោះ ភិក្ខុទាំងឡាយក៏មក រាជសីហ៍ធ្វើចិត្តឲ្យជ្រះថ្លាហើយក្នុងព្រះសង្ឃ ។ ព្រះសាស្តា ទ្រង់ប្រមើលមើលចិត្តរបស់រាជសីហ៍ហើយ ទ្រង់ព្យាករថា នឹងបានជាព្រះពុទ្ធក្នុងអនាគត ។ ព្រះនគររបស់ព្រះមានព្រះភាគបទុម ឈ្មោះចម្បកៈ ព្រះរាជាព្រះនាមបទុមជាព្រះបិតា ព្រះរាជ-មាតាព្រះនាមអសមា អគ្គសាវកឈ្មោះសាលៈ ១ ឧបសាលៈ ១ ឧបដ្ឋាកឈ្មោះវរុណៈ អគ្គសាវិកាឈ្មោះរាមា ១ សុរាមា ១ សោណព្រឹក្ស គឺដើមម្រុំជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំដូច្នេះឯង ។

> ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សីមក មាន
> ព្រះសម្ពុទ្ធព្រះនាមបទុម ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមាន
> បុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ក្នុងកាលខាងក្រោយមកទៀត ព្រះសាស្តាព្រះនាមនារទៈកើតឡើងហើយសាវកសន្និបាតមាន ៣ ដង ក្នុងសន្និបាតលើកដំបូង មានភិក្ខុ ១ សែនកោដិ លើកទីពីរមានភិក្ខុ ៩០ សែនកោដិ លើកទីបីមានភិក្ខុ ៨០ សែនកោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វបួសជាឥសី ជាអ្នកបដិបត្តិរហូតជំនាញក្នុងអភិញ្ញា ៥ សមាបត្តិ ៨ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន បានធ្វើការបូជាដោយចន្ទន៍ក្រហម ព្រះសាស្តាបានព្យាករឥសីនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។ ព្រះនគររបស់ព្រះសាស្តា

អង្គនោះឈ្មោះធញ្ញវតី ក្សត្រព្រះនាមសុមេធជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមអនោមា អគ្គសាវកឈ្មោះភទ្ទបាល ១ ជិតមិត្ត ១ ឧបដ្ឋាកឈ្មោះវាសេដ្ឋ: អគ្គសាវិកាឈ្មោះឧត្តរា ១ ផគ្គុណី ១ ដើមមហាសោណព្រឹក្សជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមមក មានព្រះសម្ពុទ្ធព្រះនាមនារទ: ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះពុទ្ធព្រះនាមនារទ: ក្នុងកប្បមួយ ក្នុងទីបំផុតមួយសែនកប្ប រាប់អំពីកប្បនេះ កន្លងបានមួយអសង្ខេយ្យ ព្រះពុទ្ធមួយអង្គព្រះនាមបទុមុត្តរ: ទ្រង់កើតឡើងហើយ ។ សាវកសន្និបាតរបស់ព្រះអង្គមាន ៣ ដង ក្នុងលើកដំបូង មានភិក្ខុ ១ សែនកោដិ លើកទីពីរត្រង់ភ្នំវេភារបព៌ត មានភិក្ខុ ៩០ សែនកោដិ លើកទីបី មានភិក្ខុ ៨០ ពាន់កោដិ ក្នុងកាលនោះ ព្រះពោធិសត្វជាជដិល ឈ្មោះមហារដ្ឋិយ: បានថ្វាយចីវរ-ទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះអង្គក៏បានព្យាករថា បុរសនេះនឹងបានជាព្រះពុទ្ធក្នុងអនាគត ។ ក្នុងសាសនាព្រះមានព្រះភាគបទុមុត្តរ: មិនមានពួកតិរ្ថិយ ។ ពួកទេវតា និងមនុស្សទាំងពួង បានដល់នូវព្រះពុទ្ធប៉ុណ្ណោះជាសរណ: ព្រះនគររបស់ព្រះអង្គព្រះនាមហង្សវតី ក្សត្រព្រះនាមអានន្ទជាព្រះរាជបិតា ព្រះមាតាព្រះនាមសុជាតា អគ្គសាវកឈ្មោះទេវល: ១ សុជាត: ១ ឧបដ្ឋាកឈ្មោះសុមន: អគ្គសាវិកាឈ្មោះអមិត្តា ១ អសមា

១ ដើមសាលព្រឹក្សជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ រស្មីផ្សាយចេញអំពីព្រះកាយ ១២ យោជន៍ដោយជុំវិញ ព្រះជន្មាយុ ១ សែនឆ្នាំ ដូច្នេះ ។

ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះ
សម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្មោះមារ
ទ្រង់មិនរំភើប ឧបមាដូចសាគរ ដូច្នេះ ។

បន្ទាប់អំពីព្រះពុទ្ធព្រះនាមបទុមុត្តរៈ កន្លងទៅបាន ៣ ម៉ឺនកប្ប ក្នុងកប្បមួយ មានព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះសុមេធ ១ ព្រះសុជាត ១ កើតឡើងហើយ ។ សាវកសន្និបាតរបស់ព្រះពុទ្ធព្រះនាមសុមេធក៏មាន ៣ ដង ក្នុងសន្និបាតគ្រាដំបូង ក្នុងសុទស្សនគរ មានព្រះខីណាស្រព ១០០ កោដិ គ្រាទីពីរមាន ៩០ កោដិ គ្រាទី ៣ មាន ៨០ កោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វជាមាណពឈ្មោះឧត្តរៈ លះទ្រព្យ ៨០ កោដិ កប់ទុកទាំងអស់ គឺថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌ហើយ តាំងនៅក្នុងសរណៈ ចេញបួស ទ្រង់ក៏ព្យាករថា មាណពនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។ នគររបស់ព្រះមានព្រះភាគសុមេធ ឈ្មោះសុទស្សនៈ ព្រះរាជាព្រះនាមសុទត្តៈជាព្រះបិតា ព្រះមាតាព្រះនាមសុទត្តា អគ្គសាវក ២ អង្គ ឈ្មោះសុមនៈ ១ សព្វកាម ១ ឧបដ្ឋាកឈ្មោះសាគរ អគ្គសាវិកា ២ អង្គ ឈ្មោះរាមា ១ សុរាមា ១ ។ មហានិម្ពព្រឹក្ស គឺដើមស្តៅធំ ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុបាន ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ មក

មានព្រះពុទ្ធព្រះនាមសុមេធ ព្រះអង្គជានាយក គេគ្របសង្កត់បាន ដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រីដ៏ប្រសើរ ឧត្តមជាងលោកទាំងមូល ដូច្នេះ ។

ក្នុងកាលបន្ទាប់មក ព្រះសាស្តាព្រះនាមសុជាត កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គមាន ៣ ដង ក្នុងសន្និបាតដំបូងមានភិក្ខុ ៦ ម៉ឺន លើកទីពីរមាន ៥ ម៉ឺន លើកទីបីមាន ៤ ម៉ឺន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាស្តេចចក្រពត្តិ បានឮថា ព្រះពុទ្ធកើតឡើងហើយ ទើបចូលទៅគាល់ស្តាប់ធម៌ ទើបថ្វាយរាជសម្បត្តិក្នុងទ្វីបទាំង ៤ មួយអន្លើដោយរតនៈ ៧ ប្រការ ដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបួសក្នុងសម្នាក់របស់ព្រះមុនី អ្នកដែនទាំងអស់ កាន់យកប្រាក់ដែលកើតឡើងក្នុងរដ្ឋ ទទួលនាទីជាអ្នកទំនុកបម្រុងវត្ត ។ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានជានិច្ច ។ ព្រះសាស្តាទ្រង់ព្យាករថា ភិក្ខុអង្គនេះនឹងបានជាព្រះពុទ្ធក្នុងអនាគត នគរនៃព្រះមានព្រះភាគ ឈ្មោះសុមង្គល ព្រះរាជាព្រះនាមឧគ្គតៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមបភាវតី អគ្គសាវកឈ្មោះសុទស្សនៈ ១ សុទេវៈ ១ ឧបដ្ឋាកឈ្មោះនារទៈ អគ្គសាវិកាឈ្មោះនាគា ១ នាគសមាលា ១ មហាវេឡុព្រឹក្ស គឺដើមឫស្សីធំជាឈើត្រាស់ដឹង បានឮថា ដើមឫស្សីនោះមិនមានប្រហោង ដើមរឹងមាំ មានស្លឹកធំដុះឡើងទៅខាងលើ ល្អ គួរគេយកគន់ ដូចកន្ទុយក្ងោក ។ ព្រះសរីរៈរបស់ព្រះសាស្តាអង្គនោះ កម្ពស់ ៥០ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធ ជានាយក ព្រះនាមសុជាត ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ទ្រង់មានព្រះស្មូរង ដូចជាកនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ដូច្នេះ ។

បន្ទាប់អំពីព្រះសម្ពុទ្ធសុជាត ក្នុងកប្បមួយ ក្នុងទីបំផុត ១៨ កប្បអំពីកប្បនេះ មានព្រះពុទ្ធ ៣ អង្គកើតឡើង គឺព្រះបិយទស្សី ១ អត្ថទស្សី ១ ធម្មទស្សី ១ ។ សាវកសន្និបាតរបស់ព្រះបិយទស្សី មាន ៣ ដង លើកទីមួយ មានភិក្ខុ ១ សែនកោដិ លើកទីពីរមាន ៩០ កោដិ លើកទីបីមាន ៨០ កោដិ ក្នុងកាលនោះ ព្រះពោធិសត្វជាមាណពឈ្មោះកស្សបៈ រៀនចប់វេទទាំង ៣ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា បានបរិច្ចាគទ្រព្យមួយសែនកោដិ ធ្វើសង្ឃារាម តាំងនៅក្នុងសរណៈ និងសីល ហើយពេលនោះ ព្រះសាស្ដាទ្រង់ព្យាករថា នឹងបានជាព្រះពុទ្ធ កាលកន្លងទៅ ១៨០០ កប្ប ។ នគររបស់ព្រះសាស្ដាអង្គនោះឈ្មោះអនោបមៈ ព្រះរាជាព្រះនាមសុទិន្នជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមចន្ទា អគ្គសាវកឈ្មោះបាលិតៈ ១ សព្វទស្សី ១ ឧបដ្ឋាកឈ្មោះសោភិតៈ អគ្គសាវិកាឈ្មោះសុជាតា ១ ធម្មទិន្នា ១ កកុធព្រឹក្ស គឺដើមថ្កាន់ ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយនៃព្រះសម្ពុទ្ធ ព្រះនាមសុជាតមក មានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោកនាយក ទ្រង់

មានយសច្រើន គេគ្របសង្កត់បានដោយក្រ ព្រះអង្គស្មើដោយ
ព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ដូច្នេះ ។

បន្ទាប់អំពីព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតឡើងហើយ ។ សាវកសន្និបាតរបស់ទ្រង់មាន ៣ ដង សន្និបាតដំបូង មានភិក្ខុ ៩ លាន ៨ សែន គ្រាទីពីរ ៨ សែន គ្រាទីបីក៏ស្មើគ្នា ក្នុងកាលនោះ ព្រះពោធិសត្វជាតាបសមានឫទ្ធិច្រើន ឈ្មោះសុសិមៈ បាំងឆត្រផ្កាអង្គាបុស្ស ចុះអំពីទេវលោកបូជាព្រះសាស្តា ទ្រង់ក៏បានព្យាករថា នឹងបានជាព្រះពុទ្ធក្នុងអនាគត ។ នគររបស់ព្រះសាស្តាឈ្មោះសោភិតៈ ព្រះរាជាព្រះនាមសាគរជាព្រះបិតា ព្រះរាជមាតាព្រះនាមសុទស្សនា អគ្គសាវកឈ្មោះសន្តៈ ១ ឧបសន្តៈ ១ ឧបដ្ឋាកឈ្មោះអភយា ។ អគ្គសាវិកាឈ្មោះធម្មា ១ សុធម្មា ១ ចម្បកព្រឹក្ស គឺដើមចម្ប៉ាជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ មានរស្មីផ្សាយអំពីព្រះសរីរៈប្រមាណ ១ យោជន៍ តាំងនៅសព្វកាល ព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី មានយសធំ
ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះអង្គ ព្រះសាស្តា ទ្រង់ព្រះនាមធម្មទស្សីកើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គមាន ៣ ដង លើកទីមួយ មានភិក្ខុ ១០០ កោដិ លើកទីពីរមាន ៧០ កោដិ លើកទីបី ៨០ កោដិ ក្នុងកាលនោះ ព្រះមហាសត្វជាសក្កទេវរាជ បានធ្វើការបូជាដោយផ្កា ដែលមានក្លិនដ៏

ជាទិព្វ ដោយតន្ត្រីទិព្វ ទ្រង់ក៏បានព្យាករថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។ ព្រះនគររបស់ព្រះសាស្តាអង្គនោះឈ្មោះសរណៈ ព្រះរាជាព្រះនាមសរណៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមសុនន្ទា អគ្គសាវកឈ្មោះបទុមៈ ១ បុស្សទេវៈ ១ ឧបដ្ឋាកឈ្មោះសុនេត្តៈ អគ្គសាវិកាឈ្មោះខេមា ១ សព្វនាមា ១ ដើមវត្តកុរវកព្រឹក្ស ឬដើមពិម្ពជាល[1] គឺដើមទទ្រាប់ក៏មាន ។ សរីរៈរបស់ព្រះអង្គ កម្ពស់ ៨០ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមធម្មទស្សី មានយសធំ
ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញ៉ាំងមនុស្សលោក ព្រមទាំង
ទេវលោកឲ្យរុងរឿង ដូច្នេះ ។

បន្ទាប់អំពីព្រះសម្ពុទ្ធអង្គនោះ ក្នុងកប្បមួយ ក្នុងទីបំផុតនៃ ៩០ កប្បអំពីកប្បនេះ ព្រះពុទ្ធមួយអង្គព្រះនាមសិទ្ធត្ថ កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ក្នុងសន្និបាតលើកដំបូង មានភិក្ខុ ១ សែនកោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វជាតាបស ឈ្មោះមង្គល មានតេជៈខ្លាំងក្លា សម្បូរដោយអភិញ្ញាពល បាននាំផ្លែព្រីងធំមកថ្វាយដល់ព្រះតថាគត ។ ព្រះសាស្តាសោយផ្លែឈើនោះហើយ ទ្រង់បានព្យាករព្រះពោធិសត្វថា ក្នុងទីបំផុតអំពីកប្បនេះ ៩៤ កប្ប អ្នកនឹងបានជាព្រះពុទ្ធ ។ នគររបស់ព្រះសាស្តាអង្គនោះឈ្មោះវេភារៈ ព្រះរាជាព្រះនាមជយសេនជាព្រះរាជបិតា ព្រះរាជមាតាព្រះនាម

---

១- បាលីពុទ្ធវង្ស ជាតិម្ពជាលព្រឹក្ស ។

សុផស្សា អគ្គសាវកឈ្មោះសម្ពលៈ ១ សុមិត្ត ១ ឧបដ្ឋាកឈ្មោះរេវតៈ អគ្គសាវិកាឈ្មោះសិវលា ១ សុរាមា ១ កណ្ណិកព្រឹក្សជាឈើត្រាស់ដឹង ។ ព្រះសរីរៈកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាមសិទ្ធត្ថ

ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះសិទ្ធត្ថ ក្នុងទីបំផុតនៃកប្បទី ៩២ អំពីកប្បនេះ មានព្រះពុទ្ធកើតឡើង ២ ព្រះអង្គ ក្នុងកប្បតែមួយ គឺព្រះតិស្សៈ ១ ព្រះផុស្សៈ ១ ។ សម្រាប់ព្រះសាស្តាព្រះនាមតិស្សៈ មានសាវកសន្និបាត ៣ លើក លើកទីមួយមានភិក្ខុ ១០០ កោដិ លើកទីពីរមាន ៩០ កោដិ លើកទីបីមាន ៨០ កោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វជាក្សត្រ មានភោគៈច្រើន មានយសធំ ឈ្មោះសុជាត ទ្រង់បួសជាឥសី ដល់នូវភាពជាអ្នកមានឫទ្ធិច្រើន បានឮថា ព្រះពុទ្ធកើតឡើងហើយ កាន់យកផ្កាមណ្ឌារវៈ ផ្កាឈូកក្រហម និងផ្កាបារិច្ឆត្តកៈដែលជាទិព្វមកបូជាព្រះតថាគត ដែលគង់នៅក្នុងកណ្តាលបរិស័ទ ៤ ក្នុងអាកាស បានធ្វើពិតានផ្កាថ្វាយ ។ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករថា ក្នុងកប្បទី ៩០ អំពីកប្បនេះ អ្នកនឹងបានជាព្រះពុទ្ធ ។ នគរព្រះសាស្តាអង្គនោះឈ្មោះខេមៈ ក្សត្រព្រះនាមជនសន្ធៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមបទុមា អគ្គសាវកឈ្មោះព្រហ្មទេវៈ ១ ឧទយៈ ១ ឧបដ្ឋាកឈ្មោះសម្ភវៈ អគ្គសាវិកាឈ្មោះបុស្សា ១ សុទត្តា ១ អសនព្រឹក្សគឺដើមធ្នង់ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុ ១

សែនឆ្នាំ ។

ក្រោយពីព្រះពុទ្ធព្រះនាមសិទ្ធត្ថមក មានព្រះពុទ្ធព្រះនាមតិស្សៈ
ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមាន
បុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់
ពុំបាន ដូច្នេះ ។

បន្ទាប់មកទៀត ព្រះសាស្តាព្រះនាមផុស្សៈ កើតឡើងហើយ សន្និបាតរបស់ព្រះអង្គក៏មាន ៣ ដង ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៦០ សែន លើកទី ២ មាន ៥០ សែន លើកទី ៣ មាន ៣២ សែន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាក្សត្រព្រះនាមវិជិតាវី ទ្រង់លះរាជសម្បត្តិធំ ហើយបួសក្នុងសម្នាក់ព្រះសាស្តា ទ្រង់រៀនព្រះត្រៃបិដកហើយ ទ្រង់សម្តែងធម្មកថាដល់មហាជន ទ្រង់បំពេញសីលបារមី ។ ព្រះផុស្សៈអង្គនោះក៏ព្យាករថា នឹងបានជាព្រះពុទ្ធ នគររបស់ព្រះសាស្តាអង្គនោះឈ្មោះកាសី ព្រះរាជាព្រះនាមជយសេន ជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមសិរិមា អគ្គសាវកឈ្មោះសុរក្ខិតៈ ១ ធម្មសេនៈ ១ ឧបដ្ឋាកឈ្មោះសោភិយៈ អគ្គសាវិកាឈ្មោះចាលា ១ ឧបចាលា ១ អាមលកព្រឹក្ស គឺដើមកន្ទួតព្រៃ ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តាព្រះនាមបុស្សៈ ទ្រង់មិន
មានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយ
ព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរក្នុងលោក

ដូច្នេះ ។

បន្ទាប់មក ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះមានព្រះភាគទ្រង់ព្រះនាមវិបស្សី ទ្រង់កើតឡើងហើយ ។ សាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ ដង ក្នុងសន្និបាតដំបូង មានភិក្ខុ ៦៨ សែន លើកទីពីរមាន ៩១ សែន លើកទីបីមាន ៨ ម៉ឺន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាស្តេចនាគឈ្មោះអតុលៈ មានឫទ្ធិច្រើន មានអានុភាពច្រើន បានថ្វាយតាំងធំ ធ្វើដោយមាសរំលេចដោយកែវ ៧ ប្រការដល់ព្រះសាស្តា សូម្បីទ្រង់ក៏បានព្យាករនាគនោះថា ក្នុងកប្បទី ៩១ អំពីកប្បនេះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ។ នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះពន្ធុមតី ព្រះរាជាព្រះនាមពន្ធុមៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមពន្ធុមតី អគ្គសាវកឈ្មោះខណ្ឌៈ ១ តិស្សៈ ១ ពុទ្ធុបដ្ឋាកឈ្មោះអសោកៈ អគ្គសាវិកាឈ្មោះចន្ទា ១ ចន្ទមិត្តា ១ បាដលិព្រឹក្ស គឺដើមប្រទៀង ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨០ ហត្ថ ព្រះរស្មីចេញអំពីព្រះកាយ ផ្សាយចេញទៅអស់ ៧ យោជន៍ ព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ។

ក្រោយអំពីព្រះពុទ្ធព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ មានព្រះ
នាមវិបស្សី ដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុកើតឡើងក្នុង
លោក ដូច្នេះ ។

បន្ទាប់អំពីនោះមក ចំនួន ៣១ កប្ប មានព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះសិខី ១ ព្រះវេស្សភូ ១ សាវកសន្និបាតរបស់ព្រះសិខីក៏មាន ៣ ដង ក្នុង

សន្និបាតលើកទី ១ មានភិក្ខុ ១ សែន លើកទី ២ មាន ៨ ម៉ឺន លើកទី ៣ មាន ៧ ម៉ឺន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាព្រះរាជា ទ្រង់ព្រះនាម អរិន្ទមៈ បានថ្វាយមហាទាន មួយអន្លើដោយចីវរដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយដំរីកែវដែលតាក់តែងដោយកែវ ៧ ប្រការ បានថ្វាយកប្បិយភណ្ឌ ធ្វើឲ្យមានទំហំប៉ុនខ្នងដំរី ព្រះអង្គក៏ទ្រង់ព្យាករថា នឹងបានជាព្រះពុទ្ធក្នុងកប្បទី ៣១ អំពីកប្បនេះ ។ នគររបស់ព្រះសាស្តាអង្គនោះមានឈ្មោះអរុណវតី ក្សត្រនាមអរុណជាព្រះរាជបិតា ព្រះរាជមាតាព្រះនាមបភាវតី អគ្គសាវកនាមអភិភូ ១ សម្ភវៈ ១ ឧបដ្ឋាកឈ្មោះខេមង្ករ អគ្គ-សាវិកាឈ្មោះខេមា ១ បទុមា ១ ។ បុណ្ឌរិកព្រឹក្ស គឺដើមស្វាយសជាឈើត្រាស់ដឹង សរីរៈកម្ពស់ ៣៧ ហត្ថ ព្រះរស្មីចេញអំពីព្រះសរីរៈផ្សាយទៅ ៣០០ យោជន៍ ព្រះជន្មាយុ ៣ ម៉ឺន ៧ ពាន់ឆ្នាំ ។

ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី ទ្រង់
ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀប
ផ្ទឹមបាន ដូច្នេះ ។

ក្នុងកាលជាបន្តមកទៀត ព្រះសាស្តាព្រះនាមថា វេស្សភូទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ ដង ក្នុងសន្និបាតលើកដំបូងមានភិក្ខុ ៨ លាន លើកទី ២ មាន ៧ លាន លើកទី ៣ មាន ៦ លាន កាលនោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាមសុទស្សនៈ ថ្វាយមហាទានព្រមទាំងចីវរដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់បួសក្នុងសម្នាក់ព្រះ

សាស្តា ជាអ្នកបរិបូណ៌ដោយអាចារគុណ ច្រើនទៅដោយការកោតក្រែង និង បីតិ ក្នុងព្រះពុទ្ធរ័តន៍ សូម្បីទ្រង់ក៏បានព្យាករព្រះអង្គថា ក្នុងកប្បទី ៣១ អំពីកប្បនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ នគររបស់ព្រះសាស្តាអង្គនោះឈ្មោះ អនោមៈ ព្រះរាជាព្រះនាមសុប្បតីតៈជាព្រះរាជបិតា ព្រះរាជមាតាព្រះនាម យសវតី អគ្គសាវកឈ្មោះសោណៈ ១ ឧត្តរៈ ១ ឧបដ្ឋាកឈ្មោះឧបសន្តៈ អគ្គសាវិកាឈ្មោះរាមា ១ សុមាលា ១ សាលព្រឹក្សជាដើមឈើត្រាស់ដឹង ។ ព្រះសរីរៈកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាមវេស្សភូ ព្រះអង្គ
មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើង
ក្នុងលោក ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះអង្គ ក្នុងកទ្ទកប្បនេះ មានព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះកកុសន្ធៈ ១ កោនាគមនៈ ១ កស្សបៈ ១ ព្រះមានព្រះភាគនៃយើង ១ សម្រាប់ព្រះសាស្តាព្រះនាមកកុសន្ធៈ មានសាវកសន្និបាតមួយលើក ក្នុងសាវកសន្និបាតនោះ មានភិក្ខុ ៤ ម៉ឺន ។ ក្នុងកាលនោះ ព្រះពោធិសត្វជាព្រះរាជានាមខេមៈ ថ្វាយមហាទាន មួយអន្លើដោយបាត្រ និងចីវរ និងភេសជ្ជៈ មានថ្នាំបន្តក់ភ្នែកជាដើមដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ទ្រង់ព្រះផ្នួស ព្រះសាស្តាអង្គនោះ ក៏បានព្យាករហើយ ។ នគររបស់ព្រះសាស្តាកកុសន្ធៈឈ្មោះខេមៈ ព្រាហ្មណ៍ឈ្មោះ អគ្គិទត្តៈជាព្រះបិតា ព្រាហ្មណីឈ្មោះវិសាខាជាមាតា អគ្គសាវកឈ្មោះវិធូរៈ

១ សញ្ជីវៈ ១ ឧបដ្ឋាកឈ្មោះពុទ្ធិជៈ អគ្គសាវិកាឈ្មោះសាខា ១ សារម្ភា ១ ។ មហាសិរិសព្រឹក្ស គឺដើមប្រេសធំជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៤០ ហត្ថ ព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធ ព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់ មិនបាន គេគ្របសង្កត់បានដោយកម្រ ដូច្នេះ ។

បន្ទាប់អំពីព្រះអង្គ ព្រះសាស្តាព្រះនាមកោនាគមនៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មានម្តង ក្នុងសន្និបាតនោះ មានភិក្ខុ ៣ ម៉ឺន រូប ក្នុងកាលនោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាមបព្វតៈ មានពួកអមាត្យ ចោមរោម យាងទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ព្រះធម្មទេសនា ហើយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានហើយ ថ្វាយ សំពត់បត្តុណ្ណ គឺសំពត់សូត្រ ចីនបជៈ គឺសំពត់កោជវៈ សំពត់កម្ពល និង សំពត់សម្បកឈើសាច់ល្អ រួមទាំងសំពត់ដែលត្បាញដោយមាស ហើយទ្រង់ ព្រះផ្នួសក្នុងសម្នាក់ព្រះសាស្តា ទ្រង់ព្យាករព្រះពោធិសត្វហើយ នគររបស់ ព្រះសាស្តាអង្គនោះឈ្មោះសោភវតី ព្រាហ្មណ៍ឈ្មោះយញ្ញទត្តៈជាព្រះបិតា ព្រាហ្មណីឈ្មោះឧត្តរាជាព្រះមាតា អគ្គសាវកឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១ ឧបដ្ឋាកឈ្មោះសោត្ថិជៈ អគ្គសាវិកាឈ្មោះសមុទ្ទា ១ ឧត្តរា ១ ឧទុម្ពរព្រឹក្ស គឺដើមល្វាជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ២០ ហត្ថ ព្រះជន្មាយុបាន ៣ ម៉ឺនឆ្នាំ ។

កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រីសម្ពុទ្ធ ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ដូច្នេះ ។

បន្ទាប់អំពីព្រះសម្ពុទ្ធកោនាគមនៈ ព្រះសាស្តាព្រះនាមកស្សបៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មានត្រឹមតែម្តងប៉ុណ្ណោះ ក្នុងសន្និបាតនោះ មានភិក្ខុ ២ ម៉ឺន ក្នុងគ្រានោះ ព្រះពោធិសត្វជាមាណពឈ្មោះជោតិបាល រៀនចប់ត្រៃវេទ ជាអ្នកមានឈ្មោះបោះសំឡេង ទាំងលើផែនដី និងលើអាកាស បានជាមិត្តរបស់នាយស្មូនឆ្នាំងឈ្មោះឃដិការ ។ មាណពនិងស្មូនឆ្នាំងនោះ ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម្មកថាហើយបួស ធ្វើនូវសេចក្តីព្យាយាម រៀននូវព្រះត្រៃបិដក ដែលជាលម្អក្នុងព្រះពុទ្ធសាសនា ព្រោះដល់ព្រមដោយវត្តបដិបត្តិ ព្រះសាស្តាទ្រង់ក៏បានព្យាករមាណពហើយ ។ ព្រះនគរដែលជាទីប្រសូត របស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា ពារាណសី ព្រាហ្មណ៍ឈ្មោះព្រហ្មទត្តជាបិតា ព្រាហ្មណីឈ្មោះធនវតីជាមាតា អគ្គសាវកឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ ឧបដ្ឋាកឈ្មោះសព្វមិត្ត អគ្គសាវិកាឈ្មោះអនុឡា ១ ឧរុវេឡា ១ ។ និគ្រោធព្រឹក្ស គឺដើមជ្រៃជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ២០ ហត្ថ ព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ។

កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនៈមក មានព្រះសម្ពុទ្ធព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់

ធ្វើពន្ទឹ[១] ដូច្នេះ ។

ក្នុងកប្បដែលព្រះទសពលទីបង្ករកើតឡើង ព្រះពុទ្ធនឹងមានដល់ ៣ អង្គ ព្រះពោធិសត្វមិនបានទទួលព្យាករអំពីសម្នាក់ព្រះពុទ្ធទាំងនោះ ព្រោះដូច្នោះ ទើបព្រះពុទ្ធទាំងនោះ លោកមិនបានសម្ដែងក្នុងទីនេះ តែក្នុងអដ្ឋកថា ដើម្បីនឹងសម្ដែងព្រះពុទ្ធទាំងអស់ ចាប់តាំងអំពីកប្បនោះ ទើបលោកពោលពាក្យនេះថា

ព្រះសម្ពុទ្ធទាំងនេះ គឺព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ ព្រះទីបង្ករសម្ពុទ្ធ ព្រះកោណ្ឌញ្ញៈដ៏ឧត្តមជាងនរៈ ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈដ៏ជាមុនី ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សី ទ្រង់មានយសធំ ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថ ដ៏ជាលោកនាយក ព្រះតិស្សៈ ព្រះបុស្សៈដ៏ជាសម្ពុទ្ធ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះលោក-នាយកកស្សបៈ ទ្រង់សុទ្ធតែមានរាគៈទៅប្រាសហើយ មានព្រះហឫទ័យតាំងមាំ ទ្រង់កម្ចាត់ងងឹតធំបាន ដូចព្រះអាទិត្យ ទ្រង់កើត

---

(១) គាថាទាំងអស់ចាប់អំពីសុមេធកថាមក នគរក្តី ព្រះបិតាក្តី ព្រះមាតាក្តី អគ្គ-សាវកជាដើមក្តី របស់ព្រះពុទ្ធទាំងឡាយ សេចក្តីពិស្តារមានហើយ ក្នុងគម្ពីរពុទ្ធវង្ស ឯណោះ តែមានសេចក្តីខុសប្លែកគ្នាវាងឈ្មោះ អាយុ ឈើត្រាស់ដឹង ចំនួនសាវកក្នុងសន្និបាតរបស់ព្រះពុទ្ធទាំងឡាយខ្លះៗ បណ្ឌិតគប្បីកាន់យកន័យទាំងពីរ ប្រៀបធៀបគ្នាហើយកាន់យកដោយល្អចុះ ។

ឡើងហើយ ភ្លឺសន្ធោសន្ធៅ ដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ មួយអន្លើដោយសាវ័ក ដូច្នេះ ។

ក្នុងរឿងនោះ ព្រះពោធិសត្វនៃយើងសាងគុណក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះទីបង្ករជាដើម អស់ ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប បន្ទាប់អំពីព្រះមានព្រះភាគព្រះនាមកស្សបៈ មិនមានព្រះពុទ្ធដទៃវៀរព្រះសម្មាសម្ពុទ្ធអង្គនេះ ។ ព្រះពោធិសត្វបានទទួលព្យាករនៅក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ មានព្រះទីបង្ករជាដើម ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១ ភាពសម្បូរ ដោយភេទ ១ ហេតុ ១ ការបានជួបព្រះសាស្តា ១ ការបួស ១ ការដល់ព្រមដោយគុណ ១ ការធ្វើធំក្រៃលែង ១ ឆន្ទៈ ១ ការប្រាថ្នាដែលតាំងចិត្តពិត រមែងសម្រេចបាន ដូច្នេះ ។

ព្រះមហាសត្វបានធ្វើសេចក្តីប្រាថ្នាធំក្រៃលែង ទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមទីបង្ករ សមោធានធម៌ ៨ ប្រការនេះ មកហើយ ធ្វើនូវឧស្សាហៈថា ណ្ហើយចុះ អញនឹងជ្រើសរើសធម៌ដែលធ្វើឲ្យជាព្រះពុទ្ធ អំពីទីនោះខ្លះ ទីនេះខ្លះ បានឃើញពុទ្ធការកធម៌ មានទានបារមីជាដើម ដោយពោលថា កាលតថាគតកំពុងជ្រើសរើស បានឃើញទានបារមីជាដំបូង បំពេញធម៌ទាំងនោះរហូតដល់អត្តភាពជាព្រះវេស្សន្តរ កាលមកដល់ ក៏បានមកសម្រេចអានិសង្សសម្រាប់ព្រះពោធិសត្វ ដែលបានធ្វើសេចក្តីប្រាថ្នាដែលតាំងចិត្តពិត ដូច

លោកពណ៌នាជាច្រើនថា

នរជនដែលសម្បូរដោយអង្គគុណគ្រប់ប្រការ ជាអ្នកទៀងចំពោះពោធិញ្ញាណអស់សង្សារ ដែលមានរយៈកាលយូរ រាប់ដោយរយកោដិកប្ប នឹងមិនកើតក្នុងអវិចី ក្នុងលោកន្តរនរកដូចគ្នា បើកើតក្នុងទុគ្គតិ មិនកើតជានិជ្ឈាមតណ្ហិកប្រេត ខុប្បិបាសាប្រេត កាឡកញ្ជិកាសុរ មិនកើតជាសត្វតូចៗ បើកើតក្នុងមនុស្ស មិនជាមនុស្សខ្វាក់អំពីកំណើត មិនជាមនុស្សថ្លង់ មិនជាមនុស្ស-គ មិនកើតជាស្ត្រី មិនជាឧភតោព្យញ្ជនកៈ គឺមនុស្សភេទ ២ និងខ្ទើយ នរជនដែលទៀងចំពោះពោធិញ្ញាណ មិនមានចិត្តជាប់ជំពាក់ក្នុងវត្ថុណា ផុតចាកអនន្តរិយកម្ម ជាអ្នកមានគោចរស្អាត ក្នុងទីទាំងពួង មិនសេពនូវមិច្ឆាទិដ្ឋិ ព្រោះឃើញផលក្នុងការធ្វើកម្ម សូម្បីនៅក្នុងពួកសត្វទាំងឡាយ ក៏មិនកើតជាអសញ្ញីសត្វ ក្នុងពួកដែលនៅក្នុងសុទ្ធាវាស ក៏មិនមានហេតុទៅកើត ជាសប្បុរស បង្អោនចិត្តទៅក្នុងនេក្ខម្មៈ ដោះនូវភពតូចភពធំចេញហើយ ប្រព្រឹត្តតែប្រយោជន៍ដល់លោក បំពេញបារមីគ្រប់ប្រការ ត្រាច់ទៅ ដូច្នេះ ។

កាលព្រះមហាសត្វ ទ្រង់បំពេញបារមីនោះឯង អត្តភាពដែលបំពេញទានបារមី គឺក្នុងកាលជាព្រាហ្មណ៍ឈ្មោះអកិត្តិ ក្នុងកាលជាព្រាហ្មណ៍ឈ្មោះសង្ខៈ ក្នុងកាលជាព្រះរាជាព្រះនាមធនញ្ជ័យ ក្នុងកាលជាព្រះបាទមហាសុទស្សនៈ ក្នុងកាលជាមហាគោវិន្ទ ក្នុងកាលជានិមិមហារាជ ក្នុងកាលជា

ចន្ទកុមារ ក្នុងកាលជាវិសយ្ហសេដ្ឋី ក្នុងកាលជាព្រះបាទសិវិរាជ ក្នុងកាលជាព្រះវេស្សន្តរ ក៏គួរហួសទឹងរាប់បាន តែទានបារមីរបស់ព្រះពោធិសត្វ ដែលបរិច្ចាគខ្លួន ក្នុងសសបណ្ឌិតជាតក ( ចរិយាបិដក សសបណ្ឌិតចរិយា ) យ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន ជារបស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទានរបស់តថាគត មិនមានឡើយ នេះជាទានបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

ដូចគ្នានេះដែរ អត្តភាពដែលបំពេញសីលបារមី គឺក្នុងកាលជាសីលវនាគរាជ ( ក្នុងសីលវនាគជាតក ) ក្នុងកាលជាចម្បេយ្យនាគរាជ ក្នុងកាលជាភូរិទត្តនាគរាជ ក្នុងកាលដែលជាឆទ្ទន្តនាគរាជ ( ក្នុងកាលដែលជាស្តេចដំរីឈ្មោះឆទ្ទន្ត ) ក្នុងកាលជាជយទិសរាជបុត្ត ក្នុងកាលដែលជាអលីនសត្តុកុមារ ក៏ហួសទឹងរាប់បាន តែសីលបារមីរបស់ព្រះពោធិសត្វ ដែលបរិច្ចាគខ្លួន ក្នុងសង្ខបាលជាតក ( សង្ខបាលចរិយា ) យ៉ាងនេះថា

( ប៉ុន្តែ ) តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច និងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

ដូចគ្នានោះដែរ អត្តភាពដែលព្រះពោធិសត្វ លះរាជសម្បត្តិយ៉ាងធំ

បំពេញនេក្ខម្មបារមី គឺក្នុងកាលដែលជាសោមនស្សកុមារ ក្នុងកាលដែលជាហត្ថិបាលកុមារ ក្នុងកាលដែលជាអយោឃរបណ្ឌិត ក៏នៅរាប់បាន តែនេក្ខម្មបារមីរបស់ព្រះពោធិសត្វ ដែលលះរាជសម្បត្តិចេញបួស ជាបុគ្គលប្រាសចាកគ្រឿងជាប់ជំពាក់ ក្នុងចូឡសុតសោមជាតកយ៉ាងនេះថា

តថាគតលះរាជសម្បត្តិយ៉ាងធំ ដែលនៅក្នុងកណ្ដាប់ដៃ ដូចដុំទឹកមាត់ ហើរទៅ កាលតថាគតលះបង់ហើយ មិនមានការជាប់ជំពាក់ឡើយ នេះជានេក្ខម្មបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

ដូចគ្នានោះដែរ អត្តភាពដែលបំពេញបារមី គឺក្នុងកាលដែលជាវិធុរបណ្ឌិត ក្នុងកាលដែលជាមហាគោវិន្ទបណ្ឌិត ក្នុងកាលដែលជាកុទ្ទាលបណ្ឌិត ក្នុងកាលដែលជាអរកបណ្ឌិត ក្នុងកាលដែលជាពោធិបរិព្វាជក ក្នុងកាលដែលជាមហោសថបណ្ឌិត ក៏ហួសនឹងរាប់បាន តែបញ្ញាបារមីរបស់ព្រះពោធិសត្វដែលបង្ហាញពស់នៅក្នុងថ្ងៃ ក្នុងកាលដែលនៅជាសេនកបណ្ឌិត ក្នុងជាតកដែលពោលអំពីថ្ងៃសដូវ ( សេនកជាតក ) យ៉ាងនេះថា

កាលតថាគតពិចារណាដោយបញ្ញា ដោះនូវព្រាហ្មណ៍ឲ្យផុតចាកទុក្ខបាន បុគ្គលដែលស្មើដោយបញ្ញារបស់តថាគតមិនមាន នេះជាបញ្ញាបារមីរបស់តថាគត ដូច្នេះ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

ដូច្នោះដូចគ្នា អត្តភាពដែលបំពេញវិរិយបារមីជាដើម ក៏ហួសនឹងរាប់បាន តែវិរិយបារមីរបស់ព្រះពោធិសត្វដែលឆ្លងមហាសមុទ្រ ក្នុងមហាជនកជាតក

យ៉ាងនេះថា

ក្នុងកណ្តាលអន្លង់ទឹក តថាគតមើលមិនឃើញត្រើយឡើយ ពួកមនុស្សត្រូវស្លាប់ទាំងអស់ ភាពជវៃទៃនៃចិត្តមិនមានឡើយ នេះជាវិរិយបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមីពិតប្រាកដ ។

ខន្តិបារមីរបស់ព្រះពោធិសត្វដែលអត់ធន់នូវទុក្ខ ព្រោះធ្វើដូចជាមិនមានចិត្ត ក្នុងខន្តិវាទីជាតកយ៉ាងនេះថា

តថាគតមិនក្រោធ ក្នុងព្រះបាទកាសិករាជ ដែលវាយតថាគតដូចមិនមានចិត្ត កាប់ដោយពូថៅដ៏មុត នេះជាខន្តិបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

សច្ចបារមីរបស់ព្រះពោធិសត្វដែលលះជីវិត តាមរក្សានូវសច្ចៈ ក្នុងមហាសុតសោមជាតកយ៉ាងនេះថា

តថាគត កាលតាមរក្សានូវសច្ចវាចា លះបង់ជីវិតរបស់តថាគត ដោះនូវក្សត្រ ១០១ អង្គបានហើយ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

អធិដ្ឋានបារមីរបស់ព្រះពោធិសត្វ ដែលលះជីវិតអធិដ្ឋានវត្ត ក្នុងមូគ-ផក្ខជាតក ( តេមិយជាតក ) យ៉ាងនេះថា

មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួន ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាន

នោះ[១] ដូច្នេះ ។ ចាត់ជាបរមត្ថបារមី ពិតប្រាកដ ។

មេត្តាបារមីរបស់ព្រះពោធិសត្វ ដែលមិនសម្លឹងមើលសូម្បីតែជីវិត គង់មានមេត្តានៅក្នុងឯករាជជាតកយ៉ាងនេះថា

សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគតក៏មិនខ្លាច
សត្វណាមួយឡើយ កាលណោះ កម្លាំងមេត្តាឧបត្ថម្ភតថាគត ឲ្យ
តថាគតនៅក្នុងព្រៃដោយសួស្តី[២] ដូច្នេះ ។ ចាត់ជាបរមត្ថបារមី
ពិតប្រាកដ ។

ឧបេក្ខាបារមីរបស់ព្រះពោធិសត្វ ដែលមិនប្រព្រឹត្តកន្លងឧបេក្ខា កាលពួកក្មេងអ្នកស្រុកបង្កទុក្ខ និងសុខឲ្យកើត ដោយការស្តោះទឹកមាត់ជាដើមខ្លះ ដោយការនាំផ្កាឈើ និងគ្រឿងក្រអូបមកឲ្យខ្លះ ក្នុងលោមហំសជាតក ( មហាលោមហំសចរិយា ) យ៉ាងនេះថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃស្មសាន
ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយ សម្តែងនូវ
ប្រការដ៏ប្លែកច្រើនយ៉ាង ដូច្នេះ ។ ចាត់ជាបរមត្ថបារមីពិតប្រាកដ ។

សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណត្រឹមប៉ុណ្ណេះ ។ ឯដោយពិស្តារគប្បីកាន់យកអត្ថនោះអំពីចរិយាបិដក ។ ព្រះពោធិសត្វបំពេញបារមីយ៉ាងនេះ

---

១- គាថានេះ មានក្នុងចរិយាបិដក ។

២- គាថានេះ មិនមានក្នុងឯករាជជាតក ( ឯករាជចរិយា ) តែមានក្នុងសុវណ្ណសាមចរិយា ព្រះអដ្ឋកថាបានពោល ទើបយើងរក្សា ។

ហើយ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ធ្វើមហាកុសលដែលជាហេតុឲ្យមហាប្រឹថពីកម្រើកហើយ ( ក្នុងវេស្សន្តរចរិយា ) យ៉ាងនេះថា

ប្រឹថពី មិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហាប្រឹថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទាន របស់តថាគត ដូច្នេះ ។

ក្នុងកាលអស់អាយុ ចុតិអំពីនោះ បានទៅកើតក្នុងតុសិតភព តាំងអំពីបាទមូលរបស់ព្រះពុទ្ធព្រះនាមទីបង្ករ រហូតដល់ព្រះពោធិសត្វកើតក្នុងតុសិតបុរី សេចក្តីនោះ គប្បីជ្រាបថា ជាទូរេនិទាន ។

**ទូរេនិទានកថា ចប់**

## អវិទូរេនិទាន

កាលព្រះពោធិសត្វនៅក្នុងតុសិតបុរីនោះឯង ពុទ្ធកោលាហលបានកើតឡើងហើយ ពិតហើយ ក្នុងលោក រមែងមានកោលាហល ៣ យ៉ាង កើតឡើង គឺកប្បកោលាហល ១ ពុទ្ធកោលាហល ១ ចក្កពត្តិកោលាហល ១ ។

ពួកទេវតាជាន់កាមាវចរ ឈ្មោះលោកព្យូហដឹងថា ហេតុការណ៍ដែលកើតឡើង គឺកប្បត្រូវវិនាស នឹងមានក្នុងកាលកន្លងទៅមួយសែនឆ្នាំ មានក្បាលសើម រំសាយសក់ មានមុខជោកដោយទឹកភ្នែក យកដៃជូតទឹកភ្នែក ស្លៀកសំពត់ក្រហម មានរូបរាងចម្លែក ត្រាច់ទៅប្រាប់ដល់ពួកមនុស្សថា នែអ្នកនិទ្ទុក្ខទាំងឡាយ កន្លងទៅមួយសែនឆ្នាំទៀត ការវិនាសនៃកប្បនឹងមានឡើង លោកនេះ ក៏នឹងវិនាសទៅ មហាសមុទ្រក៏នឹងវិនាស មហាប្រឹថពីនេះ

និងស្តេចកុំសិនេរុ នឹងត្រូវភ្លើងឆេះវិនាសទៅ សេចក្តីវិនាស នឹងមានរហូតដល់ព្រហ្មលោក នែអ្នកនិទ៌ុក្ខទាំងឡាយ ចូរពួកអ្នកចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខា ចូរបម្រើ មាតា បិតា ចូរជាអ្នកឱនលំទោនចំពោះរៀមច្បងក្នុងត្រកូល ដូច្នេះ នេះ ឈ្មោះថា **កប្បកោលាហល** ។

ពួកទេវតាឈ្មោះលោកបាល ដឹងថា កន្លងទៅ ១០០០ ឆ្នាំ ព្រះសព្វញ្ញុ-ពុទ្ធ នឹងកើតឡើងក្នុងលោក ដូច្នេះហើយ នាំគ្នាត្រាច់ប្រកាស នេះ ឈ្មោះថា **ពុទ្ធកោលាហល** ។

ទេវតាពួកនោះឯង ដឹងថា កន្លងទៅ ១០០ ឆ្នាំ ស្តេចចក្រពត្តិ នឹងកើតឡើង ដូច្នេះហើយ នាំគ្នាត្រាច់ប្រកាសថា នែអ្នកនិទ៌ុក្ខទាំងឡាយ ក្នុងកាលកន្លងទៅ ១០០ ឆ្នាំទៀត ស្តេចចក្រពត្តិ នឹងកើតឡើងក្នុងលោក ដូច្នេះ នេះឈ្មោះថា **ចក្កពត្តិកោលាហល** ។

ក្នុងកោលាហលទាំង ៣ ប្រការនេះ ឈ្មោះថា ជារបស់ធំ ៗ បណ្តាកោលាហលទាំង ៣ នោះ ទេវតាក្នុងម៉ឺនចក្កវាឡបានស្តាប់សំឡេងកោលា-ហល រឿងពុទ្ធកោលាហលហើយ ទើបប្រជុំគ្នា ដឹងថា សត្វឈ្មោះនោះនឹងបានជាព្រះពុទ្ធ ចូលទៅរកហើយ អារាធនាហើយ អារាធនាទៀត ក្នុងកាលបុព្វនិមិត្តកើតឡើងហើយ ៗ ក្នុងកាលនោះ ទេវតាទាំងពួង មួយអន្លើដោយចាតុម្មហារាជ សក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចនិម្មានរតីស្តេចបរនិម្មិតវសវត្តី និងស្តេចមហាព្រហ្ម ក្នុងចក្រវាលមួយ មកប្រជុំគ្នាក្នុងចក្រវាលមួយ ហើយនាំគ្នាទៅកាន់សម្នាក់របស់ព្រះពោធិសត្វក្នុងឋានតុសិត

អារាធនាថា បពិត្រលោកនិទ៌ុក្ខ លោកកាលបំពេញបារមី ១០ ក៏មិនបាន ប្រាថ្នាសម្បត្តិសក្កទេវរាជ សម្បត្តិមារ សម្បត្តិស្តេចចក្រពត្តិ សម្បត្តិរបស់ព្រហ្ម តែលោកបំពេញប្រាថ្នាសព្វញ្ញុតញ្ញាណ ដើម្បីនាំសត្វចេញចាកលោក បពិត្រលោកនិទ៌ុក្ខ ឥឡូវនេះ ដល់ពេលដែលលោកត្រាស់ជាព្រះពុទ្ធហើយ ដល់សម័យដែលលោកនឹងបានជាព្រះពុទ្ធហើយ ។

លំដាប់នោះព្រះមហាសត្វមិនទាន់ឲ្យប្តេជ្ញាដល់ទេវតាទាំងឡាយ ប្រមើលមើលមហាវិលោកនៈ គឺទីដែលត្រូវជ្រើសរើសធំ ៥ ប្រការ គឺកាល ១ ទ្វីប ១ ប្រទេស ១ ត្រកូល ១ ការកំណត់អាយុរបស់មាតា ១ ។ ក្នុង ៥ ប្រការនោះ ព្រះពោធិសត្វសម្លឹងមើលកាលថា កាលនេះសមគួរឬហ្ន៎ ។ ក្នុងសេចក្តីនោះ កាលនៃអាយុដែលចម្រើនឡើងលើសមួយសែនឆ្នាំ ជាកាលមិនសមគួរ ព្រោះហេតុអ្វី ព្រោះក្នុងកាលនោះ ជាតិ ជរា និងមរណៈ មិនប្រាកដដល់សត្វទាំងឡាយ ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ ដែលផុតចាកត្រៃលក្ខណ៍មិនមាន កាលទ្រង់ត្រាស់ថា អនិច្ចំ ទុក្ខំ អនត្តា ពួកមនុស្សគិតថា ទ្រង់ត្រាស់សេចក្តីនោះធ្វើអ្វី ហើយមិនសម្គាល់ថា គួរស្តាប់ គួរជឿ បន្ទាប់អំពីនោះ ក៏មិនមានការត្រាស់ដឹង កាលមិនមានការត្រាស់ដឹង សាសនាក៏មិនជាវត្ថុនាំចេញចាកទុក្ខ ព្រោះហេតុនោះ ទើបជាកាលមិនគួរ ។ កាលអាយុក្រោម ១០០ ឆ្នាំ ក៏ជាកាលដែលមិនគួរ ព្រោះហេតុអ្វី ព្រោះក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ឱវាទដែលឲ្យដល់បុគ្គលក្រាស់ដោយកិលេស មិនតាំងនៅជាឱវាទ ឱវាទនោះ ក៏នឹងបាត់ប្រាសទៅដោយ

រហ័ស ដូចស្នាមឈើប្រត់ក្នុងទឹក ដូច្នោះ ព្រោះហេតុនោះ កាលនោះ ក៏ចាត់ថា ជាកាលមិនគួរ ។ កាលនៃអាយុថយចុះអំពីមួយសែន ឡើងទៅអំពី ១០០ ចាត់ជាកាលគួរ ។ ក្នុងកាលនោះ ជាកាលនៃអាយុ ១០០ ឆ្នាំ ព្រះមហាសត្វ ក៏សម្លឹងឃើញថា ជាកាលដែលគួរកើតបានហើយ ។ បន្ទាប់អំពីនោះ កាលប្រមើលមើលទ្វីប ក៏ប្រមើលមើលទ្វីបធំ ៤ ឃើញទ្វីប ១ ថា ក្នុងទ្វីបទាំង ៣ ព្រះពុទ្ធទាំងឡាយ មិនកើតឡើយ តែងកើតក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។ តអំពីនោះ ក៏ប្រមើលមើលប្រទេសថា ធម្មតាជម្ពូទ្វីបធំធេង មានប្រមាណដល់ទៅមួយម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយ នឹងកើតឡើងក្នុងប្រទេសណាហ្ន៎ ទើបសម្លឹងឃើញមជ្ឈិមប្រទេស ។ ឈ្មោះថា មជ្ឈិមប្រទេស គឺប្រទេសដែលលោកពោលក្នុងវិនយបិដក ( មហាវគ្គ ) យ៉ាងនេះថា

បណ្ដាជនបទទាំងនោះ ជនទាំងឡាយនេះ ដែលជាបច្ចន្តិមជនបទ គឺក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គល-និគមនោះ មាននិគមឈ្មោះ មហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេត-កណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុក

ព្រាហ្មណ៍ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិម-ជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ដូច្នេះ ។

មជ្ឈិមប្រទេសនោះ បណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ វង្វង់ជុំវិញ ៩០០ យោជន៍ ។ ក្នុងប្រទេសនោះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ អគ្គសាវក អសីតិមហាសាវក ស្តេចចក្រពត្តិ ក្សត្រ ព្រាហ្មណ៍ គហបតី-មហាសាល បុគ្គលមានសក្តិធំដទៃ រមែងកើតឡើង នគរឈ្មោះកបិលពស្តុនេះ ក៏តាំងនៅក្នុងមជ្ឈិមប្រទេសនេះ ទើបព្រះពោធិសត្វ មានការសម្រេចចិត្តថា អញគួរទៅកើតក្នុងនគរនោះ ។

បន្ទាប់ពីនោះ ព្រះពោធិសត្វ កាលជ្រើសរើសត្រកូល ទើបឃើញត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនកើតឡើងក្នុងត្រកូលវេស្សៈ ឬក្នុងត្រកូលសូទ្រៈ តែកើតឡើងក្នុងត្រកូលក្សត្រ ឬក្នុងត្រកូលព្រាហ្មណ៍ ដែលសត្វលោកលើកតម្កើងត្រកូល ២ នេះប៉ុណ្ណោះ ឥឡូវនេះ ត្រកូលក្សត្រ សត្វលោកលើកតម្កើងហើយ អញនឹងកើតក្នុងត្រកូលនោះ ព្រះបាទសុទ្ធោទនមហារាជនឹងជាបិតារបស់អញ ដូច្នេះ បន្តពីនោះ កាលជ្រើសរើសមាតា ក៏ឃើញថា ធម្មតាពុទ្ធមាតា រមែងមិនល្មោះល្មោភក្នុងបុរស មិនជាអ្នកលេងសុរា និងជាអ្នកបំពេញបារមីមកអស់សែនកប្ប ចាប់តាំងអំពីកើត មានសីល ៥ មិនដាច់ ព្រះទេវីព្រះនាមមាយានេះ ព្រះនាងមានសភាពបែបនេះ

ព្រះនាងជាព្រះមាតារបស់អញ ដូច្នេះ កាលប្រមើលមើលថា ព្រះនាងមានព្រះជន្មាយុបានប៉ុនណា ក៏ឃើញថា មានអាយុនៅសល់ ១០ ខែ ៧ ថ្ងៃ ។

ព្រះពោធិសត្វប្រមើលមើលវិលោកនៈ ៥ ប្រការ ដោយប្រការដូច្នេះហើយ ពោលថា នែអ្នកនិទ្ទុក្ខដល់កាលគួររបស់ខ្ញុំហើយ ដែលនឹងត្រាស់ជាព្រះពុទ្ធ កាលធ្វើនូវសេចក្តីសង្គ្រោះដល់ទេវតាទាំងឡាយ ទើបឲ្យនូវបដិញ្ញា រួចពោលថា សូមពួកលោកទៅចុះ បញ្ជូនទេវតាទាំងនោះត្រឡប់ទៅ មានទេវតាជាន់តុសិតចោមរោម ហើយទៅកាន់នន្ទនវ័នក្នុងតុសិតបុរី ។ ពិតហើយនន្ទនវ័ន មានគ្រប់ទេវលោកនោះឯង ។ ទេវតាក្នុងនន្ទនវ័ន ក្នុងទេវលោកនោះពោលថា បពិត្រលោកនិទ្ទុក្ខ សូមលោកចុតិចាកនន្ទនវ័ននេះ ទៅកាន់សុគតិចុះ ដាស់តឿនឲ្យព្រះមហាសត្វរឭកដល់ឱកាសនៃកុសលកម្ម ដែលធ្លាប់ធ្វើក្នុងកាលមុន ព្រះពោធិសត្វ កាលពួកទេវតាដាស់តឿនឲ្យរឭកដល់កុសលកម្ម ចោមរោមហើយយ៉ាងនេះ ត្រាច់ទៅក្នុងទេវលោកនោះ ចុតិហើយ បដិសន្ធិក្នុងគភ៌នៃព្រះនាងមហាមាយាទេវី ដើម្បីឲ្យជាក់ច្បាស់ដល់វិធីដែលព្រះពោធិសត្វបដិសន្ធិ មានពាក្យបរិយាយតាមលំដាប់ដូច្នេះថា

បានឮថា ក្នុងកាលនោះ នគរកបិលពស្តុ មានអាសាឡ្ហនក្ខត្តឫក្សយ៉ាងគគ្រឹកគគ្រេង មហាជនលេងបុណ្យនក្ខត្តឫក្សនោះ ឯព្រះនាងមាយាទេវី ៧ ថ្ងៃទៀត ដល់ថ្ងៃពេញបូណ៌មី ទ្រង់ចូលរួមលេងនក្ខត្តឫក្ស តែមិនផឹកសុរា រៀបចំផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងប្រដាប់ ក្នុងថ្ងៃទី ៧ ព្រះនាងក្រោកឡើងអំពីព្រលឹម ព្រះនាងស្រេពស្រង់ដោយគ្រឿងក្រអូប លះព្រះរាជទ្រព្យ

៤ សែនឲ្យទាន ហើយតែងព្រះកាយដោយគ្រឿងប្រដាប់សព្វយ៉ាង សោយព្រះក្រយាហារយ៉ាងល្អ អធិដ្ឋានអង្គឧបោសថ ចូលកាន់បន្ទប់ដ៏មានសិរី ផ្ទំលើសិរីសេយ្យាសនៈ ឈានចុះកាន់និទ្រា ព្រះនាងសុបិនថា មហារាជទាំង ៤ លើកព្រះនាងឡើង មួយអន្លើដោយព្រះទែនបន្ទំនោះឯង ទៅកាន់ព្រៃហិមពាន្ត ដាក់ត្រង់ផ្ទៃសិលាប្រមាណ ៦០ យោជន៍ ខាងក្រោមដើមសាលព្រឹក្សធំ កម្ពស់ប្រមាណ ៧ យោជន៍ បានឈរក្នុងទីសមគួរ នាចំណែកម្ខាង គ្រានោះ មហេសីរបស់ស្តេចមហារាជទាំង ៤ នោះ នាំព្រះនាងទៅកាន់អនោតត្តស្រះ ឲ្យព្រះនាងស្រង់ ដើម្បីជម្រះនូវមន្ទិលរបស់មនុស្សចេញ ឲ្យស្លៀកដណ្តប់សំពត់ទិព្វ លាបដោយគ្រឿងក្រអូបទិព្វ ប្រដាប់ដោយផ្កាទិព្វ ក្នុងទីមិនឆ្ងាយអំពីទីនោះ មានភ្នំប្រាក់ ១ ខាងក្នុងភ្នំនោះ មានវិមានមាស ទេវតាទាំងនោះរៀបចំព្រះទែនបន្ទំដែលជាទិព្វ បែរសីសៈទៅទិសខាងកើត ទូលឲ្យផ្ទំក្នុងវិមាននោះ ព្រះពោធិសត្វជាស្តេចដំរីដ៏ប្រសើរ មានពណ៌សសុទ្ធ ដើរកាត់ភ្នំមាស ដែលនៅមិនឆ្ងាយអំពីទីនោះ ចុះអំពីភ្នំមាសនោះ ឡើងទៅកាន់ភ្នំប្រាក់ មកតាមផ្លូវទិសឧត្តរ យកប្រមោយដែលមានពណ៌ដូចកម្រងប្រាក់ចាប់ផ្កាបទុមជាតិពណ៌ស បន្លឺកោញ្ចនាទ ចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណព្រះទែនព្រះរាជមាតា ៣ ជុំហើយ ប្រាកដដូចទម្លុះឆ្អឹងជំនីរស្តាំចូលទៅក្នុងព្រះឧទររបស់ព្រះនាង ។ ព្រះពោធិសត្វបដិសន្ធិក្នុងថ្ងៃអាសាឡ្ហនក្ខត្តឫក្ស ដោយប្រការដូច្នេះ ។

ស្អែកឡើង ព្រះទេវីតើនអំពីព្រះបន្ទំ ក្រាបទូលសុបិននោះដល់ព្រះរាជា

ព្រះរាជាឲ្យអញ្ជើញព្រាហ្មណ៍ដែលជាព្រឹទ្ធាចារ្យទាំង ៦៤ នាក់ ឲ្យចូលគាល់ ឲ្យក្រាលអាសនៈដែលមានតម្លៃច្រើន លើទីដែលបូកលាបដោយគោម័យស្រស់ មានគ្រឿងសក្ការៈដែលជាមង្គល ធ្វើដោយលាជជាដើម ឲ្យដាក់មធុ- បាយាសដ៏ប្រសើរ ដែលចម្អិនដោយសប្បិ ទឹកឃ្មុំ និងស្ករក្រាម ដាក់ពេញជាសមាស និងថាសប្រាក់ យកថាសមាស និងថាសប្រាក់គ្របហើយ ឲ្យជនទាំងនោះឆ្អែតស្កប់ស្កល់ មួយអន្ទើដោយសំពត់ថ្មី និងមេគោក្របាមជាដើម កាលពួកព្រាហ្មណ៍ទាំងនោះឆ្អែតស្កប់ស្កល់ ដោយរបស់ដែលត្រូវការគ្រប់យ៉ាងហើយ ទើបប្រាប់ព្រះសុបិន ហើយត្រាស់សួរថា នឹងមានអ្វីកើតឡើង ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំវិតក្កឡើយ ព្រះទេវីតាំងព្រះគភ៌ហើយ ព្រះគភ៌នោះ ជាគភ៌របស់បុរស មិនមែនគភ៌របស់ស្ត្រី ទ្រង់នឹងមានព្រះរាជបុត្ត បើព្រះរាជបុត្តនោះនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើចេញបួស នឹងបានជាព្រះពុទ្ធ ទ្រង់មានកិលេស ដូចដំបូលដែលបើកហើយក្នុងលោក ។

ក្នុងខណៈដែលព្រះពោធិសត្វ ទ្រង់បដិសន្ធិក្នុងគភ៌របស់ព្រះមាតានោះឯង លោកធាតុមួយម៉ឺនកម្រើកញាប់ញ័រព្រមគ្នា ។ បុព្វនិមិត្ត ៣២ ប្រការប្រាកដឡើងហើយ ។ ក្នុងម៉ឺនចក្រវាលមានពន្លឺមិនមានប្រមាណផ្សាយទៅ ។ ពួកមនុស្សភ្នែកខ្វាក់ ក៏មានភ្នែកល្អឡើង ហាក់មានបំណងថា នឹងមើលព្រះសិរីរបស់ព្រះពោធិសត្វនោះ ពួកមនុស្សត្រចៀកថ្លង់ក៏ស្តាប់សំឡេងបាន ពួកមនុស្សគក៏និយាយបាន ពួកមនុស្សគមក៏មានខ្លួនត្រង់ ពួកមនុស្សខ្វិន ក៏ដើរ

ដោយជើងបាន សត្វទាំងពួងដែលត្រូវចង ក៏ផុតចាកគ្រឿងចង មានឃ្នោងជាដើម ។ ក្នុងនរកគ្រប់អន្ទើ ភ្លើងក៏រលត់ ក្នុងបិត្តិវិស័យ ការស្រេកឃ្លានក៏ស្ងប់រម្ងាប់ ។ ពួកសត្វតិរច្ឆានក៏មិនមានការភ័យខ្លាច រោគ និងភ្លើងកិលេសមានរាគៈជាដើមរបស់សត្វទាំងពួងក៏ស្ងប់រម្ងាប់ សត្វទាំងពួងមានវាចាគួរជាទីស្រឡាញ់ សេះទាំងឡាយក៏កញ្ជ្រៀវ ដំរីទាំងឡាយ ក៏កង្កួចដោយសំឡេងស្រទន់ ។ បណ្ដាតន្ត្រីគ្រប់ប្រភេទក៏កងរំពងឯង មិនមានបុគ្គលណាម្នាក់ប្រគំឡើយ គ្រឿងអាភរណៈដែលពាក់ត្រង់ដៃរបស់មនុស្សទាំងឡាយ ក៏លាន់ឮឡើង ទិសទាំងអស់ភ្លឺស្វាង ខ្យល់ត្រជាក់ស្រទន់បក់មក ធ្វើឲ្យកើតសុខដល់សត្វទាំងឡាយ ។ ភ្លៀងពុំដូកាលក៏ធ្លាក់ ទឹកក៏ជ្រែកចេញមកអំពីផែនដី ពួកបក្សីមិនហើរទៅក្នុងអាកាស ទឹកក៏មិនហូរ ទឹកស្ទឹងក៏នៅស្ងៀមមិនហូរ ទឹកក្នុងមហាសមុទ្រ ក៏មានរសឆ្ងាញ់ ផ្ទៃសមុទ្រទូទៅ ក៏ដេរដាសដោយផ្កាឈូក ដែលមានពណ៌ ៥ ផ្កាគ្រប់ប្រភេទ ដែលកើតលើផែនដី និងកើតក្នុងទឹក ក៏រីកទូទៅ ។ ត្រង់ដើមឈើ ឈូកដើម ក៏ចេញអំពីដើម ឯឈូកមែកក៏ចេញផ្កាអំពីមែក ឯឈូកវល្លិ ក៏ផ្កាអំពីវល្លិ ត្រង់ផែនដីមានផ្កាឈូកជ្រែកផែនថ្មផុសឡើង មួយកន្លែងៗ ៧ ផ្កា ក្នុងអាកាសក៏មានឈូកអាកាសកើតឡើងសំយុង ភ្លៀងផ្កា ក៏ធ្លាក់រោយរាយចុះមកដោយជុំវិញ ទិព្វតន្ត្រីក៏បន្លឺឡើងក្នុងអាកាស ក្នុងម៉ឺនលោកធាតុ ពេញដោយទង់ជ័យ និងកម្រងផ្កាជាប់គ្នាតែមួយរសាត់ទៅ ហាក់បីដូចកម្រងផ្កាដែលគេប្រមូលចងជាបាច់រួមគ្នា និងដូចគ្នានឹងជំណោកផ្កា ដែលប្រដាប់តាក់តែងហើយ មានផ្កាជាកម្រងតែមួយ

( ក្នុងម៉ឺនចក្កវាឡ ) ហាក់បីដូចផ្ទិតវាលវិជនីកំពុងបក់ផ្សាយនូវក្លិន គ្រឿងក្រអូប មួយអន្លើដោយក្លិនផ្សែងក្រអូប ជាលោកជាតុដែលដល់នូវលម្អដ៏ស្រស់ត្រកាលហើយ ចាប់តាំងអំពីព្រះពោធិសត្វបដិសន្ធិយ៉ាងនេះហើយ ដើម្បីការពារមិនឲ្យកើតអន្តរាយដល់ព្រះពោធិសត្វ និងព្រះរាជមាតារបស់ព្រះពោធិសត្វ ទេវបុត្រ ៤ អង្គ មានដៃកាន់ព្រះខ័ន ឃ្លាំថែរក្សា ។ ការគិតទាក់ទងដោយរាគៈក្នុងបុរសទាំងឡាយ មិនកើតដល់ព្រះរាជមាតារបស់ព្រះពោធិសត្វ ។ ព្រះនាងមានតែដល់នូវភាពដ៏លើសដោយលាភ និងយសសុខ មានព្រះកាយមិនលំបាក និងទតឃើញព្រះពោធិសត្វដែលនៅក្នុងព្រះគភ៌ទេវ ដូចអំបោះពណ៌សដែលដោតក្នុងកែវមណី ជម្មតាគភ៌ទេវដែលព្រះពោធិសត្វអាស្រ័យនៅ ដូចគ្នានឹងបន្ទប់របស់ចេតិយ សត្វដទៃមិនអាចនៅអាស្រ័យ ឬបរិភោគបាន ព្រោះហេតុនោះ ទើបព្រះរាជមាតានៃព្រះពោធិសត្វសោយព្រះវិលាល័យ ហើយទៅកើតក្នុងតុសិតបុរី ក្នុងកាលព្រះពោធិសត្វប្រសូតហើយ ៧ ថ្ងៃ ស្រីដទៃមិនដល់ ១០ ខែខ្លះ ហួស ១០ ខែខ្លះ អង្គុយប្រសូតខ្លះ ដេកប្រសូតខ្លះ យ៉ាងណា ព្រះរាជមាតារបស់ព្រះពោធិសត្វមិនមែនដូច្នោះឡើយ តែព្រះនាងបរិបាលព្រះពោធិសត្វក្នុងព្រះគភ៌ អស់ ១០ ខែ ហើយប្រថាប់ឈរប្រសូត សេចក្តីនេះឯង ជាជម្មតានៃព្រះមាតារបស់ព្រះពោធិសត្វ ។ ព្រះនាងមាយាទេវីបរិបាលព្រះពោធិសត្វក្នុងព្រះគភ៌ទេវ អស់ ១០ ខែ ដូចបរិបាលប្រេងក្នុងបាត្រ ដូច្នោះ មានព្រះគភ៌គ្រប់ខែហើយ មានព្រះរាជបំណងយាងទៅកាន់ផ្ទះញាតិ ទើបទូលព្រះបាទសុទ្ធោទនមហារាជ

ថា បពិត្រសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នាទៅកាន់នគរទេវទហៈ ដែលជានគររបស់ត្រកូល ។ ព្រះបាទសុទ្ធោទនៈទទួលថា សាធុ ហើយបញ្ជាឲ្យធ្វើផ្លូវតាំងអំពីនគរកបិលពស្តុ ដល់ទេវទហនគរ ឲ្យពង្រាបល្អហើយ លម្អដោយដើមចេក ក្អមពេញដោយទឹក ទង់ជ័យ និងទង់ផ្កាលា ឲ្យព្រះទេវីគង់ប្រថាប់ក្នុងវិមាស ឲ្យអមាត្យ ១០០០ នាក់សែងទៅ ទ្រង់បញ្ជូនទៅ មួយអន្លើដោយបរិវារច្រើន ។ ក្នុងចន្លោះព្រះនគរទាំង ២ សូម្បីអ្នកនគរទាំង ២ ក៏មានសាលវ័នជាមង្គលឈ្មោះលុម្ពិនីវ័ន ។ ក្នុងសម័យនោះ សាលវ័នទាំងពួងមានផ្ការីកដូចគ្នាតែមួយ តាំងអំពីគល់ រហូតដល់ចុង ។ ក្នុងរវាងមែក និងរវាងផ្កា បក្សីមានពណ៌ ៥ មានពណ៌ដូចសត្វកន្ធំ ហើរឆ្វៀលឆ្វាត់ យំល្វើយល្វេង លុម្ពិនីវ័នទាំងមូល ដូចគ្នានឹងចិត្តលតាវ័ន ដូចជាមណ្ឌលដែលមកប្រជុំគ្នាផឹក ។ ព្រះទេវីមានបំណងលេងកីឡាក្នុងសាលវ័ន ព្រោះទតឃើញលុម្ពិនីវ័ននោះ ។ ពួកអមាត្យនាំព្រះទេវីចូលទៅកាន់សាលវ័ន ព្រះនាងមានបំណងយាងទៅកាន់គល់សាលព្រឹក្ស ដែលជាមង្គល ហើយចាប់ត្រង់មែកសាលព្រឹក្ស មែកសាលព្រឹក្សក៏ទន់ចុះ ដូចលំពង់ផ្តៅដែលរោលឲ្យក្តៅហើយព្រះហស្តរបស់ព្រះទេវីល្មមឈោងដល់បាន ព្រះនាងទ្រង់លាព្រះហស្តចាប់ ។

ក្នុងខណៈនោះឯង ខ្យល់កម្មជវាតរបស់ព្រះនាងក៏បក់ឡើង ពេលនោះមហាជនព័ទ្ធវាំងននដល់ព្រះនាងហើយ ក៏ចៀសចេញទៅ ។ កាលព្រះនាងចាប់មែកសាលព្រឹក្ស ប្រថាប់ឈរនោះឯង បានប្រសូតហើយ ។ ក្នុងខណៈនោះឯង មហាព្រហ្មមានចិត្តបរិសុទ្ធ ៤ អង្គមកដល់ព្រម មួយអន្លើដោយ

បណ្ដាញមាស យកបណ្ដាញមាសនោះ ទទួលព្រះពោធិសត្វដាក់ត្រង់ព្រះភក្ត្រ របស់ព្រះមាតាបណ្ដឹរ ទូលបណ្ដឹរថា បពិត្រព្រះទេវី សូមព្រះនាងពេញព្រះហឫទ័យចុះ ព្រះរាជបុត្ររបស់ព្រះនាងមានសក្តិធំ កើតឡើងហើយ ។

សត្វដទៃកាលប្រសូតអំពីផ្ទៃមាតា រមែងប្រឡាក់ដោយវត្ថុបដិកូលដែលមិនស្អាត យ៉ាងណា ព្រះពោធិសត្វ មិនមែនដូច្នោះឡើយ ព្រះពោធិសត្វនោះ សណ្ដូកដៃ និងជើងទាំង ២ ឈរត្រង់ ដូចធម្មកថិកចុះអំពីធម្មាសនៈ ដូចបុរសចុះអំពីជណ្ដើរ មិនប្រឡាក់ដោយរបស់មិនស្អាតណាមួយ ដែលមានក្នុងព្រះគភ៌មាតា ជាបុគ្គលស្អាតបរិសុទ្ធ រុងរឿងដូចកែវមណី ដែលដាក់លើសំពត់កាសិកពស្ត្រ ប្រសូតចាកព្រះគភ៌របស់ព្រះមាតា កាលបើដូច្នោះក្តី ធារទឹកទាំង ២ ខ្សែ ក៏ហូរចុះមកអំពីអាកាស ស្រោចស្រពព្រះសរីរៈរបស់ព្រះពោធិសត្វ និងព្រះមាតា ធ្វើឲ្យកក់ក្ដៅសប្បាយ ដើម្បីជាគ្រឿងសក្ការៈដល់ព្រះពោធិសត្វ និងព្រះមាតា បន្ទាប់អំពីនោះ មហារាជ ៤ អង្គបានទទួលព្រះពោធិសត្វនោះអំពីដៃរបស់ព្រហ្ម ដែលឈរយកបណ្ដាញមាសទទួលដោយកម្រាលដែលធ្វើដោយស្បែកខ្លាជំបង មានសម្ផស្សទន់ ដែលសន្មតថាជាមង្គល ទើបពួកមនុស្សយកទុកូលពស្ត្រ ទទួលអំពីដៃរបស់មហារាជទាំងនោះ លុះផុតចាកដៃរបស់ពួកមនុស្ស ព្រះពោធិសត្វ ក៏ប្រថាប់ឈរលើផែនដី ទតទិសខាងកើត ។ ចក្រវាលច្រើនពាន់ប្រាកដតែមួយ ពួកទេវតា និងមនុស្សក្នុងទីនោះ នាំគ្នាបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ក្រាបទូលថា បពិត្រមហាបុរស អ្នកដទៃក្នុងទីនេះ ដូចគ្នានឹងព្រះអង្គមិនមានទេ តើបុគ្គល

ដែលក្រៃលែងជាងនឹងមានមកអំពីណា ។ ព្រះពោធិសត្វ សម្លឹងមើលសព្វទិសធំ ទិសតូចទាំង ១០ គឺទិសធំ ៤ ទិសតូច ៤ ខាងក្រោម ខាងលើ ក៏មិនបានឃើញបុគ្គលណាដូចគ្នានឹងព្រះអង្គ ទើបព្រះតម្រិះថា នេះជាទិសខាងជើង ដូច្នេះហើយ យាងទៅដោយព្រះបាទ ៧ ជំហាន មានមហាព្រហ្មបាំងស្វេតច្ឆត្រ សុយាមទេវបុត្តកាន់ផ្លិតវាលវីជនី ទេវតាដទៃមានដៃកាន់នូវគ្រឿងរាជកកុធភណ្ឌដ៏សេស យាងតាម បន្ទាប់អំពីនោះ ប្រថាប់ឈរត្រង់ជំហានទី ៧ ទ្រង់បន្លឺអាសភិវាចាថា យើងជាបុគ្គលកំពូលនៃលោកជាដើម ទ្រង់បន្លឺសីហនាទហើយ ។

ពិតហើយ ព្រះមហាសត្វគ្រាន់តែប្រសូតចាកព្រះគភ៌មាតាប៉ុណ្ណោះ ក៏បន្លឺវាចាបាន ក្នុង ៣ អត្តភាព គឺ ១ អត្តភាពជាមហោសថ ២ អត្តភាពជាព្រះវេស្សន្តរ ៣ អត្តភាពនេះ ។ បានឮថា ក្នុងអត្តភាពជាមហោសថ កាលព្រះពោធិសត្វ ប្រសូត សក្កទេវរាជយាងមក ទ្រង់ដាក់ខ្លឹមចន្ទន៍ត្រង់ដៃ ហើយយាងទៅ ព្រះពោធិសត្វក្តាប់ខ្លឹមចន្ទន៍នោះក្នុងកណ្តាប់ដៃប្រសូតមក គ្រានោះ មាតាសួរថា នៃកូន កូនកាន់អ្វីមក ។ ព្រះពោធិសត្វឆ្លើយថា បពិត្រអ្នកម៉ែ ថ្នាំ ។ ព្រោះកាន់យកថ្នាំមក ទើបមនុស្សទាំងឡាយឲ្យឈ្មោះថា ឱសថ-ទារក ជនទាំងឡាយយកថ្នាំនោះដាក់ក្នុងថ្លាងឱសថនោះឯង បានជាថ្នាំព្យា-បាលរោគសព្វយ៉ាង ដល់មនុស្សខ្វាក់ និងមនុស្សថ្លង់ ដែលនាំគ្នាមក បន្ទាប់មក ព្រោះកាន់យកពាក្យដែលនិយាយគ្នាថា ឱសថនេះមានគុណច្រើន ឱសថនេះមានគុណច្រើន ទើបឲ្យឈ្មោះបន្ថែមទៀតថា មហោសថ ។ ឯក្នុងអត្តភាព

ជាព្រះវេស្សន្តរ ព្រះពោធិសត្វគ្រាន់តែប្រសូតចាកគភ៌របស់មាតា ក៏លាដៃចេញ ពោលថា បពិត្រអ្នកម៉ែ ក្នុងផ្ទះមានទ្រព្យខ្លះទេ ខ្ញុំនឹងឲ្យទាន ហើយប្រសូតមក ពេលនោះ ព្រះមាតារបស់ព្រះពោធិសត្វពោលថា នែបា កូនកើតក្នុងត្រកូលមានទ្រព្យ ពោលហើយ ដាក់ថង់ប្រាក់ ១០០០ ហើយ ទើបដាក់ដៃរបស់កូនលើបាតដៃរបស់ព្រះនាង ក្នុងអត្តភាពជាព្រះពោធិសត្វ បន្លឺសីហនាទនេះ ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វ គ្រាន់តែប្រសូតចាកព្រះគភ៌មាតាប៉ុណ្ណោះ ក៏បន្លឺវាចាបានក្នុង ៣ អត្តភាព ដោយប្រការដូច្នេះ ។ ក្នុងខណៈបដិសន្ធិ យ៉ាងណា សូម្បីក្នុងខណៈប្រសូតក៏យ៉ាងនោះ ។ បុព្វនិមិត្ត ៣២ ប្រការ ក៏បានប្រាកដឡើងក្នុងសម័យដែលព្រះពោធិសត្វនៃយើង កើតហើយក្នុងលុម្ពិនីវន សម័យនោះឯង ព្រះទេវីដែលជាព្រះរាជមាតារបស់ព្រះរាហុល ឆន្នអមាត្យ កាឡុទាយិអមាត្យ អានន្ទកុមារ ស្តេចសេះឈ្មោះកណ្ឋកៈ មហាពោធិព្រឹក្ស កំណប់ទ្រព្យទាំង ៤ រណ្តៅ ក៏កើតឡើងព្រមគ្នា ។ បណ្តាកំណប់ទ្រព្យទាំងនោះ កំណប់ទី ១ មានប្រមាណមួយគាវុត កំណប់ទី ២ មានប្រមាណកន្លះយោជន៍ កំណប់ទី ៣ មានប្រមាណ ៣ គាវុត កំណប់ទី ៤ មានប្រមាណ ១ យោជន៍ ព្រោះដូច្នោះ ទើបរួមជាសហជាត ៧ យ៉ាងនេះ ។ ពួកអ្នកក្រុង ២ នគរ បាននាំព្រះពោធិសត្វត្រឡប់ទៅកាន់នគរកបិលពស្តុនោះឯង ក្នុងថ្ងៃនោះ ទេវតាក្នុងតាវត្តិង្សព្រិកពគ្រែកអរថា ព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជកើតហើយក្នុងនគរកបិលពស្តុ រាជកុមារនេះ នឹងគង់ប្រថាប់ត្រង់

មណ្ឌលពោធិ៍ នឹងបានជាព្រះពុទ្ធ ដូច្នេះ នាំគ្នាគ្រវីសំពត់ សម្ដែងសេចក្ដីត្រេកអរទ្រហឹងអឹងអាប់ ។

ក្នុងសម័យនោះ មានតាបសអ្នកស្និទ្ធស្នាលនឹងត្រកូលព្រះបាទសុទ្ធោទនមហារាជ សម្រេចសមាបត្តិ ៨ ឈ្មោះកាឡទេវល ឆាន់ស្រេចបាច់ហើយ ទើបហោះទៅកាន់តាវត្តិង្សពិភព ដើម្បីសម្រាកក្នុងពេលថ្ងៃ អង្គុយសម្រាកពេលថ្ងៃក្នុងទីនោះ ឃើញទេវតាទាំងនោះ ទើបសួរថា ព្រោះហេតុអ្វី ទើបពួកលោកមានចិត្តត្រេកអរ លេងយ៉ាងសុខសាន្តយ៉ាងនេះ ចូរប្រាប់ហេតុនោះដល់អាត្មាផងចុះ ពួកទេវតាបានប្រាប់ហេតុនោះថា បពិត្រលោកនិទ្ទុក្ខ ព្រះរាជឱរសព្រះបាទសុទ្ធោទនៈកើតឡើងហើយ ក្នុងកាលនោះ ទ្រង់នឹងប្រថាប់គង់ត្រង់គល់ពោធិព្រឹក្ស ហើយនឹងបានត្រាស់ជាព្រះពុទ្ធប្រកាសព្រះធម្មចក្រ ពួកខ្ញុំត្រេកអរ ព្រោះហេតុនេះថា ពួកយើងនឹងបានឃើញព្រះពុទ្ធលីលាដែលមិនមានទីបំផុត នឹងបានស្ដាប់ធម៌របស់ព្រះអង្គ តាបសនោះស្ដាប់ពាក្យរបស់ទេវតាហើយ ចុះអំពីទេវលោកមួយរំពេច ចូលទៅកាន់ព្រះរាជនិវេសន៍ អង្គុយលើអាសនៈ ដែលគេក្រាលហើយ ក្រាបទូលថា មហាបពិត្រ បានឮថា ព្រះរាជឱរសរបស់ព្រះអង្គកើតហើយ អាត្មាចង់ឃើញ ព្រះរាជាត្រាស់ឲ្យនាំព្រះរាជកុមារដែលប្រដាប់តាក់តែងហើយមក ទ្រង់ពទៅដើម្បីឲ្យនមស្ការតាបស ព្រះបាទទាំង ២ របស់ព្រះពោធិសត្វ បែរជាទៅប្រតិស្ឋានលើជដានៃតាបសពិតហើយ បុគ្គលដទៃដែលឈ្មោះថា ព្រះមហាសត្វគប្បីថ្វាយបង្គំដោយអត្តភាពនោះ មិនមាន បើបុគ្គលដែលមិនដឹង គប្បីដាក់សីសៈរបស់ព្រះ

ពោធិសត្វទៀបបាទមូលរបស់តាបស ក្បាលរបស់តាបសនោះ គប្បីបែកជា ៧ ភាគ តាបសគិតថា ការធ្វើខ្លួនរបស់អាត្មាអញឲ្យវិនាសមិនសមគួរ ដូច្នេះហើយ ទើបក្រោកចាកអាសនៈ ហើយផ្គងអញ្ជលីដល់ព្រះពោធិសត្វ ព្រះរាជាទ្រង់ទតឃើញហេតុអស្ចារ្យនោះ ទើបទ្រង់ថ្វាយបង្គំបុត្ររបស់ខ្លួន ។ តាបសរឭកបាន ៨០ កប្ប គឺក្នុងអតីត ៤០ ក្នុងអនាគត ៤០ ឃើញលក្ខណសម្បត្តិរបស់ព្រះពោធិសត្វ ទើបពិចារណាថា ព្រះរាជកុមារនឹងបានជាព្រះពុទ្ធឬហ្ន៎ ជ្រាបថា នឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ ទើបគិតថា ព្រះរាជបុត្រនេះ ជាអច្ឆរិយបុរស ទើបធ្វើការញញឹមឲ្យប្រាកដ បន្ទាប់អំពីនោះ ទើបពិចារណាថា អញនឹងបានឃើញភាពជាព្រះពុទ្ធឬហ្ន៎ ក៏ឃើញថា នឹងមិនបានឃើញ នឹងស្លាប់មុនក្នុងចន្លោះនោះ ហើយទៅកើតក្នុងអរូបភព ដែលព្រះពុទ្ធ ១០០ អង្គក្តី ១០០០ អង្គក្តី មិនអាចយាងទៅដើម្បីឲ្យត្រាស់ដឹងបាន ហើយគិតថា អញមិនឃើញអច្ឆរិយបុរសដែលជាព្រះពុទ្ធបែបនេះ អញនឹងវិនាសធំ ដូច្នេះហើយ ក៏ទ្រហោយំ ។

ពួកមនុស្សឃើញហើយ ទើបសាកសួរថា លោកម្ចាស់របស់យើងសើចអម្បាញ់មិញនេះឯង ហើយបែរជាទ្រហោយំ បពិត្រលោកម្ចាស់ អន្តរាយណាមួយនឹងកើតដល់ព្រះអយ្យបុត្ររបស់ពួកយើងឬ ។ តាបសឆ្លើយថា ទ្រង់មិនមានអន្តរាយ នឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ ។

ពួកមនុស្សសួរថា បើដូច្នោះ ហេតុអ្វី ទើបលោកទ្រហោយំ ។ តាបសឆ្លើយថា ខ្ញុំស្រណោះខ្លួន ព្រោះមិនបានឃើញព្រះមហាបុរសជាព្រះពុទ្ធបែប

នេះ ការវិនាសធំនឹងមានដល់ខ្ញុំ ដូច្នេះ ទើបខ្ញុំយំ ។

បន្ទាប់អំពីនោះ តាបសពិចារណាថា ក្នុងញាតិរបស់អញ អ្នកណាខ្លះនឹងឃើញភាពជាព្រះពុទ្ធ បានឃើញទារកទារកជាក្មួយ ទើបចូលទៅកាន់ផ្ទះរបស់ប្អូនស្រី សួរថា តើទារកៈកូនរបស់នាងនៅឯណា ។ ប្អូនស្រីឆ្លើយថា បពិត្រលោកម្ចាស់ ទារកៈនៅក្នុងផ្ទះ ។ តាបសពោលថា ចូរហៅមក ឲ្យហៅមកហើយ ។ តាបសពោលនឹងទារកៈដែលមកកាន់សម្នាក់របស់ខ្លួនថា នែបា ព្រះរាជឱរសកើតហើយក្នុងត្រកូលរបស់ព្រះបាទសុទ្ធោទនមហារាជ ជាពន្លកសពេជ្ញ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលកន្លងទៅ ៣៥ ឆ្នាំទៀត បាទឹងបានឃើញព្រះអង្គ ចូរបាបួសក្នុងថ្ងៃនេះឯង កុមារកើតក្នុងត្រកូលមានទ្រព្យ ៨៧ កោដិ គិតថា អឺរបស់អញ មិនមែនណែនាំក្នុងផ្លូវមិនមានប្រយោជន៍ឡើយ រំពេចនោះឯង ឲ្យមនុស្សទិញសំពត់កាសាវពស្ត្រ និងបាត្រដីមកអំពីផ្សារ ឲ្យកោរសក់ និងពុកមាត់ ដណ្តប់កាសាវពស្ត្រ ផ្គងអញ្ជលីបែរមុខទៅរកព្រះពោធិសត្វ ពោលថា អគ្គបុគ្គលក្នុងលោកអង្គណា ខ្ញុំសូមបួសឧទ្ទិសអង្គនោះ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន យកបាត្រដាក់ក្នុងស្ពាក ពាក់ត្រង់ចង្កេះស្មាហើយ ទៅកាន់ហិមវន្តប្បទេស បំពេញសមណធម៌ ។ លោកចូលទៅគាល់ព្រះសាស្តាដែលបានសម្រេចអភិសម្ពោធិគ្រាដំបូង ទូលសូមឲ្យទ្រង់សម្តែងនាលកបដិបទា ហើយចូលទៅកាន់ព្រៃហិមពាន្តវិញ សម្រេចអរហត្ត បដិបត្តិបដិបទាយ៉ាងតឹងរ៉ឹង រក្សាអាយុមកបាន ៧ ខែ ឈរផ្អែកភ្នំមាសនោះឯង បរិនិព្វានហើយ ដោយអនុបាទិសេ-

សនិព្វានជាតុ ។

ក្នុងថ្ងៃទី ៥ ព្រះញាតិទាំងឡាយ គិតថា ក្នុងថ្ងៃទី ៥ ពួកយើងនឹងស្រង់សីសៈព្រះពោធិសត្វ ហើយថ្វាយព្រះនាមដល់ព្រះអង្គ ដូច្នេះហើយ បូកលាបព្រះរាជមន្ទីរដោយគន្ធជាតិ ៤ បាចផ្កា មានលាជជាគម្រប់ ៥ ឲ្យចម្អិនបាយាសសុទ្ធៗ ហើយនិមន្តព្រាហ្មណ៍ដែលរៀនចប់ត្រៃវេទ ១០៨ នាក់ អង្គុយឲ្យក្នុងរាជមន្ទីរ ឲ្យបរិភោគភោជនយ៉ាងល្អ ជូនសក្ការៈជាច្រើន ហើយសួរថា អ្វីហ្នឹងមានហើយ ឲ្យពិនិត្យមើលលក្ខណៈ បណ្ដាព្រាហ្មណ៍ទាំងនោះ

ព្រាហ្មណ៍ ៨ នាក់ គឺព្រាហ្មណ៍ឈ្មោះរាមៈ ១ ធជៈ ១ លក្ខណៈ ១ សុជាតិមន្តី[១] ១ ភោជៈ ១ សុយាមៈ ១ កោណ្ឌញ្ញៈ ១ សុទត្តៈ ១ ក្នុងកាលនោះ ពួកជនទាំងនោះ ជ្រើសរើសបានព្រាហ្មណ៍ ៨ នាក់ ដែលរៀនចប់វេទាង្គសាស្ត្រទាំង ៦ ព្យាករមន្តហើយ ។ ព្រាហ្មណ៍ទាំងនោះ បានជាអ្នកពិនិត្យមើលលក្ខណៈហើយ សូម្បីព្រះសុបិនក្នុងថ្ងៃដែលបដិសន្ធិ ព្រាហ្មណ៍ទាំងនេះឯងក៏បានពិនិត្យមើលហើយ ។ បណ្ដាព្រាហ្មណ៍ទាំង ៨ នោះ ៧ នាក់ លើកម្រាមដៃ ២ ព្យាករជា ២ ផ្លូវថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្រពត្តិ បើចេញបួស នឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ នាំគ្នាប្រាប់ដល់សម្បត្តិដ៏មានសិរីរបស់ស្ដេចចក្រពត្តិ តែមាណពឈ្មោះកោណ្ឌញ្ញៈ ដោយ

---

១- ក្នុងទី១ៈ ជាជោតិមន្តី ជាតិមន្តី ដូច្នេះក៏មាន ។

គោត្រ ក្មេងជាងព្រាហ្មណ៍ទាំងនោះ ពិចារណាមើលដោយការសម្បូរនៃលក្ខណៈរបស់ព្រះពោធិសត្វ លើកម្រាម ១ ប៉ុណ្ណោះ ដោយព្យាករតែម្យ៉ាងថា ព្រះពោធិសត្វនេះមិនមានហេតុនៅគ្រប់គ្រងផ្ទះ នឹងបានជាព្រះពុទ្ធ ទ្រង់ប្រាសចាកកិលេស ដូចដំបូលដែលបើកហើយដោយចំណែកមួយប៉ុណ្ណោះ ។ ពិតហើយ កោណ្ឌញ្ញព្រាហ្មណ៍នេះ សាងសេចក្តីល្អមកហើយ ជាសត្វដែលកើតក្នុងភពចុងក្រោយ មានបញ្ញាក្រៃលែងជាងជនទាំង ៧ បានឃើញគតិ ១ ប៉ុណ្ណោះថា សម្រាប់បុគ្គលដែលប្រកបដោយលក្ខណៈទាំងនេះ មិនមានឋានៈដែលតាំងនៅត្រង់កណ្តាលផ្ទះ នឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ ព្រោះហេតុនោះទើបលើកម្រាម ១ ឡើង ហើយព្យាករតែមួយផ្លូវ ។ បន្ទាប់មកពួកព្រាហ្មណ៍ទាំងនោះ ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន នាំគ្នាហៅកូនមកប្រាប់ថា នែបាទាំងឡាយ ឪពុកចាស់ហើយ នឹងបានឃើញព្រះរាជបុត្ររបស់ព្រះបាទសុទ្ធោទនមហារាជ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ឬមិនបានឃើញនោះទេពួកបា កាលព្រះរាជកុមារនេះសម្រេចសព្វញ្ញុតញ្ញាណហើយ គប្បីបួសក្នុងសាសនារបស់ទ្រង់ចុះ ជនទាំង ៧ នាក់នោះ តាំងនៅដរាបអស់អាយុក្ស័យក៏ស្លាប់ទៅតាមយថាកម្ម កោណ្ឌញ្ញមាណពប៉ុណ្ណោះ មិនមានជំងឺតម្កាត់ នៅមានជីវិត ។ កាលព្រះមហាសត្វធំចម្រើនវ័យឡើងហើយ ទ្រង់ចេញមហាភិនេស្រ្កមណ៍ យាងទៅកាន់ឧរុវេលាបទេសតាមលំដាប់ ទ្រង់ព្រះតម្រិះថា ទីកដីនេះ គួរជាទីត្រេកអរពិតហ្ន៎ ទីនេះសមគួរនឹងបំពេញព្យាយាម សម្រាប់កុលបុត្តដែលត្រូវការសេចក្តីព្យាយាម ដូច្នេះហើយ ចាំវស្សាក្នុងទីនោះ ។

កោណ្ឌញ្ញៈបានឮថា ព្រះមហាបុរសបួសហើយ ចូលទៅរកកូនព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះថា បានឮថា ព្រះសិទ្ធត្ថកុមារទ្រង់ព្រះផ្នួសហើយ ព្រះអង្គនឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ បើបិតារបស់ពួកអ្នកនៅមានជីវិត ពួកគាត់នឹងចេញបួសក្នុងថ្ងៃនេះពិត បើពួកអ្នកត្រូវការជូច្នោះដែរ មក ពួកយើងនឹងបួសតាមព្រះមហាបុរសនោះ កាលជនទាំងអស់មិនអាចមានការយើញជាឯកច្ឆន្ទ ៣ នាក់មិនបួស ជនក្រៅពីនេះ ៤ នាក់ ចេញបួស តាំងឲ្យកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន ជនទាំង ៥ នាក់នោះ បានឈ្មោះថា បញ្ចវគ្គិយត្ថេរ ។

ក្នុងកាលនោះ ព្រះរាជាត្រាស់សួរថា កូនរបស់យើងឃើញអ្វី ទើបចេញបួស ។ ពួកអមាត្យក្រាបទូលថា បុព្វនិមិត្ត ៤ ។ ព្រះរាជាសួរថា បុព្វនិមិត្ត ៤ គឺអ្វីខ្លះ ។ ពួកអមាត្យក៏ក្រាបទូលថា មនុស្សចាស់ព្រោះជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ បព្វជិត ១ ព្រះរាជាត្រាស់ថា ចាប់ពីថ្ងៃនេះទៅ ពួកអ្នកកុំឲ្យនិមិត្តបែបនេះ ចូលទៅកាន់សម្នាក់នៃបុត្តរបស់យើង យើងមិនត្រូវការឲ្យបុត្តរបស់យើងបានជាព្រះពុទ្ធ យើងចង់ឃើញបុត្តរបស់យើងគ្រប់គ្រងរាជសម្បត្តិជាធំ និងគ្រប់គ្រងទ្វីបធំទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារចោមរោមទៅដោយបរិស័ទ មានបរិមណ្ឌល ៣៦ យោជន៍ ត្រាច់ទៅក្នុងនភាកាស ។ កាលព្រះរាជាត្រាស់យ៉ាងនោះហើយ ទ្រង់ឲ្យរៀបចំការរក្សាក្នុងទីគ្រប់ៗ គាវុត ក្នុងទិសទាំង ៤ ដើម្បីឃាត់មិនឲ្យបរិស័ទ ៤ ប្រការនោះចូលមកកាន់គន្លងចក្ខុរបស់ព្រះរាជកុមារ ក្នុងថ្ងៃនោះ កាលត្រកូលញាតិ

៨០០០០ អង្គប្រជុំគ្នា ក្នុងទីមង្គលដ្ឋាន ព្រះញាតិទាំងអស់យល់ព្រមឲ្យកូនម្នាក់មួយៗ ថា ព្រះរាជកុមារសិទ្ធត្ថនេះ បានជាព្រះពុទ្ធក្តី ជាព្រះរាជាក្តី ពួកយើងនឹងឲ្យកូនម្នាក់មួយដល់ព្រះពុទ្ធ ក៏នឹងមានសមណក្សត្រឲ្យនូវកិត្តិយស និងចោមរោម ទោះជាព្រះរាជាក៏នឹងមានខត្តិយកុមារឲ្យនូវកិត្តិយស និងចោមរោមត្រាច់ទៅ ឯព្រះរាជា ទ្រង់តាំងស្រីស្នំមានរូបស្អាតកំពូលៗ ប្រាសចាកទោសសព្វយ៉ាងដល់ព្រះពោធិសត្វៗ ទ្រង់ចម្រើនវ័យដោយបរិវារជាអនេក ដោយចំណែកនៃលម្អដ៏ធំក្រៃលែង ។

សម័យមួយ ព្រះរាជា មានព្រះរាជពិធីវប្បមង្គល គឺច្រត់ព្រះនង្គ័ល ថ្ងៃនោះ ពួកអ្នកនគរ រៀបចំនគរគ្រប់ចំណែកដូចទេវវិមាន ពួកទាសៈ និងកម្មករទាំងអស់ស្លៀកសំពត់ថ្មី ប្រដាប់ដោយកម្រងផ្កា និងគ្រឿងក្រអូប ប្រជុំគ្នាក្នុងរាជត្រកូល ។ ក្នុងព្រះរាជពិធី មានការទឹមនង្គ័ល ១០០០ ក្នុងថ្ងៃនោះ នង្គ័ល ១០៨ ខ្វះ ១ ស្រោបដោយប្រាក់ មួយអន្ទើដោយគោ ខ្សែទាម និងខ្សែបរ ។ ត្រង់យាមនង្គ័លរបស់ព្រះរាជា ស្រោបដោយមាសទឹកដប់ ស្នែងរបស់គោ ខ្សែទាម ខ្សែបរ និងជន្ទញ ស្រោបដោយមាសទាំងអស់ ។ ព្រះរាជា មួយអន្ទើដោយបរិវារជាច្រើន យាងចេញអំពីព្រះនគរ ទ្រង់នាំព្រះរាជឱរសទៅផង ក្នុងទីប្រកបព្រះរាជពិធី មានដើមព្រីងមួយ មានស្លឹកក្រាស់ មានស្រមោលក្រាស់ ។ ខាងក្រោមដើមព្រីងនោះឯង ព្រះរាជាត្រាស់ឲ្យដាក់ទែនព្រះបន្ទំរបស់ព្រះរាជឱរស ខាងលើឲ្យចងពិតានដែលប៉ាក់ ដែលព្យួរដោយផ្កាយមាស ឲ្យព័ទ្ធដោយរាំងននធ្វើការរក្សាចំណែក ទ្រង់ប្រដាប់ដោយគ្រឿង

អលង្ការ មានពួកអមាត្យចោមរោម យាងទៅកាន់ទីប្រត់ព្រះនង្គ័ល ក្នុងទីនោះ ព្រះរាជាទ្រង់កាន់យកនង្គ័លមាស ពួកអមាត្យកាន់យកនង្គ័លប្រាក់ ១០៧ ពួកអ្នកស្រែកាន់យកនង្គ័លដ៏សេស ជនទាំងនោះ នាំគ្នាកាន់នង្គ័លភ្ជួរទៅខាងនោះខ្លះ ខាងនេះខ្លះ ។ តែព្រះរាជាទ្រង់ភ្ជួរទៅផ្នែកខាងក្រៅ ចេញអំពីផ្នែកខាងក្រៅ ចូលមកផ្នែកខាងក្នុង ។ ក្នុងទីនោះ មានមហាសម្បត្តិ ។ ស្រីស្នំដែលអង្គុយចោមរោមព្រះពោធិសត្វ នាំគ្នាចេញមកខាងក្រៅ គឺចេញអំពីខាងក្នុងរាំងនន ដោយគិតថា ពួកយើងនឹងមើលមហាសម្បត្តិរបស់ព្រះរាជា ។ ព្រះពោធិសត្វ ទតឆ្វេងស្តាំ មិនឃើញបុគ្គលណាមួយ ទើបក្រោកឡើងដោយរហ័ស ទ្រង់អង្គុយពត់ភ្នែន កំណត់ខ្យល់ដង្ហើមចេញ-ចូល ធ្វើបឋម-ជ្ឈានឲ្យកើតឡើងហើយ ពួកស្រីស្នំនាំគ្នាត្រាច់ទៅក្នុងរវាងកាលបរិភោគអាហារយឺតយូរបន្តិច ។ ស្រមោលដើមឈើដ៏សេសជ្រេទៅ ឯស្រមោលដើមឈើនោះ នៅជាបរិមណ្ឌល ។ ពួកស្រីស្នំគិតបានថា ព្រះអយ្យបុត្តប្រថាប់នៅមួយអង្គឯង ទើបប្រញាប់បើករាំងនន ចូលទៅខាងក្នុង ឃើញព្រះពោធិសត្វប្រថាប់គង់ពត់ភ្នែនលើទែនបន្ទំ និងបាដិហារ្យនោះ ទើបទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារប្រថាប់គង់យ៉ាងនេះ ស្រមោលដើមឈើដទៃជ្រេទៅ ស្រមោលនៃដើមព្រីងតាំងជាបរិមណ្ឌលយ៉ាងនេះ ព្រះរាជាប្រញាប់យាងមក ទតឃើញបាដិហារ្យ ទើបត្រាស់ថា នែបា នេះជាការថ្វាយបង្គំលើកទី ២ ហើយ ក៏ទ្រង់ថ្វាយបង្គំ ។

ក្នុងកាលតមក ព្រះពោធិសត្វមានព្រះជន្មបាន ១៦ វស្សាដោយលំដាប់

ព្រះរាជាទ្រង់បញ្ជាឲ្យសាង ៣ ប្រាសាទ សមគួរដល់រដូវទាំង ៣ គឺប្រាសាទទី ១ មាន ៩ ជាន់ ប្រាសាទទី ២ មាន ៧ ជាន់ ប្រាសាទទី ៣ មាន ៥ ជាន់ សម្រាប់ព្រះពោធិសត្វ និងរៀបចំបាំស្រី ៤០០០០ នាក់ ព្រះពោធិសត្វមានស្រីបាំតែងខ្លួនស្រស់ស្អាតចោមរោម ដូចទេវបុត្តដែលចោមរោមដោយពួកទេពអប្សរ ដូច្នោះ ត្រូវបម្រើដោយតន្ត្រី មិនមានបុរសឡើយ ទ្រង់សោយសម្បត្តិធំ ប្រថាប់នៅក្នុងប្រាសាទទាំងនោះ តាមរដូវកាល ។ ឯរាហុលមាតាបានជាអគ្គមហេសីរបស់ព្រះអង្គ កាលទ្រង់សោយមហាសម្បត្តិ ថ្ងៃមួយមានពាក្យកើតឡើងក្នុងវង់ពួកញាតិយ៉ាងនេះថា ព្រះសិទ្ធត្ថខ្វល់ខ្វាយតែក្នុងការលេងប៉ុណ្ណោះ មិនបានសិក្សាសិប្បៈណាមួយឡើយ បើសង្គ្រាមកើតឡើងនឹងធ្វើដូចម្ដេច ។ ព្រះរាជាទ្រង់ត្រាស់ឲ្យហៅព្រះពោធិសត្វមក ហើយត្រាស់ថា នែបា ពួកញាតិរបស់បានិយាយគ្នាថា ព្រះសិទ្ធត្ថមិនបានសិក្សាសិប្បៈណាមួយឡើយ ខ្វល់ខ្វាយតែក្នុងការលេង ដូច្នេះ កូនឃើញថា ដល់កាលដែលគួរឬនៅ ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមានកិច្ចដែលត្រូវសិក្សាសិប្បៈ សូមទ្រង់ត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរដើម្បីឲ្យមកមើលការសម្តែងសិប្បៈរបស់ទូលបង្គំ បន្ទាប់អំពីនេះ ៧ ថ្ងៃទៀតទូលបង្គំនឹងសម្តែងសិប្បៈដល់ព្រះញាតិទាំងឡាយ ។ ព្រះរាជាបានធ្វើតាមនោះ ។ ព្រះពោធិសត្វត្រាស់ឲ្យប្រជុំនាយខ្មាន់ធ្នូ ដែលអាចបាញ់បានដូចផ្លេកបន្ទោរ បាញ់កន្ទុយរោមសត្វបាន បាញ់បំបាក់ព្រួញដែលគេបាញ់មកបាន បាញ់តាមសំឡេងបាន និងបាញ់តាមពីក្រោយព្រួញបាន ហើយទ្រង់សម្តែងសិប្បៈ

១២ យ៉ាង ដែលពួកខ្មាន់ផ្ទួដទៃមិនមាន ដល់ញាតិទាំងឡាយ ក្នុងកណ្ដាលមហាជន សេចក្ដីនោះ គប្បីជ្រាបតាមន័យដែលមកក្នុងសរភង្គជាតកនោះចុះ ។ គ្រានោះ ពួកព្រះញាតិរបស់ព្រះអង្គ បានអស់ព្រះហឫទ័យសង្ស័យហើយ ។

សម័យមួយ ព្រះពោធិសត្វ មានបំណងនឹងយាងទៅកាន់ភូមិភាគ ក្នុងព្រះឧទ្យាន ទើបហៅសារថីមក ត្រាស់ថា ចូរទឹមរថ សារថីពោលថា សាធុ ទើបតាក់តែងរថដែលល្អបំផុត មានតម្លៃច្រើន ដោយគ្រឿងអលង្ការគ្រប់ប្រភេទ ទឹមដោយសេះសិន្ធពដែលជាមង្គល ៤ ដែលមានពណ៌ដូចផ្កាឈូកសស្រេចហើយ ទូលដល់ព្រះពោធិសត្វៗ ឡើងរថដូចទេវវិមាន បែរមុខទៅកាន់ព្រះឧទ្យាន ទេវតាទាំងឡាយគិតថា កាលដែលនឹងត្រាស់ដឹងរបស់ព្រះសិទ្ធត្ថរាជកុមារជិតចូលមកហើយ ពួកយើងនឹងសម្ដែងបុព្វនិមិត្ត ហើយប្រាប់ទេវបុត្តមួយរូប ឲ្យធ្វើជាមនុស្សចាស់ជរា មានធ្មេញបាក់ មានសក់ស្កូវ មានខ្នងកោងដូចបង្កង់ផ្ទះ មានខ្លួនឱនចុះ មានដៃកាន់ឈើច្រត់ ដើរផ្ងក់ៗ ព្រះពោធិ-សត្វ និងសារថី ក៏បានទតឃើញរូបកាពនោះឯង ។ ពេលនោះ ព្រះពោធិសត្វត្រាស់សួរតាមន័យដែលមានមកក្នុងអបទាននោះឯងថា នែសម្លាញ់ បុរសនេះឈ្មោះអ្វី សក់របស់បុរសនេះ មិនដូចរបស់ជនដទៃ ដូច្នេះ ទ្រង់ស្ដាប់ពាក្យរបស់សារថីហើយ ទ្រង់មានព្រះហឫទ័យសង្វេគថា នែអ្នកដ៏ចម្រើន គួរតិះដៀលពិតហ្ន៎ ការកើត ការចាស់នេះ នឹងត្រូវប្រាកដដល់សត្វដែលកើតហើយយ៉ាងពិតប្រាកដ ដូច្នេះហើយ ទ្រង់ត្រឡប់អំពីព្រះរាជឧទ្យាន ឡើងកាន់

ប្រាសាទនោះឯង ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបបុត្តរបស់យើង ត្រឡប់លឿនម៉្លេះ ។ ពួកអមាត្យទូលថា ព្រោះទ្រង់ទតឃើញមនុស្សចាស់ ព្រះរាជាត្រាស់ថា ពួកអ្នកពោលថា កូនរបស់យើង ឃើញមនុស្សចាស់ ហើយនឹងបួស ព្រោះហេតុអ្វី ទើបបំផ្លាញយើង ចូរប្រញាប់រកល្ខោនមក សម្តែងដល់បុត្តរបស់យើង បុត្តរបស់យើងសោយសម្បត្តិហើយ នឹងមិននឹកនាដល់បព្វជ្ជា ហើយឲ្យបន្ថែមការរក្សាច្រើនឡើង រាយមនុស្សគ្រប់ៗ កន្លះយោជន៍ ក្នុងទីគ្រប់ទិស ។ ក្នុងថ្ងៃស្អែកឡើង ព្រះពោធិសត្វយាងទៅកាន់ឧទ្យានដូចមុន ទតឃើញមនុស្សឈឺ ដែលទេវតានិម្មិតឡើង ទើបត្រាស់សួរដោយន័យមុននោះឯង ទ្រង់មានព្រះហឫទ័យសង្វេគ ហើយត្រឡប់ឡើងកាន់ប្រាសាទ ។ ឯព្រះរាជាទ្រង់ត្រាស់សួរហើយ ទ្រង់ចាត់ចែងតាមន័យដែលពោលហើយនោះឯង ទ្រង់ធ្វើការរក្សាបន្ថែមឡើងទៀត ក្នុងទីមានប្រមាណ ៣ គាវុតដោយជុំវិញ ។ មួយថ្ងៃមកទៀត ព្រះពោធិសត្វយាងទៅកាន់ឧទ្យានដូចមុន ឃើញមនុស្សស្លាប់ ដែលទេវតានិម្មិត ត្រាស់សួរដោយន័យមុននោះឯង មានព្រះហឫទ័យសង្វេគ ហើយទ្រង់ឡើងទៅកាន់ប្រាសាទ ។ ឯព្រះរាជាក៏ត្រាស់សួរហើយ ទ្រង់ចាត់ចែងតាមន័យដែលពោលហើយខាងដើមនោះឯង ទ្រង់ដាក់ការរក្សាបន្ថែមឡើងទៀត ក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ ។ ក្នុងថ្ងៃបន្ទមកទៀត ព្រះពោធិសត្វយាងទៅកាន់ព្រះរាជឧទ្យាន ទតឃើញបព្វជិតស្លៀកដណ្តប់រៀបរយ ដែលទេវតានិម្មិតឡើងដូចមុននោះឯង ទើបត្រាស់សួរសារថីថា នែសម្លាញ់ បុគ្គលនោះឈ្មោះអ្វី សារថីមិន

ជ្រាបដល់បព្វជិត ឬគុណដែលធ្វើឲ្យជាបព្វជិតឡើយ ព្រោះមិនមានការកើតឡើងនៃព្រះពុទ្ធក៏ពិត តែដោយអានុភាពនៃទេវតា ទើបក្រាបទូលថា បុគ្គលនោះ គេហៅថា បព្វជិត ហើយពណ៌នាគុណនៃការបួស ព្រះពោធិសត្វឲ្យរឭក កើតការពេញព្រះហឫទ័យក្នុងបព្វជ្ជា បានយាងទៅកាន់ព្រះឧទ្យានក្នុងថ្ងៃនោះ ។ តែទីឃនិកាយាចារ្យពោលថា ព្រះពោធិសត្វបានទតឃើញនិមិត្តទាំង ៤ ក្នុងថ្ងៃមួយប៉ុណ្ណោះ ព្រះពោធិសត្វប្រពាតឧទ្យានអស់មួយថ្ងៃ ទ្រង់ស្រពស្រង់ក្នុងស្រះបោក្ខរណីដែលជាមង្គល កាលព្រះអាទិត្យលិចហើយប្រថាប់ គង់លើផ្ទាំងថ្មដែលជាមង្គល មានបំណងនឹងតាក់តែងព្រះកាយ ពេលនោះ ពួកបរិចារិការបស់ព្រះអង្គ នាំគ្នាកាន់យកសំពត់មានពណ៌ផ្សេងៗ គ្រឿងអាភរណៈច្រើនប្រភេទ ផ្កា គ្រឿងក្រអូប និងគ្រឿងលាប មកឈរដោយជុំវិញ ។ ខណៈនោះ អាសនៈដែលប្រថាប់គង់របស់សក្កទេវរាជក្តៅ ហើយទ្រង់ពិចារណាថា នរណាហ្ន៎មានបំណងឲ្យអាត្មាអញ ឃ្លាតចាកទីនេះ ទតឃើញកាលដែលត្រូវប្រដាប់តាក់តែងរបស់ព្រះពោធិសត្វ ទើបហៅវិស្សុ-កម្មទេវបុត្តមកត្រាស់ថា វិស្សុកម្មសម្លាញ់ ថ្ងៃនេះ សិទ្ធត្ថរាជកុមារនឹងយាងចេញមហាភិនេស្រ្កមណ៍ ក្នុងកណ្តាលរាត្រី នេះជាគ្រឿងតាក់តែងចុងក្រោយរបស់ទ្រង់ ចូរអ្នកទៅកាន់ព្រះរាជឧទ្យាន ជួបព្រះមហាបុរសហើយ ចូរប្រដាប់ដោយគ្រឿងប្រដាប់គ្រប់ប្រភេទ វិស្សុកម្មទេវបុត្តទទួលព្រះតម្រាស់ថា សាធុ ហើយចូលទៅរកក្នុងខណៈនោះឯងដោយទេវានុភាព កាឡាខនជាងទាន់ព្រះកេសរបស់ទ្រង់នោះឯង រូបទទួលយកសំពត់ជូតក្បាលអំពីដៃរបស់ខ្មាន់ព្រះកេស

មករុំសីសៈរបស់ព្រះពោធិសត្វ ។ ព្រះមហាសត្វជ្រាបដោយសម្ផស្សនៃដៃប៉ុណ្ណោះ ដឹងថា បុគ្គលនេះ មិនមែនមនុស្ស ជាទេវបុត្ត លុះរុំសំពត់ជួតក្បាលហើយ សំពត់ ១០០០ ក៏ផុសឡើងដោយអាការដូចកែវមណី ត្រង់ព្រះមោលីលើព្រះសីសៈ លុះរុំទៀត ក៏ជាសំពត់ ១០០០ ព្រោះដូច្នោះ កាលរុំ ១០ ជង សំពត់មួយម៉ឺនផ្ទាំងក៏កំពុងឡើង ។ បុគ្គលណាម្នាក់មិនគួរគិតថា ព្រះសីសៈតូច មានសំពត់ច្រើនផុសឡើងបានដូចម្ដេច បណ្ដាសំពត់ទាំងនោះ សំពត់ដែលធំបំផុត មានប្រមាណប៉ុនផ្កាអាមលតា សំពត់ដ៏សេសក្រៅអំពីនេះ មានប្រមាណប៉ុនផ្កាកុសុម្ភកៈ ព្រះសីសៈរបស់ព្រះពោធិសត្វ ក្រាស់ទៅដោយសក់ ដូចផ្កាសារកីដែលក្រាស់ដោយកេសរ ។

បន្ទាប់មក កាលពួកអ្នកតន្ត្រីសម្ដែងបដិភាណរបស់ខ្លួន កាលពួកព្រាហ្មណ៍លើកតម្កើង ដោយពាក្យជាដើមថា បពិត្រព្រះចមនរិន្ទ សូមទ្រង់មានជ័យជម្នះចុះ កាលពួកសារថី និងអ្នកពួកអ្នកពោលមង្គលជាដើមពោលសរសើរ ដោយពាក្យដែលជាមង្គល ពាក្យសរសើរ និងពាក្យប្រកាសច្រើនប្រការដល់ព្រះពោធិសត្វ ដែលប្រដាប់ហើយដោយគ្រឿងអលង្ការសព្វយ៉ាងទ្រង់ក៏បានឡើងកាន់រាជរថដ៏ប្រសើរ ដែលលម្អដោយគ្រឿងអលង្ការគ្រប់យ៉ាង ។

ក្នុងសម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានដំណឹងថា ព្រះរាជមាតារបស់ព្រះរាហុលប្រសូតព្រះរាជឱរសហើយ ទើបទ្រង់បញ្ជូនដំណឹងទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកប្រាប់សេចក្ដីត្រេកអររបស់ខ្ញុំដល់បុត្រ

ផង ។ ព្រះពោធិសត្វទ្រង់ស្តាប់ដំណឹងនោះហើយ ត្រាស់ថា រាហុលកើតហើយ ចំណងកើតហើយ ។ ព្រះរាជាត្រាស់សួរអមាត្យដែលនាំដំណឹងទៅថា បុត្តរបស់យើងពោលពាក្យអ្វីខ្លះ ទ្រង់ស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា តាំងអំពីនេះទៅ ចៅរបស់យើងមានឈ្មោះថា រាហុលកុមារចុះ ។ ឯព្រះពោធិសត្វ ឡើងកាន់រាជរថដ៏ប្រសើរចូលព្រះនគរ ដោយព្រះយសធំក្រៃលែង ដោយព្រះសិរីដែលគួរជាទីត្រេកអរនៃចិត្តក្រៃលែង ក្នុងសម័យនោះ ព្រះនាងកិសាគោតមីខត្តិយកញ្ញា ឈរត្រង់ផ្ទៃប្រាសាទខាងលើ ទតព្រះរូបសិរីរបស់ព្រះពោធិសត្វ ដែលទ្រង់ធ្វើប្រទក្សិណនគរ ព្រះនាងកើតបីតិ និងសោមនស្ស ទើបបន្លឺឧទាននេះថា

ស្រីណា ជាមាតារបស់ព្រះកុមារនេះ ស្រីនោះ រម្ងត់ទុក្ខបាន បុរសណា ជាបិតារបស់ព្រះរាជកុមារនេះ បុរសនោះ រម្ងត់ទុក្ខបាន ព្រះរាជកុមារនេះ ជាប្តីនៃស្រីណា ស្រីនោះ រម្ងត់ទុក្ខបាន ដូច្នេះ ។

ព្រះពោធិសត្វស្តាប់គាថានោះហើយ ទ្រង់ព្រះតម្រិះថា ព្រះនាងកិសាគោតមីនេះ មានសវនីយ៍យ៉ាងនេះថា ហទយៈរបស់មាតា ហទយៈរបស់បិតា ហទយៈរបស់កិរិយាដែលឃើញអត្តភាពបែបនេះ រមែងរម្ងត់ទុក្ខបាន កាលណារលត់ហ្ន៎ កាលណា ទើបហទយៈរម្ងត់ទុក្ខបាន ។ ពេលនោះ ព្រះពោធិសត្វមានទឹកព្រះហឫទ័យប្រាសចាកតម្រេកហើយ ក្នុងកិលេសទាំងឡាយ ទ្រង់ព្រះតម្រិះថា កាលភ្លើង គឺរាគៈរលត់ ឈ្មោះថា ការរលត់ទុក្ខក៏មាន កាលភ្លើង គឺទោសៈរលត់ ឈ្មោះថា ការរលត់ទុក្ខក៏មាន កាលភ្លើង

គឺមោហៈរលត់ ឈ្មោះថា ការរលត់ទុក្ខក៏មាន កាលកម្តៅទាំងឡាយ ក្នុងកិលេសទាំងពួង មានមានះ និងទិដ្ឋិជាដើមរលត់ហើយ ឈ្មោះថា ការរលត់ទុក្ខក៏មាន ព្រះនាងឲ្យអញបានស្តាប់ពាក្យល្អ សេចក្តីពិត អញកំពុងស្វែងរកព្រះនិព្វាន អញគួរលះយកវាសចេញទៅបួស និងស្វែងរកព្រះនិព្វានក្នុងថ្ងៃនេះឯង ហើយទ្រង់ដោះកម្រងគជ់ ដែលមានតម្លៃ ១០០០ អំពីព្រះសូរងប្រគល់ឲ្យដល់ព្រះនាង កិសាគោតមី ដោយទ្រង់ព្រះតម្រិះថា របស់នេះ ចូរជាអាចរិយភាគ គឺរបស់ដែលកូនសិស្សបូជាគ្រូសម្រាប់ព្រះនាងចុះ ។ ព្រះនាងកើតបីតិសោមនស្សថា សិទ្ធត្ថព្រះរាជកុមារចូលចិត្តអាត្មាអញ ទើបបញ្ជូនបណ្ណាការមកឲ្យ ។

ចំណែកព្រះពោធិសត្វ ឡើងកាន់ប្រាសាទរបស់ទ្រង់ ដោយព្រះសិរីដ៏ធំ ទ្រង់ផ្ទំលើព្រះសិរីសេយ្យាសនៈ ក្នុងវេលានោះឯង ពួកស្ត្រីដែលប្រដាប់ដោយគ្រឿងប្រដាប់គ្រប់យ៉ាង បានសិក្សាមកល្អហើយ ក្នុងការរាំ និងការប្រគំជាដើមផង មានរូបឆោមដ៏ស្រស់ត្រកាលផង ដូចគ្នានឹងទេវកញ្ញា កាន់យកតន្ត្រីច្រើនប្រភេទ មកចោមរោម ហើយបម្រើព្រះពោធិសត្វឲ្យត្រេកអរ នាំគ្នាសម្តែងអាការរាំច្រៀង និងប្រគំ ។ ព្រះពោធិសត្វ ព្រោះទ្រង់មានព្រះហឫទ័យប្រាសចាកតម្រេកហើយ ក្នុងកិលេសទាំងឡាយ ទើបទ្រង់មិនត្រេកអរក្នុងការរាំជាដើម មួយស្របក់ប៉ុណ្ណោះ ក៏ទ្រង់ចូលកាន់និទ្រា ។ ពួកស្ត្រីទាំងនោះគិតថា ពួកយើងសម្តែងការរាំជាដើម ដើម្បីជាប្រយោជន៍ដល់ព្រះរាជកុមារណា ព្រះរាជកុមារនោះ ទ្រង់ចូលកាន់និទ្រាហើយ ឥឡូវនេះ នឹង

លំបាកធ្វើអ្វី ដូច្នេះ នាំគ្នាដាក់ឧបករណ៍តន្ត្រីចុះ ហើយដេកលក់ទៅ ។ ប្រទីបប្រេងនៅឆេះនៅឡើយ ព្រះពោធិសត្វទ្រង់ភ្ញាក់ពីបន្ទំ គង់ប្រថាប់ពត់ភ្នែនលើព្រះទែនបន្ទំ បានទតឃើញស្ត្រីទាំងនោះដេកលក់ សង្កត់លើគ្រឿងតន្ត្រី ពួកខ្លះមានទឹកមាត់ហូរ មានខ្លួនប្រឡាក់ដោយទឹកមាត់ ពួកខ្លះសង្កៀតធ្មេញ ពួកខ្លះស្រមុក ពួកខ្លះមមើ ពួកខ្លះហាមាត់ ពួកខ្លះរបូតសំពត់ ប្រាកដឲ្យឃើញអវយវៈស្ត្រីដែលគួរខ្ពើម ព្រះពោធិសត្វទតឃើញអាការខុសប្រក្រតីរបស់ស្រីទាំងនោះ ទ្រង់មានព្រះហឫទ័យប្រាសចាកតម្រេកក្នុងកាមទាំងឡាយយ៉ាងខ្លាំង ។ ផ្ទៃមហាប្រាសាទ ដែលប្រដាប់តាក់តែងហើយ ដូចគ្នានឹងភពរបស់សក្កទេវរាជ បានប្រាកដដល់ព្រះពោធិសត្វ ដូចព្រៃខ្មោច ពេញដោយសាកសពផ្សេងៗ ដែលគេចោល ភព ៣ ប្រាកដដូចផ្ទះដែលត្រូវភ្លើងឆេះ ទើបទ្រង់ឧទានឡើងថា វិកវហ្ន៎ ស្ទុគស្មាញហ្ន៎ ព្រះហឫទ័យបង្អោនទៅក្នុងបព្វជ្ជាពន់ពេក ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អាត្មាអញ គួរចេញមហាភិនេស្រ្កមណ៍ក្នុងថ្ងៃនេះឯង ដូច្នេះហើយ ទើបក្រោកឡើងចាកទីបន្ទំ ទៅកាន់ទីជិតទ្វារ ត្រាស់ថា អ្នកណានៅក្នុងទីនេះ ឆន្នអមាត្យដេកយកក្បាលកើយធរណីទ្វារ ទូលតបថា បពិត្រអយ្យបុត្រ ទូលបង្គំឆន្ន ព្រះពោធិសត្វត្រាស់ថា ថ្ងៃនេះ ខ្ញុំមានបំណងចេញមហាភិនេស្រ្កមណ៍ ចូររៀបចំសេះមួយ ឆន្នទូលថា សាធុ ហើយយកគ្រឿងតាក់តែងសេះមក ទៅកាន់រោងសេះដែលប្រទីបប្រេងកំពង់ឆេះនៅឡើយ ឃើញស្តេចសេះកណ្ឋកៈឈរលើភូមិភាគដែលគួរត្រេកអរ ខាង

ក្រោមពិតាន ដែលសន្ទឹងដោយជុំវិញ គិតថា ថ្ងៃនេះ អញគួរតែរៀបចំសេះកណ្ឋកៈនេះថ្វាយ ដូច្នេះហើយ ទើបរៀបចំសេះកណ្ឋកៈថ្វាយ ។ សេះកណ្ឋកៈកាលគេរៀបចំ បានដឹងថា ការរៀបចំលើកនេះ ខ្ជាប់ខ្ជួនមែនពិត មិនដូចការរៀបចំក្នុងកាលទៅលេងក្នុងព្រះរាជឧទ្យាន ក្នុងថ្ងៃដទៃឡើយ ថ្ងៃនេះ ព្រះអយ្យបុត្តរបស់អញ ប្រហែលជាទ្រង់មានបំណងចេញមហាភិនេស្រ្កមណ៍ ក៏មានចិត្តត្រេកអរ ស្រែក ដោយសំឡេងខ្លាំង ។ សំឡេងនោះលាន់ឮពេញព្រះនគរទាំងមូល តែទេវតាពាំងមិនឲ្យបុគ្គលណាមួយឮឡើយ ។ ចំណែកព្រះពោធិសត្វ ទ្រង់ប្រើឆន្នអាមាត្យទៅហើយ ទ្រង់ព្រះតម្រិះថា អញនឹងមើលកូនជាមុនសិន ដូច្នេះហើយ ទើបទ្រង់ក្រោកចាកអំពីទីប្រថាប់ ទៅកាន់ទីបន្ទំរបស់រាហុលមាតា បើកទ្វារបន្ទប់ហើយ ខណៈនោះ ប្រទីបប្រេងកំពុងឆេះនៅឡើយ សូម្បីរាហុលមាតា ក៏ផ្ទំដាក់ព្រះហស្តអំពីខាងលើព្រះសិរសារបស់ព្រះរាជឱរស លើទីបន្ទំដែលដេរដាសដោយផ្កាម្លិះរួត និងផ្កាម្លិះលាជាដើមប្រមាណមួយអម្ពណៈ គឺប្រមាណ ១១ ទោណ ។ ព្រះពោធិសត្វ ប្រថាប់ឈរដាក់ព្រះបាទលើធរណីទ្វារនោះឯង ទតមើលហើយ ទ្រង់ព្រះតម្រិះថា បើអញលើកដៃព្រះទេវីចេញ ហើយស្ទាបអង្អែលកូនរបស់អញ ព្រះទេវីនឹងភ្ញាក់ អន្តរាយនៃការទៅនឹងមានដល់អញ បើអញបានជាព្រះពុទ្ធហើយ ក៏នឹងត្រឡប់មកមើលកូនបាន ដូច្នេះហើយ ទើបចុះអំពីប្រាសាទទៅ ។ ពាក្យដែលពោលក្នុងអដ្ឋកថាជាតកថា ពេលនោះ រាហុលកុមារប្រសូតបាន ៧ ថ្ងៃ មិនមានក្នុងអដ្ឋកថាដ៏សេស ព្រោះហេតុនោះ គប្បីកាន់យកពាក្យក្នុងទី

នេះឯង ។

ព្រះពោធិសត្វ ចុះអំពីផ្ទៃប្រាសាទដោយប្រការនេះហើយ ទៅជិតសេះ ហើយត្រាស់ថា បាកណ្ឋកៈ ថ្ងៃនេះ ចូរអ្នកឲ្យយើងឆ្លងត្រើយត្រឹមមួយយប់ចុះ យើងអាស្រ័យអ្នកបានជាព្រះពុទ្ធហើយ នឹងឲ្យសត្វលោក ព្រមទាំងទេវលោកឆ្លងដែរ គ្រានោះ ព្រះពោធិសត្វ ក៏ផែលលើខ្នងសេះកណ្ឋកៈដែលមានបណ្តោយ ១៨ ហត្ថ រាប់អំពីក កម្ពស់ក៏មានប្រមាណប៉ុណ្ណោះ សម្បូរដោយកម្លាំង និងសម្ទុះ ជាសេះសសុទ្ធ ដូចស័ង្ខដែលគេខាត់ល្អហើយ ។ បើកណ្ឋកៈនោះគប្បីស្រែក ឬទន្ទ្រាំជើង សំឡេងក៏លាន់ខ្ទាំងពេញព្រះនគរ ព្រោះហេតុនោះ ទើបទេវតានាំគ្នាពាំងសំឡេងស្រែករបស់សេះនោះ ដោយអាការកុំឲ្យអ្នកដទៃបានឮដោយអានុភាពរបស់ខ្លួន ហើយទើបយកបាតដៃដាក់ក្រោមជើងសេះ ក្នុងខណៈដែលសេះឈានជើង ។ ព្រះពោធិសត្វឡើងកាន់ខ្នងសេះដ៏ប្រសើរ ទ្រង់ឲ្យឆន្នអមាត្យចាប់កន្ទុយសេះ ស្តេចដល់ជិតខ្លោងទ្វារធំទាំងកណ្តាលរាត្រី ក្នុងថ្ងៃនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះពោធិសត្វមិនអាចបើកទ្វារព្រះនគរចេញទៅបាន ទោះក្នុងពេលណាក៏ដោយ ដូច្នេះហើយ ទើបត្រាស់ឲ្យធ្វើសន្ទះទ្វារទាំង ២ មួយបន្ទះបុរស ១០០០ ទើបបើកបានដោយប្រការដូច្នេះ ។ ព្រះពោធិសត្វទ្រង់សម្បូរដោយព្រះកម្លាំងដ៏ក្រៃលែង ស្មើនឹងដំរីធម្មតាមួយពាន់កោដិ បើប្រៀបធៀបនឹងកម្លាំងបុរស ទ្រង់មានកម្លាំងស្មើនឹងបុរសមួយម៉ឺនកោដិ ។ ព្រោះដូច្នោះ ទើបទ្រង់ព្រះតម្រិះថា បើទ្វារមិនបើក ថ្ងៃនេះ អញនឹងអង្គុយលើខ្នងសេះនេះឯង នឹងយកភ្លៅកៀបសេះ

កណ្ឋកៈ ហើយលោតឆ្លងកំពែងកម្ពស់ ១៨ ហត្ថចេញទៅ ឆន្នអមាត្យគិតថា បើទ្វារមិនបើក អញនឹងឲ្យព្រះអយ្យបុត្តប្រថាប់គង់ត្រង់កអញ ហើយយកដៃស្តាំឱបសេះកណ្ឋកៈត្រង់ពោះ ធ្វើសេះឲ្យនៅក្រោមក្លៀកហើយលោតឆ្លងកំពែងទៅ សេះកណ្ឋកៈក៏គិតថា បើទ្វារមិនបើកអញនឹងលើកម្ចាស់របស់អញទាំងដែលកំពុងអង្គុយលើខ្នងនេះឯង មួយអន្លើដោយឆន្នដែលកំពុងចាប់កន្ទុយលោតឆ្លងកំពែងទៅ ។ បើទ្វារមិនមានអ្នកបើកឲ្យ បណ្តាជនទាំង ៣ ជនណាមួយគង់ធ្វើដូចការគិតពិត តែទេវតាដែលអាស្រ័យនៅត្រង់ទ្វារបើកឲ្យ ។

ក្នុងខណៈនោះឯង មារមានចិត្តបាបមកដោយគិតថា អញនឹងឲ្យព្រះពោធិសត្វត្រឡប់ ហើយឈរក្នុងអាកាសពោលថា បពិត្រអ្នកនិទ្ទុក្ខ អ្នកកុំចេញទៅឡើយ ៧ ថ្ងៃទៀត រាប់អំពីថ្ងៃនេះទៅ ចក្ករ័តន៍នឹងប្រាកដដល់អ្នក អ្នកនឹងគ្រប់គ្រងរាជសម្បត្តិនៃទ្វីបធំទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ បពិត្រអ្នកនិទ្ទុក្ខ ចូរអ្នកត្រឡប់ក្រោយចុះ ។ ព្រះពោធិសត្វសួរថា អ្នកជានរណា មារឆ្លើយថា ខ្ញុំជាវសវត្តីមារ ។ ព្រះពោធិសត្វត្រាស់ថា នៃមារ ខ្ញុំដឹងថា ចក្ករ័តន៍ប្រាកដដល់ខ្ញុំ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះឡើយ ខ្ញុំនឹងឲ្យលោកធាតុមួយម៉ឺនញាប់ញ័រ ហើយត្រាស់ជាព្រះពុទ្ធ ។ មារពោលថា ចាប់ពីឥឡូវនេះទៅ ក្នុងកាលដែលអ្នកគិតដល់កាមវិតក្កៈ ព្យាបាទវិតក្កៈ វិហិង្សាវិតក្កៈ ខ្ញុំនឹងដឹងកម្មដែលគួរធ្វើ ហើយស្វែងរកឱកាស ជាប់តាមព្រះអង្គទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

ឯព្រះពោធិសត្វ មិនមានសេចក្តីអាឡោះអាល័យ លះបង់ចក្រពត្តិរាជ-

សម្បត្តិដែលនៅក្នុងកណ្តាប់ដៃ ដូចខ្ទាក់ចោលនូវដុំទឹកមាត់ ចេញអំពីព្រះនគរ ដោយសក្ការៈធំ ។ ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ កាលទក្ខត្តឫក្សក្នុងខែឧត្តរាសាឡ្ហ គឺខែទុតិយាសាឍកំពុងប្រព្រឹត្តទៅ កាលស្តេចចេញអំពីព្រះនគរហើយ មានបំណងនឹងបែរមើលព្រះនគរ កាលព្រះពោធិសត្វមានការគិតកើតឡើងប៉ុណ្ណោះ ប្រឹថពីហាក់នឹងទូលថា បពិត្រមហាបុរស ទ្រង់មិនចាំបាច់បែរក្រោយ ទតព្រះនគរទេ ទើបវិលដូចចក្ររបស់ស្មូនឆ្នាំង ព្រះពោធិសត្វឈរប្រថាប់ បែរព្រះភក្ត្រទៅកាន់ព្រះនគរ ទតព្រះនគរហើយ ទ្រង់ប្រតិស្ឋានចេតិយ ជាទីត្រឡប់របស់សេះកណ្ឋកៈក្នុងទីនោះ ទ្រង់ធ្វើសេះកណ្ឋកៈឲ្យបែរមុខទៅកាន់ផ្លូវដែលទ្រង់យាង ទ្រង់ទៅហើយដោយសក្ការៈធំ ដោយការរុងរឿងដ៏ឧឡារ ។ បានឮថា ក្នុងកាលនោះ ទេវតាទាំងឡាយ ធូលគប់ភ្លើង ៦ ម៉ឺនដើមអំពីខាងមុខព្រះពោធិសត្វ ខាងក្រោយ ៦ ម៉ឺនដើម ខាងស្តាំ ៦ ម៉ឺនដើម ខាងឆ្វេង ៦ ម៉ឺនដើម ។ ទេវតាមួយពួកទៀត កាន់គប់ភ្លើងប្រមាណមិនបានត្រង់ក្នុំកណ្តាប់ចក្រវាល ។ ទេវតា នាគ គ្រុឌជាដើម មួយពួកទៀតដើរបូជាដោយគ្រឿងក្រអូប ផ្កា លម្អិត និងធូមគន្ធៈដែលជាទិព្វ ផ្ទៃដី និងផ្ទៃមេឃជាប់តគ្នាទៅ មិនមានចន្លោះ លម្អដោយផ្កាបារិច្ឆត្តកៈ និងផ្កាមណ្ឌារវៈដូចភ្លៀងផ្កាធ្លាក់ចុះមក ដូច្នោះ ទិព្វតន្ត្រីទាំងឡាយបានប្រព្រឹត្តទៅហើយ ។ តន្ត្រី ៦ ម៉ឺន ៨ ពាន់ប្រភេទ បន្លឺទូទៅឡើងហើយ ។ កាលរមែងប្រព្រឹត្តទៅ ដូចកាលដែលមេឃគំរាមផ្ទៃមហាសមុទ្រ និងដូចកាលដែលសាគរមានសំឡេងកងរំពង ត្រង់ចន្លោះភ្នំយុគន្ធរ ដូច្នោះ ។

ព្រះពោធិសត្វ កាលយានទៅដោយសិរីដ៏ប្រសើរនេះ រំលងរាជ-អាណាចក្រទាំង ៣ ដោយមួយរាត្រីប៉ុណ្ណោះ ទ្រង់យានដល់ស្ទឹងអនោមាក្នុងទីបំផុតផ្លូវ ៣០ យោជន៍ ។ សួរថា សេះអាចទៅឆ្ងាយជាងនោះបានឬទេ ។ ឆ្លើយថា អាចទៅបាន ព្រោះសេះនោះអាចទៅដល់កណ្តាប់ចក្រវាលដោយមិនមានដែនកំណត់យ៉ាងនេះ ដូចជាន់កង់រទេះត្រង់ជុំ ហើយត្រឡប់មកបរិភោគអាហារព្រឹកត្រង់ទីដែលគេរៀបចំសម្រាប់ខ្លួន ។ ក្នុងកាលនោះ សេះទាញនូវរាងកាយ ដែលលិចដោយគ្រឿងក្រអូប និងផ្កាជាដើម ដែលទេវតានាគ និងគ្រុឌជាដើម ឈរក្នុងអាកាស ហើយបាចចុះមក រហូតដល់ឌុបទេសហើយលុយកាត់គ្រឿងក្រអូប និងផ្កាទៅ ទើបមានការយឺតយូរពន់ពេក ព្រោះដូច្នោះ ទើបសេះទៅបានត្រឹម ៣០ យោជន៍ប៉ុណ្ណោះ ។ ព្រះពោធិសត្វប្រថាប់ឈរត្រង់ឆ្នេរស្ទឹង ហើយត្រាស់សួរឆន្នអមាត្យថា ស្ទឹងនេះឈ្មោះអ្វី ឆន្នក្រាបទូលថា បពិត្រព្រះអង្គ ស្ទឹងនេះ ឈ្មោះអនោមា ។ ព្រះពោធិសត្វត្រាស់ថា បព្វជ្ជារបស់អញ មិនថោកថយ ទើបយកកែងព្រះបាទគោះឲ្យសញ្ញាសេះ ហើយសេះបានលោតឆ្លងស្ទឹង ដែលមានប្រមាណ ៨ ឧសភឈរនៅត្រើយម្ខាងហើយ ព្រះពោធិសត្វចុះអំពីខ្នងសេះ ប្រថាប់ឈរត្រង់ផ្ទូកខ្សាច់ ដែលមានពណ៌ដូចប្រាក់ ត្រាស់ហៅឆន្នមកថា ឆន្នសម្លាញ់ ចូរអ្នកនាំយកអាភរណៈ និងសេះរបស់យើងទៅ យើងនឹងបួសក្នុងទីនេះឯង ។ ឆន្នក្រាបទូលថា បពិត្រសម្មតិទេព ទូលបង្គំនឹងបួសជាមួយព្រះអង្គដែរ ។ ព្រះពោធិសត្វឃាត់ ៣ ដងថា អ្នកបួសមិនបានទេ ចូរអ្នកទៅចុះ ហើយទ្រង់

ប្រគល់គ្រឿងអាភរណៈ និងសេះកណ្ឋកៈ ឲ្យឆន្នទទួលទៅ ហើយទ្រង់ព្រះតម្រិះថា សក់ទាំងឡាយរបស់អញនេះ មិនសមគួរដល់សមណៈ ទ្រង់ព្រះតម្រិះថា បុគ្គលដទៃដែលសមគួរកាត់សក់របស់ព្រះពោធិសត្វ រមែងមិនមាន ព្រោះហេតុនោះ អញនឹងកាត់ខ្លួនឯងដោយព្រះខ័ន ។ ដូច្នេះហើយ ទើបយកព្រះហស្តស្តាំចាប់ព្រះខ័ន យកព្រះហស្តឆ្វេង ចាប់ព្រះចូឡា និងព្រះមោលី ហើយកាត់ព្រះកេសានៅសល់ប្រមាណ ២ ធ្នាប់ ព្រះកេសានោះក៏ដុះវិលស្តាំក្រាប់ជាប់លើសិរសា ។ ព្រះកេសាមានប្រមាណប៉ុណ្ណោះ ដរាបដល់ទ្រង់បរិនិព្វាន ។ ព្រះមស្សុក៏មានល្មមសមគួរដល់ព្រះកេសានោះ ឈ្មោះថា កិច្ចដោយការកោរសក់ និងពុកមាត់ មិនមានទៀតឡើយ ។ ព្រះពោធិសត្វចាប់ព្រះចូឡា មួយអន្លើដោយព្រះមោលី ទ្រង់អធិដ្ឋានថា បើអាត្មាអញបានត្រាស់ជាព្រះពុទ្ធសោត មោលីចូរតាំងនៅក្នុងអាកាស បើមិនបានជាព្រះពុទ្ធទេ ចូរធ្លាក់ចុះលើផែនដី ដូច្នេះហើយ ទ្រង់បោះទៅក្នុងអាកាស ព្រះចូឡានោះទៅដល់ទីប្រមាណមួយយោជន៍ ហើយតាំងនៅក្នុងអាកាស ។ សក្កទេវរាជប្រមើលមើលដោយទិព្វចក្ខុ ទើបយកប្រអប់កែវ ទំហំប្រមាណមួយយោជន៍មកទទួល នាំទៅប្រតិស្ឋានក្នុងចូឡាមណីចេតិយនាតាវត្តិង្សភព ដូចលោកពោលថា

អគ្គបុគ្គល កាត់ព្រះមោលី ដែលអប់ដោយក្លិនក្រអូបដ៏ប្រសើរ
ហើយបោះទៅក្នុងអាកាស ស្តេចវាសវៈដែលមានព្រះនេត្រ ១០០០
យកប្រអប់មាសដ៏ប្រសើរទទួល ទូលលើសីសៈហើយ ដូច្នេះ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះទៀតថា សំពត់កាសិកពស្ត្រទាំងនេះ មិនសមគួរដល់សមណៈសម្រាប់អញឡើយ ។ លំដាប់នោះ ឃដិការមហាព្រហ្មដែលជាសម្លាញ់ចាស់ ក្នុងសាសនាព្រះពុទ្ធកស្សបៈ មានភាពជាមិត្តមួយពុទ្ធន្តរ គិតថា ថ្ងៃនេះ សម្លាញ់របស់អញចេញមហាភិនេស្ក្រមណ៍ អញនឹងយកសមណបរិក្ខាររបស់សម្លាញ់អញទៅ ដូច្នេះហើយ ទើបនាំបរិក្ខារ ៨ គឺ ត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ មានតម្រងទឹកជាគម្រប់ ៨ រមែងគួរដល់ភិក្ខុអ្នកប្រកបព្យាយាមមកឲ្យ ។ ព្រះពោធិសត្វ ទ្រង់ដណ្តប់ទង់ជ័យអរហត្តហើយ កាន់យកភេទបព្វជ្ជាដ៏ឧត្តម ទើបទ្រង់បញ្ជូនឆន្នទៅ ដោយព្រះតម្រាស់ថា ឆន្ន បូរអ្នកទូលដល់ការមិនមានរោគ មិនមានជំងឺ ដល់ព្រះជនក ព្រះជននី តាមពាក្យរបស់យើងផងចុះ ឆន្នថ្វាយបង្គំព្រះពោធិសត្វ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ឯសេះកណ្ឋកៈ ឈរស្តាប់វាចារបស់ព្រះពោធិសត្វដែលត្រាស់ជាមួយឆន្ន គិតថា ឥឡូវនេះ អញនឹងមិនមានការបានឃើញអយ្យបុត្តតទៅទៀត ដូច្នេះហើយ កាលផុតអំពីគន្លងចក្ខុ មិនអាចអត់ធន់នឹងសេចក្តីសោកបាន ហទយៈក៏បែកធ្លាយ ទើបកើតជាកណ្ឋកទេវបុត្តក្នុងស្ថានតាវត្តិង្ស ។ ដំបូង ឆន្នមានសេចក្តីសោកតែមួយ កាលសេះកណ្ឋកៈស្លាប់ទៅ ឆន្នត្រូវសេចក្តីសោកមួយទៀតគ្របសង្កត់ ដើរយំទៅកាន់ព្រះនគរ ។

មហាសត្វទ្រង់បព្វជ្ជាហើយ សម្ងំនៅដោយសុខដែលកើតអំពីបព្វជ្ជាអស់មួយសប្តាហ៍ ក្នុងអនុបិយម្ពវ័ន ដែលមានក្នុងទីកដីនោះឯង ហើយយាង

ដោយព្រះបាទ អស់ចម្ងាយផ្លូវ ៣០ យោជន៍ ដោយមួយថ្ងៃប៉ុណ្ណោះ ហើយយាងទៅកាន់ក្រុងរាជគ្រឹះ កាលចូលទៅហើយ ទ្រង់ចារិកបិណ្ឌបាតតាមលំដាប់ច្រក ។ អ្នកនគរទាំងមូល ដល់នូវការភ្ញាក់ផ្អើល ព្រោះបានឃើញនូវព្រះរូបរបស់ព្រះពោធិសត្វ ដូចគ្នានឹងដំរីធនបាល ចូលទៅកាន់ក្រុងរាជគ្រឹះ និងដូចទេវនគរ ដែលស្តេចអសុរចូលទៅ ដូច្នោះ ។ សម័យនោះ រាជបុរសទាំងឡាយមកក្រាបទូលដល់ព្រះរាជាថា បពិត្រសម្មតិទេព បុគ្គលបែបនេះត្រាច់បិណ្ឌបាតក្នុងព្រះនគរ ពួកទូលបង្គំមិនដឹងថា បុគ្គលនេះ ឈ្មោះអ្វី ជាទេវតា មនុស្ស នាគ ឬគ្រុឌឡើយ ព្រះរាជាប្រថាប់ឈរខាងលើប្រាសាទទតឃើញព្រះមហាបុរស កើតអស្ចារ្យដែលមិនធ្លាប់កើត ទ្រង់បញ្ជាពួករាជ-បុរសថា នែបា ចូរអ្នកទាំងឡាយពិចារណាមើល បើជាអមនុស្ស កាលចេញអំពីព្រះនគរហើយ នឹងបាត់ទៅ បើជាទេវតានឹងហោះទៅ បើជានាគនឹងមុជដីទៅ បើជាមនុស្ស នឹងបរិភោគកិក្ខាតាមដែលបាន ។ ឯមហាបុរសប្រមូលភត្តចូលគ្នាហើយ ដឹងថា ភត្តមានប្រមាណប៉ុណ្ណោះ ល្មមសម្រាប់ទ្រង់ ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ទ្រង់ចេញអំពីព្រះនគរ តាមទ្វារដែលទ្រង់ចូលទៅនោះឯង បែរព្រះភក្ត្រទៅកាន់ទិសខាងកើត គង់ប្រថាប់ត្រង់ស្រមោលរបស់បណ្ឌវបព៌ត ផ្តើមដើម្បីសោយព្រះក្រយាហារ ។ លំដាប់នោះ ពោះវៀនធំរបស់មហាបុរស ដល់អាការនឹងចេញមកតាមព្រះឱស្ឋ ។ គ្រានោះ ព្រះពោធិសត្វទ្រង់សង្កត់ព្រះហឫទ័យដោយអាហារបដិកូល ព្រោះអត្តភាពនោះទ្រង់មិនធ្លាប់ឃើញអាហារបែបនោះ សូម្បីដោយភ្នែក ទើបទ្រង់ទូន្មានខ្លួនយ៉ាង

នេះថា ម្នាលសិទ្ធត្ថ អ្នកកើតក្នុងទីដែលមានភោជន មានរសប្រសើរផ្សេងៗ ដោយភោជននៃស្រូវសាលីមានក្លិនក្រអូប ដែលទុកអស់ ៣ ឆ្នាំ ក្នុងត្រកូលដែលមានបាយ និងទឹកវកបានងាយ បានឃើញបព្វជិតអ្នកទ្រទ្រង់សំពត់បង្សុកូលមួយរូប ហើយគិតថា កាលណាហ្ន៎ អញនឹងជាបុគ្គលមានសភាពបែបនោះ ត្រាច់បិណ្ឌបាតបរិភោគ កាលនោះ នឹងមានឬទេហ្ន៎ សម្រាប់អាត្មាអញ ទើបចេញបួស ឥឡូវនេះ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច កាលទ្រង់ទូន្មានខ្លួនយ៉ាងនេះហើយ ទ្រង់មិនមានអាការខុសប្រក្រតី ទ្រង់សោយព្រះក្រយាហារ ។ រាជបុរសទាំងឡាយឃើញការប្រព្រឹត្តទៅនោះហើយ ទើបទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ព្រះរាជាបានស្ដាប់ពាក្យរបស់ទូតប៉ុណ្ណោះ ទ្រង់ប្រញាប់ចេញអំពីព្រះនគរ ទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ទ្រង់ជ្រះថ្លាក្នុងឥរិយាបថប៉ុណ្ណោះ ទើបទ្រង់ប្រគល់ភាពជាធំឲ្យដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រាស់ថា មហាបពិត្រ អាត្មាមិនត្រូវការវត្ថុកាម ឬកិលេសកាមទាំងឡាយឡើយ អាត្មាត្រូវការបរមាភិសម្ពោធិញ្ញាណ ទើបចេញបួស ។ ព្រះរាជាទ្រង់អង្វរជាអនេកប្រការ ក៏មិនបានទឹកព្រះហឫទ័យរបស់ព្រះពោធិសត្វនោះ ទើបត្រាស់ថា ទ្រង់នឹងបានជាព្រះពុទ្ធពិត បើទ្រង់បានជាព្រះពុទ្ធហើយ សូមមកកាន់ដែនរបស់ខ្ញុំមុន ។ នេះជាសេចក្ដីសង្ខេបក្នុងទីនេះ ឯសេចក្ដីពិស្ដារ គប្បីមើលសព្ទក្នុង ( សុត្តនិបាត ) បព្វជ្ជាសូត្រថា ខ្ញុំនឹងសម្ដែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ ទ្រង់បានព្រះផ្នួសហើយ ដូច្នេះ និងអដ្ឋកថាហើយគប្បីជ្រាបចុះ ។

ឯព្រះពោធិសត្វ ទ្រង់ប្តេជ្ញាដល់ព្រះរាជា ហើយទ្រង់ចារិកទៅដោយលំដាប់ ចូលទៅរកអាឡារតាបសកាលាមគោត្រ និងឧទកតាបសរាមបុត្រ ធ្វើសមាបត្តិឲ្យកើតហើយ ទ្រង់ព្រះតម្រិះថា នេះមិនមែនជាផ្លូវដើម្បីត្រាស់ដឹងដូច្នេះហើយ ទើបមិនទាន់ពេញព្រះហឫទ័យ ក្នុងសមាបត្តិភាវនានោះ មានបំណងនឹងតាំងមហាបធាន ដើម្បីសម្តែងកម្លាំង និងសេចក្តីព្យាយាមរបស់ព្រះអង្គដល់សត្វលោក ព្រមទាំងទេវលោក ទើបយាងទៅកាន់ឧរុវេលាប្រទេស ទ្រង់ព្រះតម្រាស់ថា ភូមិភាគនេះ គួរជាទីត្រេកអរហ្ន៎ ដូច្នេះហើយទើបយាងចូលទៅក្នុងតំបន់ឧរុវេលានោះ ទ្រង់ផ្តើមតាំងមហាបធាន ។ បព្វជិត ៥ រូប មានកោណ្ឌញ្ញៈជាប្រធាននោះឯង នាំគ្នាត្រាច់បិណ្ឌបាតក្នុងគាមនិគមនិងរាជធានី ជួបព្រះពោធិសត្វក្នុងឧរុវេលានិគមនោះ ។ បព្វជិតទាំង ៥ រូបនោះ ឧបដ្ឋាកព្រះពោធិសត្វដែលផ្តើមតាំងមហាបធាន ព្យាយាមអស់ ៦ ឆ្នាំដោយវត្តបដិបត្តិ មានការបោសបរិវេនជាដើម ដោយទន្ទឹងថា នឹងបានជាព្រះពុទ្ធក្នុងឥឡូវនេះ ហើយនៅក្នុងសម្នាក់របស់ព្រះពោធិសត្វនោះ ។

ឯព្រះពោធិសត្វទ្រង់ព្រះតម្រិះថា នឹងធ្វើទុក្ករកិរិយាឲ្យដល់ទីបំផុត ទើបទ្រង់នៅសម្ងំដោយអង្ករ និងល្ងត្រឹម ១ គ្រាប់ជាដើម ទ្រង់ធ្វើការកាត់បន្ថយអាហាររហូតដល់អស់ ដោយប្រការទាំងពួង ។ ចំណែកទេវតានាំឱជៈដាក់ក្នុងរណ្តៅរោមទាំងឡាយ ក្នុងកាលដែលព្រះពោធិសត្វនោះ មានព្រះវរកាយដល់នូវការទន់ខ្សោយក្រៃលែង ព្រោះជាបុគ្គលមិនមានព្រះក្រយាហារនោះ ព្រះកាយដែលមានពណ៌ដូចមាស ព្រះឆវីស្រអាប់ទៅ មហាបុរិសលក្ខណៈ

៣២ ក៏ត្រូវបិទបាំង មិនប្រាកដ ។ ក្នុងគ្រាខ្លះ កាលទ្រង់សម្ងំឈានដែល មិនមានខ្យល់ចេញចូល ត្រូវវេទនាធំគ្របសង្កត់ ទ្រង់វិសញ្ញី សន្ទប់ដួល ចុះក្នុងទីបំផុតនៃទីចង្រ្កម លំដាប់នោះ ទេវតាពួកខ្លះពោលដល់ព្រះពោធិសត្វ នោះថា ព្រះសមណគោតមធ្វើកាលកិរិយាហើយ ទេវតាពួកខ្លះពោលថា នេះ ជាវិហារធម៌របស់ព្រះអរហន្តទេតើ ។ បណ្តាទេវតាទាំងនោះ ពួកទេវតាដែល ពោលថា ព្រះសមណគោតមបានធ្វើកាលកិរិយាហើយនោះ នាំគ្នាទៅក្រាប ទូលដល់ព្រះបាទសុទ្ធោទនមហារាជថា ព្រះរាជឱរសរបស់ព្រះអង្គ សោយ ទិវង្គតហើយ ។ ព្រះបាទសុទ្ធោទនមហារាជត្រាស់ថា កូនរបស់យើង បើមិន ទាន់បានត្រាស់ជាព្រះពុទ្ធ មិនស្លាប់ឡើយ ទេវតាទាំងនោះក្រាបទូលថា ព្រះ ឱរសរបស់ព្រះអង្គ មិនអាចបានជាព្រះពុទ្ធទេ ទ្រង់ដួលចុះត្រង់ផែនដីសម្រាប់ ព្យាយាម សោយទិវង្គតហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនេះ ទើបត្រាស់ថា ខ្ញុំមិនជឿ កូនរបស់ខ្ញុំ បើមិនសម្រេចពោធិញ្ញាណ ហើយធ្វើកាលកិរិយា មិនមាន ។ សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនជឿ ។ ឆ្លើយថា ព្រោះទ្រង់ បានឃើញបាដិហារ្យទាំងឡាយ ក្នុងថ្ងៃដែលថ្វាយបង្គំកាឡទេវលតាបស និង ត្រង់មណ្ឌលដើមព្រីង ។ ព្រះពោធិសត្វទ្រង់បាននូវសញ្ញាក្រោកឡើងទៀត កាលព្រះមហាសត្វក្រោកឡើងហើយ ទេវតាទាំងនោះ មកក្រាបទូលដល់ព្រះ រាជាថា បពិត្រមហារាជ ព្រះរាជឱរសរបស់ព្រះអង្គ មិនមានរោគឡើយ ។ ព្រះរាជាត្រាស់ថា យើងតែងដឹងថា បុត្តរបស់យើងមិនស្លាប់ ។

កាលព្រះមហាសត្វ ទ្រង់បំពេញទុក្ករកិរិយា ៦ វស្សា ពេលវេលា

ដូចជាក្ដួចកំណួចក្នុងអាកាស ព្រះមហាសត្វនោះ ទ្រង់ព្រះតម្រិះថា ឈ្មោះថា ការធ្វើទុក្ករកិរិយានេះ មិនមែនផ្លូវត្រាស់ដឹង ទើបត្រាច់ទៅបិណ្ឌបាតតាមគាម-និគម ដើម្បីអាហារគ្រោតគ្រាត ហើយនាំអាហារមក កាលនោះ មហាបុរិ-សលក្ខណៈ ៣២ របស់ព្រះពោធិសត្វ ក៏មានជាប្រក្រតី ព្រះវរកាយមានឆវីវណ្ណដូចមាស បញ្ចវគ្គិយនាំគ្នាគិតថា មហាបុរសនេះ សូម្បីធ្វើទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំ ក៏មិនអាចចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណបាន ឥឡូវនេះ ត្រាច់បិណ្ឌបាតក្នុងស្រុកជាដើម នាំអាហារគ្រោតគ្រាតមក នឹងអាចត្រាស់ដឹងបានដូចម្ដេច មហាបុរសនេះ ក្លាយជាអ្នកប្រាថ្នាច្រើន ប្រាសចាកសេចក្ដីព្យាយាម ឈ្មោះថា ការគិតគ្នេរដល់គុណវិសេសអំពីសម្នាក់មហាបុរសនេះនៃពួកយើង ក៏ដូចបុគ្គលលាបស្រឡាបក្បាល គិតគ្នេរដោយប្រើទឹកសន្សើម ដូច្នោះ ប្រយោជន៍អ្វីដោយមហាបុរសនេះដល់ពួកយើង ទើបនាំគ្នាលះបង់មហាបុរស កាន់យកបាត្រ និងចីវររៀងៗ ខ្លួន ធ្វើដំណើរទៅក្នុងទីប្រមាណ ១៨ យោជន៍ ចូលទៅកាន់ព្រៃឥសិបតនៈ ។

សម័យនោះឯង ទារិកាឈ្មោះសុជាតា កើតក្នុងផ្ទះរបស់សេនាកុដុម្ពិកៈ ក្នុងតំបន់ឧរុវេលាសេនានិគម ចម្រើនវ័យហើយ បានធ្វើសេចក្ដីប្រាថ្នាត្រង់ដើមជ្រៃមួយដើមថា បើអញទៅកាន់ត្រកូលដែលមានជាតិស្មើគ្នា ហើយបានបុត្រប្រុសក្នុងគភ៌ជាដំបូង អញនឹងធ្វើពលីកម្ម ដោយបរិច្ចាគទ្រព្យមួយសែនរាល់ៗ ឆ្នាំ សេចក្ដីប្រាថ្នារបស់នាងនោះ ក៏សម្រេចហើយ ។ កាលព្រះមហាសត្វនោះធ្វើទុក្ករកិរិយាគ្រប់ ៦ ឆ្នាំបរិបូណ៌ នាងសុជាតានោះ បំណងនឹងធ្វើ

ពលីកម្ម ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ក្នុងមុនថ្ងៃនោះ បានលែងគោទឹកដោះ ១០០០ ឲ្យត្រាច់ទៅក្នុងព្រៃឈើឯម ឲ្យគោ ៥០០ ផឹកទឹកដោះរបស់គោ ១០០០ នោះ ហើយឲ្យគោ ២៥០ ផឹកទឹកដោះរបស់គោ ៥០០ នោះ នាងប្រាថ្នាទឹកដោះខាប់ និងមានឱជះ ទើបឲ្យគោផឹកទឹកដោះបន្តៗ រហូតដល់ ៨ ក្បាល ផឹកទឹកដោះគោ ១៦ នោះ យ៉ាងនេះ ។ ស្អែកឡើង ថ្ងៃវិសាខបុណ្ណមី នាងសុជាតានោះ ក្រោកឡើងក្នុងវេលាទៀបភ្លឺនៃរាត្រី គិតថា នឹងធ្វើពលីកម្ម ដូច្នេះហើយ ទើបឲ្យរឹតទឹកដោះគោ ៨ នោះ កូនគោទាំងឡាយមិនទាន់បានទៅដល់កន្សោមដោះទាំងនោះ គ្រាន់តែភាជនៈថ្មីចូលទៅជិតកន្សោមដោះប៉ុណ្ណោះ ធារទឹកដោះក៏ហូរចេញតាមធម្មតារបស់ខ្លួន នាងសុជាតាបានឃើញសេចក្តីអស្ចារ្យនោះ ទើបដងទឹកដោះដោយដៃរបស់ខ្លួនឯង ដាក់ក្នុងភាជនៈថ្មី ហើយបង្កាត់ភ្លើងដោយដៃខ្លួនឯង ផ្តើមនឹងចម្អិន កាលកំពុងចម្អិនបាយាសនោះឯង ពពុះធំៗ តាំងឡើង ហូរវិលជាទក្ខិណាវដ្ត ។ តំណក់ទឹកដោះសូម្បីត្រឹមតែមួយតំណក់ ក៏មិនកំពប់ចេញមកក្រៅ ផ្សែងសូម្បីមានប្រមាណតិច ក៏មិនតាំងឡើងអំពីចង្ក្រាន ។ គ្រានោះ ស្តេចចតុលោកបាលជាអ្នករក្សាត្រង់ជើងប្រាន ។ មហាព្រហ្មបាំងឆត្រ សក្កទេវរាជនាំឧសមកដាក់ឲ្យឆេះ ។ ពិតហើយ ទេវតាទាំងឡាយប្រមូលឱជះ ដែលសម្រេចដោយការទំនុកបម្រុងរបស់ទេវតា និងមនុស្សទាំងឡាយ ( ឧបកប្បនឱជះ ) ក្នុងទ្វីបទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារ ដាក់ចូលក្នុងមធុបាយាសនោះ ដោយអានុភាពរៀងៗ ខ្លួន ដូចបុគ្គលប្របាច់សម្បុកឃ្មុំ ដែលជាប់នៅលើបន្ទង ហើយកាន់យកតែទឹក

ផ្អែម ដូច្នោះ ។

ពិតហើយ ក្នុងកាលដទៃៗ ទេវតាទាំងឡាយដាក់ឱជៈក្នុងពំនូតបាយ តែក្នុងថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វាន ដាក់ឱជៈក្នុងថ្នាំងនោះឯង ។

នាងសុជាតា បានឃើញការអស្ចារ្យមិនមែនតិច ដែលប្រាកដដល់ខ្លួន ក្នុងទីនោះ ដោយមួយថ្ងៃប៉ុណ្ណោះ ទើបហៅនាងបុណ្ណទាសីមកពោលថា នែនាងបុណ្ណា ថ្ងៃនេះ ទេវតារបស់យើង គួរជ្រះថ្លាពន់ពេក ក្នុងកាលមានប្រមាណប៉ុណ្ណោះ ខ្ញុំមិនធ្លាប់ឃើញការអស្ចារ្យបែបនេះ ចូរនាងប្រញាប់ទៅមើលទេវស្ថានដោយរហ័ស នាងបុណ្ណទាសីនោះ ទទួលពាក្យរបស់នាងសុជាតានោះថា សាធុ ហើយបានប្រញាប់ប្រញាល់ទៅកាន់គល់ជ្រៃ ។

ចំណែកព្រះពោធិសត្វ បានឃើញមហាសុបិន ៥ ប្រការ ក្នុងរាត្រីនោះ ទ្រង់ធ្វើការសន្និដ្ឋានថា ថ្ងៃនេះ អញនឹងបានត្រាស់ជាព្រះពុទ្ធ ដោយឥតសង្ស័យ ។ គ្រាន់តែរាត្រីនោះកន្លងទៅ ទ្រង់ធ្វើកិច្ចបដិបត្តិសរីរៈ រង់ចាំពេលភិក្ខាចារ លុះដល់ព្រឹក ទើបមកគង់ត្រង់គល់ជ្រៃនោះ ទ្រង់ធ្វើគល់ជ្រៃទាំងមូលឲ្យភ្លឺ ដោយរស្មីរបស់ព្រះអង្គ ។

សម័យនោះ នាងបុណ្ណទាសីនោះមក បានឃើញព្រះពោធិសត្វ គង់ត្រង់គល់ជ្រៃ ទតមើលលោកធាតុទិសខាងកើត ។ ព្រោះបានឃើញដើមជ្រៃទាំងមូល មានពណ៌ដូចមាស ដោយព្រះរស្មីដែលផ្សាយចេញអំពីសរីរៈរបស់ព្រះពោធិសត្វនោះ ទើបនាងគិតដូច្នេះថា ថ្ងៃនេះ ទេវតារបស់យើងទាំងឡាយប្រហែលជាចុះអំពីដើមឈើ មកអង្គុយដើម្បីទទួលពលីកម្មដោយដៃរបស់ខ្លួន

នោះឯង ដូច្នេះហើយ ទើបជាបុគ្គលដល់នូវការត្រេកអរដោយបីតិ ប្រញាប់ទៅប្រាប់សេចក្តីនោះដល់នាងសុជាតា ។ នាងសុជាតាបានស្តាប់ពាក្យរបស់នាងបុណ្ណាទាសីនោះហើយ ក៏ត្រេកអរពោលថា ថ្ងៃនេះ តាំងអំពីឥឡូវនេះទៅ ចូរនាងតាំងនៅក្នុងឋានៈជាធីតាច្បងរបស់យើង ហើយបានឲ្យគ្រឿងអលង្ការទាំងពួង ដែលសមគួរដល់ធីតា ។ ព្រោះក្នុងថ្ងៃសម្រេចភាពជាព្រះពុទ្ធការបានថាសមាស ដែលមានតម្លៃមួយសែន ទើបគួរ ព្រោះដូច្នោះ ទើបនាងសុជាតានោះមានគំនិតកើតឡើងថា នឹងដាក់បាយាសក្នុងថាសមាស ឲ្យអ្នកបម្រើនាំថាសមាសមានតម្លៃមួយសែនចេញមក បំណាងនឹងដាក់បាយាសក្នុងថាសមាសនោះ ទន្ទឹងដល់កោជនដែលឆ្អិនហើយ ។ បាយាសទាំងអស់បានរមៀលចូលទៅប្រតិស្ឋានក្នុងថាស ដូចទឹករមៀលចាកស្លឹកឈូក ដូច្នោះ បាយាសនោះ មានប្រមាណពេញថាសមួយល្មម ។ ទើបនាងយកថាសមាសមួយទៀត គ្របថាសនោះ ហើយយកសំពត់សរុំ ប្រដាប់តាក់តែងរាងកាយដោយគ្រឿងអលង្ការទាំងពួង យកថាសនោះទូលលើក្បាលរបស់ខ្លួនដើរទៅកាន់គល់ជ្រៃនោះ ដោយអានុភាពធំ សម្លឹងមើលព្រះពោធិសត្វ កើតនូវសោមនស្សជាកម្លាំង សម្គាល់ថាជារុក្ខទេវតា ទើបបន្ទោនកាយចុះ ដើរទៅតាំងអំពីទីដែលបានឃើញ ដាក់ថាសអំពីក្បាលហើយ លាសំពត់ យកសុវណ្ណភិង្ការដាក់ទឹកដែលអប់ដោយផ្កា ហើយបានចូលទៅឈរក្បែរព្រះពោធិសត្វ ។ បាត្រដីដែលឃដិការមហាព្រហ្មថ្វាយ មិនឆ្ងាយព្រះពោធិសត្វអស់កាលយូរមានប្រមាណប៉ុណ្ណេះ បានបាត់ទៅក្នុងខណៈនោះ ។ ព្រះ

ពោធិសត្វមិនឃើញបាត្រ ទើបលាព្រះហស្តស្តាំទទួល ។ ទើបនាងសុជាតាដាក់ថាសបាយាសក្នុងព្រះហស្តរបស់មហាបុរសៗ ទតមើលនាងសុជាតាៗកំណត់អាការហើយ ទើបទូលថា បពិត្រព្រះអង្គ សូមទ្រង់កាន់យកវត្ថុដែលខ្ញុំបរិច្ចាគចុះ ថ្វាយបង្គំហើយ ទូលថា មនោរថ គឺសេចក្តីប្រាថ្នាសូមសម្រេចដល់ព្រះអង្គ ដូចសម្រេចដល់ខ្ញុំព្រះអង្គចុះ នាងមិនមានអាល័យក្នុងថាសមាសមានតម្លៃមួយសែន ដូចកាជនៈដីចាស់ ចៀសចេញទៅហើយ ។

ឯព្រះពោធិសត្វ ក្រោកឡើងចាកទីគង់ ទ្រង់ធ្វើប្រទក្សិណដើមជ្រៃ យាងទៅកាន់ស្ទឹងនេរញ្ជរា ក្នុងថ្ងៃដែលព្រះពោធិសត្វត្រាស់ដឹង ត្រង់កំពង់ឈ្មោះសុបតិដ្ឋិតៈ ជាទីស្ថានដែលទ្រង់ចុះស្រេពស្រង់ ទើបទ្រង់ដាក់ថាសត្រង់កំពង់ឈ្មោះសុបតិដ្ឋិតៈនោះ ទ្រង់ចុះស្រង់ស្រេចហើយ ទ្រង់ស្លៀកទង់ជ័យអរហត្ត ដែលជាគ្រឿងស្លៀកដណ្តប់របស់ព្រះពុទ្ធច្រើនសែនអង្គ ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ទ្រង់ធ្វើជាពំនូត ៤៩ ពំនូត ប្រមាណប៉ុនៗ គ្រាប់ត្នោត ហើយសោយមធុបាយាសដែលមានទឹកតិចទាំងអស់ ។ មធុបាយាសនោះបានជាអាហាររហូត ៧ សប្តាហ៍ សម្រាប់ព្រះពោធិសត្វ ដែលនឹងបានជាព្រះពុទ្ធ គង់ត្រង់ពោធិមណ្ឌល ។ ក្នុងកាលមានប្រមាណប៉ុណ្ណោះ មិនមានអាហារដទៃ មិនមានការស្រង់ មិនមានការជម្រះព្រះឱស្ឋ មិនមានការបន្ទោបង់ព្រះឧច្ចារៈ ទ្រង់នៅសម្ងំដោយឈានសុខ មគ្គសុខ និងផលសុខប៉ុណ្ណោះ ។ ព្រះពោធិសត្វ កាលសោយមធុបាយាសនោះហើយ ទ្រង់ចាប់ថាសមាសអធិដ្ឋានថា បើអញបានជាព្រះពុទ្ធក្នុងថ្ងៃនេះសោត ចូរថាសរបស់

អញនេះ អណ្តែតប្រាសខ្សែទឹក បើមិនបានត្រាស់ ចូរអណ្តែតតាមខ្សែទឹក លុះទ្រង់អធិដ្ឋានហើយ បានបណ្តែតថាសទៅ ថាសនោះអណ្តែតកាត់ខ្សែទឹក ដល់កណ្តាលស្ទឹង ហើយបានអណ្តែតប្រាសខ្សែទឹកទៅ អស់ទីប្រមាណ ៨០ ហត្ថ ប្រៀបដូចសេះដែលមានសម្ទុះដើរហ័ស ដូច្នោះហើយ លិចចុះត្រង់អន្លង់ទឹកមួយ ដល់ពិភពកាឡនាគ ប៉ះនឹងគ្រឿងបរិភោគរបស់ព្រះពុទ្ធទាំង ៣ ព្រះអង្គ មានសំឡេងក្រឹកៗ ហើយជ្រៀតចូលខាងក្រោមថាសទាំងនោះ ។ កាឡនាគបានឮសំឡេងនោះហើយ ពោលថា ម្សិលមិញ ព្រះពុទ្ធទ្រង់កើតហើយមួយព្រះអង្គ ថ្ងៃនេះ កើតមួយអង្គទៀត ទើបឈរពោលសរសើរដោយបទច្រើនរយ ។ បានឮថា មហាប្រឹថពីជុះឡើង ក្នុងអាកាសប្រមាណ ១ យោជន៍ ៣ គាវុត ហាក់ដូចជាថ្ងៃនេះ ឬថ្ងៃស្អែកនេះដល់កាឡនាគនោះ ។

ឯព្រះពោធិសត្វ ទ្រង់សម្រាកពេលថ្ងៃ ក្នុងសាលវ័នដែលមានផ្ការីកស្គុសស្គាយ ក្បែរមាត់ស្ទឹងពេលល្ងាច ក្នុងវេលាដែលផ្កាទាំងឡាយ ជ្រុះចាកទង ក៏បានបែរមុខទៅកាន់ពោធិព្រឹក្សតាមផ្លូវប្រមាណ ៨ ឧសភ ដែលទេវតាទាំងឡាយតាក់តែង ដូចសីហៈកែក្រាយ ដូច្នោះ នាគ យក្ខ និងគ្រុឌជាដើម បានបូជាដោយគ្រឿងក្រអូប និងផ្កាជាទិព្វជាដើម ។ លោកធាតុមួយម៉ឺនមានក្លិនក្រអូបតែមួយ មានជួរនៃផ្កាឈើតែមួយ មានសំឡេងសាធុការតែមួយ ។ សម័យនោះ ព្រាហ្មណ៍ឈ្មោះសោត្ថិយៈ ជាអ្នករែកស្មៅ កាន់ស្មៅ ដើរប្រាសផ្លូវមក ដឹងអាការរបស់មហាបុរស ទើបថ្វាយស្មៅ ៨ ក្តាប់ ព្រះពោធិសត្វទទួលស្មៅហើយ ឡើងកាន់ពោធិមណ្ឌល បានប្រថាប់ឈរក្នុង

ទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងជើង ខណៈនោះ ចក្រវាលខាងត្បូងស្រុតចុះ ហាក់ដូចជាដល់អវិចី ចក្រវាលខាងជើងអណ្តែតឡើង ហាក់ដូចទល់គ្នានឹងភវគ្គព្រហ្ម ព្រះពោធិសត្វទ្រង់ត្រិះរិះថា ទីនេះ មិនមែនជាទីដែលសម្រេចនូវសម្ពោធិញ្ញាណឡើយ ទើបធ្វើប្រទក្សិណ ទ្រង់ទៅកាន់ទិសខាងលិច ប្រថាប់ឈរបែរព្រះភក្ត្រទៅទិសខាងកើត ។ គ្រានោះ ចក្រវាលទិសខាងលិចបានស្រុតចុះ ហាក់ដូចទល់គ្នានឹងអវិចី ចក្រវាលខាងកើតអណ្តែតឡើង ហាក់ដូចជាទល់គ្នានឹងភវគ្គព្រហ្ម បានឮថា ក្នុងទីដែលមហាបុរសនោះប្រថាប់ឈរហើយ មហាព្រឹថពីបានស្រុតចុះ និងប៉ោងឡើង ដូចកង់រទេះធំដែលតម្កល់នៅក្នុងដុំ ត្រូវមនុស្សជាន់វង្វង់ម្ខាងនៃកង់នោះ ដូច្នោះ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ទីនេះ មិនមែនជាទីដែលសម្រេចពោធិញ្ញាណទើបធ្វើប្រទក្សិណ ទ្រង់យាងទៅទិសខាងជើង ប្រថាប់ឈរបែរព្រះភក្ត្រទៅទិសខាងត្បូង ។ គ្រានោះ ចក្រវាលក្នុងទិសខាងជើងបានស្រុតចុះ ហាក់ដូចទល់គ្នានឹងអវិចី ចក្រវាលទិសខាងត្បូង អណ្តែតឡើង ហាក់ដល់ភវគ្គព្រហ្ម ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ទីនេះ ប្រហែលជាមិនមែនទីដែលត្រាស់ដឹងព្រះសម្ពោធិញ្ញាណទេ ទើបទ្រង់ធ្វើប្រទក្សិណទៅកាន់ទិសខាងកើត បានឈរបែរព្រះភក្ត្រទៅកាន់ទិសខាងលិច ឯទីដែលផុសឡើងនៃបល្ល័ង្ករបស់ព្រះពុទ្ធទាំងឡាយ មានក្នុងទិសខាងកើត ទើបទីនោះ មិនញាប់ញ័រ មិនរង្គើ ។ ព្រះមហាសត្វទ្រង់ជ្រាបថា ទីនោះ ជាទីដែលព្រះពុទ្ធទាំងពួង ទ្រង់មិនលះបង់ជាទីមិនញាប់ញ័រ ជាទីកម្ចាត់ទ្រុង គឺកិលេស ទើបទ្រង់ចាប់ចុងស្មៅ ហើយ

អន្រ្ទន ។ រំពេចនោះឯង មានបល្ល័ង្ក ១៤ ហត្ថ ស្មៅទាំងនោះក៏តាំងនៅដូច ដើម ដោយការក្រាលបែបនោះ ដែលជាងគំនូរ ឬជាងបូកលាបដ៏ឈ្លាស ក៏ មិនអាចគូរ ឬបូកលាបបានឡើយ ។

ព្រះពោធិសត្វបែរព្រះកក្រ្តទៅទិសខាងកើត ដោយឲ្យដើមពោធិ៍នៅខាង ក្រោយ ជាអ្នកមានព្រះមនសៈមាំទាំ ទ្រង់គង់ពត់ភ្នែន លើអបរាជិតបល្ល័ង្ក ដែលរន្ទះបាញ់រាប់រយដង ក៏មិនបែកធ្លាយ ដោយទ្រង់អធិដ្ឋានថា

*សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈ របស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ កាលអាត្មាអញមិន សម្រេចសម្មាសម្ពោធិញ្ញាណលើបល្ល័ង្កនេះ ក៏នឹងមិនទម្លាយភ្នែន នេះ ដូច្នេះ ។*

សម័យនោះ ទេវបុត្តមារគិតថា សិទ្ធត្ថកុមារបំណងនឹងកន្លងអំណាចរបស់ អញ ឥឡូវនេះ អញនឹងមិនឲ្យសិទ្ធត្ថកុមារនោះកន្លងផុតបានឡើយ ទើបទៅ កាន់សម្នាក់របស់ពលមារ ប្រាប់សេចក្តីនោះ ឲ្យស្រែកហ៊ោ ហើយនាំពល មារចេញទៅ ។ សេនាមារនោះ ខាងមុខកម្រាស់ ១២ យោជន៍ ខាងស្តាំ ខាងឆ្វេងកម្រាស់ ១២ យោជន៍ ខាងក្រោយទល់នឹងកណ្តាប់ចក្រវាល ខាង លើកម្រាស់ ៩ យោជន៍ បន្លឺសំឡេងលាន់ឮដូចផែនដីស្រុតប្រមាណមួយ ពាន់យោជន៍ ។ លំដាប់នោះ ទេវបុត្តមារឡើងជិះដំរីឈ្មោះគិរីមេខៈ កម្ពស់ ១៥០ យោជន៍ និម្មិតដៃមួយពាន់ កាន់អាវុធច្រើនប្រភេទ ក្នុងបរិស័ទមារ ក្រៅអំពីនេះ មារ ២ នាក់ មិនមានអាវុធដូចគ្នា ជាអ្នកមានមុខផ្សេងៗ គឺមុខ

ម្នាក់ម្យ៉ាងនាំគ្នាមក ហាក់ដូចលិចលង់ព្រះមហាសត្វ ទេវតាក្នុងម៉ឺនចក្រវាល បានឈរពោលសរសើរព្រះមហាសត្វ ឯសក្កទេវរាជបានឈរផ្លុំស័ង្ខ ឈ្មោះវិជយុត្តរ បានឮថា ស័ង្ខនោះ មានប្រវែង ១២០ ហត្ថ កាលផ្លុំខ្យល់ចូលទៅតែម្តងហើយ មានសំឡេងតាំងនៅអស់ ៤ ខែ ទើបសំឡេងនោះអស់ទៅ ។ មហាកាឡនាគរាជ បានឈរពោលសរសើរគុណច្រើនជាង ១០០ គាថា មហាព្រហ្មបានឈរបាំងស្វេតច្ឆត្រ តែកាលពលមារចូលមកជិតពោធិមណ្ឌល បណ្តាទេវតាជាដើមនោះ សូម្បីតែមួយអង្គក៏មិនអាចតាំងនៅបាន នាំគ្នាគេចទៅក្នុងទីចំពោះមុខរៀងៗ ខ្លួន មហាកាឡនាគរាជជ្រែកដីទៅកាន់នាគពិភពដែលមានមណ្ឌលប្រមាណ ៥០០ យោជន៍ ដេកយកដៃទាំង ២ ខ្ទប់មុខ សក្កទេវរាជ កាន់ស័ង្ខវិជយុត្តរដាក់ក្រោយខ្នង ឈរត្រង់ភ្នំកណ្តាប់ចក្រវាល មហាព្រហ្មចាប់ចុងឆត្រ ទៅកាន់ព្រហ្មលោកមួយរំពេច សូម្បីទេវតាមួយអង្គឈ្មោះថា អាចតាំងនៅបាន មិនមាន មហាបុរសមួយអង្គប៉ុណ្ណោះគង់ប្រថាប់ក្នុងទីនោះ ។

ឯមារក៏ពោលនឹងបរិស័ទរបស់ខ្លួនថា នែបាទាំងឡាយ ឈ្មោះថា បុរសដទៃ ដូចគ្នានឹងសិទ្ធត្ថឱរសរបស់ព្រះបាទសុទ្ធោទនៈរមែងមិនមាន ពួកយើងមិនអាចធ្វើការច្បាំងពីមុខ ពួកយើងនឹងចូលពីក្រោយ ឯមហាបុរសសម្លឹងមើលទិសទាំង ៣ ទ្រង់ឃើញតែកាពទទេ ព្រោះទេវតាទាំងពួង នាំគ្នាគេចទៅអស់ ទ្រង់បានឃើញពលមារ នាំគ្នាចូលមកអំពីទិសខាងជើងទៀត ទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះប្រាថ្នាអញតែម្យ៉ាង ដែលធ្វើនូវសេចក្តី

ព្យាយាមដ៏ធំ ក្នុងទីនេះ បិតា មាតា កូនប្រុស កូនស្រី បងប្អូនប្រុស ឬញាតិដទៃណាម្នាក់មិនមាន មានតែបារមី ១០ នេះប៉ុណ្ណោះ ដែលជាបុត្ត និងបរិវាររបស់អញអស់កាលយូរ ព្រោះដូច្នោះ អញនឹងធ្វើបារមីឲ្យជាខែល ហើយប្រហារដោយសស្ត្រា គឺបារមីនោះឯង កម្ចាត់ពួកពលនេះ ទើបគួរ រួចទ្រង់រឭកដល់បារមី ១០ ។ លំដាប់នោះ ទេវបុត្តមារបានបណ្ដាលមណ្ឌលប្រទេសឲ្យកើតជាខ្យល់តាំងឡើង ដោយគិតថា អញនឹងធ្វើសិទ្ធត្ថនេះឲ្យគេចទៅដោយខ្យល់នេះឯង ខណៈនោះ ខ្យល់ មានខ្យល់ទិសខាងកើតជាដើមបានតាំងឡើង អាចទម្លាយកំពូលភ្នំទំហំកន្លះយោជន៍ មួយយោជន៍ ពីរយោជន៍ និងបីយោជន៍ ដកនូវឫសឈើ គុម្ពឈើ និងដើមឈើជាដើម ធ្វើគាមនិគមជុំវិញឲ្យល្អិត ជាលម្អិតតូចធំទៅបាន ក៏មានអានុភាពដែលតេជះនៃបុណ្យរបស់មហាបុរសកម្ចាត់ចេញហើយ លុះមកដល់ព្រះពោធិសត្វ ក៏មិនអាចធ្វើត្រឹមតែជាយចីវរឲ្យកម្រើកបាន គ្រានោះ ទេវបុត្តមារបានបណ្ដាលឲ្យភ្លៀងធំតាំងឡើង ដោយបំណងថា នឹងឲ្យទឹកលិចស្លាប់ដោយអានុភាពនៃទេវបុត្តមារនោះ ពពក ១០០ ស្រទាប់ ១០០០ ស្រទាប់តាំងឡើងខាងលើ ហើយធ្លាក់ចុះមក ផែនដីបានជាចន្លោះៗ ដោយកម្លាំងនៃធារទឹក មហាមេឃអណ្ដែតមកខាងលើព្រៃ និងដើមឈើជាដើម ក៏មិនអាចឲ្យទឹកត្រឹមតែមួយតំណក់ សើមចីវររបស់ព្រះមហាសត្វ បន្ទាប់អំពីនោះ បានបណ្ដាលឲ្យភ្លៀងថ្មកើតឡើង កំពូលភ្នំធំៗទន្ទិចគ្នាបែកជាផ្សែង ឆេះជាអណ្ដាតភ្លើង អណ្ដែតមកតាមអាកាស លុះដល់ព្រះពោធិសត្វ ក៏ក្លាយជាចង្កោមផ្កាទិព្វ បន្ទាប់អំពីនោះ បានបណ្ដាលឲ្យភ្លៀង

គ្រឿងប្រហារតាំងឡើង សស្ត្រាវុធ មានដាវ លំពែង និងព្រួញជាដើម មានមុខម្ខាងខ្លះ មានមុខសងខាងខ្លះ ទង្គិចគ្នាបែកជាផ្សែង ឆេះជាអណ្ដាតភ្លើងអណ្ដែតមកតាមអាកាស លុះដល់ព្រះពោធិសត្វ ក៏ក្លាយជាផ្កាទិព្វ បន្ទាប់ពីនោះ បានបណ្ដាលឲ្យភ្លៀងរងើកភ្លើងតាំងឡើង រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្កាចារ អណ្ដែតមកតាមអាកាស ក្លាយជាផ្កាទិព្វរោយរាយទៀបបាទមូលរបស់ព្រះពោធិសត្វ បន្ទាប់អំពីនោះ បានបណ្ដាលឲ្យភ្លៀងផេះតាំងឡើង គឺផេះដ៏ក្ដៅ មានពណ៌ដូចភ្លើង ធ្លាក់មកអំពីអាកាស ក្លាយជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះទៀបបាទមូលរបស់ព្រះពោធិសត្វ បន្ទាប់អំពីនោះ បានបណ្ដាលឲ្យភ្លៀងខ្សាច់តាំងឡើង ខ្សាច់ទាំងឡាយល្អិតក្រៃលែង ធ្លាក់ចុះជាផ្សែង ឆេះជាភ្លើង អណ្ដែតមកអំពីអាកាស ក្លាយជាផ្កាទិព្វ ធ្លាក់ចុះទៀបបាទមូលរបស់ព្រះពោធិសត្វ បន្ទាប់អំពីនោះ ទើបបណ្ដាលជាភ្លៀងភក់ឲ្យតាំងឡើង ភក់ប៉ះគ្នាបែកជាផ្សែង ឆេះជាភ្លើង អណ្ដែតមកតាមអាកាស ក្លាយជាគ្រឿងលាបដែលជាទិព្វ ធ្លាក់ចុះទៀបបាទមូលរបស់ព្រះពោធិសត្វ តពីនោះ បានបណ្ដាលឲ្យងងឹតតាំងឡើង ដោយគិតថា អញនឹងធ្វើឲ្យកិតភ័យដោយងងឹតនេះហើយឲ្យសិទ្ធត្ថចៀសចេញទៅ ។ ងងឹតនោះ ជាងងឹតប្រកបដោយអង្គ ៤ ។ លុះដល់ព្រះពោធិសត្វ ក៏អន្តរធានទៅ ដូចងងឹតដែលត្រូវកម្ចាត់ដោយពន្លឺនៃព្រះអាទិត្យ មារមិនអាចធ្វើឲ្យព្រះពោធិសត្វគេចទៅដោយខ្យល់ ភ្លៀង ភ្លៀងថ្មភ្លៀងគ្រឿងប្រហារ ភ្លៀងរងើកភ្លើង ភ្លៀងផេះ ភ្លៀងខ្សាច់ ភ្លៀងភក់ និងភ្លៀង គឺងងឹត ៩ យ៉ាងនេះ ដោយប្រការដូច្នេះ ។ ទើបបញ្ជាបរិស័ទនោះថា

នៃបា ពួកអ្នកឈប់ធ្វើអ្វី ចូរចាប់សិទ្ធត្ថកុមារនេះ ចូរសម្លាប់ ចូរធ្វើឲ្យគេចទៅ ឯខ្លួនឯងអង្គុយលើ-កដីរីគិរីមេខៈ កាន់ចក្រាវុធ ចូលទៅជិតព្រះពោធិ-សត្វ ហើយពោលថា សិទ្ធត្ថ ចូរក្រោកឡើងអំពីបល្ល័ង្កនេះៗ មិនមែនជារបស់អ្នក បល្ល័ង្កនេះ ជារបស់យើង ។ មហាសត្វស្តាប់ពាក្យរបស់មារនោះ ទើបត្រាស់ថា ម្នាលមារ អ្នកមិនបានបំពេញបារមី ១០ ឧបបារមី ១០ និងបរមត្ថបារមី ១០ ទាំងមិនបានបំពេញមហាបរិច្ចាគ ៥ មិនបានបំពេញនូវញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា ទើបបល្ល័ង្កនេះ មិនមែនបល្ល័ង្ករបស់អ្នកទេ ជារបស់តថាគត ។ មារក្រោធ អត់ធន់នឹងកម្លាំងសេចក្តីក្រោធមិនបាន ទើបគ្រវែងចក្រាវុធ សំដៅព្រះមហាសត្វ កាលព្រះមហាសត្វនោះ ទ្រង់រំពឹងដល់បារមី ១០ ចក្រាវុធនោះ បានតាំងជាពិតានអំពីខាងលើបានឮថា ចក្រាវុធនោះ មុតក្លាក្រៃពេក មារនោះក្រោធហើយ បោលទៅក្នុងទីដទៃ អាចកាត់សសរថ្មដ៏ក្រាស់ ដូចកាត់ទំពាំង តែឥឡូវនេះ ចក្រាវុធនោះក្លាយជាពិតានផ្កា តាំងនៅ បរិស័ទមារក៏គិតថា សិទ្ធត្ថកុមារនឹងក្រោកចាកបល្ល័ង្ក គេចទៅក្នុងឥឡូវនេះ ទើបនាំគ្នាលែងកំពូលភ្នំធំៗ ចុះមក កាលមហាបុរសទ្រង់រំពឹងដល់បារមី ១០ សូម្បីកំពូលភ្នំថ្មទាំងនោះ ក៏ដល់នូវភាវៈជាចង្កោមផ្កា ធ្លាក់ចុះត្រង់ផែនដី ទេវតាទាំងឡាយ ត្រង់កណ្តាប់ចក្រវាលអើត-កមើលដោយគិតថា អ្នកដ៏ចម្រើន អត្តភាពដ៏ស្អាតនៃព្រះរូបឆោមរបស់សិទ្ធត្ថកុមារ វិនាសហើយហ្ន៎ សិទ្ធត្ថកុមារ ទ្រង់ធ្វើដូចម្តេចហ្ន៎ ។

លំដាប់នោះ មហាបុរសត្រាស់ថា បល្ល័ង្កកើតឡើងដល់តថាគត ក្នុងថ្ងៃដែលព្រះពោធិសត្វទាំងឡាយបំពេញបារមី ហើយត្រាស់ដឹងក្រៃលែង ដូច្នេះហើយ ត្រាស់នឹងមារដែលឈរថា ម្នាលមារ អ្នកណាជាសាក្សីក្នុងភាពដែលអ្នកឲ្យទានហើយ មារលាដៃត្រង់ទៅកាន់ពួកមារ ពោលថា មារទាំងនេះ មានប្រមាណប៉ុណ្ណេះជាបន្ទាល់ ។ ខណៈនោះ សំឡេងបរិស័ទមារប្រព្រឹត្តទៅថា ខ្ញុំជាសាក្សី ខ្ញុំជាបន្ទាល់ ដូច្នេះ ហាក់ដូចជាសំឡេងផែនដីស្រុត ។ សម័យនោះ ទើបមារពោលនឹងមហាបុរសថា នែសិទ្ធត្ថ ក្នុងការៈដែលអ្នកឲ្យទាន អ្នកណាជាសាក្សី មហាបុរសត្រាស់ថា សម្រាប់អ្នកក្នុងការៈដែលឲ្យទាន ពលមារទាំងឡាយមានចិត្តជាបន្ទាល់ តែសម្រាប់តថាគតបុគ្គលណាមួយដែលមានចិត្ត ឈ្មោះថា ជាបន្ទាល់ មិនមានក្នុងទីនេះ ទានដែលតថាគតឲ្យហើយក្នុងអត្តភាពដទៃៗ លើកទុកចុះ ក្នុងការៈដែលតថាគតតាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ហើយបានឲ្យទាន ដែលមានវត្ថុក្នុងមួយមុខ ៧០០ មហាប្រឹថពីដ៏ក្រាស់នេះ មិនមានចិត្ត ក៏ធ្វើជាសាក្សីឲ្យ ទើបទ្រង់ដកព្រះហស្តស្តាំចេញក្រៅស្រទាប់ចីវរ ចន្លុលចុះទៅកាន់មហាប្រឹថពី ព្រមដោយព្រះតម្រាស់ថា ក្នុងកាលដែលតថាគត តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ហើយឲ្យសត្តសតកមហាទាន អ្នកបានជាសាក្សី ឬមិនបានទេ ។ មហាប្រឹថពីបានញាប់ញ័រ ហាក់ដូចលិចលង់ពួកមារ ដោយសំឡេង ១០០០ ថា ក្នុងកាលនោះខ្ញុំជាសាក្សី បន្ទាប់អំពីនោះ មហាប្រឹថពីបានពោលថា បពិត្រសិទ្ធត្ថ ទានដែលព្រះអង្គឲ្យហើយ ជាមហាទាន ជាឧត្តមទាន កាលមហាបុរសពិចារណាដល់ទានដែលបានឲ្យ ដោយអត្តភាពជាព្រះវេស្សន្តរ ដំរី

គិរីមេខៈកម្ពស់ ១៥០ យោជន៍ ក៏លុតជង្គង់ចុះ បរិស័ទរបស់មារ នាំគ្នាគេច ទៅកាន់ទិសានុទិស ។ ឈ្មោះថា មារ ២ នាក់ទៅផ្លូវ ១ មិនមាន លះ គ្រឿងប្រដាប់ក្បាល និងសំពត់ដែលស្លៀកដណ្ដប់ គេចទៅចំពោះទិសទាំង ឡាយ ត្រង់ចំពោះមុខៗ ។ គ្រានោះ ពួកទេវតាទាំងឡាយឃើញមារ និងពល គេចទៅហើយ ពោលថា មារបរាជ័យ ចុះចាញ់ព្រះអង្គហើយ សិទ្ធត្ថកុមារ មានជ័យជម្នះហើយ ពួកយើង មក ធ្វើការបូជាការមានជ័យជម្នះ ដូច្នេះ ពួក នាគក៏ប្រកាសដល់ពួកនាគ ពួកគ្រុឌក៏ប្រកាសដល់ពួកគ្រុឌ ពួកទេវតាក៏ ប្រកាសដល់ពួកទេវតា ពួកព្រហ្មក៏ប្រកាសដល់ពួកព្រហ្ម ពួកវិជ្ជាធរ ក៏ ប្រកាសដល់ពួកវិជ្ជាធរ មានដៃកាន់គ្រឿងក្រអូប និងផ្កាជាដើម មកកាន់ ពោធិបល្ល័ង្ក ដែលជាសម្នាក់របស់មហាបុរស កាលមារ និងពលទាំងនោះ គេចទៅយ៉ាងនេះហើយ ។

ក្នុងកាលនោះ ពួកនាគមានចិត្តត្រេកអរ ប្រកាសជ័យជម្នះរបស់ព្រះ មហេសីត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី ទ្រង់មានជ័យជម្នះ មារមាន ចិត្តបាប ចុះចាញ់ហើយ ។

ក្នុងកាលនោះ ពួកគ្រុឌមានចិត្តត្រេកអរ ប្រកាសជ័យជម្នះរបស់ព្រះ មហេសីត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី ទ្រង់មានជ័យជម្នះ មារមាន ចិត្តបាប ចុះចាញ់ហើយ ។

ក្នុងកាលនោះ ពួកទេវតាមានចិត្តត្រេកអរ ប្រកាសជ័យជម្នះរបស់ព្រះ មហេសីត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី ទ្រង់មានជ័យជម្នះ មារមាន

ចិត្តបាប ចុះចាញ់ហើយ ។

ក្នុងកាលនោះ ពួកព្រហ្មមានចិត្តត្រេកអរ ប្រកាសជ័យជម្នះរបស់ព្រះមហេសីត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី ទ្រង់មានជ័យជម្នះ មារមានចិត្តបាប ចុះចាញ់ហើយ ។

ក្នុងកាលនោះ ទេវតាក្នុងម៉ឺនចក្រវាលដ៏សេស បូជាដោយផ្កា គ្រឿងក្រអូប គ្រឿងលាបជាដើម បានឈរពោលសាធុការ មានប្រការផ្សេងៗ កាលព្រះអាទិត្យនៅមានពន្លឺនៅឡើយនោះឯង ព្រះមហាបុរសទ្រង់កម្ចាត់មារនិងពលបានហើយ ដែលពន្លកពោធិព្រឹក្សធ្លាក់ចុះលើចីវរ ដូចត្របកកែវប្រពាលក្រហមបូជា ទ្រង់រឭកបានបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ទ្រង់ញ៉ាំងញាណឲ្យឈមចុះក្នុងបដិច្ចសមុប្បាទក្នុងបច្ឆិមយាម កាលព្រះមហាបុរសទ្រង់ពិចារណាបច្ចយាការ ដែលប្រកបដោយអង្គ ១២ ដោយអនុលោម និងបដិលោម ដោយវដ្តៈ និងវិវដ្តៈ លោកធាតុមួយម៉ឺនញាប់ញ័រ អស់ ១២ ដង រហូតដល់ទឹកទ្រផែនដីជាទីបំផុត ព្រះមហាបុរសទ្រង់ញ៉ាំងលោកធាតុមួយម៉ឺនឲ្យលាន់ឮ និងញាប់ញ័រហើយ ទ្រង់ដឹងច្បាស់ព្រះសព្វញ្ញុតញ្ញាណក្នុងពេលអរុណរះ កាលព្រះមហាបុរសទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយ លោកធាតុមួយម៉ឺន មានការប្រដាប់តាក់តែងហើយ ដោយស្ទើរបស់ទង់ជ័យ និងទង់ជ្វាលា ដែលលើកឡើងត្រង់កណ្ដាប់ចក្រវាលទិសខាងកើត រហូតដល់កណ្ដាប់ចក្រវាលទិសខាងលិច ដែលលើកឡើងក្នុងកណ្ដាប់ចក្រវាលទិសខាងលិច ក៏ដល់កណ្ដាប់ចក្រវាលទិសខាងកើត

ដែលលើកឡើងក្នុងកណ្តាប់ចក្រវាលទិសខាងជើង ក៏ដល់កណ្តាប់ចក្រវាលទិសខាងត្បូង ដែលលើកឡើងក្នុងកណ្តាប់ចក្រវាលទិសខាងត្បូង ក៏ដល់កណ្តាប់ចក្រវាលទិសខាងជើង ចំណែករស្មីរបស់ទង់ជ័យ និងទង់ផ្កាលា ដែលលើកឡើងលើផែនដី បានតាំងនៅទល់គ្នានឹងព្រហ្មលោក រស្មីដែលតាំងនៅក្នុងព្រហ្មលោក ក៏ដល់ផែនដី ដើមឈើផ្កាក្នុងមួយម៉ឺនចក្រវាលក៏ចេញផ្កា ដើមឈើផ្លែ ក៏បានចេញផ្លែ ឈូកដើម ក៏ចេញផ្កាអំពីដើម ឈូកមែក ក៏ចេញផ្កាអំពីមែក ឈូកវល្លិ ក៏ចេញផ្កាអំពីវល្លិ ឈូកសំយុង ក៏ចេញផ្កាក្នុងអាកាស ឈូករួតក៏ទម្លុះផ្ទាំងថ្ម តាំងឡើងត្រួតលើគ្នា ៧ ជាន់ៗ ម៉ឺនលោកធាតុបានរីលទៅ ដូចដុំអំបោះដែលលាអំបោះចេញ និងដូចកម្រាលដែលគេក្រាលល្អហើយ ដូច្នោះ លោកន្តរនរកទំហំ ៥០០ យោជន៍ ក្នុងចន្លោះចក្រវាលទាំងឡាយ មិនធ្លាប់ភ្លឺដោយពន្លឺព្រះអាទិត្យ ៧ ដួង ក៏មានពន្លឺភ្លឺស្វាងតែមួយ មហាសមុទ្រជម្រៅ ៨៤០០០ យោជន៍ ក៏មានរសផ្អែម ទឹកទាំងឡាយមិនហូរ មនុស្សខ្វាក់អំពីកំណើតឃើញរូប មនុស្សថ្លង់អំពីកំណើតបានឮសំឡេង មនុស្សខ្វិនអំពីកំណើតដើរបាន កម្មករណៈទាំងឡាយ មានគ្រឿងចងជាដើម នៃបណ្តាគ្រឿងចង មានឃ្នាងជាដើម បានរបូតទៅ ។ ព្រះមហាបុរសដែលទេវតា និងមនុស្សទាំងឡាយបូជាដោយសម្បត្តិ ដែលប្រកបដោយសិរីប្រមាណមិនបាន ដោយប្រការយ៉ាងនេះ កាលអច្ឆរិយធម៌ដែលគួរអស្ចារ្យទាំងឡាយ មានប្រការផ្សេងៗ ប្រាកដហើយ បានចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ទើបទ្រង់បន្លឺនូវឧទាន ដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ថា

កាលតថាគតមិនទាន់ជួបប្រទះ ( ពោធិញ្ញាណ វេលាតែ ) ស្វះស្វែង
រកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់
សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។
នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នក
នឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺ
កិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូល
ផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់
ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជា
គ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ឋានៈមានប្រមាណប៉ុណ្ណេះ ផ្តើមតាំងអំពីតុសិតបុរី រហូតដល់ត្រាស់ដឹង
នូវសព្វញ្ញុតញ្ញាណ ត្រង់មណ្ឌលពោធិព្រឹក្សនេះ ឈ្មោះថា អវិទូរេនិទាន
ដោយប្រការដូច្នេះ ។

អវិទូរេនិទាន ចប់

## សន្តិកេនិទាន

សន្តិកេនិទាន លោកពោលថា ព្រះមានព្រះភាគ កាលគង់នៅក្នុងទី
នោះៗ យ៉ាងនេះថា ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន ដែលជាអារាម
របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី និងពោលថា គង់នៅក្នុងកូដាគារ-
សាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ដូច្នេះជាដើម សន្តិកេនិទាន តែង
មានក្នុងទីនោះៗ ឯង ។ លោកពោលយ៉ាងនេះក៏ពិត តែសន្តិកេនិទាន គប្បី

ជ្រាបយ៉ាងនេះ ចាប់អំពីខាងដើមតទៅថា

ព្រះមានព្រះភាគ គង់លើបល្ល័ង្កជ័យ បន្លឺឧទាននេះហើយ មានព្រះតម្រិះដូច្នេះថា តថាគតអន្ទោលទៅអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ក៏ព្រោះហេតុនៃបល្ល័ង្កនេះ តថាគតកាត់ក្បាលដែលប្រដាប់ហើយត្រង់ដងក ឲ្យទៅជាទាន អស់កាលមានប្រមាណប៉ុណ្ណោះ ហេតុនៃបល្ល័ង្កនេះ តថាគតខ្វេះភ្នែក ដែលបន្តក់ថ្នាំល្អហើយ និងខ្វេះសាច់បេះដូង ឲ្យទៅជាទាន តថាគតឲ្យបុត្រ ដូចជាជាលីកុមារ ឲ្យធីតា ដូចជាកណ្ហាជិនាកុមារី និងឲ្យភរិយា ដូចជាមទ្រីទេវី ដើម្បីឲ្យជាខ្ញុំបម្រើរបស់អ្នកដទៃ ព្រោះហេតុនៃបល្ល័ង្កនេះ ។ បល្ល័ង្កនេះ ជាបល្ល័ង្កជ័យ ជាបល្ល័ង្កដ៏ប្រសើររបស់តថាគត ការត្រិះរិះរបស់តថាគតដែលអង្គុយលើបល្ល័ង្កនេះ មិនទាន់បរិបូណ៌ដរាបណា តថាគតមិនក្រោកឡើងចាកបល្ល័ង្កនេះដរាបនោះ ដូច្នេះ ទើបទ្រង់ចូលសមាបត្តិច្រើនសែនកោដិ លើបល្ល័ង្កនោះឯង អស់មួយសប្តាហ៍ ដែលលោកពោលថា

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់សោយវិមុត្តិសុខដោយបល្ល័ង្ក ១ អស់មួយសប្តាហ៍ ក្នុងកាលនោះ ទេវតាពួកខ្លះ កើតបរិវិតក្កថា ថ្ងៃនេះ ព្រះសិទ្ធត្ថនៅមានកិច្ចត្រូវធ្វើឬហ្ន៎ ព្រោះមិនទាន់លះសេចក្តីអាល័យក្នុងបល្ល័ង្ក ។ ព្រះសាស្តាទ្រង់ជ្រាបវិតក្ករបស់ទេវតាទាំងឡាយ ដើម្បីរម្ងាប់បរិវិតក្ករបស់ទេវតាទាំងនោះ ទើបទ្រង់ហោះឡើងទៅកាន់អាកាស ទ្រង់សម្តែងយមកបា្បដិហារ្យ ពិតហើយ យមកបា្បដិហារ្យដែលទ្រង់ធ្វើក្នុងមហាពោធិមណ្ឌលក្តី បាដិហារ្យដែលទ្រង់ធ្វើក្នុងសមាគមព្រះញាតិក្តី បាដិហារ្យដែលទ្រង់ធ្វើក្នុង

សមាគមអ្នកបាជលីបុត្តក្តី ក៏ដូចគ្នានឹងយមកបា្បដិហារ្យត្រង់មណ្ឌលគណ្ឌម្ព-ព្រឹក្ស គឺក្រោមដើមស្វាយនោះឯង ។

ព្រះសាស្តា កាលទ្រង់រម្ងាប់បរិវិតក្ករបស់ទេវតាទាំងឡាយ ដោយបាដិហារ្យនេះហើយ ទ្រង់ប្រថាប់ឈរទិសខាងជើងឆៀងទៅខាងកើតបន្តិចអំពីបល្ល័ង្ក ទ្រង់ព្រះតម្រិះថា តថាគតដឹងច្បាស់នូវសព្វញ្ញុតញ្ញាណលើបល្ល័ង្កនេះហ្ន៎ ទើបបើកព្រះនេត្រទាំង ២ មិនប៉ប្រិច សម្លឹងមើលបល្ល័ង្កដែលជាទីសម្រេចផលនៃបារមី ដែលទ្រង់បំពេញអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ទ្រង់សម្ងំអស់មួយសប្តាហ៍ ទីនោះ ឈ្មោះថា អនិមិសចេតិយ ។

លំដាប់នោះ ទ្រង់និម្មិតទីចង្ក្រមក្នុងចន្លោះទីបល្ល័ង្ក និងទីប្រថាប់ឈរហើយទ្រង់ចង្ក្រមក្នុងរតនចង្ក្រម ដែលលាតសន្ធឹងពីកើតទៅលិច ទ្រង់សម្ងំមួយសប្តាហ៍ ទីនោះ ឈ្មោះថា រតនចង្កមចេតិយ ។

តែក្នុងសប្តាហ៍ទី ៤ ទេវតាទាំងឡាយនិម្មិតផ្ទះកែវក្នុងទិសពាយព្យនៃដើមពោធិ៍ ប្រថាប់លើបល្ល័ង្កក្នុងផ្ទះកែវនោះ ហើយទ្រង់ពិចារណាព្រះអភិធម្មបិដក និងសមន្តប្បដ្ឋានអនន្តន័យក្នុងផ្ទះកែវនេះ ដោយពិសេស ទ្រង់សម្ងំអស់មួយសប្តាហ៍ ចំណែកអភិធម្មាចារ្យពោលថា ផ្ទះដែលវិចិត្រដោយកែវ ឈ្មោះថា រតនឃរៈ ទីដែលទ្រង់ពិចារណាបករណ៍ទាំង ៧ ឈ្មោះថា រតនឃរៈ ។ ព្រោះបរិយាយទាំង ២ នេះ រមែងប្រើបានក្នុងទីនេះ ដូច្នោះពាក្យទាំង ២ នេះ គួរកាន់យកនោះឯង ។ ចាប់តាំងអំពីនោះមក ទីនោះ ឈ្មោះថា រតនឃរចេតិយ ។

ព្រះសាស្តា ទ្រង់សម្ងំក្នុងទីជិតពោធិព្រឹក្សនោះឯង អស់ ៤ សប្តាហ៍ ដោយប្រការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ ទើបយាងចេញអំពីមណ្ឌលពោធិព្រឹក្ស ចូលទៅកាន់អជបាលនិគ្រោធ ទ្រង់ពិចារណាព្រះធម៌ និងសោយវិមុត្តិសុខត្រង់ដើមអជបាលនិគ្រោធនោះ ។

សម័យនោះ ទេវបុត្តមារជាប់តាមអស់កាលមានប្រមាណប៉ុណ្ណេះ សម្លឹងរកទោស មិនបានឃើញកំហុសណាមួយរបស់ព្រះសិទ្ធត្ថនេះ ទើបដល់នូវទោមនស្សថា ឥឡូវនេះ សិទ្ធត្ថនេះ កន្លងផុតវិស័យរបស់អញហើយ ទើបអង្គុយត្រង់ផ្លូវធំ គិតដល់ហេតុ ១៦ ប្រការ ទើបគូសគំនូស ១៦ លើផែនដី គឺគិតថា អញមិនបានបំពេញទានបារមីដូចសិទ្ធត្ថនេះ ដោយហេតុនោះ ទើបអញមិនដូចសិទ្ធត្ថនេះ ហើយគូសគំនូស ១ ។ ម្យ៉ាងទៀត គិតថា អញមិនបានបំពេញសីលបារមី ១ នេក្ខម្មបារមី ១ បញ្ញាបារមី ១ វីរិយបារមី ១ ខន្តិបារមី ១ សច្ចបារមី ១ អធិដ្ឋានបារមី ១ មេត្តាបារមី ១ ឧបេក្ខាបារមី ១ ដូចសិទ្ធត្ថនេះឡើយ ដោយហេតុនោះ ទើបអញមិនដូចសិទ្ធត្ថនេះ ហើយគូសគំនូសទី ២ ដល់ ១០ ។ ម្យ៉ាងទៀត គិតថា អញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យនៃការត្រាស់ដឹង អាសយានុសយញ្ញាណ ១ ឥន្ទ្រិយបរោបរិយញ្ញាណ ១ មហាករុណាសមាបត្តិញ្ញាណ ១ យមកប្បាដិហារិយញ្ញាណ ១ អនាវរណញ្ញាណ ១ សព្វញ្ញុតញ្ញាណ ដែលមិនទូទៅដល់អ្នកដទៃ ១ ដូចសិទ្ធត្ថនេះ ដោយហេតុនោះ ទើបអញមិនដូចសិទ្ធត្ថនេះ រួចគូសគំនូសទី ១១ ដល់ទី ១៦ ។ កាលទេវបុត្តមារនោះ អង្គុយគូសគំនូស

១៦ ត្រង់ផ្លូវធំ ដោយប្រការដូច្នេះហើយ គ្រានោះ ធីតាមារទាំង ៣ គឺនាងតណ្ហា នាងអរតី និងនាងរាគានិយាយគ្នាថា បិតារបស់ពួកយើងមិនប្រាកដឥឡូវនេះនៅទីណាហ្ន៎ ទើបរកមើលបានឃើញទេវបុត្តមារនោះកំពុងទោមនស្សអង្គុយគូសផែនដី ទើបនាំគ្នាទៅកាន់សម្នាក់របស់បិតា សួរថា បពិត្របិតាព្រោះហេតុអ្វី ទើបបិតាដល់នូវភាពជាទុក្ខ សៅហ្មងក្នុងចិត្ត ទេវបុត្តមារពោលថា នែកូន មហាសមណៈនេះ កន្លងផុតអំណាចរបស់យើងហើយ បិតារង់ចាំមើលអស់កាលមានប្រមាណប៉ុណ្ណោះ នៅតែមិនឃើញឱកាសរបស់សមណៈនេះ ដោយហេតុនោះ ទើបបិតាជាទុក្ខទោមនស្សក្នុងចិត្ត ។ មារធីតាពោលថា បើដូច្នោះ សូមបិតាកុំទោមនស្សឡើយ ពួកខ្ញុំនឹងធ្វើសមណៈនោះឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក ។ ទេវបុត្តមារពោលថា នែបុត្រី បុគ្គលណាម្នាក់ ក៏មិនអាចធ្វើសមណៈនេះឲ្យនៅក្នុងអំណាចបានដែរ បុរសនេះតាំងនៅក្នុងសទ្ធាដែលមិនញាប់ញ័រ ។ មារធីតាពោលថា បពិត្របិតា ពួកខ្ញុំជាស្រី ពួកខ្ញុំនឹងយកអន្ទាក់ គឺរាគៈជាដើម ចងមហាសមណៈឲ្យជាប់ ហើយនាំមកឲ្យឥឡូវនេះឯង សូមបិតាកុំគិតថ្វីឡើយ ។ ពោលហើយ ទើបធីតាមារទាំង ៣ នោះ ចេញអំពីទីនោះ ទៅរកព្រះសាស្តា ក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងបម្រើបាតជើងរបស់ព្រះអង្គ ។ ព្រះសាស្តា មិនបានបើកព្រះនេត្រមើល មានព្រះមនសៈបង្អោនទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏កំពូល គង់ប្រថាប់សោយសុខ ដែលកើតអំពីវិវេកប៉ុណ្ណោះ ។ មារធីតាគិតទៀតថា បំណងរបស់បុរសមិនដូចគ្នាទេ បុរសខ្លះ ស្រឡាញ់កុមារីជំទង់ បុរសខ្លះ

ស្រឡាញ់ស្រីដែលនៅក្នុងបឋមវ័យ បុរសខ្លះ ស្រឡាញ់ស្រីដែលតាំងនៅក្នុងមជ្ឈិមវ័យ បុរសខ្លះ ស្រឡាញ់ស្រីដែលតាំងនៅក្នុងបច្ឆិមវ័យ កាលបើដូច្នោះ ពួកយើងគួរប្រលោមដោយរូបច្រើនប្រការ ដូច្នេះហើយ ទើបមារធីតាម្នាក់ៗ និម្មិតអត្តភាពជាមួយរយៗ ដោយរូបស្រ្តីជំទង់ ស្រ្តីមិនទាន់ប្រសូត ស្រ្តីប្រសូតម្តង ស្រ្តីប្រសូត ២ ដង ស្រ្តីកណ្តាលមនុស្ស និងស្រ្តីវ័យចំណាស់ ចូលទៅរកព្រះសាស្តា អស់ ៦ ដង ហើយពោលថា បពិត្រព្រះសមណៈ ពួកខ្ញុំនឹងបម្រើបាទារបស់ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់មិនដាក់ព្រះហឫទ័យដល់សេចក្តីនោះ ដោយប្រការដែលទ្រង់បង្អោនទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏កំពូល ។ ឯអាចារ្យពួកខ្លះពោលថា ព្រះសាស្តាកាលទ្រង់ឃើញធីតាមារទាំងនោះចូលមករក ដោយភាពជាស្រីធំ ទើបទ្រង់អធិដ្ឋានថា ស្រីទាំងនេះ ចូរជាស្រីធ្មេញបាក់ សក់ស្កូវយ៉ាងនេះៗ ពាក្យរបស់កេចិអាចារ្យនោះ មិនគួរកាន់យក ព្រោះព្រះសាស្តា ទ្រង់មិនធ្វើអធិដ្ឋានបែបនោះ ។ ព្រះមានព្រះភាគត្រាស់ថា ចូរពួកនាងចៀសចេញទៅ ហេតុអ្វីពួកនាងព្យាយាមបែបនេះ ឈ្មោះថា កម្មបែបនេះ គួរធ្វើចំពោះមុខបុគ្គលដែលមិនទាន់ប្រាសចាករាគៈជាដើម តែតថាគតលះរាគៈ ទោសៈ មោហៈបានហើយ ទើបទ្រង់ប្រារព្ធដល់ការលះកិលេសរបស់ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ត្រាស់ព្រះគាថា ២ គាថា ក្នុងធម្មបទ ពុទ្ធវគ្គ ដូច្នេះថា

ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គ

នោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចររកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ។ តណ្ហា ដែលមានបណ្ដាញផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចររកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ដូច្នេះ ។

មារធីតាទាំងនោះពោលពាក្យជាដើមថា បានឮថា បិតារបស់ពួកយើងនិយាយពិត ព្រះអរហន្តសុគត ជាបុគ្គលដែលបុគ្គលណាម្នាក់ នាំទៅមិនបានងាយឡើយក្នុងលោកដោយរាគៈ ហើយបាននាំគ្នាទៅកាន់សម្នាក់របស់បិតា ។

ឯព្រះមានព្រះភាគ ទ្រង់សម្ងំនៅត្រង់អជបាលនិគ្រោធនោះមួយសប្ដាហ៍ ហើយបានយាងទៅត្រង់គល់មុចលិន្ទ ក្នុងទីនោះ ភ្លៀងរលឹមកើតឡើង ៧ ថ្ងៃ មុចលិន្ទនាគរាជព័ទ្ធដោយរង្វេល ៧ ជុំ ដើម្បីការពាររងាជាដើម សោយវិមុត្តិសុខ ហាក់បីដូចគង់នៅក្នុងព្រះគន្ធកុដិ ដែលមិនចង្អៀត ទ្រង់សម្ងំមួយសប្ដាហ៍ ហើយយាងទៅកាន់ដើមរាជាយតនៈ គង់សោយវិមុត្តិសុខត្រង់ដើមរាជាយតនៈនោះមួយសប្ដាហ៍ ដោយលំដាប់កាលប្រមាណប៉ុណ្ណេះ សប្ដាហ៍ទាំងឡាយ ៧ ក៏គ្រប់បរិបូណ៌ ។

ក្នុងចន្លោះនេះ មិនមានការជម្រះ លុបលាងព្រះភក្ត្រ មិនមានកិច្ចបដិបត្តិសរីរៈ មិនមានកិច្ចដោយព្រះក្រយាហារ ទ្រង់សម្ងំដោយឈានសុខ មគ្គសុខ

និងផលសុខ ។ ក្នុងថ្ងៃទី ៤៩ ដែលជាថ្ងៃចុងក្រោយនៃសប្តាហ៍ទី ៧ នោះ ព្រះសាស្តាគង់ប្រថាប់ត្រង់ដើមរាជាយតនៈនោះ ទ្រង់មានបំណងនឹងស្រេចស្រង់ព្រះភក្ត្រ ។ សក្កទេវរាជស្តេចទេវតា ទ្រង់បាននាំផ្លែសម៉ មកថ្វាយដោយព្រះអង្គឯង ។ ព្រះសាស្តាសោយផ្លែសម៉នោះ ។ ដោយហេតុនោះ ទើបទ្រង់មានការបន្ទោរបង់ព្រះឧច្ចារៈ ។ លំដាប់នោះ សក្កទេវរាជបានថ្វាយឈើស្ទន់ឈ្មោះនាគលតា និងទឹកលុបព្រះភក្ត្រដល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ទំពាឈើស្ទន់ លុបព្រះភក្ត្រដោយទឹកក្នុងអនោតត្តស្រះ ហើយគង់ត្រង់គល់រាជាយតនៈនោះឯង ។

សម័យនោះ ពាណិជពីរនាក់ ឈ្មោះតបុស្សៈ និងភល្លិកៈ មកអំពីឧក្កលាជនបទ ទៅកាន់មជ្ឈិមប្រទេស ដោយរទេះ ៥០០ ត្រូវទេវតាដែលជាញាតិសាលោហិតរបស់ខ្លួនបិទផ្លូវរទេះធ្វើឲ្យឧស្សាហ៍ក្នុងការប្រគេនអាហារដល់ព្រះសាស្តា ទើបកាន់យកសត្តុវដុំ និងនំធ្វើអំពីទឹកឃ្មុំ ហើយចូលទៅជិតព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់អនុគ្រោះទទួលអាហារនេះចុះ ហើយឈរក្នុងទីសមគួរ ។ ព្រោះបាត្របាត់ទៅក្នុងថ្ងៃទទួលមធុបាយាសនោះឯង ទើបព្រះសាស្តាទ្រង់ព្រះតម្រិះថា ព្រះតថាគតទាំងឡាយ រមែងមិនទទួលផ្ទាល់នឹងដៃ តថាគតទទួលដូចម្តេចហ្ន៎ ។

គ្រានោះ មហារាជទាំង ៤ មកអំពីទិសទាំង ៤ ដឹងព្រះតម្រិះរបស់ព្រះសាស្តា ទើបបង្អោនបាត្រ ដែលសម្រេចដោយកែវឥន្ទនិល ចូលទៅថ្វាយ ។ ព្រះសាស្តាទ្រង់បដិសេធបាត្រទាំងនោះ ។ ទើបមហារាជបង្អោនបាត្រ ៤ ដែល

សម្រេចដោយថ្ម មានពណ៌ដូចសណ្តែកបាយចូលទៅថ្វាយ ។ ដើម្បីអនុគ្រោះទេវបុត្រ ៤ អង្គ ទើបទ្រង់ទទួលបាត្រទាំង ៤ ហើយដាក់ត្រួតលើគ្នា អធិដ្ឋានថា បាត្រនេះ ចូរជាបាត្រតែមួយ ។ ទើបបាត្រទាំង ៤ មានស្នាមប្រាកដត្រង់កណ្តាប់មាត់បាត្រ រួមជាបាត្រតែមួយ ជាបាត្រខ្នាតកណ្តាល ។ ព្រះមុនីទ្រង់ទទួលកត្តុជាយបាត្រដែលសម្រេចដោយសិលា ដែលឃើញប្រចក្សនោះ សោយហើយ ទ្រង់ធ្វើអនុមោទនា ។ ពាណិជពីរនាក់បងប្អូនដល់នូវព្រះពុទ្ធ ព្រះធម៌ជាសរណៈ ជាទ្វេវាចិកឧបាសក បន្ទឹវាចាដល់សរណៈទាំង ២ ។ លំដាប់នោះ កាលពាណិជទាំង ២ នោះក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ប្រទានឋានៈដែលគប្បីប្រណិប័តន៍ណាមួយ ដល់ខ្ញុំព្រះអង្គទាំង ២ ចុះ ទើបព្រះសាស្តា ទ្រង់យកព្រះហស្តស្តាំអង្អែលព្រះសិរសៈរបស់ទ្រង់ ហើយប្រទានព្រះកេសធាតុទាំងឡាយឲ្យពាណិជទាំង ២ នោះ ទើបពាណិជទាំង ២ សាងព្រះចេតិយបញ្ចុះព្រះធាតុទុកខាងក្នុង នាក្រុងរបស់ខ្លួន ។

ចាប់តាំងអំពីនោះ ព្រះសម្មាសម្ពុទ្ធ យាងទៅកាន់ដើមអជបាលនិគ្រោធទៀត ទ្រង់គង់ត្រង់ដើមនិគ្រោធ ។ លំដាប់នោះ ព្រះសម្មាសម្ពុទ្ធអង្គនោះ លុះទ្រង់គង់ត្រង់ដើមនិគ្រោធនោះប៉ុណ្ណោះ ក៏ទ្រង់ពិចារណាធម៌ដែលទ្រង់បាក់ធ្លុះហើយ ជាធម៌ជ្រាលជ្រៅ ទ្រង់ព្រះតម្រិះថា ធម៌នេះ ព្រះពុទ្ធទាំងពួងសន្សំហើយ តថាគតបានសម្រេចហើយ ទើបកើតនូវការត្រិះរិះដែលដល់នូវអាការគឺមិនបំណាងសម្តែងធម៌ដល់ជនដទៃ ។ គ្រានោះ សហម្បតីព្រហ្មត្រាស់ថា អ្នកដ៏ចម្រើនទាំងឡាយ លោកនឹងវិនាសហ្ន៎ អ្នកដ៏ចម្រើន លោកនឹងវិនាសហ្ន៎

ហើយទ្រង់នាំសក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចវសវត្តី និង ស្តេចមហាព្រហ្មក្នុងម៉ឺនចក្រវាល ទៅគាល់ព្រះសាស្តា ទូលអារាធនាឲ្យទ្រង់ សម្តែងធម៌ ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មេត្តា សម្តែងធម៌ ព្រះសាស្តាទ្រង់បានឲ្យបដិញ្ញាដល់សហម្បតីព្រហ្មនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ជាបឋមដល់នរណាហ្ន៎ ទ្រង់ញ៉ាំងព្រះតម្រិះឲ្យកើតឡើងថា អាឡារតាបសជាបណ្ឌិត អាឡារតាបសនោះ នឹងដឹងទូទៅដល់ធម៌នេះដោយរួសរាន់ ហើយទ្រង់ប្រមើលមើលទៀត បានជ្រាបថា អាឡារតាបសនោះធ្វើកាលកិរិយាបាន ៧ ថ្ងៃហើយ ទើបទ្រង់អាវជ្ជនៈដល់ ឧទកតាបស ទ្រង់បានជ្រាបថា ឧទកតាបសនោះ បានធ្វើកាលកិរិយាទៅហើយ កាលពីព្រលប់ម្សិលមិញនេះ ទើបទ្រង់មនសិការប្រារព្ធដល់បញ្ច-វគ្គិយថា បញ្ចវគ្គិយមានឧបការៈច្រើនដល់តថាគត ទើបទ្រង់អាវជ្ជនៈថា ឥឡូវនេះ បញ្ចវគ្គិយនោះ នៅឯណាហ្ន៎ បានជ្រាបថា នៅត្រង់ព្រៃឥសិបតន-មិគទាយវ័ន ទៀបក្រុងពារាណសី ទ្រង់ព្រះតម្រិះថា តថាគតនឹងទៅត្រង់ព្រៃឥសិបតនមិគទាយវ័ននោះ ហើយសម្តែងធម្មចក្រ ទើបយាងទៅបិណ្ឌបាតដោយជុំវិញ មិនឆ្ងាយអំពីពោធិមណ្ឌលនោះ អស់ ២-៣ ថ្ងៃ ទ្រង់ព្រះតម្រិះថា តថាគតនឹងទៅកាន់ក្រុងពារាណសីក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ពាក់កណ្តាលខែអាសាឍ ។ លុះដល់ថ្ងៃចាតុទ្ទសី ១៤ កើត ក្នុងពេលបច្ចូសសម័យរាត្រីកាលអស់ហើយ ក្នុងពេលព្រឹក ទ្រង់កាន់បាត្រ និងចីវរ យាងទៅ រួចទ្រង់ធ្វើដំណើរទៅអស់សម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់ជួបឧបកាជីវកក្នុងរវាង

ផ្លូវ ទើបត្រាស់ប្រាប់កាលដែលទ្រង់ជាព្រះពុទ្ធដល់ឧបកាជីវកនោះ ហើយបាន យាងទៅដល់ព្រៃឥសិបតនមិគទាយវ័ន ក្នុងវេលាល្ងាចនោះឯង ។ បញ្ចវគ្គិយ ឃើញព្រះតថាគតយាងមកអំពីចម្ងាយនោះឯង ទើបធ្វើកតិកាគ្នាថា នែអ្នក ទាំងឡាយ ព្រះសមណគោតមនេះ វិលមកដើម្បីភាពជាបុគ្គលល្មោភក្នុង បច្ច័យ មានកាយសម្បូរ មានឥន្ទ្រិយផូរផង់ មានពណ៌សម្បុរដូចមាស កំពុង យាងមក យើងមិនចាំបាច់ធ្វើសាមីចិកម្ម អភិវាទនកម្មជាដើម ដល់ព្រះ សមណគោតមនេះឡើយ ។ តែដោយសារទ្រង់ប្រសូតក្នុងត្រកូលខ្ពង់ខ្ពស់ យើងគួរតែរៀបចំអាសនៈ ដោយហេតុនោះ ពួកយើងនឹងក្រាលត្រឹមតែអាសនៈ ដើម្បីទ្រង់ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា បញ្ចវគ្គិយនេះគិតដូចម្តេចហ្ន៎ ទ្រង់ ជ្រាបការគិតដោយព្រះញាណ ដែលអាចដឹងវារៈចិត្តរបស់សត្វលោក ព្រម ទាំងទេវលោក ។ លំដាប់នោះ ទើបទ្រង់បង្អោនមេត្តាចិត្តដែលផ្សាយទៅដោយ មិនចំពោះក្នុងពួកទេវតា និងមនុស្សទាំងពួង ហើយទ្រង់ផ្សាយមេត្តាចិត្តទៅ ។ បញ្ចវគ្គិយទាំងនោះ ដែលព្រះសាស្តាទ្រង់ឲ្យពាល់ត្រូវហើយដោយមេត្តាចិត្ត កាលទ្រង់ចូលទៅជិត មិនអាចតាំងនៅក្នុងកតិការបស់ខ្លួន នាំគ្នាធ្វើកិច្ចទាំង-ឡាយ មានការអភិវាទ និងការក្រោកទទួលជាដើម តែមិនទាន់ដឹងថា ព្រះ សាស្តាជាព្រះសម្មាសម្ពុទ្ធនៅឡើយ ទើបប្រើវាចាហៅដោយឈ្មោះ និងដោយ ពាក្យថាអាវុសោតែម្យ៉ាង ។ គ្រានោះ ព្រះសាស្តាទ្រង់ញ៉ាំងបញ្ចវគ្គិយទាំង នោះ ឲ្យដឹងថា ទ្រង់ជាព្រះពុទ្ធហើយ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ កុំហៅតថាគតដោយឈ្មោះ និងដោយវាទៈថា អាវុសោ

ឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធ ដូច្នេះហើយ គង់លើពុទ្ធាសនៈដ៏បវរដែលគេតាក់តែង កាលផ្កាយនក្ខត្តឫក្សនៃខែឧត្តរាសាឡ្ហ គឺខែទុតិយាសាឍកំពុងគោចរទៅ ទ្រង់ចោមរោមដោយព្រហ្ម ១៨ កោដិ បានត្រាស់ហៅបញ្ចវគ្គិយមក ទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ។ បណ្តាបញ្ចវគ្គិយទាំងនោះ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរបញ្ជូនញាណទៅតាមក្រសែនៃព្រះធម្មទេសនាក្នុងកាលចប់ព្រះសូត្រ បានតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ។ ព្រះសាស្តាទ្រង់ចូលវស្សាក្នុងព្រៃឥសិបតនមិគទាយវ័ននោះឯង ស្អែកឡើង ទ្រង់គង់ទូន្មានព្រះវប្បៈក្នុងលំនៅនោះឯង ព្រះថេរៈ ៤ រូបត្រាច់ទៅបិណ្ឌបាត ។ ព្រះវប្បត្ថេរ បានសម្រេចសោតាបត្តិផលក្នុងពេលព្រឹកនោះឯង ។ ដោយឧបាយនេះឯង ទ្រង់ញុំាងព្រះភទ្ទិយត្ថេរឲ្យតាំងនៅក្នុងសោតា-បត្តិផលក្នុងថ្ងៃស្អែកឡើង ព្រះមហានាមត្ថេរក្នុងថ្ងៃស្អែកឡើង និងព្រះអស្សជិត្ថេរក្នុងថ្ងៃស្អែកបន្ទាប់មកទៀត រួមសេចក្តីថា ទ្រង់ញុំាងព្រះថេរៈទាំងពួង ឲ្យតាំងនៅក្នុងសោតាបត្តិផលហើយ ក្នុងតិថីទី ៥ នៃបក្ខ បានធ្វើព្រះថេរៈទាំង ៥ ប្រជុំគ្នា ហើយទ្រង់សម្តែងអនត្តលក្ខណសូត្រ ក្នុងពេលចប់ទេសនា ព្រះថេរៈទាំង ៥ តាំងនៅក្នុងអរហត្ត ។

គ្រានោះ ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យរបស់យសកុលបុត្រ កុល-បុត្រនេះនឿយណាយក្នុងផ្ទះ ចេញទៅទាំងកណ្តាលរាត្រី ទើបត្រាស់ហៅថា មកចុះយស ហើយឲ្យតាំងនៅក្នុងសោតាបត្តិផល នារាត្រីនោះឯង ។ ស្អែកឡើង ឲ្យតាំងនៅក្នុងអរហត្ត ហើយទ្រង់ញុំាងជនដទៃទៀត ៥៤ នាក់ ដែល

ជាសម្លាញ់របស់យសនោះឲ្យបព្វជ្ជា ដោយឯហិភិក្ខុ ហើយឲ្យសម្រេចអរហត្ត ។ កាលព្រះអរហន្ត ៦១ អង្គ កើតឡើងក្នុងលោក ដោយប្រការយ៉ាងនេះហើយ លុះចេញវស្សាបវារណាហើយ ព្រះសាស្តាទ្រង់បញ្ជូនភិក្ខុ ៦០ អង្គនោះទៅក្នុងទិសទាំងឡាយ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅ ចំណែកព្រះអង្គយាងទៅកាន់ឧរុវេលាប្រទេស ក្នុងរវាងផ្លូវ បានទូន្មានភទ្ទវគ្គិយកុមារ ៣០ នាក់ ក្នុងព្រៃកប្បាស ។ បណ្តាភទ្ទវគ្គិយកុមារទាំងនោះ ទាបបំផុត ជាព្រះសោតាបន្ន ខ្ពស់បំផុត ជាអនាគាមី ។ ទ្រង់ឲ្យភទ្ទវគ្គិយកុមារទាំងនោះបព្វជ្ជាដោយឯហិភិក្ខុដូចគ្នា ហើយទ្រង់បញ្ជូនទៅកាន់ទិសទាំងឡាយ ហើយយាងទៅកាន់តំបន់ឧរុវេលា ទ្រង់សម្តែងបាដិហារ្យ ៣៥០០ ទូន្មានជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម មានបរិវារ ១០០០ ឲ្យបព្វជ្ជាជាឯហិភិក្ខុដូចគ្នា ហើយឲ្យអង្គុយត្រង់គយាសីសប្រទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ដែលព្រះអរហន្ត ១០០០ ចោមរោម ទ្រង់ព្រះតម្រិះថា នឹងដោះនូវបដិញ្ញាដែលទ្រង់ឲ្យដល់ព្រះបាទពិម្ពិសារ ទើបយាងទៅកាន់លដ្ឋិវនឧទ្យាន ក្នុងនគររាជគ្រឹះ ។ ព្រះរាជាទ្រង់បានដំណឹងអំពីសម្នាក់របស់ឧទ្យានបាលថា ព្រះសាស្តាយាងមក ទើបទ្រង់ចោមរោមដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ ចូលទៅគាល់ព្រះសាស្តា ។ កាលផ្ទៃព្រះបាទដែលវិចិត្រដោយចក្រ កំពុងបញ្ចេញពន្លឺ ឈានឡើង ហាក់បីដូចពិតានមាស ទើបទ្រង់ក្រាបទៀបព្រះបាទារបស់ព្រះតថាគត រួចគង់ប្រថាប់នាចំណែកម្ខាង មួយអន្លើដោយបរិស័ទ ។ គ្រានោះ ព្រាហ្មណ៍

និងគហបតីទាំងនោះ គិតយ៉ាងនេះថា ព្រះមហាសមណៈ ប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ឧរុវេលកស្សបៈ ឬឧរុវេកស្សបៈ ប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមហាសមណៈ ព្រះសាស្តាទ្រង់ជ្រាបបរិវិតក្ករបស់ព្រាហ្មណ៍ និងគហបតីទាំងនោះ ទើបត្រាស់នឹងព្រះថេរៈ ដោយព្រះគាថាថា

អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើអ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោលចេញ ។ ម្នាលកស្សបៈ តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើង ដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី ដូច្នេះ ។

ឯព្រះថេរៈដឹងព្រះបំណងរបស់ព្រះសាស្តា ទើបពោលគាថានេះថា

ជនទាំងឡាយ តែងពោលសរសើរចំពោះនូវកាមទាំងឡាយ គឺរូបសំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយផង ព្រោះការបូជាខ្ញុំព្រះអង្គដឹងថា កាមគុណ មានរូបជាដើមនេះ ជាគ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះហេតុដូច្នោះ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការបូជាតូច ( គឺការគោរពភ្លើងរាល់ថ្ងៃ ) ដូច្នេះ ។

ដើម្បីប្រកាសភាពដែលខ្លួនជាសាវ័ក ទើបយកថ្ងាសដាក់ត្រង់ខ្នងព្រះបាទព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ដូច្នេះហើយ ហោះឡើងទៅកាន់អាកាស ៧ ដង គឺ ១ ជួរដើមត្នោត ២ ជួរដើមត្នោត រហូតដល់ ៧ ជួរដើមត្នោតហើយ ចុះមកថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងចំណែកម្ខាង ។ មហាជនបានឃើញនូវ

បាដិហារ្យនោះហើយ នាំគ្នាពណ៌នាគុណរបស់ព្រះសាស្តាថា គួរអស្ចារ្យ ព្រះពុទ្ធទ្រង់មានអានុភាពច្រើន សូម្បីឧបុវេលកស្សប: ជាអ្នកមានទិដ្ឋិរឹងត្អឹងយ៉ាងនេះ សម្គាល់ខ្លួនថាជាព្រះអរហន្ត ក៏ត្រូវព្រះតថាគតទម្លាយសំណាញ់គឺទិដ្ឋិ ហើយទូន្មាន ។ ព្រះសាស្តាត្រាស់ថា តថាគតទូន្មានឧរុវេលាកស្សប: តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងអតីតកាល ឧរុវេលាកស្សប:នេះ ក៏ត្រូវតថាគតទូន្មានហើយដូចគ្នា ហើយត្រាស់មហានារទកស្សបជាតក ព្រោះអត្ថុប្បត្តិហេតុនេះ ទ្រង់ក៏ប្រកាសសច្ច: ៤ ។ ព្រះបាទមគធរាជទ្រង់តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយបរិវារ ១១ ម៉ឺន ១ ម៉ឺនទៀត ប្រកាសខ្លួនជាឧបាសក ។ ព្រះរាជាប្រថាប់នៅក្នុងសម្នាក់ព្រះសាស្តា ហើយទ្រង់ប្រកាសហេតុដែលមកនូវសេចក្តីសប្បាយព្រះហឫទ័យ ( សេចក្តីប្រាថ្នា ) ៥ ប្រការ[១] ហើយទ្រង់ដល់នូវសរណ: និមន្តព្រះសាស្តាសោយក្នុងថ្ងៃស្អែក ហើយទ្រង់ក្រោកចាកអាសន: ធ្វើប្រទក្សិណព្រះសាស្តាហើយ ចៀសចេញទៅ ។

ស្អែកឡើង ពួកមនុស្សអ្នកក្រុងរាជគ្រឹះ ប្រមាណ ១៨ កោដិ ទាំងដែលបានឃើញព្រះសាស្តា ទាំងមិនបានឃើញ មានបំណងនឹងឃើញព្រះតថាគត

---

១- បំណង ៥ ប្រការ គឺសូមឲ្យបានអភិសេកក្នុងរាជសម្បត្តិ ១ សូមឲ្យព្រះអរហន្តសម្មាសម្ពុទ្ធគប្បីចូលមកកាន់ដែន ១ សូមឲ្យបានចូលទៅសេពគប់នឹងព្រះមានព្រះភាគ ១ សូមឲ្យព្រះមានព្រះភាគសម្តែងធម៌ដល់ទ្រង់ ១ សូមឲ្យដឹងច្បាស់នូវធម៌របស់ព្រះមានព្រះភាគ ១ ។

ទើបចេញអំពីក្រុងរាជគ្រឹះ ទៅកាន់លដ្ឋិវ័នអំពីព្រលឹម ។ ផ្លូវ ៣ គាវុត មិនគ្រប់គ្រាន់ លដ្ឋិវ័នឧទ្យានទាំងមូល ពេញណែនទាំងអស់ មហាជនសម្លឹងមើលអត្តភាពដែលមានលម្អដោយព្រះរូបឆោមរបស់ព្រះទសពល មិនអាចធ្វើឲ្យឆ្អែតបាន ។ ក្នុងឋានៈទាំងឡាយបែបនេះ គប្បីពណ៌នាលម្អនៃព្រះរូបកាយទាំងមូលនេះ ដែលមានប្រភេទជាព្រះលក្ខណៈ និងព្រះអនុព្យញ្ជនៈរបស់ព្រះតថាគត ឈ្មោះថា វណ្ណរូប ( ពណ៌នារូប ) ។ មហាជនសម្លឹងមើលព្រះសរីរៈរបស់ព្រះមុនី ដែលដល់នូវភាពស្អាត ដោយព្រះរូបឆោមច្រើនកុះករដោយប្រការយ៉ាងនេះ ទើបមិនមានឱកាសឲ្យភិក្ខុសូម្បីមួយរូប ចេញទៅអំពីឧទ្យានដោយផ្លូវ ។ បានឮថា ថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ដាច់ព្រះក្រយាហារ ការដាច់ព្រះក្រយាហារនោះកុំបីមានឡើយ ព្រោះហេតុនោះ ទើបអាសនៈដែលសក្កទេវរាជប្រថាប់គង់ សម្តែងអាការក្តៅ សក្កទេវរាជទ្រង់ពិចារណាទ្រង់បានជ្រាបហេតុការណ៍នោះ ទើបទ្រង់និម្មិតភេទជាមាណពតូច ច្រៀងចម្រៀងដែលបដិសំយុត្តដោយព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ទ្រង់ចុះត្រង់ព្រះភក្ត្ររបស់ព្រះទសពល បានឱកាសដោយទេវានុភាព យាងនាំទៅខាងមុខពោលគុណរបស់ព្រះសាស្តា ដោយគាថាទាំងនេះថា

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ ( នូវឥន្ទ្រិយ )
មានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គ
មានពណ៌ ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុង
រាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ

( នូវឥន្ទ្រិយ ) ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ ( ចាក អាសវធម៌ ) ។

ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យផុតហើយ ( ចាក សេចក្តីសៅហ្មង ) និងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាក អាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលមានចិត្តផុតហើយ ( ចាកសេចក្តីសៅហ្មង ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

ព្រះដ៏មានព្រះភាគ ទ្រង់ឆ្លង ( ចាកលោក ) ហើយ ទាំងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលឆ្លងហើយ ( ចាកលោក ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យរម្ងាប់ហើយ ( ចាក អកុសលធម៌ ) ទាំងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាក អាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលមានចិត្តរម្ងាប់ហើយ ( ចាកអកុសលធម៌ ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

ព្រះដ៏មានព្រះភាគនោះ ទ្រង់មានអរិយវាស ១០ យ៉ាង ទ្រង់មានកម្លាំង ១០ ព្រះអង្គជ្រាបច្បាស់នូវធម៌ ( គឺកម្មបថ ) ១០ ប្រការ ទ្រង់ប្រកបដោយអង្គជារបស់នៃអសេក្ខបុគ្គល ១០ យ៉ាង មានភិក្ខុសង្ឃ ១ ពាន់ជាបរិវារ ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ[១] ដូច្នេះ ។

១- សេចក្ដីពិស្ដារសូមមើលក្នុងបិដកខ្មែរលេខ ៦ ចុះ ។

មហាជនបានឃើញលម្អនៃរូបរបស់មាណពតូចហើយ គិតថា មាណពតូចនេះ មានរូបល្អពន់ពេក មាណពតូចនេះ អញមិនធ្លាប់ឃើញឡើយ ទើបពោលថា មាណពតូចនេះមកអំពីណា ជារបស់អ្នកណា ។ មាណពតូចបានស្ដាប់ដូច្នោះ ទើបពោលគាថាថា

អ្នកប្រាជ្ញណាទូន្មានឥន្ទ្រិយទាំងអស់បានហើយ មានព្រះហឫទ័យស្អាត រកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវ ពោល គឺ កិលេស មានដំណើរល្អក្នុងលោក ខ្ញុំឯងជាអ្នកបម្រើអ្នកប្រាជ្ញនោះ ដូច្នេះ ។

ព្រះសាស្ដា ទ្រង់យាងតាមផ្លូវដែលមានឱកាស ដែលសក្កទេវរាជទ្រង់ធ្វើហើយ ទ្រង់ចោមរោមដោយភិក្ខុ ១០០០ យាងទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះរាជាទ្រង់ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចប្រព្រឹត្តទៅ ដោយវៀររតនៈទាំង ៣ ខ្ញុំព្រះអង្គនឹងមកគាល់ទ្រង់ក្នុងកាលខ្លះ ក្នុងវិកាលខ្លះ លដ្ឋិវន

ឧទ្យានឆ្ងាយពេក តែវេឡុវ័នឧទ្យានរបស់ខ្ញុំព្រះអង្គនេះ មិនជិតពេក មិនឆ្ងាយពេក ជាសេនាសនៈសម្បូរដោយគមនាគមន៍ សមគួរដល់ព្រះពុទ្ធ សូមទ្រង់ទទួលវេឡុវ័ននេះចុះ ហើយទ្រង់យកឃ្នោកមាស ដែលមានពណ៌ដូចកែវមណីអប់ដោយផ្កា និងគ្រឿងក្រអូប កាលទ្រង់បរិច្ចាគវេឡុវ័នឧទ្យាន ទើបទ្រង់ប្រូចទឹកលើព្រះហស្តរបស់ព្រះទសពល ក្នុងខណៈដែលទ្រង់ទទួលអារាមនោះ មហាប្រឹថពីបានកម្រើក ជាហេតុឲ្យដឹងថា ឫសកែវរបស់ព្រះពុទ្ធ-សាសនា បានចាក់ចុះហើយ ពិតហើយ ជម្ពូទ្វីប វៀរវត្តវេឡុវ័នចេញហើយ សេនាសនៈដទៃ ដែលទ្រង់ទទួលហើយ ផែនដីញាប់ញ័រមិនមាន ។ ឯក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា មិនមានសេនាសនៈដទៃ ដែលទទួលហើយ ផែនដីញាប់ញ័រនោះឡើយ វៀរលែងតែមហាវិហារ ។ ព្រះសាស្តា កាលទ្រង់ទទួលវេឡុវ័នារាមហើយ ទ្រង់ធ្វើអនុមោទនាដល់ព្រះរាជា ហើយក្រោកចាកអាសនៈ ចោមរោមដោយភិក្ខុសង្ឃ យាងទៅកាន់វេឡុវ័ន ។

សម័យនោះឯង បរិព្វាជកទាំង ២ គឺសារីបុត្ត និងមោគ្គល្លានអាស្រ័យក្រុងរាជគ្រឹះ ស្វែងរកអមតធម៌ ។ បណ្តាបរិព្វាជកទាំង ២ នោះ សារីបុត្តឃើញព្រះអស្សជិត្ថេរចូលទៅបិណ្ឌបាត មានចិត្តជ្រះថ្លា ទើបចូលទៅអង្គុយជិត បានស្តាប់គាថាថា **យេ ធម្មា ហេតុប្បភវា** ធម៌ទាំងឡាយណា មានហេតុជាដែនកើត ដូច្នេះជាដើម បានតាំងនៅក្នុងសោតាបត្តិផល បានពោលគាថានោះឯងដល់មោគ្គល្លានបរិព្វាជកសម្លាញ់របស់ខ្លួន ។ ឯមោគ្គល្លានបរិ-ព្វាជកបានតាំងនៅក្នុងសោតាបត្តិផល ។ សម្លាញ់ទាំង ២ នោះ លាសញ្ជ័យ

បរិព្វាជក ហើយបួសក្នុងសម្នាក់របស់ព្រះសាស្តា មួយអន្លើដោយបរិស័ទរបស់ខ្លួន ។ បណ្តាសម្លាញ់ទាំង ២ នោះ ព្រះមោគ្គល្លានត្ថេរ សម្រេចអរហត្តក្នុងរយៈពេល ៧ ថ្ងៃ ព្រះសារីបុត្តត្ថេរ សម្រេចអរហត្ត កន្លងទៅកន្លះខែ ។ ព្រះសាស្តាទ្រង់តាំងព្រះថេរៈទាំង ២ ក្នុងតំណែងអគ្គសាវក ក្នុងថ្ងៃដែលព្រះសារីបុត្តត្ថេរសម្រេចអរហត្តនោះឯង ទ្រង់បានធ្វើសាវកសន្និបាត ។

កាលព្រះសាស្តាគង់នៅក្នុងវេឡុវ័នឧទ្យាននោះឯង ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានឮថា បុត្ររបស់ទ្រង់ប្រព្រឹត្តទុក្ករកិរិយា ៦ ឆ្នាំ សម្រេចបរមាភិសម្ពោធិញ្ញាណ ហើយប្រកាសធម្មចក្កដ៏បវរ អាស្រ័យក្រុងរាជគ្រឹះគង់នៅក្នុងវេឡុវ័ន ទើបត្រាស់ហៅអមាត្យម្នាក់មកត្រាស់ថា នែអ្នក ចូរអ្នកនាំបុរស ១០០០ ធ្វើដំណើរទៅក្រុងរាជគ្រឹះ ពោលតាមពាក្យរបស់ខ្ញុំថា ព្រះបាទសុទ្ធោទនមហារាជ ជាបិតារបស់ព្រះអង្គ មានបំណងចង់ជួប ហើយនាំកូនរបស់យើងមក ។ អមាត្យនោះ ទទួលព្រះតម្រាស់របស់ព្រះរាជាថា បពិត្រព្រះអង្គ យ៉ាងនោះឯង ហើយមានបុរស ១០០០ ជាបរិវារ ស្រូតដំណើរទៅអស់ចម្ងាយផ្លូវ ៦០ យោជន៍ អង្គុយក្នុងកណ្តាលបរិស័ទ ៤ នៃព្រះទសពល ហើយចូលទៅកាន់វិហារ ក្នុងពេលសម្តែងធម៌ អមាត្យនោះគិតថា ព្រះរាជសាសន៍របស់ព្រះរាជាដែលបញ្ជូនមក ស្ទេះសិនចុះ ឈរខាងក្រោយបរិស័ទ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា តាមដែលឈរនោះឯង បានសម្រេចអរហត្ត មួយអន្លើដោយបុរសជាបរិវារ ១០០០ ទើបទូលសូមបព្វជ្ជា ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា អ្នកទាំងឡាយចូរជាភិក្ខុ

ចុះ ។ ក្នុងខណៈនោះឯង មនុស្សទាំងអស់ ទ្រទ្រង់បាត្រ និងចីវរ ដែល សម្រេចដោយឫទ្ធិ ហាក់ដូចជាព្រះថេរៈមានវស្សា ៦០ ដូច្នោះ ។ ធម្មតា ព្រះអរិយៈទាំងឡាយ រមែងមានខ្លួនជាកណ្ដាល ចាប់តាំងអំពីពេលដែល សម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបមិនបានក្រាបទូលរាជសាសន៍ ដែលព្រះរាជាទ្រង់បញ្ជូនមកដល់ព្រះទសពល ។ ព្រះរាជាត្រាស់ថា អមាត្យ ដែលទៅហើយ ក៏មិនឃើញមក ដំណឹងក៏មិនបានដឹង មកចុះអ្នក ចូរអ្នកទៅ ហើយបញ្ជូនអមាត្យដទៃទៅ តាមទំនងនោះឯង អមាត្យនោះទៅហើយ បាន សម្រេចអរហត្ត មួយអន្លើដោយបរិស័ទ ដោយន័យមុននោះឯង ក៏បានអង្គុយ ស្ងៀម ព្រះរាជាទ្រង់បញ្ជូនអមាត្យ ៩ នាក់ មានបរិវារម្នាក់ ១០០០ ទៅ ដោយទំនងនេះឯង អមាត្យគ្រប់គ្នា ញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេចហើយ ក៏ ជាអ្នកអង្គុយនៅក្នុងក្រុងរាជគ្រឹះនោះឯង ។ ព្រះរាជាមិនបានអមាត្យដែលគ្រាន់ តែនាំដំណឹងមកប្រាប់ ទើបទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះ មិន នាំត្រឡប់មកត្រឹមតែដំណឹង ព្រោះមិនមានការស្រឡាញ់ក្នុងអញ នរណាហ្ន៎ នឹងធ្វើតាមពាក្យរបស់អញ កាលទ្រង់ត្រួតពលទាំងអស់ ក៏បានឃើញកាឡុ- ទាយិអមាត្យ ។ បានឮថា កាឡុទាយីនោះ ជាអមាត្យដែលញុំាងរាជកិច្ចទាំង ពួងឲ្យសម្រេច ជាមនុស្សខាងក្នុង ស្និទ្ធស្នាលក្រៃលែង កើតក្នុងថ្ងៃជាមួយ ព្រះពោធិសត្វ ជាសម្លាញ់លេងដីជាមួយគ្នា ។ លំដាប់នោះ ព្រះរាជាត្រាស់ ហៅកាឡុទាយិអមាត្យមកថា បាឧទាយី ខ្ញុំប្រាថ្នាឃើញកូនរបស់ខ្ញុំ ទើបបញ្ជូន បុរសទៅ ៩០០០ សូម្បីបុរសត្រឹមតែម្នាក់ ដែលមកដើម្បីប្រាប់ដំណឹង ក៏

មិនមាន អន្តរាយនៃជីវិតរបស់ខ្ញុំ ដឹងបានលំបាក ខ្ញុំនៅមានជីវិត ប្រាថ្នានឹងឃើញកូន អ្នកអាចបង្ហាញបុត្តដល់ខ្ញុំបានឬទេ ។ កាឡុទាយិអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំអាច បើទូលបង្គំបាននូវបព្វជ្ជា ។ ព្រះរាជាត្រាស់ថា នែបា អ្នកបានបួស ឬមិនបានបួសក៏ដោយ ឲ្យតែបង្ហាញបុត្តដល់ខ្ញុំ ។ កាឡុទាយិអាមាត្យនោះ ទទួលព្រះតម្រាស់ហើយ កាន់យកព្រះរាជសាសន៍ ទៅកាន់ក្រុងរាជគ្រឹះ ឈរខាងចុងបរិស័ទ ក្នុងកាលដែលព្រះសាស្តាទ្រង់សម្តែងព្រះធម្មទេសនា បានស្តាប់ធម៌ហើយ មួយអន្លើដោយបរិស័ទ ក៏សម្រេចអរហត្តផល តាំងនៅក្នុងភាពជាឯហិភិក្ខុ ។

ឯព្រះសាស្តា បានជាព្រះពុទ្ធហើយ គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ខាងក្នុងវស្សាជំបូង ចេញវស្សាបវារណាហើយ យាងទៅកាន់ឧរុវេលា គង់នៅត្រង់ឧរុវេលានោះអស់ ៣ ខែ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូន មានភិក្ខុ ១០០០ ជាបរិវារ ក្នុងថ្ងៃពេញបូណ៌មី ខែបុស្ស ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ គង់នៅអស់ ២ ខែ ដោយលំដាប់កាលមានប្រមាណប៉ុណ្ណោះ គឺអស់កាល ៥ ខែ សម្រាប់ព្រះសាស្តា ដែលយាងចេញអំពីក្រុងពារាណសី ។ ហេមន្តរដូវកន្លងទៅហើយ ចាប់តាំងអំពីថ្ងៃដែលព្រះឧទាយីមកហើយ កន្លងទៅ ៧-៨ ថ្ងៃ ក្នុងថ្ងៃ ១៥ កើត ខែ ផល្គុន ព្រះឧទាយីគិតថា ហេមន្តរដូវកន្លងទៅហើយ វស្សន្តរដូវកំពុងចូលមក ពួកមនុស្សជកសន្ទូង ហើយផ្លូវក្នុងទីចំពោះមុខ ផែនដីដេរដាសទៅដោយស្មៅមានពណ៌ខៀវស្រងាត់ ដងព្រៃមានផ្ការីកស្គុសស្គាយ ផ្លូវក៏សមគួរដល់ការធ្វើដំណើរ កាល

នេះ ជាកាលដែលព្រះទសពលទ្រង់ធ្វើការសង្គ្រោះព្រះញាតិ ។ លំដាប់នោះ ព្រះឧទាយិត្ថេរ ចូលទៅគាល់ព្រះសាស្ដា ពណ៌នាផ្លូវយាងទៅ ដើម្បីឲ្យព្រះទសពលទៅកាន់ព្រះនគររបស់រាជត្រកូល ដោយប្រមាណ ៦០ គាថាថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ រុងរឿងដូចជាអណ្ដាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ ជាកាលគួរបានចំណែកធម្មរសហើយ ។បេ។ ឧតុមិនត្រជាក់ពេក មិនក្ដៅពេក មិនខ្វះខាតស្បៀងអាហារ ផ្ទៃដីក៏មានស្បូវក្លាំងខៀវស្រងាត់ បពិត្រព្រះមហាមុនី កាលនេះ ជាកាលសមគួរហើយ ដែលនឹងយាងទៅ ដូច្នេះ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងឧទាយិត្ថេរថា ម្នាលឧទាយី ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពណ៌នាការទៅដោយសំឡេងដ៏ពីរោះ ព្រះឧទាយិត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជ ព្រះជនករបស់ព្រះអង្គ មានបំណងនឹងឃើញព្រះអង្គ សូមទ្រង់ធ្វើការសង្គ្រោះដល់ព្រះញាតិទាំងឡាយចុះ ព្រះមុនីត្រាស់ថា សាធុ ឧទាយី តថាគតនឹងធ្វើការសង្គ្រោះព្រះញាតិ ចូរអ្នកប្រាប់ដល់ភិក្ខុសង្ឃ ភិក្ខុទាំងឡាយនឹងបានបំពេញគមិកវត្ត ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ ហើយប្រាប់ដល់ភិក្ខុសង្ឃ ។

ព្រះមានព្រះភាគ ទ្រង់ចោមរោមដោយភិក្ខុខីណាស្រព ២ ម៉ឺនអង្គ គឺកុលបុត្តអ្នកអង្គៈ និងអ្នកមគធៈ ១ ម៉ឺនអង្គ កុលបុត្តអ្នកកបិលពស្ដុ ១ ម៉ឺន

អង្គ យាងចេញអំពីក្រុងរាជគ្រឹះ ទ្រង់យាង ១ ថ្ងៃ ១ យោជន៍ ។ ព្រះមុនី ទ្រង់ព្រះតម្រិះថា នឹងយាងចេញអំពីក្រុងរាជគ្រឹះ ដល់ក្រុងកបិលពស្តុ ៦០ យោជន៍ អស់កាល ២ ខែ ទើបចារិកទៅដោយមិនប្រញាប់ ឯព្រះថេរៈគិតថា នឹងក្រាបទូលកាលដែលព្រះមានព្រះភាគយាងមកហើយ ទើបហោះឡើងទៅកាន់អាកាស ប្រាកដក្នុងរាជនិវេសន៍របស់ព្រះរាជា ។ ព្រះរាជាទតឃើញព្រះថេរៈហើយ ទ្រង់សប្បាយព្រះហឫទ័យ និមន្តឲ្យគង់លើបល្ល័ង្កដ៏សមគួរមានតម្លៃច្រើន ទ្រង់បានដាក់បាត្រឲ្យពេញដោយភោជន មានរសដ៏លើសផ្សេងៗ ដែលគេត្រៀមដើម្បីព្រះអង្គ ហើយប្រគេន ។ ព្រះថេរៈក្រោកឡើងសម្តែងអាការទៅ ព្រះរាជាត្រាស់ថា សូមនិមន្តឆាន់ចុះ ព្រះថេរៈទូលថា មហាបពិត្រ អាត្មាទៅកាន់សម្នាក់របស់ព្រះសាស្តាហើយ ទើបឆាន់ ។ ព្រះរាជាត្រាស់ថា ព្រះសាស្តានៅទីណា ព្រះឧទាយិត្ថេរទូលថា មហាបពិត្រ ព្រះសាស្តាមានភិក្ខុ ២ ម៉ឺនជាបរិវារ យាងចារិកដើម្បីឃើញទ្រង់ ព្រះរាជាទ្រង់សប្បាយព្រះហឫទ័យ ត្រាស់ថា សូមលោកម្ចាស់ឆាន់ភត្តនេះ ហើយសូមនាំបិណ្ឌបាតអំពីរាជនិវេសន៍ទៅថ្វាយព្រះឱរសនោះ ទម្រាំឱរសរបស់ខ្ញុំមកដល់នគរនេះ ព្រះថេរៈទទួលថា សាធុ ។ ព្រះរាជាអង្គាសព្រះថេរៈ អប់បាត្រដោយលម្អិតក្រអូប ដាក់ពេញដោយភោជនដ៏ឧត្តម ហើយដាក់ត្រង់ដៃរបស់ព្រះថេរៈ ដោយត្រាស់ថា សូមលោកម្ចាស់ថ្វាយព្រះតថាគត ។ ព្រះថេរៈ កាលមនុស្សក្នុងវាំងកំពុងឃើញនោះឯង បានបោះបាត្រទៅក្នុងអាកាស ហើយហោះឡើងកាន់វេហាស៍ នាំបិណ្ឌបាតទៅដាក់ចំពោះព្រះកត្រ្តរបស់ព្រះ

សាស្តាៗ សោយបិណ្ឌបាតនោះ ព្រះថេរៈបាននាំបិណ្ឌបាតមករាល់ៗ ថ្ងៃ ដោយឧបាយនេះ ។ ព្រះសាស្តាក៏សោយតែបិណ្ឌបាតរបស់ព្រះរាជាប៉ុណ្ណោះ ក្នុងរវាងផ្លូវ ។ ក្នុងកាលស្រេចភត្តកិច្ចរាល់ៗ ថ្ងៃ ព្រះថេរៈក៏ពោលថា ថ្ងៃនេះ ព្រះសាស្តាយាងបានរយៈផ្លូវមានប្រមាណប៉ុណ្ណោះ ថ្ងៃនេះ យាងមកអស់រយៈផ្លូវមានប្រមាណប៉ុណ្ណោះ បានធ្វើរាជត្រកូលទាំងមូលឲ្យមានសេចក្តីជ្រះថ្លា កើតឡើងក្នុងព្រះសាស្តា ដោយវៀរការបានឃើញព្រះសាស្តា ដោយធម្មីកថាដែលសម្បយុត្តដោយពុទ្ធគុណ ។ ដោយហេតុនោះឯង ទើបព្រះសាស្តាស្ថាបនាឧទាយិត្ថេរនោះក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកាឡុទាយិ ដូច្នេះ ។

ឯស្តេចសក្យៈទាំងឡាយ កាលព្រះមានព្រះភាគយាងដល់ដោយលំដាប់ហើយ បានប្រឹក្សាគ្នាថា ពួកយើងនឹងឃើញព្រះញាតិដ៏ប្រសើររបស់ពួកយើង ទើបប្រជុំគ្នាពិចារណាស្ថានទីគង់នៅរបស់ព្រះសាស្តា កំណត់គ្នាថា អារាមរបស់ព្រះបាទនិគ្រោធសក្យៈ គួរជាទីត្រេកអរ ទើបឲ្យធ្វើការជួសជុលគ្រប់យ៉ាងក្នុងអារាមនោះ កាន់គ្រឿងក្រអូប និងផ្កា កាលនឹងធ្វើការទទួល ទើបបញ្ជូនក្មេងប្រុស និងក្មេងស្រី កំលោះ ក្រមុំ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងទៅមុន បន្ទាប់អំពីនោះ ទើបបញ្ជូនរាជកុមារ និងរាជកុមារីទៅ ខ្លួនឯងបូជាដោយគ្រឿងក្រអូប ផ្កា និងលម្អិតជាដើម រវាងរាជកុមារ និងរាជកុមារីទាំងនោះ បាននាំព្រះសាស្តាទៅកាន់និគ្រោធារាមនោះឯង ។ ក្នុង

និគ្រោធារាមនោះ ព្រះសាស្តាចោមរោមដោយព្រះខីណាស្រព ២ ម៉ឺន គង់លើបវរពុទ្ធាសនៈដែលគេក្រាលហើយ ។ ធម្មតាសក្យៈទាំងឡាយ ជាអ្នកមានជាតិប្រកបដោយមានះរឹងត្អឹង សក្យៈទាំងនោះត្រិះរិះថា សិទ្ធត្ថកុមារ ក្មេងជាងយើងទាំងឡាយ ជាប្អូនប្រុស ជាក្មួយ ជាកូន ជាចៅរបស់យើងទាំងឡាយ ទើបត្រាស់នឹងរាជកុមារទាំងឡាយដែលមានវ័យក្មេងៗ ថា ចូរអ្នកទាំងឡាយថ្វាយបង្គំព្រះសាស្តា ពួកខ្ញុំនឹងអង្គុយខាងក្រោយអ្នកទាំងឡាយ ។

កាលសក្យៈទាំងនោះ មិនថ្វាយបង្គំ ប្រថាប់គង់ហើយយ៉ាងនេះ ព្រះមុនីទ្រង់ទតអជ្ឈាស្រ័យរបស់សក្យៈទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ព្រះញាតិទាំងឡាយ មិនថ្វាយបង្គំតថាគត ណ្ហើយចុះ តថាគតនឹងឲ្យព្រះញាតិទាំងនោះថ្វាយបង្គំ ទើបទ្រង់ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញអំពីឈានហើយហោះឡើងទៅកាន់អាកាស ហាក់ដូចរោយធូលីព្រះបាទលើសីសៈរបស់សក្យៈទាំងនោះ ទ្រង់បានធ្វើបាដិហារ្យ ដូចយមកបាដិហារ្យ ត្រង់គល់គណ្ឌម្ពព្រឹក្សព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ទើបត្រាស់ថា បពិត្រព្រះមានព្រះភាគ ក្នុងថ្ងៃដែលទ្រង់ប្រសូត ខ្ញុំព្រះអង្គបានឃើញព្រះបាទរបស់ព្រះអង្គ ដែលខ្ញុំព្រះអង្គនាំចូលទៅឲ្យថ្វាយបង្គំកាឡទេវលតាបស ត្រឡប់ទៅប្រតិស្ឋានលើក្បាលរបស់ព្រាហ្មណ៍ ក៏បានថ្វាយបង្គំទ្រង់ នេះជាការថ្វាយបង្គំលើកទី ១ របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃវប្បមង្គលក៏បានឃើញការចម្លែករបស់ស្រមោលដើមព្រីង ដែលទ្រង់ផ្ទំលើព្រះបន្ទំ ប្រកបដោយសិរីក្រោមម្លប់ដើមព្រីង ក៏បានថ្វាយបង្គំព្រះបាទ នេះជាការថ្វាយបង្គំលើកទី ២ ឥឡូវនេះ បានឃើញបាដិហារ្យ

នេះដែលមិនធ្លាប់ឃើញ ទើបថ្វាយបង្គំព្រះបាទរបស់ទ្រង់ នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំព្រះអង្គ ។ កាលព្រះរាជាថ្វាយបង្គំហើយ សូម្បីសក្យៈមួយអង្គដែលមិនថ្វាយបង្គំព្រះសាស្តា ហើយអាចតាំងនៅមិនមាន ស្តេចសក្យៈទាំងឡាយនាំគ្នាថ្វាយបង្គំទាំងអស់ ។

ព្រះសាស្តាទ្រង់ឲ្យព្រះញាតិទាំងឡាយថ្វាយបង្គំ ដោយប្រការដូច្នេះហើយ ទើបយាងចុះអំពីអាកាស គង់លើអាសនៈដែលគេបានក្រាល ។ កាលព្រះសាស្តាគង់ហើយ សមាគមព្រះញាតិដ៏ធំមានឡើងហើយ ស្តេចសក្យៈទាំងពួង មានចិត្តតម្កល់មាំប្រថាប់គង់ហើយ ។ សម័យនោះ មហាមេឃបានបង្អុរភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ចុះមក ទឹកពណ៌ក្រហម មានសំឡេងហូរទៅខាងក្រោម បុគ្គលបំណងឲ្យសើម ទើបសើម ភ្លៀងបោក្ខរព័ស្សត្រឹមតែ ១ តំណក់ក៏មិនធ្លាក់លើរាងកាយរបស់បុគ្គលដែលមិនបំណងឲ្យសើម ។ សក្យៈទាំងពួងឃើញដូច្នោះ កើតអស្ចារ្យ ដែលមិនធ្លាប់កើត ទើបសន្ទនាគ្នាថា ឱ ! គួរអស្ចារ្យ ឱ ! មិនធ្លាប់មាន ព្រះសាស្តាត្រាស់ថា ភ្លៀងបោក្ខរព័ស្សធ្លាក់ចុះក្នុងសមាគមនៃញាតិរបស់តថាគត តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងអតីតក៏បានធ្លាក់ហើយ ទើបត្រាស់វេស្សន្តរជាតក ព្រោះអត្ថុប្បត្តិហេតុនេះ ។ សក្យៈទាំងពួងស្តាប់ធម្មទេសនាហើយ ថ្វាយបង្គំ ក្រោកឡើងហើយ ចៀសចេញទៅ ។ ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាសូម្បីមួយអង្គដែលក្រាបទូលថា សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គទាំងឡាយក្នុងថ្ងៃស្អែក មិនមានដូច្នេះហើយ ចៀសចេញទៅ ។

ស្អែកឡើង ព្រះសាស្តាទ្រង់ចោមរោមដោយភិក្ខុ ២ ម៉ឺនអង្គ ចូលទៅបិណ្ឌបាតក្នុងក្រុងកបិលពស្តុ មិនមានបុគ្គលណាម្នាក់ទៅនិមន្ត ឬទទួលបាត្រព្រះសាស្តាទ្រង់ឈរត្រង់សសរខឿន អាវជ្ជនះថា ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុនត្រាច់បិណ្ឌបាតក្នុងព្រះនគររបស់ត្រកូលដូចម្តេចហ្ន៎ យាងទៅកាន់ផ្ទះឥស្សរជន រំលងលំដាប់ ឬត្រាច់ចារិកទៅតាមលំដាប់ប្រេក ទ្រង់មិនឃើញព្រះពុទ្ធសូម្បីត្រឹមតែមួយអង្គ ដែលយាងរំលងលំដាប់ ហើយទ្រង់ព្រះតម្រិះថា នេះជាវង្សរបស់ព្រះពុទ្ធទាំងឡាយ នេះជាប្រពៃណីរបស់តថាគតៗ ក៏គួរវៀរក្នុងឥឡូវនេះ សាវកទាំងឡាយរបស់តថាគត នឹងសិក្សាតាមនោះឯង នឹងបំពេញបិណ្ឌបាតចារិកវត្តតទៅ ទើបយាងបិណ្ឌបាតទៅតាមលំដាប់ប្រេក តាំងអំពីផ្ទះខាងចុងទៅ ។ មហាជនភ្ញាក់ផ្អើល ព្រោះបានឮថា សិទ្ធត្ថកុមារត្រាច់ទៅដើម្បីដុំបាយ ទើបបើកបង្អួចលើប្រាសាទជាន់ទី ២ ជាន់ទី ៣ ជាដើម ជាអ្នកខ្វល់ខ្វាយដើម្បីមើល ។

ឯព្រះទេវីរាហុលមាតា ព្រះនាងព្រះតម្រិះថា បានឮថា អយ្យបុត្រត្រាច់ទៅដោយវមាសជាដើម ដោយរាជានុភាពធំ ក្នុងនគរនេះឯង ឥឡូវនេះកោរសក់ និងពុកមាត់ ដណ្តប់កាសាវពស្ត្រ កាន់អំបែងត្រាច់ទៅដើម្បីដុំបាយស្អាតដែរឬហ្ន៎ ទើបព្រះនាងបើកសីហបញ្ជរទតមើល បានឃើញព្រះសាស្តាទ្រង់ញុំាងវិថីក្នុងនគរឲ្យរុងរឿង ដោយព្រះរស្មីនៃព្រះសរីរៈដ៏រុងរឿងផ្សេងៗ រុងរឿងដោយពុទ្ធសិរី មិនអាចឧបមាបាន ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ រុងរឿងដោយអនុព្យញ្ជនៈ ៨០ ដែលជាប់តាមដោយជុំវិញ ដោយ

ព្រះរស្មីមួយព្យាម ទើបព្រះនាងសរសើរតាំងអំពីថ្វាស របូតដល់ផ្ទៃព្រះបាទ ដោយគាថា ឈ្មោះនរសីហ: ៨ ប្រការ យ៉ាងនេះថា

ព្រះនរសីហ: មានព្រះកេសារលកទន់ខ្មៅរលោង មានថ្ងាស ទូលាយ ប្រាសចាកមន្ទិលដូចព្រះអាទិត្យ មានព្រះនាសាវែងខ្ពស់ ទន់សម មានបណ្ដាញរស្មីផ្សាយចេញអំពីកាយ ។

ព្រះនរសីហ: ជាបិតារបស់អ្នកនោះឯង មានផ្ទៃព្រះបាទ ក្រហម កំណត់ដោយចក្រដ៏ល្អ មានព្រះបណ្ហិ ( កែងជើង ) វែង ប្រដាប់ដោយលក្ខណ: មានព្រះបាទប្រដាប់ដោយចាមរ និងឆត្រ ។

ព្រះនរសីហ: ជាបិតារបស់អ្នកនោះឯង ជាសក្យកុមារ ដ៏ប្រសើរ ជាស្ដេចសុខុមាលជាតិ មានសរីរ:ស្អាត វិចិត្រដោយ លក្ខណ:ជាមហាវីរ: ទ្រង់យាងមកដើម្បីប្រយោជន៍សត្វលោក ។

ព្រះនរសីហ: ជាបិតារបស់អ្នកនោះឯង មានទងព្រះកាណ៌ វែង សក្តិសម មានព្រះនេត្រដូចភ្នែកនៃកូនគោ មានពណ៌ខៀវ ស្រស់ មានរោមចិញ្ចើមខ្មៅកោង ដូចឥន្ទធនូ ។

ព្រះនរសីហ: ជាបិតារបស់អ្នកនោះសោត មានព្រះភក្ត្រដូច ព្រះចន្ទពេញវង់ ជាទីស្រឡាញ់នៃពួកទេវតា និងមនុស្ស ជានរ: ដ៏ប្រសើរ ទ្រង់មានដំណើរយាងយាស ដូចស្ដេចដំរី ។

ព្រះនរសីហ: ជាបិតារបស់អ្នកនោះឯង មានព្រះសូរសៀង

មូលជ្រៅ មានព្រះជិវ្ហាក្រហមល្អ សម្បុរដូចហិង្គុលជាតិ មាន ព្រះទន្តសបរិសុទ្ធចំនួន ៤០ គត់ ។

ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានជាតិជាក្សត្រ ជាកំពូលនៃត្រកូលដែលទេវតា និងមនុស្ស តែងនមស្ការព្រះបាទា ទ្រង់មានព្រះហឫទ័យតាំងមាំក្នុងសីល សមាធិ ។

ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានព្រះសូរងមូលក្លំ មានចង្កាដូចសីហៈ មានសរីរៈ គឺដងខ្លួនដូចស្តេចម្រឹគ មានសម្បុរ ស្បែកល្អដូចមាស ។

ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានព្រះកេសាខ្មៅ ដូចផ្កាអញ្ចន មានថ្ងាសបរិសុទ្ធដូចដំបារមាស មានរោមប្រជុំ ចិញ្ចើមសសុទ្ធ ដូចផ្កាយព្រឹក ។

ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង ជាធំជាងសរណៈ ស្តេចយាងត្រង់កណ្តាលសាវក ដូចព្រះចន្ទចោមរោមដោយហ្វូង ផ្កាយ គោចរក្នុងវិថី ដូច្នោះ ។

ហើយទើបក្រាបទូលដល់ព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គ ត្រាច់ទៅ ដើម្បីដុំបាយ ។ ព្រះរាជាទ្រង់ស្លុតព្រះហឫទ័យ ទ្រង់ស្លៀកសំពត់សាដកឲ្យ ខ្ជាប់ដោយព្រះហស្ត រួតរះចេញទៅដោយរហ័ស ប្រថាប់ឈរចំពោះព្រះភក្ត្រ របស់ព្រះសាស្តា ហើយត្រាស់ថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ទើបទ្រង់ធ្វើ ឲ្យខ្ញុំដល់នូវការខ្មាស ទ្រង់ត្រាច់ទៅដើម្បីដុំបាយ ហេតុអ្វី ទើបទ្រង់សម្គាល់ថា

ភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះ មិនអាចបានកត្តាហារ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នេះជាវង្ស ជាចារិតរបស់តថាគត ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ យើងទាំងឡាយជាវង្សរបស់មហាសម្មតិរាជ មិនមែនឬ ក្នុងមហាសម្មតិរាជវង្សនោះ ក្សត្រសូម្បីតែមួយអង្គ ដែលដើរទៅដើម្បីកិក្ខាមិនមាន ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ឈ្មោះថា វង្សនេះ ជាវង្សរបស់ទ្រង់ តែឈ្មោះថា ពុទ្ធវង្ស គឺព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ ព្រះកស្សបៈ ជាវង្សនៃតថាគត ព្រះពុទ្ធទាំងនោះ រាប់ពាន់ បានសម្រេចការចិញ្ចឹមជីវិត ដោយការបិណ្ឌបាតប៉ុណ្ណោះ ព្រះសាស្តាទ្រង់ឈរក្នុងចន្លោះវិថីនោះឯង ត្រាស់ព្រះគាថានេះថា

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូច្នេះ ។

ក្នុងកាលចប់គាថា ព្រះរាជាតាំងនៅក្នុងសោតាបត្តិផល និងបានស្តាប់គាថានេះថា

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូច្នេះ ។ បានតាំងនៅក្នុងសកទាគាមិផល ។

ទ្រង់បានស្តាប់ធម្មបាលជាតក តាំងនៅក្នុងអនាគាមិផល សម័យទៀប

សោយទិវង្គត ទ្រង់ផ្ទំលើទីបន្ទំ ប្រកបដោយសិរី ខាងក្រោមស្វេតច្ឆត្រ បាន សម្រេចអរហត្ត ។ កិច្ចក្នុងការតាមប្រកបសេចក្ដីព្យាយាម ដោយការនៅព្រៃ មិនមានដល់ព្រះរាជា ។ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលប៉ុណ្ណោះ ទ្រង់ទទួលបាត្ររបស់ព្រះសាស្ដា ទ្រង់និមន្តព្រះសាស្ដា មួយអន្លើដោយភិក្ខុ សង្ឃ ឡើងកាន់មហាប្រាសាទ ទ្រង់អង្គាសដោយខាទនីយ ភោជនីយាហារ ដ៏ប្រណីត ក្នុងកាលស្រេចភត្តកិច្ច ស្នំទាំងឡាយ វៀររាហុលមាតា នាំគ្នាមក ថ្វាយបង្គំព្រះសាស្ដា ។ រាហុលមាតានោះ ទោះជនជាបរិវារពោលថា សូម ព្រះនាងយាងទៅថ្វាយបង្គំព្រះអយ្យបុត្រចុះ ក៏ត្រាស់ថា បើសេចក្ដីល្អរបស់ ខ្ញុំមាន ព្រះអយ្យបុត្រ នឹងមកកាន់សម្នាក់ខ្ញុំដោយព្រះអង្គឯង ខ្ញុំនឹងថ្វាយបង្គំ ព្រះអយ្យបុត្រនោះ ដែលយាងមកប៉ុណ្ណោះ ដូច្នេះហើយ ក៏មិនយាងទៅ ។

ព្រះសាស្ដាទ្រង់ឲ្យព្រះរាជាកាន់បាត្រ ហើយយាងទៅកាន់បន្ទប់ដ៏មានសិរី របស់ព្រះរាជធីតា មួយអន្លើដោយអគ្គសាវកទាំង ២ ហើយត្រាស់ថា ព្រះ រាជធីតា កាលថ្វាយបង្គំតាមគាប់ចិត្ត មិនគប្បីពោលពាក្យណាមួយឡើយ ហើយគង់លើអាសនៈដែលគេក្រាល ។ ព្រះរាជធីតាយាងមកដោយរហ័ស ចាប់កព្រះបាទទាំង ២ ទម្លាក់សីសៈលើខ្នងព្រះបាទ ថ្វាយបង្គំតាមព្រះ អធ្យាស្រ័យ ព្រះរាជាត្រាស់គុណសម្បត្តិ មានការស្រឡាញ់ និងការរាប់ អានច្រើនក្នុងព្រះសាស្ដា របស់ព្រះរាជធីតាថា បពិត្រព្រះអង្គ កូនស្រីរបស់ ខ្ញុំ បានឮដំណឹងថា ទ្រង់ស្លៀកដណ្ដប់កាសាវពស្ត្រ តាំងអំពីនោះមក នាងក៏ ស្លៀកដណ្ដប់កាសាវពស្ត្រដែរ បានឮថា ទ្រង់សោយភត្តមួយពេល ក៏មាន

កត្តមួយពេលដែរ បានឮថា ទ្រង់លះឧច្ចាសយនមហាសយនា នាងក៏ផ្ទំលើគ្រែតូច ដែលពាសដោយកំណាត់សំពត់ដែរ នាងជ្រាបថា ទ្រង់វៀរចាកផ្កាកម្រង គ្រឿងក្រអូបជាដើម នាងក៏វៀរចាកផ្កា និងគ្រឿងក្រអូបដែរ កាលព្រះញាតិបញ្ជូនដំណឹងមកថា យើងទាំងឡាយ នឹងបដិបត្តិក្នុងញាតិទាំង-ឡាយរបស់ខ្លួន ក៏មិនសម្លឹងមើលសូម្បីត្រឹមតែញាតិមួយអង្គ បពិត្រព្រះមានព្រះភាគ ធីតារបស់ខ្ញុំ ដល់ព្រមដោយគុណយ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ធីតារបស់ទ្រង់ រក្សាគ្រប់គ្រងតែក្នុងឥឡូវនេះ គប្បីរក្សាគ្រប់គ្រងខ្លួន ក្នុងកាលដែលញាណចាស់ក្លាហើយនេះ មិនជាការអស្ចារ្យទេ កាលមុន ព្រះរាជធីតានេះ មិនមានការរក្សា ត្រាច់ទៅត្រង់ជើងភ្នំ ក៏រក្សាខ្លួនបាន ក្នុងកាលដែលញាណមិនទាន់ចាស់ក្លា ដូច្នេះហើយ ទ្រង់បន្ទោបង់នូវសេចក្តីសោករបស់ព្រះរាជធីតានោះ ត្រាស់ចន្ទកិន្នរីជាតក ទ្រង់ឲ្យសោតា-បត្តិផលហើយ ក្រោកចាកអាសនៈ ចៀសចេញទៅ ។

ក្នុងថ្ងៃទី ២ កាលវិវាហមង្គល ទាក់ទងក្នុងការយាងចូលព្រះដំណាក់អភិសេករបស់ននូរាជកុមារកំពុងប្រព្រឹត្តទៅ ព្រះសាស្តាយាងទៅកាន់ដំណាក់របស់ននូរាជកុមារនោះ ទ្រង់ឲ្យព្រះរាជកុមារកាន់បាត្រ មានបំណងឲ្យបួស ទើបត្រាស់មង្គលកថា ហើយក្រោកឡើងចាកអាសនៈ ចៀសចេញទៅ ព្រះនាងជនបទកល្យាណី ឃើញព្រះរាជកុមារកំពុងយាងទៅ ទើបទូលថា បពិត្រអយ្យបុត្រ សូមទ្រង់ប្រញាប់មក ហើយព្រះនាងអើត-កមើល ។ ឯព្រះរាជកុមារនោះ មិនអាចទូលព្រះសាស្តាថា សូមទ្រង់ទទួលយកបាត្រវិញ

ចុះ បានយាងទៅកាន់វិហារនោះឯង នន្ទកុមារនោះមិនប្រាថ្នាឡើយ ព្រះមានព្រះភាគទ្រង់ឲ្យបួសហើយ ។ ព្រះមានព្រះភាគយាងទៅកាន់កបិលពស្តុបុរី ទ្រង់ឲ្យនន្ទកុមារបួសក្នុងថ្ងៃទី ៣ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ រាហុលមាតាតុបតែងព្រះរាជកុមារ បញ្ជូនទៅគាល់ព្រះសាស្តា ដោយព្រះតម្រាស់ថា នែបុត្ត ចូរបាមើលសមណៈដែលមានរូបដូចព្រហ្ម មានពណ៌ដូចមាស ចោមរោមដោយសមណៈ ២ ម៉ឺនអង្គ យ៉ាងនោះ សមណៈនេះជាបិតារបស់បុត្ត សមណៈនោះមានកំណប់ទ្រព្យធំ តាំងអំពីសមណៈនោះចេញបួសហើយ មាតាមិនឃើញកំណប់ទ្រព្យនោះ ចូរបាទៅសូមមត៌កនឹងព្រះសមណៈនោះថា បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាកុមារ បានទទួលអភិសេកហើយ នឹងបានជាស្តេចចក្រពត្តិ ខ្ញុំព្រះអង្គត្រូវការទ្រព្យ សូមទ្រង់ប្រទានទ្រព្យដល់ខ្ញុំព្រះអង្គ ព្រោះបុត្តរមែងជាម្ចាស់ទ្រព្យដែលជារបស់បិតា ដូច្នេះ ។ កុមារយាងទៅកាន់សម្នាក់របស់ព្រះសាស្តានោះឯង បែរជាបាននូវសេចក្តីស្រឡាញ់ចំពោះព្រះបិតា មានចិត្តត្រេកអរ ក្រាបទូលថា បពិត្រសមណៈ ម្លប់របស់ព្រះអង្គត្រជាក់ណាស់ ហើយឈរត្រាស់ពាក្យដទៃៗ ជាច្រើនដ៏សមគួរដល់ទ្រង់ ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់ធ្វើអនុមោទនាហើយ ក្រោកចាកអាសនៈ ចៀសចេញទៅ ។ ឯព្រះកុមារយាងតាមព្រះសាស្តាទៅ ដោយត្រាស់ថា បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំបពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំ ។ ព្រះសាស្តាទ្រង់មិនឲ្យកុមារត្រឡប់ បរិវារជនមិនអាចញ៉ាំងព្រះរាជកុមារដែលយាងទៅព្រមនឹងព្រះ

សាស្តាឲ្យត្រឡប់ ។ ព្រះរាជកុមារនោះ បានយាងទៅកាន់អារាមជាមួយព្រះសាស្តា ដោយប្រការដូច្នេះ ។ ព្រះសាស្តាយាងទៅ ទ្រង់ព្រះតម្រិះថា កុមារនេះប្រាថ្នាទ្រព្យដែលជារបស់បិតា សឹងប្រព្រឹត្តទៅតាមវដ្តៈ ដែលប្រកបសេចក្តីចង្អៀតចង្អល់ ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានដោយចំពោះ ត្រង់ពោធិមណ្ឌលដល់កុមារនេះ តថាគតនឹងធ្វើឲ្យជាម្ចាស់ទ្រព្យដែលជាលោកុត្តរ រួចត្រាស់ហៅព្រះសារីបុត្រមកថា ម្នាលសារីបុត្រ ចូរអ្នកឲ្យរាហុលបួសចុះ ។ កាលព្រះរាជកុមារបួសហើយ ទុក្ខមានប្រមាណក្រៃលែង កើតឡើងដល់ព្រះរាជា ។ កាលទ្រង់មិនអាចអត់សង្កត់នូវសេចក្តីទុក្ខនោះ ទើបទូលឲ្យព្រះសម្ពុទ្ធទ្រង់ជ្រាបហើយ ទ្រង់សូមពរថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គសូមឱកាស លោកម្ចាស់ទាំងឡាយ មិនគប្បីបំបួសកុលបុត្រ ដែលឪពុកម្តាយមិនបានអនុញ្ញាតឡើយ ។ ព្រះសាស្តាទ្រង់ទទួលព្រះរាជតម្រាស់របស់ព្រះរាជានោះ ក្នុងថ្ងៃស្អែកឡើង សោយព្រះក្រយាហារព្រឹកក្នុងព្រះរាជនិវេសន៍ ព្រះរាជាគង់ក្នុងចំណែកម្ខាង ត្រាស់ថា បពិត្រព្រះអង្គ ក្នុងកាលទ្រង់បំពេញទុក្ករកិរិយា ទេវតាមួយអង្គចូលមករកខ្ញុំ ពោលថា ឱរសរបស់ព្រះអង្គធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះ ឃាត់ទេវតានោះថា កូនរបស់ខ្ញុំ បើមិនទាន់សម្រេចនូវពោធិញ្ញាណ មិនធ្វើកាលកិរិយាឡើយ ព្រះសម្ពុទ្ធត្រាស់ថា ឥឡូវនេះ ទ្រង់ជឿបានដូចម្តេច សូម្បីក្នុងកាលមុន មនុស្សយកឆ្អឹងបង្ហាញ ពោលថា កូនរបស់អ្នកស្លាប់ហើយ ក៏ទ្រង់នៅតែមិនជឿ ហើយត្រាស់មហាធម្មបាលជាតក

ព្រោះអត្ថុប្បត្តិហេតុនេះ ។ ក្នុងកាលចប់គាថា ព្រះរាជាតាំងនៅអនាគាមិផល ។ ព្រះសាស្តាទ្រង់ឲ្យបិតាតាំងនៅក្នុងផលទាំង ៣ ដោយប្រការដូច្នេះហើយ មានភិក្ខុសង្ឃចោមរោមហើយ យាងទៅកាន់ក្រុងរាជគ្រឹះទៀត ទ្រង់គង់ត្រង់ព្រៃសីតវ័ន ។

សម័យនោះ អនាថបិណ្ឌិកសេដ្ឋី យករទេះ ៥០០ ដាក់ទំនិញ ទៅកាន់ផ្ទះរបស់សេដ្ឋីដែលជាសម្លាញ់របស់ខ្លួន[១] ក្នុងក្រុងរាជគ្រឹះ បានឮថា ព្រះសាស្តាទ្រង់កើតឡើងក្នុងក្រុងរាជគ្រឹះនោះ ក្នុងពេលទៀបភ្លឺ បានចូលទៅគាល់ព្រះសាស្តាតាមទ្វារដែលបើកដោយអានុភាពរបស់ទេវតា ស្តាប់ធម៌ហើយ តាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃទី ២ បានថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន បានសូមឲ្យព្រះសាស្តាទ្រង់ទទួលប្តេជ្ញា ដើម្បីយាងមកក្រុងសាវត្ថី ក្នុងចន្លោះផ្លូវ បានឲ្យទ្រព្យ ១ សែនសាងវិហារ ១ យោជន៍មួយៗ ក្នុងទីប្រមាណ ៤៥ យោជន៍ រួចទិញឧទ្យានរបស់ព្រះអង្គម្ចាស់ជេត ដោយប្រាក់ ១៨ កោដិ ដោយក្រាលកហាបណៈប្រមាណ ១ កោដិលើផ្ទៃដី ហើយធ្វើការកសាងស្រេច គឺសាងព្រះគន្ធកុដិ ដើម្បីព្រះទសពលត្រង់កណ្តាល ហើយសាងវិហារដែលគួរជាទីត្រេកអរ ជុំវិញព្រះគន្ធកុដិនោះ ក្នុងផ្ទៃដីដែលគួរជាទីត្រេកអរ ដោយបរិច្ចាគប្រាក់ ១៨ កោដិ គឺសាងសេនាសនៈ ដូចជាកុដិទោល កុដិ ២ ខ្នង ផ្ទះកំពូល សាលា និងបារាំ និងស្រះបោក្ខរណី ទីចង្ក្រម ទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃជាដើម ជាអាវាសសម្រាប់

---

១- ក្នុងវិនយបិដក សេនាសនក្ខន្ធកថា ទៅផ្ទះរបស់រាជគហសេដ្ឋីដែលជាបងថ្លៃ ។

អ្នកនៅអាស្រ័យម្នាក់ឯង តាមលំដាប់ៗ ដើម្បីព្រះថេរៈធំ ៨០ អង្គ ហើយបញ្ជូនទូតទៅដើម្បីយាងព្រះសាស្តាមក ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ទូតហើយ មានមហាភិក្ខុសង្ឃជាបរិវារ ចេញអំពីក្រុងរាជគ្រឹះ ដល់ក្រុងសាវត្ថីដោយលំដាប់ ។

ឯមហាសេដ្ឋីត្រៀមនូវការឆ្លងវិហារ ក្នុងថ្ងៃដែលព្រះសាស្តាយាងចូលវត្តជេតពន បានតុបតែងគ្រឿងអលង្ការដល់បុត្រ ដោយគ្រឿងអលង្ការទាំងពួង ហើយបញ្ជូនទៅជាមួយកុមារ ៥០០ ដែលស្អិតស្អាងហើយ ។ សេដ្ឋីបុត្រព្រមទាំងបរិវារ កាន់ទង់ ៥០០ ដែលវិចិត្រដោយកំណាត់សំពត់ ដែលមានពណ៌ ៥ បាននៅក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះទសពល ។ នៅពីក្រោយកុមារទាំងនោះ មានធីតាសេដ្ឋី ២ នាក់ គឺនាងសុភទ្ទា និងចូឡសុភទ្ទា មួយអន្លើដោយកុមារី ៥ រយនាក់ កាន់ថ្នាំងដែលពេញដោយទឹកដើរទៅ ។ ខាងក្រោយកុមារីទាំងនោះ ភរិយារបស់សេដ្ឋី ប្រដាប់ដោយអលង្ការទាំងពួង មួយអន្លើដោយមាតុគ្រាម ៥០០ កាន់ថាសពេញដោយអាហារ ចេញទៅក្រោយគេបង្អស់ ។ ឯមហាសេដ្ឋី ស្លៀកសំពត់ថ្មី មួយអន្លើដោយសេដ្ឋី ៥០០ ដែលស្លៀកសំពត់ថ្មី ឆ្ពោះទៅកាន់ព្រះមានព្រះភាគក្រោយគេបង្អស់ ។ ព្រះសាស្តាទ្រង់ធ្វើឧបាសកបរិស័ទនេះខាងមុខ ចោមរោមដោយមហាភិក្ខុសង្ឃ ធ្វើចន្លោះព្រៃឲ្យមានពណ៌ក្រហមព្រឿងៗ ដូចស្រោចដោយទឹកមាស ដោយរស្មីនៃព្រះសរីរៈរបស់ព្រះអង្គ យាងចូលកាន់វត្តជេតពនវិហារ ដោយពុទ្ធ-លីលា និងដោយពុទ្ធសិរី មិនមានអ្វីប្រៀប ។ លំដាប់នោះ អនាថបិណ្ឌិក-

សេដ្ឋីទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបដិបត្តិក្នុងវិហារនេះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលគហបតី បើដូច្នោះ ចូរអ្នកប្រគេនដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ដែលមកហើយកាន់វិហារនេះចុះ សេដ្ឋីទទួលពុទ្ធដីកាថា សាធុ ហើយកាន់ឃ្លោកមាស ច្រួចលើព្រះហស្តរបស់ព្រះទសពល ហើយប្រគេនដោយពាក្យថា ខ្ញុំព្រះអង្គសូមវេរនូវវត្តជេតពននេះដល់សង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាទ្រង់ទទួលវិហារហើយ កាលទ្រង់ធ្វើអនុមោទនា បានត្រាស់អានិសង្សវិហារទាន ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា

( វិហារ គឺទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពារត្រជាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច និងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់ និងកម្តៅថ្ងៃ ដ៏ក្លាខ្លាំងដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។ វិហារទាន គឺការឲ្យលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយ តែងសរសើរថា ជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរស ( ស្ត្រី ) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ក៏គួរសាងព្រះវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោក ដែលជាពហុស្សុត គឺលោកអ្នកចេះដឹងច្រើនទាំង

ឡាយឲ្យនៅក្នុងទីនោះ ។ គួរមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានចិត្តត្រង់ហើយប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយ ដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសម្ដែងធម៌ជាគ្រឿងបន្ទោបង់ ឲ្យឃ្លាតចាកទុក្ខ គ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះ ។

ចាប់ពីថ្ងៃទី ២ ទៅ អនាថបិណ្ឌិកសេដ្ឋីផ្ដើមទូវការធ្វេីវិហារ ការធ្វេីវិហាររបស់នាងវិសាខា ៤ ខែ ទើបស្រេច តែការធ្វេីវិហាររបស់អនាថ-បិណ្ឌិកសេដ្ឋី ៩ ខែ ទើបស្រេច ដោយចំណាយទ្រព្យ ១៨ កោដិ អនាថ-បិណ្ឌិកសេដ្ឋីចំណាយទ្រព្យ ៥៤ កោដិ ចំពោះវិហារមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងអតីតកាល ក្នុងសម័យព្រះវិបស្សីសម្ពុទ្ធ សេដ្ឋីឈ្មោះបុនព្វសុមិត្តទិញដីដោយការក្រាលឥដ្ឋមាស ហើយសាងសង្ឃារាមប្រមាណមួយយោជន៍ក្នុងទីនោះឯង ក្នុងសម័យព្រះសិខី សេដ្ឋីឈ្មោះសិរិវឌ្ឍ ទិញដីដោយការក្រាលបណ្ដាញមាស ហើយសាងសង្ឃារាមប្រមាណ ៣ គាវុតក្នុងទីនោះឯងសម័យព្រះវេស្សភូ សោត្ថិយៈ[១] ដោយការក្រាលឥដ្ឋមាស ទិញដីដោយការក្រាលប្រអប់ជើងដំរីមាស ហើយសាងសង្ឃារាម ប្រមាណកន្លះយោជន៍ក្នុងទីនោះឯង ក្នុងសម័យនៃព្រះកកុសន្ធៈ សេដ្ឋីឈ្មោះថាអច្ចុតៈ ទិញដី

---

១- ក្នុងទីខ្វះ ជាសោត្ថិជៈ ។

ហើយសាងសង្ឃារាមប្រមាណមួយគាវុត ក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះកោនាគមនៈ សេដ្ឋីឈ្មោះជាឧគ្គៈ ទិញដីដោយក្រាលអណ្តើកមាស ហើយសាងសង្ឃារាមប្រមាណកន្លះគាវុត ក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះកស្សបៈ សេដ្ឋីឈ្មោះសុមង្គល ទិញដីដោយការក្រាលអណ្តើកមាស ហើយសាងសង្ឃារាមប្រមាណ ១៦ ករីស ក្នុងទីនោះឯង ។ ក្នុងសម័យព្រះសាស្តានៃយើង សេដ្ឋីឈ្មោះថា អនាថបិណ្ឌិកទិញដី ដោយក្រាលកហាបណៈចំនួន ១ កោដិ ហើយសាងសង្ឃារាមប្រមាណ ៨ ករីស ក្នុងទីនោះឯង ។ បានឮថា ទីនោះ ជាទីដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ឡើយ ។

តាំងអំពីទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ត្រង់មហាពោធិមណ្ឌល រហូតដល់គ្រែដែលជាទីបរិនិព្វាន ព្រះមានព្រះភាគប្រថាប់នៅក្នុងទីណា ទីនោះឈ្មោះថា **សន្តិកេនិទាន** ដោយប្រការដូច្នេះ ខ្ញុំនឹងពណ៌នាជាតកទាំងពួង ដោយអំណាចសន្តិកេនិទាននោះឯង ។

**និទានកថា ចប់**

# អដ្ឋកថា
# ជាតក ឯកនិបាត

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## អបណ្ណកវគ្គ
## អបណ្ណកជាតក
## អដ្ឋកថា អបណ្ណកជាតក

[១] ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យនគរសាវត្ថី គង់នៅក្នុងវត្តជេតពនមហាវិហារ ត្រាស់អបណ្ណកធម្មទេសនានេះ ជាបឋម ។ សួរថា រឿងនេះកើតឡើង ព្រោះប្រារព្ធបុគ្គលណា ។ ឆ្លើយថា ព្រោះប្រារព្ធសាវករបស់តិរ្ថិយ ៥០០ ដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី ។

សេចក្តីពិស្តារថា ថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី នាំសាវករបស់តិរ្ថិយ ៥០០ នាក់ ដែលជាសម្លាញ់របស់ខ្លួនឲ្យកាន់កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបជាច្រើន និងប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ជាគ្រឿងបិទបាំង ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា បូជាដោយផ្កាកម្រង គ្រឿងក្រអូបជាដើម លះបង់ភេសជ្ជៈ និងសំពត់ប្រគេនដល់ភិក្ខុសង្ឃ ហើយអង្គុយក្នុងទីបំផុត នា

ចំណែកម្ខាង ដោយវៀរទោសនៃការអង្គុយ ៦ ប្រការ ។ សាវកនៃតិរ្ថិយទាំងនោះ ថ្វាយបង្គំព្រះតថាគត ហើយសម្លឹងមើលព្រះភក្ត្រព្រះសាស្តា ដែលរុងរឿងដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត សម្លឹងមើលព្រះវរកាយ ដូចកាយព្រហ្ម ដែលប្រដាប់ដោយលក្ខណៈ និងអនុព្យញ្ជនៈ ចោមរោមដោយព្រះរស្មីមួយព្យាម សម្លឹងមើលពុទ្ធរង្សីដែលផ្សាយចេញជារង្វង់ៗ ជាគូៗ ទើបអង្គុយជិតអនាថបិណ្ឌិកសេដ្ឋី ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់ធម្មកថាដ៏ពីរោះវិចិត្រដោយន័យផ្សេងៗ ដោយព្រះសូរសៀង ដូចសំឡេងព្រហ្ម គួរស្តាប់ ប្រកបដោយអង្គ ៨ ប្រការ ដល់សាវករបស់តិរ្ថិយទាំងនោះ ប្រៀបដូចរាជសីហ៍ជំទង់ បន្លឺសីហនាទលើផ្ទាំងមនោសិលា ដូចផ្គរលាន់ក្នុងរដូវភ្លៀង ដូចធ្វើអាកាសគង្គា[១] ឲ្យហូរចុះមក និងដូចក្រងកែវ ដូច្នោះ ។ សាវករបស់តិរ្ថិយទាំងនោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លា ក្រោកឡើង ថ្វាយបង្គំព្រះទសពល ទម្លាយនូវសរណៈរបស់តិរ្ថិយហើយ បានដល់ព្រះពុទ្ធជាសរណៈ ។ ចាប់តាំងអំពីនោះ ពួកតិរ្ថិយទាំងនោះមានដៃកាន់នូវគ្រឿងក្រអូប និងផ្កាជាដើម ទៅព្រះវិហារ ស្តាប់ធម៌ ឲ្យទានរក្សាសីល ធ្វើឧបោសថកម្មជាមួយអនាថបិណ្ឌិកសេដ្ឋីជានិច្ចកាល ។ លំដាប់នោះ ព្រះសាស្តាបានយាងចេញអំពីក្រុងសាវត្ថី ទៅកាន់ក្រុងរាជគ្រឹះ ។

(១) ខ្សែទឹកមួយខ្សែដែលហូរមកអំពីអនោតត្តស្រះ ត្រោះទៅកាន់ទិសខាងត្បូងប៉ះនិងភ្នំមួយធ្លាក់ទឹកទំហំ ប្រមាណ ៣០ គាវុត ក៏បាញ់ឡើងទៅលើអាកាស អស់ចម្ងាយ ៦០ យោជន៍ ទើបធ្លាក់មកកាន់ផែនដី ទើបធ្លារទឹកនេះ ឈ្មោះថា អាកាសគង្គា ( អដ្ឋកថាបោតលិសូត្រ ) ។

ក្នុងពេលដែលព្រះតថាគតយាងទៅហើយ សាវកតិរ្ថិយទាំងនោះ ក៏បានទម្លាយនូវសរណៈនោះចោល ត្រឡប់ទៅដល់តិរ្ថិយជាសរណៈវិញ តាំងនៅក្នុងឋានៈដែលជាមូលដើមរបស់ខ្លួននោះឯង ចំណែកព្រះសាស្តាសម្ងំ ៧-៨ ខែ បានយាងត្រឡប់ទៅកាន់ជេតពនវិញ ។ អនាថបិណ្ឌិកសេដ្ឋី ក៏នាំសាវកតិរ្ថិយទាំងនោះទៅគាល់ព្រះសាស្តាម្តងទៀត បូជាព្រះសាស្តាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាង ។ ពួកតិរ្ថិយទាំងនោះ ក៏ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងចំណែកម្ខាង ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលដល់ព្រះសាស្តា ដល់ភាពដែលពួកតិរ្ថិយសាវកទាំងនោះ គ្រាទ្រង់ចារិកទៅហើយ បានទម្លាយសរណៈដែលទទួលទុក ត្រឡប់ទៅកាន់យកតិរ្ថិយជាសរណៈ តាំងនៅក្នុងឋានៈដើមវិញ ។ ព្រះសាស្តាទ្រង់បើកមណ្ឌលព្រះឱស្ឋ ដូចបើកប្រអប់កែវ ដែលពេញដោយគ្រឿងក្រអូបផ្សេងៗ ដែលមានក្លិនក្រអូប ដោយគ្រឿងក្រអូបជាទិព្វ ព្រោះអានុភាពវចីសុចរិត ដែលទ្រង់បំពេញឲ្យប្រព្រឹត្តទៅមិនដាច់ អស់កោដិកប្បរាប់មិនអស់ កាលទ្រង់បន្លឺព្រះសូរសៀងដ៏ពីរោះ ត្រាស់សួរថា បានឮថា ពួកអ្នកជាឧបាសកទម្លាយនូវសរណៈ ៣ ហើយដល់នូវតិរ្ថិយជាសរណៈ ពិតឬ ។ សម័យនោះ កាលពួកសាវកតិរ្ថិយទាំងនោះ មិនអាចបិទបាំងបាន នាំគ្នាក្រាបទូលថា ពិតហើយ ព្រះអង្គ ទើបព្រះសាស្តាត្រាស់ថា ម្នាលឧបាសកទាំង-ឡាយ ក្នុងលោកធាតុ ខាងក្រោមទល់គ្នានឹងអវិចីមហានរក ខាងលើទល់គ្នានឹងភវគ្គព្រហ្ម ខាងទទឹងប្រមាណមិនបាន បុគ្គលឈ្មោះថា ដូចគ្នានឹងព្រះពុទ្ធ

ដោយគុណទាំងឡាយ មានសីលជាដើមមិនមាន បុគ្គលដែលក្រៃលែងជាង នឹងមានមកអំពីណា ហើយទ្រង់ប្រកាសគុណរបស់ព្រះរតនត្រ័យ ដែលទ្រង់ប្រកាសដោយព្រះសូត្រទាំងឡាយ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី ។បេ។ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ដូច្នេះ ។

និង ( ក្នុងរតនសូត្រ ) ថា

ទ្រព្យណាមួយក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី ។បេ។ ទ្រព្យនិងរតនវត្ថុទាំងនោះឯង ស្មើដោយព្រះតថាគតមិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដូច្នេះ ។

និង ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ថា បុណ្យ គឺអាយុដ៏ប្រសើរផង សម្បុរកាយដ៏ប្រសើរផង ។បេ។ តែងបានទៅកើតជាទេវតា ឬមនុស្សដល់នូវសេចក្តីប្រសើរ រមែងរីករាយ ដូច្នេះហើយ ទើបត្រាស់ថា បុគ្គលទោះជាឧបាសកក្តី ឧបាសិកាក្តី ជាអ្នកដល់ព្រះរតនត្រ័យ ដែលប្រកបដោយឧត្តមគុណយ៉ាងនេះ ឈ្មោះថា ជាអ្នកកើតក្នុងនរកជាដើម រមែងមិនមានម្យ៉ាងទៀត កាលផុតចាកការកើតក្នុងអបាយហើយ នឹងកើតឡើងក្នុងទេវលោក បានសោយមហាសម្បត្តិ ព្រោះហេតុអ្វី ទើបអ្នកនាំគ្នាទម្លាយសរណៈ

បែបនេះ ហើយដល់នូវត្រៃសរណៈ ធ្វើកម្មដែលមិនសមគួរ ដូច្នេះ ។

ក្នុងទីនេះ ដើម្បីសម្ដែងដល់ភាពដែលបុគ្គលដល់ព្រះរតនត្រ័យជាសរណៈ ដោយអំណាចការរួបផុត និងដោយអំណាចជារតនៈដ៏ឧត្ដម មិនមានការកើតក្នុងអបាយទាំងឡាយ បណ្ឌិតគប្បីសម្ដែងព្រះសូត្រទាំងនេះ ( ទីឃនិកាយ មហាវគ្គ ) ថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ទីរឭកហើយ ពួកជនទោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ។

ពួកជនណាមួយ បានដល់នូវព្រះធម៌ជាទីពឹង ទីរឭកហើយ ពួកជនទោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ។

ពួកជនណាមួយ បានដល់នូវព្រះសង្ឃជាទីពឹង ទីរឭកហើយ ពួកជនទោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ដូច្នេះ ។

និងក្នុងគាថាធម្មបទថា

មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាម និងរុក្ខចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្ដមទេ បុគ្គលអាស្រ័យ

នូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយ-សច្ច ១ និរោធសច្ច ១ កន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯង ជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ដូច្នេះ ។

ព្រះសាស្ដាទ្រង់សម្ដែងធម៌ មានប្រមាណប៉ុណ្ណេះ ដល់ពួកសាវកតិរ្ថិយទាំងនោះ ម្យ៉ាងទៀត ។ ទ្រង់បានសម្ដែងធម៌ដោយន័យជាដើមយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ ឈ្មោះថា ពុទ្ធានុស្សតិកម្មដ្ឋាន ធម្មានុស្សតិកម្មដ្ឋាន សង្ឃានុស្សតិកម្មដ្ឋាន រមែងឲ្យសោតាបត្តិមគ្គ រមែងឲ្យសោតាបត្តិផល រមែងឲ្យសកទាគាមិមគ្គ រមែងឲ្យសកទាគាមិផល រមែងឲ្យអនាគាមិមគ្គ រមែងឲ្យអនាគាមិផល រមែងឲ្យអរហត្តមគ្គ រមែងឲ្យអរហត្តផល កាលទ្រង់សម្ដែងធម៌ហើយ ទើបត្រាស់ថា ពួកអ្នកទម្លាយសរណៈ ដែលមានសភាពបែបនេះ ធ្វើកម្មមិនសមគួរ ហើយម្យ៉ាងទៀត ពុទ្ធានុស្សតិកម្មដ្ឋានជាដើម ជាផ្លូវឲ្យដល់សោតាបត្តិមគ្គជាដើមនេះ គប្បីសម្ដែងដោយព្រះសូត្រទាំងឡាយ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ធម៌ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាស

ចាកតម្រេក ដើម្បីរម្ងត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វានដោយពិត ។ ធម៌ ១ គឺអ្វី ។ គឺពុទ្ធានុស្សតិ ដូច្នេះ ។

កាលព្រះសាស្ដាទ្រង់ទូន្មានឧបាសកទាំងឡាយ ដោយប្រការផ្សេងៗ យ៉ាងនេះហើយ បានត្រាស់ថា ម្នាលឧបាសកទាំងឡាយ ក្នុងកាលមុន មនុស្សទាំងឡាយ កាន់យកវត្ថុដែលមិនមែនសរណៈ ថាជាសរណៈ ដោយការដៅស្មាន ដោយការកាន់យកខុស បានធ្លាក់ទៅជាអាហាររបស់យក្ខ ក្នុងផ្លូវកន្ដារ ដែលអមនុស្សហួងហែង ហើយដល់នូវអន្តរាយធំ ឯពួកមនុស្សដែលកាន់យកប្រពៃតាមធម៌ កាន់យកសេចក្ដីពិត កាន់យកមិនខុស បានដល់នូវទីសួស្ដីក្នុងផ្លូវកន្ដារនោះឯង កាលត្រាស់ហើយ ទ្រង់បាននៅស្ងៀមលំដាប់នោះឯង អនាថបិណ្ឌិកគហបតីក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំព្រះសាស្ដា ពោលសរសើរ ហើយផ្គងអញ្ជលីលើសិរសា ក្រាបទូលយ៉ាងនេះថា ឥឡូវនេះ ការដែលពួកឧបាសកទាំងនេះ ទម្លាយសរណៈដ៏ឧត្ដម ហើយកាន់យកសរណៈដោយការដៅស្មាន កាន់យកខុស ប្រាកដដល់ខ្ញុំព្រះអង្គមុន ឯក្នុងកាលមុន ពួកមនុស្សកាន់យកខុស ដោយការដៅស្មាន មានសេចក្ដីវិនាសហើយ ពួកមនុស្សដែលកាន់យកដោយប្រពៃតាមធម៌ មានសួស្ដីក្នុងផ្លូវកន្ដារ ដែលអមនុស្សហួងហែង កំបាំងនៅឡើយ សម្រាប់ខ្ញុំព្រះអង្គ តែប្រាកដដល់ព្រះអង្គ ខ្ញុំព្រះអង្គសូមឱកាស សូមទ្រង់ធ្វើហេតុនេះឲ្យប្រាកដ ដូចញុំាងព្រះចន្ទពេញវង់ ឲ្យអណ្ដែតឡើងក្នុងអាកាស ដូច្នោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី តថាគតបំពេញបារមី ១០ អស់កាលប្រមាណមិនបាន ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ក៏ដើម្បីកាត់នូវសេចក្តីសង្ស័យរបស់សត្វលោកនោះឯង ចូរអ្នកផ្ទៀងសោតៈស្តាប់ដោយគោរព ដូចបុគ្គលយកថាសមាសដាក់ពេញដោយខ្លាញ់រាវនៃសត្វរាជសីហ៍ដូច្នោះ រួចទ្រង់ញុំាងសតិឲ្យកើតដល់សេដ្ឋី ហើយទ្រង់ធ្វើហេតុការណ៍ដែលអន្តរភពបិទបាំងឲ្យប្រាកដ ដូចទម្លាយដុំពពកទាំងឡាយ នាំព្រះចន្ទចេញមកដូច្នេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសិករដ្ឋ ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញរទេះ នៅក្នុងផ្ទៃអស់ ១០ ខែ ប្រសូតហើយ ដល់នូវការចម្រើនវ័យដោយលំដាប់ បានត្រាច់ធ្វើនូវការជួញដូរដោយរទេះ ៥០០ ។ ព្រះពោធិសត្វនោះ ជួនកាល ចេញទៅកាន់ចុងដែន ជួនកាល ចេញទៅកាន់ដើមដែន ។ ក្នុងក្រុងពារាណសីនោះ មានកូនឈ្មួញរទេះម្នាក់ទៀត ។ កូនឈ្មួញរទេះនោះ ជាបុគ្គលល្ងង់ខ្លៅ ជាបុគ្គលមិនមានបញ្ញា មិនឈ្លាសក្នុងឧបាយ ក្នុងកាលនោះ ព្រះពោធិសត្វយកទំនិញដែលមានតម្លៃច្រើនអំពីក្រុងពារាណសី ដាក់ពេញរទេះ ៥០០ ធ្វើការត្រៀមដើរផ្លូវ ហើយសម្រាក ។ ឯបុត្តឈ្មួញល្ងង់ខ្លៅនោះ ផ្ទុកទំនិញពេញរទេះ ៥០០ ដូចគ្នា ហើយត្រៀមធ្វើដំណើរ ។ ព្រះពោធិសត្វគិតថា បើបុត្តឈ្មួញរទេះល្ងង់ខ្លៅនេះ ទៅព្រមគ្នាជាមួយនឹងអញសោត កាលរទេះ ១០០០ ទៅព្រមគ្នា ផ្លូវក៏មិនគ្រប់គ្រាន់

ខស និងទឹកជាដើមរបស់ពួកមនុស្សក្តី ស្មៅរបស់គោទាំងឡាយក្តី នឹងរកបានលំបាក កូនឈ្មួញរទេះល្ងង់ខ្លៅនេះ គួរទៅមុន ឬអញគួរទៅមុន ។ ទើបព្រះពោធិសត្វហៅកូនឈ្មួញរទេះនោះមកប្រាប់សេចក្តីនោះ ហើយពោលថា យើងទាំង ២ មិនអាចទៅរួមគ្នា អ្នកទៅមុន ឬទៅក្រោយ ។ កូនឈ្មួញរទេះនោះគិតថា បើអញទៅមុន នឹងមានអានិសង្សច្រើន ផ្លូវក៏មិនទាន់បែក គោទាំងឡាយនឹងទំពាស៊ីស្មៅ ដែលមិនទាន់មានអ្នកណាពាល់ត្រូវ ពួកមនុស្សនឹងមានបន្លែដែលជាឧបការៈដល់សម្ល ដែលមិនទាន់អ្នកណាពាល់ត្រូវ ទឹកនឹងថ្លា អញនឹងទៅតាមគាប់ចិត្ត នឹងតាំងតម្លៃទំនិញលក់ដូរបាន ។ ទើបកូនរបស់ឈ្មួញនោះពោលថា សម្លាញ់ ខ្ញុំនឹងទៅមុន ។ ព្រះពោធិសត្វបានឃើញការទៅក្រោយថា មានអានិសង្សច្រើន ព្រះពោធិសត្វគិតយ៉ាងនេះថា មនុស្សទាំងនេះ កាលទៅមុន នឹងធ្វើទីពុំរាបស្មើក្នុងផ្លូវឲ្យរាបស្មើ អញនឹងធ្វើដំណើរតាមផ្លូវដែលជនទាំងនេះទៅហើយ កាលគោបម្រើដែលទៅមុន ស៊ីស្មៅចាស់ និងរឹង គោទាំងឡាយរបស់អញ នឹងស៊ីស្មៅខ្ចីដែលទើបនឹងដុះឡើង បន្លែដែលធ្វើនូវសម្លរបស់ពួកមនុស្សដែលដុះឡើងអំពីទីដែលត្រូវក្តិចយក នឹងជារបស់ឆ្ងាញ់ ក្នុងទីដែលមិនមានទឹក មនុស្សទាំងនេះ នឹងជីកអណ្តូងឲ្យកើតឡើង អញនឹងផឹកទឹកក្នុងអណ្តូងដែលមនុស្សទាំងនេះជីក ឈ្មោះថា ការតាំងតម្លៃទំនិញ ដូចគ្នានឹងការផ្តាច់ជីវិតមនុស្ស អញទៅខាងក្រោយនឹងលក់តាមតម្លៃដែលមនុស្សទាំងនោះតាំងទុក ។ ព្រះពោធិសត្វឃើញអានិ-សង្ស មានប្រមាណប៉ុណ្ណេះ ទើបពោលថា នែសម្លាញ់ ចូរអ្នកទៅមុនចុះ

កូនរបស់ឈ្មួញរទេះដែលល្ងង់ខ្លៅទទួលពាក្យហើយ ទើបទឹមរទេះទាំងឡាយ ចេញទៅ ចូងផុតលំនៅរបស់មនុស្ស គឺដល់មាត់ផ្លូវកន្តារដោយលំដាប់ ។

ឈ្មោះថា កន្តារ មាន ៥ យ៉ាង គឺ **ចោរកន្តារ** កន្តារព្រោះចោរ ១ **វាឡកន្តារ** កន្តារព្រោះសត្វសាហាវ ១ **និរុទកកន្តារ** កន្តារព្រោះមិនមានទឹក ១ **អមនុស្សកន្តារ** កន្តារព្រោះអមនុស្ស ១ **អប្បភក្ខកន្តារ** កន្តារព្រោះមានអាហារតិច ១ ។ ក្នុងកន្តារ ៥ យ៉ាងនោះ ផ្លូវដែលពួកចោរចាំស្កាត់ ឈ្មោះថា កន្តារព្រោះចោរ ផ្លូវដែលមានសីហៈជាដើមនៅអាស្រ័យ ឈ្មោះថា កន្តារព្រោះសត្វសាហាវ ទីដែលមិនមានទឹកងូត ឬទឹកផឹក ឈ្មោះថា កន្តារព្រោះមិនមានទឹក ផ្លូវដែលអមនុស្សនៅអាស្រ័យ ឈ្មោះថា កន្តារព្រោះអមនុស្ស ទីដែលមិនមានរបស់ទំពា មានរបស់កើតអំពីមើមជាដើម ឈ្មោះថា កន្តារព្រោះមានអាហារតិច ។ ក្នុងកន្តារ ៥ យ៉ាងនោះ កន្តារនោះសំដៅយកកន្តារព្រោះមិនមានទឹក និងកន្តារ ព្រោះអមនុស្ស ។ ព្រោះហេតុនោះ ទើបកូនរបស់ឈ្មួញល្ងង់ខ្លៅនោះ រៀបចំពាងធំៗ ដាក់លើរទេះទាំងឡាយ ផ្ទុកពេញដោយទឹក ធ្វើដំណើរកាត់ផ្លូវកន្តារ ៦០ យោជន៍ ។

ក្នុងកាលកូនឈ្មួញរទេះល្ងង់ខ្លៅនោះ ដល់ពាក់កណ្តាលផ្លូវកន្តារ យក្ខដែលនៅអាស្រ័យក្នុងផ្លូវកន្តារគិតថា អញនឹងឲ្យពួកមនុស្សទាំងនេះចាក់ទឹកដែលផ្ទុកមកចោល ធ្វើឲ្យខ្សោយកម្លាំង ហើយស៊ីពួកវាទាំងអស់ ទើបនិម្មិតយានតូច គួរជាទីត្រេកអរ ទឹមដោយគោបម្រើពណ៌ស ចោមរោមដោយអមនុស្ស ១២ នាក់ សើមដោយទឹក និងភក់ កាន់អាវុធ មួយអន្ទើដោយ

ខែលជាដើម ប្រដាប់នូវផ្កាឧប្បល និងផ្កាកុមុទ មានសក់សើម និងសំពត់សើម អង្គុយលើយានតូចនោះ ហាក់បីដូចឥស្សរជន មានកង់យានប្រឡាក់ដោយភក់ ធ្វើដំណើរបញ្រ្ចាសផ្លូវមក ។

ឯពួកអមនុស្ស ដែលជាបរិវាររបស់យក្ខនោះ ដើរទៅមកខាងមុខ និងខាងក្រោយ មានសក់សើម និងសំពត់សើម ប្រដាប់ផ្កាឧប្បល និងផ្កាកុមុទ កាន់បាច់ផ្កាឈូក និងផ្កាបុណ្ឌរិក ទំពាស៊ីក្រអៅឈូក មានតំណក់ទឹក និងភក់ស្រក់ បាននាំគ្នាដើរទៅ ។ ធម្មតាឈ្មួញរទេះទាំងឡាយ កាលណាខ្យល់បក់មកខាងមុខ ក្នុងកាលនោះ នឹងអង្គុយលើយានតូច ចោមរោមដោយអ្នកបម្រើ ចៀសវាងនូវធូលីក្នុងផ្លូវទៅខាងមុខគេ ក្នុងកាលណាខ្យល់បក់មកពីក្រោយ ក្នុងកាលនោះ ក៏នៅពីក្រោយគេ ដោយន័យនោះឯង ។ ក្នុងកាលនោះ មានខ្យល់បក់មកខាងមុខ ព្រោះហេតុនោះ ទើបកូនរបស់ឈ្មួញរទេះល្ងង់ខ្លៅនោះ បររទេះទៅខាងមុខគេ ។ យក្ខនោះឃើញកូនឈ្មួញរទេះនោះកំពុងមក ទើបឲ្យយានតូចរបស់ខ្លួនចុះចេញអំពីផ្លូវ ធ្វើបដិសណ្ឋារៈនឹងកូនឈ្មួញរទេះនោះថា អ្នកទាំងឡាយទៅណា ។ ឯកូនឈ្មួញរទេះក៏ញុំាងយានតូចរបស់ខ្លួន ឲ្យចៀសអំពីផ្លូវ ឲ្យឱកាសរទេះទាំងឡាយទៅ ហើយឈរក្នុងចំណែកម្ខាង ពោលនឹងយក្ខថា អ្នកដ៏ចម្រើន ពួកយើងមកអំពីនគរពារាណសី ឯអ្នកទាំងឡាយ ប្រដាប់ដោយផ្កាឧប្បល និងផ្កាកុមុទ កាន់ផ្កាបទុម និងផ្កាបុណ្ឌរិកជាដើម ទំពាស៊ីនូវមើមឈូកប្រឡាក់ដោយភក់ មានតំណក់ទឹកហូរ នាំគ្នាមក ក្នុងផ្លូវដែលអ្នកទាំងឡាយមក ភ្លៀងធ្លាក់ល្អ មាន

ស្រះទឹក ដេរដាសដោយផ្កាឧប្បលជាដើមឬ យក្ខបានស្តាប់ពាក្យរបស់កូនឈ្មួញរទេះនោះហើយ ទើបពោលថា នែសម្លាញ់ អ្នកនិយាយអ្វី ទីនោះជនព្រៃខៀវស្រងាត់នៅប្រាកដ តាំងអំពីទីនោះទៅ ព្រៃទាំងមូល មានទឹកទូទៅ ភ្លៀងធ្លាក់ជាប្រចាំ សូម្បីញកភ្នំ ក៏ពេញដោយទឹក ក្នុងទីនោះៗ មានស្រះទឹកដេរដាសដោយផ្កាឈូក ។ កាលរទេះទាំងឡាយចូលទៅដោយលំដាប់ ទើបសួរថា អ្នកនាំរទេះទាំងនេះមក នឹងទៅណា ពួកកូនឈ្មួញរទេះពោលថា នឹងទៅកាន់ជនបទឈ្មោះនោះ ។ យក្ខពោលថា ក្នុងរទេះនេះ និងរទេះនេះ មានទំនិញអ្វីខ្លះ ។ កូនរបស់ឈ្មួញរទេះឆ្លើយថា មានទំនិញឈ្មោះនោះ និងឈ្មោះនោះ ។ យក្ខពោលថា រទេះដែលមកខាងក្រោយ ជារទេះដែលធ្ងន់កំពុងមក ក្នុងរទេះនោះ មានទំនិញអ្វី កូនឈ្មួញរទេះពោលថា ក្នុងរទេះនោះ មានទឹក យក្ខពោលថា មុនដំបូង អ្នកទាំងឡាយនាំទឹកមកខាងក្រោយ បានធ្វើនូវការយឺតយូរ តាំងអំពីនេះទៅ កិច្ចដោយទឹក រមែងមិនមាន ខាងមុខ មានទឹកច្រើន ចូរអ្នកទាំងឡាយវាយបំបែកពាង ចាក់ទឹកចោល ចូរទៅដោយរទេះស្រាលចុះ កាលពោលយ៉ាងនេះហើយ ទើបពោលថា ចូរអ្នកទាំងឡាយទៅចុះ ការយឺតយូរនឹងមានដល់ពួកយើង ហើយធ្វើដំណើរទៅបន្តិច ដល់ទីដែលមនុស្សទាំងនោះមើលមិនឃើញ ក៏បានទៅកាន់នគរយក្សរបស់ខ្លួននោះឯង ។

ឯឈ្មួញរទេះល្ងង់ខ្លៅនោះ ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ខ្លៅ ទើបជឿពាក្យរបស់យក្ខនោះ ទើបឲ្យគេវាយពាងទាំងឡាយ មិនសេសសល់ទឹកសូម្បីត្រឹមមួយទូកដៃ ហើយបររទេះទៅខាងមុខ ឈ្មោះថា ទឹកមានប្រមាណ

តិចមិនមាន ។ មនុស្សទាំងឡាយ មិនបានទឹកផឹក នាំគ្នាលំបាកហើយ អ្នកទាំងនោះនាំគ្នាទៅរហូតដល់ព្រះអាទិត្យអស្តង្គត ទើបដោះរទេះ តម្រៀបជារង្វង់ ចងគោត្រង់កង់រទេះ ទឹកមិនមានដល់ពួកគោ បបរ ឬភត្តក៏មិនមានដល់ពួកមនុស្ស ។ ឯពួកមនុស្សមានកម្លាំងថមថយ មិនដាក់ចិត្ត នាំគ្នាដេកលក់ក្នុងទីនោះៗ ក្នុងលំដាប់ដែលជាចំណែកនៃរាត្រី យក្ខទាំងឡាយ មកអំពីនគរយក្ខ ញុំាងគោ និងមនុស្សទាំងឡាយនោះឯង ឲ្យដល់នូវការស្លាប់ ហើយទំពាស៊ីសាច់របស់គោ និងមនុស្សទាំងនោះ សេសសល់ត្រឹមតែរាងឆ្អឹង រួចនាំគ្នាទៅ ជនទាំងអស់នោះ ដល់នូវការវិនាស ព្រោះអាស្រ័យកូនឈ្មួញរទេះល្ងង់ខ្លៅម្នាក់ ដោយប្រការដូច្នេះ ។ ឆ្អឹងដៃជាដើមបានខ្ចាត់ខ្ចាយទៅ ក្នុងទិសតូច-ធំ រទេះ ៥០០ បានតាំងនៅតាមទីដែលផ្ទុកពេញដូចដើម ។

ឯព្រះពោធិសត្វ ចាប់តាំងអំពីថ្ងៃដែលឈ្មួញល្ងង់ខ្លៅចេញទៅហើយ នៅសម្ងំប្រមាណកន្លះខែ ទើបនាំគ្នាចេញចាកព្រះនគរ មួយអន្លើដោយរទេះ ៥០០ ដល់មាត់ផ្លូវកន្តារដោយលំដាប់ ។ ទើបព្រះពោធិសត្វនោះញុំាងពាងឲ្យពេញក្នុងមាត់ផ្លូវកន្តារនោះ នាំយកទឹកជាច្រើនទៅ ឲ្យវាយស្គរប្រកាសក្នុងជំរំ ឲ្យពួកមនុស្សប្រជុំគ្នា ហើយពោលយ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកមិនសុំអនុញ្ញាតអំពីខ្ញុំ កុំចាក់ទឹកសូម្បីត្រឹមមួយទូកដៃ ឈ្មោះថា ដើមឈើពុល រមែងមានក្នុងផ្លូវកន្តារ ស្លឹកឈើ ផ្កាឈើ ឬផ្លែឈើ ដែលអ្នកទាំង-ឡាយ មិនធ្លាប់បរិភោគក្នុងកាលមុនមាន បើពួកអ្នកមិនទាន់បានសួរខ្ញុំ កុំទំពាស៊ី កាលឲ្យឱវាទដល់មនុស្សទាំងឡាយយ៉ាងនេះហើយ ទើបដើរផ្លូវកន្តារ

ដោយរទេះ ៥០០ ។

កាលព្រះពោធិសត្វដល់ផ្លូវកន្តារ យក្ខនោះបានបង្ហាញខ្លួន បញ្ច្រាសផ្លូវគ្នាដល់ព្រះពោធិសត្វ ដោយន័យមុននោះឯង ព្រះពោធិសត្វគ្រាន់តែឃើញយក្ខនោះប៉ុណ្ណោះ បានដឹងថា ក្នុងផ្លូវកន្តារនេះឯង មិនមានទឹក នេះឈ្មោះកន្តារមិនមានទឹក ម្យ៉ាងទៀត បុគ្គលនេះ មានអាកប្បកិរិយាមិនខ្លាចក្រែងអ្នកដទៃ មានភ្នែកក្រហម សូម្បីស្រមោលក៏មិនប្រាកដ កូនឈ្មួញរទេះល្វង់ខ្ញាដែលធ្វើដំណើរទៅមុនតាមផ្លូវនេះ ឲ្យចាក់ទឹកអស់នាំគ្នាលំបាក ព្រមទាំងបរិស័ទ នឹងត្រូវយក្ខនេះស៊ីហើយ ដោយឥតសង្ស័យ តែយក្ខនេះ ប្រហែលជាមិនដឹងភាពដែលអញជាបណ្ឌិត និងភាពដែលអញ ជាអ្នកឈ្លាសក្នុងឧបាយ ។

សម័យនោះ ព្រះពោធិសត្វនោះពោលនឹងយក្ខនោះថា ចូរពួកអ្នកទៅចុះ ពួកយើងឈ្មោះថា ជាឈ្មួញ បើមិនទាន់ឃើញទឹក មិនលះបង់ទឹកដែលដឹកមក តែយើងទាំងឡាយ នឹងចោលក្នុងទីដែលបានឃើញហើយ ធ្វើរទេះទាំងឡាយឲ្យស្រាលហើយ នឹងទៅ ។ ឯយក្ខទៅបានបន្តិច ចូលដល់ទីដែលមើលមិនឃើញ ហើយទៅកាន់នគរយក្ខរបស់ខ្លួននោះឯង លុះយក្ខទៅហើយទើបមនុស្សទាំងពួង ចូលទៅរកព្រះពោធិសត្វពោលថា បពិត្រលោកម្ចាស់ជនទាំងនោះពោលថា នុ៎ះដងព្រៃខៀវស្រងាត់នៅប្រាកដ ចាប់អំពីនោះទៅភ្លៀងធ្លាក់ជានិច្ច ជាអ្នកពាក់កម្រងផ្កាឈូក និងផ្កាកុមុទ កាន់ផ្កាឈូក និងផ្កាបុណ្ឌរិក ទំពាស៊ីនូវមើមឈូក មានសំពត់សើម មានសក់សើម មាន

តំណក់ទឹក និងកក់ហូរស្រក់មក ពួកយើងនឹងចោលទឹក មានរទេះស្រាល នឹងទៅបានរហ័ស ។ ឯព្រះពោធិសត្វបានស្តាប់ពាក្យរបស់ជនទាំងនោះហើយ ឲ្យរទេះសម្រាក ឲ្យមនុស្សទាំងអស់ប្រជុំគ្នាហើយ សួរថា ពួកអ្នកធ្លាប់បាន ស្តាប់មកអំពីបុគ្គលណាម្នាក់ឬថា ក្នុងផ្លូវកន្តារនេះ មានស្រះទឹក ឬស្រះ បោក្ខរណី ។ មនុស្សទាំងឡាយពោលថា បពិត្រលោកម្ចាស់ មិនធ្លាប់បានឮ ព្រះពោធិសត្វពោលថា នេះឈ្មោះថា កន្តារ ព្រោះមិនមានទឹក ។ ឥឡូវនេះ មនុស្សមួយពួកពោលថា ខាងមុខអំពីជង់ព្រៃខៀវនេះ ភ្លៀងធ្លាក់ ជម្មតាខ្យល់ ត្រជាក់ ដែលបក់ទៅក្នុងពេលភ្លៀងមានប្រមាណប៉ុនណា មនុស្សទាំងឡាយ ពោលថា ខ្យល់ត្រជាក់បក់ទៅប្រមាណ ១ យោជន៍ ។ ព្រះពោធិសត្វសួរថា ខ្យល់ និងភ្លៀង ប៉ះខ្ទប់រាងកាយរបស់បុគ្គលសូម្បីម្នាក់ បណ្តាពួកអ្នកមានឬ ។ មនុស្សទាំងឡាយពោលថា មិនមានទេ ។ ព្រះពោធិសត្វសួរថា ជម្មតាដុំ ពពក តែងប្រាកដក្នុងទីមានប្រមាណប៉ុនណា ។ មនុស្សទាំងឡាយពោលថា ក្នុងទីប្រមាណ ៣ យោជន៍ ។ ព្រះពោធិសត្វសួរថា បណ្តាអ្នកទាំងឡាយ បុគ្គលណាម្នាក់ឃើញដុំពពកមួយដុំមានឬ ។ មនុស្សទាំងឡាយពោលថា មិន មានទេ ។

ព្រះពោធិសត្វពោលថា ជម្មតាផ្លេកបន្ទោរប្រាកដក្នុងទីមានប្រមាណប៉ុន ណា ។ មនុស្សទាំងឡាយពោលថា ក្នុងទីប្រមាណ ៤-៥ យោជន៍ ។ ព្រះ ពោធិសត្វសួរថា បណ្តាអ្នកទាំងឡាយ បុគ្គលណាមួយដែលឃើញពន្លឺផ្លេក បន្ទោរមានឬ ។ មនុស្សទាំងឡាយពោលថា មិនមានទេ ។ ព្រះពោធិសត្វ

ពោលថា ធម្មតាផ្គរលាន់ បានឮក្នុងទីមានប្រមាណប៉ុនណា ។ មនុស្សទាំងឡាយពោលថា ក្នុងទី ១-២ យោជន៍ ។ ព្រះពោធិសត្វពោលថា បណ្ដាអ្នកទាំងឡាយ បុគ្គលណាម្នាក់ដែលបានឮសំឡេងផ្គរលាន់មានឬ ។ មនុស្សទាំងឡាយពោលថា មិនមានទេ ។ ព្រះពោធិសត្វពោលថា អ្នកទាំងឡាយស្គាល់មនុស្សនោះឬ ។ មនុស្សទាំងឡាយពោលថា មិនស្គាល់ទេ ។ ព្រះពោធិសត្វពោលថា ជនទាំងនោះ មិនមែនមនុស្ស ជនទាំងនោះជាយក្ខ ពួកវាមកដើម្បីញុះញង់ឲ្យយើងចាក់ទឹកចោល ធ្វើឲ្យខ្សោយកម្លាំងហើយ នឹងទំពាស៊ី កូនឈ្នួលរទេះល្វង់ខ្ញៅដែលទៅមុន មិនឈ្លាសក្នុងឧបាយ នឹងត្រូវយក្ខទាំងនេះធ្វើឲ្យចោលទឹក លំបាកហើយ ទំពាស៊ីដោយពិត រទេះ ៥០០ នឹងចតនៅតាមដែលផ្ទុកពេញនោះឯង ថ្ងៃនេះ ពួកយើងនឹងឃើញរទេះទាំងនោះ អ្នកទាំងឡាយកុំចោលទឹក សូម្បីត្រឹមមួយទូកដៃ ចូរប្រញាប់បររទេះទៅដោយរហ័ស ។

ព្រះពោធិសត្វនោះមកឃើញរទេះ ៥០០ តាមដែលផ្ទុកពេញនោះឯង ធ្អឹងថ្គាមជាដើមរបស់មនុស្សទាំងឡាយ និងរបស់គោ រាត់រាយទៅក្នុងទិសតូចធំ ទើបឲ្យដោះរទេះបោះជំរំ ដោយយករទេះព័ទ្ធជុំវិញ ឲ្យមនុស្ស និងគោបរិភោគអាហារល្ងាច មេឃនៅភ្លឺនៅឡើយ ឲ្យគោទាំងឡាយដេកនៅកណ្ដាល ហើយឲ្យមនុស្សមានកម្លាំងខ្លាំងកាន់ដាវ ធ្វើការរក្សាអស់រាត្រីទាំង ៣ យាម ឈរប៉ុណ្ណោះ មិនដេក រហូតដល់ថ្ងៃរះឡើង ។ ស្អែកឡើង ព្រះពោធិសត្វធ្វើកិច្ចទាំងពួងឲ្យសម្រេចអំពីព្រលឹម ឲ្យគោទាំងឡាយស៊ី ហើយចោល

រទេះដែលមិនរឹងមាំ ឲ្យកាន់យករទេះដែលរឹងមាំ ឲ្យចោលរបស់ដែលមានតម្លៃតិច ឲ្យជញ្ជូនរបស់ដែលមានតម្លៃច្រើន ទៅកាន់ទីដែលប្រាថ្នា លក់របស់ដោយតម្លៃ ចំណេញ ២-៣ ដង នាំបរិស័ទទាំងអស់ ទៅកាន់នគររបស់ខ្លួននោះឯង ។

ព្រះសាស្តា កាលត្រាស់ធម្មកថានេះហើយ ត្រាស់ថា ម្នាលគហបតី ក្នុងកាលមុន បុគ្គលមានប្រក្រតីកាន់យក ដោយការដៅស្មាន ដល់នូវសេចក្តីវិនាសធំ ដោយប្រការដូច្នេះ ឯបុគ្គលដែលមានប្រក្រតីកាន់យកតាមសេចក្តីពិត ផុតចាកកណ្តាប់ដៃរបស់ពួកអមនុស្ស ទៅដល់ទីដែលខ្លួនប្រាថ្នា ដោយសួស្តី ហើយត្រឡប់មកកាន់ទីលំនៅរបស់ខ្លួន កាលទ្រង់បន្តរឿងទាំង ២ ទ្រង់ជាបុគ្គលត្រាស់ដឹងក្រៃលែងឯង ក្នុងអបណ្ណកធម្មទេសនានេះ ទើបត្រាស់គាថានេះថា

បុគ្គលពួកខ្លះ ជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស បុគ្គល
ពួកខ្លះ ត្រិះរិះយកឯង រមែងប្រកាន់ហេតុទី ២ ( ហេតុខុស )
មេធាវីបុគ្គល បានដឹងនូវហេតុដែលខុស និងហេតុដែលមិនខុសនេះ
ហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបណ្ណកំ** បានដល់ ប្រព្រឹត្តទៅយ៉ាងពិតប្រាកដ គឺមិនខុស ជាគ្រឿងនាំចេញចាកទុក្ខ ។ បទថា **ឋានំ** បានដល់ហេតុ ។ ពិតហើយ ក្នុងហេតុ ព្រោះហេតុដែលផល ឈ្មោះថា រមែងតាំងនៅ ព្រោះមានការប្រព្រឹត្តទៅ ទាក់ទងនឹងហេតុនោះ ដូច្នោះ ទើបលោកហៅ

ហេតុនោះថា ឋានៈ និងគប្បីជ្រាបប្រយោគនៃបទថា **ឋានំ** នោះ ក្នុងប្រយោគជាដើមថា **ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ** ( ព្រះតថាគតក្នុងលោកនេះ ) ជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង ជ្រាបច្បាស់តាមពិតនូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង ដូច្នេះ ។ ដូច្នោះសូម្បីដោយបទទាំង ២ ថា **អបណ្ណកដ្ឋានំ** លោកសម្តែងថា ហេតុណានាំមកនូវសេចក្តីសុខ ដោយចំណែកមួយ ហេតុនោះ បណ្ឌិតទាំងឡាយបដិបត្តិហើយ ហេតុដែលប្រព្រឹត្តទៅយ៉ាងពិតប្រាកដ ហេតុដែលល្អ ឈ្មោះថា **អបណ្ណក** នេះ ជាហេតុដែលមិនខុស ជាហេតុនាំចេញចាកទុក្ខ ។ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។ តែកាលពោលដោយប្រភេទសរណគមន៍ ៣ សីល ៥ សីល ៨ សីល ១០ បាតិមោក្ខសំវរៈ ឥន្ទ្រិយ-សំវរៈ អាជីវបារិសុទ្ធិសីលសំវរៈ បច្ចយបដិសេវនៈ គឺការសេពបច្ច័យ ចតុប្បារិសុទ្ធិសីលទាំងអស់ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ជាគរិយានុយោគ ឈាន វិបស្សនា អភិញ្ញា សមាបត្តិ អរិយមគ្គ អរិយផល ទាំងអស់នេះ ជាឋានៈដែលមិនខុស អធិប្បាយថា បដិបទាមិនខុស បដិបទាដែលជាគ្រឿងនាំចេញចាកទុក្ខ ។

ព្រោះហេតុដែលឋានៈដែលមិនខុសនោះ ជាឈ្មោះរបស់បដិបទាជាគ្រឿងនាំចេញចាកទុក្ខ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិបទាដែលមិនខុសនោះ ទើបត្រាស់ព្រះសូត្រនេះ ( អង្គុត្តរនិកាយ តិកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថា អ្នក

ប្រតិបត្តិនូវសេចក្តីប្រតិបត្តិមិនខុស ទាំងហេតុក៏ឈ្មោះថា លោក បានផ្តួង ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ តែជាអ្នកមិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមកគប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ បានឮសំឡេងដោយត្រចៀកហើយ ។បេ។ បានធុំក្លិនដោយច្រមុះហើយ ។បេ។ បានជញ្ជក់ជញ្ជាបរសដោយអណ្តាតហើយ ។បេ។ បានពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយហើយ ។បេ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែជាអ្នកមិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិ

ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានពិចារណាដោយឧបាយនៃប្រាជ្ញា បរិភោគនូវអាហារដោយគិតថា មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថ ៤ ក្តី ការមិនមានទោស គឺមិនខ្ជិលច្រអូសក្តី ការនៅជាសុខក្តី នឹងមានដល់អាត្មាអញដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ( ធម៌ជាគ្រឿងរារាំង ) ដោយការចង្រ្កម ដោយការអង្គុយអស់ ១ ថ្ងៃ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចនូវសីហ-

សេយ្យាសន៍ ផ្អៀងទៅខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងលើជើង ប្រកបដោយសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវសេចក្តីសម្គាល់ថា នឹងក្រោក ហើយក៏ក្រោកក្នុងបច្ឆិមយាមនៃរាត្រី ធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្ក្រម ដោយការអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក ដូច្នេះ ។

ក្នុងព្រះសូត្រនេះ ត្រាស់ធម៌ ៣ ប្រការ ជាអបណ្ណកបដិបទា គឺកិច្ចបដិបត្តិមិនខុសនេះ រមែងប្រើបាន រហូតដល់អរហត្តផលនោះឯង ។ ក្នុងអបណ្ណកបដិបទានោះ សូម្បីអរហត្តផល ក៏រមែងឈ្មោះថា ជាបដិបទាដល់ការនៅដោយផលសមាបត្តិ និងដល់អនុបាទិសេសនិព្វាន ។ បទថា **ឯកេ** បានដល់ បុគ្គលជាបណ្ឌិតពួក ១ ។ ក្នុងបទថា **ឯកេ** នោះ មិនមានការកំណត់យ៉ាងពិតប្រាកដថា បុគ្គលឈ្មោះនោះក៏ពិត តែពាក្យថា **ឯកេ** ដែលប្រែថា ពួក ១ នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅយកព្រះពោធិសត្វ ព្រមទាំងបរិស័ទ ។ បទថា **ទុតិយំ** ក្នុងបទថា **ទុតិយំ អាហុ តក្កិកា** នេះ បានដល់ ហេតុនៃការកាន់យកដោយការដៅស្មាន គឺហេតុដែលមិនជាគ្រឿងនាំចេញចាកទុក្ខ ថាជាទី ២ ចាកឋានៈដែលមិនខុសទី ១ គឺចាកហេតុដែលជាគ្រឿងនាំចេញចាកទុក្ខ ។

ក្នុងបទថា **អាហុ តក្កិកា** នោះ មានការប្រកបសេចក្តីជាមួយបទដំបូងដូចតទៅនេះ បុគ្គលដែលជាបណ្ឌិតពួកមួយ មានព្រះពោធិសត្វជាប្រធាន

កាន់យកឋានៈដែលមិនខុស គឺហេតុដែលប្រព្រឹត្តទៅយ៉ាងពិតប្រាកដ បាន ដល់ ហេតុដែលមិនខុស ហេតុដែលជាគ្រឿងនាំចេញចាកទុក្ខ ចំណែកអ្នកដៅស្មាន មានកូនឈ្មួញវទេះល្ងង់ខ្លៅជាប្រធាននោះ ពាល គឺបានកាន់យកឋានៈដែលប្រព្រឹត្តទៅដោយមិនពិតប្រាកដ គឺហេតុដែលខុស បានដល់ ហេតុដែលមិនជាគ្រឿងនាំចេញចាកទុក្ខ ដែលមានទោសថាជាទី ២ បណ្តាជនទាំង ២ ពួកនោះ ជនដែលកាន់យកឋានៈមិនខុសនោះ ជាអ្នកបដិបត្តិបដិបទា.ស ឯជនដែលកាន់យកហេតុមិនជាគ្រឿងនាំចេញចាកទុក្ខ ពាល គឺការកាន់យកដោយប៉ាន់ស្មានថា ខាងមុខមានទឹក ថាជាទី ២ នោះ ជាអ្នកបដិបត្តិបដិបទាខ្មៅ ។

បដិបទា ២ យ៉ាងនោះ បដិបទា.ស ជាបដិបទាមិនសាបសូន្យ ឯបដិបទាខ្មៅ ជាបដិបទាវិនាស ព្រោះដូច្នោះ ជនដែលបដិបត្តិបដិបទា.ស ជាអ្នកមិនវិនាស ដល់នូវសួស្តី ឯជនដែលបដិបត្តិបដិបទាខ្មៅ ជាអ្នកវិនាសដល់នូវការវិនាសអន្តរាយ ។ ព្រះសាស្តាត្រាស់ដល់អនាថបិណ្ឌិកសេដ្ឋី ដល់អត្ថដូចពណ៌នានេះហើយ ត្រាស់ព្រះតម្រាស់នេះឲ្យក្រៃលែងឡើងថា មេធាវីបុគ្គលបានដឹងនូវហេតុដែលខុស នឹងហេតុដែលមិនខុសនេះហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតទញ្ញាយ មេធាវី** សេចក្តីថា កុលបុត្តដែលប្រកបដោយបញ្ញាដ៏បរិសុទ្ធឧត្តម ដែលបានឈ្មោះថា **មេធា** ដឹងគុណនិងទោស សេចក្តីចម្រើន និងសេចក្តីវិនាស ប្រយោជន៍ និងមិនមែនជា

ប្រយោជន៍ ឋានៈ និងមិនមែនជាឋានៈ ក្នុងឋានៈទាំងឡាយ ពោល គឺការកាន់យកឋានៈមិនខុស និងការកាន់យកដោយការជៅស្មានទាំង ២ គឺក្នុងឋានៈដែលមិនខុស និងឋានៈដែលខុសនេះ ។

បទថា **តំ គណ្ហេ យទបណ្ណកំ** សេចក្ដីថា គួរកាន់យកឋានៈដែលមិនខុស គឺដែលប្រព្រឹត្តទៅដោយពិតប្រាកដ ជាបដិបទា.ស ជាហេតុនាំចេញចាកទុក្ខ ពោល គឺបដិបទាដែលមិនវិនាសនោះឯង ។ ព្រោះហេតុអ្វី ព្រោះភាវៈមានការប្រព្រឹត្តទៅពិតប្រាកដជាដើម ។ ឯក្រៅអំពីនេះ មិនគួរកាន់យក ។ ព្រោះហេតុអ្វី ព្រោះភាវៈមានការប្រព្រឹត្តទៅមិនពិតប្រាកដ ។ ពិតហើយ ឈ្មោះថា អបណ្ណកបដិបទានេះ ជាបដិបទារបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្តទាំងពួងនោះឯង ។ ព្រះពុទ្ធទាំងឡាយ តាំងនៅចំពោះក្នុងអបណ្ណកបដិបទា បំពេញបារមីទាំងឡាយ ដោយសេចក្ដីព្យាយាមមាំ ឈ្មោះថា ជាព្រះពុទ្ធត្រង់មណ្ឌលពោធិព្រឹក្ស ។ សូម្បីព្រះបច្ចេកពុទ្ធ ក៏ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើង សូម្បីពុទ្ធបុត្តទាំងឡាយ ក៏ត្រាស់ដឹងចំពោះសាវកបារមីញាណ ។

ព្រះសាស្ដា ទ្រង់ប្រទានកុសលសម្បត្តិទាំង ៣ កាមាវចរស្ហគ៌ ៦ និងសម្បត្តិក្នុងព្រហ្មលោក ដល់ឧបាសកទាំងនោះ ដោយប្រការដូច្នេះ ក្នុងទីបំផុតទ្រង់សម្ដែងអបណ្ណកធម្មទេសនានេះថា ជាបដិបទាមិនខុស នាំមកនូវអរហត្តផល ឈ្មោះថា បដិបទាដែលខុស ឲ្យនូវការកើតក្នុងអបាយ ៤ និងត្រកូលទាប ៥ ហើយទ្រង់ប្រកាសអរិយសច្ច ៤ ដោយអាការ ១៦ ឲ្យក្រៃលែង

ឡើង ។ ក្នុងពេលចប់អរិយសច្ច ៤ ឧបាសកទាំង ៥០០ នាក់នោះ តាំងនៅក្នុងសោតាបត្តិផល ។

ព្រះសាស្តា កាលទ្រង់សម្តែងព្រះធម្មទេសនានេះហើយ ទ្រង់សម្តែងរឿងទាំងពីរបន្តអនុសន្ធិគ្នា ហើយទ្រង់សមោធានជាតកមកសម្តែង ទ្រង់ធ្វើទេសនាឲ្យចប់ថា កូនឈ្មួញរទេះល្ងង់ខ្លៅក្នុងសម័យនោះ បានជាទេវទត្ត ក្នុងឥឡូវនេះ បរិស័ទរបស់ឈ្មួញរទេះល្ងង់ខ្លៅនោះ បានជាបរិស័ទរបស់ទេវទត្ត ក្នុងឥឡូវនេះ បរិស័ទរបស់ឈ្មួញរទេះដែលជាបណ្ឌិតក្នុងកាលនោះ បានជាពុទ្ធបរិស័ទ ក្នុងឥឡូវនេះ ឯបុត្តរបស់ឈ្មួញរទេះដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អបណ្ណកជាតក ចប់

# សុត្តន្តជាតក

## វណ្ណុបថជាតក

[ ២ ] ( ព្រះសម្ពុទ្ធត្រាស់ថា ) ពួកជនមិនខ្ជិលច្រអូស កាលជីក (ផែនដី ) ត្រង់ផ្លូវខ្សាច់ ឬក្នុងទីទួល បាននូវទឹកត្រង់ផ្លូវនោះ ( យ៉ាងណា ) អ្នកប្រាជ្ញ បរិបូណ៌ដោយព្យាយាម និងកម្លាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវសេចក្ដីស្ងប់រម្ងាប់នៃហឫទ័យយ៉ាងនោះដែរ ។

វណ្ណុបថជាតកទី ២ ចប់

# អដ្ឋកថា

## វណ្ណុបថជាតក

[ ២ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកិលាសុនោ** ដូច្នេះជាដើម ។ សួរថា ទ្រង់ប្រារព្ធអ្នកណា ។ ឆ្លើយថា ទ្រង់ប្រារព្ធភិក្ខុដែលលះបង់សេចក្តីព្យាយាមមួយរូប ។

បានឮមកថា កាលព្រះតថាគតគង់នៅក្នុងនគរសាវត្ថី មានកុលបុត្តអ្នកក្រុងសាវត្ថីម្នាក់ ទៅវត្តជេតពនវិហារ ស្តាប់ព្រះធម្មទេសនាក្នុងសម្នាក់នៃព្រះសាស្តា មានចិត្តជ្រះថ្លា ឃើញទោសក្នុងកាម អានិសង្សក្នុងការចេញចាកកាម ទើបបួស ឧបសម្បទាបាន ៥ វស្សា រៀនបានមាតិកា ២ បទ សិក្សាការប្រព្រឹត្តវិបស្សនា ទទួលកម្មដ្ឋានតាមគាប់ចិត្ត ក្នុងសម្នាក់របស់ព្រះសាស្តា ចូលទៅកាន់ព្រៃ ចាំវស្សា ព្យាយាមអស់ត្រៃមាស មិនអាចធ្វើត្រឹមតែឱភាស ឬនិមិត្តឲ្យកើតឡើងឡើយ ។ លំដាប់នោះ ភិក្ខុនោះមានការគិតដូច្នេះថា ព្រះសាស្តាត្រាស់បុគ្គល ៤ ពួក ក្នុងបុគ្គល ៤ ពួកនោះ អាត្មាអញប្រហែលជាបទបរមបុគ្គល អាត្មាអញប្រហែលជាមិនមានមគ្គ ឬផលក្នុងអត្តភាពនេះ អញនឹងធ្វើអ្វីដោយការនៅព្រៃ អញនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា មើលព្រះរូបរបស់ទ្រង់ ដែលដល់នូវលម្អនៃព្រះរូបយ៉ាងក្រៃលែង ស្តាប់ព្រះធម្មទេសនាដ៏ពីរោះល្អជាង លុះគិតហើយ ត្រឡប់មកកាន់ជេតពនមហាវិហារនោះឯងទៀត ។

លំដាប់នោះ ភិក្ខុទាំងឡាយដែលជាសម្លាញ់ធ្លាប់ឃើញគ្នា ពោលនឹងភិក្ខុនោះថា អាវុសោ លោករៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ហើយទៅ

ដោយបំណងថា នឹងធ្វើសមណធម៌ តែឥឡូវនេះ មកដើម្បីត្រេកអរ ដោយការប្រឡូកប្រឡំដោយពួកគណៈ កិច្ចនៃបព្វជិតរបស់លោកដល់ទីបំផុតហើយឬហ្ន៎ លោកជាបុគ្គលមិនមានបដិសន្ធិទេឬ ។ ភិក្ខុនោះពោលថា អាវុសោទាំង-ឡាយ ខ្ញុំមិនបានមគ្គ ឬផល ទើបគិតថា អញប្រហែលជាអភព្វបុគ្គល ទើបបានលះសេចក្ដីព្យាយាម ហើយមក ។ ភិក្ខុទាំងឡាយពោលថា អាវុសោ លោកបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលជាអ្នកមានសេចក្ដីព្យាយាមមាំ ហើយធ្វើនូវវត្ថុដែលមិនមែនហេតុហើយ មកចុះ ពួកយើងនឹងបង្ហាញលោកដល់ព្រះតថាគត ។ កាលពោលហើយ ទើបភិក្ខុទាំងនោះនាំភិក្ខុនោះទៅកាន់សម្នាក់របស់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ឃើញភិក្ខុនោះ ទើបត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ ពួកអ្នកនាំភិក្ខុដែលមិនប្រាថ្នារូបនេះមកធ្វើអ្វី ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ មិនអាចធ្វើសមណធម៌ លះបង់នូវសេចក្ដីព្យាយាមមកហើយ ។ គ្រានោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ បានឮថាអ្នកលះបង់សេចក្ដីព្យាយាមពិតឬ ភិក្ខុនោះក្រាបទូលថា ពិតហើយ ព្រះអង្គ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ ហេតុអ្វី ទើបមិនឲ្យគេដឹងយ៉ាងនេះថា ខ្លួនជាអ្នកប្រាថ្នាតិច សន្ដោស ជាអ្នកប្រកបដោយវិវេក ឬជាបុគ្គលមិនជាប់ជំពាក់ ឬជាអ្នកប្រារព្ធសេចក្ដីព្យាយាម បែរជាឲ្យគេស្គាល់ថា ជាអ្នកលះបង់សេចក្ដីព្យាយាម

ក្នុងកាលមុន អ្នកជាបុគ្គលប្រកបដោយសេចក្តីព្យាយាមមិនមែនឬ កាលរទេះ ៥០០ ទៅក្នុងផ្លូវកន្តារព្រោះខ្សាច់ ពួកមនុស្ស និងគោទាំងឡាយ បាននូវទឹកផឹក មានសេចក្តីសុខ ព្រោះអាស្រ័យសេចក្តីព្យាយាមដែលអ្នកម្នាក់ឯងធ្វើហើយ ព្រោះហេតុអ្វី ឥឡូវនេះ ទើបអ្នកលះបង់សេចក្តីព្យាយាម ភិក្ខុនោះ បាននូវកម្លាំងចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

ឯភិក្ខុទាំងឡាយ បានស្តាប់ព្រះតម្រាស់នោះ ទើបអារាធនាព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីព្យាយាមដែលភិក្ខុនេះលះបង់ហើយ ប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយ ក្នុងឥឡូវនេះហើយ ចុះក្នុងកាលមុន គោ និងមនុស្សទាំងឡាយ បានផឹកទឹកមានសេចក្តីសុខ ក្នុងផ្លូវកន្តារព្រោះខ្សាច់ អាស្រ័យសេចក្តីព្យាយាមដែលភិក្ខុនេះធ្វើ កំបាំងសម្រាប់ខ្ញុំព្រះអង្គទាំងឡាយ ប្រាកដដល់ព្រះអង្គ ដែលទ្រង់សម្រេចសព្វញ្ញុតញ្ញាណប៉ុណ្ណោះ សូមទ្រង់ត្រាស់ហេតុនេះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ ព្រះសាស្តាញ៉ាំងស្មារតី ឲ្យកើតដល់ភិក្ខុទាំងឡាយ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយស្តាប់ ហើយបានធ្វើហេតុដែលអន្តរកពបិទបាំងឲ្យប្រាកដថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ដែនកាសី ព្រះពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញរទេះ ។ ព្រះពោធិសត្វនោះចម្រើនវ័យហើយ ត្រាច់ធ្វើការជួញដូរដោយរទេះ ៥០០ ។ ព្រះពោធិសត្វធ្វើដំណើរកាត់ផ្លូវកន្តារ ព្រោះខ្សាច់មួយកន្លែង មានប្រមាណ ៦០ យោជន៍ ក្នុងផ្លូវកន្តារនោះ ខ្សាច់ល្អិតមួយក្តាប់ដែលកាន់ត្រង់ដៃ តាំងអំពីព្រះ

អាទិត្យរះឡើង មានការក្ដៅដូចរងើកភ្លើង មិនអាចដូងទៅបាន ព្រោះហេតុនោះ ព្រះពោធិសត្វនោះ កាលធ្វើដំណើរកាត់ផ្លូវកន្ដារនោះ ទើបយករទេះដាក់ឧស ទឹក ប្រេង និងអង្ករជាដើម ធ្វើដំណើរក្នុងពេលយប់ ក្នុងពេលថ្ងៃរះឡើង ធ្វើរទេះឲ្យជារង្វង់ហើយ ធ្វើបារាំខាងលើ ធ្វើកិច្ចក្នុងរឿងអាហារឲ្យសម្រេចអំពីព្រលឹមហើយ អង្គុយក្នុងម្លប់អស់ថ្ងៃ កាលព្រះអាទិត្យអស្ដង្គតហើយ បរិភោគអាហារល្ងាច កាលផែនដីត្រជាក់ ទើបទឹមរទេះចេញដំណើរទៅ ការទៅ ដូចគ្នានឹងការទៅក្នុងសមុទ្រនោះឯង មានក្នុងផ្លូវកន្ដារនោះ ជម្ងាអ្នកកំណត់បទ គឺអ្នកនាំផ្លូវ គួរមាន ព្រោះហេតុនោះ ទើបព្រះពោធិសត្វឲ្យធ្វើការប្រកបការ ទៅរបស់ពួករទេះ តាមសញ្ញារបស់ផ្កាយ ។

ក្នុងកាលនោះ ឈ្មួញរទេះនោះ កាលទៅកាន់ផ្លូវកន្ដារនោះតាមទំនងនោះឯង ទើបទៅបាន ៥៩ យោជន៍ គិតថា ឥឡូវនេះ ដោយរាត្រីមួយប៉ុណ្ណោះនឹងចូងផុតវាលខ្សាច់ ទើបបរិភោគអាហារល្ងាច ប្រើឧស និងទឹកទាំងពួងឲ្យអស់ហើយ ទឹមរទេះបរទៅ អ្នកនាំផ្លូវឲ្យក្រាលអាសនៈក្នុងរទេះមុនគេ ដេកមើលផ្កាយក្នុងលម្ហមេឃប្រាប់ថា ចូរបរទៅខាងនេះ ចូរបរទៅខាងនោះ អ្នកនាំផ្លូវនោះហត់នឿយ ព្រោះខានដេកអស់កាលយូរ ក៏ដេកលក់ទៅ កាលគោត្រឡប់ក្រោយ ក៏មិនដឹង គោទាំងឡាយបានធ្វើដំណើរទៅអស់មួយយប់ ។ អ្នកនាំផ្លូវភ្ញាក់ឡើងក្នុងពេលអរុណរះ សម្លឹងមើលផ្កាយនក្ខត្តឫក្សហើយ ពោលថា ចូរត្រឡប់រទេះ ចូរត្រឡប់រទេះ គ្រាមនុស្សទាំងឡាយ នាំគ្នាត្រឡប់រទេះតាមលំដាប់នោះឯង ថ្ងៃរះឡើងហើយ ។ មនុស្សទាំងឡាយនាំគ្នាពោលថា

នេះជាទីបោះជំរំរបស់ពួកយើង កាលពីម្សិលមិញ នេះឧស និងទឹករបស់ពួកយើងអស់ហើយ ឥឡូវនេះ ពួកយើងវិនាសហើយ ទើបដោះរទេះតម្រៀបជារង្វង់ ហើយធ្វើបារាំខាងលើ ដេកសោយសោកខាងក្រោមរទេះរៀងៗ ខ្លួន ព្រះពោធិសត្វគិតថា បើអញលះបង់សេចក្ដីព្យាយាម មនុស្សទាំងអស់នោះ នាំគ្នាវិនាស ទាន់ពេលព្រឹក ទើបត្រាច់ទៅ ក្នុងកាលដែលមានភាពត្រជាក់ ឃើញគុម្ពស្បូវក្ដាំងមួយគុម្ព ទើបគិតថា ស្មៅទាំងនេះកើតឡើង ព្រោះភាពត្រជាក់របស់ទឹកខាងក្រោម ទើបឲ្យមនុស្សយកចបមក ឲ្យជីកត្រង់ទីនោះ មនុស្សទាំងនោះ ជីកបានជម្រៅ ៦០ ហត្ថ ។ កាលមនុស្សទាំងឡាយជីកទៅដល់ទីមានប្រមាណប៉ុណ្ណោះ ចបបានទង្គិចនឹងថ្ម លុះចបប៉ះថ្ម មនុស្សទាំងឡាយ ក៏នាំគ្នាលះបង់សេចក្ដីព្យាយាម ឯព្រះពោធិសត្វគិតថា ខាងក្រោមថ្មនេះ គប្បីមានទឹក ទើបចុះទៅឈរត្រង់ផ្ទាំងថ្ម ក្រាបចុះ យកត្រចៀកផ្ទៀងស្ដាប់ បានឮសំឡេងទឹកនៅខាងក្រោម ទើបឡើងមក ប្រាប់អ្នកបម្រើម្នាក់ថា នែបា បើអ្នកលះបង់សេចក្ដីព្យាយាម ពួកយើងនឹងវិនាស អ្នកកុំលះបង់សេចក្ដីព្យាយាម ចូរកាន់យកញញួរដែកនេះចុះក្នុងរណ្ដៅ វាយថ្មនេះ អ្នកបម្រើនោះទទួលពាក្យរបស់ព្រះពោធិសត្វហើយ មិនលះបង់សេចក្ដីព្យាយាម ក្នុងកាលមនុស្សទាំងពួងលះបង់សេចក្ដីព្យាយាម ហើយឈរ ទើបចុះទៅវាយថ្ម ។ ថ្មបែកជា ២ ធ្លាក់ទៅខាងក្រោមទទឹងខ្សែទឹក កម្ពស់ទឹកប្រមាណប៉ុនដើមត្នោតបាញ់ឡើងលើ ។ មនុស្សទាំងពួងនាំគ្នាផឹក ហើយងូត ពុះដុំរទេះ និងនឹមជាដើមដែលសេសសល់ ដាំបបរ និងកត្តបរិភោគ និងឲ្យគោស៊ី កាលព្រះ

អាទិត្យអស្តង្គត ក៏ចងទង់ក្បែរអណ្តូងទឹក ហើយនាំគ្នាទៅកាន់ទីដែលខ្លួនប្រាថ្នា ។ មនុស្សទាំងនោះលក់ទំនិញក្នុងទីនោះ បានលាភ ២-៣ ដង ទើបនាំគ្នាទៅកាន់លំនៅរៀងៗ ខ្លួន ។ មនុស្សទាំងនោះ តាំងនៅក្នុងអត្តភាពនោះ ដរាបអស់អាយុហើយ ទៅតាមយថាកម្ម ។ ឯព្រះពោធិសត្វធ្វើបុណ្យ មានទានជាដើម បានទៅតាមយថាកម្មដូចគ្នា ។

ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់ជាអ្នកត្រាស់ដឹងក្រៃលែងឯង ទើបត្រាស់ព្រះគាថានេះថា

ពួកជនមិនខ្ជិលច្រអូស កាលជីក ( ផែនដី ) ត្រង់ផ្លូវខ្សាច់ ឬក្នុង
ទីទួល បាននូវទឹកត្រង់ផ្លូវនោះ ( យ៉ាងណា ) អ្នកប្រាជ្ញ បរិបូណ៌
ដោយព្យាយាម និងកម្លាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវសេចក្តី
ស្ងប់រម្ងាប់ នៃហឫទ័យយ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អកិលាសុនោ** បានដល់ មិនខ្ជិលច្រអូស គឺប្រារព្ធសេចក្តីព្យាយាម ។ បទថា **វណ្ណុបថេ** សេចក្តីថា ខ្សាច់ លោកហៅថា វណ្ណៈក្នុងផ្លូវខ្សាច់ ។ បទថា **ខណន្តា** ប្រែថា ជីកនូវផែនដី ។ សព្ទថា **ឧទ** ក្នុងបទថា **ឧទង្គណេ** នេះ ជានិបាត សេចក្តីថា ក្នុងទីកណ្តាលវាល អធិប្បាយថា ក្នុងទីដែលសញ្ចរទៅរបស់ពួកមនុស្ស គឺក្នុងភូមិភាគដែលមិនបិទបាំង ។ បទថា **តត្ថ** សេចក្តីថា ក្នុងផ្លូវខ្សាច់នោះ ។ បទថា **បបំ អវិន្ទុំ** ប្រែថា បាននូវទឹក ។ ពិតហើយ ទឹក លោកហៅថា **បបា** ព្រោះជាគ្រឿងផឹក ម្យ៉ាងទៀត ទឹកដែលហូរទៅ ឈ្មោះថា **បបា** អធិប្បាយថា ទឹកច្រើន ។

បទថា **ឯវំ** ជាបទធ្វើឧបមាឲ្យសម្រេច ។ បទថា **មុនិ** សេចក្តីថា ញាណ លោកហៅថា **មោន** ម្យ៉ាងទៀត មោនេយ្យណាមួយ ក្នុងកាយមោនេយ្យជាដើម លោកហៅថា **មោន** បុគ្គលដែលលោកហៅថា មុនី ព្រោះប្រកបដោយ **មោន** នោះ ។ មុនីនោះមានច្រើនយ៉ាង គឺអាគារិយមុនី អនាគារិយមុនី សេក្ខ-មុនី អសេក្ខមុនី បច្ចេកមុនី និងមុនិមុនី ។ បណ្តាមុនីទាំងនោះ គ្រហស្ថដែលសម្រេចផល ដឹងច្បាស់នូវសាសនា ឈ្មោះថា **អាគារិយមុនី** ។ បព្វជិតបែបនោះឯង ឈ្មោះថា **អនាគារិយមុនី** ។ ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា **សេក្ខមុនី** ។ ព្រះខីណាស្រព ឈ្មោះថា **អសេក្ខមុនី** ។ ព្រះបច្ចេកពុទ្ធ ឈ្មោះថា **បច្ចេកមុនី** ។ ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **មុនិមុនី** ។ ក្នុងអត្ថនេះ កាលពោលដោយសរុប បុគ្គលដែលប្រកបដោយបញ្ញា ពោល គឺមោនេយ្យ គប្បីជ្រាបថា **មុនី** ។ បទថា **វិរិយពលូបបន្នោ** បានដល់ បុគ្គលប្រកបដោយសេចក្តីព្យាយាម និងកម្លាំងកាយ កម្លាំងញាណ ។ បទថា **អកិលាសុ** សេចក្តីថា បុគ្គលមិនខ្ជិលច្រអូស គឺឈ្មោះថា ជាអ្នកមិនខ្ជិលច្រអូស ព្រោះប្រកបដោយសេចក្តីព្យាយាម ដែលប្រកបដោយអង្គ ៤ ដែលលោកពោលយ៉ាងនេះថា

សូមឲ្យស្បែកសរសៃ និងឆ្អឹងសល់នៅចុះ ឯសាច់ឈាម ក្នុង
សរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ ដូច្នេះ ។

បទថា **វិន្ទេ ហានយស្ស សន្តឹ** សេចក្តីថា រមែងជួប គឺបានចំពោះនូវអរិយធម៌ ពោល គឺឈាន វិបស្សនា អភិញ្ញា និងអរហត្តមគ្គញ្ញាណ ដែល

ដល់នូវការរាប់ថា សន្តិ ព្រោះធ្វើនូវការត្រជាក់ទាំងចិត្ត និងហទយរូប ។ ពិត ហើយ ព្រះមានព្រះភាគពណ៌នាការនៅជាទុក្ខរបស់អ្នកខ្ជិលច្រអូស និងការ នៅជាសុខរបស់អ្នកប្រារព្ធសេចក្តីព្យាយាម ដោយព្រះសូត្រទាំងឡាយ មិន មែនតិច ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ជិលច្រអូស រមែងច្រឡូកច្រឡំ ដោយអកុសលធម៌ដ៏លាមក នៅជាទុក្ខ ថែមទាំងញ៉ាំងប្រយោជន៍ នៃខ្លួនដ៏ធំឲ្យសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គល ដែលមានព្យាយាមតឹងរ៉ឹង រមែងស្ងប់ស្ងាត់ចាកអកុសលធម៌ដ៏ លាមក នៅជាសុខ ថែមទាំងញ៉ាំងប្រយោជន៍នៃខ្លួនដ៏ធំឲ្យបរិបូណ៌ ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងការនៅជាសុខនោះឯង ដែលបុគ្គលប្រារព្ធ ព្យាយាម ដែលមិនធ្វើនូវការប្រកាន់មាំ ដែលឃើញច្បាស់ គប្បីសម្រេច បានដោយកម្លាំង និងសេចក្តីព្យាយាម ទើបព្រះមានព្រះភាគត្រាស់ថា អ្នក ប្រាជ្ញ បរិបូណ៌ដោយព្យាយាម និងកម្លាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវ សេចក្តីស្ងប់រម្ងាប់នៃហឫទ័យយ៉ាងនោះដែរ ដូច្នោះ លោកអធិប្បាយនេះថា ឈ្មួញទាំងនោះ មិនខ្ជិលច្រអូស ជីកក្នុងផ្លូវខ្សាច់ រមែងបានទឹក យ៉ាងណា ភិក្ខុក្នុងសាសនានេះ ក៏ដូច្នោះ ជាអ្នកឈ្លាស មិនខ្ជិលច្រអូស ព្យាយាម រមែង បាននូវការស្ងប់ចិត្ត មានបឋមជ្ឈានជាដើម ។ ម្នាលភិក្ខុ ក្នុងកាលមុន អ្នក ធ្វើសេចក្តីព្យាយាម ដើម្បីទឹក ឥឡូវនេះ ព្រោះហេតុអ្វី ទើបអ្នកលះបង់នូវ

សេចក្តីព្យាយាមក្នុងសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ ដើម្បីជាប្រយោជន៍ដល់មគ្គផលបែបនេះ ។

ព្រះសាស្តា កាលទ្រង់សម្តែងព្រះធម្មទេសនានេះយ៉ាងនេះហើយ ទើបទ្រង់ប្រកាសសច្ចៈ ៤ ។ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលលះសេចក្តីព្យាយាមតាំងនៅក្នុងអរហត្ត ដែលជាអគ្គផល ។ ព្រះសាស្តាត្រាស់ ២ រឿង បន្តគ្នាទ្រង់ប្រជុំជាតកថា អ្នកបម្រើដែលមិនលះបង់សេចក្តីព្យាយាម បំបែកថ្មឲ្យទឹកដល់មហាជនក្នុងកាលនោះ បានជាភិក្ខុដែលលះបង់សេចក្តីព្យាយាមរូបនេះ ក្នុងឥឡូវនេះ បរិស័ទដ៏សេសក្នុងកាលនោះ បានជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯប្រធានឈ្មួញរទេះ គឺតថាគតនេះឯង ដូច្នេះ បានឲ្យធម្មទេសនាចប់ហើយ ។

## អដ្ឋកថា វណ្ណុបថជាតក ចប់

# សុត្តន្តបិដក

## សេរិវវាណិជជាតក

[ ៣ ] ( ព្រះសម្ពុទ្ធត្រាស់ថា ) បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ ឲ្យឃ្លាតចាកសាសនានេះហើយ អ្នករមែងក្តៅក្រហាយរឿយៗ អស់កាលយូរ ដូចជាពាណិជ ឈ្មោះ សេរិវៈនេះ ។

*សេរិវវាណិជជាតកទី ៣ ចប់*

# អដ្ឋកថា

## សេរិវវាណិជជាតក

[ ៣ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលលះសេចក្តីព្យាយាម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥធចេ នំ វិរាធេសិ** ដូច្នេះជាដើម ។

ព្រះសាស្តា ទ្រង់ឃើញភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយនាំមក ដោយន័យមុននោះឯង ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលឲ្យនូវមគ្គ-ផលយ៉ាងនេះ កាលលះបង់សេចក្តីព្យាយាម នឹងសោយសោកអស់កាលយូរ ដូចសេរិវវាណិជវិនាសចាកថាសមាស ដែលមានតម្លៃមួយសែន ដូច្នោះ ភិក្ខុទាំងឡាយទូលអារាធនាព្រះសាស្តា ដើម្បីទ្រង់សម្តែងរឿងនោះ ឲ្យជាក់ច្បាស់ ។ ព្រះសាស្តា ទ្រង់ធ្វើហេតុដែលកពបិទបាំង ឲ្យប្រាកដ ។

ក្នុងអតីតកាល ក្នុងកប្បទី ៥ បន្ទាប់អំពីភទ្ទកប្បនេះ ព្រះពោធិសត្វបានជាឈ្មួញលោហៈ ឈ្មោះសេរិវៈ ក្នុងដែនសេរិវរដ្ឋ ។ សេរិវវាណិជនោះ កាលទៅដើម្បីលក់ដូរជាមួយឈ្មួញលោហៈឡេះឡោះម្នាក់ ឈ្មោះថា សេរិវៈ ឆ្លងស្ទឹងឈ្មោះនីលពាហៈ ហើយចូលទៅកាន់នគរឈ្មោះអរិដ្ឋបុរៈ ចែកផ្លូវក្នុងព្រះនគរម្នាក់មួយផ្លូវហើយ ដើរលក់ដូរក្នុងផ្លូវដែលជួបជាមួយខ្លួន ។ ឯពាណិជក្រៅអំពីនោះ កាន់យកផ្លូវដែលជួបជាមួយខ្លួនប៉ុណ្ណោះ ។ ក្នុងនគរនោះ មានត្រកូលសេដ្ឋីម្នាក់ ជាត្រកូលបុរាណ ។ កូនក្តី បងក្តី ប្អូនក្តី ទ្រព្យសម្បត្តិទាំងពួងក្តី បានអស់ទៅ ។ មានក្មេងស្រីម្នាក់នៅសល់ និងជីដូន ។ យាយ ចៅ ទាំង ២ នាក់នោះ ធ្វើការស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិត ។ ក្នុង

ផ្ទះមានថាសមាស ដែលមហាសេដ្ឋីរបស់យាយ និងចៅនោះធ្លាប់ប្រើប្រាស់ជាមួយភាជនៈដទៃៗ កាលមិនបានប្រើប្រាស់យូរ ច្រេះក៏ចាប់ យាយ និងចៅមិនស្គាល់ថាសនោះថាជាថាសមាស ។

សម័យនោះ ពាណិជឡេះឡោះនោះត្រាច់ពពាយនាយថា ចូរកាន់យកគ្រឿងប្រដាប់ ចូរកាន់យកគ្រឿងប្រដាប់ បានទៅដល់ទ្វារផ្ទះនោះ ។ កុមារិកានោះ ឃើញពាណិជនោះ ទើបពោលនឹងជីដូនថា លោកយាយ សូមលោកយាយ ទិញគ្រឿងប្រដាប់មួយឲ្យចៅ យាយពោលថា នែនាង យើងជាអ្នកក្រ នឹងយកអ្វីទៅទិញ កុមារិកាពោលថា ពួកយើងមានថាសនេះ ថាសនេះមិនជាឧបការៈដល់ពួកយើង ឲ្យថាសនេះ ហើយកាន់យក ។ ទើបយាយឲ្យហៅនាយពាណិជមកហើយ ឲ្យអង្គុយលើអាសនៈ ឲ្យថាសនោះហើយពោលថា នែអ្នក ចូរអ្នកកាន់យកថាសនេះ ហើយឲ្យគ្រឿងប្រដាប់ណាមួយក៏បាន ដល់ក្មួយស្រីរបស់អ្នក ។ នាយពាណិជយកដៃចាប់ថាសនោះឯង គិតថា ជាថាសមាស ទើបត្រឡប់យកម្ជុលគូសត្រង់គូទថាស ដឹងថា ជាមាស ទើបគិតថា អញនឹងមិនឲ្យវត្ថុណាមួយដល់ជនទាំងនេះ នឹងនាំយកថាសនេះទៅ ហើយពោលថា ថាសនេះ នឹងមានតម្លៃអ្វី តម្លៃរបស់ថាសនេះ មិនដល់តម្លៃកន្លះមាសកៈ ទើបបោះទៅត្រង់ផែនដី ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

ព្រះពោធិសត្វគិតថា អ្នកដទៃរមែងបានចូលទៅកាន់ផ្លូវដែលនាយពាណិជនោះចូលទៅ ហើយចេញទៅ ទើបចូលទៅកាន់ផ្លូវនោះ ស្រែកលក់ថា ចូរកាន់

យកគ្រឿងប្រដាប់ ដូច្នេះ បានទៅដល់ទ្វារផ្ទះនោះឯង ។ កុមារិកានោះ ពោលនឹងជីដូនយ៉ាងនោះឯងទៀត លំដាប់នោះ ជីដូនបានពោលនឹងកុមារិកានោះថា នែចៅ នាយពាណិជមកកាន់ផ្ទះនេះ បោះថាសនោះលើផែនដី ទៅហើយ ឥឡូវនេះ យើងនឹងឲ្យអ្វី ហើយកាន់យកគ្រឿងប្រដាប់ ។ កុមារិកាពោលថា បពិត្រលោកយាយ ពាណិជនោះនិយាយគ្រោតគ្រាត ចំណែកពាណិជនេះ គួរស្រឡាញ់ និយាយទន់ភ្លន់ ប្រហែលជាទទួលយក ជីដូនពោលថា បើដូច្នោះ ចូរហៅបុរសនោះមក ទើបកុមារិកានោះហៅនាយពាណិជនោះមក លំដាប់នោះ យាយ និងចៅ បានឲ្យថាសនោះដល់ព្រះពោធិសត្វ ដែលចូលទៅកាន់ផ្ទះ ហើយអង្គុយ ព្រះពោធិសត្វដឹងថា ថាសនោះជាថាសមាស ទើបពោលថា ថាសនេះមានតម្លៃរាប់សែន ទំនិញដែលមានតម្លៃស្មើថាស មិនមានក្នុងដៃរបស់ខ្ញុំ យាយ និងចៅពោលថា នាយពាណិជដែលមកមុនពោលថា ថាសនេះ មានតម្លៃមិនដល់កន្លះមាសកៈ ហើយបោះថាសលើផែនដី តែថាសនេះកើតជាថាសមាស ព្រោះបុណ្យរបស់អ្នក ពួកយើងឲ្យថាសនេះដល់អ្នក អ្នកឲ្យរបស់ណាមួយ ក៏បានដល់ពួកយើង ហើយកាន់យកថាសនេះទៅចុះ ។ ខណៈនោះ ទើបព្រះពោធិសត្វឲ្យកហាបណៈ ៥០០ ដែលមាននៅក្នុងដៃ និងទំនិញដែលមានតម្លៃ ៥០០ កហាបណៈទាំងអស់ ហើយសូមយកត្រឹមតែជញ្ជីង និងថង់ និងកហាបណៈ ៨ ប៉ុណ្ណោះ កាន់យកថាសនោះ ចៀសចេញទៅ ។ ព្រះពោធិសត្វនោះប្រញាប់ទៅកាន់ច្រាំងស្ទឹង ឲ្យម្ចាស់ទូក ៨ កហាបណៈ ហើយឡើងទូកទៅ ។ ឯនាយពាណិជពាល ត្រឡប់ទៅផ្ទះនោះ

ទៀត ហើយពោលថា ចូរអ្នកនាំថាសនោះមក យើងនឹងឲ្យរបស់ណាមួយ ដល់អ្នក ។ ស្រីនោះជេរពាណិជពាលនោះ ហើយពោលថា អ្នកបានធ្វើ ថាសមាស ដែលមានតម្លៃរាប់សែនរបស់ពួកយើង ឲ្យមានតម្លៃត្រឹមកន្លះ មាសកៈ តែនាយពាណិជដែលមានធម៌ម្នាក់ដូចគ្នានឹងអ្នកនោះឯង ឲ្យទ្រព្យ ១០០០ ដល់ពួកយើង ហើយកាន់យកថាសនោះទៅហើយ ។ ពាណិជពាល បានស្តាប់ដូច្នោះ គិតថា អញជាអ្នកវិនាសចាកថាសមាសដែលមានតម្លៃរាប់ សែន ពាណិជនេះធ្វើការវិនាសធំដល់អញហ្ន៎ កើតសេចក្តីសោកមានកម្លាំង មិនអាចតាំងនូវសតិបាន ក៏ដួលសន្លប់ទៅ បានបាចកហាបណៈដែលនៅក្នុង ដៃ និងរបស់របរត្រង់ទ្វារផ្ទះនោះឯង បោះសំពត់ស្លៀក និងសំពត់ដណ្តប់ កាន់ ជងជញ្ជីងធ្វើជាដំបង ចៀសចេញទៅតាមស្នាមជើងរបស់ព្រះពោធិសត្វ ទៅ ដល់ស្ទឹងនោះ ឃើញព្រះពោធិសត្វកំពុងទៅ ទើបពោលថា នាយទូកដ៏ចម្រើន ចូរត្រឡប់ទូក ព្រះពោធិសត្វឃាត់ថា នែអ្នកកុំត្រឡប់ឡើយ ។

កាលពាណិជពាលក្រៅអំពីនេះ ឃើញព្រះពោធិសត្វទៅនោះឯង កើត នូវសេចក្តីសោកដ៏មានកម្លាំង ហទយៈក្តៅ ខ្ញុរឈាមតាមមាត់ បែកនូវហទយៈ ដូចភក់ក្នុងបឹង ដូច្នោះ ។ ពាណិជពាលនោះ ចងអាឃាតព្រះពោធិសត្វដល់ នូវការអស់ជីវិតក្នុងទីនោះឯង នេះជាការចងអាឃាតក្នុងព្រះពោធិសត្វរបស់ ទេវទត្តគ្រាដំបូង ។ ព្រះពោធិសត្វធ្វើបុណ្យ មានទានជាដើម បានទៅតាម យថាកម្ម ។

ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់ជាអ្នកត្រាស់

ដឹងព្រមចំពោះហើយ បានត្រាស់ព្រះគាថានេះថា

បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ ឲ្យឃ្លាតចាកសាសនានេះហើយ អ្នករមែងក្តៅក្រហាយរឿយៗ អស់កាលយូរ ដូចជាពាណិជឈ្មោះសេរិវៈនេះ ដូច្នះ ។

បណ្តាបទទាំងនោះ បទថា **ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមកំ** សេចក្តីថា បើអ្នកឃ្លៀងឃ្លាត គឺបើអ្នកក្លាំងក្លាត់សោតាបត្តិមគ្គ ពោល គឺការកំណត់នៃព្រះសទ្ធម្មយ៉ាងនេះ ក្នុងសាសនានេះ អធិប្បាយថា អ្នកកាលលះនូវសេចក្តីព្យាយាម នឹងមិនសម្រេច គឺមិនបាន ។ បទថា **ចិរំ ត្វំ អនុតប្បេសិ** សេចក្តីថា កាលបើដូច្នោះ អ្នកកាលសោយសោក គឺកន្ទក់កន្ទេញអស់កាលយូរ ឈ្មោះថា នឹងក្តៅក្រហាយខាងក្រោយសព្វកាល ម្យ៉ាងទៀត ក្នុងបទនេះ មានអធិប្បាយដូច្នេះថា អ្នកកើតក្នុងនរកជាដើម សោយទុក្ខមានប្រការផ្សេងៗ អស់កាលយូរ ឈ្មោះថា នឹងក្តៅក្រហាយក្នុងកាលជាក្រោយ គឺឈ្មោះថា លំបាក ព្រោះភាពជាអ្នកលះបង់សេចក្តីព្យាយាម គឺព្រោះភាពជាអ្នកឃ្លាតចាកអរិយមគ្គ ។ សួរថា នឹងក្តៅក្រហាយខាងក្រោយដូចម្តេច ។ ឆ្លើយថា នឹងក្តៅក្រហាយខាងក្រោយ ដូចនាយពាណិជឈ្មោះសេរិវៈនេះ អធិប្បាយថា ដូចនាយពាណិជនេះ ដែលមានឈ្មោះយ៉ាងនេះថា សេរិវៈ ។ លោកពោលពាក្យអធិប្បាយនេះថា កាលមុន ពាណិជឈ្មោះសេរិវៈបានថាសមាសមានតម្លៃមួយសែន មិនធ្វើសេចក្តីព្យាយាមដើម្បីកាន់យកថាសមាសនោះ ទើបវិនាសចាកថាសមាសនោះ ក្តៅក្រហាយចិត្តក្នុងកាលខាងក្រោយ

យ៉ាងណា សូម្បីអ្នកក៏ដូច្នោះដូចគ្នា កាលមិនសម្រេចអរិយមគ្គ ដែលដូចគ្នានឹងថាសមាស ដែលគេរៀបចំឲ្យក្នុងសាសនានេះ ព្រោះលះសេចក្ដីព្យាយាម ជាអ្នកវិនាសជុំវិញចាកអរិយមគ្គនោះ នឹងក្រៅក្រហាយចិត្តខាងក្រោយអស់កាលយូរ បើមិនលះសេចក្ដីព្យាយាមសោត នឹងបានទូវលោកុត្តរធម៌ទាំង ៩ ក្នុងសាសនារបស់តថាគត ដូចពាណិជដែលជាបណ្ឌិតបានទូវថាសមាសដូច្នោះ ។

ព្រះសាស្ដាទ្រង់កាន់យកកំពូលដោយអរហត្ត ទ្រង់សម្ដែងព្រះធម្មទេសនានេះ ដល់ភិក្ខុនេះយ៉ាងនេះ ហើយទ្រង់ប្រកាសសច្ចៈទាំង ៤ ។ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលលះសេចក្ដីព្យាយាម តាំងនៅក្នុងអរហត្តដែលជាអគ្គផល ។ ព្រះសាស្ដា ក៏ទ្រង់ត្រាស់ ២ រឿង បន្តគ្នា ហើយប្រជុំជាតកថា ពាណិជពាលក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ ពាណិជដែលជាបណ្ឌិត គឺតថាគតនេះឯង ព្រះសាស្ដាទ្រង់ឲ្យទេសនាចប់ហើយ ។

**អដ្ឋកថា សេរិវវាណិជជាតក ចប់**

# សុត្តន្តបិដក

## ចុល្លកសេដ្ឋិជាតក

[ ៤ ] *( ព្រះសាស្តាត្រាស់ថា ) អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។*

*ចុល្លកសេដ្ឋិជាតកទី ៤ ចប់*

# អដ្ឋកថា

## ចុល្លកសេដ្ឋិជាតក

[ ៤ ] ព្រះសាស្តា យាងចូលទៅអាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងជីវកម្ពវ័ន ទ្រង់ប្រារព្ធព្រះចូឡបន្ថកត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អប្បកេនបិ មេធាវី** ដូច្នេះជាដើម ។ ខាងដើម គប្បីពោលការកើតឡើង និងបព្វជ្ជារបស់ចូឡបន្ថកៈ ក្នុងអម្ពវ័ននោះសិន ដែលមានកថាតាមលំដាប់ដូចតទៅនេះ

បានឮថា ក្នុងក្រុងរាជគ្រឹះ មានធីតារបស់សេដ្ឋី អ្នកមានទ្រព្យច្រើន បានធ្វើនូវការជិតស្និទ្ធជាមួយទាសៈរបស់ខ្លួនឯង ខ្លាចអ្នកដទៃដឹងកម្មរបស់ខ្លួន ក៏ពោលយ៉ាងនេះថា ពួកយើងមិនអាចនៅក្នុងទីនេះ បើមាតាបិតារបស់យើងដឹងទោសនេះ នឹងធ្វើឲ្យជាកំណាត់តូច-ធំ ពួកយើងនឹងទៅប្រទេសដទៃ ទើបកាន់យករបស់ដែលសំខាន់ ដែលអាចកាន់យកទៅបាន ចេញតាមទ្វារកំពាំងទាំង ២ នាក់បាននាំគ្នាទៅ ដោយគិតថា នឹងទៅកាន់ទីដែលអ្នកដទៃមិនស្គាល់ ហើយនៅក្នុងទីណាមួយ ។ លុះប្តីប្រពន្ធទាំង ២ នោះ នៅក្នុងទីមួយកន្លែង ព្រោះអាស្រ័យការនៅរួមគ្នា ធីតាសេដ្ឋីក៏តាំងគភ៌ ។ ធីតាសេដ្ឋីនោះអាស្រ័យគភ៌ចាស់ ទើបប្រឹក្សាជាមួយស្វាមី ហើយពោលថា គភ៌របស់ខ្ញុំចាស់ហើយ ការប្រសូតិបុត្រក្នុងទីឆ្ងាយអំពីញាតិ និងមិត្រ រមែងជាទុក្ខ សម្រាប់យើងទាំង ២ ពួកយើងនឹងទៅកាន់ផ្ទះរបស់ត្រកូល ស្វាមីនោះគិតថា បើយើងទៅឥឡូវនេះ ជីវិតរបស់យើងមិនមាន ទើបពន្យាថា នឹងទៅថ្ងៃនេះ នឹងទៅថ្ងៃស្អែកនេះ ធីតាសេដ្ឋីនោះគិតថា ប្តីនេះ ជាមនុស្សល្ងង់ មិនឧស្សាហៈដែលនឹងទៅ ព្រោះ

ទោសរបស់ខ្លួនមានច្រើន ធម្មតា ឪពុកម្ដាយ មានប្រយោជន៍ដោយចំណែក មួយក្នុងបុត្រធីតា ប្ដីនេះ ទៅក្ដី មិនទៅក្ដី អញគួរទៅ កាលប្ដីនោះចេញអំពីផ្ទះ ទើបនាងទុកដាក់បរិក្ខារក្នុងផ្ទះ ប្រាប់ភាពដែលខ្លួនទៅផ្ទះរបស់ត្រកូលដល់អ្នកភូមិផងរបងជាមួយ ហើយធ្វើដំណើរទៅ ។

លំដាប់នោះ បុរសនោះមកកាន់ផ្ទះ មិនឃើញនាង ទើបសួរបុគ្គលដែលស្និទ្ធស្នាល បានឮថា ទៅផ្ទះត្រកូល ទើបប្រញាប់រត់តាមទៅ ទាន់ក្នុងចន្លោះផ្លូវ ។ ឯធីតាសេដ្ឋីនោះ បានប្រសូតបុត្រក្នុងចន្លោះផ្លូវនោះឯង ប្ដីនោះសួរថា នែនាង នេះជាអ្វី ។ ធីតាសេដ្ឋីពោលថា កូនមួយកើតហើយ ស្វាមីពោលថា ឥឡូវនេះ ពួកយើងនឹងធ្វើដូចម្ដេច ធីតាសេដ្ឋីពោលថា ពួកយើងនឹងទៅផ្ទះរបស់ត្រកូល ដើម្បីជាប្រយោជន៍ដល់កម្មណា កម្មនោះ បានសម្រេចហើយក្នុងចន្លោះផ្លូវ ពួកយើងនឹងទៅទីនោះធ្វើអ្វី ពួកយើងនឹងត្រឡប់ ជនទាំង ២ នាក់ ជាអ្នកគិតដូចគ្នាត្រឡប់ហើយ ។ ព្រោះទារកនោះកើតក្នុងចន្លោះផ្លូវ ទើបមាតាបិតាដាក់ឈ្មោះថា បន្ថក: មិនយូរប៉ុន្មាន នាងក៏តាំងគភ៌ទៀត ។ រឿងទាំងពួងគប្បីឲ្យពិស្ដារដោយន័យមុននោះឯង ។ ព្រោះទារកនោះកើតក្នុងផ្លូវទើបមាតាបិតាដាក់ឈ្មោះបុត្តដែលកើតដំបូងថា មហាបន្ថក: ដាក់ឈ្មោះបុត្រទី ២ ថា ចូឡបន្ថក: ។ ស្វាមីភរិយានោះនាំទារកទាំង ២ មកកាន់លំនៅរបស់ខ្លួននោះឯង ។ កាលស្វាមីភរិយាទាំង ២ នោះ នៅក្នុងទីនោះ មហាបន្ថក: បានស្ដាប់ជនដទៃពោលថា មា ពោលថា អ៊ំ ពោលថា តា ពោលថា យាយ ទើបសួរម្ដាយថា បពិត្រអ្នកម៉ែ កុមារដទៃៗ និយាយថា មា និយាយថា អ៊ំ

និយាយថា តា និយាយថា យាយ ញាតិរបស់យើង មិនមានទេឬ មាតា ពោលថា នែបា ក្នុងទីនេះ ញាតិរបស់ពួកយើង មិនមានទេ តែក្នុងនគររាជគ្រឹះ ពួកយើងមានជីតា ឈ្មោះមហាធនសេដ្ឋី ញាតិរបស់ពួកយើង ក្នុងនគររាជគ្រឹះនោះមានច្រើន មហាបន្ថកៈពោលថា ព្រោះហេតុអ្វី ទើបពួកយើងមិនទៅក្រុងរាជគ្រឹះនោះ ។ នាងមិនប្រាប់ហេតុ ដែលខ្លួនមកដល់បុត្រ កាលបុត្រទាំង ២ រំអុកសួរ ទើបពោលនឹងប្តីថា កូនទាំងនេះ ធ្វើយើងឲ្យលំបាកពន់ពេក មាតាបិតាឃើញពួកយើងហើយ នឹងស៊ីសាច់ឬ មក ពួកយើងនឹងបង្ហាញត្រកូលរបស់ជីតាដល់កូនទាំងឡាយ ប្តីពោលថា ខ្ញុំមិនអាចទៅក្នុងទីចំពោះមុខ តែខ្ញុំនឹងនាំទៅ ភរិយាពោលថា សាធុ ពួកកូនទាំងឡាយ គួរឃើញត្រកូលរបស់ជីតានោះឯង ដោយវិធីណាមួយ ។ ជនទាំង ២ នោះនាំទារកទាំង ២ ទៅដល់ក្រុងរាជគ្រឹះដោយលំដាប់ ហើយស្នាក់នៅក្នុងសាលាមួយក្នែង ជិតទ្វារក្រុង ហើយឲ្យគេប្រាប់ដល់មាតាបិតានូវភាពដែលខ្លួននាំទារកទាំង ២ នាក់មក តាយាយទាំងនោះបានស្តាប់ដំណឹងនោះហើយ ពោលថា បុគ្គលឈ្មោះថាមិនមែនបុត្ត មិនមែនធីតា រមែងមិនមានដល់យើងទាំងឡាយ ដែលត្រាច់ទៅក្នុងសង្សារវដ្ត អ្នកទាំងនោះ មានកំហុសច្រើនដល់ពួកយើង អ្នកទាំងនោះមិនអាចតាំងនៅក្នុងគន្លងចក្ខុរបស់ពួកយើង ជនទាំង ២ ចូរកាន់យកទ្រព្យ មានប្រមាណប៉ុណ្ណេះ ទៅកាន់ទីផាសុក ចិញ្ចឹមជីវិតចុះ តែចូរបញ្ជូនទារកទាំង ២ មកក្នុងទីនេះ ។ ធីតាសេដ្ឋីកាន់យកទ្រព្យដែលមាតាបិតាបញ្ជូនមក ហើយបញ្ជូនទារកទាំង ២ ឲ្យទៅក្នុងដៃរបស់ពួកទូត ដែល

មកនោះឯង ទារកទាំង ២ ចម្រើនក្នុងត្រកូលរបស់ជីតា ។

បណ្ដាទារកទាំង ២ នោះ ចូឡបន្ថកៈនៅក្មេងពេក ឯមហាបន្ថកៈ ទៅស្ដាប់ធម្មកថារបស់ព្រះទសពលជាមួយជីតា កាលមហាបន្ថកៈនោះស្ដាប់ធម៌ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដាជានិច្ច ចិត្តក៏បង្អោនទៅដើម្បីបព្វជ្ជា ។ ទើបពោលនឹងជីតាថា បើលោកតាព្រមទទួល ខ្ញុំនឹងបួស ។ ជីតាពោលថា ចៅនិយាយអ្វី ចៅជាទីស្រឡាញ់របស់តា បព្វជ្ជារបស់ចៅប៉ុណ្ណោះ ល្អជាងបព្វជ្ជារបស់សត្វលោកទាំងមូល បើចៅអាច ចូរបួសចុះ ។ កាលទទួលពាក្យហើយទើបទៅកាន់សម្នាក់របស់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា សេដ្ឋី អ្នកបានទារកនេះឬ ។ សេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទារកនេះ ជាចៅរបស់ខ្ញុំព្រះអង្គ ចៅនេះពោលថា នឹងបួសក្នុងសម្នាក់របស់ព្រះអង្គ ទើបទ្រង់ត្រាស់ឲ្យភិក្ខុអ្នកបិណ្ឌបាតជាវត្តមួយរូបថា ចូរអ្នកឲ្យទារកនេះបួស ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់មហាបន្ថកៈនោះ ហើយឲ្យបួស មហាបន្ថកៈនោះរៀនពុទ្ធវចនៈដ៏ច្រើន មានវស្សាគ្រប់បរិបូណ៌ហើយ បានឧបសម្បទាជាឧបសម្បន្ន ធ្វើកម្មដ្ឋានដោយយោនិសោមនសិការ បានសម្រេចអរហត្តហើយ ។

ព្រះមហាបន្ថកៈនោះ សម្ងំនៅក្នុងឈានសុខ និងមគ្គសុខ ទើបគិតថាអញអាចឬទេហ្ន៎ ដើម្បីឲ្យសុខនេះដល់ចូឡបន្ថកៈ លំដាប់នោះ ទើបមហា-បន្ថកៈទៅកាន់សម្នាក់របស់សេដ្ឋីដែលជាជីតា ពោលថា បពិត្រមហាសេដ្ឋីបើលោកយល់ព្រម អាត្មានឹងឲ្យចូឡបន្ថកៈបួស ។ មហាសេដ្ឋីពោលថា សូមឲ្យបួសចុះ លោកម្ចាស់ ព្រះថេរៈឲ្យចូឡបន្ថកៈបួស ហើយឲ្យតាំងនៅក្នុងសីល

១០ សាមណេរចូឡបន្ថកៈ គ្រាន់តែបួសហើយប៉ុណ្ណោះ បានជាអ្នកល្ងង់ខ្លៅ សមដូចលោកពោលថា អស់កាល ៤ ខែ មិនអាចរៀនមួយគាថា ( ក្នុង សំយុត្តនិកាយ សគាថវគ្គ ) ថា

ផ្កាឈូក ( ក្រហមប្រាល ) រីកក្នុងវេលាព្រឹក មានក្លិនក្រអូប មិន ប្រាសចាកក្លិន យ៉ាងណា អ្នកចូរមើលនូវព្រះសម្មាសម្ពុទ្ធ មានរស្មី ផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿង ដូចព្រះអាទិត្យដែលរុងរឿង ក្នុងអាកាសយ៉ាងនោះឯង ដូច្នេះ ។

បានឮថា ព្រះចូឡបន្ថកៈនោះ បួសក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ជាអ្នកមានបញ្ញា បានធ្វើការសើចចំអក ក្នុងពេលដែលភិក្ខុល្ងង់ខ្លៅមួយរូប រៀនឧទ្ទេស ។ ភិក្ខុនោះខ្មាសព្រោះការចំអកនោះ ទើបមិនរៀនឧទ្ទេស មិនធ្វើ ការស្វាធ្យាយ ព្រោះកម្មនោះ ទើបព្រះចូឡបន្ថកៈនេះគ្រាន់តែបួសប៉ុណ្ណោះ កើតជាបុគ្គលល្ងង់ខ្លៅ កាលរៀនបទបន្តៗ ទៅ បទដែលរៀនហើយ ក៏ភ្លេច អស់ទៅ កាលព្រះចូឡបន្ថកៈនោះព្យាយាមរៀនគាថានេះប៉ុណ្ណោះ ៤ ខែកន្លង ទៅហើយ ។ លំដាប់នោះ ទើបព្រះមហាបន្ថកៈ អូសព្រះចូឡបន្ថកៈនោះចេញ អំពីវិហារ ដោយពោលថា ចូឡបន្ថកៈ អ្នកជាអភព្វបុគ្គល ក្នុងសាសនានេះ ព្រោះ ៤ ខែ មិនអាចរៀនមួយគាថាបាន អ្នកនឹងធ្វើកិច្ចនៃបព្វជិតឲ្យដល់ទី បំផុតបានដូចម្ដេច ចូរចេញទៅអំពីវិហារ ។ ព្រះចូឡបន្ថកៈមិនប្រាថ្នាភាពជា គ្រហស្ថ ព្រោះស្រឡាញ់ក្នុងសាសនា ។

គ្រានោះ ព្រះមហាបន្ថកៈបានជាភត្តុទ្ទេសក៍ គឺជាអ្នកចែកភត្ត ។ ពេទ្យ

ជីវកកោមារភច្ច កាន់យកគ្រឿងក្រអូប និងផ្កាជាច្រើន ទៅកាន់អម្ពវ័នរបស់ខ្លួន បូជាព្រះសាស្តា ស្តាប់ធម៌ហើយក្រោកឡើងចាកអាសនៈ ថ្វាយបង្គំព្រះទសពលហើយ ចូលទៅរកព្រះមហាបន្ថកៈ សួរថា បពិត្រលោកម្ចាស់ ក្នុងសម្នាក់របស់ព្រះសាស្តា មានភិក្ខុប៉ុន្មាន ។ ព្រះមហាបន្ថកៈពោលថា មានភិក្ខុប្រមាណ ៥០០ រូប ។ ពេទ្យជីវកពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ទៅទទួលភិក្ខាក្នុងនិវេសន៍របស់ខ្ញុំ ។ ព្រះថេរៈពោលថា ឧបាសក ឈ្មោះព្រះចូឡ-បន្ថកៈ ជាអ្នកល្ងង់ខ្លៅ មានធម៌មិនដុះដាល អាត្មានឹងនិមន្ត ដើម្បីភិក្ខុដ៏សេសវៀរព្រះចូឡបន្ថកៈនោះ ។ ព្រះចូឡបន្ថកៈបានស្តាប់ដូច្នោះ ទើបគិតថា ព្រះថេរៈបងប្រុសរបស់អញ កាលទទួលនិមន្តដើម្បីភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណោះ ក៏ទទួល អញខាងក្រៅ បងប្រុសរបស់អញ ស្អប់អញដោយឥតសង្ស័យ ឥឡូវនេះ ប្រយោជន៍អ្វីដោយសាសនានេះ អញនឹងសឹកទៅជាគ្រហស្ថ ធ្វើបុណ្យ មានទានជាដើម ចិញ្ចឹមជីវិត ។ ថ្ងៃស្អែកឡើង ព្រះចូឡ-បន្ថកៈនោះទៅអំពីព្រលឹម ដោយគិតថា សឹកជាគ្រហស្ថ ។ ក្នុងវេលាទៀបភ្លឺព្រះសាស្តា ទ្រង់ប្រមើលមើលលោក ទ្រង់ឃើញហេតុនោះឯង ទើបយាងទៅមុន ទ្រង់បានចង្ក្រមត្រង់ខ្លោងទ្វារក្បែរផ្លូវដែលព្រះចូឡបន្ថកៈទៅ ។ ព្រះចូឡបន្ថកៈ កាលនឹងដើរទៅកាន់ផ្ទះ ឃើញព្រះសាស្តា ទើបចូលទៅថ្វាយបង្គំ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងចូឡបន្ថកៈនោះថា ចូឡបន្ថកៈអ្នកទៅណាក្នុងពេលនេះ ព្រះចូឡបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បង

ប្រុស អួសខ្ញុំព្រះអង្គចេញ ដោយហេតុនោះ ខ្ញុំព្រះអង្គនឹងទៅដោយគិតថា នឹងជាគ្រហស្ថ ព្រះសាស្តាត្រាស់ថា ម្នាលចូឡបន្ថកៈ ឈ្មោះថា បព្វជ្ជារបស់អ្នក ក្នុងសម្នាក់របស់តថាគត អ្នកត្រូវបងប្រុសអួសចេញទៅ ព្រោះហេតុអ្វីទើបមិនមកកាន់សម្នាក់របស់តថាគត ប្រយោជន៍អ្វីដល់អ្នក ដោយភាពជាគ្រហស្ថ អ្នកនឹងនៅក្នុងសម្នាក់របស់តថាគត ហើយទ្រង់នាំព្រះចូឡបន្ថកៈទៅ ឲ្យព្រះចូឡបន្ថកៈនោះអង្គុយត្រង់យ៉មុខព្រះគន្ធកុដិ ត្រាស់ថា ចូឡបន្ថកៈ ចូរអ្នកបែរមុខទៅកាន់ទិសខាងកើត ចូរនៅក្នុងទីនេះឯង អង្អែលកំណាត់សំពត់ បរិកម្មថា **រជោហរណំ រជោហរណំ** សំពត់ជាគ្រឿងនាំធូលីទៅ សំពត់ជាគ្រឿងនាំធូលីទៅ ហើយទ្រង់ប្រទានសំពត់ដ៏បរិសុទ្ធ ដែលទ្រង់តាក់តែងដោយឫទ្ធិ កាលបុគ្គលក្រាបទូលកត្តកាលឲ្យទ្រង់ជ្រាប ទើបចោមរោមដោយភិក្ខុសង្ឃ យាងទៅកាន់និវេសន៍របស់ពេទ្យជីវក គង់លើអាសនៈដែលគេក្រាលហើយ ឯព្រះចូឡបន្ថកៈ សម្លឹងមើលព្រះអាទិត្យ អង្គុយអង្អែលកំណាត់សំពត់នោះថា **រជោហរណំ រជោហរណំ** កាលព្រះចូឡបន្ថកៈនោះអង្អែលសំពត់នោះ សំពត់បានសៅហ្មង ទើបព្រះចូឡបន្ថកៈគិតថា កំណាត់សំពត់នោះបរិសុទ្ធក្រៃលែង តែព្រោះអាស្រ័យអត្តភាពនេះ ទើបលះប្រក្រតីកើតនូវការសៅហ្មងយ៉ាងនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ទើបផ្តើមតាំងនូវការអស់ទៅ សូន្យទៅ ចម្រើនវិបស្សនា ព្រះសាស្តាទ្រង់ជ្រាបថា ចិត្តរបស់ចូឡបន្ថកៈឡើងកាន់វិបស្សនាហើយ ទើបត្រាស់ថា ម្នាលចូឡបន្ថកៈ អ្នកកុំធ្វើសេចក្តីសម្គាល់ថា កំណាត់សំពត់នោះប៉ុណ្ណោះជារបស់សៅហ្មង ប្រឡាក់

ដោយផង់ធូលី តែធូលី គឺរាគៈជាដើមនោះ មាននៅខាងក្នុង ចូរអ្នកនាំធូលី គឺរាគៈជាដើមនោះទៅហើយ ទ្រង់បញ្ចេញឱភាស ដែលមានព្រះរូបឆោម ប្រាកដដូចគង់ក្នុងទីចំពោះមុខ បានត្រាស់ព្រះគាថានេះ ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា

ធូលី គឺរាគៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺទោសៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺមោហៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃមោហៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលីដូច្នេះ ។

ក្នុងកាលចប់គាថា ព្រះចូឡបន្ថកៈសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ បិដកទាំង ៣ មកដល់ព្រះចូឡបន្ថកៈនោះ មួយអន្លើដោយបដិសម្ភិទាទាំងឡាយនោះឯង ។

បានឮថា ក្នុងកាលមុន ព្រះចូឡបន្ថកៈនោះជាព្រះរាជា កំពុងធ្វើប្រទក្សិណនគរ កាលព្រះសេទោហូរចេញអំពីព្រះនលាដ ទើបយកសំពត់

សាដកបរិសុទ្ធ ជូតព្រះនលាដ សំពត់សាដកបានសៅហ្មង ព្រះរាជាទ្រង់បាននូវអនិច្ចសញ្ញា ដោយអត្ថថា មិនទៀង ព្រោះថា សំពត់សាដកដែលបរិសុទ្ធបែបនេះ លះប្រក្រតីដើម សៅហ្មង ព្រោះអាស្រ័យកាយនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដោយហេតុនោះ សំពត់ជាគ្រឿងនាំចេញនូវធូលីទៅប៉ុណ្ណោះ កើតជាបច្ច័យដល់ព្រះចូឡបន្ថកៈនោះ ។

ឯពេទ្យជីវកកោមារភច្ច នាំទឹកទក្ខិណោទកចូលទៅថ្វាយព្រះទសពល ព្រះសាស្តាយកព្រះហស្តបិទបាត្រ ដោយត្រាស់ថា ម្នាលជីវក ក្នុងវិហារមានភិក្ខុនៅមិនមែនឬ ព្រះមហាបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវិហារមិនមានភិក្ខុមិនមែនឬ ព្រះសាស្តាត្រាស់ថា ម្នាលជីវក ក្នុងវិហារមានភិក្ខុ ។ ទើបទេព្យជីវកបញ្ជូនបុរសទៅ ដោយប្រាប់ថា នែអ្នក បើដូច្នោះ ចូរអ្នកទៅ ម្យ៉ាងទៀត ចូរអ្នកដឹងថា ក្នុងវិហារមានភិក្ខុ ឬមិនមាន ។ ខណៈនោះ ព្រះចូឡបន្ថកៈគិតថា បងប្រុសរបស់អញពោលថា ក្នុងវិហារ មិនមានភិក្ខុ អញនឹងប្រកាសភាពដែលភិក្ខុទាំងឡាយមានក្នុងវិហារដល់បងប្រុសរបស់អញនោះ ហើយបណ្តាលឲ្យអម្ពវ័នទាំងមូល ពេញទៅដោយភិក្ខុទាំងអស់ ភិក្ខុមួយពួក ធ្វើចីវរកម្ម ភិក្ខុមួយពួកជ្រលក់ចីវរ ភិក្ខុមួយពួក ធ្វើការស្វាធ្យាយលោកនិម្មិត ភិក្ខុ ១០០០ រូប ដូចគ្នាយ៉ាងនេះ ។ បុរសនោះឃើញភិក្ខុជាច្រើនក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា បពិត្រលោកម្ចាស់ អម្ពវ័នទាំងមូល ពេញដោយភិក្ខុទាំងឡាយ ។ សមដូចព្រះថេរៈពោល ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

បន្ទកភិក្ខុនិម្មិតខ្លួនជាមួយពាន់ ហើយអង្គុយក្នុងអម្ពវនជាទីរីករាយ ដរាបដល់ការប្រាប់នូវកត្តកាល ដូច្នេះ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងបុរសនោះថា ចូរអ្នកទៅវិហារពោលថា ព្រះសាស្ដាត្រាស់ហៅភិក្ខុឈ្មោះចូឡបន្ថកៈ កាលបុរសនោះទៅពោលយ៉ាងនោះហើយ មាត់រាប់ពាន់ក៏បន្លឺឡើងថា អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ។ បុរសទៅក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ភិក្ខុទាំងអស់ ឈ្មោះចូឡបន្ថកៈនោះឯង ។ ព្រះសាស្ដាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកទៅចាប់ដៃភិក្ខុដែលពោលមុនគេថា អាត្មាឈ្មោះចូឡបន្ថកៈ ភិក្ខុដ៏សេសនឹងអន្តរធានទៅ បុរសនោះបានធ្វើយ៉ាងនោះ គ្រានោះ ភិក្ខុប្រមាណ ១០០០ រូប បានអន្តរធានទៅ ។ ព្រះថេរៈបានទៅជាមួយបុរសនោះ ។ ក្នុងកាលចប់កត្តកិច្ច ព្រះសាស្ដាត្រាស់ហៅជីវកមកថា ម្នាលជីវក ចូរអ្នកទទួលបាត្ររបស់ចូឡបន្ថកៈៗ នេះ នឹងធ្វើអនុមោទនាដល់អ្នក ។ ពេទ្យជីវកបានធ្វើយ៉ាងនោះ ព្រះថេរៈបន្លឺសីហនាទ ដូចរាជសីហ៍ជំទង់ ញុំាងបិដកទាំង ៣ ឲ្យជាក់ច្បាស់ ធ្វើអនុមោទនា ព្រះសាស្ដាក្រោកឡើងចាកអាសនៈ មានភិក្ខុសង្ឃជាបរិវារ យាងទៅកាន់វិហារ កាលភិក្ខុទាំងឡាយសម្ដែងវត្តហើយ ទ្រង់ក្រោកចាកអាសនៈ ទ្រង់ឈរត្រង់យ៉មុខព្រះគន្ធកុដិ ប្រទានសុគតោវាទដល់ភិក្ខុសង្ឃ ហើយត្រាស់ប្រាប់កម្មដ្ឋាន ទ្រង់បញ្ជូនភិក្ខុសង្ឃទៅហើយ យាងចូលព្រះគន្ធកុដិ ដែលអប់ដោយគ្រឿងក្រអូប ដែលមានក្លិនក្រអូប ទ្រង់ចូលសីហសេយ្យា ដោយព្រះបង្អៀងស្ដាំ ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយដូចវាំង-នននសំពត់កម្ពលក្រហម ប្រារព្ធរឿងព្រះគុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ ព្រះមហាបន្ថកៈមិនដឹងអធ្យាស្រ័យរបស់ព្រះចូឡបន្ថកៈ មិនអាចឲ្យរៀនគាថា អស់កាល ៤ ខែ ទាញចេញអំពីវិហារ ដោយពោលថា ចូឡ-បន្ថកៈនេះ ល្ងង់ខ្លៅ តែព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រទានព្រះអរហត្ត ព្រមដោយបដិសម្ភិទាដល់ព្រះចូឡបន្ថកៈនោះ ក្នុងរវាងភត្តមួយប៉ុណ្ណោះ ព្រោះទ្រង់ជាព្រះធម្មរាជាដ៏កំពូល បិដកទាំង ៣ មកព្រមដោយបដិសម្ភិទានោះឯង គួរអស្ចារ្យ ឈ្មោះថា កម្លាំងនៃព្រះពុទ្ធធំក្រៃលែង ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបការប្រព្រឹត្តទៅនៃរឿងនេះ ក្នុងរោងធម្មសភា ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ តថាគតគួរទៅ ទើបទ្រង់ក្រោកឡើងចាកពុទ្ធសេយ្យា ស្លៀកសំពត់ ២ ជាន់ដែលក្រហមល្អ ទ្រង់ចងវត្ថពន្ធចង្កេះ ដូចផ្លេកបន្ទោរ ទ្រង់ដណ្តប់មហាសុគតចីវរ ដូចគ្នានឹងសំពត់កម្ពលក្រហម ចេញអំពីព្រះគន្ធកុដិ ដែលមានក្លិនក្រអូប យាងទៅកាន់រោងធម្មសភា ដោយពុទ្ធលីលា ដូចដំរីចុះប្រេងដ៏ប្រសើរ និងដូចរាជសីហ៍ ដោយការយាងយាសមិនមានទីបំផុត ទ្រង់ឡើងកាន់បវរពុទ្ធាសនៈដែលក្រាល ទ្រង់បញ្ចេញពុទ្ធរស្មីមាន ៦ ពណ៌ ដូចទ្រង់ញុំាងផ្ទៃសមុទ្រឲ្យរញ្ជួយ ដូចព្រះអាទិត្យបញ្ចេញរស្មីស្រទន់ លើកំពូលភ្នំយុគន្ធរ ដូច្នោះ គង់កណ្តាលអាសនៈ កាលព្រះសម្មាសម្ពុទ្ធគ្រាន់តែយាងមកភិក្ខុសង្ឃ វៀរការនិយាយ នៅស្ងៀម ព្រះសាស្តាទ្រង់សម្លឹងមើលបរិស័ទដោយព្រះមេត្តាចិត្តដ៏ស្រទន់ ទ្រង់ព្រះតម្រិះថា បរិស័ទនេះល្អពន់ពេក ការ

គ្នាំគ្នងដៃជើងក្តី សំឡេងក្អក សំឡេងកណ្តាសក្តី របស់ភិក្ខុមួយរូបក៏មិនមាន ភិក្ខុទាំងពួងនេះ មានការគោរពក្នុងព្រះពុទ្ធ ដែលតេជះរបស់ព្រះពុទ្ធគំរាម ហើយ កាលតថាគតគង់ មិនពោលអស់មួយកប្ប ភិក្ខុទាំងឡាយ ក៏មិនតាំងវាចាឡើង ឈ្មោះថា វត្ត ក្នុងការផ្តើមរឿងតថាគតគួរដឹង តថាគតនឹងពោលមុន ទើបត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះសូរសៀង ដូចសំឡេងព្រហ្មដ៏ពីរោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកពោលក្នុងចន្លោះ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ អង្គុយក្នុងទីនេះ មិនពោលតិរច្ឆានកថាដទៃ អង្គុយពណ៌នាគុណទាំងឡាយរបស់ទ្រង់ប៉ុណ្ណោះថា អាវុសោទាំងឡាយ ព្រះមហាបន្ថកៈ មិនដឹងអធ្យាស្រ័យរបស់ព្រះចូឡបន្ថកៈ មិនអាចឲ្យរៀនមួយគាថា អស់កាល ៤ ខែ អូសចេញអំពីវិហារ ដោយពោលថា ចូឡបន្ថកៈនេះល្ងង់ខ្លៅ តែព្រះសម្មាសម្ពុទ្ធបានប្រទានអរហត្ត មួយអន្លើដោយបដិសម្ភិទាដល់ព្រះចូឡបន្ថកៈនោះ ក្នុងចន្លោះភត្តមួយពេលប៉ុណ្ណោះ ព្រោះទ្រង់ជាធម្មរាជាដ៏កំពូល គួរអស្ចារ្យ ឈ្មោះថា កម្លាំងនៃព្រះពុទ្ធទាំងឡាយធំក្រៃលែង ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូឡបន្ថកៈសម្រេចដល់ភាពជាធំក្នុងធម៌ ក្នុងធម៌ទាំង-ឡាយ ក្នុងឥឡូវនេះ ព្រោះអាស្រ័យតថាគត សូម្បីក្នុងកាលមុនចូឡបន្ថកៈនេះ ដល់នូវភាពជាធំក្នុងភោគៈក្នុងភោគៈទាំងឡាយ ក៏ព្រោះអាស្រ័យតថាគត ។ ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះមុនី ដើម្បីត្រាស់រឿងនោះឲ្យ

ជាក់ច្បាស់ ព្រះសាស្តាទ្រង់បានធ្វើហេតុដែលអន្តរកពបិទបាំងឲ្យប្រាកដ ដូចតទៅនេះ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ក្នុងដែនកាសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ចម្រើនវ័យហើយ បានទទួលតំណែងសេដ្ឋី បានឈ្មោះថា ចូឡកសេដ្ឋី ។ ចូឡកសេដ្ឋីនោះជាបណ្ឌិត ឈ្លាសក្នុងនិមិត្តទាំងពួង ។ ថ្ងៃមួយ ចូឡកសេដ្ឋីនោះ ទៅកាន់ទីបម្រើព្រះរាជា ឃើញកណ្តុរងាប់ក្នុងចន្លោះផ្លូវ គណនានក្ខត្តឫក្សក្នុងខណៈនោះហើយ ពោលពាក្យនេះថា កុលបុត្តមានភ្នែក គឺបញ្ញា អាចយកកណ្តុរនេះទៅធ្វើការចិញ្ចឹមកិរិយា និងប្រកបការងារបាន ។

កុលបុត្តក្រីក្រម្នាក់ ឈ្មោះចូឡន្តេវាសិក បានស្តាប់ពាក្យរបស់សេដ្ឋីនោះហើយ គិតថា លោកសេដ្ឋីនេះមិនដឹង មិននិយាយឡើយ ទើបយកកណ្តុរទៅលក់ក្នុងផ្សារមួយកន្លែង ដើម្បីជាចំណីឆ្មា បានទ្រព្យមួយកាកណិក ទើបទិញទឹកអំពៅដោយទ្រព្យមួយកាកណិកនោះ ហើយយកឆ្នាំងមួយដងទឹកទៅ ឃើញពួកមាលាការចេញអំពីព្រៃ ទើបឲ្យទឹកអំពៅម្នាក់បន្តិច ហើយឲ្យទឹកម្នាក់មួយត្រឡោក ពួកមាលាការទាំងនោះ បានឲ្យផ្កាម្នាក់មួយក្តាប់ដល់បុរសនោះ ។

ស្អែកឡើង គាត់យកតម្លៃផ្កានោះ ទិញទឹកអំពៅ និងទឹកផឹកមួយក្អមទៅកាន់សួនផ្កានោះឯង ពួកមាលាការបានឲ្យផ្កាដែលបេះហើយកន្លះបាច់ដល់បុរសនោះ ក្នុងថ្ងៃនោះ ហើយក៏ទៅ មិនយូរប៉ុន្មាន បុរសនោះសន្សំប្រាក់បាន

៨ កហាបណៈដោយឧបាយនេះ ។

ក្នុងថ្ងៃមួយ មានភ្លៀង ខ្យល់ ឈើស្ងួត មែកឈើ និងស្លឹកឈើជាច្រើន ក្នុងព្រះរាជឧទ្យាន ត្រូវខ្យល់កាច់បំបាក់ ធ្លាក់ចុះមក ឧទ្យានបាលមិនឃើញឧបាយ ដើម្បីយកចោល ចូឡន្តេវាសិកទៅក្នុងឧទ្យាននោះ ហើយពោលនឹងអ្នកយាមឧទ្យានថា បើអ្នកឲ្យឈើ និងស្លឹកឈើទាំងនេះដល់ខ្ញុំ ខ្ញុំនឹងនាំរបស់ទាំងអស់ចេញទៅអំពីឧទ្យាននេះ អ្នករក្សាឧទ្យាននោះទទួលថា អើ យកទៅចុះ ។ ទើបចូឡន្តេវាសិកទៅកាន់ទីលេងរបស់កុមារ ឲ្យទឹកអំពៅ ឲ្យជញ្ជូនឈើ និងស្លឹកឈើទាំងអស់ចេញទៅ ក្នុងពេលមួយសម្មុះប៉ុណ្ណោះ ឲ្យគរត្រង់ទ្វារឧទ្យាន ក្នុងកាលនោះ ស្មូនឆ្នាំងរបស់ព្រះរាជាដើររកឧសដើម្បីដុតភាជនៈរបស់ព្រះរាជា ឃើញឈើ និងស្លឹកឈើទាំងនោះត្រង់ទ្វារឧទ្យាន ទើបទិញយកអំពីដៃរបស់ចូឡន្តេវាសិកនោះ ថ្ងៃនោះ ចូឡន្តេវាសិកបានទ្រព្យ ១៦ កហាបណៈ និងភាជនៈ ៥ យ៉ាង មានថ្លាងជាដើម ដោយការលក់ឧស ។

កាលមានទ្រព្យ ២៤ កហាបណៈ ទើបចូឡន្តេវាសិកនោះគិតថា អញមានឧបាយនេះ ហើយតម្កល់ថ្លាងទឹកមួយក្នុងទីមិនឆ្ងាយអំពីទ្វារព្រះនគរ ទំនុកបម្រុងអ្នករែកស្មៅ ៥០០ នាក់ ដោយទឹកផឹក ។ អ្នករែកស្មៅទាំងនោះពោលថា នែសម្លាញ់ អ្នកមានឧបការៈច្រើនដល់ពួកយើង ពួកយើងនឹងធ្វើអ្វីដល់អ្នកបានខ្លះ ចូឡន្តេវាសិកពោលថា កាលមានកិច្ចកើតឡើងដល់ខ្ញុំ សឹមអ្នកទាំងឡាយធ្វើ ហើយត្រាច់ទៅក្នុងទីផ្សេងៗ បានធ្វើសេចក្ដីស្និទ្ធស្នាល ដោយភាពជាមិត្រជាមួយបុគ្គលដែលធ្វើការងារផ្លូវគោក និងអ្នកធ្វើការងារផ្លូវទឹក ។

អ្នកធ្វើការផ្លូវគោក ប្រាប់ដល់ចូឡន្តេវាសិកនោះថា ស្អែកនេះ ឈ្មួញសេះ នឹងនាំសេះ ៥០០ មកកាន់នគរនេះ ។ ចូឡន្តេវាសិកនោះ បានស្តាប់ពាក្យរបស់អ្នកធ្វើការផ្លូវគោកនោះហើយ ទើបពោលនឹងអ្នករែកស្មៅថា ថ្ងៃនេះ ចូរអ្នកឲ្យស្មៅដល់ខ្ញុំម្នាក់មួយបាច់ កាលខ្ញុំមិនទាន់បានលក់ស្មៅ អ្នកទាំងឡាយកុំទាន់លក់ស្មៅរបស់ខ្លួន អ្នករែកស្មៅទាំងនោះទទួលពាក្យហើយ នាំស្មៅ ៥០០ បាច់ មកដាក់ត្រង់ទ្វារផ្ទះរបស់ចូឡន្តេវាសិកនោះ ។ ឈ្មួញសេះមិនបានអាហារសម្រាប់សេះ ក្នុងនគរទាំងមូល ទើបឲ្យទ្រព្យ ១០០០ ដល់ចូឡន្តេវាសិកនោះ ហើយកាន់យកស្មៅនោះទៅ ។

បន្ទាប់អំពីនោះ កន្លងទៅ ២-៣ ថ្ងៃ សម្លាញ់ដែលធ្វើការងារផ្លូវទឹកប្រាប់ដល់ចូឡន្តេវាសិកនោះថា ទូកធំមកចតត្រង់កំពង់ហើយ ។ ចូឡន្តេវាសិកនោះគិតថា មានឧបាយនេះ ទើបយកប្រាក់ ៨ កហាបណៈទៅជួលរថដែលដល់ព្រមដោយបរិវារទាំងពួង ហើយទៅកាន់កំពង់ទូកដោយយសធំ ឲ្យចិញ្ចៀនមួយវង់បញ្ចាំដល់ម្ចាស់ទូក ឲ្យបាំងវាំងនន អង្គុយក្នុងទីមិនឆ្ងាយ ប្រាប់មនុស្សថា បើឈ្មួញដទៃមក ចូរពួកអ្នកប្រាប់ដោយការប្រាប់ពន្យា ៣ ដង ។ ឈ្មួញប្រមាណ ១០០ នាក់ ចេញអំពីក្រុងពារាណសី បានឮថា ទូកមកហើយ ទើបមកដោយពោលថា ពួកយើងនឹងទិញយកទំនិញ ។ ម្ចាស់ទូកពោលថា ពួកអ្នកមិនបានទំនិញឡើយ ឈ្មួញធំក្នុងទីឈ្មោះនោះបានកក់ហើយ ឈ្មួញទាំងនោះបានស្តាប់ដូច្នោះ ទើបមកកាន់សម្នាក់របស់ចូឡន្តេវាសិកនោះ ។ ទើបអ្នកបម្រើជិតស្និទ្ធ ប្រាប់ភាពដែលពួកឈ្មួញទាំងនោះមក ដោយការពន្យាពេល

៣ ជងតាមសញ្ញា ។ ឈ្នួញប្រមាណ ១០០ នាក់នោះ ឲ្យទ្រព្យម្នាក់ ១០០០ ដើម្បីជាភាគហ៊ុននឹងចូឡន្តេវាសិកនោះ ហើយឲ្យម្នាក់ ១០០០ ដើម្បីផ្ដាច់ ធ្វើទំនិញឲ្យជារបស់ខ្លួន ចូឡន្តេវាសិកកាន់យកទ្រព្យ ២ សែនត្រឡប់មកក្រុងពារាណសី គិតថា អញគួរជាបុគ្គលកតញ្ញូ ទើបកាន់យកទ្រព្យមួយសែនទៅកាន់ទីជិតចូឡកសេដ្ឋី ។ លំដាប់នោះ ទើបចូឡកសេដ្ឋីសួរចូឡន្តេវាសិកនោះថា នែបា អ្នកធ្វើអ្វី ទើបបានទ្រព្យនេះ ។ ចូឡន្តេវាសិកនោះពោលថា ខ្ញុំតាំងនៅក្នុងឧបាយដែលលោកម្ចាស់ប្រាប់ ទើបបានទ្រព្យនេះក្នុងកាល ៤ ខែប៉ុណ្ណោះ ហើយប្រាប់រឿងទាំងអស់ តាំងអំពីកណ្ដុរស្លាប់ជាដើមទៅ ។ ចុល្លកមហាសេដ្ឋីបានស្ដាប់ពាក្យរបស់ចូឡន្តេវាសិកនោះហើយ គិតថា ឥឡូវនេះអញនឹងធ្វើទារកបែបនេះឲ្យជារបស់អញ ទើបគួរ ទើបឲ្យធីតារបស់ខ្លួនដែលចម្រើនវ័យហើយ ធ្វើឲ្យជាម្ចាស់ទ្រព្យទាំងអស់ កាលលោកសេដ្ឋីអនិច្ចកម្មទៅហើយ ចូឡន្តេវាសិកនោះ ក៏បានតំណែងសេដ្ឋីក្នុងត្រកូលនោះ ។ ឯព្រះពោធិសត្វក៏បានទៅតាមយថាកម្ម ។

ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ព្រះធម្មទេសនានេះ ទ្រង់ជាអ្នកត្រាស់ដឹងព្រមក្រៃលែង បានត្រាស់ព្រះគាថានេះថា

> អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើមទុន
> សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អប្បកេនបិ** បានដល់ សូម្បីតិចតួច គឺតិចតួច ។ បទថា **មេធាវី** បានដល់ អ្នកមានប្រាជ្ញា ។ បទថា **ចាភតេន** បាន

ដល់ ដោយដើមទុនរបស់ទំនិញ ។ បទថា **វិចក្ខណោ** បានដល់ អ្នកឈ្លាស ក្នុងវោហារ ។ បទថា **សមុដ្ឋាបេតិ អត្តានំ** សេចក្តីថា ញ៉ាំងទ្រព្យ និង យសធំឲ្យកើតឡើង ហើយតម្កល់ខ្លួន គឺញ៉ាំងខ្លួនឲ្យតាំងនៅក្នុងទ្រព្យ និង យសនោះ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចបុគ្គលបង្កាត់ភ្លើងតូចឲ្យទៅជាគំនរ ធំ អធិប្បាយថា បុរសដែលជាបណ្ឌិតដាក់គោម័យ និងលម្អិតជាដើម ហើយ ផ្លុំដោយមាត់ បង្កាត់ភ្លើងបន្តិចបន្តួចឡើង គឺឲ្យចម្រើនឡើង បានដល់ ធ្វើឲ្យ ជាគំនរភ្លើងធំ ដោយលំដាប់ យ៉ាងណា បណ្ឌិតក៏ដូច្នោះដូចគ្នា បានទ្រព្យ ដែលជាទុនតិចតួច ហើយប្រកបឧបាយផ្សេងៗ រមែងនាំទ្រព្យ និងយសឲ្យ កើតឡើង គឺឲ្យបន្ថែមឡើង កាលឲ្យចម្រើនឡើងហើយ ក៏តម្កល់ខ្លួនក្នុង ទ្រព្យ និងយសនោះ ឬរមែងតម្កល់ខ្លួន ធ្វើឲ្យដឹង គឺឲ្យប្រាកដ ព្រោះភាព ជាធំក្នុងទ្រព្យ និងយសនោះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងធម្មទេសនានេះយ៉ាងនេះថា ម្នាលភិក្ខុទាំង ឡាយ ចូឡបន្ថកៈអាស្រ័យតថាគតហើយ ដល់នូវភាពជាធំក្នុងធម៌ ព្រោះធម៌ ទាំងឡាយ ក្នុងឥឡូវនេះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏អាស្រ័យតថាគត ទើបដល់នូវភាពជាធំក្នុងភោគៈ ក្នុងភោគៈទាំងឡាយ ហើយត្រាស់រឿងទាំង ២ បន្តអនុសន្ធិគ្នា ហើយទ្រង់ប្រជុំជាតកថា ចូឡន្តេវាសិកក្នុងកាលនោះ បានជា ចូឡបន្ថកៈ ក្នុងកាលឥឡូវនេះ ឯចូឡកមហាសេដ្ឋី គឺតថាគតនេះឯង ។៚

## អដ្ឋកថាចុល្លកសេដ្ឋិជាតក ចប់

# សុត្តន្តបិដក

## តណ្ឌុលនាឡិជាតក

[ ៥ ] ( អាមាត្យពោធិសត្វសួរថា ) អង្ករមួយនាឡិ ថ្លៃ ( ស្មើនឹង ) ក្រុងពារាណសី ទាំងខាងក្នុងទាំងខាងក្រៅ ឬសេះ ៥០០ នេះ ថ្លៃត្រឹមតែអង្ករមួយនាឡិទេឬ ។

តណ្ឌុលនាឡិជាតកទី ៥ ចប់

# អដ្ឋកថា

## តណ្ឌុលនាឡិជាតក

[ ៥ ] ព្រះសាស្ដា កាលគង់នៅក្នុងជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះលោឡុទាយិត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កិមគ្ឃតី តណ្ឌុលនាឡិកា** ដូច្នេះជាដើម ។

សម័យនោះ ព្រះទព្វមល្លបុត្រ បានជាភត្តុទ្ទេសក៍របស់សង្ឃ កាលព្រះទព្វមល្លបុត្រនោះ សម្ដែងសលាកភត្តជាដើមអំពីព្រលឹម ជួនកាល ភត្តល្អក៏ដល់លំដាប់ឧទាយិត្ថេរ ជួនកាល ភត្តអាក្រក់ ក្នុងថ្ងៃដែលបានភត្តអាក្រក់ព្រះឧទាយិត្ថេរនោះ ក៏ធ្វើរោងស្លាកឲ្យវឹកវរ ពោលថា ព្រះទព្វៈប៉ុណ្ណោះដឹងដើម្បីឲ្យស្លាកឬ ពួកយើងមិនដឹងទេឬ ។ កាលព្រះឧទាយីនោះធ្វើរោងស្លាកឲ្យវឹកវរ ភិក្ខុទាំងឡាយបានឲ្យល្អីស្លាក ដោយពាក្យថា ណ្ហើយចុះ សូមលោកឲ្យស្លាកឥឡូវនេះ ។ ចាប់តាំងអំពីនោះ ព្រះឧទាយីនោះ បានឲ្យស្លាកដល់សង្ឃ កាលនឹងឲ្យ រមែងមិនដឹងថា នេះភត្តល្អ ឬភត្តអាក្រក់ឡើយ ឬរមែងមិនដឹងថា ភត្តល្អតម្កល់ក្នុងរោងនោះ ភត្តអាក្រក់តម្កល់ក្នុងរោងនោះ កាលធ្វើការពិនិត្យបញ្ជី មិនកំណត់ថា បញ្ជីសម្ដែងសរុបចំនួនក្នុងរោងនោះ ។ ក្នុងកាលដែលភិក្ខុទាំងឡាយឈរ ក៏គូសត្រង់ផែនដី ឬត្រង់ជញ្ជាំងឲ្យដឹងថា ក្នុងទីនេះ បញ្ជីដែលតាំងលំដាប់នេះឈរក្នុងទីនេះ បញ្ជីតាំងលំដាប់នេះឈរ ។ ស្អែកឡើង ក្នុងរោងស្លាក មានភិក្ខុតិចជាងខ្លះ ច្រើនជាងខ្លះ កាលភិក្ខុទាំង-ឡាយនោះតិចជាង ស្នាមគំនូសក៏ទាប កាលភិក្ខុទាំងឡាយច្រើនជាង ស្នាមគំនូសក៏ខ្ពស់ ។ ព្រះឧទាយីនោះ មិនដឹងបញ្ជីដែលតាំងលំដាប់ ទើបឲ្យស្លាក

ទៅតាមស្នាមគំនូស ។

លំដាប់នោះ ទើបភិក្ខុទាំងឡាយពោលនឹងព្រះឧទាយីនោះថា អាវុសោឧទាយី ធម្មតាស្នាមគំនូស ទោះទាប ឬខ្ពស់ក៏ដោយចុះ តែកត្តល្អ តាំងនៅត្រង់រោងនោះ កត្តអាក្រក់តាំងនៅក្នុងរោងនោះ ។ ព្រះឧទាយី កាលឆ្លើយនឹងភិក្ខុទាំងឡាយ ទើបពោលថា បើដូច្នោះ ព្រោះហេតុអ្វី ទើបស្នាមគំនូសនេះតាំងនៅយ៉ាងនេះ ខ្ញុំនឹងជឿពួកលោកដូចម្តេចបាន ខ្ញុំជឿតាមស្នាមគំនូសនេះ ។ លំដាប់នោះ ទើបភិក្ខុកំលោះ និងសាមណេរទាំងឡាយពោលនឹងព្រះឧទាយីនោះថា អាវុសោឧទាយី បើលោកឲ្យស្លាក ភិក្ខុទាំងឡាយនាំគ្នាវិនាសលាភ លោកមិនគួរឲ្យស្លាក ចូរចេញទៅអំពីរោងស្លាក ហើយទាញចេញពីរោងស្លាក ខណៈនោះ ក្នុងរោងស្លាកមានការរឹករវរធំ ។

ព្រះសាស្តាបានស្តាប់ដូច្នោះ ទើបត្រាស់សួរព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ក្នុងរោងស្លាក មានកោលាហលធំ នុ៎ះជាសំឡេងអ្វី ។ ព្រះថេរៈបានក្រាបទូលរឿងនោះដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ឧទាយីធ្វើនូវសេចក្តីវិនាសលាភដល់អ្នកដទៃ ព្រោះភាពដែលខ្លួនជាបុគ្គលល្ងង់មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុនក៏បានធ្វើហើយដូចគ្នា ។ ព្រះថេរៈទូលអារាធនាព្រះសាស្តា ដើម្បីត្រាស់រឿងនោះឲ្យជាក់ច្បាស់ ព្រះសាស្តាទ្រង់បានធ្វើហេតុដែលកពបិទបាំងឲ្យប្រាកដដូចតទៅនេះ

ក្នុងអតីកាល ព្រះរាជាព្រះនាមព្រហ្មទត្ត នៅក្នុងនគរពារាណសី ដែនកាសី ។ ក្នុងកាលនោះ ព្រះពោធិសត្វនៃយើងបានជាភ្នាក់ងារវាយតម្លៃទំនិញ

របស់ព្រះបាទព្រហ្មទត្តនោះ បានវាយតម្លៃដំរី សេះ កែវមណី និងមាសជាដើម កាលវាយតម្លៃហើយ ឲ្យមូលតម្លៃ សមគួរដល់កណ្ឌៈនោះឯង ដល់ម្ចាស់នៃកណ្ឌៈទាំងឡាយ តែព្រះរាជាទ្រង់ជាមនុស្សរចង់បាន ព្រោះភាពជាអ្នកល្មោភ ទើបព្រះរាជានោះត្រិះរិះយ៉ាងនេះថា ភ្នាក់ងារវាយតម្លៃនេះ កាលវាយតម្លៃយ៉ាងនេះ មិនយូរប៉ុន្មាន ទ្រព្យក្នុងវាំងរបស់អញ នឹងដល់នូវការអស់ទៅ អញនឹងតាំងអ្នកដទៃឲ្យជាភ្នាក់ងារវាយតម្លៃ ។ ព្រះរាជាទ្រង់ឲ្យបើកសីហបញ្ជរទតលានព្រះរាជវាំង ឃើញបុរសអ្នកស្រុកម្នាក់ ជាអ្នកឡេះឡោះផង ល្ងង់ខ្លៅផង កំពុងដើរឆ្លងកាត់លានព្រះរាជវាំង ទើបទ្រង់ព្រះតម្រិះថា បុរសនេះប្រហែលជាអាចធ្វើភ្នាក់ងារក្នុងតំណែងអ្នកវាយតម្លៃរបស់អញបាន ទើបបញ្ជាឲ្យហៅមក ហើយត្រាស់ថា នែអ្នក អ្នកអាចធ្វើការងារក្នុងតំណែងភ្នាក់ងារវាយតម្លៃរបស់យើងបានដែរទេ ។ បុរសនោះទូលថា បពិត្រព្រះអង្គ ទូលបង្គំអាច ទើបព្រះរាជាតាំងបុរសល្ងង់ខ្លៅនោះ ក្នុងតំណែងភ្នាក់ងាររបស់អ្នកវាយតម្លៃ ដើម្បីរក្សាទ្រព្យរបស់ព្រះអង្គ តាំងអំពីនោះ បុរសល្ងង់ខ្លៅនោះ កាលវាយតម្លៃដំរី សេះជាដើម ពោលវាយតម្លៃតាមការពេញចិត្ត ធ្វើឲ្យខូចតម្លៃ ព្រោះគាត់តាំងនៅក្នុងតំណែងពោលពាក្យណា ពាក្យនោះ ជាតម្លៃ ។ កាលនោះ ឈ្មួញសេះម្នាក់ នាំសេះ ៥០០ មកអំពីឧត្តរាបថ ព្រះរាជាត្រាស់ឲ្យហៅបុរសនោះមកឲ្យវាយតម្លៃសេះ បុរសនោះបានតាំងតម្លៃសេះ ៥០០ ដោយអង្ករមួយនាឡិ កាលវាយតម្លៃរួចហើយ ទើបពោលថា ចូរអ្នកទាំងឡាយឲ្យអង្ករមួយនាឡិដល់ឈ្មួញសេះ រួចឲ្យនាំសេះមករក្សាក្នុងរោងសេះ ។

ឈ្មួញសេះទៅកាន់សម្នាក់ភ្នាក់ងារវាយតម្លៃកាលពីមុន ប្រាប់រឿងនោះ ហើយសួរថា ឥឡូវនេះ គួរធ្វើដូចម្តេច ។ ភ្នាក់ងារវាយតម្លៃចាស់នោះពោលថា អ្នកទាំងឡាយ ចូរឲ្យសំណូកដល់បុរសនោះ ហើយសួរយ៉ាងនេះថា សេះទាំងឡាយរបស់ខ្ញុំ មានតម្លៃត្រឹមអង្ករមួយនាឡិ សេចក្តីនេះ យើងដឹងហើយ តែខ្ញុំបំណងនឹងដឹងអង្ករមួយនាឡិ ព្រោះអាស្រ័យលោក លោកអាចឈរក្នុងសម្នាក់ព្រះរាជា ហើយពោលថា អង្ករមួយនាឡិនេះ មានតម្លៃប៉ុណ្ណេះ បានដែរឬទេ កាលបុរសនោះពោលថា អាច ចូរពួកអ្នកនាំបុរសនោះទៅកាន់សម្នាក់របស់ព្រះរាជា ឯខ្ញុំក៏នឹងទៅក្នុងទីនោះ ។ ឈ្មួញទទួលពាក្យព្រះពោធិសត្វហើយ ឲ្យសំណូកដល់អ្នកវាយតម្លៃ ហើយប្រាប់សេចក្តីនោះ អ្នកវាយតម្លៃនោះបានសំណូកប៉ុណ្ណោះ ក៏ពោលថា ខ្ញុំអាចវាយតម្លៃអង្ករមួយនាឡិបាន ឈ្មួញសេះពោលថា បើដូច្នោះ ពួកយើងនឹងនាំគ្នាទៅកាន់រាជត្រកូល ហើយបាននាំអ្នកវាយតម្លៃនោះ ទៅកាន់សម្នាក់របស់ព្រះរាជា ។ ព្រះពោធិសត្វក្តី អមាត្យដទៃជាច្រើនក្តី បាននាំគ្នាទៅហើយ ។ ឈ្មួញសេះថ្វាយបង្គំព្រះរាជា ហើយទូលសួរថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គបានជ្រាបថា សេះ ៥០០ មានតម្លៃស្មើនឹងអង្ករមួយនាឡិ តែអង្ករមួយនាឡិនេះ មានតម្លៃប៉ុនណា បពិត្រព្រះសម្មតិទេព សូមទ្រង់សាកសួរភ្នាក់ងារអ្នកវាយតម្លៃ ។ ព្រះរាជាមិនជ្រាបការប្រព្រឹត្តទៅនោះ ទើបត្រាស់សួរថា នែអ្នកដ៏ចម្រើន សេះ ៥០០ មានតម្លៃប៉ុន្មាន ភ្នាក់ងារវាយតម្លៃក្រាបទូលថា មានតម្លៃស្មើនឹងអង្ករមួយនាឡិ ព្រះរាជាត្រាស់សួរថា ណ្ហើយ

ចុះ សេះទាំងឡាយមានតម្លៃស្មើនឹងអង្ករមួយនាឡិ លើកទុកចុះ តែអង្ករមួយនាឡិនោះ មានតម្លៃប៉ុនណា បុរសល្ងង់ខ្លៅនោះ ក្រាបទូលថា បពិត្រព្រះអង្គ អង្ករមួយនាឡិ មានតម្លៃស្មើនឹងក្រុងពារាណសីទាំងខាងក្នុង និងខាងក្រៅ ។

បានឮថា ក្នុងកាលមុន បុរសល្ងង់នោះ អនុវត្តតាមព្រះរាជា ទើបវាយតម្លៃសេះទាំងឡាយ ដោយអង្ករមួយនាឡិ បានសំណូកអំពីដៃរបស់ឈ្មួញ បែរជាវាយតម្លៃក្រុងពារាណសី ទាំងខាងក្នុង និងខាងក្រៅ ដោយអង្ករមួយនាឡិនោះ ។ ក្នុងកាលនោះ ក្រុងពារាណសីបានព័ទ្ធដោយកំពែងប្រមាណ ១២ យោជន៍ ដែនខាងក្នុង និងខាងក្រៅក្រុងពារាណសីនេះ ប្រមាណ ៣០០ យោជន៍ ។ បុរសល្ងង់ខ្លៅនោះ បានវាយតម្លៃក្រុងពារាណសីទាំងខាងក្នុង និងខាងក្រៅ ដ៏ធំមហិមាយ៉ាងនេះ ដោយអង្ករមួយនាឡិ ដូច្នេះ ។ ព្រះពោធិសត្វ បានស្តាប់ដូច្នោះ កាលនឹងសួរ ទើបពោលគាថានេះថា

អង្ករមួយនាឡិ ថ្លៃ ( ស្មើនឹង ) ក្រុងពារាណសី ទាំងខាងក្នុង
ទាំងខាងក្រៅ ឬសេះ ៥០០ នេះ ថ្លៃត្រឹមតែអង្ករមួយនាឡិទេឬ
ដូច្នេះ ។

អមាត្យទាំងឡាយបានស្តាប់ដូច្នោះ ទើបនាំគ្នាទះដៃសើច ធ្វើការចំអកថា ក្នុងកាលមុន ពួកយើងសម្គាល់ថា ផែនដី និងរាជសម្បត្តិ មានតម្លៃកាត់ថ្លៃមិនបាន បានឮថា រាជសម្បត្តិក្នុងក្រុងពារាណសី ព្រមទាំងព្រះរាជាដែលជាធំយ៉ាងនេះ មានតម្លៃត្រឹមតែអង្ករមួយនាឡិ ឱ ! ការដល់ព្រមរបស់ភ្នាក់ងារអ្នកវាយតម្លៃ អ្នកជាភ្នាក់ងារវាយតម្លៃ តាំងនៅអស់កាលមាន

ប្រមាណប៉ុណ្ណោះ ក្នុងទីណា អ្នកសមគួរដល់ព្រះរាជារបស់ពួកយើង ។ កាលនោះ ព្រះរាជាទ្រង់ខ្មាស ឲ្យអ្នកសុបុរសល្ងង់នោះចេញទៅ ហើយព្រះរាជទានតំណែងភ្នាក់ងារវាយតម្លៃដល់ព្រះពោធិសត្វដូចមុន ។ ព្រះពោធិសត្វបានទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ ២ រឿងបន្តអនុសន្ធិគ្នា ហើយទ្រង់ប្រជុំជាតកថា ភ្នាក់ងារវាយតម្លៃ ដែលជាអ្នកល្ងង់ខ្លៅក្នុងកាលនោះ បានជាឧទាយីក្នុងកាលឥឡូវនេះ ភ្នាក់ងារវាយតម្លៃដែលជាបណ្ឌិត គឺតថាគតនេះឯង ។៚

## អដ្ឋកថា តណ្ឌុលនាឡិជាតក ចប់

# សុត្តន្តបិដក

## ទេវធម្មជាតក

[ ៦ ] *( ព្រះមហិសាសរាជកុមារពោធិសត្វពោលថា ) ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថា មានទេវធម៌ក្នុងលោក ។*

***ទេវធម្មជាតកទី ៦ ចប់***

# អដ្ឋកថា

## ចេវធម្មជាតក

[ ៦ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានភណ្ឌៈច្រើនមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ហិរិ-ឱត្តប្បសម្បន្នា** *ដូច្នេះជាដើម ។*

*បានឮថា កុដុម្ពិកៈអ្នកក្រុងសាវត្ថីម្នាក់ កាលភរិយាស្លាប់ ក៏បួស កុដុម្ពិកៈនោះ កាលបួស បានឲ្យគេធ្វើបរិវេណរោងភ្លើង និងបន្ទប់ដាក់សម្ភារៈ ធ្វើបន្ទប់ដាក់របស់របរ ឲ្យពេញដោយសប្បិ និងអង្ករសម្រាប់ខ្លួនជាដើមហើយទើបបួស កាលបួសហើយ ឲ្យហៅទាសៈរបស់ខ្លួនមក ឲ្យចម្អិនអាហារតាមគាប់ចិត្ត ហើយទើបបរិភោគ បានជាអ្នកមានបរិក្ខារច្រើន ក្នុងពេលយប់ មានសំពត់ស្លៀក និងសំពត់ដណ្តប់ ១ ផ្ទាំង ពេលថ្ងៃ មានសំពត់មួយផ្ទាំងទៀត រូបនៅខាងចុងវិហារ ។ ថ្ងៃមួយ កាលភិក្ខុនោះនាំចីវរ និងកម្រាលចេញជាដើម មកហាលក្នុងបរិវេណ ភិក្ខុអ្នកជនបទជាច្រើនចារិកទៅតាមសេនាសនៈ ទៅដល់បរិវេណ ឃើញចីវរជាដើម ទើបសួរថា ចីវរជាដើមនេះរបស់អ្នកណា ភិក្ខុនោះពោលថា អាវុសោ ទុំះ គឺរបស់ខ្ញុំ ។ ភិក្ខុទាំងនោះសួរថា ចីវរនេះក្តី សំពត់ស្លៀកនេះក្តី គ្រឿងកម្រាលនេះក្តី ទាំងអស់ជារបស់លោកប៉ុណ្ណោះឬ ។ ភិក្ខុនោះពោលថា ជារបស់ខ្ញុំទាំងអស់នោះឯង ។ ភិក្ខុទាំងឡាយពោលថា អាវុសោ ព្រះសាស្តាទ្រង់អនុញ្ញាតចីវរ ៣ មិនមែនឬ លោកបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលជាអ្នកប្រាថ្នាតិចយ៉ាងនេះ មានបរិក្ខារច្រើនយ៉ាងនេះ មក ពួកយើងនឹងនាំលោកទៅកាន់សម្នាក់របស់ព្រះ*

ទសពល ហើយបាននាំភិក្ខុនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ។

លុះទ្រង់ឃើញភិក្ខុនោះប៉ុណ្ណោះ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ នាំភិក្ខុមិនប្រាថ្នានោះមកហើយឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះមានកណ្ហៈច្រើន មានបរិក្ខារច្រើន ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកមានកណ្ហៈច្រើន ពិតឬ ភិក្ខុនោះក្រាបទូលថា ព្រះករុណា ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ព្រោះហេតុអ្វី ទើបអ្នកមានកណ្ហៈច្រើន តថាគតពោលគុណនៃភាពជាអ្នកប្រាថ្នាតិច សន្តោស ស្ងាត់ និងការប្រារព្ធសេចក្តីព្យាយាមមិនមែនឬ ។ ភិក្ខុនោះបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ក៏ក្រោធ គិតថា ឥឡូវនេះ អញនឹងត្រាច់ទៅដោយទំនងនេះ ដូច្នេះហើយ ទើបចោលសំពត់ដណ្តប់ មានចីវរមួយផ្ទាំងសម្រាប់ស្លៀក ឈរក្នុងកណ្តាលបរិស័ទ ។ លំដាប់នោះ ព្រះសាស្តា កាលទ្រង់ឧបត្ថម្ភភិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុ កាលមុន ក្នុងកាលដែលអ្នកជាអារក្ខទឹក ស្វែងរកហិរិឱត្តប្បៈ អ្នកស្វែងរកហិរិឱត្តប្បៈអស់ ១២ ឆ្នាំ កាលបើដូច្នោះ ព្រោះហេតុអ្វី ក្នុងឥឡូវនេះ អ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលជាទីគោរពយ៉ាងនេះ ទើបលះបង់សំពត់ក្នុងកណ្តាលបរិស័ទ លះបង់ហិរិឱត្តប្បៈ ហើយឈរ ។ ភិក្ខុនោះ ស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ញ៉ាំងហិរិឱត្តប្បៈឲ្យតាំងឡើង ទើបដណ្តប់ចីវរនោះ ហើយថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងចំណែកម្ខាង ភិក្ខុទាំងឡាយ ទូលអារាធនាព្រះសាស្តា ដើម្បីទ្រង់ញ៉ាំងរឿងនោះឲ្យជាក់ច្បាស់ ព្រះសាស្តាទ្រង់ធ្វើហេតុ

ដែលអន្តរកពបិទបាំង ឲ្យប្រាកដដូចតទៅនេះ

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសី ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសី នៃព្រះបាទព្រហ្មទត្តនោះ ។ កាលគ្រប់ទសមាស ព្រះនាងប្រសូតព្រះឱរស ក្នុងថ្ងៃថ្វាយព្រះនាមព្រះឱរសនោះ ព្រះញាតិទាំង-ឡាយបានដាក់ឈ្មោះថា មហិសាសកុមារ ។ ក្នុងកាលដែលកុមារនោះរត់លេងបាន ព្រះឱរសមួយអង្គទៀតក៏ប្រសូត ញាតិទាំងឡាយ ដាក់ឈ្មោះឱរសនោះថា ចន្ទកុមារ ។ ក្នុងពេលដែលចន្ទកុមារនោះ រត់លេងបាន ព្រះមាតារបស់ព្រះពោធិសត្វ ក៏សោយព្រះវិលាល័យ ព្រះរាជាទ្រង់តាំងស្នំដទៃក្នុងតំណែងអគ្គមហេសី ។ អគ្គមហេសីនោះ បានជាទីស្រឡាញ់ ជាទីប្រោសប្រាណរបស់ព្រះរាជា ។ អគ្គមហេសីនោះ អាស្រ័យការនៅរួមគ្នា ក៏ប្រសូតឱរសមួយអង្គទៀត ។ ព្រះញាតិទាំងឡាយបានដាក់នាមឱរសនោះថា សុរិយ-កុមារ ។ ព្រះរាជាទ្រង់ឃើញព្រះឱរសហើយ មានព្រះហឫទ័យត្រេកអរត្រាស់ថា នែនាងដ៏ចម្រើន យើងឲ្យពរដល់បុត្តរបស់នាង ។ ព្រះទេវីទទួលពរនោះ នឹងទទួលយកក្នុងពេលត្រូវការពរនោះ ។ កាលព្រះឱរសចម្រើនវ័យហើយ ព្រះនាងក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ក្នុងកាលដែលព្រះឱរសរបស់ខ្ញុំម្ចាស់ប្រសូត ទ្រង់បានប្រទានពរ មិនមែនឬ សូមទ្រង់ប្រទានរាជសម្បត្តិដល់ឱរសរបស់ខ្ញុំម្ចាស់ ។ ព្រះរាជាឃាត់ថា ព្រះឱរស ២ អង្គរបស់យើង រុងរឿងដូចគំនរភ្លើង យើងមិនអាចឲ្យរាជសម្បត្តិដល់ឱរស

របស់នាងឡើយ កាលនាងអង្វររឿយៗ ទ្រង់ព្រះតម្រិះថា ស្រីនេះគិតសូម្បីកម្មដ៏លាមកដល់ឱរសទាំងឡាយរបស់អញ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅឱរសទាំង ២ មកហើយ ត្រាស់ថា បាទាំង ២ ក្នុងពេលដែលសុរិយកុមារប្រសូត ឪពុកបានឲ្យពរ ឥឡូវនេះ មាតារបស់សុរិយកុមារនោះទូលសូមរាជសម្បត្តិ ឪពុកមិនប្រាថ្នានឹងឲ្យដល់សុរិយកុមារនោះឡើយ ធម្មតាមាតុគ្រាមអាក្រក់ គិតសូម្បីវត្ថុដែលលាមកដល់ពួកអ្នក កូនទាំង ២ ត្រូវចូលព្រៃ ទម្រាំឪពុកទិវង្គតទៅ ចូរគ្រងរាជសម្បត្តិក្នុងនគរ ដែលជារបស់មាននៃត្រកូល ហើយទ្រង់ព្រះកន្សែងរៀបរាប់ ថើបត្រង់សីសៈ ហើយបញ្ជូនទៅ ។ សុរិយកុមារទ្រង់លេងត្រង់លានព្រះរាជវាំង ឃើញព្រះឱរសទាំង ២ នោះថ្វាយបង្គំព្រះរាជបិតា ហើយចុះអំពីប្រាសាទ ទ្រង់ឃើញហេតុនោះ គិតថា អញក៏នឹងទៅជាមួយម្ចាស់បងទាំង ២ ទើបចេញទៅជាមួយឱរសទាំង ២ នោះឯង ព្រះឱរសទាំងនោះ ចូលទៅកាន់ព្រៃហិមពាន្ត ។

ព្រះពោធិសត្វចៀសចេញអំពីផ្លូវ ប្រថាប់ត្រង់គល់ឈើ ហៅសុរិយកុមារមកថា បាសុរិយៈ ចូរទៅកាន់ស្រះនោះ ងូត និងផឹកហើយ ចូរយកស្លឹកឈូកខ្ចប់ទឹកផឹកមក ដើម្បីយើងទាំង ២ ស្រះនោះជាស្រះដែលអារក្ខទឹកមួយរូប បានពរអំពីសម្នាក់របស់ស្តេចវេស្សវ័ណថា នឹងបានបរិភោគអ្នកដែលចុះកាន់ស្រះនេះ វៀរតែបុគ្គលដែលចេះទេវធម៌ប៉ុណ្ណោះ ។ តាំងអំពីនោះ ទើបអារក្ខទឹកនោះ សួរទេវធម៌ជាមួយអ្នកដែលចុះក្នុងស្រះនោះ ហើយស៊ីបុគ្គលដែលមិនចេះទេវធម៌ ។ គ្រានោះឯង សុរិយកុមារទៅកាន់ស្រះនោះ មិនបានពិចារណា ចុះទៅ លំដាប់នោះ អារក្ខនោះចាប់សុរិយកុមារ ហើយសួរថា

អ្នកចេះទេវធម៌ឬ សុរិយកុមារពោលថា អើ ខ្ញុំចេះ ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា ទេវធម៌ សម័យនោះ ទើបអារក្ខពោលនឹងសុរិយកុមារនោះថា អ្នកមិនចេះទេវធម៌ទេ ហើយនាំទៅទុកក្នុងលំនៅរបស់ខ្លួន ឯព្រះពោធិសត្វ ឃើញសុរិយកុមារនោះយឺតយូរ ទើបបញ្ជូនចន្ទកុមារទៅ អារក្ខក៏ចាប់ចន្ទកុមារនោះ ហើយសួរថា អ្នកចេះទេវធម៌ដែរឬទេ ចន្ទកុមារពោលថា អើ ខ្ញុំចេះ ទិសទាំង ៤ ឈ្មោះថា ទេវធម៌ អារក្ខទឹកពោលថា អ្នកមិនចេះទេវធម៌ទេ ហើយនាំចន្ទកុមារនោះទៅទុកត្រង់លំនៅរបស់ខ្លួននោះឯង ។

កាលចន្ទកុមារយឺតយូរ ព្រះពោធិសត្វគិតថា អន្តរាយឯណានីមួយ គប្បីមាន ដូច្នេះហើយ ទើបយាងទៅកាន់ស្រះនោះដោយព្រះអង្គឯង ឃើញស្នាមជើងចុះរបស់អនុជទាំង ២ ទើបត្រិះរិះថា ស្រះនេះ ពិតជាស្រះដែលអារក្ខទឹកហួងហែង ទើបសឹកព្រះខ័ន កាន់ធ្នូ ឈរក្នុងទីនោះ ។ អារក្ខទឹកឃើញព្រះពោធិសត្វមិនចុះទឹក ទើបកាឡាខ្លួនជាច្នៃរព្រៃ ពោលនឹងព្រះពោធិសត្វថា បុរសដ៏ចម្រើន អ្នកហត់នឿយក្នុងរវាងផ្លូវ ហេតុអ្វីមិនចុះក្នុងស្រះនេះ ងូតផឹក បរិភោគនូវមើមឈូក ប្រដាប់ផ្កា តាមសប្បាយ ។ ព្រះពោធិសត្វគ្រាន់តែឃើញ ស្គាល់ថា បុរសនេះជាយក្ខ ទើបពោលថា អ្នកចាប់ប្អូនប្រុសរបស់យើងឬ អារក្ខទឹកពោលថា អើ ខ្ញុំចាប់ ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី ។ អារក្ខទឹកពោលថា ខ្ញុំរមែងបានបុគ្គលដែលចុះកាន់ស្រះនេះ ។ ព្រះពោធិសត្វសួរថា អ្នករមែងបានទាំងអស់ឬ ។ អារក្ខទឹកពោលថា ខ្ញុំបានទាំងអស់ វៀរតែអ្នកចេះទេវធម៌ ។ ព្រះពោធិសត្វត្រាស់សួរថា អ្នកត្រូវការ

ទេវធម៌ឬ អារក្ខទឹកពោលថា អើ ខ្ញុំត្រូវការ ។ ព្រះពោធិសត្វត្រាស់ថា បើដូច្នោះ ខ្ញុំនឹងប្រាប់ទេវធម៌ដល់អ្នក អារក្ខទឹកពោលថា បើដូច្នោះ ចូរអ្នកប្រាប់ យើងនឹងស្តាប់ទេវធម៌ ។ ព្រះពោធិសត្វត្រាស់ថា ខ្ញុំមានខ្លួនស្មោកគ្រោក ទើបយក្ខឲ្យព្រះពោធិសត្វងូត ផឹក ឲ្យប្រដាប់នូវផ្កា លាបស្រឡាបនូវគ្រឿងក្រអូប បានលាតបល្ល័ង្កឲ្យត្រង់កណ្តាលបារាំដែលប្រដាប់ហើយ ។ ព្រះពោធិសត្វគង់ប្រថាប់លើអាសនៈ ឲ្យយក្ខនោះអង្គុយទៀបបាទាហើយត្រាស់ថា បើយ៉ាងនោះ ចូរអ្នកផ្ទៀងនូវសោតស្តាប់ធម៌ដោយគោរព ហើយត្រាស់គាថានេះថា

ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថា មានទេវធម៌ក្នុងលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិរិឱត្តប្បសម្បន្នា** បានដល់ ជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ បណ្តាហិរិ និងឱត្តប្បៈទាំងនោះ ដែលឈ្មោះថា ហិរិ ព្រោះខ្មាសអំពីកាយទុច្ចរិតជាដើម ពាក្យថា **ហិរិ** នេះ ជាឈ្មោះនៃការខ្មាស ។ ដែលឈ្មោះថា **ឱត្តប្ប** ព្រោះខ្លាចអំពីកាយទុច្ចរិតជាដើមនោះឯង ពាក្យថា **ឱត្តប្ប** នេះ ជាឈ្មោះរបស់ការខ្លាចអំពីបាប បណ្តាហិរិ និងឱត្តប្បៈនោះ ហិរិមានសមុដ្ឋានដែលតាំងឡើងខាងក្នុង ឱត្តប្បៈមានសមុដ្ឋានដែលតាំងឡើងខាងក្រៅ ។ ហិរិមានខ្លួនជាធំ ឱត្តប្បៈមានលោកជាធំ ហិរិតាំងនៅក្នុងភាវៈដែលគួរខ្មាស ឱត្តប្បៈតាំងនៅក្នុងភាវៈដែលគួរខ្លាច ហិរិមានលក្ខណៈគោរព

ក្រែង ឱត្តប្បៈមានលក្ខណៈ ឃើញទោស និងឃើញភ័យ ។

បណ្តាហិរិ និងឱត្តប្បៈនោះ បុគ្គលរមែងញុំាងហិរិ ដែលមានសមុដ្ឋានជាខាងក្នុង ឲ្យតាំងឡើងដោយហេតុ ៤ ប្រការ គឺព្រោះពិចារណាដល់ជាតិកំណើត ១ ពិចារណាដល់វ័យ ១ ពិចារណាដល់សេចក្តីក្លាហាន ១ ពិចារណាដល់ភាពជាពហូសូត ១ សេចក្តីនេះដូចម្តេច បុគ្គលពិចារណាដល់ជាតិកំណើតយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ មិនមែនជាកម្មរបស់បុគ្គលដែលសម្បូរដោយជាតិ ជាកម្មរបស់បុគ្គលដែលមានជាតិថោកទាប មានព្រានសន្ទូចជាដើមគប្បីធ្វើ បុគ្គលដែលសម្បូរដោយជាតិដូចអ្នក មិនគួរធ្វើកម្មនេះ ហើយមិនធ្វើបាណាតិបាតជាដើម ឈ្មោះថា ញុំាងហិរិឲ្យតាំងឡើង ម្យ៉ាងទៀត បុគ្គលពិចារណាដល់វ័យយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មដែលមនុស្សក្មេងៗ គប្បីធ្វើ កម្មនេះ បុគ្គលដែលតាំងនៅក្នុងវ័យដូចអ្នក មិនគួរធ្វើឡើយ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ញុំាងហិរិឲ្យតាំងឡើង ម្យ៉ាងទៀត បុគ្គលពិចារណាដល់ភាពជាអ្នកអង់អាចយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មរបស់បុគ្គលមានជាតិទន់ខ្សោយ កម្មនេះ បុគ្គលដែលសម្បូរដោយការអង់អាចដូចអ្នក មិនគួរធ្វើឡើយ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ញុំាងហិរិឲ្យតាំងឡើង ម្យ៉ាងទៀត បុគ្គលពិចារណាដល់ភាពជាពហូសូតយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មរបស់បុគ្គលអន្ធពាល កម្មនេះ ដែលបុគ្គលជាពហូសូត ជាបណ្ឌិតដូចអ្នក មិនគួរធ្វើ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ញុំាង

ហិរិឲ្យតាំងឡើង បុគ្គលឈ្មោះថា ញុំាងហិរិដែលមានសមុដ្ឋានខាងក្នុង ឲ្យតាំងឡើងដោយហេតុ ៤ ប្រការដូច្នេះ កាលឲ្យតាំងឡើងហើយ ញុំាងហិរិឲ្យចូលទៅក្នុងចិត្ត មិនធ្វើបាបដោយខ្លួន ហិរិ ឈ្មោះថា មានសមុដ្ឋានខាងក្នុងយ៉ាងនេះ ។

ឱត្តប្បៈ ឈ្មោះថា មានសមុដ្ឋានខាងក្រៅដូចម្តេច បុគ្គលពិចារណាថា បើអ្នកធ្វើបាបសោត អ្នកនឹងត្រូវតិះដៀលក្នុងបរិស័ទ ៤ និងថា វិញ្ញូជនទាំង-ឡាយ នឹងតិះដៀលអ្នក ដូចអ្នកស្រុកតិះដៀលរបស់មិនស្អាត នៃភិក្ខុ អ្នកដែលជាអ្នកមានសីលទាំងឡាយ វៀរឆ្ងាយហើយ នឹងធ្វើដូចម្តេច ដូច្នេះ ។ រមែងមិនធ្វើបាបកម្ម ព្រោះឱត្តប្បៈដែលតាំងឡើងខាងក្រៅ ឱត្តប្បៈតែងឈ្មោះថា មានសមុដ្ឋានខាងក្រៅយ៉ាងនេះ ។

ហិរិ ឈ្មោះថា មានខ្លួនជាធំដូចម្តេច កុលបុត្តពួកខ្លះក្នុងលោកនេះ ធ្វើខ្លួនឲ្យជាធំ ឲ្យជាប្រធាន មិនធ្វើបាបដោយគិតថា បុគ្គលបួសដោយសទ្ធា ជាពហុសូត មានវាទៈក្នុងការកម្ចាត់កិលេសដូចអ្នក មិនគួរធ្វើបាបកម្ម ហិរិតែងឈ្មោះថា មានខ្លួនជាធំយ៉ាងនេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា

ភិក្ខុនេះ ធ្វើខ្លួនឯងឲ្យជាអាធិបតេយ្យហើយ រមែងលះបង់អកុសល
ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើ
ដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ដូច្នេះ ។

ឱត្តប្បៈ ឈ្មោះថា មានលោកជាធំដូចម្តេច កុលបុត្តពួកខ្លះក្នុងលោកនេះ

ធ្វើលោកឲ្យជាធំ ឲ្យជាប្រធាន ហើយមិនធ្វើបាបកម្ម សមដូចព្រះតម្រាស់ត្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា

លោកសន្និវាសនេះសោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណ-ព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្រនេះ ចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្រឡូកប្រឡល់ដោយធម៌ជាអកុសលដ៏លាមក ។ ម្យ៉ាងទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្រនេះ ចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្រឡូកប្រឡល់ដោយធម៌ជាអកុសលដ៏លាមក ។ ភិក្ខុនោះពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាម មិនឲ្យធូរថយ នឹងប្រុងសតិ មិនឲ្យវង្វេងភ្លេច ឲ្យកាយស្ងប់រម្ងាប់ មិនឲ្យធូរថយ ឲ្យចិត្តតម្កល់មាំ មានអារម្មណ៍តែមួយ ។ លុះភិក្ខុនោះ ប្រារព្ធលោកឲ្យជាអាធិបតេយ្យហើយ តែងលះបង់អកុសល ចម្រើនកុសល

លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ដូច្នេះ ។

ក្នុងពាក្យថា ហិរិ តាំងនៅក្នុងសភាវៈគួរខ្មាស ឱត្តប្បៈ តាំងនៅក្នុងភាវៈគួរខ្លាចនេះ មានវិនិច្ឆ័យដូចតទៅនេះ អាការខ្មាស ឈ្មោះថា ខ្មាស ហិរិតាំងនៅដោយសភាវៈនោះ ការខ្លាចអបាយ ឈ្មោះថា ភ័យ ឱត្តប្បៈតាំងនៅដោយសភាវៈនោះ ។ ហិរិ និងឱត្តប្បៈទាំង ២ នោះ រមែងប្រាកដក្នុងការវៀរចាកបាប ពិតហើយ បុគ្គលខ្លះឈានចុះកាន់ធម៌ គឺការខ្មាសដែលជាខាងក្នុង មិនធ្វើបាបកម្ម ដូចកុលបុត្ត កាលបន្ទោបង់ឧច្ចារបស្សាវៈជាដើម ឃើញបុគ្គលម្នាក់ ដែលគួរខ្មាស គប្បីជាអ្នកដល់នូវអាការខ្មាស ត្រូវឧច្ចារបស្សាវៈគ្របសង្កត់រហូតស្ទើរតែចេញមក ក៏បន្ទោបង់ឧច្ចារបស្សាវៈមិនបាន ដូច្នោះ បុគ្គលខ្លះខ្លាចភ័យក្នុងអបាយ ទើបមិនធ្វើបាបកម្ម ក្នុងសេចក្ដីនោះ មានឧបមាដូចតទៅ

ឧបមាដូចដុំដែក ២ ដុំ ១ ដុំត្រជាក់ តែប្រឡាក់លាមក ១ ដុំក្ដៅក្រហមឆ្អិនឆ្អៅ ។ ដុំដែក ២ ដុំនោះ បណ្ឌិតស្អប់ខ្ពើម មិនចាប់ដុំដែកដែលត្រជាក់ ព្រោះដុំដែកនោះប្រឡាក់លាមក មិនចាប់ដុំដែកក្ដៅ ព្រោះខ្លាចភ្លើងឆេះ យ៉ាងណា ហិរិ និងឱត្តប្បៈ ក៏ដូច្នោះ គប្បីជ្រាបការឈមចុះកាន់លជ្ជីធម៌ដែលជាខាងក្នុង ហើយមិនធ្វើបាបកម្ម ដូចបណ្ឌិតខ្ពើមដុំដែកត្រជាក់ ដែលប្រឡាក់លាមក ទើបមិនចាប់ ហើយគប្បីជ្រាបការមិនធ្វើបាប ព្រោះខ្លាចភ័យក្នុងអបាយ ដូចបណ្ឌិតមិនចាប់ដុំដែកក្ដៅ ព្រោះខ្លាចឆេះ ដូច្នោះ ។

ពាក្យទាំង ២ ថា ហិរិមានលក្ខណៈខ្មាសក្រែង ឱត្តប្បៈមានលក្ខណៈខ្លាចទោស និងឃើញភ័យ ដូច្នេះ រមែងប្រាកដចំពោះក្នុងការវៀរចាកបាប ប៉ុណ្ណោះ ពិតហើយ បុគ្គលខ្លះ ញុំាងហិរិដែលមានលក្ខណៈកោតក្រែងឲ្យកើតឡើង ដោយហេតុ ៤ ប្រការ គឺពិចារណាដល់ភាពជាធំដោយជាតិ ពិចារណាដល់ភាពជាធំនៃព្រះសាស្តា ពិចារណាដល់ភាពជាធំដោយមតិក និងពិចារណាដល់ភាពជាធំនៃសព្រហ្មចារី ហើយមិនធ្វើបាប ។

បុគ្គលខ្លះ ញុំាងឱត្តប្បៈដែលមានលក្ខណៈខ្លាចទោស និងឃើញភ័យឲ្យតាំងឡើង ដោយហេតុ ៤ ប្រការ គឺភ័យក្នុងការតិះដៀលខ្លួនឯង ១ ភ័យក្នុងការដែលអ្នកដទៃតិះដៀល ១ ភ័យ គឺអាជ្ញា ១ និងភ័យក្នុងទុគ្គតិ ១ ហើយមិនធ្វើបាប ។ ក្នុងសេចក្តីដែលពោលដោយហិរិឱត្តប្បៈនេះ គប្បីពោលការពិចារណាភាពជាធំដោយជាតិជាដើម និងភ័យក្នុងការតិះដៀលខ្លួនជាដើមឲ្យពិស្តារ សេចក្តីពិស្តារនៃការពិចារណាភាពជាធំដោយជាតិជាដើមនោះ បានពោលហើយ ក្នុងអដ្ឋកថា អង្គុត្តរនិកាយ ។

បទថា **សុក្កធម្មសមាហិតា** សេចក្តីថា កុសលធម៌ដែលគួរធ្វើ មានហិរិឱត្តប្បៈនេះឯងជាខាងដើម ឈ្មោះថា សុក្កធម៌ គឺធម៌ស កាលពោលដោយន័យរួម កាន់យកទាំងអស់ សុក្កធម៌នោះ គឺធម៌ដែលជាលោកិយ និងលោកុត្តរ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលប្រកបហើយ ប្រកបព្រមហើយដោយហិរិ និងឱត្តប្បៈទាំង ២ នោះ ។ បទថា **សន្តោ សប្បុរិសា លោកេ** សេចក្តីថា ឈ្មោះថា **សន្តោ** ព្រោះកាយកម្មជាដើមស្ងប់រម្ងាប់ហើយ ឈ្មោះ

ថា **សប្បុរិសា** ព្រោះជាបុរសដែលស្អាតដោយកតញ្ញូកតវេទី ។ ក្នុងបទថា **លោកេ** នេះ លោកមានច្រើន គឺសង្ខារលោក សត្វលោក ឱកាសលោក ខន្ធលោក អាយតនលោក និងធាតុលោក ។ ក្នុងលោកទាំងនោះ សង្ខារ-លោក លោកពោលក្នុងប្រយោគ ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ ។បេ។ លោក ១៨ បានដល់ ធាតុ ១៨ ដូច្នេះ ។ លោក មានខន្ធលោកជាដើម រួមនៅក្នុងសង្ខារលោកនោះឯង ។ ឯសត្វលោក លោកពោលក្នុងប្រយោគ ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា លោកនេះ លោកមុខ ព្រមទាំងព្រហ្ម-លោក ព្រមទាំងទេវលោក ដូច្នេះជាដើម ។

ឱកាសលោក លោកពោលក្នុងប្រយោគនេះ ( ព្រហ្មនិមន្តនិកសូត្រ ) ថា ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺ បានត្រឹមណា លោក គឺចក្រវាលទាំងមួយពាន់ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នក ប្រព្រឹត្តទៅ បានតែត្រឹមចក្រវាលមួយពាន់នុ៎ះ ដូច្នេះ ។

បណ្ដាលោកទាំងនោះ ក្នុងទីនេះ បំណងយកសត្វលោក ។ ពិតហើយ ក្នុងសត្វលោកប៉ុណ្ណោះ មានសប្បុរសបែបនេះ សប្បុរសទាំងនោះ លោក ពោលថា មានទេវធម៌ ។ បទថា **ទេវ** ក្នុងបទថា **ទេវធម្មា** នោះ ទេវៈមាន ៣ គឺសម្មតិទេព ១ ឧបបត្តិទេព ១ និងវិសុទ្ធិទេព ១ បណ្ដាទេវៈទាំងនោះ ព្រះរាជា និងព្រះរាជកុមារជាដើម ឈ្មោះថា **សម្មតិទេព** ព្រោះសត្វលោក

សន្មតថា ជាទេវៈ ចាប់តាំងអំពីមហាសម្មតិរាជមក ។ ទេវតាដែលកើតក្នុងទេវលោក ឈ្មោះថា **ឧបបត្តិទេព** ។ ព្រះខីណាស្រព ឈ្មោះថា **វិសុទ្ធិទេព** ។

សមដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា ពួកព្រះរាជា ព្រះរាជកុមារ និងព្រះទេពី លោកហៅថា សម្មតិទេព ។ ឧបបត្តិទេព តើដូចម្តេច ។ ពួកទេពឋិតនៅក្នុងចាតុម្មហារាជិកា ពួកទេពឋិតនៅក្នុងតាវត្តិង្ស ពួកទេពឋិតនៅក្នុងយាមា ពួកទេពឋិតនៅក្នុងតុសិត ពួកទេពឋិតនៅក្នុងនិម្មានរតី ពួកទេពឋិតនៅក្នុងបរនិម្មិតវសវត្តី និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលឋិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ វិសុទ្ធិទេព តើដូចម្តេច ។ ពួកព្រះអរហន្តខីណាស្រព ជាសាវ័ករបស់ព្រះតថាគត និងពួកព្រះខីណាស្រព ដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិទេព ។ ព្រះមានព្រះភាគ ជាទេពរបស់ពួកសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ជាទេពដ៏ក្រៃលែងផង ជាទេពធំកន្លងជាងពួកទេពផង ជាសីហៈ ធំជាងសីហៈផង ជានាគធំជាងនាគផង ជាមេគណៈធំជាងមេគណៈផង ជាមុនីធំជាងមុនីផង ជាព្រះរាជា ធំជាងព្រះរាជាផង ដូច្នេះ ។

ធម៌របស់ទេវៈទាំងនេះ ឈ្មោះថា **ទេវធម៌** ។

បទថា **វុច្ចរេ** បានដល់ រមែងពោល ពិតហើយ កុសលធម៌ទាំងឡាយមានហិរិឱត្តប្បៈជាមូល ឈ្មោះថា ជាធម៌របស់ទេវៈទាំង ៣ ប្រភេទនេះ

ព្រោះអត្ថថា ជាហេតុនៃកុសលសម្បទា នៃការកើតក្នុងទេវលោក និងនៃការបរិសុទ្ធ ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវធម្ម** បុគ្គលដែលប្រកបដោយទេវធម៌ទាំងនោះ ក៏ជាអ្នកមានទេវធម៌ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ទាំងនោះ ដោយបុគ្គលាធិដ្ឋានទេសនា ទើបត្រាស់ថា **សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ** ដូច្នេះ ។

យក្ខកាលបានស្តាប់ធម្មទេសនានេះ មានសេចក្តីជ្រះថ្លា ទើបពោលនឹងព្រះពោធិសត្វថា បពិត្របណ្ឌិត ខ្ញុំជ្រះថ្លាជាមួយលោក នឹងឲ្យប្អូនប្រុសម្នាក់ តើឲ្យនាំប្អូនមួយណាមក ព្រះពោធិសត្វត្រាស់ថា ចូរនាំប្អូនពៅមកចុះ យក្ខពោលថា នែបណ្ឌិត លោកដឹងតែទេវធម៌តែម្យ៉ាងប៉ុណ្ណោះ តែមិនប្រព្រឹត្តក្នុងទេវធម៌ទាំងនោះទេ ព្រះពោធិសត្វត្រាស់សួរថា ព្រោះហេតុអ្វី យក្ខពោលថា ព្រោះលោកវៀរប្អូនប្រុស ឲ្យនាំប្អូនពៅមក ឈ្មោះថា មិនធ្វើកម្មរបស់បុគ្គលអ្នកឱនលំទោនដល់បុគ្គលចម្រើន ។ ព្រះពោធិសត្វត្រាស់ថា នែយក្ខ ខ្ញុំដឹងទេវធម៌ និងប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ ព្រោះថា យើងទាំងឡាយចូលព្រៃនេះ ព្រោះអាស្រ័យប្អូនប្រុសនេះ ដ្បិតថា ព្រះមាតារបស់ប្អូនប្រុសនេះ ទូលសូមរាជសម្បត្តិនឹងព្រះបិតារបស់ពួកយើង ដើម្បីជាប្រយោជន៍ដល់ប្អូនប្រុសនេះ តែបិតារបស់ពួកយើង មិនឲ្យពរនោះ ដើម្បីរក្សាពួកយើង ទើបទ្រង់

អនុញ្ញាតការនៅព្រៃ ព្រះកុមារនោះជាប់តាមមកជាមួយពួកយើង កាលពួកយើងពោលថា យក្ខក្នុងព្រៃស៊ីកុមារនោះហើយ បុគ្គលណាក៏មិនជឿ ដោយហេតុនោះ យើងខ្លាចអំពីភ័យ គឺការនិន្ទា ទើបឲ្យនាំប្អូនពៅនោះឯងមក យក្ខមានចិត្តជ្រះថ្លា ឲ្យសាធុការដល់ព្រះពោធិសត្វថា សាធុ សាធុ បណ្ឌិតលោកចេះទេវធម៌ផង បដិបត្តិក្នុងទេវធម៌ទាំងនោះផង ដូច្នេះហើយ ទើបនាំប្អូនប្រុសទាំង ២ នាក់មកឲ្យ ។ លំដាប់នោះ ព្រះពោធិសត្វត្រាស់នឹងយក្ខនោះថា នែសម្លាញ់ អ្នកកើតជាយក្ខ មានសាច់ និងឈាមរបស់អ្នកដទៃជាអាហារ ព្រោះបាបកម្មដែលខ្លួនធ្វើក្នុងជាតិមុន ឥឡូវនេះ អ្នកធ្វើបាបកម្មនោះដដែលទៀត ព្រោះថា បាបកម្មនឹងមិនឲ្យផុតចាកនរកជាដើម ព្រោះហេតុនោះតាំងអំពីនេះទៅ ចូរអ្នកលះបាបកម្ម ហើយធ្វើតែកុសល ។ ព្រះពោធិសត្វកាលទូន្មានយក្ខនោះហើយ ជាបុគ្គលដែលយក្ខនោះរៀបចំការរក្សាក្នុងទីនោះឯង ។ ថ្ងៃមួយ សម្លឹងមើលនក្ខត្តឫក្ស ដឹងថា ព្រះជនកសោយទិវង្គត ទើបនាំយក្ខទៅកាន់ក្រុងពារាណសី កាន់យករាជសម្បត្តិ ប្រទានតំណែងឧបរាជដល់ចន្ទកុមារ ប្រទានតំណែងសេនាបតីដល់សុរិយកុមារ ឲ្យសាងលំនៅក្នុងទីដែលគួរត្រេកអរដល់យក្ខ ទ្រង់បានធ្វើដោយប្រការដែលយក្ខបាននូវការបូជាដ៏លើស ផ្កាដ៏ក្រៃលែង គ្រឿងក្រអូបដ៏ក្រៃលែង ផ្លែឈើដ៏ក្រៃលែង និងភត្ត

ដ៏ក្រៃលែង ។ ព្រះពោធិសត្វគ្រងរាជ្យដោយធម៌ ទៅតាមយថាកម្មហើយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ព្រះសម្មាសម្ពុទ្ធ ក៏ត្រាស់ ២ រឿង បន្តអនុសន្ធិជាប់គ្នាទៅ ហើយទ្រង់ប្រជុំជាតកថា អារក្ខទឹកក្នុងកាលនោះ បានជាភិក្ខុមានកណ្ឋៈច្រើន ក្នុងកាលឥឡូវនេះ សុរិយកុមារ បានមកជាអានន្ទ ចន្ទកុមារ បានមកជាសារីបុត្រ ឯមហិសាសកុមារដែលជាច្បង គឺតថាគតនេះឯង ៕

**អដ្ឋកថា ទេវធម្មជាតក ចប់**

# សុត្តន្តបិដក

## កណ្ឌហារិជាតក

[ ៧ ] ( ព្រះរាជកុមារពោធិសត្វពោលថា ) បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្តេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វដែលជាបុត្ររបស់ព្រះអង្គផង ។

*កណ្ឌហារិជាតកទី ៧ ចប់*

# អដ្ឋកថា

# កដ្ឋហារិជាតក

[ ៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះនាងវាសភខត្តិយា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បុត្តោ ត្យាហំ មហារាជ** ដូច្នេះជាដើម ។

រឿងព្រះនាងវាសភខត្តិយា មានជាក់ច្បាស់ហើយក្នុងភទ្ទសាលជាតក ទ្វាទសកនិបាត ។ បានឮថា ព្រះនាងវាសភខត្តិយានោះ ជាព្រះរាជធីតារបស់ព្រះបាទសក្យមហានាម ប្រសូតចាកគភ៌របស់ទាសី ឈ្មោះនាគមុណ្ឌា សម័យក្រោយមក បានជាអគ្គមហេសីរបស់ព្រះបាទបសេនទិកោសល ព្រះនាងប្រសូតព្រះរាជឱរស ។ ក្រោយមក ព្រះរាជាទ្រង់ដឹងថា ព្រះនាងជាទាសី ទើបទ្រង់ដកតំណែង សូម្បីវិឌូឌភៈជាឱរសក៏ត្រូវដកតំណែងដូចគ្នា ម្តាយកូនទាំង ២ នៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គនោះឯង ។ ព្រះសាស្តាទ្រង់ជ្រាបហេតុនោះ ក្នុងពេលល្ងាច ទ្រង់ចោមរោមដោយភិក្ខុ ៥០០ យាងទៅកាន់ព្រះរាជនិវេសន៍របស់ព្រះរាជា គង់លើអាសនៈដែលគេក្រាលហើយ ត្រាស់ថា ព្រះនាងវាសភខត្តិយា ប្រថាប់នៅទីណា ។ ទើបព្រះរាជាក្រាបទូលហេតុនោះឲ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់សួរថា មហាបពិត្រ ព្រះនាងវាសភ-ខត្តិយា ជាធីតារបស់អ្នកណា ព្រះរាជាទូលថា ជាធីតារបស់មហានាម ។ ព្រះសាស្តាត្រាស់សួរថា កាលព្រះនាងវាសភខត្តិយាយាងមក យាងមកដើម្បីអ្នកណា ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីខ្ញុំព្រះអង្គនោះឯង ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះនាងវាសភខត្តិយានេះ ជាធីតារបស់ព្រះ

រាជា និងមកដើម្បីព្រះរាជា ព្រោះអាស្រ័យព្រះរាជានោះឯង ទើបបានឱរស ព្រោះហេតុអ្វី ទើបព្រះរាជឱរសនោះមិនបានជាម្ចាស់របស់រាជសម្បត្តិ ដែលជារបស់ព្រះបិតា ។ ព្រះរាជាទាំងឡាយក្នុងកាលមុន បានព្រះឱរសក្នុងគភ៌របស់ស្រីរកឧស ដែលជាករិយាម្ដងម្កាល ក៏គង់ព្រះរាជទានរាជសម្បត្តិដល់ព្រះឱរស ។ ព្រះរាជាទ្រង់ទូលអារាធនាព្រះសាស្ដា ដើម្បីត្រាស់រឿងនោះឲ្យប្រាកដ ។ ព្រះសាស្ដា ទ្រង់បានធ្វើហេតុ ដែលអន្តរកពបិទបាំងឲ្យប្រាកដដូច្នេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងនគរពារាណសី យាងទៅព្រះរាជឧទ្យាន ដោយព្រះយសធំ ទ្រង់ត្រាច់ទៅក្នុងព្រះរាជឧទ្យាននោះ ទ្រង់ត្រេកអរក្នុងផ្កា និងផ្លែឈើ ទ្រង់ឃើញស្រីម្នាក់ ច្រៀងបណ្ដើរ កាប់ឧសបណ្ដើរក្នុងព្រៃ ក្នុងព្រះរាជឧទ្យាន ទ្រង់មានចិត្តប្រតិព័ទ្ធ ទើបសម្រេចការនៅរួមគ្នាក្នុងខណៈនោះឯង ព្រះពោធិសត្វ ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ស្រីនោះ រំពេចនោះគភ៌របស់នាងបានធ្ងន់ ដូចពេញដោយពេជ្រ នាងដឹងថា តាំងគភ៌ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគភ៌ហើយ ព្រះរាជាបានព្រះរាជទានព្រះទម្រង់ ត្រាស់ថា បើជាធីតា ចូរនាងចំណាយចិញ្ចៀនចិញ្ចឹមរក្សា បើជាបុត្ត ចូរនាំមកកាន់សម្នាក់របស់យើង មួយអន្ទើដោយចិញ្ចៀននេះ ។ លុះត្រាស់ហើយ ទើបយាងចៀសចេញទៅ ។ ឯស្រីនោះមានគភ៌ចាស់ហើយ ក៏ប្រសូតព្រះពោធិសត្វ ។ កាលព្រះពោធិសត្វលេងក្នុងទីលានសម្រាប់លេង ក្នុងកាលដែលរត់ទៅមកបាន មានមនុស្ស

ពោលយ៉ាងនេះថា ពួកយើងត្រូវអាកូនឥតឪវាយហើយ ព្រះពោធិសត្វស្តាប់ដូច្នោះ ទើបចូលទៅរកមាតា សួរថា បពិត្រអ្នកម៉ែ អ្នកណាជាឪពុករបស់ខ្ញុំ មាតាពោលថា នែកូន បាជាឱរសរបស់ព្រះបាទពារាណសី ព្រះពោធិសត្វពោលថា បន្ទាល់ណាមួយមានឬ មាតាពោលថា នែបា ព្រះរាជាប្រទានព្រះទម្រង់នេះ ហើយត្រាស់ថា បើជាធីតា គប្បីលក់ដូរចិញ្ចឹមចុះ បើជាបុត្ត គប្បីនាំមក មួយអន្លើដោយចិញ្ចៀននេះ ដូច្នេះហើយ ក៏យាងទៅ ព្រះពោធិសត្វពោលថា បពិត្រអ្នកម៉ែ បើដូច្នោះ ព្រោះហេតុអ្វី ទើបមិននាំខ្ញុំទៅកាន់សម្នាក់របស់ព្រះបិតា នាងដឹងអធ្យាស្រ័យរបស់បុត្ត ទើបទៅកាន់ទ្វារព្រះរាជវាំង ឲ្យមនុស្សក្រាបទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប និងជាបុគ្គលដែលព្រះរាជាត្រាស់ឲ្យចូលគាល់ ទើបចូលទៅថ្វាយបង្គំព្រះរាជាហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះឱរសរបស់ព្រះអង្គ ព្រះរាជាទ្រង់ជ្រាប តែព្រោះខ្មាសក្នុងកណ្តាលបរិស័ទ ទើបត្រាស់ថា មិនមែនបុត្តរបស់យើងឡើយ ស្រីនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះព្រះទម្រង់របស់ព្រះអង្គ ទ្រង់ចាំព្រះទម្រង់នេះបានដែរឬទេ ។ ព្រះរាជាត្រាស់ថា សូម្បីព្រះទម្រង់នេះ ក៏មិនមែនរបស់យើង ។ ស្រីនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ឥឡូវនេះវៀរសច្ចកិរិយាចេញ អ្នកដទៃដែលជាសាក្សីរបស់ខ្ញុំម្ចាស់មិនមាន បើទារកនេះកើតព្រោះអាស្រ័យព្រះអង្គ កាលខ្ញុំម្ចាស់បោះទារកឡើងទៅហើយ ចូរនៅក្នុងអាកាស បើមិនបានអាស្រ័យព្រះអង្គកើតទេ សូមធ្លាក់មកលើផែនដី ហើយចាប់ជើងទាំង ២ របស់ព្រះពោធិសត្វ បោះទៅក្នុងអាកាស ព្រះពោធិសត្វ

អន្ទុយពត់ក្អែកក្នុងអាកាស កាលពោលធម៌ដល់ព្រះបិតា ដោយសំឡេង ដ៏ពីរោះ ទើបត្រាស់គាថានេះថា

បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាង ពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជន ដទៃបាន ម្ដេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វដែលជាបុត្ររបស់ ព្រះអង្គផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុត្តោ ត្យាហំ** កាត់បទជា **បុត្តោ តេ អហំ** ប្រែថា ទូលបង្គំជាឱរសរបស់ទ្រង់ ។ ឈ្មោះថា បុត្ត មាន ៤ ពួក គឺបុត្ត កើតក្នុងខ្លួន ១ បុត្តកើតក្នុងខេត្ត ១ បុត្តដែលជាអន្តេវាសិក ១ និងបុត្ត ដែលគេឲ្យ ១ ។

បណ្ដាបុត្ត ៤ ប្រភេទនោះ បុត្តដែលអាស្រ័យខ្លួនកើត ឈ្មោះថា បុត្ត ដែលកើតក្នុងខ្លួន បុត្តដែលកើតក្នុងទីទាំងឡាយ មានលើដំណេក លើបល្ល័ង្ក និងទ្រូង ឈ្មោះថា កូនដែលកើតក្នុងខេត្ត ។ បុគ្គលដែលរៀនសិប្បៈ ឈ្មោះថា កូនសិស្ស បុត្តដែលគេឲ្យមកចិញ្ចឹម ឈ្មោះថា បុត្តដែលគេឲ្យ គឺបុត្រចិញ្ចឹម តែក្នុងទីនេះ លោកសំដៅយកបុត្តដែលកើតក្នុងខ្លួន ទើបពោលថា **បុត្តោ** ដូច្នេះ ។

ដែលឈ្មោះថា ព្រះរាជា ព្រោះធ្វើឲ្យជនត្រេកអរ ដោយសង្គហវត្ថុ ៤ ព្រះរាជាដែលជាធំ ឈ្មោះថា មហារាជា ព្រះពោធិសត្វ កាលត្រាស់ហៅ ព្រះរាជានោះ ទើបត្រាស់ថា **មហារាជ** ដូច្នេះ ។

បទថា **ត្វំ មំ ចោស ជនាធិប** សេចក្តីថា បពិត្រព្រះអង្គជាធំក្នុងមហាជន ព្រះអង្គចិញ្ចឹម គឺសូមចិញ្ចឹមទូលបង្គំចុះ ។ បទថា **អញ្ញេបិ ទេវោ ចោសេតិ** សេចក្តីថា ជនច្រើនពួកដទៃ បានដល់ ពួកមនុស្សដែលចិញ្ចឹមដំរីជាដើម និងសត្វតិរច្ឆាន មានដំរី និងសេះជាដើម ទ្រង់គង់ចិញ្ចឹមបាន ។ សព្ទថា **កិញ្ចា** ក្នុងបទថា **កិញ្ចា ទេវោ សកំ បជំ** នេះ ជានិបាតសព្ទ ប្រើក្នុងអត្ថថា តិះដៀល និងអត្ថថា អនុគ្រោះ ។ ព្រះពោធិសត្វទ្រង់ទូន្មានថា ប្រជារាស្ត្ររបស់ព្រះអង្គ គឺទូលបង្គំជាឱរសរបស់ទ្រង់ ទ្រង់មិនចិញ្ចឹម ដូច្នេះ ឈ្មោះថា រមែងតិះដៀល ។ កាលត្រាស់ថា ជនដទៃជាច្រើន ព្រះអង្គទ្រង់ចិញ្ចឹមបាន ដូច្នេះ ឈ្មោះថា រមែងអនុគ្រោះ ជួយស្រោចស្រង់ ។ ដូច្នោះ ព្រះពោធិសត្វ កាលទ្រង់តិះដៀល ទើបត្រាស់ថា ម្តេចព្រះសម្មតិទេពក៏មិនចិញ្ចឹម សត្វដែលជាបុត្ររបស់ព្រះអង្គផង ដូច្នេះ ។

កាលព្រះពោធិសត្វ ប្រថាប់គង់ក្នុងអាកាសសម្តែងធម៌យ៉ាងនេះ ព្រះរាជាបានស្តាប់ហើយ ទើបទ្រង់លាព្រះហស្តត្រាស់ថា ចូរមកចុះបា យើងនឹងចិញ្ចឹមបា កាលដៃរាប់ពាន់លាមកហើយ ព្រះពោធិសត្វមិនចុះក្នុងដៃអ្នកដទៃ ចុះក្នុងព្រះហស្តរបស់ព្រះរាជាប៉ុណ្ណោះ ហើយប្រថាប់គង់លើភ្លៅ ព្រះរាជាទ្រង់ប្រទានភាពជាឧបរាជដល់ព្រះពោធិសត្វនោះ ហើយទ្រង់តាំងមាតាឲ្យជាអគ្គមហេសី កាលព្រះបិតាសោយទិវង្គតហើយ ព្រះពោធិសត្វបានជាព្រះរាជាព្រះនាមកដ្ឋវាហនៈ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ បានយាងទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំព្រះទេសនានេះមកសម្តែងដល់ព្រះបាទកោសល ហើយ ទ្រង់សម្តែង ២ រឿង បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា ព្រះមាតាក្នុងកាលនោះ បានមកជាព្រះនាងមហាមាយាទេវី ក្នុងកាលឥឡូវនេះ ព្រះបិតាបានមកជាព្រះបាទសុទ្ធោទនមហារាជ ឯព្រះបាទកដ្ឋវាហនរាជ គឺតថាគតនោះឯង ៕

## អដ្ឋកថា កដ្ឋហារិជាតក ចប់

# សុត្តន្តបិដក

## គាមណិជាតក

[ ៨ ] ( គាមណិកុមារពោលថា ) ការប្រាថ្នានូវផល តែងសម្រេចព្រមដល់ពួកជនអ្នកមិនរួសរាន់ អញជាអ្នកមានព្រហ្មចារ្យចាស់ថ្លាហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ ។

*គាមណិជាតកទី ៨ ចប់*

# អដ្ឋកថា

## គាមណិជាតក

[ ៨ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធភិក្ខុលះបង់សេចក្តីព្យាយាម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ អតរមានានំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន និងរឿងអតីត ក្នុងជាតកនេះ មានច្បាស់ក្នុងសំវរជាតកឯកាទសកនិបាត ក្នុងសំវរជាតកនោះ និងជាតកនេះ ជារឿងដូចគ្នាតែមួយ តែគាថាផ្សេងគ្នា មានសេចក្តីសង្ខេបថា គាមណិកុមារតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ សូម្បីជាព្រះកនិដ្ឋារបស់ព្រះភាតា ១០០ ព្រះអង្គ ក៏ជាបុគ្គលដែលព្រះភាតាទាំង ១០០ អង្គចោមរោម ប្រថាប់គង់លើបល្ល័ង្កដ៏ប្រសើរ ខាងក្រោមស្វេតច្ឆត្រ ទតយសសម្បត្តិរបស់ព្រះអង្គ ទ្រង់ត្រេកអរថា យសសម្បត្តិរបស់អញនេះ ជារបស់អាចារ្យនៃអញ ទើបទ្រង់បន្លឺឧទានថា

ការប្រាថ្នានូវផល តែងសម្រេចព្រម ដល់ពួកជនអ្នកមិនរួសរាន់
អញជាអ្នកមានព្រហ្មចារ្យចាស់ថ្លាហើយ ម្នាលគាមណិ អ្នកចូរដឹង
យ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ សព្ទថា **អបិ** ត្រឹមតែជានិបាត ។ បទថា **អតរ-មានានំ** បានដល់ ដែលតាំងនៅក្នុងឱវាទរបស់បណ្ឌិតទាំងឡាយដែលមិនរួសរាន់ ធ្វើការដោយឧបាយ ។ បទថា **ផលាសាវ សមិជ្ឈតិ** សេចក្តីថា ការសង្ឃឹមក្នុងផលដែលប្រាថ្នា ឈ្មោះថា រមែងសម្រេចពិត ព្រោះការសម្រេច

ផលនោះ ។ ម្យ៉ាងទៀត បទថា **ផលាសា** បានដល់ ផលនៃការសង្ឃឹម ផលតាមដែលប្រាថ្នា រមែងសម្រេចនោះឯង ។ ក្នុងបទថា **វិបក្កព្រហ្ម-ចរិយោស្មិ** នេះ សង្គហវត្ថុ ៤ ឈ្មោះថា **ព្រហ្មចរិយៈ** ព្រោះជាការប្រព្រឹត្តដ៏ប្រសើរ ព្រហ្មចរិយៈនោះ ឈ្មោះថា ចាស់ក្លាហើយនោះឯង ព្រោះបានចំពោះយសសម្បត្តិ ដែលមានសង្គហវត្ថុនោះជាមូល យសដែលសម្រេចដោយគាមណិកុមារនោះ ឈ្មោះថា **ព្រហ្មចរិយៈ** ព្រោះអត្ថថា ប្រសើរ ។ ដោយហេតុនោះ ទើបលោកពោលថា ខ្ញុំជាអ្នកមានព្រហ្មចរិយៈចាស់ក្លាហើយ ។ បទថា **ឯវំ ជានាហិ គាមណិ** សេចក្តីថា ក្នុងទីខ្វះនៃបុរសអ្នកស្រុកក្តី មេស្រុកក្តី ឈ្មោះថា គាមណិ តែក្នុងទីនេះ សំដៅយកខ្លួនឯងដែលជាប្រធាននៃមនុស្សទាំងពួង ទើបពោលថា នៃគាមណិដ៏ចម្រើន ចូរអ្នកដឹងហេតុនេះយ៉ាងនេះថា ខ្ញុំឈានកន្លងបងប្រុសរាប់រយនាក់ បានទទួលរាជសម្បត្តិធំនេះ ព្រោះអាស្រ័យអាចារ្យ ដូច្នេះ បន្លឺឧទានហើយ ។

កាលគាមណិកុមារនោះ បានរាជសម្បត្តិហើយ លុះវេលាកន្លងទៅបាន ៧-៨ ថ្ងៃ បងប្រុសទាំងអស់ បានទៅកាន់លំនៅរៀងៗ ខ្លួន ព្រះបាទគាមណិគ្រងរាជសម្បត្តិដោយធម៌ ហើយទៅតាមយថាកម្ម ឯព្រះពោធិសត្វធ្វើបុណ្យហើយ ក៏បានទៅតាមយថាកម្មដូចគ្នា ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ចទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលលះសេចក្តីព្យាយាម បានតាំងនៅក្នុងអរហត្ត ដូច្នេះ ។ ព្រះសាស្តាត្រាស់ ២ រឿង

បន្តអនុសន្ធិតគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះបាទគាមណិក្នុងកាលនោះ បានជាអានន្ទ ក្នុងកាលឥឡូវនេះ ឯអាចារ្យ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា គាមណិជាតក ចប់

# សុត្តន្តបិដក

## មឃទេវជាតក

[ ៩ ] ( ព្រះរាជាពោធិសត្វទ្រង់ត្រាស់ថា ) សក់ទាំងឡាយនេះនាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ ទេវទូត កើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់អញ ។

*មឃទេវជាតកទី ៩ ចប់*

# អដ្ឋកថា

## មឃទេវជាតក

[ ៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការចេញមហាភិនេស្រ្កមណ៍ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧត្តមង្គរុហា មយ្ហំ** ដូច្នេះជាដើម ។

ការយាងចេញមហាភិនេស្រ្កមណ៍នោះ បានពោលហើយ ក្នុងនិទានកថា ( អវិទូរេនិទាន ) ខាងដើមនោះឯង ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយអង្គុយពណ៌នាការចេញបព្វជ្ជារបស់ព្រះទសពល ។

លំដាប់នោះ ព្រះសាស្តាយាងមកកាន់រោងធម្មសភា គង់លើពុទ្ធាសនៈត្រាស់ហៅភិក្ខុទាំងឡាយមក សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មិនបានអង្គុយសន្ទនាគ្នាដោយរឿងដទៃឡើយ អង្គុយពណ៌នាការយាងចេញបួសរបស់ព្រះអង្គប៉ុណ្ណោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញបួសក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុន ក៏បានចេញបួសហើយដូចគ្នា ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះមានព្រះភាគ ដើម្បីត្រាស់រឿងនោះឲ្យជាក់ច្បាស់ ព្រះសាស្តាទ្រង់ធ្វើហេតុដែលអន្តរកពបិទបាំង ឲ្យប្រាកដដូចតទៅ

ក្នុងអតីតកាល ក្នុងក្រុងមិថិលាវិទេហរដ្ឋ មានព្រះរាជានាមមឃទេវៈជាព្រះមហាធម្មរាជា តាំងនៅក្នុងធម៌ ព្រះបាទមឃទេវៈនោះ ទ្រង់ឲ្យកាលវេលាដ៏យូរអស់ទៅ ថ្ងៃមួយ ហៅខ្មាន់ព្រះកេសមកប្រាប់ថា នែសម្លាញ់ អ្នក

ឃើញសក់ស្កូវលើក្បាលរបស់ខ្ញុំក្នុងកាល ចូរអ្នកប្រាប់ដល់ខ្ញុំក្នុងកាលនោះ ឯខ្មាន់ព្រះកេសក៏បានធ្វើកាលដ៏យូរឲ្យអស់ទៅ ថ្ងៃមួយ ឃើញព្រះកេសាស្កូវ ១ សរសៃ ក្នុងចន្លោះព្រះកេសាទាំងឡាយ ដែលមានពណ៌ដូចផ្កាអញ្ចន់ របស់ព្រះរាជា ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះកេសាមួយសរសៃ ប្រាកដដល់ព្រះអង្គ ព្រះរាជាត្រាស់ថា សម្លាញ់ បើដូច្នោះ ចូរអ្នកដកស្កូវរបស់ខ្ញុំនោះយកមកដាក់ក្នុងបាតដៃ កាលព្រះរាជាត្រាស់យ៉ាងនោះ ទើបខ្មាន់ព្រះកេសយកសណ្ឌាសមាសដក ហើយឲ្យព្រះកេសាស្កូវប្រតិស្ឋានទៅក្នុងបាតព្រះហស្តរបស់ព្រះរាជា ក្នុងកាលនោះ ព្រះរាជានៅមានព្រះជន្មាយុនៅសល់ ៨៤០០០ ឆ្នាំ កាលបើដូច្នោះ ព្រះរាជាបានឃើញសក់ស្កូវហើយ ក៏ទ្រង់សម្គាល់ហាក់បីដូចស្តេចមច្ចុរាជមកឈរក្បែរៗ ហាក់បីដូចខ្លួនឯង ចូលមកក្នុងបណ្ណសាលា ដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ ដូច្នោះ ទ្រង់បានដល់នូវសេចក្តីសង្វេគ ទើបទ្រង់ព្រះតម្រិះថា ម្នាលមឃទេវៈល្ងង់ខ្លៅ អ្នកមិនអាចលះកិលេសទាំងនេះ ដរាបដល់សក់ស្កូវកើតឡើង ។ កាលព្រះបាទមឃទេវៈនោះ ទ្រង់ពិចារណាដល់សក់ស្កូវដែលប្រាកដហើយ ការក្តៅក្រហាយខាងក្នុងក៏កើតឡើង ព្រះសេទោក្នុងសរីរៈក៏ហូរចេញ សំពត់សាជកក៏ដល់នូវអាការដែលត្រូវជូត ។ ព្រះបាទមឃទេវៈ ទ្រង់ព្រះតម្រិះថា អញគួរចេញបួសក្នុងថ្ងៃនេះឯង ទើបទ្រង់ព្រះរាជទានស្រុកដែលល្អ ជាទីតាំងឡើងនៃទ្រព្យ ៧០០០ ដល់ខ្មាន់ព្រះកេស ហើយត្រាស់ឲ្យហៅព្រះឱរសច្បងមក ត្រាស់ថា នែបា សក់ស្កូវប្រាកដលើក្បាលរបស់ឪពុកហើយ ឪពុកជាមនុស្សចាស់ហើយ

កាមរបស់មនុស្ស ឪពុកបានបរិភោគហើយ ឥឡូវនេះ ឪពុកនឹងស្វែងរកកាមដែលជាទិព្វ នេះជាកាលចេញបួសរបស់ឪពុក ចូរបាគ្រប់គ្រងរាជសម្បត្តិនេះ ឪពុកបួសហើយ ធ្វើនូវសមណធម៌ ក្នុងអម្ពវនឧទ្យាន ឈ្មោះមឃទេវៈ ។ អមាត្យទាំងឡាយចូលទៅគាល់ ព្រះរាជានោះដែលមានបំណងនឹងបួសយ៉ាងនោះ ហើយទូលសួរថា បពិត្រព្រះសម្មតិទេព អ្វីជាហេតុនៃផ្នួសរបស់ព្រះអង្គ ព្រះរាជាទ្រង់កាន់យកសក់ស្កូវ ត្រាស់ព្រះគាថានេះដល់អមាត្យទាំងឡាយថា

សក់ទាំងឡាយនេះនាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ

ទេវទូត កើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់អញ

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧត្តមង្គរុហា** បានដល់ សក់ ពិតហើយ សក់ទាំងឡាយ ហៅថា **ឧត្តមង្គរុហា** ព្រោះដុះឡើងលើទីខ្ពស់នៃអវយវៈមានដៃ-ជើងជាដើម គឺលើក្បាល ។ បទថា **មយ្ហំ ជាតា វយោហរា** សេចក្ដីថា ចូរអ្នកទាំងឡាយមើល សក់ស្កូវទាំងនេះកើតហើយ ឈ្មោះថា ជាហេតុនាំយកវ័យទៅ ព្រោះនាំយកវ័យទាំង ៣ ទៅ ដោយការៈប្រាកដនៃសក់ស្កូវ ។ បទថា **បាតុភូតា** បានដល់ កើតឡើងហើយ ។

មច្ចុ ឈ្មោះថា ទេវៈ ដែលឈ្មោះថា ទេវទូត ព្រោះជាទូតនៃទេវៈនោះ ពិតហើយ កាលសក់ស្កូវទាំងឡាយប្រាកដលើក្បាល បុគ្គលរមែងដូចជាឈរនៅក្នុងសម្នាក់របស់ស្ដេចមច្ចុរាជ ព្រោះដូច្នោះ ទើបសក់ស្កូវទាំងឡាយ លោកហៅថា ទូតរបស់ទេវៈ គឺមច្ចុ ។ ដែលឈ្មោះថា **ទេវទូត** ព្រោះជាទូតដូចទេវៈ

ដូច្នេះក៏មាន ឧបមាដូចបុគ្គលកាលទេវតា ដែលប្រដាប់តាក់តែងល្អហើយ ឈរក្នុងអាកាសពោលថា អ្នកនឹងស្លាប់ក្នុងថ្ងៃឈ្មោះនោះ យ៉ាងណា កាលសក់ស្កូវទាំងឡាយប្រាកដហើយលើសីសៈ យ៉ាងនេះ រមែងដូចគ្នានឹងទេវតាព្យាករ ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបសក់ស្កូវទាំងឡាយ លោកពោលថា ជាទូតដូចទេវៈ ។ ដែលឈ្មោះថា **ទេវទូត** ព្រោះជាទូតរបស់វិសុទ្ធិទេពទាំងឡាយ ដូច្នេះក៏មាន ពិតហើយ ព្រះពោធិសត្វទាំងឡាយគ្រប់អង្គ ទតឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិតប៉ុណ្ណោះ ក៏ដល់នូវការសង្វេគ ចេញបួស សមដូចព្រះតម្រាស់ត្រាស់ ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខ ទាំងឃើញ
មនុស្សដល់នូវការអស់ទៅនៃអាយុ ស្លាប់ហើយ ហេតុនោះ ខ្ញុំ
លះបង់កាមជាទីត្រេកអរនៃចិត្ត ហើយចេញបួស ដូច្នេះ ។

ដោយបរិយាយនេះ សក់ស្កូវទាំងឡាយ លោកហៅថា **ទេវទូត** ព្រោះជាទូតនៃវិសុទ្ធិទេពទាំងឡាយ ។ ដោយបទថា **បព្វជ្ជាសមយោ មមំ** នេះ លោកសម្តែងថា នេះជាកាលនៃការកាន់យកសមណភេទ ដែលបានឈ្មោះថា បព្វជ្ជា ព្រោះអត្ថថា ចេញចាកភាពជាគ្រហស្ថរបស់ខ្ញុំ ។

ព្រះបាទមឃទេវៈនោះ កាលត្រាស់យ៉ាងនេះហើយ ទើបលះរាជសម្បត្តិ បួសជាឥសីក្នុងថ្ងៃនោះឯង ប្រថាប់នៅក្នុងមឃអម្ពវ័ន ចម្រើនព្រហ្មវិហារ ៤ អស់ ៨៤០០០ ឆ្នាំ តាំងនៅក្នុងឈានមិនសាបសូន្យ សោយទិវង្គតហើយ

កើតក្នុងព្រហ្មលោក ចុតិចាកព្រហ្មលោកនោះ បានជាព្រះរាជាឈ្មោះនេមិ ក្នុងក្រុងមិថិលានោះឯងទៀត បន្តវង្សរបស់ព្រះអង្គដែលវិនាស ទើបទ្រង់ចេញបួស ក្នុងអម្ពវ័ននោះឯង ចម្រើនព្រហ្មវិហារ ទៅកើតក្នុងព្រហ្មលោកសាជាថ្មីទៀត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញមហាភិនេស្រ្កមណ៍ ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានចេញហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសអរិយសច្ច ៤ ក្នុងកាលចប់អរិយសច្ច ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ព្រះសាស្តាត្រាស់ ២ រឿងនេះ បន្តអនុសន្ធិ ដោយប្រការដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ខ្មាន់ព្រះកេសក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ រាជបុត្តក្នុងកាលនោះ បានជាព្រះរាហុល ឯស្តេចមឃទេវៈ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា មឃទេវជាតក ចប់

# សុត្តន្តបិដក

## សុខវិហារិជាតក

[ ១០ ] ( ឥសីពោធិសត្វពោលថា ) ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ ។

សុខវិហារិជាតកទី ១០ ចប់

អបណ្ណកវគ្គទី ១ ចប់

### ឧទ្ទាននៃអបណ្ណកវគ្គនោះ គឺ

និយាយអំពីបុគ្គលខ្លះ ប្រកាន់ហេតុមិនខុសដ៏ប្រសើរ ក្នុងអបណ្ណកជាតក ១ វណ្ណុបថជាតក ១ សេរិវវាណិជជាតក ១ បុគ្គលមានប្រាជ្ញាជាគ្រឿងពិចារណា ក្នុងចូឡសេដ្ឋិជាតក ១ តណ្ឌុលនាឡិជាតក ១ បុគ្គលមានហិរិក្នុងទេវធម្មជាតក ១ ព្រះរាជបុត្តក្នុងកដ្ឋហារិជាតក ១ គាមណិជាតក ១ មឃទេវជាតក ១ ជនណាមិនរក្សាជនដទៃ ក្នុងសុខវិហារិជាតក ១ ត្រូវជា ១០ ជាតក ។

# អដ្ឋកថា

## សុខវិហារិជាតក

[ ១០ ] ព្រះសាស្តា កាលទ្រង់អាស្រ័យអនុបិយនគរ គង់នៅក្នុងអនុបិយម្ពវ័ន ទ្រង់ប្រារព្ធព្រះភទ្ទិយត្ថេរ ដែលមានប្រក្រតីនៅជាសុខ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យញ្ច អញ្ញេ ច រក្ខន្តិ** ដូច្នេះជាដើម ។

ព្រះភទ្ទិយត្ថេរ ជាអ្នកមានប្រក្រតីនៅជាសុខ មានព្រះឧបាលីជាគម្រប់ ៧ បួសក្នុងសមាគមក្សត្រ ៦ អង្គ បណ្តាព្រះថេរៈទាំងនោះ ព្រះភទ្ទិយត្ថេរ ព្រះកិម្ពិលត្ថេរ ព្រះភគ្គុត្ថេរ ព្រះឧបាលិត្ថេរ សម្រេចអរហត្ត ព្រះអានន្ទត្ថេរ ជាព្រះសោតាបន្ន ព្រះអនុរុទ្ធត្ថេរមានទិព្វចក្ខុ ព្រះទេវទត្តជាអ្នកបានឈាន ។ រឿងក្សត្រទាំង ៦ អង្គ មានច្បាស់ក្នុងខណ្ឌហាលជាតក ។ ព្រះភទ្ទិយត្ថេរ រក្សាគ្រប់គ្រងខ្លួន កាលនៅជាព្រះរាជា ទ្រង់ឃើញភ័យកើតឡើងដល់ព្រះអង្គ ដែលគេរក្សា ដោយការរក្សាច្រើន ដូចទេវតារៀបចំការរក្សា និងភ័យដែលកើតដល់ព្រះអង្គ ទ្រង់បម្រះទៅមកលើមហាបន្ទំ ក្នុងប្រាសាទជាន់លើ ឥឡូវនេះ សម្រេចអរហត្តហើយ នៅក្នុងទីណាមួយ មានព្រៃជាដើម ក៏ពិចារណាឃើញភាពដែលព្រះអង្គជាអ្នកប្រាសចាកភ័យ ទើបបន្លឺឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ភិក្ខុទាំងឡាយបានស្តាប់ដូច្នោះ ទើបក្រាបទូលដល់ព្រះសាស្តាថា ព្រះភទ្ទិយត្ថេរព្យាករអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភទ្ទិយៈមានប្រក្រតីនៅជាសុខ ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុនមានប្រក្រតីនៅជាសុខដូចគ្នា ទើបភិក្ខុទាំងឡាយ ទូលអារាធនាព្រះសាស្តា

ដើម្បីឲ្យទ្រង់ប្រកាសរឿងនោះ ។ ទើបព្រះសាស្តាទ្រង់ធ្វើហេតុ ដែលអន្តរកពបិទបាំង ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វ ជាព្រាហ្មណ៍មហាសាល កើតក្នុងត្រកូលខ្ពស់ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងការចេញបួស ទើបលះកាមទាំងឡាយ ចូលព្រៃហិមពាន្ត បួសជាឥសី ធ្វើសមាបត្តិ ៨ ឲ្យកើតឡើង សូម្បីបរិវាររបស់ព្រះពោធិសត្វនោះ បានជាបរិវារធំ មានតាបស ៥០០ ។ ក្នុងរដូវភ្លៀង ព្រះពោធិសត្វចេញអំពីព្រៃហិមពាន្ត ចោមរោមដោយពួកតាបសចារិកទៅក្នុងគាម និងនិគមជាដើម ដល់ក្រុងពារាណសី ទ្រង់អាស្រ័យព្រះរាជា សម្រេចការនៅក្នុងព្រះរាជឧទ្យាន ទ្រង់នៅក្នុងព្រះរាជឧទ្យាននោះអស់ ៤ ខែ ក្នុងរដូវភ្លៀង ហើយទូលលាព្រះរាជា ។ លំដាប់នោះ ព្រះរាជាទ្រង់អង្វរព្រះពោធិសត្វនោះថា បពិត្រលោកម្ចាស់ៗ ក៏ចាស់ជរាហើយ ប្រយោជន៍អ្វីដោយការនៅក្នុងព្រៃហិមពាន្ត សូមលោកម្ចាស់បញ្ជូនអន្តេវាសិកទៅកាន់ព្រៃហិមពាន្ត ហើយនៅក្នុងទីនេះចុះ ។ ព្រះពោធិសត្វប្រគល់តាបស ៥០០ រូប ដល់អន្តេវាសិកធំ ហើយបញ្ជូនតាបសទាំងនោះទៅដោយពាក្យថា ចូរអ្នកទៅក្នុងព្រៃហិមពាន្តជាមួយតាបសទាំងនេះ ឯខ្ញុំនៅក្នុងទីនេះឯង ហើយសម្រេចការនៅក្នុងព្រះរាជឧទ្យាននោះឯង ។ អន្តេវាសិកដែលជាសិស្សច្បងរបស់ព្រះពោធិសត្វនោះ ជារាជបព្វជិត លះរាជសម្បត្តិធំចេញបួស ធ្វើកសិណ-បរិកម្មបានសមាបត្តិ ៨ ប្រធានអន្តេវាសិកនោះ នៅក្នុងព្រៃហិមពាន្តជាមួយតាបសទាំងឡាយ ថ្ងៃមួយ មានបំណងនឹងឃើញអាចារ្យ ទើបហៅតាបស

ទាំងនោះមកហើយ ពោលថា អ្នកទាំងឡាយ កុំបីរំខាន ចូរនៅក្នុងទីនេះឯង ខ្ញុំឃើញអាចារ្យហើយ នឹងត្រឡប់មក ហើយទៅកាន់សម្នាក់របស់អាចារ្យ ថ្វាយបង្គំហើយ ធ្វើបដិសណ្ឋារៈ ក្រាលនូវកន្ទេលផែងមួយផ្ទាំង ដេកក្នុងសម្នាក់របស់អាចារ្យនោះឯង ។ សម័យនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា នឹងសួរសុខទុក្ខតាបស ដូច្នេះហើយ ទើបយាងទៅកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំហើយ គង់ក្នុងចំណែកម្ខាង ។ តាបសដែលជាអន្តេវាសិក ឃើញព្រះរាជាក៏មិន ក្រោកឡើង ដេកបន្លឺឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ព្រះរាជាអាក់អន់ព្រះហឫទ័យថា តាបសនេះឃើញអញ ក៏មិនក្រោកឡើង ទើបត្រាស់នឹងព្រះពោធិសត្វថា បពិត្រលោកម្ចាស់ តាបសនេះ ប្រហែលជាឆ្អន់តាមត្រូវការ ទើបដេកយ៉ាងសប្បាយ បន្លឺឧទាន ព្រះពោធិសត្វពោលថា មហាបពិត្រ តាបសនេះ ពីមុន ក៏ជាព្រះរាជាដូចទ្រង់ដែរ តាបសនេះគិតថា ពីមុន កាលអញនៅជាគ្រហស្ថ សោយសិរីរាជសម្បត្តិ ដែលមនុស្សជាច្រើន មានដៃកាន់អាវុធយាមការពារ ក៏មិនបាននូវសុខបែបនេះ ទើបប្រារព្ធសុខក្នុងការបួស និងសុខក្នុងឈានរបស់ខ្លួន ទើបដេកបន្លឺឧទាននេះ កាលពោលយ៉ាងនេះហើយ ទើបសម្តែងធម្មកថាដល់ព្រះរាជា ដោយគាថានេះថា

ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជន
ដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្តីអាឡោះអាល័យ
ក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យញ្ច អញ្ញេ ន រក្ខន្តិ** សេចក្តីថា បុគ្គល

ដទៃជាច្រើន មិនរក្សាបុគ្គលណា ។ បទថា **យោ ច អញ្ញេ ន រក្ខតិ** សេចក្តីថា បុគ្គលណាក៏មិនរក្សាអ្នកដទៃជាច្រើន ដោយគិតថា អាត្មាអញម្នាក់ឯងគ្រងរាជសម្បត្តិ ។ បទថា **ស វេ រាជសុខំ សេតិ** សេចក្តីថា មហាបពិត្រ បុគ្គលនោះតែម្នាក់ឯង មិនមានសម្លាញ់ ស្ងាត់ស្ងៀម ហើយជាអ្នកដល់ព្រមដោយសេចក្តីសុខផ្លូវកាយ និងផ្លូវចិត្ត រមែងដេកជាសុខ ។ ពាក្យថា ដេកជាសុខនេះ ជាមាតិកាទេសនាប៉ុណ្ណោះ រមែងដេកជាសុខតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន បុគ្គលបែបនេះ ដើរ ឈរ អង្គុយ ដេក ក៏ជាសុខ គឺបានទទួលសុខគ្រប់ឥរិយាបថនោះឯង ។ បទថា **កាមេសុ អនបេក្ខវា** សេចក្តីថា មហាបពិត្រ បុគ្គលបែបនេះ វៀរចាកការសម្លឹងក្នុងវត្ថុកាម និងកិលេសកាម គឺប្រាសចាកឆន្ទរាគៈ មិនមានតណ្ហា រមែងនៅជាសុខគ្រប់ឥរិយាបថ ។

ព្រះរាជាទ្រង់បានស្តាប់ធម្មទេសនាហើយ មានព្រះហឫទ័យត្រេកអរ ថ្វាយបង្គំហើយ យាងទៅកាន់ព្រះរាជនិវេសន៍នោះឯង ឯអន្តេវាសិក ក៏ថ្វាយបង្គំអាចារ្យ ហើយទៅកាន់ព្រៃហិមពាន្តដូចគ្នា ចំណែកព្រះពោធិសត្វនៅទីនោះឯង មានឈានមិនសាបសូន្យ ធ្វើកាលកិរិយាហើយ កើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ ២ រឿងបន្តអនុសន្ធិគ្នាហើយ ទ្រង់ប្រជុំជាតកថា អន្តេវាសិកក្នុងកាលនោះ បានជាភទ្ទិយត្ថេរ ក្នុងកាលឥឡូវនេះ ឯអាចារ្យរបស់គណៈ គឺតថាគតនេះឯង ៕

**អដ្ឋកថាសុខវិហារិជាតក ចប់**

**អបណ្ណកវគ្គទី ១ ចប់**

# សុត្តន្តបិដក

## សីលវគ្គ

## លក្ខណជាតក

[ ១១ ] ( ម្រឹគពោធិសត្វពោលថា ) សេចក្តីចម្រើន តែងមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្តបដិសន្ថារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈកំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ ( កំពុងដើរមក ) ឬទេ ។

លក្ខណជាតកទី ១ ចប់

# អដ្ឋកថា
# សីលវគ្គ

## លក្ខណមិគជាតក

[ ១១ ] ព្រះសាស្តា កាលចូលទៅអាស្រ័យនគររាជគ្រឹះ គង់នៅក្នុងវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ហោតិ សីលវតំ អត្ថោ** ដូច្នេះជាដើម ។

រឿងព្រះទេវទត្ត រហូតដល់ការប្រកបកម្ម គឺកាសម្លាប់យ៉ាងធ្ងន់ នឹងមានច្បាស់ក្នុងកណ្ឌហាលជាតក រឿងការលែងជីវិតធនបាលកៈ នឹងមានច្បាស់ក្នុងចូឡហង្សជាតក ការត្រូវផែនដីស្រូប នឹងមានជាក់ច្បាស់ក្នុងសមុទ្ទពាណិជ-ជាតក ក្នុងទ្វាទសកនិបាត ។

សម័យមួយ ទេវទត្តទូលសូមវត្ថុ ៥ ប្រការ កាលមិនបាន ទើបបំបែកសង្ឃ នាំភិក្ខុ ៥០០ ទៅត្រង់គយាសីសប្រទេស កាលនោះ ញាណរបស់ភិក្ខុទាំងនោះចាស់ក្លាហើយ ព្រះសាស្តាទ្រង់ជ្រាបដូច្នោះ ទើបត្រាស់ហៅអគ្គ-សាវកទាំង ២ មកថា ម្នាលសារីបុត្រ និងមោគ្គល្លាន ភិក្ខុទាំង ៥០០ ដែលជានិស្សិតរបស់អ្នកទាំងឡាយគាប់ចិត្តក្នុងលទ្ធិរបស់ទេវទត្តទៅជាមួយទេវទត្តហើយ ឥឡូវនេះ ញាណរបស់ភិក្ខុទាំងនោះចាស់ក្លាហើយ ចូរពួកអ្នកទៅទីនោះ មួយអន្លើដោយភិក្ខុច្រើន សម្តែងធម៌ដល់ភិក្ខុទាំងនោះ ឲ្យភិក្ខុទាំងនោះត្រាស់ដឹងមគ្គផល ហើយចូរនាំមក ទើបអគ្គសាវកទាំង ២ នោះ ទៅគយា-

សីសប្រទេសនោះឯង សម្តែងធម៌ដល់ភិក្ខុទាំងនោះ ឲ្យត្រាស់ដឹងធម៌ដោយមគ្គផលហើយ ស្អែកឡើង កាលអរុណរះ ទើបនាំភិក្ខុទាំងនោះ មកកាន់វេឡុវ័នវិហារនោះឯង ក្នុងកាលដែលព្រះសារីបុត្តត្ថេរមកថ្វាយបង្គំព្រះសាស្តាហើយឈរ ភិក្ខុទាំងឡាយនាំគ្នាសរសើរព្រះថេរៈ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះធម្មសេនាបតី បងប្រុសធំរបស់ខ្ញុំព្រះអង្គទាំងឡាយ ដែលភិក្ខុ ៥០០ ចោមរោមមកល្អពន់ពេក ឯទេវទត្ត មានបរិវារវិនាសហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមានពួកញាតិចោមរោមមករមែងស្អាត តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ស្អាតដូចគ្នា ឯទេវទត្តសាបសូន្យចាកពួកញាតិ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុន ក៏វិនាសហើយដូចគ្នា ភិក្ខុទាំងឡាយអារាធនាព្រះសាស្តាដើម្បីឲ្យទ្រង់ប្រកាសរឿងនោះឲ្យជាក់ច្បាស់ ព្រះសាស្តាទ្រង់បានធ្វើហេតុដែលអន្តរភពបិទបាំងឲ្យប្រាកដដូចតទៅ

ក្នុងអតីតកាល ព្រះបាទមគធៈ សោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ក្នុងដែនមគធៈ ក្នុងកាលនោះ ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងកំណើតម្រឹគ ចម្រើនវ័យ មានម្រឹគ ១០០០ ជាបរិវារ នៅក្នុងព្រៃ ។ ព្រះពោធិសត្វមានកូន ២ គឺលក្ខណៈ ១ និងកាឡៈ ១ ។ ក្នុងកាលខ្លួនចាស់ ព្រះពោធិសត្វពោលថា នែកូនទាំង ២ ឥឡូវនេះ ឪពុកចាស់ហើយ បាទាំង ២ ចូរគ្រប់គ្រងហ្វូងម្រឹគនេះ រួចប្រគល់ម្រឹគប្រាំរយៗ ឲ្យ ។ តាំងអំពីនោះ ម្រឹគទាំង ២ គ្រប់គ្រងហ្វូងម្រឹគ សម័យនោះ ក្នុងដែនមគធៈ ស្រែទាំងឡាយពេញដោយសន្ទូង

អន្តរាយរមែងកើតដល់ម្រឹគទាំងឡាយក្នុងព្រៃ ព្រោះមនុស្សត្រូវការសម្លាប់ម្រឹគដែលមកស៊ីស្រូវ ទើបជីករណ្តៅ ធ្វើអន្ទាក់ថ្មយន្ត ដាក់អន្ទាក់ មានរម្ងកជាដើម ម្រឹគជាច្រើនដល់នូវសេចក្តីវិនាស ព្រះពោធិសត្វដឹងកាលដែលស្រែពេញដោយសន្ទូង ទើបហៅកូនទាំង ២ មកប្រាប់ថា បាទាំង ២ សម័យនេះជាសម័យដែលសម្បូរដោយសន្ទូង ម្រឹគជាច្រើនដល់នូវសេចក្តីវិនាស អញចាស់ហើយ នឹងសម្ងំក្នុងទីមួយកន្លែង ដោយឧបាយណាមួយ ចូរពួកបានាំពួកម្រឹគចូលទៅកាន់ជើងភ្នំក្នុងព្រៃ ក្នុងកាលដែលគេដកសន្ទូងហើយ សឹមមក ៗ កូនទាំង ២ ទទួលពាក្យរបស់ឪពុកហើយ នាំបរិវារចេញទៅ ។ ពួកមនុស្សទាំងឡាយ ដឹងផ្លូវដែលពួកម្រឹគទាំងនោះទៅ និងមកថា ពេលនេះពួកម្រឹគកំពុងចុះពីភ្នំ ពេលនេះ កំពុងឡើងភ្នំ មនុស្សទាំងនោះនាំគ្នាអង្គុយក្នុងទីកំបាំងក្នុងទីនោះ សម្លាប់ម្រឹគជាច្រើនឲ្យស្លាប់ ។ ចំណែកកាឡម្រឹគព្រោះភាពដែលខ្លួនល្ងង់ ទើបមិនដឹងថា ពេលឈ្មោះនេះគួរទៅ ដូច្នេះហើយទើបនាំក្រុមម្រឹគទៅតាមផ្លូវទ្វារស្រុក ទាំងក្នុងពេលព្រឹក និងក្នុងពេលល្ងាចទាំងក្នុងពេលព្រលប់ និងពេលទៀបភ្លឺ ពួកមនុស្សឈរ និងអង្គុយតាមប្រក្រតីនោះឯង ក្នុងទីនោះៗ ញ៉ាំងម្រឹគជាច្រើនឲ្យដល់សេចក្តីវិនាស កាឡម្រឹគនោះ ឲ្យម្រឹគជាច្រើនដល់នូវសេចក្តីវិនាស ព្រោះភាពដែលខ្លួនល្ងង់ខ្លៅយ៉ាងនេះ ទើបចូលកាន់ព្រៃដោយម្រឹគ មានប្រមាណតិចតួចប៉ុណ្ណោះ ។

ឯលក្ខណម្រឹគជាបណ្ឌិត មានបញ្ញា ឈ្លាសក្នុងឧបាយ ដឹងថា ពេលនេះ គួរទៅ ពេលនេះ មិនគួរទៅ លក្ខណម្រឹគនោះ មិនទៅតាមទ្វារស្រុក

មិនទៅក្នុងពេលថ្ងៃខ្លះ មិនទៅក្នុងពេលព្រលប់ខ្លះ ពេលទៀបភ្លឺខ្លះ នាំពួកម្រឹគទៅកណ្តាលយប់ប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលក្ខណម្រឹគ មិនធ្វើម្រឹគសូម្បីតែមួយឲ្យវិនាស ចូលព្រៃហើយ ម្រឹគទាំងនោះ នៅក្នុងព្រៃនោះ ៤ ខែ កាលពួកមនុស្សប្រមូលស្រូវហើយ ទើបនាំគ្នាចុះអំពីភ្នំ ។ ម្រឹគឈ្មោះកាឡៈទៅខាងក្រោយ ក៏ធ្វើម្រឹគទាំងអស់ឲ្យដល់នូវសេចក្តីវិនាស ដោយន័យមុននោះឯង មកម្នាក់ឯងប៉ុណ្ណោះ ឯលក្ខណម្រឹគ មិនធ្វើម្រឹគសូម្បីតែមួយឲ្យវិនាស មានម្រឹគ ៥០០ ចោមរោម មកកាន់សម្នាក់មេបា ឯព្រះពោធិសត្វឃើញកូនទាំង ២ មក កាលប្រឹក្សានឹងម្រឹគញី ទើបពោលគាថាថា

*សេចក្តីចម្រើន តែងមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្តបដិសន្ថារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ ( កំពុងដើរមក ) ឬទេ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **សីលវតំ** សេចក្តីថា ឈ្មោះថា អ្នកមានសីល គឺសម្បូរដោយអាចារ ព្រោះមានសេចក្តីសុខជាប្រក្រតី ។ បទថា **អត្ថោ** បានដល់ សេចក្តីចម្រើន ។ បទថា **បដិសន្ថារវុត្តិនំ** សេចក្តីថា ឈ្មោះថា ជាអ្នកមានប្រក្រតីប្រព្រឹត្តក្នុងបដិសណ្ឋារៈ ព្រោះមានប្រក្រតីប្រព្រឹត្តក្នុងធម្មប្បដិសណ្ឋារៈ និងអាមិសប្បដិសណ្ឋារៈនោះ ។ ដល់ជនទាំងនោះ ដែលមានប្រក្រតីប្រព្រឹត្តក្នុងបដិសណ្ឋារៈ ក្នុងទីនេះ គប្បីជ្រាបធម្មប្បដិសណ្ឋារៈ ដូចជាការហាមធ្វើបាប ការទូន្មាន និងអនុសាសន៍ជាដើម គប្បី

ជ្រាបអាមិសប្បដិសណ្ឋារៈ ដូចជាការឲ្យបានទីរកស៊ី ការរក្សាពេលមានជំងឺ និងការរក្សាដែលប្រកបដោយធម៌ លោកអធិប្បាយថា ឈ្មោះថា ការចម្រើន រមែងមានដល់ជនដែលជាបណ្ឌិត ជាអ្នកដល់ព្រមដោយអាចារ ដែលតាំងនៅក្នុងបដិសណ្ឋារៈទាំង ២ នេះ ។ ឥឡូវនេះ ព្រះពោធិសត្វ កាលហៅមេរបស់ម្រឹគ ដើម្បីបង្ហាញសេចក្តីចម្រើននោះ ទើបពោលពាក្យជាដើមថា ចូរនាងមើលម្រឹគឈ្មោះលក្ខណៈ ដូច្នេះ ក្នុងពាក្យដែលពោលនោះ មានសេចក្តីសង្ខេបដូច្នេះ

ចូរនាងមើលកូនរបស់ខ្លួន ដែលសម្បូរដោយអាចារ និងបដិសណ្ឋារៈ មិនធ្វើម្រឹគ ១ ឲ្យវិនាស ដែលពួកញាតិធ្វើទុកខាងមុខ គឺហែហមមក តែចូរនាងមើលម្រឹគឈ្មោះកាឡៈនេះ ជាអ្នកមានបញ្ញាថោកថយ វៀរចាកសម្បទា គឺអាចារ និងបដិសណ្ឋារៈ ដែលវិនាសចាកញាតិទាំងឡាយ មិនសល់ញាតិសូម្បីតែ ១ មកម្នាក់ឯង ។

ព្រះពោធិសត្វសរសើរកូនយ៉ាងនេះហើយ តាំងនៅដរាបដល់អស់អាយុ បានទៅតាមយថាកម្មហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមានពួកញាតិចោមរោម រមែងស្អាតក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ទោះក្នុងកាលមុន ក៏រុងរឿងដូចគ្នា ទេវទត្តវិនាសចាកពួកគណៈ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏វិនាសហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ ២ រឿង បន្តអនុសន្ធិជាប់គ្នា ហើយទ្រង់ប្រជុំ

ជាតកថា ម្រឹគកាឡៈក្នុងកាលនោះ បានជាទេវទត្ត ក្នុងកាលឥឡូវនេះ បរិស័ទរបស់ម្រឹគកាឡៈ ក្នុងកាលនោះ បានជាបរិស័ទរបស់ទេវទត្ត ម្រឹគឈ្មោះលក្ខណៈ ក្នុងកាលនោះ បានជាសារីបុត្ត បរិស័ទរបស់ម្រឹគលក្ខណៈ ក្នុងកាលនោះ បានជាពុទ្ធបរិស័ទ មេម្រឹគក្នុងកាលនោះ បានជារាហុលមាតា ឯបាម្រឹគក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា លក្ខណមិគជាតក ចប់**

# សុត្តន្តបិដក

## និគ្រោធមិគជាតក

[ ១២ ] ( មេម្រឹគពោលថា ) បុគ្គលគប្បីសេពនូវម្រឹគឈ្មោះនិគ្រោធៈតែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ កាលស្លាប់ក្នុងសម្នាក់នៃម្រឹគឈ្មោះនិគ្រោធៈ ជាការប្រសើរ ការរស់នៅក្នុងសម្នាក់នៃម្រឹគឈ្មោះសាខៈ ពុំប្រសើរឡើយ ។

**និគ្រោធមិគជាតកទី ២ ចប់**

# អដ្ឋកថា

## និគ្រោធមិគជាតក

[ ១២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីកុមារកស្សបមាតា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **និគ្រោធមេវ សេវេយ្យ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនីនោះ បានជាធីតារបស់សេដ្ឋី មានទ្រព្យច្រើន ក្នុងនគររាជគ្រឹះ មានកុសលមូលក្រាស់ មានសង្ខារញ៉ាំញីហើយ ជាបច្ឆិមភវិកសត្វ ឧបនិស្ស័យនៃអរហត្តភ្លឺរុងរឿងក្នុងហទយៈរបស់នាង ដូចប្រទីបឆេះនៅក្នុងឆ្នាំង ដូច្នោះ ។ គ្រានោះ តាំងអំពីកាលដែលដឹងក្តីហើយ ធីតារបស់សេដ្ឋីនោះ មិនត្រេកអរក្នុងផ្ទះ មានបំណងនឹងបួស ទើបពោលនឹងមាតាបិតាថា បពិត្រលោកឪពុកអ្នកម្តាយ ចិត្តរបស់ខ្ញុំ មិនត្រេកអរក្នុងឃរាវាស ខ្ញុំមានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ សូមលោកទាំងឡាយឲ្យខ្ញុំបួសចុះ ។ មាតាបិតាពោលថា នាងនិយាយអ្វី ត្រកូលយើងមានទ្រព្យច្រើន នាងក៏ជាកូនស្រីតែម្នាក់របស់យើងទាំងឡាយ កូនមិនគួរបួសទេ ។ ទោះជានាងអង្វររឿយៗ ក៏មិនបានចេញបួសអំពីសម្នាក់មាតាបិតា ទើបគិតថា ណ្ហើយចុះ អញទៅកាន់ត្រកូលស្វាមី ញ៉ាំងប្តីឲ្យត្រេកអរហើយ នឹងបួស ។ នាងចម្រើនវ័យហើយ បានទៅកាន់ត្រកូលប្តី ជាអ្នកមានសីល មានកល្យាណធម៌ គ្រប់គ្រងផ្ទះ ។ លំដាប់នោះ ព្រោះអាស្រ័យការនៅរួម នាងក៏មានគភ៌ ។ នាងមិនដឹងថា មានគភ៌ ។ គ្រានោះ ជនទាំង-ឡាយឃោសនាបុណ្យនក្ខត្តឫក្សក្នុងព្រះនគរ អ្នកនគរទាំងមូល នាំគ្នាលេង

នក្ខត្តឫក្ស ។ ព្រះនគរមានការប្រដាប់តាក់តែងដូចទេវនគរ គ្រាលេងនក្ខត្តឫក្ស សូម្បីគគ្រឹកគគ្រេងដល់ម៉្លោះប្រព្រឹត្តទៅ នាងក៏មិនលាបស្រឡាបរាងកាយរបស់ខ្លួន មិនពាក់គ្រឿងអលង្ការ ត្រាច់ទៅដោយភេទធម្មតានោះឯង ។ លំដាប់នោះ ប្ដីនាងពោលថា នាងដ៏ចម្រើន នគរទាំងមូល អាស្រ័យនក្ខត្តឫក្ស តែនាងមិនបដិបត្តិរាងកាយ មិនតែងខ្លួន ព្រោះហេតុអ្វី នាងក៏ពោលថា បពិត្រអយ្យបុត្រ រាងកាយពេញដោយរបស់មិនស្អាត ៣២ ប្រការ ប្រយោជន៍អ្វីដោយរាងកាយនេះ ដែលប្រដាប់ហើយ ព្រោះកាយនេះ ទេវតាព្រហ្ម មិនបានជប់មក មិនមែនកើតអំពីមាស កែវមុណី ចន្ទន៍លឿង មិនមែនកើតអំពីផ្កាបុណ្ឌរិក ផ្កាកុមុទ និងផ្កាឧប្បលខៀវ តែពេញទៅដោយលាមកមិនស្អាត មិនមែនពេញដោយអមតឱសថ ដោយពិត កើតក្នុងរបស់មិនស្អាត មានឪពុកម្ដាយជាដែនកើត មានការដុសលាង និងគក់ប្រហាប់ជានិច្ច មានការបែកធ្លាយ និងការខ្ចាត់ខ្ចាយទៅជាធម្មតា ជាព្រៃខ្មោច ដែលតណ្ហាប្រកាន់មាំ ជាហេតុនៃសោក ជាទីតាំងនៃការខ្សឹកខ្សួល ជាលំនៅនៃរោគទាំងឡាយ ជាទីទទួលគ្រឿងកម្មករណ៍ ជារបស់ស្អុយក្នុង ហូរចេញជានិច្ច ជាលំនៅរបស់ដង្កូវច្រើនត្រកូល នឹងទៅកាន់ឈាបនដ្ឋាន មានការស្លាប់ជាទីបំផុត នឹងប្រែប្រួលទៅក្នុងចក្ខុនៃសត្វលោកទាំងពួង ។

កាយ ប្រកបដោយឆ្អឹង និងសរសៃទាំងឡាយ គ្របដណ្ដប់ដោយ
ស្បែក និងសាច់ បិទបាំងដោយសម្បុរថ្ងៃ មិនប្រាកដតាមពិត ។
កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង ដោយដុំ

ថ្លើមផង ដោយក្រពះនោមផង ដោយពោះដូនផង ដោយសួតផង ដោយទាចផង ដោយក្រពះបាយផង ដោយទឹកសម្បោរផង ដោយទឹកមាត់ផង ដោយញើសផង ដោយខ្លាញ់ខាប់ផង ដោយឈាមផង ដោយទឹករម្អិលផង ដោយទឹកប្រមាត់ផង ដោយខ្លាញ់រាវផង ។

មួយទៀត វត្ថុមិនស្អាត រមែងហូរចេញតាមរន្ធទាំង ៩ របស់កាយនោះសព្វកាល គឺព្រៀកភ្នែក ហូរចេញអំពីភ្នែក មូលត្រចៀកហូរចេញអំពីត្រចៀក ទឹកសម្បោរហូរចេញអំពីច្រមុះ ជួនណាចេញតាមមាត់ ប្រមាត់ និងស្លេស្មក៏ខ្ជារចេញតាមមាត់ដែរ ញើសនិងក្អែលហូរចេញអំពីកាយ ។

មួយទៀត កាយនោះ មានក្បាលប្រហោង ពេញដោយខួរក្នុងក្បាល ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសម្គាល់កាយនោះថាល្អ ដូច្នេះ(១) ។

រាងកាយជារបស់ មានទោស រកទីបំផុតគ្មាន មានឧបមាដូចដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ ដូច្នេះ(២) ។

បើត្រឡប់ផ្នែកខាងក្នុងរបស់រាងកាយនេះ ឲ្យមកខាងក្រៅ នឹងត្រូវកាន់ដំបងចាំដេញក្អែក និងឆ្កែដោយពិត ។

កាយមិនស្អាត មានក្លិនស្អុយ ពេញដោយសាកសព ប្រៀបដូច

---

១- បិ. ៥៤ ទំ. ៦៥ ។ ២- បិ. ៣៥ ទំ. ២៩៦ ។

បង្គន់ បុគ្គលមានចក្ខុ តិះដៀល តែបុគ្គលល្ងង់ខ្លៅ នាំគ្នាត្រេកអរហើយ ។

កាយនេះ ត្រូវស្បែកស្រស់បិទបាំងទុក មានទ្វារ ៩ ប្រៀបដូចមុខដំបៅ ជារបស់មិនស្អាត មានក្លិនស្អុយហូរចេញជុំទិស[១] ដូច្នេះ ។

កាលណាកាយនោះស្លាប់ទៅ ដេកនៅ ហើមប៉ោង មានពណ៌ខៀវ ត្រូវគេបោះចោលទៅក្នុងព្រៃស្មសានហើយ កាលណោះ ជនទាំងឡាយជាញាតិក៏លែងរមិល ស្វាន ចចក ក្អែ ដង្កូវ ជញ្ជ្រូងស៊ីកាយស្លាប់នោះ ចំណែកពួកសត្វដទៃ មានក្អែក ត្មាតជាដើម ក៏ចឹកស៊ីនូវកាយស្លាប់នោះដែរ ។

ភិក្ខុណា ក្នុងសាសនានេះ ជាអ្នកមានបញ្ញា បានស្តាប់នូវពុទ្ធវចនៈហើយ ភិក្ខុនោះ រមែងកំណត់ដឹងនូវកាយនោះ ព្រោះឃើញច្បាស់តាមពិត ។ សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់ទុំះ ក៏យ៉ាងនោះ សរីរៈស្លាប់ទុំះយ៉ាងណា សរីរៈរស់នេះ ក៏យ៉ាងនោះ ភិក្ខុគប្បីរំសាយនូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ[២] ដូច្នេះ ។

បពិត្រអយ្យបុត្រ ខ្ញុំប្រដាប់រាងកាយនេះធ្វើអ្វី ការប្រដាប់កាយនេះ រមែងដូចគ្នានឹងការធ្វើចិត្រកម្មខាងក្រៅធ្នាំង ដែលពេញដោយលាមក ។ សេដ្ឋីបុត្របានស្តាប់ពាក្យរបស់នាង ដូច្នោះ ទើបពោលថា នែនាង បើនាង

---

១- វិសុទ្ធិមគ្គ អសុភកម្មដ្ឋាននិទ្ទេស ។ ២- ខ. ៥៤ ទំ. ៦៦ ។

ឃើញទោសទាំងឡាយនៃរាងកាយយ៉ាងនេះ ហេតុអ្វីក៏មិនបួស ។ នាងពោលថា បពិត្រអយ្យបុត្រ បើខ្ញុំអាចបួសបាន នឹងបួសថ្ងៃនេះឯង សេដ្ឋីបុត្រពោលថា សាធុ ខ្ញុំនឹងឲ្យនាងបួស ហើយបំពេញមហាទាន ធ្វើមហាសក្ការៈ នាំទៅកាន់សម្នាក់របស់ភិក្ខុនីដោយបរិវារធំ ។ កាលឲ្យនាងបួស បានឲ្យបួសក្នុងសម្នាក់ភិក្ខុនីដែលជាគ្នីគ្នារបស់ទេវទត្ត ។ នាងបានបព្វជ្ជាហើយ មានតម្រិះពេញបរិបូណ៌ត្រេកអរហើយ ។ គ្រានោះ កាលគភ៌នាងចាស់ហើយ ភិក្ខុនីទាំងឡាយឃើញភាពដែលឥន្ទ្រិយទាំងឡាយ ប្រែទៅជាដទៃ ខ្នងដៃ ខ្នងជើងហើម និងមានពោះធំ ទើបសួរនាងថា អ្នកនាងម្ចាស់ នាងប្រាកដហាក់ដូចមានគភ៌ តើមែន ឬមិនមែន ភិក្ខុនីនោះពោលថា អ្នកនាងម្ចាស់ទាំងឡាយ ខ្ញុំក៏មិនដឹងថា ហេតុឈ្មោះនេះ តែសីលរបស់ខ្ញុំនៅបរិបូណ៌ ។ លំដាប់នោះ ទើបភិក្ខុនីទាំងនោះ នាំភិក្ខុនីនោះទៅកាន់សម្នាក់របស់ទេវទត្ត សួរទេវទត្តថា បពិត្រលោកម្ចាស់ កុលធីតានេះ ញ៉ាំងស្វាមីឲ្យប្រោសប្រាណបានដោយលំបាក ទើបបាននូវបព្វជ្ជា ឥឡូវនេះ គភ៌របស់នាងប្រាកដ យើងមិនដឹងថា កុលធីតានេះ តាំងគភ៌ក្នុងកាលជាគ្រហស្ថ ឬក្នុងកាលបួសហើយ ឥឡូវនេះ យើងទាំងឡាយនឹងធ្វើដូចម្ដេច ។ ព្រោះភាពដែលខ្លួនមិនដឹង និងព្រោះខន្តីមេត្តា និងករុណាមិនមាន ទើបទេវទត្តគិតយ៉ាងនេះថា ការនិន្ទានឹងកើតដល់អញថា ភិក្ខុនីដែលនៅក្នុងចំណែករបស់ទេវទត្តមានគភ៌ តែទេវទត្តបែរជាព្រងើយកន្តើយ អញនឹងឲ្យភិក្ខុនីនេះសឹក ទើបគួរ ។ ទេវទត្តនោះ មិនពិចារណា ស្ទុះចេញទៅ ដូចដុំប្រមៀល ពោលថា ចូរពួកនាងឲ្យភិក្ខុនីនេះសឹក ។

ភិក្ខុនីនោះស្តាប់ពាក្យរបស់ទេវទត្តហើយ ក្រោកឡើងថ្វាយបង្គំ ហើយទៅកាន់សម្នាក់ ។ លំដាប់នោះ ភិក្ខុនីនោះពោលនឹងភិក្ខុនីទាំងឡាយថា អ្នកនាងម្ចាស់ទាំងឡាយ ទេវទត្ត មិនមែនជាព្រះពុទ្ធ ការបួសរបស់ខ្ញុំ ក្នុងសម្នាក់ទេវទត្តនោះក៏មិនមែន បព្វជ្ជារបស់ខ្ញុំ ក្នុងសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលក្នុងលោក ម្យ៉ាងទៀត បព្វជ្ជានោះ ខ្ញុំបានដោយលំបាក អ្នកនាងម្ចាស់ទាំងឡាយ កុំធ្វើផ្នួសនោះឲ្យអន្តរធានទៅឡើយ មកអ្នកនាងម្ចាស់ទាំងឡាយ ពួកយើងទៅកាន់វត្តជេតពន គាល់ព្រះសាស្តា ។ ទើបភិក្ខុនីទាំងឡាយនាំភិក្ខុនីនោះទៅអំពីក្រុងរាជគ្រឹះ អស់ចម្ងាយផ្លូវ ៤៥ យោជន៍ ដល់វត្តជេតពនមហាវិហារដោយលំដាប់ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ភិក្ខុនីនេះតាំងគភ៌ក្នុងកាលដែលជាគ្រហស្ថដោយពិត បើដូច្នោះ ពួកតិរ្ថិយនឹងបានឱកាសថា ព្រះសមណគោតមទទួលយកភិក្ខុនី ដែលទេវទត្តបោះបង់ចោលហើយ ត្រាច់ទៅ ព្រោះហេតុនោះដើម្បីកាត់នូវពាក្យនេះ គួរវិនិច្ឆ័យអធិករណ៍នេះក្នុងកណ្តាលបរិស័ទ ដែលមានព្រះរាជា ។ ស្អែកឡើង ទើបឲ្យយាងព្រះបាទកោសល អញ្ជើញអនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា និងត្រកូលធំៗដទៃៗ ដែលមានឈ្មោះបោះសំឡេង ក្នុងវេលាល្ងាច កាលបរិស័ទទាំង ៤ ប្រជុំគ្នាហើយ ទើបត្រាស់ហៅព្រះឧបាលិត្ថេរមកថា ចូរអ្នកជម្រះកម្មរបស់ភិក្ខុនីនេះកណ្តាលបរិស័ទ ៤ ។ ព្រះថេរៈទទួលព្រះតម្រាស់ហើយ ទើបទៅ

កណ្តាលបរិស័ទ អង្គុយលើអាសនៈដែលគេរៀបចំដើម្បីខ្លួន ហើយឲ្យហៅនាងវិសាខាឧបាសិកា មកក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះរាជា ឲ្យទទួលអធិ-ករណ៍នេះថា ឧបាសិកា ចូរនាងទៅ ចូរដឹងថា ភិក្ខុនីនេះ បួសក្នុងខែនោះថ្ងៃនោះ ហើយចូរដឹងថា នាងមានគភ៌នេះមុន ឬក្រោយបួស មហាឧបាសិកាទទួលពាក្យហើយ ទើបឲ្យបាំងរាំងនន ពិនិត្យមើលត្រង់ទីបំផុតដៃ ជើង ផ្ចិត និងពោះរបស់ភិក្ខុនីខាងក្នុងរាំងនន រាប់ខែ និងថ្ងៃ ដឹងថា នាងបានតាំងគភ៌ក្នុងកាលជាគ្រហស្ថដោយពិត ទើបទៅកាន់សម្នាក់របស់ព្រះថេរៈ ហើយប្រាប់សេចក្តីនោះ ។ ព្រះថេរៈបានធ្វើភិក្ខុនីនោះឲ្យជាអ្នកបរិសុទ្ធក្នុងកណ្តាលបរិស័ទ ៤ ។ ភិក្ខុនីនោះជាអ្នកបរិសុទ្ធហើយ ថ្វាយបង្គំភិក្ខុសង្ឃ និងថ្វាយបង្គំព្រះសាស្តា ហើយទៅកាន់សម្នាក់នោះឯង មួយអន្លើដោយភិក្ខុនីទាំងឡាយ ភិក្ខុនីនោះអាស្រ័យគភ៌ចាស់ហើយ បានប្រសូតបុត្រ មានអានុភាពច្រើន ដែលតាំងសេចក្តីប្រាថ្នាទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាយាងទៅក្បែរៗ សម្នាក់របស់ភិក្ខុនី បានឮសំឡេងទារក ទើបត្រាស់សួរអមាត្យទាំងឡាយ ។ អមាត្យទាំងឡាយដឹងហេតុនោះទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុនីនោះ ប្រសូតបុត្រហើយ នុ៎ះជាសំឡេងកូនភិក្ខុនីនោះឯង ។ ព្រះរាជាត្រាស់ថា កិច្ចប្រតិបត្តិទារក ជាគ្រឿងកង្វល់សម្រាប់ភិក្ខុនីទាំងឡាយ ពួកយើងនឹងប្រណិប័តន៍ទារកនោះ ។ ព្រះរាជាទ្រង់ប្រគល់ទារកនោះដល់ស្រីរបាំទាំងឡាយ ឲ្យធាត់ធំដោយការរក្សាដូចរាជកុមារ ។ ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ បានតាំងឈ្មោះថា កស្សបៈ ។ គ្រា

នោះ មនុស្សទាំងឡាយស្គាល់ថា កុមារកស្សបៈ ព្រោះចម្រើនដោយការបរិហារដូចរាជកុមារ ក្នុងកាលមានអាយុ ៧ ឆ្នាំ កុមារកស្សបៈនោះ បួសក្នុងសម្នាក់របស់ព្រះសាស្តា លុះមានអាយុគ្រប់ ២០ ក៏បានឧបសម្បទា ។ ពេលកន្លងទៅ លោកបានជាធម្មកថិកដ៏វិចិត្រ ក្នុងបណ្តាធម្មកថិកទាំងឡាយ លំដាប់នោះ ព្រះសាស្តាទ្រង់តាំងព្រះកុមារកស្សបៈនោះ ក្នុងតំណែងឯតទគ្គៈដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះសម្តីដ៏វិចិត្រ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកុមារកស្សបៈ ដូច្នេះ ។ ក្រោយមក កុមារកស្សបៈនោះសម្រេចអរហត្ត ដោយស្តាប់វម្មិកសូត្រ ។ សូម្បីភិក្ខុនីដែលជាម្តាយរបស់កុមារកស្សបៈនោះឃើញច្បាស់ហើយ សម្រេចមគ្គផល ។ កុមារកស្សបត្ថេរ ប្រាកដក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញវង់ អណ្តែតកណ្តាលអាកាស ដូច្នោះ ។

ថ្ងៃមួយ ព្រះតថាគតត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត ប្រទានឱវាទដល់ភិក្ខុទាំងឡាយ ហើយយាងចូលកាន់ព្រះគន្ធកុដិ ភិក្ខុទាំងឡាយទទួលព្រះឱវាទហើយ ឲ្យចំណែកនៃថ្ងៃអស់ទៅក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ រៀងៗខ្លួន ក្នុងវេលាល្ងាច ប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយពណ៌នាពុទ្ធគុណថា អាវុសោទាំងឡាយ ទេវទត្តធ្វើមនុស្សទាំង ២ គឺកុមារកស្សបៈនិងព្រះថេរីឲ្យវិនាស ព្រោះភាពដែលខ្លួនមិនដឹង និងព្រោះការមិនមានខន្តី និងមេត្តាជាដើម តែព្រះសម្មាសម្ពុទ្ធជាបច្ច័យដល់ជនទាំង ២ នោះ ព្រោះទ្រង់ជាធម្មរាជា ព្រោះទ្រង់ដល់ព្រមដោយខន្តី មេត្តា និងករុណា ។ ព្រះសាស្តា

យានមកកាន់រោងធម្មសភាដោយពុទ្ធលីលា គង់លើអាសនៈដែលគេក្រាល ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងព្រះគុណរបស់ព្រះអង្គប៉ុណ្ណោះ ហើយក្រាបទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ។ ព្រះមុនីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ និងជាទីពឹងដល់ជនទាំង ២ នេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងហើយដូចគ្នា ។ ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះសាស្តា ដើម្បីឲ្យរឿងនោះជាក់ច្បាស់ ព្រះសាស្តាទ្រង់ធ្វើហេតុដែលអន្តរកពបិទបាំង ឲ្យប្រាកដដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ឯព្រះពោធិសត្វ ទ្រង់បដិសន្ធិក្នុងកំណើតម្រឹគជាតិ ព្រះពោធិសត្វ កាលចេញចាកឧទររបស់មេ មានពណ៌ដូចមាស ភ្នែកទាំង ២ របស់ម្រឹគនោះ ដូចដុំកែវមណី ជើងទាំងគូមានពណ៌ដូចប្រាក់ មុខមានពណ៌ដូចគំនរសំពត់កម្ពលក្រហម ចុងជើងមុខ និងចុងជើងក្រោយ ដូចគូសវាសដោយទឹកល័ខ កន្ទុយដូចកន្ទុយចាមរី រាងកាយរបស់ម្រឹគនោះធំប្រមាណប៉ុនកូនសេះ ។ ម្រឹគនោះមានបរិវារ ៥០០ ដោយឈ្មោះមានឈ្មោះថា និគ្រោធមិគរាជ សម្រេចការនៅព្រៃ ។ ក្នុងទីមិនឆ្ងាយនៃស្តេចម្រឹគឈ្មោះនិគ្រោធនោះ មានម្រឹគដទៃឈ្មោះសាខៈ មានបរិវារ ៥០០ នៅអាស្រ័យ សូម្បីសាខម្រឹគ ក៏មានពណ៌ដូចមាស ។ សម័យនោះ ព្រះបាទពារាណសី ទ្រង់ខ្វល់ខ្វាយក្នុងការសម្លាប់

ម្រឹគ មិនមានសាច់មិនសោយ ទ្រង់ធ្វើពួកមនុស្សឲ្យខាតការងារ ញុំាងអ្នកនិគម និងអ្នកជនបទទាំងពួងឲ្យប្រជុំគ្នា ហើយយាងទៅសម្លាប់ម្រឹគរាល់ថ្ងៃ ។ ពួកមនុស្សគិតគ្នាថា ស្តេចនេះ ធ្វើឲ្យពួកយើងខាតនូវការងារ បើដូច្នោះ ពួកយើងដាំចំណីម្រឹគក្នុងព្រះរាជឧទ្យាន រៀបចំទឹកសម្រាប់ផឹក កៀងម្រឹគជាច្រើនឲ្យចូលទៅកាន់ព្រះរាជឧទ្យាន ហើយបិទទ្វារថ្វាយព្រះរាជា ។ ទើបមនុស្សទាំងនោះដាំបន្លែ ដែលជាចំណីរបស់ម្រឹគក្នុងព្រះរាជឧទ្យាន រៀបចំទឹកផឹកឲ្យដល់ព្រម ហើយធ្វើទ្វារ កាន់អន្ទាក់ កាន់អាវុធ ច្រើនប្រភេទ មានដំបងជាដើមចូលព្រៃ ស្វែងរកម្រឹគ គិតថា ពួកយើងនឹងចាប់ម្រឹគទាំងឡាយដែលនៅត្រង់កណ្តាល ទើបព័ទ្ធទីប្រមាណមួយយោជន៍ កាលបង្រួតចូលមកក៏ហ៊ុមព័ទ្ធម្រឹគនិគ្រោធ និងម្រឹគសាខៈទុកត្រង់កណ្តាល កាលឃើញម្រឹគនោះទើបយកដំបងវាយដើមឈើ គុម្ពឈើជាដើម និងវាយផែនដី កៀងម្រឹគចេញអំពីព្រៃ នាំគ្នាងារអាវុធទាំងឡាយ មានដាវ លំពែង និងធ្នូជាដើម ស្រែកដោយសំឡេងខ្លាំង កៀងម្រឹគនោះឲ្យចូលព្រះរាជឧទ្យាន ហើយបិទទ្វារ នាំគ្នាចូលទៅគាល់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលទ្រង់យាងទៅសម្លាប់ម្រឹគជាប្រចាំ ទ្រង់ធ្វើការងាររបស់ទូលបង្គំទាំងឡាយឲ្យវិនាស ទូលបង្គំកៀងម្រឹគទាំងឡាយដាក់ពេញព្រះរាជឧទ្យាននៃព្រះអង្គ តាំងអំពីថ្ងៃនេះទៅ សូមទ្រង់សោយសាច់របស់ម្រឹគទាំងនោះ ហើយទូលលាព្រះរាជា នាំគ្នាចៀសចេញទៅ ។

ព្រះរាជា ទ្រង់បានស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ យាងទៅព្រះ

រាជឧទ្យាន ទតម្រឹគទាំងឡាយ ទ្រង់ឃើញម្រឹគ ២ មានពណ៌ដូចមាស ទើបព្រះរាជទានអភ័យដល់ម្រឹគទាំង ២ នោះ ។ តាំងអំពីនោះមក ជួនកាល ទ្រង់ទៅឯង សម្លាប់ម្រឹគ ១ ហើយនាំមក ជួនកាល អ្នកគ្រួរបស់ព្រះអង្គទៅសម្លាប់ហើយនាំមក ។ ម្រឹគទាំងឡាយគ្រាន់តែឃើញធ្នូប៉ុណ្ណោះ ត្រូវមរណភ័យគំរាម នាំគ្នារត់ទៅ បានទទួលការប្រហារ ២-៣ ដង លំបាកខ្លះ របួសខ្លះ ដល់នូវការស្លាប់ខ្លះ ទើបពួកម្រឹគប្រាប់ព្រឹត្តិហេតុនោះដល់ព្រះពោធិសត្វ ព្រះពោធិសត្វឲ្យហៅសាខម្រឹគមកហើយ ពោលថា នែសម្លាញ់ ម្រឹគជាច្រើននាំគ្នាវិនាស កាលម្រឹគគង់តែស្លាប់ដោយចំណែកមួយ តាំងអំពីនេះទៅ អ្នកសម្លាប់ កុំចាំយកព្រួញបាញ់ម្រឹគឡើយ វេនរបស់ម្រឹគទាំងឡាយ ចូរមានក្នុងទីនៃជ្រញ់របស់អ្នកសម្លាប់ វារៈដល់បរិស័ទរបស់យើងមួយថ្ងៃ ដល់បរិស័ទរបស់អ្នកមួយថ្ងៃ ម្រឹគដែលដល់វេន ចូរទៅដេកដាក់ក្បាលត្រង់ជ្រញ់ របស់អ្នកសម្លាប់ កាលបើដូច្នោះ ម្រឹគទាំងឡាយនឹងមិនតក់ស្លុត សាខម្រឹគទទួលពាក្យហើយ ។ តាំងអំពីនោះមក ម្រឹគដែលដល់វារៈ នឹងទៅដេកដាក់កត្រង់ជ្រញ់អ្នកសម្លាប់ អ្នកគ្រួមកចាប់យកម្រឹគដែលដេកក្នុងទីនោះឯងទៅ ។ ថ្ងៃមួយ វារៈដល់មេម្រឹគ ដែលមានគភ៌មួយក្បាល ជាបរិស័ទរបស់សាខៈ មេម្រឹគនោះ ចូលទៅរកសាខម្រឹគ ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំមានទម្ងន់ កើតកូនហើយ ពួកយើងទាំង ២ នឹងទៅតាមវារៈ សូមលោកម្ចាស់ឲ្យវារៈរបស់ខ្ញុំរំលងសិនចុះ ម្រឹគសាខៈពោលថា អញមិនអាចធ្វើវារៈរបស់ឯងឲ្យដល់ម្រឹគដទៃឡើយ ឯងប៉ុណ្ណោះនឹងដឹងវារៈរបស់ឯង ចូរឯង

ទៅចុះ ។ មេម្រឹគនោះ មិនបានការជួយស្រោចស្រង់អំពីសម្នាក់របស់ម្រឹគសាខៈ ទើបចូលទៅរកព្រះពោធិសត្វប្រាប់សេចក្ដីនោះ ព្រះពោធិសត្វបានស្ដាប់ពាក្យរបស់មេម្រឹគនោះ ទើបគិតថា ព្រះពោធិសត្វទាំងឡាយ ក្នុងកាលមុន ឃើញទុក្ខរបស់អ្នកដទៃ តែងមិនជាប់ជំពាក់ក្នុងជីវិតរបស់ខ្លួន ប្រយោជន៍អ្នកដទៃអំពីប្រយោជន៍ខ្លួននោះឯង ជារបស់ធ្ងន់ សម្រាប់ព្រះពោធិសត្វទាំងនោះ ។

ពួកបក្សី បសុសត្វ ម្រឹគក្នុងព្រៃទាំងអស់ រមែងរស់នៅដោយខ្លួនឯងអ្នកប្រាជ្ញទាំងឡាយ ដែលជាអ្នកស្ងប់ ត្រេកអរហើយ ក្នុងប្រយោជន៍អនុគ្រោះដល់សត្វ រមែងញ៉ាំងអ្នកដទៃឲ្យរស់នៅ អ្នកប្រាជ្ញទាំងនោះលះទ្រព្យ អវយវៈនិងជីវិត ដើម្បីជាប្រយោជន៍ អាត្មាអញជាអ្នកអាចញ៉ាំងពួកសត្វជាច្រើនព្រមទាំងទេវលោកឲ្យឆ្លងបានផង ឯការមិនមានបុណ្យ ព្រោះកាយដែលឥតសារៈនេះ អញនឹងបានលាភ ( បុណ្យ ) របស់បុគ្គលដែលស្ថិតស្ថេរដោយខ្លួនឯងពិត ដូច្នេះ ។

កាលគិតដូច្នេះហើយ ទើបពោលថា ចូរនាងទៅចុះ យើងនឹងឲ្យវារៈរបស់នាងធ្លងទៅ កាលពោលហើយ ខ្លួនឯងក៏ទៅដេកដាក់ក្បាលត្រង់ជ្រញ់អ្នកគ្រួឃើញដូច្នោះ ទើបគិតថា ស្ដេចម្រឹគនេះ បានទទួលព្រះរាជទានអភ័យដេកត្រង់ជ្រញ់ ព្រោះហេតុអ្វីហ្ន៎ ទើបទៅក្រាបទូលព្រះរាជាៗ ឡើងកាន់រថក្នុងរំពេចនោះឯង យាងទៅដោយបរិវារធំ ឃើញព្រះពោធិសត្វ ទើបត្រាស់ថា នៃស្ដេចម្រឹគសម្លាញ់ យើងឲ្យអភ័យដល់អ្នកហើយមិនមែនឬ ព្រោះហេតុ

អ្វី ទើបអ្នកដេកក្នុងទីនេះ ស្តេចម្រឹគទូលថា បពិត្រមហារាជ មេម្រឹគមានគភ៌ ពោលថា សូមលោកញ៉ាំងវារៈរបស់ខ្ញុំឲ្យដល់ម្រឹគដទៃ ទូលបង្គំមិនអាចបោះ មរណទុក្ខរបស់ម្រឹគមួយ ទៅឲ្យម្រឹគដទៃមួយទៀតបាន ទើបទូលបង្គំឲ្យជីវិត របស់ខ្លួនដល់មេម្រឹគនោះ កាន់យកការស្លាប់ដែលជារបស់មេម្រឹគនោះហើយ ទើបដេកក្នុងទីនេះ បពិត្រមហារាជ សូមទ្រង់កុំងឿងឆ្ងល់ក្នុងហេតុដទៃឡើយ ព្រះរាជាត្រាស់ថា ម្នាលសុវណ្ណម្រឹគ សូម្បីពួកមនុស្សទាំងឡាយ ខ្ញុំក៏មិនធ្លាប់ ឃើញបុគ្គលដែលដល់ព្រមដោយខន្តី មេត្តា និងករុណាដូចអ្នកឡើយ ដោយ ហេតុនោះ ទើបខ្ញុំជ្រះថ្លាក្នុងអ្នក ក្រោកឡើងចុះ ខ្ញុំឲ្យអភ័យដល់អ្នក និងដល់ មេម្រឹគនោះ ស្តេចម្រឹគពោលថា បពិត្រព្រះអង្គជាធំជាងជន កាលទូលបង្គំ ទាំង ២ បានអភ័យហើយ ម្រឹគដ៏សេសក្រៅអំពីនោះ នឹងធ្វើដូចម្តេច ព្រះ រាជាត្រាស់ថា នែអ្នក ខ្ញុំឲ្យអភ័យដល់ម្រឹគដ៏សេស ស្តេចម្រឹគក្រាបទូលថា បពិត្រមហារាជ បើដូច្នោះ ម្រឹគទាំងឡាយក្នុងព្រះរាជឧទ្យានប៉ុណ្ណោះនឹងបាន អភ័យ ម្រឹគដ៏សេស ទ្រង់ធ្វើដូចម្តេច ព្រះរាជាត្រាស់ថា នែអ្នក ខ្ញុំឲ្យអភ័យ ដល់ម្រឹគទាំងនោះ ស្តេចម្រឹគក្រាបទូលថា បពិត្រមហារាជ ខាងដើម ម្រឹគ ទាំងឡាយបានទទួលអភ័យ សត្វជើង ៤ ដ៏សេស ទ្រង់គិតដូចម្តេច ព្រះ រាជាត្រាស់ថា ខ្ញុំឲ្យអភ័យដល់សត្វជើង ៤ ទាំងនោះ ស្តេចម្រឹគក្រាបទូល ថា បពិត្រមហារាជ សត្វជើង ៤ ទ្រង់បានព្រះរាជទានអភ័យហើយ ចុះពួក បក្សីនឹងធ្វើដូចម្តេច ព្រះរាជាត្រាស់ថា នែអ្នក ពួកបក្សីទាំងនោះ ខ្ញុំក៏ឲ្យអភ័យ ស្តេចម្រឹគក្រាបទូលថា ពួកបក្សីបានទទួលព្រះរាជទានអភ័យ ពួកត្រីដែលនៅ

ក្នុងទឹក នឹងធ្វើដូចម្ដេច ព្រះរាជាត្រាស់ថា អើ សូម្បីពួកត្រីទាំងនោះ ក៏ខ្ញុំឲ្យអភ័យ ព្រះមហាសត្វទូលសូមអភ័យដល់សព្វសត្វនឹងព្រះរាជាយ៉ាងនេះហើយ បានក្រោកឡើងឈរ ឲ្យព្រះរាជាតាំងនៅក្នុងសីល ៥ ហើយសម្ដែងធម៌ដល់ព្រះរាជា ដូចពុទ្ធលីលាថា បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះជនក ព្រះជននី ក្នុងព្រះឱរស ព្រះធីតា ក្នុងព្រាហ្មណ៍គហបតី ក្នុងអ្នកនិគមនិងអ្នកជនបទ កាលទ្រង់ប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ខាងមុខអំពីស្លាប់ ព្រោះកាយបែក នឹងចូលដល់សុគតិទេវលោក ដូច្នេះហើយ នៅក្នុងឧទ្យាន ២-៣ ថ្ងៃ ឲ្យឱវាទដល់ព្រះរាជាហើយ មានពួកម្រឹគចោមរោម ចូលទៅកាន់ព្រៃហើយ មេម្រឹគកូនខ្ចីនោះ កើតកូនមក ដូចគ្នានឹងបាច់ផ្កា កូនម្រឹគនោះ កាលរត់លេងបាន ទើបទៅកាន់សម្នាក់របស់ម្រឹគសាខៈ ។ លំដាប់នោះ មេម្រឹគឃើញកូនម្រឹគនោះ កំពុងទៅកាន់សម្នាក់របស់ម្រឹគសាខៈនោះ ទើបពោលថា នែកូន តាំងអំពីនេះទៅ បាកុំទៅកាន់សម្នាក់របស់សាខៈនោះ គប្បីទៅកាន់សម្នាក់របស់និគ្រោធម្រឹគប៉ុណ្ណោះ កាលនឹងឲ្យឱវាទ ទើបពោលគាថាថា

បុគ្គល គប្បីសេពនូវម្រឹគឈ្មោះនិគ្រោធៈតែម្យ៉ាង កុំគប្បីសេពនូវ
ម្រឹគឈ្មោះសាខៈឡើយ កាលស្លាប់ក្នុងសម្នាក់នៃម្រឹគឈ្មោះ
និគ្រោធៈ ជាការប្រសើរ ការរស់នៅក្នុងសម្នាក់នៃម្រឹគឈ្មោះ
សាខៈ ពុំប្រសើរឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និគ្រោធមេវ សេវេយ្យ** សេចក្ដីថា នែបាអ្នក ឬអ្នកដទៃក្ដី បុគ្គលប្រាថ្នាចំពោះប្រយោជន៍ដល់ខ្លួន គួរសេព ឬគួរគប់រក

ដល់ស្ដេចម្រឹគឈ្មោះនិគ្រោធប៉ុណ្ណោះ គឺគប្បីចូលទៅជិតស្ដេចម្រឹគនោះ ។ បទថា **ន សាខំ ឧបសំវសេ** សេចក្ដីថា តែម្រឹគឈ្មោះសាខៈ មិនគួរចូលទៅនៅរួម គឺមិនគួរចូលទៅនៅក្បែរ ហើយនៅរួម បានដល់ មិនគួរអាស្រ័យម្រឹគសាខៈនោះចិញ្ចឹមជីវិតឡើយ ។ បទថា **និគ្រោធស្មឹ មតំ សេយ្យោ** សេចក្ដីថា សូម្បីការស្លាប់ទៀបជើងរបស់ស្ដេចម្រឹគឈ្មោះនិគ្រោធប្រសើរជាងគឺឧត្ដមបំផុត ។ បទថា **យញ្ចេ សាខស្មិ ជីវិតំ** សេចក្ដីថា ការរស់នៅក្នុងសម្នាក់របស់ម្រឹគឈ្មោះសាខៈនោះ មិនប្រសើរ គឺមិនឧត្ដម មិនខ្ពង់ខ្ពស់ឡើយ ។

ចាប់តាំងអំពីនោះ ពួកម្រឹគកាលបានទទួលអភ័យ នាំគ្នាបរិភោគសន្ទូងរបស់ពួកមនុស្សៗ ទាំងឡាយមិនអាចវាយ ឬដេញម្រឹគទាំងឡាយ ដោយគិតថា ម្រឹគទាំងនេះបានព្រះរាជទានអភ័យ ទើបនាំគ្នាប្រជុំត្រង់លានព្រះរាជវាំង ក្រាបទូលសេចក្ដីនោះដល់ព្រះរាជាៗ ត្រាស់ថា យើងមានសេចក្ដីជ្រះថ្លាឲ្យពរដល់ស្ដេចម្រឹគឈ្មោះនិគ្រោធ ទោះបីយើងលះរាជសម្បត្តិ ក៏មិនទម្លាយបដិញ្ញានោះ ចូរអ្នកទាំងឡាយទៅចុះ បុគ្គលណាម្នាក់ មិនអាចប្រហារម្រឹគទាំងឡាយក្នុងដែនរបស់យើងឡើយ ។ ស្ដេចម្រឹគឈ្មោះនិគ្រោធបានស្ដាប់ហេតុការណ៍នោះ ទើបឲ្យពួកម្រឹគប្រជុំគ្នា ឲ្យឱវាទម្រឹគទាំងឡាយថា ចាប់តាំងអំពីនេះទៅ អ្នកទាំងឡាយ កុំស៊ីសន្ទូងរបស់អ្នកដទៃ ដូច្នេះហើយ ប្រាប់ដល់មនុស្សទាំងឡាយថា តាំងអំពីនេះទៅ មនុស្សទាំងឡាយដែលធ្វើសន្ទូងកុំធ្វើរបងដើម្បីរក្សាសន្ទូង តែសូមចងសញ្ញា ដោយស្លឹកឈើក្នុងស្រែ ។ បាន

ឮថា តាំងអំពីកាលនោះ ទើបកើតសញ្ញាក្នុងការបងស្លឹកឈើក្នុងស្រែទាំងឡាយ តាំងអំពីកាលនោះ ម្រឹគដែលកន្លងល្មើសសញ្ញា ក្នុងការបងស្លឹកឈើ រមែងមិនមាន បានឮថា សេចក្តីនេះ ជាឱវាទដែលពួកម្រឹគទាំងនោះបានអំពីព្រះពោធិសត្វ ។ ព្រះពោធិសត្វទូន្មានម្រឹគយ៉ាងនេះហើយ តាំងនៅដរាបដល់អស់អាយុ ឯម្រឹគទាំងឡាយបានទៅតាមយថាកម្មហើយ ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យទាំងឡាយ បានទៅតាមយថាកម្មហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងរបស់នាងថេរី និងកុមារកស្សបៈ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងហើយដូចគ្នា ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់បង្វិលទេសនាដោយសច្ចៈទាំង ៤ ត្រាស់ ២ រឿង បន្តអនុសន្ធិគ្នាហើយទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ បរិស័ទរបស់សាខម្រឹគនោះ ក្នុងកាលនោះ បានជាបរិស័ទរបស់ទេវទត្តនោះ ក្នុងកាលឥឡូវនេះឯង ។ មេម្រឹគកូនខ្ចី ក្នុងកាលនោះ បានជានាងថេរី កូនម្រឹគក្នុងកាលនោះ បានជាកុមារកស្សបៈ ព្រះរាជាក្នុងកាលនោះ គឺអានន្ទ ឯស្តេចម្រឹគឈ្មោះនិគ្រោធ ជាតថាគតនេះឯង ៕

**អដ្ឋកថា និគ្រោធមិគជាតក ចប់**

# សុត្តន្តបិដក

## កណ្ឌិនជាតក

[ ១៣ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ចូរតិះដៀលនូវបុរស អ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្រីជាបរិណាយិកា ( អ្នកត្រួតត្រា ) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះ ម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ ។

**កណ្ឌិនជាតកទី ៣ ចប់**

# អដ្ឋកថា

## កណ្ឌិនជាតក

[ ១៣ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការលួងលោមរបស់បុរាណកិរិយា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធិរត្ថុ កណ្ឌិនំ សល្លំ** ដូច្នេះជាដើម ។

ការប្រលោមនោះ មានច្បាស់ក្នុងឥន្ទ្រិយជាតក អដ្ឋកនិបាត ។ ព្រះសាស្ដាបានត្រាស់ព្រះតម្រាស់នេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកអាស្រ័យមាតុគ្រាមនេះ ដល់នូវការអស់ជីវិត នៅលើរងើកភ្លើង ដែលប្រាសចាកអណ្ដាត ភិក្ខុទាំងឡាយទូលអារាធនាព្រះសាស្ដា ដើម្បីទ្រង់ប្រកាសរឿងនោះឲ្យជាក់ច្បាស់ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុ ដែលអន្ទរកពបិទឲ្យប្រាកដហើយ ខាងមុខអំពីនេះទៅ ខ្ញុំមិនពោលដល់ការដែលភិក្ខុទាំងឡាយទូលអារាធនា និងភាពដែលហេតុត្រូវអន្ទរកពបិទបាំង នឹងពោលចំពោះពាក្យមានប្រមាណប៉ុណ្ណេះថា **អតីតំ អាហរិ** ប្រែថា ( ទ្រង់នាំអតីតនិទានមក ) ប៉ុណ្ណោះ ។ កាលពោលពាក្យមានប្រមាណប៉ុណ្ណេះ គប្បីប្រកបហេតុការណ៍ទាំងអស់នេះ គឺការទូលអារាធនា ការប្រៀបធៀប ដូចនាំព្រះចន្ទចេញចាកពពក និងភាពដែលហេតុត្រូវអន្ទរកពបិទបាំង ដោយន័យដូចពោលខាងដើមនោះឯងហើយ គប្បីជ្រាប ។

ក្នុងអតីតកាល កាលព្រះបាទមគធៈគ្រងរាជសម្បត្តិ ក្នុងនគររាជគ្រឹះ មគធរដ្ឋ ជាសម័យដកស្ទូងរបស់អ្នកមគធៈ ពួកម្រឹគទាំងឡាយ មានអន្តរាយច្រើន ទើបម្រឹគទាំងនោះឡើងទៅកាន់ភ្នំ ។ ម្រឹគភ្នំមួយ ធ្វើសេចក្ដីស្និទ្ធស្នាល

ជាមួយម្រឹគញីស្រុក កាលពួកម្រឹគទាំងនោះចុះអំពីភ្នំ ត្រឡប់មកកាន់ជាយដែន បានចុះមកជាមួយម្រឹគទាំងនោះឯង ព្រោះមានចិត្តប្រតិព័ទ្ធក្នុងម្រឹគញីនោះ ។ លំដាប់នោះ ម្រឹគញីនោះពោលនឹងម្រឹគភ្នំថា បពិត្រអ្នក អ្នកជាម្រឹគភ្នំដែលល្ងង់ខ្លៅ ធម្មតាជាយដែនគួររង្កៀស មានភ័យចំពោះមុខ អ្នកកុំចុះមកជាមួយខ្ញុំឡើយ ។ ម្រឹគភ្នំនោះមិនព្រមត្រឡប់ ព្រោះមានចិត្តស្រឡាញ់ម្រឹគញីនោះ បានមកជាមួយម្រឹគញីនោះឯង ។ អ្នកមគធៈដឹងថា ឥឡូវនេះជាពេលដែលម្រឹគចុះអំពីភ្នំ ដូច្នេះហើយ ទើបឈរក្នុងគុម្ពឈើដែលគេកាប់ដើម្បីបិទបាំងខ្លួនក្បែរផ្លូវ ក្នុងផ្លូវដែលម្រឹគទាំង ២ នោះដើរមក មានព្រានម្នាក់ឈរក្នុងគុម្ពឈើដែលបិទជិត ។ ម្រឹគញីបានក្លិនមនុស្ស គិតថា នឹងមានព្រានម្នាក់ឈរ ទើបឲ្យម្រឹគឈ្មោលដើរពីមុខ ឯខ្លួនឯង ដើរឯក្រោយ ។ នាយព្រានបានធ្វើម្រឹគនោះឲ្យដួលចុះត្រង់នោះឯង ដោយការបាញ់ដោយព្រួញមួយប៉ុណ្ណោះ ។ ម្រឹគញីដឹងថា ម្រឹគនោះត្រូវព្រួញ ទើបលោតគេចទៅដោយសម្ទុះរហ័សដូចខ្យល់ ។ ព្រានចេញអំពីគុម្ពឈើ ពុះសាច់ បង្កាត់ភ្លើងអាំងម្រឹគលើរងើកប្រាសចាកអណ្តាត ទំពាស៊ី ហើយផឹកទឹក យកដងរែករែកសាច់ដែលសល់ទៅ មានតំណក់ឈាមហូរ បានទៅកាន់ផ្ទះ ញុំាងកូនទាំងឡាយឲ្យត្រេកអរហើយ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតជាទេវតាក្នុងដងព្រៃនោះ ព្រះពោធិសត្វឃើញហេតុការណ៍នោះ គិតថា ម្រឹគល្ងង់នេះស្លាប់ ព្រោះអាស្រ័យមេ ព្រោះអាស្រ័យបា ក៏មិនមែន ដោយពិត ស្លាប់ព្រោះអាស្រ័យកាម ពិតហើយ ព្រោះ

កាមជានិមិត្តហេតុ ទើបសត្វទាំងឡាយដល់នូវទុក្ខច្រើនប្រការ មានការកាត់ដៃជាដើម ក្នុងសុគតិ និងចំណង ៥ ប្រការជាដើមក្នុងទុគ្គតិ ឈ្មោះថាការធ្វើទុក្ខ គឺការស្ងាប់ឲ្យកើតឡើងដល់អ្នកដទៃ ក៏ត្រូវតិះដៀលក្នុងលោកនេះ ទោះជនបទណា មានស្ត្រីជាអ្នកដឹកនាំ ចាត់ចែងគ្រប់គ្រង ក៏ត្រូវតិះដៀល ពួកសត្វដែលធ្លាក់នៅក្នុងអំណាចរបស់មាតុគ្រាម ក៏ត្រូវតិះដៀលដូចគ្នា ហើយសម្តែងរឿងសម្រាប់តិះដៀល ៣ ប្រការ ដោយមួយគាថា កាលទេវតាទាំងឡាយទៅព្រៃ ឲ្យសាធុការ ហើយបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម កាលញ៉ាំងដងព្រៃនោះ ឲ្យបន្លឺឡើងដោយសំឡេងដ៏ពីរោះ ទើបសម្តែងធម៌ដោយគាថានេះថា

ចូរតិះដៀលនូវបុរស អ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង[១] ស្រីជាបរិណាយិកា ( អ្នកត្រួតត្រា ) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះម្យ៉ាងទៀត សត្វទាំងឡាយណាលុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ ដូច្នេះ ។

សព្ទថា **ធិរត្ថុ** ក្នុងគាថានោះ ត្រឹមតែជានិបាត ប្រើក្នុងអត្ថថា តិះដៀល

---

១- គួរប្រែថា ចូរតិះនូវបុរសដែលមានសរ ( ជាអាវុធ ) ដែលបាញ់ទៅពេញកម្លាំង ទើបត្រូវតាមន័យរបស់អដ្ឋកថា ព្រោះព្រះពោធិសត្វតិះដៀលជន ៣ ពួក គឺបុគ្គលដែលធ្វើទុក្ខ គឺការស្ងាប់ឲ្យកើតឡើងដល់អ្នកដទៃ ( អ្នកកាន់ធ្នូ ) ១ ជនបទដែលមានស្រីដឹកនាំ ១ សត្វដែលធ្លាក់ក្នុងអំណាចមាតុគ្រាម ១ ។

ក្នុងទីនេះ សព្ទថា **ធិរត្ថុ** នេះ គប្បីឃើញថា ប្រើក្នុងការតិះដៀល ដោយអំណាចការតក់ស្លុត និងការខ្លាច ពិតហើយ ព្រះពោធិសត្វជាអ្នកតក់ស្លុតផង ភ័យខ្លាចផង ទើបពោលយ៉ាងនោះ បុគ្គលដែលឈ្មោះថា **កណ្ណី** ព្រោះមានព្រួញ ។ នូវបុគ្គលដែលមានព្រួញនោះ ។ ព្រួញនោះ គេហៅថា **សល្លុ** ព្រោះអត្ថថា ចាក់ចូលទៅ ព្រោះហេតុនោះ ក្នុងពាក្យថា **កណ្ណិនំ សល្លំ** នេះ ទើបមានអត្ថថា បុគ្គលមានព្រួញជាអាវុធ ។ មា៉្យងទៀត ឈ្មោះថា អ្នកមានព្រួញ ព្រោះមានសរ ។ បុគ្គលមានសរនោះ ។ ឈ្មោះថា **គាឡ្ហវេធិនំ** ជាអ្នកបាញ់ទៅពេញកម្លាំង ព្រោះកាលឲ្យនូវការប្រហារយ៉ាងពេញកម្លាំង ទើបបាញ់ពេញទំហឹង ដោយធ្វើឲ្យមានមុខរបួសធំ ។ បុគ្គលដែលបាញ់ទៅពេញទំហឹងនោះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា យើងតិះដៀលបុគ្គលដែលប្រកបដោយអាវុធ មានប្រការផ្សេងៗ ឈ្មោះថា **សល្លុ** គឺព្រួញព្រោះរត់ទៅដោយត្រង់ ដោយមានសណ្ឋានដូចស្លឹកកុមុទជាផល ដែលបាញ់ទៅយ៉ាងពេញកម្លាំង ។ បទថា **បរិណាយិកា** បានដល់ ជាធំ គឺជាអ្នកប្រាកដច្បាស់ ។ បទថា **ធិក្កិតា** បានដល់ តិះដៀលហើយ ។ ពាក្យដ៏សេសក្នុងគាថានេះ ងាយយល់ទាំងអស់ហើយ ។

ខាងមុខអំពីនេះទៅ ខ្ញុំមិនពោលពាក្យមានប្រមាណប៉ុណ្ណោះ ពណ៌នាតែ

ពាក្យដែលលំបាកៗ ប៉ុណ្ណោះ ។ ព្រះពោធិសត្វ កាលសម្តែងរឿងសម្រាប់តិះដៀល ៣ ប្រការ ដោយមួយគាថាយ៉ាងនេះហើយ បានធ្វើព្រៃឲ្យខូរខ្វារឡើង ហើយសម្តែងធម៌ដោយលំនាំពុទ្ធលីលា ។ ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលអផ្សុក តាំងនៅក្នុងសោតាបត្តិផល ព្រះសាស្តាត្រាស់ ២ រឿង បន្តអនុសន្ធិគ្នាហើយ ទ្រង់ប្រជុំជាតក ឯរឿងបន្ទាប់អំពីនេះទៅ ខ្ញុំនឹងមិនពោលពាក្យថា ព្រះមានព្រះភាគត្រាស់ ២ រឿងនេះ ពោលចំពោះតែពាក្យមានប្រមាណប៉ុណ្ណោះថា ទ្រង់បន្តអនុសន្ធិ ។ ពាក្យនេះ សូម្បីមិនពោលក៏គប្បីប្រកបកាន់យក ដោយន័យដូចពោលខាងដើមនោះឯង ។ ម្រឹគភ្នំក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ចង់សឹកក្នុងកាលឥឡូវនេះ ម្រឹគញីក្នុងកាលនោះ បានជាភរិយាចាស់ក្នុងកាលឥឡូវនេះ ចំណែកទេវតាដែលឃើញទោសក្នុងកាមទាំងឡាយ ហើយសម្តែងធម៌ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា កណ្ឌិជាតក ចប់**

# សុត្តន្តបិដក

## វាតមិគជាតក

[ ១៤ ] ( ព្រះរាជាទ្រង់មានព្រះឱង្ការថា ធនូរាគ ) ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងធនូរាគ ដោយរសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះសញ្ជ័យ បាននាំសត្វឈ្លូស ដែលអាស្រ័យនៅព្រៃស្បាត មកកាន់អំណាច ( របស់ខ្លួន ) បានព្រោះតែរូបទាំងឡាយ ។

**វាតមិគជាតកទី ៤ ចប់**

# អដ្ឋកថា

## វាតមិគជាតក

[ ១៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធចូឡបិណ្ឌបាតិកតិស្សត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន កិរត្ថិ រសេហិ បាបិយោ** ដូច្នេះជាដើម ។

បានឮថា កាលព្រះសាស្តាទ្រង់អាស្រ័យនគររាជគ្រឹះ គង់នៅក្នុងវត្តវេឡុវ័ន ។

ថ្ងៃមួយ បុត្តរបស់ត្រកូលសេដ្ឋី ដែលមានទ្រព្យច្រើន ឈ្មោះតិស្សកុមារទៅកាន់វិហារវេឡុវ័ន ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ បំណងនឹងបួស ទើបទូលសូមបព្វជ្ជា តែឪពុកម្តាយមិនអនុញ្ញាត ទើបបដិសេធ បានធ្វើការអត់អាហារ ៧ ថ្ងៃ ឲ្យមាតាបិតាអនុញ្ញាតហើយ ដូចគ្នានឹងព្រះរដ្ឋបាលត្ថេរ បានបួសក្នុងសម្នាក់របស់ព្រះសាស្តាហើយ ។ ព្រះសាស្តា កាលទ្រង់ឲ្យតិស្សកុមារនោះបួសហើយ គង់នៅក្នុងវេឡុវ័នវិហារ ប្រមាណកន្លះខែហើយបានយាងទៅកាន់វត្តជេតពន ក្នុងវត្តជេតពននោះ កុលបុត្តនេះ សមាទានធុតង្គ ១៣ ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ប្រក ក្នុងនគរសាវត្ថី ញុំាងកាលវេលាឲ្យកន្លងទៅ បុគ្គលណាម្នាក់ក៏ហៅថា ព្រះចូឡបិណ្ឌបាតិកតិស្សៈជាអ្នកប្រាកដទូទៅក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញវង់ ក្នុងលម្អអាកាសដូច្នោះ ។

ក្នុងកាលនោះ កាលថ្ងៃលេងនក្ខត្តឫក្ស កំពុងប្រព្រឹត្តទៅក្នុងនគររាជគ្រឹះ មាតាបិតារបស់ព្រះថេរៈ ក៏យកគ្រឿងប្រដាប់ដែលមាន កាលព្រះថេរៈនៅជា

គ្រហស្ត ដាក់ក្នុងប្រអប់ប្រាក់ យកមកដាក់ត្រង់ទ្រូង យំរៀបរាប់ថា ក្នុងថ្ងៃលេងនក្ខត្តឫក្សដទៃៗ កូនរបស់អញប្រដាប់ដោយគ្រឿងប្រដាប់នេះ លេងនក្ខត្តឫក្ស ព្រះសមណគោតមនាំយកបុត្តតូចនោះ របស់អញទៅកាន់នគរសាវត្ថី ឥឡូវនេះ បុត្តតូចរបស់អញនោះ អង្គុយទីណាហ្ន៎ ឈរទីណាហ្ន៎ ។ លំដាប់នោះ នាងវណ្ណទាសីម្នាក់ទៅកាន់ត្រកូលនោះ ឃើញភរិយារបស់សេដ្ឋីកំពុងយំ ទើបសួរថា បពិត្រអ្នកម៉ែ អ្នកម៉ែយំធ្វើអ្វី ទើបភរិយារបស់សេដ្ឋីនោះ ប្រាប់សេចក្តីនោះ នាងវណ្ណទាសីពោលថា បពិត្រអ្នកម៉ែ កូនរបស់អ្នកម៉ែស្រឡាញ់អ្វី ភរិយាសេដ្ឋីពោលថា ស្រឡាញ់វត្ថុឈ្មោះនោះ និងឈ្មោះនោះ ។ នាងវណ្ណទាសីពោលថា បើអ្នកម៉ែឲ្យភាពជាធំទាំងអស់ក្នុងផ្ទះនេះដល់ខ្ញុំសោត ខ្ញុំនឹងនាំកូនរបស់អ្នកម៉ែមក ។ ភរិយាសេដ្ឋីទទួលពាក្យថា សាធុ ហើយឲ្យស្បៀង បញ្ជូននាងវណ្ណទាសីទៅដោយបរិវារធំ ពោលថា ចូរនាងទៅនាំបុត្តរបស់យើងមកដោយសមត្ថភាពរបស់ខ្លួន នាងវណ្ណទាសីនោះអង្គុយក្នុងយានតូចដែលបិទបាំង ទៅកាន់នគរសាវត្ថី កាន់យកការនៅអាស្រ័យទៀបផ្លូវថ្នល់ ដែលព្រះថេរៈត្រាច់បិណ្ឌបាត មិនឲ្យព្រះថេរៈឃើញមនុស្សដែលមកអំពីត្រកូលសេដ្ឋីឡើយ ចោមរោមដោយបរិវាររបស់ខ្លួនប៉ុណ្ណោះ កាលព្រះថេរៈចូលទៅបិណ្ឌបាត បានថ្វាយយាគូមួយបោយ និងភិក្ខាមានរស ចងដោយចំណងក្នុងរសអំពីខាងដើម ហើយឲ្យអង្គុយក្នុងផ្ទះ ប្រគេនភិក្ខាដោយលំដាប់ ដឹងថា ព្រះថេរៈធ្លាក់នៅក្នុងអំណាចរបស់ខ្លួន ទើបសម្តែងអាការធ្វើជាឈឺ ដេកក្នុងបន្ទប់ ។ ឯព្រះថេរៈត្រាច់ទៅតាមលំដាប់ប្រកក្នុងពេលភិក្ខាចារ

បានទៅដល់ទ្វារផ្ទះ ជនដែលជាបរិវារទទួលបាត្ររបស់ព្រះថេរៈហើយ និមន្ត ព្រះថេរៈឲ្យអង្គុយក្នុងផ្ទះ ។ ព្រះថេរៈអង្គុយហើយ សួរថា ឧបាសិកាទៅណា ជនជាបរិវារពោលថា បពិត្រលោកម្ចាស់ ឧបាសិកាមានជំងឺប្រាថ្នានឹងឃើញ លោកម្ចាស់ ។ ព្រះថេរៈត្រូវចំណង់ក្នុងរសចងទ្វាក់ ទម្លាយការសមាទានវត្ត របស់ខ្លួន ចូលទៅកាន់ទីដែលនាងវណ្ណទាសីនោះដេក នាងវណ្ណទាសីប្រាប់ ហេតុនៃការមករបស់ខ្លួន ទើបប្រលោមព្រះថេរៈនោះ ចងដោយតណ្ហាក្នុង រស ឲ្យសឹកហើយ តាំងនៅក្នុងអំណាចរបស់ខ្លួន ឲ្យអង្គុយក្នុងយាន បានទៅ កាន់នគររាជគ្រឹះនោះឯង ដោយបរិវារធំ ។ ដំណឹងនោះបានប្រាកដហើយ ។

ភិក្ខុទាំងឡាយ អង្គុយប្រជុំគ្នាក្នុងរោងធម្មសភា សន្ទនាគ្នាថា បានឮថា នាងវណ្ណទាសីម្នាក់ ចងព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ដោយតណ្ហាក្នុងរស ហើយនាំទៅ ។ ព្រះសាស្តាយាងចូលទៅកាន់រោងធម្មសភា គង់លើអាសនៈ ដែលគេតាក់តែង ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងនោះបានក្រាបទូលរឿងនោះថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុនេះជាប់ក្នុងរសតណ្ហា ធ្លាក់នៅក្នុងអំណាចរបស់នាងវណ្ណ-ទាសីនោះ ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្លាក់នៅក្នុង អំណាចរបស់នាងដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកថា

ក្នុងអតីតកាល ក្នុងនគរពារាណសី មាននាយឧទ្យានបាលរបស់ព្រះបាទ ព្រហ្មទត្ត ឈ្មោះសញ្ជ័យ ។ កាលនោះ ម្រឹគស្មាន់មួយមកកាន់ឧទ្យាននោះ

ឃើញនាយឧទ្យានបាលសញ្ជ័យ ទើបគេចទៅ ។ ឯសញ្ជ័យមិនបានបង្អើល ម្រឹគស្មាន់នោះឲ្យចេញទៅ ទើបម្រឹគស្មាន់នោះមកក្នុងឧទ្យាននោះរឿយៗ ឧទ្យានបាលនាំយកផ្កា និងផ្លែឈើ មានប្រការផ្សេងៗ មកអំពីឧទ្យានអំពីព្រលឹម ចូលទៅថ្វាយព្រះរាជា រាល់ៗ ថ្ងៃ ។ ថ្ងៃមួយ ព្រះរាជាត្រាស់សួរឧទ្យានបាលនោះថា នែឧទ្យានបាលសម្លាញ់ អ្នកឃើញអ្វីចម្លែកក្នុងឧទ្យានខ្លះទេ ឧទ្យានបាលក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនឃើញវត្ថុដទៃ តែម្រឹគស្មាន់មួយតែងត្រាច់មកកាន់ឧទ្យាន ទូលបង្គំបានឃើញវត្ថុនេះ ។ ព្រះរាជាត្រាស់សួរថា អ្នកអាចចាប់ម្រឹគនោះបានដែរទេ ឧទ្យានបាលក្រាបទូលថា បើបានទឹកឃ្មុំបន្តិច ទូលបង្គំអាចនាំម្រឹគស្មាន់នោះមកខាងក្នុងព្រះរាជ-និវេសន៍បាន ។ ព្រះរាជាបានឲ្យទឹកឃ្មុំដល់នាយឧទ្យានបាលនោះ ។ ឧទ្យាន-បាលនោះទទួលទឹកឃ្មុំនោះហើយ ទៅកាន់ឧទ្យាន យកទឹកឃ្មុំលាបចុងស្មៅទាំងឡាយ ក្នុងទីដែលម្រឹគស្មាន់ត្រាច់ទៅ ។ ម្រឹគស្មាន់មកស៊ីស្មៅដែលលាបដោយទឹកឃ្មុំ ជាប់ក្នុងរសតណ្ហា មិនទៅទីដទៃ មកចំពោះឧទ្យានប៉ុណ្ណោះ ។ នាយឧទ្យានបាលដឹងថា ម្រឹគស្មាន់នោះជាប់ចិត្តក្នុងស្មៅ ដែលលាបដោយទឹកឃ្មុំ ទើបបង្ហាញខ្លួនឲ្យឃើញដោយលំដាប់ ។ ម្រឹគស្មាន់នោះ ឃើញនាយឧទ្យានបាលនោះ ២-៣ ថ្ងៃ ដំបូងក៏គេចទៅ លុះឃើញរឿយៗ ទើបស្និទ្ធស្នាល ស៊ីស្មៅដែលនៅក្នុងដៃរបស់នាយឧទ្យានបាលបានដោយលំដាប់ ។ នាយឧទ្យានបាលដឹងថា ម្រឹគស្មាន់នោះស្និទ្ធស្នាលហើយ ទើបយកកន្ទេលផែនដាក់សងខាងផ្លូវ រហូតដល់ព្រះរាជនិវេសន៍ ហើយយកមែកឈើដោតក្នុងទី

នោះៗ ស្ដាយឃ្លោកដាក់ទឹកឃ្មុំ កាន់បាច់ស្មៅ ហើយបាចស្មៅដែលលាប ដោយទឹកឃ្មុំខាងមុខម្រឹគ បានទៅខាងក្នុងព្រះរាជនិវេសន៍នោះឯង ។ កាល ម្រឹគចូលទៅខាងក្នុងហើយ ទើបមនុស្សទាំងឡាយបិទទ្វារ ម្រឹគឃើញមនុស្ស ទាំងឡាយ មានខ្លួនញ័របំប្រប់ ខ្លាចចំពោះមរណភ័យ រត់ច្រូច្រាទៅមកខាង ក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាចុះពីប្រាសាទ ទតឃើញម្រឹគនោះមានខ្លួន ញ័ររន្ធត់ ទើបត្រាស់ថា ធម្មតាម្រឹគតែងមិនទៅកាន់ទីដែលមនុស្សឃើញអស់ ៧ ថ្ងៃ រមែងមិនទៅកាន់ទីដែលត្រូវគំរាមអស់មួយជីវិត ម្រឹគស្មាន់អាស្រ័យ ព្រៃស្ពុកបែបនេះ ត្រូវចងដោយចំណង់ក្នុងរស មកកាន់ទីបែបនេះ ក្នុងឥឡូវ នេះ អ្នកដ៏ចម្រើនទាំងឡាយ ឈ្មោះថា វត្ថុដែលលាមកជាងចំណង់ក្នុងរស រមែងមិនមានក្នុងលោកហ្ន៎ ហើយទ្រង់ផ្ដើមតាំងធម្មទេសនាដោយគាថានេះថា

> ធន្ធរាគ ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំង
> ឡាយ ជាសភាវៈលាមកជាងធន្ធរាគ ដោយរសទាំងឡាយ មិន
> មានទេ ឧយ្យានបាលឈ្មោះសញ្ជ័យបាននាំសត្វឈ្លូស ដែល
> អាស្រ័យនៅព្រៃស្បាត មកកាន់អំណាច ( របស់ខ្លួន ) បាន
> ព្រោះតែរូបទាំងឡាយ ដូច្នេះ ។

សព្ទថា **កិរ** ក្នុងគាថានោះ ជានិបាត ប្រើក្នុងអត្ថថា បានឮ បានស្ដាប់ ។ បទថា **រសេហិ** សេចក្ដីថា ជាងរសផ្អែម និងរសជូរជាដើម ដែលគប្បីដឹង ដោយអណ្ដាត ។ បទថា **ធាបិយោ** បានដល់ អាក្រក់ជាង ។ បទថា **អាវាសេហិ វា សណ្ឋវេហិ វា** សេចក្ដីថា តម្រេកដោយអំណាចការពេញ

ចិត្តក្នុងលំនៅ ពោល គឺលំនៅជាប្រចាំក្តី ការស្និទ្ធស្នាលដោយអំណាចភាពជាមិត្រក្តី លាមកពិត តែរសក្នុងការបរិភោគដែលប្រព្រឹត្តទៅដោយឆន្ទរាគៈនោះឯង ជាសភាពអាក្រក់ជាង ជាងទីលំនៅ ជាងការស្និទ្ធស្នាល ដោយភាពជាមិត្រ ដែលមានការបរិភោគដោយឆន្ទរាគៈទាំងនេះ ១០០ ដង ១០០០ ដង ព្រោះអត្ថថា សេពចំពោះជាប្រចាំ និងព្រោះរៀរអាហារ ការរក្សាជីវិតិន្ទ្រិយក៏មិនមាន ព្រះពោធិសត្វធ្វើសេចក្តីនេះ ឲ្យដូចម្រឹគដែលតាមមកដោយល្អទើបត្រាស់ថា ឆន្ទរាគដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគ ដោយរសទាំងឡាយមិនមានទេ ដូច្នេះ ។ ឥឡូវនេះ ព្រះពោធិសត្វ កាលសម្តែងថា រសទាំងនោះអាក្រក់ជាង ទើបត្រាស់ពាក្យជាដើមថា **វាតមិគំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **គហននិស្សិតំ** បានដល់ អាស្រ័យព្រៃស្តុក លោកអធិប្បាយថា អ្នកទាំងឡាយ ចូរមើលភាពដែលរសទាំងឡាយជាសភាវៈអាក្រក់ជាង សញ្ជ័យឧទ្យានបាលនាំម្រឹគស្ទាន់នេះ ដែលអាស្រ័យនៅក្នុងព្រៃស្តុក ក្នុងដងព្រៃមកកាន់អំណាចរបស់ខ្លួនដោយរសទឹកឃ្មុំ វត្ថុដទៃដែលអាក្រក់ជាង គឺលាមកជាង ឈ្មោះថា អាក្រក់ជាងរសទាំងឡាយដែលមានការបរិភោគដោយឆន្ទរាគៈ រមែងមិនមាន ដោយប្រការទាំងពួង ។ ព្រះពោធិសត្វត្រាស់ទោសនៃតណ្ហាក្នុងរស ដោយប្រការដូច្នេះ កាលត្រាស់រួចហើយ ទើបទ្រង់បញ្ជូនម្រឹគនោះទៅកាន់ព្រៃនោះឯង ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងវណ្ណទាសីចងភិក្ខុនោះ ដោយតណ្ហាក្នុងរស ធ្វើទុកក្នុងអំណាចរបស់ខ្លួន ក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏បានធ្វើហើយដូចគ្នា កាលទ្រង់នាំធម្មទេសនា នេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា សញ្ជ័យក្នុងកាលនោះ បានមក ជានាងវណ្ណទាសីក្នុងកាលឥឡូវនេះ ម្រឹគស្មាន់ក្នុងកាលនោះ បានមកជាចូឡ- បិណ្ឌបាតិកភិក្ខុ ឯព្រះបាទពារាណសី ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

## អដ្ឋកថា វាតមិគជាតក ចប់

# សុត្តន្តបិដក

## ខរាទិយជាតក

[ ១៥ ] ( ម្រឹគពោធិសត្វពោលថា ) ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចគល់ និងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលនៃដំបូន្មាន ៧ នោះបានឡើយ ។

*ខរាទិយជាតកទី ៥ ចប់*

# អដ្ឋកថា

## ខរាទិយជាតក

[ ១៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អដ្ឋក្ខុរំ ខរាទិយេ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ប្រដៅក្រ មិនទទួលឱវាទ ។ លំដាប់នោះ ព្រះមុនីបានត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកប្រដៅក្រ មិនទទួលឱវាទពិតឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយ ។ ព្រះសាស្តាត្រាស់ថា ក្នុងកាលមុន អ្នកក៏មិនទទួលឱវាទរបស់បណ្ឌិតទាំងឡាយព្រោះជាអ្នកប្រដៅក្រ ទើបជាប់អន្ទាក់ ដល់នូវការអស់ជីវិត ហើយទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វជាម្រឹគ ចោមរោមដោយពួកម្រឹគដែលនៅក្នុងព្រៃលំដាប់នោះ ម្រឹគដែលជាប្អូនស្រីរបស់ម្រឹគនោះ បង្ហាញកូនតូច ហើយឲ្យទទួលយកដោយពាក្យថា បពិត្របងប្រុស នេះជាក្មួយរបស់បង សូមបងបង្រៀនមាយាម្រឹគណាមួយ ។ ម្រឹគនោះ ពោលនឹងក្មួយនោះថា ក្នុងពេលឈ្មោះនោះ ចូរមករៀនយក ម្រឹគដែលជាក្មួយមិនមកតាមកាលដែលពោលកន្លងទៅ ៧ ថ្ងៃ ដូចមួយថ្ងៃ ម្រឹគដែលជាក្មួយនោះ មិនបានរៀនមាយារបស់ម្រឹគត្រាច់ទៅ ទើបជាប់អន្ទាក់ ចំណែកមេរបស់ម្រឹគនោះ ចូលទៅរកម្រឹគដែលជាបងប្រុស ហើយសួរថា បពិត្របង បងឲ្យក្មួយរៀនមាយាម្រឹគហើយ

ឬ ព្រះពោធិសត្វពោលថា នាងកុំទោមនស្សចំពោះកូនដែលមិនទទួលពាក្យប្រៀនប្រដៅនោះ កូនរបស់នាងមិនរៀនយកមាយាម្រឹគខ្លួនឯង ជាអ្នកមិនមានបំណងទទួលឱវាទនោះឡើយ ក្នុងឥឡូវនេះ ទើបពោលគាថានេះថា

ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មាន
ស្នែងវៀចគល់ និងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលនៃ
ជំបូន្មាន ៧ នោះបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋក្ខុរំ** បានដល់ ក្រចក ៨ ដោយជើងនីមួយៗ មានក្រចក ២ ។ ព្រះពោធិសត្វហៅម្រឹគនោះ ដោយឈ្មោះថា ខរាទិយា ។ បទថា **មិគំ** ជាពាក្យកាន់យកម្រឹគគ្រប់ប្រភេទ ។ បទថា **វង្កាតិវង្កិនំ** បានដល់ វៀចក្រៃលែងជាងវៀច គឺវៀចតាំងអំពីគល់ រហូតដល់ចុង ឈ្មោះថា មានស្នែងវៀចអំពីគល់រហូតដល់ចុង ព្រោះម្រឹគនោះមានស្នែងដូច្នោះ ទើបឈ្មោះថា ស្នែងវៀចតាំងអំពីគល់រហូតដល់ចុង គឺមានស្នែងវៀចតាំងអំពីគល់រហូតដល់ចុងនោះ ។ បទថា **សត្តកាលេហាតិក្កន្តំ** បានដល់ កន្លងនូវឱវាទ ដោយកាលដែលជាឱវាទអស់ ៧ ថ្ងៃ ។ ដោយបទថា **ន នំ ឱវទិតុស្សហេ** នេះ លោកសម្ដែងថា អញមិនអាចទូន្មានម្រឹគដែលប្រដៅក្រនេះ ការគិតដើម្បីទូន្មានម្រឹគនេះ ក៏មិនកើតឡើងដល់អញ ។

គ្រានោះ ព្រានសម្លាប់ម្រឹគដែលប្រដៅក្រជាប់អន្ទាក់នោះ កាន់យកតែសាច់ ហើយទៅ ។

ឯព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកជាអ្នកប្រដៅក្រ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រដៅក្រដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា ម្រឹគដែលជាក្មួយក្នុងកាលនោះ បានជាភិក្ខុដែលប្រដៅក្រក្នុងកាលឥឡូវនេះ ម្រឹគដែលជាប្អូនស្រីក្នុងកាលនោះ បានជាឧប្បលវណ្ណា ឯម្រឹគដែលឲ្យឱវាទក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ខរាទិយជាតក ចប់**

# សុត្តន្តបិដក

## តិបល្លត្ថមិគជាតក

[ ១៦ ] ( ម្រឹគពោធិសត្វពោលថា ) អញបានញុំាងម្រឹគមានដំណោក ៣ មានក្របក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយ បានដកដង្ហើមខ្ជប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត ( ព្រានព្រៃ ) ដោយកល ៦ យ៉ាង ។

*តិបល្លត្ថមិគជាតកទី ៦ ចប់*

# អដ្ឋកថា

## តិបល្លត្ថមិគជាតក

[ ១៦ ] ព្រះសាស្តា កាលគង់នៅក្នុងពទរិការាម នគរកោសម្ពី ទ្រង់ប្រារព្ធរាហុលត្ថេរដែលប្រាថ្នាចំពោះការសិក្សា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មិគំ តិបល្លត្ថំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យមួយ កាលព្រះសាស្តាចូលទៅអាស្រ័យក្រុងអាឡវី គង់នៅក្នុងអគ្គាឡវចេតិយ ឧបាសក ឧបាសិកា ភិក្ខុ និងភិក្ខុនីជាច្រើន ទៅកាន់វិហារដើម្បីស្តាប់ធម៌ ។ ពេលថ្ងៃ មានការស្តាប់ធម៌ កាលកន្លងទៅ ឧបាសិកា និងភិក្ខុនីទាំងឡាយមិនទៅ មានតែពួកភិក្ខុ និងឧបាសកទាំងឡាយ តាំងអំពីនោះ ទើបកើតមានការស្តាប់ធម៌នៅពេលយប់ ក្នុងពេលចប់ការស្តាប់ធម៌ ភិក្ខុទាំងឡាយដែលជាថេរៈ នាំគ្នាទៅកាន់លំនៅរៀងៗ ខ្លួន ភិក្ខុកំលោះ និងពួកឧបាសក ដេកត្រង់ឧបដ្ឋានសាលា គឺរោងឆាន់ ។ កាលពួកភិក្ខុកំលោះ និងពួកឧបាសកទាំងនោះចូលដល់នូវការនិទ្រា អ្នកខ្លះដេកស្រមុក ខ្លះដេកសង្កៀតធ្មេញ ខ្លះដេកមួយស្របក់ក្រោកឡើង ។ ពួកឧបាសកឃើញអាការចម្លែករបស់ភិក្ខុកំលោះ ទើបក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះហើយ យាងទៅកាន់នគរកោសម្ពី ។ ក្នុងការដែលទ្រង់បញ្ញត្តសិក្ខាបទនោះ ទើបភិក្ខុទាំងឡាយពោលនឹងរាហុលថា អាវុសោរាហុល ព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទហើយ ឥឡូវនេះ ចូរអ្នកដឹងលំនៅរបស់ខ្លួន ។ កាលមុន ភិក្ខុទាំងឡាយបានសង្គ្រោះព្រះរាហុលនោះ

ដែលមកកាន់លំនៅរៀងៗ ខ្លួន យ៉ាងល្អ ព្រោះអាស្រ័យសេចក្តីគោរពក្នុងព្រះសាស្តា និងភាពដែលព្រះរាហុលនោះប្រាថ្នាចំពោះការសិក្សា បានក្រាលគ្រែតូច ឲ្យចីវរដើម្បីកើយ តែថ្ងៃនោះ សូម្បីតែលំនៅ ក៏មិនបានឲ្យ ព្រោះខ្លាចចំពោះសិក្ខាបទ ។ ឯព្រះរាហុលកន្លួ ក៏មិនទៅកាន់សម្នាក់របស់ព្រះទសពល ដោយគិតថា ជាព្រះបិតារបស់អញ ឬរបស់ព្រះធម្មសេនាបតី ដោយគិតថា ជាឧបជ្ឈាយ៍របស់អញ ឬទៅកាន់សម្នាក់របស់ព្រះមហាមោគ្គល្លាន ដោយគិតថា ជាអាចារ្យរបស់អញ ឬទៅកាន់សម្នាក់ព្រះអានន្ទ ដោយគិតថា ជាឪពុកមារបស់អញ បានចូលទៅកាន់វច្ចកុដិ សម្រាប់បន្ទោបង់របស់ព្រះទសពល ដូចចូលទៅកាន់វិមានរបស់ព្រហ្ម សម្រេចការនៅហើយ ។ ទ្វារកុដិសម្រាប់ប្រើប្រាស់របស់ព្រះពុទ្ធទាំងឡាយដែលបិទជិតនោះ ធ្វើការប្រោះព្រំដោយផែនក្រអូប និងកម្រងផ្កាសំយុងចុះ អុជប្រទីបមួយយប់ទល់ភ្លឺ ។ ព្រះរាហុលកន្លួអាស្រ័យសម្បត្តិនេះរបស់កុដិនោះ ទើបចូលទៅក្នុងកុដិនោះ ។ ម្យ៉ាងទៀត ព្រោះភិក្ខុទាំងឡាយពោលថា ចូរអ្នកដឹងលំនៅ និងព្រោះភាពជាអ្នកប្រាថ្នាចំពោះការសិក្សា ដោយគោរពក្នុងឱវាទ ទើបចូលទៅក្នុងកុដិនោះក្នុងចន្លោះៗ ភិក្ខុទាំងឡាយឃើញព្រះរាហុលនោះមកអំពីចម្ងាយ ដើម្បីសាកល្បងរាហុលនោះ ទើបចោលកាកសំណល់អំបោស ឬភាជនៈសម្រាប់ចាក់សំរាមខាងក្រៅ ។ កាលព្រះរាហុលមកដល់ ទើបពោលថា អាវុសោ អ្នកណាចោលវត្ថុនេះ ក្នុងការធ្វើនោះ កាលភិក្ខុពួកខ្លះពោលថា ព្រះរាហុលមកតាមផ្លូវនេះ ។ រាហុលនោះមិនពោលថា បពិត្រលោកដ៏ចម្រើន ខ្ញុំមិនដឹងរឿង

នេះ បែរជាទុកដាក់វត្ថុទាំងនោះ ហើយសូមខមាទោសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ អត់ទោសដល់ខ្ញុំ ហើយទៅ ។ ព្រះរាហុលនេះ ជាអ្នកស្រឡាញ់ចំពោះការសិក្សាយ៉ាងនេះ ។ ព្រះរាហុលនោះអាស្រ័យភាព ជាអ្នកប្រាថ្នាដល់ការសិក្សានោះឯង ទើបចូលទៅក្នុងកុដិនោះ ។

កាលមុនអរុណ ព្រះសាស្តាទ្រង់ឈរត្រង់ទ្វារវច្ចកុដិ ហើយទ្រង់ព្រះឧកាសិតៈ ( គ្រហែម ) ឯព្រះរាហុលក៏គ្រហែមតប ព្រះសាស្តាត្រាស់សួរថា អ្នកណានោះ ព្រះរាហុលក្រាបទូលថា ខ្ញុំព្រះអង្គរាហុល ហើយចេញមកថ្វាយបង្គំ ព្រះសាស្តាត្រាស់សួរថា រាហុល ព្រោះហេតុអ្វី ទើបអ្នកដេកទីនេះ ព្រះរាហុលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះមិនមានលំនៅ ព្រោះថា កាលមុន ភិក្ខុទាំងឡាយ ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំព្រះអង្គ ឥឡូវនេះ មិនឲ្យលំនៅ ព្រោះខ្លាចត្រូវអាបត្តិ ខ្ញុំព្រះអង្គគិតថា ទីនេះ ដែលមិនបៀតបៀនអ្នកដទៃ ដោយហេតុនោះ ទើបដេកក្នុងទីនេះ ។ សម័យនោះ ព្រះសាស្តាកើតនូវធម្មសង្វេគឡើងថា ខាងដើម ភិក្ខុទាំងឡាយលះបង់រាហុលយ៉ាងនេះ អំណឹះតទៅ ឲ្យពួកក្មេងក្នុងត្រកូលទាំងឡាយបួសហើយ នឹងធ្វើដូចម្តេច ។ គ្រានោះ ព្រះសាស្តាឲ្យភិក្ខុទាំងឡាយប្រជុំគ្នាអំពីព្រលឹម ត្រាស់សួរព្រះធម្មសេនាបតីថា ម្នាលសារីបុត្ត អ្នកដឹងទេថា ថ្ងៃនេះ រាហុលនៅឯណា ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ថ្ងៃនេះ រាហុលនៅត្រង់វច្ចកុដិ ម្នាលសារីបុត្ត អ្នកទាំងឡាយបោះបង់រាហុលបានយ៉ាងនេះ អំណឹះតទៅ ឲ្យក្មេង

ក្នុងត្រកូលទាំងឡាយបួសហើយ នឹងធ្វើដូចម្តេច កាលបើដូច្នោះ កុលបុត្រដែលបួសក្នុងសាសនានេះ នឹងជាបុគ្គលមិនមានទីពឹង ឥឡូវនេះ តាំងអំពីនេះទៅ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នកទាំងឡាយសម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្នអស់ ២ យប់ ឬ ៣ យប់បាន ដូច្នេះ ក្នុងថ្ងៃទី ៣ ដឹងលំនៅរបស់អនុបសម្បន្នទាំងនោះហើយ ចូរឲ្យនៅខាងក្រៅហើយទ្រង់បញ្ញត្តសិក្ខាបទទៀត ទ្រង់ធ្វើឲ្យជាអនុប្បញ្ញត្តក្នុងសេចក្តីនេះ ។

សម័យនោះ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នា ក្នុងរោងធម្មសភា ហើយពោលគុណរបស់ព្រះរាហុលថា មើលចុះអាវុសោទាំងឡាយ រាហុលនេះប្រាថ្នាចំពោះការសិក្សាជាកំណត់ ឈ្មោះថា ត្រូវភិក្ខុទាំងឡាយពោលថា អ្នកចូរដឹងលំនៅរបស់អ្នក ក៏មិនធ្លើយ សូម្បីនឹងភិក្ខុមួយរូបថា ខ្ញុំជាឱរសរបស់ព្រះទសពល អ្នកទាំងឡាយជានរណា ចូរពួកលោកចេញទៅ ដូច្នេះហើយបានសម្រេចការនៅក្នុងវច្ចកុដិ កាលភិក្ខុទាំងនោះ នាំគ្នាពោលយ៉ាងនេះ ព្រះសាស្តាចូលទៅកាន់រោងធម្មសភា គង់លើអាសនៈដែលគេក្រាល ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ អង្គុយនិយាយគ្នាដោយសិក្ខាកាមកថា ពោលអំពីការប្រាថ្នាចំពោះការសិក្សារបស់ព្រះរាហុល មិនមែនដោយរឿងដទៃឡើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នកប្រាថ្នាចំពោះការសិក្សា តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន កើតក្នុងកំណើតតិរច្ឆាន

ក៏ជាអ្នកប្រាប់ចំពោះការសិក្សាដូចគ្នា ហើយទ្រង់នាំអតីតនិទានមកដូចតទៅ

ក្នុងអតីតកាល ព្រះបាទមគធរាជមួយអង្គ គ្រងរាជសម្បត្តិ នៅក្នុងនគររាជគ្រឹះ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគដែលពួកម្រឹគចោមរោមនៅក្នុងព្រៃ ។ សម័យនោះ មេម្រឹគដែលជាប្អូនស្រីរបស់ព្រះពោធិសត្វនោះ នាំកូនតូចរបស់ខ្លួនចូលទៅរកហើយ ពោលថា បពិត្របង សូមបងឲ្យក្មួយរបស់បងនេះសិក្សានូវមាយារបស់ម្រឹគ ។ ព្រះពោធិសត្វទទួលពាក្យហើយពោលថា នែបា ចូរបាទៅក្នុងពេលឈ្មោះនោះ ចូរមកសិក្សា ។ ម្រឹគដែលជាក្មួយនោះ មិនកន្លងពេលដែលអ៊ំប្រាប់ ចូលទៅរកអ៊ំនោះ ហើយសិក្សាមាយារបស់ម្រឹគ ។ ថ្ងៃមួយ ម្រឹគនោះត្រាច់ទៅក្នុងព្រៃ ជាប់អន្ទាក់ ទើបស្រែកប្រាប់ឲ្យដឹងថា ខ្លួនជាប់អន្ទាក់ ពួកម្រឹគនាំគ្នាទៅប្រាប់ដល់មេរបស់ម្រឹគនោះថា កូនរបស់នាងជាប់អន្ទាក់ ។ មេម្រឹគនោះទៅកាន់សម្នាក់បងប្រុស រួចសួរថា បងឲ្យក្មួយសិក្សាមាយារបស់ម្រឹគហើយឬ ព្រះពោធិសត្វពោលថា នាងកុំរង្កៀសកម្មដ៏លាមកណាមួយរបស់កូននាងឡើយ អញឲ្យកូនរបស់នាងសិក្សាមាយារបស់ម្រឹគល្អហើយ បន្តិចទៀត កូនរបស់នាង នឹងលះបង់អន្ទាក់នោះ ហើយគេចទៅ នឹងត្រឡប់មក ហើយពោលគាថានេះថា

អញបានញុំាងម្រឹគមានដំណោក ៣ មានក្រចក ៨ ជាសត្វផឹកទឹក
ក្នុងពេលអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយបានដក
ដង្ហើមខ្ទប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត ( ព្រានព្រៃ )
ដោយកល ៦ យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគំ** បានដល់ ម្រឹគដែលជាក្មួយ ។ បទថា **តិបល្លត្ថំ** សេចក្តីថា ការដេក ហៅថា **បល្លត្ថ** ឈ្មោះថា មានការដេក ៣ បែប ព្រោះមានការដេកដោយអាការ ៣ យ៉ាង គឺដោយចំហៀង ទាំងសង ខាង និងដោយអាការដូចគោដេក គឺពោះចុះក្រោម ម្យ៉ាងទៀត ព្រោះមាន ការដេក ៣ បែប ។ នូវម្រឹគនោះដែលមានការដេក ៣ បែប ។ បទថា **អនេកមាយំ** បានដល់ មានមាយាច្រើន គឺមានការបោកបញ្ឆោតច្រើន ។ បទថា **អដ្ឋក្ខុរំ** បានដល់ ប្រកបដោយក្រចក ៨ ដោយជើងនីមួយៗ មាន ក្រចក ២ ។ បទថា **អឌ្ឍរត្តាបចាយឹ** សេចក្តីថា ម្រឹគ ឈ្មោះថា ផឹក ទឹកក្នុងកណ្តាលយប់ ព្រោះរំលងយាមមួយទៅហើយ ក្នុងមជ្ឈិមយាម ទើប មកអំពីព្រៃ ហើយផឹកទឹក ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកផឹកទឹកក្នុង កណ្តាលរាត្រី ។ នូវម្រឹគនោះ ។ អធិប្បាយថា ម្រឹគដែលផឹកទឹកក្នុងពេល យប់ ។ អញឲ្យម្រឹគដែលជាក្មួយប្រុសរបស់អញ រៀនមាយារបស់ម្រឹគល្អ ហើយ ។ សួរថា ឲ្យរៀនដូចម្តេច ។ ឆ្លើយថា នែប្អូនស្រី អញឲ្យរៀន ដោយប្រការដែលម្រឹគជាក្មួយប្រុស ដកដង្ហើមត្រង់ផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោតនាយព្រានដោយកល ៦ ប្រការ ។ លោកអធិប្បាយថា អញឲ្យកូន របស់នាងរៀនយកហើយ ដោយប្រការដែលម្រឹគជាក្មួយប្រុសអត់ដង្ហើមក្នុង រន្ធច្រមុះខាងលើ ហើយដកដង្ហើមត្រង់រន្ធច្រមុះដែលជាប់នឹងផែនដីនោះឯង ដោយរន្ធច្រមុះខាងក្រោមដែលជាប់នឹងផែនដី ទើបគ្របសង្កត់ អធិប្បាយថា ទើបបញ្ឆោតនាយព្រានដោយកល ៦ ប្រការ គឺដោយចំណែក ៦ ។ កល ៦

ប្រការដូចម្ដេច កល ៦ ប្រការ គឺដោយការសណ្ដូកជើង ៤ ដេកផ្អៀង ១ ដោយប្រើក្រចកទាំងឡាយកាយស្មៅ និងដីផង់ ១ ដោយធ្វើអណ្ដាតលៀនចេញមក ១ ដោយធ្វើឲ្យពោះធំ ១ ដោយបន្ទោបង់ឧច្ចារបស្សាវៈហៀរចេញមក ១ ដោយការអត់ដង្ហើម ១ ។ មួយវិញទៀត លោកសម្ដែងថា នែប្អូនស្រី អញឲ្យម្រឹគក្ខុយនោះរៀនមាយារបស់ម្រឹគ ដោយប្រការដែលគេបោកបញ្ឆោតឲ្យព្រានសម្គាល់ថា ម្រឹគនេះស្លាប់ហើយ ដោយកល ៦ ប្រការនេះ គឺដោយកាយយកកម្ទេចដីមកដាក់ត្រង់មុខ ១ ដោយការបង្អោនខ្លួនទៅ ១ ដោយការដែលបម្រះទៅទាំងសងខាង ១ ដោយធ្វើពោះឲ្យហើម ១ ដោយធ្វើពោះឲ្យផត ១ ។ មួយវិញទៀត អញឲ្យម្រឹគក្ខុយនោះរៀនយកហើយ ដោយប្រការដែលម្រឹគក្ខុយនោះដកដង្ហើមត្រង់ផែនដីដោយរន្ធច្រមុះម្ខាង ធ្វើកលដោយល្បិច ៦ ប្រការ គឺធ្វើកលដោយហេតុ ៦ ប្រការ ដែលបានសម្ដែងក្នុងន័យទាំង ២ អធិប្បាយថា នឹងធ្វើល្បិចកល គឺនឹងបញ្ឆោតនាយព្រាន ។ ព្រះពោធិសត្វហៅម្រឹគដែលជាប្អូនស្រីថា **ភោតិ** ប្រែថា នាងដ៏ចម្រើន ។ ដោយបទថា **ភាគិនេយ្យោ** នេះ ព្រះពោធិសត្វសំដៅដល់ម្រឹគដែលជាក្មួយប្រុស បញ្ឆោតដោយហេតុ ៦ ប្រការ ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វ កាលសម្ដែងភាពដែលម្រឹគក្មួយប្រុសរៀនមាយារបស់ម្រឹគល្អហើយ ទើបលួងលោមម្រឹគ ដែលជាប្អូនស្រីឲ្យធូរស្រាលចិត្ត ដោយប្រការដូច្នេះ ។ កូនម្រឹគនោះជាប់អន្ទាក់ មិនបម្រះនទៀលឡើយ ដេកសណ្ដូកជើងទាំង ៤ ទៅកាន់ទិសដែលជាផាសុកច្រើន ត្រង់ផែនដី យកក្រចកទាំង

ឡាយនោះឯង កាយក្នុងទីជិតៗ ដោយជើងទាំង ៤ ធ្វើដី និងស្មៅឲ្យខ្ពាយឡើង បន្ទោបង់ឧច្ចារបស្សាវៈចេញមក ធ្វើឲ្យក្បាលសំយុងចុះ អណ្តាតលៀនចេញ ធ្វើសរីរៈឲ្យប្រឡាក់ដោយទឹកមាត់ ធ្វើឲ្យខ្លួនហើមប៉ោងដោយខ្យល់ ធ្វើភ្នែកទាំង ២ ឲ្យលៀន ធ្វើខ្យល់ឲ្យដើរក្នុងរន្ធច្រមុះខាងក្រោម អត់ដង្ហើមក្នុងរន្ធច្រមុះខាងលើ ធ្វើខ្លួនឲ្យរឹង សម្តែងអាការរបស់ម្រឹគដែលស្លាប់ហើយ ឯរុយខៀវក៏រោមម្រឹគនោះ ក្អែកទាំងឡាយនាំគ្នាមកក្បែរទីនោះ នាយព្រានយកដៃទះពោះ គិតថា ម្រឹគជាប់អន្ទាក់ពីព្រឹកពេក ទើបស្អុយ ក៏ស្រាយខ្សែម្រឹគនោះចេញ គិតថា អញនឹងពន្លះម្រឹគនេះក្នុងទីនេះឯង យកតែសាច់ទៅ ជាអ្នកមិនសង្ស័យ ទើបដើររកមែកឈើ និងស្លឹកឈើ ។ ឯកូនម្រឹគក្រោកឡើងឈរដោយជើងទាំង ៤ រលាស់កាយ អើតក ហើយបានទៅកាន់សម្នាក់របស់មេ ដោយរហ័ស ដូចដុំពពកត្រូវខ្យល់ព្យុះធំបក់ទៅ ដូច្នោះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នកប្រាថ្នាចំពោះការសិក្សាក្នុងឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏ជាអ្នកស្រឡាញ់ចំពោះការសិក្សាដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមក បន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា កូនម្រឹគជាក្មួយក្នុងកាលនោះ បានមកជារាហុលក្នុងកាលឥឡូវនេះ ឯមេម្រឹគក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា ម្រឹគដែលជាអាក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា តិបល្លត្ថមិគជាតក ចប់**

# សុត្តន្តបិដក

## មាលុតជាតក

[ ១៧ ] ( ឥសីពោធិសត្វពោលថា ) កាលណា ខ្យល់បក់ ទោះខាងរនោចក្តី ខាងខ្នើតក្តី កាលនោះ ត្រជាក់ទាំងឡាយ ក៏កើតអំពីខ្យល់ អ្នកទាំងពីរ មិនចាល់ចាញ់ក្នុងប្រស្នានេះឡើយ ។

**មាលុតជាតកទី ៧ ចប់**

# អដ្ឋកថា

## មាលុតជាតក

[ ១៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធបព្វជិតដែលបួសឯចាស់ ២ រូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាឡេ វា យទិ វា ជុណ្ហេ** ដូច្នេះជាដើម ។

បានឮថា បព្វជិត ២ រូបនោះ នៅក្នុងព្រៃមួយកន្លែងក្នុងកោសលជនបទ មួយរូបឈ្មោះកាឡត្ថេរ មួយរូបឈ្មោះជុណ្ហត្ថេរ ។ សម័យថ្ងៃមួយ ព្រះជុណ្ហៈសួរព្រះកាឡៈថា បពិត្រលោកម្ចាស់កាឡៈ ធម្មតារងាមានក្នុងកាលណា ព្រះកាឡៈនោះពោលថា រងាមានក្នុងកាលខាងរនោច ។ ថ្ងៃមួយ ព្រះកាឡៈសួរព្រះជុណ្ហៈថា បពិត្រលោកម្ចាស់ជុណ្ហៈ ធម្មតារងាមានក្នុងពេលណា ព្រះជុណ្ហៈពោលថា មានក្នុងខាងខ្នើត ព្រះថេរៈទាំង ២ រូប មិនអាចកាត់សេចក្តីសង្ស័យរបស់ខ្លួនបាន ទើបនាំគ្នាទៅកាន់សម្នាក់របស់ព្រះបរមសាស្តា ថ្វាយបង្គំហើយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតារងាមានក្នុងពេលណា ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំង ២ នោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន តថាគតក៏ឆ្លើយបញ្ហានេះដល់អ្នកទាំង ២ ហើយ តែអ្នកទាំងឡាយកំណត់មិនបាន ព្រោះនៅក្នុងសង្ខេបនៃភព ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល នាជើងភ្នំមួយ មានសត្វដែលជាសម្លាញ់នឹងគ្នា ២ គឺរាជសីហ៍ ១ ខ្លាធំ ១ នៅក្នុងគុហាជាមួយគ្នានោះឯង កាលនោះ ព្រះពោធិសត្វបួសជាឥសីនៅត្រង់ជើងភ្នំនោះដូចគ្នា ថ្ងៃមួយ វិវាទកើតឡើងដល់អ្នក

ទាំងនោះ ព្រោះអាស្រ័យការរនោ ខ្លាធំពោលថា រនោមានក្នុងរនោច រាជសីហ៍ពោលថា មានខាងខ្នើត ។ សម្លាញ់ទាំង ២ នោះ កាលមិនអាចកាត់នូវសេចក្ដីសង្ស័យរបស់ខ្លួន ទើបសួរព្រះពោធិសត្វ ព្រះពោធិសត្វបានពោលគាថានេះថា

កាលណា ខ្យល់បក់ ទោះខាងរនោចក្ដី ខាងខ្នើតក្ដី កាលនោះ ត្រជាក់ទាំងឡាយ ក៏កើតអំពីខ្យល់ អ្នកទាំងពីរ មិនចាលចាញ់ក្នុងប្រស្នានេះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាឡេ វា យទិ វា ជុណ្ហេ** បានដល់ ក្នុងបក្ខខាងរនោចក្ដី ក្នុងបក្ខខាងខ្នើតក្ដី ។ បទថា **យទា វាយតិ មាលុតោ** សេចក្ដីថា សម័យណា ខ្យល់ដែលផ្សេងគ្នាដោយខ្យល់ទិសខាងកើតជាដើម រមែងបក់មក សម័យនោះ រនោរមែងមាន ។ ព្រោះហេតុអ្វី ព្រោះរនោកើតពីខ្យល់ អធិប្បាយថា ព្រោះហេតុដែលមានខ្យល់នោះឯង ទើបរនោមាន ។ ក្នុងសេចក្ដីនេះ បក្ខខាងរនោច ឬបក្ខខាងខ្នើត មិនជាប្រមាណ ។ បទថា **ឧភោត្ថមបរាជិតា** សេចក្ដីថា អ្នកទាំង ២ មិនចាញ់គ្នាក្នុងប្រស្នានេះ ។

ព្រះពោធិសត្វឲ្យសម្លាញ់ទាំងនោះយល់ព្រម ដោយប្រការយ៉ាងនេះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏ឆ្លើយបញ្ហានេះដល់អ្នកទាំងឡាយហើយ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ

ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ព្រះថេរៈទាំង ២ នោះ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តា ទ្រង់បន្តអនុសន្ធិ ហើយប្រជុំជាតកថា ខ្លាធំក្នុងកាលនោះ បានមកជាកាឡុត្ថេរ ក្នុងកាលឥឡូវនោះ រាជសីហ៍ក្នុងកាលនោះ បានជាជុណ្ហត្ថេរ តាបសដែលឆ្លើយបញ្ហាក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា មាលុតជាតក ចប់**

# សុត្តន្តបិដក

## មតកភត្តជាតក

[ ១៨ ] *( រុក្ខទេវតាពោធិសត្វពោលថា ) បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក ។*

***មតកភត្តជាតកទី ៨ ចប់***

# អដ្ឋកថា

## មតកភត្តជាតក

[ ១៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធមតកភត្ត ទើបផ្តើមព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯវញ្ចេ សត្តា ជានេយ្យុំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ មនុស្សទាំងឡាយសម្លាប់ពពែជាដើមជាច្រើន ឲ្យមតកភត្ត ឧទ្ទិសដល់ញាតិទាំងឡាយដែលស្លាប់ទៅហើយ ភិក្ខុទាំងឡាយឃើញមនុស្សទាំងនោះធ្វើយ៉ាងនោះ ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ មនុស្សទាំងឡាយធ្វើសត្វមានជីវិតជាច្រើនឲ្យដល់នូវការអស់ជីវិត ហើយឲ្យឈ្មោះថា មតកភត្ត សេចក្តីចម្រើនក្នុងការឲ្យមតកភត្តមានឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាសេចក្តីចម្រើនណាមួយ ក្នុងបាណាតិបាតដែលគេធ្វើ ដោយគិតថា ពួកយើងនឹងឲ្យមតកភត្ត ដូច្នេះ រមែងមិនមាន ក្នុងកាលមុន បណ្ឌិតទាំងឡាយអង្គុយក្នុងអាកាសសម្តែងធម៌ ពោលទោសក្នុងការធ្វើបាណាតិបាតនេះ ឲ្យមនុស្សក្នុងជម្ពូទ្វីបទាំងមូលលះនូវកម្មនោះ តែឥឡូវនេះ កម្មនោះប្រាកដឡើងទៀត ព្រោះសត្វទាំងឡាយនោះ ជាអ្នកនៅក្នុងសង្ខេបនៃភព ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី មានអាចារ្យទិសាបាមោក្ខ អ្នកសម្រេចវេទម្នាក់ គិតថា នឹងឲ្យមតកភត្ត ទើបឲ្យចាប់ពពែមួយក្បាល ពោលនឹងអន្តេវាសិកទាំងឡាយថា នែបាទាំងឡាយ

ចូរពួកអ្នកនាំពពែនេះទៅកាន់ស្ទឹង ឲ្យងូតទឹកហើយ យកកម្រងផ្កាពាក់ត្រង់ក តាក់តែងគ្រឿងអលង្ការ ហើយនាំមក ។ អន្តេវាសិកទាំងឡាយទទួលពាក្យ ហើយ នាំពពែនោះទៅកាន់ស្ទឹង ឈាងទឹក ប្រដាប់ហើយ ចងនៅត្រង់មាត់ ស្ទឹង ។ ពពែនោះ ឃើញកម្មចាស់របស់ខ្លួន កើតសោមនស្សថា អញនឹង ផុតចាកទុក្ខឈ្មោះនេះក្នុងថ្ងៃនេះ ទើបសើច ដូចវាយឆ្នាំងដី គិតថា ព្រាននេះ សម្លាប់អញហើយ នឹងបាននូវសេចក្តីទុក្ខដែលអញបានហើយ កើតករុណា ដល់ព្រាហ្មណ៍ ទើបយំដោយសំឡេងខ្លាំង ។ លំដាប់នោះ ទើបមាណពសួរ ពពែនោះថា នែសម្លាញ់ អ្នកសើចផង យំផង ដោយសំឡេងខ្លាំង ព្រោះ ហេតុអ្វីហ្ន៎ ទើបអ្នកសើច ហេតុអ្វី ទើបអ្នកយំ ។ ពពែពោលថា លោកទាំង ឡាយគប្បីសួរហេតុនេះនឹងខ្ញុំ ក្នុងសម្នាក់អាចារ្យរបស់លោក ទើបមាណព ទាំងនោះនាំពពែនោះទៅហើយ រួចប្រាប់ហេតុនោះដល់អាចារ្យៗ បានស្តាប់ ពាក្យរបស់មាណពទាំងនោះ ហើយសួរពពែថា នែពពែ ព្រោះហេតុអ្វី ទើប អ្នកសើច ព្រោះហេតុអ្វី ទើបអ្នកយំ ពពែរឭកដល់កម្មដែលខ្លួនធ្វើ ដោយ បុព្វេនិវាសានុស្សតិញ្ញាណ ពោលដល់ព្រាហ្មណ៍ថា លោកព្រាហ្មណ៍ កាល មុន ខ្ញុំជាព្រាហ្មណ៍ស្វាធ្យាយមន្ត ដូចលោកនោះឯង គិតថា នឹងឲ្យមតកភត្ត ទើបសម្លាប់ពពែមួយ ហើយឲ្យនូវមតកភត្ត ព្រោះខ្ញុំសម្លាប់ពពែមួយក្បាល ទើបខ្ញុំត្រូវគេកាត់ក្បាលអស់ ៤៩៩ អត្តភាព នេះជាអត្តភាពទី ៥០០ របស់ ខ្ញុំ ដែលតាំងនៅក្នុងទីបំផុត ខ្ញុំកើតសោមនស្សថា ថ្ងៃនេះ អញនឹងផុតទុក្ខ បែបនេះ ដោយហេតុនោះ ទើបសើច តែកាលខ្ញុំយំ បានយំព្រោះអាណិត

លោក ដោយគិតថា ពីមុន អញសម្លាប់ពពែមួយ ដល់នូវសេចក្ដីទុក្ខ គឺត្រូវកាត់ក្បាលអស់ ៥០០ ជាតិ នឹងផុតទុក្ខនោះក្នុងថ្ងៃនេះ ឯព្រាហ្មណ៍សម្លាប់ខ្ញុំហើយ នឹងបាននូវសេចក្ដីទុក្ខ គឺត្រូវកាត់ក្បាលអស់ ៥០០ ជាតិដូចខ្ញុំ ព្រាហ្មណ៍ពោលថា នែពពែ អ្នកកុំខ្លាចឡើយ អញនឹងមិនសម្លាប់អ្នក ពពែពោលថា បពិត្រលោកព្រាហ្មណ៍ លោកនិយាយអ្វី ទោះលោកសម្លាប់ក្ដី មិនសម្លាប់ក្ដី ខ្ញុំមិនអាចផុតសេចក្ដីស្លាប់ទៅបាន ។ ព្រាហ្មណ៍ពោលថា អ្នកកុំខ្លាចឡើយ អញនឹងថែរក្សាអ្នក ត្រាច់ទៅជាមួយអ្នកប៉ុណ្ណោះ ។ ពពែពោលថា បពិត្រព្រាហ្មណ៍ ការរក្សារបស់លោកមានប្រមាណតិច ឯបាបដែលខ្ញុំធ្វើមានកម្លាំងច្រើន ។ ព្រាហ្មណ៍ឲ្យលែងពពែហើយ ពោលថា យើងមិនឲ្យអ្នកណាមួយសម្លាប់ពពែនេះទេ ទើបនាំពួកអន្តេវាសិកត្រាច់ទៅជាមួយពពែនោះឯង ។ ពពែគ្រាន់តែលែងប៉ុណ្ណោះ ក៏អើតក បម្រុងស៊ីស្លឹកឈើដែលអាស្រ័យផ្ទាំងថ្មមួយកន្លែង ។ រំពេចនោះឯង រន្ទះក៏ធ្លាក់ចុះត្រង់ផ្ទាំងថ្មនោះ បំណែកថ្មមួយបែកធ្លាក់ត្រង់កពពែ ដែលកំពុងងើយកាត់ក្បាលដាច់ទៅ ។ មហាជនប្រជុំគ្នា ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតជារុក្ខទេវតាក្នុងទីនោះ ព្រះពោធិសត្វនោះ កាលមហាជន កំពុងឃើញនោះឯង អង្គុយពត់ភ្នែនក្នុងអាកាស ដោយទេវានុភាពពោលថា សត្វនោះ ត្រូវផលនៃបាបយ៉ាងនេះ បុគ្គលមិនគួរធ្វើបាណាតិបាត កាលនឹងសម្ដែងធម៌ដោយសំឡេងដ៏ពីរោះ បានពោលគាថានេះថា

បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំមក
នូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ
រមែងសោយសោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវញ្ចេ សត្តា ជានេយ្យុំ** សេចក្ដីថា សត្វទាំងនេះ គប្បីដឹងយ៉ាងនេះ ។ គប្បីដឹងដូចម្ដេច គប្បីដឹងថា ជាតិសម្ភពនេះជាទុក្ខ អធិប្បាយថា បើដឹងថា ការកើតក្នុងភពនោះៗ និងការសម្ភព ពោលគឺការចម្រើននៃបុគ្គលដែលកើតដោយលំដាប់នេះ ឈ្មោះថា ជាទុក្ខ ព្រោះជាវត្ថុទីតាំងនៃទុក្ខទាំងឡាយ មានជរា ព្យាធិ មរណៈ និងការជួបនូវវត្ថុមិនជាទីស្រឡាញ់ ការព្រាត់ប្រាសវត្ថុដែលជាទីស្រឡាញ់ និងការត្រូវកាត់ដៃ កាត់ជើងជាដើម ។ បទថា **ន ចាណោ ចាណិនំ ហញ្ញេ** សេចក្ដីថា សត្វណាមួយដឹងថា ជាតិសម្ភព ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខថា បុគ្គលធ្វើសត្វដទៃឲ្យចម្រើន រមែងបាននូវការចម្រើនក្នុងជាតិសម្ភព កាលបៀតបៀនសត្វដទៃ តែងបានទទួលការបៀតបៀន ដូច្នេះ ទើបមិនគួរសម្លាប់សត្វដទៃ អធិប្បាយថា សត្វមិនគួរសម្លាប់សត្វ ព្រោះហេតុអ្វី ព្រោះអ្នកមានប្រក្រតីសម្លាប់សត្វ រមែងសោយសោក អធិប្បាយថា ព្រោះបុគ្គលដែលមានប្រក្រតីសម្លាប់សត្វ ដោយការចូលទៅកាត់ជីវិតិន្ទ្រិយរបស់សត្វដទៃ ដោយប្រយោគឯណានីមួយ ក្នុងបណ្ដាប្រយោគទាំង ៦ មានសាហត្ថិកប្បយោគជាដើម សោយមហន្តទុក្ខក្នុងអបាយទាំង ៤ គឺក្នុងមហានរក ៨ រណ្ដៅ ក្នុងឧស្សទនរក ១៦ រណ្ដៅ ក្នុងកំណើតសត្វតិរច្ឆាន មានប្រការផ្សេងៗ ក្នុងបិត្តិ-

វិស័យ និងក្នុងអសុរកាយ ឈ្មោះថា រមែងសោយសោកដោយសេចក្ដីសោកដែលមានការដុតខាងក្នុងជាលក្ខណៈ អស់កាលយូរ ម្យ៉ាងទៀត សត្វដឹងថា ពពែនេះសោយសោកហើយ ព្រោះមរណភ័យ យ៉ាងណា បុគ្គលមានប្រក្រតីសម្លាប់សត្វ រមែងសោយសោកអស់កាលយូរ ក៏យ៉ាងនោះ ដូច្នេះហើយ មិនគួរសម្លាប់សត្វ អធិប្បាយថា បុគ្គលណាម្នាក់ មិនគួរធ្វើកម្ម គឺបាណាតិបាត បុគ្គលដែលវង្វេងព្រោះមោហៈ កាលអវិជ្ជាធ្វើឲ្យជាមនុស្សខ្វាក់ហើយ មិនឃើញទោសនេះ រមែងធ្វើបាណាតិបាត ។

ព្រះពោធិសត្វសម្ដែងធម៌ ដោយយកភ័យក្នុងនរកមកគំរាមដោយប្រការយ៉ាងនេះ មនុស្សទាំងឡាយស្ដាប់ធម្មទេសនានោះហើយ ខ្លាចភ័យក្នុងនរកនាំគ្នាវៀរចាកបាណាតិបាត ។ ចំណែកព្រះពោធិសត្វ កាលសម្ដែងធម៌ហើយញ៉ាំងមហាជនឲ្យតាំងនៅក្នុងសីល ៥ ហើយទៅតាមយថាកម្ម ។ ចំណែកមហាជនតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យ មានទានជាដើម ធ្វើទេវនគរឲ្យពេញហើយ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ម្នាលភិក្ខុទាំងឡាយ រុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា មតកភត្តជាតក ចប់**

# សុត្តន្តបិដក

## អាយាចិតភត្តជាតក

[ ១៩ ] ( រុក្ខទេវតាពោលថា ) បើអ្នកចង់រួច ត្រូវរួចក្នុងលោកខាងនាយ ព្រោះថា អ្នករួចឥឡូវនេះ គង់ជាប់ ( ដោយបាបកម្ម ) អ្នកប្រាជ្ញទាំងឡាយ មិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថាចំណងវិញទេ ។

**អាយាចិតភត្តជាតកទី ៩ ចប់**

# អដ្ឋកថា

## អាយាចិតភត្តជាតក

[ ១៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធពលិកម្ម បន់ស្រន់ដល់ទេវតាទាំងឡាយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សចេ មុញ្ចេ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ មនុស្សទាំងឡាយ កាលទៅជួញដូរ បានសម្លាប់សត្វធ្វើពលិកម្មដល់ទេវតាទាំងឡាយ ដោយបួងសួងថា យើងខ្ញុំដល់នូវការសម្រេចប្រយោជន៍ ដោយមិនមានឧបសគ្គ មកហើយ នឹងធ្វើពលិកម្មដល់លោកទាំងឡាយទៀត ទើបនាំគ្នាទៅ ។ ក្នុងកាលនោះ ពួកមនុស្សបានដល់នូវការសម្រេចប្រយោជន៍ដោយមិនមានអន្តរាយ មកហើយ សម្គាល់ថា ផលនេះ កើតដោយអានុភាពរបស់ទេវតា ទើបសម្លាប់សត្វជាច្រើនធ្វើពលិកម្ម ដើម្បីដោះនូវបេ្លជ្ញា ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទើបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ប្រយោជន៍ក្នុងការបន់ស្រន់នេះ មានដែរឬ ទើបព្រះមានព្រះភាគទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល មានកុដុម្ពិកៈម្នាក់ ក្នុងស្រុកមួយ ក្នុងដែនកាសី បេ្លជ្ញាពលិកម្មដល់ទេវតា ដែលអាស្រ័យនៅត្រង់ដើមជ្រៃ ក្បែរទ្វារស្រុក ហើយត្រឡប់មកដោយមិនមានអន្តរាយ ទើបសម្លាប់សត្វជាច្រើន ហើយទៅកាន់គល់ជ្រៃ ដោយតាំងចិត្តថា នឹងលាបំណន់ ។ រុក្ខទេវតាដែលឈរត្រង់ប្រគាបឈើ ពោលគាថានេះថា

បើអ្នកចង់រួច ត្រូវរួចក្នុងលោកខាងនាយ ព្រោះថា អ្នករួចឥឡូវនេះ គង់ជាប់ ( ដោយបាបកម្ម ) អ្នកប្រាជ្ញទាំងឡាយ មិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថា ចំណងវិញទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សចេ មុញ្ចេ បេច្ច មុញ្ចេ** សេចក្តីថា បុរសដ៏ចម្រើន បើអ្នកចង់រួច គឺប្រាថ្នានឹងដោះខ្លួន អ្នកលះលោកនេះទៅហើយ ក៏នឹងផុតបាន គឺចូរផុតដោយប្រការដែលផុតក្នុងលោកខាងមុខ ។ បទថា **មុច្ច-មានោ ហិ ពជ្ឈសិ** សេចក្តីថា អ្នកកាលដោះដោយប្រការដែលប្រាថ្នាដើម្បីសម្លាប់សត្វ ហើយដោះ ឈ្មោះថា នៅជាប់ដោយបាបកម្ម ព្រោះហេតុអ្វី ព្រោះអ្នកប្រាជ្ញទាំងឡាយ មិនមែនដោះខ្លួនដោយអាការយ៉ាងនេះឡើយ អធិប្បាយថា បុរសដែលជាបណ្ឌិតទាំងនោះ រមែងមិនដោះខ្លួន ដោយពាក្យសន្យាយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះការដោះខ្លួនបែបនេះ ជាហេតុនាំឲ្យជាប់របស់បុគ្គលពាល គឺធម្មតាការដោះខ្លួន ព្រោះការធ្វើបាណាតិបាតនេះ រមែងជាហេតុជាប់យ៉ាងធ្ងន់របស់បុគ្គលពាល ។ រុក្ខទេវតាសម្តែងធម៌ដោយប្រការដូចពោលមកនេះ ។

តាំងអំពីនោះ មនុស្សទាំងឡាយវៀរចាកកម្ម គឺបាណាតិបាតបែបនោះ នាំគ្នាប្រព្រឹត្តធម៌ ញ៉ាំងទេវនគរឲ្យពេញហើយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា រុក្ខទេវតាក្នុងសម័យនោះ គឺ តថាគតនេះឯង ។៚

# សុត្តន្តបិដក

## ឆទ្ទន្តជាតក

[ ២០ ] ( ស្វាពោធិសត្វពោលថា ) យើងឃើញស្នាមជើង ដែលមិនឡើង ឃើញតែស្នាមជើងដែលចុះ យើងផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់យើងមិនបានឡើយ ។

នឡបានជាតកទី ១០ ចប់

សីលវគ្គទី ២ ចប់

## ឧទ្ទាននៃសីលវគ្គនោះ គឺ

និយាយអំពីលក្ខណជាតក ១ ម្រឹគឈ្មោះសាខៈ ( ក្នុងនិគ្រោធមិគជាតក ) ១ ចូរតិះដៀល ( ក្នុងកណ្ឌិនជាតក ) ១ មិនលាមកជាងរសទាំងឡាយ ( ក្នុងវាតមិគជាតក ) ១ ខរាទិយជាតក ១ ម្រឹគបញ្ឆោតព្រានព្រៃ ( ក្នុងតិបល្លត្ថមិគជាតក ) ១ មាលុតជាតក ១ បុគ្គលមិនត្រូវសម្លាប់សត្វដទៃ ( ក្នុងមតកភត្តជាតក ) ១ ការបួច ( ក្នុងអាយាចិតភត្តជាតក ) ១ នឡបានជាតក ១ ត្រូវជា ១០ ។

# អដ្ឋកថា

## នឡបានជាតក

[ ២០ ] ព្រះសាស្តា កាលទ្រង់ចារិកទៅក្នុងកោសលជនបទ ដល់ស្រុកនឡកបានគាម គង់នៅក្នុងកេតកវ័ន ជិតនឡកបានបោក្ខរណី ទ្រង់ប្រារព្ធដើមបបុសទាំងឡាយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទិស្វា បទមនុត្តិណ្ណំ** ដូច្នេះជាដើម ។

បានឮថា គ្រានោះ ភិក្ខុទាំងឡាយងូតទឹកក្នុងស្រះបោក្ខរណី ឈ្មោះថានឡកបាន ហើយឲ្យពួកសាមណេរយកកំណាត់ដើមបបុស ដើម្បីធ្វើបំពង់ម្ជុល ឃើញកំណាត់បបុសទាំងនោះធ្លុះរហូត ទើបចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គកាន់យកកំណាត់បបុសទាំងឡាយមក ដើម្បីធ្វើបំពង់ម្ជុល កំណាត់បបុសទាំងនោះ ប្រហោងរហូត តាំងអំពីគល់រហូតដល់ចុង ព្រោះហេតុអ្វីហ្ន៎ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាការអធិដ្ឋានកាលអំពីមុនរបស់តថាគត ហើយទ្រង់នាំអតីតនិទានមកសម្តែងថា

បានឮថា ក្នុងអតីតកាល ព្រៃស្បាតនោះជាព្រៃមានអារក្ខទឹកមួយរូបទំពាស៊ីអ្នកដែលចុះទៅក្នុងស្រះនោះ ។ កាលនោះ ព្រះពោធិសត្វជាស្តេចកបិមានទំហំប៉ុនសត្វរមាំង ចោមរោមដោយពួកស្វា ៨០០០០ បរិហារហ្វូងក្នុងព្រៃនោះ ។ ស្តេចស្វានោះ បានឲ្យឱវាទដល់ពួកស្វាថា នែបាទាំងឡាយ ក្នុងព្រៃនេះមានដើមឈើពុលខ្លះ ស្រះបោក្ខរណីដែលកើតឯង មានអមនុស្សហួងហែងខ្លះ មានក្នុងព្រៃនេះឯង អ្នកទាំងឡាយកាលនឹងទំពាស៊ីផ្លែឈើតូចធំ

ដែលមិនធ្លាប់ទំពាស៊ី ឬមានទឹកមិនធ្លាប់ផឹក ត្រូវសាកសួរយើងជាមុន ។ ពួកពានរទាំងនោះទទួលពាក្យហើយ ថ្ងៃមួយ ទៅដល់ទីដែលមិនធ្លាប់ទៅ ត្រាច់ទៅក្នុងទីនោះច្រើនថ្ងៃ កាលស្វែងរកទឹក ឃើញស្រះបោក្ខរណីមួយ មិនទាន់ផឹក អង្គុយរង់ចាំការមករបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វមកដល់ ទើបពោលថា បាទាំងឡាយ ហេតុអ្វី ទើបមិនផឹកទឹក ពួកពានរពោលថា ពួកខ្ញុំរង់ចាំការមករបស់លោកម្ចាស់ ព្រះពោធិសត្វពោលថា អើ បាទាំងឡាយ ពួកអ្នកធ្វើល្អហើយ ទើបដើរវែ្លលស្រះបោក្ខរណីនោះ ពិនិត្យមើលគន្លងជើង ឃើញតែស្នាមជើងចុះ មិនឃើញស្នាមជើងឡើង ព្រះពោធិសត្វដឹងថា ស្រះបោក្ខរណីនេះ អមនុស្សហួងហែងដោយឥតសង្ស័យ ទើបពោលថា បាទាំងឡាយ អ្នកទាំងឡាយមិនផឹកទឹក ធ្វើល្អហើយ ស្រះបោក្ខរណីនេះ មានអមនុស្សហួងហែងហើយ ឯអារក្ខទឹកដឹងថា ស្វាទាំងនេះមិនចុះ ទើបកាឡាខ្លួនជាមនុស្ស មានពោះខៀវ មុខលឿង មានជើងក្រហម រូបរាងគួរខ្លាច គួរខ្ពើម ញែកទឹកចេញមកពោលថា ព្រោះហេតុអ្វី ទើបពួកអ្នកអង្គុយ ចូរចុះក្នុងស្រះបោក្ខរណី ផឹកទឹកចុះ ។ គ្រានោះ ព្រះពោធិសត្វសួរអារក្ខទឹកនោះថា អ្នកជាអារក្ខទឹកកើតក្នុងស្រះនេះឬ អារក្ខទឹកពោលថា អើ យើងកើតហើយ ព្រះពោធិសត្វសួរថា អ្នករមែងបានបុគ្គលដែលចុះទៅកាន់ស្រះបោក្ខរណីឬ អារក្ខទឹកពោលថា អើ យើងបានហើយ មិនលែងបុគ្គលណាមួយ សូម្បីបក្សីដែលចុះក្នុងស្រះបោក្ខរណីនេះ សូម្បីពួកអ្នក យើងក៏នឹងស៊ី ។ ព្រះពោធិសត្វពោលថា ពួកយើងមិនឲ្យអ្នកស៊ីឡើយ អារក្ខទឹកពោលថា ពួកអ្នកមិនផឹកទឹក

ទេឬ ព្រះពោធិសត្វពោលថា អើ ពួកយើងផឹក តែនឹងមិនធ្លាក់ក្នុងអំណាចរបស់អ្នកទេ អារក្ខទឹកពោលថា កាលបើដូច្នោះ ពួកអ្នកនឹងផឹកដូចម្តេច ព្រះពោធិសត្វពោលថា អ្នកសម្គាល់ថា យើងចុះទៅផឹកឬ ដ្បិតថា ពួកយើងជាពានរទាំង ៨០០០០ នឹងមិនចុះទៅ កាន់កំណាត់ដើមបបុសម្នាក់មួយកំណាត់ និងផឹកទឹកក្នុងស្រះបោក្ខរណីរបស់អ្នក ដូចផឹកដោយដើមឈូក កាលបើដូច្នេះ អ្នកមិនអាចស៊ីយើងបាន ។ ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទ្រង់ដឹងច្បាស់នូវសេចក្តីនេះ ទើបត្រាស់ ២ បាទ នៃគាថានេះថា **ទិស្វា បទមនុត្តិណ្ណំ ទិស្វានោតរិតំ បទំ** ដូច្នេះ ។

អត្ថនៃពាក្យដែលជាគាថានោះថា ម្នាលភិក្ខុទាំងឡាយ ស្តេចស្វាជាមហាបុរស មិនបានឃើញស្នាមជើងឡើងត្រឹមតែ ១ ក្នុងស្រះបោក្ខរណីនោះ បានឃើញតែស្នាមជើងចុះប៉ុណ្ណោះ កាលឃើញយ៉ាងនោះ គឺមិនឃើញស្នាមជើងឡើង ឃើញតែស្នាមជើងចុះ ទើបដឹងថា ស្រះបោក្ខរណីនេះ អមនុស្សហួងហែងពិត កាលចរចាជាមួយអារក្ខទឹកនោះ ទើបពោលថា យើងផឹកទឹកដោយដើមបបុស អធិប្បាយសេចក្តីនៃពាក្យនោះថា ពួកយើងនឹងផឹកទឹកក្នុងស្រះបោក្ខរណីដោយដើមបបុស ។ ព្រះពោធិសត្វពោលបន្តទៅថា អ្នកនឹងសម្លាប់យើងមិនបានឡើយ អធិប្បាយថា យើង និងបរិស័ទ ផឹកទឹកដោយដើមបបុសយ៉ាងនេះ អ្នកនឹងសម្លាប់មិនបាន ។

ព្រះពោធិសត្វកាលពោលយ៉ាងនេះហើយ ទើបនាំកំណាត់បបុសមកមួយកំណាត់ ពិចារណាដល់បារមីទាំងឡាយ ហើយធ្វើសច្ចកិរិយា យកមាត់ផ្លុំ

ដើមបបុសបានជាបំពង់រហូតទៅ មិនមានថ្នាំងណាមួយខាងក្នុង ព្រះពោធិសត្វឲ្យនាំកំណាត់បបុសមួយកំណាត់មកហើយ បានផ្លុំហុចទៅ ដោយទំនងនេះ កាលពោលមកដូច្នេះ មិនអាចឲ្យសម្រេចបាន ព្រោះដូច្នោះ មិនគួរកាន់យកយ៉ាងនោះ ឯព្រះពោធិសត្វអធិដ្ឋានថា ដើមបបុសទាំងអស់ ដែលកើតជុំវិញស្រះបោក្ខរណីនេះ ចូរទៅជាបំពង់ ព្រោះការតាំងព្រះហឫទ័យដើម្បីប្រយោជន៍របស់ព្រះពោធិសត្វទាំងឡាយ ជាសភាវៈធំក្រៃលែង ការអធិដ្ឋាន រមែងសម្រេច តាំងពីនោះមក បបុសដែលកើតជុំវិញស្រះបោក្ខរណីគ្រប់ដើម ជាបំពង់រហូត ។

ពិតហើយ ក្នុងកប្បនេះ ឈ្មោះថា បាដិហារ្យដែលតាំងនៅអស់កប្បមាន ៤ ប្រការ ។ ៤ ប្រការ តើអ្វីខ្លះ ។ រូបទន្សាយលើដួងព្រះចន្ទ តាំងនៅអស់មួយកប្ប ១ ទីដែលភ្លើងមិនឆេះក្នុងវដ្ដកជាតក ភ្លើងមិនឆេះអស់មួយកប្ប ១ ទីដែលជាលំនៅរបស់ឃដិការស្មូនឆ្នាំង ភ្លៀងស្រក់មិនចំអស់មួយកប្ប ១ ដើមបបុសដែលនៅជុំវិញស្រះបោក្ខរណីជាប្រហោង មិនមានថ្នាំងអស់មួយកប្ប ១ ឈ្មោះថា បាដិហារ្យដែលតាំងនៅអស់កប្ប ៤ ប្រការ ដូចពណ៌នាមក ដូច្នេះ ។

ព្រះពោធិសត្វ កាលអធិដ្ឋានយ៉ាងនេះហើយ ទើបអង្គុយកាន់ដើមបបុស ១ ឯពានរទាំង ៨០០០០ នោះ ក៏កាន់យកបបុសមួយដើមៗ អង្គុយចោមរោមស្រះបោក្ខរណី ក្នុងពេលដែលព្រះពោធិសត្វយកដើមបបុសបឺតទឹក ពានរទាំងនោះអង្គុយត្រង់ច្រាំងនោះឯង ផឹកទឹកហើយ កាលពានរទាំងនោះ

ផឹកទឹកយ៉ាងនេះ អារក្ខទឹកមិនបាននូវពានរណាមួយ ក៏អាក់អន់ចិត្ត ទើបទៅកាន់និវេសន៍របស់ខ្លួននោះឯង ឯព្រះពោធិសត្វ មួយអន្លើដោយបរិវារក៏ចូលទៅកាន់ព្រៃដូចគ្នា ។

ចំណែកព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការដែលដើមបបុសទាំងឡាយនេះ ជាបំពង់នោះ ជាការអធិដ្ឋានដែលមានក្នុងកាលមុនរបស់តថាគតនោះឯង ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា អារក្ខទឹកក្នុងកាលនោះ បានជាទេវទត្ត ក្នុងកាលឥឡូវនេះ ពានរ ៨០០០០ ក្នុងកាលនោះ បានជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯស្តេចកបិដែលឈ្លាសក្នុងឧបាយ ក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

**អដ្ឋកថា នឡបានជាតក ចប់**

**សីលវគ្គ ចប់**

# សុត្តន្តបិដក

## កុរុង្គវគ្គ

### កុរុង្គមិគជាតក

[ ២១ ] ( ព្រើសពោធិសត្វពោលថា ) ម្នាលដើមចំបក់ អ្នកជម្រុះផ្លែមកដោយហេតុណា ហេតុនោះ អញជាព្រើសបានដឹងហើយ អញនឹងទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនចេញចិត្តទេ ។

កុរុង្គមិគជាតកទី ១ ចប់

# អដ្ឋកថា

# កុរុង្គវគ្គ

## កុរុង្គមិគជាតក

[ ២១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ញាតមេតំ កុរុង្គស្ស** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ភិក្ខុទាំងឡាយ អង្គុយប្រជុំគ្នាក្នុងធម្ម-សភា ពោលទោសរបស់ទេវទត្តថា អាវុសោទាំងឡាយ ទេវទត្ត ប្រកប នាយខ្មាន់ធ្នូ ដើម្បីផ្តាច់ព្រះជន្មព្រះសាស្តា ប្រមៀលថ្ម លែងនូវដំរីធនបាលក: ខ្នះខ្នែងដើម្បីផ្តាច់ព្រះជន្មព្រះទសពលក្នុងកាលទាំងពួង ។ ព្រះមុនីយាងមក ហើយ គង់លើអាសនៈដែលគេក្រាលហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំង ឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំង ឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ អង្គុយ សន្ទនាគ្នា ដោយការពោលទោសរបស់ទេវទត្តថា ទេវទត្តប្រឹងប្រែង ដើម្បី ផ្តាច់ព្រះជន្មរបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រឹងប្រែង ដើម្បីសម្លាប់តថាគតក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុន ក៏ខ្នះខ្នែងដូចគ្នា តែមិនអាចសម្លាប់តថាគតបាន ហើយទ្រង់នាំ អតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាប្រើស ទំពាស៊ីផលាផលទាំងឡាយ ក្នុងដងព្រៃមួយកន្លែង ។ សម័យមួយ ប្រើសនោះស៊ីផ្លែចំបក់ដែលមានផ្លែស្អែកស្កះ ។ លំដាប់នោះ មានព្រានធ្នះពិចារណាស្នាមជើងម្រឹគទាំងឡាយហើយ ទើបចងធ្នះលើដើមឈើ ហើយអង្គុយលើធ្នះនោះ យកលំពែងចាក់ម្រឹគ ដែលមកទំពាស៊ីផ្លែឈើ ហើយលក់សាច់របស់សត្វទាំងនោះចិញ្ចឹមជីវិត ។ ថ្ងៃមួយព្រាននោះឃើញស្នាមជើងរបស់ព្រះពោធិសត្វត្រង់គល់ឈើនោះ ទើបចងធ្នះលើដើមចំបក់នោះ ហើយបរិភោគអាហារអំពីព្រហាម កាន់លំពែងចូលព្រៃឡើងទៅកាន់ដើមឈើនោះ ហើយអង្គុយលើធ្នះ ។ ឯព្រះពោធិសត្វក៏ចេញអំពីលំនៅពីព្រលឹម ដោយចំណងថា នឹងស៊ីផ្លែចំបក់ តែមិនប្រញាប់ប្រញាល់ចូលទៅត្រង់គល់ឈើនោះ គិតថា ជួនកាលព្រានធ្នះ នឹងចងធ្នះលើដើមឈើអន្តរាយបែបនេះមានឬហ្ន៎ ទើបបានឈរពិចារណាអំពីខាងក្រៅ ឯនាយព្រានដឹងថា ព្រះពោធិសត្វមិនមក អង្គុយលើធ្នះនោះឯង បោះផ្លែចំបក់ឲ្យធ្លាក់ចុះត្រង់មុខព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វគិតថា ផ្លែទាំងនេះ មកធ្លាក់ខាងមុខអញ នៅលើដើមឈើនោះមានព្រានឬហ្ន៎ កាលសម្លឹងមើលរឿយៗ ក៏ឃើញនាយព្រាន តែធ្វើមិនឃើញ ពោលថា ដើមឈើដ៏ចម្រើន កាលមុនអ្នកឲ្យផ្លែទាំងឡាយធ្លាក់ចុះមកដោយត្រង់ ដូចអង្រួនផ្លែដែលសំយុង ដូច្នោះឥឡូវនេះ អ្នកលះបង់រុក្ខធម៌ចោលហើយ គ្រាអ្នកលះបង់រុក្ខធម៌ចោលយ៉ាងនេះ ខ្ញុំនឹងទៅកាន់គល់ឈើដទៃ ស្វែងរកអាហាររបស់ខ្ញុំ ហើយទើបពោល

គាថានេះថា

ម្នាលដើមចំបក់ អ្នកជម្រុះផ្លែមក ដោយហេតុណា ហេតុនោះ អញជាប្រើសបានដឹងហើយ អញនឹងទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ញាតំ** បានដល់ ប្រាកដ គឺកើតហើយ ។ បទថា **ឯតំ** យោគជា **ឥធំ** ប្រែថា កម្មនេះ ។ បទថា **កុរុង្គស្ស** បានដល់ ម្រឹគប្រភេទប្រើស ។ បទថា **យំ ត្វំ សេបណ្ណិ សេយ្យសិ** សេចក្ដីថា នៃដើមចំបក់ដ៏ចម្រើន ការដែលអ្នកបណ្ដោយឲ្យផ្លែរមៀលធ្លាក់ចុះមកខាងមុខ គឺហាក់ដូចជាមានផ្លែខ្ចាយមកនោះ ទាំងអស់កើតជាវត្ថុលាមកសម្រាប់ប្រើស ។ ដោយបទថា **ន មេ តេ រុច្ចតេ** នេះ ប្រើសពោលថា អញមិនគាប់ចិត្តក្នុងផ្លែរបស់អ្នក ដែលឲ្យផ្លែយ៉ាងនេះ ចូរអ្នកឈប់ចុះ អញនឹងទៅទីដទៃ ដូច្នេះ បានទៅហើយ ។

លំដាប់នោះ នាយព្រានទាំងអង្គុយនៅលើផ្ទះនោះឯង ពួយលំពែងទៅដើម្បីព្រះពោធិសត្វ ហើយពោលថា ចូរឯងទៅចុះ ឥឡូវនេះ អញខុសបំណងហើយ ព្រះពោធិសត្វត្រឡប់មកឈរ ពោលថា បុរសដ៏ចម្រើន ឥឡូវនេះ លោកខុសបំណងជាមួយខ្ញុំក៏ពិត តែលោកនឹងមិនខុសបំណងក្នុងមហានរក ៨ រណ្ដៅ ឧស្សទនរក ១៦ រណ្ដៅ និងកម្មករណៈទាំងឡាយ មានចំណង ៥ ប្រការជាដើម លុះពោលយ៉ាងនេះហើយ ក៏បានទៅកាន់ទីគាប់ចិត្ត ឯនាយព្រានចុះមកហើយ ទៅតាមគាប់ចិត្ត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តខ្នះខ្នែងសម្លាប់តថាគតក្នុង កាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ប្រឹងប្រែងហើយដូចគ្នា តែមិនអាចសម្លាប់តថាគតបាន កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា នាយព្រានធ្នូក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនោះ ឯប្រើសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កុរុង្គមិគជាតក ចប់**

# សុត្តន្តបិដក

## កុក្កុរជាតក

[ ២២ ] ( សុខនពោធិសត្វពោលថា ) ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរ និងកម្លាំង ចម្រើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថា សម្លាប់ ដោយត្រឹមត្រូវឡើយ នេះឈ្មោះថា សម្លាប់តែឆ្កែដែលមានកម្លាំងខ្សោយ ។

កុក្កុរជាតកទី ២ ចប់

# អដ្ឋកថា

## កុក្កុរជាតក

[ ២២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការប្រព្រឹត្តប្រយោជន៍ដល់ញាតិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យេ កុក្កុរា** ដូច្នេះជាដើម ។

ការប្រព្រឹត្តប្រយោជន៍ដល់ញាតិនោះ នឹងមានជាក់ច្បាស់ក្នុងភទ្ទសាលជាតក ទ្វាទសកនិបាត ។ ព្រះសាស្តាទ្រង់តាំងរឿងនេះហើយ ទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វទ្រង់អាស្រ័យកម្មបែបនោះ កើតក្នុងកំណើតសុនខ ចោមរោមដោយបរិវារមិនមែនតិច នៅក្នុងមហាស្មសាន ។ សម័យថ្ងៃមួយ ព្រះរាជាយាងឡើងរថ ទឹមដោយសេះសិន្ធពពណ៌ស ប្រដាប់ដោយគ្រឿងប្រដាប់ទាំងពួង យាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាននោះ អស់ចំណែកនៃថ្ងៃ កាលព្រះអាទិត្យអស្តង្គត ទើបយាងចូលព្រះនគរ រាជបុរសទាំងឡាយ ដាក់ខ្សែស្បែករថនោះតាមដែលចងនោះឯងត្រង់លានព្រះរាជវាំង ។ កាលភ្លៀងធ្លាក់ពេលយប់ រថនោះក៏សើមដោយភ្លៀង ឯឆ្កែដែលចិញ្ចឹមក្នុងរាជត្រកូល ចុះអំពីប្រាសាទជាន់លើ កកេរព្រ័ត្រនិងកូនកំព្រានៃរថនោះ ។ ស្អែកឡើង ទើបពួករាជបុរសក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ឆ្កែទាំងឡាយ ចូលមកតាមលូទឹក កកេរព្រ័ត្រ និងកូនកំព្រារបស់រថនោះ ព្រះរាជាទ្រង់ព្រះពិរោធនឹងឆ្កែ ទើបត្រាស់ថា ចូរពួក

អ្នកសម្លាប់ក្តែក្នុងទីដែលបានឃើញហើយ ។ តាំងអំពីនោះមក ការវិនាសធំកើតឡើងដល់ពួកក្តែ ។ ក្តែទាំងនោះ កាលត្រូវសម្លាប់ក្នុងទីដែលប្រទះ ទើបរត់ចូលទៅក្នុងព្រៃ នាំគ្នាទៅកាន់សម្នាក់ព្រះពោធិសត្វ ។ ព្រះពោធិសត្វសួរថា អ្នកទាំងឡាយ នាំគ្នាមកប្រជុំព្រោះហេតុអ្វីហ្ន៎ ក្តែទាំងនោះពោលថា ព្រះរាជាទ្រង់ក្រោធថា បានឮថា ក្តែស៊ីព្រ័ត្រ និងកូនកំព្រារបស់រថខាងក្នុងព្រះរាជវាំង ទើបទ្រង់បញ្ជាឲ្យសម្លាប់ក្តែ ក្តែជាច្រើនវិនាស ភ័យកើតឡើងហើយ ។ ព្រះពោធិសត្វគិតថា ក្នុងទីដែលមានការរក្សា ក្តែទាំងឡាយខាងក្រៅ រមែងមិនមានឱកាស កម្មនេះ នឹងជាកម្មរបស់ពួកក្តែចិញ្ចឹមខាងក្នុងព្រះរាជនិវេសន៍នោះឯង ភ័យណាមួយ រមែងមិនមានដល់ពួកចោរ ឯពួកដែលមិនមែនចោរ បែរជាបានទូវការស្លាប់ បើដូច្នោះ អញនឹងបង្ហាញពួកចោរដល់ព្រះរាជា ហើយឲ្យជីវិតទានដល់ពួកញាតិ ព្រះពោធិសត្វនោះ លួងលោមញាតិទាំងឡាយ ឲ្យធូរស្រាលចិត្ត ហើយពោលថា អ្នកទាំងឡាយកុំខ្លាច ខ្ញុំនឹងនាំការមិនមានភ័យ មកឲ្យដល់ពួកអ្នកទាំងឡាយ ចូរពួកអ្នកនៅទីនេះឯងទម្រាំខ្ញុំបានគាល់ព្រះរាជា ហើយអធិដ្ឋានដល់បារមី ធ្វើមេត្តាការនាឲ្យជាបុរេចារិក ហើយអធិដ្ឋានថា បុគ្គលណាម្នាក់ កុំបីអាចចោលដុំដី ឬដំបងលើអាត្មាអញឡើយ ម្នាក់ឯងប៉ុណ្ណោះ ចូលទៅខាងក្នុងព្រះនគរ សម័យនោះសូម្បីសត្វមួយឃើញព្រះពោធិសត្វហើយ ឈ្មោះថា ក្រោធ ហើយក្រឡេកមើលមិនមាន ។ ឯព្រះរាជាទ្រង់បញ្ជាឲ្យសម្លាប់ក្តែហើយ គង់ប្រថាប់ក្នុងទីវិនិច្ឆ័យដោយព្រះអង្គឯង ព្រះពោធិសត្វទៅក្នុងទីវិនិច្ឆ័យនោះឯង ហើយរត់

ចូលទៅក្រោមអាសនៈរបស់ព្រះរាជា ។ លំដាប់នោះ ពួករាជបុរស នាំព្រះពោធិសត្វចេញមក តែព្រះរាជាទ្រង់ឃាត់ ។ ព្រះពោធិសត្វសម្រាកបន្តិចហើយចេញអំពីខាងក្រោមអាសនៈ ថ្វាយបង្គំព្រះរាជាហើយ ទូលសួរថា បពិត្រព្រះអង្គ បានឮថា ទ្រង់ឲ្យសម្លាប់ឆ្កែពិតឬ ។ ទ្រង់ត្រាស់ថា អើ យើងឲ្យសម្លាប់ ។ ព្រះពោធិសត្វទូលសួរថា បពិត្រព្រះអង្គជាធំជាងជន ឆ្កែទាំងនោះ មានកំហុសអ្វី ។ ព្រះរាជាត្រាស់ថា ឆ្កែទាំងឡាយស៊ីព្រ័ត្រ និងកូនកំព្រានៃរថរបស់យើង ព្រះពោធិសត្វទូលសួរថា ទ្រង់ស្គាល់ឆ្កែដែលស៊ីហើយឬ ។ ព្រះរាជាត្រាស់ថា មិនស្គាល់ ។ ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព ការដែលទ្រង់មិនដឹងដោយពិតថា ចោរដែលស៊ីព្រ័ត្រ ឈ្មោះនេះ ហើយទ្រង់ឲ្យសម្លាប់ឆ្កែក្នុងទីដែលបានជួប បានឃើញ មិនសមគួរ ។ ព្រះរាជាត្រាស់ថា ព្រោះពួកឆ្កែទំពាស៊ីព្រ័ត្រ ទើបយើងបញ្ជាឲ្យសម្លាប់ឆ្កែថា ចូរពួកអ្នកសម្លាប់ឆ្កែដែលបានឃើញទាំងអស់ ។ ព្រះពោធិសត្វទូលថា មនុស្សទាំងឡាយនោះ សម្លាប់ឆ្កែទាំងអស់ឬ ឬឆ្កែមិនបាននូវការស្លាប់មានដែរ ។ ព្រះរាជាត្រាស់ថា មាន ឆ្កែចិញ្ចឹមក្នុងដំណាក់របស់យើង មិនត្រូវបានសម្លាប់ ។ ព្រះមហាសត្វទូលថា បពិត្រមហារាជ ទ្រង់បានត្រាស់អម្បាញ់មិញនេះថា ព្រោះពួកឆ្កែស៊ីព្រ័ត្រចងរថ ទើបយើងបញ្ជាឲ្យសម្លាប់ឆ្កែថា ចូរពួកអ្នកសម្លាប់ឆ្កែទាំងអស់ដែលបានឃើញ តែឥឡូវនេះ ទ្រង់ត្រាស់ថា ឆ្កែចិញ្ចឹមក្នុងដំណាក់របស់យើងមិនត្រូវបានសម្លាប់ កាលបើដូច្នោះ ទ្រង់រមែងលុះនូវអគតិដូចជាឆន្ទាគតិជាដើម ឈ្មោះថា ការលុះនូវអគតិមិនសមគួរ និងមិនជាទស-

ពិធរាជធម៌ ធម្មតាព្រះរាជាដែលស្វែងរកហេតុ និងមិនមែនហេតុ ដូចគ្នានឹងជញ្ជីង ទើបគួរ ។ ឥឡូវនេះ ឆ្កែចិញ្ចឹមក្នុងរាជត្រកូល មិនបាននូវការស្លាប់ ឆ្កែដែលទុព្វលប៉ុណ្ណោះ ទើបបាន កាលបើដូច្នោះ នេះមិនជាការសម្លាប់ឆ្កែទាំងអស់ តែនេះ ឈ្មោះថា ជាការសម្លាប់ឆ្កែដែលទុព្វល កាលទូលយ៉ាងនោះហើយ ទើបបន្លឺសំឡេងដ៏ពីរោះ ក្រាបទូលថា បពិត្រមហារាជ វត្ថុដែលទ្រង់ធ្វើនោះ មិនជាធម៌ឡើយ កាលសម្តែងធម៌ដល់ព្រះរាជា ទើបពោលគាថានេះថា

*ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរ និងកម្លាំង ចម្រើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថា សម្លាប់ដោយត្រឹមត្រូវឡើយ នេះឈ្មោះថា សម្លាប់តែឆ្កែដែលមានកម្លាំងខ្សោយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យេ កុក្កុរា** បានដល់ ឆ្កែពួកណា ។ ដូចបស្សាវៈ សូម្បីក្តៅ ក៏ហៅថា មូត្រស្អុយ ឆ្កែចចក សូម្បីកើតក្នុងថ្ងៃនោះ ក៏ហៅថា ឆ្កែចចកចាស់ ។ វល្លិផោម សូម្បីនៅខ្ចីក៏ហៅថា វល្លិស្អុយ កាយសូម្បីមានពណ៌ដូចមាស ក៏ហៅថា កាយស្អុយ យ៉ាងណា ឆ្កែសូម្បីមានអាយុ ១០០ ឆ្នាំ ក៏ហៅថា **កុក្កុរ** ( កូនឆ្កែ ) ក៏ដូច្នោះដូចគ្នា ។ ព្រោះហេតុនោះ ឆ្កែទាំងនោះចាស់ តែសម្បូរដោយកម្លាំងកាយ ក៏ហៅថា **កុក្កុរ** ដូចគ្នា ។ បទថា **វឌ្ឍា** បានដល់ ចម្រើនធំធាត់ ។ បទថា **កោលេយ្យកា** បានដល់ កើតហើយ មានហើយ ចម្រើនហើយក្នុងរាជត្រកូល ។ បទថា **វណ្ណពល-**

**បបន្នា** បានដល់ សម្បូរដោយពណ៌រាងកាយ និងកម្លាំងកាយ ។ បទថា **គោមេ ន វជ្ឈា** សេចក្តីថា ឆ្កែទាំងនេះមានម្ចាស់រក្សា ទើបមិនត្រូវសម្លាប់ ។ បទថា **មយមស្ម វជ្ឈា** សេចក្តីថា យើងទាំងឡាយមិនមានម្ចាស់ មិនមានការរក្សា ជាឆ្កែដែលត្រូវសម្លាប់ ។ បទថា **ឆាយំ សយច្ចា** សេចក្តីថា កាលបើយ៉ាងនោះ នេះរមែងមិនឈ្មោះថា មានការសម្លាប់ដោយមិនប្លែកគ្នា ។ បទថា **ទុព្វលឃាតិកាយំ** សេចក្តីថា ចំណែកនេះ រមែងឈ្មោះថា ជាការសម្លាប់ដែលទុព្វល ព្រោះសម្លាប់ចំពោះឆ្កែទុព្វលទាំងឡាយ អធិប្បាយថា ធម្មតាព្រះរាជាទាំងឡាយ គួរសង្កត់សង្កិនពួកចោរ ពួកដែលមិនមែនជាចោរ មិនគួរសង្កត់សង្កិន តែក្នុងហេតុការណ៍នេះ ទោសណាមួយមិនមានដល់ពួកចោរ ពួកដែលមិនមែនចោរ បែរជាបាននូវការស្លាប់ ឱ ! ក្នុងលោកនេះ វត្ថុដែលមិនគួរ រមែងប្រព្រឹត្តទៅ ឱ ! អធម៌ រមែងប្រព្រឹត្តទៅ ។

ព្រះរាជា បានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទើបត្រាស់ថា នែបណ្ឌិត អ្នកដឹងឬថា ឆ្កែឈ្មោះនោះស៊ីព្រ័ត្រចងរថ ។ ព្រះពោធិសត្វពោលថា បពិត្រព្រះអង្គ ទូលបង្គំដឹង ។ ព្រះរាជាត្រាស់ថា ឆ្កែពួកណាស៊ី ។ ព្រះពោធិសត្វទូលថា ពួកឆ្កែចិញ្ចឹមក្នុងដំណាក់របស់ព្រះអង្គស៊ី ។ ព្រះរាជាត្រាស់ថា ចូរអ្នកពិសោធឲ្យដឹងថា ឆ្កែទាំងនោះស៊ីដូចម្តេច ។ ព្រះពោធិសត្វទូលថា ទូលបង្គំនឹងសម្តែងភាពដែលឆ្កែទាំងនោះស៊ី ។ ព្រះរាជាត្រាស់ថា ចូរបង្ហាញចុះបណ្ឌិត ។ ព្រះពោធិសត្វទូលថា សូមទ្រង់ឲ្យនាំឆ្កែចិញ្ចឹមក្នុងដំណាក់របស់ទ្រង់មក ហើយឲ្យនាំតក្កៈ និងស្បូវក្លាំងមកបន្តិច ។ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាង

នោះ ៗ លំដាប់នោះ ព្រះពោធិសត្វឲ្យប្រឫបាច់ស្មៅ និងតក្កៈ ហើយទូលព្រះរាជាថា សូមទ្រង់ឲ្យក្ដែទាំងនោះផឹក ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះ ហើយឲ្យផឹក ៗ ក្ដែទាំងឡាយដែលផឹកហើយ ក៏បន្ទោបង់ចេញមក មួយអន្លើដោយព្រ័ត្រទាំងឡាយ ព្រះរាជាទ្រង់ត្រេកអរថា ( សុនខនេះព្យាករ ) ដូចការព្យាកររបស់ព្រះសព្វញ្ញុពុទ្ធ ទើបធ្វើការបូជាព្រះពោធិសត្វដោយស្វេតច្ឆត្រ ៗ ព្រះពោធិសត្វសម្ដែងធម៌ដល់ព្រះរាជាដោយគាថា ពោលអំពីការប្រព្រឹត្តធម៌ ១០ ប្រការ ដែលមកក្នុងតេសកុណជាតកជាដើមថា បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ ... ដូច្នេះហើយទូលបន្ថា បពិត្រមហារាជ ចាប់តាំងអំពីនេះទៅ សូមទ្រង់កុំប្រមាទ ហើយឲ្យព្រះរាជាតាំងនៅក្នុងសីល ៥ ទើបបានថ្វាយស្វេតច្ឆត្រដល់ព្រះរាជា ៗ ព្រះរាជាទ្រង់បានស្ដាប់ធម្មកថារបស់មហាសត្វ ហើយទ្រង់ឲ្យអភ័យដល់សត្វទាំងពួង ទ្រង់ផ្ដើមតាំងនិច្ចភត្ត ដូចគ្នានឹងភោជនរបស់ព្រះអង្គដល់ក្ដែទាំងពួង មានព្រះពោធិសត្វជាដើម ទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យមានទានជាដើម ដរាបដល់អស់ជ្រះជន្មាយុ ហើយកើតក្នុងទេវលោក កុក្កុរោវាទប្រព្រឹត្តទៅមួយម៉ឺនឆ្នាំ ឯព្រះពោធិសត្វតាំងនៅដរាបដល់អស់អាយុហើយ បានទៅតាមយថាកម្ម ៗ

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រព្រឹត្តប្រយោជន៍ដល់ញាតិទាំងឡាយក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏បានប្រព្រឹត្តហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះ មកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាព្រះអានន្ទក្នុងកាលឥឡូវនេះ បរិស័ទដ៏សេសក្រៅអំពីនេះក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកកុក្កុរបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។ ល។

**អដ្ឋកថា កុក្កុរជាតក ចប់**

# សុត្តន្តបិដក

## កោជាជានីយជាតក

[ ២៣ ] ( សេះអាជានេយ្យពោធិសត្វពោលថា ) សេះកោជាជានីយៈ សូម្បីត្រូវសរទាំងឡាយមុតហើយ ដេកផ្អៀង គង់ប្រសើរជាងសេះសាមញ្ញ នៃសារថី អ្នកចូរទឹមខ្ញុំដោយគ្រឿងក្រឹសទាំងឡាយចុះ ។

កោជាជានីយជាតកទី ៣ ចប់

# អដ្ឋកថា

## ភោជាជានីយជាតក

[ ២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុលះសេចក្តីព្យាយាមមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ បស្សេន សេមានោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យនោះ ព្រះសាស្តាត្រាស់ហៅភិក្ខុនោះមកហើយត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុន បានធ្វើសេចក្តីព្យាយាមក្នុងទីដែលមិនមែនលំនៅ បានទទួលនូវការឈឺចាប់ ក៏មិនលះបង់នូវសេចក្តីព្យាយាម ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេះសិន្ធព ឈ្មោះភោជាជានីយៈសម្បូរដោយអាការទាំងពួង បានជាសេះមង្គលរបស់ព្រះបាទពារាណសី ព្រះពោធិសត្វនោះបរិភោគភោជនស្រូវសាលី មានក្លិនក្រអូបដែលរក្សាទុកអស់ ៣ ឆ្នាំ ដល់ព្រមដោយរសផ្សេងៗ ក្នុងថាសមាសដែលមានតម្លៃមួយសែនឈរក្នុងផ្ទៃដី ដែលលាបដោយគ្រឿងក្រអូប គឺគន្ធជាតិ ៤ ប្រការប៉ុណ្ណោះទីដែលឈរនោះ ព័ទ្ធដោយវាំងននកម្ពលពណ៌ក្រហម ខាងលើពិតានសំពត់វិចិត្រដោយផ្កាយមាស សំយុងដោយគ្រឿងក្រអូប និងកម្រងផ្កា អុជប្រទីបប្រេងក្រអូប ឈ្មោះថា ព្រះរាជាទាំងឡាយដែលមិនប្រាថ្នារាជសម្បត្តិ ក្នុងនគរពារាណសី រមែងមិនមាន ។ សម័យមួយ ព្រះរាជា ៧ អង្គនាំគ្នាព័ទ្ធនគរពារាណសី បញ្ជូនរាជសាសន៍ដល់ព្រះបាទពារាណសីថា នឹងឲ្យរាជ-

សម្បត្តិដល់យើងទាំងឡាយ ឬច្បាំង ។ ព្រះបាទពារាណសីឲ្យប្រជុំអមាត្យទាំងឡាយ ហើយប្រាប់រាជសាសន៍នោះ សួរថា នែបាទាំងឡាយ ឥឡូវនេះពួកយើងនឹងធ្វើដូចម្តេច អមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេពខាងដើម ទ្រង់មិនចាំបាច់ច្បាំងឡើយ សូមទ្រង់បញ្ជូនទាហានសេះឈ្មោះនោះឲ្យធ្វើការច្បាំង កាលទាហានសេះនោះមិនអាច ទូលបង្គំទាំងឡាយ នឹងដឹងក្នុងកាលជាក្រោយ ។ ព្រះរាជាត្រាស់ឲ្យហៅទាហានសេះនោះមកហើយ ត្រាស់ថា នែបា អ្នកអាចធ្វើចម្បាំងជាមួយព្រះរាជា ៧ អង្គ ឬទេ ។ ទាហានក្រាបទូលថា បពិត្រព្រះសម្មតិទេព បើទូលបង្គំបានសេះសិន្ធពឈ្មោះភោជាជានីយៈសោត ព្រះរាជា ៧ អង្គលើកទុកចុះ ទូលបង្គំនឹងអាចច្បាំងជាមួយព្រះរាជាទាំងជម្ពូទ្វីប ។ ព្រះរាជាត្រាស់ថា នែបា ចូរអ្នកយកសេះសិន្ធពភោជាជានីយៈ ឬសេះដទៃតាមតែចិត្តចុះ ។ នាយទាហានសេះនោះទទួលព្រះតម្រាស់ហើយថ្វាយបង្គំព្រះរាជា ចុះអំពីប្រាសាទ ឲ្យនាំសេះសិន្ធពភោជាជានីយៈមកខ្លួនឯងក៏ចងក្រឹសគ្រប់យ៉ាង សៀតនូវព្រះខ័ន ឡើងខ្នងសេះសិន្ធពដ៏ប្រសើរ ចេញអំពីព្រះនគរទៅ ដូចផ្លេកបន្ទោរ ទម្លាយកងពលទី ១ ចាប់ព្រះរាជាបានមួយអង្គ នាំមកប្រគល់ឲ្យដល់ពលក្នុងនគរ ហើយត្រឡប់ទៅទៀត ទម្លាយកងពលទី ២ ទី ៣ ក៏ដូចគ្នា ចាប់ព្រះរាជាបាន ៥ អង្គយ៉ាងនេះ ដោយប្រការដូច្នេះ ហើយទម្លាយកងពលទី ៦ ក្នុងគ្រាចាប់ព្រះរាជាអង្គទី ៦ សេះសិន្ធពភោជាជានីយៈ បានត្រូវរបួស ឈាមហូរ វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅ ។ ទាហានសេះដឹងថា សេះសិន្ធពរបួស ទើបឲ្យសេះសិន្ធពភោជាជានីយៈ ដេក

ត្រង់ទ្វារព្រះរាជវាំង ផ្ដើមធ្វើក្រឹសឲ្យធូរ បំពាក់ក្រឹសសេះដទៃ ។ ព្រះពោធិសត្វទាំងដែលដេកផ្អៀងដែលមានផាសុកច្រើន បើកភ្នែកឡើង ឃើញទាហានសេះធ្វើយ៉ាងនោះ ទើបគិតថា ទាហានសេះនេះ បំពាក់ក្រឹសសេះដទៃ សេះនេះមិនអាចទម្លាយកងពលទី ៧ ចាប់ព្រះរាជាទី ៧ បានទេ កម្មដែលអញធ្វើហើយ នឹងវិនាសអស់ សូម្បីនាយទាហានដែលមិនមានគូប្រៀបក៏នឹងវិនាស ព្រះរាជាក៏នឹងធ្លាក់ក្នុងកណ្ដាប់ដៃរបស់ព្រះរាជាដទៃ វៀរអញចេញហើយ សេះដទៃដែលឈ្មោះថា អាចទម្លាយកងពលទី ៧ ហើយចាប់ព្រះរាជាអន្ដទី ៧ បាន រមែងមិនមាន ទាំងដែលនៅដេកនោះឯង ឲ្យហៅនាយទាហានសេះមក ហើយពោលថា នែសម្លាញ់ វៀរខ្ញុំចេញហើយ ឈ្មោះថា សេះដទៃដែលអាចទម្លាយកងពលទី ៧ ហើយចាប់ព្រះរាជាអន្ដទី ៧ បាន រមែងមិនមាន ខ្ញុំមិនធ្វើកម្មដែលខ្ញុំធ្វើហើយឲ្យវិនាស ចូរឲ្យខ្ញុំក្រោកឡើង ហើយចងក្រឹសចុះ ទើបពោលគាថានេះថា

> សេះភោជាជានីយៈ សូម្បីត្រូវសរទាំងឡាយមុតហើយ ដេកផ្អៀង
> គង់ប្រសើរជាងសេះសាមញ្ញ នែសារថី អ្នកចូរទឹមខ្ញុំដោយគ្រឿង
> ក្រឹសទាំងឡាយចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបិ បស្សេន សេមានោ** បានដល់ សូម្បីដេកផ្អៀងម្ខាង ។ បទថា **សល្លេភិ សល្លលីកតោ** សេចក្ដីថា ជាអ្នកត្រូវសរទាំងឡាយមុតហើយ ។ បទថា **សេយ្យោវ វឡវា ភោជ្ជោ** សេចក្ដីថា សេះសាមញ្ញជម្មតា ដែលមិនកើតក្នុងត្រកូលសេះសិន្ធព ឈ្មោះថា **វឡវ** សេះ

កោជាជានីយសិន្ធព ឈ្មោះថា **ភោជ្ជ** ដូច្នោះ សេះកោជាជានីយសិន្ធពនោះ ឯង សូម្បីត្រូវសរមុតហើយ គង់ប្រសើរ គឺក្រៃលែង ឧត្តមជាងសេះសាមញ្ញនោះ ។ ដោយបទថា **យុញ្ជ មញ្ញោវ សារថី** នេះ ព្រះពោធិសត្វពោលថា ព្រោះហេតុដែលយើងទៅដោយអាការយ៉ាងនេះ ក៏គង់ប្រសើរជាង ដូច្នោះ សូមលោកទឹមខ្ញុំចុះ កុំទឹមសេះដទៃឡើយ ។

នាយទាហាន លើកសេះពោធិសត្វឲ្យក្រោកឡើង រុំរបួសហើយ ចង ក្រោះរៀបរយ អង្គុយលើខ្នងព្រះពោធិសត្វនោះ ទម្លាយកងពលទី ៧ ចាប់ព្រះរាជាអង្គទី ៧ ហើយប្រគល់ឲ្យដល់ពលរបស់ព្រះរាជា មនុស្សទាំងឡាយ នាំព្រះពោធិសត្វមកកាន់ទ្វារព្រះរាជវាំង ព្រះរាជាទ្រង់ចេញដើម្បីទតព្រះពោធិ-សត្វនោះ ព្រះមហាសត្វទូលព្រះរាជាថា បពិត្រមហារាជ ទ្រង់កុំសម្លាប់ព្រះរាជាទាំង ៧ អង្គឡើយ សូមឲ្យធ្វើសម្បថ ហើយដោះលែងទៅ សូមទ្រង់ប្រទានយសដែលគប្បីប្រទានដល់ទូលបង្គំ និងទាហានសេះ ឲ្យយសចំពោះដល់ទាហានសេះប៉ុណ្ណោះ ការចាប់ព្រះរាជា ៧ អង្គបានហើយ ធ្វើទាហានដែលធ្វើការច្បាំងឲ្យវិនាស រមែងមិនគួរ សូម្បីព្រះអង្គក៏ទ្រង់បំពេញទាន រក្សាសីល ទ្រង់គ្រងរាជសម្បត្តិដោយធម៌ កាលព្រះពោធិសត្វឲ្យឱវាទដល់ព្រះរាជាយ៉ាងនេះហើយ ទើបមនុស្សទាំងឡាយដោះគ្រឿសរបស់ព្រះពោធិសត្វចេញ កាលដោះគ្រឿសប៉ុណ្ណោះ ព្រះពោធិសត្វនោះ ក៏អស់ជីវិតទៅហើយ ។ ព្រះរាជាទ្រង់ធ្វើឈាបនកិច្ចសរីរៈរបស់ព្រះពោធិសត្វនោះ បានប្រទានយសធំដល់នាយទាហានសេះ ទ្រង់ឲ្យព្រះរាជាទាំង ៧ អង្គធ្វើសម្បថ ដើម្បីមិន

ប្រទូស្តព្រះអង្គទៀត ហើយទ្រង់បញ្ជូនទៅកាន់លំនៅរៀងៗ ខ្លួន ទ្រង់គ្រង
រាជសម្បត្តិដោយធម៌ស្មើ ក្នុងកាលអស់ព្រះជន្មាយុ បានទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីបានធ្វើសេចក្តីព្យាយាមក្នុងទីដែលមិនមែនជាអណ្តូងកើតយ៉ាងនេះ បានទទួលរបួសបែបនេះ ក៏មិនលះបង់សេចក្តីព្យាយាម ឯអ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ ព្រោះហេតុអ្វី ទើបលះបង់នូវសេចក្តីព្យាយាម ហើយទ្រង់ប្រកាសសច្ចៈទាំង ៤ ក្នុងកាលចប់សច្ចៈ ភិក្ខុលះការព្យាយាម តាំងនៅក្នុងអរហត្តផល ចំណែកព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ទាហានសេះក្នុងកាលនោះ បានមកជាសារីបុត្រ ឯភោជាជានីយសិន្ធពក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ភោជាជានីយជាតក ចប់**

# សុត្តន្តបិដក

## អាជញ្ញជាតក

[ ២៤ ] *( សេះអាជានេយ្យពោធិសត្វពោលថា ) សេះអាជានេយ្យធ្វើនូវសម្បុះក្នុងទីណា ក្នុងកាលណាមួយៗ ឬ ក្នុងខណៈណា ក្នុងមណ្ឌលចម្បាំងណា ក្នុងកាលណាមួយៗ សេះសាមញ្ញទាំងឡាយ តែងសាបសូន្យក្នុងកាលណោះ ក្នុងទីនោះ ។*

*អាជញ្ញជាតកទី ៤ ចប់*

# អដ្ឋកថា

## អាជញ្ញជាតក

[ ២៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលលះបង់សេចក្តីព្យាយាមដូចគ្នា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យទា យទា** ដូច្នេះជាដើម ។

ព្រះសាស្តា ត្រាស់ហៅភិក្ខុនោះមកហើយថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីជាអ្នកបាននូវការប្រហារក្នុងទីដែលមិនមែនជាអាយតនៈ ក៏បានធ្វើសេចក្តីព្យាយាម ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះរាជា ៧ អង្គ នាំគ្នាព័ទ្ធព្រះនគរ ដោយន័យក្នុងរឿងមុននោះឯង ។ លំដាប់នោះ អ្នកចម្បាំងម្នាក់ទឹមរថមានសេះសិន្ធព ២ នាក់បងប្អូនចេញចាកព្រះនគរ ទម្លាយកងពលទី ៦ ចាប់បានព្រះរាជា ៦ អង្គ ។ ខណៈនោះ សេះបងបានត្រូវរបួស ទើបសារថីបញ្ជូនរថមកកាន់ព្រះរាជវាំង ដោះសេះដែលជាបងចេញអំពីរថ ធ្វើក្រោះឲ្យធូរ ហើយឲ្យដេកផ្អៀង ផ្តើមពាក់ក្រោះសេះដទៃ ។ ព្រះពោធិសត្វឃើញដូច្នោះ ទើបគិតដោយន័យក្នុងរឿងមុននោះឯង ហើយឲ្យហៅសារថីមកទាំងដែលដេកនោះឯង បានពោលគាថានេះថា

> សេះអាជានេយ្យ ធ្វើនូវសម្ពុះក្នុងទីណា ក្នុងកាលណាម្តងៗ ឬក្នុង
> ខណៈណា ក្នុងមណ្ឌលចម្បាំងណា ក្នុងកាលណាម្តងៗ សេះ
> សាមញ្ញទាំងឡាយ តែងសាបសូន្យ ក្នុងកាលណោះ ក្នុងទីនោះ
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទា យទា** បានដល់ ក្នុងកាលណាមួយ មានពេលព្រឹកជាដើម ។ បទថា **យត្ថ** បានដល់ ក្នុងទីណា គឺក្នុងផ្លូវ ឬក្នុងមណ្ឌលចម្បាំង ។ បទថា **យទា** គឺក្នុងខណៈណា ។ បទថា **យត្ថ យត្ថ** បានដល់ ក្នុងមណ្ឌលចម្បាំងដែលច្រើន ដូចគ្នានឹងកងពល ៧ កង ។ បទថា **យទា យទា** បានដល់ ក្នុងកាលណាមួយ គឺក្នុងកាលដែលបានទទួលរបួស ឬមិនបានទទួល ។ បទថា **អាជញ្ញោ កុរុតេ ជវំ** សេចក្តីថា សេះអាជានេយ្យ គឺសេះសិន្ធពដ៏ប្រសើរ ដែលមានភាវៈដឹងដល់ហេតុ ដែលចិត្តរបស់សារថីពេញចិត្ត ប្រើកម្លាំងរហ័ស គឺព្យាយាមប្រារព្ធសេចក្តីព្យាយាម ។ បទថា **ហាយន្តិ តត្ថ វាឡវា** សេចក្តីថា កាលសេះអាជានេយ្យនោះ ប្រើកម្លាំងរហ័ស សេះសាមញ្ញ ពាល គឺសេះញីក្រៅអំពីនោះ រមែងខ្ចាតចេញ គឺរមែងលាថយទៅ ព្រោះដូច្នោះ សូមលោកទឹមចំពោះខ្ញុំប៉ុណ្ណោះក្នុងរថនេះ ។

សារថីផ្គងព្រះពោធិសត្វឲ្យក្រោកឡើង ទឹមហើយ ទម្លាយនូវកងពលទី ៧ នាំយកព្រះរាជាអង្គទី ៧ មក បររថទៅកាន់ទ្វាររាជវាំង ហើយដោះសេះសិន្ធព ។ ព្រះពោធិសត្វដេកផ្អៀងម្ខាង ថ្វាយឱវាទដល់ព្រះរាជា ដោយន័យក្នុងរឿងមុននោះឯង ហើយអស់ជីវិតទៅ ។ ព្រះរាជាត្រាស់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់ព្រះពោធិសត្វនោះ ហើយធ្វើសមានៈ ( ការរាប់អាន ) ដល់សារថីប្រចាំរថនោះ ទ្រង់គ្រងរាជសម្បត្តិប្រកបដោយធម៌ស្មើ ស្តេចទៅតាមយថាកម្ម ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ ក្នុងវេលាចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងអរហត្តផល ។ ព្រះសាស្ដា ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ សារថីក្នុងកាលនោះ បានមកជាសារីបុត្រ ឯសេះអាជញ្ញ គឺតថាគតដែលជាសម្មាសម្ពុទ្ធនេះឯង ៕០៚

## អដ្ឋកថា អាជញ្ញជាតក ចប់

# សុត្តន្តបិដក

## តិត្ថជាតក

[ ២៥ ] *( អាមាត្យពោធិសត្វពោលថា ) ម្នាលសារថី អ្នកចូរញ៉ាំងសេះឲ្យផឹក ( ទឹក ) តាមកំពង់ទឹកទាំងឡាយដទៃៗ ចុះ ឯសេះផ្អែតដោយបាយាស ដោយការស៊ីជ្រុលហើយ ( រមែងមិនត្រូវការបរិភោគទៀតទេ ) ។*

***តិត្ថជាតកទី ៥ ចប់***

# អដ្ឋកថា

## តិត្ថជាតក

[ ២៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលធ្លាប់ជាជាងមាសមួយរូប ជាសទ្ធិវិហារិករបស់ព្រះធម្មសេនាបតី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អញ្ញមញ្ញេហិ តិត្ថេហិ** ដូច្នេះជាដើម ។

អាសយានុសយញ្ញាណ រមែងមានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមានដល់អ្នកដទៃ ព្រោះដូច្នោះ ទើបព្រះធម្មសេនាបតីមិនដឹងអាសយៈ គឺអជ្ឈាស្រ័យ និងអនុស័យ គឺកិលេសដែលត្រាំក្នុងសន្តានរបស់សទ្ធិវិហារិក ព្រោះភាពដែលខ្លួនមិនមានអាសយានុសយញ្ញាណ ទើបប្រាប់ចំពោះអសុភកម្មដ្ឋានប៉ុណ្ណោះ អសុភកម្មដ្ឋាននោះ មិនជាទីសប្បាយដល់សទ្ធិវិហារិកនោះ ព្រោះហេតុអ្វី ព្រោះបានឮថា សទ្ធិវិហារិករបស់ព្រះធម្មសេនាបតីនោះ បដិសន្ធិក្នុងផ្ទះរបស់ជាងមាសប៉ុណ្ណោះ អស់ ៥០០ ជាតិ តាមលំដាប់ កាលបើដូច្នោះ ទើបអសុភកម្មដ្ឋាន មិនជាទីសប្បាយដល់សទ្ធិវិហារិកនោះ ព្រោះជាអ្នកធ្លាប់ គឺជិតស្និទ្ធក្នុងការឃើញមាសបរិសុទ្ធប៉ុណ្ណោះ អស់កាលដ៏យូរ សទ្ធិវិហារិកនោះ មិនអាចធ្វើត្រឹមតែនិមិត្តឲ្យកើតឡើងក្នុងកម្មដ្ឋានោះបាន ឲ្យកាលកន្លងទៅ ៤ ខែ ។ ព្រះធម្មសេនាបតី កាលមិនអាចឲ្យអរហត្តដល់សទ្ធិវិហារិករបស់ខ្លួន ទើបគិតថា ភិក្ខុនេះជាពុទ្ធវេនេយ្យពិតប្រាកដ អញនឹងនាំទៅកាន់សម្នាក់នៃព្រះតថាគត ទើបនាំសទ្ធិវិហារិកនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាដោយខ្លួនឯងអំពីព្រលឹម ។ ព្រះសាស្តាត្រាស់សួរថា ម្នាលសារីបុត្រ អ្នកនាំភិក្ខុមួយរូបមកឬ ។ ព្រះសារីបុត្រក្រាបទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យកម្មដ្ឋានដល់ភិក្ខុនេះ តែភិក្ខុនេះមិនអាចធ្វើត្រឹមតែនិមិត្តឲ្យកើតឡើងបាន ដោយកាល ៤ ខែ ខ្ញុំព្រះអង្គគិតថា ភិក្ខុនេះជាពុទ្ធវេនេយ្យ ទើបនាំមកកាន់សម្នាក់របស់ទ្រង់ ។ ព្រះសាស្ដាត្រាស់សួរថា អ្នកឲ្យកម្មដ្ឋានប្រភេទណាដល់សទ្ធិវិហារិករបស់អ្នក ។ ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឲ្យអសុភកម្មដ្ឋាន ។ ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្រ អ្នកមិនមានញាណជាគ្រឿងដឹងអធ្យាស្រ័យ និងអនុស័យរបស់សត្វទាំងឡាយទេ អ្នកទៅសិនចុះ ល្ងាចអ្នកមក គប្បីនាំសទ្ធិវិហារិករបស់អ្នកទៅចុះ ។ ព្រះសាស្ដាទ្រង់បញ្ជូនព្រះថេរៈទៅយ៉ាងនេះហើយ បានឲ្យសំពត់ដណ្ដប់ និងចីវរដែលគួរពេញចិត្តដល់ភិក្ខុនោះ ហើយទ្រង់នាំភិក្ខុនោះចូលកាន់ស្រុកដើម្បីបិណ្ឌបាត ឲ្យនូវរបស់ទំពា និងរបស់ឆាន់ដ៏ប្រណីត ហោមរោមដោយមហាភិក្ខុសង្ឃ ត្រឡប់មកកាន់វិហារ ទ្រង់ញុំាងថ្ងៃឲ្យអស់ទៅក្នុងព្រះគន្ធកុដិ លុះពេលល្ងាច ទ្រង់នាំភិក្ខុនោះ ត្រាច់ចារិកទៅក្នុងវិហារ ហើយទ្រង់និម្មិតស្រះបោក្ខរណីមួយក្នុងអម្ពវ័ន ហើយទ្រង់និម្មិតគុម្ពឈូកធំក្នុងស្រះបោក្ខរណីនោះ ទ្រង់និម្មិតផ្កាឈូកធំមួយ ត្រង់កណ្ដាលគុម្ពឈូកនោះ ហើយប្រាប់ឲ្យអង្គុយចុះដោយព្រះតម្រាស់ថា ម្នាលភិក្ខុ ចូរអ្នកអង្គុយមើលផ្កាឈូកនេះ ហើយទ្រង់យាងចូលព្រះគន្ធកុដិ ។ ភិក្ខុនោះ សម្លឹងមើលផ្កាឈូកនោះរឿយៗ ។ ព្រះសាស្ដាទ្រង់ឲ្យផ្កាឈូកនោះស្រពោន ។ ផ្កាឈូកនោះ កាលភិក្ខុនោះកំពុងមើលនោះឯង បានប្តូរពណ៌ទៅ កាលបើដូច្នោះ ត្របកផ្កាឈូកនោះក៏ជ្រុះទៅ តាំងអំពីត្របកខាងក្រៅ បានជ្រុះទៅអស់មួយរំពេចនោះឯង ។

តអំពីនោះ កេសរក៏ជ្រុះទៅ សល់តែបណ្តូលខាងក្នុង ។ ភិក្ខុនោះឃើញដូច្នោះ ទើបគិតថា ផ្កាឈូកនេះល្អគួរមើលនោះឯង កាលបើដូច្នោះ ពណ៌របស់វាក៏ប្រែប្រួលទៅ ត្របក និងកេសរក៏រោយទៅ នៅសល់តែបណ្តូលប៉ុណ្ណោះ ការជរាគង់មានដល់ផ្កាឈូកមានសភាពបែបនេះ ចំណង់បើរាងកាយរបស់អញ សង្ខារទាំងឡាយ មិនទៀងហ្ន៎ ទើបផ្តើមវិបស្សនា ព្រះសាស្តាទ្រង់ជ្រាបថា ចិត្តរបស់ភិក្ខុនោះឡើងកាន់វិបស្សនាហើយ គង់នៅឯព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញឱភាសទៅ ហើយត្រាស់គាថានេះថា

អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទៈ
ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាព
តែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសម្តែងទុកហើយ ដូច្នេះ ។

ក្នុងកាលចប់គាថា ភិក្ខុនោះសម្រេចអរហត្ត ហើយគិតថា អញជាអ្នករួចផុតហើយចាកភពទាំងពួងហ្ន៎ ទើបបន្លឺឧទានដោយគាថាទាំងឡាយជាដើមថា

ខ្ញុំមានជន្មជាគ្រឿងនៅចប់ហើយ មានធន្ទៈក្នុងចិត្តបរិបូណ៌ហើយ
មានអាសវៈអស់ទៅហើយ ទ្រទ្រង់ទុកនូវរាងកាយជាទីបំផុត
មានសីលបរិសុទ្ធ មានឥន្ទ្រិយតាំងមាំដោយល្អ រួចផុតហើយ
ដូចព្រះចន្ទផុតចាកមាត់រាហូដូច្នោះ ខ្ញុំបន្ទោបង់មន្ទិលទាំងពួង
ដែលធ្វើនូវនិមិត្ត ដែលងងឹតអន្ធការព្រោះមោហៈ បានជាសមុច្ឆេទ
ដូចព្រះអាទិត្យមានរស្មីរាប់ពាន់កំពុងចែងចាំង ធ្វើនូវភាពរុងរឿង
ដោយពន្លឺ ក្នុងលម្អអាកាស ដូច្នោះ ។

កាលបន្ទឹឧទានហើយ ទើបមកថ្វាយបង្គំព្រះសាស្តា ឯព្រះថេរៈក៏មកថ្វាយបង្គំព្រះសាស្តា ហើយបានទាំសទ្ធិវិហារិករបស់ខ្លួនទៅ ។ ដំណឹងនេះកើតប្រាកដក្នុងភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយអង្គុយពណ៌នាគុណរបស់ព្រះទសពលក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ សារីបុត្តត្ថេរមិនដឹងអធ្យាស្រ័យសទ្ធិវិហារិករបស់ខ្លួន ព្រោះមិនមានអាសយានុសយញ្ញាណ តែព្រះសាស្តាទ្រង់ជ្រាប បានប្រទានអរហត្ត មួយអន្លើដោយបដិសម្ភិទាដល់ភិក្ខុនោះក្នុងពេលតែមួយថ្ងៃប៉ុណ្ណោះ ឱ ! ឈ្មោះថា ព្រះពុទ្ធទាំងឡាយ ទ្រង់មានអានុភាពច្រើន ព្រះសាស្តាយាងមកហើយ គង់លើអាសនៈដែលក្រាលហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយរឿងដទៃក៏មិនមែន តែអង្គុយសន្ទនាដោយរឿងព្រះញាណដឹងអធ្យាស្រ័យ និងអនុស្ស័យនៃសទ្ធិវិហារិករបស់ព្រះធម្មសេនាបតីរបស់ទ្រង់ប៉ុណ្ណោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនគួរអស្ចារ្យទេ ព្រោះឥឡូវនេះ តថាគតបានជាព្រះពុទ្ធហើយ តែងដឹងអធ្យាស្រ័យរបស់ភិក្ខុនោះ សូម្បីក្នុងកាលមុន តថាគតក៏ដឹងអធ្យាស្រ័យរបស់ភិក្ខុនោះដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ក្នុងកាលនោះ ព្រះពោធិសត្វជាអ្នកប្រដៅអត្ថ និងធម៌ដល់ព្រះរាជាអង្គនោះ ។ ក្នុងកាលនោះ អ្នកចិញ្ចឹមសេះឲ្យសេះសាមញ្ញខ្ទកជើង ងូត

មុនសេះដទៃ ក្នុងទីដែលសេះមង្គលរបស់ព្រះរាជាផឹក ។ សេះមង្គលត្រូវគេឲ្យចុះត្រង់កំពង់ដែលសេះខ្ចកផឹក ទើបខ្ពើមមិនប្រាថ្នានឹងចុះ អ្នកចិញ្ចឹមសេះមកក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សេះមង្គលមិនប្រាថ្នាចុះទឹក ព្រះរាជាទ្រង់ប្រាប់ព្រះពោធិសត្វថា នែបណ្ឌិត ចូរអ្នកទៅ ចូរដឹងថា ព្រោះហេតុអ្វី ទើបសេះគេឲ្យចុះទឹកមិនព្រមចុះ ។ ព្រះពោធិសត្វទទួលព្រះរាជបញ្ជា ហើយទៅកាន់ច្រាំងស្ទឹង ពិនិត្យមើលសេះ ក៏ដឹងថា សេះមិនមានរោគ ទើបពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ទើបសេះមិនចុះកំពង់នេះ បានគិតថា សេះដទៃនឹងត្រូវផឹកត្រង់កំពង់នេះមុន ដោយហេតុនោះ ទើបសេះនោះរង្កៀសមិនចុះទឹក ហើយសួរកន្សាលសេះថា នែអ្នក កំពង់នេះ អ្នកទាំងឡាយ ឲ្យសេះណាផឹកមុន ពួកអ្នកចិញ្ចឹមសេះពោលថា បពិត្រលោកម្ចាស់ ឲ្យពួកសេះខ្ចកផឹកមុនសេះដទៃ ។ ព្រះពោធិសត្វ ដឹងអធ្យាស្រ័យរបស់សេះនោះថា សេះនេះរង្កៀស ទើបមិនប្រាថ្នាផឹកក្នុងកំពង់នេះ ព្រោះខ្លួនជាសត្វមានសម្បត្តិ ការឲ្យសេះនេះផឹកក្នុងកំពង់ដទៃ ទើបគួរ ដូច្នេះហើយ ទើបពោលថា នែកន្សាលដ៏ចម្រើន បាយាសដែលចម្អិនដោយសប្បិ ទឹកឃ្មុំ និងទឹកអំពៅ កាលបុគ្គលបរិភោគរឿយៗ មុន រមែងមានការធុញទ្រាន់ សេះនេះផឹកក្នុងកំពង់នេះច្រើនដង ជាបឋម ចូរពួកអ្នក ឲ្យសេះនោះចុះកំពង់ដទៃ ហើយឲ្យផឹក និងផឹក ទើបពោលគាថានេះថា

ម្នាលសារថី អ្នកចូរញ៉ាំងសេះឲ្យផឹក ( ទឹក ) តាមកំពង់ទឹកទាំងឡាយដទៃៗ ចុះ ឯសេះឆ្អែតដោយបាយាស ដោយការស៊ី

ជ្រុលហើយ ( រមែងមិនត្រូវការបរិភោគទៀតទេ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អញ្ញមញ្ញោហិ** ញែកសព្ទចេញជា **អញ្ញោហិ អញ្ញោហិ** ប្រែថា ដទៃៗ ។ បទថា **ចាយេហិ** ប្រែថា ចូរឲ្យផឹក នេះជាមាតិកាទេសនា អធិប្បាយថា ចូរឲ្យងូត និងឲ្យផឹក ។ បទថា **អច្ចាសនស្ស** នេះជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា បរិភោគក្រៃលែង គឺបរិភោគច្រើន ។ បទថា **ចាយាសស្សាបិ តប្បតិ** សេចក្តីថា រមែងឆ្អែត គឺជាអ្នកឆ្អែត ជាបុគ្គលដែលគេឲ្យបរិភោគឆ្អែតហើយដោយមធុបាយាស ចម្អិនដោយសប្បិជាដើម រមែងមិនដល់នូវភាពជាបុគ្គលដែលត្រូវការបរិភោគទៀត ព្រោះដូច្នោះ សេះនេះក៏នឹងដល់នូវការគ្រប់គ្រាន់ ព្រោះការងូតជាប្រចាំត្រង់កំពង់នេះ ចូរអ្នកឲ្យងូតត្រង់កំពុងដទៃចុះ ។

អ្នកចិញ្ចឹមសេះទាំងនោះ បានស្តាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ ទើបឲ្យសេះចុះត្រង់កំពង់ដទៃ ឲ្យផឹក និងឲ្យងូត ក្នុងកាលដែលសេះផឹកងូតហើយ ព្រះពោធិសត្វបានមកកាន់សម្នាក់របស់ព្រះរាជាៗ ត្រាស់សួរថា នៃបា សេះងូត និងផឹកហើយឬ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ផឹក ងូតហើយ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបដំបូងសេះមិនប្រាថ្នា ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រោះហេតុឈ្មោះនេះ ហើយក្រាបទូលហេតុទាំងពួង ។ ព្រះរាជាត្រាស់ថា ឱ ! អ្នកជាបណ្ឌិត រមែងដឹងអធ្យាស្រ័យរបស់សត្វតិរច្ឆានបែបនេះ ហើយប្រទាន

យសធំដល់ព្រះពោធិសត្វ ក្នុងកាលអស់អាយុ បានទៅតាមយថាកម្ម ហើយ ឯព្រះពោធិសត្វ ក៏ទៅតាមយថាកម្មដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតដឹងអធ្យាស្រ័យរបស់ភិក្ខុនេះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ដឹងដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា សេះមង្គលក្នុងកាលនោះ បានមកជាភិក្ខុរូបនេះ ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯអមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា តិត្ថជាតក ចប់

# សុត្តន្តបិដក

## មហិឡាមុខជាតក

[ ២៦ ] *( អាមាត្យពោធិសត្វពោលថា ) ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ ( ហ្មដំរី ) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។*

**មហិឡាមុខជាតកទី ៦ ចប់**

# អដ្ឋកថា

## មហិឡាមុខជាតក

[ ២៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពោរាណចោរាន វចោ និសម្ម** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ទេវទត្តធ្វើឲ្យអជាតសត្តុកុមារជ្រះថ្លា ហើយញ៉ាំង លាភសក្ការៈឲ្យកើតឡើង អជាតសត្តុកុមារឲ្យសាងវិហារត្រង់តំបន់គយាសីសៈ ដើម្បីទេវទត្តភិក្ខុ ហើយនាំទៅចំពោះភោជន ស្រូវសាលីមានក្លិនក្រអូបដែល រក្សា ៣ ឆ្នាំ ១ ថ្ងៃ ៥០០ សម្រាប់ ដោយរសដ៏លើសផ្សេងៗ ព្រោះ អាស្រ័យលាភសក្ការៈ ទើបបរិវាររបស់ទេវត្តធំឡើង ទេវទត្ត ព្រមទាំងបរិវារ នៅក្នុងវិហារនោះឯង ។ សម័យនោះ មានសម្លាញ់ ២ នាក់ ដែលជាអ្នក ក្រុងរាជគ្រឹះ ក្នុងសម្លាញ់ ២ នាក់នោះ ម្នាក់បួសក្នុងសម្នាក់របស់ព្រះសាស្តា ម្នាក់បួសក្នុងសម្នាក់ទេវទត្ត សម្លាញ់ទាំង ២ នោះ រមែងឃើញគ្នាក្នុងទីនោះៗ សូម្បីទៅវិហារក៏នៅឃើញគ្នា ។ ថ្ងៃមួយ ភិក្ខុដែលជានិស្សិតរបស់ទេវទត្ត ពោលនឹងភិក្ខុក្រៅអំពីនោះថា អាវុសោ អ្នកត្រាច់បិណ្ឌបាត មានញើសហូរ រាល់ៗ ថ្ងៃធ្វើអ្វី លោកអង្គុយក្នុងវិហារត្រង់តំបន់គយាសីសៈប៉ុណ្ណោះ នឹង បានបរិភោគភោជនល្អ ដោយរសដ៏ប្រសើរផ្សេងៗ បាយាសបែបនេះ មិន មានក្នុងវិហារនេះ លោកនៅសោយទុក្ខធ្វើអ្វី ប្រយោជន៍អ្វីដល់លោក ការ មកកាន់គយាសីសៈអំពីព្រលឹម ហើយផាន់បបរ មួយអន្ទើដោយសម្ភារៈត្តិរិកទ្គ ទំពារបស់គួរទំពា ១៨ ប្រភេទ ហើយបរិភោគភោជនល្អ ដោយរសដ៏ប្រសើរ

ផ្សេងៗ មិនគួរឬ ។ ភិក្ខុនោះ ត្រូវបបួលរឿយៗ ជាអ្នកបំណាន់នឹងទៅ ។ តាំងអំពីនោះ ទើបទៅកាន់គយាសីសៈ បរិភោគហើយ មកកាន់វត្តវេឡុវ័ន ក្នុងពេលរសៀល ។ ភិក្ខុនោះមិនអាចបិទបាំងបានរហូត មិនយូរប៉ុន្មាន ដំណឹងក៏ប្រាកដថា ភិក្ខុនោះទៅគយាសីសៈ បរិភោគភត្តដែលគេឧបដ្ឋាកទេវទត្ត ។

សម័យនោះ សម្លាញ់ទាំងឡាយ នាំគ្នាសួរភិក្ខុនោះថា អាវុសោ បានឮថា លោកបរិភោគភត្តដែលគេឧបដ្ឋាកដល់ទេវទត្តពិតឬ ភិក្ខុនោះពោលថា អ្នកណាពោលយ៉ាងនេះ ។ សម្លាញ់ទាំងនោះពោលថា បុគ្គលនោះ និងបុគ្គលនោះ ជាអ្នកពោល ភិក្ខុនោះពោលថា អាវុសោទាំងឡាយ ខ្ញុំទៅគយាសីសៈ បរិភោគពិត តែទេវទត្តមិនបានឲ្យដល់ខ្ញុំ អ្នកដទៃៗ ឲ្យ ។ ភិក្ខុជាសម្លាញ់ពោលថា អាវុសោ ទេវទត្តជាបច្ចាចំពោះព្រះពុទ្ធ ជាអ្នកទ្រុស្តសីល ញុំាងព្រះបាទអជាតសត្តុឲ្យជ្រះថ្លា ហើយញុំាងលាភសក្ការៈឲ្យកើតដល់ខ្លួន មិនប្រកបដោយធម៌ លោកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ ហើយបរិភោគភោជនដែលកើតឡើងដល់ទេវទត្ត ដែលមិនប្រកបដោយធម៌មិនសមគួរឡើយ មកយើងទាំងឡាយ នឹងនាំលោកទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយនាំភិក្ខុនោះមកកាន់ធម្មសភា ។ ព្រះសាស្តាទ្រង់ឃើញភិក្ខុនោះប៉ុណ្ណោះ ទើបត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនប្រាថ្នានេះមកហើយឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបួសក្នុងសម្នាក់របស់ព្រះអង្គ ហើយបរិភោគភោជនដែលកើតឡើងដល់ទេវទត្ត ដែលមិនប្រកបដោយធម៌ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ

បានឮថា អ្នកបរិភោគភោជនដែលកើតដល់ទេវទត្ត ដែលមិនប្រកបដោយធម៌ពិតឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តភិក្ខុមិនបានឲ្យភត្តដល់ខ្ញុំព្រះអង្គទេ អ្នកដទៃឲ្យដល់ខ្ញុំព្រះអង្គ ទើបខ្ញុំព្រះអង្គបរិភោគភត្តនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកកុំបណ្តោះបណ្តៅក្នុងរឿងនេះ ទេវទត្តជាអ្នកមិនមានអាចារ ជាអ្នកទ្រុស្តសីល បួសក្នុងសាសនានេះហើយ គប់រកសាសនារបស់តថាគតនោះឯង បរិភោគភត្តរបស់ទេវទត្តបានដូចម្តេច អ្នកមានប្រក្រតីគប់រកជានិច្ចកាល ក៏គង់គប់រកបុគ្គលដែលឃើញហើយ កាលត្រាស់ហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអមាត្យរបស់ព្រះបាទព្រហ្មទត្តនោះ ក្នុងកាលនោះ ដំរីមង្គលរបស់ព្រះបាទព្រហ្មទត្ត ឈ្មោះមហិឡាមុខ ជាដំរីមានសីល សម្បូរដោយអាចារមារយាទ មិនបៀតបៀនបុគ្គលណាម្នាក់ ថ្ងៃមួយ ចោរទាំងឡាយមកក្នុងទីជិតរោងដំរីនោះ ក្នុងលំដាប់កាលដែលជាចំណែករាត្រី អង្គុយប្រឹក្សាការលួច ក្នុងទីមិនឆ្ងាយអំពីដំរីនោះថា ត្រូវជីកឧមង្គយ៉ាងនេះ ត្រូវធ្វើការកាត់ទីតយ៉ាងនេះ ការធ្វើឧមង្គ និងការកាត់ទីតឲ្យប្រាសចាកព្រៃ ឲ្យប្រាសចាកគុម្ពឈើ ដូចគ្នានឹងផ្លូវ ដូចគ្នានឹងកំពង់ទឹក ហើយលួចយកវត្ថុទៅ ទើបគួរ ។ បុគ្គលកាលលួច ត្រូវសម្លាប់ និងត្រូវប្រហារហើយ សឹមលួច កាលបើដូច្នេះ បុគ្គលដែលឈ្មោះថា អាចក្រោកឡើង នឹងមិនមាន ធម្មតាចោរត្រូវជាអ្នកមិនប្រកបដោយសីល និងអាចារ ត្រូវតែជាមនុស្សរឹងត្អឹង គ្រោតគ្រាត ក្អេង

ក្អាន កាលប្រឹក្សាគ្នាយ៉ាងនេះហើយ ទើបឲ្យគ្នានិងគ្នារៀនយក ហើយបាន នាំគ្នាទៅ ពួកចោរមកប្រឹក្សាក្នុងទីនោះ ដោយន័យនោះឯងច្រើនថ្ងៃ គឺក្នុងថ្ងៃ ស្អែកឡើង ខានស្អែកឡើង ។ ដំរីបានស្តាប់ពាក្យរបស់ចោរទាំងនោះ សម្គាល់ ថា មនុស្សទាំងនេះ ឲ្យអញសិក្សា ទើបគិតថា ឥឡូវនេះ អញត្រូវតែរឹងត្អឹង គ្រោតគ្រាត ឃោរឃៅ ក៏បានទៅជាបុគ្គលបែបនោះ យកប្រមោយចាប់ហ្មដំរី ដែលមកអំពីព្រលឹម បោកផ្ទប់នឹងផែនដីឲ្យស្លាប់ សម្លាប់មនុស្សដែលមក ហើយម្តងមួយៗ ។

ពួករាជបុរស ក្រាបទូលដល់ព្រះរាជាថា ដំរីមហិឡាមុខច្កូត សម្លាប់ មនុស្សដែលបានឃើញហើយ ព្រះរាជាទ្រង់បញ្ជូនព្រះពោធិសត្វទៅ ដោយ ព្រះតម្រាស់ថា នែបណ្ឌិត ចូរអ្នកទៅ ចូរដឹងថា ដំរីនោះកាច ព្រោះហេតុអ្វី ។ ព្រះពោធិសត្វទៅហើយ ដឹងថា ដំរីនោះមិនមានរោគក្នុងកាយ ទើបគិតថា ព្រោះហេតុអ្វីហ្ន៎ ទើបដំរីនេះ ក្លាយជាដំរីកាច លុះពិចារណា ទើបសន្និដ្ឋានថា ដំរីនេះបានស្តាប់ពាក្យរបស់អ្នកណាម្នាក់ ក្នុងទីមិនឆ្ងាយ សម្គាល់ថា មនុស្ស ទាំងនេះឲ្យអញសិក្សា ទើបទៅជាដំរីកាចដោយពិត សួរពួកអ្នកចិញ្ចឹមដំរីថា បុគ្គលពួកខ្លះ ធ្លាប់ពោលពាក្យណាមួយក្នុងពេលយប់ ក្នុងទីជិតដំរីមានឬហ្ន៎ ពួកអ្នកចិញ្ចឹមដំរីពោលថា បពិត្រលោកម្ចាស់ ពួកចោរនាំគ្នាមកពោល ទើប ព្រះពោធិសត្វក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ការពិការមិន មានក្នុងរាងកាយនៃដំរីទ្រង់ទេ ដំរីនោះកាច ព្រោះបានស្តាប់ពាក្យរបស់ពួក ចោរ ។ ព្រះរាជាត្រាស់សួរថា ឥឡូវនេះ គួរធ្វើដូចម្តេច ព្រះពោធិសត្វក្រាប

ទូលថា គួរនិមន្តសមណព្រាហ្មណ៍អ្នកមានសីល ឲ្យអង្គុយក្នុងរោងដំរី ហើយពោលដល់សីល និងអាចារ ។ ព្រះរាជាត្រាស់ថា ចូរធ្វើយ៉ាងនោះចុះ ។ ទើបព្រះពោធិសត្វនិមន្តសមណព្រាហ្មណ៍ទាំងឡាយដែលមានសីល ឲ្យអង្គុយក្នុងរោងដំរី ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយពោលសីលកថា ។ សមណព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីមិនឆ្ងាយ នាំគ្នាពោលសីលកថាថា មិនគប្បីបៀតបៀនអ្នកដទៃ មិនគប្បីជេរបុគ្គលណាម្នាក់ គួរជាអ្នកដល់ព្រមដោយសីល និងអាចារ ជាអ្នកប្រកបដោយខន្តី មេត្តា និងការអាណិតអាសូរ ដំរីនោះបានស្តាប់ដូច្នោះ គិតថា សមណព្រាហ្មណ៍ទាំងនេះឲ្យអញសិក្សា ចាប់តាំងអំពីនេះទៅ អញគួរជាអ្នកមានសីល ទើបជាអ្នកមានសីលហើយ ។ ព្រះរាជាត្រាស់សួរព្រះពោធិសត្វថា តើដំរីជាអ្នកមានសីលហើយឬ ។ ព្រះពោធិសត្វក្រាបទូលថា មានហើយ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ដំរីកាចបែបនេះ អាស្រ័យបណ្ឌិតទាំងឡាយ ទើបតាំងនៅក្នុងបុរាណធម៌បាន ហើយពោលគថានេះថា

ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយ
មុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ ( ហ្មដំរី ) លុះបាន
ស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ ក៏បានតាំងនៅ
ក្នុងគុណគ្រប់យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុរាណចោរានំ** បានដល់ ពួកចោរសម័យមុន ។ បទថា **និសម្ម** បានដល់ ព្រោះបានស្តាប់ អធិប្បាយថា ព្រោះបាន

ស្តាប់ពាក្យរបស់ពួកចោរមុន ។ បទថា **មហិឡាមុខោ** បានដល់ មានមុខដូចគ្នានឹងមុខដំរីញី ម្យ៉ាងទៀត ដំរីញី កាលសម្លឹងខាងមុខ ទើបស្អាត សម្លឹងមើលខាងក្រោយ មិនស្អាត យ៉ាងណា ដំរីនោះក៏ដូច្នោះ កាលមើលខាងមុខទើបស្អាត ព្រោះដូច្នោះ ទើបជនទាំងឡាយតាំងឈ្មោះដំរីនោះថា មហិឡាមុខ ។ បទថា **ចោជយមានុចារិ** សេចក្តីថា ត្រាច់តាមវាល គឺសម្លាប់ ម្យ៉ាងទៀតព្រះបាលីក៏យ៉ាងនោះឯង ។ បទថា **សុសញ្ញតានំ** បានដល់ សង្រួមដោយល្អ គឺមានសីល ។ បទថា **គជុត្តមោ** បានដល់ ដំរីឧត្តម គឺដំរីមង្គល ។ បទថា **សព្វគុណេសុ អដ្ឋ** បានដល់ តាំងនៅចំពោះបុរាណគុណទាំងពួង ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះពោធិសត្វដឹងអធ្យាស្រ័យ សូម្បីសត្វតិរច្ឆានទាំងឡាយ ទើបប្រទានយសធំ ព្រះរាជានោះ តាំងនៅដរាបដល់អស់ព្រះជន្មាយុ ទៅតាមយថាកម្ម ឯព្រះពោធិសត្វក៏ដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកក៏គប់រកបុគ្គលដែលជួបហើយ ឃើញហើយដូចគ្នា ព្រោះបានស្តាប់ពាក្យរបស់ពួកចោរ ក៏បានសេពគប់ពួកចោរ ព្រោះបានស្តាប់ពាក្យរបស់សមណព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ ទើបគប់រកបុគ្គលដែលតាំងនៅក្នុងធម៌ កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា ដំរីមហិឡាមុខក្នុងកាលនោះ បានមកជាភិក្ខុត្រចៀកស្រោលក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯអមាត្យក្នុងកាលនោះ គឺតថាគតជាសម្មាសម្ពុទ្ធនេះឯង ។ល។

# សុត្តន្តបិដក

## អភិណ្ហជាតក

[ ២៧ ] *( អាមាត្យពោធិសត្វពោលថា ) ( ដំរី ) មិនអាចកាន់យកនូវពំនូតបាយ មិនអាចកាន់យកនូវដុំបាយ មិនអាចកាន់យកនូវស្មៅទាំងឡាយ មិនអាចត្រដុស ( សរីរៈ ) ទេ ខ្ញុំសម្គាល់ថា ដំរីបានធ្វើសេចក្ដីស្រឡាញ់ស្និទ្ធស្នាលចំពោះឆ្កែ ព្រោះការឃើញរឿយៗ ។*

***អភិណ្ហជាតកទី ៧ ចប់***

# អដ្ឋកថា

## អភិណ្ហជាតក

[ ២៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ និងព្រះថេរៈចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **នាលំ កពលំ បទាតវេ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានសម្លាញ់ ២ នាក់ បណ្ដាសម្លាញ់ទាំង ២ នោះ ម្នាក់បួសហើយ បានទៅកាន់ផ្ទះរបស់សម្លាញ់ក្រៅអំពីនេះរាល់ថ្ងៃ ។ សម្លាញ់នោះ បានប្រគេនភិក្ខាដល់ភិក្ខុជាសម្លាញ់នោះ សូម្បីខ្លួនឯងក៏បរិភោគហើយ បានទៅវិហារជាមួយភិក្ខុសម្លាញ់នោះឯង អង្គុយសន្ទនា ប្រាស្រ័យរហូតព្រះអាទិត្យអស្តង្គត ទើបត្រឡប់ចូលក្រុង ។ ឯភិក្ខុជាសម្លាញ់ក្រៅអំពីនេះ ក៏តាមសម្លាញ់នោះទៅរហូតដល់ទ្វារក្រុង ហើយក៏ត្រឡប់ ។ ការស្និទ្ធស្នាលរបស់សម្លាញ់ទាំង ២ នោះ កើតប្រាកដក្នុងរវាងភិក្ខុទាំងឡាយ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយ អង្គុយពោលដល់ការស្និទ្ធស្នាលរបស់សម្លាញ់ទាំង ២ នោះ ក្នុងធម្មសភា ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថារឿងឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ទាំង ២ នេះ ជាអ្នកស្និទ្ធស្នាលគ្នាតែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាអ្នកស្និទ្ធស្នាលដូចគ្នា ហើយទ្រង់នាំអតីតនិទានមកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ក្នុងកាលនោះ ព្រះពោធិសត្វបានជាអមាត្យរបស់ព្រះបាទព្រហ្មទត្តនោះ ។ ក្នុងកាលនោះ ឆ្កែមួយទៅកាន់រោងដំរីមង្គល ស៊ីគ្រាប់បាយដែលធ្លាក់ក្នុងទីដំរីមង្គលបរិភោគ ឆ្កែនោះជំពាក់ដោយភោជននោះឯង ទើបកើតការស្និទ្ធស្នាលជាមួយដំរីមង្គល បរិភោគក្នុងសម្នាក់ដំរីរបស់ដំរីមង្គលនោះឯង សត្វទាំង ២ មិនអាចប្រព្រឹត្តទៅវៀរចាកគ្នាបាន ។ ដំរីនោះយកប្រមោយចាប់ឆ្កែនោះប្រមៀលលេងទៅមក លើកដាក់លើពោងខ្នះ ។ ថ្ងៃមួយ មនុស្សអ្នកស្រុកម្នាក់ឲ្យមូលតម្លៃដល់អ្នកចិញ្ចឹមដំរី ហើយនាំយកឆ្កែនោះទៅផ្ទះរបស់ខ្លួន តាំងអំពីនោះ ដំរីនោះមិនឃើញឆ្កែ ក៏មិនបរិភោគ មិនផឹក មិនងូត ទើបអ្នកចិញ្ចឹមដំរីក្រាបទូលរឿងនោះដល់ព្រះរាជាៗ ទ្រង់បញ្ជូនព្រះពោធិសត្វទៅដោយព្រះតម្រាស់ថា នែបណ្ឌិត ចូរអ្នកទៅ ចូរដឹងថា ព្រោះហេតុអ្វី ទើបដំរីធ្វើយ៉ាងនោះ ព្រះពោធិសត្វទៅកាន់រោងដំរី ដឹងថា ដំរីខូចចិត្ត គិតថា រោគមិនប្រាកដក្នុងរាងកាយរបស់ដំរីនេះ ឯការស្និទ្ធស្នាលក្នុងឋានៈជាមិត្រជាមួយសត្វណាមួយ គប្បីមានដល់ដំរីនោះ ដំរីនោះប្រហែលជាមិនឃើញមិត្រ ទើបត្រូវសេចក្ដីសោកគ្របសង្កត់ កាលគិតហើយ ទើបសួរពួកអ្នកចិញ្ចឹមដំរីថា ការស្និទ្ធស្នាលជាមួយសត្វណាមួយរបស់ដំរីនេះមានឬ ។ ពួកអ្នកចិញ្ចឹមដំរីពោលថា មាន ដំរីនេះធ្លាប់ស្និទ្ធស្នាលជាមួយឆ្កែមួយក្បាល ។ ព្រះពោធិសត្វសួរថា ឥឡូវនេះ ឆ្កែនោះនៅឯណា អ្នកចិញ្ចឹមដំរីពោលថា មនុស្សម្នាក់នាំទៅ ព្រះពោធិសត្វ សួរថា ទីនៅអាស្រ័យរបស់មនុស្សនោះ ពួកអ្នកដឹងឬទេ ពួកអ្នក

ចិញ្ចឹមដំរីពោលថា មិនដឹងទេ ព្រះពោធិសត្វបានទៅកាន់សម្នាក់របស់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ជំងឺណាមួយរបស់ដំរីមិនមាន តែដំរីនោះមានការស្និទ្ធស្នាលយ៉ាងខ្លាំងក្លា ជាមួយឆ្កែមួយក្បាល ដំរីនោះប្រហែលជាមិនឃើញឆ្កែនោះ ទើបមិនបរិភោគ ហើយពោលគាថានេះថា

( ដំរី ) មិនអាចកាន់យក នូវពំនូតបាយ មិនអាចកាន់យកនូវដុំបាយ
មិនអាចកាន់យកនូវស្មៅទាំងឡាយ មិនអាចត្រដុស ( សរីរៈ )
ទេ ខ្ញុំសម្គាល់ថា ដំរី បានធ្វើសេចក្ដីស្រឡាញ់ស្មោះចំពោះឆ្កែ
ព្រោះការឃើញរឿយៗ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នាលំ** បានដល់ មិនអាច ។ បទថា **កពលំ** បានដល់ ដុំបាយដែលឲ្យដំបូងក្នុងពេលបរិភោគ ។ បទថា **បធាតវេ** បានដល់ ដើម្បីទទួលយក ។ គប្បីជ្រាបការលុប **អា** អក្ខរៈ ទាក់ទងដោយវិធីសន្ធិ គឺការភ្ជាប់សព្ទ អធិប្បាយថា ដើម្បីកាន់យក ។ បទថា **ន បិណ្ឌំ** បានដល់ មិនអាចទទួលយកដុំកត្ត ដែលចែករំលែកឲ្យ ។ បទថា **ន កុសេ** បានដល់ មិនអាចទទួលយកស្មៅទាំងឡាយដែលគេឲ្យបរិភោគ ។ បទថា **ន ឃំសិតុំ** សេចក្ដីថា ឲ្យងូតក៏មិនអាចនឹងត្រដុសរាងកាយ ។ ព្រះពោធិសត្វក្រាបទូលព្រះរាជាដល់ហេតុទាំងពួង ដែលដំរីនោះមិនអាចធ្វើយ៉ាងនេះហើយ កាលក្រាបទូលដល់ហេតុដែលខ្លួនកំណត់ ព្រោះដំរីនោះមិនអាច ទើបក្រាបទូលពាក្យជាដើមថា **មញ្ញាមិ** ដូច្នេះ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ ទើបត្រាស់សួរថា

នៃបណ្ឌិត ឥឡូវនេះ គួរធ្វើដូចម្តេច ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព បានឮថា មនុស្សម្នាក់នាំយកឆ្កែដែលជាសម្លាញ់របស់ដំរីមង្គលទៅ សូមទ្រង់ឲ្យមនុស្សវាយស្គរប្រកាសថា ជនទាំងឡាយ ឃើញឆ្កែនោះក្នុងផ្ទះរបស់បុគ្គលណា បុគ្គលនោះនឹងពិន័យយ៉ាងនេះ ដូច្នេះ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះ ។ បុរសនោះបានស្តាប់ដំណឹងនោះ ទើបលែងឆ្កែ ឆ្កែនោះប្រញាប់ទៅ បានទៅកាន់សម្នាក់របស់ដំរីនោះឯង ដំរីយកប្រមោយចាប់ឆ្កែនោះដាក់លើពោង អង្អួចហើយ លើកចុះអំពីក្បាល កាលឆ្កែនោះស៊ី ទើបខ្លួនស៊ីជាខាងក្រោយ ព្រះរាជាទ្រង់តម្រិះថា ព្រះពោធិសត្វដឹងអធ្យាស្រ័យរបស់សត្វតិរច្ឆាន ទើបបានប្រទានយសធំដល់ព្រះពោធិសត្វ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ២ រូបនេះ ជាអ្នកស្និទ្ធស្នាលក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាអ្នកស្និទ្ធស្នាលមកហើយ កាលទ្រង់នាំទេសនានេះមកហើយ ទ្រង់សម្តែងកថាពោលដោយសច្ចៈ ៤ ទ្រង់បន្តអនុសន្ធិ ហើយប្រជុំជាតក ឈ្មោះថា បរិវត្តដោយសច្ចៈ ៤ នេះ រមែងមានគ្រប់ជាតកនោះឯង តែយើងទាំងឡាយ នឹងសម្តែងបរិវត្តក្នុងជាតកដែលប្រាកដអានិសង្សដល់បុគ្គលនោះប៉ុណ្ណោះ ។ ឆ្កែក្នុងកាលនោះ បានជាឧបាសកក្នុងកាលឥឡូវនេះ ដំរីក្នុងកាលនោះ បានមកជាព្រះថេរៈ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯបណ្ឌិតដែលជាអមាត្យក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថាអភិណ្ហជាតក ចប់**

# សុត្តន្តបិដក

## នន្ទិវិសាលជាតក

[ ២៨ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាននិយាយពាក្យជាទីគាប់ចិត្ត ( គោនន្ទិវិសាល ) បានទាញភារៈដ៏ធ្ងន់រួច ញ៉ាំងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយ ដោយការញ៉ាំងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង ។

*នន្ទិវិសាលជាតកទី ៨*

# អដ្ឋកថា

## នន្ទិវិសាលជាតក

[ ២៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការពោលពាក្យគ្រោតគ្រាតរបស់ឆព្វគ្គិយភិក្ខុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មនុញ្ញមេវ ភាសេយ្យ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យនោះ ពួកឆព្វគ្គិយកាលធ្វើទូវជម្លោះ រមែងសម្តុតរមែងគំរាម រមែងចាក់ដោត រមែងជេរដោយអាក្កោសវត្ថុ ១០ ប្រការ ទើបភិក្ខុទាំងឡាយក្រាបទូលដល់ព្រះមានព្រះភាគៗ ត្រាស់ឲ្យហៅឆព្វគ្គិយភិក្ខុមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកធ្វើទូវជម្លោះពិតឬ កាលឆព្វគ្គិយភិក្ខុក្រាបទូលថា ពិតហើយព្រះអង្គ ទើបទ្រង់តិះដៀលហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា វាចាគ្រោតគ្រាតនាំតែសេចក្តីវិនាសមកឲ្យ វាចានេះមិនជាទីពេញចិត្ត សូម្បីតែសត្វតិរច្ឆាន ក្នុងកាលមុនសត្វតិរច្ឆានមួយ រមែងញុំាងបុគ្គលដែលហៅខ្លួនដោយពាក្យគ្រោតគ្រាតឲ្យចាញ់ដោយទ្រព្យ ១០០០ ហើយទើបទ្រង់សម្តែងអតីតនិទានដូចតទៅ

ក្នុងអតីតកាល ព្រះរាជាឈ្មោះគន្ធារៈ គ្រងរាជសម្បត្តិ ក្នុងនគរតក្កសិលា ដែនគន្ធារៈ ព្រះពោធិសត្វកើតក្នុងកំណើតគោ ។ ក្នុងកាលដែលព្រះពោធិសត្វជាគោជំទង់នោះឯង ព្រាហ្មណ៍ម្នាក់ បានព្រះពោធិសត្វនោះមកអំពីសម្នាក់របស់ទាយកដែលឲ្យទក្ខិណា តាំងឈ្មោះថា នន្ទិវិសាល ហើយតាំងទុកក្នុងឋានៈជាបុត្តដែលជាទីស្រឡាញ់ ឲ្យបបរ និងភត្តជាដើម ទំនុកបម្រុងហើយ ។ ព្រះពោធិសត្វចម្រើនវ័យហើយ គិតថា ព្រាហ្មណ៍នេះប្រណិប័តន៍

អញបានដោយលំបាក ឈ្មោះថា គោជទៃដែលមានធុរៈស្មើអញ រមែងមិនមានក្នុងជម្ពូទ្វីបទាំងមូល បើដូច្នោះ អញគប្បីសម្ដែងកម្លាំងរបស់ខ្លួន ហើយគប្បីឲ្យថ្លៃចិញ្ចឹមដល់ព្រាហ្មណ៍ ។ ថ្ងៃមួយ ព្រះពោធិសត្វនោះពោលនឹងព្រាហ្មណ៍ថា ព្រាហ្មណ៍ សូមលោកចូលទៅរកគោវិន្ទកសេដ្ឋីនោះ ហើយពោលថា គោបម្រើរបស់ខ្ញុំ អាចញ៉ាំងរទេះ ១០០ ដែលចងជាប់គ្នាឲ្យទៅមុខបាន សូមលោកធ្វើការភ្នាល់ដោយទ្រព្យ ១០០០ កហាបណៈ ទើបព្រាហ្មណ៍នោះទៅកាន់សម្នាក់សេដ្ឋីសន្ទនាថា ក្នុងនគរនេះ គោរបស់អ្នកណាដល់ព្រមដោយកម្លាំង និងសម្ទុះ ។ លំដាប់នោះ ទើបសេដ្ឋីពោលនឹងព្រាហ្មណ៍នោះថា គោរបស់អ្នកនោះ និងគោរបស់អ្នកនោះ ហើយពោលថា គោក្នុងនគរទាំងមូលដូចគោរបស់ខ្ញុំមិនមាន ព្រាហ្មណ៍ពោលថា គោរបស់ខ្ញុំអាចឲ្យរទេះ ១០០ ដែលចងភ្ជាប់គ្នា កម្រើកទៅបាន ។ សេដ្ឋីពោលថា នែគហបតី គោបែបនេះនឹងមានមកអំពីណា ។ ព្រាហ្មណ៍ពោលថា មានក្នុងផ្ទះរបស់ខ្ញុំ ។ សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកដាក់ដើមផាន់ ព្រាហ្មណ៍ពោលថា សាធុ ខ្ញុំនឹងដាក់ ហើយបានដាក់ដើមផាន់ ដោយទ្រព្យ ១០០០ កហាបណៈ ។

ព្រាហ្មណ៍នោះញ៉ាំងរទេះឲ្យពេញដោយខ្សាច់ ក្រួស និងថ្មជាដើម ហើយតម្រៀបតាមលំដាប់ ចងរទេះទាំងអស់ចូលគ្នា ដោយខ្សែស្រម្រាប់ចងភ្លៅ ហើយឲ្យគោនន្ទិវិសាលងូតទឹក ប្រោះព្រំដោយគ្រឿងក្រអូប ប្រដាប់នូវកម្រងមាលាត្រង់ក ហើយទឹមគោមួយប៉ុណ្ណោះ ត្រង់ទូករទេះទី ១ ខ្លួនឯងអង្គុយត្រង់ទូករទេះ ងារនូវពន្លួញឡើង ពោលថា ចូរអូសទៅ អាគោកៀច ចូរនាំ

ទៅអាគោកៀច ។ ព្រះពោធិសត្វគិតថា ព្រាហ្មណ៍នេះ ហៅអញដែលជាអ្នកមិនកៀចដោយវាទៈថា កៀច ទើបបានឈរធ្វើជើងទាំង ៤ នៅស្ងៀមដូចសសរ ។ រំពេចនោះ ទើបសេដ្ឋីឲ្យព្រាហ្មណ៍នាំទ្រព្យ ១០០០ កហាបណៈមក ព្រាហ្មណ៍ចាញ់ដោយទ្រព្យ ១០០០ កហាបណៈ ទើបដោះគោ ហើយទៅផ្ទះ ត្រូវសេចក្តីសោកគ្របសង្កត់ ទើបដេក ។ គោនន្ទិវិសាលត្រាច់ទៅហើយ ត្រឡប់មក ឃើញព្រាហ្មណ៍ត្រូវសេចក្តីសោយគ្របសង្កត់ ទើបចូលទៅរក ហើយពោលថា ព្រាហ្មណ៍ លោកដេកលក់ឬ ព្រាហ្មណ៍ពោលថា យើងចាញ់ក្នាល់ដោយទ្រព្យ ១០០០ មានការដេកលក់មកអំពីណា គោនន្ទិ-វិសាលពោលថា នែព្រាហ្មណ៍ ខ្ញុំនៅក្នុងផ្ទះរបស់លោក អស់កាលមានប្រមាណប៉ុណ្ណោះ ធ្លាប់ធ្វើភាជនៈណាមួយឲ្យបែក ធ្លាប់ជាន់អ្នកណាមួយ ធ្លាប់បន្ទោបង់ឧច្ចារបស្សាវៈក្នុងទីដែលមិនគួរ មានឬ ។ ព្រាហ្មណ៍ពោលថា មិនមានទេបា ។ លំដាប់នោះ គោនន្ទិវិសាលពោលថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកហៅខ្ញុំដោយវាទៈថា អាគោកៀច នុ៎ះជាទោសរបស់លោកប៉ុណ្ណោះ ទោសរបស់ខ្ញុំមិនមាន សូមលោកទៅដាក់ដើមផាន់ដោយទ្រព្យ ២០០០ កហាបណៈជាមួយសេដ្ឋីនោះ ខ្ញុំសូមតែម្យ៉ាង សូមលោកកុំហៅខ្ញុំដែលជាសត្វមិនកៀចដោយពាក្យថា អាគោកៀចឡើយ ព្រាហ្មណ៍បានស្តាប់ពាក្យរបស់គោនន្ទិ-វិសាលនោះហើយ ធ្វើដើមផាន់ ២ ពាន់កហាបណៈ ចងរទេះ ១០០ ជាប់គ្នាដោយន័យដែលមានហើយក្នុងកាលមុន ប្រដាប់គោនន្ទិវិសាល ហើយទឹមត្រង់រទេះទី ១ ។ សួរថា ទឹមដូចម្តេច ឆ្លើយថា ព្រាហ្មណ៍ចងនឹមម្ខាងឲ្យ

ណែនត្រង់ទូករទេះ ហើយទឹមគោនន្ទិវិសាលត្រង់នឹមម្ខាង យកខ្សែចងត្រង់ទូករទេះ ហើយមកចងត្រង់ចុងនឹមម្ខាង ដាក់កាំនឹម ភ្ជាប់ និងចន្ទល់ ហើយយកខ្សែចងឲ្យណែនបញ្ឈរទុក ។ កាលធ្វើយ៉ាងនេះ នឹមមិនកម្រើកទៅក្នុងទីផ្សេងៗ គោមួយប៉ុណ្ណោះអាចអូសទៅបាន គ្រានោះ ព្រាហ្មណ៍អង្គុយលើទូករទេះ អង្អែលខ្នងគោនន្ទិវិសាលបណ្តើរ ពោលបណ្តើរថា គោដ៏ចម្រើន ចូរបាទៅ គោដ៏ចម្រើន ចូរបាអូសទៅ ។ ព្រះពោធិសត្វអូសរទេះ ១០០ ដែលចងជាប់គ្នាដោយកម្លាំងដ៏ខ្លាំងតែម្តងប៉ុណ្ណោះ ឲ្យរទេះដែលនៅខាងក្រោយ តាំងនៅក្នុងទីដែលរទេះខាងមុខតាំងនៅ ។ គោវិន្ទសេដ្ឋីចាញ់ហើយ បានឲ្យទ្រព្យ ២០០០ កហាបណៈដល់ព្រាហ្មណ៍ មនុស្សដទៃៗ ក៏បានឲ្យទ្រព្យជាច្រើនដល់ព្រះពោធិសត្វ ទ្រព្យទាំងអស់នោះ បានជារបស់ព្រាហ្មណ៍ទាំងអស់ ព្រាហ្មណ៍នោះអាស្រ័យព្រះពោធិសត្វ ទើបបានទ្រព្យជាច្រើន ដោយប្រការយ៉ាងនេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ពាក្យគ្រោតគ្រាតមិនជាទីពេញចិត្តរបស់បុគ្គលណាម្នាក់ ហើយទ្រង់តិះដៀលពួកឆព្វគ្គិយភិក្ខុរូបបញ្ញត្តសិក្ខាបទ ទ្រង់ជាអ្នកត្រាស់ដឹងព្រមចំពោះហើយ ទើបត្រាស់ព្រះគាថានេះថា

បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាននិយាយពាក្យជាទីគាប់ចិត្ត ( គោនន្ទិវិសាល ) បានទាញភារៈដ៏ធ្ងន់រួច ញ៉ាំងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយ ដោយការញ៉ាំង

*ព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **មនុញ្ញមេវ ភាសេយ្យ** *សេចក្ដីថា បុគ្គល កាលពោលនឹងអ្នកដទៃ គប្បីពោលចំពោះបិយវាចាដែលទន់ផ្អែម ជាទីពេញចិត្ត ពីព្រោះ វៀរចាកទោស ៤ ប្រការ ។ បទថា* **គរុភារំ ឧទទ្ធរិ** *សេចក្ដីថា គោនន្ទិវិសាល កាលព្រាហ្មណ៍ពោលពាក្យមិនជាទីពេញចិត្ត ក៏មិនអូសភារៈ កាលព្រាហ្មណ៍ពោលពាក្យជាទីស្រឡាញ់ ជាទីពេញចិត្តខាងក្រោយ ទើបអូសភារៈធ្ងន់ទៅឲ្យដល់ ។* **ឧ** *អក្ខរៈ ក្នុងបទថា* **ឧទទ្ធរិ** *នោះ ក្នុងគាថានេះ ជាអក្ខរៈ ធ្វើការភ្ជាប់បទ ដោយការភ្ជាប់ព្យញ្ជនៈ ។*

*ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកថា* **មនុញ្ញមេវ ភាសេយ្យ** *ដោយប្រការដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ឯគោនន្ទិវិសាល គឺតថាគតអរហន្ត-សម្មាសម្ពុទ្ធនេះឯង ។*

**អដ្ឋកថានន្ទិវិសាលជាតក ចប់**

# សុត្តន្តបិដក

## កណ្ហជាតកំ

[ ២៩ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះទៅបាន ។

កណ្ហជាតកទី ៩ ចប់

# អដ្ឋកថា

## កណ្ហជាតក

[ ២៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធយមកប្បាដិហារ្យ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យតោ យតោ គរុ ធុរំ** ដូច្នេះជាដើម ។

យមកប្បាដិហារ្យនោះ និងការចុះអំពីទេវលោក មានប្រាកដក្នុងសរភង្គជាតក តេរសកនិបាត ។ កាលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើយមកប្បាដិហារ្យហើយ យាងទៅក្នុងទេវលោក ។ ក្នុងថ្ងៃមហាបវារណា យាងចុះត្រង់ទ្វារសង្កស្សនគរ ហើយទៅកាន់វត្តជេតពនមហាវិហារ ព្រមដោយបរិវារធំ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយពោលដល់ព្រះគុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ ឈ្មោះថា ព្រះតថាគត មានធុរៈមិនមានបុគ្គលស្មើ អ្នកដទៃ ឈ្មោះថា អាចនាំធុរៈដែលព្រះតថាគតនាំទៅហើយ រមែងមិនមាន គ្រូទាំង ៦ ពោលថា ពួកយើងប៉ុណ្ណោះ នឹងធ្វើបាដិហារ្យ ពួកយើងប៉ុណ្ណោះនឹងធ្វើបាដិហារ្យ សូម្បីបាដិហារ្យមួយ ក៏មិនបានធ្វើ គួរអស្ចារ្យ ព្រះសាស្តា ទ្រង់មានធុរៈមិនមានបុគ្គលស្មើ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយរឿងដទៃក៏មិនមែន អង្គុយសន្ទនាដោយរឿងព្រះគុណចំពោះរបស់ព្រះអង្គឈ្មោះនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាម្នាក់ នឹងនាំទៅនូវធុរៈដែលតថាគតនាំទៅហើយ ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិន

មែន សូម្បីក្នុងកាលមុន តថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ក៏មិនមានអ្នកណាមួយ មានធុរៈស្មើនឹងតថាគត ហើយទ្រង់នាំអតីតនិទានមកដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតគោ ក្នុងកាលដែលនៅជាគោជំទង់នោះឯង ម្ចាស់ទ្រព្យទាំងឡាយក្នុងផ្ទះរបស់ស្រីចាស់ម្នាក់ កំណត់ថ្លៃឈ្នួលដែលនៅអាស្រ័យ ទើបបានឲ្យកូនគោនោះ ។ ស្រីចាស់នោះបដិបត្តិកូនគោនោះដោយបបរ និងភត្តជាដើម តាំងក្នុងឋានៈជាកូន ឲ្យធំធាត់ហើយកូនគោនោះប្រាកដឈ្មោះថា អយ្យិកាកាឡកៈ ។ គោនោះចម្រើនវ័យហើយជាអ្នកមានពណ៌ដូចផ្កាអញ្ចន់ ត្រាច់ទៅជាមួយគោស្រុក បានជាអ្នកដល់ព្រមដោយសីល និងអាចារ ពួកក្មេងអ្នកស្រុកចាប់គោនោះត្រង់ស្នែងខ្លះ ត្រង់ត្រចៀកខ្លះ ត្រង់កខ្លះ បូកខ្លះ ចាប់ត្រង់កន្ទុយខ្លះ ទាញមកខ្លះ អង្គុយលើខ្នងខ្លះ ។ ថ្ងៃមួយ គោនោះគិតថា មាតារបស់អញក្រីក្រ តាំងអញក្នុងឋានៈជាបុត្ត ចិញ្ចឹមមកដោយលំបាក បើដូច្នោះ អញធ្វើការស៊ីឈ្នួល ដោះមាតានេះឲ្យផុតពីភាពក្រីក្រ ចាប់តាំងអំពីនោះ គោនោះ ត្រាច់ធ្វើការស៊ីឈ្នួល ។

ថ្ងៃមួយ កូនឈ្មួញរទេះម្នាក់ មានរទេះ ៥០០ ចេញដំណើរទៅជួបកំពង់រាក់ មិនរាបស្មើ គោទាំងឡាយរបស់ឈ្មួញរទេះនោះ មិនអាចញុំាងរទេះទាំងឡាយឲ្យឆ្លងបាន គោទាំងឡាយដែលអូសរទេះ ៥០០ ដែលម្ចាស់ទ្រព្យយកនឹមមកទឹមតៗ គ្នា ក៏មិនអាចឲ្យរទេះសូម្បីតែមួយឆ្លងឡើងបាន ឯព្រះពោធិសត្វ និងពួកគោអ្នកស្រុកត្រាច់ទៅក្នុងទីក្បែរកំពង់ ។ ឯកូនឈ្មួញ

រទេះ ក៏ជាអ្នកចេះវិជ្ជាគោ ពិចារណាថា ក្នុងហ្វូងគោទាំងនេះ គោឧសភ-អាជានេយ្យ អាចញុំាងរទេះទាំងនេះឲ្យឆ្លងផុត មានឬហ្ន៎ បានឃើញព្រះពោធិសត្វហើយ គិតថា នេះគោអាជានេយ្យ នឹងអាចញុំាងរទេះទាំងឡាយរបស់អញឲ្យឆ្លងផុតបាន អ្នកណាហ្ន៎ ជាម្ចាស់របស់គោនេះ ទើបសួរពួកអ្នកចិញ្ចឹមគោថា អ្នកដ៏ចម្រើន អ្នកណាហ្ន៎ជាម្ចាស់របស់គោនេះ ខ្ញុំនឹងទឹមគោនេះ ក្នុងរទេះទាំងឡាយ កាលរទេះទាំងឡាយដែលគោនេះឲ្យឆ្លងឡើងបាន នឹងឲ្យថ្លៃឈ្នួល ។ ពួកអ្នកចិញ្ចឹមគោទាំងនោះពោលថា លោកទាំងឡាយចូរចាប់គោនេះទឹមចុះ ម្ចាស់របស់គោនេះ ក្នុងទីនេះមិនមាន ។ ទើបកូនឈ្មួញរទេះនោះយកខ្សែចងព្រះពោធិសត្វនោះត្រង់ច្រមុះ ហើយទាញ មិនអាចឲ្យកម្រើកបាន ។ បានឮថា ព្រះពោធិសត្វមិនបានទៅដោយគិតថា បើប្រាប់តម្លៃអញ អញនឹងទៅ ។ ឈ្មួញរទេះដឹងបំណងរបស់ព្រះពោធិសត្វ ទើបពោលថា នែគោដ៏ចម្រើន កាលឯងឲ្យរទេះ ៥០០ ឆ្លងហើយ អញនឹងឲ្យរទេះមួយ ២ កហាបណៈ ជាថ្លៃឈ្នួល គឺឲ្យ ១០០០ កហាបណៈ ។ ក្នុងកាលនោះព្រះពោធិសត្វបានដើរទៅឯង ។ លំដាប់នោះ ទើបបុរសទាំងឡាយ ទឹមព្រះពោធិសត្វត្រង់រទេះទាំងឡាយ ។ គ្រានោះ ព្រះពោធិសត្វលើករទេះនោះឡើងដោយកម្លាំងតែមួងប៉ុណ្ណោះ ឲ្យរទេះតាំងនៅលើគោក ញុំាងរទេះទាំងអស់ឲ្យឆ្លងដោយឧបាយនេះ កូនឈ្មួញរទេះទុក ១ កហាបណៈ សម្រាប់រទេះនីមួយៗធ្វើកហាបណៈ ៥០០ ឲ្យជាកញ្ចប់កណ្ឌៈ ហើយចងត្រង់ករបស់ព្រះពោធិ-សត្វនោះ ព្រះពោធិសត្វនោះគិតថា កូនរបស់ឈ្មួញរទេះមិនឲ្យតម្លៃតាមដែល

បានកំណត់ ឥឡូវនេះ អញនឹងមិនឲ្យកូនឈ្នួញរទេះនោះទៅ ទើបឈររាំងផ្លូវរទេះដែលនៅមុខគេ មនុស្សទាំងឡាយទោះព្យាយាមឲ្យចៀសចេញទៅ ក៏មិនអាចឲ្យព្រះពោធិសត្វនោះចៀសទៅបាន កូនឈ្នួញរទេះគិតថា គោនេះប្រហែលជាដឹងថា តម្លៃរបស់ខ្លួនមិនគ្រប់ ទើបដាក់ ២ កហាបណៈ សម្រាប់រទេះនីមួយៗ ចងទ្រព្យ ១០០០ ឲ្យជាកញ្ចប់ ហើយព្យួរត្រង់កពោលថា នេះជាថ្លៃឈ្នួលក្នុងការញ៉ាំងរទេះឡើងរបស់ឯង ។ ព្រះពោធិសត្វនោះនាំយកកញ្ចប់ទ្រព្យ ១០០០ បានទៅកាន់សម្នាក់របស់មាតា ពួកក្មេងអ្នកស្រុកបានទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ដោយគិតថា នេះជាអ្វីត្រង់កអយ្យិកា-កាឡកៈ ។ ព្រះពោធិសត្វនោះ ត្រូវក្មេងអ្នកស្រុកដេញតាម ទើបគេចទៅកាន់សម្នាក់មាតា ។ ព្រោះឲ្យរទេះ ៥០០ ឆ្លងឡើង ទើបប្រាកដជាអ្នកហត់នឿយ មានភ្នែកទាំង ២ ក្រហម ។ ដូនចាស់ឃើញថង់ទ្រព្យ ១០០០ ត្រង់ករបស់ព្រះពោធិសត្វ ទើបពោលថា នែបា ទ្រព្យនេះបាបានមកអំពីណា ហើយសួរពួកក្មេងអ្នកស្រុក បានស្តាប់សេចក្តីនោះហើយ ទើបពោលថា នែបា យើងត្រូវការចិញ្ចឹមជីវិតដោយថ្លៃឈ្នួលដែលបាបានមកឬ ព្រោះហេតុអ្វី ទើបបាសោយទុក្ខបែបនេះ ទើបឲ្យព្រះពោធិសត្វងូតទឹកក្តៅ យកប្រេងលាបរាងកាយ ឲ្យទឹកផឹក ឲ្យបរិភោគភោជនដែលជាសប្បាយ ក្នុងកាលអស់ជីវិត បានទៅតាមយថាកម្ម ឯព្រះពោធិសត្វក៏ដូចគ្នា ។

ចំណែកព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកមានធុរៈដែលបុគ្គលណាមួយស្មើមិនបាន ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បី

ក្នុងកាលមុន ក៏មានធុរៈដែលបុគ្គលណាមួយស្មើមិនបានដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិ ជាអ្នកត្រាស់ដឹងព្រមចំពោះហើយ ត្រាស់ព្រះគាថានេះថា

ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសទូវធុរៈដ៏ធ្ងន់នោះទៅបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ យតោ គរុ ធុរំ** សេចក្តីថា ក្នុងទីណាមានធុរៈធ្ងន់ គឺគ្រោតគ្រាត គោបម្រើដទៃៗ មិនអាចលើកឡើងបាន ។ បទថា **យតោ គម្ភីរវត្តនិ** សេចក្តីថា ឈ្មោះថា **វត្តនិ** ប្រែថា ផ្លូវ ព្រោះជាទីទៅនៃមនុស្ស ។ ពាក្យថា **វត្តនិ** នេះ ជាឈ្មោះរបស់ផ្លូវ អធិប្បាយថា ក្នុងទីណាមានផ្លូវ ឈ្មោះថា ជ្រៅ ព្រោះមានទឹក និងភក់ច្រើន ឬព្រោះភាពជាផ្លូវមិនរាបស្មើ និងជាផ្លូវមានថ្នាក់ ។ សព្ទថា **អស្សុ** ក្នុងបទថា **តទាស្សុ កណ្ហំ យុញ្ជន្តិ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ក្នុងកាលនោះ ជនទាំងឡាយរមែងទឹមគោខ្មៅ លោកអធិប្បាយថា ក្នុងកាលណាមានធុរៈធ្ងន់ និងមានផ្លូវជ្រៅ ក្នុងកាលនោះ ទើបជនទាំងឡាយយកគោបម្រើដទៃចេញ ហើយទឹមគោខ្មៅប៉ុណ្ណោះ ។ បទថា **អស្សុ** ក្នុងបទថា **ស្វាស្សុ តំ វហតេ ធុរំ** នេះ ត្រឹមតែជានិបាតសព្ទដូចគ្នា អធិប្បាយថា គោខ្មៅនោះ រមែងនាំធុរៈនោះទៅ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ គោខ្មៅប៉ុណ្ណោះនាំធុរៈទៅ ដូច្នេះ ដោយប្រការដូច្នេះហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ស្រីចាស់ក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណាក្នុងកាលឥឡូវនេះ ឯគោអយ្យិកាកាឡកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាកណ្ហជាតក ចប់**

# សុត្តន្តបិដក

## មុណិកជាតក

[ ៣០ ] ( គោពោធិសត្វឈ្មោះមហាលោហិតៈពោលថា ) អ្នកកុំចូលចិត្ត ( ភោជន ) របស់ជ្រូកឈ្មោះ មុណិកៈ ( ព្រោះ ) ជ្រូកមុណិកៈ ស៊ីភោជនក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយស៊ីតែចំបើងចុះ នេះជាលក្ខណៈនៃអាយុវែង ។

មុណិកជាតកទី ១០ ចប់

កុរុង្គវគ្គទី ៣ ចប់

### ឧទ្ទាននៃកុរុង្គវគ្គនោះ គឺ

និយាយអំពីកុរុង្គមិគជាតក ១ កុក្កុរជាតក ១ ភោជាជានីយ-ជាតក ១ សេះដ៏ប្រសើរ ( ក្នុងអាជញ្ញជាតក ) ១ សេះសាមញ្ញនិងសេះដ៏ប្រសើរ ( ក្នុងតិត្ថជាតក ) ១ មហិឡាមុខជាតក ១ អភិណ្ហជាតក ១ បុគ្គលមិន ត្រូវពោលពាក្យមិនគាប់ចិត្ត ( ក្នុងនន្ទិវិសាលជាតក ) ១ គោកណ្ហអូសទូវធុរៈ ( ក្នុងកណ្ហជាតក ) ១ មុណិកជាតក ១ ត្រូវជា ១០ ។

# អដ្ឋកថា

## មុណិកជាតក

[ ៣០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ក្រមុំចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **មា មុណិកស្ស** ដូច្នេះជាដើម ។

រឿងការលួងលោមនោះ មានជាក់ច្បាស់នៅក្នុងចូឡនារទកស្សបជាតក តេរសកនិបាត ។ ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះទូលថា ករុណាព្រះអង្គ ។ ព្រះសាស្ដាត្រាស់សួរថា ព្រោះអាស្រ័យអ្វី ភិក្ខុនោះក្រាបទូលថា ព្រោះអាស្រ័យការប្រលោមរបស់ក្រមុំចាស់ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ក្រមុំចាស់នោះ ធ្វើការវិនាសដល់អ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក្នុងថ្ងៃរៀបការរបស់ក្រមុំចាស់នេះ អ្នកក៏ដល់នូវការអស់ជីវិត បានជាសម្ភារៈក្នុងកត្តិកង្គរបស់មហាជន ហើយទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតគោ ក្នុងផ្ទះរបស់កុដុម្ពិកៈម្នាក់ក្នុងស្រុកមួយ ដោយឈ្មោះមានឈ្មោះមហាលោហិត ឯប្អូនប្រុសរបស់ព្រះពោធិសត្វ ឈ្មោះចូឡលោហិត ធុរៈក្នុងត្រកូលនោះឯង រមែងប្រព្រឹត្តទៅបាន ព្រោះអាស្រ័យគោទាំង ២ បងប្អូននោះឯង ក្នុងត្រកូលនោះមានកុមារីម្នាក់ ។ កុលបុត្រអ្នកក្រុងម្នាក់ ដណ្ដឹងកុមារីនោះដើម្បីបុត្ររបស់ខ្លួន ។ មាតាបិតារបស់ក្មេងស្រីនោះ ឲ្យបបរ និងកត្ត ចិញ្ចឹមជ្រូកឈ្មោះមុណិកៈ

ដោយគិតថា ទុកធ្វើសម្ភឧត្តរិកង្គដើម្បីភ្ញៀវទាំងឡាយ ដែលមកក្នុងថ្ងៃរៀបការរបស់កុមារីនោះ ។ គោឈ្មោះចូឡលោហិតឃើញដូច្នោះ ទើបសួរបងថា ធុរៈ គឺការងារក្នុងត្រកូលនេះ កាលនឹងប្រព្រឹត្តទៅ ក៏អាស្រ័យបងប្អូនយើងទាំង ២ ទើបប្រព្រឹត្តទៅបាន តែមនុស្សទាំងនេះឲ្យតែស្មៅ និងស្លឹកឈើដល់ពួកយើង បែរជាបំប៉នជ្រូកដោយបបរ និងភត្ត ព្រោះហេតុអ្វីហ្ន៎ ទើបជ្រូកនេះបានបបរ និងភត្តនេះ ។ លំដាប់នោះ គោច្បងពោលនឹងគោប្អូនថា នែចូឡលោហិត អ្នកកុំប្រណែននឹងភោជនរបស់ជ្រូកនោះឡើយ ជ្រូកនេះកំពុងបរិភោគភត្តដែលជាហេតុស្លាប់ ក្នុងថ្ងៃអាពាហ៍ពិពាហ៍របស់កុមារិកា ជ្រូកនេះ នឹងបានជាសម្ភឧត្តរិកង្គសម្រាប់ភ្ញៀវដែលមក ព្រោះហេតុនោះ ទើបជនទាំងនេះចិញ្ចឹមជ្រូកនេះ ដោយកន្លងទៅ ២-៣ ថ្ងៃ បន្ទាប់អំពីនេះទៅ មនុស្សទាំងឡាយនឹងនាំគ្នាមក កាលបើដូច្នោះ អ្នកនឹងបានឃើញជ្រូកនោះត្រូវចាប់ត្រង់ជើងទាំងឡាយ ទាញមកអំពីក្រោមគ្រែ ត្រូវគេសម្លាប់ ធ្វើសម្ភនិងម្ហូបដើម្បីភ្ញៀវទាំងឡាយ ហើយពោលគាថានេះថា

អ្នកកុំចូលចិត្ត ( ភោជន ) របស់ជ្រូកឈ្មោះមុណិកៈ ( ព្រោះ )<br>
ជ្រូកមុណិកៈ ស៊ីភោជនក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយ<br>
តិច ហើយស៊ីតែចំបើងចុះ នេះជាលក្ខណៈនៃអាយុវែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា មុណិកស្ស បិហយិ** សេចក្តីថា អ្នកកុំញុំាងសេចក្តីប្រណែនឲ្យកើតឡើងក្នុងភោជនរបស់ជ្រូកមុណិកៈ គឺកុំប្រណែនចំពោះជ្រូកមុណិកៈថា ជ្រូកនេះបរិភោគភោជនល្អ បានដល់ កុំប្រាថ្នាដូចជ្រូក

មុណិកៈថា កាលណាហ្ន៎ អញនឹងមានសេចក្ដីសុខយ៉ាងនេះ ព្រោះជ្រូកមុណិកៈនេះបរិភោគអាហារដែលជាហេតុក្ដៅក្រហាយ ។ បទថា **អាតុរន្នានិ** បានដល់ ភោជនជាហេតុឲ្យស្លាប់ ។ បទថា **អប្បោស្សុក្កោ ភុសង្ខាទ** សេចក្ដីថា ចូរអ្នកជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិចក្នុងភោជនរបស់ជ្រូកមុណិកៈនោះ ចូរបរិភោគចំបើងដែលខ្លួនបានចុះ ។ បទថា **ឯតំ ទីឃាយុលក្ខណំ** សេចក្ដីថា នេះជាហេតុនៃភាពជាបុគ្គលមានអាយុវែង ។

បន្ទាប់អំពីនោះមិនយូរប៉ុន្មាន អ្នកទាំងនោះនាំគ្នាមកសម្លាប់ជ្រូកមុណិកៈ ហើយធ្វើនូវអាហារដោយប្រការផ្សេងៗ ព្រះពោធិសត្វពោលនឹងគោចូឡលោហិតថា នែបា បានឃើញមុណិកៈហើយឬ ។ គោចូឡលោហិតពោលថា បពិត្របង ផលនៃការបរិភោគរបស់ជ្រូកមុណិកៈ ខ្ញុំឃើញហើយ របស់ត្រឹមតែជាស្មៅ ស្លឹកឈើ និងចំបើងប៉ុណ្ណោះរបស់ពួកយើងឧត្ដម មិនមានទោស និងជាលក្ខណៈនៃភាពជាបុគ្គលមានអាយុវែងជាងកត្តរបស់ជ្រូកមុណិកៈ ១០០ ដង ១០០០ ដង ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកអាស្រ័យកុមារិកានេះដល់នូវការអស់ជីវិត ដល់នូវភាពជាសម្ភខត្ដរិកន្តរបស់មហាជន ដោយប្រការដូច្នេះឯង ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអផ្សុកចង់សឹក តាំងនៅក្នុងសោតាបត្តិផល ។ សូម្បីព្រះសាស្ដាក៏ទ្រង់បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា មុណិកសូករៈក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកចង់សឹកក្នុងកាល

ឥឡូវនោះ កុមារិកាក្នុងកាលនោះ បានមកជានាងក្រមុំចាស់ គោចូឡលោហិតក្នុងកាលនោះ បានមកជាអានន្ទ ឯគោមហាលោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថាមុណិកជាតក ចប់

## កុរុង្គវគ្គ ចប់

# សុត្តន្តបិដក

# កុលាវកវគ្គ

## កុលាវកជាតក

[ ៣១ ] ( *ព្រះឥន្ទ្រពោធិសត្វពោលថា* ) *ម្នាលមាតលិ ពួកកូនក្រុឌ ( ទំ ) នៅដើមរកា អ្នកចូរចៀសវាង ( កុំឲ្យពួកវាលំបាក ) ដោយមុខចន្ទោលរថឡើយ តាមពិត យើងស៊ូលះជីវិតចំពោះពួកអសុរវិញ កុំឲ្យតែកូនក្រុឌទាំងនេះ មានសម្បុកខ្ទាត់ខ្ទាយ ។*

*កុលាវកជាតកទី ១ ចប់*

# អដ្ឋកថា

# កុលាវកវគ្គ

## កុលាវកជាតក

[ ៣១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលផឹកទឹកមិនត្រង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កុលាវកា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុកំលោះ ២ រូប ជាសម្លាញ់នឹងគ្នា ចេញអំពីក្រុងសាវត្ថីទៅកាន់ជនបទ នៅក្នុងទីផាសុកមួយកន្លែងតាមអធ្យាស្រ័យ ហើយគិតថា នឹងគាល់ព្រះសម្មាសម្ពុទ្ធ ទើបចេញអំពីជនបទនោះ បែរមុខទៅកាន់វត្តជេតពនទៀត ។ ភិក្ខុមួយរូបមានតម្រងទឹក ចំណែកមួយរូបមិនមាន ភិក្ខុទាំង ២ រូបក៏រួមគ្នាត្រងទឹកផឹក ហើយទើបផឹក ។ ថ្ងៃមួយ ភិក្ខុទាំង ២ រូបនោះ បានធ្វើវិវាទឈ្លោះប្រកែកគ្នា ។ ភិក្ខុដែលជាម្ចាស់តម្រងទឹក មិនឲ្យតម្រងទឹក ដល់ភិក្ខុមួយរូបទៀតត្រងទឹកផឹកចំពោះខ្លួនឯង ហើយផឹក ឯភិក្ខុក្រៅអំពីនេះ កាលមិនបានតម្រងទឹក មិនអាចអត់សង្កត់សេចក្តីស្រេក ទើបផឹកទឹកដែលមិនបានត្រង ភិក្ខុទាំង ២ នោះ មកដល់ជេតពនវិហារដោយលំដាប់ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយ ។ ព្រះសាស្តាទ្រង់ត្រាស់សម្មោទនីយកថាហើយ ត្រាស់សួរថា ពួកអ្នកមកអំពីណា ភិក្ខុទាំង ២ នោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមកអំពីស្រុកមួយ ក្នុងកោសលជនបទ ចេញអំពីស្រុក

នោះមក ដើម្បីគាល់ព្រះអង្គ ព្រះសាស្តាត្រាស់សួរថា ពួកអ្នកជាអ្នកស្រឡាញ់គ្នា នាំគ្នាមកឬ ភិក្ខុមិនមានតម្រេងទឹកទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះវិវាទជាមួយខ្ញុំព្រះអង្គក្នុងចន្លោះផ្លូវ ហើយមិនឲ្យតម្រងទឹក ។ ភិក្ខុមួយរូបទៀតក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះមិនត្រងទឹក ផឹកទឹកដែលមានសត្វទាំងជីងខ្លួននោះឯង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកផឹកទឹកមានសត្វទាំងជីងខ្លួនពិតឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គផឹកទឹកមិនបានត្រងមែន ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុន គ្រងរាជសម្បត្តិក្នុងទេវនគរ ចាញ់សង្គ្រាមគេចទៅតាមផ្លូវសមុទ្រ ទើបគិតថា អញនឹងមិនធ្វើការសម្លាប់សត្វ ព្រោះអាស្រ័យភាពជាធំ បានលះបង់យសធំ ឲ្យជីវិតដល់កូនគ្រុឌ ទើបឲ្យត្រឡប់រថ ហើយទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទមគធរាជមួយអង្គ សោយរាជសម្បត្តិ ក្នុងនគររាជគ្រឹះ ដែនមគធៈ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតជាកូនរបស់ត្រកូលធំក្នុងស្រុក មចលគ្រាមនោះឯង ដូចក្នុងឥឡូវនេះ សក្កទេវរាជកើតក្នុងស្រុកមចលគ្រាម ដែនមគធៈ ក្នុងអត្តភាពមុន ដូច្នោះ ។ ក្នុងថ្ងៃដាក់ឈ្មោះព្រះពោធិសត្វ ញាតិទាំងឡាយបានដាក់ឈ្មោះថា មឃកុមារ ។ មឃកុមារនោះចម្រើនវ័យហើយ ប្រាកដឈ្មោះថា មឃមាណព ។ លំដាប់នោះ ឪពុកម្តាយរបស់មឃមាណព នាំកុមារិកាមកអំពីត្រកូលដែលមានជាតិស្មើគ្នា ។ មឃមាណពនោះ ចម្រើនដោយបុត្ត និងធីតាទាំងឡាយ បានជា

ទានបតី រក្សាសីល ៥ ក្នុងស្រុកនោះ មាន ៣០ ត្រកូលប៉ុណ្ណោះ ថ្ងៃមួយ មនុស្សក្នុងត្រកូលទាំង ៣០ នោះ ឈរកណ្តាលស្រុក ធ្វើការងារក្នុងស្រុក ព្រះពោធិសត្វយកជើងទាំង ២ បោសធូលីក្នុងទីដែលឈរ ធ្វើប្រទេសនោះ ឲ្យគួរត្រេកអរ ឈរហើយ ។ គ្រានោះ អ្នកដទៃម្នាក់មកឈរក្នុងទីនោះ ទើបព្រះពោធិសត្វធ្វើទីដទៃទៀត ឲ្យគួរត្រេកអរ ហើយបានឈរ ។ ក្នុងទីនោះ អ្នកដទៃក៏មកឈរទៀត ព្រះពោធិសត្វធ្វើទីដទៃៗ ឲ្យជាទីត្រេកអរ សេចក្តីថា បានធ្វើទីឈរឲ្យគួរត្រេកអរដល់មនុស្សទាំងពួង ។ សម័យតមក ឲ្យសាងបារាំក្នុងទីនោះ សូម្បីបារាំក៏ឲ្យរើចោល ហើយឲ្យសាងសាលា ក្រាលអាសនៈបន្ទះក្តារក្នុងសាលានោះ ហើយតម្កល់ក្អមទឹក សម័យតមក ជន ៣២ នាក់នោះ មានឆន្ទៈស្មើជាមួយព្រះពោធិសត្វ ទើបព្រះពោធិសត្វឲ្យជន ៣២ នាក់នោះ តាំងនៅក្នុងសីល ៥ តាំងអំពីនោះទៅ ក៏ត្រាច់ធ្វើបុណ្យទាំងឡាយជាមួយមនុស្សទាំងនោះ ។ ជនទាំងនោះ ធ្វើបុណ្យជាមួយព្រះពោធិសត្វនោះឯង ទើបក្រោកឡើងអំពីព្រលឹម កាន់កាំបិត ពូថៅ និងអង្រែ យកអង្រែវាយបំបែកដុំថ្មក្នុងផ្លូវធំ ដែលមានមុំ ៤ ជាដើម ហើយបោះចោលទៅ នាំយកដើមឈើដែលប៉ះភ្លៅរថទាំងឡាយ ធ្វើទីពុំរាបស្មើឲ្យស្មើ ធ្វើស្ពាន ជីកស្រះបោក្ខរណី សាងសាលា ឲ្យទាន រក្សាសីល ដោយច្រើន អ្នកស្រុកទាំងមូល តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ហើយរក្សាសីល ដោយប្រការដូច្នេះ ។ សម័យនោះ ចៅហ្វាយស្រុករបស់ជនទាំងនោះគិតថា ក្នុងកាលមុនកាលអ្នកទាំងនេះផឹកស្រា ធ្វើបាណាតិបាតជាដើម អញបានទ្រព្យដោយ

អំណាចកហាបណៈថ្លៃក្រឡស្រាជាដើម និងដោយអំណាចពលី តែឥឡូវនេះ មយមាណព ដឹកនាំឲ្យរក្សាសីល មិនឲ្យជនទាំងនោះ ធ្វើបាណាតិបាតជាដើម ម្យ៉ាងទៀត ឥឡូវនេះ នឹងឲ្យយើងទាំងឡាយរក្សាសីល ៥ ទើបខឹងក្រោធ ចូលទៅគាល់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកចោរ ជាច្រើន ធ្វើការសម្លាប់អ្នកស្រុកជាដើម ។ ព្រះរាជាទ្រង់បានស្តាប់ពាក្យរបស់ មេស្រុកនោះ ទើបត្រាស់ថា ចូរអ្នកទៅនាំមនុស្សទាំងនោះមក ទើបមេស្រុក ទៅចងជនទាំងអស់ ហើយនាំមក ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះ សម្មតិទេព ពួកជនដែលទូលបង្គំនាំមកនេះ ជាចោរ ។ គ្រានោះ ព្រះរាជា ទ្រង់មិនជម្រះកម្មជនទាំងនោះឡើយ ត្រាស់ថា អ្នកទាំងឡាយ ចូរឲ្យដំរីជាន់ ជនទាំងនេះ ។ បន្ទាប់អំពីនោះ ទើបរាជបុរសឲ្យជនទាំងនោះ ដេកត្រង់លាន ព្រះរាជវាំង ហើយនាំដំរីមក ព្រះពោធិសត្វបានឲ្យឱវាទដល់ជនទាំងនោះថា អ្នកទាំងឡាយ ចូរពិចារណាដល់សីល ចូរចម្រើនមេត្តាក្នុងបុគ្គលដែលញុះ ញង់ក្នុងព្រះរាជា ក្នុងដំរី និងក្នុងរាងកាយរបស់ខ្លួនឲ្យដូចគ្នា ជនទាំងនោះបាន ធ្វើយ៉ាងនោះ ។ លំដាប់នោះ ទើបរាជបុរសទាំងឡាយនាំដំរីចូលទៅដើម្បីឲ្យ ជាន់ជនទាំងនោះ ដំរីនោះ សូម្បីមនុស្សនាំចូលទៅ ក៏មិនចូលទៅ អង្គួចហើយ រត់គេចទៅ ។ គ្រានោះ ទើបនាំដំរីដទៃៗ មក ដំរីទាំងនោះ ក៏គេចទៅយ៉ាង នោះដូចគ្នា ។ លំដាប់នោះ រាជបុរសទាំងឡាយ ក៏នាំដំរីដទៃៗ មក ដំរីទាំង នោះ ក៏រត់គេចយ៉ាងនោះដូចគ្នា ។

ព្រះរាជាត្រាស់ថា ប្រហែលជាមានឱសថណាមួយ នៅក្នុងដៃនៃជន

ទាំងនេះ ចូរពួកអ្នកមើល ។ ពួករាជបុរសពិនិត្យមើលហើយ ក៏មិនឃើញ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនមានទេ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ជនទាំងនេះនឹងរាយមន្តណាមួយ ចូរអ្នកទាំងឡាយសួរពួកគេមើល ថា មន្តសម្រាប់រាយរបស់អ្នកទាំងឡាយមានឬ ។ ទើបរាជបុរសទាំងឡាយ សាកសួរ ព្រះពោធិសត្វក៏ពោលថា មាន រាជបុរសទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព បានឮថា មន្តសម្រាប់រាយ មាន ។ ព្រះរាជាត្រាស់ឲ្យ ហៅជនទាំងនោះមក ហើយត្រាស់ថា ចូរអ្នកទាំងឡាយ ប្រាប់មន្តដែលអ្នក ទាំងឡាយដឹង ។ ព្រះពោធិសត្វបានក្រាបទូលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា មន្តរបស់ទូលបង្គំទាំងឡាយដទៃមិនមាន តែពួកទូលបង្គំប្រមាណ ៣៣ នាក់ មិនសម្លាប់សត្វ មិនលួចទ្រព្យ មិនប្រព្រឹត្តខុសក្នុងកាម មិន ពោលពាក្យកុហក មិនផឹកទឹកស្រវឹង ចម្រើនមេត្តា ឲ្យទាន និងធ្វើផ្លូវឲ្យរាប ស្មើ ជីកស្រះបោក្ខរណី សាងសាលា នេះជាមន្ត ជាគ្រឿងការពារ ជាសេចក្តី ចម្រើនរបស់ទូលបង្គំទាំងឡាយ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងជនទាំងនោះ ទ្រង់ បានឲ្យសម្បត្តិក្នុងផ្ទះទាំងអស់របស់មេស្រុក ដែលធ្វើការញុះញង់ ហើយឲ្យ មេស្រុកនោះធ្វើជាទាសៈរបស់ជនទាំងនោះ បានឲ្យដំរី និងស្រុកដល់ជនទាំង នោះដូចគ្នា ។ ចាប់តាំងអំពីកាលនោះ ជនទាំងនោះធ្វើបុណ្យទាំងឡាយតាម គាប់ចិត្ត គិតថា នឹងសាងសាលាធំ ក្នុងផ្លូវបែកជា ៤ ទើបឲ្យហៅជាង ឈើមកសាងសាលា តែមិនបានឲ្យមាតុគ្រាមទាំងឡាយ មានចំណែកបុណ្យ ក្នុងសាលានោះ ព្រោះមិនមានការពេញចិត្តក្នុងមាតុគ្រាមទាំងឡាយ ។

សម័យនោះ ក្នុងផ្ទះរបស់ព្រះពោធិសត្វ មានស្ត្រី ៤ នាក់ គឺនាងសុធម្មា ១ សុចិត្រា ១ សុនន្ទា ១ និងនាងសុជាតា ១ ។ បណ្ដាស្ត្រីទាំងនោះ នាងសុធម្មាជាមួយគ្នានឹងជាងឈើពោលថា បពិត្របងប្រុស សូមបងធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះ ដូច្នេះហើយ បានឲ្យសំណូក ជាងឈើនោះទទួលពាក្យហើយ ញុំាងឈើហោជាងឲ្យស្ងួតនោះឯង ហើយចាំងចោះ ធ្វើហោជាងឲ្យសម្រេច យកកំណាត់រុំហើយរក្សា ។ ក្នុងកាលនោះ ពេលសាងសាលាស្រេចហើយ ឲ្យលើកហោជាង ទើបពោលថា ឱហ្ន៎ ! អ្នកទាំងឡាយ ខ្ញុំមិនបានគិតដល់វត្ថុម្យ៉ាង ជនទាំងនោះសួរថា របស់ឈ្មោះអ្វី ។ ជាងឈើពោលថា ការបានហោជាង ទើបគួរ ។ ជនទាំងនោះពោលថា ណ្ហើយចុះ យើងនឹងនាំមកឲ្យ ជាងឈើពោលថា ពួកយើងមិនអាចធ្វើដោយឈើដែលកាត់ភ្លាមៗត្រូវបានហោជាងដែលគេកាត់ទុកអំពីមុន ចាំងចោះ ធ្វើឲ្យសម្រេចហើយ ទើបគួរ ។ ជនទាំងនោះពោលថា ឥឡូវនេះ នឹងធ្វើដូចម្ដេច ជាងឈើពោលថា បើហោជាងសម្រាប់លក់គេធ្វើស្រេចហើយ ទុកក្នុងផ្ទះរបស់បុគ្គលណាមួយមាន អ្នកត្រូវរកហោជាងនោះ ជនទាំងនោះកាលស្វែងរក បានជួបក្នុងផ្ទះរបស់នាងសុធម្មា មិនបានដោយមូលតម្លៃ តែកាលនាងសុធម្មាពោលថា ចូរអ្នកទាំងឡាយធ្វើខ្ញុំឲ្យមានចំណែកបុណ្យផង ខ្ញុំនឹងឲ្យ ទើបនាំគ្នាពោលថា ពួកយើងមិនឲ្យបុណ្យដល់មាតុគ្រាមទាំងឡាយទេ ។ គ្រានោះ ទើបជាងឈើពោលនឹងជនទាំងនោះថា នៃអ្នក អ្នកទាំងឡាយពោលអ្វី ឈ្មោះថា ទីដែលវៀរចាកមាតុគ្រាម រមែងមិនមាន វៀរតែព្រហ្មលោក ចូរអ្នកទាំងឡាយកាន់យក

ហោជាងចុះ កាលបើដូច្នោះ ការងារទាំងឡាយរបស់ពួកយើងនឹងដល់នូវការសម្រេច ជនទាំងនោះពោលថា សាធុ ហើយកាន់យកហោជាង ញ៉ាំងសាលាឲ្យសម្រេច ហើយក្រាលបន្ទះក្តារសម្រាប់អង្គុយ តម្កល់ថ្លាងទឹក រៀបចំបបរនិងកត្តជាដើមជាប្រចាំ ព័ទ្ធសាលាដោយកំពែង ប្រកបដោយទ្វារ រោយខ្សាច់ក្នុងកំពែង ដាំដើមត្នោតខាងក្រៅកំពែង ឯនាងសុចិត្រា បានធ្វើឧទ្យានក្នុងទីនោះ ។ មិនមានពាក្យដែលនឹងពោលថា ដើមឈើដែលមានផ្កា និងដើមឈើមានផ្លែឈ្មោះនោះមិនមានក្នុងឧទ្យាននោះ ។ ឯនាងសុនន្ទាបានធ្វើស្រះបោក្ខរណីក្នុងទីនោះដូចគ្នា ញ៉ាំងផ្កាឈូកដែលមាន ៥ ពណ៌ ឲ្យដេរដាស គួរជាទីត្រេកអរ នាងសុជាតាមិនធ្វើអ្វីមួយ ។ ព្រះពោធិសត្វបំពេញវត្តបទ ៧ គឺការបម្រើមាតា ១ ការបម្រើបិតា ១ ការធ្វើនូវការឱនលំទោនដល់រៀមច្បងក្នុងត្រកូល ១ ពោលពាក្យពិត ១ ពោលវាចាមិនគ្រោតគ្រាត ១ ពោលវាចាមិនញុះញង់ ១ មិនកំណាញ់ ១ ដល់នូវភាពជាបុគ្គលគួរសរសើរយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នកក្រោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់សេចក្តីកំណាញ់ មានសម្តីទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯង ថាជាសប្បុរស ដូច្នេះ ។

ក្នុងកាលអស់ជីវិត ទៅកើតជាសក្កទេវរាជ ក្នុងស្ថានតាវត្តិង្ស សម្លាញ់

របស់ព្រះពោធិសត្វនោះ នាំគ្នាកើតក្នុងស្ថានតាវត្តិង្សនោះដូចគ្នា ។

ក្នុងកាលនោះ អសុរទាំងឡាយអាស្រ័យនៅក្នុងស្ថានតាវត្តិង្ស សក្កទេវរាជទ្រង់ព្រះតម្រិះថា រាជសម្បត្តិជាសាធារណៈទូទៅដល់អ្នកដទៃ មានប្រយោជន៍អ្វីដល់យើង ទើបឲ្យពួកអសុរផឹកទឹកដែលជាទិព្វ ហើយចាប់ពួកអសុរដែលស្រវឹងត្រង់ជើង បោះទៅកាន់ជើងភ្នំសិនេរុ ពួកអសុរទាំងនោះរមែងដល់កពអសុរនោះឯង ។ ឈ្មោះថា កពអសុរ មានទំហំប៉ុនស្ថានតាវត្តិង្សទេវលោក ក្នុងផ្ទៃខាងក្រោមភ្នំសិនេរុ ក្នុងកពអសុរនោះ មានដើមឈើតាំងនៅអស់មួយកប្ប ឈ្មោះថា ដើមចិត្តបាដលិ គឺដើមប្រទៀង ដូចគ្នានឹងបារិច្ឆត្តកៈរបស់ពួកទេវតាដែរ ។ កាលដើមចិត្តបាដលិរីក ពួកអសុរទាំងនោះដឹងថា នេះមិនមែនជាទេវលោករបស់ពួកយើងទេ ព្រោះថា ក្នុងទេវលោកដើមបារិច្ឆត្តកៈរមែងរីក ។ គ្រានោះ ទើបពួកអសុរពោលថា សក្កទេវរាជធ្វើពួកយើងឲ្យស្រវឹង បោះពួកយើងមកកាន់មហាសមុទ្រ ដណ្តើមនគររបស់ពួកយើង យើងទាំងឡាយនឹងច្បាំងជាមួយសក្កៈកញ្ចាស់នោះ ហើយកាន់យកទេវនគររបស់ពួកយើងមកវិញ ទើបក្រោកឡើង សញ្ចរទៅតាមភ្នំសិនេរុ ដូចស្រមោចភ្ញើងឡើងសសរ ដូច្នោះ ។ សក្កទេវរាជទ្រង់ព្វដំណឹងថា ពួកអសុរឡើងមក ទើបហោះឡើងទៅលើមហាសមុទ្រច្បាំង ត្រូវពួកអសុរទាំងនោះឲ្យចាញ់ហើយ ទើបគេចទៅកាន់មហាសមុទ្រទិសខាងត្បូង ដោយវេជយន្តរថមានប្រមាណ ១៥០ យោជន៍ ។ សម័យនោះ រថរបស់សក្កៈរសាត់លើផ្ទៃសមុទ្រ ដោយសម្ទុះដ៏រហ័ស ទើបចូលទៅកាន់ព្រៃរកា ទម្លាយព្រៃរកា ដូច

ទម្លាយព្រៃបបុស ក្នុងផ្លូវដែលសក្កៈនោះយាងទៅ ដាច់ធ្លាក់ចុះក្នុងមហាសមុទ្រ កូនគ្រុឌធ្លាក់ក្នុងសមុទ្រ នាំគ្នាយំខ្សៀវខ្សារ ។ សក្កទេវរាជត្រាស់សួរមាតលីសារថីថា មាតលីសម្លាញ់ នុ៎ះជាសំឡេងអ្វី ស្រែកយំគួរករុណាពន់ពេក ។ មាតលីទូលថា បពិត្រទេវៈ ព្រៃរកាដាច់ធ្លាក់ទៅដោយកម្លាំងសម្ទុះនៃរថរបស់ទ្រង់ ពួកកូនគ្រុឌត្រូវមរណភ័យគំរាម ទើបនាំគ្នាយំ ជាសំឡេងតែមួយ ។ ព្រះមហាសត្វត្រាស់ថា មាតលីសម្លាញ់ កូនគ្រុឌទាំងនេះ ចូរកុំលំបាកព្រោះអាស្រ័យយើងឡើយ ខ្ញុំមិនអាស្រ័យភាពជាធំ ធ្វើកម្ម គឺការសម្លាប់សត្វ ដើម្បីជាប្រយោជន៍ដល់កូនគ្រុឌនោះ យើងនឹងលះបង់ជីវិតឲ្យដល់ពួកអសុរ ចូរអ្នកត្រឡប់រថ ហើយត្រាស់ព្រះគាថានេះថា

*ម្នាលមាតលិ ពួកកូនគ្រុឌ ( ទំ ) នៅដើមរកា អ្នកចូរចៀសវាង ( កុំឲ្យពួកវាលំបាក ) ដោយមុខចន្ទោលរថឡើយ តាមពិត យើងស៊ូលះជីវិតចំពោះពួកអសុរវិញ កុំឲ្យតែកូនគ្រុឌទាំងនេះ មានសម្បុកខ្ចាត់ខ្ចាយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **កុលាវកា** បានដល់ ពួកកូនគ្រុឌនោះឯង សក្កទេវរាជត្រាស់ហៅនាយសារថីថា មាតលិ ដោយបទថា **សិម្ពលិស្មឹ** នេះ លោកសម្តែងថា ចូរអ្នកមើលកូនគ្រុឌទាំងនេះដែលកំពុងទំត្រង់ដើមរកា ។ បទថា **ឦសាមុខេន បរិវជ្ជយស្សុ** សេចក្តីថា ចូរអ្នកវៀរកូនគ្រុឌទាំងនោះ ដោយប្រការដែលពួកគ្រុឌមិនក្តៅក្រហាយ ដោយចន្ទោលរថនេះ ។ បទថា **កាមំ ចជាម អសុរេសុ បាណំ** សេចក្តីថា បើយើងលះជីវិតដល់ពួកអសុរ

សួស្តីនឹងមានដល់កូនគ្រុឌទាំងនោះ ខ្ញុំនឹងលះដោយពិត គឺលះជីវិតរបស់ខ្ញុំឲ្យពួកអសុរដោយពិតនោះឯង ។ បទថា **មាយិមេ ទិជា វិកុលាវា អហេសុំ** សេចក្តីថា បក្សីទាំងនេះ គឺកូនគ្រុឌទាំងនេះ ឈ្មោះថា កុំបីព្រាត់ប្រាសចាកសម្បុក ព្រោះសម្បុកត្រូវខ្ទេចខ្ទី គឺកុំបោះនូវទុក្ខរបស់ពួកយើង ទៅលើកូនគ្រុឌទាំងនេះ ចូរអ្នកត្រឡប់រថ ។

មាតលិសារថីបានស្តាប់ពាក្យរបស់សក្កៈនោះហើយ ទើបត្រឡប់រថបែរមុខទៅកាន់ទេវលោក ដោយផ្លូវដទៃ ឯពួកអសុរឃើញសក្កៈត្រឡប់រថប៉ុណ្ណោះ គិតថា សក្កទេវរាជក្នុងចក្រវាលដទៃនាំគ្នាមកពិត ទើបរត់ត្រឡប់ព្រោះបាននូវកម្លាំងពល ជាអ្នកខ្លាចចំពោះមរណភ័យ ទើបនាំគ្នាគេចចូលទៅកាន់ភពអសុរវិញ ឯសក្កទេវរាជ ក៏យាងទៅកាន់ទេវនគរ ចោមរោមដោយពួកទេវតា ក្នុងទេវលោកទាំង ២ បានឈរប្រថាប់កណ្តាលនគរ ។ ខណៈនោះ វេជយន្តប្រាសាទកម្ពស់ ១០០០ យោជន៍ ជ្រែកប្រឹថពីផុសឡើង ព្រោះប្រាសាទផុសឡើងខាងចុងនៃជ័យជម្នះ ទើបទេវតាទាំងឡាយដាក់ឈ្មោះប្រាសាទនោះថា វេជយ័ន្ត ។ លំដាប់នោះ សក្កទេវរាជទ្រង់រៀបចំការរក្សាក្នុងទី ៥ អន្លើ ដើម្បីមិនឲ្យពួកអសុរត្រឡប់មកទៀត ដូចលោកពោលថា

**អន្តរា ទ្វិន្នំ អយុជ្ឈបុរានំ បញ្ចវិធា ឋបិតា អភិរក្ខា**
**ឧរគករោដិ បយស្ស ច ហារី មទនយុតា ចតុរោ ច មហន្តា ។**

ក្នុងរវាងអាយុជ្ឈបុរីទាំង ២ សក្កទេវរាជ ទ្រង់តាំងនូវការរក្សាយ៉ាងតឹងរ៉ឹងក្នុងទី ៥ កន្លែង គឺនាគ ១ គ្រុឌ ១ កុម្ភណ្ឌ ១ យក្ស ១

មហារាជទាំងបួន ១ ដូច្នេះ ។

នគរទាំង ២ គឺទេវនគរ និងអសុរនគរ ក៏ឈ្មោះថា អយុទ្ធបុរៈ ( អយុជ្ឈបុរៈ ) ព្រោះបុគ្គលណាម្នាក់ មិនអាចកាន់យកបានដោយការច្បាំង ព្រោះថា ក្នុងកាលណា ពួកអសុរមានកម្លាំង ក្នុងកាលនោះ ពួកទេវតាគេចចូលទេវនគរ ហើយបិទទ្វារ ពួកអសុររាប់សែនក៏មិនអាចធ្វើអ្វីបាន ក្នុងកាលណាពួកទេវតាមានកម្លាំង ក្នុងកាលនោះ កាលពួកអសុរគេចទៅ បិទទ្វារអសុរនគរ ពួកទវតាសូម្បីរាប់សែនក៏មិនអាចធ្វើអ្វីបាន ដូច្នោះ ទើបនគរទាំង ២ នេះ ឈ្មោះថា **អយុទ្ធបុរៈ** ប្រែថា នគរដែលបុគ្គលណាម្នាក់ច្បាំងមិនបាន ។ រវាងនគរទាំង ២ នោះ សក្កទេវរាជទ្រង់តាំងនូវការរក្សាក្នុងឋានៈទាំង ៥ ប្រការ មាននាគជាដើម ។ បណ្ដាឋានៈ ៥ ប្រការនោះ លោកកាន់យកនាគដោយសព្ទថា **ឧរគ** ។ នាគទាំងនោះមានកម្លាំងក្នុងទឹក ព្រោះដូច្នោះ ទើបនាគទាំងនោះ មានការរក្សាត្រង់សង្កាត់ទី ១ នៃភ្នំសិនេរុ ។ លោកកាន់យកគ្រុឌដោយសព្ទថា **ករោដិ** បានឮថា គ្រុឌទាំងនោះមានបានៈ និងភោជនឈ្មោះថា **ករោដិ** ទើបគ្រុឌទាំងនោះបានឈ្មោះតាមទឹក និងភោជនទនោះ គ្រុឌទាំងនោះ មានការរក្សាត្រង់សង្កាត់ទី ២ នៃនគរទាំង ២ ។ លោកកាន់យកកុម្ភណ្ឌដោយសព្ទថា **បយស្ស ហារិ** ។ បានឮថា ពួកកុម្ភណ្ឌទាំងនោះគឺទានវៈ ( យក្ខព្រៃ ) និងពួកអារក្ខទឹក ពួកកុម្ភណ្ឌទាំងនោះមានការរក្សាត្រង់សង្កត់ទី ៣ នៃនគរទាំង ២ លោកកាន់យកពួកយក្ខដោយសព្ទថា **មទ-នយុត** បានឮថា យក្ខទាំងនោះ មានប្រក្រតីត្រាច់ទៅមិនស្មើ ជាអ្នកចម្បាំង

យក្ខទាំងនោះមានការរក្សាត្រង់សង្កាត់ទី ៤ នៃនគរទាំង ២ ។ លោកពោលដល់ទេវមហារាជទាំង ៤ ដោយបទថា **ចតុរោ ច មហន្តា** នេះ ។ ទេវ-មហារាជទាំង ៤ នោះ មានការរក្សាត្រង់សង្កាត់ទី ៥ នៃនគរទាំង ២ ព្រោះដូច្នោះ បើពួកអសុរក្រោធ មានចិត្តខឹងសម្បា ចូលទៅកាន់ទេវបុរី បណ្តាអ្នកចម្បាំង ៥ ប្រភេទ ពួកនាគត្រូវការពារភ្នំបរិភណ្ឌទី ១ នោះ រក្សាទីដ៏សេស ក្នុងឋានៈដ៏សេស ក៏យ៉ាងនោះ ។

កាលសក្កៈ ជាស្តេចទេវតាទ្រង់តាំងនូវការរក្សាក្នុងទី ៥ អន្លើយ៉ាងនេះហើយ សោយទិព្វសម្បត្តិ នាងសុធម្មា ចុតិមកកើតជាបាទបរិចារិការបស់សក្កៈនោះឯង ។ ទេវសភាឈ្មោះសុធម្មាមានប្រមាណ ៥០០ យោជន៍ ជាទីដែលសក្កទេវរាជគង់ប្រថាប់លើបល្ល័ង្កមាស ទំហំមួយយោជន៍ ក្រោមស្វេតច្ឆត្រទិព្វ ទ្រង់ធ្វើកិច្ចដែលគប្បីធ្វើដល់ទេវតា និងមនុស្ស បានកើតឡើងដល់នាងសុធម្មា ព្រោះវិបាកដែលឲ្យនូវហោជាង ។ នាងសុចិត្រាក៏ចុតិមកកើតជាបាទបរិចារិការបស់សក្កទេវរាជនោះដូចគ្នា និងឧទ្យានឈ្មោះថា ចិត្ត-លតាវ័ន ក៏កើតឡើងដល់នាងសុចិត្រានោះ ព្រោះផលវិបាកនៃការធ្វើឧទ្យាន ។ ឯនាងសុនន្ទាចុតិមកកើតជាបាទបរិចារិការបស់សក្កៈនោះដូចគ្នា ស្រះបោក្ខរណីឈ្មោះនន្ទាកើតឡើងដល់នាងសុនន្ទានោះ ព្រោះផលវិបាកនៃការជីកស្រះបោក្ខ-រណី ។ ចំណែកនាងសុជាតាកើតជាកុកញី នៅត្រង់ញកភ្នំត្រង់ព្រៃមួយកន្លែង ព្រោះមិនបានធ្វើកុសលកម្ម សក្កទេវរាជទ្រង់រំពឹងថា នាងសុជាតាមិនប្រាកដនាងកើតក្នុងទីណាហ្ន៎ កាលទ្រង់ឃើញនាងសុជាតានោះ ទើបយាងទៅត្រង់

ញកក្អំនោះ នាំនាងមកកាន់ទេវលោក ទ្រង់បង្ហាញទេវនគរដែលគួរជាទីត្រេកអរ ទេវសភាឈ្មោះសុធម្មា ឧទ្យានចិត្តលតាវ័ន និងនន្ទាបោក្ខរណីដល់នាង ហើយទ្រង់ឲ្យឱវាទថា ស្រីទាំងនេះបានធ្វើនូវកុសល ទើបមកកើតជាបាទបរិចារិកា របស់យើង ឯនាងមិនបានធ្វើកុសល ទើបកើតក្នុងកំណើតតិរច្ឆាន តាំងអំពីនេះទៅ ចូរនាងរក្សាសីល ហើយឲ្យនាងតាំងនៅក្នុងសីល ៥ នាំទៅលេងក្នុងញកក្អំនោះឯង ឯកុកនោះ ក៏រក្សាសីលតាំងអំពីកាលនោះ ដោយកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជទ្រង់ព្រះតម្រិះថា កុកញីអាចរក្សាសីលឬហ្ន៎ ដូច្នេះហើយ ទើបយាងទៅ កាឡាខ្លួនជាត្រីដេកផ្ងារនៅខាងមុខ កុកញីនោះសម្គាល់ថា ត្រីស្លាប់ ទើបចឹកត្រង់ក្បាល ត្រីកម្រើកកន្ទុយ លំដាប់នោះ ទើបកុកញីនោះលែងត្រីនោះ ដោយសម្គាល់ថា ត្រីមានជីវិត សក្កទេវរាជត្រាស់ថា សាធុ សាធុ នាងអាចរក្សាសីលបានហើយ បានទៅកាន់ទេវលោក កុកញីនោះចុតិចាកអត្តភាពនោះ មកកើតក្នុងផ្ទះរបស់ស្មូនឆ្នាំង ក្នុងនគរពារាណសី ។

សក្កៈទ្រង់ព្រះតម្រិះថា កុកញីមកកើតក្នុងទីណាហ្ន៎ ទ្រង់ដឹងថា កើតក្នុងត្រកូលស្មូនឆ្នាំង ទើបទ្រង់យកល្ពៅមាសដាក់ពេញរទេះតូច កាឡាខ្លួនជាមនុស្សចាស់អង្គុយត្រង់កណ្តាលស្រុកប្រកាសថា ចូរអ្នកទាំងឡាយទទួលល្ពៅ មនុស្សទាំងឡាយពោលថា បពិត្រលោកឪពុក សូមលោកឲ្យ ។ សក្កទេវរាជត្រាស់ថា ខ្ញុំឲ្យដល់មនុស្សទាំងឡាយដែលរក្សាសីល ចូរអ្នកទាំងឡាយរក្សាសីល មនុស្សទាំងឡាយពោលថា ឈ្មោះថា សីល ពួកយើងមិនស្គាល់ ខ្ញុំនឹងឲ្យមូលតម្លៃ ។ សក្កទេវរាជត្រាស់ថា ខ្ញុំមិនត្រូវការដោយតម្លៃ ខ្ញុំនឹងឲ្យ

ចំពោះដល់អ្នករក្សាសីលប៉ុណ្ណោះ មនុស្សទាំងឡាយពោលថា នេះល្ពៅអ្វីហ្ន៎ ហើយក៏ចៀសចេញទៅ ។ នាងសុជាតាបានដឹងដំណឹងនោះហើយ គិតថា បុរសនេះនាំមកដើម្បីអញ ទើបពោលថា បពិត្រលោកឪពុក សូមលោកឲ្យចុះ ។ សក្កទេវរាជត្រាស់ថា នែនាង នាងរក្សាសីលហើយឬ នាងសុជាតាពោលថា ខ្ញុំរក្សាសីលហើយ ។ សក្កៈត្រាស់ថា វត្ថុនេះ ខ្ញុំនាំមកដើម្បីប្រយោជន៍ដល់នាងប៉ុណ្ណោះ ហើយដាក់ត្រង់ទ្វារផ្ទះ មួយអន្ទើដោយយានតូច ហើយចៀសចេញទៅ ។

ឯនាងសុជាតានោះ រក្សាសីលដរាបដល់អស់អាយុ ចុតិអំពីអត្តភាពនោះ ទៅកើតជាធីតារបស់ស្តេចអសុរ ឈ្មោះវេបចិត្តិ បានជាអ្នកមានរូបស្អាតដោយអានិសង្សនៃសីល ក្នុងកាលធីតានោះចម្រើនវ័យហើយ ស្តេចវេបចិត្តិទ្រង់ព្រះតម្រិះថា ធីតារបស់អញ ចូរជ្រើសរើសប្តីតាមគាប់ចិត្តរបស់ខ្លួន ទើបឲ្យពួកអសុរប្រជុំគ្នា ។ សក្កទេវរាជទ្រង់ប្រមើលមើលថា នាងសុជាតានោះកើតក្នុងទីណាហ្ន៎ កាលទ្រង់ជ្រាបថា នាងកើតក្នុងអសុរភព ទើបព្រះតម្រិះថា នាងសុជាតាកាលនឹងជ្រើសរើសស្វាមីតាមគាប់ចិត្ត នឹងជ្រើសរើសយកអញ ទើបទ្រង់និម្មិតភេទជាអសុរ ហើយទៅក្នុងទីប្រជុំនោះ ។ ញាតិទាំងឡាយស្អិតស្អាងនាងសុជាតាហើយ នាំមកកាន់ទីប្រជុំពោលថា ចូរនាងជ្រើសរើសយកប្តីតាមដែលគាប់ចិត្ត នាងពិនិត្យមើលឃើញសក្កៈ ដោយអំណាចសេចក្តីស្រឡាញ់ដែលមានក្នុងកាលមុន ទើបបានជ្រើសរើសយកថា បុរសនេះជាប្តីរបស់ខ្ញុំ ។ ទើបសក្កៈទ្រង់នាំនាងមកកាន់ទេវនគរ ទ្រង់ធ្វើឲ្យជាធំជាងស្នំចំនួន

២ កោដិកន្ទះ[១] ទ្រង់តាំងនៅដរាបដល់អាយុ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ បណ្ឌិតក្នុងកាលមុន គ្រងរាជសម្បត្តិក្នុងទេវលោក ទោះបី លះបង់ជីវិតរបស់ខ្លួន ក៏មិនធ្វើបាណាតិបាត ដោយប្រការដូច្នេះ ឈ្មោះថា អ្នកបួសក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខបែបនេះ ហេតុអ្វី ទើបផឹកទឹក មានសត្វដែលមិនបានត្រង ទើបទ្រង់តិះដៀលភិក្ខុនោះ ហើយទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា មាតលិសារថីក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវ នេះ ឯសក្កៈទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ៕ ✽

**អដ្ឋកថាកុលាវកជាតក ចប់**

---

១- បាលីថា អឌ្ឍតេយ្យានំ នាដិកា កោដីនំ ក្នុងទី២ះ ប្រែថា ស្រីរបាំ ២៥០០ កោដិ ទី២ះ ប្រែថា ២៥ កោដិ ។

# សុត្តន្តបិដក

## នច្ចជាតក

[ ៣២ ] ( ស្តេចហង្សព្រមាសពោលថា ) សំឡេងយំ ( របស់អ្នក ) ក៏ពីរោះ ខ្នងក៏រុងរឿង កមានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពិទូរ្យ ស្លាបទាំងឡាយ ប្រមាណមួយព្យាម អញមិនឲ្យកូនស្រីដល់អ្នក ព្រោះតែការរាំឡើយ ។

នច្ចជាតកទី ២ ចប់

# អដ្ឋកថា

## ឆព្វជាតក

[ ៣២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានកណ្ឋៈច្រើនមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **រុធំ មនុញ្ញំ** ដូច្នេះជាដើម ។

រឿងដូចគ្នានឹងរឿងដែលបានពោលហើយ ក្នុងទេវធម្មជាតកខាងដើមនោះឯង ។ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា ពួកអ្នកជាអ្នកមានកណ្ឋៈច្រើនឬ ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់សួរថា ព្រោះហេតុអ្វី ទើបអ្នកជាអ្នកមានកណ្ឋៈច្រើន ភិក្ខុនោះលុះបានស្តាប់ព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ក៏ក្រោធ ទើបដោះសំពត់ស្បៀកសំពត់ដណ្តប់ គិតថា ឥឡូវនេះ អញនឹងត្រាច់ទៅដោយទំនងនេះឯង ហើយបានឈរជាបុគ្គលអាក្រាតក្នុងទីចំពោះព្រះភក្ត្រ ។ មនុស្សទាំងឡាយនាំគ្នាពោលថា គួរតិះដៀលហ្ន៎ គួរតិះដៀលហ្ន៎ ។ ភិក្ខុនោះគេចទៅអំពីទីនោះ ហើយវិលមកដើម្បីជាអ្នកថោកទាប គឺសឹក ។ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា នាំគ្នាពោលទោសភិក្ខុនោះថា ភិក្ខុនោះធ្វើកម្មបែបនេះ ចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនោះលះហិរិនិងឱត្តប្បៈ ជាមនុស្សអាក្រាតដូចក្មេងអ្នកស្រុកកណ្តាលបរិស័ទ ៤ ចំពោះព្រះភក្ត្រព្រះអង្គ បុគ្គលទាំងឡាយរង្កៀស ទើបវិលមកដើម្បីភាពជាបុគ្គលថោកទាប វិនាសចាកព្រះ

សាសនា ដូច្នោះ ទើបខ្ញុំព្រះអង្គទាំងឡាយ អង្គុយប្រជុំគ្នាដោយការពោលទោសរបស់ភិក្ខុនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះវិនាសចាកសាសនា គឺព្រះរតនៈក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ជាអ្នកវិនាសហើយ ចាកឥត្ថីរតនៈដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសម្តែងថា

ក្នុងអតីតកាល ក្នុងបឋមកប្ប សត្វជើង ៤ ទាំងឡាយតាំងរាជសីហ៍ឲ្យជាព្រះរាជា ពួកត្រីតាំងត្រីអានន្ទឲ្យជាព្រះរាជា ពួកបក្សីតាំងសុវណ្ណហង្សឲ្យជាព្រះរាជា ។ ធីតារបស់សុវណ្ណហង្សនោះឯង ជាកូនហង្សមានរូបស្អាត ស្តេចហង្សនោះបានឲ្យពរដល់កូនស្រីនោះ ។ ធីតានោះ សូមជ្រើសរើសប្តីតាមគាប់ចិត្តរបស់ខ្លួន ស្តេចហង្សឲ្យពរដល់ធីតានោះ ហើយឲ្យបក្សីទាំងពួងក្នុងព្រៃហិមពាន្តប្រជុំគ្នា ពួកបក្សីច្រើនប្រភេទ មានហង្ស និងក្ងោកជាដើមមកព្រមគ្នាហើយ ប្រជុំគ្នាត្រង់ផ្ទាំងថ្មធំមួយកន្លែង ស្តេចហង្សហៅធីតាមកថា ចូរនាងជ្រើសរើសស្វាមីតាមគាប់ចិត្តរបស់ខ្លួនចុះ ។ ធីតានោះ ពិនិត្យមើលបក្សី ឃើញក្ងោកមានផ្ទៃកពណ៌ដូចកែវមណី មានកន្ទុយស្អាតវិចិត្រ ទើបប្រាប់ថា បក្សីនេះ សូមជាស្វាមីរបស់ខ្ញុំ ។ ទើបពួកបក្សីទាំងឡាយចូលទៅរកក្ងោក ហើយពោលថា ក្ងោកសម្លាញ់ ព្រះរាជធីតាពេញចិត្តស្វាមី ក្នុងកណ្តាលពួកបក្សីមានប្រមាណប៉ុណ្ណេះ បានញុំាងការស្រឡាញ់ឲ្យកើតឡើងដល់អ្នក ។ ក្ងោកគិតថា ថ្ងៃនេះ ពួកបក្សីមិនទាន់ឃើញកម្លាំងរបស់អញដូច្នេះហើយ ទើបទម្លាយហិរិឱត្តប្បៈ ព្រោះត្រេកអរពេក ។ ជាបឋមបានលា

ស្វាបចេញ ផ្ដើមរាំពត់ពេនក្នុងកណ្ដាលហ្វូងបក្សីធំ រាំពត់ពេនពេញទំហឹង មិនមានចំណុចបិទបាំងឡើយ ។ ស្ដេចហង្សខ្មាស ពោលថា ក្ងោកនេះ មិនមានហិរិ ដែលមានសមុដ្ឋានតាំងឡើងខាងក្នុងឡើយ ឱត្តប្បៈមានសមុដ្ឋានតាំងខាងក្រៅ នឹងមានអំពីណា យើងមិនឲ្យធីតារបស់យើងដល់ក្ងោកនោះ ព្រោះទម្លាយហិរិឱត្តប្បៈ ( គឺបើកកន្ទុយឲ្យគេឃើញកេរ្តិ៍ខ្មាស ) ហើយពោលគាថានេះ កណ្ដាលពួកបក្សីថា

សំឡេងយំ ( របស់អ្នក ) ក៏ពីរោះ ខ្នងក៏រុងរឿង កមានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពិទូរ្យ ស្លាបទាំងឡាយ ប្រមាណមួយព្យាម អញមិនឲ្យកូនស្រីដល់អ្នក ព្រោះតែការរាំឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រុទំ មនុញ្ញំ** ក្នុងគាថានោះ លោកផ្លាស់ **ត** អក្ខរៈ ជា **ទ** អក្ខរៈ អធិប្បាយថា សំឡេងជាទីចាប់ចិត្ត គឺសំឡេងយំពីរោះ ។ បទថា **រុចិរា ច បិដ្ឋិ** សេចក្ដីថា សូម្បីខ្នងរបស់អ្នកក៏វិចិត្រល្អ ។ បទថា **វេឡុរិយវណ្ណូបនិភា** បានដល់ ដូចគ្នានឹងពណ៌នៃកែវពិទូរ្យ ។ បទថា **ព្យាមមត្តានិ** បានដល់ មានប្រមាណមួយព្យាម ។ បទថា **បេក្ខុណានិ** បានដល់ រោមកន្ទុយ ។ បទថា **នច្ចេន តេ ធីតរំ នោ ទទាមិ** សេចក្ដីថា ស្ដេចហង្សពោលថា អញមិនឲ្យកូនស្រីរបស់អញដល់អ្នក ដែលមិនមានខ្មាសបែបនេះ ព្រោះអ្នកទម្លាយហិរិឱត្តប្បៈ ហើយរាំនោះឯង ហើយឲ្យធីតាដល់កូនហង្សជាក្មួយរបស់ខ្លួន ក្នុងកណ្ដាលបរិស័ទនោះឯង ។

ក្អែកមិនបានកូនស្រីរបស់ហង្ស ក៏ខ្មាស ទើបហើរទៅ ឯស្តេចហង្សក៏ទៅកាន់លំនៅរបស់ខ្លួននោះឯង ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ទម្លាយហិរិឱត្តប្បៈហើយវិនាសចាកសាសនា គឺរតនៈ ឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ជាអ្នកវិនាសហើយចាកឥត្ថីរតនៈដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុមានភណ្ឌៈច្រើន ក្នុងកាលឥឡូវនេះ ឯស្តេចហង្សក្នុងកាលនោះ គឺតថាគតនេះឯង ។l៚

**អដ្ឋកថានច្ចជាតក ចប់**

# សុត្តន្តបិដក

## សម្មោទមានជាតក

[ ៣៣ ] ( ព្រះសាស្តាត្រាស់ថា ) ពួកបក្សីស្រុះស្រួលគ្នា នាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះ ជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនោះ នឹងលុះអំណាចអញ ក្នុងកាលនោះមិនខានឡើយ ។

**សម្មោទមានជាតកទី ៣ ចប់**

# អដ្ឋកថា

## សម្មោទមានជាតក

[ ៣៣ ] ព្រះសាស្តា កាលយាងចូលទៅអាស្រ័យនគរកបិលពស្តុ គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធការឈ្លោះគ្នានៃព្រះញាតិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សម្មោទមានា** ដូច្នេះជាដើម ។

ការឈ្លោះនៃព្រះញាតិនោះ មានច្បាស់ក្នុងកុណាលជាតក ។ ក្នុងកាលនោះ ព្រះសាស្តាត្រាស់ហៅព្រះញាតិទាំងឡាយមកហើយ ត្រាស់ថា មហាបពិត្រទាំងឡាយ ឈ្មោះថា ការឈ្លោះគ្នានិងគ្នានៃព្រះញាតិទាំងឡាយ មិនសមគួរ ពិតហើយ ក្នុងកាលមុន ក្នុងពេលសាមគ្គីគ្នា សូម្បីសត្វតិរច្ឆានទាំងឡាយក៏គ្របសង្កត់បច្ចាមិត្រ ដល់នូវសួស្តី ក្នុងកាលណា ដល់នូវការវិវាទគ្នា ក្នុងកាលនោះ ក៏ដល់នូវសេចក្តីវិនាសធំ ព្រះសាស្តាដែលរាជត្រកូលនៃព្រះញាតិទាំងឡាយអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតចាប មានចាបច្រើនពាន់ជាបរិវារនៅក្នុងព្រៃ ។ ក្នុងកាលនោះ ព្រានចាបម្នាក់ ទៅកាន់លំនៅរបស់ចាបទាំងនោះ ធ្វើសំឡេងយំដូចចាប ដឹងថា ចាបទាំងនោះប្រជុំគ្នាហើយ ទើបបង់សំណាញ់លើចាបទាំងនោះ ហើយសង្កត់ជាយជុំវិញ ធ្វើចាបទាំងអស់ឲ្យមករួមគ្នា ហើយដាក់ពេញកំប្រោងទៅផ្ទះ លក់ចាបទាំងនោះចិញ្ចឹមជីវិត ដោយតម្លៃនោះ ។ ថ្ងៃមួយ ព្រះពោធិសត្វពោលនឹងចាបទាំងនោះថា នាយព្រានបក្សីនេះ ធ្វើពួកញាតិរបស់យើងឲ្យវិនាស អញដឹងឧបាយមួយ ដែលជាហេតុ

ឲ្យនាយព្រាននោះ មិនអាចចាប់អញបាន ចាប់តាំងពីនេះទៅ កាលព្រាននេះ បង់សំណាញ់គ្របពួកយើង អ្នកទាំងឡាយ ចូរស៊កក្បាលក្នុងក្រឡាសំណាញ់ នីមួយៗ នាំគ្នាលើកសំណាញ់ហើយ ហើរទៅកាន់ទីដែលត្រូវការ ហើយចុះ លើគុម្ពឈើដែលមានបន្លា កាលបើដូច្នោះ ពួកយើងនឹងគេចទៅផ្នែកខាងក្រោម នោះ ចាបទាំងនោះទទួលពាក្យហើយ ក្នុងថ្ងៃទី ២ កាលព្រានបង់សំណាញ់ ខាងលើ ក៏នាំគ្នាលើកសំណាញ់ឡើង ដោយន័យដែលព្រះពោធិសត្វពោល ហើយនោះឯង ហើយចុះត្រង់គុម្ពឈើមានបន្លាមួយកន្លែង ឯខ្លួនឯងគេចទៅ ផ្លូវនោះៗ ដោយចំណែកខាងក្រោម កាលព្រានដោះសំណាញ់អំពីគុម្ពឈើ នោះឯង ក៏យប់ ទើបព្រានបក្សីនោះជាអ្នកមានដៃទទេត្រឡប់ទៅ ។ ស្អែក ឡើង ចាបទាំងនោះ ក៏ធ្វើយ៉ាងនោះឯង ។ ឯនាយព្រានកាលដោះសំណាញ់ ក៏ដោះរហូតដល់ព្រះអាទិត្យអស្តង្គត មិនបានសត្វណាមួយ ជាអ្នកមានដៃទទេ ទៅផ្ទះ ។ គ្រានោះ ភរិយារបស់ព្រានក្រោធ ពោលថា អ្នកត្រឡប់មកដៃ ទទេរាល់ថ្ងៃ ប្រហែលជាអ្នកត្រូវចិញ្ចឹមអ្នកខាងក្រៅដទៃទៀត ។ ព្រានបក្សី ពោលថា នែនាង ខ្ញុំមិនមានទីដែលត្រូវចិញ្ចឹមអ្នកដទៃផ្សេងទៀតឡើយ តែ ចាបទាំងនោះព្រមព្រៀងគ្នាត្រាច់ទៅ វានាំគ្នាយកសំណាញ់ គ្រាន់តែអញបង់ ទៅ ទៅចុះលើគុម្ពឈើមានបន្លា តែពួកវាមិនមែនក្បៀវក្លាបានគ្រប់កាលទាំង ពួងទេ នាងកុំទោមនស្សឡើយ កាលណាពួកវាដល់នូវការវិវាទ កាលនោះ យើងនឹងនាំពួកវាទាំងអស់មក ធ្វើមុខរបស់នាងឲ្យស្រស់ស្រាយ ហើយ ពោលគាថានេះដល់ភរិយាថា

ពួកបក្សីស្រុះស្រួលគ្នា នាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះ ជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនោះ នឹងលុះអំណាចអញ ក្នុងកាលនោះមិនខានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យទា តេ វិវទិស្សន្តិ** សេចក្ដីថា ក្នុងកាលណាចាបទាំងនោះ មានលទ្ធិផ្សេងៗ គ្នា មានការកាន់យកផ្សេងៗ គ្នា និងវិវាទគ្នា គឺទឹងឈ្លោះគ្នា ។ បទថា **តទា ឯហិន្តិ មេ វសំ** សេចក្ដីថា ក្នុងកាលនោះ ចាបទាំងអស់នោះនឹងមកកាន់អំណាចរបស់យើង កាលបើដូច្នោះ យើងនឹងចាប់ចាបទាំងនោះមក ធ្វើមុខរបស់នាងឲ្យស្រស់ស្រាយ ព្រានបក្សីលួងលោមភរិយា ដោយប្រការដូច្នេះ ។

ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ សត្វចាបមួយ កាលចុះត្រង់ផែនដីរកស៊ីមិនបានកំណត់ ទើបជាន់ក្បាលរបស់ចាបដទៃ ។ ចាបដែលត្រូវជាន់ក្បាលក្រោធថា អ្នកណាជាន់ក្បាលអញ កាលចាបនោះពោលថា ខ្ញុំមិនបានសង្កេតទើបជាន់ សូមអ្នកកុំក្រោធឡើយ ចាបនោះក៏នៅតែក្រោធនោះឯង ។ ចាបទាំងនោះ កាលនាំគ្នាពោលដដែលៗ ទើបធ្វើនូវជម្លោះថា ប្រហែលជាអ្នកប៉ុណ្ណោះទេដឹងលើកសំណាញ់ឡើងបាន កាលចាបទាំងនោះឈ្លោះគ្នា ព្រះពោធិសត្វគិតថា ឈ្មោះថា ការទាស់ទែងគ្នា រមែងមិនមានការផុតភ័យ ឥឡូវនេះឯង ចាបទាំងនោះនឹងមិនលើកសំណាញ់ បន្ទាប់ពីនោះ នឹងនាំគ្នាដល់នូវការវិនាសធំ នាយព្រាននឹងបានឱកាស អញមិនអាចនៅក្នុងទីនេះបានឡើយ ទើបព្រះពោធិសត្វនាំបរិស័ទរបស់ខ្លួនទៅកាន់ទីដទៃ ។ ឯព្រានបក្សី កន្លងទៅ

២-៣ ថ្ងៃ ក៏មកហើយយំដូចសំឡេងចាប បង់សំណាញ់ទៅលើចាបទាំងនោះ ដែលមកប្រជុំគ្នា ។ លំដាប់នោះ ចាបមួយពោលថា ឮថា អ្នកម្នាក់ឯងលើកសំណាញ់ឡើងប៉ុណ្ណោះ ទើបរោមក្បាលទុំពេក ឥឡូវនេះ ចូរលើកឡើង ចាបមួយទៀតពោលថា បានឮថា កាលអ្នកលើកសំណាញ់ឡើងរហូតស្លាបទាំងឡាយជ្រុះទៅ ឥឡូវនេះ ចូរអ្នកលើកឡើង ។ ដូច្នោះ កាលចាបទាំងនោះរវល់តែពោលថា ចូរអ្នកលើកឡើង ចូរអ្នកលើកឡើង ព្រានបក្សីមកប្រមូលសំណាញ់ ឲ្យចាបទាំងនោះមករួមគ្នាហើយ ដាក់ពេញទ្រុង បានទៅកាន់ផ្ទះ ធ្វើកិរិយាឲ្យត្រេកអរ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រទាំងឡាយ ឈ្មោះថា ជម្លោះនៃព្រះញាតិទាំងឡាយ មិនគួរយ៉ាងនេះ ព្រោះការឈ្លោះជាមូលនៃការវិនាសតែម្យ៉ាង ហើយទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិគ្នាហើយ ទ្រង់ប្រជុំជាតកថា ចាបដែលមិនជាបណ្ឌិតក្នុងកាលនោះ បានជាទេវទត្ត ក្នុងកាលឥឡូវនេះ ឯចាបដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សម្មោទមានជាតក ចប់**

# សុត្តន្តបិដក

## មច្ឆជាតក

[ ៣៤ ] ( ត្រីឈ្មោលពោលថា ) ត្រជាក់មិន ( បៀតបៀន ) អញទេ ក្តៅក៏មិន ( បៀតបៀន ) អញដែរ ការបៀតបៀនអញព្រោះលបមិនមានឡើយ ( អញ ) ព្រួយតែត្រង់ត្រីញីសម្គាល់អញថា ត្រីឈ្មោលនោះទៅរកត្រីញីដទៃ ដោយតម្រេក ។

មច្ឆជាតកទី ៤ ចប់

# អដ្ឋកថា

## មច្ឆជាតក

[ ៣៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន មំ សីតំ ន មំ ឧណ្ហំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគពិតហើយ ព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរថា ព្រោះហេតុអ្វី ទើបអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុរាណភរិយារបស់ខ្ញុំព្រះអង្គជាអ្នកមានប្ដីដៃឆ្ងាញ់ ខ្ញុំព្រះអង្គមិនអាចលះបង់នាង ។ គ្រានោះ ព្រះសាស្តាបានត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនោះ ជាអ្នកធ្វើនូវសេចក្តីវិនាសដល់អ្នកក្នុងកាលមុន កាលអ្នកដល់នូវការស្លាប់ ព្រោះអាស្រ័យស្រីនោះ តែផុតចាកសេចក្តីស្លាប់ ព្រោះអាស្រ័យតថាគត ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្តនោះ ក្នុងកាលនោះ ពួកអ្នកប្រមង់បានបង់សំណាញ់ក្នុងទឹក កាលនោះត្រីធំមួយ មកលេងជាមួយត្រីញីរបស់ខ្លួន ដោយការត្រេកអរ ។ ត្រីញីនោះហែលទៅខាងមុខរបស់ត្រីធំនោះ បាននូវក្លិនសំណាញ់ ទើបគេចទៅ ។ ឯត្រីធំនោះ ជាប់ក្នុងកាម ជាត្រីល្ងង់ បានចូលទៅក្នុងសំណាញ់នោះឯង ។ ពួកអ្នកប្រមង់

ដឹងថា ត្រីធំនោះជាប់សំណាញ់ ទើបលើកសំណាញ់ឡើង ចាប់យកត្រី មិនសម្លាប់ បោះទៅលើឆ្នេរខ្សាច់ គិតថា នឹងអាំងស៊ី ទើបបង្កាត់ភ្លើង សម្រួចឈើអណ្តោត ។ ត្រីវក្រឹកខ្សួលថា ការអាំងលើរងើកភ្លើង ឬការដោតដោយឈើស្រួចនោះ ឬអ្វីៗ ដទៃ មិនធ្វើឲ្យអញលំបាកឡើយ តែត្រីញីនោះដល់នូវទោមនស្សក្នុងអញថា ត្រីធំនោះបានទៅរកត្រីដទៃ ដោយការត្រេកអរនោះប៉ុណ្ណោះ បៀតបៀនអញ ទើបពោលគាថានេះថា

ត្រជាក់មិន ( បៀតបៀន ) អញទេ ក្តៅក៏មិន ( បៀតបៀន )
អញដែរ ការបៀតបៀនអញព្រោះលប[១] មិនមានឡើយ ( អញ )
ព្រួយតែត្រង់ ត្រីញីសម្គាល់អញថា ត្រីឈ្មោលនោះ ទៅរកត្រីញី
ដទៃ ដោយតម្រេកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន មំ សីតំ ន មំ ឧណ្ហំ** សេចក្តីថា ត្រីទាំងឡាយរមែងមានសេចក្តីរងា ក្នុងពេលត្រូវនាំចេញអំពីទឹក កាលសេចក្តីរងានោះប្រាសទៅ ការក្តៅមែងមាន ត្រីសំដៅយករងា និងក្តៅទាំង ២ នោះទើបខ្សឹកខ្សួលថា ត្រជាក់មិន ( បៀតបៀន ) អញទេ ក្តៅក៏មិន ( បៀតបៀន ) អញដែរ ត្រីសំដៅយកសេចក្តីទុក្ខដែលមានការអាំងលើរងើកភ្លើងដែលនឹងមានឡើងនោះ ទើបខ្សឹកខ្សួលថា ក្តៅក៏មិន ( បៀតបៀន ) អញដែរ ។ ដោយបទថា **ន មំ ជាលស្មិ ពាធនំ** នេះ ត្រីរមែងខ្សឹកខ្សួលថា ការបៀតបៀនអញព្រោះសំណាញ់មិនមានឡើយ ។

---

១- ពាក្យថា លបនេះ មកពីបាលីថា ជាលៈ ប្រែថា សំណាញ់ក៏បាន ។

ក្នុងបទថា **យញ្ចុ មំ** ដូច្នេះជាដើម មានការសរុបសេចក្តីដូចតទៅនេះថា ត្រីញីនោះមិនដឹងថា អញជាប់នៅក្នុងសំណាញ់ ត្រូវពួកអ្នកប្រមង់ទាំងនេះចាប់យកទៅ កាលមិនឃើញអញ ក៏គិតថា ឥឡូវនេះ ត្រីធំនោះនឹងជាប់តាមត្រីញីដទៃ ដោយសេចក្តីត្រេកអរក្នុងកាម ការដែលត្រីនោះដល់នូវទោមនស្សដូច្នោះ រមែងបៀតបៀនអញ ព្រោះហេតុនោះ ទើបត្រីធំនោះ ដេកកន្ទក់កន្ទេញលើខ្សាច់ ។

សម័យនោះ បុរោហិតដែលទាសៈចោមរោម មកកាន់ប្រាំងស្ទឹងដើម្បីងូតទឹក បុរោហិតនោះជាអ្នកដឹងសំឡេងយំរបស់សត្វគ្រប់ប្រភេទ ។ ដោយហេតុនោះ បុរោហិតនោះ បានស្តាប់ត្រីខ្សឹកខ្សួល ទើបគិតថា ត្រីនេះ ខ្សឹកខ្សួលព្រោះកិលេស ត្រីនេះ មានចិត្តសោប់សល់យ៉ាងនេះ ស្លាប់ទៅ នឹងទៅកើតក្នុងនរកប៉ុណ្ណោះ អញនឹងជាទីពឹងអាស្រ័យរបស់ត្រីនេះ ។

ទើបបុរោហិតនោះទៅរកអ្នកប្រមង់ ហើយពោលថា អ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកមិនឲ្យត្រីយើង ដើម្បីធ្វើម្ហូប សូម្បីត្រឹមមួយថ្ងៃ អ្នកប្រមង់ទាំងឡាយពោលថា បពិត្រលោកម្ចាស់ លោកនិយាយអ្វី សូមលោកជ្រើសយកត្រីដែលលោកគាប់ចិត្តទៅចុះ ។ បុរោហិតពោលថា កិច្ចរបស់ខ្ញុំមិនទាក់ទងជាមួយអ្នកដទៃ ចូរពួកអ្នក ឲ្យត្រីមួយ ( នេះ ) ប៉ុណ្ណោះ ពួកអ្នកប្រមង់ពោលថា យកចុះលោកម្ចាស់ ព្រះពោធិសត្វយកដៃទាំង ២ ចាប់ត្រីនោះទៅអង្គុយត្រង់ប្រាំងស្ទឹង ពោលប្រៀនប្រដៅថា ត្រីដ៏ចម្រើន ថ្ងៃនេះ បើខ្ញុំមិនឃើញអ្នក អ្នកនឹងដល់នូវការស្លាប់ តាំងអំពីនេះទៅ អ្នកកុំធ្លាក់ក្នុងអំណាច

*របស់កិលេសឡើយ រួចលែងទៅក្នុងទឹក ខ្លួនឯង ក៏ចូលទៅកាន់នគរ ។*

*ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ។ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ឯព្រះសាស្តាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ត្រីញីក្នុងកាលនោះ បានមកជាភរិយាចាស់ក្នុងកាលឥឡូវនេះ ត្រីឈ្មោលក្នុងកាលនោះ បានមកជាភិក្ខុដែលអផ្សុកក្នុងកាលឥឡូវនេះ ឯបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។៚*

**អដ្ឋកថាមច្ឆជាតក ចប់**

# សុត្តន្តបិដក

## វដ្ដកជាតក

[ ៣៥ ] ( កូនចាបពោធិសត្វពោលថា ) ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេនិងបា ( របស់យើង ) ចេញបាត់ទៅហើយ នែភ្លើងព្រៃអ្នក ចូរថយទៅចុះ ។

វដ្ដកជាតកទី ៥ ចប់

# អដ្ឋកថា

## វដ្ដកជាតក

[ ៣៥ ] ព្រះសាស្ដា កាលត្រាច់ចារិកទៅក្នុងមគធជនបទ ទ្រង់ប្រារព្ធការរលត់ភ្លើងព្រៃ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សន្តិ បក្ខា** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដាកាលចារិកទៅក្នុងមគធជនបទទាំងឡាយ បានយាងបិណ្ឌបាតក្នុងភូមិអ្នកមគធៈមួយកន្លែង ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត មានភិក្ខុសង្ឃចោមរោម ទ្រង់យាងចុះកាន់ផ្លូវ ។ សម័យនោះ ភ្លើងព្រៃដ៏ខ្លាំងក្លាតាំងឡើង ភិក្ខុជាច្រើន ឃើញទាំងខាងមុខ និងខាងក្រោយ ។ ផ្សែង និងអណ្ដាតភ្លើងទាំងឡាយ ឆេះរាលទូទៅនោះឯង ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុបុថុជ្ជនមួយពួកខ្លាចចំពោះមរណភ័យ ពោលថា ពួកយើងនឹងដុតភ្លើងកាត់ភ្លើងដែលឆេះមក នឹងមិនឆេះត្រង់ទីដែលភ្លើងនោះឆេះហើយ ទើបនាំបំពង់ប៉ុយចេញមកដុត ។ ភិក្ខុមួយពួកទៀតពោលថា អាវុសោ ពួកអ្នកធ្វើអ្វី ពួកអ្នកមិនឃើញព្រះសម្មាសម្ពុទ្ធដែលជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ដែលយាងទៅជាមួយពួកយើងនោះឯង ដូចបុគ្គលមិនឃើញព្រះចន្ទ ដែលអណ្ដែតក្នុងលម្ហ មិនឃើញព្រះអាទិត្យប្រដាប់ដោយរស្មី ១០០០ កំពុងរះឡើងអំពីលោកធាតុទិសខាងកើត ដូចបុគ្គលឈរត្រង់ច្រាំងសមុទ្រ មិនឃើញសមុទ្រ ដូចបុគ្គលឈរផ្អែកភ្នំសិនេរុ មិនឃើញភ្នំសិនេរុ ដូច្នោះ នាំគ្នាពោលថា ពួកយើងដុតភ្លើងកាត់ផ្លូវភ្លើង ឈ្មោះថាពួកលោកមិនដឹងកម្លាំងរបស់ព្រះពុទ្ធ មកចុះ ពួកយើងនឹងទៅកាន់សម្នាក់

របស់ព្រះសាស្តា ភិក្ខុទាំងនោះ កាលទៅខាងមុខ និងខាងក្រោយទាំងអស់ បានរួមគ្នាទៅកាន់សម្នាក់របស់ព្រះទសពល ។ ព្រះមុនីមានមហាភិក្ខុជាបរិវារ បានឈរប្រថាប់ក្នុងប្រទេសមួយកន្លែង ភ្លើងព្រៃឆេះ សំឡេងខ្លាំងមក ហាក់ដូចជាលិចលង់ កាលមកដល់ទីដែលព្រះតថាគតឈរប្រថាប់ លុះដល់ទីដែលព្រះសាស្តាប្រថាប់ឈរប្រមាណ ១៦ ករីស ជុំវិញប្រទេសនោះក៏រលត់ទៅ ដូចគប់ភ្លើងដែលគេជ្រលក់ក្នុងទឹក ដូច្នោះ មិនអាចឆាបឆេះទីប្រមាណ ៣២ ករីស[១] ដោយអណ្តាត ដូច្នេះ ។ ភិក្ខុទាំងឡាយ នាំគ្នាពោលគុណរបស់ព្រះសាស្តាថា គួរអស្ចារ្យ ព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ភ្លើងនេះមិនមានចិត្ត មិនអាចឆាបឆេះទីដែលព្រះពុទ្ធឈរប្រថាប់ រមែងរលត់ទៅ ដូចគប់ភ្លើងស្មៅរលត់ដោយទឹក ដូច្នោះ គួរអស្ចារ្យ អានុភាពរបស់ព្រះពុទ្ធទាំងឡាយ ។ ព្រះសាស្តា ទ្រង់បានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះ ដល់នូវភូមិប្រទេសនេះហើយរលត់ទៅ មិនមែនជាកម្លាំងរបស់តថាគតឥឡូវនេះប៉ុណ្ណោះទេ នេះជាកម្លាំងនៃសច្ចៈ ដែលមានអំពីមុនរបស់តថាគត ដ្បិតថា ក្នុងប្រទេសនេះ ភ្លើងនឹងមិនឆេះ អស់កប្បទាំងមូល នេះឈ្មោះថា បាដិហារ្យតាំងនៅមួយកប្ប ។ លំដាប់នោះ ព្រះអានន្ទក្រាលសង្ឃាដី ៤ ជាន់ ដើម្បីជាទីគង់របស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់គង់ពត់ភ្នែន ឯភិក្ខុសង្ឃក៏ថ្វាយបង្គំព្រះតថាគត អង្គុយចោមរោម ។ គ្រា

១- ទីដែលទ្រង់ឈរ ១៦ ករីស ទីជុំវិញដែលភ្លើងមិនរាលមកនោះ ១៦ ករីសទៀត ទើបជា ៣២ ករីស ។

នោះ ព្រះសាស្តា កាលភិក្ខុទាំងឡាយទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនេះប្រាកដហើយដល់ខ្ញុំព្រះអង្គទាំងឡាយ ឯរឿងអតីតកំបាំងនៅឡើយ សូមទ្រង់ធ្វើរឿងអតីតនោះ ឲ្យប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល ក្នុងប្រទេសនោះឯង ក្នុងដែនមគធៈ ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតសត្វក្រួច កើតអំពីផ្ទៃមាតា ក្នុងកាលញាស់មក បានជាកូនក្រួច មានខ្លួនប្រមាណប៉ុនដុំរទេះផ្ទុកទំនិញខ្នាតធំ គ្រានោះ មេបាឲ្យព្រះពោធិសត្វដេកក្នុងសម្បុក ហើយនាំអាហារមកចិញ្ចឹមដោយចំពុះ ។ ព្រះពោធិសត្វមិនមានកម្លាំង នឹងបើកស្លាបហើរទៅក្នុងអាកាស ឬមិនមានកម្លាំងលើកជើងដើរទៅត្រង់ទីទួល ឯភ្លើងព្រៃរមែងឆេះក្នុងទីនោះៗ រាល់ឆ្នាំ ។ គ្រានោះ ភ្លើងព្រៃនោះក៏ឆេះប្រទេសនោះដោយសំឡេងខ្លាំង ។ ពួកបក្សីនាំគ្នាចេញអំពីសម្បុករៀងៗ ខ្លួន ខ្លាចចំពោះមរណភ័យ ស្រែកយំគេចទៅ មេបារបស់ព្រះពោធិសត្វខ្លាចចំពោះមរណភ័យ ទើបចោលព្រះពោធិសត្វគេចទៅ ព្រះពោធិសត្វដេកក្នុងសម្បុកនោះឯង អើត-ក ឃើញភ្លើងព្រៃកំពុងឆេះមក ទើបគិតថា បើអញមានកម្លាំងបើកស្លាបហើរទៅក្នុងអាកាសសោត អញគប្បីហើរទៅទីដទៃ បើអញមានកម្លាំងលើកជើងដើរលើដីបានសោត អញនឹងឈានជើងទៅកាន់ទីដទៃ ឯមេបារបស់អញ ខ្លាចចំពោះមរណភ័យ បោះបង់អញឲ្យនៅម្នាក់ឯង កាលនឹងការពារខ្លួន ទើបគេចទៅ ។ ឥឡូវនេះ ទីពឹងដទៃរបស់អញមិនមាន អញមិនមានទីជ្រកកោន មិនមានទីពឹង ថ្ងៃនេះ អញ

នឹងធ្វើដូចម្ដេចហ្ន៎ ទើបគួរ ។ សម័យនោះ ព្រះពោធិសត្វគិតយ៉ាងនេះថា ឈ្មោះថា គុណនៃសីល រមែងមានក្នុងលោកនេះ ឈ្មោះថា គុណនៃសច្ចៈ ក៏រមែងមាន ក្នុងអតីតកាល ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ទ្រង់បំពេញបារមីទាំងឡាយ គង់ប្រថាប់ត្រង់មណ្ឌលពោធិព្រឹក្ស បានត្រាស់ដឹងព្រមក្រៃលែងហើយ ទ្រង់ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ទ្រង់ប្រកបដោយសច្ចៈ មេត្តា ករុណា និងខន្តី បុគ្គលដែលចម្រើនមេត្តាភាវនា ដែលប្រព្រឹត្តទៅហើយ ក្នុងសព្វសត្វទាំងឡាយ រមែងមាន គុណរបស់ព្រះធម៌ទាំងឡាយដែលព្រះសព្វញ្ញុពុទ្ធទាំងឡាយនោះទ្រង់ដឹងច្បាស់ហើយ រមែងមាន ម្យ៉ាងទៀត សច្ចៈណាមួយ រមែងមានចំពោះអញពិត សភាវធម៌ណាមួយ រមែងមានប្រាកដ ព្រោះហេតុនោះ អញគប្បីរឭកដល់ព្រះពុទ្ធទាំងឡាយក្នុងអតីត និងគុណទាំងឡាយ ដែលអតីតពុទ្ធនោះដឹងច្បាស់ហើយ កាន់យកសភាវធម៌ គឺសច្ចៈ ដែលមានក្នុងអាត្មាអញ ធ្វើសច្ចកិរិយាឲ្យភ្លើងថយត្រឡប់ទៅ ធ្វើនូវសួស្ដីដល់ខ្លួន និងពួកបក្សី ដ៏សេសក្នុងថ្ងៃនេះ ដោយហេតុនោះ ទើបលោកពោល ( ក្នុងខុទ្ទកនិកាយ ពុទ្ធវំស ) ថា

ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ ( សេចក្ដីស្អាត ) និងសេចក្ដីអាណិត សឹងមានក្នុងលោក ( បើដូច្នោះ ) អញនឹងធ្វើនូវសច្ចកិរិយាដ៏ឧត្ដម ដោយសច្ចៈនោះ ។ តថាគតពិចារណាកម្លាំងធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន

*ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ ( នោះ ) ដូច្នេះ ។*

*គ្រានោះ ព្រះពោធិសត្វរំលឹកដល់គុណទាំងឡាយរបស់ព្រះពុទ្ធ ដែលបរិនិព្វានទៅហើយក្នុងអតីត ហើយប្រារព្ធសភាវៈ គឺសច្ចៈ ដែលមានក្នុងខ្លួន កាលធ្វើសច្ចកិរិយា ទើបពោលគាថានេះថា*

*ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរ*
*មិនបាន មេ និងបា ( របស់យើង ) ចេញបាត់ទៅហើយ នៃភ្លើង*
*ព្រៃអ្នកចូរថយទៅចុះ ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **សន្តិ បក្ខា អបតនា** *សេចក្ដីថា ឈ្មោះថាស្លាបទាំង ២ របស់ខ្ញុំមាន គឺកើតមាន តែមិនអាចហើរ គឺទៅតាមអាកាសដោយស្លាបទាំងនោះបាន ហេតុនោះ ទើបឈ្មោះថា ហើរមិនបាន ។ បទថា* **សន្តិ បាទា អវញ្ចនា** *សេចក្ដីថា ជើងទាំង ២ របស់ខ្ញុំក៏មាន តែមិនអាចដើរ គឺទៅដោយការឈានជើងទៅ ដោយជើងទាំង ២ នោះ ព្រោះហេតុនោះ ទើបឈ្មោះថា ដើរមិនបាន ។ បទថា* **មាតា បិតា ចនិក្ខន្តា** *សេចក្ដីថា ម្យ៉ាងទៀត មេបាដែលនាំអាត្មាអញទៅទីដទៃនោះ ក៏ចេញទៅហើយ ព្រោះខ្លាចស្លាប់ ព្រះពោធិសត្វហៅភ្លើងថា* **ជាតវេទ** *ពិតហើយ ភ្លើងនោះ កាលកើតក៏ដឹង គឺប្រាកដ ព្រោះដូច្នោះ ទើបហៅថា* **ជាតវេទ** *ប្រែថា កើតក៏ដឹង ដោយបទថា* **បដិក្កម** *នេះ ព្រះពោធិសត្វបញ្ជាភ្លើងថា ចូរថយទៅ គឺចូរត្រឡប់ទៅ ។ ដូច្នោះ ព្រះមហាសត្វដេកក្នុងសម្បុកនោះឯង បានធ្វើសច្ចកិរិយាថា បើស្លាបទាំង ២ របស់អញមាន ភាវៈ គឺការលើកស្លាបទាំង ២*

ហើរទៅក្នុងអាកាសមិនបាន ១ ភាពដែលជើងទាំង ២ មាន ១ ភាវៈ គឺការលើកជើងទាំង ២ នោះដើរទៅមិនបាន ១ ភាពដែលមាតាបិតាចោលអាត្មាអញក្នុងសម្បុកនោះឯង គេចទៅ ១ ជាសេចក្តីពិតទាំងអស់ ម្នាលភ្លើងដោយពាក្យសច្ចៈនេះ ចូរអ្នកត្រឡប់ទៅអំពីទីនេះ ។

ជាមួយគ្នានឹងសច្ចកិរិយារបស់ព្រះពោធិសត្វនោះ ភ្លើងបានថយទៅក្នុងទីប្រមាណ ១៦ ករីស កាលនឹងថយទៅ ក៏ឆេះទៅកាន់ទីដទៃក្នុងព្រៃ រលត់ហើយក្នុងទីនោះឯង ដូចគប់ភ្លើងដែលបុគ្គលឲ្យលិចចូលក្នុងទឹក ដូច្នោះ ដោយហេតុនោះ ទើបលោកពោល ( ក្នុងខុទ្ទកនិកាយ ពុទ្ធវំស ) ថា

ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះ
សន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីស ( ហើយរលត់ក្នុង
នោះ ) ដូចជាគប់ភ្លើង ដែលបុគ្គលជ្រលក់ទៅក្នុងទឹក កុសល-
ធម៌ដទៃ ស្មើនឹងសច្ចៈនៃតថាគតពុំមានឡើយ នេះជាសច្ចបារមី
របស់តថាគត ដូច្នេះ ។

ស្ថានទីនោះកើតជាបាដិហារ្យ ឈ្មោះថា តាំងនៅអស់មួយកប្ប ព្រោះភ្លើងមិនឆេះក្នុងកប្បនេះ ។ ព្រះពោធិសត្វ លុះធ្វើសច្ចកិរិយាយ៉ាងនេះហើយ ក្នុងកាលអស់ជីវិត បានទៅតាមយថាកម្ម ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភ្លើងមិនឆេះក្នុងទីនេះ ជាកម្លាំងរបស់តថាគតក្នុងកាល

ឥឡូវនេះក៏មិនមែន កម្លាំងនោះជារបស់បុរាណ ជាកម្លាំងសច្ចៈ របស់តថាគត ក្នុងកាលជាកូនក្រួច ដូច្នេះ ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុខ្លះ បានជាព្រះសោតាបន្ន ពួកខ្លះ បានជាព្រះសកទាគាមី ពួកខ្លះ បានជាព្រះអនាគាមី ពួកខ្លះ សម្រេចអរហត្ត ឯព្រះសាស្ដាក៏ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា មេបាក្នុងកាលនោះ បានជាមាតាបិតា ក្នុងកាលឥឡូវនេះ ចំណែកស្ដេចក្រួច ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វដ្ដកជាតក ចប់**

# សុត្តន្តបិដក

## សកុណជាតក

[ ៣៦ ] ( សត្វស្លាបពោធិសត្វពោលថា ពួកសត្វស្លាប ) អាស្រ័យនឹងដើមឈើណា ដែលដុះលើផែនដី ដើមឈើនោះ ក៏បញ្ចេញភ្លើង ម្នាលអ្នកមានអវយវៈ ( ក្បាល និងក ) វៀចទាំងឡាយ អ្នកទាំងឡាយ ចូរគប់ទិស ( ទាំង ៤ ) ចុះ ភ័យកើតអំពីដើមឈើជាទីពឹងហើយ ។

សកុណជាតកទី ៦ ចប់

# អដ្ឋកថា

## សក្កុណជាតក

[ ៣៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលត្រូវភ្លើងឆេះបណ្ណសាលា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យស្មិំសិ្សតា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ហើយចេញអំពីវត្តជេតពនមហាវិហារ ទៅអាស្រ័យបច្ចន្តគាម ក្នុងកោសលជនបទ ក្នុងសេនាសនៈព្រៃមួយកន្លែង ។ លំដាប់នោះ បណ្ណសាលារបស់ភិក្ខុនោះ ត្រូវភ្លើងឆេះក្នុងខែដំបូងនោះឯង ភិក្ខុនោះគិតថា បណ្ណសាលារបស់អញត្រូវភ្លើងឆេះហើយ អញនៅលំបាក ទើបប្រាប់ដល់មនុស្សទាំងឡាយៗ អាងដល់ការងារនោះៗ យ៉ាងនេះថា ឥឡូវនេះ ស្រែរបស់ពួកខ្ញុំក្រៀមស្ងួត ពួកខ្ញុំនឹងបាចទឹកបញ្ចូលក្នុងស្រែហើយ សឹមធ្វើឲ្យ កាលបាចទឹកបញ្ចូលស្រែហើយ ព្រោះពូជ កាលព្រោះពូជហើយ ធ្វើរបង កាលធ្វើរបងហើយ ថែទាំ កាលថែទាំហើយ ច្រូត កាលច្រូតហើយ បោកបែន ដូច្នេះ បានឲ្យកាលវេលាកន្លងទៅ ៣ ខែ ភិក្ខុនោះលំបាកក្នុងទីវាលអស់ ៣ ខែ មិនអាចចម្រើនកម្មដ្ឋាន ញុំាងគុណវិសេសឲ្យកើត កាលបវារណាហើយ ក៏ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយនាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុនោះ ហើយត្រាស់សួរថា ម្នាលភិក្ខុ អ្នកនៅចាំវស្សាដោយស្រួលឬ កម្មដ្ឋានរបស់អ្នកដល់ទីបំផុតហើយឬ ។ ភិក្ខុនោះក្រាបទូលរឿងនោះ ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដ្ឋានរបស់ខ្ញុំព្រះអង្គ

មិនដល់ទីបំផុតទេ ព្រោះមិនមានសេនាសនៈដែលជាសប្បាយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន សូម្បីតែសត្វតិរច្ឆានទាំងឡាយ ក៏គង់ដឹងទីដែលជាសប្បាយ និងមិនសប្បាយរបស់ខ្លួន ព្រោះហេតុអ្វី ទើបអ្នកមិនដឹងហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតបក្សី មានពួកបក្សីចោមរោមអាស្រ័យដើមឈើធំ ដែលសម្បូរដោយមែក និងប្រគាប ក្នុងដងព្រៃ ។ មួយថ្ងៃ លម្អិតធ្លាក់ត្រង់មែកទាំងឡាយរបស់ដើមឈើនោះៗ សង្កៀតគ្នាទៅមកផ្សែងកើតឡើង ។ ព្រះពោធិសត្វឃើញដូច្នោះ គិតថា មែកទាំង ២ នេះសង្កៀតគ្នាយ៉ាងនេះ នឹងឆេះជាភ្លើង ភ្លើងនោះធ្លាក់ចុះទៅជាប់ស្លឹកឈើងាប់ៗចាប់តាំងអំពីនោះ ភ្លើងនឹងឆេះដើមឈើនេះ ពួកយើងមិនអាចនៅក្នុងទីនេះពួកយើងនឹងគេចអំពីទីនេះទៅទីដទៃ ទើបគួរ ព្រះពោធិសត្វក៏ពោលគាថានេះដល់ពួកបក្សីថា

ពួកសត្វស្លាប អាស្រ័យនឹងដើមឈើណា ដែលដុះលើផែនដី
ដើមឈើនោះ ក៏បញ្ចេញភ្លើង ម្នាលអ្នកមានអវយវៈ ( ក្បាល
និងក ) វៀចទាំងឡាយ អ្នកទាំងឡាយចូរគប់ទិស ( ទាំង ៤ )
ចុះ ភ័យកើតអំពីដើមឈើជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆគតិរុហំ** សេចក្តីថា ប្រឹថពី ហៅថា **ឆគតិ** ដើមឈើហៅថា **ឆគតិរុហា** ព្រោះដើមឈើកើតត្រង់ដីនោះ ។ បទថា

**វិហង្គមា** សេចក្តីថា អាកាស ហៅថា **វិហា** បក្សីទាំងឡាយ ហៅថា **វិហំគម** ព្រោះទៅក្នុងអាកាសនោះ ។ បទថា **ឆិសា ភជថ** សេចក្តីថា អ្នកទាំងឡាយ កាលលះដើមឈើនេះ គេចទៅអំពីទីនេះ ចូលទៅកាន់ទិស ទាំង ៤ ។ ព្រះពោធិសត្វហៅបក្សីទាំងឡាយថា **វង្កង្គា** ព្រោះថា បក្សី ទាំងនោះ ធ្វើកដែលទៅត្រង់ ឲ្យវៀចក្នុងកាលខ្លះ ព្រោះដូច្នោះ ទើបហៅថា **វង្កង្គា** ។ ម្យ៉ាងទៀត ឈ្មោះថា **វង្កង្គា** ព្រោះ **វង្គ** គឺស្លាបទាំងឡាយកើត ត្រង់ចំហៀងទាំង ២ របស់បក្សីទាំងនោះ ដូច្នេះក៏មាន ។ បទថា **ជាតំ សរណតោ ភយំ** សេចក្តីថា ភ័យកើតអំពីដើមឈើដែលជាទីពឹងអាស្រ័យ របស់ពួកយើងនោះឯង មកពួកយើងនាំគ្នាទៅទីដទៃ ។

បក្សីទាំងឡាយ ដែលឈ្លាសវៃ ធ្វើតាមពាក្យរបស់ព្រះពោធិសត្វ នាំ គ្នាហើរឡើងព្រមជាមួយព្រះពោធិសត្វនោះ ទៅក្នុងទីដទៃ ឯបក្សីទាំងឡាយ ដែលមិនឈ្លាសវៃ នាំគ្នាពោលយ៉ាងនេះថា បក្សីនេះឃើញថា មានក្រពើ នៅក្នុងទឹកមួយតំណក់ ទើបមិនជឿពាក្យរបស់ព្រះពោធិសត្វនោះ នៅក្នុងទី នោះឯង ។ តមកមិនយូរប៉ុន្មាន ភ្លើងកើតឡើងត្រង់ដើមឈើនោះ តាមអាការ ដែលព្រះពោធិសត្វគិតហើយនោះឯង កាលផ្សែង និងអណ្តាតតាំងឡើង បក្សី ទាំងឡាយមានភ្នែកងងឹតព្រោះផ្សែង ទើបមិនអាចទៅទីណាបាន ធ្លាក់ក្នុងភ្លើង ដល់នូវសេចក្តីវិនាស ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន សត្វតិរច្ឆានទាំងឡាយ នៅលើចុងឈើ ក៏ដឹងភាពជាសប្បាយ និងមិនសប្បាយរបស់ខ្លួនយ៉ាងនេះ

ព្រោះហេតុអ្វី ទើបអ្នកមិនដឹង ដូច្នេះ ។ កាលទ្រង់នាំព្រះធម្មទេសនានេះមក ហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ឯព្រះសាស្តាទ្រង់ក៏បន្តអនុសន្ធិប្រជុំជាតកថា បក្សីទាំងឡាយ ដែលធ្វើតាមពាក្យរបស់ព្រះពោធិសត្វ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯបក្សីដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

## អដ្ឋកថា សកុណជាតក ចប់

# សុត្តន្តបិដក

## តិត្តិរជាតក

[ ៣៧ ] ( ព្រះសាស្ដាទ្រង់ត្រាស់ថា ) ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចម្រើនហើយ ពួកជននោះ អ្នកផង គប្បីសរសើរក្នុងបច្ចុប្បន្នផង សម្បរាយលោក គឺសុគតិ ក៏កើត ( ដល់ពួកជននោះ ) ផង ។

**តិត្តិរជាតកទី ៧ ចប់**

# អដ្ឋកថា

## តិត្តិរជាតក

[ ៣៧ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធការហាមសេនាសនៈព្រះសារីបុត្រ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យេ វុឌ្ឍមបចាយន្តិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កាលអនាថបិណ្ឌិកសេដ្ឋីសាងវិហារស្រេចហើយ បញ្ជូនទូតទៅនិមន្តព្រះសាស្តាៗ យាងចេញអំពីនគររាជគ្រឹះ ដល់នគរវេសាលី គង់នៅក្នុងនគរវេសាលីនោះ តាមពេញព្រះហឫទ័យ ហើយទ្រង់ព្រះតម្រិះថា នឹងទៅនគរសាវត្ថី ទើបយាងទៅតាមផ្លូវ ។ សម័យនោះ អន្តេវាសិកទាំងឡាយរបស់ឆព្វគ្គិយភិក្ខុនាំគ្នាចេញដំណើរទៅមុន កាលព្រះថេរៈទាំងឡាយមិនទាន់បានទៅរកសេនាសនៈ នាំគ្នាហួងហែងសេនាសនៈ ដោយការពោលថា សេនាសនៈនេះជារបស់ឧបជ្ឈាយ៍ពួកយើង សេនាសនៈនេះជារបស់អាចារ្យពួកយើង សេនាសនៈនេះជារបស់ពួកយើងប៉ុណ្ណោះ ។ ព្រះថេរៈទាំងឡាយដែលមកឯក្រោយ មិនបានសេនាសនៈ ។ អន្តេវាសិកទាំងឡាយរបស់សារីបុត្តត្ថេរ នាំគ្នាស្វែងរកសេនាសនៈដើម្បីព្រះថេរៈក៏មិនបាន ។ ព្រះថេរៈកាលមិនបានសេនាសនៈ ទើបសម្ងំដោយការអង្គុយ និងការដើរចង្ក្រម ត្រង់គល់ឈើមួយកន្លែង ក្នុងទីដែលមិនឆ្ងាយអំពីសេនាសនៈរបស់ព្រះសាស្តានោះឯង ។ ក្នុងពេលជិតភ្លឺ ព្រះសាស្តាយាងចេញមក ទ្រង់ព្រះឧក្កាសិតៈ គឺគ្រហែម ព្រះថេរៈក៏គ្រហែមតប ព្រះសាស្តាត្រាស់សួរថា នុ៎ះជានរណា ព្រះសារីបុត្រក្រាបទូលថា ខ្ញុំព្រះអង្គ សារីបុត្រ ។ ព្រះសាស្តាត្រាស់សួរថា

ម្នាលសារីបុត្រ អ្នកធ្វើអ្វីក្នុងទីនេះ ពេលនេះ ។ ទើបព្រះសារីបុត្រទូលរឿងនោះ ។ កាលព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ព្រះសារីបុត្រហើយ ទ្រង់រំពឹងថា សូម្បីតថាគតនៅមានជីវិត ភិក្ខុទាំងឡាយមិនគោរព មិនកោតក្រែងដល់គ្នានិងគ្នា កាលតថាគតបរិនិព្វានទៅហើយ ភិក្ខុទាំងឡាយនឹងធ្វើអ្វីដល់គ្នានិងគ្នាហ្ន៎ ធម្មសង្វេគក៏កើតឡើង ។ លុះរាត្រីអស់ហើយ ទើបទ្រង់ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នា ហើយសាកសួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយបានឮថា ឆព្វគ្គិយភិក្ខុទៅមុន ដណ្តើមសេនាសនៈរបស់ភិក្ខុទាំងឡាយ ដែលជាថេរៈពិតឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយ ។ បន្ទាប់អំពីនោះ ទើបទ្រង់តិះដៀលឆព្វគ្គិយភិក្ខុ ហើយត្រាស់ធម្មកថាហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ នរណាហ្ន៎ រមែងគួរដល់អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយប្រសើរ ។ ភិក្ខុពួកខ្លះ ក្រាបទូលថា អ្នកបួសដែលចេញអំពីខត្តិយត្រកូល ពួកខ្លះ ក្រាបទូលថា អ្នកបួសដែលចេញអំពីព្រាហ្មណត្រកូល ។ ពួកខ្លះ ក្រាបទូលថា អ្នកបួសដែលចេញអំពីគហបតីត្រកូល ភិក្ខុមួយពួកទៀតក្រាបទូលថា ព្រះវិនយធរ ព្រះធម្មកថិក លោកអ្នកបានបឋមជ្ឈាន លោកអ្នកបានទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ភិក្ខុមួយពួកទៀត ក្រាបទូលថា ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះអរហន្ត លោកអ្នកមានវិជ្ជា ៣ អ្នកមានអភិញ្ញា ៦ រមែងគួរដល់អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ។ ក្នុងពេលដែលភិក្ខុទាំងឡាយ ពោលដល់បុគ្គលដែលគួរដល់សេនាសនៈដ៏ប្រសើរជាដើម

តាមគាប់ចិត្តរៀងៗ ខ្លួនយ៉ាងនោះ ទើបព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដល់អាសនៈដ៏ប្រសើរជាដើម ក្នុងសាសនារបស់តថាគត មិនមែនជាអ្នកបួសដែលចេញពីត្រកូលក្សត្រជាប្រមាណឡើយ អ្នកបួសក្នុងត្រកូលព្រាហ្មណគហបតី វិនយធរ អ្នកព្រះសូត្រ អ្នកអភិធម្ម អ្នកបានបឋមជ្ឈានព្រះសោតាបន្នជាដើមឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដោយពិត ក្នុងសាសនានេះ គួរធ្វើការអភិវាទ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម តាមដែលចាស់ជាង គួរបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរដល់បុគ្គលដែលចាស់ជាង នេះជាប្រមាណក្នុងសាសនានេះ ព្រោះដូច្នោះភិក្ខុដែលចាស់ជាង ជាបុគ្គលគួរដល់អាសនៈដ៏ប្រសើរជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះឯង សារីបុត្រអគ្គសាវករបស់តថាគត ជាអ្នកប្រកាសធម្មចក្រដូចតថាគតបាន គួរបានសេនាសនៈជាប់នឹងតថាគត សារីបុត្រនោះកាលមិនបានសេនាសនៈ ទើបនៅត្រង់គល់ឈើអស់រាត្រីនេះ ឥឡូវនេះឯងអ្នកទាំងឡាយ មិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគគ្នាយ៉ាងនេះ អំណឹះតទៅ ពួកអ្នកនឹងធ្វើអ្វី ។ លំដាប់នោះ ដើម្បីប្រទានឱវាទដល់ភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុនសត្វតិរច្ឆានទាំងឡាយ ក៏នាំគ្នាគិតថា ការដែលពួកយើងមិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគដល់គ្នានិងគ្នា មិនសមគួរដល់ពួកយើងបណ្ដាយើងទាំងឡាយ ពួកយើងនឹងដឹងអ្នកដែលចាស់ជាង ហើយធ្វើអភិវាទជាដើមដល់បុគ្គលចាស់ជាងនោះ ទើបពិចារណាសាទៅក្រោយ ហើយដឹងថា

បណ្តាយើងទាំងឡាយ អ្នកនេះជាបុគ្គលចាស់ជាង ទើបធ្វើអភិវាទជាដើមដល់អ្នកចាស់ជាងនោះ ញុំាងផ្លូវទៅទេវលោកឲ្យពេញ ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល មានសម្លាញ់ ៣ នាក់ គឺសត្វទទា ស្វា និងដំរី នៅអាស្រ័យដើមជ្រៃធំមួយ ក្នុងហិមវន្តប្បទេស ។ សម្លាញ់ទាំង ៣ នោះ បានជាបុគ្គលមិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគគ្នានិងគ្នា ។ សម័យនោះ សម្លាញ់ទាំង ៣ នោះ គិតដូច្នេះថា យើងទាំងឡាយនៅយ៉ាងនេះមិនសមគួរ បើដូច្នោះ ពួកយើងគប្បីធ្វើអភិវាទជាដើមដល់បណ្តាពួកយើងដែលចាស់ជាង ។ សម្លាញ់ទាំង ៣ គិតគ្នាថា បណ្តាពួកយើង អ្នកណាជាអ្នកចាស់ជាង ថ្ងៃមួយ គិតគ្នាថា ឧបាយនេះមាន ដូច្នេះហើយ ទើបសត្វទាំង ៣ អង្គុយត្រង់គល់ជ្រៃ សត្វទទា និងស្វាសួរដំរីថា នែដំរីសម្លាញ់ អ្នកស្គាល់ដើមជ្រៃនេះតាំងពីពេលណា ដំរីនោះពោលថា នែសម្លាញ់ទាំងឡាយក្នុងកាលជាកូនដំរីជំទង់ ខ្ញុំដើរ ធ្វើដើមជ្រៃនេះទុកក្នុងរវាងភ្លៅ ក្នុងពេលដែលខ្ញុំឈរសង្កត់ពីលើ ត្រួយរបស់ដើមជ្រៃនេះ ប៉ះពោះរបស់ខ្ញុំ ទើបខ្ញុំស្គាល់ដើមជ្រៃនេះតាំងអំពីកាលដែលនៅជាគុម្ព ។ ទើបសម្លាញ់ទាំង ២ សួរស្វាដោយន័យមុននោះឯងទៀត ស្វានោះពោលថា សម្លាញ់ទាំងឡាយ ខ្ញុំជាកូនស្វា អង្គុយត្រង់ផែនដី មិនចាំបាច់អើត-កឡើយ ទំពាស៊ីត្រួយជ្រៃខ្ចីនេះ កាលបើដូច្នេះ ទើបខ្ញុំស្គាល់ដើមជ្រៃនេះ តាំងអំពីនៅតូច ។ គ្រានោះ ទើបសម្លាញ់ទាំង ២ សួរទទាដោយន័យមុននោះឯង ។ ទទានោះពោលថា សម្លាញ់ទាំង

ឡាយ កាលមុន ដើមជ្រៃធំមានក្នុងទីឈ្មោះនោះ ខ្ញុំស៊ីផ្លែរបស់វាហើយ បន្ទោបង់ឧច្ចារៈក្នុងទីនេះ បន្ទាប់ពីនោះ ទើបដើមជ្រៃនេះដុះត្រង់ទីនេះ ខ្ញុំស្គាល់ដើមជ្រៃនេះ តាំងអំពីវាមិនទាន់កើត ព្រោះដូច្នោះ ទើបខ្ញុំចាស់ជាងអ្នកទាំងឡាយ ដោយកំណើត ។ កាលទទាពោលយ៉ាងនេះ ទើបស្វា និងដំរីពោលនឹងទទា ដែលជាបណ្ឌិតថា នែសម្លាញ់ លោកជាបុគ្គលចាស់ជាងយើងទាំងឡាយ ចាប់តាំងអំពីនេះទៅ ពួកយើងនឹងធ្វើសក្ការៈ ការគោរព ការរាប់អាន ការថ្វាយបង្គំ ការបូជា កាអភិវាទ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្មដល់លោក និងតាំងនៅក្នុងឱវាទរបស់លោក ម្យ៉ាងទៀត តាំងអំពីនេះទៅ លោកគប្បីឲ្យឱវាទ និងអនុសាសនីដល់យើងទាំងឡាយ ។ តាំងអំពីនោះមក សត្វទទាបានឲ្យឱវាទដល់ស្វា និងដំរីទាំងនោះ ឲ្យតាំងនៅក្នុងសីល សូម្បីខ្លួនឯងក៏សមាទានសីល ។ សម្លាញ់ទាំង ៣ នោះតាំងនៅក្នុងសីល ៥ មានការគោរពកោតក្រែងនូវគ្នានិងគ្នា មានការប្រព្រឹត្តជាសភាគគ្នា ក្នុងកាលអស់ជីវិត ជាអ្នកមានទេវលោក ជាទីទៅខាងមុខ ។ ការសមាទាននៃសម្លាញ់ទាំង ៣ នោះ ឈ្មោះថា **តិត្តិរព្រហ្មចរិយៈ។**

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា សត្វតិរច្ឆានទាំងនោះ គង់មានការគោរព មានការកោតក្រែងដល់គ្នានិងគ្នា ឯអ្នកទាំងឡាយក៏បួសក្នុងធម្មវិន័យដែលតថាគតពោលល្អហើយយ៉ាងនេះ ព្រោះហេតុអ្វី ទើបមិនគោរពកោតក្រែងគ្នានិងគ្នា ម្នាលភិក្ខុទាំងឡាយ តាំងអំពីនេះទៅ តថាគតអនុញ្ញាតការអភិវាទ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម ដល់បុគ្គល

ដែលចាស់ជាង អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ តាមដែលចាស់ជាង ដល់អ្នកទាំងឡាយ តាំងអំពីនេះទៅ បុគ្គលខ្ទីជាង មិនគប្បីហាមសេនាសនៈដល់បុគ្គលចាស់ជាង ភិក្ខុណាហាម ភិក្ខុនោះត្រូវអាបត្តិទុក្កដ ដូច្នេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកយ៉ាងនេះហើយ ទ្រង់ត្រាស់ដឹងព្រមចំពោះហើយ ទើបត្រាស់គាថានេះថា

ពួកជនណា ជាអ្នកឈ្លាស ក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចម្រើនហើយ ពួកជននោះ អ្នកផង គប្បីសរសើរ ក្នុងបច្ចុប្បន្នផង សម្បរលោក គឺសុគតិ ក៏កើត ( ដល់ពួកជននោះ ) ផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ វុឌ្ឍមបចាយន្តិ** សេចក្ដីថា បុគ្គលធំ ៣ ពួក គឺធំដោយជាតិ ១ ធំដោយវ័យ ១ ធំដោយគុណ ១ បណ្ដាអ្នកធំ ៣ ពួកនោះ បុគ្គលសម្បូរដោយជាតិ ឈ្មោះថា អ្នកធំដោយជាតិ បុគ្គលដែលតាំងនៅក្នុងវ័យ ឈ្មោះថា ធំដោយវ័យ បុគ្គលសម្បូរដោយគុណ ឈ្មោះថា ធំដោយគុណ ។ បណ្ដាអ្នកធំ ៣ ពួកនោះ បុគ្គលចម្រើនដោយវ័យ សម្បូរដោយគុណ លោកបំណងថា ជាអ្នកធំក្នុងទីនេះ ។ បទថា **អបចាយន្តិ** សេចក្ដីថា បូជាដោយកម្ម គឺការឱនលំទោនចំពោះបុគ្គលចម្រើន ។ បទថា **ធម្មស្ស កោវិទា** បានដល់ ជាអ្នកឈ្លាសក្នុងធម៌ គឺការប្រព្រឹត្ត រមែងបង្អោនចំពោះបុគ្គលចម្រើន ។ បទថា **ទិដ្ឋេ ធម្មេ** បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា **បាសំសា** បានដល់ គួរដល់ការសរសើរ ។ បទថា **សម្បរាយោ ច**

**សុគ្គតិ** សេចក្ដីថា ឈ្មោះថា **សម្បរាយោ** ព្រោះត្រូវទៅខាងមុខ គឺគប្បីលះលោកនេះទៅ ដ្បិតថា លោកខាងមុខ រមែងជាសុគតិរបស់ជនទាំងនោះឯង ។ ក្នុងទីនេះ មានអត្ថដែលសរុបដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ទោះជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ឬសត្វតិរច្ឆានក៏ដោយ សត្វទាំងឡាយណាដែលជាអ្នកឈ្លាសក្នុងធម៌ គឺការគោរព កោតក្រែងចំពោះអ្នកធំ ធ្វើការឱនលំទោនចំពោះអ្នកធំដោយវ័យទាំងឡាយ ជាអ្នកសម្បូរដោយគុណ សត្វទាំងនោះរមែងបាននូវការសរសើរ គឺពណ៌នាសរសើរក្នុងអត្តភាពនេះឯង ជាអ្នកឱនលំទោនដល់បុគ្គលចម្រើនបំផុត ព្រោះកាយបែកទៅហើយតែង កើតក្នុងស្ថានសួគ៌ ។

ព្រះសាស្ដាត្រាស់គុណរបស់ធម៌ គឺការគោរពចំពោះអ្នកចម្រើនយ៉ាងនេះហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ដំរីដ៏ប្រសើរក្នុងកាលនោះ បានមកជាមោគ្គល្លាន ក្នុងកាលឥឡូវនេះ ស្វាក្នុងកាលនោះ បានមកជាសារីបុត្រ ឯសត្វទទាដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អដ្ឋកថាតិត្តិរជាតក ចប់

# សុត្តន្តបិដក

## ពកជាតក

[ ៣៨ ] ( រុក្ខទេវតាពោធិសត្វពោលថា ) បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត រមែងមិនដល់សេចក្តីសុខ អស់កាលជានិច្ច ព្រោះបញ្ញាជាគ្រឿងបញ្ឆោតឡើយ បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត ( នោះ ) រមែងបាន ( នូវលទ្ធផលអាក្រក់ ) ដូចសត្វកុក ( បាននូវការដាច់ក ) អំពីក្តាម ។

*ពកជាតកទី ៨ ចប់*

# អដ្ឋកថា

## ពកជាតក

[ ៣៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលចម្រើនដោយចីវរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នាច្ចន្តំ និកតិប្បញ្ញោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនៅក្នុងវត្តជេតពនមួយរូប ជាអ្នកឈ្លាសក្នុងកម្មឯណាមួយ មានការកាត់ ការខាត់ ការរៀបចំ និងការដេរសំពត់ ដែលគប្បីធ្វើក្នុងចីវរជាដើម ។ ភិក្ខុនោះ ចីវរ រមែងចម្រើនដោយភាពជាអ្នកឈ្លាសនោះ ព្រោះដូច្នោះ ទើបប្រាកដឈ្មោះថា **ចីវរវឌ្ឍក** ( បុគ្គលដែលចម្រើនដោយចីវរ ) ។ សួរថា ភិក្ខុនេះធ្វើដូចម្តេច ។ ឆ្លើយថា ភិក្ខុនេះយកសំពត់ចាស់ ដែលចាស់គ្រាំគ្រា មកសម្តែងហត្ថកម្ម ធ្វើចីវរឲ្យជាចីវរមានសម្ផស្សល្អ គួរពេញចិត្ត ក្នុងកាលជ្រលក់ស្រេច ក៏ជ្រលក់ដោយទឹកម្សៅ ខាត់ដោយស័ង្ខ ធ្វើឲ្យភ្លឺរលោង ជាទីពេញចិត្ត ហើយបត់ទុកដាក់ ។ ភិក្ខុទាំងឡាយមិនចេះធ្វើចីវរកម្ម ទើបកាន់យកសំពត់សាដកថ្មីៗ ទាំងឡាយ ទៅកាន់សម្នាក់របស់ភិក្ខុនោះ រួចពោលថា ពួកខ្ញុំមិនចេះធ្វើចីវរ សូមលោកធ្វើចីវរឲ្យដល់ពួកខ្ញុំ ។ ភិក្ខុនោះពោលថា អាវុសោទាំងឡាយ ចីវរ កាលធ្វើរមែងយូរ ចីវរដែលខ្ញុំធ្វើ មានលោកទាំងឡាយ ដាក់សំពត់សាដកថ្មីទាំងនេះ ហើយកាន់យកចីវរដែលធ្វើហើយនោះទៅចុះ ពោលហើយ ទើបនាំមកឲ្យមើល ។ ភិក្ខុទាំងនោះឃើញវណ្ណសម្បត្តិរបស់ចីវរប៉ុណ្ណោះ មិនដឹងដល់ខាងក្នុង សម្គាល់ថា មាំទាំល្អ ទើបឲ្យសំពត់សាដកថ្មីទាំងឡាយដល់ចីវរវឌ្ឍកៈ ហើយកាន់យកចីវរនោះទៅ ។

ចីវរនោះ ដែលភិក្ខុទាំងនោះ បោកដោយទឹកក្តៅ ក្នុងកាលដែលប្រឡាក់តិចតួច ទើបចីវរនោះបង្ហាញប្រក្រតីរបស់ខ្លួន គឺចាស់គ្រាំគ្រា ប្រាកដក្នុងទីនោះៗ ភិក្ខុទាំងនោះមាននូវវិប្បដិសារី ។ ភិក្ខុនោះ យកសំពត់ចាស់បញ្ឆោតភិក្ខុទាំងឡាយដែលមកហើយ ដោយអាការយ៉ាងនេះ រហូតប្រាកដក្នុងទីទាំងពួង ។ ក្នុងស្រុកមួយទៀត មានចីវរវឌ្ឍកៈមួយរូប បោកបញ្ឆោតភិក្ខុទាំងឡាយ ដូចចីវរវឌ្ឍកៈក្នុងជេតពនវិហារនេះដែរ ភិក្ខុទាំងឡាយ ដែលជាមិត្ររបស់ភិក្ខុនោះប្រាប់ថា អាវុសោ បានឮថា ចីវរវឌ្ឍកៈមួយរូបក្នុងវត្តជេតពន បោកបញ្ឆោតភិក្ខុទាំងឡាយយ៉ាងនេះ ។ គ្រានោះ ចីវរវឌ្ឍកៈស្រុកក្រៅនោះ មានគំនិតយ៉ាងនេះថា ណ្ហើយចុះ អញនឹងបោកចីវរវឌ្ឍកៈអ្នកក្រុងរូបនោះ ហើយធ្វើចីវរចាស់ឲ្យជាទីពេញចិត្តក្រៃលែង ជ្រលក់យ៉ាងល្អ បានដណ្តប់ចីវរនោះទៅកាន់វត្តជេតពន ។ ឯចីវរវឌ្ឍកៈអ្នកក្រុងឃើញចីវរនោះប៉ុណ្ណោះ កើតនូវការចង់បាន ទើបសួរថា អាវុសោ ចីវរនេះ លោកធ្វើឯងឬ ព្រះចីវរវឌ្ឍកៈស្រុកក្រៅពោលថា អាវុសោ ខ្ញុំធ្វើឯង ។ ចីវរវឌ្ឍកៈអ្នកក្រុងពោលថា អាវុសោ សូមលោកឲ្យចីវរនេះដល់ខ្ញុំ លោកនឹងបានចីវរដទៃ ។ ចីវរវឌ្ឍកៈស្រុកក្រៅពោលថា អាវុសោ ខ្ញុំជាអ្នកស្រុកក្រៅ រកបច្ច័យបានដោយលំបាក ខ្ញុំឲ្យចីវរនេះដល់លោកហើយ ខ្លួនឯងនឹងដណ្តប់អ្វី ។ ព្រះចីវរវឌ្ឍកៈអ្នកក្រុងពោលថា អាវុសោ សំពត់សាដកថ្មីៗ ក្នុងសម្នាក់របស់ខ្ញុំមាន សូមលោកកាន់យកសំពត់សាដកនោះ ធ្វើចីវររបស់លោកចុះ ។ ព្រះចីវរវឌ្ឍកៈស្រុកក្រៅពោលថា អាវុសោ ខ្ញុំសម្តែងហត្ថកម្មក្នុងចីវរនេះ បើលោកពោលយ៉ាង

នេះ ខ្ញុំនឹងពោលដូចម្ដេច សូមលោកកាន់យកចីវរផ្ទាំងនេះ ហើយឲ្យចីវរដែលធ្វើដោយសំពត់ចាស់ដល់ចីវរវឌ្ឍកៈអ្នកក្រុងនោះ ហើយកាន់យកសំពត់សាដកថ្មី បញ្ឆោតព្រះចីវរវឌ្ឍកៈអ្នកក្រុងនោះ ហើយចៀសទៅ ឯចីវរវឌ្ឍកៈដែលនៅក្នុងវត្តជេតពន ក៏ជណ្ដប់ចីវរនោះ លុះកន្លងទៅ ២-៣ ថ្ងៃ ទើបបោកដោយទឹកក្ដៅ ឃើញថា ជាចីវរចាស់ក៏ខ្មាស ។ ភាពដែលព្រះចីវរវឌ្ឍកៈអ្នកក្រុងនោះត្រូវបោកបញ្ឆោតកើតប្រាកដទៅក្នុងជំនុំសង្ឃថា បានឮថា ចីវរវឌ្ឍកៈដែលនៅក្នុងវត្តជេតពន ត្រូវចីវរវឌ្ឍកៈស្រុកក្រៅ បោកបញ្ឆោតហើយ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយ នាំគ្នាអង្គុយពោលរឿងនោះក្នុងធម្មសភា ។ ព្រះសាស្ដា ទ្រង់យាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចីវរវឌ្ឍកៈនៅក្នុងវត្តជេតពន រមែងបញ្ឆោតភិក្ខុដទៃក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បោកបញ្ឆោតមកហើយដូចគ្នា ឯចីវរវឌ្ឍកៈស្រុកក្រៅបានបោកបញ្ឆោតចីវរវឌ្ឍកៈ ដែលនៅក្នុងវត្តជេតពនក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានបោកបញ្ឆោតហើយដូចគ្នា ទ្រង់បាននាំអតីតនិទានមកសម្ដែងដូចតទៅ

ក្នុងអតីតកាល ព្រះពោធិសត្វកើតជារុក្ខទេវតា នៅត្រង់ដើមឈើដែលតាំងអាស្រ័យស្រះឈូកមួយកន្លែង ក្នុងដងព្រៃមួយ ។ ក្នុងកាលនោះ នារដូវក្ដៅ ទឹកក្នុងស្រះមួយកន្លែង ដែលមិនធំពេក បានតិចចុះ តែក្នុងស្រះនោះ

មានត្រីច្រើន គ្រានោះ កុកមួយឃើញត្រីទាំងឡាយហើយ គិតថា អញនឹងបោកត្រីទាំងនេះ ដោយឧបាយណាមួយ ទើបទៅឈរគិតត្រង់មាត់ច្រាំង ។ លំដាប់នោះ ត្រីទាំងឡាយឃើញកុកនោះ ទើបសួរថា នែអ្នក អ្នកសំកុកគិតដល់រឿងអ្វីឬ កុកពោលថា ខ្ញុំគិតដល់ពួកអ្នក ត្រីទាំងឡាយសួរថា នែអ្នក អ្នកគិតអ្វីដល់ពួកយើង ។ កុកពោលថា ខ្ញុំគិតដល់ពួកអ្នកថា ទឹកក្នុងស្រះនេះតិច ទីសញ្ចរក៏តូច កម្ដៅក៏មានខ្លាំង ឥឡូវនេះ ត្រីទាំងនេះនឹងធ្វើដូចម្ដេច សម័យនោះ ទើបពួកត្រីពោលថា នែអ្នក ពួកខ្ញុំនឹងធ្វើដូចម្ដេច ។ កុកពោលថា បើអ្នកទាំងឡាយធ្វើតាមពាក្យរបស់ខ្ញុំ ខ្ញុំអាចយកចំពុះ ពាំបណ្ដាពួកអ្នកម្ដងមួយ នាំទៅលែងក្នុងស្រះធំមួយកន្លែង ដែលដេរដាសដោយផ្កាឈូកមាន ៥ ពណ៌ ។ ត្រីទាំងឡាយពោលថា នែអ្នក តាំងអំពីបឋមកប្បមក ឈ្មោះថា កុក បំណងល្អចំពោះត្រី រមែងមិនមាន អ្នកបំណងស៊ីពួកយើងម្ដងមួយ ពួកយើងមិនជឿអ្នកឡើយ ។ កុកពោលថា ខ្ញុំមិនស៊ីទេ បើពួកអ្នកមិនជឿខ្ញុំថាស្រះទឹកមាន ចូរពួកអ្នកបញ្ជូនត្រីមួយ ទៅមើលស្រះនោះជាមួយខ្ញុំ ។ ត្រីទាំងឡាយក៏ជឿកុកនោះ គិតថា ត្រីនេះអាចទាំងផ្លូវទឹក និងផ្លូវគោក ទើបឲ្យត្រីធំផង ខ្មៅផង ទៅ ដោយពាក្យថា សូមអ្នកនាំយកត្រីនេះទៅ កុកនោះពាំត្រីនោះ នាំទៅលែងក្នុងស្រះ បង្ហាញស្រះទាំងអស់ហើយ នាំត្រឡប់មកលែងក្នុងសម្នាក់របស់ត្រីទាំងនោះ ។ ទើបត្រីនោះពណ៌នាសម្បត្តិរបស់ស្រះដល់ត្រីទាំងនោះ ។ ត្រីទាំងនោះបានស្ដាប់ពាក្យរបស់ត្រីនោះ ជាអ្នកចង់ទៅ ទើបនាំគ្នាពោលថា សាធុ ចូរអ្នកពាំយើងទៅ ។

កុកពាំត្រីខ្មៅផង ធំផង ដំបូងនោះឯង ហើយនាំទៅកាន់ច្រាំងរបស់ស្រះ បង្ហាញស្រះទឹកឲ្យឃើញ រួចលាក់ទុកត្រង់ដើមថ្ងាន់ដែលកើតត្រង់មាត់ស្រះ ដាក់ត្រីនោះត្រង់ប្រគាប ហើយចឹកដោយចំពុះឲ្យស្លាប់ ហើយស៊ីសាច់ ចោលឆ្អឹងឲ្យធ្លាក់ចុះត្រង់គល់ឈើ ហើយត្រឡប់ទៅ ពោលថា ត្រីនោះ ខ្ញុំលែងទៅហើយ ចូរត្រីដទៃមក ហើយពាំយកម្តងមួយដោយឧបាយនោះ ស៊ីត្រីអស់ ត្រឡប់មកទៀត សូម្បីត្រីមួយក៏មិនឃើញ ។ ក្នុងស្រះនេះមានក្តាមមួយ កុកចង់ស៊ីសាច់ក្តាមនោះ ទើបពោលថា ក្តាមដ៏ចម្រើន ខ្ញុំនាំត្រីទាំងអស់នោះទៅលែងក្នុងស្រះធំ ដែលដេរដាសដោយផ្កាឈូក មក ខ្ញុំនឹងនាំអ្នកទៅ ។ ក្តាមសួរថា អ្នកកាលនាំខ្ញុំទៅ នាំទៅដូចម្តេច កុកពោលថា ខ្ញុំពាំនាំយកទៅ ។ ក្តាមពោលថា កាលអ្នកនាំទៅយ៉ាងនេះ នឹងធ្វើខ្ញុំឲ្យធ្លាក់ចុះមក ខ្ញុំមិនទៅជាមួយអ្នកទេ ។ កុកពោលថា កុំខ្លាចឡើយ ខ្ញុំនឹងពាំអ្នកឲ្យល្អ រួចទៅ ។ ក្តាមគិតថា ឈ្មោះថា ការពាំយកត្រីទៅលែងក្នុងស្រះ រមែងមិនមានដល់កុកនេះ បើលែងអញក្នុងស្រះនោះជាការល្អ បើមិនលែង អញនឹងកៀបកវាឲ្យអស់ជីវិត ។ គ្រានោះ ទើបក្តាមពោលនឹងកុកយ៉ាងនេះថា នែកុកសម្លាញ់ អ្នកមិនអាចពាំខ្ញុំទៅឲ្យល្អបាន បើខ្ញុំកៀបផង ទើបជាការល្អ បើខ្ញុំយកដង្កៀបកៀប-កអ្នកសោត ខ្ញុំនឹងធ្វើករបស់អ្នក ដែលខ្ញុំកៀបល្អហើយ ទើបទៅជាមួយអ្នក ។ កុកនោះគិតឯខាងបោកក្តាម មិនដឹងថា ក្តាមនេះបញ្ឆោតខ្លួន ទើបយល់ព្រមថា សាធុ ។ ក្តាមយកដង្កៀបទាំង ២ កៀប-កកុកនោះយ៉ាងណែន ដូចកៀបដោយអណ្តកៀបរបស់ជាងមាស ហើយពោលថា ចូរអ្នកទៅឥឡូវ

នេះ ។ កុកនោះនាំក្តាមទៅឲ្យឃើញស្រះហើយ បែរមុខទៅកាន់ដើមថ្ងាន់ ។ ក្តាមពោលថា អ៊ំ ស្រះនេះនៅខាងនោះ តែអ៊ំពាំខ្ញុំទៅខាងនេះ ។ កុកពោលថា អញជាអ៊ំជាទីស្រឡាញ់ តែឯងមិនមែនជាក្មួយរបស់អញទេ្បីយ ហើយពោលថា ឯងប្រហែលជាសម្គាល់ថា កុកនេះ ជាខ្ញុំបម្រើរបស់ឯង នាំអញត្រាច់ទៅ ចូរឯងមើលឆ្អឹងត្រីត្រង់គល់ថ្ងាន់នោះ សូម្បីឯង អញក៏នឹងស៊ី ដូចស៊ីត្រីទាំងអស់នោះ ។ ក្តាមពោលថា ត្រីទាំងនោះ លោកស៊ីបាន ព្រោះភាពដែលខ្លួនជាត្រីល្ងង់ តែខ្ញុំមិនឲ្យលោកស៊ី លោកនោះឯង នឹងដល់នូវសេចក្តីវិនាស ដ្បិតថា លោកមិនដឹងថា ត្រូវខ្ញុំបញ្ឆោត ព្រោះភាពជាសត្វល្ងង់ យើងទាំង ២ បើស្លាប់ ក៏ស្លាប់ជាមួយគ្នា ខ្ញុំនឹងកាត់ក្បាលរបស់លោក ឲ្យធ្លាក់ចុះលើផែនដី ពោលហើយ ទើបយកដង្កៀបដូចដង្កាប់កៀបកកុកនោះ ។ កុកហាមាត់ ហូរទឹកភ្នែក តាមភ្នែកទាំងសងខាង ត្រូវមរណភ័យគំរាម ទើបពោលថា បពិត្រលោក ខ្ញុំមិនស៊ីលោក សូមលោកឲ្យជីវិត ។ ក្តាមពោលថា បើដូច្នោះ ចូរអ្នកបន្ទាបខ្លួន ហើយដាក់ខ្ញុំក្នុងស្រះ កុកនោះវិលមកកាន់ស្រះនោះឯង ហើយដាក់ក្តាមលើភក់ ត្រង់មាត់ស្រះ ក្តាមកៀប-កកុកនោះដាច់ធ្លាក់ចូលទៅក្នុងទឹក ដូចកាត់ដើមឈូកដោយកន្ត្រៃ ដូច្នោះ ទេវតាដែលអាស្រ័យត្រង់ដើមថ្ងាន់ ឃើញនូវហេតុអស្ចារ្យនោះ កាលនឹងឲ្យសាធុការធ្វើព្រៃឲ្យខ្ទរខ្ទារ ទើបពោលគាថានេះ ដោយសំឡេងដ៏ពីរោះថា

បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត រមែងមិនដល់សេចក្តីសុខអស់កាលជានិច្ច ព្រោះបញ្ញាជាគ្រឿងបញ្ឆោតឡើយ បុគ្គលមានប្រាជ្ញា

ជាគ្រឿងបញ្ឆោត ( នោះ ) រមែងបាន ( នូវលទ្ធផលអាក្រក់ )

ដូចសត្វកុក ( បាននូវការដាច់ក ) អំពីក្តាម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាច្ចន្តំ និកតិប្បញ្ញោ និកត្យា សុខមេធតិ** សេចក្តីថា ការបោកបញ្ឆោត ហៅថា **និកតិ** បុគ្គលអ្នកមានបញ្ញា ឈ្មោះថា **និកតិ** គឺបុគ្គលមានបញ្ញាបោកបញ្ឆោត រមែងមិនដល់នូវសេចក្តីសុខដោយចំណែកមួយ គឺមិនអាចតាំងនៅក្នុងសេចក្តីសុខនោះឯង អស់កាលជានិច្ច ព្រោះការបញ្ឆោត គឺការបោកបញ្ឆោតនោះ តែរមែងដល់នូវការវិនាសដោយចំណែកមួយប៉ុណ្ណោះ ។ បទថា **អារាធេតិ** បានដល់ រមែងបានចំពោះ ។ បទថា **និកតិប្បញ្ញោ** សេចក្តីថា បុគ្គលអាក្រក់មានបញ្ញាបោកបញ្ឆោត គឺមានបញ្ញាដែលសិក្សានូវភាពជាបុគ្គលវៀចវេរ រមែងបានចំពោះ គឺរមែងជួបនូវផលនៃបាបដែលខ្លួនធ្វើ រមែងជួបផលបាបដូចម្តេច រមែងជួបនូវផលបាបដូចកុកដាច់កព្រោះក្តាម ដូច្នោះ អធិប្បាយថា បាបបុគ្គល រមែងជួប គឺរមែងបានចំពោះភ័យក្នុងបច្ចុប្បន្ន ឬក្នុងលោកខាងមុខ ព្រោះបាបដែលខ្លួនធ្វើ ដូចកុកដល់នូវការដាច់កព្រោះក្តាម ដូច្នោះ ។ មហាសត្វ កាលប្រកាសសេចក្តីនេះ ទើបសម្តែងធម៌ ញ៉ាំងព្រៃឲ្យខ្ទរខ្ទារ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចីវរវឌ្ឍកៈអ្នកក្រុង ត្រូវចីវរវឌ្ឍកៈស្រុកក្រៅនោះឯងបញ្ឆោតហើយ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនទោះក្នុងអតីតកាល ក៏ត្រូវបោកបញ្ឆោតហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា កុកក្នុងកាលនោះបានមកជាចីវរវឌ្ឍកៈក្នុងវត្តជេតពនក្នុងកាលឥឡូវនេះ ក្តាមក្នុងកាលនោះ បានមកជាចីវរវឌ្ឍកៈស្រុកក្រៅ ឯរុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាពកជាតក ចប់**

# សុត្តន្តបិដក

## ឆក្កជាតក

[ ៣៩ ] ( កុដុម្ពិកពោធិសត្វពោលថា ) យើងសម្គាល់ថា គំនរមាស និងកម្រងមាស មានក្នុងទីដែលខ្ញុំប្រុសឈ្មោះនន្ទុកៈ ជាកូនរបស់ខ្ញុំស្រី ឈ្មោះអាមា ឈរពោលនូវពាក្យអាក្រក់នោះ ។

**នន្ទុកជាតកទី ៩ ចប់**

# អដ្ឋកថា

## ឆន្នជាតក

[ ៣៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មញ្ញេ សោវណ្ណយោ រាសិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាអ្នកប្រដៅងាយ អត់ធន់ចំពោះពាក្យប្រៀនប្រដៅ ធ្វើឧបការៈដល់ព្រះថេរៈ ដោយឧស្សាហៈដ៏ច្រើន ។ សម័យមួយ ព្រះថេរៈទូលលាព្រះសាស្តា ចារិកទៅហើយ បានត្រឡប់មកកាន់ទក្ខិណាគិរីជនបទ ក្នុងពេលដែលព្រះថេរៈទៅក្នុងទក្ខិណាគិរីជនបទនោះ ភិក្ខុនោះ ជាអ្នកប្រកាន់ខ្លួន មិនធ្វើតាមពាក្យរបស់ព្រះថេរៈ កាលព្រះថេរៈពោលថា អាវុសោ អ្នកចូរធ្វើកម្មឈ្មោះនេះ ក៏បានជាចំណែកផ្ទុយចំពោះព្រះថេរៈៗ មិនដឹងអធ្យាស្រ័យរបស់ភិក្ខុនោះ ព្រះថេរៈត្រាច់ចារិកទៅក្នុងទក្ខិណាគិរីជនបទនោះ វិលត្រឡប់មកកាន់វត្តជេតពនទៀត ភិក្ខុនោះក៏ដូច្នោះឯងទៀត ចាប់តាំងអំពីព្រះថេរៈមកកាន់ជេតវនវិហារ ទើបព្រះថេរៈក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិកមួយរូបរបស់ខ្ញុំព្រះអង្គ ក្នុងទីមួយ ហាក់ដូចជាទាសៈដែលលោះមកដោយទ្រព្យ ១០០ តែក្នុងទីមួយ ជាអ្នកប្រកាន់ខ្លួន កាលខ្ញុំព្រះអង្គប្រាប់ថា ចូរធ្វើវត្តឈ្មោះនេះ បែរជាធ្វើជំទាស់ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្រ ភិក្ខុនេះមានប្រក្រតីយ៉ាងនេះ តែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ភិក្ខុនេះទៅកាន់ទីមួយ ហាក់ដូចជាទាសៈ ដែលលោះមកដោយទ្រព្យ ១០០ តែទៅកាន់ទីមួយទៀត បែរជាមានចំណែកផ្ទុយជា

សត្រូវ កាលព្រះថេរៈទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងត្រកូលកុដុម្ពិកៈមួយ កុដុម្ពិកៈដែលជាសម្លាញ់របស់ព្រះពោធិសត្វនោះ ខ្លួនឯងជាមនុស្សចាស់ តែភរិយាកុដុម្ពិកៈនោះជាស្រីក្មេង នាងអាស្រ័យកុដុម្ពិកៈនោះ ទើបបានបុត្រប្រុស កុដុម្ពិកៈនោះគិតថា ស្រីនេះ កាលអញស្លាប់ទៅហើយ ក៏នឹងបានបុរសណាម្នាក់នោះឯងជាប្តី ព្រោះនៅក្មេង និងធ្វើទ្រព្យរបស់អញឲ្យវិនាស មិនឲ្យដល់កូនរបស់អញ បើដូច្នោះ អញនឹងកប់ទ្រព្យនេះក្នុងផែនដី ទើបនាំទាសៈក្នុងផ្ទះឈ្មោះនន្ទៈទៅព្រៃ កប់ទ្រព្យនោះក្នុងទីមួយកន្លែង ហើយប្រាប់ដល់នាយនន្ទៈនោះទូន្មានថា នែនន្ទៈ ទ្រព្យនេះ អំណើះឥតពីអញទៅ អ្នកគប្បីប្រាប់ដល់កូនរបស់អញ កុំបរិច្ចាគទ្រព្យរបស់អញឡើយ ដូច្នេះហើយ បានស្លាប់ទៅ បុត្ររបស់កុដុម្ពិកៈនោះ ជាអ្នកចម្រើនវ័យដោយលំដាប់ ៗ លំដាប់នោះ មាតាពោលនឹងបុត្រនោះថា នែបា ឪពុករបស់អ្នកនាំនាយនន្ទៈ ដែលជាទាសៈទៅកប់ទ្រព្យ ចូរអ្នកឲ្យនាំទ្រព្យនោះមកជាសម្បត្តិ ។ ថ្ងៃមួយ បុត្រនោះពោលនឹងទាសៈឈ្មោះនន្ទៈថា អ៊ំ ទ្រព្យណាមួយ ដែលបិតារបស់ខ្ញុំកប់ទុកមានឬ ។ នន្ទទាសៈពោលថា មាន លោកម្ចាស់ បុត្រនោះ សួរថា កប់ក្នុងទីណា ។ នន្ទៈឆ្លើយថា ក្នុងព្រៃ ។ បុត្រនោះពោលថា បើដូច្នោះ ពួកយើងនាំគ្នាទៅ ហើយកាន់យកចប និងល្អី ទៅកាន់ទីកប់ទ្រព្យ ហើយពោលថា នែអ៊ំ ទ្រព្យ

មាននៅក្នុងទីណា ។ នន្ទះឡើងឈរខាងលើទ្រព្យ អាស្រ័យទ្រព្យ ធ្វើមានះឲ្យកើតឡើង ជេរកុមារថា វ៉ៃយ អាចេតកៈកូនទាសី ទ្រព្យក្នុងទីនេះរបស់អានឹងមានមកអំពីណា កុមារធ្វើជាមិនបានឮពាក្យគ្រោតគ្រាតរបស់គាត់ ពោលថា បើដូច្នោះ ពួកយើងនាំគ្នាត្រឡប់ចុះ ហើយនាំននូ្ទះនោះត្រឡប់ កន្លងទៅ ២-៣ ថ្ងៃ ក៏បានទៅទៀត ននូ្ទះក៏ជេរយ៉ាងនោះឯង កុមារមិនពោលពាក្យគ្រោតគ្រាតជាមួយគាត់ គិតថា ទាសៈនេះទៅដោយគិតថា នឹងប្រាប់ទ្រព្យចាប់តាំងអំពីនោះទៅ កាលទៅហើយ បែរជាជេរអញមិនដឹងហេតុក្នុងសេចក្តីនោះ កុដុម្ពិកៈដែលជាសម្លាញ់របស់បិតាអញមានហ្ន៎ អញនឹងសាកសួរកុដុម្ពិកៈហើយនឹងដឹងបាន ទើបទៅក្នុងសម្នាក់របស់ព្រះពោធិសត្វ ប្រាប់រឿងទាំងអស់នោះហើយ សួរថា បពិត្រលោកឪពុក ព្រោះហេតុអ្វី ព្រះពោធិសត្វពោលថា ននូ្ទះឈរជេរអ្នកក្នុងទីណា ទ្រព្យដែលជារបស់បិតាអ្នកនៅក្នុងទីនោះឯង ព្រោះដូច្នោះ ក្នុងកាលណាននូ្ទះជេរអ្នក ក្នុងកាលនោះ ចូរអ្នកអូសននូ្ទះនោះមកដោយពាក្យថា នៃទាសៈ ចូរអ្នកមកជេរ ហើយកាន់យកចបជីកទម្លាយទីនោះ នាំទ្រព្យដែលជារបស់ត្រកូលចេញមក ឲ្យទាសៈនោះនាំទ្រព្យនោះមក កាលពោលហើយ ទើបពោលគាថានេះថា

យើងសម្គាល់ថា គំនរមាស និងកម្រងមាស មានក្នុងទីដែលខ្ញុំប្រុស
ឈ្មោះននូ្ទកៈ ជាកូនរបស់ខ្ញុំស្រី ឈ្មោះអាមា ឈរពោលនូវពាក្យ
អាក្រក់នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មញ្ញេ** បានដល់ ខ្ញុំដឹងយ៉ាងនេះ ។ បទថា

**សោវណ្ណយោ** សេចក្តីថា ឈ្មោះថា សុវណ្ណ ព្រោះមានពណ៌ស្អាត សុវណ្ណទាំងនោះ គឺអ្វី គឺរតនៈទាំងឡាយ មានប្រាក់ កែវមណី មាស និងកែវប្រពាលជាដើម ។ ក្នុងឋានៈនេះ លោកបំណងយករតនៈទាំងអស់នេះថា **សុវណ្ណ** ។ គំនរនៃរតនៈទាំងនោះ ឈ្មោះថា **សោវណ្ណយរាសិ** ប្រែថា គំនរនៃរតនៈ មានពណ៌ស្អាត ។

បទថា **សោវណ្ណមាលា ច** សេចក្តីថា អញរមែងដឹងថា កម្រងមាសដែលជារបស់បិតាអ្នក ក៏មាននៅទីនេះដូចគ្នា ។ បទថា **ឆន្នកោ យត្ថ ទាសោ** សេចក្តីថា ទាសៈឈ្មោះនន្ទៈឈរក្នុងទីណា ។ បទថា **អាមជាតោ** សេចក្តីថា បុត្ររបស់ទាសី ពោល គឺនាងអាមទាសី ព្រោះចូលដល់ភាពជាទាសីដោយភាពជាខ្ញុំ ដោយការពោលយ៉ាងនេះថា **អាម អហំ វោ ទាសិ** ចាំះ ខ្ញុំជាទាសីរបស់អ្នក ។ បទថា **ឋិតោ ថុល្លានិ គជ្ជតិ** សេចក្តីថា ទាសៈឈ្មោះនន្ទៈឈរក្នុងទីណា ពោលពាក្យគ្រោតគ្រាត គឺពាក្យទ្រគោះ ទ្រព្យដែលជារបស់ត្រកូលនៃអ្នក មានក្នុងទីនោះឯង អញដឹងទ្រព្យនោះយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះពោធិសត្វប្រាប់ឧបាយជាគ្រឿងកាន់យកទ្រព្យដល់កុមារ ។ កុមារថ្វាយបង្គំព្រះពោធិសត្វ ហើយទៅផ្ទះ នាំនន្ទៈទៅកាន់ទីកប់ទ្រព្យ បដិបត្តិតាមដែលព្រះពោធិសត្វទូន្មានហើយ នាំយកទ្រព្យនោះមកជាសម្បត្តិ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យទាំងឡាយ មានទានជាដើម ក្នុងកាលអស់ជីវិត បានទៅតាមយថាកម្ម ។

*ព្រះសាស្តាត្រាស់ថា ក្នុងកាលមុន សទ្ធិវិហារិករបស់សារីបុត្រនេះ ជាអ្នកមានប្រក្រតីយ៉ាងនេះដូចគ្នា ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ទាសៈឈ្មោះនន្ទៈក្នុងកាលនោះ បានមកជាសទ្ធិវិហារិករបស់សារីបុត្រ ក្នុងកាលឥឡូវនេះ កូនរបស់កុដុម្ពិកៈ ក្នុងកាលនោះ បានមកជាសារីបុត្រ ឯកុដុម្ពិកៈដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ។៚*

**អដ្ឋកថានន្ទជាតក ចប់**

# សុត្តន្តបិដក

## ខទិរង្គារជាតក

[ ៤០ ] ( សេដ្ឋីពោធិសត្វពោលថា ) តាមពិត ខ្ញុំព្រះអង្គស៊ូមានជើងឡើងលើ មានក្បាលចុះក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូមព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ។

ខទិរង្គារជាតកទី ១០ ចប់

កុលាវកវគ្គទី ៤ ចប់

### ឧទ្ទាននៃកុលាវកវគ្គនោះ គឺ

និយាយអំពីមាតលី ( ក្នុងកុលាវកជាតក ) ១ ធីតា ( ក្នុងនច្ចជាតក ) ១ ពួកបក្សីដ៏ប្រសើរ ( ក្នុងសម្មោទមានជាតក ) ១ ត្រីឈ្មោលទៅដោយតម្រេក ( ក្នុងមច្ឆជាតត ) ១ មេបា ( ក្នុងវដ្តកជាតក ) ១ ដើមឈើដុះលើផែនដី ( ក្នុងសកុណជាតក ) ១ បុគ្គលចម្រើន ( ក្នុងតិត្តិរជាតក ) ១ ក្តាមឈ្លាសវៃក្នុងពកជាតក ១ នន្ទជាតក ១ ដុំបាយដ៏ប្រសើរ ក្នុងខទិរង្គារជាតក ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ខទិរង្គារជាតក

[ ៤០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធទានរបស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឆាមំ បតាមិ និរយំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា លោកអនាថបិណ្ឌិកសេដ្ឋី ប្រារព្ធចំពោះវិហារប៉ុណ្ណោះ ចំណាយនូវទ្រព្យ ៥៤ កោដិ ក្នុងព្រះពុទ្ធសាសនា មិនបានធ្វើសេចក្ដីសម្គាល់ក្នុងវត្ថុដទៃថា ជារតនៈក្រៅអំពីរតនៈទាំង ៣ ឲ្យកើតឡើយ ។ កាលព្រះសាស្ដាគង់នៅក្នុងជេតពនមហាវិហារ រមែងទៅកាន់ទីបម្រើធំ ៣ ដងរាល់ថ្ងៃ គឺពេលព្រឹកទៅម្ដង ទទួលទានអាហារព្រឹកហើយទៅម្ដង ពេលល្ងាចទៅម្ដង ទីបម្រើក្នុងរវាងដទៃ ក៏មានដូចគ្នា ។ កាលនឹងទៅ មិនធ្លាប់មានដៃទៅទទេ ដោយគិតថា សាមណេរ ឬភិក្ខុកំលោះទាំងឡាយ គប្បីសម្លឹងមើលដៃរបស់អញ ដោយគិតថា លោកសេដ្ឋីកាន់អ្វីមកហ្ន៎ កាលទៅពេលព្រឹក បានឲ្យមនុស្សកាន់យាគូទៅ ទទួលទានអាហារព្រឹកហើយ កាលនឹងទៅ ឲ្យមនុស្សកាន់យកសប្បិ នវនីត ទឹកឃ្មុំ និងទឹកអំពៅជាដើមទៅ កាលទៅក្នុងពេលល្ងាច កាន់យកគ្រឿងក្រអូប ផ្កា និងសំពត់ទៅ កាលលោកសេដ្ឋីនោះបរិច្ចាគយ៉ាងនេះរាល់ៗ ថ្ងៃ ប្រមាណក្នុងការបរិច្ចាគ រមែងមិនមាន ។ ឯអ្នកអាស្រ័យការលក់ដូរចិញ្ចឹមជីវិតជាច្រើន ធ្វើបញ្ជីទុកក្នុងដៃរបស់លោកសេដ្ឋី ខ្ចីទ្រព្យទៅ ១៨ កោដិ ។ លោកសេដ្ឋីឲ្យទារយកទ្រព្យរបស់បុគ្គលទាំងនោះមក ម្យ៉ាងទៀត ទ្រព្យ ១៨ កោដិដទៃ ជាទ្រព្យប្រចាំត្រកូលរបស់សេដ្ឋីនោះ

កប់ទុកត្រង់ប្រាំងស្ទឹង កាលប្រាំងត្រូវទឹកស្ទឹងអចិរវតីច្រោះទម្លាយហូរទៅកាន់មហាសមុទ្រ ។ ក្អមលោហៈដែលបិទ និងប្រថាប់ត្រានោះ ក៏រមៀលទៅក្នុងសមុទ្រ ក្នុងផ្ទះរបស់សេដ្ឋីនោះ នៅមាននិច្ចភត្តជាប្រចាំសម្រាប់ភិក្ខុ ៥០០ រូប ពិតហើយ ផ្ទះរបស់សេដ្ឋី ដូចគ្នានឹងស្រះបោក្ខរណីដែលជីកក្នុងផ្លូវធំមានមុំ ៤ សម្រាប់ភិក្ខុសង្ឃ តាំងនៅក្នុងឋានៈជាបិតាមាតារបស់ភិក្ខុទាំងពួង ដោយហេតុនោះ ព្រះសម្មាសម្ពុទ្ធក៏យាងទៅកាន់ផ្ទះរបស់សេដ្ឋីនោះ ។ ឯព្រះមហាថេរៈ ៨០ អង្គ ក៏ទៅដូចគ្នា ឯភិក្ខុទាំងឡាយដ៏សេសទៅមកៗ ប្រមាណមិនបាន ។

ផ្ទះនោះមាន ៧ ជាន់ ប្រដាប់ដោយខ្លោងទ្វារ ៧ មានទេវតាជាមិច្ឆាទិដ្ឋិមួយអង្គនៅអាស្រ័យត្រង់ខ្លោងទ្វារទី ៤ នៃផ្ទះនោះ ។ ទេវតានោះ កាលព្រះសម្មាសម្ពុទ្ធចូលទៅកាន់ផ្ទះ និងយាងចេញ មិនអាចនៅក្នុងវិមានរបស់ខ្លួនបានពទារកចុះមកឈរលើផែនដី កាលព្រះមហាថេរៈទាំង ៨០ អង្គ ចូលទៅ និងចេញមក ក៏ធ្វើយ៉ាងនោះ ។ ទេវតានោះគិតថា កាលព្រះសមណគោតម និងពួកសាវ័ករបស់ព្រះសមណគោតមនោះ នៅចេញចូលផ្ទះនេះឈ្មោះថា សេចក្តីសុខរបស់អញមិនមាន អញមិនអាចចុះមកឈរលើផែនដីអស់កាលជានិច្ចបាន អញនឹងធ្វើដោយប្រការដែលសមណៈទាំងនេះ ចូលមកកាន់ផ្ទះនេះមិនបាន ទើបគួរ ។ ថ្ងៃមួយ ទេវតានោះ ទៅកាន់សម្នាក់របស់បុគ្គលដែលជាមហាកម្មន្តិកៈ ( អ្នកជំនួយការ ) ដែលកំពុងចូលដេក ហើយបានឈរផ្សាយឱភាស កាលមហាកម្មន្តិកៈពោលថា អ្នកណានៅទីនេះ ទើប

ពោលថា ខ្ញុំជាទេវតាដែលកើតត្រង់ខ្លោងទ្វារទី ៤ មហាកម្មន្តិកៈពោលថា លោកមកព្រោះហេតុអ្វី ។ ទេវតាពោលថា អ្នកមិនឃើញការធ្វើរបស់លោកសេដ្ឋីទេឬ លោកសេដ្ឋីមិនសម្លឹងមើលកាលដែលនឹងមានខាងក្រោយរបស់ខ្លួន នាំទ្រព្យចេញ បំពេញចំពោះព្រះសមណគោតមប៉ុណ្ណោះឲ្យពេញបរិបូណ៌ មិនប្រកបការជួញដូរ មិនផ្ដើមធ្វើការងារ ចូរអ្នកឲ្យឱវាទដល់សេដ្ឋី ចូរអ្នកធ្វើដោយប្រការដែលលោកសេដ្ឋីធ្វើការងាររបស់ខ្លួន និងព្រះសមណគោតម ព្រមទាំងសាវក កុំឲ្យចូលមកកាន់ផ្ទះនេះ ។ គ្រានោះ មហាកម្មន្តិកៈនោះបានពោលនឹងទេវតានោះថា នែទេវតាពាល លោកសេដ្ឋីកាលលះទ្រព្យ ក៏លះក្នុងព្រះពុទ្ធសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ លោកសេដ្ឋីនោះ បើនឹងចាប់ខ្ញុំត្រង់ផ្នួងសក់ យកទៅលក់ ក៏មិនពោលពាក្យណាឡើយ ចូរអ្នកទៅចុះ ។ ថ្ងៃមួយ ទេវតានោះចូលទៅរកបុត្រច្បងរបស់លោកសេដ្ឋី ហើយពោលប្រៀនប្រដៅយ៉ាងនោះ ឯបុត្រសេដ្ឋីក៏គំរាមទេវតានោះ ដោយន័យមុននោះឯង តែទេវតានោះមិនអាចពោលនឹងលោកសេដ្ឋីបានឡើយ ចំណែកលោកសេដ្ឋីបានឲ្យទានមិនដាច់ មិនធ្វើជំនួញ កាលទ្រព្យសម្បត្តិមានតិច ទ្រព្យក៏ដល់នូវការអស់ទៅ ។ កាលលោកសេដ្ឋីនោះធ្លាក់ខ្លួនក្រដោយលំដាប់ សំពត់សាដកទីដេក និងភាជនៈ ដែលជាគ្រឿងបរិភោគប្រើប្រាស់ មិនដូចអំពីមុន ។ តែទោះជាយ៉ាងនេះ លោកសេដ្ឋីក៏នៅតែឲ្យទានដល់ភិក្ខុសង្ឃ តែមិនអាចធ្វើឲ្យប្រណីត ហើយឲ្យ ។ ថ្ងៃមួយ ព្រះសាស្ដាត្រាស់សួរសេដ្ឋីនោះ ដែលថ្វាយបង្គំ ហើយអង្គុយថា ម្នាលគហបតី ទានក្នុងត្រកូល អ្នកនៅតែឲ្យឬ ។ សេដ្ឋី

នោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នៅតែឲ្យ តែទាននោះសៅហ្មង ជាបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីនោះថា គហបតី អ្នកកុំធ្វើចិត្តឲ្យលំបាកថា អញឲ្យទានសៅហ្មងឡើយ ព្រោះថា កាលចិត្តប្រណីត ទានដែលថ្វាយដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកទាំងឡាយ រមែងមិនឈ្មោះថា សៅហ្មងឡើយ ។ ព្រោះហេតុអ្វី ព្រោះទាននោះមានផលច្រើន ។ ក្នុងសេចក្តីនេះ គួរជ្រាបយ៉ាងនេះថា កាលធ្វើចិត្តឲ្យប្រណីត ទាន ឈ្មោះថា សៅហ្មងមិនមានឡើយ សមដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងខុទ្ទកនិកាយ វិមានវត្ថុ ) ថា

កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគត ជាសម្ពុទ្ធ ឬសាវករបស់
ព្រះតថាគតហើយ ទក្ខិណាទាន ឈ្មោះថា មានផលតិច មិនមែន
ឡើយ ដូច្នេះ ។

នឹងដូចព្រះតម្រាស់មួយកន្លែងទៀត ( កុម្មាសបិណ្ឌជាតក ) ថា

បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមាន
ពោធិញ្ញាណមិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ
អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលសោះកក្រោះ ឥតរសប្រៃ
ដូច្នេះ ។

ម្យ៉ាងទៀត ព្រះសាស្តាត្រាស់ថា ម្នាលគហបតី អ្នកកាលឲ្យទានសៅហ្មង គង់ឲ្យដល់ព្រះអរិយបុគ្គល ៨ ពួក តថាគតកាលនៅជាវេលាមព្រាហ្មណ៍ ឲ្យរតនៈទាំង ៧ ធ្វើជម្ពូទ្វីបទាំងមូល មិនចាំបាច់ឲ្យក្អួរស្រែ ញុំាង

មហាទានឲ្យប្រព្រឹត្តទៅក្នុងស្ទឹងធំ ៥ ខ្សែ ឲ្យពេញជាអន្លង់តែមួយ មិនបាន បុគ្គលណាម្នាក់ដែលដល់សរណៈ ៣ ឬអ្នករក្សាសីល ៥ បុគ្គលដែលគួរដល់ ទក្ខិណារកបានលំបាកយ៉ាងនេះ ព្រោះហេតុនោះ អ្នកកុំធ្វើចិត្តឲ្យលំបាកថា ទានរបស់អញសៅហ្មង កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់វេលាមសូត្រ ។

គ្រានោះ ទេវតានោះមិនអាចពោលនឹងសេដ្ឋី ក្នុងកាលដែលលោកសេដ្ឋី នៅភាពជាធំ សម្គាល់ថា ឥឡូវនេះ សេដ្ឋីនោះនឹងកាន់យកពាក្យរបស់អញ ព្រោះជាបុគ្គលធ្លាក់ខ្លួនក្រ ក្នុងពេលកណ្ដាលអធ្រាត្រ ទើបចូលទៅកាន់បន្ទប់ ដែលជាសិរី បានផ្សាយពន្លឺ ឈរនៅក្នុងអាកាស សេដ្ឋីឃើញដូច្នោះ ទើប ពោលថា នុ៎ះជានរណា ។ ទេវតានោះពោលថា លោកសេដ្ឋី ខ្ញុំជាទេវតាស្ថិត នៅត្រង់ខ្លោងទ្វារទី ៤ សេដ្ឋីពោលថា អ្នកមកដើម្បីអ្វី ទេវតាពោលថា ខ្ញុំ បំណងនឹងទូន្មានលោក ទើបមក សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកពោលចុះ ។ ទេវតាពោលថា មហាសេដ្ឋី លោកមិនគិតដល់កាលក្រោយ មិនឃើញដល់ បុត្រធីតា បាចទ្រព្យជាច្រើនក្នុងសាសនារបស់ព្រះសមណគោតម លោក កើតជាជនក្រីក្រ ព្រោះអាស្រ័យព្រះសមណគោតម ដោយលះបង់ទ្រព្យហួស ព្រំដែន ឬដោយមិនធ្វើការលក់ដូរ និងការងារ អ្នកទោះបីជាយ៉ាងនេះ ក៏មិន បោះបង់ព្រះសមណគោតម សូម្បីរាល់ថ្ងៃនេះ សមណៈទាំងនោះ ក៏ចូលទៅ កាន់ផ្ទះនោះឯង ទ្រព្យដែលពួកសមណៈទាំងនោះនាំចេញទៅហើយ បុគ្គល ណាម្នាក់ មិនអាចនាំត្រឡប់មកបាន ដោយការកាន់យកឡើយ តាំងអំពីនេះ ទៅ ខ្លួនអ្នកកុំទៅកាន់សម្នាក់របស់ព្រះគោតម កុំឲ្យសាវ័កទាំងឡាយរបស់ព្រះ

គោតមនោះចូលមកកាន់ផ្ទះនេះ លោកសូមឲ្យព្រះសមណគោតមនោះត្រឡប់ទៅហើយ កុំបីក្រឡេកមើល ចូរធ្វើនូវការទានបំណុល និងការលក់ដូររបស់ខ្លួនប្រមូលទ្រព្យសម្បត្តិ ។ សេដ្ឋីពោលនឹងទេវតានោះយ៉ាងនេះថា នេះជាឱវាទដែលអ្នកឲ្យខ្ញុំឬ ។ ទេវតាពោលថា អើ នេះជាឱវាទ លោកសេដ្ឋីពោលថាខ្ញុំដែលព្រះទសពលធ្វើឲ្យជាបុគ្គល ដែលពួកទេវតាដូចអ្នករាប់រយក្តី រាប់ពាន់ក្តី រាប់សែនក្តី ឲ្យញាប់ញ័រមិនបាន សទ្ធារបស់ខ្ញុំមិនញាប់ញ័រ តាំងមាំល្អហើយ ដូចស្តេចភ្នំសិនេរុ ខ្ញុំលះទ្រព្យក្នុងរតនៈសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ លោកពោលពាក្យមិនគួរ លោកមិនមានអាចារ ជាអ្នកទ្រុស្តសីល ជាកាឡកិណីបែបនេះ ឲ្យនូវការប្រហារព្រះពុទ្ធសាសនា ខ្ញុំមិនមានកិច្ច គឺការនៅរួមក្នុងផ្ទះជាមួយគ្នានឹងបុគ្គលដូចអ្នកទេ ចូរប្រញាប់ចេញពីផ្ទះរបស់យើង ទៅកាន់ទីដទៃចុះ ។

ទេវតានោះ បានស្តាប់ពាក្យរបស់ព្រះអរិយសាវក ដែលជាសោតាបន្នមិនអាចតាំងនៅបាន ទើបទៅកាន់លំនៅរបស់ខ្លួន ហើយយកដៃចាប់ទារកចេញទៅ កាលចេញទៅហើយ មិនបានលំនៅ ក្នុងទីដទៃ គិតថា នឹងឲ្យសេដ្ឋីអត់ទោស ហើយនៅត្រង់ខ្លោងទ្វារនោះឯង ដូច្នេះហើយ ទើបទៅកាន់សម្នាក់របស់ទេវបុត្រ ដែលរក្សាព្រះនគរ ថ្វាយបង្គំទេវបុត្រនោះហើយ ឈរទេវបុត្ររក្សាព្រះនគរពោលថា នាងមកព្រោះមានការអ្វី ទើបពោលថា ខ្ញុំមិនបានពិចារណា និយាយនឹងលោកអនាថបិណ្ឌិកសេដ្ឋីៗ នោះ ក្រោធនឹងខ្ញុំបណ្តេញខ្ញុំចេញពីទីលំនៅ សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់លោកសេដ្ឋី

ឲ្យលោកអត់ទោសឲ្យ ហើយឲ្យនូវលំនៅដល់ខ្ញុំ ។ ទេវបុត្រដែលរក្សាព្រះនគរសួរថា នាងនិយាយជាមួយលោកសេដ្ឋីដូចម្ដេច ទេវតានោះពោលថា ខ្ញុំពោលនឹងលោកសេដ្ឋីយ៉ាងនេះថា លោកសេដ្ឋី តាំងអំពីនេះទៅ លោកកុំឧបដ្ឋាកព្រះពុទ្ធ និងព្រះសង្ឃ លោកកុំឲ្យព្រះសមណគោតមចូលទៅក្នុងផ្ទះ ។ ទេវបុត្រអ្នករក្សាព្រះនគរពោលថា នាងពោលពាក្យដែលមិនសមគួរ នាងឲ្យនូវការប្រហារក្នុងព្រះសាសនា ខ្ញុំមិនអាចនាំនាងទៅកាន់សម្នាក់របស់សេដ្ឋីបានឡើយ ។ ទេវតានោះ មិនបាននូវការជួយស្រោចស្រង់អំពីសម្នាក់របស់ទេវបុត្រនោះ ទើបទៅកាន់សម្នាក់របស់មហារាជទាំង ៤ សូម្បីមហារាជទាំង ៤ ក៏បដិសេធយ៉ាងនោះ ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលរឿងនោះ ហើយអង្វរយ៉ាងនេះថា បពិត្រទេវរាជ ខ្ញុំមិនមានលំនៅ ដឹកដៃទារក ជាបុគ្គលអនាថា ត្រាច់ទៅ សូមទ្រង់ធ្វើសេដ្ឋីឲ្យផ្ដល់នូវលំនៅដល់ខ្ញុំ ដោយសិរីរបស់ទ្រង់ ។ សក្កៈនោះ ក៏ត្រាស់នឹងទេវតានោះថា នាងធ្វើកម្មមិនសមគួរ នាងឲ្យនូវការប្រហារក្នុងសាសនារបស់ព្រះជិនស្រី យើងមិនអាចពោលនឹងលោកសេដ្ឋី ព្រោះអាស្រ័យនាង តែខ្ញុំប្រាប់ឧបាយឲ្យលោកសេដ្ឋីនោះ អត់ទោសដល់នាងម្យ៉ាង ។ ទេវតានោះក្រាបទូលថា សាធុ សូមទ្រង់ប្រាប់ឧបាយមកចុះ ។ សក្កទេវរាជត្រាស់ថា មនុស្សទាំងឡាយធ្វើបញ្ជីទុកក្នុងដៃរបស់លោកសេដ្ឋី កាន់យកទ្រព្យ ១៨ កោដិ នាងចូរកាឡាខ្លួនជាមនុស្ស អ្នកកាន់បញ្ជីរបស់លោកសេដ្ឋីនោះ កុំឲ្យបុគ្គលណាម្នាក់ស្គាល់ កាន់យកបញ្ជីទាំងនោះ មានពួកយក្ខកំលោះ ២-៣ រូបចោមរោម ដៃមួយកាន់បញ្ជី ដៃមួយកាន់ប៉ាកកា

ទៅផ្ទះរបស់មនុស្សទាំងនោះ ឈរកណ្តាលផ្ទះ ធ្វើមនុស្សទាំងនោះឲ្យខ្លាច ដោយអានុភាពយក្ខរបស់ខ្លួន ហើយពោលថា ចូរពួកអ្នកមើលបញ្ជីទ្រព្យ ដែលខ្ចីសេដ្ឋីរបស់ពួកយើង មិនពោលពាក្យណាមួយនឹងពួកអ្នក ក្នុងកាលដែលខ្លួនជាធំ ឥឡូវនេះ សេដ្ឋីធ្លាក់ខ្លួនក្រីក្រ ចូរពួកអ្នកឲ្យកហាបណៈដែលពួកអ្នកជំពាក់ហើយ រួចសម្តែងអានុភាពនៃយក្ខរបស់ខ្លួន ហើយទារប្រាក់ ១៨ កោដិ ធ្វើឃ្លាំងទទេរបស់សេដ្ឋីឲ្យពេញ ទ្រព្យដែលកប់ត្រង់ច្រាំងស្ទឹងអចិរវតីកាលច្រាំងបាក់ ទើបទឹកនាំទៅកាន់មហាសមុទ្រមាន ចូរនាំទ្រព្យនោះមក ដោយអានុភាពរបស់ខ្លួន ហើយធ្វើឃ្លាំងឲ្យពេញ ទ្រព្យមួយកន្លែងទៀត ១៨ កោដិ មិនមានម្ចាស់ក្នុងទីឈ្មោះនោះ ចូរនាំយកទ្រព្យនោះមក ធ្វើឃ្លាំងទទេឲ្យពេញ ចូរនាងធ្វើឃ្លាំងទទេឲ្យពេញដោយទ្រព្យ ៥៤ កោដិនេះឲ្យជាទណ្ឌកម្ម ហើយឲ្យមហាសេដ្ឋីអត់ទោស ។

ទេវតានោះ ទទួលពាក្យរបស់សក្កៈថា សាធុ ព្រះអង្គ ហើយនាំទ្រព្យទាំងអស់មក ដោយន័យដូចពោលហើយនោះឯង ក្នុងកណ្តាលយប់ ទើបចូលទៅកាន់បន្ទប់ប្រកបដោយសិរីរបស់សេដ្ឋី បញ្ចេញពន្លឺឈរក្នុងអាកាស លុះសេដ្ឋីពោលថា នុ៎ះជានរណា ទើបពោលថា មហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យនៅត្រង់ខ្លោងទ្វារទី ៤ របស់លោក ខ្ញុំជាបុគ្គលវង្វេង ព្រោះមោហៈធំ មិនស្គាល់គុណព្រះពុទ្ធទាំងឡាយ បានពោលពាក្យណាមួយជាមួយនឹងលោកក្នុងកាលមុនមាន ចូរលោកអត់ទោសនោះដល់ខ្ញុំ ខ្ញុំនាំទ្រព្យ ៥៤ កោដិ តាមព្រះតម្រាស់របស់សក្កទេវរាជ គឺទ្រព្យ ១៨ កោដិដោយការទារបំណុល ទ្រព្យ

១៨ កោដិ ដែលហូរទៅកាន់មហាសមុទ្ទ និងទ្រព្យ ១៨ កោដិដែលមិនមានម្ចាស់ក្នុងទីនោះៗ ធ្វើទណ្ឌកម្មដោយធ្វើឃ្លាំងទទេឲ្យពេញ ទ្រព្យដែលដល់នូវការអស់ទៅ ព្រោះប្រារព្ធការសាងព្រះវិហារ ខ្ញុំបានប្រមូលមកទាំងអស់ ខ្ញុំកាលមិនបានលំនៅ រមែងលំបាក បពិត្រលោកសេដ្ឋី លោកកុំដាក់ចិត្តនឹងពាក្យដែលខ្ញុំពោលព្រោះការមិនដឹង សូមអត់ទោសផងចុះ ។

អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ពាក្យរបស់ទេវតានោះហើយ គិតថា ទេវតានេះពោលថា ខ្ញុំបានធ្វើទណ្ឌកម្មហើយ នឹងប្តេជ្ញាព្រមទទួលទោសរបស់ខ្លួន ព្រះសាស្តាទ្រង់ណែនាំទេវតានេះហើយ ឲ្យស្គាល់គុណរបស់ខ្លួន អញនឹងបង្ហាញទេវតានេះដល់ព្រះសម្មាសម្ពុទ្ធ លំដាប់នោះ ទើបមហាសេដ្ឋីពោលនឹងទេវតានោះថា នែសម្លាញ់ សូម្បីអ្នកឲ្យខ្ញុំអត់ទោស ចូរឲ្យអត់ទោសក្នុងសម្នាក់ព្រះសាស្តា ។ ទេវតានោះពោលថា សាធុ ខ្ញុំនឹងធ្វើយ៉ាងនោះ ចូរលោកនាំខ្ញុំទៅកាន់សម្នាក់របស់ព្រះសាស្តាចុះ ។ មហាសេដ្ឋីនោះពោលថា សាធុ លុះរាត្រីអស់ហើយ ទើបនាំទេវតានោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាអំពីព្រលឹម ហើយក្រាបទូលកម្ម ដែលទេវតានោះធ្វើទាំងអស់ដល់ព្រះតថាគត ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់មហាសេដ្ឋីនោះហើយ ទើបត្រាស់ថា ម្នាលគហបតី បុគ្គលលាមកក្នុងលោកនេះ រមែងឃើញកម្មដែលចម្រើន ដរាបដែលបាបមិនទាន់ឲ្យផល កាលណាបាបឲ្យផលដល់បុគ្គលលាមកនោះ កាលនោះ បុគ្គលលាមកនោះ រមែងឃើញតែបាបប៉ុណ្ណោះថាជាបាប ឯបុគ្គលដែលចម្រើន រមែងឃើញកម្មដែលចម្រើនទាំងឡាយថាអាក្រក់ ដរាបណាកម្ម

ចម្រើនមិនទាន់ឲ្យផល ក្នុងកាលណា កម្មចម្រើនឲ្យផលដល់បុគ្គលចម្រើន នោះ ក្នុងកាលនោះ បុគ្គលចម្រើននោះ រមែងឃើញតែកម្មដែលចម្រើន ប៉ុណ្ណោះថាជាកម្មដែលចម្រើនហើយ ហើយបានត្រាស់ ២ គាថា ក្នុងធម្មបទ ដូច្នេះថា

បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្តី
ចម្រើនត្រឹមនោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើប
ឃើញបាប ក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាប
ត្រឹមនោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញ
ល្អ ក្នុងកាលនោះ ដូច្នេះ ។

ក្នុងកាលចប់គាថាទាំងនេះ ទេវតានោះ តាំងនៅហើយក្នុងសោតាបត្តិផល ទេវតានោះក្រាបចុះត្រង់ព្រះបាទទាំង ២ របស់ព្រះសាស្តា ដែលរំលេចដោយចក្រឲ្យព្រះសាស្តាអត់ទោសថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ដែលរាគៈជ្រលក់ហើយ ដែលទោសៈប្រទូស្តហើយ វង្វេងហើយដោយមោហៈ ងងឹតព្រោះអវិជ្ជា មិនដឹងគុណទាំងឡាយរបស់ទ្រង់ បានពោលពាក្យដ៏លាមក សូមទ្រង់អត់ទោសនូវពាក្យនោះដល់ខ្ញុំព្រះអង្គ ហើយញ៉ាំងមហាសេដ្ឋីឲ្យអត់ទោស ។ សម័យនោះ អនាថបិណ្ឌិកសេដ្ឋីពោលគុណរបស់ខ្លួន ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ទេវតានេះសូម្បីឃាត់ថា ចូរកុំធ្វើការឧបដ្ឋាកព្រះពុទ្ធជាដើម ក៏មិនអាចហាមខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គត្រូវទេវតានេះ

ហាមថា មិនគួរឲ្យទាន ក៏បានឲ្យនោះឯង បពិត្រព្រះអង្គដ៏ចម្រើន នេះគុណរបស់ខ្ញុំព្រះអង្គមិនមែនឬ ។ ព្រះសាស្ដាត្រាស់ថា ម្នាលគហបតី អ្នកជាព្រះអរិយសាវកបានសោតាបន្ន មានសទ្ធាមិនញាប់ញ័រ មានទស្សនៈបរិសុទ្ធ ការដែលអ្នកត្រូវទេវតាដែលមានសក្តិតូចនេះឃាត់ ក៏ឃាត់មិនបាន មិនជាអស្ចារ្យទេ បណ្ឌិតទាំងឡាយក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង តាំងនៅក្នុងញាណដែលមិនទាន់ចាស់ក្លា ត្រូវមារដែលជាធំក្នុងកាមាវចរកព ឈរនៅក្នុងអាកាសសម្តែងរណ្តៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ដោយពោលថា បើអ្នកនៅតែឲ្យទានសោត អ្នកនឹងឆេះក្នុងនរកនេះ ហើយឃាត់ថា អ្នកកុំឲ្យទាន ក៏បានឈរកណ្តាលផ្កាឈូកឲ្យទាន នេះគួរអស្ចារ្យ កាលអនាថបិណ្ឌិកសេដ្ឋីទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ក្នុងនគរពារាណសី ដែលញាតិទាំងឡាយឲ្យចម្រើនព្រមដោយគ្រឿងឧបករណ៍ទាំងពួង មានប្រការផ្សេងៗ ដូចទេពកុមារ ដល់នូវភាពដឹងក្តីដោយលំដាប់ ក្នុងកាលមានអាយុ ១៦ ឆ្នាំប៉ុណ្ណោះ ក៏ដល់នូវការសម្រេចក្នុងសិប្បៈទាំងពួង កាលបិតាអនិច្ចកម្មទៅ ព្រះពោធិសត្វនោះតាំងនៅក្នុងតំណែងសេដ្ឋី ឲ្យសាងរោងទាន ៦ កន្លែង គឺត្រង់ទ្វារក្រុង ៤ កណ្តាលព្រះនគរ ១ ត្រង់ទ្វារនិវេសន៍របស់ខ្លួន ១ រួចឲ្យមហាទាន រក្សាសីល រក្សាឧបោសថកម្ម ។ ថ្ងៃមួយ ក្នុងវេលាអាហារព្រឹក កាលអ្នកបម្រើនាំយកភោជនដែលជាទីគាប់ចិត្ត មានរសដ៏ប្រសើរផ្សេងៗ ចូល

ទៅឲ្យព្រះពោធិសត្វ ។ ព្រះបច្ចេកពុទ្ធមួយអង្គ កាលកន្លងទៅ ៧ ថ្ងៃ បាន ចេញអំពីនិរោធសមាបត្តិ កំណត់ពេលភិក្ខាចារហើយ គិតថា ថ្ងៃនេះ អាត្មា អញនឹងទៅកាន់ទ្វារផ្ទះរបស់ពារាណសីសេដ្ឋី ទើបគួរ ដូច្នេះហើយ ទំពាឈើ ស្ទន់ឈ្មោះនាគលតា លុបមុខត្រង់អនោតត្តស្រះ ឈរលើផ្ទាំងមនោសិលា ស្លៀកស្បង់ ចងវត្ថពន្ធចង្កេះ ឃុំចីវរ កាន់បាត្រដី ដែលសម្រេចដោយឫទ្ធិ មកតាមអាកាស ។ លុះអ្នកបម្រើនាំកត្តចូលទៅឲ្យព្រះពោធិសត្វ ក៏បានឈរ ត្រង់ទ្វារផ្ទះ ព្រះពោធិសត្វឃើញដូច្នោះ ក៏ក្រោកចាកអាសនៈ សម្តែងអាការ ឱនលំទោន ហើយសម្លឹងមើលបុរសដែលធ្វើការងារ កាលបុរសធ្វើការងារ ពោលថា ខ្ញុំនឹងធ្វើអ្វី ទើបពោលថា ចូរនាំបាត្រលោកម្ចាស់មក ។

រំពេចនោះ មារមានចិត្តបាប ញាប់ញ័រ ក្រោកឡើងហើយ គិតថា ព្រះ បច្ចេកពុទ្ធនេះ មិនបានអាហារមក ៧ ថ្ងៃហើយ រាប់អំពីថ្ងៃនេះ ថ្ងៃនេះ បើ មិនបាននឹងវិនាស អញនឹងធ្វើព្រះបច្ចេកពុទ្ធនេះឲ្យវិនាស នឹងធ្វើអន្តរាយដល់ ទានរបស់សេដ្ឋី ដូច្នេះហើយ ទើបមកក្នុងខណៈនោះឯង ហើយនិម្មិតរណ្តៅ រងើកភ្លើងជម្រៅ ៨០ ហត្ថ ត្រង់ចន្លោះ ។ រណ្តៅរងើកភ្លើងនោះ ពេញ ដោយរងើកភ្លើងដើមគគីរ ភ្លើងឆេះមានពន្លឺប្រាលឆ្អៅ ប្រាកដដូចអវិចីមហា នរក មារកាលនិម្មិតរណ្តៅរងើកភ្លើងនោះហើយ ក៏ឈរក្នុងអាកាស ។ បុរស ដែលមកដើម្បីទទួលបាត្រឃើញដូច្នោះ ដល់នូវការខ្លាចក្រៃលែង ទើបត្រឡប់ ទៅ ។ ព្រះពោធិសត្វសួរថា នែបា អ្នកនាំបាត្រត្រឡប់មកហើយឬ បុរស នោះពោលថា បពិត្រលោកម្ចាស់ រណ្តៅរងើកភ្លើងធំនេះ មានពន្លឺប្រាលឆ្អៅ

នៅត្រង់ចន្លោះ កាលបើដូច្នោះ មនុស្សដទៃៗ ទៅក្តី មកក្តី ដល់នូវការខ្ទាចប្រញាប់គេចទៅដោយរហ័ស ។

ព្រះពោធិសត្វគិតថា ថ្ងៃនេះ វសវត្តីមារបំណងនឹងធ្វើអន្តរាយដល់ទានរបស់អញ នឹងជាអ្នកប្រកបឡើង តែវសវត្តីមារនោះមិនដឹងថា អញដែលបុគ្គលដូចមារ ១ រយ ១ ពាន់ ១ សែនធ្វើឲ្យញាប់ញ័រមិនបាន ថ្ងៃនេះ អញនឹងដឹងថា អញ និងមារ មួយណាមានកម្លាំងជាង មានអានុភាពជាង លុះគិតហើយ ទើបកាន់យកថាសភត្តដែលគេត្រៀមនោះ ចេញទៅអំពីផ្ទះ ឈរត្រង់មាត់រណ្តៅរងើកភ្លើង សម្លឹងមើលអាកាស ឃើញមារ ទើបពោលថា អ្នកជានរណា មារពោលថា យើងជាមារ ។ ព្រះពោធិសត្វសួរថា រណ្តៅរងើកភ្លើងនេះ អ្នកនិម្មិតឬ ។ មារពោលថា អើ យើងនិម្មិត ។ ព្រះពោធិសត្វសួរថា និម្មិតដើម្បីអ្វី ។ មារពោលថា ដើម្បីធ្វើអន្តរាយដល់ទានរបស់អ្នក និងដើម្បីឲ្យជីវិតរបស់ព្រះបច្ចេកពុទ្ធវិនាស ។ ព្រះពោធិសត្វពោលថា ខ្ញុំនឹងមិនឲ្យលោកធ្វើអន្តរាយដល់ទានរបស់ខ្ញុំ និងមិនឲ្យធ្វើអន្តរាយដល់ជីវិតរបស់ព្រះបច្ចេកពុទ្ធ ថ្ងៃនេះ ខ្ញុំនឹងដឹងថា ខ្ញុំ ឬលោកមានកម្លាំងជាង ទើបឈរត្រង់ប្រាំងរណ្តៅ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទោះបីខ្ញុំមានក្បាលដាំចុះ ធ្លាក់ក្នុងរណ្តៅរងើកភ្លើងនេះ ក៏មិនត្រឡប់ក្រោយ សូមលោកម្ចាស់ទទួលភោជន ដែលខ្ញុំប្រគេនតែម្យ៉ាង ហើយពោលគាថានេះថា

តាមពិត ខ្ញុំព្រះអង្គស្ទើមានជើងឡើងលើ មានក្បាលចុះក្រោម ហើយ
ធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូម

ព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្តីដូចតទៅនេះថា បពិត្រលោកម្ចាស់ បើខ្ញុំប្រគេនបិណ្ឌបាតដល់លោកម្ចាស់ ទោះបីមានក្បាលចុះក្រោម មានជើងឡើងលើ ធ្លាក់ចុះទៅកាន់នរកដោយពិត តែទោះជាយ៉ាងនោះ ខ្ញុំនឹងមិនធ្វើនូវការមិនឲ្យទាន និងការមិនរក្សាសីល ដែលហៅថា អនរិយៈ ព្រោះបុគ្គលប្រសើរមិនធ្វើ តែបុគ្គលមិនប្រសើរធ្វើនោះ សូមនិមន្តលោកម្ចាស់ទទួលដុំបាយដែលខ្ញុំប្រគេននេះចុះ ។ សព្ទថា **ហន្ទ** ក្នុងគាថានេះ ជានិបាត ប្រើក្នុងអត្ថនៃឧបសគ្គ ។

ព្រះពោធិសត្វ លុះពោលយ៉ាងនេះហើយ មានការសមាទានយ៉ាងមាំទាំកាន់ថាសកត្ត ដើរលើរណ្តៅរងើកភ្លើង រំពេចនោះឯង ផ្កាឈូកធំមួយ រីកស្គុសស្គាយ ផុសឡើងជាជាន់ៗ អំពីរណ្តៅរងើកភ្លើង ជម្រៅ ៨០ ហត្ថ ទទួលជើងទាំង ២ របស់ព្រះពោធិសត្វ បន្ទាប់អំពីនោះ កេសរមួយនាឡិផ្សាយឡើង តាំងនៅលើសីសៈរបស់ព្រះមហាសត្វ ហើយជ្រុះចុះមក ធ្វើរាងកាយទាំងមូលដូចរោយដោយលម្អងមាស ព្រះពោធិសត្វឈរលើផ្កាឈូកញ៉ាំងភោជន មានរសប្រសើរផ្សេងៗ ឲ្យប្រតិស្ឋានក្នុងបាត្ររបស់ព្រះបច្ចេក-ពុទ្ធៗ ទទួលភោជននោះហើយ ធ្វើអនុមោទនា បោះបាត្រទៅក្នុងអាកាស កាលមហាជនកំពុងឃើញនោះឯង ក៏ហោះឡើងកាន់អាកាស ទៅកាន់ព្រៃហិមពាន្ត ដូចជាន់ពពក មានប្រការផ្សេងៗ ទៅ ដូច្នោះ ។ ឯមារចាញ់ហើយ ក៏ដល់នូវទោមនស្ស ទៅកាន់ទីលំនៅរបស់ខ្លួននោះឯង ។ ចំណែកព្រះ

ពោធិសត្វឈរលើផ្កាឈូកសម្ដែងធម៌ដល់មហាជន ដោយពណ៌នាដល់ទាន និងសីល ដែលមហាជនចោមរោម ចូលទៅកាន់និវេសន៍របស់ខ្លួន ធ្វើបុណ្យទាំងឡាយ មានទានជាដើម ដរាបដល់អស់ជីវិតហើយ ទៅតាមយថាកម្ម ។

ព្រះសាស្ដាត្រាស់ថា ម្នាលគហបតី ការដែលអ្នកសម្បូរដោយទស្សនៈយ៉ាងនេះ ដែលទេវតាឲ្យញាប់ញ័រមិនបាន ក្នុងឥឡូវនេះ មិនគួរអស្ចារ្យ វត្ថុដែលបណ្ឌិតទាំងឡាយបានធ្វើក្នុងកាលមុនប៉ុណ្ណោះ គួរអស្ចារ្យ ។ កាលទ្រង់នាំបឋមទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយក្នុងទីនោះឯង ឯពារាណសីសេដ្ឋីធ្វើមារឲ្យចាញ់ ឈរលើផ្កាឈូក ហើយថ្វាយបិណ្ឌបាត ដល់ព្រះបច្ចេកពុទ្ធក្នុងកាលនោះ គឺព្រះតថាគតនេះឯង ។៚

**អដ្ឋកថា ខទិរង្គារជាតក ចប់**

**កុលាវកវគ្គ ចប់**

# សុត្តន្តបិដក

## អត្ថកាមវគ្គ

### លោសកជាតក

[ ៤១ ] *( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) បុគ្គលណា កាលលោកអ្នកប្រាប់ថ្នាសេចក្ដីចម្រើន អនុគ្រោះដោយប្រយោជន៍ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈ ប្រតោងជើងនៃមេពពែសោកសៅ ។*

*លោសកជាតកទី ១ ចប់*

# អដ្ឋកថា
# ឯកនិបាត

## អត្ថកាមវគ្គ

### លោសកជាតក

[ ៤១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះលោសកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យោ អត្ថកាមស្ស** ដូច្នេះជាដើម ។

ព្រះថេរៈដែលមានឈ្មោះលោសកៈនេះ ជានរណា ។ លោកជាកូនអ្នកប្រមង់ម្នាក់ ក្នុងដែនកោសល ជាអ្នកទម្លាយវង្សរបស់ខ្លួន មិនមានលាភ មកបួសក្នុងពួកភិក្ខុ ។

បានឮថា លោកចុតិអំពីទីដែលកើតហើយ បដិសន្ធិក្នុងផ្ទៃរបស់ស្រីអ្នកប្រមង់ម្នាក់ ក្នុងស្រុកអ្នកប្រមង់មួយកន្លែង ដែលនៅរួមគ្នា ១០០០ ត្រកូល ក្នុងដែនកោសល ។ ក្នុងថ្ងៃកុលបុត្តនេះបដិសន្ធិ អ្នកប្រមង់រាប់ពាន់គ្រួសារនោះ នាំគ្នាកាន់សំណាញ់ដើររកត្រីក្នុងអូរ និងបឹង មិនបានសូម្បីត្រឹមតែត្រីតូចមួយ ។ តាំងអំពីថ្ងៃនោះមក ពួកអ្នកប្រមង់ទាំងនោះ ក៏នាំគ្នាទ្រុឌទ្រោមនោះឯង ។ កាលនៅក្នុងផ្ទៃម្ដាយនោះសោត ផ្ទះរបស់អ្នកប្រមង់ទាំងនោះ ត្រូវភ្លើងឆេះអស់ ៧ ដង ត្រូវព្រះរាជាពិន័យអស់ ៧ ដង ។ ដោយន័យនេះ

អ្នកប្រមង់ទាំងនោះ ទើបដល់នូវភាពក្រីក្រដោយលំដាប់ ។ ពួកគេគិតគ្នាថា ពីមុន រឿងទំនងបែបនេះ មិនធ្លាប់មានដល់ពួកយើងឡើយ តែឥឡូវនេះ ពួកយើងដល់នូវការលំបាក ក្នុងចំណោមពួកយើង ពិតជាមានមនុស្សកាឡកិណី ម្នាក់ ពួកយើងចែកគ្នាជា ២ ពួកចុះ ដូច្នេះហើយ ក៏ចែកគ្នាជា ២ ផ្នែក មួយផ្នែក ៥០០ ត្រកូល ។ តែមាតាបិតារបស់ទារកនោះនៅក្នុងក្រុមណា ក្រុមនោះក៏លំបាក ក្រុមដទៃចម្រើន ។ ក្រុមដែលជួបការលំបាកនោះ ក៏ចែកគ្នាជា ២ ទៀត ដោយទំនងនោះ រហូតសល់តែមួយត្រកូល ទើបគេទាំងឡាយដឹងថា បុគ្គលទាំងនោះជាកាឡកិណី ក៏ចោមរោមវាយតប់បណ្តេញចេញទៅ ។ កាលនោះ មាតាបិតារបស់ទារកនោះ ចិញ្ចឹមជីវិតមកដោយការលំបាក លុះគ្រប់ខែ ក៏កើតក្នុងទីមួយកន្លែង ធម្មតាសត្វដែលជាបច្ឆិមភព មិនមាននរណាអាចទម្លាយបាន ព្រោះមានឧបនិស្ស័យនៃអរហត្តផល រុងរឿងនៅក្នុងហទយៈ ដូចប្រទីបឆេះក្នុងឆ្នាំង ដូច្នោះ ។ ម្តាយនោះចិញ្ចឹមទារកនោះ រហូតដល់ចេះរត់ទៅរត់មកបាន ក៏យកអំបែងឆ្នាំងដីមួយដាក់ក្នុងដៃបណ្តើរ ដេញទៅបណ្តើរ ដោយពាក្យថា ចូរអ្នកទៅកាន់ផ្ទះនោះចុះ ដូច្នេះហើយ គេចទៅ ។ ចាប់តាំងពីនោះមក កុមារក៏រស់នៅឯកោ ដើររកស៊ីទៅតាមយថាកម្ម ភ្ញាក់ពីដេកក្នុងទីមួយកន្លែង មិនបានងូតទឹក មិនបានបដិបត្តិរាងកាយ ដូចបិសាចប្រឡាក់ធូលី ចិញ្ចឹមជីវិតមកដោយលំបាក ។ លុះមានអាយុ ៧ ឆ្នាំ ដោយលំដាប់ រើសគ្រាប់បាយបរិភោគម្តងមួយគ្រាប់ៗ ដូចក្អែកក្នុងទីសម្រាប់ចាក់ទឹកលាងឆ្នាំង ក្បែរទ្វារផ្ទះមួយកន្លែង ។

គ្រានោះ ព្រះធម្មសេនាបតីត្រាច់បិណ្ឌបាត នៅក្នុងក្រុងសាវត្ថី ឃើញហើយ ពិចារណាថា កុមារនេះ គួរអាសូរពេកណាស់ ជាអ្នកស្រុកណាហ្ន៎ ផ្សាយមេត្តាចិត្តទៅក្នុងកុមារនោះក្រៃលែងឡើង ទើបហៅដោយពាក្យថា មកនេះកុមារតូច កុមារនោះមកថ្វាយបង្គំព្រះថេរៈ ហើយឈរ លំដាប់នោះ ព្រះថេរៈសួរថា អ្នកជាអ្នកស្រុកណា ឪពុកម្ដាយរបស់អ្នកនៅឯណា ។ កុមារតបថា បពិត្រលោកម្ចាស់ ខ្ញុំមិនមានទីពឹង ពុកម៉ែរបស់ខ្ញុំពោលថា ព្រោះខ្ញុំធ្វើឲ្យលោកលំបាក ទើបលះបង់ខ្ញុំគេចទៅ ។ ព្រះថេរៈសួរថា អើ ចុះអ្នកម្ដេចក៏មិនបួស ។ កុមារឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំចង់បួសណាស់ តែមនុស្សអនាថាដូចខ្ញុំ អ្នកណានឹងឲ្យបួស ព្រះថេរៈពោលថា យើងនឹងឲ្យបួស កុមារពោលថា សាធុ សូមលោកម្ចាស់អនុគ្រោះឲ្យខ្ញុំបួសចុះ ។ ទើបព្រះថេរៈឲ្យរបស់ទំពា របស់បរិភោគដល់កុមារ ហើយនាំទៅវិហារ ងូតទឹកឲ្យដោយខ្លួនឯង ឲ្យបព្វជ្ជា លុះមានអាយុគ្រប់ ២០ ទើបឲ្យឧបសម្បទា ក្នុងកាលចាស់ លោកមានឈ្មោះថា លោសកតិស្សត្ថេរ ជាអ្នកមិនមានបុណ្យ មានលាភតិច បានឮថា ក្នុងកាលអសទិសទាន លោកក៏មិនបានឆាន់ពេញពោះ បានទំពាឆាន់ត្រឹមល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ព្រោះកាលបុគ្គលណាមួយ ដាក់បាត្រត្រឹមបបរមួយវែក បាត្រក៏ប្រាកដហាក់ដូចពេញស្មើកណ្ដាប់មាត់ហើយ កាលបើដូច្នោះ មនុស្សទាំងឡាយសម្គាល់ថា បាត្ររបស់ភិក្ខុនេះពេញហើយ ក៏រំលង ហើយប្រគេនដល់អង្គដទៃៗ ។ អាចារ្យពួកខ្លះពោលថា ក្នុងពេលប្រគេនបបរ មកដល់បាត្ររបស់លោក បបរក្នុងភាជនៈ

របស់ទាយកទាំងឡាយក៏បាត់ទៅ ដូច្នេះក៏មាន ។ ក្នុងបច្ច័យដទៃ មានខាទនីយជាដើមក៏មានន័យដូចគ្នា ។ សម័យតមក លោកចម្រើនវិបស្សនា តាំងនៅក្នុងអរហត្ត ជាផលដ៏កំពូល តែក៏នៅជាបុគ្គលដែលមានលាភតិច ។ កាលអាយុសង្ខាររបស់លោកទ្រុឌទ្រោមចុះដោយលំដាប់ ក៏ដល់វ័យដែលត្រូវបរិនិព្វាន ។

ព្រះធម្មសេនាបតីពិចារណា ក៏ដឹងដល់កាលបរិនិព្វានរបស់លោក ទើបត្រិះរិះថា ថ្ងៃនេះ លោសកតិស្សត្ថេរនឹងបរិនិព្វាន អាត្មាអញគួរឲ្យអាហារដល់លោករហូតឆ្អែតស្កប់ស្កល់ ដូច្នេះហើយ នាំលោកចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ព្រោះនាំលោកទៅដែរ ព្រះថេរៈក៏មិនបានសូម្បីត្រឹមតែអញ្ជលីកម្មក្នុងក្រុងសាវត្ថី ដែលមានមនុស្សសន្ធឹកសន្ធាប់ ទើបព្រះថេរៈពោលថា អាវុសោ ចូរលោកអង្គុយចាំត្រង់រោងឆាន់ចុះ ដូច្នេះហើយ បញ្ជូនលោកត្រឡប់ ។ គ្រាន់តែព្រះថេរៈចេញអំពីទីនោះប៉ុណ្ណោះ ពួកមនុស្សក៏ពោលថា លោកម្ចាស់របស់យើងមកហើយ និមន្តឲ្យគង់លើអាសនៈ ប្រគេនភត្តាហារព្រះថេរៈក៏បញ្ជូនអាហារដែលបានហើយនោះទៅ ដោយពោលនឹងមនុស្សទាំងនោះថា ចូរពួកអ្នកឲ្យភត្តនេះដល់ព្រះលោសកតិស្សត្ថេរ មនុស្សដែលទទួលភត្តនោះទៅ ក៏ភ្លេចព្រះលោសកតិស្សត្ថេរ នាំគ្នាស៊ីអស់ ។ លុះដល់ពេលព្រះថេរៈទៅដល់វិហារ ព្រះលោសកតិស្សត្ថេរក៏ទៅនមស្ការព្រះថេរៈៗ បែរមកសួរថា អាវុសោ អ្នកបានអាហារហើយឬ លោកឆ្លើយថា មិនបានទេលោកម្ចាស់ ព្រះថេរៈដល់នូវការសង្វេគ មើលពេលវេលា ក៏មិនទាន់ហួសនៅឡើយ ទើបពោលថា ណ្ហើយចុះ អាវុសោ ចូរលោកអង្គុយត្រង់នេះឯង

កាលឲ្យព្រះលោសកតិស្សៈអង្គុយរង់ចាំក្នុងរោងឆាន់ហើយ ក៏ទៅកាន់ព្រះរាជវាំងរបស់ព្រះបាទកោសល ព្រះរាជាទទួលបាត្ររបស់ព្រះថេរៈ ទ្រង់កំណត់ថា មិនមែនកាលនៃភត្ត ទើបដាក់បង្អែម ៤ យ៉ាង រហូតពេញបាត្រ ព្រះថេរៈទទួលបាត្រត្រឡប់ទៅ ទើបហៅព្រះលោសកតិស្សត្ថេរថា មកអាវុសោតិស្សៈ ឆាន់បង្អែម ៤ យ៉ាងនេះចុះ ហើយកាន់បាត្រឈរ ។ ព្រះលោសកតិស្សត្ថេរគោរពក្នុងព្រះថេរៈ ទើបមិនឆាន់ គ្រានោះ ព្រះថេរៈពោលថា មកចុះអាវុសោតិស្សៈ ខ្ញុំឈរកាន់បាត្រឲ្យ ចូរលោកអង្គុយឆាន់ បើខ្ញុំលែងបាត្រអំពីដៃ បាត្រនឹងមិនមានអ្វី ។ លំដាប់នោះ ព្រះលោសកតិស្សត្ថេរកាលព្រះធម្មសេនាបតីជាអគ្គសាវកឈរកាន់បាត្រឲ្យ ទើបអង្គុយឆាន់បង្អែម ៤ យ៉ាងនោះ បង្អែម ៤ យ៉ាងនោះ មិនដល់នូវការអស់ ដោយកម្លាំងនៃអរិយឫទ្ធិរបស់ព្រះថេរៈ ។ ព្រះលោសកតិស្សត្ថេរ ឆាន់រហូតស្កប់ស្កល់តាមសេចក្តីត្រូវការក្នុងពេលនោះ ។ ថ្ងៃនោះឯង លោកក៏បរិនិព្វានដោយអនុ-បាទិសេសនិព្វានធាតុ ។ ព្រះសម្មាសម្ពុទ្ធយាងមកកាន់សម្នាក់របស់លោក ទ្រង់ឲ្យធ្វើការបូជាសរីរៈ ជនទាំងឡាយក៏យកធាតុ សាងចេតិយបញ្ចុះ ។

ក្នុងកាលនោះ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នា ក្នុងធម្មសភា សន្ទនាគ្នាថា អាវុសោទាំងឡាយ គួរអស្ចារ្យពិត ព្រះលោសកតិស្សត្ថេរ មានបុណ្យតិច មានលាភតិច បុគ្គលមានបុណ្យតិច មានលាភតិចបែបនេះ នឹងសម្រេចអរិយ-ធម៌បានដូចម្តេច ។ ព្រះបរមសាស្តាយាងទៅកាន់ធម្មសភា មានព្រះតម្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយ

*រឿងអ្វី ។ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោសកតិស្សៈនេះបានប្រកបកម្ម គឺភាពជាអ្នកមានលាភតិច និងជាអ្នកបាននូវអរិយធម៌របស់ខ្លួនដោយខ្លួនឯង ព្រោះក្នុងកាលមុន លោសកៈធ្វើអន្តរាយលាភរបស់អ្នកដទៃ ទើបជាអ្នកមានលាភតិច តែជាអ្នកសម្រេចអរិយធម៌បាន ដោយផលដែលបំពេញវិបស្សនា គឺអនិច្ចំ ទុក្ខំ អនត្តា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ*

*បានឮថា ក្នុងអតីតកាល កាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ភិក្ខុមួយរូប អាស្រ័យកុដុម្ពិកៈម្នាក់ នៅក្នុងអាវាសជាប្រចាំ ជាបុគ្គលរាបស្មើ មានសីល ព្យាយាមចម្រើនវិបស្សនា ។ កាលនោះ មានព្រះខីណាស្រពមួយអង្គ នៅក្នុងព្រៃហិមពាន្ត បានមកដល់លំនៅរបស់កុដុម្ពិកៈដែលឧបដ្ឋាកភិក្ខុនោះដោយលំដាប់ ។ កុដុម្ពិកៈជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះថេរៈ ទើបទទួលបាត្រ និមន្តចូលកាន់ផ្ទះ ឲ្យឆាន់ភត្តាហារដោយគោរព ស្តាប់ព្រះធម្មកថាតិចតួចហើយ ថ្វាយបង្គំព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តទៅកាន់វិហារជិតស្រុករបស់ខ្ញុំមុនចុះ ចាំពេលល្ងាច ពួកខ្ញុំនឹងទៅសួរសុខទុក្ខ ទើបព្រះថេរៈទៅកាន់វិហារ នមស្ការព្រះថេរៈដែលជាម្ចាស់អាវាស សាកសួររួច អង្គុយក្នុងទីសមគួរ ។ ម្ចាស់អាវាសធ្វើបដិសណ្ឋារៈ ហើយសួរថា អាវុសោ លោកបានទទួលភត្តាហារហើយឬ លោកឆ្លើយថា បានទទួលហើយ ។ ចៅអាវាសសួរថា លោកបានក្នុងទីណា ព្រះថេរៈឆ្លើយថា បានក្នុងផ្ទះកុដុម្ពិកៈជិតៗ វិហារនេះឯង លុះប្រាប់យ៉ាងនេះហើយ ក៏សួរដល់*

សេនាសនៈរបស់ខ្លួន រៀបចំបោសសម្អាត ទុកដាក់បាត្រ និងចីវរស្រេចបាច់ អង្គុយសម្ងំ នៅដោយឈានសុខ និងដោយសេចក្ដីសុខក្នុងផលសមាបត្តិ ។ ដល់ពេលល្ងាច កុដុម្ពិកៈក៏ឲ្យមនុស្សកាន់យកកម្រងផ្កា និងប្រេង អុជប្រទីប ទៅកាន់វិហារ នមស្ការព្រះថេរៈដែលជាម្ចាស់អាវាស ហើយសួរថា បពិត្រលោកម្ចាស់ មានព្រះថេរៈអាគន្តុកៈ មកស្នាក់នៅមួយរូប មិនមែនឬ លោកឆ្លើយថា អើ មានស្នាក់នៅ ។ គហបតីសួរថា ឥឡូវនេះ លោកស្នាក់នៅឯណា ក៏ឆ្លើយថា ត្រង់សេនាសនៈឈ្មោះនោះ ។ កុដុម្ពិកៈទៅកាន់សម្នាក់របស់លោក ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ ស្ដាប់ធម្មកថារហូតដល់ព្រលប់ ទើបបូជាព្រះចេតិយ និងពោធិព្រឹក្ស អុជប្រទីបបំភ្លឺ ហើយនិមន្តភិក្ខុទាំង ២ ឲ្យទទួលចង្ហាន់ក្នុងថ្ងៃស្អែក ហើយត្រឡប់ទៅ ។ ឯព្រះថេរៈម្ចាស់អាវាស គិតថា កុដុម្ពិកៈនេះត្រូវអាគន្តុកៈញុះញង់ឲ្យបែកពីអញហើយ បើលោកនៅក្នុងវិហារនេះសោត កុដុម្ពិកៈនឹងលែងរាប់អានអញ កើតនូវការមិនពេញចិត្តក្នុងព្រះថេរៈ គិតថា អញគួរសម្ដែងអាការមិនឲ្យលោកនៅក្នុងវិហារនេះដូច្នេះហើយ ក្នុងពេលដែលមកប្រណិប័តន៍ ក៏មិននិយាយជាមួយ ។ ព្រះថេរៈដែលជាខីណាស្រពជ្រាបអជ្ឈាស្រ័យរបស់ភិក្ខុម្ចាស់អាវាស ពិចារណាថា ព្រះថេរៈនេះ មិនបានជ្រាបដល់ការដែលអញមិនមានការជាប់ជំពាក់ក្នុងត្រកូល ក្នុងលាភ ឬក្នុងគណៈ ហើយត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួន សម្ងំដោយឈានសុខ និងសុខក្នុងផលសមាបត្តិ ស្អែកឡើង ម្ចាស់អាវាស ក៏វាយជួងដោយខ្នងក្រចក គោះទ្វារដោយក្រចក ហើយទៅផ្ទះរបស់កុដុម្ពិកៈៗ ទទួល

បាត្រ និមន្តឲ្យគង់លើអាសនៈដែលក្រាលហើយ សួរថា បពិត្រលោកម្ចាស់ព្រះថេរៈដែលជាអាគន្តុកៈទៅណា ។ ព្រះថេរៈឆ្លើយថា អាត្មាមិនដឹងការប្រព្រឹត្តរបស់លោកដែលជិតស្និទ្ធរបស់អ្នកទេ អាត្មាវាយជួង គោះទ្វារ ក៏មិនអាចឲ្យភ្ញាក់បាន កាលពីម្សិលមិញ ឆាន់ភោជនដែលប្រណីត ក្នុងផ្ទះរបស់អ្នកហើយ ប្រហែលជាឆ្អែតដល់ថ្ងៃនេះ ឥឡូវនេះ នៅដេកលក់នោះឯង កាលអ្នកជ្រះថ្លា ក៏ជ្រះថ្លាក្នុងភិក្ខុដែលមានសភាពបែបនេះឯង ។ ឯព្រះថេរៈខីណាស្រព កំណត់កាលភិក្ខាចាររបស់ខ្លួនហើយ ក៏ជម្រះសរីរៈ កាន់បាត្រ និងចីវរ ហោះទៅក្នុងអាកាស ទៅកាន់ទីដទៃ ។

កុដុម្ពិកៈនិមន្តព្រះថេរៈម្ចាស់អាវាសឆាន់បាយាស ដែលផ្សំដោយសប្បិ ទឹកឃ្មុំ ស្ករក្រាម ហើយអប់បាត្រដោយគ្រឿងក្រអូប ដាក់បាយាសពេញរួចពោលថា បពិត្រលោកម្ចាស់ ព្រះថេរៈនោះប្រហែលជាហត់នឿយ អស់កម្លាំងក្នុងការធ្វើដំណើរ សូមលោកម្ចាស់នាំបាយាសនេះទៅឲ្យលោកផងចុះ ហើយប្រគេនបាត្រទៅ ។ ព្រះថេរៈម្ចាស់អាវាសមិនឃាត់ ទទួលបាត្រមកដើរទៅ គិតថា បើភិក្ខុនោះ បានបាយាសនេះសោត ទោះបីអញចាប់ត្រង់កអូសទៅ ក៏មិនទៅ បើអញឲ្យបាយាសនេះដល់មនុស្ស កម្មរបស់អញនឹងប្រាកដ បើចាក់ក្នុងទឹក សប្បិក៏នឹងប្រាកដលើទឹកបាន បើចោលលើផែនដី ហ្វូងក្អែកនឹងចោមរោមស៊ី កម្មរបស់អញក៏ប្រាកដ អញគួរចោលបាយាសនេះ ក្នុងទីណាហ្ន៎ ដូច្នេះ ឃើញស្រែភ្លើងឆេះមួយកន្លែង កកាយផេះ ចាក់បាយាសលុបដោយផេះ ហើយទៅកាន់វិហារ កាលមិនឃើញភិក្ខុរូបនោះ ទើប

គិតថា ភិក្ខុនោះប្រហែលជាព្រះខីណាស្រព ដឹងអធ្យាស្រ័យរបស់អញហើយ ទៅកាន់ទីដទៃពិត ឱ! ព្រោះតែក្រពះជាហេតុ អញធ្វើកម្មមិនសមគួរឡើយ ។ វេលានោះឯង ទោមនស្សដ៏មានកម្លាំងកើតឡើងដល់ភិក្ខុនោះ ។ ចាប់តាំងអំពីថ្ងៃនោះទៅ លោកក៏ក្លាយជាមនុស្សប្រេត មិនយូរប៉ុន្មាន ស្លាប់ទៅកើតក្នុងនរក ។

ភិក្ខុនោះ ឆេះក្នុងនរកច្រើនសែនឆ្នាំ សេសសល់ផលរបស់កម្ម មកកើតជាយក្ខ ៥០០ ជាតិតាមលំដាប់ មិនធ្លាប់បរិភោគអាហារពេញពោះ សូម្បីត្រឹមតែមួយថ្ងៃឡើយ គឺបានស៊ីសុកមនុស្សពេញពោះត្រឹមមួយថ្ងៃ ។ កើតជាឆ្កែ ៥០០ ជាតិ ក្នុងកាលជាឆ្កែនោះ ក៏បានស៊ីកម្អួតពេញពោះមួយថ្ងៃប៉ុណ្ណោះ ។ ក្នុងកាលដ៏សេស មិនធ្លាប់ស៊ីពេញពោះឡើយ ។ ចុតិអំពីឆ្កែមកកើតក្នុងត្រកូលក្រីក្រមួយ ក្នុងដែនកាសី តាំងអំពីថ្ងៃដែលកុមារកើតមកត្រកូលនោះក៏ធ្លាក់ខ្លួនក្រីក្រលំបាកពន់ពេក ។ សូម្បីតែទឹក និងចុងអង្ករកន្ទះពោះ ក៏មិនធ្លាប់បានបរិភោគ ។ បុរសនោះមានឈ្មោះថាមិត្តវិន្ទុកៈ ។ ឪពុកម្តាយរបស់បុរសនោះ មិនអាចអត់ធន់ចំពោះសេចក្តីទុក្ខដែលកើតអំពីសេចក្តីលំបាកបាន ក៏ពោលថា ទៅចុះ អាកូនកាឡកិណី ដេញវាយឲ្យចេញទៅ ។ មិត្តវិន្ទុកៈមិនមានទីអាស្រ័យ ក៏ត្រាច់ទៅដល់ក្រុងពារាណសី ។ គ្រានោះ ព្រះពោធិសត្វសោយព្រះជាតិជាអាចារ្យទិសាបាមោក្ខ បង្រៀនសិប្បៈដល់មាណព ៥០០ ក្នុងនគរពារាណសី ក្នុងវេលានោះអ្នកនគរពារាណសី ឲ្យដើមទុនដល់មនុស្សក្រីក្រ ឲ្យសិក្សាសិប្បៈ មិត្តវិន្ទុកៈនេះ ក៏បានសិក្សាសិប្បៈក្នុងសម្នាក់

របស់ព្រះពោធិសត្វ មិត្តវិន្ទុកៈជាក្មេងគ្រោតគ្រាត មិនស្តាប់ឱវាទ ដើរផ្តេសផ្តាសទៅ សូម្បីព្រះពោធិសត្វទូន្មាន ក៏មិនស្តាប់ឱវាទ ។ អាស្រ័យហេតុនោះ ការបម្រើនធំធាត់របស់មិត្តវិន្ទុកៈនោះ ទើបជាបុគ្គលល្ងង់ខ្លៅ ។ កាលនោះ មិត្តវិន្ទុកៈឈ្លោះជាមួយពួកមាណពផង មិនស្តាប់ពាក្យទូន្មានផង រត់គេចដល់តំបន់ជាយដែនមួយ ស៊ីឈ្នួលគេចិញ្ចឹមជីវិត ។ មិត្តវិន្ទុកៈនោះបានស្ត្រីក្រីក្រម្នាក់ជាប្រពន្ធក្នុងស្រុកនោះ បានកូន ២ នាក់ ។ ពួកអ្នកស្រុកបានប្រគល់ការងារ បញ្ជូនដំណឹងឲ្យធ្វើថា អ្នកគប្បីប្រាប់ដំណឹងល្អ ដំណឹងអាក្រក់ដល់ពួកយើង ឲ្យថ្លៃឈ្នួល និងធ្វើខ្ទមឲ្យនៅត្រង់ទ្វារស្រុក ។ ព្រោះអាស្រ័យមិត្តវិន្ទុកៈនោះជាដើមហេតុ ធ្វើឲ្យពួកអ្នកស្រុកជាយដែននោះ ត្រូវរាជទណ្ឌ ៧ ដង ភ្លើងឆេះផ្ទះ ៧ ដង ទឹកអណ្តូងរីងស្ងួត ៧ ដង ទើបពួកជនទាំងនោះប្រឹក្សាគ្នាថា មុនមិត្តវិន្ទុកៈនេះមកនៅ ពួកយើងមិនធ្លាប់មានរឿងយ៉ាងនេះឡើយ ឥឡូវនេះ តាំងអំពីមិត្តវិន្ទុកៈនេះមក ពួកយើងលំបាកទៅៗ តាមលំដាប់ ទើបនាំគ្នាចោមរោមវាយបណ្តេញចេញទៅ គាត់នាំកូន ២ នាក់ និងភរិយាទៅកាន់ទីដទៃ ចូលចូលដល់ព្រៃ ដែលអមនុស្សគ្រប់គ្រងមួយកន្លែង ពួកអមនុស្សចោមរោមចាប់កូន និងប្រពន្ធរបស់គាត់សម្លាប់ ស៊ីសាច់ក្នុងព្រៃនោះឯង ។

មិត្តវិន្ទុកៈរត់គេចទៅបាន ត្រាច់ទៅរឿយៗ រហូតដល់កំពង់មួយ ឈ្មោះគម្ភីរ ជួនជាថ្ងៃដែលគេចេញសំពៅទៅ ក៏ធ្វើជាកម្មករចុះទូកទៅ សំពៅរសាត់ទៅក្នុងសមុទ្របាន ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានកឿងកណ្តាលសមុទ្រ ដូចគេទាញ

អ្នកជិះសំពៅទាំងអស់ ក៏នាំគ្នាចាប់ស្លាករកមនុស្សកាឡកិណី ស្លាកកាឡកិណី បានធ្លាក់ដល់មិត្តវិន្ទុកៈរហូតដល់ ៧ ដង ពួកអ្នកជិះសំពៅបានធ្វើក្បូនឫស្សីមួយ ហើយចាប់មិត្តវិន្ទុកៈ បោះក្នុងសមុទ្រ គ្រាន់តែមិត្តវិន្ទុកៈធ្លាក់ចូលកាន់សមុទ្រ សំពៅក៏ទៅមុខទៀតបាន ។

មិត្តវិន្ទុកៈដេកលើក្បូនឫស្សី អណ្តែតទៅក្នុងសមុទ្រ ដោយផលដែលបានរក្សាសីលក្នុងសាសនារបស់ព្រះកស្សបៈ ទើបបានជួបនឹងទេពធីតា ៤ រូប ដែលនៅក្នុងវិមានកែវផលិកកណ្តាលសមុទ្រ សោយសុខក្នុងសម្នាក់ទេពធីតាទាំងនោះអស់ ៧ ថ្ងៃ ឯនាងវេមានិកប្រេត សោយសុខ ៧ ថ្ងៃ សោយទុក្ខ ៧ ថ្ងៃ កាលនាងវិលទៅសោយទុក្ខ ក៏ប្រាប់មិត្តវិន្ទុកៈថា ចូរអ្នកកុំទៅណាទម្រាំពួកខ្ញុំមក ហើយក៏នាំគ្នាទៅ កាលនាងនាំគ្នាទៅហើយ មិត្តវិន្ទុកៈ ក៏ចុះដេកក្នុងក្បូនឫស្សីបន្តដំណើរទៅមុខទៀត បានជួបនឹងទេពធីតា ៨ រូប ក្នុងវិមានប្រាក់ ទេពធីតាទាំងនោះ ក៏ជាវេមានិកប្រេតដូចគ្នា ។ មិត្តវិន្ទុកៈបន្តដំណើរទៅទៀត បានជួបទេពធីតា ១៦ រូប ក្នុងវិមានកែវមណី ។ ហើយក៏បណ្តែតក្បូនតទៅទៀត បានជួបទេពធីតា ៣២ រូប ក្នុងវិមានមាស គាត់មិនបានស្តាប់ពាក្យរបស់ទេពធីតាទាំងនោះ ទើបបណ្តែតក្បូនតទៅទៀត បានជួបយក្ខមួយក្នុងកោះ ។ ក្នុងនគរនោះ មានយក្ខិនីមួយរូប កាឡាខ្លួនជាមេពពែត្រាច់ទៅ ។ មិត្តវិន្ទុកៈមិនដឹងថា មេពពែជាយក្ខិនី គិតថា អញនឹងបរិភោគសាច់ពពែដូច្នេះ លោតចាប់ត្រង់ជើង យក្ខិនីក៏លើកមិត្តវិន្ទុកៈឡើង រលាស់ទៅដោយអានុភាពរបស់យក្ខ មិត្តវិន្ទុកៈត្រូវយក្ខិនីរលាស់ឆ្លងសមុទ្រ ទៅធ្លាក់

ត្រង់គុម្ពបន្ទាមួយក្បែរគូទឹកក្រុងពារាណសី ហើយក៏រមៀលធ្លាក់ត្រង់ផែនដី កាលនោះ មេពពែរបស់ព្រះរាជាជាច្រើន រកស៊ីក្បែរគូទឹកនោះ ត្រូវពួកចោរលួចទៅ ពួកអ្នកចិញ្ចឹមពពែ គិតថា ពួកយើងនឹងចាប់ចោរឲ្យបាន នាំគ្នាពួនក្នុងទីមួយកន្លែង មិត្តវិន្ទុកៈរមៀលចុះមក ឈរត្រង់ផែនដីបានហើយ ឃើញមេពពែទាំងនោះ គិតថា អញចាប់មេពពែមួយ ក្នុងកោះមួយកណ្តាលសមុទ្រ ត្រូវវាធាក់អញ ខ្ទាតមកធ្លាក់ត្រង់ទីនេះ បើអញចាប់មេពពែមួយត្រង់ជើង វាគង់ធាក់អញ ខ្ទាតត្រឡប់ទៅដល់សម្នាក់ទេពធីតាដែលមានវិមានដូចមុន គាត់ដៅស្មានយ៉ាងនេះ ដោយមិនត្រូវទំនង ដូច្នេះហើយ ក៏លោតចាប់មេពពែមួយត្រង់ជើង ។ ពពែត្រូវគេចាប់ជើងប៉ុណ្ណោះ ក៏ស្រែក ពួកគង្វាលក៏នាំគ្នាស្ទុះមកដោយជុំវិញ ស្រែកថា អញចាំមើលយូរហើយ អាចោរលួចពពែក្នុងរាជត្រកូល គឺអានេះឯង ដូច្នេះហើយ ចោមរោមវាយតប់ ចាប់ចងនាំទៅកាន់ព្រះរាជវាំង ។ ក្នុងខណៈនោះ ព្រះពោធិសត្វចោមរោមទៅដោយមាណព ៥០០ ចេញអំពីក្រុងទៅ ងូតទឹក ឃើញមិត្តវិន្ទុកៈក៏ចាំបាន ទើបនិយាយនឹងជនទាំងនោះថា នែអ្នកទាំងឡាយ បុគ្គលនេះជាកូនសិស្សរបស់ខ្ញុំ ពួកអ្នកចាប់គេព្រោះហេតុអ្វី មនុស្សទាំងនោះឆ្លើយថា បពិត្រលោកម្ចាស់ គេជាមនុស្សអាក្រក់ លួចពពែរបស់ស្តេច ចាប់មេពពែមួយត្រង់ជើង ហេតុនោះ ទើបពួកខ្ញុំចាប់គេ ព្រះពោធិសត្វសំណូមពរថា បើដូច្នោះ ចូរឲ្យគេជាទាសៈរបស់ពួកខ្ញុំចុះ គេនឹងអាស្រ័យពួកយើងចិញ្ចឹមជីវិត ពួកមនុស្សទាំងនោះទទួលថា សាធុលោកម្ចាស់ លែងមិត្តវិន្ទុកៈ ហើយនាំគ្នាទៅ លំដាប់

នោះ ទើបព្រះពោធិសត្វសួរមិត្តវិន្ទុកៈថា អស់កាលមានប្រមាណប៉ុណ្ណេះ អ្នកទៅឯណា មិត្តវិន្ទុកៈក៏ពោលរឿងដែលខ្លួនធ្វើទាំងអស់ឲ្យស្តាប់ ទើបព្រះពោធិសត្វពោលថា បុគ្គលដែលមិនធ្វើតាមពាក្យរបស់អ្នកមានបំណងល្អ រមែងបាននូវទុក្ខយ៉ាងនេះ ហើយពោលគាថានេះថា

បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយ
ប្រយោជន៍ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែង
សោកសៅ ដូចជាមិត្តវិន្ទុកៈ ប្រតោងជើងនៃមេពពែ សោកសៅ ។

បណ្តាបទទាំងនោះ បទថា **អត្ថកាមស្ស** សេចក្តីថា ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ។

បទថា **ហិតានុកម្បិនោ** សេចក្តីថា ដែលអនុគ្រោះដោយប្រយោជន៍ ។

បទថា **ឱវជ្ជមានោ** សេចក្តីថា ដាស់តឿនប្រៀនប្រដៅដោយចិត្តដែលទន់ភ្លន់ ។

បទថា **ន ករោតិ សាសនំ** សេចក្តីថា មិនធ្វើតាមពាក្យប្រៀនប្រដៅ គឺជាបុគ្គលប្រដៅក្រ ពោលប្រដៅមិនបាន ។

បទថា **មិត្តកោ វិយ សោចតិ** សេចក្តីថា បុគ្គលនោះរមែងសោយសោកអស់កាលជានិច្ច ដូចមិត្តវិន្ទុកៈនេះ ចាប់ជើងពពែហើយ រមែងសោយសោក គឺលំបាក ដូច្នោះ ។ ព្រះពោធិសត្វសម្តែងធម៌ដោយគាថានេះ ដែលមានអធិប្បាយដូចពណ៌នាមកនេះ ។

ព្រះថេរៈនោះ ធ្លាប់បានអាហារពេញពោះ ក្នុងអត្តភាពទាំង ៣ ក្នុងកាលជាយក្ខ បានស៊ីសុកមនុស្សឆ្អែតមួយថ្ងៃ ក្នុងកាលជាឆ្កែ បានស៊ីកម្អួតឆ្អែតមួយថ្ងៃ ក្នុងជាតិចុងក្រោយ ថ្ងៃបរិនិព្វាន បានឆាន់បង្អែម ៤ មុខ យ៉ាងឆ្អែត ដោយអានុភាពរបស់ព្រះធម្មសេនាបតី ឈ្មោះថា ការធ្វើអន្តរាយដល់លាភរបស់អ្នកដទៃ គប្បីជ្រាបថា មានទោសធំកន្លងយ៉ាងនេះ ។

ព្រះពោធិសត្វដែលជាអាចារ្យ និងមិត្តវិន្ទុកៈក្នុងកាលនោះ ក៏បានទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោសកតិស្សត្ថេរនោះ បានធ្វើភាពជាបុគ្គលមានលាភតិច និងភាពជាបុគ្គលបានអរិយធម៌ដល់ខ្លួនដោយខ្លួនឯង យ៉ាងនេះឯង កាលទ្រង់នាំធម្មទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាលោសកតិស្សត្ថេរ ក្នុងកាលឥឡូវនេះ អាចារ្យទិសាបាមោក្ខ ក្នុងកាលនោះ ក៏គឺតថាគតនេះឯង ។l ។

**អដ្ឋកថា លោសកជាតក ចប់**

# សុត្តន្តបិដក

## កបោតកជាតក

[ ៤២ ] ( ព្រាបពោធិសត្វពោលថា ) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ តែងដេកសោកសៅ ដូចក្អែកតាំងនៅក្នុងកណ្តាប់ដៃនៃបុគ្គលជាសត្រូវ ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប ។

**កបោតកជាតកទី ២ ចប់**

# អដ្ឋកថា

## កាកជាតក

[ ៤២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុមាននិស្ស័យឡេះឡោះមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ អត្ថកាមស្ស** ដូច្នេះជាដើម ។

រឿងការឡេះឡោះរបស់ភិក្ខុនោះ មានសម្តែងយ៉ាងពិស្តារក្នុងកាកជាតកនវកនិបាត ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយនាំភិក្ខុនោះមកក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះមាននិស្ស័យឡេះឡោះ ។ ខណៈនោះ ព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬ ភិក្ខុនោះក្រាបទូលថា ពិតហើយ ព្រះអង្គ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកក៏ជាបក្សីឡេះឡោះ អស់ជីវិតព្រោះការឡេះឡោះរបស់ខ្លួន សូម្បីបណ្ឌិតដែលអាស្រ័យអ្នក ក៏ត្រូវព្រាត់ប្រាសចាកទីលំនៅផងដែរ ហើយទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជ្យសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាសត្វព្រាប ។ ក្នុងកាលនោះ អ្នកស្រុកពារាណសី នាំគ្នាព្យួរកំប្រោងស្មៅក្នុងទីនោះៗ ដើម្បីឲ្យហ្វូងបក្សីអាស្រ័យនៅយ៉ាងសប្បាយ ព្រោះភាពជាអ្នកប្រាថ្នាបុណ្យ ប្រាថ្នាកុសល ។ ក្នុងកាលនោះ ចុងភៅប្រុសរបស់សេដ្ឋីក្រុងពារាណសី ក៏ព្យួរកំប្រោងស្មៅក្នុងរោងបាយមួយដូចគ្នា ។ ព្រាបពោធិសត្វបានចូលទៅនៅក្នុងកំប្រោងនោះ ពេលព្រឹក

ក៏ហើរចេញរកស៊ី ពេលល្ងាច ក៏ហើរត្រឡប់មកក្នុងរោងបាយនោះ ដូច្នេះសព្វកាល ។ ថ្ងៃមួយ ក្អែកមួយហើរកាត់រោងបាយ ហិតក្លិនឈ្ងុយនៃរសជូរ រសប្រៃ ត្រី និងសាច់ ក៏កើតនូវការលោភឡើង គិតថា នឹងអាស្រ័យអ្នកណាហ្ន៎ ទើបបានត្រី និងសាច់នេះ គិតដូច្នេះហើយ ក៏ទំក្នុងទីមិនឆ្ងាយ រំពៃមើលផ្លូវ លុះពេលល្ងាច ឃើញព្រះពោធិសត្វហើរមក ហើយចូលទៅកាន់រោងបាយ ក៏គិតថា អញត្រូវអាស្រ័យព្រាបនេះ ទើបបានស៊ីសាច់ ។ លុះស្អែកឡើង ក៏ហើរមកអំពីព្រលឹម ក្នុងពេលដែលព្រះពោធិសត្វហើរចេញទៅរកស៊ី ក៏ហើរទៅខាងក្រោយ ។ លំដាប់នោះ ទើបព្រះពោធិសត្វពោលនឹងក្អែកថា នែសម្លាញ់ ហេតុអ្វី ទើបអ្នកហើរតាមខ្ញុំ ក្អែកឆ្លើយថា នែអ្នក ខ្ញុំគាប់ចិត្តក្នុងកិរិយារបស់អ្នក តាំងអំពីឥឡូវនេះទៅ ខ្ញុំសូមប្រណិប័តន៍អ្នក ។ ព្រះពោធិសត្វពោលថា នែសម្លាញ់ ពួកអ្នកមានអាហារមួយបែប ពួកខ្ញុំមានអាហារមួយបែប មិនដូចគ្នា ការប្រណិប័តន៍របស់ពួកអ្នកៗ ធ្វើបានលំបាក ក្អែកឆ្លើយថា នែអ្នក ពេលអ្នកហើរទៅរកស៊ី ខ្ញុំក៏ហើរទៅរកស៊ីជាមួយអ្នក ព្រះពោធិសត្វពោលថា សាធុ ចូរអ្នកជាអ្នកមិនប្រមាទតែម្យ៉ាង ព្រះពោធិសត្វទូន្មានក្អែកយ៉ាងនេះហើយ ក៏ត្រាច់ស្វែងរកអាហារ បរិភោគអាហារ មានតិណជាតិ និងធញ្ញជាតិជាដើម ក្នុងកាលដែលព្រះពោធិសត្វកំពុងរកស៊ី ក្អែកក៏ហើរទៅជួបនឹងគំនរអាចម៍គោ ទើបកកាយហើយ ចឹកសត្វល្អិតស៊ី លុះពេញតែហើយ ក៏មកកាន់សម្នាក់ព្រះពោធិសត្វ ពោលថា នែអ្នក អ្នករកស៊ីហួសពេល ការធ្វើខ្លួនឲ្យបានឈ្មោះថា ជាអ្នកល្មោភមិនគួរមិនមែនឬ ដូច្នេះ

ហើយ ចូលទៅកាន់រោងបាយជាមួយព្រះពោធិសត្វ ដែលរកអាហារស៊ីហើយ ក៏ហើរមកក្នុងពេលល្ងាច ។ ចុងភៅប្រុសពោលថា ព្រាបរបស់អញ នាំសត្វដទៃមក ដូច្នេះហើយ ក៏ព្យួរកំប្រោងឲ្យក្អែកដែរ តាំងអំពីនោះមកបក្សីទាំងពីរ ក៏នៅជាមួយគ្នា ។

សម័យថ្ងៃមួយ មនុស្សទាំងឡាយនាំត្រី និងសាច់ មកឲ្យសេដ្ឋីជាច្រើន ចុងភៅទទួលយកមកព្យួរក្នុងរោងបាយ ក្អែកឃើញហើយ កើតនូវចំណង់ គិតក្នុងចិត្ត ស្អែកនេះ អញមិនទៅរកស៊ី នឹងស៊ីត្រី មួយអន្ទើដោយសាច់នេះឯង ហើយក៏ដេកតម្អក់អស់រាត្រី ។ ស្អែកឡើង ព្រះពោធិសត្វទៅរកស៊ី ក៏ពោលថា មកចុះសម្លាញ់ ក្អែកឆ្លើយថា សូមអ្នកទៅចុះ ខ្ញុំកំពុងឈឺពោះ ព្រះពោធិសត្វពោលថា នែសម្លាញ់ ធម្មតារោគឈឺពោះ មិនធ្លាប់កើតដល់ពួកក្អែកឡើយ តាំងអំពីកាលណាមក ក្នុងយាមទាំង ៣ នៃរាត្រី ក្អែករមែងឃ្លានរាល់ៗ យាម ទោះបីលេបប្រឆេះប្រទីបចូលទៅ ក្អែកក៏ឆ្អែតត្រឹមមួយសម្ទុះ ប្រហែលជាអ្នកចង់ស៊ីត្រី និងសាច់នេះ មក ឈ្មោះថា របស់ស៊ីនៃមនុស្ស ជារបស់ដែលពួកអ្នកមិនគួរស៊ីទេ កុំធ្វើយ៉ាងនេះឡើយ ទៅរកស៊ីជាមួយខ្ញុំចុះ ក្អែកពោលថា នែអ្នក ខ្ញុំមិនអាចទៅបាន ។ ទើបព្រះពោធិសត្វជាស់តឿនថា បើដូច្នោះ អ្នកនឹងត្រូវទទួលស្គាល់នូវកម្មរបស់ខ្លួន អ្នកកុំលុះក្នុងអំណាចសេចក្តីលោភ ចូរជាអ្នកមិនប្រមាទចុះ ដូច្នេះហើយ ក៏ទៅរកស៊ី ។ ចុងភៅក៏ចម្អិនអាហារផ្សេងៗ មានត្រី និងសាច់ មានប្រការផ្សេងៗ ស្រេចហើយ ក៏បើកភាជនៈបន្តិច ដើម្បីឲ្យចំហាយចេញទៅ ដាក់កន្ត្រងក្នុងភាជនៈមួយទៀត ហើយ

ក៏ចេញទៅខាងក្រៅ ឈរជួតញើស ។ ខណៈនោះ ក្អែកក៏អើត-កចេញពីកំប្រោង សម្លឹងមើលរោងបាយទូទៅ ដឹងថា ចុងភៅចេញទៅខាងក្រៅ ទើបគិតថា ឥឡូវនេះ សេចក្តីប្រាថ្នារបស់អញសម្រេចបំណងហើយ អញចង់ស៊ីសាច់ នឹងស៊ីចម្រៀកធំ ឬសាច់ចម្រៀកតូចល្អហ្ន៎ ហើយក៏សម្លឹងឃើញថា ជម្ពូតាដុំសាច់តូចៗ អញមិនអាចស៊ីឲ្យពេញពោះបានរហ័សឡើយ អញត្រូវពាំដុំសាច់ធំៗ មកដាក់ក្នុងកំប្រោង ដេកលេប ទើបល្អ ។ ហើយក៏ស្ទុះចេញអំពីកំប្រោង ពួនក្បែរកន្ត្រង ។ សំឡេងកន្ត្រងលាន់គ្រឹកៗ ចុងភៅស្តាប់សំឡេងនោះហើយ គិតថា នុ៎ះសំឡេងអ្វី ត្រឡប់ចូលមកមើល ឃើញក្អែកហើយគិតថា ក្អែកចង្រៃប្រាថ្នានឹងស៊ីសាច់ចៀនរបស់មហាសេដ្ឋី អញត្រូវអាស្រ័យលោកសេដ្ឋីចិញ្ចឹមជីវិត មិនមែនអាស្រ័យក្អែកពាលនេះទេ ទុកវាធ្វើអ្វី ហើយបិទទ្វារចាប់ក្អែកបាន ដករោមអស់ពីខ្លួន យកខ្ញីស្រស់បុកជាមួយអំបិល លាយនឹងទធិ លាបពេញខ្លួនក្អែកនោះ ហើយបោះក្នុងកំប្រោងរបស់ក្អែក ក្អែកឈឺចាប់ដ៏ខ្លាំងក្លា ដេកថ្ងូរ ។ ល្ងាចឡើង ព្រះពោធិសត្វហើរត្រឡប់មក ឃើញក្អែកជួបនូវការវិនាស ទើបពោលថា នែក្អែកឡេះឡោះ អ្នកមិនស្តាប់ពាក្យរបស់ខ្ញុំ អាស្រ័យសេចក្តីល្មោភរបស់អ្នកជាហេតុ ទើបជួបនូវទុក្ខដ៏ធំ ដូច្នេះហើយ ពោលគាថានេះថា

បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ តែងដេកសោកសៅ ដូចក្អែកតាំងនៅក្នុងកណ្តាប់ដៃនៃបុគ្គលជាសត្រូវ

ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប ។

បណ្ដាបទទាំងនោះ បទថា **ការោតកស្ស វចនំ អកត្វា** សេចក្ដីថា មិនជឿពាក្យប្រៀនប្រដៅដែលប្រាថ្នាប្រយោជន៍របស់ព្រាប ។

បទថា **អមិត្តហត្ថត្តគតោវ សេតិ** សេចក្ដីថា ទើបបុគ្គលនោះដល់នូវការវិកវរធំ ដេកសោកសៅ ដូចក្អែកដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់សត្រូវ គឺបុគ្គលដែលធ្វើនូវសេចក្ដីវិនាស និងញុំាងទុក្ខឲ្យកើត ។

ព្រះពោធិសត្វពោលគាថានេះហើយ គិតថា ឥឡូវនេះ អញមិនអាចនៅក្នុងទីនេះបានទេ ទើបហើរទៅកាន់ទីដទៃ ក្អែកក៏អស់ជីវិតនៅក្នុងកំប្រោងនោះឯង ទើបចុងភៅយកក្អែកទៅទាំងកំប្រោងបោលត្រង់គំនរសំរាម ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលឡេះឡោះ សូម្បីក្នុងកាលមុន ក៏ជាអ្នកឡេះឡោះដូចគ្នា សូម្បីបណ្ឌិតទាំងឡាយ អាស្រ័យសេចក្ដីឡេះឡោះរបស់អ្នកនោះ ក៏ត្រូវព្រាត់ប្រាសទីលំនៅរបស់ខ្លួន កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសអរិយសច្ចទាំងឡាយ ក្នុងកាលចប់ការប្រកាសអរិយសច្ច ភិក្ខុនោះសម្រេចអនាគាមិផល ។ ព្រះបរមសាស្ដា ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានជាភិក្ខុឡេះឡោះក្នុងកាលនេះ ព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ការោតជាតក ចប់**

# សុត្តន្តបិដក

## វេឡុកជាតក

[ ៤៣ ] ( ឥសីពោធិសត្វពោលថា ) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុក ។

*វេឡុកជាតកទី ៣ ចប់*

# អដ្ឋកថា

## វេឡុកជាតក

[ ៤៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ អត្ថកាមស្ស** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ព្រះសាស្តាកាលត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬ ដែលថា អ្នកជាបុគ្គលប្រដៅក្រ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ក៏ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលប្រដៅក្រ សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលប្រដៅក្រដូចគ្នា ព្រោះជាបុគ្គលប្រដៅក្រនោះឯង ទើបមិនធ្វើតាមពាក្យរបស់បណ្ឌិតទាំងឡាយ ហើយត្រូវពស់ចឹកស្លាប់ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលមានសម្បត្តិច្រើន ក្នុងដែនកាសី ដល់នូវភាពជាអ្នកដឹងក្តីហើយ សម្លឹងឃើញទោសក្នុងកាមគុណ និងអានិសង្សក្នុងការចេញបួស ទើបលះកាមទាំងឡាយ ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី បំពេញកសិណបរិកម្ម ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ សម្ងំដោយសេចក្តីសុខ ដែលកើតអំពីឈាន ក្នុងកាលតមក មានបរិវារច្រើន មានតាបស ៥០០ ចោមរោម ជាសាស្តារបស់គណៈហើយ ។ កាលនោះ មានកូនពស់មួយលូនទៅតាមធម្មតារបស់ខ្លួន រហូតដល់អាស្រមបទរបស់តាបសមួយរូប ។ តាបសឃើញហើយ កើតសេចក្តីស្រឡាញ់ដូចកូន ទើបចាប់យក

មកចិញ្ចឹម ឲ្យដេកក្នុងបំពង់ឫស្សី ព្រោះពស់នោះដេកក្នុងបំពង់ឫស្សី ទើបតាបសទាំងឡាយឲ្យឈ្មោះថា វេឡុកៈ ព្រោះតាបសនោះចិញ្ចឹមពស់នោះដោយសេចក្តីស្រឡាញ់ដូចជាកូន ទើបតាបសទាំងឡាយឲ្យឈ្មោះថា វេឡុកបិតា ។ កាលនោះ ព្រះពោធិសត្វបានឮដំណឹងថា តាបសមួយរូប ចិញ្ចឹមអាសិរពិស ទើបហៅមកសួរថា បានឮថា អ្នកចិញ្ចឹមអាសិរពិសឬ កាលតាបសនោះឆ្លើយថា ពិត ក៏ពោលដាស់តឿនថា ឈ្មោះថា អាសិរពិស ទុកចិត្តមិនបានឡើយ អ្នកកុំចិញ្ចឹមវា តាបសឆ្លើយថា បពិត្រលោកអាចារ្យ ពស់នោះ ដូចកូនរបស់ខ្ញុំ ខ្ញុំមិនអាចព្រាត់ប្រាសវាបាន ព្រះពោធិសត្វដាស់តឿនទៀតថា បើដូច្នោះ អ្នកនឹងដល់នូវការស្លាប់ ព្រោះជិតស្និទ្ធនឹងពស់នោះ ។ តាបសនោះមិនជឿពាក្យរបស់ព្រះពោធិសត្វ និងមិនអាចលែងអាសិរពិស បន្ទាប់អំពីនោះ កន្លងមក ២-៣ ថ្ងៃប៉ុណ្ណោះ តាបសទាំងឡាយ ក៏នាំគ្នាទៅរកមហាផល កាលដល់ទីហើយ ក៏ឃើញថា ផ្លែឈើរកបានងាយ ស្នាក់នៅក្នុងទីនោះឯង ២-៣ ថ្ងៃ សូម្បីតាបសវេឡុកបិតា កាលទៅជាមួយតាបសនោះ ក៏ឲ្យអាសិរពិសដេកក្នុងបំពង់ឫស្សី បិទបំពង់ហើយ ទើបទៅ លុះកន្លងទៅ ២-៣ ថ្ងៃ ទើបត្រឡប់មកព្រមជាមួយពួកតាបស គិតថា អញនឹងឲ្យអាហារដល់វេឡុកៈ បើកបំពង់ឫស្សីហើយ ពោលថា មកចុះកូន អ្នកប្រហែលជាឃ្លានហើយ លូកដៃចូលទៅ អាសិរពិសក្រោធ ព្រោះអត់អាហារអស់ ២ ឬ ៣ ថ្ងៃ ទើបចឹកដៃដែលលូកចូលទៅ ធ្វើឲ្យតាបសដល់នូវការអស់ជីវិតត្រង់នោះឯង ហើយក៏លូនចូលព្រៃ ។ តាបសទាំងឡាយឃើញដូច្នោះ ក៏ប្រាប់

ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វប្រាប់ឲ្យធ្វើសរីរកិច្ចរបស់តាបសដែលអស់ជីវិត ហើយអង្គុយត្រង់កណ្តាលពួកឥសី ពោលគាថានេះ ទូន្មានពួកឥសីថា

បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុកៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ សោ និហតោ សេតិ** សេចក្តីថា បុគ្គលណា មិនជឿពាក្យប្រៀនប្រដៅរបស់ឥសីទាំងឡាយ បុគ្គលនោះ រមែងដល់នូវការវិនាសធំ ត្រូវវិបត្តិកម្ចាត់ ដេកស្លាប់ ដូចតាបសនេះ ត្រូវកម្ចាត់ឲ្យដល់នូវការស្អុយរលួយ ដេកស្លាប់ ដោយអំណាចមាត់អាសិរពិស ដូច្នោះ ។

ព្រះពោធិសត្វពោលទូន្មានឥសីយ៉ាងនេះហើយ អប់រំព្រហ្មវិហារ ៤ ឲ្យចម្រើនហើយ លុះអស់អាយុ ក៏ទៅកើតក្នុងព្រហ្មលោក ។

សូម្បីព្រះបរមសាស្តាក៏ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលប្រដៅក្រ សូម្បីក្នុងកាលមុន អ្នកក៏ជាអ្នកប្រដៅក្រដូចគ្នា ព្រោះភាពជាបុគ្គលប្រដៅក្រ ទើបដល់នូវការស្អុយរលួយ ព្រោះមាត់អាសិរពិសជាហេតុ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា វេឡុកបិតាក្នុងកាលនោះ ជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ បរិស័ទដ៏សេស គឺពុទ្ធបរិស័ទ ព្រះសាស្តារបស់គណៈឥសី គឺតថាគតនេះឯង ។៚

# សុត្តន្តបិដក

## មកសជាតក

[ ៤៤ ] ( ឈ្មោះពោធិសត្វពោលថា ) បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថា អញនឹងសម្លាប់មូស ត្រឡប់ជាបំបែកក្បាលបិតាវិញ ។

**មកសជាតកទី ៤ ចប់**

# អដ្ឋកថា

## មកសជាតក

[ ៤៤ ] ព្រះសាស្តា កាលយាងចារិកទៅក្នុងពួកជនអ្នកមគធៈ ទ្រង់ប្រារព្ធអ្នកស្រុកដែលជាបុគ្គលពាល ក្នុងស្រុកមួយកន្លែង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សេយ្យោ អមិត្តោ** ដូច្នេះជាដើម ។

បានឮមកថា ក្នុងសម័យមួយ ព្រះតថាគតយាងចេញអំពីនគរសាវត្ថីទៅកាន់ដែនមគធៈ ខណៈកំពុងយាងចារិកទៅក្នុងដែនមគធៈនោះ ទ្រង់ដល់តំបន់មួយ ។ ស្រុកនោះ កុះករទៅដោយពួកមនុស្សអន្ធពាល ។ ថ្ងៃមួយ ពួកអន្ធពាលប្រជុំប្រឹក្សាគ្នាថា អ្នកទាំងឡាយ ពួកមូសចោមរោមខាំយើង ខណៈដែលទៅធ្វើការងារក្នុងព្រៃ ព្រោះហេតុនោះ ការងាររបស់យើងទាំងឡាយទើបដាច់ទៅ ពួកយើងនឹងកាន់ធ្នូ អាវុធគ្រប់ដៃនោះឯង នាំគ្នាទៅច្បាំងនឹងមូស សម្លាប់វាចោល ចាក់ទម្លុះវាចោលឲ្យស្លាប់អស់ ដូច្នេះហើយ នាំគ្នាទៅព្រៃ ដោយបំណងថា អញនឹងបាញ់ហ្វូងមូស បែរជាបាញ់គ្នាឯង គ្រប់គ្នាដល់នូវការរបួស ត្រឡប់មកដេកក្នុងស្រុកក៏មាន កណ្តាលស្រុកក៏មាន ត្រង់ទ្វារស្រុកក៏មាន ។ ព្រះសាស្តា ចោមរោមដោយភិក្ខុសង្ឃ យាងទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ពួកជនដែលជាបណ្ឌិតដ៏សេសឃើញព្រះមានព្រះភាគទើបសាងមណ្ឌបត្រង់ទ្វារស្រុក ថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយបង្គំព្រះសាស្តា អង្គុយហើយ ។ គ្រានោះ ព្រះសាស្តាទតឃើញមនុស្សទាំងឡាយ ដេករបួសក្នុងទីនោះៗ ក៏ត្រាស់សួរឧបាសកទាំងនោះថា ជនទាំងនេះធ្វើអ្វី ទើបត្រូវរបួសជាច្រើន ឧបាសកទាំងនោះក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងនេះ មូលគំនិតគ្នាថា ពួកយើងនឹងធ្វើចម្បាំងនឹងហ្វូងមូស ហើយនាំគ្នាទៅ បែរជាច្បាំងគ្នាឯង ត្រូវរបួសគ្រប់គ្នា ។ ព្រះសាស្តាត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលពួកមនុស្សអន្ធពាលគិតគ្នាថា យើងនឹងប្រហារមូស បែរជាប្រហារខ្លួនឯង សូម្បីក្នុងកាលមុន ក៏ធ្លាប់គិតថា នឹងប្រហារមូស តែបែរជាប្រហារអ្នកដទៃ មកហើយដូចគ្នា ហើយទ្រង់តុណ្ហី ។ កាលពួកមនុស្សទាំងនោះទូលអារាធនា ទ្រង់នាំអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ព្រះពោធិសត្វចិញ្ចឹមជីវិតដោយការជួញដូរ ។ កាលនោះ ត្រង់ស្រុកជាយដែនមួយកន្លែង ក្នុងដែនកាសី មានពួកជាងឈើអាស្រ័យនៅច្រើនជាមួយគ្នា ។ ជាងឈើក្បាលតម្ពែកម្នាក់ ក្នុងស្រុកជាងឈើទាំងនោះ កំពុងចាំងឈើ ខណៈនោះ មានមូសមួយហើរមកទំត្រង់ក្បាល ដែលដូចគ្នានឹងផ្តិលមាសដែលផ្កាប់ ហើយខាំដោយចំពុះ ដូចគ្នានឹងប្រហារដោយលំពែង ។ ទើបជាងឈើប្រាប់កូនរបស់ខ្លួន ដែលកំពុងអង្គុយជិតថា នែកូន មូសខាំក្បាលឪពុក ឈឺដូចត្រូវចាក់ដោយលំពែង ចូរសម្លាប់វាចោល ។ កូនពោលថា សូមពុកនៅឲ្យស្ងៀម ខ្ញុំនឹងសម្លាប់វា ដោយការប្រហារត្រឹមតែម្តងប៉ុណ្ណោះ ។ ក្នុងកាលនោះ ព្រះពោធិសត្វ កំពុងត្រាច់ស្វែងរកទំនិញរបស់ខ្លួន ដល់ស្រុកនោះអង្គុយសម្រាកក្នុងរោងរបស់ជាងឈើនោះ ។ ដំណាលគ្នានឹងពេលដែលជាងឈើនោះប្រាប់កូនថា នែកូន ដេញមូសនេះ កូនទទួលថា ខ្ញុំនឹងដេញវា និយាយ

បណ្តើរ ផាវពូថៅធំដ៏មុត ឈរខាងក្រោយខ្នងឪពុក កាប់ពេញទំហឹង ដោយគិតថា នឹងប្រហារមូស ក៏ពុះក្បាលឪពុកជា ២ ចម្រៀក ។ ជាងឈើដល់នូវការស្លាប់ក្នុងទីនោះឯង ។ ព្រះពោធិសត្វឃើញការធ្វើរបស់កូនជាងឈើហើយ បានគិតថា សូម្បីបច្ចាមិត្រដែលជាបណ្ឌិត ក៏គង់ល្អជាង ព្រោះបុគ្គលនោះ គង់ខ្លាចអាជ្ញាផែនដី មិនដល់ថ្នាក់សម្លាប់មនុស្ស ហើយពោលគាថានេះថា

បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថា អញនឹងសម្លាប់មូស ត្រឡប់ជាបំបែកក្បាលបិតាវិញ ។

បណ្តាបទទាំងនោះ បទថា **សេយ្យោ** សេចក្តីថា ប្រសើរ គឺឧត្តម ។ បទថា **មតិយា ឧបេតោ** បានដល់ ប្រកបដោយបញ្ញា ។

បទថា **ឯឡមូគោ** បានដល់ ល្ងីល្ងើ គឺល្ងង់ខ្លៅ ។ បទថា **បុត្តោ បិតុ អព្ភិទា ឧត្តមង្គំ** សេចក្តីថា ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ខ្លៅសូម្បីជាកូនក៏គិតថា អញនឹងសម្លាប់មូស ក៏គង់ពុះក្បាលរបស់ឪពុកជា ២ ចម្រៀក ព្រោះហេតុនោះ បណ្ឌិត ទោះជាសត្រូវ ក៏គង់ល្អជាងមិត្រដែលល្ងង់ខ្លៅ ។

ព្រះពោធិសត្វ កាលពោលគាថានេះហើយ ក៏ក្រោកឡើងធ្វើការផាវតាមនាទីរបស់ខ្លួន ។ ពួកញាតិក៏បានរៀបចំធ្វើសរីរកិច្ចរបស់ជាងឈើ ។

ព្រះសាស្តាត្រាស់ថា ម្នាលឧបាសកទាំងឡាយ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានមនុស្សដែលបានគិតថា អញនឹងប្រហារមូស តែបែរជាប្រហារអ្នកដទៃមកហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ឈ្មោញដែលជាបណ្ឌិតពោលគាថាហើយចៀសចេញទៅ បានជាតថាគតនេះឯង ។ល។

**អដ្ឋកថាមកសជាតក ចប់**

# សុត្តន្តបិដក

## រោហិណីជាតក

[ ៤៥ ] *( សេដ្ឋីពោធិសត្វពោលថា ) បុគ្គលជាសត្រូវ តែជាអ្នកប្រាជ្ញ ប្រសើរជាង ឯបុគ្គលពាល ជាអ្នកទំនុកបម្រុង មិនប្រសើរឡើយ អ្នកចូរមើលទាសីឈ្មោះរោហិណី ជាស្រីអាក្រក់ សម្លាប់ម្តាយ ហើយសោកសៅ ។*

***រោហិណីជាតកទី ៥ ចប់***

# អដ្ឋកថា

## រោហិណិជាតក

[ ៤៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទាសីរបស់អនាថបិណ្ឌកសេដ្ឋីម្នាក់ មានពាក្យផ្តើមថា **សេយ្យោ អមិត្តោ** ដូច្នេះជាដើម ។

បានឮមកថា អនាថបិណ្ឌិកសេដ្ឋី មានទាសីម្នាក់ ឈ្មោះរោហិណី ថ្ងៃមួយ មាតារបស់ទាសីដែលជាស្រីចាស់ មកដេកក្នុងរោងក្បឿង ។ ហ្វូងរុយចោមរោមមាតារបស់នាងរោហិណីនោះ ខាំឈឺដូចចាក់ដោយម្ជុល ទើបនាងប្រាប់កូនស្រីថា នែនាង រុយចោមរោមខាំម៉ែ ចូរនាងដេញវា នាងទទួលពាក្យថា ចាំម៉ែ ខ្ញុំនឹងដេញវា គិតក្នុងចិត្តថា អញនឹងវាយរុយដែលរោមខ្លួនរបស់ម៉ែឲ្យស្លាប់ ឲ្យដល់នូវសេចក្តីវិនាស ហើយក៏ងារអង្រែបុកអង្ករ វាយមាតាស្លាប់មួយរំពេច ។ កាលឃើញម្តាយស្លាប់ហើយ ក៏ទ្រហោយំថា ម៉ែរបស់ខ្ញុំស្លាប់ហើយ ទើបមនុស្សទាំងឡាយប្រាប់រឿងរ៉ាវដល់លោកសេដ្ឋី ។ លោកសេដ្ឋីបានធ្វើសរីរកិច្ចតាមសមគួរហើយ ក៏ទៅកាន់វិហារ ក្រាបទូលរឿងរ៉ាវទាំងអស់ដល់ព្រះបរមសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងទាសីនេះ ប្រហារមាតារបស់ខ្លួនស្លាប់ដោយអង្រែ ព្រោះបំណងថា នឹងប្រហាររុយដែលរោមមាតា សូម្បីក្នុងកាលមុន ក៏ធ្លាប់ប្រហារមាតាឲ្យស្លាប់ ដោយអង្រែមកហើយដូចគ្នា សេដ្ឋីទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី កាលបិតាអស់ជីវិត ក៏គ្រប់

គ្រងតំណែងសេដ្ឋី ។ សេដ្ឋីនោះមានទាសីម្នាក់ ឈ្មោះរោហិណីដូចគ្នា ។ កាល មាតាមកកាន់រោងក្បឿង ប្រាប់ឲ្យដេញរុយថា នែនាង ចូរនាងបក់រុយឲ្យម៉ែផង ទាសីនោះក៏បានសម្លាប់មាតារបស់ខ្លួនឲ្យស្លាប់ ដោយអង្រែយ៉ាងនេះឯងដូច គ្នា ។ កាលមាតាអស់ជីវិត ក៏ស្រែកយំ ។ ព្រះពោធិសត្វស្តាប់រឿងនោះ ហើយ ត្រិះរិះថា សូម្បីជាសត្រូវ ក៏សូមឲ្យតែជាបណ្ឌិតចុះ គង់ប្រសើរពិត ហើយពោលគាថានេះថា

*បុគ្គលជាសត្រូវ តែជាអ្នកប្រាជ្ញ ប្រសើរជាង ឯបុគ្គលពាល ជា អ្នកទំនុកបម្រុង មិនប្រសើរឡើយ អ្នកចូរមើលទាសីឈ្មោះ រោហិណី ជាស្រីអាក្រក់ សម្លាប់ម្តាយ ហើយសោកសៅ ។*

បណ្តាបទទាំងនោះ បទថា **មេធាវី** បានដល់ បណ្ឌិត គឺបុគ្គលដែល មានការដឹងច្បាស់ ។ បទថា **យំ** ក្នុងបាទគាថាថា **យញ្ចេ ពាលានុកម្បកោ** នេះ លោកធ្វើជាលិង្គវិបល្លាស ។ សព្ទថា **ចេ** ជានិបាត ប្រើក្នុងអត្ថនៃនាម ។ សេចក្តីថា បណ្ឌិត ទោះជាសត្រូវ ក៏គង់ល្អជាងបុគ្គលល្ងង់ខ្លៅដែលមានចិត្ត ករុណា រាប់រយ រាប់ពាន់ដង ម្យ៉ាងទៀត បទថា **យំ** ជានិបាត ចុះក្នុងអត្ថ ថា បដិសេធ សេចក្តីថា បុគ្គលល្ងង់ខ្លៅ មានចិត្តករុណា នឹងប្រសើរបាន ដូចម្តេច ។

បទថា **ជម្មី** បានដល់ បុគ្គលឡេះឡោះ ល្ងង់ខ្លៅ ។

បទថា **មាតរំ ហន្ត្វាន សោចតិ** សេចក្តីថា នាងរោហិណីនេះ ជា បុគ្គលល្ងង់ខ្លៅ បំណងថា នឹងសម្លាប់រុយ បែរជាសម្លាប់មាតាបង្កើត ហើយ

ទ្រហោយំខ្សឹកខ្សួលដោយខ្លួនឯង ។ ដោយហេតុនេះ ក្នុងលោកនេះ សូម្បីមានសត្រូវ ក៏សូមឲ្យសត្រូវនោះជាបណ្ឌិត គង់ល្អជាងពិត ។ ព្រះពោធិសត្វកាលសរសើរបណ្ឌិត សម្ដែងធម៌ហើយ ដោយគាថានេះ ។

ព្រះសាស្ដាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងរោហិណីគិតថា អញនឹងសម្លាប់រុយ បែរត្រឡប់ជាសម្លាប់មាតា សូម្បីក្នុងកាលមុន ក៏ធ្លាប់សម្លាប់មកហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកត្រាស់ហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា មាតារបស់នាងរោហិណី ក្នុងកាលនោះ បានជាមាតាក្នុងកាលឥឡូវនេះ កូនស្រីក្នុងកាលនោះ បានជាធីតាក្នុងកាលនេះដូចគ្នា មហាសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។៚

## អដ្ឋកថា រោហិណិជាតក ចប់

# សុត្តន្តបិដក

## អារាមទូសកជាតក

[ ៤៦ ] ( បណ្ឌិតបុរសពោធិសត្វពោលថា ) ការប្រព្រឹត្តនូវសេចក្តីចម្រើន របស់អ្នកមិនឈ្លាសក្នុងហេតុចម្រើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន ( បានធ្វើប្រយោជន៍ឲ្យវិនាស ) ។

អារាមទូសកជាតកទី ៦ ចប់

# អដ្ឋកថា

## អារាមទូសកជាតក

[ ៤៦ ] ព្រះសាស្តា កាលគង់នៅក្នុងឧទ្យាន ក្នុងតំបន់មួយនាដែនកោសល ទ្រង់ប្រារព្ធអ្នកប្រទូស្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆ ៧ អនត្ថកុសលេន** ដូច្នេះជាដើម ។

បានឮមកថា កាលព្រះបរមសាស្តាចារិកទៅក្នុងដែនកោសល ដល់តំបន់មួយ កុដុម្ពិកៈម្នាក់ក្នុងស្រុកនោះ និមន្តព្រះតថាគត ឲ្យគង់នៅក្នុងចម្ការរបស់ខ្លួន ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់យាងទៅក្នុងចម្ការនេះ តាមគាប់ព្រះហឫទ័យចុះ ។ ភិក្ខុទាំងឡាយក៏នាំគ្នាក្រោកឡើង បបួលឧទ្យានបាលត្រាច់ទៅក្នុងចម្ការ ឃើញទីស្រឡះមួយកន្លែង ទើបសួរឧទ្យានបាលថា ឧបាសក ចម្ការនេះ ទីដទៃមានដើមឈើខៀវស្រងាត់ តែត្រង់នេះមិនមានដើមឈើ ឬគុម្ពឈើអ្វីឡើយ រឿងនេះ ព្រោះហេតុអ្វី ឧទ្យានបាលឆ្លើយថា បពិត្រលោកម្ចាស់ កាលដាំចម្ការនេះ មានក្មេងអ្នកស្រុកម្នាក់ កាលស្រោចទឹកដើមឈើ ត្រូវដកដើមឈើដែលទើបតែដាំក្នុងទីត្រង់នេះមើលឫសសិន ហើយទើបស្រោចទឹក ទៅតាមប្រវែងឫសជាប្រមាណ ដើមឈើដែលដាំថ្មីទាំងនោះ ក៏ក្រៀមស្ងួត ងាប់គ្មានសល់ ដោយហេតុនោះ ទើបត្រង់ទីនេះ ជាទីវាល ។ ភិក្ខុទាំងឡាយចូលទៅគាល់ព្រះបរមសាស្តា ហើយក្រាបទូលរឿងនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងអ្នកស្រុកនោះ មិនមែនបំផ្លាញចម្ការតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់ជាអ្នកបំផ្លាញចម្ការដូចគ្នា ហើយទ្រង់នាំ

អតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ពួកអ្នកស្រុកប្រកាសការលេងនក្ខត្តឫក្សក្នុងព្រះនគរ ។ តាំងអំពីបានឮសំឡេងស្គរប្រគំក្នុងថ្ងៃនក្ខត្តឫក្ស អ្នកនគរទាំងអស់ នាំគ្នាលេងនក្ខត្តឫក្ស ទៅមកយ៉ាងសុខសាន្ត ។ គ្រានោះ ឧទ្យានរបស់ព្រះរាជា មានហ្វូងស្វានៅអាស្រ័យជាច្រើន អ្នកយាមឧទ្យានគិតថា ក្នុងក្រុងមាននក្ខត្តឫក្សគគ្រឹកគគ្រេង អញប្រាប់ឲ្យស្វាទាំងនេះស្រោចទឹកដើមឈើ ហើយអញនឹងលេងនក្ខត្តឫក្សបាន ដូច្នោះហើយ ក៏ចូលទៅរកពានរមេហ្វូង សួរថា នែពានរសម្លាញ់ ឧទ្យាននេះ មានឧបការៈច្រើនដល់អ្នកទាំងឡាយ ពួកអ្នកបាននាំគ្នាទំពាស៊ីផ្កាឈើផ្លែឈើ និងត្រួយឈើក្នុងឧទ្យាននេះ ឥឡូវនេះ ក្នុងព្រះនគរកំពុងមានបុណ្យនក្ខត្តឫក្សគគ្រឹកគគ្រេង ខ្ញុំទៅលេងនក្ខត្តឫក្សនឹងគេ ចូរពួកអ្នកជួយស្រោចដើមឈើដែលកំពុងដាំថ្មីៗ ក្នុងឧទ្យាននេះ ទម្រាំខ្ញុំមក តើបានឬទេ ពានរមេហ្វូងទទួលថា សាធុ ពួកខ្ញុំនឹងស្រោចឲ្យ ។ ឧទ្យានបាលក៏បញ្ជាក់ថា បើដូច្នោះ ចូរពួកអ្នកថែរក្សាកុំប្រមាទ រៀបចំក្អមស្បែក និងក្អមឈើសម្រាប់ដងទឹកឲ្យពួកស្វាហើយក៏ទៅ ។ ពួកពានរ នាំគ្នាកាន់ក្អមស្បែក និងក្អមឈើស្រោចដើមឈើ ។ ពេលនោះ ស្វាមេហ្វូងនិយាយនឹងពានររបស់ខ្លួនយ៉ាងនេះថា នែអ្នកទាំងឡាយ ធម្មតាទឹកជារបស់គប្បីថែរក្សា ពួកអ្នកនឹងស្រោចដើមឈើ ត្រូវដកដើមឈើឡើងមើលឫស ប្រសិនដើមឈើណាឫសវែង ត្រូវស្រោចទឹកច្រើន ដើមឈើណាឫសខ្លី ស្រោចតែបន្តិច ព្រោះនៅពេលក្រោយ ទឹកយើងរកបាន

ដោយលំបាក ។ ពួកពានរទទួលថា សាធុ ហើយនាំគ្នាធ្វើតាមនោះ ។ គ្រា នោះ មានបុរសឈ្លាសវៃម្នាក់ ឃើញពួកស្វាក្នុងព្រះរាជឧទ្យានទាំងនោះ នាំ គ្នាធ្វើដូច្នោះ ទើបពោលថា នែពានរទាំងឡាយ ហេតុអ្វី ទើបអ្នកដកដើម ឈើតូចៗ ហើយស្រោចទឹកតាមប្រមាណឫសយ៉ាងនេះ ពួកពានរឆ្លើយថា ពានរជាប្រធាន ប្រាប់យ៉ាងនេះ ។ បណ្ឌិតស្តាប់ពាក្យនោះហើយ ត្រិះរិះថា ឱហ្ន៎ ! ស្វាល្ងង់ មិនឈ្លាស គិតថា នឹងធ្វើប្រយោជន៍ បែរជាធ្វើសេចក្តី វិនាសទៅវិញ ហើយពោលគាថានេះថា

ការប្រព្រឹត្តនូវសេចក្តីចម្រើន របស់អ្នកមិនឈ្លាសក្នុងហេតុ ចម្រើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន ( បានធ្វើ ប្រយោជន៍ឲ្យវិនាស ) ។

បណ្តាបទទាំងនោះ បទថា វេ ត្រឹមតែជានិបាត ។

បទថា **អនត្ថកុសលេន** សេចក្តីថា បុគ្គលឈ្លាសក្នុងការដែលមិនមែន ជាប្រយោជន៍ គឺក្នុងការដែលមិនមែនជាទីកើតនៃប្រយោជន៍ ឬបានដល់អ្នក ដែលមិនឈ្លាសក្នុងប្រយោជន៍ គឺក្នុងហេតុដែលជាទីកើតនៃប្រយោជន៍ ។

បទថា **អត្ថចរិយា** បានដល់ ធ្វើនូវសេចក្តីចម្រើន ។

បទថា **សុខាវហា** សេចក្តីថា បុគ្គលមិនឈ្លាសក្នុងប្រយោជន៍បែបនេះ មិនអាចបំពេញប្រយោជន៍ ពោល គឺសេចក្តីសុខផ្លូវកាយ និងសេចក្តីសុខ ផ្លូវចិត្ត បានដល់ មិនអាចនាំសេចក្តីសុខមកឲ្យបានឡើយ សួរថា ព្រោះហេតុ

អ្វី ឆ្លើយថា ព្រោះថា បុគ្គលល្ងង់ រមែងធ្វើប្រយោជន៍ឲ្យវិនាស បានដល់ បុគ្គលល្ងង់ គិតថា អញនឹងបំពេញប្រយោជន៍ ក៏បានតែធ្វើប្រយោជន៍ឲ្យ វិនាសទៅ បុគ្គលនោះ រមែងធ្វើតែអំពីដែលឥតប្រយោជន៍ ដោយចំណែក មួយប៉ុណ្ណោះ ។

បទថា **កបិ អារាមិកោ យថា** សេចក្តីថា ស្វាដែលបានទទួលនាទី មើលថែឧទ្យាន ប្រកបកិច្ចការក្នុងឧទ្យាន គិតថា អញនឹងធ្វើប្រយោជន៍ ក៏ធ្វើ បានតែការដែលមិនប្រយោជន៍ប៉ុណ្ណោះ យ៉ាងណា បុគ្គលដែលមិនឈ្លាសក្នុង ប្រយោជន៍ទូទៅ ក៏ដូច្នោះ មិនអាចប្រព្រឹត្តប្រយោជន៍ នាំសេចក្តីសុខមកឲ្យ បុគ្គលណាបានឡើយ បានតែញុំាងប្រយោជន៍នោះឯង ឲ្យវិនាសទៅប៉ុណ្ណោះ បុរសដែលជាបណ្ឌិតនោះ តិះដៀលពានរមេហ្វូងដោយគាថានេះហើយ ក៏នាំ បរិស័ទរបស់ខ្លួន ចេញអំពីឧទ្យានទៅ ដោយប្រការដូច្នេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងអ្នកស្រុកនេះ មិនមែន ទើបតែប្រទូស្តចម្ការក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បាន ប្រទូស្តចម្ការមកហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ បន្តអនុសន្ធិ ប្រជុំជាតកថា ពានរមេហ្វូងក្នុងកាលនោះ មកកើតជាក្មេងអ្នក ស្រុកដែលបំផ្លាញចម្ការក្នុងកាលឥឡូវនេះឯង ឯបុរសដែលជាបណ្ឌិតក្នុង កាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាអារាមទូសកជាតក ចប់**

# សុត្តន្តបិដក

## វារុណិទូសកជាតក

[ ៤៧ ] ( សេដ្ឋីពោធិសត្វពោលថា ) ការប្រព្រឹត្តនូវសេចក្តីចម្រើន របស់អ្នកមិនឈ្លាសក្នុងហេតុចម្រើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចកោណ្ឌញ្ញបានញុាំងសុរាឲ្យវិនាស ។

វារុណិទូសកជាតកទី ៧ ចប់

# សុត្តន្តបិដក

## វារុណិទូសកជាតក

[៤៧] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុគ្គលបំផ្លាញស្រា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន វេ អនត្ថកុសលេន** ដូច្នេះជាដើម ។

បានឮមកថា ឈ្មួញស្រាម្នាក់ ជាសម្លាញ់របស់អនាថបិណ្ឌិក ផ្សំស្រាមានរសឆ្ងាញ់ លក់បានមាសប្រាក់ច្រើន ។ ថ្ងៃមួយ កាលមហាជនប្រជុំគ្នាក្នុងរានផ្សារ ទើបប្រាប់កូនឈ្នួលថា នែបា ពួកអ្នកចូរលក់ស្រាតាមតម្លៃដែលគេទិញ ហើយក៏ទៅងូតទឹក ។ កូនឈ្នួល កាលលក់ស្រាឲ្យមហាជន ឃើញមនុស្សទាំងនោះ ឲ្យយកអំបិលមកក្រេមបណ្តើរៗ ទើបគិតថា ស្រានេះប្រហែលជាមិនប្រៃ អញត្រូវថែមអំបិល ដូច្នេះហើយ ដាក់អំបិលក្នុងស្រាប្រមាណមួយនាឡិ ដួសលក់ឲ្យដល់ជនទាំងនោះ ។ មនុស្សទាំងនោះផឹកពេញមាត់ហើយ ក៏ខ្ជាក់ចោល សួរថា អ្នកធ្វើដូចម្តេច កូនឈ្នួលលក់ស្រាតបថា ខ្ញុំឃើញពួកលោកផឹកស្រា ហើយឲ្យយកអំបិលមកទំពាស៊ី ទើបខ្ញុំដាក់អំបិលចូលទៅ មនុស្សទាំងនោះនាំគ្នាតិះដៀលកូនឈ្នួលនោះថា វ៉ឺយ បុរសល្ងង់ហេតុអ្វីធ្វើស្រាល្អបែបនេះឲ្យខូចអស់ ហើយក្រោកឡើងចៀសចេញអស់ទៅ ។ ឈ្មួញស្រាត្រឡប់មក មិនឃើញអ្នកផឹក សូម្បីតែម្នាក់ ទើបសួរថា ពួកអ្នកផឹកស្រាទៅណាអស់ ទើបកូនឈ្នួលប្រាប់រឿងនោះឲ្យជ្រាប ។ លំដាប់នោះ ឈ្មួញស្រាតិះរិះថា វ៉ឺយ បុគ្គលល្ងង់ ឯងធ្វើស្រាល្អឲ្យខូចអស់ ហើយប្រាប់ហេតុឲ្យអនាថបិណ្ឌិកជ្រាប ។ អនាថបិណ្ឌិកសេដ្ឋីតិះរិះថា ឥឡូវនេះ អញ

មានរឿងនៃការប្រកបកថាមគ្គហើយ ទៅកាន់វិហារជេតពន ថ្វាយបង្គំព្រះបរមសាស្តា ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលបុគ្គលនេះធ្វើស្រាឲ្យវិនាស សូម្បីក្នុងកាលមុន ក៏ធ្វើស្រាឲ្យវិនាសហើយដូចគ្នា ។ កាលអនាថបិណ្ឌិកក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី ក្រុងពារាណសី ។ ឈ្មួញស្រាម្នាក់នៅអាស្រ័យសេដ្ឋីនោះចិញ្ចឹមជីវិត ។ ថ្ងៃមួយ ឈ្មួញស្រាផ្សំរសស្រាឆ្ងាញ់ហើយ ក៏ប្រាប់កូនឈ្នួលថា ចូរអ្នកលក់ស្រាទាំងនេះ ហើយក៏ទៅងូតទឹក ។ ឈ្មួញចេញផុតទៅប៉ុណ្ណោះ បុរសនោះក៏យកអំបិលដាក់ក្នុងស្រា ធ្វើឲ្យស្រាខូចអស់ ដោយន័យមុននោះឯង ។ កាលឈ្មួញត្រឡប់មក បានជ្រាបរឿងរបស់កូនឈ្នួលហើយ ទៅជម្រាបឲ្យលោកសេដ្ឋីជ្រាប ។ សេដ្ឋីពោលថា ធម្មតា បុគ្គលល្ងង់ មិនយល់ ប្រយោជន៍គិតថា នឹងធ្វើប្រយោជន៍ បែរជាធ្វើឲ្យខូចប្រយោជន៍ទៅវិញ ដូច្នេះហើយ ពោលគាថានេះថា

ការប្រព្រឹត្តនូវសេចក្តីចម្រើនរបស់អ្នកមិនឈ្លាស ក្នុងហេតុចម្រើន
រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រ-
យោជន៍ឲ្យសាបសូន្យ ដូចកោណ្ឌញ្ញបានញុំាងសុរាឲ្យវិនាស ។

បណ្តាបទទាំងនោះ បទថា **កោណ្ឌញ្ញោ វារុណឹ យថា** សេចក្តីថា កូនឈ្នួលរបស់ឈ្មួញស្រានេះ ឈ្មោះថា កោណ្ឌញ្ញៈ គិតថា អញនឹងធ្វើនូវ

ប្រយោជន៍ ដាក់អំបិលក្នុងស្រា ធ្វើស្រាឲ្យខូចរសអស់តម្លៃ ត្រូវចាក់ចោល យ៉ាងណា មនុស្សដែលមិនឈ្លាសក្នុងប្រយោជន៍ទូទៅ ក៏ធ្វើប្រយោជន៍ឲ្យខូចទៅបាន ដូច្នោះ ។ ព្រះពោធិសត្វសម្តែងធម៌ដោយគាថានេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលបុគ្គលនេះធ្វើស្រាឲ្យវិនាសទៅនោះទេ សូម្បីក្នុងកាលមុន ក៏ធ្វើស្រាឲ្យវិនាសដូចគ្នា ដូច្នេះហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា បុរសដែលធ្វើស្រាឲ្យខូចក្នុងកាលនោះ បានជាបុគ្គលដែលធ្វើស្រាឲ្យវិនាសក្នុងកាលឥឡូវនេះ ឯសេដ្ឋីក្រុងពារាណសី គឺតថាគតនេះឯង ។ល។

**អដ្ឋកថាវារុណិទូសកជាតក ចប់**

# សុត្តន្តបិដក

## វេទព្វជាតក

[ ៤៨ ] ( កូនសិស្សពោធិសត្វពោលថា ) បុគ្គលណា ប្រាថ្នាសេចក្តីចម្រើន ដោយខុសឧបាយ បុគ្គលនោះ រមែងលំបាក ដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្វព្រាហ្មណ៍ ចោរទាំងអស់នោះ ក៏ដល់នូវសេចក្តីវិនាស ។

*វេទព្វជាតកទី ៨ ចប់*

# អដ្ឋកថា

## វេទព្ភជាតក

[ ៤៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **អនុបាយេន យោ អត្ថំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ព្រះសាស្ដាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលប្រដៅក្រ សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រដៅក្រដូចគ្នា ព្រោះមិនធ្វើតាមពាក្យរបស់បណ្ឌិត ត្រូវកាប់ដោយដាវដាច់ជា ២ កំណាត់ ដេកស្លាប់កណ្ដាលផ្លូវ ព្រោះអាស្រ័យអ្នកតែម្នាក់ អ្នកដទៃ ១០០០ នាក់ ក៏ត្រូវអស់ជីវិតទៅដែរ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី មានព្រាហ្មណ៍ម្នាក់ ក្នុងតំបន់មួយ ចេះមន្តឈ្មោះវេទព្ភៈ ។ បានឮថា មន្តនោះ មានតម្លៃកាត់ថ្លៃមិនបាន គួរបូជាក្រៃលែង កាលបានឫកហើយ ម្ចាស់របស់មន្ត រាយមន្តនោះ ងើយមើលអាកាស ភ្លៀងកែវ ៧ ប្រការ ក៏ធ្លាក់ចុះមកអំពីអាកាស ។ គ្រានោះ ព្រះពោធិសត្វ រៀនសិប្បៈក្នុងសម្នាក់របស់ ព្រាហ្មណ៍នោះ ។ ថ្ងៃមួយ ព្រាហ្មណ៍បបួលព្រះពោធិសត្វចេញចាកស្រុកនៃខ្លួន ធ្វើដំណើរទៅកាន់ដែនចេតី ដោយធុរៈណាមួយ ។ ក្នុងរវាងផ្លូវជាជង្រៃមួយ មានចោរឈ្មោះបេសនកៈ ប្រមាណ ៥០០ នាក់ នៅស្កាត់ផ្លូវ ។ ពួកចោរទាំងនោះ បានចាប់ព្រះពោធិសត្វ និងវេទព្ភព្រាហ្មណ៍ ។

ព្រោះហេតុអ្វី ទើបពួកចោរនេះ ឈ្មោះថា បេសនកចោរ ព្រោះបានឮថា ចោរនេះ បើចាប់បានមនុស្ស ២ នាក់ ហើយប្រើមនុស្សម្នាក់ទៅយកប្រាក់មកឲ្យពួកវា ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយ ហៅចោរនោះថា បេសនកចោរ ពួកចោរទាំងនោះ ពួនត្រង់បរិវេណព្រៃមួយ បើចាប់ឪពុក និងកូនបាន ក៏និយាយនឹងឪពុកថា ចូរទៅយកទ្រព្យមកឲ្យយើង សឹមទទួលយកកូនទៅ ដោយទំនងនេះ ។ បើចាប់ម៉ែ និងកូនស្រីបាន ក៏លែងម៉ែទៅ បើចាប់បង និងប្អូនបាន ក៏លែងបងទៅ បើចាប់អាចារ្យ និងកូនសិស្សបាន ក៏លែងសិស្សទៅ ក្នុងគ្រានោះ ទើបពួកចោរទុកវេទព្ភព្រាហ្មណ៍ ហើយលែងព្រះពោធិសត្វ ។

ព្រះពោធិសត្វថ្វាយបង្គំអាចារ្យហើយ ពោលដាស់តឿនថា ខ្ញុំទៅត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះ សូមលោកអាចារ្យកុំភ័យខ្លាចឡើយ ម្យ៉ាងទៀត សូមធ្វើតាមពាក្យរបស់ខ្ញុំផងចុះ ក្នុងថ្ងៃនេះ នឹងមានឫក្សដែលអាចឲ្យភ្លៀង គឺទ្រព្យធ្លាក់ចុះមក សូមលោកអត់ធន់នូវសេចក្ដីលំបាក កុំរាយមន្តឲ្យប្រាក់ និងមាសធ្លាក់ចុះមកជាច់ខាត បើលោកឲ្យភ្លៀងប្រាក់ ភ្លៀងមាសធ្លាក់ចុះមកសោត ខ្លួនលោកនឹងដល់នូវសេចក្ដីអន្តរាយ ចោរទាំង ៥០០ នេះ នឹងសម្លាប់លោកចោល ។ កាលដាស់តឿនអាចារ្យយ៉ាងនេះហើយ ក៏ចេញទៅដើម្បីរកទ្រព្យឯពួកចោរ លុះព្រះអាទិត្យអស្តង្គត ក៏ចងព្រាហ្មណ៍ឲ្យដេកផ្ងារ ។ ខណៈនោះឯង ចន្ទមណ្ឌលដែលបរិបូណ៌ ក៏បានរះឡើងអំពីលោកធាតុទិសខាងកើត ។ ព្រាហ្មណ៍សម្លឹងឃើញឫក្ស គិតថា បានឫកដែលអាចឲ្យភ្លៀងប្រាក់ ភ្លៀងមាស

ហូរចុះមកបានហើយ រឿងអ្វីដែលអញត្រូវសោយទុក្ខលំបាក រាយមន្តឲ្យភ្លៀងកែវធ្លាក់ចុះមក យកទ្រព្យឲ្យពួកចោរហើយ នឹងជាឥស្សរៈទៅតាមសប្បាយ ហើយទើបហៅពួកចោរមក សួរថា នែចោរ ពួកលោកចាប់ខ្ញុំទុកដើម្បីអ្វី ពួកចោរឆ្លើយថា ដើម្បីទ្រព្យ ទើបព្រាហ្មណ៍ពោលថា នែអ្នកទាំងឡាយ បើត្រូវការទ្រព្យ ចូរស្រាយខ្ញុំដោយរហ័ស ឲ្យខ្ញុំប្រោះព្រំក្បាល ស្លៀកសំពត់សប្រោះព្រំដោយគ្រឿងក្រអូប ប្រដាប់ដោយកម្រងផ្កាហើយ គ្រប់គ្រងខ្ញុំទុកចុះ ពួកចោរស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ក៏ធ្វើតាមគ្រប់ប្រការ ។ ព្រាហ្មណ៍ដឹងឫក្សហើយ ក៏រាយមន្តសម្លឹងមើលអាកាស រំពេចនោះឯង កែវទាំងឡាយក៏ជ្រុះមកអំពីអាកាស ពួកចោរក៏នាំគ្នាកើបយកទ្រព្យដាក់ក្នុងសំពត់ស ហើយនាំទៅ ព្រាហ្មណ៍ក៏ដើរតាមពួកចោរអំពីក្រោយ ។ គ្រានោះ មានពួកចោរដទៃ ៥០០ ដូចគ្នា នាំគ្នាចាប់ចោរទាំងនោះ កាលពួកដែលត្រូវចាប់សួរថា អ្នកទាំងឡាយចាប់យើងធ្វើអ្វី ក៏ឆ្លើយថា ដើម្បីទ្រព្យ ។ ទើបពួកចោរដែលត្រូវចាប់ប្រាប់ថា បើពួកអ្នកត្រូវការទ្រព្យ សូមចាប់ព្រាហ្មណ៍នោះចុះ គាត់សម្លឹងមើលអាកាសហើយ ឲ្យទ្រព្យធ្លាក់ចុះមកបាន ទ្រព្យរបស់យើងនេះ គាត់ឲ្យនោះឯង ។ ពួកចោរក៏លែងពួកចោរដែលចាប់ ឃុំខ្លួនព្រាហ្មណ៍ទុកពោលថា ចូរអ្នកឲ្យទ្រព្យដល់ពួកយើងផងដែរ ព្រាហ្មណ៍ពោលថា ខ្ញុំត្រូវឲ្យទ្រព្យដល់អ្នកពិត តែឫក្សដែលហៅទ្រព្យ ឲ្យធ្លាក់ចុះមកបាន នៅឆ្នាំក្រោយឯណោះរាប់អំពីថ្ងៃនេះទៅ បើពួកអ្នកត្រូវការទ្រព្យ ត្រូវរង់ចាំដល់កាលនោះ ខ្ញុំនឹងឲ្យភ្លៀងទ្រព្យហូរចុះមក ។ ពួកចោរនាំគ្នាក្រោធពោលថា ថ្វីយ អាព្រាហ្មណ៍

អាក្រក់ អ្នកជទៃ ហេតុអ្វីក៏ឯងហៅភ្លៀងប្រាក់ ភ្លៀងមាសឲ្យធ្លាក់ចុះមកបាន តែដល់វេទពួកយើង ប្រាប់ឲ្យរង់ចាំរាប់ឆ្នាំ ដូច្នេះហើយ កាប់ព្រាហ្មណ៍ដាច់ជា ២ កំណាត់ដោយដាវដ៏មុត បោះចោលត្រង់ផ្លូវ លើកគ្នីគ្នាតាមទៅដោយរហ័ស បានប្រយុទ្ធជាមួយពួកចោរទាំងនោះ សម្លាប់ពួកចោរទាំងនោះអស់ ដណ្តើមយកទ្រព្យទៅ ក៏បែកគ្នាជា ២ ពួក ម្ខាង ២៥០ នាក់ កាប់សម្លាប់គ្នា ហើយបែកគ្នាជា ២ សម្លាប់គ្នាទៀត ដោយទំនងនេះ រហូតដល់សល់ ចោរ ២ នាក់ ហើយសម្លាប់គ្នាឯងស្លាប់ទាំងអស់ មនុស្ស ១០០០ ដល់នូវសេចក្តីវិនាស ដោយប្រការដូច្នេះ ។

ចោរទាំង ២ ដែលសល់ចុងក្រោយនោះ កាន់យកទ្រព្យនោះមកបាន ដោយឧបាយនោះ នាំគ្នាយកទៅលាក់ត្រង់ព្រៃស្ដុកមួយកន្លែងក្បែរស្រុក ចោរម្នាក់កាន់ដាវអង្គុយយាមទ្រព្យ ចោរម្នាក់យកអង្ករ ចូលទៅកាន់ស្រុក ដើម្បីចម្អិនជាអាហារ ។ ឈ្មោះថា សេចក្តីលោភ ជាមូលនៃសេចក្តីវិនាសនោះឯង ព្រោះដូច្នោះ ចោរដែលអង្គុយយាមទ្រព្យគិតថា បើចោរម្នាក់នោះមក ទ្រព្យនេះនឹងត្រូវចែកជា ២ ចំណែក ណ្ហើយចុះ បើវាមក អញនឹងកាប់វាដោយដាវ ក៏ចប់រឿង គិតហើយ ក៏សំលៀងដាវ អង្គុយរង់ចាំចោរនោះមក ។ ឯចោរម្នាក់ទៀតគិតថា ទ្រព្យនោះនឹងត្រូវចែកជា ២ ចំណែក បើដូច្នោះ អញយកថ្នាំពុលដាក់ក្នុងអាហារ ឲ្យអាម្នាក់នោះស៊ី អស់ជីវិតហើយ អញនឹងបានទ្រព្យតែម្នាក់ឯង ។ លុះបាយឆ្អិន ក៏ប្រញាប់ប្រញាល់បរិភោគខ្លួនឯងមុន ចំណែកដ៏សេសក៏ដាក់ថ្នាំពិស កាន់មករកជនម្នាក់ទៀតដែលនៅរង់ចាំ គ្រាន់

តែឱនដាក់អាហារ ចោរដែលនៅរង់ចាំ ក៏កាប់ដោយដាវ ដាច់ជា ២ កំណាត់ អូសទៅចោលក្នុងព្រៃ ហើយត្រឡប់មកបរិភោគអាហារនោះ ខ្លួនឯងក៏អស់ជីវិតក្នុងទីនោះឯង ។ មនុស្សទាំងអស់ដល់នូវសេចក្តីវិនាស ព្រោះអាស្រ័យទ្រព្យនោះ ដោយប្រការដូច្នេះ ។

លុះកន្លងទៅបាន ២-៣ ថ្ងៃ ព្រះពោធិសត្វកាន់យកទ្រព្យមក មិនឃើញអាចារ្យក្នុងទីនោះ ឃើញតែទ្រព្យដែលខ្ចាត់ខ្ចាយ គិតថា អាចារ្យមិនស្តាប់ពាក្យរបស់អញ ប្រហែលជាធ្វើទ្រព្យឲ្យធ្លាក់ចុះមកពិត ជនទាំងអស់ដល់នូវសេចក្តីវិនាស ដូច្នេះហើយ ដើរទៅកាន់ផ្លូវធំ ។ កាលដើរទៅដល់ ក៏ឃើញអាចារ្យដាច់ ២ កំណាត់ គិតថា អាចារ្យស្លាប់ព្រោះមិនជឿពាក្យអញ ហើយកាប់ឧស ធ្វើជាជើងថ្កូរដុតអាចារ្យ ។ បូជាដោយផ្កា ហើយធ្វើដំណើរទៅឃើញចោរ ៥០០ នាក់ស្លាប់ ដើរទៅទៀតឃើញចោរ ២៥០ ស្លាប់ ដោយលំដាប់ ក្នុងទីបំផុត ឃើញជនទាំង ២ អស់ជីវិត ទើបគិតថា បុគ្គលទាំងនេះដល់នូវសេចក្តីវិនាស ១០០០ នាក់ខ្វះ ២ នឹងត្រូវមានចោរ ២ នាក់ទៀតពិតប្រាកដ តែចោរទាំង ២ នាក់ ក៏មិនអាចរស់នៅបាន ចោរទាំង ២ នៅទីណាហ្ន៎ ដូច្នេះហើយ ធ្វើដំណើរទៅ ឃើញផ្លូវដែលចូលទៅកាន់ទីលាក់ទ្រព្យរបស់ជនទាំង ២ ដើរតទៅទៀត ក៏ឃើញគំនរទ្រព្យ ដែលដាក់ក្នុងបង្វេចទុក ឃើញចោរម្នាក់ស្លាប់ក្បែរថាសបាយ ក្នុងលំដាប់នោះ ក៏កំណត់ហេតុទាំងអស់បានថា ចោរទាំងនោះនឹងត្រូវធ្វើយ៉ាងនេះ ហើយក៏គិតថា បុរសនោះនៅឯណា រកមើលក៏ឃើញចោរម្នាក់នោះនៅក្នុងគុម្ពោតព្រៃ ទើបគិតថា អាចារ្យ

របស់អញ មិនធ្វើតាមពាក្យអញ ព្រោះជាអ្នកប្រដៅក្រ ក៏ដល់នូវសេចក្ដីវិនាស មិនតែប៉ុណ្ណោះ ធ្វើឲ្យអ្នកដទៃ ១០០០ ដល់នូវការវិនាសទៅ អនិច្ចាហ្ន៎ បុគ្គលដែលប្រាថ្នាសេចក្ដីចម្រើនដល់ខ្លួន ដោយហេតុមិនមែនឧបាយ មិនមែនការណ៍ នឹងត្រូវដល់នូវសេចក្ដីវិនាសធំនោះឯង ដូចអាចារ្យរបស់អញដែលដល់នូវសេចក្ដីវិនាស ដូច្នោះហើយ ពោលគាថានេះថា

បុគ្គលណា ប្រាថ្នាសេចក្ដីចម្រើន ដោយខុសឧបាយ បុគ្គលនោះ
រមែងលំបាក ដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្ភ-
ព្រាហ្មណ៍ ចោរទាំងអស់នោះ ក៏ដល់នូវសេចក្ដីវិនាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោ វិហញ្ញតិ** សេចក្ដីថា បុគ្គលនោះគិតថា អញប្រាថ្នាប្រយោជន៍ គឺសេចក្ដីចម្រើន សេចក្ដីសុខដល់ខ្លួន ធ្វើនូវសេចក្ដីព្យាយាម ដោយហេតុដែលមិនមែនឧបាយ ក្នុងខណៈមិនមែនកាល រមែងក្ដៅក្រហាយ គឺលំបាក បានដល់ នូវសេចក្ដីវិនាសយ៉ាងធំ ។

បទថា **ចេតា** បានដល់ ពួកចោរដែលនៅក្នុងចេតរដ្ឋ ។

បទថា **ហនឹសុ វេទព្ភំ** សេចក្ដីថា ចោរអ្នកចេតរដ្ឋ នាំគ្នាសម្លាប់ព្រាហ្មណ៍ ឈ្មោះវេទព្ភៈ ព្រោះចេះមន្ដវេទព្ភៈចោលហើយ ។

បទថា **សព្វេ តេ ព្យសនមជ្ឈគុំ** សេចក្ដីថា មនុស្សទាំងអស់នោះសម្លាប់គ្នាឯង ដល់នូវសេចក្ដីវិនាស មិនមានសេសសល់ត្រឹមតែម្នាក់ឡើយ ។

កាលមានហេតុយ៉ាងនេះ ទើបព្រះពោធិសត្វប្រកាសរំពងព្រៃថា អាចារ្យរបស់អញ ធ្វើសេចក្ដីព្យាយាមក្នុងរឿងមិនមែនឋានៈ ដោយហេតុមិនមែន

*ឧបាយ ហៅទ្រព្យឲ្យធ្លាក់ចុះមក សូម្បីខ្លួនឯង ក៏ដល់នូវការអស់ជីវិត ហើយនៅជាបច្ច័យនៃការវិនាសដល់អ្នកដទៃៗ ទៀត ៥ រយ ២ ជន យ៉ាងណា សូម្បីជនដទៃៗ ណា ដែលប្រាថ្នាប្រយោជន៍ដល់ខ្លួន នឹងធ្វើសេចក្តីព្យាយាម ដោយហេតុមិនមែនឧបាយ បុគ្គលទាំងអស់នោះ នឹងវិនាសដោយខ្លួនឯងពិត នឹងជាបច្ច័យឲ្យអ្នកដទៃវិនាសផងដែរ ដូច្នេះ កាលពួកទេវតានាំគ្នាឲ្យសាធុការ ក៏សម្តែងធម៌ដោយគាថានេះ នាំទ្រព្យនោះមកកាន់ផ្ទះរបស់ខ្លួន ដោយឧបាយដ៏ប្រពៃ ធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើម តាំងនៅដរាបដល់អាយុក្ស័យ កាលអស់ជីវិត ក៏ធ្វើស្ថានសួគ៌ឲ្យពេញបរិបូណ៌ ។*

*ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលប្រដៅក្រ សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រដៅក្រដូចគ្នា ព្រោះជាអ្នកប្រដៅក្រ ទើបដល់នូវសេចក្តីវិនាសយ៉ាងធំ ដូច្នេះ ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា វេទព្ភ-ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ឯកូនសិស្ស បានជាតថាគតនេះឯង ។៚*

**អដ្ឋកថាវេទព្ភជាតក ចប់**

# សុត្តន្តបិដក

## នក្ខត្តជាតក

[ ៤៩ ] ( បណ្ឌិតបុរសពោធិសត្វពោលថា ) ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ ដែលរាប់អាននក្ខត្តឫក្ស ( ព្រោះ ) សេចក្តីចម្រើននៃប្រយោជន៍ ឈ្មោះថានក្ខត្តឫក្ស ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

**នក្ខត្តជាតកទី ៩ ចប់**

# អដ្ឋកថា

## ឆក្ខត្តជាតក

[ ៤៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាជីវកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឆក្ខត្តំ បដិមានេន្តំ** ដូច្នេះជាដើម ។

បានឮថា កុលបុត្តស្រុកក្រៅម្នាក់ ទៅដណ្ដឹងកុលធីតាម្នាក់ ក្នុងក្រុងសាវត្ថី ឲ្យដល់កូនប្រុសរបស់ខ្លួន សន្យាគ្នាថា ក្នុងថ្ងៃនោះ នឹងមកទទួលយកកូនក្រមុំទៅ ។ លុះដល់ថ្ងៃនោះ ទើបសួរអាជីវកដែលចូលទៅកាន់ត្រកូលរបស់ខ្លួនថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ពួកខ្ញុំនឹងធ្វើមង្គលមួយ តើឫក្សល្អដែរឬទេ ។ អាជីវកនោះក្រោធ ពោលថា ជនទាំងនេះ ពីដំបូង មិនសួរអញសោះ ឥឡូវនេះ ហួសថ្ងៃទៅហើយ បែរជាមកសួរអញ ណ្ហើយចុះ អញត្រូវប្រៀនប្រដៅជនទាំងនេះខ្លះ ទើបពោលថា ថ្ងៃនេះ ឫក្សមិនល្អ ពួកអ្នកកុំធ្វើមង្គលក្នុងថ្ងៃនេះឡើយ បើនៅចចេសធ្វើ នឹងវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលនាំគ្នាជឿអាជីវកនោះ មិនទៅទទួលកូនក្រមុំក្នុងថ្ងៃនោះ ។ ឯពួកអ្នកក្រុង ចាត់ការមង្គលព្រមហើយ មិនឃើញជនទាំងនោះមក ក៏ពោលថា ជនទាំងនោះ កំណត់ថ្ងៃនេះហើយ ក៏មិនមក សូម្បីការងាររបស់ពួកយើងក៏ជិតសម្រេចហើយ រឿងអ្វីដែលត្រូវរង់ចាំជនទាំងនោះ អញលើកធីតារបស់អញឲ្យទៅអ្នកដទៃចុះ ហើយក៏លើកធីតាឲ្យដល់ត្រកូលដទៃ ដោយការមង្គលដែលបានត្រៀមនោះឯង ។ ស្អែកឡើង ទើបជនទាំងនោះនាំគ្នាមក ហើយពោលថា សូមពួកអ្នកបញ្ជូនកូនក្រមុំឲ្យពួកយើងចុះ ។ ក្នុងវេលានោះ អ្នក

ក្រុងសាវត្ថីក៏នាំគ្នា បរិភាសជនទាំងនោះថា ពួកអ្នកសមនឹងឈ្មោះជាមនុស្សស្រុកក្រៅ ខ្វះនូវភាពជាមនុស្សល្អ ជាបុគ្គលលាមក កំណត់ថ្ងៃទុកហើយមើលងាយ មិនមកតាមកំណត់ អ្នកមកផ្លូវណា អញ្ជើញទៅវិញតាមផ្លូវនោះឯង ពួកយើង លើកកូនក្រមុំឲ្យអ្នកដទៃហើយ ។ ពួកអ្នកស្រុកក្រៅក៏ឈ្លោះជាមួយអ្នកស្រុកក្នុងក្រុង កាលមិនបានកូនក្រមុំ ក៏នាំគ្នាទៅតាមផ្លូវដែលមកនោះឯង ។ រឿងដែលអាជីវកធ្វើអន្តរាយដល់មង្គលរបស់មនុស្សទាំងនោះប្រាកដទូទៅ ក្នុងរោងភិក្ខុទាំងឡាយ ភិក្ខុទាំងនោះប្រជុំគ្នាក្នុងធម្មសភា អង្គុយនិយាយគ្នាថា អាវុសោទាំងឡាយ អាជីវកធ្វើអន្តរាយការងារមង្គលរបស់ត្រកូលហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអាជីវកធ្វើអន្តរាយនូវមង្គលរបស់ត្រកូលនោះ សូម្បីក្នុងកាលមុន ក៏ក្រោធនឹងអ្នកទាំងនោះ ធ្វើអន្តរាយនូវមង្គលហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ពួកអ្នកនគរនាំគ្នាទៅដណ្តឹងធីតារបស់អ្នកជនបទ កំណត់ថ្ងៃហើយសួរអាជីវកដែលធ្លាប់ស្និទ្ធស្នាលថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ខ្ញុំធ្វើមង្គលមួយ ឫក្សល្អដែរឬទេ ។ អាជីវកនោះក្រោធហើយ ពោលថា ជនទាំងនេះកំណត់ថ្ងៃតាមគាប់ចិត្តរបស់ខ្លួន ឥឡូវនេះ បែរជាមកសួរអញ ហើយគិតថា

ក្នុងថ្ងៃនេះ អញនឹងធ្វើការរារាំងការងាររបស់ជនទាំងនោះ ហើយពោលថា ថ្ងៃនេះ ឫក្សមិនល្អ បើពួកអ្នកធ្វើការមង្គល នឹងដល់នូវសេចក្ដីវិនាសធំ ។ មនុស្សទាំងនោះ នាំគ្នាជឿអាជីវក ទើបមិនទៅទទួលកូនក្រមុំ ។ អ្នកជនបទដឹងថា ជនទាំងនោះមិនមក ក៏និយាយគ្នាថា ជនទាំងនោះ កំណត់ថ្ងៃក្នុងថ្ងៃនេះហើយ ក៏មិនមក ធុរៈអ្វីនឹងត្រូវរង់ចាំជនទាំងនោះ ពួកយើងនឹងលើកធីតាឲ្យដល់អ្នកដទៃ ។ ហើយក៏លើកធីតាឲ្យដល់អ្នកដទៃ ។ ស្អែកឡើង អ្នកក្រុងនាំគ្នាមកទទួលកូនក្រមុំ អ្នកជនបទពោលថា ពួកអ្នកឈ្មោះថា ជាអ្នកក្រុងតែខ្វះនូវភាពជាមនុស្សល្អ កំណត់ថ្ងៃហើយ តែមិនមកទទួលកូនក្រមុំ ព្រោះពួកអ្នកមិនមក ទើបខ្ញុំលើកឲ្យទៅអ្នកដទៃ ។ អ្នកក្រុងពោលថា ពួកយើងសួរអាជីវក ដឹងថា ឫក្សមិនល្អ ទើបមិនមក ចូរពួកអ្នកឲ្យកូនស្រីដល់ពួកយើងចុះ ។ អ្នកជនបទជំទាស់ថា ព្រោះពួកអ្នកមិនមក ទើបពួកយើងលើកកូនស្រីឲ្យអ្នកដទៃទៅហើយ គ្រានេះ នឹងនាំកូនក្រមុំដែលឲ្យគេទៅហើយមកវិញបានដូចម្ដេច កាលអ្នកទាំងនោះជជែកគ្នាទៅមកយ៉ាងនេះ គាប់ជួនកាលនោះ មានបុរសជាបណ្ឌិត អ្នកក្រុងម្នាក់ទៅជនបទ ដោយកិច្ចឯណានីមួយ បានឮអ្នកក្រុងទាំងនោះពោលថា ពួកយើងសួរអាជីវកហើយ ទើបមិនមក ព្រោះឫក្សមិនល្អ ក៏ពោលថា ឫក្សនឹងមានប្រយោជន៍អ្វី ព្រោះការបានកូនក្រមុំជាឫក្សទៅហើយ មិនមែនឬ ដូច្នេះហើយ ពោលគាថានេះថា

ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ ដែលរាប់អានទក្ខត្តឫក្ស
( ព្រោះ ) សេចក្ដីចម្រើននៃប្រយោជន៍ ឈ្មោះថានក្ខត្តឫក្ស ឯ

ផ្កាយទាំងឡាយ នឹងធ្វើអ្វីបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិមានេន្តំ** សេចក្ដីថា អ្នករង់ចាំមើល អធិប្បាយថា រវល់តែចាំមើលថា ឫក្សនឹងមានក្នុងឥឡូវនេះ នឹងមានក្នុងឥឡូវនេះ ។

បទថា **អត្ថោ ពាលំ ឧបច្ចគា** សេចក្ដីថា ប្រយោជន៍ ពោល គឺការបានកូនក្រមុំកន្លងបង់បុគ្គលល្ងង់ខ្លៅ ដែលជាអ្នកក្រុងនោះ ។

បទថា **អត្ថោ អត្ថស្ស នក្ខត្តំ** សេចក្ដីថា បុគ្គលស្វែងរកប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថា នក្ខត្តឫក្សនៃប្រយោជន៍ ។

បទថា **កឹ ករិស្សន្តិ តារកា** សេចក្ដីថា ផ្កាយទាំងឡាយក្នុងអាកាស ក្រៅអំពីនេះ នឹងញ៉ាំងប្រយោជន៍អ្វីឲ្យសម្រេចបាន ។

ពួកអ្នកក្រុងឈ្លោះជាមួយជនទាំងនោះហើយ ក៏មិនបានកូនក្រមុំនោះឯង នាំគ្នាទៅ ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអាជីវកនោះ ធ្វើនូវការរារាំងមង្គលរបស់ត្រកូលនោះ សូម្បីក្នុងកាលមុន ក៏បានធ្វើហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកត្រាស់ហើយ ទើបបន្តអនុសន្ធិ ប្រជុំជាតកថា អាជីវកក្នុងកាលនោះ បានមកជាអាជីវកក្នុងកាលឥឡូវនេះ ត្រកូលទាំងនោះ ក្នុងកាលនោះ ក៏បានជាត្រកូលក្នុងកាលឥឡូវនេះ ឯបុរសដែលជាបណ្ឌិត ឈរពោលគាថា បានជាតថាគតនោះឯង ។ ៕

# សុត្តន្តបិដក

## ទុម្មេធជាតក

[ ៥០ ] ( ព្រះរាជាពោធិសត្វពោលថា ) ការបូជា អញបានបួងសួង ហើយ ដោយសារមនុស្សអោប់ឥតប្រាជ្ញារាប់ពាន់នាក់ ឥឡូវនេះ អញនឹង បូជា ( ព្រោះ ) ជនមិនប្រកបដោយធម៌ច្រើននាក់ ។

ទុម្មេធជាតកទី ១០ ចប់

អត្ថកាមវគ្គទី ៥ ចប់

បឋមបណ្ណាសក ចប់

### ឧទ្ទាននៃអត្ថកាមវគ្គនោះ គឺ

និយាយអំពីមិត្តវិន្ទុក ( ក្នុងលោសកជាតក ) ១ កបោតកជាតក ១ វេឡុកជាតក ១ បុគ្គលល្ងង់ខ្លៅ ( ក្នុងមកសជាតក ) ១ រោហិណីជាតក ១ ស្វា ( ក្នុងអារាមទូសកជាតក ) ១ វារុ-ណិទូសកជាតក ១ ចោរនៅក្នុងដែនចេតៈ ( ក្នុងវេទព្វជាតក ) ១ ផ្កាយ ( ក្នុងនក្ខត្តជាតក ) ១ ការបូជា ( ក្នុងទុម្មេធជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ទុម្មេធជាតក

[ ៥០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបំពេញនូវលោកត្ថចរិយា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទុម្មេធានំ** ដូច្នេះជាដើម ។ គាថានោះ នឹងមានជាក់ច្បាស់ ក្នុងមហាកណ្ហជាតក ក្នុងទ្វាទសកនិបាតឯណោះ ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងគភ៌ របស់អគ្គមហេសីនៃព្រះរាជាអង្គនោះ ។ កាលប្រសូតចាកគភ៌មាតាហើយ ពួកញាតិថ្វាយព្រះនាមថា **ព្រហ្មទត្តកុមារ** ។ លុះមានព្រះជន្ម ១៦ វស្សា ក៏បានសិក្សាសិប្បៈក្នុងនគរតក្កសិលា ចេះចប់ត្រៃវេទ សម្រេចសិល្បសាស្ត្រ ១៨ ប្រការ ។ ក្នុងកាលតមក ព្រះរាជបិតាទ្រង់ព្រះរាជទានតំណែងឧបរាជដល់ព្រះអង្គ ។

ក្នុងកាលនោះ ប្រជាជនក្នុងក្រុងពារាណសី រាប់អានទេវតាថា ជាវត្ថុសក្តិសិទ្ធិ នាំគ្នាមស្ការទេវតា សម្លាប់ពពែ ចៀម មាន់ និងជ្រូកសន្ទឹកសន្ទាប់ ធ្វើការបួងសួង បូជាដោយកម្រងផ្កា និងគ្រឿងក្រអូបច្រើនប្រភេទ និងបូជាដោយសាច់ និងឈាម ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ឥឡូវនេះ ប្រជានុរាស្ត្រ រាប់អានទេវតាថា ជាវត្ថុសក្តិសិទ្ធិ នាំគ្នាសម្លាប់សត្វ មហាជនធ្ងន់ចិត្តក្នុងអធម៌ដោយច្រើន កាលអញបានរាជសម្បត្តិ ក្រោយអំពីព្រះបិតាសោយទិវង្គត អញនឹងមិនឲ្យសត្វសូម្បីតែមួយ ដល់នូវសេចក្តីលំបាកឡើយ ត្រូវរកឧបាយមិនឲ្យអ្នកណាម្នាក់សម្លាប់សត្វ បំបាត់ជីវិត ឲ្យទាល់តែបាន ។

ថ្ងៃមួយ ទ្រង់យាងដោយរថចេញអំពីព្រះនគរ ទតឃើញមហាជនប្រជុំគ្នា ត្រង់ដើមជ្រៃមួយដើម អ្នកណាចង់បានវត្ថុណាមួយ មានកូនប្រុស កូនស្រី យស និងទ្រព្យជាដើម ក៏នាំគ្នាបន់ក្នុងសម្នាក់របស់ទេវតា ដែលស្ថិតនៅក្នុង ដើមជ្រៃនោះ ទើបទ្រង់ចុះអំពីរថ យាងចូលទៅក្បែរដើមឈើនោះ ទ្រង់បូជា ដោយគ្រឿងក្រអូប ផ្កា កម្រង ប្រោះព្រំ ធ្វើប្រទក្សិណដើមឈើ ដូចគ្នានឹង ពួកជនដែលគោរព រាប់អាន ទេវតាថា ជាវត្ថុសក្តិសិទ្ធិ ។ ថ្វាយបង្គំទេវតា ហើយ ឡើងរថត្រឡប់ចូលព្រះនគរ ។ តាំងអំពីនោះមក ទ្រង់ក៏យាងទៅកាន់ ដើមឈើនោះរាល់ៗ គ្រា ដែលទ្រង់ទំនេរ ទ្រង់ធ្វើការបូជា ដូចជនដែលរាប់ អានទេវតាថាជាសក្តិសិទ្ធិ ដូចពណ៌នាមកហើយនោះឯង ។ សម័យក្រោយមក ព្រះរាជបិតាសោយទិវង្គត ទ្រង់បានសោយរាជ្យ ទ្រង់វៀរអគតិ ៤ ប្រការ ទ្រង់ប្រព្រឹត្តទសពិធរាជធម៌យ៉ាងម៉ឺងម៉ាត់ គ្រងរាជ្យដោយធម៌ ទ្រង់ព្រះតម្រិះ ថា មនោរថរបស់អញដល់ទីបំផុតហើយ អញតាំងនៅក្នុងរាជសម្បត្តិហើយ តែរឿងមួយដែលអញបានគិតក្នុងកាលមុននោះ ក៏នឹងត្រូវឲ្យដល់ទីបំផុតក្នុង ឥឡូវនេះ ទ្រង់មានព្រះរាជតម្រាស់ហៅពួកអមាត្យ និងប្រជានុរាស្ត្រ មាន ព្រាហ្មណ៍ គហបតីជាដើម មកប្រជុំគ្នា ត្រាស់ប្រកាសថា អ្នកដ៏ចម្រើនទាំង ឡាយ ពួកអ្នកដឹងទេថា ហេតុអ្វី ទើបខ្ញុំបានរាជសម្បត្តិ ប្រជារាស្ត្រនាំគ្នា ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំមិនដឹងទេ ។ ព្រះរាជាត្រាស់សួរថា កាលខ្ញុំបូជាដើមជ្រៃនោះ ដោយគ្រឿងក្រអូបជាដើម ផ្គងអញ្ជលីថ្វាយបង្គំ ពួកអ្នកធ្លាប់ឃើញដែរឬទេ ។ ប្រជារាស្ត្រទូលថា បពិត្រព្រះអង្គធ្លាប់ឃើញ ។

ទើបព្រះរាជាមានព្រះតម្រាស់ថា ក្នុងកាលនោះ ខ្ញុំតាំងសេចក្តីប្រាថ្នាថា បើបានរាជសម្បត្តិ នឹងធ្វើពលីកម្ម ខ្ញុំបានរាជសម្បត្តិដោយអានុភាពរបស់ទេវតានោះ ឥឡូវនេះ ខ្ញុំនឹងធ្វើពលីកម្មដល់ទេវតា ពួកអ្នកកុំយំបន្អង់ឡើយ នាំគ្នាត្រៀមពលីកម្មដល់ទេវតាដោយប្រញាប់ចុះ ។ ពួកអមាត្យជាដើមទូលសួរថា បពិត្រព្រះអង្គ ពួកខ្ញុំនឹងបានវត្ថុណា ។ ព្រះរាជាត្រាស់ថា នែអ្នកទាំងឡាយ កាលខ្ញុំបន់ទេវតា ខ្ញុំបានបន់ថា ខ្ញុំនឹងសម្លាប់មនុស្សដែលនាំគ្នាប្រព្រឹត្តកម្ម គឺទុស្សសីល ៥ ប្រការ មានសម្លាប់សត្វជាដើម និងដែលនាំគ្នាប្រព្រឹត្តអកុសលកម្មបថ ១០ ប្រការ ក្នុងរជ្ជកាលរបស់ខ្ញុំ ហើយនឹងធ្វើពលីកម្ម ដោយពោះវៀន ឈាម និងសាច់នៃមនុស្សទាំងនោះ ព្រោះដូច្នោះ ចូរពួកអ្នកវាយគងប្រកាសថា ព្រះរាជារបស់ពួកយើង ក្នុងកាលតាំងនៅជាឧបរាជនោះឯង ទ្រង់បន់ទេវតាយ៉ាងនេះថា បើទ្រង់បានគ្រងរាជសម្បត្តិ នឹងសម្លាប់មនុស្សដែលទុស្សសីល ក្នុងរជ្ជកាលរបស់ទ្រង់ឲ្យអស់ ហើយធ្វើពលីកម្ម ឥឡូវនេះទ្រង់មានបំណងសម្លាប់មនុស្ស ដែលប្រព្រឹត្តកម្មរបស់បុគ្គលទុស្សសីល ៥ ប្រការ ដែលមានមនុស្សទុស្សសីលប្រមាណ ១០០០ នាក់ ហើយយកគ្រឿងក្នុង មានបេះដូង និងសាច់ជាដើមនៃមនុស្សទាំងនោះ ធ្វើពលីកម្មដល់ទេវតា ចូរអ្នកនគរទាំងឡាយដឹងយ៉ាងនេះចុះ ។ កាលត្រាស់យ៉ាងនេះហើយ ទ្រង់ប្រកាសព្រះរាជបំណងថា គ្រានេះ រាប់អំពីនេះទៅ ខ្ញុំនឹងត្រូវសម្លាប់មនុស្សដែលប្រព្រឹត្តកម្មរបស់អ្នកទុស្សសីល ឲ្យគ្រប់ ១០០០ នាក់ បូជាយញ្ញទើបផុតចាកបំណន់ បានត្រាស់គាថានេះថា

ការបូជា អញបានបួងសួងហើយ ដោយសារមនុស្សអប្បឥត
ប្រាជ្ញារាប់ពាន់នាក់ ឥឡូវនេះ អញនឹងបូជា ( ព្រោះ ) ជនមិន
ប្រកបដោយធម៌ច្រើននាក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុម្មេធានំ សហស្សេន** សេចក្តីថា បុគ្គល ឈ្មោះថា អប្បឥតប្រាជ្ញា ព្រោះមិនដឹងថា កម្មនេះគួរធ្វើ កម្មនេះមិនគួរធ្វើ ឬ ឈ្មោះថា ល្ងង់ ព្រោះប្រព្រឹត្តក្នុងអកុសលកម្មបថ ១០ ប្រការ ។ ដោយ បុគ្គលល្ងង់ខ្លៅអប្បឥតប្រាជ្ញានោះ ១០០០ នាក់ ។

បទថា **យញ្ញោ មេ ឧបយាចិតោ** សេចក្តីថា ខ្ញុំបានចូលទៅរកទេវតា បន់នូវការបូជាយញ្ញថា នឹងបូជាយញ្ញយ៉ាងនេះ ។

បទថា **ឥទានិ ខោហំ យជិស្សាមិ** សេចក្តីថា ខ្ញុំនឹងបូជាយញ្ញឥឡូវនេះ ព្រោះបានគ្រងរាជសម្បត្តិដោយការបន់នេះ ។

ព្រោះហេតុអ្វី ព្រោះឥឡូវនេះ បុគ្គលដែលប្រព្រឹត្តអធម៌មានច្រើន ព្រោះ ដូច្នោះ ត្រូវចាប់យកទៅធ្វើពលីកម្មឥឡូវនេះឯង ។

ពួកអមាត្យស្តាប់ព្រះតម្រាស់ព្រះពោធិសត្វហើយ ទទួលព្រះបរមរាជ-ឱង្ការថា ករុណាព្រះអង្គ ។ ហើយវាយស្គរប្រកាសពេញក្រុងពារាណសី ដែល មានបរិមណ្ឌល ១២ យោជន៍ ។ ប្រជានុរាស្ត្រទូទៅស្តាប់អាជ្ញាអំពីការវាយ ស្គរប្រកាសហើយ រកបុគ្គលទ្រុស្តសីលសូម្បីតែម្នាក់ក៏មិនបាន ។ ដោយ កុសលោបាយដ៏តឹងតែងនេះ អស់កាលដែលព្រះពោធិសត្វនៅគ្រងរាជសម្បត្តិ បុគ្គលដែលធ្វើកម្ម មានការទ្រុស្តសីល ៥ ប្រការ ឬ ១០ ប្រការ សូម្បី

ត្រឹមតែម្នាក់មិនប្រាកដ ។ ព្រះពោធិសត្វ ទ្រង់មិនឲ្យបុគ្គលសូម្បីត្រឹមតែម្នាក់លំបាកឡើយ ឲ្យអ្នកដែនទូទៅរក្សាសីល សូម្បីព្រះអង្គឯង ក៏ទ្រង់បំពេញបុណ្យ មានការឲ្យទានជាដើម ក្នុងកាលអស់ព្រះជន្ម ទ្រង់នាំបរិស័ទរបស់ព្រះអង្គទៅកកកុញក្នុងទេវនគរ ដោយប្រការដូច្នេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតប្រព្រឹត្តលោកត្ថចរិយា សូម្បីក្នុងកាលមុន ក៏ប្រព្រឹត្តហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯស្តេចពារាណសី បានជាតថាគតនេះឯង ។ល។

**អដ្ឋកថា ធុម្មេធជាតក ចប់**

**អត្ថកាមវគ្គទី ៥ ចប់**

**បណ្ណាសកទី ១ ចប់**

# សុត្តន្តបិដក

# អាសីសវគ្គ

## មហាសីលវជាតក

[ ៥១ ] *( ព្រះរាជាសីលវពោធិសត្វពោលថា )* *បុរសជាបណ្ឌិត គប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ ។*

***មហាសីលវជាតកទី ១ ចប់***

# អដ្ឋកថា
# អាសីសវគ្គ

## មហាសីលវជាតក

[ ៥១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលមានសេចក្ដីព្យាយាមធូរថយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អាសីសេថេវ បុរិសោ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬដែលអ្នកជាបុគ្គលមានព្យាយាមធូរថយ កាលលោកទទួលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខបានបែបនេះ ហេតុអ្វី ទើបមានសេចក្ដីព្យាយាមធូរថយ ក្នុងកាលមុនបណ្ឌិតទាំងឡាយ សូម្បីសាបសូន្យចាករាជសម្បត្តិ ក៏គង់តាំងនៅក្នុងសេចក្ដីព្យាយាមរបស់ខ្លួននោះឯង ធ្វើនូវយសដែលបាត់ទៅហើយឲ្យកើតឡើងបានហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងព្រះគភ៌នៃអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ក្នុងថ្ងៃថ្វាយព្រះនាម ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមថាសីលវកុមារ ។ លុះមានព្រះជន្ម ១៦ វស្សា ទ្រង់សិក្សាសិប្បៈសម្រេចគ្រប់យ៉ាង ក្រោយមកព្រះរាជបិតាសោយទិវង្គត ទ្រង់បានគ្រងរាជ្យ មានព្រះនាមថា មហាសីលវ-

រាជ ។ ទ្រង់ប្រព្រឹត្តធម៌ ទ្រង់ជាធម្មរាជា ។ ទ្រង់ត្រាស់ឲ្យសាងរោងទាន ៦ គឺរោងទាន ៤ ត្រង់ទ្វារនគរទាំង ៤ រោងមួយត្រង់កណ្ដាលនគរ រោងមួយត្រង់ទ្វារព្រះរាជវាំង ទ្រង់ឲ្យទានដល់ជនអនាថា អ្នកដំណើរ ទ្រង់រក្សាសីល រក្សាឧបោសថ ទ្រង់សម្បូរដោយខន្តី មេត្តា និងករុណា ទ្រង់ឲ្យសព្វសត្វត្រេកអរ ដូចញ៉ាំងព្រះឱរស ដែលគង់ប្រថាប់លើភ្លៅឲ្យត្រេកអរ ដូច្នោះ ទ្រង់គ្រងរាជ្យដោយធម៌ ។ មានអមាត្យរបស់ព្រះរាជាម្នាក់ កន្លងល្មើសក្នុងព្រះរាជដ្ឋាន ( ប្រទូស្តស្រីស្នំ ) ក្រោយមក ក៏ប្រាកដឡើង អមាត្យទាំងឡាយនាំគ្នាក្រាបទូលឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់ឃ្លាំមើល ក៏ជ្រាបដោយប្រចក្សដោយព្រះអង្គ ទើបទ្រង់ត្រាស់ឲ្យហៅអមាត្យនោះចូលមកគាល់ ហើយបណ្ដេញទៅថា នែបុគ្គលអន្ធពាល អ្នកធ្វើកម្មមិនសមគួរឡើយ មិនគួរនៅក្នុងដែនរបស់យើងទេ ចូរដញ្ជូនប្រាក់មាស និងនាំកូន ប្រពន្ធ របស់ខ្លួនទៅទីដទៃចុះ ។

អមាត្យនោះ ទៅផុតអំពីដែនកាសី ដល់ដែនកោសល ចូលធ្វើរាជការក្នុងដែនរបស់ព្រះបាទកោសល បានជាទីទុកព្រះរាជហឫទ័យយ៉ាងជិតស្និទ្ធរបស់ព្រះរាជាដោយលំដាប់ ។ ថ្ងៃមួយ អមាត្យនោះ ក្រាបទូលព្រះបាទកោសលថា បពិត្រព្រះអង្គដ៏ចម្រើន រាជសម្បត្តិក្នុងក្រុងពារាណសីប្រៀបដូចសម្បុកឃ្មុំដែលប្រាសចាកមេ ព្រះរាជាក៏ទន់ខ្សោយ យើងអាចដណ្ដើមយកបាន ដោយពលពាហនៈមានប្រមាណតិចប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ស្ដាប់ហើយ ព្រះតម្រិះថា រាជសម្បត្តិក្នុងក្រុងពារាណសីធំសម្បើម តែអមាត្យ

នេះនិយាយថា អាចដណ្តើមបានដោយពលពាហនៈមានប្រមាណតិចប៉ុណ្ណោះ អមាត្យនេះ ប្រហែលជាចារបុរសទេដឹងហ្ន៎ គួរសង្ស័យពន់ពេក ទើបមានព្រះតម្រាស់ថា ប្រហែលឯងជាចារបុរសទេដឹង ។ អមាត្យនោះទូលថា បពិត្រព្រះអង្គ ទូលបង្គំមិនមែនជាចារបុរសឡើយ សេចក្តីដែលទូលបង្គំទូលជាការពិតទាំងអស់ បើទ្រង់មិនជឿទូលបង្គំទេ សូមទ្រង់បញ្ជូនមនុស្សទៅប្ញន់ស្រុកជាយដែនចុះ ព្រះបាទពារាណសី ចាប់មនុស្សទាំងនោះបាន ក៏នឹងព្រះរាជទានទ្រព្យផ្ទាល់ព្រះអង្គដល់មនុស្សទាំងនោះ ហើយទ្រង់ដោះលែង ។ ព្រះបាទ កោសលទ្រង់ព្រះតម្រិះថា អមាត្យនេះនិយាយអង់អាចពន់ពេក អញនឹងល្បងមើលឲ្យដឹងពិតប្រាកដ ក្នុងឥឡូវនេះហើយ ទ្រង់បញ្ជូនមនុស្សរបស់ទ្រង់ទៅឲ្យប្ញន់ស្រុកជាយដែនរបស់ព្រះបាទពារាណសី ។ រាជបុរសចាប់ចោរទាំងនោះបាន នាំខ្លួនទៅថ្វាយព្រះបាទពារាណសី ។ ព្រះរាជាទតមនុស្សទាំងនោះហើយ ត្រាស់សួរថា នែបា ហេតុអ្វី ទើបនាំគ្នាប្ញន់ស្រុក អ្នកទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំ មិនមានអ្វីបរិភោគ ទើបប្ញន់ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ហេតុអ្វី ទើបអ្នកមិននាំគ្នាមករកយើង បន្ទាប់អំពីនេះទៅខាងមុខ ពួកអ្នកកុំធ្វើដូច្នេះឡើយ ហើយទ្រង់ព្រះរាជទានទ្រព្យផ្ទាល់ខ្លួនដល់មនុស្សទាំងនោះ ហើយលែងទៅ មនុស្សទាំងនោះនាំគ្នាទៅក្រាបទូលព្រឹត្តិការណ៍នោះ ដល់ព្រះបាទកោសល ។ សូម្បីទ្រង់ដឹងយ៉ាងនោះ ក៏មិនអាចលើកទ័ពចេញទៅ ទ្រង់បញ្ជូនមនុស្សទៅឲ្យប្ញន់ជនបទត្រង់កណ្តាលនគរទៀត ។ ឯព្រះបាទពារាណសី ក៏ទ្រង់ព្រះរាជទានទ្រព្យដល់មនុស្សទាំង

នោះ ហើយទ្រង់ដោះលែងទៅនោះឯង ។ ព្រះបាទកោសល ទោះបីជ្រាប យ៉ាងនេះ ក៏ទ្រង់មិនទាន់យាងទៅ បញ្ជូនមនុស្សឲ្យប្លន់ត្រង់វិថីទៀត សូម្បី ព្រះបាទពារាណសី ក៏ទ្រង់ព្រះរាជទានទ្រព្យដល់មនុស្សទាំងនោះ ហើយទ្រង់ ដោះលែងទៅ ។ ពេលនោះ ទើបព្រះបាទកោសល ទ្រង់ជ្រាបថា ព្រះរាជា តាំងនៅក្នុងធម៌ល្អគ្មានអ្វីប្រៀប ទើបទ្រង់លើកពលពាហនៈយាងទៅដោយ បំណងថា នឹងដណ្ដើមរាជសម្បត្តិ ក្នុងនគរពារាណសី ។

សម័យនោះ ព្រះបាទពារាណសី មានអ្នកចម្បាំងធំប្រមាណ ១០០០ នាក់ សុទ្ធតែជាបុគ្គលក្លៀវក្លា មិនអាចបុគ្គលណាម្នាក់ទម្លាយបានឡើយ សូម្បីដំរីចុះប្រេងរត់មកចំពោះមុខ មេទ័ពក៏ច្បាំងមិនថយ សូម្បីរន្ទះធ្លាក់មក ត្រង់សីសៈ ទាហានទាំងនោះក៏មិនតក់ស្លុត ជាអ្នកអាចដណ្ដើមរាជសម្បត្តិ ក្នុងជម្ពូទ្វីប មកថ្វាយព្រះរាជាបាន ក្នុងកាលព្រះបាទសីលវមហារាជ ទ្រង់ ពេញព្រះរាជហឫទ័យ ។ អ្នកចម្បាំងទាំងនោះបានដំណឹងថា ព្រះបាទកោសល លើកទ័ពមក នាំគ្នាចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះបាទកោសលមានបំណងដណ្ដើមរាជសម្បត្តិ ក្នុងក្រុងពារាណសី លើកកងទ័ពមក ទូលបង្គំទាំងឡាយ សូមប្រទានព្រះបរមរាជានុញ្ញាត ទៅ ចាប់ស្ដេចកោសល ធ្វើទារុណកម្ម មិនឲ្យរុករានរាជសីមារបស់ទ្រង់បាន ឡើយ ។ ព្រះបាទពារាណសីទ្រង់ឃាត់ថា នែបាទាំងឡាយ ខ្ញុំមិនត្រូវការឲ្យ អ្នកដទៃលំបាកព្រោះខ្ញុំឡើយ កាលព្រះបាទកោសលចង់បានរាជសម្បត្តិ សូម យាងមកគ្រប់គ្រងចុះ ពួកអ្នកទាំងឡាយ កុំច្បាំងឡើយ ។ ព្រះបាទកោសល

នាំពលបំពានរាជសីមា ចូលមកកាន់ជនបទផ្នែកកណ្តាល ពួកអមាត្យ និង ទាហានដ៏ក្លៀវក្លា ក៏នាំគ្នាគាល់ព្រះរាជាព្រមគ្នា ក្រាបទូលដូច្នោះម្តងទៀត ព្រះរាជាក៏ទ្រង់ហាមដោយន័យមុននោះឯង ។ ព្រះបាទកោសលលើកពលមកប្រឈមមុខ ខាងក្រៅព្រះនគរនោះឯង បញ្ជូនព្រះរាជសារមកដល់ព្រះបាទសីលវៈថា តើព្រមលើករាជសម្បត្តិឲ្យ ឬច្បាំង ។ ព្រះបាទសីលវមហារាជបញ្ជូនរាជសាសន៍តបទៅថា យើងមិនច្បាំងជាមួយទេ សូមទ្រង់គ្រងរាជ-សម្បត្តិចុះ ។ ពួកអមាត្យចូលគាល់ព្រះរាជាម្តងទៀត ក្រាបទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំមិនព្រមឲ្យព្រះបាទកោសលចូលនគរបានទេ នឹងចាប់ធ្វើទារុណកម្ម ក្រៅព្រះនគរនោះឯង ។ ព្រះរាជាក៏ទ្រង់ឃាត់ដូចកាលមុន មានព្រះតម្រាស់ឲ្យបើកទ្វារនគរទាំងអស់ ហើយប្រថាប់លើរាជបល្ល័ង្កក្នុងប្រាសាទមួយអន្លើដោយអមាត្យ ១០០០ នាក់ ។ ព្រះបាទកោសលយាងចូលកាន់ក្រុងពារាណសី មួយអន្លើពល និងពាហនៈជាច្រើន ។ មិនបានទតឃើញបុគ្គលដែលជាសត្រូវ សូម្បីត្រឹមតែម្នាក់ឡើយ ក៏យាងចូលកាន់ទ្វារព្រះរាជវាំងចោមរោមដោយអមាត្យ ឡើងកាន់ប្រាសាទដែលប្រដាប់តាក់តែងហើយ ក្នុងព្រះរាជវាំង ដែលមានទ្វារបើកហើយ មានព្រះតម្រាស់ឲ្យចាប់ព្រះបាទសីលវ-មហារាជ ដែលមិនមានកំហុស កំពុងគង់ប្រថាប់ មួយអន្លើដោយអមាត្យទាំង ១០០០ នាក់ ត្រាស់ថា ចូរពួកឯងចងព្រះរាជានេះ មួយអន្លើដោយអមាត្យ ក្រពាត់ស្លាបសេក ចងឲ្យជាប់ ហើយនាំទៅកាន់ព្រៃខ្មោច ជីករណ្តៅឲ្យជ្រៅត្រឹមក យកមនុស្សទាំងនេះកប់ត្រឹមក លុបឲ្យណែន កុំឲ្យលើក

ដៃឡើងបាន សូម្បីត្រឹមតែម្នាក់ ក្នុងពេលយប់ ពួកឆ្កែចចក នឹងនាំគ្នាមក ហើយធ្វើកិច្ចដែលគួរធ្វើដល់មនុស្សទាំងនេះឯង ។ ពួកមនុស្សទាំងឡាយ ស្តាប់ពាក្យអាជ្ញារបស់ចោររាជហើយ នាំគ្នាចងព្រះរាជា និងពួកអមាត្យ ក្រពាត់ស្ពាយសេកយ៉ាងតឹង នាំចេញទៅ ។

ក្នុងកាលនោះ ព្រះបាទសីលវមហារាជ ទ្រង់មិនបានចងអាឃាតដល់ចោររាជសូម្បីត្រឹមតិចតួចឡើយ បណ្តាអមាត្យដែលត្រូវចងបណ្តើរទាំងនោះ ក៏មានទំនងដូចគ្នា មិនមានសូម្បីតែម្នាក់ដែលអាចទម្លាយព្រះតម្រាស់នៃព្រះរាជាខ្លួនបានឡើយ ។ បានឮថា បរិស័ទរបស់ព្រះបាទសីលវមហារាជនោះ មានវិន័យល្អយ៉ាងនេះ ។ កាលនោះ រាជបុរសរបស់ចោររាជទាំងនោះ លុះនាំព្រះបាទសីលវមហារាជ មួយអន្លើដោយអមាត្យ ទៅដល់ព្រៃខ្មោចហើយ នាំគ្នាជីករណ្តៅត្រឹមក ចាប់ព្រះបាទមហាសីលវរាជទម្លាក់ក្នុងរណ្តៅត្រង់កណ្តាល ចាប់ពួកអមាត្យដ៏សេសដាក់ក្នុងរណ្តៅជុំវិញ លុបដីឲ្យណែនរួចនាំគ្នាត្រឡប់មក ។ ព្រះបាទសីលវមហារាជត្រាស់ហៅពួកអមាត្យ ព្រះរាជទានឱវាទថា នែអ្នកទាំងឡាយ ចូរពួកអ្នកចម្រើនមេត្តាតែម្យ៉ាង កុំធ្វើនូវការអាក់អន់ក្នុងចោររាជឡើយ ។

លុះដល់កណ្តាលរាត្រី ហ្វូងឆ្កែចចកបំណងនឹងស៊ីសាច់មនុស្ស ទើបនាំគ្នាមក ។ ព្រះរាជា និងពួកអមាត្យឃើញហ្វូងចចកនោះហើយ ក៏បន្លឺសំឡេងដូចគ្នានោះឯង ។ ហ្វូងចចកភ័យខ្លាច នាំគ្នាគេចទៅ ។ កាលចចកត្រឡប់មកមើល មិនឃើញមាននរណាមកតាមក្រោយ ក៏នាំគ្នាមកសាជាថ្មី ។ ព្រះរាជា

និងពួកអមាត្យក៏បង្អើលចចកដោយវិធីនោះ ។ ពួកចចកគេចទៅអស់វារៈ ៣ ដង នាំគ្នាមកមើលទៀត ដឹងអាការដែលមនុស្សទាំងនោះ សូម្បីត្រឹមម្នាក់ក៏តាមមកមិនបាន ទើបសន្និដ្ឋានថា មនុស្សទាំងនេះប្រហែលជាត្រូវសម្លាប់ហើយ ទើបហ៊ានត្រឡប់ទៅ ទោះបីមនុស្សទាំងនោះធ្វើសំឡេងទៀត ក៏មិនគេចទៅ ។ ចចកមេហ្វូងដើរតម្រង់ទៅរកព្រះរាជា ចចកដ៏សេសនាំគ្នាទៅជិតពួកអមាត្យ ព្រះរាជាទ្រង់ឈ្លាសក្នុងឧបាយ ទ្រង់ជ្រាបអាការដែលឆ្កែចចកនោះមកក្បែរព្រះអង្គទ្រង់ងើយព្រះសុវណ្ណឡើង ហាក់ដូចឲ្យឱកាសដែលឆ្កែអាចខាំបាន លុះឆ្កែខាំត្រង់ព្រះសុវណ្ណ ទ្រង់ក៏សង្កត់ដោយព្រះហនុ គឺចង្កាយ៉ាងណែន ដូចសង្កត់ដោយគ្រឿងយន្ត ។ ចចកត្រូវព្រះរាជាដែលទ្រង់មានកម្លាំងដូចដំរីសារសង្កត់ដោយចង្កាយ៉ាងណែន មិនអាចរើខ្លួនបាន ខ្លាចនូវសេចក្ដីស្លាប់ ទើបស្រែកដោយសំឡេងខ្លាំង ។ ហ្វូងចចកបរិវារបានឮសំឡេងមេហ្វូងរបស់ខ្លួនហើយ នាំគ្នាគិតថា ប្រហែលជាចចកនោះ ត្រូវបុរសនោះចាប់បាន ទើបមិនអាចចូលជិតពួកអមាត្យ ខ្លាចនូវសេចក្ដីស្លាប់ នាំគ្នាគេចទៅ ចចក កាលព្រះរាជាសង្កត់យ៉ាងណែនដោយព្រះហនុ ដូចគ្នានឹងគ្រឿងយន្តបម្រះទៅមកធ្វើអាចម៍ដីដែលណែនឲ្យធូរ ចចកនោះឯងខ្លាចស្លាប់ ទើបយកជើងទាំង ៤ កាយដីដែលលុបព្រះរាជា ។ ទ្រង់ជ្រាបអាការដែលដីធូរហើយ ទ្រង់លែងចចកទៅ ។ ព្រះរាជាសម្បូរដោយកម្លាំងដូចដំរី សម្បូរដោយកម្លាំងចិត្ត រង្គៀកព្រះកាយទៅមក ក៏លើកព្រះហស្តទាំង ២ ឡើងមកបាន ទ្រង់ប្រត់មាត់រណ្ដៅលើកខ្លួនឡើងបាន ដូចវលាហកត្រូវខ្ចាត់ខ្ចាយដោយកម្លាំងខ្យល់ ដូច្នោះ តាំង

ព្រះកាយបានហើយ ទ្រង់ល្បួងលោមពួកអមាត្យ ទ្រង់កកាយដី ឲ្យឡើងផុតពីរណ្ដៅគ្រប់គ្នា ទ្រង់មានពួកអមាត្យហែមរោម ប្រថាប់នៅក្នុងព្រៃខ្មោចនោះឯង ។

សម័យនោះ ពួកមនុស្សយកសពទៅចោលក្នុងព្រៃខ្មោច តែចោលត្រង់ចន្លោះដែនយក្ខ ២ រូប យក្ខទាំងនោះ មិនអាចចែកមនុស្សដែលស្លាប់ហើយនោះបាន កើតនូវវិវាទពោលថា យើងទាំង ២ មិនអាចចែកគ្នាបាន ព្រះបាទសីលវមហារាជអង្គនេះ ជាអ្នកទ្រទ្រង់ធម៌ ទ្រង់នឹងចែកដល់ពួកយើងបាន ពួកយើងទៅកាន់សម្នាក់ព្រះអង្គ ហើយចាប់ត្រង់ជើងសាកសពនោះម្នាក់ម្ខាង អូសទៅដល់សម្នាក់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ចែកសរីរៈមនុស្សស្លាប់នេះដល់ទូលបង្គំទាំង ២ ផងចុះ ។ ព្រះបាទសីលវមហារាជទ្រង់ត្រាស់ថា នែយក្ខដ៏ចម្រើន យើងអាចចែកសរីរៈមនុស្សនេះឲ្យដល់អ្នកទាំង ២ តែយើងមានរាងកាយមិនស្អាត ត្រូវងូតទឹកជាមុនសិន ។ យក្ខទាំង ២ ក៏ទៅយកទឹកដែលអប់សម្រាប់ចោររាជមកដោយអានុភាពនៃខ្លួនថ្វាយព្រះបាទសីលវមហារាជស្រង់ ហើយទៅយកសំពត់សាដករបស់ចោររាជដែលបត់ជាសំពត់ទ្រទ្រង់របស់ព្រះអង្គមកថ្វាយ ហើយនាំយកប្រអប់ព្រះសុគន្ធដែលផ្សំដោយគន្ធជាតិ ៤ យ៉ាង មកថ្វាយឲ្យទ្រង់ប្រោះព្រំ រួចយកផ្កាផ្សេងៗ ដែលដាក់ក្នុងប្រអប់មាស និងប្រអប់កែវមកថ្វាយឲ្យទ្រង់តាក់តែង ។ កាលព្រះបាទសីលវមហារាជទ្រង់ប្រដាប់ផ្កា ហើយប្រថាប់ឈរ យក្ខទាំង ២ ក៏ក្រាបទូលសួរថា ទូលបង្គំត្រូវធ្វើអ្វីទៀត ។ ព្រះបាទសីលវមហារាជ ទ្រង់

សម្ដែងអាការថា ទ្រង់ឃ្លាន យក្ខទាំង ២ ក៏ទៅយកភោជនីយាហារ មាន រសដ៏ប្រសើរច្រើនប្រភេទ ដែលគេត្រៀមសម្រាប់ចោររាជមកថ្វាយ ។ ព្រះបាទ សីលវមហារាជទ្រង់ស្រេពស្រង់ព្រះកាយ តែងព្រះកាយ ទ្រទ្រង់នូវគ្រឿង ប្រដាប់រៀបរយហើយ ក៏សោយព្រះក្រយាហារដ៏ប្រសើរច្រើនប្រភេទ យក្ខ ទាំង ២ ក៏ទៅនាំទឹកសោយដែលអប់ហើយ មួយអន្លើដោយឃ្លោកមាស និង ផ្តិលមាសដែលគេរៀបចំសម្រាប់ចោររាជ មកថ្វាយឲ្យទ្រង់សោយ កាលទ្រង់ សោយខ្ពុរព្រះឱស្ឋ និងជម្រះព្រះទន្តហើយ នាំគ្នាទៅនាំព្រះស្រី ( ម្លូ ) ដែល ផ្សំដោយគន្ធជាតិ ៥ ប្រការ ដែលគេរៀបចំសម្រាប់ចោររាជ មកថ្វាយឲ្យ ទ្រង់ទំពា ក្នុងកាលព្រះរាជាទ្រង់ទំពាម្លូនោះហើយ ប្រថាប់ឈរ យក្ខក៏ទូល សួរថា បពិត្រព្រះអង្គ តើឲ្យទូលបង្គំធ្វើអ្វីទៀត ព្រះរាជក៏ត្រាស់ថា ចូរពួកអ្នក ទៅនាំព្រះខ័នដែលជាមង្គល ត្រង់ក្បាលដំណេករបស់ចោររាជមក យក្ខទាំង ២ ក៏ទៅនាំមកថ្វាយ ។ ព្រះបាទសីលវមហារាជ ទ្រង់ទទួលព្រះខ័ននោះ ហើយ ទ្រង់តម្កល់សាកសពនោះឲ្យត្រង់ ទ្រង់ពុះត្រង់កណ្ដាលក្បាល ចែក ជា ២ ចំណែក ឲ្យដល់យក្ខទាំង ២ នោះស្មើៗ គ្នា ហើយទ្រង់ជម្រះព្រះខ័ន សៀតត្រង់ព្រះកាយ ហើយប្រថាប់ឈរ ។ យក្ខទាំង ២ បរិភោគសាច់ មនុស្សហើយ ក៏ត្រេកអរនាំគ្នាទូលសួរថា បពិត្រមហារាជ ទូលបង្គំទាំង ២ នឹងធ្វើអ្វីទៀត ។ ព្រះបាទសីលវមហារាជ ទ្រង់ត្រាស់ថា បើដូច្នោះ ចូរអ្នក ទាំង ២ សម្ដែងអានុភាពរបស់ខ្លួន នាំយើងទៅដាក់ក្នុងបន្ទប់ដេកដ៏មាន សិរីរបស់ចោររាជ ហើយនាំពួកអមាត្យទាំងនោះទៅផ្ទះរៀងៗ ខ្លួនចុះ ។ យក្ខ

ទាំង ២ ទទួលព្រះតម្រាស់ហើយ នាំគ្នាបដិបត្តិតាមនោះ ។

គ្រានោះ ចោររាជផ្ទំលក់លើព្រះទែនសិរីសេយ្យាសនៈ ក្នុងបន្ទប់ដ៏មានសិរី ព្រះបាទសីលវមហារាជ ក៏ទ្រង់យកបន្ទះព្រះខ័នវាយព្រះឧទរចោររាជ ដែលកំពុងផ្ទំលក់យ៉ាងស្កប់ស្កល់ ចោររាជភិតភ័យ តើនចាកទីបន្ទំ ទ្រង់ចាំព្រះបាទសីលវមហារាជបាន ដោយពន្លឺប្រទីប ទ្រង់ក្រោកចាកព្រះទែន តម្កល់សតិមាំ ត្រាស់នឹងព្រះបាទសីលវមហារាជថា បពិត្រមហារាជ ក្នុងពេលយប់បែបនេះ ក្នុងវាំងបិទទ្វារ មានអ្នករក្សាខ្វាត់ខ្វែង គ្រប់កន្លែង មិនមានចន្លោះវេនយាម ទ្រង់សៀតព្រះខ័ន ប្រដាប់គាក់តែងហើយ យាងមកទីនេះបានដូចម្ដេច ព្រះបាទសីលវមហារាជត្រាស់ដល់ការយាងមកនៃទ្រង់ឲ្យស្ដាប់ដោយពិស្ដារ ចោររាជស្ដាប់រឿងនោះហើយ ទ្រង់សង្វេគត្រាស់ថា បពិត្រមហារាជ ខ្ញុំជាមនុស្ស ក៏មិនបានជ្រាបនូវព្រះគុណសម្បត្តិរបស់ទ្រង់ឡើយ តែពួកយក្ខស៊ីឈាម និងសាច់របស់អ្នកដទៃ គ្រោតគ្រាតឃោរឃៅ គង់ដឹងដល់ព្រះគុណសម្បត្តិរបស់ទ្រង់ បពិត្រព្រះអង្គប្រសើរជាងជន គ្រានេះ ទូលបង្គំមិនប្រទូស្តក្នុងព្រះអង្គ ដែលសម្បូរដោយសីលបែបនេះទៀតឡើយ ទ្រង់ចាប់ព្រះខ័ន ធ្វើនូវសម្បថ សូមខមាទោសជាមួយព្រះបាទសីលវមហារាជ យាងឲ្យផ្ទំលើព្រះទែនធំ ខ្លួនឯងទ្រង់ផ្ទំលើព្រះទែនតូច ។ ក្នុងពេលភ្លឺស្វាងព្រះអាទិត្យរះឡើងហើយ ក៏ឲ្យមនុស្សវាយស្គរត្រាច់ប្រកាសឲ្យបណ្ដាសេនាគ្រប់ពួក ក្រុមអមាត្យ ព្រាហ្មណ៍ គហបតី ប្រជុំគ្នា ត្រាស់សរសើរព្រះគុណរបស់ព្រះបាទសីលវមហាជ ប្រៀបដូចទ្រង់សរសើរព្រះចន្ទពេញបូណ៌មីក្នុង

អាកាស ខាងមុខជនទាំងនោះ ទ្រង់សូមខមាទោសព្រះបាទសីលវមហារាជ កណ្ដាលបរិស័ទនោះម្ដងទៀត ទ្រង់សងរាជសម្បត្តិ ត្រាស់ថា បពិត្រមហារាជ តាំងអំពីនេះទៅ ឧបទ្រពយដែលកើតអំពីចោរកាច ដែលកើតឡើងដល់ទ្រង់ ទូលបង្គំនឹងទទួលភារៈកម្ចាត់ សូមទ្រង់សោយរាជ្យ ដោយមានទូលបង្គំជាអ្នករក្សាចុះ ហើយទ្រង់ដាក់អាជ្ញាដល់អមាត្យដែលញុះញង់ រៀបចំពលពាហនៈ យាងទៅកាន់ដែនរបស់ព្រះអង្គ ។

ឯព្រះបាទសីលវមហារាជ ទ្រង់ប្រដាប់ដោយរាជអលង្ការ គង់ប្រថាប់លើកាញ្ចនបល្ល័ង្ក មានជ្រញ់ទ្រព្រះបាទធ្វើដោយស្បែកឈ្មុស ខាងក្រោមព្រះស្វេតច្ឆត្រ ទតមើលរាជសម្បត្តិរបស់ទ្រង់ ទ្រង់ព្រះតម្រិះថា សម្បត្តិដ៏ឱឡារបែបនេះ និងការត្រឡប់បាននូវជីវិតរបស់អមាត្យទាំង ១០០០ នាក់ បើអាត្មាអញមិនធ្វើសេចក្ដីព្យាយាម នឹងមិនមានសូម្បីត្រឹមតែម្យ៉ាង តែដោយកម្លាំងនៃការព្យាយាម ទើបបាននូវយសនេះ ដែលវិនាសទៅហើយ និងបានឲ្យជីវិតដល់អមាត្យ ១០០០ នាក់ ។ បុគ្គលមិនគួរអស់សង្ឃឹមឡើយ គួរធ្វើសេចក្ដីព្យាយាមតែម្យ៉ាង ព្រោះបុគ្គលដែលធ្វើសេចក្ដីព្យាយាមហើយ រមែងសម្រេចផលយ៉ាងនេះ ហើយត្រាស់គាថានេះ ដោយអំណាចនៃឧទានថា

បុរសជាបណ្ឌិត គប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណាបានយ៉ាងនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាសីសេថេវ** សេចក្ដីថា បុរសជាបណ្ឌិត

ត្រូវធ្វើការប៉ុនប៉ងដោយកម្លាំងព្យាយាមរបស់ខ្លួនថា កាលអាត្មាអញ ប្រារព្ធសេចក្តីព្យាយាមយ៉ាងនេះ នឹងផុតទុក្ខនេះ ដូច្នេះ ។

បទថា **ន និព្វិន្ទេយ្យ បណ្ឌិតោ** សេចក្តីថា បុរសបានឈ្មោះថាជាបណ្ឌិត គឺជាអ្នកឈ្លាសក្នុងឧបាយ កាលធ្វើសេចក្តីព្យាយាម ក្នុងទីដែលត្រូវខ្នះខ្នែង មិនគប្បីនឿយណាយ គឺមិនគួរធ្វើការលះបង់នូវការប៉ុនប៉ងថា អញប្រហែលមិនបានផលនៃការព្យាយាមនេះឡើយ ដូច្នេះ ។

បទថា **វោ** ក្នុងបទថា **បស្សាមិ វោហំ អត្តានំ** នេះ ត្រឹមតែជានិបាត សេចក្តីថា ថ្ងៃនេះ ខ្ញុំឃើញខ្លួនឯងដោយប្រចក្ស ។

បទថា **យថា ឥច្ឆឹ តថា អហុ** សេចក្តីថា ខ្ញុំឃើញខ្លួនឯងជាគំរូថា ខ្ញុំត្រូវកប់ក្នុងរណ្តៅពិតៗ គង់ផុតចាកទុក្ខបាន កាលប្រាថ្នាសម្បត្តិរបស់ខ្លួនទៀត ខ្ញុំនោះក៏ឃើញខ្លួនឯង ដល់នូវសម្បត្តិនេះហើយ ក្នុងកាលមុន ខ្ញុំប្រាថ្នាយ៉ាងណា ខ្លួនរបស់ខ្ញុំក៏យ៉ាងនោះឯង ដូច្នេះ ។

ព្រះពោធិសត្វ កាលត្រាស់ថា នៃអ្នកទាំងឡាយ ធម្មតាផលនៃសេចក្តីព្យាយាមរបស់លោកអ្នកសម្បូរដោយសីលទាំងឡាយ រមែងសម្រេចបាន គួរអស្ចារ្យពិត ដូច្នេះ ទ្រង់បន្លឺឧទានដោយគាថានេះ ។ ទ្រង់ធ្វើបុណ្យទាំងឡាយដរាបដល់អស់ព្រះជន្ម ហើយក៏ទៅតាមយថាកម្ម ដោយប្រការដូច្នេះ ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសចតុរារិយសច្ច កាលចប់ចតុរារិយសច្ច ភិក្ខុមានសេចក្តីព្យាយាមធូរថយ ក៏តាំងនៅក្នុងអរហត្តផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អមាត្យអាក្រក់ក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ អមាត្យ ១០០០ នាក់ បានជាពុទ្ធបរិស័ទ ឯស្តេចសីលវមហារាជ គឺតថាគតនេះឯង ។៚

## អដ្ឋកថា មហាសីលវជាតក ចប់

# សុត្តន្តបិដក

## ចូឡជនកជាតក

[ ៥២ ] ( ព្រះបាទជនកពោធិសត្វពោលថា ) បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ យើងឃើញខ្លួនយើងដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ ។

ចូឡជនកជាតកទី ២ ចប់

# អដ្ឋកថា

## ចូឡជនកជាតក

[ ៥២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលមានសេចក្តីព្យាយាមធូរថយដូចគ្នា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វាយមេថេវ បុរិសោ** ដូច្នេះជាដើម ។

រឿងដែលគួរពោលក្នុងជាតកនេះទាំងអស់ មានច្បាស់ក្នុងមហាជនកជាតក ។

ព្រះរាជាគង់ប្រថាប់ខាងក្រោមស្វេតច្ឆត្រ ហើយត្រាស់ព្រះគាថានេះថា

បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ
យើងឃើញខ្លួនយើង ដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វាយមេថេវ** សេចក្តីថា បុរសដែលជាបណ្ឌិតត្រូវធ្វើសេចក្តីព្យាយាមរឿយៗ ទៅ ។

បទថា **ឧទកា ថលមុព្ភតំ** សេចក្តីថា យើងឃើញច្បាស់ខ្លួនឯងថា ផុតបាកទឹកឡើងលើគោកបាន គឺតាំងនៅលើគោកបាន ។

ឥឡូវនេះ ភិក្ខុដែលមានសេចក្តីព្យាយាមធូរថយ សម្រេចអរហត្តផលហើយ ។ ព្រះបាទជនករាជ ក្នុងកាលនោះ បានមកជាព្រះសម្មាសម្ពុទ្ធ ដូច្នេះឯង ។៚

**អដ្ឋកថាចូឡជនកជាតក ចប់**

# សុត្តន្តបិដក

## បុណ្ណាធាតិជាតក

[ ៥៣ ] ( សេដ្ឋីពោធិសត្វពោលថា ) កាជន៍សុរាទៅពេញដដែល តែសម្តីចេញទៅដោយឡែក យើងដឹងបានដោយហេតុ ( នេះ ) សុរានេះ មិនមែនស្រួលទេ ។

បុណ្ណបាតិជាតកទី ៣ ចប់

# អដ្ឋកថា

## បុណ្ណានិជាតក

[ ៥៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រាលាយថ្នាំពិស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តមេវបុណ្ណានិយោ** ដូច្នេះជាដើម ។

សម័យមួយ ពួកអ្នកលេងសុរាក្នុងក្រុងសាវត្ថី ប្រជុំគ្នាប្រឹក្សាថា តម្លៃសម្រាប់ទិញសុរារបស់ពួកយើងអស់ហើយ តើរកឯណាបាន ខណៈនោះ អ្នកលេងរឹតត្បឹងម្នាក់ពោលថា កុំគិតថ្វីឡើយ ឧបាយមានម្យ៉ាង ពួកអ្នកលេងសួរថា ឧបាយដូចម្តេច អ្នកលេងរឹតត្បឹងនោះពោលថា លោកអនាថបិណ្ឌិកសេដ្ឋីពាក់ចិញ្ចៀនច្រើនវង់ ស្លៀកសំពត់សាច់ម៉ដ្ឋ ទៅគាល់ព្រះរាជា ពួកយើងយកថ្នាំពុលដាក់ក្នុងក្រឡស្រា នាំគ្នាអង្គុយ ត្រៀមនូវការផឹក ពេលលោកមក ក៏អញ្ជើញលោកថា អញ្ជើញផ្លូវនេះ លោកម្ចាស់ ហើយឲ្យគាត់ផឹក កាលសន្លប់ហើយ ក៏ដណ្តើមយកចិញ្ចៀន និងសំពត់ស្លៀក ធ្វើមូលតម្លៃទិញស្រាផឹកបាន អ្នកលេងទាំងនោះទទួលថា ល្អពិតហ្ន៎ ក៏នាំគ្នាធ្វើយ៉ាងនោះ ។ កាលសេដ្ឋីដើរមក ក៏ដើរបញ្ច្រាសផ្លូវទៅ ពោលថា បពិត្រលោកម្ចាស់អញ្ជើញមកផ្លូវនេះសិន សុរាក្នុងវង់របស់ពួកខ្ញុំ គួរត្រេកអរក្រៃពេក អញ្ជើញលោកម្ចាស់សាកបន្តិច សឹមទៅចុះ ។ អនាថបិណ្ឌិក ជាអរិយសាវកថ្នាក់សោតាបន្ន នឹងផឹកស្រាបានដូចម្តេច ទោះបីលោកមិនត្រូវការ ក៏គិតថាអញនឹងចាប់កំហុសអ្នកលេងទាំងនេះ ដូច្នេះហើយ ទើបដើរទៅកាន់ទីដែលគេរៀបចំនឹងផឹក សង្កេតមើលកិរិយារបស់ជនទាំងនោះ ក៏ជ្រាបថា ជនទាំងនេះធ្វើស្រា

នេះទុក ដោយហេតុឈ្មោះនេះ រួចត្រិះរិះបន្តថា តាំងអំពីពេលនេះទៅ ត្រូវដេញជនទាំងនេះ ឲ្យគេចទៅអំពីទីនេះ ដូច្នេះហើយ ពោលថា នែវ៉ឺយពួកអ្នកលេងសុរាអាក្រក់ ពួកអាគិតថា ពួកយើងយកថ្នាំពុលដាក់ក្នុងក្រឡស្រា ហើយផ្សំគំនិតគ្នា ឲ្យមនុស្សដែលមកនាំគ្នាផឹក សន្លប់ហើយ នឹងប្លន់យកទ្រព្យ ដូច្នេះ រៀបចំវង់ផឹក អង្គុយអួតអំពីសុរានេះតែម្យ៉ាង បុគ្គលណាម្នាក់ក៏មិនហ៊ានលើកស្រានេះផឹក បើស្រាទាំងនេះមិនលាយថ្នាំពុលសោត ពួកអ្នកនឹងត្រូវផឹកខ្លះជាមិនខាន ។ លោកសេដ្ឋីសម្លុតអ្នកលេងទាំងនោះ ឲ្យគេចទៅអំពីទីនោះ ហើយក៏ទៅផ្ទះរបស់ខ្លួន បានគិតថា អញត្រូវក្រាបទូលហេតុដែលពួក អ្នកលេងធ្វើ ឲ្យព្រះសាស្តាទ្រង់ជ្រាប ដូច្នេះហើយ ទើបទៅកាន់ជេត-ពនមហាវិហារ ក្រាបទូលព្រះសាស្តាឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលពួកអ្នកលេងទាំងនោះបំណងនឹងបោកបញ្ឆោតអ្នក សូម្បីក្នុងកាលមុន ក៏មានបំណងបោកបញ្ឆោត បណ្ឌិតទាំងឡាយមកហើយ លុះសេដ្ឋីទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាពារាណសីសេដ្ឋី ។ ក្នុងកាលនោះ ពួកអ្នកលេងទាំងនោះក៏ប្រឹក្សាគ្នាយ៉ាងនេះឯង បានរៀបចំស្រា លុះពារាណសីសេដ្ឋីដើរមក ក៏ដើរបញ្ច្រាសផ្លូវ បបួលនិយាយទំនងដូចគ្នានោះឯង ។ លោកសេដ្ឋីមិនមានបំណងនឹងផឹក ក៏ចង់ចាប់ល្បិចជនទាំងនោះ ទើបចូលទៅកាលសង្កេត

មើលកិរិយានៃអ្នកលេងទាំងនោះហើយ ក៏គិតថា ពួកអ្នកលេងទាំងនេះបំណងនឹងធ្វើវត្ថុនេះ អញនឹងដេញពួកវាចេញអំពីទីនេះ ហើយពោលយ៉ាងនេះថា នែអ្នកលេងទាំងឡាយ ធម្មតាការផឹកហើយចូលគាល់ព្រះរាជា មិនគួរ ខ្ញុំទៅគាល់ព្រះរាជាហើយមកជាថ្មី ពួកអ្នកចូរអង្គុយចាំក្នុងទីនេះឯង ។ កាលទៅគាល់ព្រះរាជាហើយ ក៏ត្រឡប់មក ។ ពួកអ្នកលេងទាំងឡាយ នាំគ្នាពោលថា លោកសេដ្ឋីអញ្ជើញផ្លូវនេះចុះ ។ សេដ្ឋីទៅទីនោះហើយ សម្លឹងមើលក្រឡស្រាដែលដាក់ថ្នាំពុល ហើយពោលថា នែអ្នកលេងទាំងឡាយ ការធ្វើរបស់ពួកអ្នកមិនគាប់ចិត្តខ្ញុំឡើយ ក្រឡស្រារបស់ពួកអ្នកនៅពេញដូចដើម ពួកអ្នកពោលអួតស្រាតែម្យ៉ាង តែមិនផឹកសោះ បើស្រាទាំងនេះឆ្ងាញ់ពិតៗ ពួកអ្នកត្រូវផឹកខ្លះតែស្រានេះ ពួកអ្នកដាក់ថ្នាំពុលដោយពិត កាលទម្លាយមនោរថរបស់ពួកអ្នកលេងទាំងនោះ ទើបពោលគាថានេះថា

កាជន៍សុរានៅពេញដដែល តែសម្តីចេញទៅដោយឡែក យើងដឹង
បានដោយហេតុ ( នេះ ) សុរានេះ មិនមែនស្រួលទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តថេវ** សេចក្តីថា ពេលដែលយើងទៅឃើញក្រឡស្រា យ៉ាងណា សូម្បីក្នុងឥឡូវនេះ ក្រឡទាំងនេះ ក៏នៅពេញយ៉ាងនោះ ។

បទថា **អញ្ញាយំ វត្តតេ វត្តតេ កថា** សេចក្តីថា ពាក្យសរសើរស្រារបស់ពួកអ្នក ជាពាក្យបោកបញ្ឆោត គឺជាពាក្យមិនពិត បានដល់ អាក្រក់ទាំងអស់ ព្រោះបើស្រានេះល្អពិត ពួកអ្នកនឹងត្រូវផឹក គប្បីនៅសល់ត្រឹមតែ

ក្រឡ តែពួកអ្នកមិនផឹកសូម្បីត្រឹមតែម្នាក់ ។

បទថា **អាការកេន ជានាមិ** សេចក្ដីថា ព្រោះដូច្នោះ ទើបយើងដឹង ដោយហេតុនេះ ។

បទថា **នេវាយំ ភទ្ទកា សុរា** សេចក្ដីថា ស្រានេះមិនល្អពិតប្រាកដ គឺ ជាសុរាផ្សំដោយថ្នាំពុល ។

លោកសេដ្ឋីសង្កត់សង្កិនពួកអ្នកលេង គំរាមមិនឲ្យជនទាំងនោះធ្វើយ៉ាង នោះទៀត ហើយលែងទៅ ធ្វើបុណ្យមានទានជាដើម ដរាបដល់អស់ជីវិត ហើយ ទៅតាមយថាកម្ម ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ប្រជុំជាតកថា ពួកអ្នក លេងក្នុងកាលនោះ បានមកជាពួកអ្នកលេងក្នុងកាលឥឡូវនេះ ឯពារាណសី សេដ្ឋី គឺតថាគតនេះឯង ។៚

**អដ្ឋកថា បុណ្ណបាតិជាតក ចប់**

# សុត្តន្តបិដក

## ផលជាតក

[ ៥៤ ] *( ឈ្មួញពោធិសត្វពោលថា ) ឈើនេះ មិនមែនលំបាកឡើង ទាំងមិនឋិតនៅឆ្ងាយអំពីស្រុក ខ្ញុំដឹងបានដោយហេតុ ( នេះ ) ឈើនេះ មិនមែនមានផ្លែស្រួលទេ ។*

*ផលជាតកទី ៤ ចប់*

# អដ្ឋកថា

## ផលជាតក

[ ៥៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ដែលឈ្លាសក្នុងការមើលផ្លែឈើម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នាយំ រុក្ខោ ទុរារុហោ** ដូច្នេះជាដើម ។

បានឮមកថា កុដុម្ពិកៈអ្នកក្រុងសាវត្ថីម្នាក់ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងចម្ការរបស់ខ្លួន ថ្វាយបបរ និងរបស់ទំពា ហើយប្រាប់អ្នកយាមចម្ការថា ចូរអ្នកត្រាច់ទៅក្នុងចម្ការជាមួយភិក្ខុទាំងឡាយ ប្រគេនផ្លែឈើផ្សេងៗ មានស្វាយជាដើមដល់លោកម្ចាស់ទាំងឡាយចុះ ។ អ្នកថែសួនទទួលពាក្យហើយ នាំភិក្ខុសង្ឃត្រាច់ទៅក្នុងចម្ការ មើលដើមឈើ ស្គាល់ផ្លែឈើដោយស្ទាត់ជំនាញថា ផ្លែនោះខ្ចី ផ្លែនោះមិនទាន់ទុំល្អទេ ផ្លែនោះទុំល្អ គាត់ពោលយ៉ាងណា ផ្លែឈើនោះក៏យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយទៅក្រាបទូលដល់ព្រះតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកយាមចម្ការនេះឈ្លាសក្នុងការមើលផ្លែឈើ ទោះឈរត្រង់ផែនដី សម្លឹងមើលផ្លែឈើហើយ ក៏ដឹងបានថា ផ្លែនោះខ្ចី ផ្លែនោះស្រគាល ផ្លែនោះទុំល្អ គាត់និយាយយ៉ាងណា ផ្លែឈើនោះក៏យ៉ាងនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកចាំចម្ការនេះ មិនមែនឈ្លាសក្នុងការមើលផ្លែឈើតែម្នាក់ឯងប៉ុណ្ណោះទេ ក្នុងកាលមុនបណ្ឌិតទាំងឡាយដែលឈ្លាសក្នុងការមើលផ្លែឈើ ក៏ធ្លាប់មានមកហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងក្រុង

ពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឈ្មួញរទេះ ចម្រើនវ័យហើយ ធ្វើជំនួញដោយរទេះ ៥០០ ។ សម័យមួយ ទៅដល់ព្រៃជ្រៅ ទើបបោះជំរំត្រង់មាត់ព្រៃ ហៅមនុស្សទាំងឡាយមកប្រជុំ ពោលថា ក្នុងព្រៃនេះ ឈ្មោះថាដើមឈើពុលមាន ស្លឹកឈើពុលក៏មាន ផ្កាឈើពុលក៏មាន ផ្លែឈើពុលក៏មាន មានរសផ្អែមពុលក៏មាន មានទូទៅ ពួកអ្នកមុននឹងបរិភោគ បើមិនទាន់ប្រាប់ស្លឹក ផ្លែ ផ្កា ណាមួយជាមួយខ្ញុំ កុំបរិភោគដាច់ខាត ។ ជនទាំងនោះទទួលពាក្យហើយ សាធុ ! ស្រុះស្រួលគ្នាចូលកាន់ព្រៃ ។ ត្រង់មាត់ព្រៃមានដើមកឹផលព្រឹក្ស ដែលនៅត្រង់ទ្វារស្រុកមួយកន្លែង ដើម មែក ស្លឹកខ្ចី ផ្កា ផ្លែ គ្រប់យ៉ាងរបស់ដើម កឹផលព្រឹក្សនោះ ដូចគ្នានឹងដើមស្វាយមិនខុសឡើយ មិនតែប៉ុណ្ណោះ ផ្លែខ្ចី និងផ្លែទុំក៏ដូចគ្នានឹងផ្លែស្វាយ ទាំងពណ៌ និងសណ្ឋាន ទាំងក្លិន និងរស មិនប្លែកគ្នាឡើយ តែកាលទំពាលេបចូលហើយក៏ធ្វើឲ្យអ្នកទំពាដល់នូវការអស់ជីវិតមួយរំពេច ដូចថ្នាំពិសដ៏ពន្លឹក ដូច្នោះ ជនដែលដើរទៅមុន ពួកខ្លះ ជាមនុស្សឡេះឡោះ សម្គាល់ថា នេះជាដើមស្វាយទំពាស៊ីលេបចូលទៅ ពួកខ្លះ គិតថា ចាំសួរមេឈ្មួញរទេះជាមុនសិន សឹមស៊ីក៏ឈររង់ចាំ ។ នាយឈ្មួញរទេះមកដល់ ក៏នាំគ្នាសួរថា បពិត្រលោកម្ចាស់ពួកខ្ញុំនឹងស៊ីផ្លែស្វាយទាំងនេះ ។ ព្រះពោធិសត្វដឹងថា នេះមិនមែនដើមស្វាយក៏ឃាត់ថា ដើមឈើនេះ ឈ្មោះថា ដើមកឹផលព្រឹក្ស មិនមែនដើមស្វាយទេ ពួកអ្នកកុំបរិភោគឡើយ ពួកជនដែលបរិភោគចូលហើយ ក៏ដាក់ថ្នាំឲ្យក្អួតចេញមក ឲ្យផឹកមធុរស ៤ យ៉ាង ធ្វើឲ្យប្រាសចាករោគបាន ។ ក្នុងកាលមុន ពួក

មនុស្សនាំគ្នាឈប់សម្រាកត្រង់គល់ឈើនេះ ទំពាផ្លែពុលទាំងនេះចូលទៅ ដោយសម្គាល់ថាជាផ្លែស្វាយ នាំគ្នាដល់នូវការអស់ជីវិត ។ ស្អែកឡើង ពួកអ្នកស្រុកក៏នាំគ្នាចេញមក ឃើញមនុស្សស្លាប់ ក៏នាំគ្នាអូសជើងយកទៅចោលត្រង់គុម្ពោតព្រៃ ហើយក៏កាន់យកទ្រព្យសម្បត្តិជនទាំងនោះ មួយអន្លើដោយរទេះ នាំគ្នាទៅ ។ ក្នុងថ្ងៃនោះ គ្រាន់តែថ្ងៃរះប៉ុណ្ណោះឯង ពួកអ្នកស្រុកទាំងនោះ ក៏និយាយគ្នាថា គោរបស់អញ រទេះត្រូវជារបស់អញ ភណ្ឌៈត្រូវជារបស់អញ នាំគ្នារត់ទៅកាន់គល់ឈើនោះ កាលឃើញមនុស្សទាំងឡាយមានសួស្តី ក៏សាកសួរថា ពួកអ្នកដឹងបានដូចម្តេចថា ដើមឈើនេះមិនមែនដើមស្វាយ អ្នកទាំងនោះក៏ឆ្លើយថា ពួកខ្ញុំមិនដឹងទេ តែលោកម្ចាស់របស់ពួកខ្ញុំ ដឹង ទើបពួកមនុស្សសួរព្រះពោធិសត្វថា នែបណ្ឌិត លោកធ្វើដូចម្តេច ទើបដឹងថា ដើមឈើនេះមិនមែនដើមស្វាយ ព្រះពោធិសត្វប្រាប់ថា ខ្ញុំដឹងដោយហេតុ ២ ប្រការ ហើយពោលគាថានេះថា

> ឈើនេះ មិនមែនលំបាកឡើង ទាំងមិនឋិតនៅឆ្ងាយអំពីស្រុក ខ្ញុំ
> ដឹងបានដោយហេតុ ( នេះ ) ឈើនេះ មិនមែនមានផ្លែស្រួល
> ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាយំ រុក្ខោ ទុរារុហោ** សេចក្តីថា ព្រះពោធិសត្វពោលថា ដើមឈើពុលនេះ ឡើងមិនលំបាក បុគ្គលណាម្នាក់ ក៏អាចឡើងបានងាយ ដូចមានមនុស្សដាក់បង្អោងពាក់ ។

បទថា **ឆបិ គាមតោ អារកា** សេចក្តីថា ព្រះពោធិសត្វសម្តែងថា

ទាំងតាំងនៅមិនឆ្ងាយអំពីភូមិស្រុក គឺតាំងនៅជិតទ្វារស្រុកនោះឯង ។

បទថា **អាការកេន ជានាមិ** សេចក្ដីថា ដោយហេតុ ២ ប្រការនេះ ទើបខ្ញុំស្គាល់ដើមឈើនេះ ។

សួរថា ស្គាល់ដូចម្ដេច ឆ្លើយថា ស្គាល់ថា ដើមឈើនេះ មិនមានផ្លែស្រួលទេ អធិប្បាយថា បើដើមឈើនេះមានផ្លែឆ្ងាញ់ ជាដើមស្វាយសោត ក្នុងកាលដើមនេះឡើងបានងាយ ហើយក៏តាំងនៅមិនឆ្ងាយយ៉ាងនេះ ផ្លែរបស់វា នឹងមិនសេសសល់ សូម្បីត្រឹមមួយផ្លែឡើយ ត្រូវមនុស្សអ្នកស៊ីផ្លែឈើ បោមពោមបេះជានិច្ចនោះឯង ខ្ញុំកំណត់ដោយការដឹងរបស់ខ្លួនយ៉ាងនេះ ទើបដឹងបានដល់ភាពដែលដើមឈើនេះ ជាដើមឈើពុល ។

ព្រះពោធិសត្វសម្ដែងធម៌ដល់មហាជនហើយ ក៏ទៅដោយសួស្ដី ។

សូម្បីព្រះបរមសាស្ដា ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន បណ្ឌិតទាំងឡាយ ក៏ធ្លាប់ជាអ្នកឈ្លាសក្នុងការមើលផ្លែឈើមកហើយយ៉ាងនេះ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយយ៉ាងនេះ ទ្រង់ក៏បន្តអនុសន្ធិ ប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯនាយឈ្មួញរទេះ គឺបានជាតថាគតនេះឯង ៗ៚

**អដ្ឋកថា ផលជាតក ចប់**

# សុត្តន្តបិដក

## បញ្ញាវុធជាតក

[ ៥៥ ] ( ព្រះសាស្ដាទ្រង់ត្រាស់ថា ) បុរសណា មានចិត្តមិនរួញរា ចម្រើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្ត មិនរួញរា បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅ នៃសំយោជនៈទាំង ពួង តាមលំដាប់ ។

*បញ្ចាវុធជាតកទី ៥ ចប់*

# អដ្ឋកថា

## បញ្ចាវុធជាតក

[ ៥៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានសេចក្តីព្យាយាមធូរថយមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ អលីនេន ចិត្តេន** ដូច្នេះជាដើម ។

ព្រះបរមសាស្តាត្រាស់ហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុពិតឬ ដែលថា អ្នកជាបុគ្គលមានសេចក្តីព្យាយាមធូរថយ កាលលោកក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយ ធ្វើសេចក្តីព្យាយាមក្នុងទីដែលគួរប្រកបព្យាយាម ក៏បានសម្រេចដល់នូវរាជសម្បត្តិហើយ ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះរាជាអង្គនោះ ក្នុងថ្ងៃដែលថ្វាយព្រះនាមព្រះពោធិសត្វនោះ រាជត្រកូលបានញុំាងព្រាហ្មណ៍ ១០៨ ឲ្យឆ្អែតស្កប់ស្កល់ដោយរបស់ដែលគួរប្រាថ្នា សព្វប្រការហើយសាកសួរលក្ខណៈរបស់ព្រះរាជកុមារ ។ ពួកព្រាហ្មណ៍ដែលឈ្លាសក្នុងការទាយលក្ខណៈ ឃើញនូវភាពសម្បូរដោយលក្ខណៈហើយ ក៏នាំគ្នាទាយថា បពិត្រមហារាជ ព្រះរាជកុមារសម្បូរដោយបុញ្ញាធិការ កាលទ្រង់សោយទិវង្គតហើយ នឹងត្រូវគ្រងរាជសម្បត្តិ នឹងមានឈ្មោះបោះសំឡេង ប្រាកដដោយការប្រើអាវុធ ៥ យ៉ាង ជាអគ្គបុរសក្នុងជម្ពូទ្វីបទាំងមូល ។ ព្រោះបានស្តាប់ពាក្យព្យាកររបស់ព្រាហ្មណ៍ទាំងឡាយ កាលនឹងថ្វាយព្រះនាម ក៏ថ្វាយ

ថា បញ្ចាវុធកុមារ ។ កាលព្រះរាជកុមារនោះដឹងក្តីហើយ មានព្រះជន្ម ១៦ វស្សា ព្រះរាជាត្រាស់ហៅមក ហើយត្រាស់ថា នែកូន ចូរអ្នករៀនសិល្ប៍-សាស្ត្រចុះ ។ ព្រះរាជកុមារទូលសួរថា ទូលបង្គំនឹងរៀនក្នុងសម្នាក់របស់អ្នកណា ព្រះរាជាត្រាស់ថា ទៅចុះបា ចូរទៅរៀនក្នុងសម្នាក់អាចារ្យទិសាបា-មោក្ខ ក្នុងនគរតក្កសិលា ដែនគន្ធារៈ ហើយឲ្យនូវទ្រព្យជាតម្លៃបូជាគុណដល់លោកចុះ ហើយព្រះរាជទានទ្រព្យ ១០០០ កហាបណៈ បញ្ជូនទៅ ។ ព្រះរាជកុមារយាងទៅកាន់សម្នាក់អាចារ្យទិសាបាមោក្ខនោះ ទ្រង់សិក្សាសិប្បៈ ទទួលអាវុធ ៥ ដែលអាចារ្យឲ្យ ថ្វាយបង្គំលាអាចារ្យ ចេញអំពីនគរតក្ក-សិលា សៀតអាវុធទាំង ៥ ជាប់នឹងកាយ ធ្វើដំណើរមកនគរពារាណសី ។ ក្នុងរវាងផ្លូវ ទ្រង់យាងមកដល់តំបន់មួយ ជាព្រៃជ្រៅដែលសិលេសលោម-យក្ខ អាស្រ័យនៅ ។ កាលនោះ ពួកមនុស្សឃើញព្រះរាជកុមារត្រង់មាត់ព្រៃ នាំគ្នាឃាត់ថា នែមាណពដ៏ចម្រើន អ្នកកុំចូលកាន់ព្រៃនេះ ក្នុងព្រៃនេះមាន យក្ខឈ្មោះសិលេសលោម នៅអាស្រ័យ យក្ខនោះធ្វើមនុស្សដែលខ្លួនឃើញឲ្យស្លាប់ច្រើនហើយ ។

ព្រះពោធិសត្វប្រយ័ត្នខ្លួន មិនធ្វេសប្រហែលឡើយ ចូលព្រៃតែម្នាក់ឯងដូចកេសរសីហរាជ ដែលមិនភ័យខ្លាច ដូច្នោះ ។ លុះដល់កណ្តាលព្រៃ យក្ខនោះក៏កាឡាខ្លួន កម្ពស់មួយដូវត្នោត ក្បាលប៉ុនផ្ទះកំពូល ភ្នែកម្ខាងៗ ប៉ុនកន្ទេះ ចង្កូមទីមួយៗ ប៉ុនត្រយោងចេក មុខស ពោះពពាល ដៃ និងជើងពណ៌ខៀវ ហើយសម្តែងខ្លួនឲ្យព្រះពោធិសត្វឃើញ ស្រែកថា ឯងទៅណា

ឈប់សិន ឯងត្រូវជាអាហាររបស់យើង ។ គ្រានោះ ព្រះពោធិសត្វសម្មុត យក្ខថា នែយក្ខ ខ្ញុំត្រៀមខ្លួនហើយ ទើបចូលមកក្នុងព្រៃ ឯងកុំប្រហែស ចូលមកជិតខ្ញុំ ព្រោះខ្ញុំនឹងបាញ់ឯងដោយព្រួញដែលលាបដោយពិស ឲ្យដួល ចុះត្រង់នេះឯង ហើយហូតព្រួញដែលឆ្អែតដោយថ្នាំពិសដ៏ខ្លាំងក្លា បាញ់ទៅ ។ ព្រួញទៅជាប់ត្រង់រោមរបស់យក្ខទាំងអស់ ។ ព្រះពោធិសត្វលែងព្រួញទៅបន្ត គ្នា មួយហើយមួយទៀត ដោយអាការយ៉ាងនេះ អស់ព្រួញ ៥០ ព្រួញទាំង អស់ ជាប់ត្រង់រោមយក្ខប៉ុណ្ណោះ យក្ខរលាស់ព្រួញទាំងអស់ឲ្យធ្លាក់ចុះក្បែរ ជើងខ្លួននោះឯង ហើយស្ទុះចូលមករកព្រះពោធិសត្វ ។ ព្រះពោធិសត្វគំរាម យក្ខទៀត ហើយដកព្រះខ័នកាប់ ។ ព្រះខ័នប្រវែង ៣៣ ធ្នាប់ ក៏ជាប់ត្រង់ រោមយក្ខទៀត ។ គ្រានោះ ព្រះពោធិសត្វក៏ចាក់យក្ខដោយលំពែង ។ សូម្បី លំពែង ក៏ជាប់ត្រង់រោមនោះឯង ។ កាលព្រះពោធិសត្វជ្រាបថា យក្ខមាន រោមស្អិត ហើយទើបវាយដោយដំបងៗ ក៏ជាប់ត្រង់រោមយក្ខនោះឯង ។ ព្រះ ពោធិសត្វដឹងអាការដែលយក្ខមានខ្លួនស្អិតនោះឯង ក៏សម្តែងសីហនាទ ដោយ មិនតក់ស្លុត ប្រកាសថា នែយក្ខ ឯងមិនធ្លាប់ឮឈ្មោះយើងថា បញ្ចាវុធ- កុមារទេឬ កាលយើងចូលព្រៃដែលអ្នកនៅអាស្រ័យ ក៏ត្រៀមអាវុធ មានធ្នូ ជាដើមចូលមក យើងត្រៀមព្រមមកហើយនោះឯង ថ្ងៃនេះ យើងនឹងវាយ ឯងឲ្យបែកជាលម្អិតតូច-ធំ ហើយស្ទុះចូលដាល់ដោយដៃខាងស្តាំ កាលដៃ ខាងស្តាំជាប់រោម ក៏ដាល់ដោយដៃខាងឆ្វេង កាលដៃឆ្វេងជាប់ទៀត ក៏ទាត់ ដោយជើងស្តាំ កាលជើងស្តាំជាប់ក៏ទាត់ដោយជើងឆ្វេង ជើងឆ្វេងក៏ជាប់ទៀត

គិតថា ត្រូវទន្ទិចយក្ខនេះដោយក្បាល ហើយក៏បោកដោយក្បាលៗ ក៏ជាប់ត្រង់រោមយក្ខដូចគ្នា ។ ព្រះពោធិសត្វជាប់ធ្ងន់ក្នុងទីទាំង ៥ តែក៏មិនខ្លាច មិនញាប់ញ័រឡើយ ។

យក្ខគិតថា បុរសនេះមានតែមួយ ជាបុរសសីហៈ ជាបុរសអាជានេយ្យ មិនមែនបុរសធម្មតា សូម្បីត្រូវយក្ខដូចអញចាប់ ក៏មិនតក់ស្លុតឡើយ ក្នុងផ្លូវនេះ អញសម្លាប់មនុស្សច្រើន មិនធ្លាប់ឃើញបុរសយ៉ាងនេះ តែម្នាក់ទេ ព្រោះហេតុអ្វីហ្ន៎ ទើបបុរសមិនខ្លាច យក្ខមិនអាចស៊ីព្រះពោធិសត្វ ទើបសួរថា នៃមាណព ព្រោះហេតុអ្វី ទើបអ្នកមិនខ្លាចស្លាប់ ព្រះពោធិសត្វឆ្លើយថា នៃយក្ខ រឿងអ្វីដែលយើងត្រូវខ្លាច ព្រោះក្នុងអត្តភាពមួយ ការស្លាប់នោះជារបស់ទៀងនោះឯង ប្រការមួយទៀត ក្នុងពោះរបស់យើងមានវជិរាវុធ ទោះបីអ្នកស៊ីយើង ក៏មិនអាចធ្វើអាវុធនោះឲ្យរលាយបាន អាវុធនោះ នឹងត្រូវមុតពោះវៀនរបស់អ្នកដាច់ជាកំណាត់ៗ តូចខ្លះ ធំខ្លះ ធ្វើឲ្យអ្នកអស់ជីវិតបាន ដោយហេតុដូចពោលមកនេះ យើងត្រូវស្លាប់ទាំង ២ ដោយហេតុនេះ ទើបយើងមិនខ្លាចស្លាប់ ។ បានឮថា ពាក្យថា វជិរាវុធនេះ ព្រះពោធិសត្វត្រាស់សំដៅដល់ អាវុធ គឺញាណខាងក្នុងព្រះអង្គ ។ យក្ខស្តាប់ពាក្យនោះហើយគិតថា មាណពនេះនិយាយពិតទាំងអស់ ដុំសាច់ សូម្បីត្រឹមប៉ុនគ្រាប់សណ្តែកបាយ អំពីរាងកាយរបស់បុរសសីហៈនេះ បើអញលេបចូលទៅក្នុងពោះ ក៏មិនអាចឲ្យរលួយបាន អញនឹងលែងបុរសនេះ ដូច្នេះហើយ កើតនូវការខ្លាចស្លាប់ ទើបលែងព្រះពោធិសត្វ ហើយពោលថា នៃមាណព អ្នកជាបុរស

សីហៈ ខ្ញុំមិនបរិភោគសាច់របស់អ្នកឡើយ ថ្ងៃនេះ អ្នកផុតចាកកណ្ដាប់ដៃរបស់ខ្ញុំ ដូចព្រះចន្ទផុតចាកមាត់រាហូ ចូរអ្នកទៅចុះ ពួកញាតិនឹងត្រេកអរ ។

គ្រានោះ ព្រះពោធិសត្វត្រាស់នឹងយក្ខថា នែយក្ខ ខ្ញុំត្រូវទៅមុន ឯអ្នកបានធ្វើអកុសលក្នុងកាលមុនហើយ ទើបកើតជាបុគ្គលកាចសាហាវ ដៃប្រឡាក់ដោយឈាម មានឈាម និងសាច់របស់ មនុស្សជាអាហារ បើអ្នកតាំងនៅក្នុងអត្តភាពនេះ នៅតែធ្វើអកុសលកម្មទៀត ក៏នឹងទៅកាន់ភាពងងឹត ចាកភាពងងឹត តាំងអំពីអ្នកជួបខ្ញុំហើយ ខ្ញុំមិនអាចបណ្ដោយឲ្យអ្នកធ្វើអកុសល-កម្ម បានឈ្មោះថា កម្ម គឺការញុំាងជីវិតសត្វឲ្យធ្លាក់ចុះ រមែងធ្វើសត្វឲ្យកើតក្នុងនគរ ក្នុងកំណើតតិរច្ឆាន ក្នុងបិត្តិវិស័យ និងក្នុងអសុរកាយ កាលមកកើតជាមនុស្ស ក៏ធ្វើឲ្យមានអាយុខ្លី ដូច្នេះហើយ ទើបត្រាស់ទោសក្នុងទុស្សី-លកម្មទាំង ៥ ដោយន័យខាងដើមនោះ ហើយទ្រង់សម្ដែងអានិសង្សនៃសីលទាំង ៥ ទូន្មានយក្ខដោយហេតុផ្សេងៗ ទ្រង់សម្ដែងធម៌ ធ្វើឲ្យយក្ខអស់ព្យសន៍កំណាច ដឹកនាំឲ្យតាំងនៅក្នុងសីល ៥ ធ្វើយក្ខនោះឲ្យជាទេវតា ទទួលពលីកម្មក្នុងព្រៃនោះ ហើយដាស់តឿនដោយអប្បមាទធម៌ ចេញអំពីព្រៃ ប្រាប់ដល់មនុស្សដែលនៅត្រង់មាត់ព្រៃ សៀតអាវុធទាំង ៥ ប្រចាំព្រះអង្គ យាងទៅកាន់នគរពារាណសី គាល់ព្រះរាជបិតា ព្រះរាជមាតា ក្រោយមក បានគ្រងរាជ្យ ក៏ទ្រង់គ្រប់គ្រងដោយធម៌ ទ្រង់បំពេញបុណ្យ មានទានជាដើម យាង

ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទើបត្រាស់ព្រះគាថានេះថា

បុរសណា មានចិត្តមិនរួញរា ចម្រើនកុសលធម៌ ដើម្បីដល់នូវ
ព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តមិនរួញរា បុរសនោះ
គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅ នៃសំយោជនៈទាំងពួង តាម
លំដាប់ ដូច្នេះ ។

ក្នុងព្រះគាថានោះ មានអត្ថដូចតទៅនេះ បុរសណាមានចិត្តមិនរួញរា គឺមិនរារែក មានចិត្តមិនរួញរាដោយប្រក្រតី ជាអ្នកមានអធ្យាស្រ័យពិតប្រាកដ ចម្រើននូវធម៌ ដែលបានឈ្មោះថា កុសល បានដល់ ពោធិបក្ខិយធម៌ ៣៧ ប្រការ ព្រោះអត្ថថា ជាធម៌ប្រាសចាកទោស បំពេញវិបស្សនា ដោយចិត្តដ៏ទូលាយ ដើម្បីសម្រេចនូវការក្សេមចាកយោគៈទាំង ៤ ពោល គឺព្រះនិព្វាន បុរសនោះ លើកឡើងនូវត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ក្នុងសង្ខារទាំងឡាយយ៉ាងនេះហើយ ញ៉ាំងពោធិបក្ខិយធម៌ដែលកើតឡើង តាំងអំពីវិបស្សនានៅទន់ខ្ចីឲ្យចម្រើន គប្បីសម្រេចអរហត្តផល ដែលដល់នូវការរាប់ថា ការអស់សំយោជនៈគ្រប់យ៉ាង ព្រោះកើតហើយ ក្នុងទីបំផុតនៃមគ្គទាំង ៤ ដែល

ជាហេតុអស់ទៅនៃសំយោជនៈទាំងឡាយ មិនមានសេសសល់ ត្រឹមតែសំយោជនៈ ១ ដោយលំដាប់ ។

ព្រះបរមសាស្ដា ទ្រង់កាន់យកកំពូលព្រះធម្មទេសនាដោយអរហត្តផល ដោយប្រការដូច្នេះ ក្នុងទីបំផុតទ្រង់ប្រកាសចតុរារិយសច្ច ក្នុងកាលចប់សច្ចធម៌ ភិក្ខុនោះ បានសម្រេចអរហត្តផល ។ ព្រះសាស្ដាទ្រង់ក៏បន្តអនុសន្ធិប្រជុំជាតកថា យក្ខក្នុងកាលនោះ បានមកជាអង្គុលិមាល ក្នុងកាលឥឡូវនេះ ឯបញ្ចាវុធកុមារ គឺតថាគតនេះឯង ។៚

**អដ្ឋកថា បញ្ចាវុធជាតក ចប់**

# សុត្តន្តបិដក

## កញ្ចនក្ខន្ធជាតក

[ ៥៦ ] *( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) បុរសណា មានចិត្តរីករាយ ចម្រើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តដែលរីករាយ បុរសនោះ គប្បីដល់ធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួងតាមលំដាប់ ។*

**កញ្ចនក្ខន្ធជាតកទី ៦ ចប់**

# អដ្ឋកថា

## កញ្ចនក្ខន្ធជាតក

[ ៥៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ បហដ្ឋេន ចិត្តេន** ដូច្នេះជាដើម ។

បានឮថា កុលបុត្តអ្នកក្រុងសាវត្ថីម្នាក់ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ បួសថ្វាយជីវិតក្នុងព្រះសាសនា គឺព្រះរតនត្រ័យ ។ កាលនោះ អាចារ្យ និងឧបជ្ឈាយ៍របស់លោកទូន្មានដល់សីលថា អាវុសោ ឈ្មោះថាសីល មាន ១ ក៏មាន មាន ២ ក៏មាន មាន ៣ ក៏មាន មាន ៤ ក៏មាន មាន ៥ ក៏មាន មាន ៦ ក៏មាន មាន ៧ ក៏មាន មាន ៨ ក៏មាន មាន ៩ ក៏មាន មាន ១០ ក៏មាន ។ ដែលឈ្មោះថា សីល មានច្រើនយ៉ាង គឺចូឡសីល មជ្ឈិមសីល មហាសីល បាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល បច្ចយបដិសេវនសីល ។ ភិក្ខុនោះគិតថា ឈ្មោះថាសីលនេះ មានច្រើនពន់ពេក អញមិនអាចសមាទាន ប្រព្រឹត្តដល់ប៉ុណ្ណោះបាន បព្វជ្ជារបស់អ្នកដែលមិនអាចបំពេញសីលឲ្យបរិបូណ៌បាន នឹងមានប្រយោជន៍អ្វី អញនឹងទៅជាគ្រហស្ថ ធ្វើបុណ្យ ឲ្យទានជាដើម ចិញ្ចឹមកូនប្រពន្ធ កាលគិតយ៉ាងនេះហើយ ក៏ប្រាប់អាចារ្យ និងឧបជ្ឈាយ៍ថា បពិត្រលោកម្ចាស់ ខ្ញុំមិនអាចរក្សាសីលបានទេ កាលមិនអាចរក្សាសីលបាន បព្វជ្ជានឹងមានប្រយោជន៍អ្វី ខ្ញុំនឹងលាសិក្ខា សូមលោកម្ចាស់ទទួលបាត្រ និងចីវររបស់លោកម្ចាស់វិញចុះ ។ លំដាប់នោះ អាចារ្យ និងឧបជ្ឈាយ៍ប្រាប់ភិក្ខុនោះថា អាវុសោ

បើដូច្នោះ ចូរលោកទៅថ្វាយបង្គំព្រះទសពល ដូច្នេះហើយ នាំទៅកាន់ធម្មសភា ដែលជាទីគង់នៅរបស់ព្រះសាស្តា ។

ព្រះសាស្តាទតឃើញភិក្ខុនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនប្រាថ្នាមកឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះប្រាប់ថា មិនអាចរក្សាសីលបាន ទើបប្រគល់បាត្រ និងចីវរឲ្យវិញ កាលបើដូច្នោះ ទើបខ្ញុំព្រះអង្គទាំងឡាយនាំមក ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី ទើបពួកអ្នកប្រាប់សីលដល់ភិក្ខុនេះច្រើនម៉្លេះ ភិក្ខុនេះអាចរក្សាបានប៉ុនណា គប្បីរក្សាប៉ុណ្ណោះឯង តាំងអំពីនេះតទៅ ពួកអ្នកកុំពោលពាក្យណាមួយ ជាមួយភិក្ខុនេះឡើយ តថាគតប៉ុណ្ណោះនឹងដឹងដល់ការដែលគួរធ្វើ ហើយត្រាស់នឹងភិក្ខុនោះថា មកភិក្ខុ អ្នកត្រូវការសីលច្រើនៗ ធ្វើអ្វី អ្នកមិនអាចរក្សាសីល ៣ ប្រភេទប៉ុណ្ណោះឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចរក្សាបាន ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ តាំងអំពីឥឡូវនេះ ចូរអ្នករក្សាទ្វារទាំង ៣ គឺកាយទ្វារ វចីទ្វារ មនោទ្វារ កុំធ្វើកម្មអាក្រក់ដោយកាយ កុំធ្វើកម្មអាក្រក់ដោយវាចា កុំធ្វើកម្មអាក្រក់ដោយចិត្ត ទៅចុះ កុំសឹកឡើយ ចូររក្សាសីល ៣ នេះប៉ុណ្ណោះចុះ ។ ព្រះពុទ្ធតម្រាស់ត្រឹមប៉ុណ្ណោះ ភិក្ខុនោះក៏មានចិត្តត្រេកអរ ក្រាបទូលថា សាធុ ព្រះអង្គ ខ្ញុំព្រះអង្គនឹងរក្សាសីលទាំង ៣ នេះ ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅ មួយអន្លើដោយអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ កាលលោកបំពេញសីលទាំង ៣ នោះឯង ទើបពិចារណាថា សីលដែលអាចារ្យ

និងឧបជ្ឈាយ៍ ប្រាប់ដល់អញក៏មានប៉ុណ្ណោះឯង តែលោកទាំងនោះ មិនអាចឲ្យអញយល់បាន ព្រោះលោកមិនមែនជាព្រះពុទ្ធ ព្រះសម្មាសម្ពុទ្ធទ្រង់សង្គ្រោះសីលទាំងអស់នេះចូលក្នុងទ្វារ ៣ ប៉ុណ្ណោះ ឲ្យអញកាន់យកបាន ព្រោះទ្រង់ជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាអ្នកដឹងល្អ ព្រោះទ្រង់ជាធម្មរាជាដ៏កំពូល ទ្រង់ជាទីពឹងរបស់អញពិត ដូច្នេះហើយ ចម្រើនវិបស្សនា តាំងនៅក្នុងអរហត្តផលក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយដឹងការប្រព្រឹត្តនោះហើយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាគ្នាដល់ពុទ្ធគុណថា អាវុសោទាំងឡាយបានឮថា ភិក្ខុនោះពោលថា មិនអាចរក្សាសីលទាំងឡាយបាន គិតនឹងសឹកព្រះសាស្តាទ្រង់សង្ខេបសីលទាំងអស់ដោយចំណែក ៣ ឲ្យលោកទទួលយកបាន ហើយសម្រេចអរហត្តផល ឱ! ឈ្មោះថាព្រះពុទ្ធទាំងឡាយ ជាអច្ឆរិយបុរសហ្ន៎ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលពួកភិក្ខុក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភារៈដ៏ធ្ងន់ក្រៃលែង តថាគតចែកដោយចំណែកតូចឲ្យហើយ ដូចជារបស់ស្រាលៗទោះបីក្នុងកាលមុន បណ្ឌិតទាំងឡាយ បានដុំមាសធំ មិនអាចលើកឡើងបានក៏ចែកជាចំណែកតូចៗ ហើយលើកទៅបាន ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរ

ពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអ្នកស្រែ នៅក្នុងជនបទមួយ ។ ថ្ងៃមួយ កំពុងតែភ្ជួរស្រែត្រង់ស្រុកដែលគេបោះបង់មួយកន្លែង ។ កាលមុន ផ្ទះមួយ ក្នុងស្រុកនោះ ធ្លាប់មានសេដ្ឋីដែលសម្បូរដោយសម្បត្តិ កប់មាស មួយដុំធំប៉ុនគល់ភ្លៅ បណ្តោយប្រមាណ ៤ ហត្ថ ហើយក៏ស្លាប់ទៅ ។ នង្គ័ល របស់ព្រះពោធិសត្វទៅជាប់ត្រង់ដុំមាសនោះ ហើយឈប់ ។ ព្រះពោធិសត្វ គិតថា ប្រហែលជាឫសឈើ ទើបកាយដីមើល ឃើញដុំមាសនោះហើយ ក៏ លុបដោយដីភ្ជួរទៅទៀតអស់មួយថ្ងៃ កាលព្រះអាទិត្យអស្តង្គតហើយ ទើប ទុកដាក់សម្ភារៈ មាននឹម និងនង្គ័លជាដើម ក្នុងទីសមគួរមួយកន្លែង គិតថា នឹងលីយកដុំមាសទៅ តែមិនអាចលីរួច ទើបអង្គុយចុះ បែកជា ៤ ចំណែក ដោយគិតថា នឹងចិញ្ចឹមក្រពះប៉ុណ្ណេះ កប់ប៉ុណ្ណេះ សងបំណុលប៉ុណ្ណេះ ធ្វើ បុណ្យជាដើមប៉ុណ្ណេះ លុះបែងចែកយ៉ាងនោះហើយ ដុំមាសនោះក៏ស្រាល ។ ព្រះពោធិសត្វ លើកយកដុំមាសនោះទៅផ្ទះ បែងចែកជា ៤ ចំណែក ធ្វើ បុណ្យមានទានជាដើម ហើយក៏ទៅតាមយថាកម្ម ។

ព្រះមានព្រះភាគត្រាស់ដឹងក្រៃលែងហើយ ទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងដូច្នេះហើយ ទើបត្រាស់គាថានេះថា

បុរសណា មានចិត្តរីករាយ ចម្រើនកុសលធម៌ ដើម្បីដល់នូវ ព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តដែលរីករាយ បុរស នោះ គប្បីដល់ធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាម លំដាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បហាដ្ឋេន** បានដល់ ប្រាសចាកនីវរណៈ ។ បទថា **បហដ្ឋមនសោ** សេចក្តីថា ព្រោះហេតុដែលមានចិត្តប្រាសចាកនីវរណៈនោះឯង ទើបឈ្មោះថា មានចិត្តត្រេកអរហើយ ដូចដុំមាស គឺជាបុគ្គលមានចិត្តរុងរឿងភ្លឺស្វាងហើយ ។

ព្រះបរមសាស្តាទ្រង់ញ៉ាំងទេសនាឲ្យចប់ដោយកំពូល គឺអរហត្ត ដោយប្រការដូច្នេះហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា បុរសបានដុំមាស ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា កញ្ចនក្ខន្ធជាតក ចប់**

# សុត្តន្តបិដក

## វានរិន្ទជាតក

[ ៥៧ ] ( ក្រពើពោលថា ) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្តីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។

**វានរិន្ទជាតកទី ៧ ចប់**

# អដ្ឋកថា

## វានរិន្ទជាតក

[ ៥៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការខ្នះខ្នែង ដើម្បីសម្លាប់របស់ទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យស្សេតេ ចតុរោ ធម្មា** ដូច្នេះជាដើម ។

ក្នុងសម័យនោះ ព្រះសាស្ដាទ្រង់ស្ដាប់ដំណឹងថា ទេវទត្តកំពុងខ្នះខ្នែង ដើម្បីផ្ដាច់ព្រះជន្ម ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាមខ្នះខ្នែងដើម្បីសម្លាប់តថាគត សូម្បីក្នុងកាលមុន ក៏ធ្លាប់ខ្នះខ្នែងហើយដូចគ្នា តែមិនអាចធ្វើហេតុត្រឹមតែការតក់ស្លុតឲ្យដល់តថាគតបានឡើយ ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធក: ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាស្ដេចស្វា ។ កាលចម្រើនវ័យ មានរាងកាយធំធាត់ ប៉ុនកូនសេះ សម្បូរដោយកម្លាំង ត្រាច់ទៅតាមច្រាំងស្ទឹងរស់នៅ ។ ត្រង់កណ្ដាលស្ទឹងនោះ មានកោះមួយសម្បូរដោយដើមឈើ ដែលមានផ្លែច្រើនប្រភេទ មានស្វាយ និងខ្នុរជាដើម ។ ព្រះពោធិសត្វមានកម្លាំងដូចដំរីសារ សម្បូរដោយសម្ពុះ លោតអំពីច្រាំងអាយហើយ ទៅសម្រាកត្រង់ថ្មដាមួយដែលដុះផុតអំពីទឹក ចន្លោះច្រាំង និងកោះ លោតអំពីថ្មនោះហើយ ក៏ឡើងលើកោះនោះបាន ទំពាស៊ីផ្លែឈើផ្សេងៗ លើកោះនោះ លុះ

ដល់ពេលល្ងាច ក៏លោតត្រឡប់មក ដោយឧបាយនោះ ដល់លំនៅរបស់ខ្លួន ព្រឹកឡើងក៏ធ្វើដូច្នោះទៀត អាស្រ័យនៅក្នុងទីនោះ ដោយទំនៀមនេះឯង ។

ក្នុងសម័យនោះ មានក្រពើមួយ មួយអន្ទើដោយក្រពើញីអាស្រ័យនៅក្នុងស្ទឹងនោះ ក្រពើញីឃើញព្រះពោធិសត្វលោតទៅលោតមក ចាញ់ផ្ទៃចង់បរិភោគសាច់បេះដូងរបស់ព្រះពោធិសត្វ ទើបនិយាយនឹងក្រពើឈ្មោលថា នែអ្នកបង ខ្ញុំចាញ់ផ្ទៃ ចង់បរិភោគសាច់បេះដូងរបស់ស្វានេះ ក្រពើឈ្មោលពោលថា បាន នាងពិតជាបាន ហើយពោលបន្តថា ថ្ងៃនេះ បងនឹងឃ្មាំចាប់កាលស្វាត្រឡប់មកអំពីកោះក្នុងវេលាល្ងាចហើយ ក៏ទៅដេករង់ចាំលើផ្ទាំងថ្ម ។

ព្រះពោធិសត្វ ត្រាច់ទៅអស់មួយថ្ងៃ ដល់វេលាល្ងាច ក៏ឈរត្រង់កោះសម្លឹងមើលផ្ទាំងថ្មហើយ ត្រិះរិះថា ឥឡូវនេះ ផ្ទាំងថ្មនេះខ្ពស់ជាងមុន ព្រោះហេតុអ្វីហ្ន៎ បានឮថា ប្រមាណរបស់ទឹក និងប្រមាណរបស់ផ្ទាំងថ្ម ព្រះពោធិ-សត្វកំណត់យ៉ាងល្អហើយ ដោយហេតុនោះ ទើបមានបរិវិតក្កថា ថ្ងៃនេះ ទឹកក៏មិនស្រក នឹងមិនឡើងទេ បើដូច្នេះ ថ្មនេះខ្ពស់ឡើង ក្រពើដេកចាំខាំអញលើថ្មនោះទេដឹង ។ ព្រះពោធិសត្វគិតថា អញនឹងសាកល្បងមើល ឈរវេរាត្រង់នោះឯង ។ ធ្វើជានិយាយនឹងថ្មថា នែថ្មដ៏ចម្រើន ក៏នៅតែគ្មានចម្លើយ ស្វាក៏ពោលទៀតថា នែថ្មដ៏ចម្រើន អស់ ៣ ដង ថ្មនឹងឆ្លើយបានដូចម្តេច ។ ពានរនៅតែនិយាយនឹងថ្មទៀតថា នែថ្មដ៏ចម្រើន ហេតុអ្វី ទើបថ្ងៃនេះមិនឆ្លើយនឹងពាក្យរបស់ខ្ញុំ ។ ក្រពើស្តាប់ហើយ គិតថា ក្នុងថ្ងៃដទៃៗ ថ្មនេះប្រហែលជាឆ្លើយនឹងស្វាដោយពិត ឥឡូវនេះ អញនឹងឆ្លើយ ហើយពោលថា មានការអ្វី

ពានរិន្ទដ៏ចម្រើន ។ ព្រះពោធិសត្វសួរថា អ្នកជានរណា ក្រពើពោលថា យើងជាក្រពើ ស្វាពោលថា អ្នកដេកទីនេះដើម្បីអ្វី ក្រពើពោលថា ដើម្បីសាច់បេះដូង ។

ព្រះពោធិសត្វត្រិះរិះថា អញមិនមានផ្លូវដទៃសម្រាប់ទៅ ថ្ងៃនេះ អញត្រូវបញ្ឆោតក្រពើនេះ ។ លុះគិតហើយ ទើបនិយាយនឹងក្រពើថា នែសម្លាញ់ យើងនឹងកាត់បេះដូង លះរាងកាយឲ្យអ្នក ចូរអ្នកហាមាត់ចាំត្របាក់យើង ក្នុងកាលដែលយើងទៅដល់ខ្លួនអ្នក ។ ធម្មតាក្រពើ កាលហាមាត់ ភ្នែកទាំង ២ នឹងត្រូវបិទ ។ ក្រពើមិនកំណត់ហេតុនោះ ក៏ហាមាត់រង់ចាំ ភ្នែកក៏បិទ ។ ទើបក្រពើដេកហាមាត់បិទភ្នែករង់ចាំ ។ ព្រះពោធិសត្វដឹងសភាពដូច្នោះ ក៏លោតអំពីកោះ ជាន់ក្បាលក្រពើ ហើយលោតអំពីក្បាលក្រពើ ទៅត្រើយម្ខាងរហ័សដូចផ្លេកបន្ទោរ ។ ក្រពើឃើញហេតុអស្ចារ្យនោះ គិតថា ពានរិន្ទនេះគួរអស្ចារ្យពេកណាស់ ពោលថា ពានរិន្ទដ៏ចម្រើន ក្នុងលោកនេះ អ្នកប្រកបដោយធម៌ ៤ ប្រការ រមែងគ្របសង្កត់សត្រូវបាន ធម៌ទាំងនោះ ប្រហែលជាមានក្នុងខ្លួនអ្នកគ្រប់យ៉ាង ហើយពោលគាថានេះថា

បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្តីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស** បានដល់ បុគ្គលណាម្នាក់ ។ បទថា **ឯតេ** សេចក្តីថា រមែងប្រាកដដោយប្របក្នុងធម៌ ដែលខ្ញុំនឹង

ពោលក្នុងឥឡូវនេះ ។

បទថា **ចតុរោ ធម្មា** បានដល់ គុណធម៌ ៤ ប្រការ ។

បទថា **សច្ចំ** បានដល់ វចីសច្ចៈ គឺប្រាប់ថា នឹងមកកាន់សម្នាក់របស់ខ្ញុំ អ្នកក៏មិនធ្វើឲ្យជាការពោលកុហក មកពិតៗ នោះឯង នេះជាវចីសច្ចៈរបស់អ្នក ។

បទថា **ធម្មោ** បានដល់ វិចារណប្បញ្ញា ពោល គឺការស្គាល់ ពិចារណាថា ធ្វើយ៉ាងនេះហើយ នឹងត្រូវមានផលយ៉ាងនេះ សេចក្ដីនេះជាវិចារណប្បញ្ញារបស់អ្នក ។

សេចក្ដីព្យាយាមដែលមិនធូរថយ លោកហៅថា ធិតិ គុណធម៌នេះ ក៏មានដល់អ្នក ។

បទថា **ចាគោ** បានដល់ ការលះបង់ខ្លួន គឺការដែលអ្នកលះជីវិតមកដល់សម្នាក់របស់ខ្ញុំ តែខ្ញុំមិនអាចចាប់អ្នកបាន នេះជាទោសរបស់ខ្ញុំតែម្យ៉ាង ។

បទថា **ទិដ្ឋំ** បានដល់ បច្ចាមិត្រ ។

បទថា **សោ អតិវត្តតិ** សេចក្ដីថា ធម៌ទាំង ៤ យ៉ាងដូចពណ៌នាមកនេះ មានក្នុងបុគ្គលណា ដូចមានដល់អ្នក បុគ្គលនោះរមែងឈានកន្លង គឺគ្របសង្កត់បានទូវបច្ចាមិត្ររបស់ខ្លួន ដូចអ្នកកន្លងផុតទូវខ្ញុំទៅបាន ក្នុងថ្ងៃនេះដូច្នោះ ។

ក្រពើសរសើរព្រះពោធិសត្វយ៉ាងនេះហើយ ក៏ទៅកាន់លំនៅរបស់ខ្លួន ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនព្យាយាមសម្លាប់តថាគតក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ប្រឹងប្រែងដូចគ្នា ដូច្នេះហើយ ទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិ ប្រជុំជាតកថា ក្រពើក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ប្រពើញីបានមកជានាងចិញ្ចមាណវិកា ឯពានរិន្ទ គឺតថាគតនេះឯង ។ល។

**អដ្ឋកថាវានរិន្ទជាតក ចប់**

# សុត្តន្តបិដក

## តយោធម្មជាតក

[ ៥៨ ] *( អារក្សទឹកពោលថា ) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្ដីសង្វាត ១ សេចក្ដីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។*

***តយោធម្មជាតកទី ៨ ចប់***

# អដ្ឋកថា

## គយោធម្មជាតក

[ ៥៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធការខ្នះខ្នែងរបស់ទេវទត្តដើម្បីសម្លាប់ព្រះអង្គនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្សេតេ ច គយោ ធម្មា** ដូច្នេះជាដើម ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ។ ទេវទត្តកើតក្នុងកំណើតពានរ រក្សាហ្វូងក្នុងហិមវន្តប្បទេស កាលកូនស្វាដែលអាស្រ័យខ្លួនកើតធំហើយ ក៏ខាំផ្តាច់ពូជរបស់កូន ពានរទាំងនោះ ព្រោះខ្លាចពានរទាំងនេះដណ្តើមហ្វូង ។ ក្នុងកាលនោះ ព្រះពោធិសត្វក៏អាស្រ័យពានរនោះឯង បដិសន្ធិក្នុងផ្ទៃរបស់មេស្វាមួយ កាលស្វាញីដឹងថាមានគភ៌ ដើម្បីនឹងរក្សាគភ៌របស់ខ្លួន ក៏បានទៅកាន់ជើងភ្នំមួយដទៃ លុះគភ៌គ្រប់ខែ ក៏កើតព្រះពោធិសត្វ ។ ព្រះពោធិសត្វចម្រើនវ័យ ដល់នូវភាពជាអ្នកដឹងក្តីហើយ ជាអ្នកសម្បូរដោយកម្លាំង ថ្ងៃមួយ សាកសួរមេថា បពិត្រអ្នកម៉ែ អ្នកណាជាបារបស់ខ្ញុំ មេស្វាឆ្លើយថា នែបា ឪពុករបស់បា គ្រប់គ្រងហ្វូងនៅត្រង់ភ្នំនោះ ព្រះពោធិសត្វពោលថា សូមម៉ែនាំខ្ញុំទៅជួបបាចុះ មេស្វាពោលថា នែកូន បាមិនអាចចូលជិតឪពុករបស់បាបានឡើយ ព្រោះឪពុករបស់បាខាំផ្តាច់អង្គជាតកូន ពានរដែលអាស្រ័យខ្លួនកើត ព្រោះខ្លាចដណ្តើមហ្វូង ។ ព្រះពោធិសត្វពោលថា នាំខ្ញុំទៅចុះ ខ្ញុំនឹងដឹង ។ ទើបស្វាញីនាំព្រះពោធិសត្វមកកាន់សម្នាក់របស់ពានរដែលជាបា ។

ពានរនោះឃើញកូនរបស់ខ្លួនហើយ ក៏គិតថា កូនស្វានេះ កាលធំ មិនព្រមឲ្យអញគ្រប់គ្រងហ្វូង អញត្រូវសម្លាប់វាក្នុងកាលឥឡូវនេះឯង អញធ្វើជាឱបវា ហើយរឹតឲ្យណែន ឲ្យអស់ជីវិតទាល់តែបាន ទើបពោលថា នែបា ចូរមកចុះ បាទៅណា បាត់យូរបែបនេះ ដូច្នេះហើយ ធ្វើជាឱបព្រះពោធិសត្វ ហើយរឹតយ៉ាងណែន ។ ព្រះពោធិសត្វមានកម្លាំងដូចដំរីសា សម្បូរដោយថាមពល ទើបឱបរឹតតប ។ កាលនោះ ឆ្អឹងទាំងអស់របស់ពានរនោះ ដល់នូវអាការដាច់ចេញពីគ្នា លំដាប់នោះ ពានរដែលជាឪពុកកើតវិតក្កថា អានេះកាលធំឡើង វានឹងសម្លាប់អញ អញត្រូវរកឧបាយសម្លាប់វាមុន ។ គ្រានោះក៏គិតបានថា មិនឆ្ងាយអំពីទីនេះ មានស្រះដែលមានអារក្ខទឹកនៅអាស្រ័យ អញនឹងឲ្យអារក្ខទឹកស៊ីវាត្រង់ស្រះនោះ ហើយទើបពោលនឹងព្រះពោធិសត្វថា នែកូន ឪពុកចាស់ហើយ នឹងប្រគល់ហ្វូងឲ្យបា ថ្ងៃនេះ នឹងតែងតាំងបាជាប្រធាន ត្រង់ទុំមានស្រះ ក្នុងស្រះនោះ ផ្កាកុមុទ ២ ផ្កាឧប្បល ៣ ផ្កាបទុម ៥ កំពុងរីក ចូរបាទៅចុះ ទៅបេះផ្កាមកអំពីស្រះនោះ ។ ព្រះពោធិសត្វទទួលពាក្យថា សាធុ ខ្ញុំនឹងនាំមក ហើយក៏ទៅ តែក៏មិនប្រញាប់ប្រញាល់ចុះទៅ ពិនិត្យមើលដោយជុំវិញស្រះ ឃើញគន្លងជើងចុះទៅប៉ុណ្ណោះ មិនឃើញស្នាមជើងដែលឡើងមក ក៏ដឹងថា ស្រះនេះពិតជាមានអារក្ខទឹកគ្រប់គ្រងពិតប្រាកដ បារបស់អញ មិនអាចសម្លាប់អញដោយខ្លួនឯង បំណងឲ្យអារក្ខទឹកទំពាស៊ីអញ អញមិនចុះស្រះនេះ នឹងត្រូវបេះផ្កាឲ្យបាន ហើយដើរទៅរកទីដែលមិនមានទឹក លោតទៅ បេះបាន ២ ផ្កានោះឯង ហើយទៅចុះត្រង់ត្រើយនាយ

លោតអំពីត្រើយនាយ មកចុះត្រង់ត្រើយអាយ ក៏ស្រវាបាន ២ ផ្កា ដោយឧបាយនោះឯង ។ ដោយវិធីនេះ ព្រះពោធិសត្វក៏បេះផ្កាបានជាគំនរទាំង ២ នៃប្រាំងស្រះ មិនចាំបាច់ចុះកាន់ទីដែលជាអាជ្ញារបស់អារក្ខទឹក កាលព្រះពោធិសត្វឃើញថា មិនអាចបេះបានច្រើនជាងនេះ ក៏ប្រមូលផ្កាគរជាគំនរនោះឯង កាលនោះ អារក្ខត្រិះរិះថា បុរសអច្ឆរិយៈ មានបញ្ញាយ៉ាងនេះ អញមិនធ្លាប់ឃើញសោះ អស់កាលមានប្រមាណប៉ុណ្ណោះ ផ្កាក៏បេះបានតាមប្រាថ្នា មិនចាំបាច់ចុះកាន់ទីដែលជាអាជ្ញារបស់អញទៀតផង ទើបផុសឡើងអំពីទឹក ចូលទៅរកព្រះពោធិសត្វ ពោលថា នៃពានរិន្ទ ក្នុងលោកនេះ បុគ្គលណា មានធម៌ ៣ ប្រការ បុគ្គលនោះរមែងគ្របសង្កត់បច្ចាមិត្របាន ប្រហែលជាខាងក្នុងខ្លួនរបស់អ្នក មានធម៌ទាំងនោះគ្រប់ប្រការដោយពិត កាលសរសើរព្រះពោធិសត្វ ទើបពោលគាថានេះថា

បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្ដីសង្វាត
១ សេចក្ដីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវ
សត្រូវបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទក្ខិយំ** បានដល់ ភាពជាអ្នកខ្មីឃ្មាត ។ បទនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដ៏ឧក្រិដ្ឋ ដែលប្រកបព្រមដោយបញ្ញា នឹងកម្ចាត់ភ័យដែលមកដល់ ។

បទថា **សូរិយំ** បានដល់ ជាអ្នកក្លាហាន ។ បទនេះ ជាឈ្មោះនៃអ្នកមានសេចក្ដីក្លៀវក្លា ។

បទថា **បញ្ញា** នេះ ជាឈ្មោះនៃអ្នកដឹងឧបាយដែលជាចំណុចចាប់ផ្តើមនៃការប្រោកជផល ។

អារក្ខនោះ សរសើរព្រះពោធិសត្វដោយគាថានេះយ៉ាងនេះហើយ ក៏សួរថា អ្នកបេះផ្កានេះធ្វើអ្វី ព្រះពោធិសត្វឆ្លើយថា ឪពុករបស់ខ្ញុំបំណាងនឹងធ្វើខ្ញុំឲ្យជាម្ចាស់ហ្វូង ខ្ញុំបេះទៅព្រោះហេតុនោះ ។ អារក្ខទឹកពោលថា ឧត្តមបុរសដូចអ្នកមិនគួរនាំផ្កានេះទៅទេ ខ្ញុំនឹងនាំទៅឲ្យ ហើយត្រកងផ្កាដើរតាមក្រោយព្រះពោធិសត្វទៅ ។ កាលនោះ បាព្រះពោធិសត្វឃើញអំពីចម្ងាយ គិតថាអញបញ្ជូនវាទៅបំណាងថា នឹងឲ្យជាចំណីរបស់អារក្ខទឹក ឥឡូវនេះ វាបែរជាប្រើឲ្យអារក្ខទឹកកាន់ផ្កាដើរតាមមក ពេលនេះ អញវិនាសហើយ ក៏បែកបេះដូងជា ៧ ចម្រៀក អស់ជីវិតក្នុងទីនោះឯង ពួកស្វាដ៏សេសប្រជុំគ្នាលើកព្រះពោធិសត្វជាមេហ្វូង ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ពានរជាម្ចាស់ហ្វូងក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ឯកូនស្វាដែលជាមេហ្វូង គឺជាតថាគតនេះឯង ៕

**អដ្ឋកថា តយោធម្មជាតក ចប់**

# សុត្តន្តបិដក

## ភេរិវាទជាតក

[ ៥៩ ] *( អ្នកវាយស្គរពោធិសត្វពោលថា ) បុគ្គលគប្បីវាយ ( ស្គរ ) ចុះ ប៉ុន្តែកុំវាយឲ្យជ្រុល ព្រោះការវាយស្គរជ្រុល ជាការអាក្រក់ កហាបណៈមួយរយ ដែលបានហើយដោយការវាយស្គរ ( កូនវាឲ្យ ) វិនាសហើយ ដោយការវាយស្គរជ្រុល ។*

***ភេរិវាទជាតកទី ៩ ចប់***

# អដ្ឋកថា

## ភេរិវាទកជាតក

[ ៥៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ធមេ ធមេ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតយ៉ាងនោះឬ ដែលថា អ្នកជាបុគ្គលប្រដៅក្រ កាលភិក្ខុនោះទទួលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនោះពិតមែន ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកជាបុគ្គលប្រដៅក្រក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលប្រដៅក្រដូចគ្នា ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកវាយស្គរក្នុងតំបន់មួយ ព្រះពោធិសត្វស្តាប់ដំណឹងថា ក្នុងក្រុងពារាណសី មានបុណ្យនក្ខត្តឫក្សគគ្រឹកគគ្រេង ក៏គិតថា អញនឹងនាំស្គរទៅវាយក្បែរបរិវេណ ដែលមានមហោស្រពរកទ្រព្យ រួចនាំកូនប្រុសទៅកាន់ក្រុងពារាណសីនោះ វាយស្គរបានទ្រព្យជាច្រើន នាំទ្រព្យមកផ្ទះរបស់ខ្លួន ឆ្លងកាត់ព្រៃដែលមានចោរ ក៏ហាមកូនប្រុសដែលវាយស្គរមិនឈប់ថា នែកូន កូនកុំវាយស្គរមិនឈប់ឡើយ ចូរវាយតាមកាលដូចគេវាយក្នុងពេលអ្នកធំធ្វើដំណើរ ។ កូនប្រុសត្រូវឪពុកហាម បែរជាពោលថា ខ្ញុំវាយដេញពួកចោរឲ្យគេចទៅ ដោយសំឡេងស្គរឲ្យទាល់តែបាន ហើយក៏វាយរឿយៗ មិនឈប់ ។ ពួកចោរស្តាប់សំឡេងស្គរដំបូង គិតថា ចង្វាក់

ស្គរ ដូចគ្នានឹងស្គរអ្នកធំធ្វើដំណើរ ក៏នាំគ្នាគេចទៅ លុះស្ដាប់សំឡេងជាប់ត គ្នាពេក ក៏ពោលថា មិនមែនជាភ្លេងសម្រាប់អ្នកធំធ្វើដំណើរទេ ត្រឡប់មក លបមើល ឃើញមនុស្ស ២ នាក់ប៉ុណ្ណោះ ក៏ចោមរោមដណ្ដើមយកទ្រព្យ ទៅ ។ ព្រះពោធិសត្វពោលថា កូនវាយស្គរជ្រុល ជាសំឡេងតែមួយ ជា ហេតុឲ្យទ្រព្យដែលយើងរកបានដោយលំបាកវិនាសអស់ ហើយពោលគាថា នេះថា

បុគ្គលគប្បីវាយ ( ស្គរ ) ចុះ ប៉ុន្តែកុំវាយឲ្យជ្រុល ព្រោះការវាយ
ស្គរជ្រុល ជាការអាក្រក់ កហាបណៈមួយរយ ដែលបានហើយ
ដោយការវាយស្គរ ( កូនវាឲ្យ ) វិនាសហើយ ដោយការវាយ
ស្គរជ្រុល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធមេ ធមេ** សេចក្ដីថា ស្គរគួរវាយ មិនមែន មិនគួរវាយ អធិប្បាយថា ស្គរវាយបាន មិនមែនមិនឲ្យវាយទេ ។

បទថា **នាតិធមេ** សេចក្ដីថា តែមិនគួរវាយជ្រុល រហូតមិនឈប់ឈរ ព្រោះហេតុអ្វី ព្រោះថា ការវាយជ្រុលប្រមាណ ជាការអាក្រក់របស់យើង ដោយអត្ថថា ការវាយស្គរមិនឈប់ឈរ ជាការអាក្រក់ គឺញ៉ាំងឲ្យកើតហេតុ ការណ៍អាក្រក់ដល់យើងទាំង ២ ក្នុងឥឡូវនេះ ។

បទថា **ធមន្តេន សតំ លទ្ធំ** សេចក្ដីថា ព្រោះការវាយស្គរក្នុងព្រះនគរ បានទ្រព្យ ១០០ កហាបណៈ ។

បទថា **អតិធន្តេន ធាសិតំ** សេចក្តីថា ឥឡូវនេះ ព្រោះកូនប្រុសរបស់ខ្ញុំ មិនធ្វើតាមដំបូន្មាន វាយស្គរជ្រុលប្រមាណត្រង់ព្រៃចោរនេះ ព្រោះការវាយស្គរជ្រុលនោះ ទ្រព្យទាំងអស់ក៏អស់ទៅហើយ ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា កូនប្រុសក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ឯបិតា គឺជាតថាគតនេះឯង ៕៙៚

**អដ្ឋកថា ភេរិវាទកជាតក ចប់**

# សុត្តន្តបិដក

## សន្ធិភេទជាតក

[ ៦០ ] ( អ្នកផុំស័ន្ធិពោធិសត្វពោលថា ) បុគ្គលគប្បីផុំ ( ស័ន្ធិ ) ចុះ ប៉ុន្តែកុំគប្បីផុំឲ្យជ្រុល ព្រោះការផុំជ្រុល ជាការអាក្រក់ ភោគៈទាំងឡាយដែលបានហើយដោយការផុំ បិតាផុំបំផ្លាញភោគៈទាំងនោះ ។

**សន្ធិភេទជាតកទី ១០ ចប់**

**អាសីសវគ្គទី ៦ ចប់**

### ឧទ្ទាននៃអាសីសវគ្គនោះ គឺ

និយាយអំពីអ្នកប្រាជ្ញប្រាថ្នាយ៉ាងណា ប្រយោជន៍ក៏កើតយ៉ាងនោះ ( ក្នុងមហាសីលវជាតក ) ១ ការឡើងអំពីទឹកមកកាន់គោក ( ក្នុងចូឡជនកជាតក ) ១ សុភ ( ក្នុងបុណ្ណបាតិជាតក ) ១ ឈើមានផ្លែមិនស្រួល ( ក្នុងផលជាតក ) ១ បុរសមានចិត្តមិនរួញរា ( ក្នុងបញ្ចាវុធជាតក ) ១ បុរសមានចិត្តរីករាយ ( ក្នុងកញ្ចនក្ខន្ធជាតក ) ១ ធម៌ ៤ ( ក្នុងវានរិន្ទជាតក ) ១ ធម៌ ៣ ( ក្នុងតយោធម្មជាតក ) ១ ការបានកហាបណៈមួយរយ ( ក្នុងភេរិវាទជាតក ) ១ ផុំស័ន្ធិបានភោគៈ ( ក្នុងសន្ធិភេទជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## សន្ធិភេទជាតក

[ ៦០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រដូចគ្នា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធមេ ធមេ** ដូច្នេះដើម ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកផ្លុំស័ង្ខ កាលបុណ្យនក្ខត្តឫក្សក្នុងក្រុងពារាណសីគគ្រឹកគគ្រេង ក៏នាំបិតាទៅផ្លុំស័ង្ខ បានទូវទ្រព្យ ។ ក្នុងគ្រាត្រឡប់មក ពោលឃាត់បិតាដែលធ្វើការផ្លុំស័ង្ខមិនឈប់ ក្បែរព្រៃចោរ ។ បិតាបែរជាពោលថា យើងនឹងដេញពួកចោរឲ្យគេចទៅ ដោយសំឡេងស័ង្ខ ហើយផ្លុំរឿយៗ ទៅមិនដាច់រយៈ ។ ពួកចោរក៏នាំគ្នាជណ្ដើមយកទ្រព្យអស់ ទំនងគ្នានឹងរឿងមុននោះឯង ព្រះពោធិសត្វពោលគាថា ដោយន័យដូចគ្នានឹងរឿងមុននោះថា

បុគ្គលគប្បីផ្លុំ ( ស័ង្ខ ) ចុះ ប៉ុន្តែកុំគប្បីផ្លុំឲ្យជ្រុល ព្រោះការផ្លុំជ្រុល
ជាការអាក្រក់ ភោគៈទាំងឡាយ ដែលបានហើយ ដោយការផ្លុំ
បិតាផ្លុំបំផ្លាញភោគៈទាំងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ តាតោ វិធមី ធមំ** សេចក្តីថា បិតារបស់ខ្ញុំផ្ទុំសម្ព័ន្ធរឿយៗ ផ្ទុំជ្រុល ធ្វើឲ្យទ្រព្យដែលបានព្រោះការផ្ទុំសម្ព័ន្ធទាំងនោះអស់ទៅ វិនាសទៅ ។

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា បិតាក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ឯបុត្រ គឺជាតថាគតនេះឯង ។

**អដ្ឋកថា សង្ខធមនជាតក ចប់**

**អាសីសវគ្គ ចប់**

# សុត្តន្តបិដក

# ឥត្ថីវគ្គ

## អសាតមន្តជាតក

[ ៦១ ] ( មាណពពោលថា ) ធម្មតាពួកស្រ្តីក្នុងលោក តែងមានសេចក្តីប្រាថ្នា ( ចំពោះបុរសដែលមានចិត្តជាប់ចំពាក់នឹងខ្លួន ) វេលា ( ឬកម្រិត ) របស់ស្រ្តីទាំងនោះ មិនមានឡើយ ( ស្រ្តីទាំងនោះ ) ត្រេកត្រអាលផង រលោភលាំផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង ( មិនរើសមុខ ) ខ្ញុំនឹងលះបង់ស្រ្តីទាំងនោះហើយបួស ចម្រើននូវវិវេកធម៌ ។

*អសាតមន្តជាតកទី ១ ចប់*

# អដ្ឋកថា

# ឥត្ថីវគ្គ

## អសាតមន្តជាតក

[ ៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចង់សឹក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អាសា លោកិត្ថិយោ ណាម** ដូច្នេះជាដើម ។

រឿងរបស់ភិក្ខុនោះ មានជាក់ច្បាស់ក្នុងឧម្មាទន្តីជាតក ។ សេចក្តីសង្ខេបមានដូច្នេះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ឈ្មោះថា ស្រី ដោយច្រើន មិនគួរត្រេកអរ ខ្វះសតិ លាមក ជាបុគ្គលមានខាងក្រោយខ្នង អ្នកអផ្សុកព្រោះស្រីអាក្រក់បែបនោះធ្វើអ្វី ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងតក្កសិលា ដែនគន្ធាររដ្ឋ ដល់នូវភាពជាអ្នកដឹងក្តីហើយ រៀនចប់ត្រៃវេទ និងសិប្បៈទាំងពួងបានជាអាចារ្យទិសាបាមោក្ខ ។ សម័យនោះ ក្នុងក្រុងពារាណសី មានត្រកូលព្រាហ្មណ៍មួយ តាំងពីថ្ងៃដែលកូននោះកើត ជនទាំងឡាយ ក៏អុជភ្លើងតម្កល់មិនឲ្យរលត់ឡើយ ។ ក្នុងកាលដែលព្រាហ្មណកុមារមានអាយុ ១៦ ឆ្នាំ ទើបមាតាបិតាពោលថា នែកូន អញជុតភ្លើង តម្កល់ក្នុងថ្ងៃដែលកូនកើតរហូតមក

បើបាបំណាងទៅកាន់ព្រហ្មលោក ចូរកាន់ភ្លើងនោះចូលព្រៃ បូជាព្រះអគ្គិទេព ក៏នឹងចូលដល់ព្រហ្មលោកបាន បើបំណងនឹងគ្រប់គ្រងផ្ទះ ក៏ចូលទៅកាន់នគរតក្កសិលា សិក្សាសិប្បៈក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ ហើយតម្កល់ខ្លួនចុះ ។ មាណពពោលថា ខ្ញុំមិនអាចចូលព្រៃបូជាភ្លើង ប្រាថ្នានឹងរៀនប៉ុណ្ណោះ ហើយលាមាតាបិតា ទទួលយកប្រាក់ ១០០០ កហាបណៈ ជាតម្លៃអាចារ្យ ធ្វើដំណើរទៅកាន់នគរតក្កសិលា រៀនសិប្បៈសម្រេចហើយត្រឡប់មក មាតាបិតារបស់គាត់ មិនត្រូវការឲ្យគ្រប់គ្រងផ្ទះ ត្រូវការឲ្យបម្រើភ្លើងក្នុងព្រៃ ។ លំដាប់នោះ មាតាប្រាថ្នានឹងសម្តែងទោសរបស់ស្ត្រីដោយចំណែកច្រើន ហើយបញ្ជូនកូននោះចូលព្រៃ ក៏ត្រិះរិះថា អាចារ្យនោះគង់ជាបណ្ឌិតជាអ្នកឈ្លាស អាចប្រាប់ទោសនៃស្ត្រីចំណែកច្រើនដល់កូនរបស់អញបាន ក៏ពោលថា កូនជាទីស្រឡាញ់ ឯងរៀនសិប្បៈសម្រេចហើយឬ មាណពឆ្លើយថា បពិត្រអ្នកម៉ែសម្រេចហើយ ទើបមាតាពោលថា សូម្បីអសាតមន្តអ្នកក៏រៀនហើយឬ មាណពឆ្លើយថា មិនទាន់រៀនទេ ។ មាតាពោលថា កូនជាទីស្រឡាញ់ បើបាមិនទាន់បានរៀនអសាតមន្តហើយ នឹងហៅថា រៀនសិប្បៈសម្រេចហើយមិនបាន ទៅចុះ រៀនហើយ សឹមត្រឡប់មក ។ មាណពទទួលពាក្យថា សាធុ ហើយក៏ឆ្ពោះមុខទៅកាន់នគរតក្កសិលាម្តងទៀត ។ មាតារបស់អាចារ្យទិសាបាមោក្ខនោះ ជាស្រីជរា អាយុ ១២០ ឆ្នាំ អាចារ្យងូតទឹកឲ្យមាតាដោយដៃរបស់ខ្លួនឯង រកអាហារឲ្យបរិភោគឯង រកទឹកឲ្យផឹកឯង ប្រណិប័តន៍មាតា មនុស្សដទៃនាំគ្នារង្កៀសនឹងអាចារ្យដែលធ្វើយ៉ាងនោះ អាចារ្យ

ត្រិះរិះថា កុំដូច្នោះឡើយ អញចូលព្រៃប្រណិប័តន៍មាតា ក្នុងព្រៃនោះចុះ ហើយក៏រៀបចំធ្វើបណ្ណសាលា ក្នុងទីមានកំពង់ល្អ ក្នុងព្រៃដែលស្ងាត់មួយកន្លែងស្រេចហើយ ជញ្ជូនទ្រព្យ មានទឹកដោះ និងអង្ករជាដើមមកបម្រុងពមាតាទៅក្នុងទីនោះ ប្រណិប័តន៍មាតាបន្តមក ។

ឯមាណពទៅដល់នគរតក្កសិលាហើយ មិនជួបអាចារ្យ ក៏សួរថា លោកអាចារ្យទៅណា កាលស្តាប់រឿងរ៉ាវនោះហើយ ក៏ទៅក្នុងព្រៃនោះ ថ្វាយបង្គំអាចារ្យ ហើយឈរ ។ គ្រានោះ អាចារ្យសាកសួរថា នែបា រឿងរ៉ាវដូចម្តេចទើបបាត្រឡប់មកដោយរហ័ស មាណពឆ្លើយថា លោកអាចារ្យមិនទាន់បានឲ្យខ្ញុំរៀនអសាតមន្តឡើយ មិនមែនឬ អាចារ្យពោលថា អ្នកណានិយាយឲ្យអ្នករៀនអសាតមន្ត មាណពពោលថា បពិត្រលោកអាចារ្យ គឺម្តាយរបស់ខ្ញុំ ។

ព្រះពោធិសត្វត្រិះរិះថា មន្តណាមួយ ដែលមានឈ្មោះថា អសាតមន្តមិនមានឡើយ តែមាតារបស់មាណពនេះ បំណងឲ្យមាណពឃើញទោសនៃស្ត្រីដោយពិត ទើបពោលថា សាធុ យើងនឹងឲ្យអសាតមន្តដល់អ្នក តាំងពីថ្ងៃនេះជាដើមទៅ ចូរបាធ្វើកិច្ចជំនួសយើង ឲ្យមាតារបស់យើងងូតទឹកដោយដៃរបស់ខ្លួន ឲ្យបរិភោគ ឲ្យផឹក ប្រណិប័តន៍ជានិច្ច ម្យ៉ាងទៀត កាលបាគក់ប្របាច់ដៃជើងក្បាល និងខ្នងរបស់មាតាយើង ត្រូវនិយាយសរសើរដៃ ជើងជាដើម ក្នុងកាលដែលកំពុងគក់ប្របាច់ថា អ្នកម៉ែ ទោះបីចាស់ជរាហើយរាងកាយរបស់អ្នកម៉ែ ក៏នៅតែស្អាត ចំណង់បើនៅក្មេង រាងកាយរបស់អ្នកម៉ែ នឹងស្អាតប៉ុនណាហ្ន៎ បើមាតារបស់យើងពោលពាក្យណានឹងឯង មិនចាំ

បាច់ខ្មាស មិនចាំបាច់សង្ស័យ ប្រាប់ពាក្យនោះដល់យើងចុះ បើឯងធ្វើយ៉ាង នេះ ទើបបានអសាតមន្ត បើមិនធ្វើ មិនបានឡើយ ។ មាណពទទួលពាក្យថា សាធុ លោកអាចារ្យ ។ តាំងអំពីថ្ងៃនោះ ក៏ធ្វើតាមពាក្យដែលអាចារ្យប្រាប់ គ្រប់យ៉ាង កាលមាណពសរសើររឿយៗ ដូនចាស់ក៏សម្គាល់ថា មាណព នេះ ត្រូវការអភិរមជាមួយអញពិត ។ ទាំងដែលចាស់ជរា ក្អែកខ្វាក់ កិលេស ក៏នៅកើតឡើងក្នុងសន្តានបាន ។ ថ្ងៃមួយ ទើបដូនចាស់ពោលនឹងមាណព ដែលកំពុងសរសើររាងកាយរបស់ខ្លួនថា ឯងប្រាថ្នានឹងរួមអភិរមជាមួយយើង ឬ មាណពពោលថា បពិត្រអ្នកម៉ែ ខ្ញុំប្រាថ្នាណាស់ពេកទៅហើយ តែខ្ញុំខ្លាច ក្រែងលោកអាចារ្យ ដូនចាស់ពោលថា បើប្រាថ្នាខ្ញុំ ក៏ចូរសម្លាប់កូនខ្ញុំចុះ មាណពពោលថា ខ្ញុំរៀនសិប្បៈអស់កាលមានប្រមាណប៉ុណ្ណេះ ក្នុងសម្នាក់ របស់លោកអាចារ្យ បើសម្លាប់អាចារ្យព្រោះអាស្រ័យហេតុត្រឹមតែកិលេសដូច ម្តេចបាន ដូនចាស់ពោលថា បើដូច្នោះ ឯងកុំបោះបង់ចោលខ្ញុំ ខ្ញុំនឹងសម្លាប់ ដោយដៃឯង ។

ឈ្មោះថា ស្រី ដោយច្រើន មិនគួរត្រេកអរ លាមក មានអាថ៌កំបាំង ខាងក្នុងយ៉ាងនេះ ទោះបីចាស់យ៉ាងនោះ ក៏គង់ស្រឡាញ់ សហាយស្មន់ ប្រាថ្នានឹងសម្លាប់កូនដែលមានឧបការៈយ៉ាងនេះបាន ។

មាណពប្រាប់ពាក្យទាំងអស់នោះដល់ព្រះពោធិសត្វៗ ពោលថា កិច្ចដែល ប្រាប់គ្រប់យ៉ាងនោះ អ្នកធ្វើត្រឹមត្រូវហើយ ។ កាលពិនិត្យមើលអាយុសង្ខារ របស់មាតាក៏ដឹងថា ត្រូវស្លាប់ក្នុងថ្ងៃនេះពិត ទើបពោលថា មកមាណព យើង

នឹងសាកល្បង ទើបកាប់ដើមល្វាមួយដើម ធ្វើរូបសិប្បនិមិត្តប៉ុនមនុស្ស ដណ្ដប់ពេញរាងកាយ ដាក់ឲ្យដេកផ្ងារលើទីដេករបស់ខ្លួន ចងស្នូធ្វើអំពីខ្សែ ហើយឲ្យសញ្ញាដល់កូនសិស្សថា នែបា ចូរបាកាន់យកពូថៅ ឲ្យសញ្ញាដល់ម្ដាយរបស់យើង ។ មាណពក៏ទៅប្រាប់ថា បពិត្រអ្នកម៉ែ លោកអាចារ្យដេកត្រង់ដំណេករបស់លោក លើបណ្ណសាលា ខ្ញុំចងស្នូខ្សែជាសញ្ញា អ្នកម៉ែកាន់ពូថៅនេះ បើអាចសម្លាប់បាន ក៏ចូរសម្លាប់ ដូនចាស់ពោលថា ឯងកុំបោះបង់ខ្ញុំណា មាណពពោលថា រឿងអ្វីដែលខ្ញុំត្រូវបោះបង់នោះ ។

ដូនចាស់ចាប់ពូថៅ ដើរទាំងត្រដ តាមខ្សែស្នូ យកដៃស្ទាបមើលសម្គាល់ពិតថា នេះកូនរបស់អញ ហើយបើកសំពត់ដណ្ដប់ចំណែកខាងមុខរូបសិប្បនិមិត្តចេញ ឆាពូថៅ ដោយគិតថា នឹងកាប់ត្រឹមតែម្ដងឲ្យស្លាប់ ហើយកាប់ត្រង់កនោះឯង កាលឮសំឡេងខ្ទាំង ទើបដឹងថា មនុស្សដែលខ្លួនកាប់នោះជាឈើ កាលនោះ ព្រះពោធិសត្វសួរថា អ្នកម៉ែធ្វើអ្វី ក៏គិតថា អញត្រូវគេបញ្ឆោតហើយ ក៏ដួលស្លាប់ក្នុងទីនោះឯង ។ បានឮថា ទោះបីដូនចាស់ដេកត្រង់បណ្ណសាលារបស់ខ្លួន ក៏គង់ស្លាប់ក្នុងខណៈនោះដោយពិត ។ ព្រះពោធិសត្វជ្រាបអាការដែលមាតាស្លាប់ហើយ ក៏បូជាសរីរកិច្ច កាលភ្លើងឆេះហើយ ក៏បូជាដោយផ្កា នាំមាណពមកកាន់ទ្វារបណ្ណសាលា ហើយទូន្មានថា នែបា ឈ្មោះថា អសាតមន្ត ដែលចាត់ជាវិជ្ជាដោយចំពោះ មិនមានទេ តែឈ្មោះថា ស្រី ដោយច្រើន មិនចេះអស់តម្រេក មាតារបស់អ្នកប្រាប់ឲ្យអ្នករៀនអសាតមន្ត ហើយបញ្ជូនមកកាន់សម្នាក់យើង ក៏បញ្ជូនមកដើម្បីឲ្យដឹង

ទោសរបស់ស្ត្រីដោយច្រើន ឥឡូវនេះ អ្នកឃើញទោសមាតាយើងដោយប្រចក្សហើយ ដោយហេតុនេះ គប្បីជ្រាបចុះថា ឈ្មោះថា ស្រី ដោយច្រើនមិនចេះឆ្អែត លាមក ដូច្នេះហើយ បញ្ជូនទៅ ។ មាណពលាអាចារ្យទៅកាន់សម្នាក់របស់មាតាបិតា ។ គ្រានោះ មាតាសួរថា អ្នករៀនអសាតមន្តចប់ហើយឬ មាណពឆ្លើយថា ខ្ញុំរៀនចប់ហើយ ។ មាតាសួរថា គ្រានេះ បាទឹងធ្វើអ្វី នឹងបួស នឹងបម្រើភ្លើង ឬនឹងនៅគ្រប់គ្រងផ្ទះ មាណពពោលថា បពិត្រអ្នកម៉ែ ខ្ញុំឃើញទោសរបស់ស្រីដោយច្រើន ដោយប្រចក្សហើយ មិននៅគ្រប់គ្រងផ្ទះ ខ្ញុំនឹងបួស កាលប្រកាសបំណងរបស់ខ្លួន ទើបពោលគាថានេះថា

ធម្មតាពួកស្ត្រីក្នុងលោក តែងមានសេចក្តីប្រាថ្នា ( ចំពោះបុរសដែលមានចិត្តជាប់ចំពាក់នឹងខ្លួន ) វេលា ( ឬកម្រិត ) របស់ស្ត្រីទាំងនោះ មិនមានឡើយ ( ស្ត្រីទាំងនោះ ) ត្រេកត្រអាលផងលោរលាំផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង ( មិនរើសមុខ ) ខ្ញុំនឹងលះបង់ស្ត្រីទាំងនោះហើយបួស ចម្រើននូវវិវេកធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសា** សេចក្តីថា មិនឈប់ឈរ គឺមានការប្រព្រឹត្តអាក្រក់ ។ ម្យ៉ាងទៀត សេចក្តីសុខ លោកហៅថា **សាត** សេចក្តីសុខនោះ មិនមានដល់ស្រីទាំងនោះ ទាំងឲ្យនូវការមិនសុខចិត្តដល់បុគ្គលដែលមានចិត្តប្រតិព័ទ្ធក្នុងខ្លួន ទើបឈ្មោះថា មិនសុខចិត្ត អធិប្បាយថា ជាទុក្ខ គឺជាទីតាំងនៃសេចក្តីទុក្ខ ។ ដើម្បីសម្តែងសេចក្តីនេះឲ្យជាក់ច្បាស់ គប្បីនាំព្រះសូត្រ ( ក្នុងមហាហង្សជាតក ) នេះ មកសាធកៈដូច្នេះថា

មួយទៀត ស្ត្រីទាំងនេះ មានមាយាដូចជាថ្ងៃបណ្ដើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះ មានអធ្យាស្រ័យដ៏វិឈ្វេស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ ( របស់មច្ចុរាជ ) បុរសណា ទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្ដាបុរសទាំងឡាយ បុរសនោះ ឈ្មោះថា បុរសថោកទាប ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លោកិត្ថិយោ** បានដល់ ស្រីទាំងឡាយក្នុងលោក ។ បទថា **វេលា តាសំ ន វិជ្ជតិ** សេចក្ដីថា បពិត្រអ្នកម៉ែ ស្រីទាំងនោះ កិលេសកើតឡើងហើយ វេលា គឺការសង្រួម ព្រំដែនប្រមាណមិនមានឡើយ ។ បទថា **សារត្តា ច បគព្ភា ច** សេចក្ដីថា ព្រំដែនមិនមានដល់ស្រីទាំងនោះ គឺជាប់ចិត្តក្នុងកាមគុណទាំង ៥ ជាអ្នកធ្លាំធ្លង ព្រោះប្រកបដោយការធ្លាំធ្លង ៣ ប្រការ គឺធ្លាំធ្លងកាយ ធ្លាំធ្លងវាចា និងធ្លាំធ្លងចិត្ត ព្រោះឈ្មោះថា ការសង្រួមក្នុងកាលដែលជួបប្រទះនូវអារម្មណ៍តាមកាយទ្វារជាដើម មិនមានខាងក្នុងស្រីទាំងនោះឡើយ ជាស្រីឡេះឡោះ ដូចក្អែក ព្រាហ្មណ៍មាណពសម្ដែងលក្ខណៈស្ត្រីដូចពណ៌នាមក ដូច្នេះ ។

បទថា **សិខី សព្វឃសោ យថា** សេចក្ដីថា ធម្មតាភ្លើង ដែលដល់នូវការរាប់ថា **សិខី** ព្រោះមានអណ្ដាតជាចម្រៀក បាននូវឧសណាមួយ ទោះជាវត្ថុមិនស្អាត មានលាមកក្ដី ឬដែលជារបស់ស្អាត មានសប្បិ ទឹកឃ្មុំ ទឹកអំពៅក្ដី គួរប្រាថ្នាក្ដី មិនគួរប្រាថ្នាក្ដី ក៏លេបត្របាក់គ្រប់យ៉ាង ព្រោះហេតុ

នោះ ទើបលោកហៅថា ស៊ីនូវរបស់គ្រប់យ៉ាង យ៉ាងណា សូម្បីស្រីទាំងឡាយ ក៏ដូច្នោះឯង ទោះជាបុគ្គលមានកំណើតថោកថយ មានការងារថោកថយ ដូចជាអ្នកចិញ្ចឹមដំរី ចិញ្ចឹមគោជាដើមក្តី ទោះជាបុគ្គលមានកំណើតខ្ពស់ ការងារខ្ពស់ ដូចជាក្សត្រជាដើមក្តី ក៏មិនបានគិតដល់ការអាក្រក់ និងភាពខ្ពង់ខ្ពស់ទេ កាលការសេរសើរដោយអំណាចកិលេសកើតឡើង ដោយអំណាចនៃការត្រេកត្រអាលក្នុងលោក បាននូវមនុស្សបែបណា ក៏សេពបានទាំងអស់ ព្រោះដូច្នោះ ទើបដូចជាភ្លើងដែលឆេះបានគ្រប់យ៉ាង ភ្លើងឆេះបានគ្រប់យ៉ាង យ៉ាងណា ស្រីទាំងនោះ ក៏គប្បីជ្រាបថា យ៉ាងនោះដូចគ្នា ។

បទថា **តា ហិត្វា បព្វជិស្សាមិ** សេចក្តីថា ខ្ញុំសូមចៀសវាងស្រីលាមក ដែលជាទីតាំងនៃសេចក្តីទុក្ខនោះ ចូលព្រៃបួសជាឥសី ។

បទថា **វិវេកមនុព្រូហយំ** សេចក្តីថា វិវេកមាន ៣ គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។ ក្នុងរឿងនេះ បណ្តាវិវេកទាំង ៣ នោះ គួរចម្រើនកាយវិវេកផង ចិត្តវិវេកផង លោកអធិប្បាយថា ព្រាហ្មណមាណពពោលថា បពិត្រអ្នកម៉ែ ខ្ញុំត្រូវការបួស ធ្វើកសិណបរិកម្ម ឲ្យសមាបត្តិទាំង ៨ និងអភិញ្ញាទាំង ៥ កើតហើយ នឹងវៀរចេញចាកគណៈ នាំចិត្តចេញចាកកិលេស ចម្រើននូវវិវេកនេះ នឹងជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ រៀងប្រពន្ធកូនសម្រាប់ខ្ញុំ លើកទុកចុះ ។

ព្រាហ្មណមាណព តិះដៀលស្រីទាំងឡាយយ៉ាងនេះ ថ្វាយបង្គំលាមាតាបិតា បួសហើយ ចម្រើននូវវិវេក មានប្រការដូចពោលហើយ បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា ស្រីទាំងឡាយ មិនគួរត្រេកអរ លាមក រលោរលាំ ឲ្យនូវទុក្ខយ៉ាងនេះ ទ្រង់សម្តែងទោសរបស់ស្ត្រីទាំងឡាយ ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា មាតាមាណពក្នុងកាលនោះ បានមកជាភិក្ខុនី ឈ្មោះភទ្ទកាបិលានី ក្នុងកាលឥឡូវនេះ បិតារបស់មាណព បានជាមហាកស្សបៈ មាណពដែលជាសិស្សបានជាអានន្ទ ឯអាចារ្យ គឺតថាគតនេះឯង ។

**អដ្ឋកថា អសាតមន្តជាតក ចប់**

# សុត្តន្តបិដក

## អណ្ឌភូតជាតក

[ ៦២ ] ( ព្រះរាជាពោធិសត្វទ្រង់ត្រាស់ថា ) ព្រាហ្មណ៍បានរុំមុខរបស់ខ្លួន ហើយដេញពិណាដោយហេតុណា ( មិនដឹងហេតុនោះទេ ) ប្រពន្ធដែលខ្លួនចិញ្ចឹមតាំងពីនៅជាអណ្ឌ ( កូននៅក្នុងគភ៌ ) អ្នកណាគប្បីទុកចិត្តចំពោះប្រពន្ធទាំងនោះ ដោយដាច់ខាតបាន ។

អណ្ឌភូតជាតកទី ២ ចប់

# អដ្ឋកថា

## អណ្ឌភូតជាតក

[ ៦២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក នោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យំ ព្រាហ្មណោ អវាទេសិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ អ្នកអផ្សុក ពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា ស្រីទាំងឡាយ បុគ្គលណាម្នាក់ ក៏រក្សាមិនបាន ក្នុងកាលមុន បណ្ឌិតទាំងឡាយ រក្សាស្រីទុកតាំងអំពីប្រសូតចាកគភ៌ ក៏មិនអាចរក្សាបាន ហើយទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វកើតក្នុងព្រះគភ៌ នៃអគ្គមហេសីរបស់ព្រះបាទ ព្រហ្មទត្តនោះ កាលទ្រង់ចម្រើនវ័យ ក៏ដល់នូវការសម្រេចក្នុងសិប្បៈគ្រប់ យ៉ាង ក្នុងកាលព្រះរាជបិតាសោយទិវង្គត ក៏បានសោយរាជ្យដោយធម៌ ។ ទ្រង់សព្វព្រះហឫទ័យលេងបាស្កាជាមួយបុរោហិត កាលទ្រង់លេង ទ្រង់ ច្រៀងនូវគាថា ( ក្នុងកុណាលជាតក ) សម្រាប់ក្នាល់ថា

ស្ទឹងទាំងអស់ មានដំណើរវៀច ព្រៃទាំងអស់ សម្រេចអំពីឈើ
( យ៉ាងណាមិញ ) ពួកស្រីទាំងអស់ ( វៀរលែងតែស្រីដែលមាន
កិលេសស្តើង ) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើនូវ
អំពើលាមកបាន ( យ៉ាងនោះដែរ ) ។

ដូច្នេះបណ្តើរ ដើរនូវបាស្កាមាសលើបន្ទះក្តារប្រាក់បណ្តើរ កាលព្រះរាជាទ្រង់លេងដោយវិធីនេះ ទ្រង់ឈ្នះជានិច្ច ។ ឯបុរោហិតចាញ់ ។

បុរោហិត កាលទ្រព្យក្នុងផ្ទះរលស់ទៅដោយលំដាប់ ក៏បានគិតថា បើនៅតែដូច្នេះ ទ្រព្យក្នុងផ្ទះគ្រប់យ៉ាង មុខជាអស់ពិត អញនឹងស្វែងរកមាតុគ្រាមម្នាក់ ដែលមិនធ្លាប់សេពជាមួយបុរសដទៃ មកទុកក្នុងផ្ទះឲ្យបាន ។ ហើយក៏កើតបរិវិតក្កថា អញមិនអាចរក្សាស្រីដែលធ្លាប់ឃើញបុរសដទៃមកហើយបាន អញនឹងរក្សាស្រីម្នាក់ តាំងអំពីមុនប្រសូត លុះចម្រើនវ័យហើយ សឹមឲ្យនៅក្នុងអំណាច ធ្វើឲ្យជាស្រីមានប្រុសតែមួយ ចាត់ចែងរក្សាយ៉ាងម៉ឺងម៉ាត់ ទើបនាំទ្រព្យមកអំពីរាជត្រកូលបាន ។ បុរោហិតជាអ្នកឈ្លាសក្នុងវិជ្ជាមើលអវយវៈដូច្នោះ លុះឃើញស្រីទុគ៌តម្នាក់មានគភ៌ ក៏ដឹងថា នាងប្រសូតកូនជាស្រី ទើបហៅនាងមក ឲ្យស្បៀង ឲ្យនៅខាងក្នុងផ្ទះប៉ុណ្ណោះ លុះប្រសូតហើយ ក៏ឲ្យប្រាក់បញ្ជូនទៅ មិនឲ្យទារិកានោះឃើញប្រុសដទៃឡើយ ប្រគល់ក្នុងដៃរបស់ពួកស្រីប៉ុណ្ណោះ ចិញ្ចឹមរហូតចម្រើនវ័យ ទើបឲ្យនាងនៅក្នុងអំណាចរបស់ខ្លួន រវាងកុមារីនោះមិនទាន់ធំ បុរោហិតមិនព្រមលេងបាស្កាក្នាល់ជាមួយព្រះរាជាឡើយ លុះឲ្យកុមារីនៅក្នុងអំណាចហើយ ក៏ក្រាបទូលព្រះរាជាថា បពិត្រមហារាជ យើងលេងបាស្កាចុះ ។ ព្រះរាជាត្រាស់ថា សាធុ ទ្រង់លេងដោយទំនងដើមនោះឯង ក្នុងកាលព្រះរាជាទ្រង់ច្រៀង ទតកូនបាស្កា បុរោហិតក៏ពោលថា វៀរតែនាងមាណវិការបស់ខ្ញុំ តាំងអំពីនោះមក បុរោហិតក៏ឈ្នះព្រះរាជាចាញ់ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ក្នុងផ្ទះរបស់បុរោហិតនេះ ពិតជាមានស្រីម្នាក់ ដែលមានប្រុសតែម្នាក់ ទ្រង់ឲ្យអមាត្យស៊ើបមើល ក៏ទ្រង់ជ្រាបថា មានពិត ទ្រង់ព្រះតម្រិះបន្តទៀតថា ត្រូវឲ្យមនុស្សទម្លាយសីលរបស់នាង ត្រាស់ឲ្យហៅអ្នកលេងម្នាក់មកចូលគាល់ មានព្រះតម្រាស់ថា អ្នកអាចទម្លាយសីលទារិការបស់បុរោហិតបានដែរឬទេ អ្នកលេងនោះទទួលស្នងព្រះរាជបំណងថា បពិត្រព្រះអង្គ ទូលបង្គំអាច ។ កាលនោះ ព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់បុរសនោះ មានព្រះតម្រាស់ថា បើដូច្នោះ ចូរអ្នកធ្វើឲ្យសម្រេចដោយឆាប់ចុះ ហើយទ្រង់បញ្ជូនទៅ ។ បុរសនោះទទួលព្រះរាជទ្រព្យហើយ ក៏ចំណាយទិញគ្រឿងក្រអូប ធូបក្រអូប លម្អិត និងកប្បូរជាដើម បើកតូបលក់គ្រឿងក្រអូបគ្រប់យ៉ាង មិនឆ្ងាយអំពីផ្ទះរបស់បុរោហិតនោះ សូម្បីផ្ទះរបស់បុរោហិតក៏ជាផ្ទះ ៧ ជាន់ មានទ្វារ ៧ កន្លែង ត្រង់ខ្លោងទ្វារគ្រប់កន្លែង មានស្រីរក្សាទាំងអស់ បុរសដទៃ វៀរតែព្រាហ្មណ៍ មិនមានអ្នកណាចូលទៅកាន់ផ្ទះបានឡើយ សូម្បីតែកំប្រោងចោលសំរាម ក៏មនុស្សស្រីចូលទៅជម្រះទាំងអស់ បុរោហិតម្នាក់ ស្រីបម្រើរបស់មាណវិកានោះម្នាក់ប៉ុណ្ណោះ ដែលបានឃើញមាណវិកានោះ ។ កាលនោះ ស្រីអ្នកបម្រើរបស់មាណវិកា កាន់យកទ្រព្យសម្រាប់ទិញគ្រឿងក្រអូប និងផ្កា ដើរទៅ កាលដើរទៅ ក៏ដើរឆ្លងទៅក្បែរហានរបស់អ្នកលេងនោះ បុរសនោះដឹងយ៉ាងល្អថា ស្រីនេះ ជាអ្នកបម្រើរបស់មាណវិកា ។ ថ្ងៃមួយ ឃើញនាងដើរមក ក៏ក្រោកឡើងអំពីហាន ចូលទៅក្រាបក្បែរជើងនាង ឱបជើងទាំងគូយ៉ាងណែន ដោយដៃទាំង ២ យំរៀបរាប់

ថា បពិត្រអ្នកម៉ែ ម៉ែទៅណាអស់កាលដ៏យូរ មានប្រមាណប៉ុណ្ណេះ ពួកអ្នកលេងបន្តប់ទុកក្នុងទីដ៏សេស ឈរក្នុងចំណែកម្ខាង ក៏នាំគ្នាពោលថា ម៉ែ និងកូនដូចគ្នា ដោយសណ្ឋានដៃ ជើង និងមុខ និងអាកប្បកិរិយាដូចគ្នាបេះបិទនោះឯង ។ ស្រីនោះ កាលមនុស្សទាំងនោះនាំគ្នាពោល ក៏ជឿពិត យល់ថាបុរសនេះ ជាកូនរបស់ខ្លួនពិត សូម្បីខ្លួនឯងក៏យំដែរ ។ ជនទាំង ២ ឱបគ្នាទ្រហោយំ ។

គ្រានោះ ទើបអ្នកលេងពោលថា បពិត្រអ្នកម៉ែ ម៉ែនៅឯណា នាងឆ្លើយថា នែបា ម៉ែបម្រើស្រីរបស់បុរោហិត ដែលមានលីលាដូចកិន្នរី មានរូបល្អក្រៃលែង ។ អ្នកលេងសួរថា ឥឡូវនេះ ម៉ែកំពុងទៅណា នាងឆ្លើយថា ម៉ែទៅទិញគ្រឿងក្រអូប និងកម្រងផ្កាឲ្យចៅហ្វាយស្រី ។ បុរសនោះពោលថា បពិត្រអ្នកម៉ែ ម៉ែចាំបាច់ទិញក្នុងទីដទៃធ្វើអ្វី តាំងអំពីនេះទៅ សូមទទួលយកគ្រឿងក្រអូបរបស់ខ្ញុំទៅចុះ ហើយមិនចាំបាច់ប្រើលុយកាក់ ហើយឲ្យរបស់របរ មានស្លា ម្លូ និងក្រវាញជាដើម មួយអន្លើដោយផ្កាផ្សេងៗ ជាច្រើនទៅមាណវិកាឃើញគ្រឿងក្រអូប និងផ្កាច្រើន ក៏ពោលថា នែនាង ថ្ងៃនេះព្រាហ្មណ៍របស់ខ្ញុំចិត្តល្អ ឬយ៉ាងណា ។ ស្រីនោះសួរវិញថា ហេតុអ្វី អ្នកនាងពោលយ៉ាងនេះ មាណវិកាឆ្លើយថា ព្រោះខ្ញុំឃើញរបស់ទាំងនេះច្រើន ។ នាងពោលថា ព្រាហ្មណ៍មិនបានឲ្យប្រាក់ច្រើនទេ តែរបស់នេះ ខ្ញុំនាំមកអំពីសម្នាក់កូនរបស់ខ្ញុំ ។

តាំងអំពីនោះមក នាងកិបតម្លៃដែលព្រាហ្មណ៍ឲ្យទុកខ្លួនឯង ហើយក៏ទៅ

ទទួលយកគ្រឿងក្រអូប និងផ្កាជាដើម មកអំពីសម្នាក់របស់អ្នកលេងនោះ រឿយៗ មក ។ រំលង ២-៣ ថ្ងៃ អ្នកលេងក៏ពុតធ្វើជាឈឺ ហើយដេក ។ នាងទៅត្រង់ពានរបស់បុរសនោះ មិនឃើញក៏សាកសួរថា កូនរបស់ខ្ញុំទៅណា ពួកមនុស្សប្រាប់ថា កូនរបស់នាងឈឺ ។ នាងទៅដល់ទីដេករបស់បុរសនោះ ហើយអង្គុយអង្អែលខ្នង សួរថា នែកូន ឯងកើតអ្វីឬ បុរសនោះក៏នៅស្ងៀម នាងសួរថា នែកូន ហេតុអ្វី មិននិយាយ អ្នកលេងពោលថា បពិត្រអ្នកម៉ែ ទោះបីខ្ញុំស្លាប់ក៏មិនអាចប្រាប់ម៉ែបាន ទើបនាងពោលថា បើឯងមិនប្រាប់ម៉ែ ហើយ តើប្រាប់ដល់អ្នកណា ប្រាប់ចុះបា ។ អ្នកលេងប្រាប់ថា បពិត្រម៉ែ ខ្ញុំ មិនឈឺអ្វីទេ តែខ្ញុំបានឮពាក្យសរសើរនាងមាណវិកាហើយ ក៏មានចិត្តប្រតិព័ទ្ធ ដ៏ខ្លាំងក្លា បើខ្ញុំបាននាង ទើបមានជីវិត បើមិនបាន នឹងស្លាប់ក្នុងទីនេះឯង ។ នាងពោលថា នែបា រឿងនេះជាភារៈរបស់ម៉ែ កូនកុំទោមនស្ស ព្រោះរឿង នេះឡើយ លួងលោមបុរសនោះហើយ ក៏ជញ្ជូនគ្រឿងក្រអូប និងផ្កាទៅ សន្ទឹកសន្ទាប់ មកដល់សម្នាក់មាណវិកា ក៏ពោលថា បពិត្រអ្នកនាង កូនខ្ញុំ បានឮពាក្យសរសើរអំពីអ្នកនាងក្នុងសម្នាក់ខ្ញុំហើយ មានចិត្តប្រតិព័ទ្ធដ៏ខ្លាំងក្លា តើធ្វើដូចម្តេចល្អហ្ន៎ ។ មាណវិកាឆ្លើយថា បើនាងនាំគេមកបាន ខ្ញុំនឹងឲ្យ ឱកាសដូចគ្នា ។ នាងស្តាប់ពាក្យរបស់មាណវិកាហើយ តាំងអំពីនោះមក ក៏ បោសសំរាមជាច្រើនអំពីញក អំពីជ្រុងរបស់ផ្ទះ ទម្លាក់លើក្បាលស្រីអ្នក យាម ។ ស្រីអ្នកយាម ទើសទាល់ចិត្តដោយរឿងនោះ ក៏ចេញទៅ ដោយ ទំនងដូចគ្នានេះឯង ស្រីដែលជាអ្នកយាមណាម្នាក់ ពោលពាក្យណាមួយ នាង

ក៏ចោលសំរាមលើក្បាលស្រីអ្នកយាមនោះៗ តាំងអំពីនោះ នាងនាំរបស់ណា ចូលមក ឬនាំចេញទៅ ក៏មិនមានអ្នកណាហ៊ានពិនិត្យមើលរបស់នោះ ។

បានឱកាស នាងឲ្យអ្នកលេងនោះ ដេកក្នុងកំប្រោងផ្កា រែកចូលទៅកាន់ សម្នាក់នាងមាណវិកា អ្នកលេងទម្លាយសីលរបស់នាងមាណវិកាហើយ បាន នៅក្នុងប្រាសាទនោះឯង ២-៣ ថ្ងៃ ។ កាលបុរោហិតចេញទៅខាងក្រៅហើយ ជនទាំង ២ ក៏រួមអភិរម ។ កាលបុរោហិតមក អ្នកលេងក៏ពួន ។ កាលកន្លង មកបាន ២-៣ ថ្ងៃ មាណវិកាក៏ពោលនឹងអ្នកលេងថា ឥឡូវនេះ អ្នកគួរទៅ ចុះ អ្នកលេងក៏ពោលថា ខ្ញុំចង់វាយក្បាលព្រាហ្មណ៍ឲ្យបានសិន សឹមទៅ ។ មាណវិកពោលថា យ៉ាងនោះក៏បាន ហើយឲ្យអ្នកលេងលាក់ខ្លួន លុះព្រាហ្មណ៍ មក ក៏ពោលយ៉ាងនេះថា បពិត្រព្រាហ្មណ៍ ខ្ញុំចង់រាំក្នុងកាលលោកលេងពិណ ព្រាហ្មណ៍ទទួលថា ចូរនាងរាំចុះ ហើយក៏លេងពិណ មាណវិកាពោលថា ខ្ញុំ ខ្មាស កាលលោកសម្លឹងមើលខ្ញុំ សូមលោកបិទភ្នែកសិន ខ្ញុំនឹងរាំ ។ បុរោហិត ពោលថា បើខ្មាស ចូរនាងធ្វើយ៉ាងនោះចុះ ។ មាណវិកាយកសំពត់ក្រាស់ បិទភ្នែកបុរោហិត ហើយចងយ៉ាងជិត ព្រាហ្មណ៍ព្រមឲ្យបិទភ្នែកលេងពិណ រឿយៗ ទៅ នាងរាំបានបន្តិចក៏ពោលថា នែលោក ខ្ញុំចង់ខោកក្បាលលោកបាន ម្តង ព្រាហ្មណ៍វង្វេងក្នុងសេចក្តី មិនដឹងហេតុការណ៍ ក៏ពោលថា ខោកចុះ ។ មាណវិកាឲ្យសញ្ញាដល់អ្នកលេង ។ គេដើរមកជិត ឈរក្រោយខ្នងព្រាហ្មណ៍ នោះឯង ហើយខោកក្បាលព្រាហ្មណ៍ដោយកែងដៃ ។ ភ្នែករបស់ព្រាហ្មណ៍ ដល់នូវការស្រវាំង ក្បាលប៉ោងឡើង ព្រាហ្មណ៍ឈឺចាប់ពន់ពេក ពោលថា

ចូរនាងឲ្យដៃមកនេះ ។ មាណវិកាដាក់ដៃរបស់ខ្លួនលើដៃព្រាហ្មណ៍ ។ ព្រាហ្មណ៍ពោលថា ដៃទន់ៗ តែខោកបានខ្លាំង ។ អ្នកលេងកាលខោកក្បាលព្រាហ្មណ៍ហើយ ក៏ពួន ។ មាណវិកាកាលអ្នកលេងពួនហើយ ក៏ស្រាយមុខព្រាហ្មណ៍យកប្រេងលាបក្បាលឲ្យ ។ កាលព្រាហ្មណ៍ចេញទៅខាងក្រៅហើយ ស្រីអ្នកបម្រើឲ្យអ្នកលេងដេកក្នុងកំប្រោងនាំចេញទៅ ទើបអ្នកលេងចូលគាល់ព្រះរាជា ក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។

ព្រះរាជាត្រាស់ដល់ព្រាហ្មណ៍ដែលមកគាល់ថា យើងលេងបាស្កាជាមួយគ្នាចុះ បុរោហិតទូលថា សាធុ ព្រះអង្គ ។ ព្រះរាជាឲ្យរៀបចំវង់ដើម្បីលេងទ្រង់ច្រៀងការភ្នាល់ ហើយទ្រង់មើលកូនបាស្កា ។ ព្រាហ្មណ៍មិនដឹងរឿងដែលមាណវិកាទម្លាយតបៈហើយ នៅតែពោលថា វៀរមាណវិកា សូម្បីពោលយ៉ាងនេះ ក៏នៅតែចាញ់នោះឯង ។ ព្រះរាជាទ្រង់ឈ្នះ ហើយត្រាស់ថា នៃព្រាហ្មណ៍ អ្នកពោលអ្វី តបៈនៃមាណវិការបស់អ្នកត្រូវទម្លាយហើយ អ្នកខំរក្សាមាតុគ្រាមតាំងអំពីនៅក្នុងគភ៌ ធ្វើការរក្សាក្នុងទី ៧ កន្លែង សម្គាល់ថាអញនឹងរក្សាបាន ឈ្មោះថា មាតុគ្រាម សូម្បីបុរសលាក់ក្នុងពោះត្រាច់ទៅ ក៏មិនអាចរក្សាបានដែរ ឈ្មោះថា ស្រី មានបុរសម្នាក់មិនមានឡើយ មាណវិការបស់អ្នកពោលថា ខ្ញុំចង់រាំ យកសំពត់ចងមុខរបស់អ្នក កំពុងលេងពិណឲ្យសហាយរបស់ខ្លួនខោកក្បាលរបស់អ្នក ហើយក៏បញ្ជូនទៅ គ្រានេះ អ្នកវៀរបានដូចម្តេច ដូច្នេះហើយ ត្រាស់គាថានេះថា

ព្រាហ្មណ៍ បានរុំមុខរបស់ខ្លួន ហើយដេញពិណាដោយហេតុណា ( មិនដឹងហេតុនោះទេ ) ប្រពន្ធ ដែលខ្លួនចិញ្ចឹមតាំងពីនៅជាអណ្ឌ ( កូននៅក្នុងគភ៌ ) អ្នកណាគប្បីទុកចិត្ត ចំពោះប្រពន្ធទាំងនោះ ដោយដាច់ខាតបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ ព្រាហ្មណោ អវាទេសិ វីណំ សមុខ-វេឋិតោ** សេចក្ដីថា ព្រាហ្មណ៍ត្រូវប្រពន្ធយកសំពត់ចងមុខឲ្យលេងពិណា ព្រោះហេតុណា មិនបានជ្រាបហេតុនោះ ។ ព្រោះប្រពន្ធត្រូវការបោកបញ្ឆោតព្រាហ្មណ៍ ទើបធ្វើយ៉ាងនេះ ។ តែព្រាហ្មណ៍មិនដឹងអាការដែលស្រីទាំងឡាយមានមាយាច្រើន វង្វេង ជឿនូវមាតុគ្រាម ទើបសម្គាល់យ៉ាងនេះថា នាងខ្មាសខ្លួន ។ ព្រះរាជាកាលប្រកាសការមិនដឹងរបស់ព្រាហ្មណ៍នោះ ទើបត្រាស់យ៉ាងនេះ នេះជាពាក្យអធិប្បាយក្នុងសេចក្ដីនេះ ។

បទថា **អណ្ឌភូតា ភតា ភរិយា** សេចក្ដីថា អណ្ឌ លោកហៅថា ពូជ គឺស្រីដែលត្រូវនាំមកចិញ្ចឹមតាំងពីកាលដែលនៅជាពូជ គឺស្រីដែលនាំមកចិញ្ចឹមតាំងពីមិនទាន់ប្រសូតចេញពីផ្ទៃម្ដាយម្យ៉ាងទៀត សព្ទថា **ភតា** សំដៅដល់ពាក្យសួរ គឺសួរថា នុ៎ះជានរណា ជាភរិយា គឺម្ចាស់របស់កូន ឬជាស្រីបម្រើ ព្រោះថា ស្រីនោះ លោកហៅថា ភរិយា ព្រោះជាស្រីដែលត្រូវចិញ្ចឹមដោយភត្ត និងសំពត់ជាដើម ១ ព្រោះមានសំរិះដែលត្រូវទម្លាយហើយ ១ ព្រោះចិញ្ចឹមដោយលោកធម៌ ១ ។

បទថា **ជាតុ** ក្នុងបាទព្រះគាថាថា **តាសុ កោ ជាតុ វិស្សសេ** នេះ ជា

ពាក្យពោលដោយចំណែកមួយ អធិប្បាយថា ក្នុងកាលកិរិយាទាំងនោះដល់នូវការថែរក្សា តាំងអំពីនៅក្នុងផ្ទៃមាតា គង់ដល់នូវវិការ គឺប្រព្រឹត្តក្រៅចិត្តយ៉ាងនេះបាន បុគ្គលណា គឺបុគ្គលឈ្មោះណាគប្បីទុកចិត្តក្នុងកិរិយាបាន យ៉ាងពិតប្រាកដ បានដល់ បុគ្គលណាគួរជឿបានថា ស្រីទាំងនេះមិនមានវិការប្រព្រឹត្តក្រៅចិត្តអញ ព្រោះថា ឈ្មោះថា មាតុគ្រាម ក្នុងកាលមានបុគ្គលហៅក្នុងកាលមានបុគ្គលអញ្ជើញ ដោយអំណាចអស្សទ្ធម្ម បុគ្គលណាម្នាក់ ក៏មិនអាចរក្សាបានឡើយ ។

ព្រះពោធិសត្វទ្រង់សម្តែងធម៌ដល់ព្រាហ្មណ៍យ៉ាងនេះ ។ ព្រាហ្មណ៍ស្តាប់ទេសនារបស់ព្រះពោធិសត្វហើយ ទៅកាន់និវេសន៍ ពោលនឹងមាណវិកានោះថា បានឮថា នាងហ៊ានធ្វើអាក្រក់ដល់ថ្នាក់នោះឬ មាណវិកាសួរថា នែលោកអ្នកណានិយាយយ៉ាងនេះ ខ្ញុំនេះឯងខោកក្បាលលោក អ្នកដទៃមិនមានទេ ។ បើអ្នកមិនជឿថា ខ្ញុំមិនជាប់សម្ផស្សប្រុស វៀរតែលោកហើយ ខ្ញុំនឹងធ្វើសច្ចកិរិយា ដើរកាត់ភ្លើងឲ្យលោកជឿ ។ ព្រាហ្មណ៍ពោលថា យ៉ាងនោះក៏បាន ទើបឲ្យបង្កាត់ភ្លើងមួយគំនរធំ ហើយហៅនាងមក ពោលថា បើនាងប្រាកដក្នុងចិត្តខ្លួនឯង ចូរដើរកាត់ភ្លើងចុះ ។ ឯមាណវិកាពោលនឹងស្រីអ្នកបម្រើខ្លួនថា នែនាង ចូរនាងទៅប្រាប់កូនរបស់នាងឲ្យទៅក្នុងទីនោះ ក្នុងពេលដែលខ្ញុំដើរកាត់ភ្លើងឲ្យចាប់ដៃខ្ញុំ ។ ស្រីនោះ ក៏ទៅប្រាប់យ៉ាងនោះ អ្នកលេងក៏មកឈរកណ្តាលមហាជន មាណវិកាបំណងនឹងបោកព្រាហ្មណ៍ ឈរត្រង់កណ្តាលមហាជន ធ្វើសច្ចកិរិយាថា បពិត្រព្រាហ្មណ៍ ឈ្មោះថា ការប៉ះពាល់

ដោយដៃរបស់បុរសដទៃ វៀរលោកហើយ ខ្ញុំមិនធ្លាប់ស្គាល់ឡើយ ដោយសច្ចៈនេះ ភ្លើងនេះ កុំបីឆេះខ្ញុំឡើយ ធ្វើអាកប្បកិរិយានឹងដើរកាត់ភ្លើង ។ ក្នុងគ្រានោះ អ្នកលេងប្រកាសថា មើលចុះអ្នកទាំងឡាយ ចូរមើលការធ្វើរបស់ព្រាហ្មណបុរោហិត គាត់ឲ្យមាតុគ្រាមស្អាតបែបនេះដើរកាត់ភ្លើង ហើយក៏ស្ទុះទៅចាប់ដៃនាង នាងរលាស់ដៃហើយ ពោលនឹងបុរោហិតថា នៃលោក សច្ចកិរិយារបស់ខ្ញុំ ត្រូវទម្លាយហើយ ខ្ញុំមិនអាចដើរកាត់ភ្លើងបានទេ ។ ព្រាហ្មណ៍សួរថា ព្រោះហេតុអ្វី មាណវិកាឆ្លើយថា ក្នុងថ្ងៃនេះ ខ្ញុំបានធ្វើសច្ចកិរិយាយ៉ាងនេះថា វៀរប្តីរបស់ខ្ញុំហើយ ខ្ញុំមិនស្គាល់ដៃអ្នកដទៃឡើយ ឥឡូវនេះ ខ្ញុំត្រូវបុរសនេះចាប់ដៃហើយ ។ ព្រាហ្មណ៍ដឹងថា អញត្រូវមាណវិកាបញ្ឆោត ក៏វាយបណ្តេញចេញទៅ បានឮថា ស្រីទាំងនេះប្រកបទៅដោយអសទ្ធម្មយ៉ាងនេះ ធ្វើអាក្រក់ជាច្រើន ដើម្បីបោកបញ្ឆោតស្វាមីរបស់ខ្លួន ធ្វើការស្បថបានទាំងស្រស់ថា ខ្ញុំមិនបានធ្វើយ៉ាងនេះ រមែងជាស្រីមានចិត្តប្រែប្រួលផ្សេងៗ សមដូចគាថាព័ន្ធ ( ក្នុងកុណាលជាតក ) ដែលលោកពោលថា

ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យសច្ចៈ គេរកបានដោយកម្រណាស់ ភាពនៃស្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។

ពាក្យកុហករបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យពិតរបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក ( ពួកស្រី ) ដូចគោស៊ីច្បិចតែស្មៅល្អៗ ខាងក្រៅ ។

ពិតណាស់ ស្រីទាំងនេះ ដូចជាចោរ មានចិត្តរឹងត្អឹង ខ្ជូចកាច តែមានសម្តីផ្អែមដូចស្ករ ការបញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការបញ្ឆោតណាមួយ ( នោះ ) ទេ ដូច្នេះ ។

ព្រះសាស្តាក៏ត្រាស់ថា មាតុគ្រាមណាមួយ រក្សាមិនបានយ៉ាងនេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសសច្ចៈ ក្នុងកាលចប់សច្ចៈទាំងឡាយ ភិក្ខុអផ្សុកក៏សម្រេចសោតាបត្តិផល ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ស្តេចក្រុងពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថាអណ្ឌភូតជាតក ចប់**

# សុត្តន្តបិដក

## តក្កជាតក

[ ៦៣ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ( ធម្មតាស្ត្រី ) ច្រើនខឹងមិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ បំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈចុះ អ្នកនោះ នឹងមិនវិនាសសេចក្តីសុខ ។

តក្កជាតកទី ៣ ចប់

# អដ្ឋកថា

## តក្កបណ្ឌិតជាតក

[ ៦៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក នោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោធនា អកតញ្ញូ** ច ដូច្នេះជាដើម ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុ នោះក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ឈ្មោះថា ស្រីទាំងឡាយ ជាបុគ្គលអកតញ្ញូ ប្រទូស្តមិត្ត ហេតុអ្វី ទើបអ្នកអផ្សុកព្រោះអាស្រ័យស្រី ទាំងនោះ ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វបួសជាឥសី សាងអាស្រមត្រង់ឆ្នេរស្ទឹងគង្គា ញុំាង សមាបត្តិ និងអភិញ្ញាឲ្យកើតហើយ នៅសម្រាំដោយសុខដែលកើតអំពីការ ត្រេកអរក្នុងឈាន ។ ក្នុងសម័យនោះ ធីតារបស់សេដ្ឋី ក្នុងនគរពារាណសី ឈ្មោះទុដ្ឋកុមារី ជាស្រីកាច គ្រោតគ្រាត ច្រើនដោយការជេរ វាយជំទាសៈ និងកម្មករ សម័យថ្ងៃមួយ ជនជាបរិវារបបួលនាងថា នឹងលេងទឹកក្នុងស្ទឹង គង្គា ។ កាលមនុស្សទាំងនោះលេងទឹកនោះឯង ជាពេលដែលព្រះអាទិត្យ ទៀបអស្តង្គត ។ ពពកខ្មៅក៏តាំងឡើង ។ ពួកមនុស្សទាំងឡាយឃើញមេឃ ភ្លៀងហើយ ក៏រត់បែកខ្ញែកគ្នាទៅ ។ ពួកទាសកម្មកររបស់ធីតាសេដ្ឋីនិយាយ គ្នាថា ថ្ងៃនេះ ពួកយើងនឹងកែកំហុសស្រីកំណាចនេះហើយ ទុកចោលក្នុងទឹក នោះឯង នាំគ្នាឡើងទៅ ភ្លៀងក៏ធ្លាក់ចុះមក ព្រះអាទិត្យក៏លិច ងងឹតជុំទិស ។

ពួកទាសៈ និងកម្មករទាំងនោះ វៀរតែធីតាសេដ្ឋីម្នាក់ទៅដល់ផ្ទះ កាលមនុស្ស ទាំងឡាយពោលថា ធីតាសេដ្ឋីទៅណា ក៏ពោលថា នាងឡើងអំពីទឹកមកមុន ហើយ កាលបើដូច្នេះ ពួកខ្ញុំមិនដឹងថា នាងទៅណា សូម្បីពួកញាតិដើររក ក៏មិនឃើញ ។

ធីតាសេដ្ឋីទ្រហោយំ អណ្តែតទៅតាមទឹក ដល់ទីជិតបណ្ណសាលារបស់ ព្រះពោធិសត្វ លុះដល់ពេលកណ្តាលយប់ព្រះពោធិសត្វបានឮសំឡេង គិត ថា នុ៎ះជាសំលេងស្រី ត្រូវជួយស្រង់នាង ទើបកាន់គប់ភ្លើង ដើរទៅកាន់ ច្រាំងស្ទឹង ឃើញហើយក៏លួងលោមថា ចូរនាងកុំខ្លាចឡើយ ចូរនាងកុំខ្លាច ឡើយ ។ តាបសមានកម្លាំងដូចដំរីសារ សម្បូរដោយថាមពល ហែលទឹកទៅ ជួយនាងឡើងបានមក នាំទៅកាន់អាស្រម បង្កាត់ភ្លើងឡើ្ន លុះនាងបាត់រងា ហើយ ក៏យកផ្លែឈើតូចធំដែលឆ្ងាញ់ៗ មកឲ្យ សួរនាងក្នុងខណៈបរិភោគ ផ្លែឈើនោះថា នាងនៅឯណា ដូចម្តេចបានជាធ្លាក់ទឹកអណ្តែតមក នាងក៏ និយាយរឿងនោះឲ្យស្តាប់ ។ គ្រានោះ ព្រះពោធិសត្វពោលថា នាងស្នាក់ទី នេះហើយ រៀបចំឲ្យនាងស្នាក់ក្នុងបណ្ណសាលា ខ្លួនឯងដេកកណ្តាលវាល ២-៣ ថ្ងៃ ហើយពោលថា ឥឡូវនេះ ចូរនាងទៅចុះ ។ ធីតាសេដ្ឋីគិតថា អញនឹងធ្វើតាបសនេះឲ្យដល់សីលភេទ រួចបបួលទៅឲ្យបាន ដូច្នេះហើយ មិន ព្រមទៅ ។ ក្នុងកាលកន្លងទៅ ក៏សម្តែងមាយាស្ត្រី ធ្វើឲ្យតាបសដាច់សីល សាបសូន្យចាកឈាន ។ តាបសបបួលនាងនៅក្នុងព្រៃនោះឯង តែនាងពោល នឹងតាបសថា យើងទាំង ២ នៅក្នុងព្រៃធ្វើអ្វី យើងនាំគ្នាទៅកាន់ស្រុកចុះ

តាបសនាំនាងទៅដល់តំបន់ជាយដែនមួយ ប្រកបមុខរបរដោយការលក់តក្កៈ ដើម្បីចិញ្ចឹមនាង ។ ព្រោះតាបសលក់ទឹកដោះជូរចិញ្ចឹមជីវិត ទើបមហាជន ដាក់ឈ្មោះថា តក្កបណ្ឌិត ។ គ្រានោះ ពួកអ្នកស្រុកនាំគ្នាឲ្យស្បៀងអាហារ ដល់លោក ពោលថា សូមលោកជួយប្រាប់ហេតុការណ៍ ដែលបុគ្គលប្រកប ល្អ ឬអាក្រក់ដល់ពួកខ្ញុំ ហើយនៅក្នុងទីនេះចុះ នាំគ្នាសង់ខ្ទមឲ្យនៅត្រង់ ទ្វារស្រុក ។

សម័យនោះ ពួកចោរនាំគ្នាចុះអំពីភ្នំ ប្លន់ជនបទជាយដែន ថ្ងៃមួយ នាំគ្នា មកប្លន់ស្រុកនោះ ហើយប្រើអ្នកជនបទទាំងនោះឯងឲ្យជញ្ជូនរបស់ទៅឲ្យ ចាប់ យកសេដ្ឋីធីតានោះទៅកាន់សម្នាក់របស់ខ្លួន ហើយដោះលែងមនុស្សដ៏សេស ។ ឯមេចោរពេញចិត្តក្នុងរូបរបស់នាង ទើបធ្វើនាងឲ្យជាភរិយារបស់ខ្លួន ព្រះ ពោធិសត្វស៊ើបសួរថា ស្រីនោះទៅទីណា សូម្បីបានដឹងថា ត្រូវមេចោរទុក ធ្វើជាភរិយាហើយ ក៏គិតថា នាងនឹងមិនបោះបង់អញនៅក្នុងទីនោះឡើយ នឹង ត្រូវត្រឡប់មកវិញដោយពិត ទន្ទឹងរង់ចាំក្នុងស្រុកនោះឯង ។ ឯសេដ្ឋីធីតាក៏ គិតថា អញនៅទីនេះជាសុខ ជួនកាល តក្កបណ្ឌិតអាស្រ័យហេតុណាមួយ ហើយ មកនាំអញទៅទីនេះ កាលបើដូច្នោះ អញនឹងវិនាសចាកសេចក្តីសុខ នេះ បើដូច្នោះ អញធ្វើដូចជានៅស្រឡាញ់ ឲ្យមនុស្សទៅហៅមក ហើយឲ្យ សម្លាប់ចោល គិតហើយ ហៅមនុស្សម្នាក់មក បញ្ជូនទៅថា ខ្ញុំរស់នៅយ៉ាង លំបាកក្នុងទីនេះ សូមតក្កបណ្ឌិតមកទទួលខ្ញុំទៅវិញផងចុះ ។ តក្កបណ្ឌិត ស្តាប់ដំណឹងនោះហើយក៏ជឿ ទើបទៅត្រង់ជំរំចោរ ឈប់ត្រង់ផ្លូវចូល បញ្ជូន

ដំណឹងទៅ ។ នាងចេញមកជួប ហើយពោលថា នែអ្នក បើអ្នកនាំខ្ញុំទៅឥឡូវនេះ មេចោរនឹងដេញតាមសម្លាប់យើងទាំង ២ យើងនឹងទៅក្នុងពេលយប់ នាំតក្កបណ្ឌិតមកឲ្យបរិភោគ ឲ្យពួនក្នុងជង្រុក ។ លុះដល់វេលាល្ងាចមេចោរត្រឡប់មក ផឹកស្រាស្រវឹង នាងក៏ពោលថា នែលោក បើលោកឃើញសត្រូវរបស់លោកក្នុងពេលនេះ តើលោកគប្បីធ្វើដូចម្តេច មេចោរពោលថា យើងនឹងធ្វើយ៉ាងនេះៗ ។ ទើបនាងប្រាប់ថា សត្រូវនោះមិននៅឆ្ងាយឡើយ អង្គុយក្នុងជង្រុកនេះឯង មេចោរកាន់ដាវដើរតម្រង់ទៅកាន់ជង្រុកឃើញតក្កបណ្ឌិត ទើបចាប់បោះឲ្យធ្លាក់ចុះមកដី វាយដោយដំបង អុកដោយកែងដៃ ក្បាលជង្គង់ជាដើម រហូតអស់ចិត្ត តក្កបណ្ឌិត ទោះបីត្រូវវាយ ក៏មិនពោលពាក្យដទៃឡើយ ពោលតែពាក្យថា ការខឹងក្រោធ អកតញ្ញូ ការញុះញង់ ការទ្រុស្តមិត្តតែម៉្យាងប៉ុណ្ណោះ ។ ឯមេចោរវាយដំតក្កបណ្ឌិតហើយចងឲ្យដេក មកបរិភោគអាហារល្ងាចហើយ ក៏ដេកលក់ទៅ ភ្ញាក់ឡើង លុះអស់នូវអំណាចស្រា ក៏ចាប់ផ្តើមវាយតក្កបណ្ឌិតទៀត ។ តក្កបណ្ឌិតក៏ពោលតែពាក្យ ៤ ម៉ាត់យ៉ាងនោះ ។ ចោរគិតថា បុរសនេះ ទោះត្រូវអញវាយយ៉ាងនេះ ក៏មិននិយាយអ្វីដទៃឡើយ ពោលតែពាក្យ ៤ មាត់ រហូតមកអញនឹងសាកសួរមើល ហើយក៏សួរតក្កបណ្ឌិតថា នែអ្នក អ្នកត្រូវយើងវាយយ៉ាងនេះ ហេតុអ្វី ទើបពោលតែពាក្យ ៤ មាត់នេះប៉ុណ្ណោះ ។ តក្កបណ្ឌិតពោលថា បើដូច្នោះ ចូរស្តាប់ ហើយពោលលំដាប់ហេតុការណ៍ តាំងអំពីដើមថា ពីមុន ខ្ញុំជាតាបសម្នាក់នៅក្នុងព្រៃ បានឈាន ខ្ញុំបានជួយស្រីនេះ

ដែលអណ្តែតមកតាមទឹកស្ទឹងគង្គាឲ្យឡើងបាន ទំនុកបម្រុង កាលបើដូច្នេះ ស្រីនេះ ក៏ប្រលោមខ្ញុំ ធ្វើឲ្យសាបសូន្យចាកឈាន ខ្ញុំបោះបង់ចោលព្រៃ នាំនាងមកចិញ្ចឹមក្នុងស្រុកជាយដែន កាលនាងបញ្ជូនដំណឹងទៅដល់ខ្ញុំថា ត្រូវពួកចោរនាំមកទីនេះរស់នៅយ៉ាងលំបាក ឲ្យជួយនាំនាងត្រឡប់ទៅ ធ្វើឲ្យខ្ញុំត្រូវធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកក្នុងឥឡូវនេះ ដោយហេតុនោះ ទើបខ្ញុំពោលយ៉ាងនេះ ។

ចោរគិតថា ស្រីនេះ បដិបត្តិខុសដល់ម្ល៉េះ ដល់បុគ្គលដែលសម្បូរដោយគុណ មានឧបការៈយ៉ាងនេះ ស្រីនេះគង់ធ្វើអន្តរាយណាមួយដល់អញក៏បាន អញត្រូវសម្លាប់វាចោល ។ មេចោរលួងលោមតក្កបណ្ឌិតឲ្យធូរស្បើយចិត្ត ដឹកដៃនាងចេញមក ពោលថា យើងនឹងសម្លាប់បុរសនេះត្រង់ទ្វារស្រុក ដើរចេញទៅខាងក្រៅស្រុកជាមួយនាង ប្រាប់ឲ្យនាងចាប់ដៃតក្កបណ្ឌិត ដោយពាក្យថា ចូរចាប់ដៃបុរសនេះ ហើយដកដាវ ធ្វើហាក់ដូចជាកាប់តក្កបណ្ឌិត ហើយក៏មកកាប់នាងដាច់ជា ២ កំណាត់ ងូតទឹកហើយ អង្គាសតក្កបណ្ឌិត ដោយបណីតភោជន ២-៣ ថ្ងៃ ក៏ពោលថា ឥឡូវនេះ លោកនឹងទៅណា តក្កបណ្ឌិតពោលថា កិច្ចដោយការនៅគ្រប់គ្រងផ្ទះមិនមានដល់ខ្ញុំឡើយ ខ្ញុំនឹងបួសជាឥសីក្នុងព្រៃនេះឯង ។ ចោរពោលថា បើដូច្នោះ ខ្ញុំនឹងបួសដែរ ។ ជន

ទាំង ២ នាំគ្នាបួសនៅក្នុងដងព្រៃនោះ ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ ក្នុងកាលអស់ជីវិត ក៏ទៅកាន់ព្រហ្មលោក ។

ព្រះសាស្ដាត្រាស់រឿងទាំង ២ នេះហើយ កាលទ្រង់ត្រាស់ដឹងហើយ ក៏ត្រាស់ព្រះគាថានេះថា

( ធម្មតាស្ត្រី ) ច្រើនខឹង មិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ បំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្ត ព្រហ្មចរិយៈចុះ អ្នកនោះ នឹងមិនវិនាសសេចក្ដីសុខ ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយសរុបសេចក្ដីដូចតទៅនេះ ម្នាលភិក្ខុ ឈ្មោះថា ស្រីទាំងឡាយ ជាអ្នកច្រើនដោយសេចក្ដីក្រោធ មិនអាចហាមសេចក្ដីក្រោធដែលកើតឡើងបានឡើយ ជាបុគ្គលអកតញ្ញូ មិនដឹងឧបការគុណ សូម្បីធំក្រៃលែង ជាអ្នកញុះញង់ ចូលចិត្តពោលពាក្យដែលសម្ដែងដល់ការញុះញង់រឿយៗ ជាអ្នកមាននិស្ស័យចូលចិត្តទម្លាយមិត្ត មានប្រក្រតីពោលពាក្យធ្វើឲ្យមិត្តបែកគ្នាជាប្រចាំ ស្រីទាំងនេះប្រកបទៅដោយធម៌ដ៏លាមកបែបនេះ ។ អ្នកនឹងត្រូវការស្រីទាំងនេះធ្វើអ្វី ម្នាលភិក្ខុ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយៈចុះ ព្រោះថា ការវៀរចាកមេថុនធម្មនេះ ឈ្មោះថា ព្រហ្មចរិយៈ ដោយអត្ថថា ជាគុណដ៏បរិសុទ្ធ អ្នកប្រព្រឹត្តព្រហ្មចរិយៈនោះ នឹងមិនឃ្លាតអំពីសេចក្ដីសុខ គឺ

កាលអ្នកប្រព្រឹត្តព្រហ្មចរិយៈនោះ នឹងមិនឃ្លាតសេចក្ដីសុខក្នុងឈាន បានដល់សេចក្ដីសុខដែលកើតអំពីមគ្គ និងសេចក្ដីសុខដែលកើតអំពីផល អធិប្បាយថា នឹងមិនលះសេចក្ដីសុខនេះ គឺនឹងមិនវិនាសចាកសេចក្ដីសុខនេះ ។ បាឋៈថា **ន បរិហាយសិ** អ្នកនឹងមិនវិនាស ដូច្នេះក៏មាន ។ ឯអត្ថ ក៏ដូចគ្នានោះឯង ។

ព្រះបរមសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះបរមសាស្ដា ទ្រង់ប្រជុំជាតកថា មេចោរក្នុងកាលនោះ បានជាអានន្ទក្នុងកាលឥឡូវនេះ ឯតក្កបណ្ឌិត គឺតថាគតនេះឯង ។

**អដ្ឋកថា តក្កបណ្ឌិតជាតក ចប់**

# សុត្តន្តបិដក

## ទុរាជានជាតក

[ ៦៤ ] *( ថា ស្ត្រីនេះ ) ប្រាថ្នាអញ កុំសោកសៅ ( ថា ស្ត្រីនេះ ) មិនប្រាថ្នាអញ ភាពរបស់ស្ត្រីទាំងឡាយ ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹក ។*

*ទុរាជានជាតកទី ៤ ចប់*

# អដ្ឋកថា

## ឧភតោភដ្ឋជាតក

[ ៦៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មា សុ នន្ទិ ឥច្ឆតិ មំ** ដូច្នេះជាដើម ។

បានឮមកថា ឧបាសកអ្នកក្រុងសាវត្ថីម្នាក់ តាំងមាំក្នុងសរណៈទាំង ៣ ក្នុងសីលទាំង ៥ ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ។ ឯភរិយាគាត់ជាស្រីទ្រុស្តសីល មានបាបធម៌ ថ្ងៃណាបានប្រព្រឹត្តក្រៅចិត្តប្តី ថ្ងៃនោះ ទន់ភ្លន់ដូចទាសី ដែលលោះមកដោយទ្រព្យ ១០០ កហាបណៈ តែក្នុងថ្ងៃណាដែលមិនបានសហាយស្មន់ ក៏វាយឫកដូចជាចៅហ្វាយនាយ កាចគ្រោតគ្រាត បុរសនោះមិនយល់ កាលបើដូច្នោះ ក៏កើតនូវការខ្វាចក្នុងនាងដែលជាភរិយា មិនបានទៅគាល់ព្រះសម្ពុទ្ធ ។ ថ្ងៃមួយ គាត់កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើមទៅថ្វាយបង្គំ ហើយអង្គុយ ។ ព្រះសាស្តាត្រាស់ថា នែឧបាសក មានរឿងអ្វី ទើបខានមកកាន់សម្នាក់តថាគត ៧-៨ ថ្ងៃ បុរសនោះក្រាបទូលថា បពិត្រព្រះអង្គ មេផ្ទះរបស់ខ្ញុំព្រះអង្គ ថ្ងៃខ្លះ ដូចទាសីដែលលោះមកដោយទ្រព្យ ១០០ កហាបណៈ ថ្ងៃខ្លះដូចជាចៅហ្វាយនាយ កាចអាក្រក់ ខ្ញុំព្រះអង្គមិនយល់សោះ ខ្ញុំព្រះអង្គធុញទ្រាន់ព្រោះនាង ទើបខានមកគាល់ ។ ព្រះសាស្តា លុះស្តាប់ពាក្យរបស់បុរសនោះហើយ ទើបត្រាស់ថា ឧបាសក ឈ្មោះថា សភាពរបស់មាតុគ្រាមដឹងបានលំបាកពិត សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយ ក៏ធ្លាប់ប្រាប់អ្នកហើយ តែអ្នកកំណត់មិនបាន

ព្រោះអន្តរាយពបិទបាំង កាលឧបាសកអារាធនាហើយ ទើបទ្រង់នាំអតីតនិទាន មកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាអាចារ្យទិសាបាមោក្ខ ឲ្យមាណព ៥០០ នាក់សិក្សាសិល្ប: កាលនោះ មាណពម្នាក់នៅស្រុកក្រៅ មករៀនសិល្ប:ក្នុងសម្នាក់របស់លោក មានចិត្តប្រតិព័ទ្ធក្នុងស្រីម្នាក់ ក៏បានស្រីនោះជាភរិយាស្នាក់នៅក្នុងនគរពារាណសីនោះឯង ខានទៅឧបដ្ឋាកអាចារ្យ ២-៣ ថ្ងៃ ឯស្រីដែលជាភរិយារបស់គេ ជាស្រីមាននិស្ស័យអាក្រក់ ក្នុងថ្ងៃដែលប្រព្រឹត្តក្រៅចិត្តប្តី ទន់ភ្លន់ដូចទាសីដែលលោះមកដោយទ្រព្យ ១០០ កហាបណ: ក្នុងថ្ងៃដែលមិនបានប្រព្រឹត្ត ដូចជាចៅហ្វាយ គ្រោតគ្រាត ។ បុរសនោះមិនអាចដឹងនូវការប្រព្រឹត្តរបស់នាងបាន ទើបធុញទ្រាន់ កង្វល់ក្នុងចិត្ត មិនបានទៅកាន់ទីបម្រើរបស់អាចារ្យ លុះកន្លង ៧-៨ ថ្ងៃ ទើបមក អាចារ្យសួរថា នៃមាណព តើអ្នកកើតអ្វី ទើបមិនមក ។ បុរសនោះប្រាប់ថា បពិត្រលោកអាចារ្យ ភរិយារបស់ខ្ញុំ ថ្ងៃខ្លះ ប្រាថ្នាខ្ញុំ ត្រូវការខ្ញុំ ដូចទាសីអស់នូវមាន:ថ្ងៃខ្លះ ដូចជាចៅហ្វាយ រឹងត្អឹង គ្រោតគ្រាត ខ្ញុំមិនយល់ចិត្តនាងសោះ ទើបធុញទ្រាន់សៅហ្មងចិត្ត មិនបានមកប្រណិប័តន៍លោកអាចារ្យ ។ អាចារ្យពោលថា នៃមាណព រឿងនេះក៏យ៉ាងនោះ ឈ្មោះថា ស្រីដែលមាននិស្ស័យអាក្រក់ ក្នុងថ្ងៃដែលប្រព្រឹត្តក្រៅចិត្តប្តីបាន ក៏រមែងទន់ភ្លន់ ធ្វើតាមប្តី ដូចទាសីដែលអស់មាន:ហើយ តែក្នុងថ្ងៃដែលប្រព្រឹត្តក្រៅចិត្តមិនបាន ក៏ក្លាយ

ជាស្រីរឹងត្អឹងដោយមានះ មិនទទួលរាប់ថាជាប្តី ឈ្មោះថា ស្រី មានការប្រព្រឹត្តថោកទាប និស្ស័យអាក្រក់យ៉ាងនេះ យ៉ាងនេះឯង ។ ឈ្មោះថាសភាពនៃស្រីទាំងនោះ ដឹងបានលំបាក ក្នុងកាលពួកនាងត្រូវការក្តី មិនត្រូវការក្តី គប្បីតាំងខ្លួនជាកណ្តាល ហើយពោលគាថាជាឱវាទថា

អ្នកកុំត្រេកអរ ( ថា ស្ត្រីនេះ ) ប្រាថ្នាអញ កុំសោកសៅ ( ថា ស្ត្រីនេះ ) មិនប្រាថ្នាអញ ភាពរបស់ស្ត្រីទាំងឡាយ ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹកជាដើម ។

បណ្តាបទទាំងនោះ **សុ** អក្ខរៈ ក្នុងបាទព្រះបាទព្រះគាថាថា **មា សុ ឆន្ទិ ឥច្ឆតិ មំ** ត្រឹមតែជានិបាត សេចក្តីថា កុំត្រេកអរថា ស្រីនេះត្រូវការអញ គឺមានសេចក្តីប្រាថ្នា មានសេចក្តីស្នេហាក្នុងអញ ។

បទថា **មា សុ សោចិ ន ឥច្ឆតិ** សេចក្តីថា ទាំងមិនត្រូវទោមនស្សថា ស្រីនេះមិនត្រូវការអញ ពង្រីកសេចក្តីថា កាលនាងត្រូវការ ក៏មិនត្រូវត្រេកអរ កាលនាងមិនត្រូវការ ក៏មិនត្រូវសោកសៅ ធ្វើចិត្តឲ្យជាកណ្តាល ។

បទថា **ថីនំ ភាវោ ទុរាជានោ** សេចក្តីថា ឈ្មោះថា សភាពនៃស្រីទាំងឡាយ ដឹងបានលំបាក ព្រោះមានមាយាស្រីបិទបាំង ។ សេចក្តីនេះប្រៀបដូចអ្វី ដូចការទៅរបស់ត្រីក្នុងទឹក ដឹងបានលំបាក ព្រោះទឹកបិទបាំង ដោយហេតុនេះឯង កាលអ្នកប្រមង់មក ត្រីក៏លាក់ខ្លួន ហែលទៅដោយទឹក គេចទៅបាន មិនឲ្យចាប់ខ្លួន យ៉ាងណា ស្រីទាំងឡាយក៏ដូច្នោះដែរ ធ្វើនូវការអាក្រក់ សូម្បីធំក្រៃលែង ក៏បិទបាំងកម្មដែលខ្លួនធ្វើ ដោយមាយាស្រី គឺ

បញ្ឆោតប្តីថា ខ្ញុំមិនបានធ្វើយ៉ាងនេះទេ ឈ្មោះថា ស្រីទាំងនេះ មានបាបធម៌ មានការប្រព្រឹត្តអាក្រក់យ៉ាងនេះ ត្រូវធ្វើចិត្តឲ្យជាកណ្តាល ក្នុងស្រីទាំងនោះ ទើបមានសេចក្តីសុខ ។

ព្រះពោធិសត្វបានឲ្យឱវាទដល់សិស្សយ៉ាងនេះ ។ តាំងពីនោះមក គាត់ក៏ប្រងើយក្នុងស្រីទាំងនោះ ។ សូម្បីកិរិយារបស់គាត់ លុះដឹងថា អាចារ្យដឹងនូវការប្រព្រឹត្តអាក្រក់របស់ខ្លួនហើយ តាំងអំពីនោះមក ក៏លះបង់ការប្រព្រឹត្តអាក្រក់ ។

ឯស្រីនោះ របស់ឧបាសកនោះ លុះដឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបដល់ដោយការប្រព្រឹត្តអាក្រក់របស់ខ្លួនហើយ តាំងអំពីនោះមក ក៏មិនធ្វើបាបកម្មនោះទៀត ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផលហើយ ព្រះសាស្តាទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ប្តីប្រពន្ធទាំង ២ ក្នុងកាលនោះ បានជាប្តីប្រពន្ធទាំងនេះក្នុងកាលឥឡូវនេះ ឯអាចារ្យ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ឧរាជានជាតក ចប់**

# សុត្តន្តបិដក

## អនភិរតិជាតក

[ ៦៥ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) ទន្លេក្តី ផ្លូវក្តី តៀមស្រាក្តី សាលាសម្នាក់ក្តី អណ្តូងទឹកក្តី ( ជារបស់សាធារណៈ ) យ៉ាងណា ធម្មតាស្ត្រីទាំងឡាយ ក្នុងលោក ក៏យ៉ាងនោះដែរ បណ្ឌិតទាំងឡាយ មិនខឹងនឹងស្ត្រីទាំងនោះទេ ។

**អនភិរតិជាតកទី ៥ ចប់**

# អដ្ឋកថា

## អនភិរតិជាតក

[ ៦៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលមានរឿងយ៉ាងនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា នទី ច បន្ថោ ច** ដូច្នេះជាដើម ។

កាលឧបាសកនោះចាំឃ្លាំមើល ក៏ដឹងនូវភាពដែលស្រីជាភរិយានោះមានការប្រព្រឹត្តអាក្រក់ ទើបមានចិត្តក្តៅក្រហាយ និងព្រោះហេតុដែលខ្លួនជាអ្នកមានចិត្តកង្វល់ ទើបខានទៅកាន់ទីបម្រើព្រះសាស្តា អស់ ៧-៨ ថ្ងៃ ថ្ងៃមួយចូលទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តា អង្គុយស្រួលបួលហើយ កាលព្រះសាស្តាត្រាស់ថា ម្នាលឧបាសក ព្រោះហេតុអ្វី ទើបខានមកអស់ ៧-៨ ថ្ងៃ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភរិយារបស់ខ្ញុំព្រះអង្គជាស្រីប្រព្រឹត្តអាក្រក់ ព្រោះខ្ញុំព្រះអង្គមានចិត្តសៅហ្មងក្នុងរឿងអាក្រក់ៗ របស់នាង ទើបខានមកគាល់ ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក បុរសមិនត្រូវធ្វើការអាក់អន់ក្នុងស្រីទាំងឡាយថា ស្រីទាំងនេះប្រព្រឹត្តអនាចារ គប្បីដាក់ខ្លួនជាកណ្តាលតែម្យ៉ាង សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយក៏ប្រាប់អ្នកហើយ តែអ្នកកំណត់ហេតុនោះមិនបាន ព្រោះអន្តរភពបិទបាំង ។ ឧបាសកទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាអាចារ្យទិសាបាមោក្ខ ដោយន័យមុននោះឯង ។ កាលនោះ កូនសិស្សរបស់លោកក៏បានឃើញទោសរបស់ភរិយាហើយ មិន

មករកអស់ ២-៣ ថ្ងៃ ព្រោះភាពជាអ្នកមានចិត្តសៅហ្មង ។ ថ្ងៃមួយ ត្រូវអាចារ្យសួរ ក៏ប្រាប់ហេតុនោះឲ្យជ្រាប ។ ទើបអាចារ្យរបស់គាត់ពោលថា នែបា ឈ្មោះថា ស្រី ជារបស់ទូទៅដល់ជនទាំងពួង បណ្ឌិតទាំងឡាយមិនធ្វើការអាក់អន់ក្នុងស្រីទាំងនោះឡើយថា ស្រីទាំងនេះ ជាអ្នកទ្រុស្តសីល ជាអ្នកមានបាបធម៌ ហើយពោលគាថានេះ ជាឧទានថា

*ទន្លេក្តី ផ្លូវក្តី តៀមស្រាក្តី សាលាសម្នាក់ក្តី អណ្តូងទឹកក្តី ( ជារបស់សាធារណៈ ) យ៉ាងណា ធម្មតាស្ត្រីទាំងឡាយ ក្នុងលោកក៏យ៉ាងនោះដែរ បណ្ឌិតទាំងឡាយ មិនខឹងនឹងស្ត្រីទាំងនោះទេ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យថា នទី** សេចក្តីថា ស្ទឹងមានកំពង់ច្រើន ជាទីសាធារណៈដល់មនុស្សជាន់ទាប មានចណ្ឌាលជាដើម និងដល់មនុស្សជាន់ខ្ពស់ មានក្សត្រជាដើម ដែលប្រាថ្នាមកដើម្បីងូត ក្នុងបណ្តាមនុស្សទាំងនោះ បុគ្គលណាម្នាក់ ឈ្មោះថា ងូតមិនបាន មិនមាន ។

ក្នុងបទជាដើមថា **បន្ថោ** អធិប្បាយថា ផ្លូវធំ ក៏ជាសាធារណៈសម្រាប់មនុស្សទាំងពួង បុគ្គលណាម្នាក់ ដែលឈ្មោះថា ដើរផ្លូវនោះមិនបាន មិនមាន ។

បទថា **ចាបាគារំ** សេចក្តីថា រោងសុរា ចាត់ជាទីសាធារណៈសម្រាប់មនុស្សទូទៅ បុគ្គលណាម្នាក់ប្រាថ្នានឹងផឹកគ្រប់ៗ គ្នា ក៏មានសិទ្ធិចូលទៅក្នុងតៀមស្រាបានទាំងអស់ សូម្បីសាលាសម្នាក់ដែលអ្នកប្រាថ្នាបុណ្យធ្វើ ជាទីស្នាក់អាស្រ័យនៃមនុស្សទាំងឡាយក្នុងទីនោះៗ ក៏ជាស្ថានសាធារណៈ បុគ្គល

ណាម្នាក់ ចូលទៅក្នុងសាលានោះមិនបាន មិនមាន សូម្បីខ្ទមតូច ដែលគេសាងឡើងតម្កល់ទឹកសម្រាប់ផឹកក្បែរផ្លូវធំ ក៏ជារបស់សាធារណៈសម្រាប់មនុស្សទូទៅ បុគ្គលណាម្នាក់ ផឹកទឹកក្នុងទីនោះមិនបាន មិនមាន យ៉ាងណា ។

បទថា **ឯវំ លោកិត្ថិយោ នាម** សេចក្តីថា នៃមាណព ស្រីទាំងឡាយក្នុងលោកនេះក៏ដូចគ្នា ជារបស់សាធារណៈសម្រាប់មនុស្សទូទៅ គឺដូចគ្នានឹងស្ទឹង ផ្លូវដើរ តៀមស្រា សាលាសម្នាក់ និងទីតម្កល់ទឹក ព្រោះអត្ថថា ជារបស់សាធារណៈនោះឯង ។ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយរមែងមិនក្រោធអាក់អន់ក្នុងស្រីទាំងនោះ អធិប្បាយថា បណ្ឌិត គឺអ្នកឈ្លាសវៃ សម្បូរដោយប្រាជ្ញា គិតថា ស្រីទាំងនេះ លាមក អនាចារ ទ្រុស្តសីល ជាស្រីសាធារណៈដល់មនុស្សទូទៅ ដូច្នេះហើយ ទើបមិនក្រោធនឹងស្រីទាំងនោះ ។

ព្រះពោធិសត្វឲ្យឱវាទដល់សិស្សយ៉ាងនេះ សិស្សស្តាប់ឱវាទនោះហើយ ទើបដាក់ចិត្តជាកណ្តាលបាន សូម្បីកិរិយារបស់បុរសនោះ ក៏គិតថា បានឮថា អាចារ្យដឹងរឿងរបស់អញហើយ តាំងពីនោះមក ក៏មិនធ្វើកម្មដ៏លាមកទៀត ។

ឯកិរិយារបស់ឧបាសកនោះ ក៏គិតថា បានឮថា ព្រះសាស្តាដឹងរឿងរបស់អញហើយ តាំងអំពីនោះ ក៏មិនធ្វើបាបកម្មទៀត ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈ ឧបាសកក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ប្តីប្រពន្ធ ២ នាក់ក្នុងកាលនោះ បានមកជាប្តីប្រពន្ធក្នុងកាលនេះ ឯព្រាហ្មណ៍ដែលជាអាចារ្យ គឺតថាគតនោះឯង ។

# សុត្តន្តបិដក

## មុទុលក្ខណជាតក

[ ៦៦ ] ( ឥសីពោធិសត្វពោលថា ) មុនអំពីពេលដែលមិនទាន់បាន នូវនាងមុទុលក្ខណា សេចក្តីប្រាថ្នាមានតែមួយ កាលណាអាត្មាភាព បាននាង មុទុលក្ខណា ជាស្ត្រីមានភ្នែកល្អហើយ សេចក្តីប្រាថ្នារឹតតែញាំងសេចក្តីប្រាថ្នា ( ផ្សេងៗ ) ឲ្យកើតទៀត ។

មុទុលក្ខណជាតកទី ៦ ចប់

# អដ្ឋកថា

## មុទុលក្ខណជាតក

[ ៦៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសភាវ-ធម៌ដែលឲ្យបុគ្គលសៅហ្មង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯកា ឥច្ឆា បុរេ អាសិ** ដូច្នេះជាដើម ។

បានឮថា បុរសអ្នកក្រុងសាវត្ថីម្នាក់ ស្តាប់ព្រះធម្មទេសនារបស់ព្រះ-សាស្តាហើយ បួសឧទ្ទិសជីវិតក្នុងសាសនា គឺព្រះរតនត្រ័យ ជាព្រះយោគាវចរបដិបត្តិមធ្យ័ត មិនវៀរកម្មដ្ឋាន ។ ថ្ងៃមួយ ត្រាច់ទៅបិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្រីម្នាក់តែងខ្លួនស្រស់ត្រកាល មិនសង្រួមចក្ខុ សម្លឹងមើលដោយភាពជារបស់ស្អាត ។ កិលេសខាងក្នុងរបស់លោកកម្រើកឡើង ដូចដើមឈើមានជ័រត្រូវធូតដោយកាំបិត ដូច្នោះ ។ ចាប់អំពីនោះ លោកក៏ធ្លាក់នៅក្នុងអំណាចរបស់កិលេស មិនសប្បាយកាយ និងចូរស្រោលចិត្តឡើយ ច្រេច្រាដូចសត្វឈ្មុស មិនត្រេកអរក្នុងព្រះសាសនា ទុកសក់ឲ្យដុះវែង ក្រចកវែង ចីវរសៅហ្មង ។ កាលនោះ ភិក្ខុទាំងឡាយដែលជាសម្លាញ់ឃើញអាការប្រែប្រួលនៃឥន្ទ្រិយរបស់លោក នាំគ្នាសួរថា នែអាវុសោ តើលោកកើតអ្វី ឥន្ទ្រិយរបស់លោកមិនដូចមុន ។ លោកឆ្លើយថា អាវុសោ ខ្ញុំអផ្សុក លែងត្រេកអរក្នុងសាសនា ។

ភិក្ខុទាំងឡាយ ក៏នាំលោកទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនប្រាថ្នាមកឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ មិនត្រេកអរឡើយ

ទើបព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកមិនត្រេកអរពិតឬ ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គកំពុងត្រាច់បិណ្ឌបាត បានឃើញស្រីម្នាក់ មិនសង្រួមចក្ខុ សម្លឹងមើលនាងលំដាប់នោះ កិលេសរបស់ខ្ញុំព្រះអង្គកម្រើក ហេតុនោះ ទើបខ្ញុំព្រះអង្គអផ្សុក ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកបែកធ្លាយឥន្ទ្រិយ សម្លឹងមើលវិសភាគា-រម្មណ៍ដោយអំណាចសុភ ហើយកិលេសកម្រើកនេះ មិនជាអស្ចារ្យទេ ក្នុងកាលមុន សូម្បីព្រះពោធិសត្វទាំងឡាយ បានអភិញ្ញា ៥ សមាបត្តិ ៨ សង្កត់កិលេសបានហើយ ដោយកម្លាំងឈាន មានចិត្តបរិសុទ្ធ ត្រាច់ទៅក្នុងអាកាសបាន កាលបែកធ្លាយឥន្ទ្រិយ សម្លឹងមើលវិសភាគារម្មណ៍ ក៏សាបសូន្យចាកឈាន កិលេសកម្រើក សោយទុក្ខយ៉ាងធំ ខ្យល់មានកម្លាំង ដែលអាចបំបាក់ភ្នំព្រះសិនេរុបាន រឿងអ្វីដែលថា មិនបក់ភ្នំតូចប៉ុនជើងដំរីឲ្យហើរទៅបាន ខ្យល់ដែលបក់ដើមព្រីងធំឲ្យបាក់ រឿងអ្វីដែលមិនបក់គុម្ពឈើដែលដុះក្បែរមាត់ច្រាំងឲ្យអណ្តែតទៅបាន ម្យ៉ាងទៀត ខ្យល់ដែលបក់មហាសមុទ្រឲ្យរីងស្ងួតបាន រឿងអ្វីដែលថា មិនបក់ទឹកក្នុងថ្លុកតូចឲ្យរីងស្ងួតទៅ កិលេសដែលធ្វើការមិនដឹងដល់ព្រះពោធិសត្វ ដែលមានប្រាជ្ញាដ៏ឧត្តម មានចិត្តផូរផង់បែបនេះ កិលេសទាំងនោះនឹងកោតក្រែងអ្វីក្នុងអ្នក សត្វបរិសុទ្ធគង់សៅហ្មងសូម្បីដល់ព្រមដោយយសដ៏ឧត្តម ក៏គង់អស់យសបាន ដូច្នេះហើយ ទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិច្រើន ក្នុងដែនកាសី ។ សម្រេចភាពជាអ្នកដឹងក្តីហើយ រៀនចប់សិប្បៈគ្រប់យ៉ាង លះកាមហើយ ទៅបួសជាឥសី ធ្វើកសិណបរិកម្ម ឲ្យអភិញ្ញាសមាបត្តិកើតឡើង ហើយនៅសម្ងំដោយឈានសុខ អាស្រ័យក្នុងហិមវន្តប្បទេស ។ គ្រាមួយ លោកមកអំពីព្រៃហិមពាន្ត ដើម្បីបរិភោគភោជន មានរសជូរ និងប្រៃ ដល់ក្រុងពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ លុះព្រឹកឡើង ធ្វើសរីរកិច្ចស្រេចហើយ គ្រងសំពត់សម្បកឈើ ដណ្តប់ស្បែកខ្លាធៀងស្មាម្ខាង ចងផ្នួងសក់ស្រេចបាច់ហើយ ទ្រទ្រង់នូវបរិក្ខារ ត្រាច់បិណ្ឌបាតក្នុងក្រុងពារាណសី ដល់ទ្វារព្រះរាជនិវេសន៍ ព្រះរាជាទ្រង់ជ្រះថ្លា ក្នុងឥរិយាបថរបស់លោក និមន្តឲ្យចូលមកឲ្យអង្គុយលើអាសនៈ ដែលមានតម្លៃច្រើន ទ្រង់អង្គាសដោយខាទនីយភោជនីយាហារដ៏ប្រណីត លោកធ្វើអនុមោទនាហើយ ព្រះរាជាអារាធនាឲ្យស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ តាបសក៏ទទួលនិមន្តឆាន់ក្នុងព្រះរាជវាំង ប្រទានឱវាទដល់រាជត្រកូល ស្នាក់នៅក្នុងព្រះរាជឧទ្យានអស់ ១៦ ឆ្នាំ ។ ថ្ងៃមួយ ព្រះរាជាយាងទៅបង្ក្រាបបច្ចន្តជនបទដែលបះបោរ ទ្រង់ត្រាស់នឹងមហេសីព្រះនាមមុទុលក្ខណាថា ចូរនាងកុំប្រមាទ ចូរប្រណិប័តន៍លោកម្ចាស់ ដូច្នេះហើយ ទ្រង់យាងទៅ ។

ព្រះពោធិសត្វ តាំងអំពីកាលព្រះរាជាយាងទៅហើយ ក៏ទៅកាន់ព្រះរាជវាំងតាមដែលខ្លួនគាប់ចិត្ត ។ ថ្ងៃមួយ ព្រះនាងមុទុលក្ខណាត្រៀមអាហារ

សម្រាប់ព្រះពោធិសត្វស្រេចហើយ ព្រះតម្រិះថា ថ្ងៃនេះ លោកម្ចាស់គង់យឺតយូរ ព្រះនាងស្រពស្រង់ដោយព្រះសុគន្ធោទកៈ តាក់តែងព្រះកាយដោយគ្រឿងអលង្ការទាំងពួង ឲ្យតាំងព្រះទែនតូចក្នុងផ្ទៃព្រះប្រាសាទ ប្រថាប់ទម្រេតព្រះកាយ រង់ចាំព្រះពោធិសត្វមក ។ ឯព្រះពោធិសត្វកំណត់កាលនៃខ្លួនហើយ ចេញអំពីឈាន ហោះទៅកាន់ព្រះរាជនិវេសន៍មួយរំពេច ព្រះនាងមុទុលក្ខណាឮសន្ធឹកសំពត់សម្បកឈើ ដឹងថា ព្រះពោធិសត្វមកហើយ ក៏ប្រញាប់ក្រោកឡើង កាលនាងក្រោកឡើងដោយប្រញាប់ សំពត់ដែលនាងទ្រទ្រង់ជាសំពត់សាច់រអិល ក៏របូត ។ គាប់ជួនតាបសចូលមកតាមបង្អួច សម្លឹងឃើញរូបារម្មណ៍ដែលជាវិសភាគរបស់ព្រះទេវី ក៏ទម្លាយឥន្ទ្រិយសម្លឹងមើលដោយអំណាចសុភនិមិត្ត ពេលនោះ កិលេសដែលនៅខាងក្នុងក៏កម្រើកដូចដើមឈើដែលមានជ័រ ត្រូវធូតដោយកាំបិត រំពេចនោះឯង ឈានក៏វិនាសដូចក្អែកបាក់ស្លាប ។ ព្រះពោធិសត្វឈរទទួលអាហារហើយ ក៏មិនបរិភោគឡើយ ព្រោះញាប់ញ័រដោយកិលេសទាំងឡាយ ចុះអំពីប្រាសាទ ដើរទៅកាន់ព្រះរាជឧទ្យាន ចូលបណ្ណសាលា ដាក់អាហារត្រង់ជំណោកលើបន្ទះក្តារសម្រាប់ដាក់ ។ វិសភាគារម្មណ៍ចាក់ដោតក្នុងចិត្ត ភ្លើងកិលេសដុតរោល ស្គាំងស្គមព្រោះអត់អាហារ ដេកលើបន្ទះក្តារអស់ ៧ ថ្ងៃ ។

ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់បង្ក្រាបបច្ចន្តជនបទរាបទាបហើយ យាងមកទ្រង់ប្រទក្សិណព្រះនគរហើយ មិនទាន់ចូលទៅកាន់ព្រះរាជនិវេសន៍ ទ្រង់ព្រះតម្រិះថា អញនឹងជួបលោកម្ចាស់ជាមុនសិន ដូច្នេះហើយ យាងបង្ហួសទៅ

កាន់ព្រះរាជឧទ្យាន ចូលទៅកាន់បណ្ណសាលា ទតឃើញព្រះពោធិសត្វដេក ទ្រង់ព្រះតម្រិះថា ប្រហែលជាកើតនូវការមិនសប្បាយណាមួយ ទ្រង់បញ្ជាឲ្យសម្អាតបណ្ណសាលា ទ្រង់ប្របាច់ជើងទាំង ២ សួរថា លោកម្ចាស់មានជំងឺឬ តាបសថ្វាយព្រះពរថា មហាបពិត្រ ជំងឺដទៃមិនមានដល់អាត្មាឡើយ តែព្រោះអំណាចកិលេស អាត្មាមានចិត្តតម្រេកហើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ចិត្តរបស់លោកម្ចាស់ប្រតិព័ទ្ធក្នុងស្រីមួយណា តាបសថ្វាយព្រះពរថា ចិត្តរបស់អាត្មា ប្រតិព័ទ្ធក្នុងព្រះនាងមុទុលក្ខណា ។ ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ ខ្ញុំត្រេកអរនឹងប្រគេន ព្រះនាងមុទុលក្ខណាដល់លោកម្ចាស់ ហើយទ្រង់នាំតាបសចូលព្រះរាជនិវេសន៍ ឲ្យព្រះទេវីប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ហើយព្រះរាជទានដល់តាបស តែកាលព្រះរាជទាននោះ ទ្រង់បានឲ្យសញ្ញាអាថ៌កំបាំងដល់ព្រះនាងមុទុលក្ខណាថា នាងត្រូវព្យាយាមការពារលោកម្ចាស់ដោយកម្លាំងរបស់ខ្លួន ។ ព្រះនាងទទួលព្រះរាជឱង្ការថា ព្រះមេម្ចាស់ ខ្ញុំម្ចាស់នឹងរក្សាខ្លួនឲ្យផុតពីដៃលោកម្ចាស់ តាបសក៏នាំព្រះទេវីចុះអំពីព្រះរាជនិវេសន៍ លុះចេញផុតទ្វារធំ ព្រះនាងត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំគួរបានផ្ទះ សូមលោកម្ចាស់ទៅក្រាបទូលសូមផ្ទះមួយខ្នងនឹងព្រះរាជាចុះ តាបសក៏ទៅក្រាបទូលសូមព្រះរាជទានផ្ទះ ។ ព្រះរាជាព្រះរាជទានផ្ទះដែលគេបោះបង់មួយខ្នង ដែលគេប្រើជាបង្គន់ លោកក៏នាំព្រះទេវីទៅត្រង់ផ្ទះនោះ ព្រះនាងទ្រង់មិនបំណាងចូលទៅ តាបសសួរថា ព្រោះហេតុអ្វី ទើបព្រះនាងមិនចូលទៅ ព្រះនាងប្រាប់ថា ព្រោះផ្ទះស្មោកគ្រោក ។ តាបស

សួរថា ឥឡូវនេះ យើងគួរធ្វើដូចម្តេច ព្រះនាងប្រាប់ថា ត្រូវសម្អាតផ្ទះនោះ ហើយបញ្ជូនតាបសទៅកាន់ព្រះរាជសម្នាក់ ប្រាប់ថា សូមលោកម្ចាស់ទៅយកចបមក យកបង្គីមក កាលតាបសនាំមកហើយ ឲ្យកើបយករបស់ស្មោកគ្រោកទៅចោល ស្រេចហើយ ឲ្យទៅជញ្ជូនអាចម៍គោមកបូកលាប លុះស្រេចហើយ ក៏ត្រាស់ថា សូមលោកម្ចាស់ជញ្ជូនគ្រែមក ជញ្ជូនតាំងមកម្តងមួយៗ ហើយឲ្យតាបសដងទឹកចាក់ពាង ។ តាបសយកក្អមទៅដងទឹកមកចាក់ពាងទាល់តែពេញសម្រាប់ងូត ក្រាលទីដេក ។ សម័យនោះ ព្រះនាងទ្រង់ចាប់តាបសដែលកំពុងអង្គុយរួមគ្នា លើទីដេក ត្រង់ចំហៀងម្ខាង ទាញឲ្យឱនមុខមកត្រង់មុខ មានព្រះសវនីយ៍ថា លោកម្ចាស់ភ្លេចខ្លួនថា ជាសមណៈឬជាព្រាហ្មណ៍ហើយឬ ។

តាបសក៏បាននូវស្មារតីក្នុងខណៈនោះឯង តែក្នុងកាលដែលកន្លងមក លោកមិនដឹងខ្លួនឡើយ ។ ឈ្មោះថា កិលេសទាំងឡាយ ធ្វើនូវការមិនដឹងខ្លួនមានប្រមាណយ៉ាងនេះ ។ ក្នុងអធិការនេះ គួរពោលអាងព្រះពុទ្ធវចនៈ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទនីវរណៈជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ដូច្នេះផងដែរ ។

តាបសបាននូវសតិ គិតថា តណ្ហានេះ កាលចម្រើនឡើង នឹងមិនឲ្យអញងើបក្បាលឡើងអំពីអបាយទាំង ៤ អញគួរថ្វាយព្រះទេវីនេះដល់ព្រះរាជាហើយត្រឡប់ទៅកាន់ព្រៃហិមពាន្តក្នុងថ្ងៃនេះឯង ដូច្នេះហើយ នាំព្រះទេវីចូលគាល់ព្រះរាជា ថ្វាយព្រះពរថា មហាបពិត្រ អាត្មាមិនត្រូវការព្រះទេវីរបស់

មហាបពិត្រទេ ព្រោះអាស្រ័យព្រះនាងតែម្នាក់ ទើបតណ្ហាចម្រើនដល់អាត្មាគ្រប់យ៉ាង ហើយពោលគាថានេះថា

មុនអំពីពេលដែលមិនទាន់បាន នូវនាងមុទុលក្ខណា សេចក្តីប្រាថ្នាមានតែមួយ កាលណាអាត្មាភាពបាននាងមុទុលក្ខណា ជាស្ត្រីមានភ្នែកល្អហើយ សេចក្តីប្រាថ្នារឹតតែញុំាំងសេចក្តីប្រាថ្នា ( ផ្សេងៗ ) ឲ្យកើតទៀត ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយសរុបដូច្នេះថា ថ្វាយព្រះពរមហាបពិត្រ កាលមុន អាត្មាមិនទាន់ទទួលព្រះរាជទានព្រះទេវីមុទុលក្ខណាអំពីមហាបពិត្រ អាត្មាមានសេចក្តីប្រាថ្នាតែមួយ គឺត្រូវការតែម្យ៉ាងប៉ុណ្ណោះថា ឱហ្ន៎ ! អញគប្បីបានព្រះនាង តែលុះអាត្មាបានទទួលព្រះរាជទានព្រះនាង ដែលមានព្រះនេត្រល្អ មានព្រះនេត្រទូលាយ មានព្រះនេត្រស្អាត ពេលនោះ សេចក្តីប្រាថ្នាដំបូងរបស់អាត្មា នាំឲ្យកើតសេចក្តីប្រាថ្នាច្រើនឡើងៗ ដូចជាប្រាថ្នាផ្ទះ ប្រាថ្នាគ្រឿងឧបករណ៍ ប្រាថ្នាគ្រឿងឧបភោគជាដើម សេចក្តីប្រាថ្នារបស់អាត្មានោះចម្រើនយ៉ាងនេះ មិនឲ្យអាត្មាងើបក្បាលឡើងអំពីអបាយបានទេ នេះគ្រាន់តែព្រះនាងជាកិរិយារបស់អាត្មា ។ សូមមហាបពិត្រទទួលអគ្គមហេសីទ្រង់វិញចុះ អាត្មានឹងទៅព្រៃហិមពាន្ត ។

ក្នុងខណៈនោះឯង តាបសក៏ធ្វើឈានដែលវិនាសទៅឲ្យកើតឡើង អង្គុយក្នុងអាកាសសម្តែងធម៌ ថ្វាយឱវាទដល់ព្រះរាជា ហើយទៅកាន់ព្រៃហិមពាន្ត

តាមអាកាស មិនមកកាន់ប្រទេសដែលជាដែនដីមនុស្សទៀតឡើយ ចម្រើនព្រហ្មវិហារ មិនសាបសូន្យចាកឈាន កើតក្នុងព្រហ្មលោក ។

ព្រះបរមសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈ ភិក្ខុនោះប្រតិស្ឋានក្នុងអរហត្តផល ។ ព្រះសាស្ដាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ព្រះនាងមុទុលក្ខណា បានជានាងឧប្បលវណ្ណា ចំណែកឥសី គឺតថាគតនេះឯង ។

## អដ្ឋកថា មុទុលក្ខណាជាតក ចប់

# សុត្តន្តបិដក

## ឧច្ឆង្គជាតក

[ ៦៧ ] ( ស្ត្រីម្នាក់ពោលថា ) បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ ( ដូចជាអន្ទក់ដែលដក់ ) ក្នុងថ្នក់ ( បានដោយងាយ ) ស្ត្រីដែលដើរទៅតាមផ្លូវរកប្តី ( បានដោយងាយ ) ឯខ្ញុំព្រះអង្គមិនឃើញប្រទេស គឺផ្ទៃនៃមាតានោះ ដែលខ្ញុំព្រះអង្គគួរនាំយកបងប្អូនប្រុសបង្កើតមកបាន ។

**ឧច្ឆង្គជាតកទី ៧ ចប់**

# អដ្ឋកថា

## ឧច្ឆង្គជាតក

[ ៦៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីជនបទម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧច្ឆង្គេ ទេវ មេ បុត្តោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ក្នុងដែនកោសល មានជន ៣ នាក់ ភ្ជួរស្រែត្រង់មាត់ព្រៃមួយកន្លែង ។ ក្នុងសម័យនោះ ពួកចោរក្នុងព្រៃប្លន់ពួកមនុស្ស ហើយនាំគ្នាគេចទៅ ពួកមនុស្សក៏ស៊ើបរកដើម្បីចាប់ចោរទាំងនោះកាលមិនជួប ទើបតាមមករហូតដល់ទីនោះ ពោលថា ពួកឯងប្លន់គេក្នុងព្រៃហើយ ឥឡូវនេះ ក្លែងធ្វើជាភ្ជួរស្រែ ចាប់មនុស្សទាំងនោះ ដោយសម្គាល់ថាជាចោរ នាំមកថ្វាយព្រះបាទកោសល ។ កាលនោះ មានស្រីម្នាក់មកយំរៀបរាប់ថា សូមទ្រង់ព្រះរាជទានគ្រឿងស្លៀកដណ្តប់ដល់ខ្ញុំម្ចាស់ចុះ ដើរក្វែលព្រះរាជនិវេសន៍ទៅមកៗ ព្រះរាជាទ្រង់ស្តាប់សំឡេងរបស់នាងហើយ ទើបត្រាស់ថា ចូរពួកអ្នកឲ្យសំពត់ដណ្តប់ដល់នាង ។ ពួករាជបុរសនាំគ្នាវេចសំពត់សាដកបញ្ជូនទៅឲ្យ នាងឃើញសំពត់នោះហើយ ពោលថា ខ្ញុំមិនបានសូមព្រះរាជទានសំពត់នេះទេ ខ្ញុំសូមព្រះរាជទានគ្រឿងស្លៀកដណ្តប់ គឺប្តី ពួកមនុស្សនាំគ្នាទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ស្រីនោះ មិនបាននិយាយដល់សំពត់ស្លៀកសំពត់ដណ្តប់នេះទេ នាងពោលថា គ្រឿងស្លៀកដណ្តប់ គឺប្តី ព្រះរាជាឲ្យហៅនាងចូលគាល់ មានព្រះរាជតម្រាស់សួរថា បានឮថា នាងសូមសំពត់ គឺប្តីឬ ។ នាងក្រាបទូលថា ព្រះមេខ្ញុំម្ចាស់ ប្តីឈ្មោះ

ថា ជាសំពត់ដណ្តប់របស់ស្ត្រីដោយពិត ព្រោះស្ត្រីកាលមិនមានប្តី ទោះមានសំពត់ស្លៀក សំពត់ដណ្តប់រាប់ពាន់កហាបណៈ ក៏ឈ្មោះថា ជាស្រីអាក្រាតនោះឯង ។ ដើម្បីឲ្យអត្ថនេះសម្រេចប្រយោជន៍ បណ្ឌិតគប្បីនាំគាថា ( ក្នុងវេស្សន្តរជាតក ) មកសាធកៈដូច្នេះ

ទន្លេដែលគ្មានទឹក ហៅថា ទន្លេស្រាត ដែនដែលគ្មានព្រះរាជា
ហៅថា ដែនស្រាត ចំណែកស្ត្រីមេម៉ាយ បើទុកជាមានបងប្អូន
ប្រុសដល់ ១០ នាក់ ក៏ហៅថា ស្ត្រីស្រាត ដូច្នេះ ។

ព្រះរាជាទ្រង់ជ្រះថ្លា ត្រាស់សួរថា ជនទាំង ៣ នាក់នេះ ជាអ្វីនឹងនាង នាងទូលថា បពិត្រព្រះអង្គ ម្នាក់ជាប្តី ម្នាក់ជាបងប្រុស ម្នាក់ជាកូន ។ ព្រះរាជាត្រាស់សួរថា យើងពេញចិត្តក្នុងនាង បណ្តាជនទាំង ៣ នេះ យើងឲ្យនាងម្នាក់ នាងត្រូវការម្នាក់ណា នាងក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំម្ចាស់នៅមានជីវិត ប្តីនឹងត្រូវរកបាន សូម្បីកូនក៏ត្រូវបានផងដែរ ព្រោះឪពុកម្តាយរបស់ខ្ញុំម្ចាស់បាត់បង់ជីវិតទៅហើយ បងប្រុសរកបានដោយលំបាក សូមទ្រង់ព្រះរាជទានបងប្រុសដល់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាត្រេកអរហើយ ឲ្យលែងជនទាំង ៣ ទៅ ព្រោះអាស្រ័យស្រីនោះតែម្នាក់ ទើបជនទាំង ៣ ផុតចាកទុក្ខបាន ដោយប្រការដូច្នេះ ។ រឿងនោះ ដឹងទូទៅដល់ពួកភិក្ខុ ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា សរសើរគុណរបស់ស្រីនោះថា អាវុសោទាំងឡាយ អាស្រ័យស្រីម្នាក់ ជន ៣ នាក់ រួចផុតទុក្ខ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំគ្នាសន្ទនាដោយរឿងអ្វី

កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ ដែលស្រីនេះ ដោះជនទាំង ៣ ឲ្យផុតចាកទុក្ខ សូម្បីក្នុងកាលមុន ក៏ដោះហើយដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ជនទាំង ៣ នាំគ្នាភ្ជួរស្រែត្រង់មាត់ព្រៃ ដូច្នេះ ។ បន្ទាប់អំពីនោះទៅ រឿងទាំងអស់ដូចគ្នានឹងរឿងខាងលើនោះឯង ។ តែសេចក្ដីប្លែក មានដូចតទៅ កាលព្រះរាជាត្រាស់សួរថា បណ្ដាជនទាំង ៣ នាងត្រូវការម្នាក់ណា ស្រីនោះក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់មិនអាចព្រះរាជទានទាំង ៣ នាក់បានទេឬ ព្រះរាជាត្រាស់ថា អើ មិនអាចបានទាំង ៣ នាក់ឡើយ ។ នាងក្រាបទូលថា បើទ្រង់មិនអាចព្រះរាជទានទាំង ៣ នាក់សោត សូមទ្រង់ព្រះរាជទានបងប្រុសដល់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាត្រាស់សួរថា នាងគួរទទួលបុត្តឬស្វាមី ហេតុអ្វី ទើបនាងត្រូវការបងប្រុស ក៏ក្រាបទូលថា បពិត្រព្រះអង្គ ធម្មតាមនុស្សទាំងនេះរកបានងាយ តែបងប្រុសរកបានលំបាក ហើយក្រាបទូលគាថានេះថា

បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ ( ដូចជាអន្ទក់ដែលដក់ ) ក្នុងថ្នក់ ( បានដោយងាយ ) ស្ត្រីដែលដើរទៅតាមផ្លូវ រកប្ដី ( បានដោយងាយ ) ឯខ្ញុំព្រះអង្គមិនឃើញប្រទេស គឺផ្ទៃនៃមាតានោះ ដែលខ្ញុំព្រះអង្គគួរនាំយកបងប្អូនប្រុសបង្កើតមកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧច្ឆង្គេ ទេវ មេ បុត្តោ** សេចក្តីថា បពិត្រព្រះសម្មតិទេព បុត្រនៅក្នុងថ្នក់របស់ខ្ញុំម្ចាស់នោះឯង ដោយប្រៀបសេចក្តីថា កាលខ្ញុំម្ចាស់ចូលព្រៃ ធ្វើសំពត់ឲ្យជាថ្នក់ បេះបន្លែដាក់ក្នុងថ្នក់នោះ ទើបបន្លែឈ្មោះថា ជារបស់រកបានងាយ ព្រោះមាននៅក្នុងថ្នក់ យ៉ាងណា ស្រីក៏រកបុត្របានងាយ ដូច្នោះ ដូចគ្នានឹងបន្លែក្នុងថ្នក់នោះឯង ដោយហេតុនោះ ទើបខ្ញុំម្ចាស់ពោលថា បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ ( ដូចជាអន្លក់ដែលដក់ ) ក្នុងថ្នក់ ( បានដោយងាយ ) ដូច្នេះ ។

បទថា **បថេ ធាវន្តិយា បតិ** សេចក្តីថា ធម្មតាប្តី ស្ត្រីគ្រាន់តែដើរតាមផ្លូវម្នាក់ឯង ក៏រកបានប្រុសដែលជួបជាប្តីបានទាំងអស់ ដោយហេតុនោះ ទើបខ្ញុំម្ចាស់ពោលថា ស្ត្រីដែលដើរទៅតាមផ្លូវ រកប្តី ( បានដោយងាយ ) ដូច្នេះ ។

បទថា **តញ្ច ទេសំ ន បស្សាមិ យតោ សោទរិយមានយេ** សេចក្តីថា តែព្រោះមាតាបិតារបស់ខ្ញុំមិនមាន ព្រោះដូច្នោះ ឥឡូវនេះ ប្រទេសដទៃពោល គឺផ្ទៃរបស់មាតាដែលខ្ញុំរកបងប្អូន ដែលនៅរួមឧទរគ្នា ព្រោះកើតរួមឧទរនោះ ខ្ញុំមើលមិនឃើញឡើយ ព្រោះហេតុនោះ សូមទ្រង់ព្រះរាជទាន បងប្រុសដល់ខ្ញុំម្ចាស់ចុះ ។

ព្រះរាជាទ្រង់ព្រះតម្រិះ ស្ត្រីនេះពោលពិត ដូច្នេះហើយ មានព្រះហឫទ័យត្រេកអរ ហើយឲ្យមនុស្សទាំង ៣ ចេញមកពីគុក ព្រះរាជទានដល់នាង ទើបនាងនាំមនុស្សទាំង ៣ ត្រឡប់ទៅ ។

*ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវ នេះប៉ុណ្ណោះទេ ក្នុងកាលមុននាងធ្លាប់ជួយមនុស្សទាំង ៣ នេះឲ្យផុតបាកទុក្ខ ហើយដូចគ្នា ដូច្នេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុ-សន្ធិប្រជុំជាតកថា ជន ៤ នាក់ក្នុងអតីត បានមកជាជន ៤ នាក់ ក្នុងបច្ចុប្បន្ន ឯព្រះរាជា គឺជាតថាគតនេះឯង ។*

**អដ្ឋកថា ឧច្ចង្គជាតក ចប់**

# សុត្តន្តបិដក

## សាកេតជាតក

[ ៦៨ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះ ដោយពិត ។

*សាកេតជាតកទី ៨ ចប់*

# អដ្ឋកថា

## សាកេតជាតក

[ ៦៨ ] ព្រះសាស្ដា កាលទ្រង់អាស្រ័យក្រុងសាកេត គង់នៅក្នុងវិហារអញ្ជនវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យស្មឹ មនោ និវិសតិ** ដូច្នេះជាដើម ។

បានឮថា ក្នុងពេលដែលព្រះមានព្រះភាគចោមរោមដោយពួកភិក្ខុ យាងចូលក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់អ្នកក្រុងសាកេតម្នាក់កំពុងដើរចេញទៅក្រៅព្រះនគរ ជួបព្រះសាស្ដាត្រង់រវាងទ្វារ ក៏ក្រាបចុះទៀបព្រះយុគលបាទ ចាប់កព្រះបាទទាំងគូយ៉ាងណែន ក្រាបទូលថា នែបា ធម្មតាកូន ត្រូវប្រណិប័តន៍មាតាបិតាក្នុងពេលចាស់មិនមែនឬ ហេតុអ្វី ទើបបាមិនបង្ហាញខ្លួន ដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ ខ្ញុំឃើញបាហើយ តែសូមបាមកជួបម្ដាយហើយនាំព្រះសាស្ដាទៅផ្ទះរបស់ខ្លួន ព្រះសាស្ដាយាងទៅផ្ទះរបស់ព្រាហ្មណ៍នោះ គង់លើអាសនៈដែលគេរៀបចំ មួយអន្លើដោយភិក្ខុសង្ឃ ឯព្រាហ្មណីបានដំណឹងថា ឥឡូវនេះ កូនរបស់យើងមកហើយ ក៏ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះសាស្ដា ហើយយំរៀបរាប់ថា នែបាជាទីស្រឡាញ់ស្មើជីវិត បាទៅណាអស់កាលដ៏យូរមានប្រមាណប៉ុណ្ណេះ ធម្មតាកូនត្រូវទំនុកបម្រុងមាតាបិតាក្នុងពេលចាស់មិនមែនឬ ហើយប្រាប់ឲ្យបុត្តធីតានាំគ្នាមកថ្វាយបង្គំ ដោយពាក្យថា ចូរពួកអ្នកថ្វាយបង្គំបងប្រុស ។ ព្រាហ្មណ៍ ២ នាក់ប្ដីប្រពន្ធត្រេកអរថ្វាយមហាទាន ព្រះសាស្ដាកាលសោយស្រេចហើយ ក៏ត្រាស់ជរាសូត្រដល់ព្រាហ្មណ៍ទាំង ២ នោះ ។ ក្នុងកាលចប់ព្រះសូត្រ ជន

ទាំង ២ ក៏តាំងនៅក្នុងអនាគាមិផល ។ ព្រះសាស្តាក្រោកចាកអាសនៈ យាង ទៅកាន់វិហារអញ្ជនវ័នវិញ ។ ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងរោងធម្មសភា សន្ទនាគ្នាថា អាវុសោទាំងឡាយ ព្រាហ្មណ៍ក៏ដឹងថា បិតារបស់ព្រះតថាគត គឺព្រះបាទសុទ្ធោទនៈ ព្រះមាតា គឺព្រះនាងមហាមាយា ទាំងដែលដឹងនោះឯង ក៏នៅតែប្រាប់ព្រះតថាគតដល់នាងព្រាហ្មណីថា បុត្តរបស់យើង សូម្បីព្រះសាស្តាក៏ទ្រង់ទទួលយកសេចក្ដីនេះ តើព្រោះហេតុអ្វីហ្ន៎ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ទាំង ២ ហៅកូនរបស់ខ្លួននោះឯងថា បុត្ត ហើយទ្រង់នាំអតីតនិទានមកថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នេះ ក្នុងអតីតកាល បានជាបិតារបស់តថាគត ៥០០ ជាតិ ជាឪពុកមារបស់តថាគត ៥០០ជាតិ ជាជីតារបស់តថាគត ៥០០ ជាតិ ជាប់តគ្នាមិនដាច់ សូម្បីព្រាហ្មណី ក៏បានជាមាតារបស់តថាគត ៥០០ ជាតិ ជាម្តាយមីង ៥០០ ជាតិ ជាជីដូន ៥០០ ជាតិ ជាប់តគ្នាមិនដាច់ តថាគតចម្រើនវ័យហើយក្នុងដៃរបស់ព្រាហ្មណ៍ ១៥០០ ជាតិ ចម្រើនវ័យហើយក្នុងដៃរបស់ព្រាហ្មណី ១៥០០ ជាតិយ៉ាងនោះ ឈ្មោះថា ទ្រង់ត្រាស់ជាតិក្នុងអតីត ៣០០០ ជាតិ លុះទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទើបត្រាស់ព្រះគាថានេះថា

> ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិន
> ធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះដោយ
> ពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្មឹ មនោ និវិសតិ** សេចក្តីថា ចិត្តចុះស៊ប់ក្នុងបុគ្គលណា ដោយគ្រាន់តែឃើញគ្នាប៉ុណ្ណោះ ។

បទថា **ចិត្តញ្ចាបិ បសីទតិ** សេចក្តីថា ម្យ៉ាងទៀត ចិត្តរមែងជ្រះថ្លាទន់ភ្លន់ក្នុងបុគ្គលណា ដោយគ្រាន់តែឃើញប៉ុណ្ណោះ ។

បទថា **អទិដ្ឋបុព្វកេ ភោសេ** សេចក្តីថា ក្នុងបុគ្គលនោះ សូម្បីជាប្រប្រតីទោះជាបុគ្គលដែលមិនធ្លាប់ឃើញគ្នាសោះ ក្នុងអត្តភាពនោះ ។

បទថា **កាមំ តស្មឹបិ វិស្សសេ** អធិប្បាយថា រមែងស្និទ្ធស្នាលដោយចំណែកមួយ គឺដល់នូវការស្និទ្ធស្នាលមួយរំពេចក្នុងបុគ្គលនោះ ដោយអំណាចសេចក្តីស្រឡាញ់ដែលធ្លាប់មានក្នុងកាលមុននោះឯង ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកយ៉ាងនេះហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រាហ្មណ៍ និងព្រាហ្មណី ក្នុងកាលនោះ បានមកជាព្រាហ្មណ៍ និងព្រាហ្មណីក្នុងកាលឥឡូវនេះឯង ឯបុត្តក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា សាកេតជាតក ចប់**

# សុត្តន្តបិដក

## វិសវន្តជាតក

[ ៦៩ ] ( ពស់ពោលថា ) អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោលហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញខ្ជាក់ហើយនោះចុះ អញស្លាប់ប្រសើរជាងរស់នៅ ។

*វិសវន្តជាតកទី ៩ ចប់*

# អដ្ឋកថា

## វិសវន្តជាតក

[ ៦៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្ម-សេនាបតី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ធិរត្ថុ តំ វិសំ វន្តំ** ដូច្នេះជាដើម ។

បានឮថា ក្នុងគ្រាដែលព្រះសារីបុត្តត្រេទំពារបស់ទំពា ដែលធ្វើដោយម្សៅ ពួកមនុស្សនាំគ្នាធ្វើរបស់ទំពាដែលធ្វើដោយម្សៅជាច្រើន មកកាន់វិហារ ដើម្បីព្រះសង្ឃ របស់ដែលសល់អំពីភិក្ខុសង្ឃមានច្រើន ពួកមនុស្សនាំគ្នាពោលថា លោកម្ចាស់ទាំងឡាយ សូមទទួលដើម្បីភិក្ខុដែលទៅក្នុងស្រុកផងចុះ ។ ខណៈនោះ ភិក្ខុកំលោះដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ ចូលទៅក្នុងស្រុក ពួកភិក្ខុទទួលចំណែករបស់លោក កាលលោកមិនទាន់មក ឃើញថា ជិតហួសពេល ក៏ប្រគេនដល់ព្រះថេរៈ ។ កាលលោកឆាន់ហើយ ភិក្ខុកំលោះក៏មកដល់ ។ កាលនោះ ព្រះថេរៈពោលនឹងភិក្ខុនោះថា អាវុសោ ខ្ញុំឆាន់ខាទនីយដើម្បីលោកអស់ហើយ ។ ភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ ធម្មតារបស់ឆ្ងាញ់ អ្នកណាមិនឃ្លាន ។ សេចក្តីសង្វេគកើតឡើងដល់ ព្រះមហាថេរៈ លោកអធិដ្ឋានថា តាំងអំពីថ្ងៃនេះទៅ អាត្មាអញនឹងមិនឆាន់ខាទនីយដែលធ្វើដោយម្សៅ ។ បានឮថា តាំងអំពីកាលនោះមក ព្រះសារីបុត្តមិនធ្លាប់ឆាន់របស់ទំពាដែលធ្វើដោយម្សៅឡើយ ។ ការដែលលោកមិនឆាន់របស់ទំពាដែលធ្វើដោយម្សៅ ល្បីទូទៅដល់ពួកភិក្ខុ ។ ភិក្ខុទាំងឡាយអង្គុយក្នុងធម្មសភា និយាយដល់រឿងនោះ ។ កាលនោះ ព្រះសាស្តាយាងមកត្រាស់

សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្នឹ៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្ត ទោះបីត្រូវអស់ជីវិត ក៏មិនព្រមទទួលវត្ថុដែលខ្លួនបោះបង់ម្តងទៀតឡើយ ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលគ្រូព្យាបាលពិសពស់ ចិញ្ចឹមជីវិតដោយវេជ្ជកម្ម សម័យនោះ ពស់ចឹកអ្នកជនបទម្នាក់ ពួកញាតិរបស់បុគ្គលនោះ មិនប្រមាទ នាំមករកគ្រូដោយរហ័ស គ្រូសួរថា តើបំពកថ្នាំបណ្តេញពិសមុន ឬហៅពស់ដែលចឹកមក ហើយឲ្យពស់នោះ ស្រូបយកពិសចេញអំពីទីដែលវាចឹក ។ ពួកញាតិនាំគ្នាពោលថា សូមហៅពស់មក ឲ្យពស់នោះបឺតពិសចេញចុះ ទើបគ្រូហៅពស់មកហើយ ពោលថា ឯងចឹកមនុស្សនេះឬពស់ឆ្លើយថា ពិតហើយ ខ្ញុំចឹក ។ គ្រូពស់ពោលថា ចូរអ្នកយកមាត់បឺតពិសអំពីមុខរបួសដែលអ្នកចឹកហើយ ពស់ពោលថា ខ្ញុំមិនធ្លាប់បឺតនូវពិសដែលខ្ញុំខ្ជាក់ចោលហើយម្តងណាឡើយ ខ្ញុំមិនបឺតពិសដែលខ្ញុំខ្ជាក់ហើយទេ ។ គ្រូពស់ឲ្យបង្កាត់ភ្លើង ហើយពោលថា បើឯងមិនបឺតនូវពិសរបស់ឯង ចូលទៅកាន់គំនរភ្លើងនេះចុះ ពស់ឆ្លើយថា ខ្ញុំសុខចិត្តចូលគំនរភ្លើង តែមិនព្រមបឺតពិសដែលខ្លួនខ្ជាក់ចោលទៅហើយជាដាច់ខាត ហើយពោលគាថានេះថា

អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោលហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញខ្ជាក់ហើយនោះចុះ អញស្លាប់ប្រសើរជាងរស់នៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធិរត្ថុ** ជានិបាត ចុះក្នុងអត្ថថា តិះដៀល ។ បទថា **តំ វិសំ** សេចក្តីថា ពិសដែលខ្ញុំខ្ជាក់ចោលហើយ នឹងត្រូវបឺតវិញ ព្រោះហេតុនៃជីវិតនោះ គួរតិះដៀលពន់ពេក ។

បទថា **មតំ មេ ជីវិតា វរំ** សេចក្តីថា ការចូលទៅកាន់គំនរភ្លើងហើយស្លាប់នោះ ប្រសើរជាងការរស់នៅរបស់ខ្ញុំ ព្រោះការស្រូបពិសនោះ ។

កាលពស់ពោលយ៉ាងនេះហើយ ក៏លូនចូលទៅកាន់គំនរភ្លើង គ្រានោះទើបគ្រូឃាត់ពស់នោះ ព្យាបាលបុរសនោះឲ្យជាសះស្បើយ ដោយឱសថ និងមន្ត ហើយឲ្យសីលដល់ពស់ពោលថា ចាប់តាំងអំពីនេះទៅ ចូរអ្នកកុំបៀតបៀនបុគ្គលណា ដូច្នេះហើយ លែងទៅ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្ត សុខចិត្តលះជីវិត មិនព្រមទទួលរបស់ដែលខ្លួនបោះបង់ចោលហើយ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ពស់ក្នុងកាលនោះបានមកជាសារីបុត្ត ក្នុងកាលឥឡូវនេះ ឯគ្រូពស់ គឺតថាគតនេះឯង ។

**អដ្ឋកថា វិសវន្តជាតក ចប់**

# សុត្តន្តបិដក

## កុក្កាលជាតក

[ ៧០ ] ( កុទ្ទាលកបណ្ឌិតពោធិសត្វ ពោលថា ) សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃមែនពិត ។

កុទ្ទាលជាតកទី ១០ ចប់

ឥត្ថីវគ្គទី ៧ ចប់

### ឧទ្ទាននៃឥត្ថីវគ្គនោះ គឺ

និយាយអំពីភ្លើងឆេះវត្ថុគ្រប់យ៉ាង ( ក្នុងអសាតមន្តជាតក ) ១ ពិណដ៏ប្រសើរ ( ក្នុងអណ្ឌភូតជាតក ) ១ ស្ត្រីជាអ្នកញុះញង់នឹងបំបែកបំបាក់មិត្ត ( ក្នុងតក្កជាតក ) ១ ការត្រេកអរ ( ក្នុងទុរាជានជាតក ) ១ ស្បថ ( ក្នុងអនភិរតិជាតក ) ១ នាងមុទុលក្ខណា ( ក្នុងមុទុលក្ខណជាតក ) ១ បងប្អូន ( ក្នុងឧច្ឆង្គជាតក ) ១ ចិត្ត ( ក្នុងសាកេតជាតក ) ១ ពិស ( ក្នុងវិសវន្តជាតក ) ១ សេចក្តីឈ្នះប្រពៃ ( ក្នុងកុទ្ទាលជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## កុទ្ទាលជាតក

[ ៧០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចិត្តហត្ថសារីបុត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន តំ ជិតំ សាធុ** ដូច្នេះជាដើម ។

បានឮថា ចិត្តហត្ថសារីបុត្ត ជាកុមារកើតក្នុងត្រកូលមួយ ក្នុងនគរសាវត្ថី ថ្ងៃមួយ ភ្ជួរស្រែហើយ គាត់ត្រឡប់ចូលទៅកាន់វិហារ បានភោជនប្រណីតមានរសឆ្ងាញ់អំពីបាត្រព្រះថេរៈមួយអង្គ គិតថា សូម្បីអញធ្វើការងារផ្សេងៗដោយដៃរបស់ខ្លួន អស់យប់ និងថ្ងៃ ក៏មិនបានអាហារឆ្ងាញ់បែបនេះ អញក៏គួរជាសមណៈ ដូច្នេះ ។ គាត់បួសហើយ បានប្រមាណកន្លះខែ កាលមិនដាក់ចិត្តដោយឧបាយ ធ្លាក់ទៅក្នុងអំណាចកិលេស សឹកទៅ លុះលំបាកដោយអាហារ ក៏មកបួសទៀត រៀនព្រះអភិធម្មដោយឧបាយនេះ សឹកហើយ បួសអស់ ៦ ដង ក្នុងគ្រាទី ៧ ជាអ្នកទ្រទ្រង់ព្រះអភិធម្ម ៧ គម្ពីរ បង្រៀនធម៌ដល់ភិក្ខុជាច្រើន បំពេញវិបស្សនាបានសម្រេចអរហត្តហើយ ។ កាលនោះភិក្ខុដែលជាសម្លាញ់របស់លោក នាំគ្នាបន្អាប់ថា អាវុសោចិត្តហត្ថ ឥឡូវនេះ កិលេសទាំងឡាយរបស់អ្នក មិនចម្រើនដូចកាលមុនទេឬ លោកឆ្លើយថា អាវុសោ តាំងអំពីនេះទៅ ខ្ញុំមិនសមគួរធ្វើជាគ្រហស្ថឡើយ ។ លុះលោកសម្រេចអរហត្តយ៉ាងនេះហើយ មានពាក្យចោទកើតឡើងក្នុងធម្មសភាថា អាវុសោទាំងឡាយ ឧបនិស្ស័យនៃអរហត្តបែបនេះមាន ព្រះចិត្តហត្ថសារីបុត្តត្រូវសឹកដល់ ៦ ដង ឱ ! ភាពជាបុថុជ្ជន មានទោសច្រើនដូច្នេះ ព្រះសាស្តា

យាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ចិត្តរបស់បុថុជ្ជនស្រាល សង្កត់សង្កិនបានដោយលំបាក តែងធ្លាក់ទៅ ជាប់ដោយអំណាចនៃអារម្មណ៍ លុះជាប់មួងហើយ ក៏មិនអាចដោះបានដោយរហ័ស ការទូន្មានចិត្តបែបនេះ ជាការល្អ ចិត្តដែលទូន្មានល្អហើយប៉ុណ្ណោះ នាំមកនូវសេចក្តីសុខ ហើយត្រាស់ព្រះគាថា ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

ហើយត្រាស់បន្តថា ព្រោះចិត្តនោះសង្កត់សង្កិនបានដោយលំបាក បណ្ឌិតទាំងឡាយ ក្នុងកាលមុន អាស្រ័យចបរលីមួយ មិនអាចបោលបាន ត្រូវសឹក អស់ ៦ ដង ដោយអំណាចសេចក្តីលោភ ក្នុងភេទបព្វជិត លុះគ្រាទី ៧ ធ្វើឈានឲ្យកើតឡើង ទើបសង្កត់សង្កិននូវសេចក្តីលោភនោះបាន ដូច្នេះហើយ ទ្រង់នាំរឿងពីអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកដាំបន្លែ ដល់នូវភាពជាអ្នកដឹង

ក្តីហើយ បានឈ្មោះថា កុទ្ទាលបណ្ឌិត ។ កុទ្ទាលបណ្ឌិតកាប់ដីដោយចប ព្រោះពូជដាំបន្លែ មានឃ្លោក ត្រឡាច ល្ពៅជាដើម បេះបន្លែទាំងនោះលក់ ចិញ្ចឹមជីវិតដោយលំបាក ។ ពិតហើយ កុទ្ទាលបណ្ឌិត ក្រៅអំពីចបមួយ ប៉ុណ្ណោះ ទ្រព្យសម្បត្តិដទៃមិនមានឡើយ ។ ថ្ងៃមួយ លោកត្រិះរិះថា នឹង មានប្រយោជន៍អ្វី ដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួស ដូច្នេះ ។ ថ្ងៃមួយ លោកលាក់ចបនោះក្នុងទីកំបាំងហើយ បួសជាឥសី ។ កាលនោះ នឹកដល់ ចបនោះហើយ មិនអាចកាត់បង់នូវសេចក្តីលោភបាន ក៏សឹក ព្រោះអាស្រ័យ ចបរិលនោះ ។ សូម្បីលើកទី ២-៣ ក៏យ៉ាងនោះ លាក់ចបនោះក្នុងទីកំបាំង បួសសឹកៗ អស់ ៦ ដង ក្នុងគ្រាទី ៧ គិតថា អញអាស្រ័យចប់គឺរិលនេះ ត្រូវសឹកអស់ច្រើនដង ពេលនេះ អញនឹងគ្រវាត់វាចោលក្នុងស្ទឹងធំ ហើយ បួស ដូច្នេះហើយ ដើរទៅកាន់ច្រាំងស្ទឹង គិតថា បើអញនៅឃើញទីដែល ចបធ្លាក់ នឹងត្រូវស្រវារកវាឡើងមកទៀត ហើយចាប់ចបត្រង់ដងគ្រវីលើ ក្បាល ៣ ជុំ ដោយកម្លាំងដូចដំរីសា សម្បូរដោយថាមពល បិទភ្នែក គ្រវាត់ ទៅត្រង់កណ្តាលស្ទឹង ហើយបន្លឺសំឡេងកងរំពងថា ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះ ហើយ ។

ក្នុងខណៈនោះ ព្រះបាទពារាណសីទ្រង់បង្ក្រាបបច្ចន្តជនបទរាបទាបហើយ ត្រឡប់មក ទ្រង់លាបស្រឡាបសីសៈត្រង់ស្ទឹងនោះ ប្រដាប់ព្រះកាយដោយ គ្រឿងអលង្ការគ្រប់យ៉ាង យាងទៅដោយដំរី ទ្រង់ស្តាប់ព្រះពោធិសត្វនោះ ទ្រង់សង្ស័យថា បុរសនេះពោលថា ខ្ញុំឈ្នះហើយ អ្នកណាដែលគេឈ្នះ ចូរ

ហៅបុរសនោះមក ហើយមានព្រះតម្រាស់ឲ្យហៅមកគាល់ ត្រាស់សួរថា នៃបុរស យើងកំពុងឈ្នះសង្គ្រាម នាំនូវជ័យជម្នះមក ឯអ្នកឈ្នះអ្វីដែរ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទោះបីទ្រង់ឈ្នះសង្គ្រាមរាប់រយជង រាប់ពាន់ជង ឬរាប់សែនជង ក៏មិនទាន់ឈ្មោះថា ឈ្នះជាសមុច្ចេទឡើយ ព្រោះមិនទាន់ឈ្នះកិលេសទាំងឡាយ តែទូលបង្គំរមែងឈ្នះកិលេសខាងក្នុងបាន យកឈ្នះកិលេសទាំងឡាយបាន ក្រាបទូលបណ្ដើរ សម្លឹងមើលទឹកបណ្ដើរ ញុំាងឈាន មានអាបោកសិណជាអារម្មណ៍ឲ្យកើតឡើងហើយ អង្គុយក្នុងអាកាសដោយអំណាចនៃឈាន និងសមាបត្តិ កាលសម្ដែងធម៌ថ្វាយព្រះរាជា ទើបពោលគាថានេះថា

> សេចក្ដីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្ដីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្ដីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្ដីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃ មែនពិតដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជីយតិ** សេចក្ដីថា ការបង្ក្រាបបច្ចាមិត្រឲ្យរាបទាប ឈ្នះនូវដែន យកមកបាន បច្ចាមិត្រទាំងនោះ គង់វាយបកត្រឡប់វិញបាន ការឈ្នះនោះ មិនឈ្មោះថា ឈ្នះរបូតឡើយ ព្រោះហេតុអ្វី ព្រោះត្រូវដណ្ដើមគ្នាទៅមករឿយៗ ។ម្យ៉ាងទៀត **ជយ** ហៅបានថា ការឈ្នះ **ជយ** ដែលបានព្រោះការច្បាំងជាមួយបច្ចាមិត្រក្នុងកាលតមក បច្ចាមិត្រយកឈ្នះបាន ក៏ត្រឡប់ជាបរាជ័យ **ជយ** នោះ មិន

ប្រសើរ ព្រោះហេតុអ្វី ព្រោះត្រឡប់ជាបរាជ័យបានវិញ ។ បទថា **តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតិ** សេចក្ដីថា ឯការគ្របសង្កត់បច្ចាមិត្របាន ហើយឈ្នះ បច្ចាមិត្រទាំងនោះ ត្រឡប់ជាដណ្ដើមជ័យជម្នះមិនបានវិញ ការបានជ័យជម្នះម្ដងហើយ មិនត្រឡប់បរាជ័យបាន ជ័យជម្នះនោះ ជាការឈ្នះជាសមុច្ឆេទ ជម្នះនោះ ឈ្មោះថា ជាជម្នះល្អ ព្រោះហេតុអ្វី ព្រោះមិនចាំបាច់ដណ្ដើមគ្នាឈ្នះទៀត ។ បពិត្រមហារាជ ព្រោះហេតុនោះ សូម្បីទ្រង់ឈ្នះសង្គ្រាមរាប់ពាន់ដង រាប់សែនដង ក៏នឹងត្រូវថ្វាយព្រះនាមថា ជាកំពូលទ័ពមិនបានឡើយ ព្រោះហេតុអ្វី ព្រោះទ្រង់មិនទាន់ឈ្នះកិលេសរបស់ទ្រង់បានទេ ឯបុគ្គលណាឈ្នះកិលេសរបស់ខ្លួនបានត្រឹមតែម្ដង បុគ្គលនោះ ចាត់ជាអ្នកចម្បាំងដ៏អង់អាចបាន ។ ព្រះពោធិសត្វ អង្គុយនៅក្នុងអាកាសនោះឯង សម្ដែងធម៌ថ្វាយព្រះរាជា ដោយព្រះពុទ្ធលីលា ក្នុងភាពជាអ្នកចម្បាំងដ៏ឧត្ដម មានព្រះសូត្រ ( ខុទ្ទកនិកាយ ធម្មបទ ) ជាសាធកៈដូចតទៅ

> អ្នកណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាមអស់ ១ ពាន់ៗ ដង
> គឺ ១ លាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ
> ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ
> ដូច្នេះ ។

កាលព្រះរាជា ទ្រង់ស្ដាប់ធម៌នោះឯង ទ្រង់លះកិលេសដោយអំណាចតទង្គប្បហាន ព្រះហឫទ័យបង្អោនទៅក្នុងបព្វជ្ជា ។ សូម្បីពួកយោធារបស់ព្រះអង្គ ក៏នាំគ្នាលះកិលេសបានដូច្នោះដូចគ្នា ។ ព្រះរាជាត្រាស់សួរព្រះ

ពោធិសត្វថា ឥឡូវនេះ លោកម្ចាស់នឹងទៅទីណា ព្រះពោធិសត្វក្រាបទូល ថា បពិត្រមហារាជ អាត្មានឹងទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ។ ព្រះរាជា ត្រាស់ថា បើដូច្នោះ ខ្ញុំក៏នឹងបួស ហើយយាងទៅជាមួយព្រះពោធិសត្វ ។ ពលនិកាយទាំងអស់ គឺព្រាហ្មណ៍គហបតី និងទាហាន ប្រជុំគ្នាក្នុងខណៈ នោះ ជាមហាសមាគម ចេញបួសជាមួយព្រះរាជាដូចគ្នា ។ អ្នកក្រុង ពារាណសី បានឮថា ព្រះរាជារបស់យើងទាំងឡាយ ទ្រង់ស្តាប់ធម្មទេសនា របស់កុទ្ទាលបណ្ឌិតហើយ ទ្រង់បែរព្រះភក្ត្រឆ្ពោះបព្វជ្ជា ទ្រង់យាងសាងព្រះ ផ្នួស មួយអន្លើដោយពួកពលនិកាយ ពួកយើងនឹងធ្វើអ្វីក្នុងក្រុងនេះ ដូច្នេះ ហើយ បណ្តាអ្នកនគរទាំងនោះ ក៏នាំគ្នាចេញអំពីក្រុងពារាណសី មានបរិ- មណ្ឌល ១២ យោជន៍ ។ បរិស័ទមានបរិមណ្ឌល ១២ ហើយ ។ ព្រះ ពោធិសត្វនាំបរិស័ទនោះចូលព្រៃហិមពាន្ត ។ ក្នុងខណៈនោះ អាសនៈរបស់ សក្កទេវរាជសម្តែងអាការក្តៅ ។ ទេវរាជទតឃើញថា កុទ្ទាលបណ្ឌិត ចេញមហាភិនេស្រ្កមណ៍ ហើយទ្រង់ត្រិះរិះថា នឹងជាមហាសមាគម គួរ បានទីលំនៅ ហើយត្រាស់ហៅវិស្សុកម្មទេវបុត្រមក ត្រាស់ថា នែបាវិស្សុកម្ម កុទ្ទាលបណ្ឌិតកំពុងចេញមហាភិនេស្រ្កមណ៍ លោកគួរបានទីលំនៅ ចូរអ្នក ទៅហិមវន្តប្បទេស និម្មិតអាស្រមបទបណ្តោយ ៣០ យោជន៍ ទទឹង ១៥ យោជន៍ ក្នុងទីដែលរាបស្មើ ។ វិស្សុកម្មទេវបុត្រទទួលទេវបញ្ជាថា បពិត្រ ព្រះអង្គ ខ្ញុំនឹងធ្វើឲ្យសម្រេច ហើយទៅ ។ នេះជាសេចក្តីសង្ខេបក្នុងអធិការ នេះ ឯសេចក្តីពិស្តារ នឹងប្រាកដក្នុងហត្ថិបាលជាតក ពិតហើយ រឿងនេះ

និងរឿងនោះ ជាបរិច្ឆេទតែមួយនោះឯង ។

ឯវិស្សកម្មទេវបុត្រ និម្មិតបណ្ណសាលាក្នុងអាស្រមបទហើយ ក៏ដេញម្រឹគ បក្សី និងអមនុស្សដែលមានសំឡេងគួរខ្លាចចេញ ហើយនិម្មិតផ្លូវដើរតូចៗ តាមទិសាភាគនោះៗ ស្រេចហើយ ត្រឡប់ទៅកាន់វិមានដែលជាលំនៅរបស់ខ្លួន ។

ចំណែកកុទ្ទាលបណ្ឌិតនាំបរិស័ទចូលកាន់ព្រៃហិមពាន្ត លុះដល់អាស្រមបទ ដែលសក្កៈទ្រង់ប្រទាន កាន់យកគ្រឿងបរិក្ខារនៃបព្វជិត ដែលវិស្សកម្មទេវបុត្រនិម្មិតទុកឲ្យ បួសខ្លួនឯងមុន ឲ្យបរិស័ទបួសឯក្រោយ រៀបចំចែកអាស្រមបទតាមសមគួរ ។ មានព្រះរាជា ៧ អង្គ លះរាជសម្បត្តិ ៧ នគរ មកបួសដែរ អាស្រមបទ ៣០ យោជន៍ ពេញបរិបូណ៌ ។ កុទ្ទាលបណ្ឌិតធ្វើបរិកម្មក្នុងកសិណដ៏សេស ចម្រើនព្រហ្មវិហារធម៌ ប្រាប់កម្មដ្ឋានដល់បរិ-ស័ទ ។ បរិស័ទទាំងពួង សុទ្ធតែបាននូវសម្បត្តិ ចម្រើនព្រហ្មវិហារហើយទៅកើតក្នុងព្រហ្មលោកទាំងអស់ ។ ឯមហាជនដែលទំនុកបម្រុងតាបសនោះក៏បានទៅកាន់ទេវលោក ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ចិត្តនេះ គិតដោយអំណាចនៃកិលេសហើយ ជាធម្មជាតដោះបានលំបាក លាភធម៌ទាំង

ឡាយដែលកើតហើយ ជាសភាវៈលះបានលំបាក រមែងធ្វើបណ្ឌិតដែលមានសភាពបែបនេះ ឲ្យក្លាយជាបុគ្គលមិនមានប្រាជ្ញាទៅបាន ដោយប្រការដូច្នេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ លុះចប់សច្ចៈ ភិក្ខុពួកខ្លះ បានជាព្រះសោតាបន្ន ពួកខ្លះ បានជាព្រះសកទាគាមី ពួកខ្លះ បានជាព្រះអនាគាមី ពួកខ្លះ សម្រេចអរហត្ត ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនោះ បរិស័ទក្នុងកាលនោះ បានមកជាបរិស័ទ ក្នុងកាលឥឡូវនេះ ឯកុទ្ទាលបណ្ឌិត គឺតថាគតនេះឯង ។៚

**អដ្ឋកថាកុទ្ទាលជាតក ចប់**

**ឥត្ថីវគ្គ ចប់**

# សុត្តន្តបិដក

# វរុណវគ្គ

## វរុណជាតក

[ ៧១ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) អំពើទាំងឡាយដែលត្រូវធ្វើក្នុងកាលមុន នរៈណាប្រាថ្នាធ្វើខាងក្រោយវិញ នរៈនោះ រមែងក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ ដូចជាមាណពដែលកាច់ឧសឈើថ្ងាន់ ។

វរុណជាតកទី ១ ចប់

# អដ្ឋកថា

# វរុណវគ្គ

## វរុណជាតក

[ ៧១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សៈ កូនកុដុម្ពិកៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ បុព្វេ ករណីយានិ** ដូច្នេះជាដើម ។

បានឮថា ក្នុងថ្ងៃមួយ កុលបុត្តអ្នកក្រុងសាវត្ថីជាសម្លាញ់នឹងគ្នាប្រមាណ ៣០ នាក់ កាន់គ្រឿងក្រអូប ផ្កា និងសំពត់ជាដើម គិតគ្នាថា ពួកយើងនឹងស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា កាលមហាជនចោមរោម នាំគ្នាទៅកាន់វិហារជេតពន អង្គុយសម្រាកក្នុងរោងឈ្មោះនាគមាឡកៈ និងវិសាលមាឡកៈជាដើម ។ លុះវេលាល្ងាច កាលព្រះសាស្តាយាង ចេញអំពីព្រះគន្ធកុដិដែលអប់ហើយដោយក្លិនក្រអូប យាងទៅកាន់ធម្មសភា គង់លើពុទ្ធាសនៈដែលតាក់តែងហើយ ទើបនាំគ្នាទៅកាន់ធម្មសភា មួយអន្លើដោយបរិវារ បូជាព្រះសាស្តាដោយគ្រឿងក្រអូប និងផ្កា ថ្វាយបង្គំទៀបបាទមូលដែលប្រដាប់ដោយចក្រ ទ្រទ្រង់នូវព្រះសិរី ដូចផ្កាឈូករីក ហើយអង្គុយស្តាប់ព្រះធម៌ទាចំណែកម្ខាង ។ ជនទាំងនោះ នាំគ្នាបរិវិតក្កថា យើងទាំងឡាយត្រូវបួស សូម្បីដឹងទូទៅដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ បានទូលំទូលាយ ក្នុងពេលដែលព្រះតថាគត ទ្រង់ចេញអំពីធម្មសភា ពួកកុលបុត្តទាំងនោះនាំគ្នាចូលទៅគាល់ថ្វាយបង្គំព្រះសាស្តាហើយ ទូលសូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់ប្រទាន

បព្វជ្ជាដល់ជនទាំងនោះ ។ ពួកជនទាំងនោះធ្វើឲ្យអាចារ្យ និងឧបជ្ឈាយ៍ស្រឡាញ់ហើយ បានឧបសម្បទានៅក្នុងសម្នាក់របស់អាចារ្យ និងឧបជ្ឈាយ៍ ៥ វស្សា ទន្ទេញមាតិកាទាំង ២ ស្ទាត់ជំនាញ ហើយដឹងរបស់ដែលជាកប្បិយ និងអកប្បិយ រៀនអនុមោទនា ៣ ជ្រលក់ចីវរហើយ ថ្វាយបង្គំលាអាចារ្យ និងឧបជ្ឈាយ៍ថា ពួកខ្ញុំនឹងបំពេញសមណធម៌ ហើយនាំគ្នាចូលគាល់ព្រះសាស្តា ថ្វាយបង្គំ រួចអង្គុយក្នុងទីដ៏សមគួរនាចំណែកម្ខាង ទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គខ្មីមរអើមក្នុងភពទាំងឡាយ ខ្លាចចំពោះការកើត ការចាស់ ការឈឺ និងការស្លាប់ សូមទ្រង់ត្រាស់ប្រាប់កម្មដ្ឋាន ដើម្បីដោះខ្លួនចាកសង្សារទុក្ខដល់ខ្ញុំព្រះអង្គទាំងឡាយផង ។ ព្រះសាស្តាទ្រង់ជ្រាបសប្បាយ ទើបត្រាស់ប្រាប់កម្មដ្ឋានមួយ ក្នុងបណ្តាកម្មដ្ឋាន ៣៨ ប្រការដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណ ទៅកាន់បរិវេណ លាអាចារ្យ និងឧបជ្ឈាយ៍ កាន់បាត្រ និងចីវរ ចេញអំពីវិហារទៅ ដោយតាំងចិត្តថា ពួកយើងនឹងបំពេញសមណធម៌ ។

កាលនោះ ក្នុងរវាងភិក្ខុទាំងនោះ មានភិក្ខុមួយរូប ឈ្មោះកុដុម្ពិកបុត្តតិស្សត្ថេរ ជាអ្នកខ្ជិលច្រអូស មានសេចក្តីព្យាយាមថោកថយ ជាប់ក្នុងរសអាហារ លោកគិតយ៉ាងនេះថា អញមិនអាចទៅនៅក្នុងព្រៃ មិនអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការត្រាច់បិណ្ឌបាត ការទៅព្រៃមិនជាប្រយោជន៍ដល់អញឡើយ អញនឹងត្រឡប់ លោកលះបង់សេចក្តីព្យាយាម ហើយដើរ

តាមភិក្ខុទាំងនោះបានបន្តិច រួចក៏ត្រឡប់ ឯភិក្ខុទាំងនោះ នាំគ្នាចារិកទៅក្នុងដែនកោសល ដល់ស្រុកជាយដែនមួយ ក៏ចូលអាស្រ័យស្រុកនោះ ចាំវស្សាត្រង់ជាយព្រៃមួយកន្លែង ជាអ្នកមិនប្រមាទ ព្យាយាម ខាងក្នុងត្រៃមាស កាន់យកបន្ទប់វិបស្សនា ញ៉ាំងប្រីថពីឲ្យញាប់ញ័រ សម្រេចអរហត្តហើយ ។ លុះចេញវស្សា បវារណាហើយ ប្រឹក្សាគ្នាថា នឹងក្រាបទូលគុណដែលខ្លួនបានសម្រេចហើយដល់ព្រះសាស្តា ទើបនាំគ្នាចេញអំពីបច្ចន្តគ្រាម ដល់ជេតពនមហាវិហារដោយលំដាប់ ទុកបាត្រ និងចីវរស្រេចបាច់ហើយ ក៏ចូលជួបអាចារ្យនិងព្រះឧបជ្ឈាយ៍ ប្រាថ្នានឹងគាល់ព្រះតថាគត នាំគ្នាទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយគាល់ ។ ព្រះសាស្តាទ្រង់បានធ្វើបដិសណ្ឋារៈដោយព្រះតម្រាស់ដ៏ពីរោះជាមួយនឹងភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ បានទទួលបដិសណ្ឋារៈហើយ ទើបក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះតថាគត ព្រះសាស្តាទ្រង់សរសើរភិក្ខុទាំងនោះ កុដុម្ពិកបុត្តតិស្សត្ថេរឃើញព្រះសាស្តាត្រាស់សរសើរគុណរបស់ភិក្ខុទាំងនោះ ខ្លួនឯងក៏បំណងបំពេញសមណធម៌ដែរ ឯភិក្ខុទាំងឡាយនេះក្រាបទូលលាព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនឹងទៅត្រង់ជាយព្រៃនោះ ព្រះសាស្តាទ្រង់អនុញ្ញាតហើយ ។ ពួកភិក្ខុទាំងនោះថ្វាយបង្គំព្រះសាស្តាហើយ នាំគ្នាទៅកាន់បរិវេណ ។ គ្រានោះ កុដុម្ពិកបុត្តតិស្សត្ថេរនោះបំពេញព្យាយាមតឹងតែងក្នុងរត្តិកាល បំពេញសមណធម៌ប្រញាប់ប្រញាល់ពេក លុះដល់មជ្ឈិមយាម ទាំងដែលឈរផ្អែកបន្ទះក្តារសម្រាប់ផ្អែក ក៏លក់ទៅ រមៀលចុះមក ឆ្អឹងស្មងរបស់លោកបាក់ កើតនូវ

វេទនាដ៏ខ្លាំងក្លា ។ កាលភិក្ខុទាំងនោះ ជួយបដិបត្តិលោក ការធ្វើដំណើរក៏ត្រូវផ្អាក ។ កាលនោះ ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះ ដែលនាំគ្នាមកក្នុងពេលបម្រើថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឈាតថាគតកាលពីម្សិលមិញថា ខ្ញុំព្រះអង្គនាំគ្នាទៅក្នុងថ្ងៃស្អែកមិនមែនឬ ភិក្ខុទាំងនោះក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ តែកុដុម្ពិកបុត្តតិស្សត្ថេរសម្លាញ់របស់ខ្ញុំព្រះអង្គ ធ្វើសមណធម៌ប្រញាប់ពេក ក្នុងពេលដែលមិនជាកាល ត្រូវងងុយគ្របសង្កត់ រមៀលធ្លាក់ចុះទៅ ឆ្អឹងស្មងក៏បាក់ ព្រោះលោកជាហេតុ ទើបពួកខ្ញុំព្រះអង្គ ផ្អាកការដើរផ្លូវ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះខ្នះខ្នែង ធ្វើសេចក្តីព្យាយាម មិនត្រូវកាលព្រោះខ្លួនជាបុគ្គលមានព្យាយាមធូរថយ ទើបធ្វើអន្តរាយដល់ការដើរផ្លូវរបស់ពួកអ្នក សូម្បីតែក្នុងកាលមុន ភិក្ខុនេះក៏បានធ្វើអន្តរាយដល់ការដើរផ្លូវរបស់ពួកអ្នកហើយដូចគ្នា ភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាអាចារ្យទិសាបាមោក្ខ ឲ្យមាណព ៥០០ នាក់រៀនសិប្ប: ក្នុងនគរតក្កសិលា ដែនគន្ធារ: ។ ថ្ងៃមួយ មាណពទាំងនោះ នាំគ្នាទៅព្រៃដើម្បីរកឧស ប្រមូលឧស ។ ក្នុងវាងមាណពទាំងនោះ មានមាណពខ្ជិលច្រអូសម្នាក់ ឃើញដើមថ្វាន់ធំ សម្គាល់ថា ដើមឈើនេះជាដើមឈើងាប់ គិតថា ដេកមួយសម្ទុះសិនក៏បាន ពេលក្រោយសឹមឡើងកាច់ឧសយកទៅ ទើបក្រាលសំពត់ដណ្តប់ ដេកលក់ស្រមុកទៅ ។

ឯមាណពក្រៅអំពីនេះ នាំគ្នាចងឧសជាបាច់ៗ ហើយរែកទៅ យកជើងទាត់មាណពដែលកំពុងដេកនោះឲ្យក្រោកឡើង ហើយនាំគ្នាទៅ ។ មាណពកម្ជិលក្រោកឡើងយកដៃញីភ្នែក លុះអស់ងងុយហើយ ក៏ឡើងដើមថ្ងាន់ ចាប់មែកទាយមកត្រង់មុខរបស់ខ្លួន កាលបាក់ហើយ ចុងមែកឈើក៏ផ្ទាត់ត្រង់ភ្នែករបស់ខ្លួនបែកទៅ យកដៃម្ខាងបិទភ្នែក ម្ខាងទៀតកាច់ឧសស្រស់ៗ ទម្លាក់អំពីដើម ចងជាបាច់រែកទៅដោយរហ័ស ទៅទម្លាក់លើឧសដែលពួកមាណពទាំងនោះគរនោះឯង ។ ក្នុងថ្ងៃនោះ ត្រកូលមួយក្នុងជនបទ និមន្តអាចារ្យថា ស្អែកនេះ ពួកខ្ញុំនឹងធ្វើការសូធ្យមន្តតាមវិធីកម្មរបស់ព្រាហ្មណ៍ ទើបអាចារ្យពោលនឹងពួកមាណពថា នែបាទាំងឡាយ ស្អែកនេះ ត្រូវទៅដល់តំបន់មួយ តែបើពួកអ្នកមិនបានបរិភោគអាហារជាមុន មិនអាចទៅបានទេ ត្រូវឲ្យគេដាំបបរអំពីព្រឹក ទៅទីនោះ កាន់យកចំណែកដែលខ្លួនត្រូវបានទទួល និងចំណែកដែលដល់លំដាប់យើង ហើយប្រញាប់នាំគ្នាមកចុះ ។ ពួកមាណពទាំងនោះដាស់ទាសីឲ្យក្រោកឡើងដើម្បីដាំបបរអំពីព្រលឹម បញ្ជាថា ចូរប្រញាប់ដាំបបរដល់ពួកយើងដោយរហ័ស ទាសីនោះទៅត្រកងឧស ក៏ប៉ះដើមថ្ងាន់ស្រស់ ទោះបីប្រើមាត់ផ្លុំរឿយៗ ក៏មិនអាចឲ្យឆេះបាន រហូតដល់ព្រះអាទិត្យរះ ។ ពួកមាណពឃើញថា យឺតពេកហើយឥឡូវនេះ យើងមិនអាចទៅបានទេ ទើបនាំគ្នាទៅកាន់សម្នាក់អាចារ្យៗ សួរថា នែបា ពួកបាមិនបានទៅទេឬ ពួកមាណពឆ្លើយថា បពិត្រលោកអាចារ្យ ពួកខ្ញុំមិនបានទៅទេ អាចារ្យសួរថា ព្រោះអ្វី ទើបពួកមាណពឆ្លើយថា មាណពកម្ជិលនោះទៅព្រៃដើម្បីរកឧសជា

មួយពួកខ្ញុំ ទៅដេកលក់ក្រោមដើមថ្ងាន់ ពេលក្រោយ ទើបប្រញាប់ឡើងទៅត្រូវមែកឈើផ្ទាត់ភ្នែកបែក កាច់យកមែកស្រស់ៗ មកខាងលើឧសដែលពួកខ្ញុំរកមក អ្នកដាំបបរជញ្ជូនយកឧសស្រស់នោះទៅ ដោយសម្គាល់ថាជាឧសងាប់ រហូតព្រះអាទិត្យរះឡើងក៏មិនអាចឲ្យភ្លើងឆេះបាន ដោយហេតុនេះ ទើបជាឧបសគ្គចំពោះការធ្វើដំណើរ ។ លោកអាចារ្យស្តាប់វត្តុដែលមាណពធ្វើខុស ហើយពោលថា សេចក្តីអន្តរាយបែបនេះ តែងមានព្រោះអាស្រ័យកម្មរបស់ពួកអន្ធពាល ហើយពោលគាថានេះថា

អំពើទាំងឡាយ ដែលត្រូវធ្វើក្នុងកាលមុន នរៈណា ប្រាថ្នាធ្វើខាង
ក្រោយវិញ នរៈនោះ រមែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង
ក្រោយ ដូចជាមាណពដែលកាច់ឧសឈើថ្ងាន់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ស បច្ឆា អនុតប្បតិ** សេចក្តីថា បុគ្គលណាម្នាក់ មិនពិចារណាឲ្យជាក់លាក់ថា កិច្ចនេះត្រូវធ្វើមុន កិច្ចនេះ ត្រូវធ្វើក្រោយ យកកិច្ចដែលត្រូវធ្វើមុន គឺកម្មដែលត្រូវធ្វើមុននោះឯង មកធ្វើក្នុងកាលជាក្រោយ បុគ្គលនោះ ជាពាលបុគ្គល រមែងក្តៅក្រហាយ គឺសោកសៅ កន្ទក់កន្ទេញ ក្នុងកាលជាខាងក្រោយ ដូចមាណពរបស់ពួកយើងដែលកាច់ឧសថ្ងាន់នេះ ។

ព្រះពោធិសត្វពោលហេតុនេះ ដល់ពួកអន្តេវាសិក ដោយប្រការដូច្នេះហើយ ធ្វើបុណ្យ មានទានជាដើម ក្នុងទីបំផុតនៃជីវិត ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ មិនមែនធ្វើនូវអន្តរាយដល់ការដើរផ្លូវរបស់ពួកអ្នក តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងគ្រាមុន ក៏បានធ្វើហើយដូចគ្នា ដូច្នេះ ។ ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មាណពដែលក្មេកបែកក្នុងកាលនោះ បានមកជាភិក្ខុដែលបាក់ឆ្អឹងស្មងក្នុងកាលឥឡូវនេះ មាណពដ៏សេសមកជាពុទ្ធបរិស័ទ ឯព្រាហ្មណ៍ដែលជាអាចារ្យ គឺតថាគតនេះឯង ។

**អដ្ឋកថា វរុណជាតក ចប់**

# សុត្តន្តបិដក

## សីលវីមំសនជាតក

[ ៧២ ] ( រុក្ខទេវតាពោលថា ) ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូនោះឲ្យ ត្រេកអរបានឡើយ ។

សីលវនាគជាតកទី ២ ចប់

# អដ្ឋកថា

## សីលវនាគជាតក

[ ៧២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកតញ្ញុស្ស ពោសស្ស** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្ត ជាបុគ្គលអកតញ្ញូ មិនដឹងគុណរបស់ព្រះតថាគត ព្រះមុនីយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តជាបុគ្គលអកតញ្ញូ សូម្បីក្នុងកាលមុនក៏ធ្លាប់ជាអកតញ្ញូមកហើយ មិនធ្លាប់ដឹងគុណរបស់តថាគត មិនថាក្នុងកាលណាឡើយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតដំរី ក្នុងហិមវន្តប្បទេស ប្រសូតចាកផ្ទៃមេ មានអវយវៈសសុទ្ធ មានពណ៌ដូចលាបដោយប្រាក់ ភ្នែកទាំងគូនៃដំរីនោះ ប្រាកដដូចកែវមណី មានបសាទគ្រប់ ៥ ចំណែក មាត់ដូចគ្នានឹងសំពត់កម្ពលក្រហម ប្រមោយដូចគ្នានឹងកម្រងប្រាក់ដែលរំលេចដោយមាសជើងទាំង៤ ដូចជ្រលក់ដោយទឹកល័ខ អត្តភាពដែលបារមីទាំង ១០ តាក់តែងរបស់ព្រះពោធិសត្វនោះ ដល់នូវការល្អក្រៃលែងដោយរូបយ៉ាងនោះ ។ គ្រា

នោះ ហ្វូងដំរីក្នុងព្រៃហិមពាន្តទាំងអស់ មកប្រជុំគ្នាហើយ នាំគ្នាទំនុកបម្រុង ព្រះពោធិសត្វ ដល់នូវកាលពេញវ័យហើយ ព្រះពោធិសត្វមានដំរី ៨ ម៉ឺនជាបរិវារ អាស្រ័យហិមវន្តប្បទេសរស់នៅ ដោយប្រការដូច្នេះ ។ ក្រោយមក ឃើញទោសក្នុងពួកគណៈ ទើបចេញចាកហ្វូង ទៅកាន់ទីស្ងប់ស្ងាត់កាយ នៅអាស្រ័យក្នុងដងព្រៃតែឯងប៉ុណ្ណោះ ។ ព្រោះដំរីពោធិសត្វជាសត្វមានសីល ទើបមានឈ្មោះថា សីលវនាគរាជ ប្រែថា ស្តេចដំរីជាអ្នកមានសីល ។

គ្រានោះ ព្រានព្រៃ អ្នកក្រុងពារាណសីម្នាក់ ចូលទៅកាន់ព្រៃហិមពាន្ត ស្វែងរករបស់របរដែលជាគ្រឿងចិញ្ចឹមជីវិតរបស់ខ្លួន មិនអាចកំណត់ទិសបាន វង្វេងផ្លូវ ជាអ្នកខ្លាចចំពោះមរណភ័យ ផ្គងដើមដៃទាំង ២ កន្ទក់កន្ទេញ ដើរយំទៅ ព្រះពោធិសត្វបានឮសំឡេងរបស់ព្រាននោះហើយ ដែលសេចក្តីករុណាដាស់តឿនថា អញនឹងជួយបុរសនេះឲ្យផុតចាកទុក្ខ ក៏ដើរទៅក្បែរ ព្រានឃើញព្រះពោធិសត្វហើយ ក៏គេចទៅ ។ ព្រះពោធិសត្វឃើញបុរសនោះរត់គេច ក៏ឈប់ត្រង់នោះ បុរសនោះឃើញព្រះពោធិសត្វឈប់ ក៏ឈប់ ហើយឈរ ព្រះពោធិសត្វក៏ដើរទៅជិតទៀត បុរសនោះក៏គេចទៀត ពេលព្រះពោធិសត្វឈប់ បុរសនោះក៏ឈប់ ហើយត្រិះរិះថា ដំរីនេះ ពេលអញរត់ក៏ឈប់ ដើរមករកក្នុងកាលដែលអញឈប់ ប្រហែលជាមិនមានបំណងអាក្រក់ គង់ប្រាថ្នានឹងជួយអញឲ្យផុតចាកទុក្ខដោយពិត ទើបហ៊ានឈរ ព្រះពោធិសត្វចូលទៅជិត សួរថា នែបុរស ហេតុអ្វី ទើបអ្នកដើរយំ បុរសឆ្លើយថា ខ្ញុំកំណត់ទិសមិនបាន វង្វេងផ្លូវ ទើបយំព្រោះខ្លាចស្លាប់ ។ គ្រានោះ ទើបព្រះ

ពោធិសត្វនាំទៅកាន់លំនៅរបស់ខ្លួន ឲ្យឆ្អែតដោយផ្លែឈើ ២-៣ ថ្ងៃ ហើយពោលថា កុំខ្លាចឡើយ ខ្ញុំនឹងនាំអ្នកទៅកាន់ទឹកដីមនុស្ស ហើយឲ្យអង្គុយលើខ្នង នាំទៅដល់ដែនដីមនុស្ស ។

គ្រានោះឯង ព្រានព្រៃជាមនុស្សមានសន្តានទម្លាយមិត្រ ទើបគិតមកតាមផ្លូវថា បើមាននរណាសួរ ត្រូវប្រាប់បាន ដូច្នេះ អង្គុយលើខ្នងព្រះពោធិសត្វ កំណត់ចំណាំត្រង់ដើមឈើ ត្រង់ភ្នំ គ្រប់កន្លែង ។ លុះព្រះពោធិសត្វនាំចេញទៅផុតអំពីព្រៃហើយ ឈប់ត្រង់ផ្លូវធំដែលជាផ្លូវដើរទៅកាន់នគរពារាណសី ប្រាប់ថា នែអ្នក ចូរអ្នកទៅផ្លូវនេះចុះ បើមាននរណាសួរដល់លំនៅរបស់ខ្ញុំ អ្នកកុំប្រាប់ឡើយ ដូច្នេះ បញ្ជូនបុរសនោះទៅហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។

កាលនោះ បុរសនោះទៅដល់នគរពារាណសីហើយ ក៏ទៅដល់វិថីរបស់ជាងធ្លាក់ភ្លុក ឃើញពួកជាងធ្លាក់ភ្លុកកំពុងធ្វើគ្រឿងភ្លុកច្រើនប្រភេទ ទើបសួរថា នែអ្នកទាំងឡាយ បើបានភ្លុកដំរីដែលនៅរស់ អ្នកទាំងឡាយទិញដែរឬទេ ពួកជាងធ្លាក់ភ្លុកតបថា នែអ្នក អ្នកនិយាយអ្វី ធម្មតា ភ្លុកដំរីរស់ មានតម្លៃជាងភ្លុកដំរីដែលស្លាប់ហើយច្រើនដង ។ បុរសនោះពោលថា បើដូច្នោះ ខ្ញុំនឹងនាំភ្លុកដំរីរស់មកឲ្យពួកអ្នក ហើយរៀបចំស្បៀង មានរណារដ៏មុតជាដើម ទៅកាន់លំនៅរបស់ព្រះពោធិសត្វៗ ឃើញបុរសនោះមក ទើបសួរថា អ្នកមកបំណងអ្វី បុរសនោះឆ្លើយថា នែដំរី ខ្ញុំជាមនុស្សក្រីក្រ កំព្រា មិនអាចចិញ្ចឹមជីវិតបាន មកសុំកាត់ភ្លុកអ្នក បើអ្នកឲ្យ នឹងយកភ្លុកនោះ ទៅលក់

ចិញ្ចឹមជីវិត ដោយទ្រព្យនោះ ។ ព្រះពោធិសត្វពោលថា យកចុះអ្នក ខ្ញុំនឹងឲ្យភ្លុកដល់អ្នក បើមានរណារសម្រាប់កាត់ភ្លុក បុរសនោះពោលថា នៃដំរី ខ្ញុំកាន់យករណារត្រៀមមកហើយ ។ ព្រះពោធិសត្វពោលថា បើដូច្នោះ ចូរអ្នកកាត់ភ្លុកចុះ ហើយលុតជង្គង់ ក្រាបចុះ ដូចគោក្រាប បុរសនោះក៏កាត់ភ្លុកទាំងគូរបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វ ចាប់ភ្លុកទាំងនោះដោយប្រមោយ តាំងបណិធានដើម្បីសព្វញ្ញុតញ្ញាណថា នៃបុរសដ៏ចម្រើន ខ្ញុំឲ្យភ្លុកទាំងគូនេះ ព្រោះភ្លុកនេះមិនជាទីស្រឡាញ់មិនជាទីពេញចិត្ត ក៏មិនមែនតែសព្វញ្ញុតញ្ញាណ ដែលអាចត្រាស់ដឹងធម៌ទាំងពួង ជាទីស្រឡាញ់របស់ខ្ញុំ ក្រៃលែង ជាងភ្លុកនេះរាប់រយ រាប់ពាន់ដង រាប់សែនដង ការឲ្យភ្លុកនេះជាទានរបស់ខ្ញុំ ចូរប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងនូវសព្វញ្ញុ-តញ្ញាណចុះ ហើយបរិច្ចាគភ្លុកទាំងគូទៅ ។

បុរសនោះយកភ្លុកនោះទៅលក់ កាលចាយទ្រព្យនោះអស់ ក៏ចូលទៅកាន់សម្នាក់របស់ព្រះពោធិសត្វទៀត ពោលថា នៃដំរី ទ្រព្យដែលបានព្រោះលក់ភ្លុករបស់អ្នក ត្រឹមតែជម្រះបំណុលរបស់ខ្ញុំប៉ុណ្ណោះ សូមឲ្យភ្លុកដែលសល់ដល់ខ្ញុំចុះ ។ ព្រះពោធិសត្វទទួលពាក្យ ហើយព្រមឲ្យបុរសនោះកាត់យកភ្លុកដែលសល់ដោយន័យដូចគ្នាក្នុងកាលមុន ។ បុរសនោះលក់ភ្លុកនោះហើយ ក៏ត្រឡប់មកទៀត ពោលសូមថា នៃដំរី ខ្ញុំមិនអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានទេ សូមឲ្យគល់ភ្លុកដល់ខ្ញុំចុះ ។ ព្រះពោធិសត្វទទួលពាក្យ ហើយក៏ក្រាបចុះដោយន័យមុន ។ មនុស្សចិត្តបាបនោះ ក៏ជាន់ភ្លុកដែលប្រៀប

ដូចកម្រងប្រាក់របស់មហាសត្វ ឈានឡើងកាន់ពោងដែលប្រៀបដូចកំពូលភ្នំកៃលាស យកពន្លាកជាប់ក្អកទាំង ២ ជ្រៀកសាច់ត្រង់គល់ក្អកឡើងមកកាន់ពោង យកវណារកាត់ក្អក ហើយចៀសចេញទៅ ។ ក្នុងកាលមនុស្សចិត្តបាបនោះ ចេញផុតគន្លងចក្ខុរបស់ព្រះពោធិសត្វប៉ុណ្ណោះ ផែនដីកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ដែលអាចទ្រទ្រង់នូវរបស់ធ្ងន់ មានភ្នំសិនេរុ និងភ្នំយុគន្ធរជាដើម និងទ្រទ្រង់នូវវត្ថុដែលគួរខ្ពើម មានក្លិនស្អុយ មានលាមក និងមូត្រជាដើម តែមិនអាចទ្រទ្រង់បាននូវគំនរនៃទោស មិនមែនគុណរបស់បុរសនោះទើបញែកឲ្យឱកាសក្នុងរំពេចនោះឯង អណ្ដាតភ្លើងមកអំពីអវីចិមហានរក លេបត្របាក់បុរសទ្រុស្តមិត្រនោះ ដូចដណ្ដប់ដោយសំពត់កម្ពលក្រហម ដែលជារបស់ត្រកូលប្រគល់ឲ្យ ។ ក្នុងកាលមនុស្សចិត្តបាបចូលទៅកាន់ផែនដីយ៉ាងនេះហើយ រុក្ខទេវតាដែលអាស្រ័យនៅត្រង់ដងព្រៃនោះ កំណត់ហេតុថា ទោះឲ្យចក្រពត្តិរាជសម្បត្តិ ក៏មិនអាចឲ្យបុរសអកតញ្ញូ ដែលជាអ្នកទម្លាយមិត្រគ្រប់គ្រាន់បាន កាលសម្ដែងធម៌ឲ្យលាន់ឮទៅក្នុងព្រៃ ទើបពោលគាថានេះថា

ប្រសិនបើគេឲ្យផែនដីទាំងមូល ដល់បុរសអកតញ្ញូ ជាអ្នកឃើញ
ទោសជានិច្ច ក៏មិនគប្បីញ៉ាំងបុរសអកតញ្ញូនោះ ឲ្យត្រេកអរបាន
ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អកតញ្ញុស្ស** សេចក្ដីថា ដល់បុគ្គលដែលមិនដឹងគុណ ដែលបុគ្គលដទៃធ្វើដល់ខ្លួន ។

បទថា **ពោសស្ស** ប្រែថា ដល់បុរស ។

បទថា **វិវរេសិ្សនោ** សេចក្តីថា ជាអ្នកសម្លឹងរកឱកាស គឺឱកាសរឿយៗ ទៅ ។

បទថា **សព្វញ្ចេ បឋវឹ ទជ្ជា** សេចក្តីថា បើនឹងឲ្យចក្រពត្តិរាជសម្បត្តិទាំងអស់ ឬម្យ៉ាងទៀត ទោះបីប្រែផែនដីធំនេះ យកក្រម៉ាផែនដីឲ្យដល់បុគ្គលបែបនោះ ។

បទថា **នេវ នំ អភិរាធយេ** សេចក្តីថា បុគ្គលណាម្នាក់ ទោះបីធ្វើយ៉ាងនេះបាន ក៏គង់មិនអាចញុំាងបុគ្គលអកតញ្ញូ ដូចបុគ្គលដែលប្រាកដ ដែលទម្លាយនូវគុណ ដែលអ្នកដទៃធ្វើហើយ ឲ្យឆ្អែត ឬឲ្យជ្រះថ្លាបានឡើយ ។

ទេវតានោះ សម្តែងធម៌រំពងព្រៃ ដោយប្រការដូច្នេះ ។ ព្រះពោធិសត្វតាំងនៅដល់អាយុក្ខ័យ បានទៅតាមតថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តជាមនុស្សអកតញ្ញូ សូម្បីក្នុងកាលមុន ក៏ជាមនុស្សអកតញ្ញូដូចគ្នាដូច្នេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បុរសទ្រុស្តមិត្រ ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ រុក្ខទេវតា បានមកជាសារីបុត្រ ឯស្តេចដំរីអ្នកមានសីលគឺជាតថាគតនេះ ៕ ០៚

**អដ្ឋកថា សីលវនាគជាតក ចប់**

# សុត្តន្តបិដក

## សច្ចង្កិរជាតក

[ ៧៣ ] ( តាបសពោធិសត្វពោលថា ) បានឮថា នរៈពួកខ្លះ ក្នុងលោកនេះ បាននិយាយពិតយ៉ាងនេះថា ឧសដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាងនរៈពួកខ្លះ ដែលគេស្រង់ឡើង ( អំពីទឹក ) មិនប្រសើរឡើយ ។

*សច្ចង្កិរជាតកទី ៣ ចប់*

# អដ្ឋកថា

## សច្ចង្កិរជាតក

[ ៧៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធការខ្នះខ្នែងដើម្បីផ្តាច់ព្រះជន្មរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សច្ចំ កិរេវមាហំសុ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលភិក្ខុសង្ឃប្រជុំគ្នាក្នុងធម្មសភា សន្ទនាដល់ទោសមិនមែនគុណរបស់ទេវទត្តថា អាវុសោទាំងឡាយ ទេវទត្តមិនបានដឹងគុណរបស់ព្រះសាស្តា ព្យាយាមដើម្បីផ្តាច់ព្រះជន្មព្រះអង្គទៀត ។ ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយនាំគ្នាក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាមដើម្បីសម្លាប់តថាគត សូម្បីក្នុងកាលមុន ក៏ព្យាយាមហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះឱរសរបស់ព្រះអង្គ ឈ្មោះទុដ្ឋកុមារ មានសន្តានឃោរឃៅគ្រោតគ្រាត ប្រៀបដូចអាសិរពិសដែលត្រូវប្រហារ បើមិនបានជេរ មិនបានវាយបុគ្គលណាហើយ ក៏មិននិយាយជាមួយបុគ្គលណា ព្រះរាជកុមារមិនជាទីពេញចិត្ត ជាទីគួរភ័យខ្លាចរបស់មនុស្សខាងក្នុង និងមនុស្សខាងក្រៅ ដូចធូលីខ្លាតចូលភ្នែក និងដូចបិសាចកាចដែលមកចាំទំពាស៊ី ។ ថ្ងៃមួយ ព្រះ

រាជកុមារប្រាថ្នានឹងលេងទឹកក្នុងស្ទឹង បានទៅកាន់ច្រាំងស្ទឹងដោយបរិវារច្រើន ខណៈនោះ ពពកក៏តាំងឡើង ទិសទាំងឡាយក៏ងងឹត ព្រះរាជកុមារត្រាស់នឹងអ្នកបម្រើថា វ៉ៃយ មកចុះ ចូរមកនាំអញទៅកណ្ដាលស្ទឹង ឲ្យអញងូតហើយនាំមក ។ អ្នកបម្រើនាំព្រះរាជកុមារ ទៅត្រង់កណ្ដាលស្ទឹង ប្រឹក្សាគ្នាថា ព្រះរាជានឹងធ្វើអ្វីពួកយើងបាន ចូរពួកយើងលេងឲ្យមនុស្សចិត្តអាក្រក់ស្លាប់ក្នុងស្ទឹងនេះឯង ដូច្នេះហើយ ពោលថា មនុស្សកាឡកិណី ចូរទៅតាមគាប់ចិត្តចុះ ហើយនាំគ្នាសង្កត់ទៅក្នុងទឹក រួចហែលទៅឈរលើច្រាំង កាលមនុស្សសួរថា ព្រះរាជកុមារទៅណា ក៏នាំគ្នាឆ្លើយថា ពួកយើងមិនឃើញព្រះរាជកុមារ កាលពពកតាំងឡើង ទើបមុជចុះទៅក្នុងទឹក ប្រហែលជាទ្រង់ទៅមុនហើយ ពួកអមាត្យក៏នាំគ្នាទៅកាន់រាជសម្នាក់ ព្រះរាជាត្រាស់សួរថា ឱរសរបស់យើងទៅណា ពួកអមាត្យក៏ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំទាំងឡាយមិនជ្រាប កាលភ្លៀងធ្លាក់ ពួកទូលបង្គំ សម្គាល់ថា ព្រះរាជកុមារមកមុនហើយ ទើបនាំគ្នាត្រឡប់មក ព្រះរាជាត្រាស់ឲ្យបើកទ្វារ យាងទៅកាន់មាត់ស្ទឹង ត្រាស់ថា ចូរពួកអ្នករកមើល ហើយឲ្យរកមើលក្នុងទីនោះៗ មិនមានអ្នកណាឃើញព្រះរាជកុមារ ។ ឯព្រះរាជកុមារនោះ ក្នុងពេលដែលមេឃងងឹតភ្លៀងធ្លាក់ ក៏អណ្ដែតទៅក្នុងស្ទឹង ឃើញកំណាត់ឈើមួយ ទើបតោងកំណាត់ឈើ ត្រូវមរណភ័យគំរាមហើយ ទ្រហោយំអណ្ដែតទៅ ។

ក្នុងកាលនោះ សេដ្ឋីក្រុងពារាណសីម្នាក់កប់ទ្រព្យ ៤០ កោដិ ត្រង់ច្រាំងស្ទឹង ព្រោះជាប់ជំពាក់ក្នុងទ្រព្យ ស្លាប់ទៅកើតជាពស់លើកំណប់ទ្រព្យ

នៅមានបុរសម្នាក់ទៀត កប់ទ្រព្យនៅត្រង់នោះដូចគ្នា ចំនួន ៣០ កោដិ ព្រោះជាប់ជំពាក់ក្នុងទ្រព្យ ស្លាប់ទៅកើតជាកណ្ដុរក្នុងទីនោះដូចគ្នា ។ ទឹកឡើងទៅដល់លំនៅរបស់ពស់ និងកណ្ដុរទាំងនោះ សត្វទាំង ២ ក៏ធ្លាក់មកតាមទឹកហូរទៅនោះឯង ហែលកាត់ខ្សែទឹកដល់កំណាត់ឈើដែលព្រះរាជកុមារតោងក៏ឡើងកាន់កំណាត់ឈើនោះម្នាក់ម្ខាង ដេកលើកំណាត់ឈើនោះឯង ។ ត្រង់មាត់ច្រាំងស្ទឹងនោះឯង មានដើមរកាមួយដើម កូនសេកមួយនៅអាស្រ័យត្រង់ដើមរកានោះ លុះដើមរកានោះត្រូវទឹកច្រោះគល់ ក៏រលំទៅក្នុងទឹក កាលភ្លៀងកំពុងធ្លាក់ កូនសេកមិនអាចហើរទៅបាន ក៏អណ្ដែតទៅជាប់នឹងកំណាត់ឈើនោះ ។ ដោយប្រការដូចពោលមកនេះ ទើបរួមជាជន ៤ នាក់អណ្ដែតទៅហើយ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងដែនកាសី ចម្រើនវ័យហើយ បួសជាឥសី សាងបណ្ណសាលា ក្បែរឆ្នេរស្ទឹងនោះ កំពុងចង្ក្រមក្នុងពេលយប់ បានឮសំឡេងយំរបស់ព្រះរាជកុមារ ក៏ត្រិះរិះថា កាលតាបសដែលសម្បូរដោយមេត្តា ករុណានៅមាន នឹងបណ្ដោយឲ្យបុរសនេះស្លាប់ មិនគួរ អញនឹងជួយឲ្យឡើងអំពីទឹក ឲ្យរស់រានមានជីវិត ហើយលួងលោមព្រះរាជកុមារថា កុំភ័យឡើយ ហែលកាត់ខ្សែទឹក ទៅចាប់កំណាត់ឈើត្រង់ចុងម្ខាងទាញមក ។ តាបសមានកម្លាំងដូចដំរីសា សម្បូរដោយថាមពល មួយសម្ទុះក៏ដល់ច្រាំង បីព្រះរាជកុមារឡើងលើច្រាំង កាលឃើញសត្វទាំងឡាយ មានពស់ជាដើម ក៏នាំឡើងទៅកាន់អាស្រមបទ បង្កាត់ភ្លើង

រូបគិតថា សត្វទាំងនេះទន់ខ្សោយជាង ឲ្យពស់ជាដើមធ្វើរក្បើងមុន ឲ្យព្រះរាជកុមារធ្វើរឯក្រោយ ធ្វើឲ្យបាត់រងា កាលនឹងឲ្យអាហារ ក៏ឲ្យដល់ពស់មុនជាដើម ហើយនាំផ្លែឈើទៅឲ្យព្រះរាជកុមារតាមក្រោយ ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា តាបសកោងនេះ មិនរាប់អានអញ ដែលជាព្រះរាជកុមារបែរជារាប់អានពួកសត្វតិរច្ឆាន ទើបចងអាឃាតក្នុងព្រះពោធិសត្វ ។ បន្ទាប់អំពីនោះ កន្លងទៅ ២-៣ ថ្ងៃ កាលព្រះកុមារ និងសត្វទាំងនោះមានកម្លាំងជាប្រក្រតីហើយ ខ្សែទឹកក្នុងស្ទឹងក៏ស្រកហើយ ពស់ថ្វាយបង្គំលាតាបសពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់បានធ្វើឧបការៈយ៉ាងធំដល់ខ្ញុំ ខ្ញុំមិនមែនអ្នកក្រីក្រ កប់ទ្រព្យ ៤០ កោដិក្នុងទីឈ្មោះនោះ បើលោកម្ចាស់ត្រូវការប្រើប្រាស់ទ្រព្យ ខ្ញុំឲ្យទ្រព្យទាំងអស់ដល់លោកម្ចាស់ សូមលោកម្ចាស់ទៅទីនោះហើយ ហៅខ្ញុំថា ទីឃៈចុះ ហើយក៏លាទៅ ឯកណ្ដុរក៏បវារណាតាបសយ៉ាងនោះដូចគ្នា ពោលថា បើលោកម្ចាស់ត្រូវការប្រើប្រាស់ សូមទៅឈរក្នុងទីឈ្មោះនោះ ហៅខ្ញុំថា ឧន្ទុរៈចុះ ដូច្នេះហើយ ក៏លាទៅ ឯសេកថ្វាយបង្គំតាបស ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនមានទ្រព្យ តែបើលោកម្ចាស់ត្រូវការស្រូវសាលីក្រហម សូមទៅលំនៅរបស់ខ្ញុំក្នុងទីឈ្មោះនោះ ហៅខ្ញុំថា សុវៈ ខ្ញុំអាចប្រាប់ដល់ពួកញាតិ ឲ្យជួយជញ្ជូនស្រូវសាលីពណ៌ក្រហមមកប្រគេន បានច្រើនរទេះ ហើយលាទៅ ឯព្រះរាជកុមារ ព្រោះដាក់ចិត្តក្នុងធម៌របស់បុគ្គលទ្រុស្តមិត្ត គិតថា បើអញមិនពោលពាក្យណាមួយ ទៅដោយព្រងើយៗ មិនសមគួរឡើយ អញនឹងសម្លាប់តាបស ពេលដែលគាត់មក

រកអញ ទើបពោលថា បពិត្រលោកម្ចាស់ កាលខ្ញុំតាំងនៅក្នុងរាជសម្បត្តិហើយ សូមលោកម្ចាស់មករកខ្ញុំចុះ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយបច្ច័យ ៤ ហើយក៏លាទៅ ។ ព្រះរាជកុមារយាងទៅមិនយូរប៉ុន្មាន ក៏តាំងនៅក្នុងរាជសម្បត្តិ ។

ព្រះពោធិសត្វត្រិះរិះថា អញនឹងសាកល្បងដល់អ្នកទាំងនោះ ដូច្នេះហើយ ទើបទៅកាន់សម្នាក់ពស់មុន ឈរមិនឆ្ងាយ ហៅថា ទីឃៈ ត្រឹមតែមួយមាត់ប៉ុណ្ណោះ ពស់ក៏លូនមកថ្វាយបង្គំព្រះពោធិសត្វ ពោលថា បពិត្រលោកម្ចាស់ ទីនេះមានទ្រព្យ ៤០ កោដិ សូមលោកម្ចាស់ជីកជញ្ជូនយកទៅទាំងអស់ចុះ ។ ព្រះពោធិសត្វពោលថា យើងផ្ញើទីនេះឯង កាលមានកិច្ចកើតឡើង សឹមគិតគូរ ប្រាប់ឲ្យពស់ត្រឡប់ទៅហើយ បណ្ដួសទៅកាន់សម្នាក់របស់កណ្ដុរ ធ្វើសំឡេងហៅ ។ កណ្ដុរបដិបត្តិយ៉ាងនោះដូចគ្នា ។ ព្រះពោធិសត្វប្រាប់ឲ្យកណ្ដុរត្រឡប់ទៅ ។ ទៅកាន់សម្នាក់របស់សេក ហៅថា សុវៈ ត្រឹមមួយម៉ាត់ប៉ុណ្ណោះដូចគ្នា សេកក៏ហើរមកអំពីចុងឈើ ថ្វាយបង្គំព្រះពោធិសត្វ ហើយសួរថា លោកម្ចាស់ ខ្ញុំនឹងត្រូវទៅរកពួកញាតិ ឲ្យជួយជញ្ជូនស្រូវសាលីដែលដុះឯង ក្នុងហិមវន្តប្បទេស មកប្រគេនលោកម្ចាស់ឬ ។ ព្រះពោធិសត្វពោលថា ចាំពេលត្រូវការសឹមដឹងគ្នា ប្រាប់ឲ្យសេកត្រឡប់ទៅហើយ គិតថា ពេលនេះ អញនឹងសាកល្បងព្រះរាជា ទើបទៅសម្រាកក្នុងព្រះរាជឧទ្យាន ស្អែកឡើង សង្រួមមារយាទរៀបរយ ចូលទៅកាន់ព្រះនគរដោយកិក្ខាចារវត្ត ។ ក្នុងខណៈនោះ ព្រះរាជាទុស្តមិត្តអង្គនោះ ប្រថាប់លើកដំរីដ៏ប្រសើរ ដែល

តាក់តែងហើយ ធ្វើប្រទក្សិណព្រះនគរ ដោយរាជបរិវារធំ ឃើញព្រះពោធិសត្វអំពីចម្ងាយ ទ្រង់ព្រះតម្រិះថា តាបសនេះ គឺតាបសកោងនោះ ប្រហែលជាចង់នៅក្នុងសម្នាក់របស់អញ ទើបមកទីនេះ អញត្រូវឲ្យរាជបុរសកាត់ក្បាល ទាន់គាត់មិនទាន់ប្រកាសគុណដែលធ្វើដល់អញ ក្នុងកណ្តាលពពួកមនុស្ស ហើយទ្រង់សម្លឹងមើលរាជបុរស កាលរាជបុរសទូលសួរថា បពិត្រព្រះសម្មតិទេព ទូលបង្គំទាំងឡាយត្រូវធ្វើអ្វី ទើបត្រាស់ថា តាបសកោងនោះ ប្រហែលជាមកសូមអ្វីមួយ ពួកអ្នកកុំឲ្យតាបសកាឡកិណីនោះឃើញយើង ចាប់វាចងក្រពាត់ស្លាបសេក វាយក្នុងទីដែលមានផ្លូវបែកជា ៤ នាំវាចេញអំពីព្រះនគរ កាត់ក្បាលត្រង់ទីពិឃាត ហើយដោតខ្លួនដោយលំពែង រាជបុរសទាំងនោះទទួលព្រះរាជបញ្ជា ហើយនាំគ្នាទៅចងព្រះពោធិសត្វ ដែលជាអ្នកប្រាសចាកកំហុស វាយក្នុងផ្លូវបែកជា ៤ ហើយនាំទៅកាន់ផ្លូវបែកជា ៤ ។ ព្រះពោធិសត្វមិនបានយំសោកថា ពុកម៉ែទាំងឡាយ ក្នុងទីដែលត្រូវវាយគ្រប់កន្លែង ប្រាសចាកការញាប់ញ័រ ពោលគាថានេះថា

បានឮថា នរៈពួកខ្លះ ក្នុងលោកនេះ បាននិយាយពិតយ៉ាងនេះថា
ឧសដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាង នរៈពួកខ្លះ ដែលគេ
ស្រង់ឡើង ( អំពីទឹក ) មិនប្រសើរឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សច្ចំ កិរេវមាហំសុ** សេចក្តីថា បានឮថា បណ្ឌិតទាំងឡាយពោលយ៉ាងនេះមិនខុសឡើយ ។

បទថា **ឆកា ឯកច្ចិយា ៩ឥ** សេចក្តីថា បុរសដែលជាបណ្ឌិតពួកខ្លះក្នុងលោកនេះ ។

បទថា **កដ្ឋំ និប្លវិតំ សេយ្យោ** សេចក្តីថា បានឮថា បុរសដែលជាបណ្ឌិតទាំងនោះ ដែលពោលថា ឈើឆាប់ ជាឈើស្រាលៗ អណ្តែតក្នុងស្ទឹង ស្រង់ឡើងមកលើគោក ទុំះប្រសើរជាង គឺល្អជាង ទុំះពោលជាការពិតព្រោះហេតុអ្វី ព្រោះថា ឈើនោះឧបការៈដល់សេចក្តីត្រូវការ អាចដាំបបរដាំបាយក៏បាន ជាឧបការៈដល់សេចក្តីត្រូវការក្នុងការអាំងភ្លើងរបស់ពួកជនដែលលំបាកដោយរងាបាន ជាឧបការៈដល់សេចក្តីត្រូវការក្នុង ការកម្ចាត់អន្តរាយដទៃៗ ក៏បាន ។

បទថា **ឆ ត្វេវេកច្ចិយោ ឆរោ** សេចក្តីថា ចំណែកបុគ្គលពួកខ្លះ គឺបុគ្គលទម្លាយមិត្រ បុគ្គលអកតញ្ញូ បុគ្គលចិត្តបាប ត្រូវក្រសែទឹកបន្សាត់ទៅជួយទាញដៃឲ្យឡើងអំពីទឹកបាន មិនប្រសើរឡើយ ជាសេចក្តីពិតនោះឯង ខ្ញុំជួយបុគ្គលចិត្តបាបនេះឲ្យរួចជីវិតបាន បែរជានាំទុក្ខមកឲ្យខ្លួន ។

ព្រះពោធិសត្វពោលគាថានេះ ក្នុងទីដែលត្រូវវាយគ្រប់កន្លែង ដោយប្រការដូច្នេះ ។ ពពួកជនបានឮគាថានោះ ជនដែលជាបណ្ឌិត នាំគ្នាពោលថាបពិត្រអ្នកបួសដ៏ចម្រើន លោកម្ចាស់ធ្វើគុណណាមួយ ដល់ព្រះរាជារបស់ពួកយើងឬ ទើបព្រះពោធិសត្វនិទានរឿងនោះ ហើយពោលថា ខ្ញុំជាអ្នកជួយព្រះរាជាឲ្យឡើងផុតពីអន្លង់ទឹកធំ បែរជាឲ្យទុក្ខដល់ខ្លួនយ៉ាងនេះ ខ្ញុំរឭកបានថា ខ្ញុំមិនបានធ្វើតាមពាក្យរបស់បណ្ឌិតអំពីកាលមុនឡើង ទើបពោលយ៉ាងនេះ ។ អ្នកនគរ មានក្សត្រ និងព្រាហ្មណ៍ជាដើម ស្តាប់ពាក្យនោះហើយ នាំ

គ្នាពោលថា ព្រោះអាស្រ័យព្រះរាជាដែលទម្លាយមិត្រ មិនបានដឹងត្រឹមតែគុណរបស់បុគ្គលដែលដល់ព្រមដោយព្រះគុណ ដែលឲ្យនូវជីវិតដល់ខ្លួនយ៉ាងនេះ ពួកយើងមានសេចក្តីចម្រើនបានអំពីណា ចូរចាប់វាចុះ ដូច្នេះហើយ នាំគ្នាក្រោធខឹង ក្រោកឡើងដោយជុំវិញ សម្លាប់ព្រះរាជានោះចោលទាំងកំពុងនៅលើកដំរីនោះឯងដោយគ្រឿងប្រហារ មានព្រួញ លំពែង ដុំថ្មនិងដំបងជាដើម ហើយចាប់ទាញជើងទម្លាក់ចុះ បោះទៅលើគូទឹក ហើយអភិសេកព្រះពោធិសត្វឲ្យគ្រងរាជ្យជំនួស ។

ឯព្រះពោធិសត្វគ្រប់គ្រងរាជ្យដោយធម៌ ថ្ងៃមួយ ទ្រង់ប្រាថ្នាពួសាកល្បងសត្វ មានពស់ជាដើម ទើបយាងទៅកាន់លំនៅរបស់ពស់ ដោយបរិវារជាច្រើន ហៅថា ទីឃៈ ពស់លូនមកថ្វាយបង្គំ ពោលថា បពិត្រអ្នកមានគុណសូមជញ្ជូនទ្រព្យរបស់លោកយកទៅចុះ ។ ព្រះរាជាមានព្រះតម្រាស់ឲ្យអមាត្យទទួលកំណប់ទ្រព្យ ៤០ កោដិ ហើយយាងទៅកាន់សម្នាក់របស់កណ្តុរ ត្រាស់ហៅថា ឧន្ទុរៈ កណ្តុរក៏មកថ្វាយបង្គំ ហើយប្រគល់សម្បត្តិ ៣០ កោដិព្រះរាជាមានព្រះតម្រាស់ឲ្យអមាត្យទទួលកំណប់នោះ ។ យាងទៅលំនៅរបស់សេក ត្រាស់ហៅថា សុវៈ សេកក៏ហើរមកថ្វាយបង្គំព្រះយុគលបាទ ក្រាបទូលថា បពិត្រអ្នកមានគុណ ខ្ញុំនឹងទៅនាំស្រូវសាលីមកឲ្យ ។ ព្រះរាជាត្រាស់ថា កាលយើងត្រូវការស្រូវសាលី សឹមនាំមកចុះ យើងនាំគ្នាទៅ ហើយទ្រង់នាំសត្វទាំង ៣ មួយអន្លើដោយទ្រព្យ ៧០ កោដិ ទៅព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទឲ្យរក្សាទ្រព្យ ត្រាស់ឲ្យធ្វើនាឡមាស ព្រះរាជទានជាទីលំនៅ

របស់ពស់ ធ្វើគុហាកែវផលិកជាលំនៅរបស់កណ្ដុរ ធ្វើទ្រុងមាសជាទីលំនៅរបស់សេក ព្រះរាជទានលាជដែលលាយដោយទឹកឃ្មុំ ដាក់ចានមាសឲ្យពស់និងសេកបរិភោគ ព្រះរាជទានអង្ករស្រូវសាលីឲ្យកណ្ដុរបរិភោគរាល់ថ្ងៃ ទ្រង់ធ្វើបុណ្យ មានទានជាដើម ។ ជនទាំង ៤ ស្រឡាញ់គ្នា រីករាយដរាបដល់អស់ជីវិត លុះអស់ជីវិតហើយ ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ ដែលទេវទត្តព្យាយាមសម្លាប់តថាគត សូម្បីក្នុងកាលមុន ក៏ព្យាយាមហើយដូចគ្នា ដូច្នេះ ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ព្រះរាជាឃោរឃៅក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ ពស់បានមកជាសារីបុត្រ កណ្ដុរបានមកជាមោគ្គល្លាន សេកបានមកជាអានន្ទ ធម្មរាជាដែលសោយរាជ្យ ក្នុងកាលជាក្រោយ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សច្ចង្កិរជាតក ចប់**

# សុត្តន្តបិដក

## រុក្ខធម្មជាតក

[ ៧៤ ] ( រុក្ខទេវតាពោធិសត្វពោលថា ) មានពួកញាតិច្រើននាក់ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរម្ងំនូវឈើជាធំក្នុងព្រៃ បរិបូណ៌ដោយមែក និងប្រគាបដែលតាំងនៅតែឯង ៗ

រុក្ខធម្មជាតកទី ៤ ចប់

# អដ្ឋកថា

## រុក្ខធម្មជាតក

[ ៧៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេចក្តីវិនាសធំ កំពុងកើតមានដល់ព្រះញាតិទាំងឡាយរបស់ទ្រង់ ព្រោះឈ្លោះគ្នារឿងជណ្តើមទឹក ក៏ហោះទៅលើអាកាស គង់ពត់ភ្នែនលើស្ទឹងរោហិណី ទ្រង់បណ្តាលឲ្យងងឹត ឲ្យព្រះញាតិទាំងឡាយតក់ស្លុត ហើយយាងចុះអំពីអាកាសគង់លើឆ្នេរស្ទឹង ទ្រង់ប្រារព្ធការឈ្លោះគ្នានោះ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សាធុ សម្ពហុលា ញាតី** ដូច្នេះជាដើម ។

ក្នុងជាតកដែលលើកឡើងមកនេះ ជាន័យដោយសង្ខេប ឯវិត្ថារន័យ ( ន័យដោយពិស្តារ ) នឹងប្រាកដក្នុងកុណាលជាតក ។ ក្នុងកាលនោះ ព្រះសាស្តាត្រាស់ហៅព្រះញាតិទាំងឡាយមក ត្រាស់ថា មហាបពិត្រ ពួកទ្រង់ជាព្រះញាតិនឹងគ្នា គួររួបរួមសាមគ្គីគ្នា ព្រោះថា កាលព្រះញាតិទាំងឡាយនៅសាមគ្គីគ្នា ពួកបច្ចាមិត្រ នឹងមិនបានឱកាស មិនមែនតែមនុស្សឡើយ សូម្បីដើមឈើទាំងឡាយដែលមិនមានចេតនា គង់គួរបាននូវការសាមគ្គីគ្នា ព្រោះក្នុងអតីតកាល ក្នុងហិមវន្តប្បទេស មហាវាតក័យបានរុករានព្រៃរាំងទាំងឡាយ តែព្រោះរាំងនោះចាក់ស្រេះជាប់គ្នានិងគ្នា ដោយមែក និងដើម គុម្ពឈើ និងវល្លិ មិនអាចឲ្យដើមឈើសូម្បីតែមួយដើមរលំបានឡើយ បក់ត្រង់តែចុងឈើប៉ុណ្ណោះ តែបានបក់ឈើធំមួយដើម ដែលដុះលើទួល សូម្បីសម្បូរដោយមែក និងប្រគាបឲ្យដួលចុះលើផែនដី ដកនូវឫសឡើង ព្រោះមិនចាក់ស្រេះជាមួយដើមឈើដទៃៗ ដោយហេតុនេះ អ្នកទាំងឡាយ គួររួបរួមសាមគ្គី

រួមចិត្តគ្នា ។ កាលព្រះញាតិទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី វេស្សវណមហារាជអង្គដំបូងចុតិ សក្កទេវរាជ ទ្រង់តាំងព្រះបាទវេស្សវណអង្គថ្មី ក្នុងគ្រាផ្លាស់ប្តូរស្តេចវេស្សវណនេះ ស្តេចវេស្សវណអង្គថ្មីបញ្ជូនដំណឹងដល់ពួកទេវតាថា ចូរចាប់ដើមឈើ គុម្ពឫស្សី គុម្ពឈើ និងលតាវល្លិធ្វើជាវិមានក្នុងទីដែលខ្លួនពេញចិត្តរៀងៗ ខ្លួនចុះ ។ កាលនោះ ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតា ក្នុងព្រៃរាំងមួយកន្លែង នាហិមវន្តប្បទេសនោះ ទ្រង់ប្រកាសប្រាប់ទេវតាដែលជាពួកញាតិថា បើអ្នកទាំងឡាយចាប់ដើមឈើធ្វើវិមាន កុំចាប់ដើមឈើដែលដុះក្នុងទីខ្ពស់ ចូរចាប់ដើមឈើធ្វើវិមាន ជុំវិញវិមានដែលខ្ញុំចាប់ហើយ ក្នុងព្រៃរាំងនេះចុះ ។ បណ្តាទេវតាទាំងនោះ ទេវតាដែលជាបណ្ឌិតធ្វើតាមពាក្យរបស់ព្រះពោធិសត្វ ចាប់ដើមឈើធ្វើវិមាន ជុំវិញវិមានរបស់ព្រះពោធិសត្វ ឯទេវតាដែលមិនមែនបណ្ឌិត នាំគ្នាពោលថា ពួកយើងត្រូវការអ្វី ដោយវិមានក្នុងព្រៃ ចូរនាំគ្នាចាប់ដើមឈើត្រង់ទ្វារស្រុក និគម និងរាជធានី ក្នុងទឹកដីមនុស្សចុះ ព្រោះថា ទេវតាដែលអាស្រ័យស្រុកជាដើម រមែងជួបនូវលាភដ៏លើស និងយសដ៏លើស ហើយនាំគ្នាចាប់ដើមឈើ ធ្វើវិមានត្រង់ដើមឈើធំៗ ដែលកើតក្នុងទីទួល ក្នុងទឹកដីមនុស្ស ។

ថ្ងៃមួយ មានភ្លៀង និងខ្យល់ធំ សូម្បីដើមឈើដែលធំៗ ក្នុងព្រៃ ដែល

មានឫសមាំទាំ មានមែក មានប្រគាប ក៏បាក់រលំ សណ្ដកទាំងឫសទាំងគល់ ព្រោះកម្លាំងខ្យល់ ។ តែលុះមកដល់ព្រៃរាំងដែលតាំងនៅជាប់តគ្នា ទោះបីបក់យ៉ាងណា ក៏មិនអាចធ្វើឲ្យដើមឈើរលំ សូម្បីតែមួយដើមឡើយ ។ ពួកទេវតាដែលមានវិមានបាក់បែក ក៏មិនមានទីស្នាក់អាស្រ័យ នាំគ្នាដឹកដៃកូនទៅកាន់ព្រៃហិមពាន្ត ប្រាប់រឿងរ៉ាវរបស់ខ្លួនដល់ទេវតាដែលនៅក្នុងព្រៃរាំង ពួកទេវតាទាំងនោះ ក៏នាំគ្នាប្រាប់រឿងដែលទេវតាទាំងនោះនាំគ្នាពពាក់ពពូនមករកព្រះពោធិសត្វ ។ ព្រះពោធិសត្វពោលថា ឈ្មោះថា បុគ្គលមិនជឿពាក្យរបស់បណ្ឌិត ហើយនាំគ្នាទៅកាន់ទីដែលមិនមានបច្ច័យ រមែងយ៉ាងនេះឯង កាលសម្ដែងធម៌ ទើបពោលគាថាថា

មានពួកញាតិច្រើននាក់ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើន
ដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរម្ងំនូវឈើជាធំក្នុងព្រៃ បរិបូណ៌
ដោយមែក និងប្រគាបដែលតាំងនៅតែឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្ពហុលា ញាតី** សេចក្ដីថា ញាតិ ចាប់ពី ៤ នាក់ឡើងទៅ ឈ្មោះថា ច្រើន បើច្រើនជាងនោះ រហូតរាប់រយ រាប់ពាន់ ឈ្មោះថា ច្រើនសន្ធឹកសន្ធាប់ កាលពួកញាតិច្រើនសន្ធឹកសន្ធាប់យ៉ាងនេះ រមែងអាស្រ័យគ្នានិងគ្នា ។ បទថា **សាធុ** បានដល់ ល្អប្រសើរបំផុត បច្ចាមិត្រកម្ចាត់មិនបាន ក៏រឹងរឹតតែល្អ ។

បទថា **អបិ រុក្ខា អរញ្ញជា** សេចក្ដីថា កុំថាឡើយតែពពួកជនដែលរួមគ្នាក្នុងពពួកមនុស្ស សូម្បីតែដើមឈើដែលកើតក្នុងព្រៃ ដែលមានច្រើន តាំង

នៅដោយអាការឧបការៈដល់គ្នានិងគ្នា ជាការល្អពិត ព្រោះទោះបីដើមឈើទាំងឡាយ ក៏គួរបានជាបច្ច័យឧបការៈដល់គ្នានិងគ្នា ។

បទថា **វាតោ វហតិ ឯកដ្ឋំ** សេចក្តីថា ខ្យល់ មានខ្យល់ទិសខាងកើតបក់មកជាដើម ធ្វើឲ្យដើមឈើដែលតាំងនៅក្នុងទីទួលតែឯងសណ្តកទៅបាន ។

បទថា **ព្រហន្តម្បិ វនប្បតិំ** សេចក្តីថា ខ្យល់រមែងបក់ដើមឈើធំសម្បូរដោយមែក ធាង និងប្រគាបឲ្យបាក់ សណ្តកទាំងឫស សណ្តកទាំងគល់ទៅបាន ។

ព្រះពោធិសត្វពោលនូវហេតុនេះ កាលអស់អាយុ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់មានព្រះតម្រាស់ថា មហាបពិត្រទាំងឡាយ ពួកញាតិគួរបាននូវការសាមគ្គីគ្នាយ៉ាងនេះឯង ព្រោះហេតុនោះ មហាបពិត្រទាំងឡាយ ចូរស្មោះស្មើរកគ្នា នៅដោយការស្រឡាញ់ ដោយការរាប់អានគ្នាចុះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ពួកទេវតាក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯទេវតាដែលជាបណ្ឌិត គឺជាតថាគតនេះឯង ។ល។

**អដ្ឋកថា រុក្ខធម្មជាតក ចប់**

# សុត្តន្តបិដក

## មច្ឆជាតក

[ ៧៥ ] ( ព្រះពោធិសត្វពោលថា ) បពិត្រមេឃ សូមអ្នកញុំាងផ្គរឲ្យលាន់ឡើង សូមបំផ្លាញកំណប់របស់ក្អែកឲ្យវិនាស សូមធ្វើទុក្ខក្អែកឲ្យសោកសៅ សូមញុំាងខ្ញុំ ( និងពួកញាតិខ្ញុំ ) ឲ្យរួចចាកសេចក្តីសោក ។

**មច្ឆជាតកទី ៥ ចប់**

# អដ្ឋកថា

## មច្ឆជាតក

[ ៧៥ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភ្លៀងដែលធ្លាក់ចុះមក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អភិត្ថនយ បជ្ជុន្ន** ដូច្នេះជាដើម ។

បានឮមកថា សម័យមួយ ក្នុងដែនកោសល ភ្លៀងមិនធ្លាក់ឡើយ សម្ទូងទាំងឡាយក្រៀមស្វិត ត្រពាំង ស្រះបោក្ខរណី និងស្រះក្នុងទីនោះៗ ក្រៀមស្ងួតអស់ សូម្បីស្រះបោក្ខរណីក្បែរខ្លោងទ្វារ ក្នុងវត្តជេតពន ក៏ខះទឹក ។ ហ្វូងក្អែក និងបក្សីជាដើមចោមរោមយកចំពុះ ដែលដូចគ្នានឹងដង្កាប់ ចឹកត្រី និងអណ្ដើកទាំងឡាយដែលលាក់ខ្លួនក្នុងភក់ យកមកស៊ី ទាំងដែលកំពុងបម្រះនទៀល ។ ព្រះសាស្ដាទតឃើញសេចក្ដីវិនាសនៃហ្វូងត្រី និងអណ្ដើក ព្រះមហាករុណាជាស់តឿនព្រះហឫទ័យ ឲ្យទ្រង់ឧស្សាហៈ ទើបត្រិះរិះថា ថ្ងៃនេះតថាគតគួរឲ្យភ្លៀងធ្លាក់ ។ រាត្រីកាលអស់ហើយ ទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈ ទ្រង់កំណត់ពេលភិក្ខាចារ មានភិក្ខុសង្ឃច្រើនចោមរោម ចូលទៅបិណ្ឌបាតក្នុងនគរសាវត្ថី ដោយព្រះពុទ្ធលីលា ខាងក្រោយភត្ត ទ្រង់ត្រឡប់អំពីបិណ្ឌបាតហើយ កាលយាងចេញអំពីនគរសាវត្ថី មកកាន់វិហារ ទ្រង់ឈរត្រង់ជណ្ដើរស្រះបោក្ខរណីជេតពន ត្រាស់ហៅព្រះអានន្ទមកថា ម្នាលអានន្ទ ចូរអ្នកយកសំពត់ងូតទឹកមក តថាគតនឹងស្រង់ទឹកក្នុងជេតវនបោក្ខរណី ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទឹកក្នុងស្រះបោក្ខរណីរីងស្ងួតអស់ហើយ សល់ត្រឹមភក់ប៉ុណ្ណោះមិនមែនឬ ទើបព្រះសាស្ដាត្រាស់ថា ម្នាល

អានន្ទ ធម្មតាកម្លាំងនៃព្រះពុទ្ធធំពន់ពេក ចូរអ្នកនាំយកសំពត់ងូតទឹកមកចុះ ព្រះថេរៈបាននាំមកថ្វាយព្រះសាស្តា ទ្រង់ស្លៀកសំពត់សាដកដោយជាយម្ខាង ជាយម្ខាងទៀត ទ្រង់ដណ្តប់ព្រះសរីរៈ ទ្រង់ឈរត្រង់ជណ្តើរ តាំងព្រះហឫទ័យថា នឹងចុះស្រង់ទឹកក្នុងជេតវនបោក្ខរណី ។

វេលានោះឯង បណ្ឌុកម្ពលសិលាសនៈរបស់សក្កៈ ក៏សម្តែងអាការក្តៅ ទ្រង់ពិចារណាថា មានរឿងអ្វីហ្ន៎ ទ្រង់ជ្រាបហេតុនោះ ទើបមានទេវបញ្ជាហៅវលាហកទេវរាជមក ត្រាស់ថា នែទេវបុត្រ ព្រះបរមសាស្តា ទ្រង់តាំងព្រះហឫទ័យថា នឹងស្រង់ទឹកក្នុងជេតវនបោក្ខរណី ទ្រង់ឈរត្រង់ជណ្តើរ ចូរអ្នកធ្វើដែនកោសលទាំងមូល ឲ្យមានពពកខ្មៅជេរជាសទូទៅ បណ្តាលឲ្យភ្លៀងធ្លាក់ដោយរហ័សចុះ ។ វលាហកទេវរាជ ទទួលទេវបញ្ជាហើយ ស្លៀកពពកមួយដុំ ដណ្តប់មួយដុំ ច្រៀងនូវចម្រៀងមេឃសង្គីតៈ បែរមុខទៅកាន់លោកធាតុទិសខាងកើត ហោះទៅហើយ ។ ក្នុងទិសាភាគខាងកើត ក៏ប្រាកដពពកខ្មៅមួយដុំ ប៉ុនលានស្រូវ ត្រួតគ្នាជា ១០០ ជាន់ ១០០០ ជាន់ ផ្គរលាន់ក៏លាន់ឡើង ផ្លេកបន្ទោរក៏បញ្ចេញពន្លឺ ភ្លៀងធ្លាក់ចុះមក ដោយអាការដូចផ្កាប់ឆ្នាំងចាក់មក ដែនកោសលទាំងមូល ពោរពេញដោយទឹក ដូចជំនន់ទឹកធំ ។ ភ្លៀងធ្លាក់មិនដាច់មួយរំពេចប៉ុណ្ណោះ ក៏ពេញជេតវនបោក្ខរណី ហៀរហូតដល់មាត់ជណ្តើរ ។

ព្រះបរមសាស្តា ទ្រង់ចុះស្រង់ក្នុងជេតវនបោក្ខរណីហើយ ទ្រង់គ្រងសំពត់ក្រហម ២ ជាន់ ចងវត្ថពន្ធចង្កេះ ទ្រង់គ្រងសុគតចីវរឆៀងស្មាម្ខាង

ចោមរោមដោយពួកភិក្ខុសង្ឃ យាងទៅគង់លើបវរពុទ្ធាសនៈ ដែលគេក្រាលក្នុងបរិវេណព្រះគន្ធកុដិ កាលភិក្ខុសង្ឃសម្តែងវត្តបដិបត្តិហើយ ទ្រង់ក៏ក្រោកឡើង ទ្រង់ឈរត្រង់ផ្លូវជណ្តើរកែវមណី ប្រទានឱវាទដល់ភិក្ខុសង្ឃ ហើយទ្រង់បញ្ជូនត្រឡប់ទៅ យាងចូលព្រះគន្ធកុដិ ដែលមានក្លិនក្រអូបឈ្ងុយឈ្ងប់ ទ្រង់ផ្ទុំដូចរាជសីហ៍ ដោយព្រះបន្ទៀងស្តាំ លុះដល់វេលាល្ងាច ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា លើករឿងឡើងសន្ទនាគ្នាថា អាវុសោទាំងឡាយ ចូរលោកទាំងឡាយមើលព្រះគុណសម្បត្តិ គឺខន្តី មេត្តា និងករុណារបស់ព្រះទសពលក្នុងកាលសមូងទាំងឡាយកំពុងក្រៀមស្វិត ជលាល័យគ្រប់ទីរីងស្ងួត ហ្វូងត្រីនិងអណ្តើកជួបនូវទុក្ខធំ ទ្រង់អាស្រ័យករុណា ទ្រង់ស្លៀកសំពត់សាដក ដោយបំណងឲ្យមហាជនផុតចាកទុក្ខ ទ្រង់ឈរត្រង់ជណ្តើរនៃជេតវនបោក្ខរណី ទ្រង់បណ្តាលឲ្យភ្លៀងធ្លាក់ ដូចជំនន់ទឹកធំជោរជន់លិចកោសលរដ្ឋ ក្នុងទីគ្រប់អន្ទើ ត្រឹមតែមួយសម្មុះប៉ុណ្ណោះ ទ្រង់ដោះមហាជនឲ្យផុតចាកទុក្ខផ្លូវកាយ ទុក្ខផ្លូវចិត្ត ហើយយាងចូលព្រះវិហារ ព្រះសាស្តាយាងចេញអំពីព្រះគន្ធកុដិ មកកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតធ្វើឲ្យភ្លៀងធ្លាក់ ក្នុងកាលមហាជនលំបាក សូម្បីក្នុងកាលមុន កាលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ជាស្តេចនៃត្រី ក៏ធ្វើឲ្យភ្លៀងធ្លាក់ហើយដូចគ្នា ហើយទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល មានត្រពាំងមួយកន្លែង ព័ទ្ធដោយព្រៃ និងវល្លិ ត្រង់បោក្ខរណីជេតវននេះ គឺក្នុងក្រុងសាវត្ថី ដែនកោសលនេះឯង ។ កាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតត្រី មានហ្វូងត្រីជាបរិវារនៅក្នុងត្រពាំងនោះ ។ ក្នុងកាលនោះ ដែននោះ ក៏ភ្លៀងមិនធ្លាក់ដូចក្នុងកាលឥឡូវនេះដែរ សម្ទូងរបស់ពួកមនុស្សក៏ក្រៀមស្ងួត ក្នុងបឹងជាដើមក៏ខះទឹក ហ្វូងត្រី និងអណ្តើកនាំគ្នាចូលក្នុងភក់ ។ ក្នុងត្រពាំងនោះ ហ្វូងត្រីនាំគ្នាត្បុលចូលក្នុងភក់ លាក់ខ្លួនពួនអាត្មាក្នុងទីនោះៗ ហ្វូងក្អែកជាដើម ក៏នាំគ្នាចោមរោមចឹកទាញចេញមកស៊ីដោយចំពុះ ។ ព្រះពោធិសត្វឃើញការវិនាសរបស់ពួកញាតិ ត្រិះរិះថា បុគ្គលដទៃ ក្រៅអំពីអាត្មាអញ បុគ្គលដែលអាចដោះនូវសេចក្តីទុក្ខរបស់ពួកត្រីទាំងនេះមិនមាន អាត្មាអញនឹងធ្វើសច្ចកិរិយាឲ្យភ្លៀងធ្លាក់ ដោះនូវហ្វូងញាតិចាកទុក្ខ គឺការស្លាប់ឲ្យបាន ហើយវែកភក់ពណ៌ខ្មៅចេញ ស្តេចត្រីមានកាយពណ៌ដូចផ្កាអញ្ចន់ បើកភ្នែកទាំង ២ ថ្លាធ្វង់ ដូចកែវមណីពណ៌ក្រហមដែលច្នៃហើយ សម្លឹងមើលអាកាស បន្លឺសំឡេង ពោលដល់ទេវរាជឈ្មោះបជ្ជុន្នៈថា បពិត្របជ្ជុន្នដ៏ចម្រើន ខ្ញុំអាស្រ័យពួកញាតិក្តៅក្រហាយច្រើន ក្នុងកាលខ្ញុំទ្រទ្រង់នូវសីល លំបាក ហេតុអ្វី ទើបលោកមិនឲ្យភ្លៀងធ្លាក់ចុះមក ខ្ញុំកើតក្នុងឋានៈដែលត្រូវស៊ីត្រីដូចគ្នា តែមិនធ្លាប់ស៊ីមច្ឆជាតិ តាំងអំពីត្រីតូចមានទំហំប៉ុនគ្រាប់អង្ករ និងដល់សត្វមានជីវិតដទៃ ខ្ញុំមិនបានក្លែងផ្តាច់ជីវិតឡើយ ដោយសច្ចវាចានេះ សូមលោកឲ្យភ្លៀងធ្លាក់ចុះមក ដោះនូវពួកញាតិរបស់ខ្ញុំឲ្យផុតចាកទុក្ខ លុះត្រាស់ហៅបជ្ជុន្នទេវរាជ ហាក់បីដូចបញ្ជាអ្នកបម្រើ

ពោលគាថានេះថា

បពិត្រមេឃ សូមអ្នកញ៉ាំងផ្គរឲ្យលាន់ឡើង សូមបំផ្លាញកំណប់របស់ក្អែកឲ្យវិនាស សូមធ្វើទុក្ខក្អែកឲ្យសោកសៅ សូមញ៉ាំងខ្ញុំ ( និងពួកញាតិខ្ញុំ ) ឲ្យរួចចាកសេចក្ដីសោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិត្ថនយ បជ្ជុន្ន** សេចក្ដីថា មេឃ ហៅថា **បជ្ជុន្ន** ស្ដេចត្រីហៅវលាហកទេវរាជ ដែលមានឈ្មោះដោយអំណាចនៃមេឃ ។ បានឮថា ស្ដេចត្រីនោះមានបំណងដូច្នេះថា ធម្មតាភ្លៀងដែលមិនមានផ្គរ មិនមានផ្លេកបន្ទោរ ទោះបីធ្លាក់ ក៏មិនល្អ ព្រោះដូច្នោះ សូមអ្នកញ៉ាំងផ្គរឲ្យគំរាម ឲ្យផ្លេកបន្ទោរតាំងឡើង ហើយឲ្យភ្លៀងធ្លាក់ចុះ ។

បទថា **និធឹ កាកស្ស នាសយ** សេចក្ដីថា ហ្វូងក្អែកនាំគ្នាចឹកហ្វូងត្រីដែលហាក់ដូចជាជីកកក់ ទាញមកដោយចំពុះ ស៊ីជាអាហារ ព្រោះហេតុនោះហ្វូងត្រីដែលនៅក្នុងកក់ ទើបហៅថា កំណប់របស់ក្អែកទាំងនោះ កាលលោកឲ្យភ្លៀងធ្លាក់ បិទបាំងដោយទឹកហើយ ក៏ឈ្មោះថា ទម្លាយកំណប់របស់ក្អែកនោះ ។

បទថា **កាកំ សោកាយ រន្ធេហិ** សេចក្ដីថា ហ្វូងក្អែក កាលត្រពាំងមានទឹកពេញហើយ មិនបានទូវហ្វូងត្រីជាអាហារ ក៏ត្រូវសោយសោក កាលលោកធ្វើឲ្យត្រពាំងនេះពេញហើយ ក៏ជាការទម្លាយហ្វូងក្អែកនោះ ដោយសេចក្ដីសោក សូមលោកញ៉ាំងភ្លៀងឲ្យធ្លាក់ ដើម្បីរម្ងាប់សេចក្ដីសោក គឺដើម្បីការត្រេកអររបស់ត្រី អធិប្បាយថា ហ្វូងក្អែក នឹងដល់នូវការសោយសោកដែល

មានលក្ខណៈផេះនៅខាងក្នុង បានដោយវិធីណា សូមលោកធ្វើវិធីនោះចុះ ។

៥ អក្ខរៈ ក្នុងបទថា **មញ្ចុ សោកា បមោចយ** នេះ មានការប្រមូលមកជាអត្ថ សេចក្ដីថា សូមលោកឲ្យខ្ញុំ និងហ្វូងញាតិទាំងអស់ផុតពីសេចក្ដីសោកដែលកើតអំពីការស្លាប់នេះចុះ ។

ព្រះពោធិសត្វហៅស្ដេចបជ្ជុន្ន ដូចបញ្ហាអ្នកបម្រើយ៉ាងនេះ ឲ្យភ្លៀងធំធ្លាក់ពេញដែនកោសល ឲ្យមហាជនផុតមរណទុក្ខ ក្នុងបរិយោសាននៃជីវិតបានទៅតាមយថាកម្ម ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតញុំាងភ្លៀងឲ្យធ្លាក់ សូម្បីក្នុងកាលមុនគ្រាកើតក្នុងកំណើតត្រី ក៏ឲ្យភ្លៀងធ្លាក់ហើយដូចគ្នាដូច្នេះ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ហ្វូងត្រីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ បជ្ជុន្នទេវរាជ បានមកជាអានន្ទ ឯស្ដេចត្រី គឺតថាគតនេះឯង ។៚

**អដ្ឋកថា មច្ឆជាតក ចប់**

# សុត្តន្តបិដក

## អសង្កិយជាតក

[ ៧៦ ] *( តាបសពោធិសត្វពោលថា ) យើងជាអ្នកមិនមានសេចក្តីរង្កៀសក្នុងស្រុក យើងជាអ្នកមិនមានភ័យក្នុងព្រៃ បានឡើងកាន់ផ្លូវត្រង់ដោយមេត្តា និងករុណាហើយ ។*

*អសង្កិយជាតកទី ៦ ចប់*

# អដ្ឋកថា

## អសង្កិយជាតក

[ ៧៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នកក្រុងសាវត្ថីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសង្កិយោម្ហិ គាមម្ហិ** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះ ជាព្រះអរិយសាវកថ្នាក់សោតាបន្ន ធ្វើដំណើរជាមួយរទេះមួយក្រុម ដោយករណីយកិច្ចឯណានីមួយ កាលឈ្មួញរទេះទាំងឡាយដោះរទេះ សម្រាកក្នុងព្រៃមួយកន្លែង ក៏ដើរចង្ក្រមត្រង់គល់ឈើមួយដើមក្បែរៗ ក្រុមរទេះនោះ ។ ពួកចោរ ៥០០ កំណត់វេលារបស់ខ្លួន ហើយគិតគ្នាថា ពួកយើងនឹងប្លន់អ្នករទេះក្នុងទីសម្រាក កាន់ធ្នូ និងដំបងជាដើម នាំគ្នាទៅព័ទ្ធទីនោះ ឧបាសកនោះក៏នៅតែដើរចង្ក្រមនោះឯង ចោរទាំងឡាយឃើញឧបាសកនោះហើយ គិតថា បុគ្គលនេះ ពិតជាអ្នកយាមទីសម្រាកពិតប្រាកដ ចាំឲ្យបុរសនេះដេកលក់សិន ពួកយើងនឹងប្លន់ កាលមិនអាចចូលប្លន់ ក៏នៅក្នុងទីនោះៗ ឧបាសកនោះនៅអធិដ្ឋានដើរចង្ក្រមនោះឯង ទាំងក្នុងបឋមយាម មជ្ឈិមយាម និងក្នុងបច្ឆិមយាម រហូតដល់ភ្លឺ ។ ពួកចោរមិនបានឱកាស ក៏បោះបង់ដុំថ្ម និងដំបងជាដើមដែលខ្លួនកាន់មក ហើយនាំគ្នាគេចទៅ ឧបាសកធ្វើកិច្ចរបស់ខ្លួនសម្រេចហើយ ត្រឡប់មកកាន់នគរសាវត្ថី ចូលគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលកំពុងរក្សាខ្លួន ក៏ជាអ្នករក្សាអ្នកដទៃផងដែរឬ ព្រះសាស្តាត្រាស់ថា ត្រូវហើយឧបាសក អ្នករក្សាខ្លួន ឈ្មោះថា រក្សាអ្នកដទៃ អ្នករក្សាអ្នកដទៃ ក៏ឈ្មោះថា រក្សាខ្លួន

នោះឯង ។ ឧបាសកនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ទ្រង់ត្រាស់ប្រាប់ហើយ ខ្ញុំព្រះអង្គធ្វើដំណើរទៅជាមួយរទេះមួយក្រុម ដើរចង្ក្រមត្រង់គល់ឈើ ដោយគិតថា នឹងរក្សាខ្លួន ក្លាយជាអ្នករក្សាក្រុមរទេះទាំងអស់ហើយ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយរក្សាខ្លួន ក៏រក្សាអ្នកដទៃផងដែរ កាលឧបាសកទូលអារាធនា ទ្រង់ក៏នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ ឃើញទោសក្នុងកាម ទើបបួសជាឥសីក្នុងព្រៃហិមពាន្ត មកកាន់ជនបទ ដើម្បីរសជូរ និងរសប្រៃ កាលដើរទៅតាមជនបទ ធ្វើដំណើរទៅជាមួយក្រុមរទេះ កាលក្រុមរទេះស្នាក់នៅក្នុងព្រៃមួយកន្លែង ក៏នៅសម្ងំដោយសេចក្តីសុខដែលកើតអំពីឈាន មិនឆ្ងាយអំពីក្រុមរទេះ ចង្ក្រមត្រង់គល់ឈើមួយ ហើយឈរ ។ កាលនោះ ពួកចោរ ៥០០ នាំគ្នាមក ដោយគិតថា នឹងប្លន់ក្រុមរទេះ ក្នុងកាលដែលបរិភោគបាយល្ងាចហើយ ព័ទ្ធក្រុមរទេះនោះ ។ ពួកចោរទាំងនោះឃើញតាបស គិតថា បើតាបសនេះ ឃើញពួកយើង គង់ប្រាប់អ្នករទេះដោយពិត ចាំគាត់ដេកលក់ សឹមពួកយើងប្លន់ចុះ ហើយនាំគ្នានៅក្នុងទីនោះឯង ។ ឯតាបសដើរទៅ ដើរមករឿយៗ អស់មួយរាត្រី ។ ពួកចោរមិនបានឱកាស នាំគ្នាបោលដំបង និងដុំថ្មដែលខ្លួនកាន់មក បន្លឺកប្រាប់អ្នករទេះថា អ្នករទេះដ៏ចម្រើន បើតាបសដែលដើរទៅមកត្រង់គល់ឈើអង្គ

នេះ មិនមានក្នុងថ្ងៃនេះហើយ ពួកអ្នកគ្រប់គ្នា នឹងត្រូវជួបការប្លន់យ៉ាងធំដោយពិត ស្អែកនេះ ពួកអ្នកគួរធ្វើសក្ការៈធំដល់តាបស ដូច្នេះហើយ នាំគ្នាចៀសចេញទៅ កាលភ្លឺហើយ ពួកអ្នករទេះឃើញដុំថ្ម និងដំបងជាដើម ដែលពួកចោរបោះចោល ក៏ភ័យខ្លាច នាំគ្នាទៅកាន់សម្នាក់ព្រះពោធិសត្វ ថ្វាយបង្គំហើយ សួរថា បពិត្រលោកម្ចាស់ៗ ឃើញពួកចោរឬ ព្រះពោធិសត្វឆ្លើយថា អើ អ្នកទាំងឡាយ យើងឃើញ ពួករទេះសួរថា បពិត្រលោកម្ចាស់ៗ ឃើញចោរមានប្រមាណប៉ុណ្ណេះ មិនមានសេចក្ដីតក់ស្លុត ការញាប់ញ័រមិនកើតឡើងទេឬ ព្រះពោធិសត្វពោលថា អ្នកទាំងឡាយ សេចក្ដីខ្លាច ការតក់ស្លុត ព្រោះឃើញពួកចោរ មានចំពោះអ្នកមានទ្រព្យ តែអាត្មាជាអ្នកគ្មានទ្រព្យ តើនឹងខ្លាចអ្វី ព្រោះកាលអាត្មានៅក្នុងស្រុកក្ដី ក្នុងព្រៃក្ដី ការខ្លាច ឬការតក់ស្លុតមិនមានឡើយ កាលសម្ដែងធម៌ដល់មនុស្សទាំងនោះ ទើបពោលគាថានេះថា

យើងជាអ្នកមិនមានសេចក្ដីរង្កៀសក្នុងស្រុក យើងជាអ្នកមិនមានភ័យ ក្នុងព្រៃ បានឡើងកាន់ផ្លូវត្រង់ ដោយមេត្តា និងករុណាហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសង្កិយោម្ហិ គាមម្ហិ** នេះ ព្រះពោធិសត្វសម្ដែងថា ខ្ញុំ ឈ្មោះថា មិនរង្កៀស ព្រោះមិនប្រកបដោយសេចក្ដីរង្កៀស មិនតាំងនៅក្នុងការរង្កៀស ទោះបីនៅក្នុងស្រុក ក៏មិនរង្កៀសជាអ្នកផុតភ័យអស់នូវសង្ស័យ ព្រោះមិនតាំងនៅក្នុងសេចក្ដីរង្កៀស ។

បទថា **អរញ្ញេ** បានដល់ ក្នុងទីដែលផុតអំពីស្រុក និងឧបចារស្រុក ។

បទថា **ឧជុមគ្គំ សមារុឡ្ហោ មេត្តាយ ករុណាយ ច** នេះ តាបសពោល សេចក្តីថា ខ្ញុំឈានឡើងកាន់ផ្លូវត្រង់ គឺផ្លូវទៅកាន់ព្រហ្មលោក ដែលវៀរចាកការវៀចផ្លូវកាយជាដើម ដោយមេត្តា និងករុណា ដែលជាអារម្មណ៍នៃតិកជ្ឈាន និងចតុក្កជ្ឈាន ។ ម្យ៉ាងទៀត ដោយបទនោះ តាបសសម្តែងថា ព្រោះភាពជាអ្នកមានសីលបរិសុទ្ធ ទើបឈ្មោះថា ឈានឡើងកាន់ផ្លូវត្រង់ បានដល់ វៀរហើយចាកការវៀចដោយកាយ វាចា ចិត្ត ដែលបានដល់ ផ្លូវទៅកាន់ព្រហ្មលោក ដូច្នេះហើយ សម្តែងការក្រៃលែងទៅជាងនោះថា ព្រោះតាំងមាំក្នុងមេត្តា និងករុណា ឈ្មោះថា ឈានឡើងកាន់ផ្លូវត្រង់ គឺផ្លូវទៅព្រហ្មលោក អធិប្បាយថា ធម៌ទាំងឡាយ មានមេត្តា និងករុណាជាដើម ឈ្មោះថា ជាផ្លូវត្រង់ ព្រោះមានឈានមិនវិនាស ជាអ្នកមានព្រហ្មលោកជាទីទៅតែម្យ៉ាង ។

ព្រះពោធិសត្វកាលសម្តែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះ ដែលមនុស្សទាំងនោះ មានចិត្តត្រេកអរហើយ បូជាហើយ ចម្រើនព្រហ្មវិហារ ៤ ដរាបដល់អស់ជីវិត ទៅកើតក្នុងព្រហ្មលោកហើយ ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អ្នករទេះក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯតាបស គឺព្រះតថាគតដូច្នេះឯង ។

**អដ្ឋកថា អសង្កិយជាតក ចប់**

# សុត្តន្តបិដក

## មហាសុបិនជាតក

[ ៧៧ ] ( ព្រះរាជាទ្រង់ត្រាស់ថា មហាសុបិន ១៦ គឺ ) គោឡើងកទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ ( មាស ) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយ ចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ ( រត់ទៅ ) ព្រោះភ្ញាក់ផ្អើល ដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចម្លែក ប្រព្រឹត្តទៅន័យទាំងឡាយ មានក្នុងសុបិនទាំងនេះ ។

**មហាសុបិនជាតកទី ៧ ចប់**

# អដ្ឋកថា

## មហាសុបិនជាតក

[ ៧៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាសុបិន ១៦ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧសភា រុក្ខា** ដូច្នេះជាដើម ។

បានឮមកថា ថ្ងៃមួយ ព្រះបាទកោសលមហារាជ ទ្រង់ចូលកាន់និទ្រាក្នុងរាត្រីកាល ក្នុងបច្ឆិមយាម ទ្រង់ឃើញមហាសុបិននិមិត្ត ១៦ ប្រការ ទ្រង់ចាំបែងព្រះហឫទ័យ តើនអំពីព្រះបន្ទំ ទ្រង់ព្រះតម្រិះថា ព្រោះអញឃើញសុបិននិមិត្តទាំងនេះ នឹងមានអ្វីកើតដល់អញហ្ន៎ ជាបុគ្គលត្រូវមរណភ័យគំរាមហើយ ទ្រង់ប្រថាប់លើព្រះទែនសយនានោះឯង រហូតកន្លងរាត្រីកាល ។

ព្រឹកឡើង ពួកព្រាហ្មណបុរោហិត ចូលគាល់ក្រាបទូលសួរថា បពិត្រមហារាជ ទ្រង់ផ្ទំជាសុខឬ ក៏ឆ្លើយថា លោកអាចារ្យទាំងឡាយ យើងមានសេចក្តីសុខបានដូចម្តេច យប់មិញក្នុងពេលទៀបភ្លឺ យើងឃើញសុបិននិមិត្ត ១៦ ប្រការ តាំងអំពីឃើញសុបិននិមិត្តទាំងនោះហើយ យើងដល់នូវការតក់ស្លុតជាកម្លាំង កាលពួកបុរោហិតក្រាបទូលថា បពិត្រមហារាជ សូមទ្រង់តំណាលរឿងនោះចុះ ពួកទូលបង្គំស្តាប់ហើយ និងទស្សន៍ទាយថ្វាយបាន ទើបត្រាស់សុបិនដែលឃើញហើយ ឲ្យពួកព្រាហ្មណ៍ស្តាប់ ហើយត្រាស់ថា ព្រោះការឃើញសុបិនទាំងនេះ នឹងមានអ្វីកើតឡើងដល់យើង ពួកព្រាហ្មណ៍នាំគ្នារលាស់ដៃ កាលព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបពួកអ្នកនាំគ្នារលាស់ដៃ ទើបពួកព្រាហ្មណ៍នាំគ្នាក្រាបទូលថា បពិត្រមហារាជ សុបិនទាំងឡាយ

អាក្រក់ពេក ។ ព្រះរាជាត្រាស់សួរថា សុបិនទាំងនោះនឹងមានផលដូចម្តេច ទើបពួកព្រាហ្មណ៍ក្រាបទូលថា នឹងមានអន្តរាយ ៣ យ៉ាង គឺអន្តរាយដល់រាជសម្បត្តិ ១ អន្តរាយ គឺរោគបៀនបៀន ១ អន្តរាយដល់ព្រះជន្ម ១ ឯណានីមួយមិនខាន ។ ព្រះរាជាត្រាស់សួរថា តើអាចកែខៃបានដែរឬទេ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រមហារាជ ព្រះសុបិនទាំងនោះ មិនមានផ្លូវកែខៃទេ ព្រោះកាចពន់ពេក តែពួកទូលបង្គំនឹងធ្វើឲ្យកែខៃបាន បើពួកទូលបង្គំមិនអាចកែខៃព្រះសុបិនទាំងនេះបានទេនោះ ឈ្មោះថា ការសម្រេចវេទនឹងមានប្រយោជន៍អ្វី ។ ព្រះរាជាត្រាស់សួរថា តើធ្វើដូចម្តេច ទើបឲ្យសាបរលាបទៅបាន ។ ពួកព្រាហ្មណ៍នាំគ្នាទូលថា បពិត្រមហារាជ ពួកទូលបង្គំត្រូវបូជាយញ្ញ ដោយវត្ថុមួយមុខបួន មួយមុខបួន ។ ព្រះរាជាទ្រង់ស្ងួតព្រះហឫទ័យ ត្រាស់ថា លោកអាចារ្យទាំងឡាយ បើដូច្នោះ យើងសុំប្រគល់ជីវិតក្នុងដៃរបស់ពួកលោកចុះ ពួកលោកប្រញាប់ធ្វើសួស្តីដល់យើងឲ្យឆាប់ចុះ ។ ពួកព្រាហ្មណ៍នាំគ្នាត្រេកអរថា ពួកយើងត្រូវបានទ្រព្យច្រើន និងត្រូវទំពាស៊ីច្រើន ហើយនាំគ្នាក្រាបទូលលួងលោមព្រះរាជាថា បពិត្រមហារាជ ទ្រង់កុំព្រះវិតក្កឡើយ ហើយនាំគ្នាចេញអំពីព្រះរាជនិវេសន៍ រៀបចំរណ្តៅបូជាយញ្ញខាងក្រៅព្រះនគរ ចាប់សត្វជើង ៤ ជាច្រើន ចងរុញបញ្ចូលត្រង់ទីបូជាយញ្ញ ប្រមូលសត្វជើង ២ ស្រេចហើយ ដើរខ្វាត់ខ្វែងទៅមកពោលថា យើងគួរបានវត្ថុនេះៗ ។

គ្រានោះឯង ព្រះនាងមល្លិកាទេវីទ្រង់ជ្រាបហេតុនោះ ក៏ចូលគាល់ព្រះ

រាជា ក្រាបទូលសួរថា បពិត្រមហារាជ ពួកព្រាហ្មណ៍នាំគ្នាដើរទៅ ដើរមក មានរឿងអ្វីឬ ។ ព្រះរាជាត្រាស់ថា នែនាង នាងរស់តែសុខ ទើបមិនដឹងថា ពស់លូនក្បែរៗ ត្រចៀករបស់ពួកយើង ។ ព្រះនាងទូលសួរថា បពិត្រមហារាជ រឿងនោះ គឺរឿងអ្វី ។ ព្រះរាជាត្រាស់ថា យើងយល់សប្តិអាក្រក់បែបនេះ ពួកព្រាហ្មណ៍ទាយថា អន្តរាយ ៣ យ៉ាងណាមួយ ក៏នឹងប្រាកដ ដើម្បីបំបាត់អន្តរាយទាំងនោះ ត្រូវបូជាយញ្ញ ទើបត្រូវសញ្ជូរទៅមករឿយៗ ព្រះនាងមល្លិកាក្រាបទូលថា បពិត្រមហារាជ បុគ្គលដែលជាកំពូលព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោក ទ្រង់បានទូលសួរព្រះសុបិននោះហើយឬ ព្រះរាជាត្រាស់សួរថា នែនាង កំពូលព្រាហ្មណ៍ក្នុងលោក និងទេវលោកនោះ ជាអ្នកណា ។ ព្រះនាងក្រាបទូលថា ទ្រង់មិនស្គាល់មហាព្រាហ្មណគោតមដ៏ជាតថាគត ទ្រង់អស់កិលេស បរិសុទ្ធហើយ ជាសព្វញ្ញូ ជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោកទេឬ ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងហេតុនៃសុបិនពិតប្រាកដ សូមទ្រង់ព្រះរាជដំណើរទៅក្រាបទូលសួរចុះ ។ ព្រះរាជាទ្រង់ត្រាស់ថា សាធុទេវី ហើយយាងទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះសាស្តាហើយ គង់ប្រថាប់ក្នុងចំណែកម្ខាង ។ ព្រះសាស្តាទ្រង់បន្លឺព្រះសូរសៀងដ៏ពីរោះ ត្រាស់សួរថា មហាបពិត្រ ហេតុអ្វី ទើបមហាបពិត្រយាងមក ហាក់ដូចប្រញាប់ប្រញាល់ម្ល៉េះ ។ ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គ ក្នុងពេលទៀបភ្លឺ ខ្ញុំព្រះអង្គយល់សប្តិ ១៦ ប្រការ ខ្ញុំព្រះអង្គតក់ស្លុត ប្រាប់ដល់ព្រាហ្មណ៍ទាំងឡាយ ពួកព្រាហ្មណ៍ទាយថា បពិត្រមហារាជ សុបិននេះកាចពេក ដើម្បីរម្ងាប់សុបិន

ទាំងនោះ ត្រូវបូជាយញ្ញ ដោយយញ្ញវត្ថុមួយមុខបួនៗ ព្រាហ្មណ៍បូជាយញ្ញ ហ្វូងសត្វជាច្រើនត្រូវមរណភ័យគំរាម បពិត្រព្រះអង្គ ទ្រង់ជាអគ្គបុគ្គលក្នុងលោក និងទេវលោក ញេយ្យធម៌កំណត់ក្នុងអតីត អនាគត បច្ចុប្បន្ន ដែលមិនទាន់មកដល់គន្លងនៃញាណមុខរបស់ទ្រង់មិនមានឡើយ បពិត្រព្រះអង្គ សូមទ្រង់មេត្តាព្យាករផលនៃសុបិនរបស់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ត្រាស់ថា ដូច្នោះឯងមហាបពិត្រ ក្នុងលោក និងទេវលោក វៀរតថាគតហើយ អ្នកដទៃដែលឈ្មោះថាអាចដឹងហេតុ ឬផលរបស់ព្រះសិប្ុនទាំងនេះ មិនមានឡើយ តថាគតនឹងព្យាករឲ្យមហាបពិត្រ សូមទ្រង់ប្រាប់សុបិនតាមទំនងដែលទ្រង់ឃើញនោះចុះ ។ ព្រះរាជាទទួលព្រះពុទ្ធតម្រាស់ថា សាធុ ក្រាបទូលព្រះសុបិនតាមទំនងដែលទ្រង់ឃើញសព្វគ្រប់ ដោយដាក់មាតិកាដូច្នេះថា

គោឡើងកទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ ( មាស ) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ ( រត់ទៅ ) ព្រោះភ្ញាក់ផ្អើលដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចម្លែកប្រព្រឹត្តទៅ ន័យទាំងឡាយ មានក្នុងសុបិនទាំងនេះ ដូច្នេះ ។

ហើយត្រាស់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឃើញសុបិនទី ១ យ៉ាងនេះ

ថា គោបាពណ៌ខ្មៅដូចគ្នានឹងផ្កាអញ្ចន់ ៤ ក្បាល គិតថា នឹងជល់គ្នា នាំគ្នារត់មកកាន់លានព្រះរាជវាំងអំពីទិសទាំង ៤ កាលមហាជនប្រជុំគ្នា គិតថា ពួកយើងនឹងមើលគោជល់គ្នា គ្រាន់តែសម្តែងឫកថា ជល់គ្នា បន្លឺសំឡេងដាក់គ្នា ហើយមិនជល់គ្នា នាំគ្នាដកថយចេញទៅ ខ្ញុំព្រះអង្គឃើញសុបិននេះជាដំបូង តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមិនមានក្នុងជួរជ្ជកាលរបស់មហាបពិត្រ និងក្នុងជួរសាសនារបស់តថាគតទេ តែក្នុងអនាគតកាលទ្វីបលោកវិលទៅដល់ការវិនាស ក្នុងកាលរបស់ស្តេចក្រក្រ ដែលមិនបានគ្រងរាជ្យដោយធម៌ និងក្នុងកាលនៃពពួកមនុស្សដែលមិនតាំងនៅក្នុងធម៌ កាលកុសលធម៌ស្រុតថយចុះទៅ អកុសលធម៌ចម្រើនឡើង ក្នុងកាលដែលលោកវិនាស ភ្លៀងនឹងរាំង ពពកក៏មិនមាន សម្ទួងនឹងក្រៀមស្វិត ទុព្ភិក្ខភ័យនឹងកើតឡើង ផ្គរលាន់ទាំងឡាយ តាំងឡើងក្នុងទិសទាំង ៤ ហាក់ដូចជាធ្លាក់ភ្លៀង លុះពួកស្ត្រីប្រញាប់ប្រញាល់សាស្រូវជាដើម ដែលយកទៅហាលថ្ងៃទុកក្នុងម្លប់ ព្រោះខ្លាចសើម កាលពួកបុរសកាន់ចប កាន់បង្គី នាំគ្នាចេញទៅដើម្បីលើកភ្លឺទប់ទឹក ក៏សម្តែងអាការនឹងធ្លាក់ភ្លៀង មានផ្គរលាន់ ផ្លេកបន្ទោរជាដើមតែមិនធ្លាក់ឡើយ អណ្តែតហួសទៅ ដូចគោសម្តែងឫកនឹងជល់គ្នាដូច្នោះ នេះជាផលរបស់សុបិននោះ តែមិនមានអន្តរាយណាមួយដល់មហាបពិត្រ ព្រោះរឿងនោះជាបច្ច័យទេ មហាបពិត្រឃើញសុបិននេះ ប្រារព្ធអនាគត ឯពួកព្រាហ្មណ៍អាស្រ័យការចិញ្ចឹមជីវិតរបស់ខ្លួន ទើបទាយដូច្នេះ ។

ព្រះមុនី កាលត្រាស់ប្រាប់ផលនៃសុបិន ដោយប្រការដូច្នេះហើយ ត្រាស់ថា សូមទ្រង់និទានសុបិនទី ២ ចុះ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញសុបិនទី ២ យ៉ាងនេះថា ដើមឈើតូចៗ និងគុម្ពឫស្សីជ្រែកផែនដី បានមួយចំអាមខ្នះ មួយហត្ថខ្នះ ក៏ចេញផ្កា ចេញផ្លែ នេះជាសុបិនទី ២ ដែលខ្ញុំព្រះអង្គបានឃើញ អ្វីជាផលអាក្រក់នៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា ផលនៃសុបិននេះ នឹងមានក្នុងកាលដែលលោកសាបសូន្យ ក្នុងពេលមនុស្សមានអាយុតិច ព្រោះថា សត្វទាំងឡាយ ក្នុងអនាគត មានរាគៈខ្លាំងក្លា កុមារីមានវ័យមិនទាន់សម្បូរ នឹងសេពគប់ជាមួយបុរសដទៃ ជាស្រីមានរដូវ មានគភ៌ នាំគ្នាចម្រើនដោយបុត្រ និងធីតា ភាពដែលកុមារីទាំងនោះមានរដូវ ប្រៀបដូចដើមឈើតូចៗ មានផ្កា កុមារីទាំងនោះចម្រើនដោយកូនប្រុស និងកូនស្រី ដូចដើមឈើតូចៗ មានផ្លែ ភ័យមាននិមិត្តនេះជាហេតុ មិនមានដល់មហាបពិត្រឡើយ ។ សូមទ្រង់ត្រាស់សុបិនទី ៣ ទៀតចុះ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញមេគោធំៗ នាំគ្នាបៅដោះកូនគោ ដែលទើបតែកើតក្នុងថ្ងៃនេះ នេះជាសុបិនទី ៣ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននោះ ។ ព្រះសាស្តាត្រាស់ថា ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា គឺក្នុងកាលដែលមនុស្សទាំងឡាយ នាំគ្នាលះជេដ្ឋាបចាយិកកម្ម គឺការប្រព្រឹត្តឱនលំទោនចំពោះត្រកូលរៀមច្បង ព្រោះក្នុង

អនាគត សត្វមិនបានតម្កល់នូវការកោតក្រែងក្នុងមាតាបិតា ឬក្នុងជីដូនជីតា គិតតែនាំគ្នាស្វែងរកទ្រព្យតែប៉ុណ្ណោះ កាលប្រាថ្នានឹងឲ្យរបស់ស៊ី របស់ប្រើប្រាស់ដល់មនុស្សចាស់ក៏ឲ្យ បើមិនប្រាថ្នាក៏មិនឲ្យ មនុស្សចាស់អស់ទីពឹងចិញ្ចឹមខ្លួនឯងមិនបាន ត្រូវអង្វរពួកកូនៗ ដើម្បីចិញ្ចឹមជីវិត ដូចមេគោធំៗ នាំគ្នាបៅដោះកូនគោ ដែលកើតក្នុងថ្ងៃនោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ៤ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញពពួកជនមិនទឹមគោធំៗ ដែលធ្លាប់នាំទឹមទៅ សម្បូរដោយមាឌ និងកម្លាំងដែលធ្លាប់បដិបត្តិគ្រប់ជំនាន់ បែរជាទឹមគោស្ទាវៗ ដែលកំពុងហ្វឹក គោស្ទាវៗ ទាំងនោះ មិនអាចនាំទឹមទៅបាន ក៏នាំគ្នារលាស់ទឹមចោល ឈរធ្វើព្រងើយ រទេះទាំងឡាយក៏ទៅមិនបាន នេះជាសុបិនទី ៤ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

មហាបពិត្រ ផលនៃសុបិននេះ ក៏នឹងមានក្នុងរជ្ជសម័យរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ព្រោះថា ខាងមុខ ព្រះរាជាអ្នកមានបុណ្យតិច មិនតាំងនៅក្នុងធម៌ នឹងមិនព្រះរាជទានយសដល់មហាមាត្យដែលជាបណ្ឌិត ឈ្លាសក្នុងបវេណី អាចញុំាងកិច្ចសព្វយ៉ាងឲ្យប្រព្រឹត្តទៅបាន ទ្រង់មិនតែងតាំងអមាត្យដែលជាបណ្ឌិត ឈ្លាសក្នុងវោហារទុកក្នុងទីវិនិច្ឆ័យក្តី តែព្រះរាជទានយសដល់មនុស្សក្មេងៗ ផ្ទុយគ្នា តាមដែលពោលហើយនោះ តែងតាំងបុគ្គលបែបនោះទុកក្នុងតំណែងអ្នកវិនិច្ឆ័យក្តី មនុស្សកំលោះទាំងនោះមិនដឹងទូទៅដល់រាជកិច្ច និងការដែលគួរ និងមិនគួរ មិនអាចតម្កល់យស

នោះបាន ទាំងមិនអាចធ្វើរាជកិច្ចឲ្យប្រព្រឹត្តទៅបាន កាលមិនអាច ក៏នាំគ្នាដាក់ធុរៈ ឯអមាត្យដែលជាបណ្ឌិត ជាអ្នកធំ កាលមិនបានយស ទោះបីអាចឲ្យរាជកិច្ចទាំងឡាយប្រព្រឹត្តទៅ ក៏នាំគ្នាពោលថា ពួកយើងត្រូវការអ្វីដោយរឿងទាំងនេះ ពួកយើងក្លាយជាមនុស្សខាងក្រៅទៅហើយ ពួកក្មេងកំលោះ ជាពួកខាងក្នុង គេគង់ដឹងល្អ ហើយមិនរក្សាការងារដែលកើតឡើង កាលបើដូច្នេះ ការវិនាសប៉ុណ្ណោះ នឹងមានដល់ព្រះរាជាទាំងនោះ ដោយប្រការទាំងពួង ដូចមនុស្សចាប់គោស្ទាវៗ ដែលកំពុងហ្វឹក មិនអាចនាំនឹមទៅបាន ទឹមក្នុងនឹម និងជាពេលដែលមិនចាប់គោធំៗ ដែលធ្លាប់នាំនឹមទៅបានមកទឹម ដូច្នោះ ភ័យមានព្រះសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ៥ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញសេះមួយ មានមាត់សងខាង ពួកជននាំគ្នាឲ្យស្មៅត្រង់មាត់ទាំង ២ របស់វា សេះទំពាស៊ីដោយមាត់ទាំង ២ នេះជាសុបិនទី ៥ របស់ខ្ញុំព្រះអង្គ អ្វីជាផលនៃសុបិននេះ។

ព្រះសាស្តាត្រាស់ថា ផលនៃសុបិននេះ ក៏នឹងមានក្នុងរជ្ជកាលរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ដ្បិតថា ក្នុងកាលខាងមុខពួកព្រះរាជាល្ងង់ខ្លៅ មិនតាំងនៅក្នុងធម៌ ទ្រង់នឹងតែងតាំងមនុស្សឡេះឡោះមិនប្រកបដោយធម៌ ក្នុងតំណែងវិនិច្ឆ័យក្តី មនុស្សទាំងនោះ ជាបុគ្គលពាលមិនអើពើក្នុងបាបបុណ្យ នាំគ្នាអង្គុយក្នុងសាលាវិនិច្ឆ័យ កាលកាត់ក្តី ក៏ទទួលសំណូកអំពីដៃនៃគូក្តីទាំង ២ មកស៊ីបុក ដូចសេះស៊ីស្មៅដោយមាត់ទាំង ២

ដូច្នោះ ភ័យមានសុបិននេះជាហេតុ រមែងមិនមានដល់មហាបពិត្រឡើយ សូមទ្រង់ប្រាប់សុបិនទី ៦ ទៀតចុះ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញមហាជនដុសសម្អាតថាសមាសតម្លៃរាប់សែនកហាបណៈ ហើយនាំទៅឲ្យឆ្កែចចកចាស់ ១ ដោយពាក្យថា សូមលោកបន្ទោបង់ដាក់ថាសមាសនេះចុះ ឆ្កែចចកចាស់នោះក៏បន្ទោបង់បស្សាវៈដាក់ក្នុងថាសមាសនោះ នេះជាសុបិនទី ៦ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ ក៏មានក្នុងអនាគតដូចគ្នា ព្រោះថា ក្នុងកាលខាងមុខ ពួកព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ទ្រង់ស្អប់កុលបុត្រដែលសម្បូរដោយជាតិ មិនព្រះរាជទានយស ព្រះរាជទានដល់បុគ្គលដែលមិនមានត្រកូលប៉ុណ្ណោះ កាលបើដូច្នេះ ត្រកូលធំៗ នឹងធ្លាក់ក្រីក្រ ត្រកូលអន់ ក៏នឹងនាំគ្នាជាធំ កាលពួកត្រកូលទាំងនោះមិនអាចចិញ្ចឹមជីវិតបាន គិតថា យើងត្រូវអាស្រ័យជនទាំងនេះ ចិញ្ចឹមជីវិតតទៅ ហើយនាំគ្នាលើកកូនស្រីឲ្យដល់បុគ្គលមិនមានត្រកូល ការនៅរួមជាមួយបុគ្គលដែលមិនមានត្រកូលនៃកុលធីតាទាំងនោះ ដូចគ្នានឹងថាសមាស ទ្រទឹកនោមចចក ភ័យ មានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ៧ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញយ៉ាងនេះ គឺបុរសម្នាក់ យកខ្សែរុំត្រង់ជើង ហើយបន្ទាយទៅមិនឆ្ងាយអំពីជើង ឆ្កែចចក

មួយក្បាល ដេកក្រោមតាំងរបស់បុរសនោះ អង្គុយទំពាស៊ីខ្សែនោះ បុរសនោះមិនបានដឹងឡើយ នេះជាសុបិនទី ៧ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា ផលនៃសុបិននេះ ក៏នឹងមានក្នុងអនាគតដូចគ្នា ដ្បិតថា ក្នុងកាលខាងមុខ ពួកស្ត្រីនាំគ្នាឡេះឡោះក្នុងបុរស លេងនូវសុរា តែងតែខ្លួន ដើរលេងតាមថ្នល់ តាមវិថី ឃើញតែអាមិស ជាស្រីទ្រុស្តសីល មានការប្រព្រឹត្តលាមក ពួកនាងនឹងខ្ជះខ្ជាយទ្រព្យដែលប្តីរកបាន មានកសិកម្ម និងគោរក្ខកម្មជាដើម សន្សំដោយលំបាក យកទៅទិញស្រាផឹកជាមួយបុរស ទិញផ្កា គ្រឿងក្រអូប និងគ្រឿងលាបមកតែងខ្លួន មិនដាក់ចិត្តក្នុងការងារបច្ចុប្បន្នក្នុងផ្ទះ គយគន់ចាំមើលសហាយ ដោយចំណែកខាងលើនៃផ្ទះដែលបិទជិតខ្លះ ក្នុងទីកំបាំងខ្លះ យកស្រូវដែលត្រៀមសម្រាប់ព្រោះក្នុងថ្ងៃស្អែក យកទៅបុក រៀបចំធ្វើជាបបរ បាយ និងរបស់ទំពាជាដើមមកបរិភោគ ដូចចចកញីដេកក្រោមតាំង កកេរខ្សែដែលរុំជើងរបស់បុរសនោះហើយ ដូច្នោះ ភ័យដែលមានអំពីសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ៨ ទៀតចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញពាងធំមួយដែលពេញដោយទឹក តាំងនៅត្រង់ទ្វាររាជវាំង នៅជុំវិញមានពាងជាច្រើនវណ្ណៈទាំង ៤ យកក្អមដងទឹកមកអំពីទិសធំទាំង ៤ និងទិសតូចទាំង ៤ មកចាក់ក្នុងពាងដែលពេញហើយនោះឯង ទឹកក៏ពេញហើយពេញទៀត ហូរទៅ

មនុស្សទាំងនោះ ក៏នៅតែចាក់ទឹកក្នុងពាងនោះរឿយៗ តែមិនមានបុគ្គលដែលក្រឡេកមើលពាងដែលទទេឡើយ នេះជាសុបិនទី ៨ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ដ្បិតថា ក្នុងកាលខាងមុខ លោកនឹងសាបសូន្យ ដែននឹងអស់គ្រឿងចំណាំ ព្រះរាជាទាំងឡាយនឹងធ្លាក់ខ្លួនក្រ ជាមនុស្សកំព្រា ព្រះរាជាអង្គណាជាធំ អង្គនោះមានព្រះរាជទ្រព្យត្រឹមតែមួយសែនកហាបណៈក្នុងឃ្លាំង ព្រះរាជាទាំងនោះ លំបាកយ៉ាងនេះ នឹងកែនឲ្យអ្នកជនបទគ្រប់គ្នាធ្វើការជួយដល់ខ្លួន ពួកមនុស្សត្រូវបៀតបៀន ត្រូវលះការងាររបស់ខ្លួន នាំគ្នាព្រោះ ដាំបុព្វណ្ណជាតិ អបរណ្ណជាតិដល់ព្រះរាជាទាំងឡាយប៉ុណ្ណោះ ត្រូវនាំគ្នារក្សា នាំគ្នាប្រូត នាំគ្នាបោកបែន នាំគ្នាជញ្ជូន នាំគ្នាកៀបទឹកអំពៅជាដើម នាំគ្នាធ្វើសួនផ្កា សួនផ្លែឈើ នាំគ្នាជញ្ជូនបុព្វណ្ណជាតិដែលខ្លួនធ្វើបានហើយក្នុងទីនោះៗមកដាក់ក្នុងជង្រុករបស់ព្រះរាជាប៉ុណ្ណោះ បុគ្គលដែលសម្លឹងមើលជង្រុកទទេក្នុងផ្ទះទាំងឡាយរបស់ខ្លួន មិនមានឡើយ ដូចគ្នានឹងការចាក់ទឹកក្នុងពាងដែលពេញហើយ មិនមើលពាងទទេៗ នោះឯង ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមត្រាស់សុបិនទី ៩ ទៀតចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញស្រះបោក្ខរណីមួយ ដេរដាសទៅដោយឈូក ៥ ពណ៌ ជ្រៅ មានកំពង់ចុះឡើងជុំវិញ ហ្វូងសត្វជើង ២ ជើង ៤ នាំគ្នាចុះផឹកក្នុងស្រះនោះដោយជុំវិញ ទឹក

ដែលនៅក្នុងទីជ្រៅកណ្ដាលស្រះនោះ ល្អក់កករ ក្នុងទីដែលសត្វជើង ២-៤ នាំគ្នាជាន់ បែរជាថ្លាស្អាត មិនល្អក់កករ ខ្ញុំព្រះអង្គបានឃើញយ៉ាងនេះ នេះជាសុបិនទី ៩ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្ដាត្រាស់ថា ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ដ្បិតថា ក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយ មិនតាំងនៅក្នុងធម៌ លុះនូវអគតិដោយអំណាចការពេញចិត្តជាដើម សោយរាជសម្បត្តិ នឹងមិនប្រទានការវិនិច្ឆ័យក្ដីដោយធម៌ឡើយ មានព្រះហឫទ័យនៅតែក្នុងសំណូក ជាអ្នកឡេះឡោះក្នុងទ្រព្យ ឈ្មោះថា គុណធម៌ គឺការអត់ធន់ មេត្តា និងការអាណិតអាសូរនៃព្រះរាជាទាំងនោះ មិនមានក្នុងអ្នកដែន ជាមនុស្សរឹងត្អឹង គ្រោតគ្រាតចាំតែបៀតបៀនពួកមនុស្ស ដូចគាបអំពៅដោយឃ្នាបយន្ត និងកំណត់ឲ្យសួយផ្សេងៗ កើតឡើង ទទួលយកទ្រព្យ ពួកមនុស្សត្រូវទារសួយអាករធ្ងន់ មិនអាចឲ្យអ្វីបាន នាំគ្នារត់បោលគាមនិគមជាដើម ភៀសខ្លួនទៅកាន់ជាយដែនរស់នៅក្នុងទីនោះ ជនបទកណ្ដាលសូន្យទទេ ជនបទជាយដែនកុះករទៅដោយមនុស្ស ដូចទឹកកណ្ដាលស្រះបោក្ខរណីល្អក់ ទឹកជុំវិញថ្លា យ៉ាងណា សេចក្ដីនេះ ក៏ដូច្នោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់ព្រះសុបិនទី ១០ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញបាយដែលមនុស្សដាំក្នុងឆ្នាំងតែមួយ តែឆ្អិនមិនស្មើគ្នា អ្នកចម្អិនពិនិត្យមើលហើយ ឃើញថា មិនឆ្អិនដោយអាការ ៣ យ៉ាង គឺមួយកន្លែងជ្រាយ មួយកន្លែងឆៅ មួយ

កន្ទែងផ្កាឈូក នេះជាសុបិនទី ១០ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគត ដូចគ្នា ដ្បិតថា ក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយ មិនតាំងនៅក្នុងធម៌ កាលព្រះរាជាទាំងឡាយមិនតាំងនៅក្នុងធម៌ហើយ អ្នករាជការក្តី ព្រាហ្មណ៍ និងគហបតីក្តី អ្នកនិគម និងអ្នកជនបទក្តី មនុស្សទូទៅទាំងអស់ មានសមណៈ និងព្រាហ្មណ៍ជាដើម ក៏នាំគ្នាមិនតាំងនៅក្នុងធម៌ ទេវតាទាំងឡាយ ក៏មិនទ្រទ្រង់ធម៌ ក្នុងរជ្ជកាលនៃអធម្មិករាជទាំងឡាយ ខ្យល់ទាំងឡាយនឹងបក់មិនស្មើ គឺបក់ខ្លាំងពេកធ្វើឲ្យវិមានក្នុងអាកាសរបស់ទេវតាទាំងនោះកម្រើក កាលវិមានទាំងនោះត្រូវខ្យល់បក់កម្រើក ទេវតាទាំងឡាយក៏នាំគ្នាខឹងសម្បារ ហើយមិនឲ្យភ្លៀងធ្លាក់ ទោះបីធ្លាក់ក៏មិនធ្លាក់គ្រប់តំបន់ កាលភ្លៀងមិនឧបការៈដល់ការសាបព្រោះក្នុងទីទាំងពួង ក៏ធ្វើមិនបានទូទៅ សូម្បីក្នុងជនបទ ក្នុងស្រុក ក្នុងត្រពាំងមួយកន្លែង ក្នុងស្រះមួយ ដូចគ្នាក្នុងដែន ដូច្នោះ កាលភ្លៀងធ្លាក់ខាងលើត្រពាំង មិនធ្លាក់ខាងក្រោម កាលធ្លាក់ខាងក្រោម ក៏មិនធ្លាក់ខាងលើ សម្ទូងក្នុងទីមួយ ខូចព្រោះភ្លៀងខ្លាំងពេក កាលភ្លៀងមិនធ្លាក់ក្នុងចំណែកមួយ សម្ទូងក៏ក្រៀមស្វិត កាលភ្លៀងធ្លាក់ល្អក្នុងចំណែកមួយ សម្ទូងនឹងបរិបូណ៌ ស្រូវដែលព្រោះហើយក្នុងខណ្ឌសីមារបស់ព្រះរាជាអង្គតែមួយ មាន ៣ ស្ថាន ដោយប្រការ ដូច្នេះ ដូចបាយក្នុងឆ្នាំងតែមួយ មានផល ៣ យ៉ាង ដូច្នោះ ភ័យ មានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់សុបិនទី ១១ ទៀតចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញមនុស្សទាំងឡាយយកខ្លឹមចន្ទន៍ មានតម្លៃរាប់សែន ទៅដូរទធិផ្អូម នេះជាសុបិនទី ១១ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ ក៏មានក្នុងអនាគតកាលសាសនារបស់តថាគតសាបសូន្យនោះឯង ក្នុងកាលខាងមុខ ពួកភិក្ខុអលជ្ជី ឃើញតែបច្ច័យមានច្រើន ភិក្ខុទាំងនោះ នឹងនាំគ្នាសម្តែងធម៌ទេសនាដែលតថាគតពោលតិះដៀលការចង់បានក្នុងបច្ច័យដល់ជនដទៃ ព្រោះហេតុនៃបច្ច័យ ៤ មានចីវរជាដើម មិនអាចសម្តែងឲ្យផុតបច្ច័យទាំងឡាយ ហើយតាំងនៅក្នុងចំណែកធម៌នាំសត្វចេញចាកទុក្ខ ឆ្ពោះទៅកាន់ព្រះនិព្វាន ជនទាំងឡាយ ស្តាប់នូវភាពសម្បូរនៃបទ និងព្យញ្ជនៈ និងសំឡេងដ៏ពីរោះតែម្យ៉ាងប៉ុណ្ណោះ ហើយនឹងប្រគេនឯង និងញុំាងដទៃឲ្យប្រគេននូវបច្ច័យទាំងឡាយមានចីវរជាដើម ដែលមានតម្លៃច្រើន ភិក្ខុទាំងឡាយពួកខ្លះ នឹងនាំគ្នាអង្គុយក្នុងទីផ្សេងៗ មានផ្លូវបំបែកជា ៤ និងទ្វារព្រះរាជវាំងជាដើម ហើយសម្តែងធម៌ដូរនូវរូបិយ មានកន្លះកហាបណៈ ១ បាទ ១ មាសកជាដើម ដោយប្រការដូច្នេះ ក៏យកធម៌ដែលតថាគតសម្តែង មានតម្លៃស្មើនឹងព្រះនិព្វាន ទៅសម្តែងដូរបច្ច័យ ៤ និងរូបិយ មានកហាបណៈ និងកន្លះកហាបណៈជាដើម ដូចហ្នឹងមនុស្សយកខ្លឹមចន្ទន៍មានតម្លៃរាប់សែន ទៅដូរទឹកដោះជូរផ្អូមដូច្នោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ១២ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញសម្បកឃ្លោកលិចទឹក តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា ផលនៃសុបិននេះ នឹងមានក្នុងអនាគតកាល គ្រាលោកវិលទៅដល់សេចក្តីសាបសូន្យ ក្នុងរជ្ជកាលរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ព្រោះថា ក្នុងកាលនោះ ព្រះរាជាទាំងឡាយ មិនព្រះរាជទានយសដល់កុលបុត្រដែលសម្បូរដោយជាតិ នឹងព្រះរាជទានដល់បុគ្គលដែលមិនមានត្រកូលប៉ុណ្ណោះ ជនទាំងនោះនឹងជាធំ ឯជនម្ខាងទៀតនឹងធ្លាក់ខ្លួនក្រ ពាក្យសម្តីរបស់ពួកមិនមានត្រកូល ដូចសម្បកឃ្លោក មើលទៅហាក់ដូចជាចាក់ឫសណែនក្នុងទីចំពោះមុខព្រះរាជាក្តី ត្រង់ទ្វាររាំងក្តី ទីប្រជុំអមាត្យក្តី រោងជំនុំជម្រះក្តី នឹងជាពាក្យមិនឃ្លេងឃ្លោង មានគោលពិតប្រាកដ សូម្បីក្នុងសង្ឃសន្និបាត ក្នុងកិច្ចកម្មដែលសង្ឃគប្បីធ្វើ ទាំងក្នុងទីជម្រះអធិករណ៍ ទាក់ទងនឹងបាត្រចីវរ និងបរិវេណជាដើមក្តី ពាក្យរបស់បុគ្គលទ្រុស្តសីលប៉ុណ្ណោះ ហាក់ដូចជាពាក្យនាំសត្វចេញចាកទុក្ខបាន មិនមែនជាពាក្យរបស់លជ្ជីភិក្ខុ កាលបើដូច្នេះ ដូចគ្នានឹងកាលដែលលិចចុះនៃសម្បកឃ្លោក ដោយប្រការទាំងពួង ភ័យមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់សុបិនទី ១៣ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញថ្មតាន់ធំ ទំហំប៉ុនផ្ទះកំពូល អណ្តែតទឹកដូចទូក តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងកាល

នោះដូចគ្នា ព្រោះថា ក្នុងកាលនោះ ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ទាំង-ឡាយ នឹងព្រះរាជទានយសដល់បុគ្គលដែលមិនមានត្រកូល ជនទាំងនោះ នឹងជាធំ ជនដែលមានត្រកូល នឹងធ្លាក់ខ្លួនក្រីក្រ បុគ្គលណាម្នាក់ មិនធ្វើនូវសេចក្ដីគោរពក្នុងជនអ្នកមានត្រកូលនោះ ធ្វើការគោរពក្នុងជនដែលជាធំតែមួយចំណែក ពាក្យរបស់កុលបុត្រអ្នកឈ្លាស ក្នុងការវិនិច្ឆ័យ ជាអ្នកធ្ងន់ដូចគ្មានឹងថ្មតាន់ មិនឈមចុះ តាំងមាំក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះរាជា ឬក្នុងទីប្រជុំអមាត្យ ឬក្នុងសាលាវិនិច្ឆ័យ កាលជនទាំងនោះកំពុងពោល ជនក្រៅពីនេះ នឹងចំអកថា ជនពួកនេះនិយាយអ្វី សូម្បីក្នុងទីប្រជុំភិក្ខុ ពួកភិក្ខុក៏នឹងមិនឃើញភិក្ខុដែលមានសីលជាទីស្រឡាញ់ បុគ្គលគួរធ្វើការគោរពថាជាសំខាន់ក្នុងឋានៈផ្សេងៗ ដូចពោលហើយ ទាំងពាក្យរបស់ភិក្ខុ ដែលជាអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ ក៏នឹងមិនធ្ងន់ មិនមាំទាំ ដូចគ្នានឹងការអណ្ដែតនៃថ្មទាំងឡាយ ដូច្នោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រទេ សូមទ្រង់ត្រាស់សុបិនទី ១៤ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញហ្វូងកង្កែបតូចៗ ប៉ុនផ្លែស្រគំ ដេញតាមខាំពស់វែកធំៗ ខាំដាច់សាច់ ដូចគេកាត់ទងឈូក ហើយទំពាស៊ី នេះជាសុបិនទី ១៤ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ ក៏មានក្នុងអនាគតក្នុងកាលលោកសាបសូន្យ ទ្រុឌទ្រោមដូចគ្នា ព្រោះថា ក្នុងកាលនោះ ពួកមនុស្សមានរាគចារិតខ្លាំងក្លា មានជាតិអាក្រក់ បណ្ដោតបណ្ដោយខ្លួន និងចិត្ត

តាមអំណាចរបស់កិលេស នឹងត្រូវប្រព្រឹត្តទៅក្នុងអំណាចនៃករិយាក្មេងៗ របស់ខ្លួន ជន មានទាសៈ និងកម្មករជាដើម សត្វពាហនៈ មានគោ ក្របី ជាដើម មាស និងប្រាក់ដែលមានក្នុងផ្ទះគ្រប់យ៉ាង នឹងត្រូវនៅក្នុងការគ្រប់គ្រងរបស់ពួកស្រីទាំងនោះ កាលពួកស្វាមីសួរដល់មាសប្រាក់នោះៗ ថានៅឯណា ឬសួរដល់ចំនួនទ្រព្យដែលមានក្តី ពួកស្រីទាំងនោះនាំគ្នាឆ្លើយថា ទ្រព្យទាំងនោះនៅឯណា ប្រយោជន៍អ្វីដែលអ្នកត្រូវត្រួតត្រា អ្នកចង់ដឹងទ្រព្យដែលមាន និងមិនមានក្នុងផ្ទះរបស់យើងធ្វើអ្វី ហើយនឹងជេរដោយប្រការផ្សេងៗ ចាក់ដោយលំពែង គឺមាត់ សង្កត់ក្នុងអំណាចដូចទាសៈ និងអ្នកបម្រើ តាំងខ្លួនជាម្ចាស់ ជាធំតទៅ កាលបើដូច្នេះ ដូចគ្នានឹងហ្វូងកង្កែបប៉ុនៗ ផ្លែស្រគំ នាំគ្នាខាំស៊ីពស់វែក ដែលមានពិសដ៏ពន្លឹក ដូច្នោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ១៥ ចុះ ។

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញស្តេចហង្សមាស ដែលឈ្មោះថា មាស ព្រោះមានរោមពណ៌ដូចមាស នាំគ្នាហែហមសត្វក្អែក ដែលប្រកបដោយអសទ្ធម្ម ១០ ប្រការ ត្រាច់រកស៊ីតាមស្រុក តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគត ក្នុងរជ្ជកាលរបស់ព្រះរាជាទុព្វលនោះឯង ដ្បិតថា ក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយ មិនឈ្លាសក្នុងសិប្បៈ មានហត្ថិសិប្បៈជាដើម មិនក្លៀវក្លាក្នុងការច្បាំង ទ្រង់មិនព្រះរាជទានភាពជាធំឲ្យដល់ពួកកុលបុត្រ ដែលមានជាតិស្មើគ្នា

ជាអ្នករង្កៀសនូវវិបត្តិនៃរាជសម្បត្តិរបស់ព្រះអង្គ នឹងព្រះរាជទានដល់ពួកក្នាក់ងារនូវគ្រឿងស្រង់ ហើយពួកខ្មាន់ព្រះកេសជាដើមដែលនៅទៀបបាទមូលរបស់ព្រះអង្គ ពួកកុលបុត្រដែលសម្បូរដោយជាតិ និងគោត្រ កាលមិនបានទីពឹងក្នុងរាជត្រកូល ក៏មិនអាចចិញ្ចឹមជីវិតបាន នាំគ្នាប្រតិបត្តិពួកជនដែលមិនមានត្រកូល មានជាតិ និងគោត្រថោកថយ ដែលតាំងឥស្សរិយយស ដូចហ្វូងស្តេចហង្សមាស ចោមរោមក្អែកជាបរិវារ ដូច្នោះ ក័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ សូមទ្រង់ត្រាស់សុបិនទី ១៦ ចុះ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនៗ ខ្លាជំបង នាំគ្នាស៊ីហ្វូងចៀម តែខ្ញុំព្រះអង្គបានឃើញហ្វូងចៀម នាំគ្នាដេញខាំហ្វូងខ្លា ទំពាស៊ីឃ្មុមៗ ពេលនោះ ខ្លាដទៃៗ មានខ្លាជំបង និងខ្លាធំជាដើម ឃើញហ្វូងចៀមអំពីចម្ងាយ ក៏ភ័យខ្លាច ដល់នូវការតក់ស្លុត នាំគ្នារត់គេច ពួនតាមគុម្ពឈើនិងព្រៃជ្រៅ លាក់ខ្លួនពួនអាត្មា ខ្លាចហ្វូងចៀម ខ្ញុំព្រះអង្គឃើញយ៉ាងនេះ តើអ្វីជាផលនៃសុបិននេះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងរជ្ជកាលនៃព្រះរាជា ដែលមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ព្រោះថា ក្នុងកាលនោះ ពួកជនមិនមានត្រកូលនឹងជាទីពេញព្រះហឫទ័យ នឹងបានជាធំ ពួកជនមានត្រកូល នឹងធ្លាក់ខ្លួនក្រីក្រ ពួកជនមិនមានត្រកូលទាំងនោះ នាំគ្នាញុំាងព្រះរាជាឲ្យកាន់យកពាក្យរបស់ខ្លួន មានកម្លាំងក្នុងទីរាជការ មានសាលាវិនិច្ឆ័យជាដើម នាំគ្នាដណ្តើមយកដីស្រែចម្ការ អារាមជាដើម ដែលជារបស់

អ្នកមានត្រកូលតាំងពីយូរមក ថានេះជារបស់ពួកយើង កាលពួកអ្នកមានត្រកូលទាំងនោះប្រកែកថា មិនមែនរបស់ពួកអ្នកទេ ជារបស់ពួកយើង នាំគ្នាមកប្តឹងសាលាវិនិច្ឆ័យជាដើម ពួកជនដែលព្រះរាជាសព្វព្រះហឫទ័យ នាំគ្នាប្រាប់ឲ្យវាយដោយផ្តៅជាដើម ចាប់ត្រង់កអូសចេញទៅ ព្រមទាំងសម្លុតគំរាមថា ពួកអាមិនស្គាល់ប្រមាណខ្លួន មករករឿងជាមួយពួកយើង ប្រយ័ត្នអញទូលព្រះរាជា ឲ្យដាក់ព្រះរាជអាជ្ញាផ្សេងៗ មានកាត់ដៃកាត់ជើងជាដើម ពួកអ្នកមានត្រកូល ភ័យខ្លាចពួកជនដែលព្រះរាជាពេញព្រះហឫទ័យ នាំគ្នាយល់ព្រមឲ្យផ្លូវដែលជារបស់ខ្លួនថា ផ្លូវទាំងនេះ បើជារបស់លោក អញ្ជើញគ្រប់គ្រងចុះ ហើយនាំគ្នាត្រឡប់មកផ្ទះ ដេកបម្រះនទៀលទៅមក សូម្បីភិក្ខុអាក្រក់ទាំងឡាយ ក៏នាំគ្នាបៀតបៀនភិក្ខុដែលមានសីលជាទីស្រឡាញ់តាមគាប់ចិត្ត ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ទាំងនោះ មិនមានទីអាស្រ័យ នាំគ្នាចូលព្រៃ រស់នៅក្នុងព្រៃស្ងាត់ ការដែលកុលបុត្រមានជាតិត្រកូលទាំងឡាយ និងភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយ ត្រូវបុគ្គលមានជាតិអាក្រក់ និងភិក្ខុលាមកទាំងឡាយ ចូលទៅប្រទូស្តយ៉ាងនេះ ដូចគ្នានឹងពួកខ្លាជំបង និងខ្លាធំទាំងឡាយ នាំគ្នាគេចទៅ ព្រោះខ្លាចហ្វូងចៀម ដូច្នោះ ភ័យមានសុបិននេះជាហេតុ មិនមានដល់មហាបពិត្រឡើយ ដោយសុបិននេះ ដែលមហាបពិត្រឃើញហើយ ប្រារព្ធអនាគតទាំងនោះ តែពួកព្រាហ្មណ៍មិនបានទាយសុបិននោះ ដោយភាពស្មោះត្រង់ក្នុងព្រះអង្គ ដោយត្រឹមត្រូវ ទាយព្រោះអាស្រ័យការចិញ្ចឹមជីវិត ព្រោះឃើញដល់អាមិសថា ពួកយើងនឹងបានទ្រព្យច្រើនៗ ។

កាលទ្រង់ព្យាករផលនៃមហាសុបិន ១៦ យ៉ាងនេះហើយ ត្រាស់ថា មហាបពិត្រ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមហាបពិត្របានសុបិននោះ ព្រះរាជាទាំងឡាយក្នុងកាលមុនៗ ក៏សុបិនហើយដូចគ្នា ។ ពួកព្រាហ្មណ៍កាន់យកសុបិនទាំងនេះ បញ្ចូលក្នុងយញ្ញពិធីយ៉ាងនេះដូចគ្នា ក្រោយមកអាស្រ័យការទូន្មាន ដែលបណ្ឌិតក្រាបទូល ទើបសួរព្រះពោធិសត្វ សូម្បីបុរាណបណ្ឌិតទាំងឡាយ លុះទាយសុបិនទាំងនេះដល់ព្រះរាជាទាំងនោះ ក៏នាំគ្នាទាយទំនងនេះឯង ។ កាលព្រះបាទបសេនទិកោសលទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយបួសជាឥសី ធ្វើអភិញ្ញាសមាបត្តិឲ្យកើតហើយ ជាអ្នកលេងឈានក្នុងហិមវន្តប្បទេស ។ ក្នុងកាលនោះ ក្នុងនគរពារាណសី ព្រះបាទព្រហ្មទត្តទ្រង់ឃើញព្រះសុបិនទាំងនេះ ដោយទំនងនេះដូចគ្នា មានព្រះតម្រាស់ត្រាស់សួរពួកព្រាហ្មណ៍ ។ ពួកព្រាហ្មណ៍ប្រារព្ធនឹងបូជាយញ្ញយ៉ាងនេះដូចគ្នា ។ បណ្ដាព្រាហ្មណ៍ទាំងនោះ បុរោហិត មានមាណពដែលជាសិស្សជាបណ្ឌិត ដែលឈ្លាស ពោលនឹងអាចារ្យថា បពិត្រលោកអាចារ្យ គម្ពីរវេទទាំង ៣ លោកអាចារ្យឲ្យខ្ញុំរៀនចប់ហើយ ក្នុងវេទទាំង ៣ គម្ពីរនេះ ពាក្យថា ការសម្លាប់មនុស្សម្នាក់ ហើយធ្វើឲ្យកើតសួស្តីដល់មនុស្សម្នាក់ទៀតមិនមានទេ មិនមែនឬ អាចារ្យឆ្លើយថា នែបា ដោយឧបាយនេះ ទ្រព្យជាច្រើនកើតដល់ពួកយើង

ពួកបា ប្រហែលជាលំបាករក្សាព្រះរាជទ្រព្យទេដឹង មាណពពោលថា បពិត្រលោកអាចារ្យ បើដូច្នោះ សូមពួកលោកធ្វើការងាររបស់ពួកលោកចុះ ខ្ញុំនឹងធ្វើអ្វីក្នុងសម្នាក់របស់ពួកលោកបាន ហើយដើរទៅរហូតដល់ព្រះរាជឧទ្យាន ។ ក្នុងថ្ងៃនោះឯង ព្រះបរមពោធិសត្វដឹងហេតុនោះ គិតថា ថ្ងៃនេះ កាលអញទៅដល់ទីកដីមនុស្ស ការរួចផុតអំពីចំណងនឹងមានដល់មហាជន ដូច្នេះហើយទើបហោះមកតាមអាកាស ចុះត្រង់ឧទ្យាននោះ អង្គុយលើផ្ទាំងថ្មដែលជាមង្គលដូចរូបបដិមាមាស ដូច្នោះ ។ មាណពចូលទៅរកព្រះពោធិសត្វ ថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាង បានធ្វើការទទួលព្រះពោធិសត្វ ។ សូម្បីព្រះពោធិសត្វក៏បានធ្វើបដិសណ្ឋារៈយ៉ាងពីរោះជាមួយមាណព ហើយសួរថា មានរឿងអ្វីមាណព ព្រះរាជាសោយរាជសម្បត្តិ ដោយធម៌ដែរឬទេ ។ មាណពប្រាប់ថា បពិត្រលោកម្ចាស់ ព្រះរាជា មានឈ្មោះថា ធម្មិករាជទេ តែពួកព្រាហ្មណ៍កំពុងដឹកព្រះអង្គទៅកាន់ផ្លូវខុស ព្រះរាជាទ្រង់ឃើញព្រះសុបិន ១៦ ត្រាស់ប្រាប់ដល់ពួកព្រាហ្មណ៍ៗ ពោលថា ពួកយើងត្រូវបូជាយញ្ញ ហើយត្រៀមរៀបចំ បពិត្រលោកម្ចាស់ បើលោកម្ចាស់ធ្វើឲ្យព្រះរាជាទ្រង់យល់ឈ្មោះថា ផលនៃសុបិននេះយ៉ាងនេះហើយ ជួយឲ្យមហាជនផុតចាកភ័យមិនគួរទេឬ ព្រះពោធិសត្វពោលថា បាមាណព អាត្មាមិនស្គាល់ព្រះរាជាៗក៏មិនស្គាល់អាត្មា បើទ្រង់យាងមកសួរក្នុងទីនេះ អាត្មាអាចប្រាប់ដល់ទ្រង់បាន ។ មាណពប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងយាងព្រះអង្គមក សូមលោកម្ចាស់បង្អង់រង់ចាំការមករបស់ខ្ញុំមួយសម្មុះសិន ឲ្យព្រះពោធិសត្វប្តេជ្ញា

ហើយ ក៏ទៅកាន់ព្រះរាជសម្នាក់ ក្រាបទូលថា បពិត្រមហារាជ តាបស ត្រាច់ទៅក្នុងអាកាសបានមួយអន្ត ចុះមកក្នុងឧទ្យានពោលថា នឹងទាយផល នៃសុបិនដែលទ្រង់ឃើញ កំពុងរង់ចាំ ព្រះរាជាទ្រង់ស្ដាប់ពាក្យមាណពនោះ ក៏ស្រួតដំណើរទៅកាន់ព្រះរាជឧទ្យានដោយបរិវារច្រើនមួយរំពេច ទ្រង់ថ្វាយ បង្គំតាបស ហើយគង់ប្រថាប់ក្នុងទីសមគួរ នាចំណែកម្ខាង មានព្រះតម្រាស់ ត្រាស់សួរថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់ដឹងផលនៃសុបិន ដែលខ្ញុំឃើញឬ ។ ព្រះពោធិសត្វពោលថា មហាបពិត្រ អាត្មាដឹង ។ ព្រះ រាជាត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់ទាយចុះ ។ ព្រះពោធិសត្វពោល ថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាទាយថ្វាយ សូមមហាបពិត្រ ត្រាស់ សុបិនតាមដែលទ្រង់ឃើញឲ្យអាត្មាភាពស្ដាប់ចុះ ។ ព្រះរាជាត្រាស់ថា សាធុ ហើយត្រាស់ថា

គោឡើងកទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ ( មាស ) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្ដែត ១ មេកង្កែប ទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយ ចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ ( រត់ទៅ ) ព្រោះភ្ញាក់ ផ្អើលដោយសេចក្ដីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចម្លែក ប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ដូច្នេះ ។

ហើយទ្រង់ត្រាស់ប្រាប់សុបិនតាមនិយម ដែលព្រះបាទបសេនទិកោសល ត្រាស់ប្រាប់នោះឯង សូម្បីព្រះពោធិសត្វ ក៏ព្យាករផលនៃសុបិនទាំងនោះដោយពិស្តារតាមទំនងដែលព្រះសាស្តាទ្រង់ទាយក្នុងឥឡូវនេះឯង ក្នុងទីបំផុត ថ្វាយព្រះពរដូច្នេះដោយខ្លួនឯងថា បរិយាយចម្លែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ដូច្នេះ ។

អធិប្បាយក្នុងពាក្យនោះ មានដូច្នេះ គឺមហាបពិត្រ ផលនៃសុបិនទាំងនោះ មានដូច្នេះ គឺការបូជាយញ្ញ ដែលកំពុងប្រព្រឹត្តទៅដើម្បីបក់ផាត់ព្រះសុបិនទាំងនោះ រមែងប្រព្រឹត្តទៅខុសសេចក្តីពិត លោកអធិប្បាយថា រមែងប្រព្រឹត្តទៅខុសចាកសេចក្តីពិត ។ ព្រោះហេតុអ្វី ព្រោះថា ផលនៃសុបិនទាំងនេះ នឹងមានក្នុងកាលដែលលោកដល់នូវសេចក្តីសាបសូន្យ គឺក្នុងកាលដែលកាន់យកមិនមែនហេតុ ថាជាហេតុ ក្នុងកាលដែលលះបង់ហេតុចោល ថាមិនមែនហេតុ ក្នុងកាលកាន់យកការមិនពិត ថាពិត ក្នុងកាលដែលលះបង់សេចក្តីពិត ថាមិនពិត ក្នុងកាលដែលពួកអលជ្ជីមានច្រើនឡើង និងក្នុងកាលដែលពួកលជ្ជីថមថយចុះ មិនមានក្នុងយុគនេះ សេចក្តីថា ផលរបស់សុបិនទាំងនេះ មិនមានក្នុងឥឡូវនេះ គឺក្នុងរជ្ជកាលរបស់មហាបពិត្រទេ ឬក្នុងសាសនារបស់តថាគតនេះ ក្នុងយុគនេះ គឺក្នុងជួរបុរសបច្ចុប្បន្ននេះ ព្រោះហេតុនោះ ការបូជាយញ្ញដែលកំពុងប្រព្រឹត្តទៅ ដើម្បីរំដោះផលនៃព្រះសុបិនទាំងនេះ ទើបប្រព្រឹត្តទៅដោយឃ្លៀងឃ្លាតចាកសេចក្តីពិត សូមទ្រង់លើកនូវការបូជាយញ្ញនោះចោលចុះ ភ័យ ឬអន្តរាយដែលមានព្រោះព្រះសុបិននេះជា

ហេតុ មិនមានដល់មហាបពិត្រឡើយ ។ ព្រះមហាបុរសធ្វើព្រះរាជាឲ្យស្បើយព្រះហឫទ័យ ដោះមហាជនអំពីចំណងហើយ ហោះឡើងទៅកាន់អាកាស ប្រទានឱវាទដល់ព្រះរាជាឲ្យតាំងមាំក្នុងសីល ៥ ហើយថ្វាយព្រះពរថា តាំងអំពីនេះទៅ មហាបពិត្រ កុំផ្សំគំនិតជាមួយព្រាហ្មណ៍ដែលបូជាយញ្ញ ដែលឈ្មោះថា បសុឃាតយញ្ញ គឺការសម្លាប់សត្វតទៅទៀតឡើយ កាលសម្តែងធម៌ហើយ ត្រឡប់ទៅលំនៅរបស់ខ្លួនតាមអាកាសនោះឯង ។ ឯព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យ មានទានជាដើម ហើយយាងទៅតាមយថាកម្ម ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ឲ្យព្រះបាទបសេនទិកោសលលើកលែងនូវការបូជាយញ្ញ ដោយព្រះពុទ្ធតម្រាស់ថា ព្រោះព្រះសុបិនជាបច្ច័យ ភ័យមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រលើកលែងនូវការបូជាយញ្ញចុះ ព្រះរាជទានជីវិតដល់មហាជន រួចទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានជាអានន្ទក្នុងកាលឥឡូវនេះ មាណពបានមកជាសារីបុត្រ ឯតាបស គឺតថាគតនេះឯង ។

កាលព្រះសាស្តាបរិនិព្វានហើយ ព្រះសង្គីតិកាចារ្យទាំងឡាយ លើកបទទាំង ៣ មានឧសភាជាដើមឡើងកាន់អដ្ឋកថា ពោលបទទាំង ៥ មាន **លាវុធិ** ជាដើម លើកឡើងកាន់បាលីឯកនិបាត ដោយប្រការដូច្នេះ ។

**អដ្ឋកថា មហាសុបិនជាតក ចប់**

# សុត្តន្តបិដក

## ផលិសជាតក

[ ៧៨ ] ( ជាងកោរកាត់ពោធិសត្វពោលថា ) ជនទាំង ២ នាក់ខ្វក ជនទាំង ២ នាក់ក្ញែង ជនទាំង ២ នាក់មានភ្នែកស្រលៀង ពកកើត ( លើក្បាល ) របស់ជនទាំង ២ នាក់ ខ្ញុំព្រះអង្គមិនស្គាល់ ( អ្នកណា ) ជាផលិសសេដ្ឋីទេ ។

ផលិសជាតកទី ៨ ចប់

# អដ្ឋកថា

## ឥល្លិសជាតក

[ ៧៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធ សេដ្ឋីឈ្មោះមច្ឆរិយកោសិយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧភោ ខញ្ជា** ដូច្នេះជាដើម ។

បានឮថា មិនឆ្ងាយអំពីនគររាជគ្រឹះ មាននិគមឈ្មោះសក្ករៈ ក្នុងនិគមនោះ មានសេដ្ឋីម្នាក់ ឈ្មោះមច្ឆរិកោសិយ មានសម្បត្តិ ៨០ កោដិ អាស្រ័យនៅ ។ សេដ្ឋីនោះយកចុងស្បូវជ្រលក់ប្រេងឲ្យទានដល់មនុស្សដទៃ ត្រឹមតែមួយតំណក់ក៏មិនមាន ទាំងខ្លួនឯងក៏មិនព្រមបរិភោគ ដោយប្រការដូច្នេះ ។ សម្បត្តិរបស់គាត់មិនបានជាប្រយោជន៍ដល់បុត្រ និងភរិយាជាដើមឡើយ មួយអន្លើដោយសមណព្រាហ្មណ៍ មិនបានពាល់ត្រូវ ឬប្រើប្រាស់ឡើយ ដូចស្រះបោក្ខរណីដែលអារក្សទឹកគ្រប់គ្រង ដូច្នោះ ។

ថ្ងៃមួយ ព្រះបរមសាស្តា ចេញអំពីព្រះមហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វដែលជាពូជល្អមទូន្មានឲ្យត្រាស់ដឹងបានពេញលោកធាតុទាំងមូល បានទតឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់សេដ្ឋីមួយអន្លើដោយភរិយា ដែលនៅឆ្ងាយដល់ទៅ ៤៥ យោជន៍ ។ ក្នុងកាលមុនបន្ទាប់អំពីថ្ងៃនោះ លោកសេដ្ឋីបានទៅកាន់ព្រះរាជវាំងគាល់ព្រះរាជា លុះត្រឡប់មកវិញ ឃើញអ្នកជនបទម្នាក់កំពុងស្រេកឃ្លាន អង្គុយបរិភោគនំអំបែងផ្សំដោយសណ្តែក កើតចំណង់ក្នុងរសនំនោះ ទៅដល់ផ្ទះរបស់ខ្លួនហើយ ត្រិះរិះថា បើអញប្រាប់ថា ចង់ស៊ីនំអំបែង មនុស្សជាច្រើន នឹងចង់

ស៊ីជាមួយអញ បើដូច្នេះ ទ្រព្យ មានអង្ករ សប្បិ ទឹកអំពៅរបស់អញ នឹងត្រូវលស់ទៅច្រើន អញនឹងមិនប្រាប់ដល់អ្នកណា ហើយអត់សង្កត់នូវចំណង់ត្រាប់ទៅ ។ លុះយូរទៅ ក៏កើតរោគស្គមលឿង មានខ្លួនរវាមដោយសរសៃ ពេលនោះ ក៏មិនអាចអត់ទ្រាំបាន ទើបចូលដេកសំកុកលើគ្រែតូច តែទោះជាយ៉ាងនោះ ក៏មិនប្រាប់ដល់បុគ្គលណា ព្រោះខ្លាចអស់ទ្រព្យ ។ ឯភរិយាចូលទៅរក អង្អែលខ្នង ពោលថា នែអ្នក អ្នកមិនសប្បាយឬ ។ សេដ្ឋីពោលថា អញមិនឈឺ មិនថ្កាត់អ្វីទេ ភរិយាពោលថា ព្រះរាជាទ្រង់ពិរោធនឹងអ្នកឬ ។ សេដ្ឋីពោលថា សូម្បីព្រះរាជាក៏មិនក្រោធនឹងអញ ភរិយាពោលថា បើដូច្នោះ កូនប្រុសស្រី បរិវារ ទាសកម្មករជាដើម នាំគ្នាធ្វើអ្វីមួយដែលមិនគាប់ចិត្តអ្នកឬ សេដ្ឋីពោលថា រឿងនោះក៏មិនមានដល់អញ ។ ភរិយាសួរថា អ្នកចង់ពិសាអ្វីមួយទេដឹង សេដ្ឋី លុះភរិយាពោលយ៉ាងនេះ ក៏មិននិយាយអ្វី ដេកស្ងៀមនោះឯង ព្រោះខ្លាចខូចទ្រព្យ ពេលនោះ ទើបភរិយាពោលនឹងសេដ្ឋីថា សូមអ្នកប្រាប់មកចុះ អ្នកចង់បរិភោគអ្វី ។ សេដ្ឋីធ្វើអាកប្បកិរិយាមិនចង់និយាយស្តី ហើយពោលថា អញចង់ស៊ីរបស់ម្យ៉ាង ភរិយាពោលថា តើអ្នកចង់បរិភោគអ្វី ។ សេដ្ឋីពោលថា អញចង់ស៊ីនំអំបែង ភរិយាពោលថា បើដូច្នោះ ហេតុអ្វី ទើបមិនប្រាប់ អ្នកជាមនុស្សក្រីក្រឬ ឥឡូវនេះ ខ្ញុំនឹងចៀននំអំបែងឲ្យច្រើន ល្មមចែកដល់អ្នកនិគមទូទៅ សេដ្ឋីពោលថា ឲ្យដល់ពួកវានោះធ្វើអ្វី ពួកវាធ្វើការងាររបស់ខ្លួន ហើយស៊ីខ្លួនឯង ។ ភរិយាពោលថា បើដូច្នោះ ចៀនល្មមចែកដល់មនុស្សមួយច្រកផ្លូវ ។ សេដ្ឋីពោលថា អញដឹង

ថា នាងមានទ្រព្យច្រើន ។ កិរិយាពោលថា បើដូច្នោះ ចៀនល្មមចែកដល់មនុស្សទាំងពួង ដែលនៅក្បែរខាង សេដ្ឋីពោលថា អញដឹងថា នាងមានអធ្យាស្រ័យទូលាយ កិរិយាពោលថា បើដូច្នោះ ចៀនត្រឹមតែចែកកូនប្រពន្ធក្នុងផ្ទះប៉ុណ្ណោះ សេដ្ឋីពោលថា នាងទៅទាក់ទាមជាមួយពួកនោះធ្វើអ្វី កិរិយាពោលថា បើដូច្នោះ ចៀនល្មមទទួលទានរវាងអ្នក និងខ្ញុំប៉ុណ្ណោះ សេដ្ឋីពោលថា នាងមកទាក់ទាមធ្វើអ្វីជាមួយអញ កិរិយាពោលថា បើដូច្នោះ ចៀនល្មមទទួលទានតែអ្នកម្នាក់ចុះ សេដ្ឋីពោលថា បើចៀនក្នុងទីនេះ មនុស្សជាច្រើននឹងនាំគ្នាចង់បរិភោគដែរ ចូរនាងជញ្ជូនចុងអង្ករ រើសអង្ករដែលល្អចេញ រៀបចំចង្ក្រាន និងអំបែងជាដើម ជញ្ជូនទៅ ដោយកាន់យកខីរៈ សប្បិ ទឹកឃ្មុំ ទឹកអំពៅ បន្តិចបន្តួចឡើងទៅកាន់ប្រាសាទខាងលើជាន់ទី ៧ ហើយចៀនចុះ អញម្នាក់នឹងអង្គុយស៊ីក្នុងទីនោះ ។ កិរិយាទទួលពាក្យហើយ ឲ្យមនុស្សជញ្ជូនរបស់របរដែលត្រូវប្រើឡើងកាន់ប្រាសាទ ដេញទាសីចុះ ឲ្យអញ្ជើញលោកសេដ្ឋីឡើងទៅ ។ សេដ្ឋីបិទទ្វារទី ១ ដាក់គន្លឹះគ្រប់កន្លែង ឡើងកាន់ផ្ទៃប្រាសាទជាន់ទី ៧ សូម្បីក្នុងជាន់ទី ៧ ក៏បិទទ្វារ ហើយអង្គុយរង់ចាំ ។ ឯកិរិយារបស់លោកសេដ្ឋីបង្កាត់ភ្លើងក្នុងជើងក្រាន ផ្ដើមចៀននំ ។

សម័យនោះ ព្រះបរមសាស្ដាត្រាស់ហៅព្រះមហាមោគ្គល្លានអំពីព្រលឹមត្រាស់ថា ម្នាលមោគ្គល្លាន សេដ្ឋីកំណាញ់ក្នុងសក្ករនិគម មិនឆ្ងាយអំពីនគររាជគ្រឹះនេះ ត្រិះរិះថា អញនឹងបរិភោគនំអំបែង ខ្លាចអ្នកដទៃៗ ឃើញ ឲ្យកិរិយាចៀននំអំបែងលើប្រាសាទជាន់ទី ៧ ចូរអ្នកទៅទីនោះ ទូន្មានសេដ្ឋីឲ្យ

អស់ព្យសន៍ ហើយឲ្យស្វាមី និងកិរិយាទាំងគូជញ្ជូននំ សប្បិ ទឹកឃ្មុំ ទឹកអំពៅមកកាន់វត្តជេតពនដោយកម្លាំងរបស់ខ្លួនចុះ ថ្ងៃនេះ តថាគត និងភិក្ខុ ៥០០ រង់ចាំក្នុងវិហារ នឹងធ្វើភត្តកិច្ចដោយនំនោះឯង ។ ព្រះថេរៈទូលស្នងព្រះតម្រាស់របស់ព្រះសាស្តាថា សាធុ ហើយទៅកាន់និគម ដោយកម្លាំងឫទ្ធិក្នុងវេលាពេចនោះឯង គ្រងស្បង់ចីវររៀបរយ ឈរក្នុងអាកាស ត្រង់មាត់បង្អួច ដូចរូបបដិមាកែវមណីអណ្តែតមក ដូច្នោះ ។ ព្រោះឃើញព្រះថេរៈចូលទៅប៉ុណ្ណោះ សេដ្ឋីរន្ធត់ចិត្ត គិតថា ព្រោះខ្លាចមនុស្សប្រភេទនេះឯង ទើបអញមកទីនេះ តែភិក្ខុនេះ មកកាន់មាត់បង្អួចទាល់តែបាន មិនឃើញរបស់ដែលល្មមឲ្យបាន ក៏បន្លឺសំឡេង តដៈ តដៈ ចេញមក ដោយការចង្អៀងចង្អល់ ដូចយកដុំអំបិលដាក់ក្នុងគំនរភ្លើងផ្ទុះប្រឹះប្រឹះ ដូច្នោះហើយ ពោលយ៉ាងនេះថា នែសមណៈ លោកឈរក្នុងអាកាស នឹងបានអ្វី ទោះបីដើរទៅដើរមក បង្ហាញស្នាមជើងក្នុងអាកាសដែលមិនមានស្នាមបាន ក៏មិនបានអ្វីនោះឯង ។ ព្រះថេរៈដើរចង្ក្រមទៅមកក្នុងទីនោះឯង ។ សេដ្ឋីពោលថា លោកចង្ក្រមនឹងបានអ្វី ទោះបីលោកអង្គុយពត់ភ្នែនក្នុងអាកាស ក៏មិនបានអ្វីឡើយ ។ ព្រះថេរៈអង្គុយពត់ភ្នែនហើយ ។ កាលនោះសេដ្ឋីពោលថា អង្គុយហើយ នឹងបានអ្វី ទោះបីមកឈរត្រង់ធរណីបង្អួច ក៏មិនបានអ្វីឡើយ ។ ព្រះថេរៈបានមកឈរត្រង់ធរណីបង្អួច ។ គ្រានោះ សេដ្ឋីពោលថា ទោះបីឈរត្រង់ធរណីបង្អួចហើយ តើនឹងបានអ្វី ទោះបីបង្ហុយផ្សែង ក៏មិនបានអ្វី ។ ទើបព្រះថេរៈបង្ហុយផ្សែង ប្រាសាទទាំងមូលមានផ្សែងទូទៅ ហាក់ដូចជាមុតភ្នែករបស់សេដ្ឋីៗ មិន

ហ៊ានពោលថា ទោះបីភ្លើងឆេះ ក៏គង់មិនបាន ព្រោះខ្លាចភ្លើងឆេះផ្ទះ ត្រិះរិះថា សមណៈនេះ ជាប់ជំពាក់ខ្លាំង បើមិនបាន ប្រហែលជាមិនព្រមទៅ អញនឹងឲ្យនំមួយចំណិតដល់សមណៈនេះ ដូច្នេះហើយ ទើបប្រាប់ភរិយាថា នែនាង ចូរនាងចៀននំតូចមួយចំណិតឲ្យសមណៈនេះ ហើយបញ្ជូនលោកទៅចុះ ។ នាងដួសម្សៅបន្តិចប៉ុណ្ណោះ ដាក់ក្នុងអំបែង នំក៏ពេញអំបែងទាំងអស់ ។ សេដ្ឋីឃើញនំនោះហើយ ពោលថា ប្រហែលជាដាក់ម្សៅច្រើនពេក ហើយយកចុងវែកនោះឯង ដួសម្សៅបន្តិច ដាក់ខ្លួនឯង នំក៏រីតតែធំជាងមុន មិនថា ដាក់បន្ទះមួយណា បន្ទះនោះៗ សុទ្ធតែធំទាំងអស់ សេដ្ឋីអស់តម្រិះ ទើបប្រាប់ភរិយាថា នែនាង ចូរឲ្យនំដល់សមណៈនេះមួយចំណិតចុះ កាលនាងចាប់នំមួយលើកឡើងចេញអំពីល្អី នំទាំងអស់ក៏ជាប់គ្នា នាងប្រាប់សេដ្ឋីថា នែអ្នក នំទាំងអស់ជាប់គ្នាតែមួយ ខ្ញុំមិនអាចបេះបានទេ ។ សេដ្ឋីពោលថា ទុកឲ្យអញធ្វើខ្លួនឯង ក៏មិនអាចបេះបាន ។ សូម្បីជនទាំងពីរ ចាប់នំម្នាក់ម្ខាងទាញ ក៏មិនអាចបំបែកនំនោះឲ្យដាច់ពីគ្នាបាន កាលសេដ្ឋីព្យាយាមហែកនំនោះឯង ញើសក៏ហូរជោកប្រាណ ចំណង់ក៏អស់ទៅ ។ កាលនោះ សេដ្ឋីនិយាយនឹងភរិយាថា នែនាង អញមិនត្រូវការនំ ចូរនាងឲ្យដល់ភិក្ខុនេះ ទាំងល្អីចុះ ។ ទើបនាងលើកល្អីទៅរកព្រះថេរៈ ហើយប្រគេននំទាំងអស់ដល់ព្រះថេរៈ ។

ព្រះថេរៈកាលសម្តែងធម៌ដល់ជនទាំង ២ ក៏ពោលដល់គុណរបស់ព្រះរតនៈទាំង ៣ ហើយសម្តែងផលនៃការឲ្យទានជាដើមថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាមានផល ជាក់ច្បាស់ហើយ ហាក់បីដូចសម្តែងឲ្យ

ឃើញព្រះចន្ទពេញវង់ អណ្តែតលើអាកាស ដូច្នោះ ។ លុះស្តាប់ធម៌ហើយ មហាសេដ្ឋីមានចិត្តជ្រះថ្លា ពោលថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់ គង់លើបល្ល័ង្កនេះឆាន់នំចុះ ព្រះថេរៈពោលថា នែលោកសេដ្ឋី ព្រះសម្មាសម្ពុទ្ធត្រាស់ថា ទ្រង់នឹងឆាន់នំ គង់ប្រថាប់ក្នុងវិហារជាមួយភិក្ខុ ៥០០ រូប បើអ្នកពេញចិត្ត ចូរឲ្យភរិយាកាន់នំ និងសប្បិជាដើម យើងនឹងទៅកាន់សម្នាក់ព្រះសាស្តា សេដ្ឋីសួរថា បពិត្រលោកម្ចាស់ ឥឡូវនេះ ព្រះសាស្តាអង្គនោះ គង់នៅឯណា ព្រះថេរៈឆ្លើយថា ព្រះអង្គគង់នៅក្នុងជេតពនមហាវិហារ ចម្ងាយអំពីទីនេះ ៤៥ យោជន៍ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅទីឆ្ងាយមានប្រមាណប៉ុណ្ណោះ ដោយមិនឲ្យហួសពេលភត្តបានដូចម្តេច ព្រះថេរៈពោលថា បើលោកសេដ្ឋីមានការពេញចិត្ត អាត្មានឹងនាំទៅដោយកម្លាំងឫទ្ធិរបស់ខ្លួន ក្បាលជណ្តើរត្រង់ប្រាសាទរបស់អ្នក នឹងប្រាកដក្នុងទីតាំងរបស់ខ្លួននោះឯង តែទីបំផុតនៃជណ្តើរ នឹងនៅត្រង់ខ្លោងទ្វារនៃវិហារជេតពន អាត្មានឹងនាំអ្នកទៅវិហារជេតពន ដោយរយៈពេលស្មើនឹងកាលដែលចុះអំពីប្រាសាទជាន់លើ មកកាន់ប្រាសាទជាន់ក្រោម សេដ្ឋីទទួលថា សាធុ លោកម្ចាស់ ។

ព្រះថេរៈអធិដ្ឋានថា ក្បាលជណ្តើរ ចូរនៅត្រង់កន្លែងដើម ជើងជណ្តើរ ចូរមានត្រង់ខ្លោងទ្វារវត្តជេតពនចុះ ការអធិដ្ឋានរបស់ព្រះថេរៈ សម្រេចយ៉ាងនោះឯង ដោយអាការយ៉ាងនេះ ។ ព្រះថេរៈនាំសេដ្ឋី និងភរិយាដល់វត្តជេតពន រហ័សដូចចុះពីប្រាសាទជាន់លើ ដល់ប្រាសាទជាន់ក្រោមនោះឯង ។ សេដ្ឋី និងភរិយាទាំង ២ ចូលគាល់ព្រះសាស្តា ក្រាបទូលភត្តកាល ព្រះ

សាស្តាយាងចូលកាន់រោងធាន់ គង់លើបវរពុទ្ធាសនៈដែលរៀបចំ មួយអន្លើ ដោយភិក្ខុសង្ឃ ។ សេដ្ឋីបានថ្វាយទក្ខិណោទកដល់ព្រះសង្ឃ មានព្រះពុទ្ធ ជាប្រធាន ភរិយារបស់លោកសេដ្ឋី ក៏ដាក់នំក្នុងបាត្ររបស់ព្រះតថាគត ព្រះ សាស្តាទ្រង់ទទួលនំគ្រប់គ្រាន់ដល់បំណងរបស់ទ្រង់ ។ សូម្បីភិក្ខុ ៥០០ រូប ក៏ដូចគ្នា ។ សូម្បីលោកសេដ្ឋីក៏ដើរប្រគេនទឹកដោះ សប្បិ ទឹកឃ្មុំ ទឹកអំពៅ និង ស្ករក្រាមជាដើម ។ ព្រះសាស្តា មួយអន្លើដោយភិក្ខុ ៥០០ ធ្វើភត្តកិច្ចស្រេច ហើយ ។ សេដ្ឋី និងភរិយាបរិភោគនំគ្រប់គ្រាន់ដល់សេចក្តីត្រូវការ ការអស់ នូវនំទាំងឡាយមិនប្រាកដឡើយ សូម្បីប្រគេនដល់ពួកភិក្ខុ និងអ្នកស៊ីដែល ក្នុងវិហារទាំងមូលហើយ ការអស់មិនប្រាកដឡើយ ។ សេដ្ឋី និងភរិយានាំ គ្នាក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នំមិនអស់ទេ ។ ព្រះ សាស្តាត្រាស់ថា បើដូច្នោះ ចូរអ្នកចាក់ចោលត្រង់ខ្លោងទ្វារវត្តជេតពនចុះ ស្វាមីភរិយាទាំង ២ ក៏ជញ្ជូនទៅចោលត្រង់ជ្រុង មិនឆ្ងាយអំពីខ្លោងទ្វារ ទើប ទីនោះប្រាកដឈ្មោះថា ជ្រុងនំអំបែងរហូតដល់សព្វថ្ងៃនេះ ។ មហាសេដ្ឋី និង ភរិយានាំគ្នាចូលគាល់ព្រះសាស្តា ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះ សាស្តាទ្រង់បានធ្វើអនុមោទនា ក្នុងវេលាចប់អនុមោទនា សេដ្ឋី និងភរិយាទាំង ២ នាក់ ក៏តាំងនៅក្នុងសោតាបត្តិផល នាំគ្នាថ្វាយបង្គំព្រះបរមសាស្តា ឈាន ឡើងកាន់ជណ្តើរដល់ប្រាសាទរបស់ខ្លួននោះឯង ។ ចាប់តាំងអំពីកាលនោះមក មហាសេដ្ឋីក៏បរិច្ចាគទ្រព្យ ៨០ កោដិក្នុងព្រះពុទ្ធសាសនានោះឯង ។

ស្អែកឡើង កាលព្រះសម្មាសម្ពុទ្ធយាងបិណ្ឌបាតក្នុងនគរសាវត្ថី ហើយ

យាងមកកាន់វត្តជេតពន ប្រទានសុគតោវាទដល់ពួកភិក្ខុ ហើយយាងចូលកាន់ព្រះគន្ធកុដិ ទ្រង់សម្ងំក្នុងពេលល្ងាច ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា អង្គុយពោលដល់គុណរបស់ព្រះថេរៈថា អាវុសោទាំងឡាយ ចូរមើលអានុភាពរបស់ព្រះមហាមោគ្គល្លានត្ថេរចុះ លោកមិនបានទម្លាយសទ្ធា មិនបានពាល់ត្រូវភោគទ្រព្យ ទូន្មានសេដ្ឋីដែលកំណាញ់ស្វិតមួយភ្លែតប៉ុណ្ណោះ ធ្វើឲ្យអស់ព្យសន៍បាន ឲ្យកាន់យកនំមកវត្តជេតពន គាល់ព្រះសាស្ដា ឲ្យតាំងនៅក្នុងសោតាបត្តិផល ឱ ! ព្រះថេរៈមានអានុភាពច្រើន ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដែលទូន្មានត្រកូលមិនត្រូវបៀតបៀនត្រកូលឲ្យលំបាក គួរធ្វើដូចកមរជាតិ ដែលក្រេបកេសរផ្កាចូលទៅជិតហើយ ឲ្យជននោះដឹងពុទ្ធគុណ កាលទ្រង់សរសើរព្រះថេរៈត្រាស់ព្រះគាថាក្នុងធម្មបទថា

កមរជាតិ មិនធ្វើផ្កាឈើ ដែលមានពណ៌ និងក្លិនឲ្យវិនាសទេ
ក្រេបយកតែរសហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់
ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ដូច្នេះ ។

ដើម្បីប្រកាសគុណរបស់ព្រះថេរៈឲ្យក្រៃលែងឡើង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលមច្ឆរិយសេដ្ឋីត្រូវមោគ្គល្លានទូន្មាន សូម្បីក្នុងកាលមុន មោគ្គល្លានក៏ធ្លាប់ទូន្មានឲ្យដឹងការសម្ពន្ធ

នៃកម្ម និងផលនៃកម្មមកហើយដូចគ្នា ហើយទ្រង់នាំរឿងក្នុងអតីតមក សាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី សេដ្ឋីឈ្មោះឥល្លិស មានទ្រព្យ ៨០ កោដិ មានរូបរាងប្រកបដោយបុរិសទោសច្រើនស្ថាន ជាមនុស្សខ្ញក ខ្វិន ភ្នែកស្រលៀង មិនមានសទ្ធា មិនជ្រះថ្លា កំណាញ់ មិនឲ្យដល់អ្នកដទៃ និងមិនបរិភោគដោយខ្លួនឯង មានក្នុងនគរពារាណសី ផ្ទះរបស់សេដ្ឋីនោះ ដូចគ្នានឹងស្រះបោក្ខរណីដែលអារក្ខគ្រប់គ្រង តែមាតាបិតារបស់លោកសេដ្ឋី ជាអ្នកឲ្យទាន ជាទានបតីមក ៧ ជួរត្រកូល កាលឥល្លិសនោះបានតំណែងសេដ្ឋី ក៏ទម្លាយវង្សត្រកូលដុតរោងទាន វាយបណ្ដេញពួកយាចក សន្សំតែទ្រព្យប៉ុណ្ណោះ ថ្ងៃមួយ ឥល្លិសនោះទៅគាល់ព្រះរាជា ខណៈដើរមកផ្ទះរបស់ខ្លួន ឃើញអ្នកស្រុកក្រៅម្នាក់ហត់នឿយអស់កម្លាំង ព្រោះការដើរផ្លូវ កាន់ដបស្រាមួយមកអង្គុយលើគ្រែតូច ច្រួចស្រាដាក់កែវសម្រាប់ផឹក ហើយកំពុងផឹក ក្លែមដោយសម្ងួតត្រីកន្តបង់ប្រហុក នឹកចង់ផឹក គិតថា បើអញផឹកសុរា កាលកំពុងផឹក មនុស្សជាច្រើន នឹងចង់ផឹកដែរ ការអស់នូវទ្រព្យនឹងកើតមានដល់អញ ដោយអាការយ៉ាងនេះ ៗ ឥល្លិសសេដ្ឋីនោះ អត់ធន់នូវចំណង់ កាលវេលាកន្លងទៅ មិនអាចអត់ធន់បាន ក៏មានខ្លួនស្គមលឿងរវាមដោយសរសៃ ដូចសំឡីកកប្បាសដែលទុំហើយ ថ្ងៃមួយ ទើបចូលបន្ទប់ ដេកសំកុកត្រង់គ្រែតូច ភរិយាចូលទៅអង្អែលខ្នង សួរថា អ្នកមិនសប្បាយឬហ្ន៎ ៗ ពាក្យទាំងអស់គប្បីជ្រាប

តាមទំនងដែលបានពោលហើយខាងដើមនោះឯង ។ កាលកិរិយាពោលថា បើដូច្នោះ ខ្ញុំនឹងបិតស្រាឲ្យល្មមដល់អ្នកម្នាក់ឯងប៉ុណ្ណោះ ។ សេដ្ឋីត្រិះរិះថា កាលបិតស្រាក្នុងផ្ទះ មនុស្សក្នុងផ្ទះ មនុស្សជាច្រើននឹងចង់ផឹកដែរ បើឲ្យទៅទិញមកអំពីផ្សារ ក៏មិនអាចអង្គុយផឹកក្នុងទីនេះបាន ទើបឲ្យប្រាក់ទៅប្រមាណមួយមាសក ឲ្យទៅទិញស្រាមកអំពីផ្សារមួយជប ឲ្យអ្នកបម្រើកាន់ចេញអំពីក្រុង ដល់ច្រាំងស្ទឹង ចូលទៅកាន់គុម្ពោតឈើមួយគុម្ពក្បែរផ្លូវធំ ឲ្យអ្នកបម្រើដាក់ជបស្រាទុកហើយ ពោលថា ចូរបាទៅចុះ ឲ្យអ្នកបម្រើអង្គុយឆ្ងាយ ប្រូចស្រាដាក់កែវ ផ្ដើមផឹកស្រា ។

ចំណែកបិតារបស់ឥល្លិសសេដ្ឋីនោះ កើតជាសក្កទេវរាជក្នុងទេវលោក ព្រោះធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើម ខណៈនោះទ្រង់ត្រិះរិះថា ទានរបស់អញនៅប្រព្រឹត្តទៅដែរឬហ្ន៎ កាលឃើញទានមិនប្រព្រឹត្តទៅ និងឃើញកូនទម្លាយវង្សចេញ ដុតរោងទាន បណ្ដេញពួកយាចក តាំងនៅក្នុងសេចក្ដីកំណាញ់ កំពុងចូលគុម្ពឈើ ផឹកស្រាម្នាក់ឯង ព្រោះខ្លាចត្រូវឲ្យដល់អ្នកដទៃ ទ្រង់ព្រះតម្រិះថា អញនឹងទៅបំបាក់ និងទូន្មានឥល្លិសនោះ ឲ្យដឹងការសម្ពន្ធនៃកម្ម និងផលរបស់កម្ម ហើយឲ្យបំពេញទាន ធ្វើឲ្យឥល្លិសសមគួរនឹងកើតក្នុងទេវលោក ដូច្នេះហើយ យាងចុះមកកាន់ស្ថានមនុស្ស ទ្រង់និម្មិតអត្តភាពជាមនុស្សខ្ចក ខ្វិន និងភ្នែកស្រលៀង ដូចគ្នានឹងឥល្លិសសេដ្ឋី ចូលទៅកាន់នគរពារាណសី ឈប់ក្នុងទ្វារព្រះរាជនិវេសន៍ ឲ្យក្រាបទូលការដែលខ្លួនមក កាលបានទទួលព្រះបរមរាជានុញ្ញាតថា ចូលមកចុះ ទើបចូលទៅ

ថ្វាយបង្គំព្រះរាជា ហើយឈរ ។ ព្រះរាជាមានព្រះតម្រាស់សួរថា នែលោក សេដ្ឋី ហេតុអ្វី ទើបលោកមកខុសកាល ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំមកដោយបំណងថា ក្នុងផ្ទះរបស់ទូលបង្គំ មានទ្រព្យប្រមាណ ៨០ កោដិ សូមទ្រង់ជញ្ជូនចូលមកដាក់ក្នុងឃ្លាំងរបស់ព្រះអង្គចុះ ។ ព្រះរាជាត្រាស់ថា កុំឡើយលោកសេដ្ឋី ទ្រព្យក្នុងវាំងរបស់យើង មានច្រើនជាងទ្រព្យរបស់អ្នក ។ សេដ្ឋីទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើទ្រង់មិនត្រូវការ ខ្ញុំព្រះអង្គនឹងចំណាយទ្រព្យ ឲ្យទានតាមគាប់ចិត្ត ។ ព្រះរាជាត្រាស់ថា ឲ្យចុះលោកសេដ្ឋី ។ ឥន្ទនិម្មិតទទួលបរមរាជានុញ្ញាតហើយ ថ្វាយបង្គំព្រះរាជា ចេញទៅកាន់ផ្ទះរបស់ឥល្លិសសេដ្ឋី ។ ពួកមនុស្សជាឧបដ្ឋាកគ្រប់គ្នា នាំគ្នាចោមរោម បុគ្គលម្នាក់ដែលអាចដឹងថា នេះមិនមែនឥល្លិសសេដ្ឋី មិនមាន ។

កាលសក្កទេវរាជចូលកាន់ផ្ទះហើយ ឈរត្រង់ធរណីទ្វារខាងក្នុងផ្ទះ ប្រាប់អ្នកយាមទ្វារថា អ្នកដទៃមានរូបដូចយើងចូលមក ពោលថា នេះផ្ទះរបស់យើង ពួកអ្នកគប្បីវាយខ្នងរបស់បុគ្គលនោះ ហើយបណ្តេញចេញទៅ ឡើងកាន់ប្រាសាទ អង្គុយលើអាសនៈដ៏ឱឡារ ឲ្យអញ្ជើញភរិយាលោកសេដ្ឋីមក សម្តែងអាការដូចលោកសេដ្ឋីមិនខុស ពោលថា នែនាង យើងនឹងឲ្យទានជាមួយគ្នាចុះ ។ ភរិយា បុត្រ ធីតា ទាសកម្មករបានឮពាក្យរបស់សេដ្ឋីហើយ នាំគ្នាពោលថា អស់កាលយូរបែបនេះ ការគិតឲ្យទានមិនមានឡើយ តែថ្ងៃនេះ ផឹកស្រាហើយ មានចិត្តល្អចង់ឲ្យទាន ពេលនោះ ភរិយាសេដ្ឋីពោលថា នែអ្នក អញ្ជើញអ្នកឲ្យទានតាមគាប់ចិត្តចុះ ។ សេដ្ឋីនិម្មិតពោលថា បើដូច្នោះ

ចូរហៅអ្នកវាយស្គរមក ឲ្យនាំស្គរទៅវាយប្រកាសពេញព្រះនគរថា អ្នកណាត្រូវការប្រាក់មាស កែវមណី និងមុក្តាជាដើម ចូរនាំគ្នាទៅកាន់ផ្ទះរបស់ឥល្លិសសេដ្ឋី អ្នកវាយស្គរបានធ្វើយ៉ាងនោះហើយ មហាជននាំគ្នាកាន់ភាជនៈមានល្អី បាវជាដើម ទៅប្រជុំគ្នាត្រង់ទ្វារផ្ទះ ។ សក្កទេវរាជទ្រង់ឲ្យបើកឃ្លាំងដែលពេញដោយរតនៈ ៧ ប្រការច្រើនឃ្លាំង ពោលថា យើងឲ្យដល់ពួកអ្នក ចូរពួកអ្នកនាំគ្នាជញ្ជូនយកទៅតាមត្រូវការចុះ ។ មហាជននាំគ្នាជញ្ជូនទ្រព្យចេញទៅគរត្រង់ផ្ទៃរោង ដាក់ពេញភាជនៈដែលនាំមកពេញហើយ ទើបនាំគ្នាទៅ ។

ចំណែកអ្នកជនបទម្នាក់ ទឹមគោរបស់ឥល្លិសសេដ្ឋីត្រង់រទេះនោះឯង ផ្ទុកពេញទៅដោយរតនៈ ៧ ប្រការ ចេញអំពីព្រះនគរ កាត់តាមលានព្រះរាជវាំង បររថទៅតាមគុម្ពោតព្រៃនោះ បរទៅបណ្តើរ ពោលដល់គុណនៃសេដ្ឋីបណ្តើរថា ឱ ! លោកឥល្លិសសេដ្ឋី សូមលោកមានជីវិតអស់រយនៃឆ្នាំចុះ គ្រានេះខ្ញុំមិនចាំបាច់ធ្វើការងារចិញ្ចឹមជីវិតអស់មួយជីវិត ព្រោះអាស្រ័យលោក រថក៏ជារបស់លោក គោទាំងពីរក៏ជារបស់លោកដូចគ្នា កែវ ៧ ប្រការក៏ក្នុងផ្ទះរបស់លោក ម្តាយខ្ញុំក៏មិនបានឲ្យ ឪពុកខ្ញុំក៏មិនបានឲ្យ ខ្ញុំបានព្រោះអាស្រ័យលោកពិត ។ ឥល្លិសសេដ្ឋីស្តាប់សំឡេងនោះហើយ កើតតក់ស្លុត ក្តុកក្តួលក្នុងចិត្ត គិតថា បុគ្គលនេះ យកឈ្មោះរបស់អញមកពោលអាងដល់រឿងនេះៗ ព្រះរាជាព្រះរាជទានទ្រព្យរបស់អញដល់អ្នកស្រុក អស់ហើយទេដឹង ហ្ន៎ ស្ទុះចេញពីគុម្ពោតព្រៃ ស្គាល់គោ និងរទេះ ពោលសម្តុតថា រ៉ឺយ អាអ្នក

បម្រើជាតិអាក្រក់ គោក៏ជារបស់អញ រថក៏ជារបស់អញ ហើយស្ទុះទៅចាប់គោត្រង់ខ្សែទាម គហបតីចុះអំពីរទេះពោលថា វ៊ុយ អាអ្នកបម្រើអាក្រក់ លោកឥល្លិសសេដ្ឋីឲ្យទានដល់មនុស្សទាំងនគរ អាជានរណា ស្ទុះទៅរកវាយពីក្រោយ ត្រង់កញ្ចឹងក ដូចរន្ទះបាញ់ ហើយទាញរថមកបរទៅ ឯឥល្លិសសេដ្ឋីក្រោកឡើងទាំងត្រដរ បោសធូលីហើយ រត់ទៅតោងរទេះទៀត គហបតីចុះពីរទេះ ចាប់ត្រង់សក់អុកដោយកែង ចាប់កគ្រវាត់ទៅត្រង់ផ្លូវមក ដែលមកហើយ ក៏ចៀសចេញទៅ ។ ឥល្លិសសេដ្ឋីត្រូវគេវាយយ៉ាងនេះ ការស្រវឹងស្រាក៏ស្វាងទៅ ដើរប៉ាក់ប៉ើកទៅកាន់ទ្វារព្រះរាជនិវេសន៍យ៉ាងរហ័ស ឃើញមហាជននាំគ្នាជញ្ជូនទ្រព្យទៅ ក៏ស្រែកថា តើមានរឿងអ្វី ព្រះរាជាឲ្យមកប្លន់ទ្រព្យរបស់យើងឬ ហើយទៅចាប់ពួកមនុស្សនោះៗ មនុស្សដែលត្រូវចាប់ក៏វាយឲ្យដួលចុះត្រង់ជើងនោះឯង សេដ្ឋីឈឺចាប់ពន់ពេក ប្រាថ្នានឹងចូលទៅកាន់ផ្ទះ ត្រូវពួកអ្នកយាមទ្វារស្រែកថា វ៊ុយ អាគហបតីអាក្រក់ អាចូលទៅណា ហើយវាយដោយមែកឫស្សី ចាប់កអូសចេញទៅ ។ សេដ្ឋីគិតថា គ្រានេះ វៀរព្រះរាជាចេញ អ្នកដទៃជាទីពឹងរបស់អញ មិនមានទេ ទៅកាន់ព្រះរាជសម្នាក់ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ឲ្យមនុស្សប្លន់ផ្ទះទូលបង្គំឬ ព្រះរាជាត្រាស់ថា លោកសេដ្ឋី យើងមិនបានឲ្យប្លន់ទេ លោកនោះឯង មករកយើង ប្រាប់ថា បើទ្រង់មិនទទួលទ្រព្យ ទូលបង្គំនឹងឲ្យទ្រព្យរបស់ទូលបង្គំជាទាន ឲ្យមនុស្សដើរវាយស្គរប្រកាសក្នុងព្រះនគរ ហើយបានឲ្យទាន មិនមែនឬ សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនបាន

មកកាន់សម្នាក់របស់ព្រះអង្គទេ ព្រះអង្គមិនជ្រាបភាពដែលទូលបង្គំជាមនុស្ស កំណាញ់ទេឬ ទូលបង្គំមិនព្រមឲ្យសូម្បីតំណក់ប្រេង ដោយចុងស្បូវដល់បុគ្គលណាម្នាក់ឡើយ បពិត្រព្រះសម្មតិទេព សូមទ្រង់ព្រះករុណាហៅមនុស្សដែលឲ្យទាននោះមក ហើយទ្រង់ពិចារណាមើលចុះ ។

ព្រះរាជាត្រាស់ឲ្យហៅឥន្ទនិម្មិតមក ការប្លែកគ្នានៃជនទាំង ២ ព្រះរាជាជ្រាបមិនបានឡើយ ពួកអមាត្យក៏មិនជ្រាប សេដ្ឋីកំណាញ់ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ចាំទូលបង្គំមិនបានឬ ទូលបង្គំជាឥល្លិសសេដ្ឋី បុគ្គលនេះ មិនមែនសេដ្ឋីទេ ។ ព្រះរាជាត្រាស់ថា យើងចាំមិនបាន តើមាននរណាចាំអ្នកបាន ក៏ក្រាបទូលថា ភរិយារបស់ខ្ញុំព្រះអង្គ ។ ព្រះរាជាមានព្រះតម្រាស់ឲ្យហៅភរិយាចូលគាល់ ហើយត្រាស់សួរថា ម្នាក់ណាជាស្វាមីរបស់នាងៗ ក្រាបទូលថា បុរសនេះ ព្រះអង្គ ហើយបានទៅឈរជិតសក្កៈនោះឯង ហៅបុត្រ ធីតា ទាសកម្មករមកសួរ គ្រប់គ្នាឈរក្នុងសម្នាក់របស់សក្កៈទាំងអស់ ។ សេដ្ឋីគិតបានថា ក្បាលរបស់អញមានពក សក់បិទបាំងជិត មានតែជាងកាត់សក់ម្នាក់ប៉ុណ្ណោះ ដែលដឹងពកនោះ ត្រូវក្រាបទូលឲ្យហៅជាងកាត់សក់មក គិតយ៉ាងនេះហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ជាងកាត់សក់គង់ចាំទូលបង្គំបាន សូមទ្រង់ហៅមកចុះ ។ ក្នុងកាលនោះ ព្រះពោធិសត្វបានជាជាងកាត់សក់របស់ឥល្លិសសេដ្ឋី ព្រះរាជាមានព្រះតម្រាស់ឲ្យហៅមក ត្រាស់សួរថា តើអ្នកចាំឥល្លិសសេដ្ឋីបានដែរឬទេ ជាងកាត់សក់ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំពិនិត្យមើលក្បាលហើយ ទើបចាំបាន ។ ព្រះរាជា

ត្រាស់ថា បើដូច្នោះ ចូរអ្នកពិនិត្យមើលក្បាលរបស់ជនទាំង ២ ចុះ ។ រំពេចនោះ សក្កទេវរាជក៏បណ្ដាលឲ្យកើតពកឡើងត្រង់ក្បាល ព្រះពោធិសត្វមើលក្បាលរបស់ជនទាំង ២ ក៏ឃើញពកដូចគ្នា ទើបក្រាបទូលថា បពិត្រមហារាជ ត្រង់ក្បាលរបស់ជនទាំង ២ មានពកដូចគ្នា ក្នុងជនទាំង ២ នេះ ទូលបង្គំមិនអាចចាំបាន ជនទាំង ២ ដល់នូវភាពជាឥល្លិសតែម្នាក់ ហើយពោលគាថានេះថា

> ជនទាំង ២ នាក់ខ្វក ជនទាំង ២ នាក់ក្ងែង ជនទាំង ២ នាក់
> មានភ្នែកស្រលៀង ពកកើត ( លើក្បាល ) របស់ជនទាំង ២
> នាក់ ខ្ញុំព្រះអង្គមិនស្គាល់ ( អ្នកណា ) ជាឥល្លិសសេដ្ឋីទេ
> ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧភោ** បានដល់ ជនទាំង ២ ។

បទថា **ខញ្ជា** បានដល់ មានជើងវៀច ។ បទថា **កុណី** បានដល់ មានដៃក្ងែង ។

បទថា **វិសមចក្ខុកា** បានដល់ មានភ្នែកមិនស្មើគ្នា អធិប្បាយថា មានភ្នែកស្រលៀង ។

បទថា **បីឡកា** សេចក្ដីថា ត្រង់ក្បាលរបស់ជនទាំង ២ មានពកកើតឡើង ២ ដុំ មានសណ្ឋានដូចគ្នា នៅក្នុងទីដូចគ្នា ។

បទថា **នាហំ បស្សាមិ** សេចក្ដីថា ជាឯកោរកាត់ក្រាបទូលថា ក្នុងជនទាំង ២ នាក់ ទូលបង្គំមិនប្រែបកក្យថា ជនណាជាឥល្លិសសេដ្ឋី គឺមិនស្គាល់

ភាពជាឥល្លិសសេដ្ឋី ថាជាបុគ្គលណាម្នាក់ទេ ។

លោកសេដ្ឋីស្តាប់ពាក្យរបស់ព្រះពោធិសត្វប៉ុណ្ណោះ មានខ្លួនញ័រចំប្រប់ មិនអាចតម្កល់ស្មារតីបាន ព្រោះស្តាយទ្រព្យ ក៏ដួលចុះត្រង់នោះឯង ។ ក្នុងខណៈនោះ សក្កទេវរាជពោលថា បពិត្រមហារាជ ខ្ញុំមិនមែនឥល្លិសេដ្ឋីទេ ខ្ញុំជាសក្កៈ ហើយបានប្រថាប់ឈរក្នុងអាកាស ដោយអាកប្បកិរិយាដ៏រុងរឿង ។ ពួកអមាត្យជួយជូតមុខឥល្លិសសេដ្ឋី ហើយប្រោះដោយទឹក ឥល្លិសសេដ្ឋីប្រញាប់ក្រោកឡើង ឈរសំពះសក្កទេវរាជ ។ រំពេចនោះ សក្កទេវរាជពោលនឹងសេដ្ឋីថា នែឥល្លិស ទ្រព្យនេះជារបស់យើង មិនមែនរបស់អ្នកទេ ព្រោះយើងជាបិតារបស់អ្នក អ្នកជាកូនរបស់យើង យើងធ្វើបុណ្យ មានឲ្យទានជាដើម ដល់នូវភាពជាសក្កទេវរាជ តែអ្នកកាត់ផ្តាច់នូវវង្សរបស់យើងចោល ជាអ្នកមិនឲ្យទាន តាំងនៅក្នុងសេចក្តីកំណាញ់ ដុតរោងទាន បណ្តេញពួកយាចក គិតតែសន្សំទ្រព្យ ខ្លួនឯងក៏មិនព្រមបរិភោគ អ្នកដទៃក៏មិនឲ្យធ្វើខ្លួនដូចអារក្ខទឹកហួងហែងស្រះ បើអ្នកសាងរោងទានឲ្យដូចប្រក្រតី ហើយឲ្យទាន ទុំះជាការល្អាស បើមិនឲ្យទាន យើងនឹងធ្វើទ្រព្យរបស់អ្នកឲ្យអន្តរធានអស់ទៅ ហើយនឹងវាយសំពងក្បាលដោយឥន្ទវជិរៈនេះឲ្យអស់ជីវិត ។ ឥល្លិស-សេដ្ឋីត្រូវគំរាមដោយមហាភ័យ បានឲ្យប្តេជ្ញាថា តាំងអំពីនេះទៅ ខ្ញុំនឹងឲ្យទាន ។ សក្កទេវរាជទទួលប្តេជ្ញារបស់សេដ្ឋីហើយ ប្រថាប់ក្នុងអាកាសនោះឯង សម្តែងធម៌ទូន្មានឲ្យសេដ្ឋីតាំងនៅក្នុងសីល ហើយយាងទៅកាន់ស្ថានរបស់ទ្រង់វិញ ។ ឯឥល្លិសសេដ្ឋីបានធ្វើបុណ្យ ឲ្យទានជាដើម បានជាអ្នកមាន

ស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមោគ្គល្លានទូន្មានសេដ្ឋីកំណាញ់ សូម្បីក្នុងកាលមុន ក៏ទូន្មានហើយដូចគ្នា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា ឥល្លិសសេដ្ឋីក្នុងកាលនោះ បានមកជាសេដ្ឋីកំណាញ់ក្នុងកាលឥឡូវនេះ សក្កទេវរាជ បានមកជាមោគ្គល្លាន ព្រះរាជាបានមកជាអានន្ទ ឯជាងកោរកាត់ គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា ឥល្លិសជាតក ចប់**

# សុត្តន្តបិដក

## ខរស្សរជាតក

[ ៧៩ ] ( ពាណិជពោធិសត្វពោលថា ) កាលណា ( ពួកចោរ ) ប្លន់ សម្លាប់គោទាំងឡាយ ដុតផ្ទះទាំងឡាយ និងនាំជនយកទៅហើយ ក្នុងកាលនោះ កូនរបស់ស្ត្រីដែលមានកូនស្លាប់ហើយ ( គឺចៅហ្វាយស្រុកឥតមានសេចក្តីអៀនខ្មាស ) វាយស្គរឲ្យមានសំឡេងខ្លាំង ដើរមក ។

**ខរស្សរជាតកទី ៩ ចប់**

# អដ្ឋកថា

## ចរស្សជាតក

[ ៧៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអមាត្យម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យតោ វិលុត្តា ច ហតា ច គាវោ** ដូច្នេះជាដើម ។

បានឮថា អមាត្យម្នាក់របស់ព្រះបាទកោសល ញ៉ាំងព្រះរាជាឲ្យប្រោសប្រាណហើយ បានកម្លាំងក្នុងបច្ចន្តគាម ទៅរួមជាមួយពួកចោរ ពោលថា យើងនឹងនាំពួកមនុស្សចូលព្រៃ ពួកឯងប្លន់ស្រុកហើយ ចែកឲ្យយើងពាក់កណ្តាល ដូច្នេះហើយ ហៅពួកមនុស្សឲ្យប្រជុំគ្នា ហើយនាំចូលព្រៃមុន កាលពួកចោរនាំគ្នាមកចាប់មេគោកាប់ស៊ីសាច់ ប្លន់ភូមិស្រុក នាំគ្នាទៅហើយ មានមហាជនចោមរោម ត្រឡប់ចូលស្រុកក្នុងវេលាល្ងាច មិនយូរប៉ុន្មាន ការធ្វើនៃអមាត្យនោះក៏ប្រាកដ ពួកមនុស្សនាំគ្នាក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យហៅមកហើយ ឲ្យកំណត់ទោស ទ្រង់ដាក់អាជ្ញាដល់ទោសានុទោស បញ្ជូនចៅហ្វាយស្រុកដទៃទៅជំនួស ហើយយាងចូលទៅវត្តជេតពន ថ្វាយបង្គំព្រះតថាគត ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលអមាត្យនោះមានប្រក្រតីប្រព្រឹត្តយ៉ាងនេះ សូម្បីក្នុងកាលមុន ក៏មានប្រក្រតីប្រព្រឹត្តយ៉ាងនេះដូចគ្នា កាលព្រះបាទកោសលក្រាបទូលអារាធនា ទ្រង់នាំរឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ

ពារាណសី ទ្រង់ព្រះរាជទានបច្ចន្តគាមដល់អមាត្យម្នាក់ ។ រឿងទាំងអស់ ដូចគ្នានឹងរឿងនេះឯង ។ ក្នុងកាលនោះ ព្រះពោធិសត្វត្រាច់ទៅក្នុងបច្ចន្តគាម ដើម្បីជួញដូរក្នុងស្រុកនោះ ព្រះពោធិសត្វ កាលមេស្រុកនោះវាយស្គរគគ្រឹកគគ្រេង មកជាមួយមហាជន ក្នុងវេលាល្ងាច ទើបពោលថា មេស្រុកអាក្រក់នេះ ផ្សំគំនិតជាមួយពួកចោរ ឲ្យចោរប្លន់ស្រុក កាលពួកចោរនាំគ្នាគេចចូលព្រៃហើយ ក៏នាំគ្នាវាយស្គរដើរមក ធ្វើដូចជាមនុស្សស្ងប់ស្ងៀម រួចពោលគាថានេះថា

កាលណា ( ពួកចោរ ) ប្លន់ សម្លាប់គោទាំងឡាយ ដុតផ្ទះទាំងឡាយ និងនាំជនយកទៅហើយ ក្នុងកាលនោះ កូនរបស់ស្ត្រីដែលមានកូនស្លាប់ហើយ ( គឺចៅហ្វាយស្រុកឥតមានសេចក្តីអៀនខ្មាស ) វាយស្គរឲ្យមានសំឡេងខ្លាំង ដើរមក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទោ** បានដល់ ក្នុងកាលណា ។

បទថា **វិលុត្តា ច ហតា ច** សេចក្តីថា ពួកចោរនាំគ្នាប្លន់ សម្លាប់គោទាំងឡាយ ដើម្បីស៊ីសាច់ ។

បទថា **គាវោ** បានដល់ ហ្វូងគោ ។

បទថា **ឧឌ្ឍានិ** សេចក្តីថា កាន់យកភ្លើងដុតផ្ទះឲ្យឆេះ ។

បទថា **ជនោ ច នីតោ** សេចក្តីថា ចាប់មនុស្សនាំទៅជាឈ្លើយ ។

បទថា **បុត្តហតាយ បុត្តោ** បានដល់ កូនរបស់ស្រីដែលមាតាលះបោលហើយ អធិប្បាយថា បានដល់ មនុស្សមុខក្រាស់ ព្រោះថា បុគ្គលប្រាសចាក

ហិរិឱត្តប្បៈហើយ ឈ្មោះថា មិនមានម៉ែ ដោយហេតុនេះ សូម្បីម្ដាយនៅមានជីវិត ក៏បុគ្គលនោះមិនតាំងនៅក្នុងឋានៈជាកូន ព្រោះដូច្នោះ បុគ្គលនោះឈ្មោះថា ជាកូនដែលម្ដាយបោះបង់ចោល ។

បទថា **ខរស្សរំ** បានដល់ សំឡេងគគ្រឹកគគ្រេង ។

បទថា **ធេណុភិមំ** បានដល់ វាយស្គរ ។

ព្រះពោធិសត្វបរិភាសមេស្រុកដោយគាថានេះ ដោយប្រការដូច្នេះ កម្មនោះ របស់បុគ្គលនោះប្រាកដចំពោះកាលមិនយូរឡើយ ។ គ្រានោះ ព្រះរាជាទ្រង់ដាក់អាជ្ញាដល់មេស្រុក សមគួរដល់ទោសតូច និងទោសធំ ។

ព្រះសាស្ដាត្រាស់ថា មហាបពិត្រ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអមាត្យនោះ មានប្រក្រតីប្រព្រឹត្តយ៉ាងនេះ សូម្បីក្នុងកាលមុន ក៏មានការប្រព្រឹត្តមកហើយដូចគ្នា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា អមាត្យក្នុងកាលនោះ បានមកជាអមាត្យក្នុងកាលឥឡូវនេះ ឯបណ្ឌិតលើកគាថាឡើងពោល គឺជាតថាគតនេះឯង ៕

**អដ្ឋកថា ខរស្សរជាតក ចប់**

# សុត្តន្តបិដក

## ភីមសេនជាតក

[ ៨០ ] ( ចូឡធនុគ្គហបណ្ឌិតពោធិសត្វពោលថា ) ម្នាលភីមសេន ក្នុងកាលមុន ឯងបានអួតហើយ ក្នុងកាលក្រោយ ស្រាប់តែគ្រឿងសម្អុយសម្រប់ហូរចេញ ( អាចម៍ ) របស់ឯង ហូរចេញមក ហេតុទាំង ២ មិនសមគ្នា គឺការនិយាយអំពីចម្បាំង និងការបង្អៀតបង្អល់ចិត្តរបស់ឯងនេះ ។

**ភីមសេនជាតកទី ១០ ចប់**

**វរុណវគ្គទី ៨ ចប់**

### ឧទ្ទាននៃវរុណវគ្គនោះ គឺ

និយាយអំពីវរុណជាតក ១ អកតញ្ញូ ( ក្នុងសីលវនាគជាតក ) ១ ពាក្យពិតដ៏ប្រសើរ ( ក្នុងសច្ចង្កិរជាតក ) ១ ឈើម្នាស់ព្រៃ ( ក្នុងរុក្ខធម្មជាតក ) ១ ការផ្ញើផ្គរឲ្យលាន់ ( ក្នុងមច្ឆជាតក ) ១ ករុណា ( ក្នុងអសង្កិយជាតក ) ១ ថ្នអណ្តែត ( ក្នុងមហាសុបិនជាតក ) ១ ឥល្លិសសេដ្ឋី ( ក្នុងឥល្លិសជាតក ) ១ ស្គរ ( ក្នុងខរស្សរជាតក ) ១ គ្រឿងសម្អុយសម្រាប់ហូរចេញ ( ក្នុងភីមសេនជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ភីមសេនជាតក

[ ៨០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអួតអាង មួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យន្តេ បវិកត្ថិតំ បុរេ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុមួយរូបដើរអួត បង្អាប់អ្នកដទៃ បោកបញ្ឆោតក្នុងពួកភិក្ខុ ដែលជាថេរៈ និងនវក និងជាមជ្ឈិម ដោយអំណាចសម្បត្តិ មានជាតិជាដើម ថា អាវុសោទាំងឡាយ បើពោលដល់ជាតិ អ្នកមិនស្មើខ្ញុំដោយជាតិទេ បើពោលដោយគោត្រ អ្នកមិនស្មើខ្ញុំដោយគោត្រទេ ពួកយើងកើតក្នុងត្រកូល មហាក្សត្របែបនេះ បុគ្គលដែលឈ្មោះថា ប្រៀបផ្ទឹមនឹងយើងដោយគោត្រ ឬ ដោយទ្រព្យ ឬដោយឋានៈនៃត្រកូល មិនមានឡើយ គំនរមាសជាដើមមាន រាប់មិនអស់ សូម្បីតែពួកទាសកម្មកររបស់យើង ក៏នាំគ្នាស៊ីបាយស្រូវសាលី ស្លៀកសំពត់ដែលមកអំពីដែនកាសីជាដើម លាបស្រឡាបនូវគ្រឿងលាប ដែលមកអំពីដែនកាសី ព្រោះជាបព្វជិត ឥឡូវនេះ យើងបរិភោគភោជន សៅហ្មង ដណ្ដប់ចីវរអន់ៗ យ៉ាងនេះ ។ គ្រានោះ ភិក្ខុមួយរូបសាកសួរទី កន្លែងនៃត្រកូលរបស់លោកបានពិតប្រាកដ ក៏ពោលភាពដែលលោកអួតនោះ ដល់ពួកភិក្ខុៗ អង្គុយប្រជុំគ្នាក្នុងធម្មសភា ពោលដល់ទោស ដែលមិនមែន គុណរបស់លោកថា នែអាវុសោទាំងឡាយ ភិក្ខុនោះបួសហើយក្នុងសាសនា ដែលនាំចេញចាកទុក្ខបែបនេះ គង់ដើរពោលបង្អាប់ បោកបញ្ឆោតបាន ។ ព្រះ សាស្ដាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នក

ប្រជុំសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនោះនិយាយអួត សូម្បីក្នុងកាលមុន ក៏ធ្លាប់អួត បន្ទុះបន្ទាប់ បោកបញ្ឆោតមកហើយ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងស្រុកមួយ ចម្រើនវ័យហើយ រៀនត្រៃវេទ ដែលជាទីតាំងនៃវិជ្ជា ១៨ ប្រការ ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ក្នុងនគរតក្កសិលា ដល់នូវការសម្រេចសិប្បៈគ្រប់យ៉ាង ឈ្មោះថា ចូឡធនុគ្គហបណ្ឌិតៗ ចេញអំពីតក្កសិលានគរ ស្វែងរកសិប្បៈក្នុងលទ្ធិសម័យគ្រប់យ៉ាង ក៏មកដល់មហេសក្ករដ្ឋ ។ ក្នុងជាតកនេះ ព្រះពោធិសត្វមានរាងកាយតូចទាប អាកប្បកិរិយាដូចមនុស្សគម ។ ព្រះពោធិសត្វត្រិះរិះថា បើអញចូលគាល់ព្រះរាជាអង្គណាមួយ ព្រះរាជានឹងពោលថា អ្នកមានរាងកាយទាបយ៉ាងនេះ នឹងធ្វើរាជការបានឬ ណ្ហើយចុះ អញគួររកមនុស្សដែលសម្បូរដោយកម្ពស់ មានរូបស្អាតម្នាក់ធ្វើជាខែល ហើយក៏ចិញ្ចឹមជីវិតក្រោយខ្នងបុគ្គលនោះ ។ គិតហើយ ក៏ស្វែងរកបុរសដែលមានរូបរាងយ៉ាងនោះ ទៅដល់លំនៅជាងតម្បាញម្នាក់ ឈ្មោះភីមសេន ធ្វើបដិសណ្ឋារៈជាមួយបុរសនោះ សាកសួរថា សម្លាញ់ឈ្មោះអ្វី ។ បុរសនោះឆ្លើយថា ខ្ញុំឈ្មោះភីមសេន ។ ចូឡធនុគ្គហបណ្ឌិតសួរថា អ្នកជាមនុស្ស

មានរូបរាងស្អាត សមប្រកបគ្រប់យ៉ាង ធ្វើការងារអន់ៗ បែបនេះធ្វើអ្វី ។ កីមសេនពោលថា ខ្ញុំមិនអាចនៅស្ងៀមបាន ចូឡធនុគ្គហបណ្ឌិតពោលថា នែសម្លាញ់ កុំធ្វើការងារនេះឡើយ ក្នុងជម្ពូទ្វីបទាំងមូល មិនមានខ្មាន់ធ្នូដែលប្រៀបនឹងខ្ញុំបានទេ តែបើខ្ញុំចូលគាល់ព្រះរាជាអង្គណា ព្រះរាជានឹងក្រោធខឹងខ្ញុំថា ឯងទាបយ៉ាងនេះ ធ្វើរាជការបានដូចម្ដេច អ្នកគប្បីចូលគាល់ព្រះរាជាទូលថា ទូលព្រះបង្គំជាខ្មាន់ធ្នូ ដូច្នេះ ព្រះរាជានឹងព្រះរាជទានតំណែងដល់អ្នក ហើយព្រះរាជទានប្រាក់ខែរឿយៗ ខ្ញុំនឹងចាំធ្វើការងារដែលកើតឡើងដល់អ្នក ខ្ញុំសុំរស់នៅពីក្រោយខ្នងរបស់អ្នក ដោយវិធីយ៉ាងនេះ យើងទាំង ២ ក៏នៅជាសុខ ចូរអ្នកធ្វើតាមពាក្យរបស់ខ្ញុំចុះ កីមសេនក៏ទទួលពាក្យ ។ ទើបចូឡ-ធនុគ្គហបណ្ឌិតនាំចូលទៅនគរពារាណសី ទុកខ្លួនជាអ្នកបម្រើ លើកកីមសេនទុកខាងមុខ ឈរត្រង់ទ្វារព្រះរាជដ្ឋាន ឲ្យក្រាបទូលព្រះរាជា កាលបានទទួលព្រះបរមរាជានុញ្ញាតថា នាំគ្នាមកចុះ ទាំង ២ នាក់ក៏ចូលទៅថ្វាយបង្គំព្រះរាជា ហើយឈរ កាលព្រះរាជាត្រាស់ថា អ្នកទាំង ២ មកធ្វើអ្វី ទើបកីមសេនក្រាបទូលថា ខ្ញុំព្រះអង្គជាខ្មាន់ធ្នូ ក្នុងជម្ពូទ្វីបមិនមានខ្មាន់ធ្នូដែលអាចផ្ទឹមនឹងខ្ញុំព្រះអង្គបានឡើយ ។ ព្រះរាជាសួរថា បើអ្នកបម្រើយើង តើអ្នកត្រូវការអ្វី ក៏ក្រាបទូលថា បើបានទ្រព្យ ១០០០ កហាបណៈ ក្នុងពេលកន្លះខែ ទើបទូលបង្គំទទួលរាជការ ។ ព្រះរាជាត្រាស់សួរថា បុរសនេះជាអ្វីរបស់អ្នក ក៏ក្រាបទូលថា ជាអ្នកបម្រើរបស់ទូលបង្គំ ។ ព្រះរាជាត្រាស់ថា ចូរបម្រើយើងចុះ ។ តាំងអំពីពេលនោះ កីមសេនក៏ទទួលរាជការ តែរាជកិច្ចដែល

កើតឡើងហើយ ព្រះពោធិសត្វធ្វើតែម្នាក់ឯង ។

សម័យនោះ ត្រង់ដែនកាសី ក្នុងព្រៃមួយកន្លែង មានខ្លាកាចស្ទាក់ផ្លូវទៅមករបស់មនុស្ស ចាប់មនុស្សយកទៅស៊ីជាច្រើន ។ អ្នកស្រុកនាំគ្នាក្រាបទូលរឿងនោះ ដល់ព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យកីមសេនចូលគាល់ ត្រាស់សួរថា នែបា បាអាចចាប់ខ្លានេះបានដែរឬទេ ។ កីមសេនក្រាបទូលថា បពិត្រព្រះអង្គ បើមិនអាចចាប់ខ្លាបាន តើឈ្មោះថា ខ្ញុំជួបានដូចម្តេច ព្រះរាជាព្រះរាជទានរង្វាន់ដល់កីមសេន ហើយបញ្ជូនទៅ ចូលទៅដល់ផ្ទះ ប្រាប់ដល់ព្រះពោធិសត្វៗ ពោលថា សាធុ សម្លាញ់ ទៅចុះ កីមសេនសួរថា សម្លាញ់ទៅដែរឬទេ ព្រះពោធិសត្វឆ្លើយថា ខ្ញុំមិនទៅទេ តែខ្ញុំនឹងប្រាប់ឧបាយ កីមសេនពោលថា ចូរប្រាប់មកចុះសម្លាញ់ ព្រះពោធិសត្វពោលថា អ្នកកុំប្រញាប់ចូលទៅកាន់លំនៅរបស់ខ្លាតែម្នាក់ឯងឲ្យសោះ តែចូរប្រជុំអ្នកស្រុក ឲ្យកាន់ធ្នូទៅ ១០០០ ឬ ២០០០ ហើយទៅកាន់លំនៅរបស់ខ្លានោះ កាលដឹងថាខ្លាក្រោកឡើង ត្រូវប្រញាប់ចូលទៅក្នុងគុម្ពឈើ ហើយដេកពួន ឯអ្នកជនបទនឹងនាំគ្នាចោមរោមចាប់ខ្លាបាន កាលអ្នកស្រុកចាប់ខ្លាបានហើយ អ្នកត្រូវយកធ្មេញខាំវល្លិមួយសរសៃ ចាប់ចុងវល្លិដើរទៅក្នុងទីនោះ ដល់ក្បែរខ្លាដែលស្លាប់ហើយ គប្បីពោលថា នែអ្នកទាំងឡាយ អ្នកណា ធ្វើឲ្យខ្លានេះស្លាប់ ខ្ញុំគិតថា នឹងចងខ្លាដោយវល្លិ ដូចគេចងគោ ដឹកទៅកាន់រាជសម្នាក់ឲ្យបាន ទើបចូលក្នុងគុម្ពោតព្រៃដើម្បីបោចវល្លិ ខ្ញុំមិនទាន់នាំវល្លិមកផង អ្នកណាសម្លាប់ខ្លានេះឲ្យស្លាប់ កាលបើដូច្នេះ អ្នកជនបទនោះ ត្រូវតក់ស្លុតពោលថា បពិត្រ

លោកម្ចាស់ សូមកុំក្រាបទូលព្រះរាជាឡើយ នាំគ្នាឲ្យទ្រព្យច្រើន ខ្លាក៏ឈ្មោះថា អ្នកម្នាក់ឯងចាប់បាន ហើយបានទ្រព្យជាច្រើនអំពីសម្នាក់ព្រះរាជាទៀតផង កីមសេន ទទួលពាក្យថា ល្អហ្ន៎ ហើយទៅចាប់ខ្លា តាមដែលព្រះពោធិសត្វណែនាំនោះឯង ធ្វើព្រៃឲ្យផុតភ័យ ហើយមានមហាជនចោមរោម មកកាន់នគរពារាណសី ចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំចាប់ខ្លាបានហើយ ធ្វើព្រៃឲ្យផុតភ័យ ព្រះរាជាទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យច្រើន ។

ក្នុងកាលតមក ពួកអ្នកស្រុកក្រាបទូលថា ក្របីកាចស្ទាក់ផ្លូវមួយកន្លែង ព្រះរាជាក៏បញ្ជូនកីមសេនទៅដោយទំនងដូចគ្នា កីមសេនចាប់ក្របីនោះមកបានដោយការណែនាំអំពីព្រះពោធិសត្វ ដូចកាលចាប់ខ្លា ដូច្នោះ ។ ព្រះរាជាបានព្រះរាជទានទ្រព្យជាច្រើនទៀត មានឥស្សរិយយសធំ គាត់ស្រវឹងដោយការស្រវឹងក្នុងភាពជាធំ ធ្វើការមើលងាយក្នុងព្រះពោធិសត្វ មិនស្តាប់ពាក្យរបស់ព្រះពោធិសត្វ ពោលពាក្យគ្រោតគ្រាតជាដើមថា យើងមិនអាស្រ័យអ្នកចិញ្ចឹមជីវិតទេ អ្នកប៉ុណ្ណោះឬដែលជាកូនប្រុស ។

កន្លងមកមិនបានប៉ុន្មានថ្ងៃ ព្រះរាជានគរជិតខាងមួយអង្គ លើកទ័ពមកព័ទ្ធនគរពារាណសី បញ្ជូនព្រះរាជសាសន៍ដល់ព្រះរាជាថា ទ្រង់ប្រគល់រាជសម្បត្តិដល់ខ្ញុំ ឬច្បាំង ព្រះរាជាទ្រង់បញ្ជូនកីមសេនចេញទៅថា កីមសេនចូរអ្នកចេញច្បាំង ។ កីមសេនពាក់គ្រោះ ទ្រទ្រង់ភេទជាព្រះរាជា អង្គុយលើខ្នងដំរីដែលពាក់គ្រឿងប្រដាប់សព្វគ្រប់ សូម្បីព្រះពោធិសត្វ ក៏ពាក់គ្រឿង

ចម្បាំងសព្វគ្រប់ អន្ទុយខាងក្រោយព្រះទីន័ងកីមសេននោះឯង ព្រោះខ្លាច កីមសេនស្លាប់ ។ ស្ដេចដ៏វី ចោមរោមដោយមហាជន រៀបក្បួនចេញទៅតាម ទ្វារព្រះនគរ លុះដល់លានចម្បាំង គ្រាន់តែឮស្គរទ័ពប៉ុណ្ណោះ ក៏ញាប់ញ័រ ព្រះពោធិសត្វគិតថា កីមសេននឹងធ្លាក់ពីលើខ្នងដំរីមិនខាន ទើបយកខ្សែចង កីមសេនយ៉ាងណែន ការពារកុំឲ្យធ្លាក់ ។ កីមសេន កាលឃើញទីលាន ប្រយុទ្ធហើយ រឹងរឹតតែខ្លាចស្លាប់ ទើបបៀរឧច្ចារបស្សាវៈដាក់ខ្នងដំរី ។ ព្រះ ពោធិសត្វពោលថា នែកីមសេន ការធ្វើក្នុងពេលក្រោយ មិនសមគ្នានឹង ពាក្យដែលនិយាយក្នុងមុនកាលពីមុន អ្នកហាក់ដូចជាធំ ដូចអ្នកឈ្នះសង្គ្រាម តែឥឡូវនេះ មកប្រទូស្តខ្នងដំរី ដូច្នេះហើយ ទើបពោលគាថានេះថា

ម្នាលកីមសេន ក្នុងកាលមុន ឯងបានអួតហើយ ក្នុងកាលក្រោយ ស្រាប់តែគ្រឿងសម្អុយ សម្រាប់ហូរចេញ ( អាចម៍ ) របស់ឯង ហូរចេញមក ហេតុទាំង ២ មិនសមគ្នា គឺការនិយាយអំពីចម្បាំង និងការបន្ទៀតបង្អល់ចិត្តរបស់ឯងនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យន្តេ បរិកត្ថិតំ បុរេ** សេចក្ដីថា ពាក្យណា គឺពាក្យដែលអួតអាង ពោលពាក្យសង្កត់សង្កិនពីមុនថា ឯងម្នាក់ឬ ដែល ជាកូនប្រុស អញមិនមែនកូនប្រុសទេឬ សូម្បីអញ ក៏ជាទាហានជំនាញក្នុង សឹក ដូច្នេះ នេះជាពាក្យមុន ។

បទថា **អថ តេ បូតិសរា សជន្តិ បច្ឆា** សេចក្ដីថា ខាងក្រោយ ទឹកមូត្រ និងលាមក ដែលឈ្មោះថា ទឹកស្អុយ ព្រោះជារបស់ស្អុយ ជា

របស់ហូរបានទាំងនេះ ហូរពាសពេញចេញមក ។

ដោយបទថា **បច្ឆា** នេះ បានដល់ ក្នុងកាលតមក ចាកទីពោលអួត ក្នុងកាលមុននោះ អធិប្បាយថា ក្នុងឥឡូវនេះ គឺក្នុងសមរភូមិនេះ ។

បទថា **ឧភយំ ន សមេតិ ភីមសេន** សេចក្តីថា នែភីមសេន ពាក្យទាំង ២ នេះ មិនសមគ្នាឡើយ ។ សួរថា តើពាក្យណាខ្លះ ឆ្លើយថា គឺពាក្យដែលអួតដល់ការច្បាំង និងការតក់ស្លុតរបស់អ្នក អធិប្បាយថា ពាក្យដែលពោលដល់ការច្បាំងក្នុងកាលមុន និងការតក់ស្លុត ការលំបាក ការបង្អៀតចង្អល់ រហូតដល់លែងនូវលាមក និងមូត្រឲ្យហូរចេញមកលើខ្នងដំរី មិនសមគ្នាឡើយ ។

ព្រះពោធិសត្វតិះដៀលយ៉ាងនេះហើយ លួងលោមថា នែសម្លាញ់ កុំខ្លាចឡើយ កាលខ្ញុំនៅ អ្នកក្តៅក្រហាយធ្វើអ្វី ដូច្នេះហើយ ឲ្យភីមសេនចុះពីកដំរី ពោលថា ទៅរកងូតទឹកចុះ បញ្ជូនត្រឡប់ទៅ ត្រិះរិះថា ថ្ងៃនេះ អញគួរបង្ហាញខ្លួន ហើយបញ្ជាដំរីចូលកាន់លានចម្បាំង បន្លឺសីហនាទ បំបែកទ័ពសត្រូវ ចាប់ព្រះរាជាដែលជាសត្រូវបាន ហើយទៅគាល់ព្រះបាទពារាណសី ព្រះរាជាទ្រង់ត្រេកអរ ព្រះរាជទានយសធំដល់ព្រះពោធិសត្វ ។ ចាប់តាំងអំពីនោះមក ឈ្មោះចូឡធនុគ្គហបណ្ឌិត ក៏ផ្សាយទៅក្នុងជម្ពូទ្វីបទាំងមូល ។ ព្រះ

ពោធិសត្វបានឲ្យរង្វាន់ដល់ភីមសេន ហើយបញ្ជូនទៅស្រុកកំណើត ធ្វើបុណ្យមានទានជាដើម ហើយក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះអួត សូម្បីក្នុងកាលមុន ក៏អួតហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ភីមសេនក្នុងកាលនោះ បានមកជាភិក្ខុអួត ក្នុងកាលឥឡូវនេះ ឯចូឡធនុគ្គហបណ្ឌិតគឺតថាគតនេះឯង ។ល។

**អដ្ឋកថាភីមសេនជាតក ចប់**

**វរុណវគ្គ ចប់**

# សុត្តន្តបិដក
# អដ្ឋាយិមហាវគ្គ

## សុរាបានជាតក

[ ៨១ ] ( ពួកតាបសពោលថា ) ពួកយើងបានផឹកសុរា បានរាំ បានច្រៀង បានយំហើយពួកយើងមិនមែនជាពានរ ព្រោះតែផឹកសុរា ដែលធ្វើឲ្យខូចសញ្ញា ទើបឃើញ ( អាក្រក់ជាល្អ ) ។

*សុរាបានជាតកទី ១ ចប់*

# អដ្ឋកថា

# អចាយិមហាវគ្គ

## សុភាចាណជាតក

[ ៨១ ] ព្រះសាស្តា ទ្រង់អាស្រ័យនគរកោសម្ពី គង់នៅក្នុងឃោសិតារាម ទ្រង់ប្រារព្ធព្រះសាគតត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អចាយិម្ហា អនច្ចិម្ហា** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កាលព្រះសាស្តាចាំវស្សាក្នុងក្រុងសាវត្ថីហើយ បានយាងចារិកទៅដល់និគមមួយ ឈ្មោះភទ្ទវតិកា ពួកអ្នកចិញ្ចឹមគោ ចិញ្ចឹមសត្វ អ្នកស្រែ និងអ្នកដំណើរឃើញព្រះសាស្តាយាងមក នាំគ្នាថ្វាយបង្គំ ក្រាបទូលឃាត់ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសាស្តាកុំយាងទៅកាន់កំពង់អម្ពៈឡើយ ត្បិតនាគឈ្មោះអម្ពតិត្ថកៈ ត្រង់អាស្រមរបស់ជដិល ក្នុងកំពង់អម្ពៈ ជាសត្វមានពិសដ៏ពន្លឹក អាចបៀតបៀនទ្រង់បាន ។ ព្រះសាស្តាធ្វើហាក់ដូចជាមិនឮនូវពាក្យរបស់មនុស្សទាំងនោះ កាលមនុស្សទាំងនោះក្រាបទូលអស់វារៈ ៣ ដង ក៏យាងទៅទាល់តែបាន ។ បានឮថា ក្នុងទីនោះ ព្រះសាស្តាគង់នៅក្នុងដងព្រៃមួយកន្លែង មិនឆ្ងាយអំពីនិគមភទ្ទវតិកា សម័យនោះឯងព្រះសាគតត្ថេរជាពុទ្ធុបដ្ឋាក ប្រកបដោយឫទ្ធិជារបស់បុថុជ្ជន ចូលទៅជិតអាស្រមនោះ ក្រាលកម្រាលដែលធ្វើដោយស្មៅ ក្នុងលំនៅរបស់នាគនោះ ហើយអង្គុយពត់ភ្នែន នាគអត់ធន់មិនបាន ក៏បញ្ចេញផ្សែង ព្រះថេរៈក៏បញ្ចេញ

ផ្សែងដែរ ។ នាគធ្វើឲ្យភ្លើងឆេះឡើង ព្រះថេរៈក៏ធ្វើឲ្យភ្លើងឆេះដែរ តេជះរបស់នាគគ្របសង្កត់ព្រះថេរៈមិនបាន តេជះរបស់ព្រះថេរៈគ្របសង្កត់នាគបាន លោកបង្ក្រាបស្ដេចនាគនោះ ឲ្យតាំងនៅក្នុងសរណៈ ក្នុងសីលបានហើយ បានទៅកាន់សម្នាក់ព្រះសាស្ដា ដោយប្រការដូច្នេះ ។ ឯព្រះបរមសាស្ដា គង់នៅក្នុងនិគមភទ្ទវតិកាតាមព្រះពុទ្ធអធ្យាស្រ័យហើយ បានយាងទៅកាន់នគរកោសម្ពី រឿងដែលព្រះសាគតត្ថេរបង្ក្រាបនាគ បានល្បីទូទៅពេញជនបទ ។

អ្នកនគរកោសម្ពីធ្វើការទទួលព្រះសាស្ដា នាំគ្នាថ្វាយបង្គំព្រះអង្គហើយ ក៏បង្អួសទៅកាន់សម្នាក់ព្រះសាគតត្ថេរ ថ្វាយបង្គំហើយ ឈរក្នុងចំណែកម្ខាង នាំគ្នាពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ វត្ថុណា ដែលលោកម្ចាស់បានដោយក្រ និមន្តប្រាប់វត្ថុនោះ ពួកខ្ញុំនឹងប្រគេនវត្ថុនោះ ព្រះថេរៈក៏នៅស្ងៀម តែឆព្វគ្គិយនាំគ្នាពោលថា អាវុសោទាំងឡាយ ស្រាក្រហមមានពណ៌ដូចជើងព្រាប ពួកបព្វជិតរកបានលំបាកពេកណាស់ ជារបស់គាប់ចិត្តផង បើពួកអ្នកជ្រះថ្លាក្នុងព្រះថេរៈ សូមរៀបចំស្រាក្រហមដែលមានពណ៌ដូចជើងព្រាបប្រគេនលោកចុះ ។ ជនទាំងនោះក៏ទទួលថា សាធុ នាំគ្នាក្រាបទូលនិមន្តព្រះសាស្ដាដើម្បីឆាន់ក្នុងថ្ងៃស្អែក នាំគ្នាចូលកាន់ព្រះនគរ នាំគ្នារៀបចំសុរាថ្លា មានពណ៌ក្រហមដូចជើងព្រាប ក្នុងផ្ទះរៀងៗ ខ្លួន បំណងថា នឹងប្រគេនដល់ព្រះថេរៈ និមន្តព្រះថេរៈទៅហើយ នាំគ្នាប្រគេនសុរាគ្រប់ៗ ផ្ទះ ព្រះថេរៈឆាន់ហើយ ស្រវឹង ដើរចេញពីព្រះនគរ ដួលត្រង់ចន្លោះទ្វារ ដេកបម្រះនទៀលទៅមក ។ ព្រះសាស្ដាទ្រង់ធ្វើភត្តកិច្ចហើយ កាលយាងចេញអំពីព្រះនគរ ទត

ឃើញព្រះថេរៈ ដេកក្នុងផ្លូវនោះ មានព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកជួយគ្រាប់សាគតៈទៅ ឲ្យពួកភិក្ខុគ្រាប់ទៅកាន់អារាម ពួកភិក្ខុដាក់ក្បាលព្រះថេរៈត្រង់បាទមូលរបស់ព្រះតថាគត ហើយឲ្យដេក ព្រះសាគតៈក៏ត្រឡប់យកជើងឆ្ពោះទៅរកព្រះតថាគត ។ ព្រះសាស្ដាត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីគោរពក្នុងតថាគត ដែលសាគតៈធ្លាប់មានពីមុននោះ ឥឡូវនេះ មានឬ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលថា មិនមានទេ ព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបង្ក្រាបស្ដេចនាគឈ្មោះអម្ពតិត្ថកៈ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន គឺព្រះសាគតត្ថេរ ទ្រង់ត្រាស់សួរថា ឥឡូវនេះ សាគតៈអាចបង្ក្រាបពស់ត្រីបានដែរឬ ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ រឿងនោះមិនបានទេ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទឹកណាដែលផឹកហើយ ប្រាសចាកសញ្ញាយ៉ាងនេះ ទឹកនោះ ភិក្ខុគប្បីផឹកឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា មិនគួរទេ ព្រះអង្គ ។ ព្រះសាស្ដាទ្រង់តិះដៀលព្រះថេរៈហើយ ទ្រង់ហៅពួកភិក្ខុមក ទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុផឹកសុរា និងមេរ័យ ត្រូវអាបត្តិបាចិត្តិយៈ ហើយទ្រង់យាងចូលកាន់ព្រះគន្ធកុដិ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងធម្មសភា និយាយដល់ទោសរបស់ការផឹកស្រាថា អាវុសោទាំងឡាយ ឈ្មោះថា ស្រា មានទោសធំពេកណាស់ ធ្វើឲ្យព្រះសាគតៈដែលជាអ្នកសម្បូរដោយបញ្ញា មានឫទ្ធិ មិនដឹងសូម្បីតែគុណព្រះសាស្ដា ទើបធ្វើយ៉ាងនោះ ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុ

ទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតផឹកស្រាហើយ នាំគ្នាមិនដឹងខ្លួន មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន រឿងនេះក៏កើតឡើងហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមក សាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងដែនកាសី ចម្រើនវ័យហើយ បួសជាឥសី បានអភិញ្ញា និងសមាបត្តិ ជាអ្នកលេងនូវឈាន ក្នុងហិមវន្តប្បទេស ចោមរោមដោយអន្តេវាសិកប្រមាណ ៥០០ ដល់រដូវភ្លៀង អន្តេវាសិកនាំគ្នាប្រាប់ថា បពិត្រលោកអាចារ្យ ពួកយើងនាំគ្នាទៅកាន់ដែនដីមនុស្ស បរិភោគរសជូរប្រៃហើយ សឹមត្រឡប់មក ឥសីពោធិសត្វពោលថា អាវុសោ យើងគួរនៅក្នុងទីនេះឯង ពួកអ្នកគួរនាំគ្នាទៅទំនុកបម្រុងរាងកាយ លុះរដូវភ្លៀងកន្លងទៅហើយ សឹមនាំគ្នាត្រឡប់មកចុះ ។ អន្តេវាសិកទាំងនោះទទួលពាក្យថា សាធុ នាំគ្នាលាអាចារ្យ ទៅកាន់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ស្អែកឡើង នាំគ្នាបិណ្ឌបាតខាងក្រៅទ្វារនគរ បានទទួលនូវការរាប់អានយ៉ាងល្អ ស្អែកឡើងទៀត នាំគ្នាចូលទៅកាន់ព្រះនគរ ពួកមនុស្សនាំគ្នាប្រគេនភិក្ខា លុះកន្លងទៅ ២-៣ ថ្ងៃ ក៏នាំគ្នាក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ឥសី ៥០០ នាំគ្នាចេញអំពីព្រៃហិមពាន្ត ស្នាក់នៅក្នុងព្រះរាជឧទ្យាន មានតបៈខ្លាំងក្លា មានឥន្ទ្រិយអប់រំហើយ ជាអ្នក

មានសីល ព្រះរាជាស្តាប់គុណឥសីទាំងនោះ យាងចូលកាន់ឧទ្យាន ទ្រង់នមស្ការហើយ ធ្វើបដិសណ្ឋារៈ និមន្តឲ្យនៅក្នុងឧទ្យាននោះឯង អស់ ៤ ខែក្នុងរដូវភ្លៀង រាប់តាំងអំពីនោះ ឥសីទាំងនោះ នាំគ្នាឆាន់ក្នុងព្រះរាជវាំងនោះឯង ហើយសម្រាកក្នុងព្រះរាជឧទ្យាន ។

ថ្ងៃមួយ ក្នុងព្រះនគរ មាននក្ខត្តឫក្ស ឈ្មោះសុរានក្ខត្តឫក្ស ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ពួកបព្វជិត រកសុរាបានដោយលំបាក ទើបឲ្យប្រគេនសុរាយ៉ាងល្អជាច្រើន ពួកតាបសនាំគ្នាផឹកសុរាហើយ នាំគ្នាត្រឡប់ទៅកាន់ឧទ្យាន ក៏ស្រវឹងស្រា ពួកខ្លះក្រោកឡើងរាំ ពួកខ្លះច្រៀង កាលរាំ និងច្រៀងហើយនាំគ្នាដេកលក់សន្លប់លើបរិក្ខារ មានដងរែកជាដើម លុះស្វាងស្រា នាំគ្នាក្រោកឡើង ឃើញអាការវិបរិតរបស់ខ្លួន ក៏ទ្រហោយំថា ពួកយើងមិនបានធ្វើការសមគួរដល់បព្វជិតឡើយ ពួកយើងនាំគ្នាលាអាចារ្យមក នាំគ្នាធ្វើកម្មមានប្រមាណប៉ុណ្ណោះ រំពេចនោះឯង នាំគ្នាបោះបង់ឧទ្យាន ត្រឡប់ទៅព្រៃហិមពាន្ត ទុកដាក់បរិក្ខារស្រេចបាច់ហើយ នាំគ្នាថ្វាយបង្គំអាចារ្យ អង្គុយហើយកាលអាចារ្យសួរថា នែបាទាំងឡាយ ពួកអ្នកមិនលំបាកដោយភិក្ខា នាំគ្នានៅជាសប្បាយក្នុងទឹកដីមនុស្សឬ ម្យ៉ាងទៀត ពួកអ្នកមានសាមគ្គីគ្នាឬ នាំគ្នាប្រាប់ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនៅដោយសប្បាយ តែពួកខ្ញុំផឹកនូវរបស់ដែលមិនគួរផឹក ដួលសន្លប់តាមគ្នា មិនអាចតម្កល់សតិបាន នាំគ្នាច្រៀងរាំតាមរឿង កាលប្រាប់រឿងនោះហើយ ក៏ពោលគាថាប្រាប់អាចារ្យថា

ពួកយើងបានផឹកសុរា បានរាំ បានច្រៀង បានយំហើយ ពួកយើង មិនមែនជាពានរ ព្រោះតែផឹកសុរា ដែលធ្វើឲ្យខូចសញ្ញា ទើបឃើញ ( អាក្រក់ជាល្អ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបាយិម្ហ** សេចក្ដីថា ពួកខ្ញុំនាំគ្នាផឹកសុរា ។

បទថា **អនច្ចិម្ហ** សេចក្ដីថា កាលផឹកសុរាហើយ ក៏ក្ដាំក្ដងដៃ និងជើង គឺនាំគ្នារាំ ។

បទថា **អគាយិម្ហ** សេចក្ដីថា បើកមាត់ច្រៀងដោយសំឡេងវែង ។

បទថា **រុទិម្ហ ច** សេចក្ដីថា មានវិប្បដិសារៈ នាំគ្នាយំថា ពួកយើងធ្វើកម្មមិនសមគួរបែបនេះ ។

បទថា **វិសញ្ញិករណឹ បិត្វា ទិដ្ឋា នាហុម្ហ វានរា** សេចក្ដីថា ព្រោះផឹកសុរាដែលឈ្មោះថា ធ្វើឲ្យសញ្ញាវិបរិត ព្រោះទម្លាយសញ្ញា មានប្រមាណប៉ុណ្ណេះ សេចក្ដីនោះនៅល្អ ដែលពួកខ្ញុំមិនក្លាយជាស្វា ។ ពួកអន្តេវាសិកទាំងនោះនាំគ្នាពោលទោសនៃខ្លួន ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វពោលថា ឈ្មោះថា នរជន ដែលឆ្ងាយចាកការនៅរួមគ្នាមួយគ្រូ រមែងមានសភាពដូច្នេះបានទាំងអស់ តិះដៀលតាបសទាំងនោះហើយ ឲ្យឱវាទថា ពួកអ្នកកុំធ្វើកម្មបែបនេះតទៅទៀត មានឈានមិនសាបសូន្យ បានទៅកាន់ព្រហ្មលោកហើយ ។

*ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា គណៈឥសីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ចំណែកសាស្តារបស់គណៈ គឺជាតថាគតនេះឯង ។*

*សូមជ្រាបថា ចាប់អំពីរឿងនេះទៅ នឹងមិនពោលដល់បទថា* **អនុសន្ធិយជេត្វា** *នេះ តទៅទៀតឡើយ ។*

**អដ្ឋកថា សុរាឆានជាតក ចប់**

# សុត្តន្តបិដក

## មិត្តវិន្ទជាតក

[ ៨២ ] *( ទេវរាជពោធិសត្វពោលថា )* អ្នកនោះ កន្លងនូវប្រាសាទកែវផ្លេកផង ប្រាសាទប្រាក់ផង ប្រាសាទកែវមណីផង ជាអ្នកត្រូវថ្ម ( គឺចក្រមានមុខមុត ដូចកាំបិតកោរ ) គ្របសង្កត់ហើយ អ្នកកាលរស់នៅមិនរួចអំពីចក្រនោះទេ ។

**មិត្តវិន្ទជាតកទី ២ ចប់**

# អដ្ឋកថា

## មិត្តវិន្ទជាតក

[ ៨២ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អតិក្កម្ម រមណកំ** *ដូច្នេះជាដើម ។*

*រឿងនៃជាតកនេះ ជារឿងកើតឡើងក្នុងសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធ នឹងមានជាក់ច្បាស់ក្នុងមហាមិត្តវិន្ទជាតកទសកនិបាត ។ ក្នុងកាលនោះ ព្រះពោធិសត្វពោលគាថានេះ ដោយសេចក្តីថា*

*អ្នកនោះ កន្លងនូវប្រាសាទកែវផ្លេកផង ប្រាសាទប្រាក់ផង ប្រាសាទកែវមណីផង ជាអ្នកត្រូវថ្ម ( គឺចក្រមានមុខមុត ដូចកាំបិតកោរ ) គ្របសង្កត់ហើយ អ្នកកាលរស់នៅ មិនរួចអំពីចក្រនោះទេ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **រមណកំ** *ជាឈ្មោះរបស់កែវផលិក ក្នុងកាលនោះ ព្រះពោធិសត្វសម្តែងថា បុរសនោះ ឆ្លងផុតប្រាសាទកែវផលិកទៅហើយ ។*

*បទថា* **សធាមត្តញ្ច** *ជាឈ្មោះរបស់ប្រាក់ ។ ព្រះពោធិសត្វសម្តែងថា បុរសនោះ ឆ្លងប្រាសាទប្រាក់ទៅហើយ ។*

*បទថា* **ទូភកំ** *ជាឈ្មោះរបស់កែវមណី ព្រះពោធិសត្វសម្តែងថា បុរសនោះ ឆ្លងប្រាសាទកែវមណីទៅហើយ ។*

*បទថា* **ស្វាសិ** *កាត់បទជា* **សោ អសិ** *ប្រែថា បុរសនោះឯង ។*

បទថា **ចាសាណមាសីនោ** សេចក្ដីថា ដែលឈ្មោះថា **ខុរចក្ក** នោះ សម្រេចដោយថ្មក៏មាន សម្រេចដោយកែវមណីក៏មាន តែចក្រដែលវិលបុរស នោះ សម្រេចដោយថ្ម ព្រោះហេតុត្រូវខុរចក្កសម្រេចដោយថ្ម កាលគួរនឹង ពោលថា **ចាសាណាសីនោ** បែរជាពោលថា **ចាសាណមាសីនោ** ដោយ កាន់យក **ម** អក្ខរៈ ដោយអំណាចព្យញ្ជនសន្ធិ មានអធិប្បាយមួយន័យ ទៀតថា ក្បាលទូលនូវខុរចក្ក គឺខុរចក្កនោះកំពុងវិល ហើយឈរ ។

បទថា **យស្មា ជីវំ ន មោក្ខសិ** សេចក្ដីថា ទាំងរស់នោះឯង មិនផុតពី ខុរចក្កបាន ត្រូវទូលរហូតបាបកម្មអស់ទៅ ។

ព្រះពោធិសត្វពោលនូវគាថានេះហើយ យាងទៅកាន់ទេវស្ថាននៃខ្លួននោះ ឯង ឯមិត្តវិន្ទកៈទូលចក្រ សោយទុក្ខយ៉ាងមហន្ត កាលបាបកម្មអស់ហើយ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មិត្តវិន្ទៈក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ឯសក្ក- ទេវរាជក្នុងកាលនោះ គឺជាតថាគតនេះឯង ។ល។

**អដ្ឋកថា មិត្តវិន្ទជាតក ចប់**

# សុត្តន្តបិដក

## កាឡកណ្ណិជាតក

[ ៨៣ ] ( មហាយសសេដ្ឋីពោធិសត្វពោលថា ) បុគ្គលដែលជាមិត្ត បានដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ៧ ជំហាន បុគ្គលជាសម្លាញ់ បាន ដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ១២ ជំហាន បុគ្គលជាញាតិ បាន ដោយ ( ការនៅជាមួយគ្នា ) ១ ខែ ឬកន្លះខែ បុគ្គលដែលទុកស្មើនឹងខ្លួន ព្រោះនៅលើសអំពីកាលនោះទៅទៀត ខ្ញុំនោះ នឹងលះបង់នូវសម្លាញ់ ឈ្មោះកាឡកិណី ដែលធ្លាប់ស្និទ្ធស្នាលអស់កាលយូរ ព្រោះហេតុនៃសេចក្តីសុខរបស់ខ្លួន ដូចម្តេចបាន ។

កាឡកណ្ណិជាតកទី ៣ ចប់

# អដ្ឋកថា

## កាឡកណ្ណិជាតក

[ ៨៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមិត្រ របស់អនាថបិណ្ឌិកសេដ្ឋីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មិត្តោ ហវេ សត្តបទេន ហោតិ** ដូច្នេះជាដើម ។

បានឮថា មិត្រនោះ ធ្លាប់ជាសម្លាញ់លេងដីជាមួយគ្នានឹងអនាថបិណ្ឌិក រៀនសិប្បៈក្នុងសម្នាក់អាចារ្យជាមួយគ្នា ដោយឈ្មោះ ឈ្មោះថា **កាឡ-កណ្ណី** ។ កាឡកិណ្ណីនោះ លុះកន្លងទៅ ក៏ជាអ្នកធ្លាក់ខ្លួនក្រ មិនអាចចិញ្ចឹម ជីវិតបាន ទើបទៅកាន់សម្នាក់របស់សេដ្ឋីៗ ក៏លួងលោមសម្លាញ់ ឲ្យស្បៀង ហើយ ប្រគល់សម្បត្តិរបស់ខ្លួនចែកឲ្យ ។ បុរសនោះ ជាអ្នកធ្វើឧបការៈដល់ សេដ្ឋី ធ្វើកិច្ចគ្រប់យ៉ាង កាលដែលគេមកកាន់សម្នាក់សេដ្ឋី មនុស្សទាំងឡាយ នាំគ្នាពោលថា ឈប់ចុះកាឡកិណ្ណី អង្គុយចុះកាឡកិណ្ណី បរិភោគចុះកាឡ-កិណ្ណី ។ ថ្ងៃមួយ ពួកមិត្រ និងអមាត្យរបស់សេដ្ឋី នាំគ្នាចូលទៅរកលោក សេដ្ឋី ហើយពោលយ៉ាងនេះថា លោកសេដ្ឋី កុំចិញ្ចឹមបុរសនេះជិតស្និទ្ធ យ៉ាងនេះឡើយ ព្រោះសូម្បីយក្ខ ក៏ត្រូវគេចទៅដោយសំឡេងថា ឈប់ចុះ កាឡកិណ្ណី អង្គុយចុះកាឡកិណ្ណី ស៊ីចុះកាឡកិណ្ណី គាត់ក៏មិនស្មើនឹងលោក ជាអ្នកក្រ ជាអ្នកលំបាក លោកចិញ្ចឹមមនុស្សបែបនេះធ្វើអ្វី ។ អនាថបិណ្ឌិក-សេដ្ឋីពោលថា ធម្មតាឈ្មោះត្រឹមតែជាពាក្យហៅ ពួកបណ្ឌិតមិនបានកាន់យក ឈ្មោះជាប្រមាណ មិនគួរជាបុគ្គលប្រភេទដែលឈ្មោះថា សុតមង្គលិក ខ្ញុំ មិនអាចអាស្រ័យហេតុត្រឹមតែឈ្មោះ ហើយបោះបង់សម្លាញ់លេងធូលីជាមួយ

គ្នា ដូច្នេះឡើយ មិនបានកាន់យកនូវពាក្យសម្តីរបស់ជនទាំងនោះ ថ្ងៃមួយ ចូលទៅកាន់ស្រុកសួយរបស់ខ្លួន បានឲ្យកាឡកិណីជាអ្នករក្សាផ្ទះរបស់ខ្លួន ។

ពួកចោរគិតថា បានឮថា សេដ្ឋីទៅស្រុកសួយ ពួកយើងនឹងប្លន់ផ្ទះរបស់គាត់ចុះ នាំគ្នាកាន់អាវុធផ្សេងៗ មកក្នុងពេលយប់ ព័ទ្ធផ្ទះ ។ ឯកាឡកិណីសង្ស័យនឹងការមករបស់ពួកចោរ ទើបអង្គុយយាម មិនព្រមដេកឡើយ កាលដឹងថា ពួកចោរនាំគ្នាមក ដើម្បីជាស់ពួកមនុស្ស ទើបបង្គាប់ថា ចូរផ្លុំស័ង្ខ ចូរវាយស្គរ ដូច្នេះហើយ ធ្វើឲ្យដូចជាមានមហោស្រពរោងធំ ធ្វើនិវេសន៍ទាំងមូលឲ្យមានសំឡេងរហូតទៅ ពួកចោរនាំគ្នាពោលថា បានឮថា ផ្ទះទទេ ពួកយើងឮមកខុស តាមពិតសេដ្ឋីនៅទីនេះ ហើយនាំគ្នាចោលដុំថ្ម និងដំបងជាដើមត្រង់នោះឯងគេចទៅ ។ ស្អែកឡើង ពួកមនុស្សឃើញដុំថ្ម និងដំបងជាដើម ដែលពួកចោរចោលក្នុងទីនោះៗ សង្វេគតាមៗ គ្នា ពោលថា បើថ្ងៃនេះ មិនមានអ្នកយាមផ្ទះដែលសម្បូរដោយចំណេះដឹងបែបនេះទេ ពួកចោរនឹងនាំគ្នាចូលបានតាមគាប់ចិត្ត ប្លន់ផ្ទះបានទាំងអស់ពិត ព្រោះអាស្រ័យមិត្រមាំទាំនេះ ទើបការចម្រើនកើតដល់លោកសេដ្ឋី នាំគ្នាសរសើរកាឡកិណីនោះ ពេលដែលសេដ្ឋីមកអំពីស្រុកសួយ នាំគ្នាប្រាប់រឿងនោះឲ្យដឹងគ្រប់ប្រការ ។ កាលនោះ សេដ្ឋីបានពោលនឹងមនុស្សទាំងនោះថា ពួកអ្នកប្រាប់ឲ្យយើងដេញមិត្រដែលរក្សាផ្ទះយ៉ាងនេះចោល បើយើងដេញសម្លាញ់តាមពាក្យរបស់ពួកអ្នក ថ្ងៃនេះ ទ្រព្យរបស់យើង ក៏មិនមានសល់ឡើយ ធម្មតាឈ្មោះ មិនជាប្រមាណឡើយ ចិត្តដែលគិតឧបការៈប៉ុណ្ណោះ ជាប្រមាណ ដូច្នេះហើយ

ឲ្យទ្រព្យជាទុនដល់បុរសនោះក្រៃលែងឡើង ត្រិះរិះថា ឥឡូវនេះ អញមានរឿងដែលនឹងផ្ដើមក្រាបទូលបានហើយ ទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលរឿងនោះ តាំងអំពីដើមរហូតដល់ចប់ដល់ព្រះសាស្ដា ព្រះសាស្ដាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមិត្រឈ្មោះកាឡកិណីរក្សាទ្រព្យក្នុងផ្ទះនៃមិត្ររបស់ខ្លួន សូម្បីក្នុងកាលមុន ក៏រក្សាហើយដូចគ្នា លោកសេដ្ឋីក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីត មកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាសេដ្ឋី មានយសធំក្រៃលែង លោកសេដ្ឋីមានមិត្រឈ្មោះកាឡកិណី ។ រឿងទាំងអស់ ដូចគ្នានឹងរឿងបច្ចុប្បន្ននេះឯង ។ ព្រះពោធិសត្វ មកអំពីស្រុកស្មួយហើយ ស្ដាប់រឿងនោះហើយ ពោលថា បើខ្ញុំដេញមិត្របែបនេះចេញទៅតាមពាក្យរបស់ពួកអ្នកហើយ ថ្ងៃនេះ ទ្រព្យសម្បត្តិរបស់យើង នឹងមិនមានសល់ឡើយ ហើយពោលគាថានេះថា

បុគ្គលដែលជាមិត្តបាន ដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ៧ ជំហាន បុគ្គលជាសម្លាញ់បាន ដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ១២ ជំហាន បុគ្គលជាញាតិបាន ដោយ ( ការនៅជាមួយគ្នា ) ១ ខែ ឬកន្លះខែ បុគ្គលដែលទុកស្មើនឹងខ្លួន ព្រោះនៅលើសអំពីកាលនោះទៅទៀត ខ្ញុំនោះ នឹងលះបង់នូវសម្លាញ់ឈ្មោះកាឡ-កិណី ដែលធ្លាប់ស្និទ្ធស្នាលអស់កាលយូរ ព្រោះហេតុនៃសេចក្ដី

សុខរបស់ខ្លួនដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហវេ** ត្រឹមតែជានិបាត ។ ឈ្មោះថា មិត្រ ព្រោះអត្ថថា ប្រព្រឹត្តមេត្រី អធិប្បាយថា ចូលទៅតាំងទុកចំពោះមេត្រីចិត្ត ធ្វើសេចក្តីស្និទ្ធស្នាលមិត្រនោះទៅជាមួយគ្នាបាន ៧ ជំហាន អធិប្បាយថា ទៅជាមួយគ្នាបាន ដោយហេតុត្រឹមតែដើរផ្លូវជាមួយគ្នាបាន ៧ ជំហាន ។

បទថា **សហាយោ បន ទ្វាទសកេន ហោតិ** សេចក្តីថា ដែល ឈ្មោះថា **សម្លាញ់** ព្រោះអត្ថថា ទៅរួមគ្នាក្នុងឥរិយាបថទាំងពួង ដោយ អំណាចនៃការធ្វើកិច្ចគ្រប់យ៉ាងរួមគ្នា អធិប្បាយថា សម្លាញ់នោះ ដើរទៅជា មួយគ្នាត្រឹម ១២ ជំហាន ។

បទថា **មាសឌ្ឍមាសេន** សេចក្តីថា នៅរួមគ្នាមួយខែ ឬកន្លះខែ ។

បទថា **ញាតិ ហោតិ** សេចក្តីថា រមែងឈ្មោះថា ជាអ្នកស្មើញាតិ ។

បទថា **តតុត្តរឹ** សេចក្តីថា ដោយការនៅរួមគ្នាក្រៃលែងជាងនោះ រមែង ឈ្មោះថា ជាអ្នកស្មើខ្លួនបាននោះឯង ។

បទថា **ជហេយ្យំ** សេចក្តីថា ខ្ញុំលះបង់សម្លាញ់បែបនេះបានដូចម្តេច ព្រះពោធិសត្វពោលដល់គុណរបស់មិត្រនោះឯង ដោយប្រការដូច្នេះ ។ តាំង

អំពីនោះមក ក៏មិនមានបុគ្គលណាម្នាក់ ដែលបានឈ្មោះថា ពោលមើលងាយកាឡកិណីនោះទៀតឡើយ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កាឡកិណីក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯពារាណសីសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា កាឡកណ្ណិជាតក ចប់**

# សុត្តន្តបិដក

## អត្ថស្សទ្វារជាតក

[ ៨៤ ] ( សេដ្ឋីពោធិសត្វជាបិតាពោលថា ) បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល ( គឺមារយាទ ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង ១ ការឧស្សាហ៍ស្តាប់ ១ ការអនុវត្តន៍នូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ ធម៌ទាំង ៦ នេះ ជាទ្វារ ទាំងជាប្រធាននៃសេចក្តីចម្រើន ។

អត្ថស្សទ្វារជាតកទី ៤ ចប់

# អដ្ឋកថា

## អត្ថស្សទ្វារជាតក

[ ៨៤ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុត្រដែលឈ្លាសក្នុងប្រយោជន៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អារោគ្យមិច្ឆេ បរមញ្ច លាភំ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ក្នុងនគរសាវត្ថី បុត្ររបស់លោកសេដ្ឋីមានសម្បត្តិច្រើនម្នាក់ កើតមកបាន ៧ ឆ្នាំ ជាអ្នកមានបញ្ញាឈ្លាសវៃក្នុងប្រយោជន៍ ។ ថ្ងៃមួយ ចូលទៅរកបិតា សួរដល់រឿងដែលឈ្មោះថា ទ្វារនៃប្រយោជន៍ សេដ្ឋីជាបិតាមិនដឹងបញ្ហានោះ ទើបកើតបរិវិតក្កថា បញ្ហានេះសុខុមពេក វៀរព្រះសម្មាសម្ពុទ្ធហើយ អ្នកដទៃក្នុងលោកសន្និវាស ដោយកំណត់ដោយភវគ្គព្រហ្មជាចំណែកបំផុតខាងលើ និងដោយអវិចីជាចំណែកបំផុតខាងក្រោម ដែលឈ្មោះថា អាចស្រាយបញ្ហានេះ មិនមានឡើយ ទើបលោកនាំបុត្រឲ្យកាន់ផ្កាគ្រឿងក្រអូប និងគ្រឿងលាបជាច្រើនទៅកាន់ជេតពនវិហារ បូជាព្រះសាស្ដាហើយថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ទូលសេចក្ដីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្មេងនេះ មានបញ្ញាឈ្លាសក្នុងប្រយោជន៍ សួររកទ្វារនៃប្រយោជន៍ជាមួយខ្ញុំព្រះអង្គៗ មិនដឹងបញ្ហានោះ ទើបមកកាន់សម្នាក់ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមទ្រង់ដោះបញ្ហានោះចុះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលឧបាសក សូម្បីក្នុងកាលមុន តថាគតក៏ត្រូវក្មេងនេះសួរបញ្ហានោះហើយ តថាគតក៏ពោលដោះស្រាយបញ្ហានោះនឹងក្មេងនោះហើយ ក្នុងកាលនោះ កុមារនេះចាំទូវបញ្ហានោះ តែឥឡូវនេះកំណត់

មិនបាន ព្រោះភពបិទបាំង លោកសេដ្ឋីទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី មានសម្បត្តិច្រើន កាលនោះ បុត្ររបស់លោកកើតមកបាន ៧ ឆ្នាំ ជាអ្នកមានបញ្ញាឈ្លាសក្នុងប្រយោជន៍ ថ្ងៃមួយ ចូលទៅរកបិតា សួរបញ្ហារឿងទ្វារនៃប្រយោជន៍ថា បពិត្របិតា អ្វីដែលឈ្មោះថាទ្វារនៃប្រយោជន៍ កាលនោះ បិតារបស់កុមារ កាលពោលឆ្លើយបញ្ហានោះ បានពោលគាថានេះថា

បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល ( គឺមារយាទ ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង ១ ការឧស្សាហ៍ស្តាប់ ១ ការអនុវត្តន៍នូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ ធម៌ទាំង ៦ នេះ ជាទ្វារ ទាំងជាប្រធាននៃសេចក្តីចម្រើនដូច្នេះ ។

បណ្តាបទទាំងនោះ ៥ អក្ខរៈ ក្នុងបទថា **អារោគ្យមិច្ឆេ បរមញ្ច លាភំ** ត្រឹមតែជានិបាត ។ ព្រះពោធិសត្វកាលសម្តែងសេចក្តីនេះថា នែបា ជាបឋមគប្បីប្រាថ្នាលាភដ៏កំពូល ពោល គឺការមិនមានរោគ ទើបពោលយ៉ាងនេះ ។

ឈ្មោះថា ការមិនមានរោគ ក្នុងបាទគាថាថា **អារោគ្យមិច្ឆេ បរមញ្ច លាភំ** នោះ បានដល់ អាការដែលមិនមានសភាវៈចាក់ដោត មិនមានអាការក្រវល់ក្រវាយតាមផ្លូវកាយ និងចិត្ត ព្រោះថា កាលរាងកាយត្រូវចាក់ដោត

ក្រវល់ក្រវាយ បុគ្គលរមែងមិនអាចញ៉ាំងលាភដែលមិនទាន់បាន ឲ្យកើតឡើង ដែលបានហើយ ក៏មិនអាចប្រើប្រាស់ តែកាលមិនក្រវល់ក្រវាយ រមែងអាចបណ្តាលឲ្យកើតបានទាំង ២ ស្ថាន ម្យ៉ាងទៀត កាលចិត្តក្តៅក្រហាយព្រោះឧបក្កិលេស បុគ្គលក៏មិនអាចញ៉ាំងលាភ គឺគុណវិសេស មានឈានជាដើម ដែលមិនទាន់កើត ឲ្យកើតឡើងបាន ដែលបានហើយ ក៏មិនអាចសរសើរដោយអំណាចនៃសមាបត្តិទៀតបាន កាលរោគនេះនៅមាន លាភដែលមិនបាន ក៏ជាការមិនបាន លាភដែលបានហើយ ក៏ឥតប្រយោជន៍ តែកាលរោគមិនមាន លាភដែលមិនទាន់បាន ក៏ត្រូវបាន លាភដែលបានហើយ រមែងឲ្យនូវប្រយោជន៍ ហេតុនោះ ការមិនមានរោគ ទើបឈ្មោះថា ជាលាភក្រៃលែង ចាំបាច់ប្រាថ្នានូវការមិនមានរោគនោះមុនគេបង្អស់ នេះជាទ្វារនៃប្រយោជន៍ទាំងអស់ នេះជាអធិប្បាយក្នុងសេចក្តីនោះ ។

បទថា **សីលញ្ច** បានដល់ អាចារសីល គឺរបៀបក្នុងចំណែកដែលជាមារយាទ ។ ព្រះពោធិសត្វសម្តែងដល់ចរិតរបស់សត្វលោកដោយបទនេះ ។

បទថា **វុទ្ធានុមតំ** បានដល់ ការអនុលោមតាមបណ្ឌិតដែលចម្រើនដោយគុណទាំងឡាយ ព្រះពោធិសត្វសម្តែងឱវាទរបស់គ្រូទាំងឡាយ ដែលសម្បូរដោយការដឹងដោយបទនេះ ។

បទថា **សុតញ្ច** គឺការស្តាប់ដែលអាស្រ័យហេតុ ព្រះពោធិសត្វសម្តែងពហុសច្ចៈ ភាពជាអ្នកចេះដឹងច្រើនដែលអាស្រ័យខ្លួនក្នុងលោកនេះ ដោយបទនេះ ។

បទថា **ធម្មានុវត្តី** ច បានដល់ ការអនុលោមតាមសុចរិតធម៌ មាន ៣ យ៉ាង ។ ព្រះពោធិសត្វសម្តែងការវៀរទុច្ចរិតធម៌ ហើយប្រព្រឹត្តសុចរិតធម៌ ដោយបទនេះ ។

បទថា **អលីនតា** ច បានដល់ ភាពដែលចិត្តមិនរួញរា មិនធ្លាក់ចុះ ។ ព្រះពោធិសត្វសម្តែងភាពដែលចិត្ត ជាសភាពប្រណីត និងជាសភាពខ្ពស់ក្រៃលែង ដោយមិនវិនាស ដោយបទនេះ ។

បទថា **អត្ថស្ស ទ្វារា បមុខា ឆឡេតេ** សេចក្តីថា ការចម្រើន ឈ្មោះថា ប្រយោជន៍ ធម៌ទាំង ៦ ប្រការនេះ ជាប្រធាន ជាទ្វារ ជាឧបាយ គឺជាផ្លូវសម្រេចប្រយោជន៍ដែលជាលោកិយ និងលោកុត្តរ ពោល គឺសេចក្តីចម្រើននោះ ។

ព្រះពោធិសត្វពោលឆ្លើយបញ្ហាទ្វារនៃប្រយោជន៍ដល់កូន ដោយប្រការដូច្នេះ ។ តាំងអំពីនោះមក ក៏ប្រព្រឹត្តក្នុងធម៌ ៦ ប្រការនោះ ព្រះពោធិសត្វបំពេញបុណ្យ មានទានជាដើម ហើយក៏ទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ប្រជុំជាតកថា បុត្រក្នុងកាលនោះ បានមកជាបុត្ររបស់អ្នកក្នុងបច្ចុប្បន្ននេះ ឯមហាសេដ្ឋី ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា អត្ថស្សទ្វារជាតក ចប់**

# សុត្តន្តបិដក

## កិម្បកជាតក

[ ៨៥ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាមទាំងឡាយ ( កាមទាំងនោះ ) តែងសម្លាប់បុគ្គលនោះ ក្នុងទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ ( ឈើពុល )ៗ

**កិម្បកជាតកទី ៥ ចប់**

# អដ្ឋកថា

## កិម្បកជាតក

[ ៨៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អាយតឹ ទោសំ ឆាញ្ញាយ** ដូច្នេះជាដើម ។

បានឮថា កុលបុត្រម្នាក់ បួសថ្វាយជីវិតក្នុងព្រះពុទ្ធសាសនា ថ្ងៃមួយត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្រីម្នាក់ តែងខ្លួនស្អាតបាត កើតអផ្សុក កាលនោះ អាចារ្យ និងឧបជ្ឈាយ៍ នាំលោកមកកាន់សម្នាក់របស់ព្រះបរមសាស្តា ។ ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកអផ្សុកពិតឬ ។ កាលលោកក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថាបញ្ចកាមគុណទាំងនេះ គួរត្រេកអរក្នុងពេលបរិភោគ តែកាលបរិភោគបញ្ចកាមគុណទាំងនោះ ប្រៀបបាននឹងការបរិភោគផ្លែឈើឈ្មោះកិម្បក្កៈ ដែលមានជាតិពុល ព្រោះជាហេតុឲ្យបដិសន្ធិក្នុងនរកជាដើម ដែលឈ្មោះថា ផ្លែកិម្បក្កៈ សម្បូរដោយពណ៌ ក្លិន និងរស តែបរិភោគចូលទៅហើយ ក៏ដាច់នូវពោះវៀន ធ្វើឲ្យអស់ជីវិត ។ ក្នុងកាលមុន មនុស្សជាច្រើន មិនឃើញទោសរបស់ផ្លែនេះ ជាប់ចិត្តក្នុងពណ៌ ក្លិន និងរស នាំគ្នាបរិភោគផ្លែនោះ ក៏ដល់នូវការអស់ជីវិត កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាឈ្មួញរទេះ គ្រប់គ្រងរទេះ ៥០០ ធ្វើដំណើរ

ទៅកាន់ជាយដែនឆ្ងាយៗ ដល់មាត់ព្រៃ ហៅមនុស្សទាំងឡាយ ប្រជុំជាស់តឿនថា ក្នុងព្រៃនេះ មានដើមឈើដែលមានពិស បើមិនសួរយើងជាមុន កុំបរិភោគផ្លែដែលមិនធ្លាប់បរិភោគមកអំពីមុនជាដាច់ខាត ជនដែលធ្វើដំណើរឆ្លងកាត់ព្រៃ បានឃើញដើមកិម្បក្កៈមួយដើម មានមែកទន់ចុះ ព្រោះធ្ងន់នឹងផ្លែ ដើមក្តី មែកក្តី ស្លឹកក្តីនៃដើមនេះ ដូចគ្នានឹងដើមស្វាយ ទាំងសណ្ឋានពណ៌ ក្លិន និងរស នាំគ្នាបរិភោគផ្លែនោះ ដោយសម្គាល់ថា ជាផ្លែស្វាយ ជនពួកខ្លះគិតថា ត្រូវសួរព្រះពោធិសត្វ សឹមបរិភោគ ឈរវង់ចាំ កាលព្រះពោធិសត្វមកដល់ទីនោះ ក៏ស្រែកប្រាប់ពួកអ្នកដែលឈរវង់ចាំនោះឲ្យចោលផ្លែឈើ ធ្វើឲ្យពួកជនដែលបរិភោគចូលទៅហើយឲ្យក្អួត ហើយឲ្យបរិភោគថ្នាំ ជនទាំងនោះក៏ជាសះស្បើយ តែជនខ្លះក៏អស់ជីវិត ឯព្រះពោធិសត្វ ក៏ធ្វើដំណើរដល់ទីដែលមានសួស្តី បានលាភហើយ ត្រឡប់មកដល់លំនៅដ្ឋានធ្វើបុណ្យទាំងឡាយ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់ត្រាស់ជីងក្រែលែងហើយ ទើបទ្រង់ត្រាស់រឿងនោះ ត្រាស់ព្រះគាថានេះថា

បុគ្គលណា មិនយល់ទោស ក្នុងអនាគត ហើយសេពកាមទាំងឡាយ ( កាមទាំងនោះ ) តែងសម្លាប់បុគ្គលនោះ ក្នុងទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ ( ឈើពុល ) ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **អាយតឹ ទោសំ ញាញ្ញាយ** សេចក្តីថា មិនដឹង គឺមិនជ្រាបនូវទោសក្នុងកាលខាងមុខ ។

បទថា **យោ កាមេ បដិសេវតិ** សេចក្តីថា បុគ្គលណាសេពវត្ថុកាម និងកិលេសកាម ។

បទថា **វិបាកន្តេ ហនន្តិ នំ** សេចក្តីថា កាមទាំងនោះ នឹងញាំងបុរសនោះ ដែលកើតហើយក្នុងនរកជាដើម ឲ្យជាប់ដោយសេចក្តីទុក្ខ មានប្រការផ្សេងៗ ក្នុងទីបំផុត ពោល គឺក្នុងកាលសោយវិបាករបស់ខ្លួន ឈ្មោះថាកម្ចាត់បុគ្គលនោះហើយ ។ កម្ចាត់ដូចម្តេច ។

ដូចផ្លែកិម្បក: ដែលបុគ្គលបរិភោគហើយ ដូច្នោះ អធិប្បាយថា ឧបមាដូចផ្លែកិម្បក: គួរពេញចិត្ត ព្រោះដល់ព្រមដោយពណ៌ ក្លិន និងរស ក្នុងកាលបរិភោគ ធ្វើឲ្យបុគ្គលដែលមិនឃើញទោសក្នុងអនាគត ស៊ីហើយ ដល់នូវការអស់ជីវិត យ៉ាងណា កាមទាំងឡាយ គួរពេញចិត្តក្នុងគ្រាបរិភោគ ក៏នឹងកម្ចាត់បុគ្គលនោះ ក្នុងកាលឲ្យផល ដូច្នោះ ។

ព្រះបរមសាស្តាទ្រង់សម្តែងធម៌តាមអនុសន្ធិ ហើយទ្រង់ប្រកាសសច្ច:ទាំងឡាយ ក្នុងកាលចប់សច្ច: ភិក្ខុអផ្សុកសម្រេចសោតាបត្តិផល បរិស័ទដ៏សេសបានជាព្រះសោតាបន្ន ពួកខ្លះ បានជាសកទាគាមី ពួកខ្លះ បានជាអនាគាមី ពួកខ្លះ បានជាព្រះអរហន្ត ។ ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯឈ្មួញរទេះក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា កឹម្បកជាតក ចប់**

# សុត្តន្តបិដក

## សីលវីមំសជាតក

[ ៨៦ ] ( ព្រាហ្មណ៍បុរោហិតពោធិសត្វពោលថា ) បានឮថា សីលជាគុណជាតល្អ សីលជាគុណជាតដ៏លើសលុប ក្នុងលោក សូមព្រះអង្គទតចុះ ពស់មានពិសដ៏ពន្លឹក មិនបៀតបៀនគេ ឈ្មោះថា ជាសត្វមានសីល ។

សីលវីមំសនជាតកទី ៦ ចប់

# អដ្ឋកថា

## សីលវីមំសនជាតក

[ ៨៦ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ដែលសាកល្បងសីលម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សីលំ កិរេវ កល្យាណំ** ដូច្នេះជាដើម ។

បានឮមកថា ព្រាហ្មណ៍នោះ អាស្រ័យព្រះបាទកោសលចិញ្ចឹមជីវិត ជាអ្នកដល់នូវត្រៃសរណគមន៍ មានសីល ៥ មិនដាច់ ជាអ្នកដល់ត្រើយនៃវេទ ព្រះរាជាទ្រង់ត្រិះរិះថា ព្រាហ្មណ៍នេះមានសីល ដូច្នេះហើយ ទ្រង់សរសើរក្រៃលែង ។ ព្រាហ្មណ៍គិតថា ព្រះរាជានេះទ្រង់សរសើរអញក្រៃលែងជាងព្រាហ្មណ៍ដទៃៗ ទ្រង់ឃើញអញដូចជាបុគ្គលគួរគោរពក្រៃលែង ទ្រង់ធ្វើការសរសើរនេះ ព្រោះអាស្រ័យជាតិសម្បត្តិ គោត្តសម្បត្តិ កុលសម្បត្តិ បទេសសម្បត្តិ និងសិប្បសម្បត្តិរបស់អញឬហ្ន៎ ឬទ្រង់អាស្រ័យសីលសម្បត្តិរបស់អញ អញនឹងសាកល្បងមើល ។ ថ្ងៃមួយ ព្រាហ្មណ៍ចូលកាន់ទីគាល់ កាលត្រឡប់មកផ្ទះ បានចាប់យកកហាបណៈ ១ អំពីហិបរបស់ហិរញ្ញិកម្នាក់ ដោយមិនបានប្រាប់ឡើយ គ្រានោះ ហិរញ្ញិកមិនបានពោលអ្វីជាមួយគាត់ ព្រោះគោរពក្នុងព្រាហ្មណ៍ អង្គុយព្រងើយ ។ ស្អែកឡើង បានចាប់យក ២ កហាបណៈ ហិរញ្ញិកក៏នៅស្ងៀមដូចគ្នា ក្នុងថ្ងៃទី ៣ ព្រាហ្មណ៍ស្រវាយកមួយក្ដាប់ កាលនោះ ហិរញ្ញិកពោលថា ថ្ងៃនេះជាថ្ងៃទី ៣ ដែលលោកយកព្រះរាជទ្រព្យទៅ ស្រែកប្រកាស ៣ ដងថា យើងចាប់ចោរលួចទ្រព្យរបស់ព្រះរាជាបានហើយ កាលនោះ មនុស្សទាំងឡាយ រត់មកអំពីទិសផ្សេងៗ

និយាយនឹងព្រាហ្មណ៍ថា អ្នកក្លែងប្រព្រឹត្តដូចជាអ្នកមានសីលមកអស់កាលយូរបែបនេះ ដូច្នេះហើយ ក៏វាយ ២-៣ ដង ចាប់ចងទៅបង្ហាញដល់ព្រះរាជាៗ ក្តៅព្រះហឫទ័យ ត្រាស់ថា នែព្រាហ្មណ៍ ហេតុអ្វី ទើបធ្វើកម្មរបស់អ្នកទ្រុស្តសីលបែបនេះ ហើយត្រាស់ថា ពួកអ្នកទៅចុះ ចូរដាក់ព្រះរាជអាជ្ញាដល់ព្រាហ្មណ៍ៗ ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមិនមែនចោរទេ ព្រះរាជាសួរថា បើដូច្នោះ ហេតុអ្វី ទើបអ្នកចាប់យកកហាបណៈអំពីហិបនៃព្រះរាជទ្រព្យ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំធ្វើនេះ ក្នុងកាលទ្រង់សរសើរទូលបង្គំក្រៃលែងបែបនោះ ក៏ដើម្បីសាកល្បងថា ព្រះរាជាសរសើរអញក្រៃលែង ព្រោះអាស្រ័យជាតិសម្បត្តិជាដើមឬដូចម្តេច ឬទ្រង់សរសើរអាស្រ័យសីល ឥឡូវនេះ ទូលបង្គំជ្រាបដោយពិតហើយ ព្រោះទ្រង់ដាក់រាជអាជ្ញាដល់ទូលបង្គំឥឡូវនេះ ក៏ដឹងបានថា ការដែលទ្រង់សរសើរដល់ទូលបង្គំនោះ អាស្រ័យសីលតែម្យ៉ាង មិនបានធ្វើព្រោះអាស្រ័យសម្បត្តិមានជាតិជាដើមឡើយ ហើយក្រាបទូលបន្តថា ទូលបង្គំបានដាក់ចិត្តដោយហេតុនេះថា ក្នុងលោកនេះ សីលប៉ុណ្ណោះ ឧត្តម សីលជាប្រធាន កាលទូលបង្គំធ្វើឲ្យសមគួរដល់សីលនេះ គង់តាំងខ្លួននៅក្នុងផ្ទះ បរិភោគ កិលេសនឹងមិនអាចធ្វើបាន ថ្ងៃនេះឯង ទូលបង្គំទៅកាន់វត្តជេតពន បួសក្នុងសម្នាក់ព្រះសាស្តា សូមទ្រង់ព្រះរាជទានបព្វជ្ជាដល់ទូលបង្គំចុះ ។ កាលបានព្រះរាជានុញ្ញាតហើយ ក៏ដើរទៅកាន់វត្តជេតពនមហាវិហារ កាលនោះ ពួកញាតិនាំគ្នារាប់អាន នាំគ្នាចោមរោម កាលមិនអាចឃាត់បាន ក៏នាំគ្នាត្រឡប់ទៅ ។

ព្រាហ្មណ៍ទៅកាន់សម្នាក់របស់ព្រះសាស្ដា ទូលសូមបព្វជ្ជា កាលបាន បព្វជ្ជា និងឧបសម្បទាហើយ ក៏មិនលះបង់កម្មដ្ឋាន ចម្រើនវិបស្សនា សម្រេច អរហត្តផល ចូលគាល់ព្រះបរមសាស្ដា ទូលព្យាករអរហត្តផលថា បពិត្រ ព្រះអង្គដ៏ចម្រើន បព្វជ្ជាខ្ញុំព្រះអង្គដល់ទីបំផុតហើយ ពាក្យព្យាករអរហត្តផល នោះ នៃភិក្ខុនោះ ប្រាកដក្នុងភិក្ខុសង្ឃហើយ ។ ថ្ងៃមួយ ពួកភិក្ខុប្រជុំគ្នាក្នុង ធម្មសភា អង្គុយសន្ទនាដល់គុណរបស់លោកថា អាវុសោទាំងឡាយ ព្រាហ្មណ៍ឧបដ្ឋាកព្រះរាជាឈ្មោះនោះ ពិសោធសីលរបស់ខ្លួនហើយ ទូលលា ព្រះរាជាបព្វជ្ជា តាំងនៅក្នុងអរហត្តហើយ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នា ដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលព្រាហ្មណ៍នេះសាកល្បងសីលរបស់ ខ្លួន ហើយបួស ធ្វើទីពឹងដល់ខ្លួនបាន សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយ ក៏ធ្លាប់សាកល្បងសីលរបស់ខ្លួន ហើយបួស ធ្វើទីពឹងដល់ខ្លួនមកហើយដូច គ្នា ។ កាលភិក្ខុទាំងនោះអារាធនាហើយ ទ្រង់នាំយកអតីតនិទានមកសាធកៈ ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វបានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្តអង្គនោះ ជា អ្នកមានចិត្តបង្អោនទៅក្នុងទាន មានសីលជាអធ្យាស្រ័យ រក្សាសីល ៥ មិន

ដាច់ ព្រះរាជាទ្រង់សរសើរក្រៃលែងជាងព្រាហ្មណ៍ដ៏សេស ។ រឿងទាំងអស់ដូចគ្នានឹងរឿងដំបូងនោះឯង ប៉ុន្តែព្រះពោធិសត្វ កាលគេចងនាំទៅកាន់សម្នាក់ព្រះរាជា ពួកអាលម្ពាយកំពុងបញ្ចូពស់ឲ្យរាំក្នុងរវាងផ្លូវ នាំគ្នាចាប់ពស់ត្រង់កន្ទុយ ចាប់ត្រង់ក យកពស់រុំក ។ ព្រះពោធិសត្វឃើញជនទាំងនោះហើយ ពោលថា នែអ្នកទាំងឡាយ អ្នកកុំចាប់ពស់នេះត្រង់កន្ទុយ កុំចាប់ត្រង់ក កុំយកមកព័ទ្ធព័ន្ធក ព្រោះពស់នេះចឹកហើយ ក៏នឹងត្រូវដល់នូវការអស់ជីវិត ពួកអាលម្ពាយពោលថា នែព្រាហ្មណ៍ ពស់នេះមានសីលបរិបូណ៌ដោយមារយាទ មិនមែនជាអ្នកទ្រុស្តសីលដូចលោកទេ លោកជាអ្នកមិនមានអាចារ ព្រោះភាពជាអ្នកទ្រុស្តសីល មានឈ្មោះថាជាចោរដណ្តើមព្រះរាជទ្រព្យ កំពុងចងនាំទៅ ព្រាហ្មណ៍បានគិតថា ពស់នេះ ទោះបីមិនចឹកអ្នកណា មិនបៀតបៀនអ្នកណា ក៏មិនឈ្មោះថា មានសីល នឹងពោលថ្វីដល់ពួកមនុស្សក្នុងលោកនេះ សីលប៉ុណ្ណោះ ឈ្មោះថា ឧត្តម វត្ថុដទៃក្រៃលែងជាងសីល មិនមាន ។ កាលមនុស្សនាំខ្លួនទៅបង្ហាញដល់ព្រះរាជា ហើយព្រះរាជាត្រាស់សួរថា នែបា នេះរឿងអ្វី ។ ពួករាជបុរសក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចោរលួចរាជទ្រព្យ ក៏ត្រាស់ថា បើដូច្នោះ ចូរពួកអ្នកធ្វើតាមរាជអាជ្ញាដល់ព្រាហ្មណ៍ចុះ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមិនមែនចោរទេ កាលទ្រង់ត្រាស់សួរថា បើដូច្នោះ ហេតុអ្វីកាន់យកកហាបណៈទៅ ទើបក្រាបទូលរឿងទាំងអស់ ដោយន័យក្នុងរឿងមុននោះឯង ហើយក្រាបទូលថា ដោយហេតុនេះ ទូលបង្គំដាក់ចិត្តហើយថា

ក្នុងលោកនេះ សីលប៉ុណ្ណោះ ជារបស់ប្រសើរ សីលជាប្រធាន ហើយក្រាបទូលថា សេចក្តីនេះ លើកទុកចុះ អាសិរពិស សូម្បីមិនចឹកអ្នកណា មិនបៀតបៀនអ្នកណា ក៏មិនបានឈ្មោះថា មានសីលឡើយ ព្រោះហេតុនេះ សីលប៉ុណ្ណោះឧត្តម សីលប៉ុណ្ណោះប្រសើរ កាលសរសើរសីល ទើបពោលគាថានេះថា

បានឮថា សីល ជាគុណជាតល្អ សីល ជាគុណជាតដ៏លើសលុប ក្នុងលោក សូមព្រះអង្គទតចុះ ពស់មានពិសដ៏ពន្លឹក មិនបៀតបៀនគេ ឈ្មោះថា ជាសត្វមានសីល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលំ កិរេវ** បានដល់ សីល គឺមារយាទពោល គឺការមិនកន្លងល្មើសនោះឯង ដោយកាយ វាចា និងចិត្ត ។

បទថា **កិរ** សេចក្តីថា ព្រះពោធិសត្វពោលតាមដែលបានឮមក ។

បទថា **កល្យាណំ** បានដល់ ស្អាត គឺប្រសើរ ។

បទថា **អនុត្តរំ** បានដល់ លើសលប់ គឺឲ្យគុណបានគ្រប់យ៉ាង ។

បទថា **បស្ស** បានដល់ ពោលសំដៅដល់ហេតុចំពោះដែលខ្លួនឃើញ ។

បទថា **សីលវាតិ ច ហញ្ញតិ** សេចក្តីថា ពស់មានពិសពន្លឹក គង់បានទទួលការសរសើរថា មានសីល ដោយហេតុគ្រាន់តែមិនចឹកបុគ្គលណាម្នាក់ មិនបៀតបៀនបុគ្គលណាម្នាក់ រមែងមិនត្រូវបុគ្គលណាប្រទូស្ត គឺមិនត្រូវបុគ្គលណាសម្លាប់ ដោយហេតុដូចពោលមកនេះ ទើបសីលនោះឯង ឈ្មោះថា ឧត្តម ។

ព្រះពោធិសត្វ សម្តែងធម៌ថ្វាយព្រះរាជាដោយគាថានេះ ដោយប្រការដូច្នេះ លះកាមទាំងឡាយ បួសជាឥសី ចូលព្រៃហិមពាន្ត ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ចំណែកបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សីលវីមំសនជាតក ចប់**

# សុត្តន្តបិដក

## មង្គលជាតក

[ ៨៧ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះ ឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល ( ភ្ញាក់ផ្អើល ) ជាអ្នកគ្របសង្កត់នូវយុគក្កិលេស និងយោគក្កិលេស រមែងមិនមកកើតទៀត ។

**មង្គលជាតកទី ៧ ចប់**

# អដ្ឋកថា

## មង្គលជាតក

[ ៨៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវនវិហារ ទ្រង់ប្រារព្ធព្រាហ្មណ៍ ដែលស្គាល់លក្ខណៈសំពត់សាដកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្ស មង្គលា សមូហតា** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍អ្នកនគររាជគ្រឹះម្នាក់ ជាអ្នកជឿមង្គលភ្ញាក់ផ្អើល មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាមិច្ឆាទិដ្ឋិ ជាអ្នកស្តុកស្តម្ភដោយទ្រព្យ មានភោគៈច្រើន ។ កណ្តុរកាត់សំពត់សាដក ដែលគាត់ទុកក្នុងហិប កាលដល់ពេលគាត់ងូតទឹក ពោលថា ចូរនាំសាដកមក ទើបមនុស្សទាំងឡាយប្រាប់ការដែលកណ្តុរកាត់សំពត់ដល់គាត់ ព្រាហ្មណ៍គិតថា បើសំពត់សាដកទាំងគូដែលកណ្តុរកាត់នេះ នៅក្នុងផ្ទះនេះ សេចក្តីវិនាសធំនឹងមាន ព្រោះសំពត់គូនេះ ជាអវមង្គល ដូចគ្នានឹងរបស់កាឡកិណី មិនអាចឲ្យដល់បុត្រធីតាផងទាសកម្មករផង ព្រោះសេចក្តីវិនាសធំ នឹងត្រូវមានដល់បុគ្គលដែលទទួលសំពត់នេះគ្រប់គ្នា អញត្រូវបោលវាក្នុងព្រៃខ្មោច តែមិនហ៊ានឲ្យក្នុងដៃពួកទាសៈជាដើម ព្រោះខ្លាចជនទាំងនោះចង់បានក្នុងគូសំពត់នេះ កាន់ទៅហើយដល់នូវសេចក្តីវិនាសតៗ គ្នា អញនឹងឲ្យកូនកាន់សំពត់គូនេះទៅ ហើយហៅកូនមកប្រាប់រឿងនោះ ប្រើទៅដោយពាក្យថា នែបា សូម្បីខ្លួនអ្នក ក៏មិនត្រូវយកដៃចាប់ ត្រូវយកឈើច្នុះទៅបោលក្នុងព្រៃខ្មោច ងូតទឹកសម្អាតខ្លួនប្រាណហើយ សឹមមក ។

ព្រះបរមសាស្តា ក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលវេនេយ្យសត្វ ឃើញឧបនិស្ស័យនៃសោតាបត្តិផលនៃឪពុក និងកូនទាំង ២ នាក់ យាងទៅដូចព្រានម្រឹគ តាមម្រឹគ ដូច្នោះ បានប្រថាប់ឈរក្នុងព្រៃខ្មោច បញ្ចេញឆព្វណ្ណរង្សី ។ មាណពទទួលឪពុកហើយ ក្តោះសំពត់នោះដោយចុងឈើច្រត់ ដូចក្តោះពស់វៀរ ដើរទៅដល់ព្រៃខ្មោច ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងបុរសនោះថា ម្នាលមាណព តើអ្នកធ្វើអ្វី មាណពទូលថា បពិត្រព្រះគោតម គូសំពត់នេះ កណ្តុរកាត់ ជាសំពត់កាឡកិណី ប្រៀបដូចថ្នាំពិសដ៏ពន្លឹក ឪពុករបស់ខ្ញុំ ខ្លាចក្រែងបោលទៅ អ្នកដទៃកើតការចង់បាន កាន់យក ទើបប្រើខ្ញុំព្រះអង្គ បពិត្រព្រះគោតម ខ្ញុំឯងក៏មកដោយបំណងថា នឹងបោលវា ងូតទឹកហើយ នឹងទៅ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ បោលចុះ ។ ទើបមាណពបោល ។ ព្រះសាស្តាត្រាស់ថា កាលនេះ ជាកាលគួរដល់តថាគត ដូច្នេះហើយ ទ្រង់កាន់យកចំពោះមុខមាណពនោះឯង ទាំងដែលមាណពនោះឃាត់ថា បពិត្រព្រះគោតម សំពត់នោះជាអវមង្គល ជាកាឡកិណី កុំចាប់ៗឡើយ ។ ព្រះសាស្តាក៏ទ្រង់កាន់យកគូសំពត់នោះ ទ្រង់យាងទៅកាន់វត្តវេឡុវ័ន ។ មាណពប្រញាប់ប្រញាល់ទៅប្រាប់ដល់ព្រាហ្មណបិតាថា បពិត្រលោកឪពុក គូសំពត់សាដកដែលខ្ញុំយកទៅបោលត្រង់ព្រៃខ្មោចនោះ ព្រះគោតមត្រាស់ថា គួរដល់តថាគត ទាំងដែលខ្ញុំហាម ទ្រង់នៅតែកាន់យកយាងទៅកាន់វត្តវេឡុវ័ន ។ ព្រាហ្មណ៍គិតថា ព្រះសមណគោតម ទ្រង់ប្រើប្រាស់សំពត់នោះ ដែលជាអវមង្គល ជាកាឡកិណី នឹងត្រូវអន្តរាយ សូម្បី

ព្រះវិហារក៏នឹងវិនាស ពេលនោះ ពួកយើងនឹងត្រូវគេនិន្ទា យើងត្រូវថ្វាយសំពត់សាដកដទៃៗ ច្រើនផ្ទាំងដល់ព្រះសមណគោតម ដើម្បីឲ្យទ្រង់ចោលសំពត់នោះ ។ ព្រាហ្មណ៍ឲ្យមនុស្សកាន់សាដកច្រើនផ្ទាំង ទៅកាន់វេឡុវនវិហារជាមួយកូន ថ្វាយបង្គំព្រះសាស្តា ឈរនៅក្នុងចំណែកម្ខាង ក្រាបទូលយ៉ាងនេះថា បពិត្រព្រះគោតម បានឮថា ព្រះអង្គទ្រង់កាន់យកគូនៃសំពត់សាដកក្នុងព្រៃខ្មោច ពិតឬ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតហើយ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម គូនៃសំពត់សាដកនោះ ជាអវមង្គល បើទ្រង់ប្រើប្រាស់ នឹងត្រូវអន្តរាយ សូម្បីព្រះវិហារទាំងមូលក៏ត្រូវបាក់បែកសំពត់ស្លៀក សំពត់ដណ្តប់របស់ទ្រង់មិនគ្រប់គ្រាន់ សូមទ្រង់ទទួលសំពត់សាដកនេះ ចោលគូសំពត់សាដកនោះចុះ កាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមានឈ្មោះថា ជាបព្វជិត សំពត់ចាស់ៗ ដែលគេចោល ឬធ្លាក់នៅទីបែបនោះ គឺព្រៃខ្មោច តាមផ្លូវ ត្រង់គំនរសំរាម ត្រង់កំពង់ទឹក ត្រង់ផ្លូវធំ រមែងគួរដល់តថាគត ឯអ្នក មិនមែនទើបតែប្រកាន់ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានទិដ្ឋិនេះដូចគ្នា ព្រាហ្មណ៍ក្រាបទូលអារាធនា ទ្រង់នាំយករឿងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទមគធរាជ ដែលទ្រទ្រង់ធម៌ សោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ដែនមគធៈ ។ សម័យនោះ ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ដល់នូវការដឹងក្តីហើយ បួសជាឥសី ញុំាងអភិញ្ញា និងសមាបត្តិឲ្យកើត ស្នាក់នៅក្នុងព្រៃហិមពាន្ត ។ សម័យមួយ ចេញអំពីព្រៃ

ហិមពាន្ត មកដល់ព្រះរាជឧទ្យាន ក្នុងនគររាជគ្រឹះ ស្នាក់នៅក្នុងទីនោះ ថ្ងៃទី ២ ចូលកាន់ព្រះនគរដើម្បីកិក្ខាចារ ព្រះរាជាទតឃើញហើយ ត្រាស់ឲ្យនិមន្ត មក អារាធនាឲ្យអង្គុយក្នុងប្រាសាទ ឲ្យឆាន់ភោជនីយាហារហើយ ឲ្យកាន់ យកប្តេជ្ញាដើម្បីការនៅក្នុងព្រះឧទ្យានតទៅ ។ ព្រះពោធិសត្វឆាន់ក្នុងព្រះរាជ-និវេសន៍ ស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ គ្រានោះ ក្នុងនគររាជគ្រឹះ មាន ព្រាហ្មណ៍ឈ្មោះថា ទុស្សលក្ខណព្រាហ្មណ៍ ( ព្រាហ្មណ៍ដែលចេះមើល លក្ខណៈសំពត់ ) ។ រឿងទាំងពួង តាំងអំពីទុកសំពត់សាដកក្នុងហិបជាដើម ដូចគ្នានឹងរឿងមុននោះឯង ប្លែកត្រង់កាលមាណពទៅដល់ព្រៃខ្មោច ព្រះ ពោធិសត្វនៅរង់ចាំមុន ហើយអង្គុយរង់ចាំត្រង់ច្រកចូលព្រៃខ្មោច កាន់យក គូសំពត់ដែលគេចោល ទៅកាន់ឧទ្យាន មាណពទៅប្រាប់ដល់បិតា ។ បិតា គិតថា តាបសដែលជិតស្និទ្ធ នឹងរាជត្រកូលគប្បីវិនាស ទើបទៅកាន់សម្នាក់ ព្រះពោធិសត្វ ពោលថា បពិត្រតាបស សូមលោកចោលសំពត់សាដក ដែលលោកកាន់យកហើយចុះ ចូរកុំវិនាសឡើយ ។ តាបសសម្តែងធម៌ដល់ ព្រាហ្មណ៍ថា សំពត់ចាស់ៗ ដែលគេចោលក្នុងព្រៃខ្មោច សមគួរដល់អាត្មា ពួកអាត្មាមិនមែនអ្នកកាន់យកមង្គលភ្ញាក់ផ្អើលឡើយ ឈ្មោះថា ការកាន់យក មង្គលភ្ញាក់ផ្អើលនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពោធិសត្វទាំងឡាយ មិនសរសើរទេ ហេតុនោះ បណ្ឌិតមិនគប្បីជាបុគ្គលកាន់យកមង្គលភ្ញាក់ផ្អើល ឡើយ ។ ព្រាហ្មណ៍ស្តាប់ធម៌ហើយ ទម្លាយទិដ្ឋិ ដល់ព្រះពោធិសត្វជាសរណៈ ហើយ ព្រះពោធិសត្វក៏មានឈានមិនសាបសូន្យ បានជាអ្នកមានព្រហ្មលោក

ជាទីទៅខាងមុខ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទ្រង់នាំអតីតនិទាននេះមក ទើបទ្រង់សម្តែងធម៌ ដល់ព្រាហ្មណ៍ ត្រាស់ព្រះគាថានេះថា

មង្គលទាំងឡាយក្តី ឧត្បាត ទាំងឡាយក្តី សុបិនទាំងឡាយក្តី
លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបាន ផ្តាច់បង់ហើយ
បុគ្គលនោះ ឈ្មោះថាអ្នកកន្លងផុតនូវទោសនៃមង្គល ( ភ្ញាក់
ផ្អើល ) ជាអ្នកគ្របសង្កត់នូវយុគក្កិលេស នឹងយោគក្កិលេស
រមែងមិនមក កើតទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស មង្គលា សមូហតា** សេចក្តីថា មង្គលទាំងនេះ គឺទិដ្ឋមង្គល ១ សុតមង្គល ១ មុតមង្គល ១ ដែលព្រះខីណាស្រពណាដកឡើងបានហើយ ។

បទថា **ឧប្បាតា សុបិនា ច លក្ខណា ច** សេចក្តីថា ប្រាប់ហេតុធំ ៥ ប្រការ គឺចន្ទគរាជ (ចន្ទ្រគ្រាស ) យ៉ាងនេះនឹងត្រូវមាន ១ សុរិយគរាជយ៉ាងនេះ នឹងត្រូវមាន ១ នក្ខត្តគរាជយ៉ាងនេះនឹងត្រូវមាន ១ ឧត្បាតយ៉ាងនេះនឹងត្រូវមាន ១ ការឆេះឥតក្នុងទិសយ៉ាងនេះនឹងត្រូវមាន ១ ដូច្នេះ ។ ការយល់ សប្តិមានប្រការផ្សេងៗ លក្ខណៈទាំងឡាយ គឺលក្ខណៈមនុស្សវាសនាល្អ លក្ខណៈមនុស្សវាសនាអាក្រក់ លក្ខណៈស្ត្រី លក្ខណៈបុរស លក្ខណៈ ទាសៈ លក្ខណៈទាសី លក្ខណៈដាវ លក្ខណៈដំរី លក្ខណៈសេះ លក្ខណៈគោឧសភៈ លក្ខណៈអាវុធ លក្ខណៈសំពត់ លក្ខណៈជាទីតាំង

នៃទិដ្ឋិទាំងនេះ ដែលបុគ្គលណា ដកបានអស់ហើយ មិនប្រកាន់ជឿជាមង្គល ឬអវមង្គលដល់ខ្លួន ដោយប្រាប់ហេតុជាដើមនេះ ។

បទថា **សោ មង្គលទោសវីតិវត្តោ** សេចក្តីថា បុគ្គលនោះ ជាភិក្ខុ- ខីណាស្រពកន្លងផុត ឈានកន្លង លះបង់នូវទោសនៃមង្គលគ្រប់យ៉ាង ។ បទថា **យុគយោគាធិគតោ** សេចក្តីថា កិលេសដែលមករួមគ្នាជាគូៗ ដោយន័យជាដើមថា កោធៈ និងឧបនាហៈ មក្ខៈ និងបលាសៈ ដូច្នេះ ឈ្មោះថា កិលេសជាគូ ។ កិលេស ៤ យ៉ាង គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ឈ្មោះថា យោគៈ ព្រោះជាហេតុប្រកប សត្វទុកក្នុងសង្សារ ភិក្ខុដែលជាខីណាស្រពសម្រេចហើយ គឺគ្របសង្កត់បាន ហើយ កន្លងផុតហើយ ឆ្លងទៅហើយដោយល្អនូវយុគ និងយោគៈ គឺទាំង យុគ និងយោគៈនោះ ។

បទថា **ន ជាតុមេតិ** សេចក្តីថា បុគ្គលនោះរមែងមិនដល់ គឺមិនត្រូវ មកកាន់លោកនេះ ដោយអំណាចនៃបដិសន្ធិដោយពិតនោះឯង ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ដល់ព្រាហ្មណ៍ដោយគាថានេះយ៉ាងនេះ ហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចៈ ព្រាហ្មណ៍ និងកូន តាំងនៅ ក្នុងសោតាបត្តិផល ព្រះសាស្តាទ្រង់ប្រជុំជាតកថា បិតា និងបុត្រក្នុងកាល នោះ បានមកជាឪពុក និងកូនទាំង ២ នេះឯងក្នុងកាលឥឡូវនេះ ឯតាបស ក្នុងកាលនោះ គឺជាតថាគតនោះឯង ។៚

**អដ្ឋកថា មង្គលជាតក ចប់**

# សុត្តន្តបិដក

## សារម្ភជាតក

[ ៨៨ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) បុគ្គលគប្បីបញ្ចេញវាចាល្អ តែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់ឡើយ ការបញ្ចេញវាចាល្អ ជាការប្រពៃ ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់ រមែងក្តៅក្រហាយ ។

សារម្ភជាតកទី ៨ ចប់

# អដ្ឋកថា

## សារម្ភជាតក

[ ៨៨ ] ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឱមសវាទសិក្ខាបទ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កល្យាណិមេវ មុញ្ចេយ្យ** ដូច្នេះជាដើម ។

ក្នុងរឿងទាំង ២ ក៏ដូចគ្នានឹងរឿងដែលពោលហើយ ក្នុងនន្ទិវិសាលជាតកខាងដើម សេចក្តីប្លែកក្នុងជាតកនេះ ព្រះពោធិសត្វសោយព្រះជាតិជាគោ ទ្រទ្រង់នូវកម្លាំង ឈ្មោះសារម្ភៈរបស់ព្រាហ្មណ៍ម្នាក់ ក្នុងនគរតក្កសិលាដែនគន្ធារៈ ។ ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយ កាលត្រាស់រឿងក្នុងអតីតនេះហើយ ត្រាស់គាថានេះថា

បុគ្គលគប្បីបញ្ចេញវាចាល្អតែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់
ឡើយ ការបញ្ចេញវាចាល្អ ជាការប្រពៃ ព្រោះបុគ្គលបញ្ចេញ
វាចាអាក្រក់ រមែងក្តៅក្រហាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កល្យាណិមេវ មុញ្ចេយ្យ** សេចក្តីថា បុគ្គលគប្បីបញ្ចេញ គឺគប្បីថ្លែង បានដល់ គប្បីពោលពាក្យដែលផុតចាកទោស ៤ យ៉ាង ឈ្មោះថា ជាពាក្យល្អ គឺមិនមានទោស ។

បទថា **ន ហិ មុញ្ចេយ្យ បាបិកំ** សេចក្តីថា មិនគប្បីបញ្ចេញនូវពាក្យអាក្រក់ គឺវាចាលាមក បានដល់ ពាក្យដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនដទៃៗ ។

បទថា **មោក្ខោ កល្យាណិយា សាធុ** សេចក្ដីថា ការបន្លឺវាចាល្អ ប៉ុណ្ណោះ ញុំាងប្រយោជន៍ឲ្យសម្រេច គឺជាការល្អ ជាការចម្រើនក្នុងលោក នេះ ។

បទថា **មុត្វា តប្បតិ បាបិកំ** សេចក្ដីថា កាលបន្លឺ គឺថ្លែង បានដល់ ពោលពាក្យអាក្រក់ គឺពាក្យគ្រោតគ្រាតហើយ បុគ្គលនោះ រមែងក្ដៅ ក្រហាយ គឺសោកសៅលំបាក ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមក ដោយប្រការដូច្នេះហើយ ទ្រង់ ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ព្រាហ្មណីក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា ឯគោសារម្ភៈ ក្នុង កាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សារម្ភជាតក ចប់**

# សុត្តន្តបិដក

## កុហកជាតក

[ ៨៩ ] ( ឈ្មួញពោធិសត្វពោលថា ) បានឮថា វាចារបស់អ្នក ដែលពោលទន់ភ្លន់ ជាវាចាពីរោះ អ្នកបានជាប់ក្នុងវត្ថុត្រឹមតែស្មៅ ត្រង់នាំគ្រឿងមាស ១០០ យកទៅ មិនជាប់សោះ ។

**កុហកជាតកទី ៩ ចប់**

# អដ្ឋកថា

## កុហកជាតក

[ ៨៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើន ដោយសេចក្ដីកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **វាចាវ កិរ តេ អាសិ** ដូច្នេះជាដើម ។

រឿងការកុហកនឹងមានប្រាកដក្នុងឧទ្ទាលជាតក ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី មានជដិលកោងម្នាក់ ជាតាបសកូតកុហក អាស្រ័យនៅក្នុងស្រុកមួយ ។ កុដុម្ពិកៈម្នាក់ បានធ្វើសាលាក្នុងព្រៃឲ្យតាបសនោះ ឲ្យតាបសនៅក្នុងបណ្ណសាលានោះ បដិបត្តិដោយអាហារដ៏ប្រណីត ក្នុងផ្ទះរបស់ខ្លួន ។ កុដុម្ពិកៈសម្គាល់តាបសកោងនោះថា ជាអ្នកមានសីល យកមាស ១០០ ដុំ ទៅកាន់សាលារបស់តាបស កប់ទុកក្នុងផែនដី ព្រោះខ្លាចចោរ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មើលថែមាសនេះផង ។ កាលនោះ តាបសពោលនឹងកុដុម្ពិកៈថា អ្នកនិយាយបែបនេះដល់ជនដែលបានឈ្មោះថា បព្វជិតមិនសមគួរឡើយ ឈ្មោះថា ការចង់បានក្នុងវត្ថុរបស់អ្នកដទៃនៃពួកយើង មិនមានឡើយ ។ កុដុម្ពិកៈពោលថា សាធុ លោកម្ចាស់ ជឿពាក្យតាបសចៀសចេញទៅ ។ តាបសអាក្រក់ គិតថា អាញអាចចិញ្ចឹមជីវិតបានដោយទ្រព្យមានប្រមាណប៉ុណ្ណេះ កន្លងទៅបាន ២-៣ ថ្ងៃ ក៏បង្វែរមាសនោះទៅត្រង់ចន្លោះផ្លូវ ហើយត្រឡប់ចូលបណ្ណសាលា ។ ស្អែកឡើង ធ្វើភត្តកិច្ចក្នុងផ្ទះរបស់កុដុម្ពិកៈហើយ ពោលយ៉ាងនេះថា យើងអាស្រ័យអ្នក

យូរហើយ ការជាប់ជំពាក់ជាមួយពួកមនុស្ស រមែងមិនមាន ធម្មតាការជាប់ជំពាក់ ជាមន្ទិលរបស់បព្វជិត ព្រោះដូច្នោះ អាត្មានឹងសូមលា កុដុម្ពិកៈអង្វរហើយអង្វរទៀត ក៏មិនប្រាថ្នានឹងត្រឡប់ គ្រានោះ ទើបកុដុម្ពិកៈពោលនឹងតាបសថា បើដូច្នោះ សូមនិមន្តទៅចុះ ដូច្នេះហើយ ជូនដំណើរដល់ទ្វារស្រុកទើបត្រឡប់ ។ តាបសដើរទៅបានបន្តិច គិតថា អញនឹងបញ្ឆោតកុដុម្ពិកៈនេះក៏យកស្បូវដាក់លើផ្នួងសក់ ដើរត្រឡប់ទៅ កុដុម្ពិកៈសួរថា បពិត្រលោកម្ចាស់ៗ ត្រឡប់មកធ្វើអ្វី ជដិលកោងឆ្លើយថា អាវុសោ ស្បូវមួយសរសៃក្នុងសំយាបផ្ទះរបស់អ្នក ជាប់ត្រង់ផ្នួងសក់អាត្មា ឈ្មោះថា អទិន្នាទាន មិនសមគួរដល់បព្វជិត ទើបអាត្មានាំវាត្រឡប់មក កុដុម្ពិកៈពោលថា សូមលោកម្ចាស់ចោល ហើយនិមន្តទៅចុះ ។ កុដុម្ពិកៈជ្រះថ្លាថា តាបសមិនកាន់យករបស់អ្នកដទៃ សូម្បីតែស្បូវមួយសរសៃ ឱ ! លោកម្ចាស់របស់អញតឹងរ៉ឹងពិតហ្ន៎ ដូច្នេះ ថ្វាយបង្គំហើយ បញ្ជូនតាបសទៅ ។

គ្រានោះ ព្រះពោធិសត្វទៅកាន់ជនបទជាយដែន ដើម្បីរកទ្រព្យ ស្នាក់ក្នុងស្រុកកុដុម្ពិកៈ បានស្តាប់ពាក្យតាបសហើយ គិតថា តាបសនេះពិតជាកាន់យកទ្រព្យណាមួយរបស់កុដុម្ពិកៈនេះទៅពិត ទើបសួរកុដុម្ពិកៈថា នែសម្លាញ់អ្នកបានផ្ញើអ្វីក្នុងសម្នាក់របស់តាបសនោះដែរឬទេ កុដុម្ពិកៈឆ្លើយថា មានសម្លាញ់ ខ្ញុំផ្ញើមាស ១០០ ដុំ ព្រះពោធិសត្វពោលថា បើដូច្នោះ ចូរអ្នកប្រញាប់ទៅពិនិត្យមើលដុំមាសនោះចុះ ។ កុដុម្ពិកៈចូលទៅកាន់បណ្ណសាលាមិនឃើញមាសនោះ ប្រញាប់ត្រឡប់មកប្រាប់ថា នែសម្លាញ់ មាសមិនមាន

ទេ ។ ព្រះពោធិសត្វប្រាប់ថា មាសរបស់អ្នកមិនមែនអ្នកដទៃយកទៅឡើយ តាបសក្លែងក្លាយនោះកាន់យកទៅ មកយើងនាំគ្នាចាប់តាបសនោះ ហើយប្រញាប់តាមទៅ ចាប់តាបសកោងបាន វាយដោយដៃខ្លះ ទាត់ដោយជើងខ្លះ ឲ្យនាំយកមាសមកវិញ ហើយចាប់ទុក ព្រះពោធិសត្វឃើញមាសហើយ ពោលថា តាបសនេះលួចមាស ១០០ ដុំ មិនវង្វៀស បែរជាមកវង្វៀសក្នុងស្បូវមួយសរសៃ កាលទឹងតិះដៀលតាបសនោះ ពោលគាថានេះថា

បានឮថា វាចារបស់អ្នក ដែលពោលទន់ភ្លន់ ជាវាចាពីរោះ អ្នក
បានជាប់ក្នុងវត្ថុត្រឹមតែស្មៅ ត្រង់នាំគ្រឿងមាស ១០០ យកទៅ
មិនជាប់សោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាចាវ កិរ តេ អាសិ សណ្ហា សខិល-ភាណិនោ** សេចក្ដីថា កាលលោកពោលពាក្យផ្អែមល្ហែម គួររាប់អានយ៉ាងនេះថា ការកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ត្រឹមតែស្បូវមួយសរសៃក៏មិនគួរដល់បព្វជិត ដូច្នេះ ពាក្យរបស់លោកដែលទន់ផ្អែមតិចក្នុងកាលណា អធិប្បាយថា ពាក្យរបស់លោកនោះ ទន់ពិតៗ ។

បទថា **តិណមត្តេ អសជ្ជិត្ថោ** សេចក្ដីថា នៃជដិលកោង លោកធ្វើនូវការរំខានចិត្តក្នុងស្មៅមួយសរសៃ មានចិត្តជាប់ជំពាក់ពិតៗ ។ បទថា **នោ ច និក្ខសតំ ហរំ** បានដល់ តែកាលលោកលួចដុំមាស ១០០ ម្ដេចមិនជាប់ជំពាក់ អស់នូវការជាប់ជំពាក់នោះឯង ។

ព្រះពោធិសត្វ លុះតិះដៀលតាបសនោះ ដោយប្រការដូច្នេះហើយ ក៏ឲ្យឱវាទដល់តាបសថា នែជដិលកោង លោកកុំធ្វើកម្មបែបនេះតទៅទៀត ដូច្នេះហើយ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះ ជាអ្នកកុហក សូម្បីក្នុងកាលមុន ក៏បានជាអ្នកកុហកហើយដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា តាបសកោងក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ ឯបុរសដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កុហកជាតក ចប់**

# សុត្តន្តបិដក

## អកតញ្ញុជាតក

[ ៩០ ] ( សេដ្ឋីពោធិសត្វពោលថា ) បុគ្គលណា មិនដឹងនូវអំពើល្អដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុនទេ បុគ្គលនោះ កាលបើកិច្ចកើតព្រមហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ ( ឧបការគុណមុននោះជាគ្នា ) ឡើយ ។

**អកតញ្ញុជាតកទី ១០ ចប់**

**អបាយិម្ហវគ្គទី ៩ ចប់**

### ឧទ្ទាននៃអបាយិម្ហវគ្គនោះ គឺ

យើងបានផឹកសុរា ( ក្នុងសុរាបានជាតក ) ១ ប្រាសាទកែវមណី ( ក្នុងមិត្តវិន្ទជាតក ) ១ ៧ ជំហាន ( ក្នុងកាឡកិណ្ណិជាតក ) ១ ធម៌ ៦ ( ក្នុងអត្ថស្សទ្វារជាតក ) ១ ទោសក្នុងអនាគត ( ក្នុងកិម្បក្កជាតក ) ១ ពស់មានសីល ( ក្នុងសីលវីមំសជាតក ) ១ ការប្រកាន់មង្គល ( ក្នុងមង្គលជាតក ) ១ វាចាលាមក ( ក្នុងសារម្ភជាតក ) ១ ក្តារមាស ១០០ ( ក្នុងកុហកជាតក ) ១ ប្រយោជន៍ដែលគេធ្វើតបវិញ ( ក្នុងអកតញ្ញុជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## អកតញ្ញុជាតក

[ ៩០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ បុព្វេ កតកល្យាណោ** ដូច្នេះជាដើម ។

បានឮថា សេដ្ឋីអ្នកបច្ចន្តជនបទម្នាក់ បានជាអទិដ្ឋសហាយ គឺសម្លាញ់កំបាំងមុខរបស់អនាថបិណ្ឌិកសេដ្ឋី ។ កាលនោះ សេដ្ឋីនោះបានទឹមរទេះ ៥០០ ដាក់ពេញដោយទ្រព្យដែលកើតឡើងក្នុងបច្ចន្តជនបទ ពោលនឹងពួកក្មាក់ងារថា ទៅចុះអ្នកទាំងឡាយៗ ចូរនាំរបស់ទាំងនេះទៅកាន់នគរសាវត្ថីលក់ឲ្យមហាសេដ្ឋីអនាថបិណ្ឌិកសម្លាញ់របស់យើង ដោយតម្លៃរបស់តបស្នង ហើយនាំគ្នាជញ្ជូនរបស់តបស្នងនោះមក ។ ក្មាក់ងារទាំងនោះ ទទួលពាក្យរបស់សេដ្ឋីហើយ នាំគ្នាទៅកាន់នគរសាវត្ថី ជួបអនាថបិណ្ឌិកសេដ្ឋីហើយឲ្យបណ្ណាការ ប្រាប់រឿងនោះឲ្យជ្រាប មហាសេដ្ឋីឃើញហើយ ក៏ពោលថា ពួកអ្នកមកល្អហើយ រៀបចំទីសម្រាក និងស្បៀងដល់បុគ្គលទាំងនោះ សាកសួរសុខទុក្ខរបស់សេដ្ឋីដែលជាសម្លាញ់ ទទួលកណ្ឌៈទុក ហើយឲ្យកណ្ឌៈតបស្នងទៅ ។ ក្មាក់ងារទាំងនោះនាំគ្នាទៅកាន់បច្ចន្តជនបទ ប្រាប់សេចក្តីនោះដល់សេដ្ឋីរបស់ខ្លួន ។ ក្រោយមក អនាថបិណ្ឌិកសេដ្ឋីក៏បញ្ជូនរទេះ ៥០០ ទៅក្នុងបច្ចន្តជនបទនោះដែរ ពួកមនុស្សទៅក្នុងបច្ចន្តជនបទនោះហើយ នាំបណ្ណាការទៅប្រគល់ឲ្យសេដ្ឋីបច្ចន្តជនបទ ។ សេដ្ឋីនោះសួរថា ពួកអ្នកមកអំពីទីណា កាលពួកអ្នកទាំងនោះប្រាប់ថា ខ្ញុំមកពីនគរសាវត្ថី អំពីសម្លាក់អនាថបិណ្ឌិក

ជាសម្លាញ់របស់លោក ក៏សើចចំអកថា ពាក្យថា អនាថបិណ្ឌិក ជាឈ្មោះនៃបុរសណាក៏បាន ហើយទទួលគ្រឿងបណ្ណាការ ហើយបញ្ជូនត្រឡប់ទៅ ដោយពាក្យថា ចូរពួកអ្នកទៅចុះ មិនបានរៀបចំទីសម្រាក និងស្បៀងឡើយ ពួកមនុស្សទាំងនោះ ត្រូវលក់របស់របរខ្លួនឯង នាំយករបស់តបស្នងមកកាន់នគរសាវត្ថី ហើយប្រាប់រឿងនោះដល់សេដ្ឋី ។ សម័យតមក សេដ្ឋីបច្ចន្តជនបទបញ្ជូនរទេះ ៥០០ យ៉ាងនោះឯង មកកាន់នគរសាវត្ថីម្តងទៀត ពួកមនុស្សនាំបណ្ណាការទៅជួបមហាសេដ្ឋី ឯពួកមនុស្សរបស់អនាថបិណ្ឌិកសេដ្ឋីឃើញជនទាំងនោះហើយ ពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងកំណត់ទីសម្រាក អាហារ និងស្បៀងរបស់ជនទាំងនោះឯង ហើយឲ្យជនទាំងនោះ ដោះរទេះទុកខាងក្រៅនគរ ពោលថា ពួកអ្នកនាំគ្នានៅទីនេះចុះ បបរ ភត្ត និងស្បៀងសម្រាប់ពួកអ្នកក្នុងផ្ទះរបស់ពួកយើងនឹងមាន ហើយនាំគ្នាទៅហៅពួកទាសៈនិងកម្មករមកប្រជុំគ្នា លុះបានឱកាស គឺពេលកណ្តាលយប់ ក៏ប្រួតគ្នាប្លន់រទេះទាំង ៥០០ ដណ្តើមយកសម្លៀកបំពាក់ស្លៀក និងសំពត់ដណ្តប់របស់អ្នកទាំងនោះក៏មិនឲ្យសល់ ដេញគោឲ្យគេចទៅទាំងអស់ ដោះរទេះ ៥០០ ចេញទុកត្រង់ផែនដី ហើយដញ្ជូនយកកង់រទេះទៅ ។ ពួកអ្នកបច្ចន្តជនបទ មិនមានសល់ សូម្បីត្រឹមតែសំពត់ស្លៀក ភ័យខ្លាច នាំគ្នារត់ទៅកាន់បច្ចន្តជនបទ ឯមនុស្សរបស់លោកសេដ្ឋី នាំគ្នាប្រាប់រឿងនោះដល់មហាសេដ្ឋី ។ មហាសេដ្ឋីគិតថា ឥឡូវនេះ មានរឿងជាលំនាំហើយ ទើបទៅកាន់សម្នាក់ព្រះបរមសាស្តាក្រាបទូលរឿងទាំងអស់ តាំងអំពីដើមដល់ចប់ ។ ព្រះសាស្តាត្រាស់ថា ម្នាល

គហបតី សេដ្ឋីអ្នកបច្ចន្តជនបទនោះ ជាអ្នកមានប្រក្រតីប្រព្រឹត្តយ៉ាងនេះ ក្នុងកាលឥឡូវប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានប្រព្រឹត្តយ៉ាងនេះហើយដូចគ្នា សេដ្ឋីទូលអារាធនា ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាសេដ្ឋី មានសម្បត្តិច្រើន ក្នុងនគរពារាណសី ។ សេដ្ឋីអ្នកបច្ចន្តជនបទម្នាក់បានជាអទិដ្ឋសហាយរបស់លោក ។ រឿងអតីតទាំងអស់ ដូចគ្នានឹងរឿងបច្ចុប្បន្ននោះឯង ប៉ុន្តែព្រះពោធិសត្វ កាលមនុស្សប្រាប់ឲ្យជ្រាបថា ថ្ងៃនេះ ពួកខ្ញុំធ្វើការងារឈ្មោះនេះ ដូច្នេះហើយ ក៏ពោលថា ជនទាំងនោះមិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ទើបទទួលកម្មបែបនេះ ក្នុងកាលខាងក្រោយ ដើម្បីសម្តែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ទើបពោលគាថានេះថា

បុគ្គលណា មិនដឹងនូវអំពើល្អ ដែលគេធ្វើហើយ នូវប្រយោជន៍
ដែលគេធ្វើហើយ ក្នុងកាលមុនទេ បុគ្គលនោះ កាលបើកិច្ចកើត
ព្រមហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ
( ឧបការគុណមុននោះជាគ្នា ) ឡើយ ដូច្នេះ ។

ក្នុងគាថានោះ មានអត្ថាធិប្បាយសរុបដូច្នេះថា បណ្តាជន មានក្សត្រជាដើម បុរសណាម្នាក់មានសេចក្តីល្អ ដែលបុគ្គលដទៃធ្វើឲ្យ គឺមានឧបការៈដែលអ្នកដទៃធ្វើមុន គឺធ្វើដំបូង មានប្រយោជន៍ដែលអ្នកដទៃធ្វើឲ្យ ជាអ្នកជួយ

ស្រោចស្រង់ធ្វើកិច្ចការឲ្យសម្រេចបានមុន មិនបានរឭកដល់គុណ និងប្រ-យោជន៍ដែលអ្នកដទៃធ្វើក្នុងខ្លួននោះឡើយ បុគ្គលនោះ កាលកិច្ចរបស់ខ្លួនកើតឡើងក្នុងកាលជាក្រោយ រមែងមិនមានបុគ្គលជួយធ្វើកិច្ចនោះបាន ។

ព្រះពោធិសត្វសម្ដែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះហើយ ធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សេដ្ឋីបច្ចន្តជនបទក្នុងកាលនោះ បានមកជាសេដ្ឋីបច្ចន្តជនបទ ក្នុងកាលឥឡូវនេះ ចំណែកពារាណសីសេដ្ឋី ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អកតញ្ញូជាតក ចប់**

**អបាយិម្ហវគ្គ ចប់**

# សុត្តន្តបិដក

# លិត្តវគ្គ

## លិត្តជាតក

[ ៩១ ] ( អ្នកលេងស្កាពោធិសត្វពោលថា ) បុរសកាលលេបនូវកូនស្កា ប្រឡាក់ដោយថ្នាំពិស មានតេជៈដ៏ខ្លាំង ក៏មិនដឹងខ្លួន ម្នាលអ្នកចង្រៃ អ្នកចូរលេបទៅ នៃអ្នកលេងអាក្រក់ អ្នកចូរលេបទៅ ពិសដ៏ផ្សាក្តៅនឹងមានដល់អ្នកក្នុងកាលជាខាងក្រោយ ។

*លិត្តជាតកទី ១ ចប់*

# អដ្ឋកថា

# លិត្តវគ្គ

## លិត្តជាតក

[ ៩១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរិភោគបច្ច័យ ដែលមិនបានពិចារណា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **លិត្តំ បរមេន តេជសា** ដូច្នេះជាដើម ។

បានឮមកថា ក្នុងកាលនោះ ពួកភិក្ខុបានបច្ច័យ មានចីវរជាដើមជាច្រើន តែមិនបានពិចារណាហើយបរិភោគ ភិក្ខុទាំងនោះមិនបានពិចារណាបច្ច័យ ៤ ហើយបរិភោគ ដោយច្រើនមិនផុតចាកនរក និងកំណើតសត្វតិរច្ឆានឡើយ ព្រះសាស្ដាទ្រង់ជ្រាបហេតុនោះ ត្រាស់ធម្មកថាដល់ភិក្ខុទាំងឡាយ ដោយបរិយាយជាច្រើន ត្រាស់ដល់ទោសក្នុងការមិនពិចារណាបច្ច័យ ហើយប្រើប្រាស់ ដោយពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុបានទទួលបច្ច័យ៤ ហើយ មិនពិចារណា បរិភោគ មិនគួរឡើយ ព្រោះដូច្នោះ តាំងអំពីនេះទៅ ពួកអ្នកត្រូវពិចារណាហើយ សឹមបរិភោគ កាលទ្រង់សម្ដែងវិធីពិចារណា ទ្រង់ដាក់បែបផែន ដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អាស្រ័យ សេព គឺប្រើប្រាស់នូវសំពត់ចីវរ ។បេ។ គ្រាន់តែដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្ដីខ្មាសឲ្យកម្រើក ដូច្នេះ ។ រួច

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការពិចារណាបច្ច័យ ៤ យ៉ាងនេះហើយ បរិភោគ រមែងសមគួរ ឈ្មោះថា ការមិនពិចារណាហើយ បរិភោគ ដូចគ្នានឹងបរិភោគថ្នាំពិស ដែលមានពិសដ៏ពន្លឹក ដ្បិតថា មនុស្សក្នុងកាលមុន មិនពិចារណា មិនដឹងទោស បរិភោគថ្នាំពិស លទ្ធផល គឺសោយទុក្ខដ៏ពន្លឹក ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលមានភោគៈច្រើនមួយ ចម្រើនវ័យហើយ ជាអ្នកពូកែលេងបាស្កា ។ សម័យនោះ មានអ្នកលេងបាស្កាកោងម្នាក់ទៀត លេងជាមួយព្រះពោធិសត្វ កាលខ្លួនជាចំណែកឈ្នះ ក៏មិនទម្លាយទីលេង ក្នុងពេលចាញ់ ក៏យកកូនបាស្កាដាក់ក្នុងមាត់ ពោលថា កូនបាស្កាខ្ញុំមិនគ្រប់ ហើយលើកលែងចោលទៅ ។ ព្រះពោធិសត្វជ្រាបហេតុរបស់អ្នកលេងនោះ គិតថា ណ្ហើយចុះ អញនឹងរកឧបាយដោះស្រាយក្នុងរឿងនេះ ដូច្នេះហើយ ប្រមូលកូនបាស្កាទៅជ្រលក់ដោយថ្នាំពិសដ៏ខ្លាំងក្លាក្នុងផ្ទះរបស់ខ្លួនហើយ ហាលឲ្យស្ងួតច្រើនដង ហើយនាំយកកូនបាស្កាទាំងនោះទៅកាន់សម្នាក់របស់បុរសនោះ ពោលថា មកសម្លាញ់ យើងលេងជុំគ្នាចុះ បុរសនោះទទួលពាក្យថា សាធុ សម្លាញ់ ក៏រៀបចំទីលេងជាមួយព្រះពោធិសត្វ លុះដល់ពេលខ្លួនចាញ់ ក៏យកកូនបាស្កាមួយដាក់ក្នុងមាត់ កាលព្រះពោធិសត្វឃើញបុរសនោះធ្វើយ៉ាងនោះ ដើម្បីនឹងចោទថា លេបចូលទៅចុះ ខាងក្រោយនឹងដឹងថា របស់នេះឈ្មោះនេះ ទើបពោលគាថានេះថា

បុរស កាលលេបនូវកូនស្កា ប្រឡាក់ដោយថ្នាំពិស មានតេជះ ដ៏ខ្លាំង ក៏មិនដឹងខ្លួន ម្នាលអ្នកចង្រៃ អ្នកចូរលេបទៅ នែអ្នកលេង អាក្រក់ អ្នកចូរលេបទៅ ពិសដ៏ផ្សាក្តៅ នឹងមានដល់អ្នកក្នុងកាល ជាខាងក្រោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លិត្តំ** សេចក្តីថា កូនបាស្កាដែលលាប ហើយ ជ្រលក់ហើយ ។

បទថា **បរមេន តេជសា** សេចក្តីថា ដោយថ្នាំពិសដោយពន្លឺក សម្បូរ ដោយឫទ្ធិ និងតេជះខ្លាំង ។

បទថា **គិលំ** បានដល់ លេប ។ បទថា **អក្ខំ** បានដល់ កូនបាស្កា ។ បទថា **ន ពុជ្ឈតិ** សេចក្តីថា មិនដឹងខ្លួនថា កាលអញលេបកូនបាស្កានេះ ឈ្មោះថា ត្រូវធ្វើកម្មនេះ ។ បទថា **គិល រេ** សេចក្តីថា លេបចុះ អ្នក លេងអាក្រក់ ។

ព្រះពោធិសត្វពោលដដែលជាស់តឿនទៀតថា **គិល** គឺចូរលេបចុះ ។

បទថា **បច្ឆា តេ កដុកំ ភវិស្សតិ** សេចក្តីថា កាលអ្នកលេបកូន បាស្កានេះទៅហើយ ខាងក្រោយ ពិសដ៏ខ្លាំងក្លា នឹងមាន ។

កាលព្រះពោធិសត្វកំពុងពោលនោះឯង បុរសនោះក៏សន្ទប់ដោយកម្លាំងថ្នាំពិស ភ្នែកត្រឡប់ កដួលចុះ ព្រះពោធិសត្វគិតថា គួរឲ្យជីវិតទានដល់អ្នកលេងនោះ ទើបឲ្យថ្នាំបន្សាត់ដែលផ្សំដោយឱសថ ធ្វើឲ្យក្អួតចេញមក នឹងឲ្យបរិភោគសប្បិ ទឹកអំពៅ ទឹកឃ្មុំ និងស្ករក្រាមជាដើម ធ្វើឲ្យជាសះស្បើយរោគ ទូន្មានថា កុំធ្វើកម្មបែបនេះទៀត ដូច្នេះហើយ ធ្វើបុណ្យ មានទានជាដើម ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការមិនពិចារណា ហើយបរិភោគ រមែងដូចគ្នានឹងការមិនចារណា ហើយបរិភោគថ្នាំពិស ដែលបុគ្គលដទៃធ្វើ ហើយទ្រង់ប្រជុំជាតកថា អ្នកលេងជាបណ្ឌិតក្នុងកាលនោះ គឺជាតថាគតនេះឯង ឯអ្នកលេងកោង លោកមិនបានពោល ប្រហែលជាមិនប្រាកដក្នុងកាលនេះ បុគ្គលនោះ មិនពោលដល់ ដូចក្នុងរឿងទាំងពួង ដូច្នេះ ។ល។

**អដ្ឋកថា លិត្តជាតក ចប់**

# សុត្តន្តបិដក

## មហាសារជាតក

[ ៩២ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) ក្នុងកាលសង្គ្រាមកើតឡើង ពួកជនរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា ក្នុងពួកអ្នកប្រឹក្សាការ គេប្រាថ្នានូវបុរសអ្នកមានវាចាមិនរោយរាយ ក្នុងកាលមានបាយទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុងកាលអាថ ( កំបាំង ) កើតឡើង គេប្រាថ្នានូវបណ្ឌិត ។

*មហាសារជាតកទី ២ ចប់*

# អដ្ឋកថា

## មហាសារជាតក

[ ៩២ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឧក្កដ្ឋេ សូរមិច្ឆន្តិ** ដូច្នេះជាដើម ។

សម័យមួយ ពួកស្នំរបស់ព្រះបាទកោសលគិតគ្នាថា ឈ្មោះថា ការកើតឡើងនៃព្រះពុទ្ធ ជាសភាពរកបានលំបាក ការបានអត្តភាពជាមនុស្ស និងការមានអាយតនៈបរិបូណ៌ ក៏រកបានលំបាកដូចគ្នា ។ ម្យ៉ាងទៀត ពួកយើងបាននូវសម្បត្តិនៃឋានៈដែលរកបានលំបាកនេះ ក៏មិនបានទៅកាន់វិហារស្ដាប់ធម៌ ឬធ្វើការបូជា ឬឲ្យទានតាមគាប់ចិត្តរបស់ខ្លួនបាន ត្រូវនៅជាមួយគ្នា ដូចត្រូវរក្សាក្នុងហិប ពួកយើងនឹងក្រាបទូលព្រះរាជា ឲ្យទ្រង់និមន្តភិក្ខុមួយរូប ដែលសមគួរសម្ដែងធម៌ប្រោស ពួកយើងនឹងនាំគ្នាស្ដាប់ធម៌ក្នុងសម្នាក់របស់លោក បទណាដែលពួកយើងត្រូវសិក្សា ក៏នឹងនាំគ្នារៀនបទនោះអំពីលោក នាំគ្នាបំពេញបុណ្យ មានទានជាដើម ដោយប្រការដូច្នេះ ។ ការបានចំពោះនូវខណៈរបស់ពួកយើងនឹងមានផល ស្នំទាំងអស់នោះ នាំគ្នាចូលគាល់ព្រះរាជា ក្រាបទូលហេតុដែលគិតគ្នា ព្រះរាជាត្រាស់ថា សាធុ ។ ថ្ងៃមួយ មានព្រះបំណងក្រសាលឧទ្យាន ក៏ត្រាស់ឲ្យហៅឧទ្យានបាលមកគាល់ ត្រាស់ថា ចូរអ្នកជម្រះឧទ្យាន ។ នាយឧទ្យានបាល កាលជម្រះឧទ្យាន ជួបព្រះសាស្ដាដែលទ្រង់គង់ត្រង់គល់ឈើមួយដើម ប្រញាប់ទៅកាន់ព្រះរាជសម្នាក់ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ឧទ្យានស្អាតរៀបរយហើយ តែព្រះសាស្ដាទ្រង់

គង់ត្រង់គល់ឈើមួយដើម ក្នុងឧទ្យាននោះ ។ ព្រះរាជាត្រាស់ថា សាធុ សម្លាញ់ យើងនឹងទៅស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ទ្រង់ឡើងលើរថទ្រង់គ្រឿង ដែលប្រដាប់ហើយ យាងទៅកាន់ព្រះរាជឧទ្យាន បានយាងទៅកាន់សម្នាក់ព្រះសាស្តា ។

ក្នុងសម័យនោះ ឧបាសកជាព្រះអនាគាមីម្នាក់ ឈ្មោះឆត្តបាណិ អង្គុយស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ។ ព្រះរាជាឃើញឆត្តបាណិឧបាសកហើយ កើតសេចក្តីសង្ស័យ ប្រថាប់ឈប់មួយស្របក់ ហើយទ្រង់ត្រិះរិះថា បើបុរសនេះជាអ្នកថោកថយ ប្រហែលមិនអាចអង្គុយស្តាប់ធម៌ ក្នុងសម្នាក់ព្រះសាស្តាបានទេ បុរសនេះមិនថោកថយឡើយ ហើយយាងចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង ឧបាសកមិនបានធ្វើការទទួលព្រះរាជា ឬថ្វាយបង្គំ ព្រោះការគោរពក្នុងព្រះពុទ្ធ ដោយហេតុនោះទើបព្រះរាជាមិនពេញព្រះហឫទ័យក្នុងឆត្តបាណិឧបាសក ។ ព្រះសាស្តាទ្រង់ជ្រាបភាពដែលព្រះរាជាទ្រង់អាក់អន់ព្រះហឫទ័យក្នុងឧបាសក ទើបត្រាស់គុណឧបាសកថា មហាបពិត្រ ឧបាសកនេះជាពហុស្សូត ជាអ្នកចាំស្ទាត់ ប្រាសចាករាគៈក្នុងកាម ។ ព្រះរាជាទ្រង់ត្រិះរិះថា ព្រះសាស្តាទ្រង់ជ្រាបគុណរបស់បុគ្គលណា បុគ្គលនោះ ជាអ្នកមិនថោកថយឡើយ ទើបត្រាស់ថា ឧបាសក បើអ្នកត្រូវការរបស់ណា ចូរប្រាប់ខ្ញុំចុះ ឧបាសកទទួលស្នងព្រះតម្រាស់ព្រះរាជាថា សាធុ ។ ព្រះរាជាទ្រង់ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ ទ្រង់ធ្វើប្រទក្សិណព្រះសាស្តា រួចយាងត្រឡប់ទៅ ។

ថ្ងៃមួយ ព្រះរាជាទ្រង់បើកព្រះសីហបញ្ជរ ឈរប្រថាប់ក្នុងប្រាសាទជាន់លើ ទតឃើញឧបាសកនោះ បរិភោគអាហារព្រឹកហើយ កាន់ឆត្រដើរទៅកាន់វត្តជេតពន ក៏ត្រាស់ឲ្យរាជបុរសទៅអញ្ជើញមក ហើយត្រាស់ថា ឧបាសកបានឮថា អ្នកជាពហូសូត ស្ត្រីរបស់ខ្ញុំត្រូវការស្តាប់ និងត្រូវការរៀនធម៌ ជាការល្អហ្ន៎ បើអ្នកគប្បីសម្តែងធម៌ គប្បីប្រាប់ធម៌ដល់ស្រីទាំងនោះៗ ឧបាសកទូលថា ធម្មតាគ្រហស្ថទាំងឡាយ មិនសមគួរសម្តែងធម៌ ឬប្រាប់ធម៌ ក្នុងព្រះរាជដ្ឋានខាងក្នុង រឿងនោះ សមគួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ឧបាសកនេះនិយាយពិត បញ្ជូនគាត់ទៅ ត្រាស់ឲ្យហៅស្នំ មកចូលគាល់ មានព្រះតម្រាស់ថា នែនាង យើងនឹងទៅកាន់សម្នាក់ព្រះសាស្តា ទូលសូមភិក្ខុមួយរូបដើម្បីសម្តែងធម៌ និងប្រាប់ធម៌ដល់ពួកនាងក្នុងមហាសាវកទាំង ៨០ អង្គ យើងនឹងសូមអង្គណាល្អហ្ន៎ ស្នំទាំងអស់ប្រឹក្សាគ្នា ក្រាបទូលដល់ព្រះអានន្ទត្ថេរដែលជាឃ្លាំងធម៌ ។ ព្រះរាជាយាងទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ក្នុងចំណែកម្ខាង ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកស្រីក្នុងវាំងរបស់ខ្ញុំព្រះអង្គប្រាថ្នាស្តាប់ និងរៀនធម៌ក្នុងសម្នាក់ព្រះអានន្ទត្ថេរ គប្បីជាការល្អហ្ន៎ បើព្រះថេរៈគប្បីសម្តែងធម៌ គប្បីប្រាប់ធម៌ ក្នុងវាំងរបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាទ្រង់ទទួលថា សាធុ មហាបពិត្រ ហើយត្រាស់ប្រាប់ដល់ព្រះថេរៈ ។ តាំងពីកាលនោះមក ស្នំរបស់ព្រះរាជា នាំគ្នាស្តាប់ និងរៀនធម៌ក្នុងសម្នាក់របស់ព្រះថេរៈ ។

សម័យថ្ងៃមួយ ព្រះចូឡាមណីរបស់ព្រះរាជាបាត់ទៅ ព្រះរាជាទ្រង់ជ្រាប ភាពដែលព្រះចូឡាមណីនោះបាត់ទៅ ទ្រង់បញ្ជាពួកអមាត្យថា ចូរពួកអ្នក ចាប់មនុស្សអ្នកបម្រើខាងក្នុងទាំងអស់ បង្គាប់ឲ្យនាំចូឡាមណីមកឲ្យបាន ពួក អមាត្យសួររកព្រះចូឡាមណី ចាប់តាំងអំពីមាតុគ្រាមរហូតមក ក៏មិនឃើញ ធ្វើ ឲ្យមហាជនលំបាក ។ ក្នុងថ្ងៃនោះ ព្រះអានន្ទចូលទៅកាន់ព្រះរាជវាំង ស្រីស្នំទាំងនោះ កាលពីមុនឃើញព្រះថេរៈប៉ុណ្ណោះ ក៏នាំគ្នាត្រេកអរ តាំង ចិត្តស្តាប់ តាំងចិត្តរៀនធម៌ មិនបានយ៉ាងនោះឡើយ គ្រប់គ្នា នាំគ្នាទោម-នស្សទាំងអស់ កាលព្រះថេរៈសួរថា ហេតុអ្វី ទើបពួកនាងមានសភាពបែប នេះក្នុងថ្ងៃនេះ ក៏នាំគ្នាប្រាប់យ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកអមាត្យពោល ថា ពួកយើងនឹងស្វែងរកព្រះចូឡាមណីរបស់ព្រះរាជា នាំគ្នាចាប់មាតុគ្រាម ធ្វើឲ្យអ្នកបម្រើខាងក្នុងលំបាក ពួកខ្ញុំមិនជ្រាបថា អ្នកណាជាអ្នកយក ហេតុ នោះ ទើបពួកខ្ញុំនាំគ្នាលំបាកចិត្ត ។ ព្រះថេរៈលួងលោមពួកស្រីទាំងនោះថា កុំគិតច្រើនឡើយ ដូច្នេះហើយ ទៅកាន់សម្នាក់ព្រះរាជា អង្គុយលើអាសនៈ ដែលគេរៀបចំ ថ្វាយព្រះពរសួរថា មហាបពិត្រ បានឮថា កែវមណីរបស់ មហាបពិត្រ បាត់ទៅឬ ព្រះរាជាត្រាស់ថា ករុណាលោកម្ចាស់ ព្រះថេរៈ ថ្វាយព្រះពរថា មហាបពិត្រ ទ្រង់មិនអាចឲ្យអ្នកណានាំមកវិញបានឬ បពិត្រ លោកម្ចាស់ ខ្ញុំឲ្យគេចាប់មនុស្សខាងក្នុងគ្រប់គ្នា ធ្វើឲ្យលំបាក ក៏នៅតែមិន អាចនាំមកវិញបាន ព្រះថេរៈថ្វាយព្រះពរថា មហាបពិត្រ ឧបាយដែលនឹង មិនចាំបាច់ឲ្យមហាជនលំបាក ហើយយកមកវិញបាន មាន ព្រះរាជាត្រាស់

ថា បពិត្រលោកម្ចាស់ តើឧបាយដូចម្តេច ព្រះថេរៈថ្វាយព្រះពរថា គឺបិណ្ឌ-ទាន មហាបពិត្រ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ បិណ្ឌទានដូចម្តេច ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ បើទ្រង់សង្ស័យនឹងមនុស្សមានប្រមាណប៉ុនណា ក៏ចាប់មនុស្សទាំងនោះប៉ុណ្ណោះ ហើយឲ្យបាច់ចំបើង ឬដុំដីស្អិត ម្នាក់មួយបាច់ ឬមួយដុំ ប្រាប់ថា ក្នុងវេលាទៀបភ្លឺ ឲ្យនាំបាច់ចំបើង ឬដុំដីនោះមកបោះត្រង់នោះ បុគ្គលណាជាអ្នកយកទៅ បុគ្គលនោះនឹងដាក់ចូឡាមណីក្នុងបាច់ចំបើង ឬដុំដីនោះនាំមកបោះក្នុងថ្ងៃទី ១ នោះឯងនុ៎ះជាការល្អ បើមិននាំមកបោះទេ គប្បីធ្វើយ៉ាងនោះឯងតទៅ ក្នុងថ្ងៃទី ២ ថ្ងៃទី៣ ដោយវិធីនេះ មហាជននឹងមិនលំបាកផង នឹងបានកែវមណីមកវិញផង លុះថ្វាយព្រះយោបល់យ៉ាងនេះ ព្រះថេរៈក៏លាទៅ ។

ព្រះរាជា បានត្រាស់ឲ្យព្រះរាជទានដោយន័យដែលព្រះថេរៈថ្វាយព្រះពរអស់ ៣ ថ្ងៃ ក៏មិនមានអ្នកនាំកែវមណីមកវិញឡើយ ក្នុងថ្ងៃទី ៣ ព្រះថេរៈក៏មកថ្វាយព្រះពរសួរថា បពិត្រមហារាជ មានអ្នកណាយកកែវមណីមកបោះហើយឬនៅ ព្រះរាជាត្រាស់ថា មិនទាន់មានអ្នកណាយកមកឡើយ ។ ព្រះអានន្ទទូលថា បើដូច្នោះ សូមមហាបពិត្របញ្ជាឲ្យដាក់ពាងធំក្នុងទីកំបាំងក្នុងផ្ទៃប្រាសាទធំនោះឯង ឲ្យដងទឹកថ្វាដាក់ឲ្យពេញ ឲ្យបាំងវាំងនន ត្រាស់ថា ពួកមនុស្សបម្រើខាងក្នុងគ្រប់គ្នា និងពួកស្ត្រី ចូរដណ្តប់សំពត់ចូលទៅក្នុងវាំងនន លាងដៃហើយចេញមក ព្រះថេរៈថ្វាយឧបាយនេះហើយ ក៏លាទៅ ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ មនុស្សដែលលួចកែវមណីទៅ គិតថា ព្រះ

ថេរៈជាកណ្ឋាគារិក មកគ្រប់គ្រងអធិករណ៍នេះ បើមិនបានកែវមណី នឹងប្រារព្ធខ្ទនបាន គ្រានេះ អញគួរលះកែវនោះ ហើយកាន់យកកែវលាក់ទុកយ៉ាងជិត ចូលទៅខាងក្នុងរាំងនទ បោះកែវក្នុងពាងហើយប្រញាប់ចេញ ក្នុងកាលចេញគ្រប់គ្នាហើយ ពួករាជបុរសចាក់ទឹក បានឃើញកែវមណី ព្រះរាជាទ្រង់សប្បាយព្រះហឫទ័យថា អញអាស្រ័យព្រះថេរៈ មិនចាំបាច់ឲ្យមហាជនលំបាក បានកែវមណីហើយ ។ សូម្បីពួកមនុស្សដែលជាខាងក្នុង ក៏នាំគ្នាត្រេកអរថា ពួកយើងអាស្រ័យព្រះថេរៈ នាំគ្នាផុតចាកទុក្ខដ៏ធំ ដោយអានុភាពរបស់ព្រះថេរៈ ព្រះរាជាទ្រង់បានព្រះចូឡាមណី ដោយអានុភាពរបស់ព្រះថេរៈ កេរ្តិ៍ឈ្មោះល្បីប្រាកដទៅក្នុងព្រះនគរទាំងមូល និងក្នុងភិក្ខុសង្ឃ ។

ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា ពណ៌នាគុណរបស់ព្រះថេរៈថា អាវុសោទាំងឡាយ ព្រះអានន្ទត្ថេរ មិនបានឲ្យមហាជនលំបាក ប្រើឧបាយប៉ុណ្ណោះសម្តែងកែវមណីឲ្យព្រះរាជាបាន ព្រោះជាពហូសូត ជាបណ្ឌិត និងជាអ្នកឈ្លាសក្នុងឧបាយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា មិនមែនអានន្ទតែមួយរូបដែលបង្ហាញភណ្ឌៈ ដែលធ្លាក់ដល់ដៃអ្នកដទៃបានក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយ ក៏មិនចាំបាច់ឲ្យមហាជនលំបាកឡើយ ប្រើតែឧបាយប៉ុណ្ណោះ ក៏បង្ហាញភណ្ឌៈ ដែលធ្លាក់ក្នុងដៃរបស់សត្វតិរច្ឆានបាន ភិក្ខុទាំងនោះក្រាបទូលអារាធនា ទ្រង់នាំយក

រឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វរៀបចប់សិល្បសាស្ត្រគ្រប់យ៉ាង ហើយបានជាអមាត្យរបស់ព្រះបាទព្រហ្មទត្តអង្គនោះ ។ សម័យថ្ងៃមួយ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ដោយបរិវារដ៏ច្រើន ទ្រង់ត្រាច់ទៅកាន់លំផ្នែកព្រៃ ហើយទ្រង់បំណងនឹងលេងឧទកកីឡា ចុះកាន់ស្រះបោក្ខរណីដែលជាមង្គលត្រាស់ហៅស្រីខាងក្នុង ។ ពួកស្ត្រីដោះអាភរណៈ មានគ្រឿងប្រដាប់ក្បាលនិងគ្រឿងប្រដាប់កជាដើមរបស់ខ្លួន ដាក់ក្នុងសំពត់ដណ្តប់លើហិប ឲ្យទាសីទាំងឡាយរក្សា នាំគ្នាចុះកាន់ស្រះបោក្ខរណី ។ កាលនោះ ស្វាញីនៅក្នុងឧទ្យាន អង្គុយលើមែកឈើ ឃើញព្រះទេវីដោះគ្រឿងប្រដាប់ដាក់ក្នុងសំពត់ ហើយដាក់លើហិប នឹកចង់ពាក់មុក្តាហារ ( កម្រងគជ់ ) របស់ព្រះនាងអង្គុយរង់ចាំមើលការភ្លេចខ្លួនរបស់ទាសី ។ ឯទាសីអ្នកយាម អង្គុយមើលក្នុងទីនោះ ក៏ដេកលក់ទៅ ស្វាញីដឹងថា ទាសីប្រមាទ លោតចុះដោយរហ័សដូចខ្យល់ ពាក់កម្រងមុក្តាហារត្រង់ក ហើយលោតឡើងដើមឈើរហ័សដូចខ្យល់ អង្គុយលើមែកឈើ ខ្លាចស្វាញីដទៃៗ ឃើញ ទើបលាក់ក្នុងប្រពន្ធ័ឈើមួយកន្លែង សម្តែងអាការស្ងប់ស្ងៀម អង្គុយយាមគ្រឿងប្រដាប់នោះ ។ ឯទាសីនោះភ្ញាក់ឡើង មិនឃើញមុក្តាហារ មានខ្លួនញ័រចំប្រប់ មិនឃើញឧបាយដទៃ ក៏ស្រែកថា មនុស្សដណ្តើមមុក្តាហាររបស់ព្រះទេវីគេចទៅហើយ ពួកមនុស្សអ្នកយាម ប្រជុំគ្នាតាមតំណែងនោះៗ កាលបានឮពាក្យរបស់នាង

ក៏ក្រាបទូលដល់ព្រះរាជាៗ ត្រាស់ថា ចូរពួកអ្នកចាប់ចោរឲ្យបាន ពួករាជបុរស ទាំងឡាយ ក៏នាំគ្នាចេញអំពីព្រះរាជឧទ្យាន ពោលថា ចូរពួកអ្នកចាប់ចោរ ចូរចាប់ចោរ នាំគ្នារកមើលក្នុងទីផ្សេងៗ ។

គ្រានោះ បុរសអ្នកជនបទម្នាក់កំពុងធ្វើពលីកម្ម បានឮសំឡេងនោះ ក៏រត់គេចទៅ ពួករាជបុរសឃើញ ក៏ដេញតាម ស្រែកថា បុគ្គលនេះជាចោរ ចាប់បាន វាយផង សម្លុតផងថា វ៉ើយ ចោរអាក្រក់ អាហ៊ានលួចគ្រឿងប្រដាប់ ឈ្មោះមហាសារផងឬ ។ បុរសនោះគិតថា បើអញប្រាប់ថា ខ្ញុំមិនបានយក ថ្ងៃនេះ គង់មិនរួចជីវិត ពួករាជបុរសគង់វាយរហូតដល់ស្លាប់ អញត្រូវតែទទួល ទើបប្រាប់ថា ខ្ញុំជាអ្នកយក ។ ពេលនោះ ពួករាជបុរសក៏នាំគ្នាចង បណ្តើរមកកាន់សម្នាក់ព្រះរាជា ចំណែកព្រះរាជាត្រាស់សួរថា គ្រឿងប្រដាប់មានតម្លៃច្រើនឯងលួចទៅឬ បុរសនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំលួចពិតមែន ព្រះរាជាត្រាស់សួរថា ឥឡូវនេះ នៅឯណា បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា វត្ថុមានតម្លៃច្រើន សូម្បីខ្ញុំព្រះអង្គមិនធ្លាប់ឃើញ តែលោកសេដ្ឋី ប្រាប់ឲ្យខ្ញុំព្រះអង្គលួចគ្រឿងប្រដាប់មានតម្លៃច្រើននោះ ទើបខ្ញុំព្រះអង្គលួចយកទៅ ហើយប្រគល់ឲ្យគាត់ សេដ្ឋីនោះឯងទើបដឹង ។ ព្រះរាជាត្រាស់ឲ្យហៅសេដ្ឋីចូលគាល់ ត្រាស់សួរថា គ្រឿងប្រដាប់មានតម្លៃច្រើន លោកទទួលយកអំពីដៃបុរសនេះឬ សេដ្ឋីក្រាបទូលថា ករុណាថ្លៃវិសេសព្រះអង្គ ព្រះរាជាត្រាស់សួរថា លោកទុកនៅឯណា សេដ្ឋីក្រាបទូលថា ទូលបង្គំឲ្យបុរោហិតទៅហើយ ។ ព្រះរាជាត្រាស់ឲ្យហៅ

បុរោហិតនោះចូលគាល់ ត្រាស់សួរដូច្នោះឯង សូម្បីបុរោហិតក៏ទទួលហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំឲ្យដល់គន្ធព្វទៅហើយ ។ ព្រះរាជាឲ្យហៅគន្ធព្វចូលគាល់ ត្រាស់សួរថា ឯងទទួលយកគ្រឿងប្រដាប់មានតម្លៃច្រើនអំពីដៃបុរោហិតឬ គន្ធព្វក្រាបទូលថា ករុណាថ្លៃវិសេស ព្រះរាជាសួរថា ឯងទុកឯណា គន្ធព្វក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំឲ្យដល់នាងវណ្ណទាសីទៅហើយ ដោយអំណាចនៃកិលេស ។ ព្រះរាជាឲ្យហៅនាងវណ្ណទាសីមកត្រាស់សួរ នាងក្រាបទូលថា ខ្ញុំម្ចាស់មិនបានទទួលទេ ។ កាលសាកសួរជនទាំង ៥ ទម្រាំនឹងគ្រប់ ព្រះអាទិត្យលិចទៅហើយ ។ ព្រះរាជាត្រាស់ថា ឥឡូវនេះ យប់ហើយ យើងនឹងត្រូវដឹងរឿងនេះក្នុងថ្ងៃស្អែក ប្រគល់ជនទាំង ៥ ដល់ពួកអមាត្យ ហើយយាងចូលកាន់ព្រះនគរ ។

ព្រះពោធិសត្វត្រិះរិះថា គ្រឿងប្រដាប់នេះ បាត់ខាងក្នុង ឯគហបតីនេះជាមនុស្សខាងក្រៅ ការយាមទ្វារក៏តឹងរ៉ឹង ហេតុនោះ សូម្បីតែមនុស្សខាងក្នុងលួចគ្រឿងប្រដាប់នោះ ក៏មិនអាចគេចបាន ទោះបីអ្នកខាងក្រៅលួចក្តី អ្នកស៊ីឈ្នួលក្នុងឧទ្យានលួចក្តី មិនអាចរត់រួចឡើយ ពាក្យដែលមនុស្សនេះពោលថា ទូលបង្គំឲ្យសេដ្ឋីទៅហើយ ជាពាក្យដោះខ្លួនពិត សូម្បីពោលថា ទូលបង្គំឲ្យដល់បុរោហិត ជាការពោលព្រោះគិតថា ពួកយើងត្រូវរួមគ្នាធ្វើឲ្យស្អុគស្អាញ សូម្បីបុរោហិតគិតថា ទូលបង្គំឲ្យគន្ធព្វទៅហើយ ក៏ពោលព្រោះគិតថា ពួកយើងត្រូវអាស្រ័យគន្ធព្វ ទើបនៅសប្បាយក្នុងគុក គន្ធព្វពោលថា ទូលបង្គំឲ្យនាងវណ្ណទាសីទៅហើយ ក៏ពោលព្រោះគិតថា ព្រោះពួកយើង បើ

បានទាន់វណ្ណទាសីនៅក្នុងគុកនឹងមិនអផ្សុក ។ ជនទាំង ៥ មិនមែនជាចោរឡើយ ក្នុងឧទ្យានមានស្វាច្រើន គ្រឿងប្រដាប់មុខជាធ្លាក់ក្នុងដៃរបស់ស្វាណាមួយពិត ។ ទើបព្រះពោធិសត្វចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ សូមទ្រង់មេត្តាប្រគល់ចោរទាំងនោះដល់ទូលបង្គំៗ នឹងជម្រះរឿងនោះឯង ។ ព្រះរាជាត្រាស់ថា សាធុ បណ្ឌិត ចូរអ្នកជម្រះចុះ ហើយទ្រង់ប្រគល់អ្នកទាំងនោះដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វឲ្យហៅអ្នកបម្រើប្រុសរបស់ខ្លួនមកឲ្យមនុស្សទាំង ៥ ទៅប្រជុំគ្នាក្នុងទីតែមួយ ធ្វើការឃុំខ្លួនជាមួយគ្នា ឲ្យមនុស្សលបស្តាប់ថា ជនទាំងនោះពោលពាក្យអ្វីខ្លះ ចូរអ្នកប្រាប់ពាក្យនោះដល់យើង ហើយចៀសចេញទៅ ជនទាំងនោះ បានធ្វើយ៉ាងនោះហើយ ។

កាលដល់ពេលដែលពួកមនុស្សស្ងួនទាគ្នា លោកសេដ្ឋីពោលនឹងគហបតីនោះថា នែគហបតីអាក្រក់ អាធ្លាប់ស្គាល់អញឬ អញធ្លាប់ជួបអាក្នុងពេលណា អាឲ្យគ្រឿងប្រដាប់អញពីអង្កាល់ គហបតីពោលថា បពិត្រលោកសេដ្ឋី ខ្ញុំមិនដែលស្គាល់ត្រឹមតែគ្រែ និងតាំង ដែលមានជើង ធ្វើដោយខ្លឹមឈើដែលឈ្មោះថាមហាសារ តែខ្ញុំពោលយ៉ាងនោះ ព្រោះគិតថា អាស្រ័យលោកសេដ្ឋី ខ្ញុំនឹងរួចខ្លួន សូមកុំខឹងខ្ញុំឡើយ ។ បុរោហិតពោលនឹងលោកសេដ្ឋីថា លោកឲ្យគ្រឿងប្រដាប់ដែលគហបតីនេះមិនបានឲ្យដល់លោក មកដល់ខ្ញុំបានដូចម្តេច លោកសេដ្ឋីពោលថា ខ្ញុំនិយាយព្រោះគិតថា យើងទាំង ២ ជាអ្នកធំដូចគ្នា ក្នុងកាលដែលយើងទៅនិយាយជាមួយគ្នា ការងារនឹងសម្រេចដោយរហ័ស ។ ឯគន្ធព្វក៏ពោលនឹងបុរោហិតថា នែព្រាហ្មណ៍ លោក

ឲ្យគ្រឿងប្រដាប់ខ្ញុំពីអង្គាល់ បុរោហិតពោលថា ខ្ញុំចេះតែពោលទៅ ព្រោះគិតថា បើបានលោកនៅជាមួយក្នុងគុក នឹងបានសេចក្តីសុខ ។ សូម្បីនាងវណ្ណ-ទាសីក៏ពោលនឹងគន្ធព្វថា នែគន្ធព្វអាក្រក់ អញធ្លាប់ទៅរកអា ឬអាធ្លាប់មករកអញពីអង្កាល់ណា អាឲ្យគ្រឿងប្រដាប់អញពីអង្កាល់ណា គន្ធព្វពោលថា នែប្អូនស្រី ព្រោះហេតុអ្វី មកខឹងនឹងខ្ញុំ កាលពួកយើងទាំង ៥ នៅរួមគ្នា ការរស់នៅបែបយកវាសនឹងត្រូវមាន អាស្រ័យនាង ពួកខ្ញុំនឹងមិនអផ្សុក នៅរួមគ្នាយ៉ាងសប្បាយ ដូច្នេះ ។

ព្រះពោធិសត្វស្តាប់ពាក្យនោះ អំពីសម្នាក់របស់មនុស្សដែលឲ្យលបស្តាប់ ដឹងភាពដែលជនទាំងនោះមិនមែនចោរ គិតថា គ្រឿងប្រដាប់ពិតជាស្វាញីលួចយកទៅ ទើបធ្វើឧបាយឲ្យស្វាបោះមកដីឲ្យបាន ហើយធ្វើគ្រឿងប្រដាប់សម្រេចដោយជ័រឈើ ឲ្យចាប់ពួកស្វាញីក្នុងឧទ្យាន ហើយតាក់តែងគ្រឿងប្រដាប់អំពីជ័រឈើ ត្រង់ដៃ ត្រង់ជើង ត្រង់ក ហើយលែងទៅ ។ ឯស្វាញីអង្គុយយាមគ្រឿងប្រដាប់ក្នុងឧទ្យាននោះឯង ព្រះពោធិសត្វបញ្ជាមនុស្សទាំងឡាយថា ចូរពួកអ្នកនាំគ្នាទៅចុះ ហើយសង្កេតមើលស្វាញីក្នុងឧទ្យាន ឃើញគ្រឿងប្រដាប់នោះនៅស្វាមួយណា ចូរធ្វើឲ្យវាភ័យ ហើយយកគ្រឿងប្រដាប់មកឲ្យបាន ។ ស្វាញីទាំងនោះ នាំគ្នាត្រេកអរថា ពួកយើងបានគ្រឿងតែងខ្លួន ហើយនាំគ្នារត់ទៅមកក្នុងឧទ្យាន ដល់សម្នាក់របស់ស្វាញីនោះ នាំគ្នាពោលថា នែនាង ចូរនាងមើលគ្រឿងប្រដាប់របស់ពួកខ្ញុំ ។ ស្វាញីនោះអត់ធន់មិនបាន គិតថា អស្ចារ្យអ្វីដោយគ្រឿងប្រដាប់ដែលធ្វើដោយជ័រឈើ

នេះ ហើយពាក់គ្រឿងមុក្តាហារ ដើម្បីបង្អួត ។ កាលនោះ មនុស្សទាំងនោះ ឃើញហើយ ធ្វើឲ្យស្វាញីភ័យ ទម្លាក់គ្រឿងប្រដាប់ ហើយនាំមកប្រគល់ ឲ្យព្រះពោធិសត្វៗ នាំគ្រឿងប្រដាប់នោះទៅថ្វាយព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះគ្រឿងប្រដាប់របស់ទ្រង់ មនុស្សទាំង ៥ នោះ មិនមែនជាចោរទេ តែគ្រឿងប្រដាប់នេះ បានមកអំពីស្វាញីក្នុងឧទ្យាន ។ ព្រះរាជាត្រាស់សួរថា នែបណ្ឌិត អ្នកបានដឹងភាពដែលគ្រឿងប្រដាប់នេះធ្លាក់ក្នុងដៃស្វាញីបានដូចម្តេច ហើយនាំយកមកវិញបានដូចម្តេច ព្រះពោធិសត្វក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់សប្បាយព្រះហឫទ័យ ត្រាស់ថា ជម្មតាមនុស្សក្លាហានជាដើម ជាបុគ្គលដែលគួរប្រាថ្នាក្នុងឋានៈតំណែងមេទ័ពជាដើម ដូច្នេះហើយ កាលទ្រង់សរសើរព្រះពោធិសត្វ ទើបត្រាស់ព្រះគាថានេះថា

ក្នុងកាលសង្គ្រាមកើតឡើង ពួកជនរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា
ក្នុងពួកអ្នកប្រឹក្សាការ គេប្រាថ្នានូវបុរសអ្នកមានវាចាមិនរោយរាយ
ក្នុងកាលមានបាយទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុង
កាលអាថ ( កំបាំង ) កើតឡើង គេប្រាថ្នានូវបណ្ឌិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧក្កដ្ឋេ** សេចក្តីថា ក្នុងកាលមានចម្បាំង គឺក្នុងកាលភាគីទាំង ២ ចូលមកប្រឈមមុខគ្នា អធិប្បាយថា ការច្បាំងក្នុងសង្គ្រាមកំពុងប្រព្រឹត្តទៅ ។

បទថា **សូរមិច្ឆន្តិ** សេចក្តីថា រមែងប្រាថ្នាបុរសដែលក្លាហាន មាន

ប្រក្រតីមិនរាថយ ទោះបីរន្ទះធ្លាក់លើអំបែងក្បាល ព្រោះថា ក្នុងខណៈនោះ ជនបែបនេះ គួរតែងតាំងឲ្យជាមេទ័ព ។

បទថា **មន្តីសុ អកុតូហលំ** សេចក្តីថា ពេលមានកិច្ចដែលត្រូវប្រឹក្សាដល់កិច្ចគួរធ្វើ និងមិនគួរធ្វើកើតឡើង ក្នុងពេលប្រឹក្សាការងារ ត្រូវការមនុស្សដែលមិននិយាយផ្តេសផ្តាស មិននិយាយរោយរាយ គឺមិននិយាយឥតប្រយោជន៍ ក្នុងបទដែលប្រឹក្សា ព្រោះបុគ្គលមានលក្ខណៈបែបនោះ សមនឹងតែងតាំងក្នុងតំណែងនោះៗ ។

បទថា **បិយញ្ច អន្នបានម្ហិ** សេចក្តីថា កាលបាយទឹកមានរសឆ្ងាញ់ប្រាកដឡើង រមែងប្រាថ្នាមនុស្សដែលជាទីស្រឡាញ់ ដើម្បីបរិភោគរួមគ្នា ព្រោះមនុស្សបែបនោះ គេត្រូវការក្នុងពេលនោះ ។

បទថា **អត្ថេ ជាតេ ច បណ្ឌិតំ** សេចក្តីថា កាលអត្ថដ៏ជ្រាលជ្រៅ និងធម៌ដ៏ជ្រាលជ្រៅកើតឡើង ឬកាលហេតុ និងបញ្ហាណាមួយកើតឡើង រមែងប្រាថ្នាបណ្ឌិត ដែលមានបញ្ញាប្រេចក្ស ព្រោះបុគ្គលមានលក្ខណៈបែបនោះ រមែងជាទីត្រូវការក្នុងសម័យនោះ ។

ព្រះរាជាត្រាស់ពណ៌នាសរសើរព្រះពោធិសត្វ ដោយប្រការដូច្នេះ ទ្រង់បូជាដោយរតនៈ ៧ ប្រការ ដូចមហាមេឃញ៉ាំងភ្លៀងឲ្យធ្លាក់ចុះ ដូច្នោះ តាំងព្រះកាយនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់បំពេញបុណ្យ មានទានជាដើម ទៅតាមយថាកម្ម សូម្បីព្រះពោធិសត្វក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់គុណរបស់ព្រះថេរៈ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯអមាត្យដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ។ ល។

**អដ្ឋកថា មហាសារជាតក ចប់**

# សុត្តន្តបិដក

## វិស្សាសភោជនជាតក

[ ៩៣ ] ( សេដ្ឋីពោធិសត្វពោលថា ) បុគ្គលមិនគប្បីស្និទ្ធស្នាលក្នុងបុគ្គលដែលមិនធ្លាប់ស្និទ្ធស្នាល មិនគប្បីស្និទ្ធស្នាលក្នុងបុគ្គល សូម្បីធ្លាប់ស្និទ្ធស្នាលហើយ ភ័យរមែងទៅតាមបុគ្គលនោះ ព្រោះសេចក្តីស្និទ្ធស្នាលដូចជាភ័យដែលជាប់តាមនូវសត្វសីហៈ ព្រោះមេម្រឹគ ។

**វិស្សាសភោជនជាតកទី ៣ ចប់**

# អដ្ឋកថា

## វិសវ្ភាសភោជនជាតក

[ ៩៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការបរិភោគដោយការទុកចិត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន វិស្សសេ អវិស្សត្ថេ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងសម័យនោះ ពួកភិក្ខុដោយច្រើន នាំគ្នាទុកចិត្ត មិនពិចារណា បរិភោគបច្ច័យ ៤ ដែលពួកញាតិប្រគេន ព្រោះគិតថា ម្តាយរបស់អញឲ្យ ឪពុករបស់អញឲ្យ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី មីងមា អ៊ំប្រុស អ៊ំស្រីឲ្យ ជនទាំងនេះ សមគួរនឹងឲ្យដល់អញ តាំងពីគ្រហស្ថមកហើយ សូម្បីក្នុងពេលអញជាភិក្ខុ ក៏គង់ជាបុគ្គលសមគួរឲ្យ ។ ព្រះសាស្តាទ្រង់ជ្រាបហេតុនោះ ទ្រង់ព្រះតម្រិះថា កាលនេះ ជាកាលគួរ ដែលតថាគតសម្តែងធម៌ទេសនាដល់ភិក្ខុទាំងឡាយ ដូច្នេះហើយ ទ្រង់ត្រាស់ឲ្យហៅភិក្ខុប្រជុំគ្នា ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ ត្រូវពិចារណាហើយ សឹមបរិភោគបច្ច័យ ៤ ដែលពួកញាតិខ្លះ អ្នកដទៃខ្លះ នាំគ្នាឲ្យ ដ្បិតថា ភិក្ខុដែលមិនពិចារណា ហើយបរិភោគ កាលធ្វើកាលកិរិយា រមែងមិនផុតចាកអត្តភាពជាយក្ខ និងប្រេត ឈ្មោះថា ការបរិភោគបច្ច័យ ៤ ដែលមិនពិចារណានេះ ដូចគ្នានឹងការបរិភោគថ្នាំពិស សូម្បីបុគ្គលដែលស្និទ្ធស្នាលឲ្យហើយក៏ដោយ បុគ្គលមិនស្និទ្ធស្នាលឲ្យហើយក៏ដោយ រមែងធ្វើឲ្យស្លាប់បានទាំងអស់ សូម្បីក្នុងកាលមុន សត្វទាំងឡាយបរិភោគថ្នាំពិស ដែលគេឲ្យ

ដោយវិស្សាស ដល់នូវការអស់ជីវិតហើយ ។ កាលភិក្ខុទាំងនោះក្រាបទូល អារាធនា ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាសេដ្ឋី មានសម្បត្តិច្រើន អ្នកចិញ្ចឹមគោរបស់សេដ្ឋីម្នាក់ កៀងហ្វូងគោចូលព្រៃ ក្នុងសម័យដែលទឹកដីពេញទៅដោយសម្លូង បោះក្រោលចិញ្ចឹមគោក្នុងព្រៃនោះ ហើយនាំគោមកឲ្យសេដ្ឋីតាមកាល ។ ក្នុងទីមិនឆ្ងាយអំពីទីចិញ្ចឹមគោនោះ មានសីហៈនៅអាស្រ័យ ពួកគោស្គាំងស្គម ព្រោះខ្លាចសីហៈ ទឹកដោះក៏ថយ ។ ថ្ងៃមួយ អ្នកចិញ្ចឹមគោនាំយកទឹកដោះមកឲ្យ សេដ្ឋីសួរថា គោបាលសម្លាញ់ មានរឿងអ្វីឬ ទើបទឹកដោះទៅជាថយ គាត់ប្រាប់ហេតុនោះ ។ សេដ្ឋីសួរថា នែសម្លាញ់ ការប្រតិព័ទ្ធណាមួយនៃសីហៈនោះមានដែរឬទេ អ្នករក្សាគោឆ្លើយថា មានលោកម្ចាស់ សីហៈនោះ ជាប់ជំពាក់ក្នុងមេម្រឹគមួយ ។ សេដ្ឋីសួរថា ឯងអាចចាប់មេម្រឹគនោះបានដែរឬទេ បុរសនោះឆ្លើយថា ខ្ញុំអាចធ្វើបាន សេដ្ឋីពោលថា បើដូច្នោះចូរអ្នកចាប់មេម្រឹគឲ្យបាន ហើយយកថ្នាំពិសលាបរោមមេម្រឹគនោះ តាំងអំពីថ្ងាស រហូតដល់ចុងកន្ទុយ ច្រើនដង ធ្វើឲ្យស្ងួត បង្ខាំងទុក ២-៣ ថ្ងៃ ហើយលែងមេម្រឹគនោះទៅ សីហៈនោះនឹងលិទ្ធខ្លួនរបស់មេម្រឹគដោយសេចក្តីស្រឡាញ់ នឹងដល់នូវការអស់ជីវិត ពេលនោះ ចូរឯងកាន់យកស្បែក ក្រចក ចង្កូម និងសាច់មក ហើយប្រគល់ថ្នាំពិសបញ្ជូនទៅ ។ អ្នកចិញ្ចឹមគោរាយសំណាញ់ ចាប់មេម្រឹគនោះបានដោយឧបាយ ហើយធ្វើតាមពាក្យប្រាប់ ។

សីហៈឃើញមេម្រឹគនោះហើយ លិទ្ធសរីរៈរបស់មេម្រឹគដោយសេចក្ដីស្នេហា យ៉ាងខ្លាំងក្លា ដល់នូវការអស់ជីវិត ឯអ្នកចិញ្ចឹមគោក៏យកស្បែកជាដើម ទៅកាន់សម្នាក់នៃព្រះពោធិសត្វ ។

ព្រះពោធិសត្វជ្រាបហេតុនោះហើយ ពោលថា ឈ្មោះថា ស្នេហាក្នុងពួកដទៃមិនគួរធ្វើ សីហៈជាម្រឹគជាតិ សម្បូរដោយកម្លាំងយ៉ាងនេះ ព្រោះអាស្រ័យការជាប់ជំពាក់ដោយអំណាចកិលេស លិទ្ធសរីរៈរបស់មេម្រឹគ ធ្វើការបរិភោគថ្នាំពិស ដល់នូវការអស់ជីវិតហើយ កាលសម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ទើបពោលគាថានេះថា

បុគ្គលមិនគប្បីស្និទ្ធស្នាល ក្នុងបុគ្គលដែលមិនធ្លាប់ស្និទ្ធស្នាល មិន
គប្បីស្និទ្ធស្នាលក្នុងបុគ្គល សូម្បីធ្លាប់ស្និទ្ធស្នាលហើយ ភ័យរមែង
ទៅតាមបុគ្គលនោះ ព្រោះសេចក្ដីស្និទ្ធស្នាល ដូចជាភ័យដែល
ជាប់តាមនូវសត្វសីហៈ ព្រោះមេម្រឹគ ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូចតទៅ បុគ្គលណា ក្នុងកាលមុនធ្លាប់មានភ័យជាមួយបុគ្គលដែលមិនស្និទ្ធស្នាលជាមួយខ្លួន មិនគប្បីទុកចិត្ត គឺមិនគប្បីស្និទ្ធស្នាលជាមួយបុគ្គល ដែលមិនធ្លាប់ស្និទ្ធស្នាលនោះ បុគ្គលណាក្នុងកាលមុន មិនធ្លាប់មានភ័យនឹងអ្នកស្និទ្ធស្នាលជាមួយខ្លួន សូម្បីក្នុងបុគ្គលដែលធ្លាប់ស្និទ្ធស្នាលនោះ ក៏មិនគួរទុកចិត្ត គឺមិនគប្បីធ្វើនូវភាពជាអ្នកស្និទ្ធស្នាលឡើយ ព្រោះហេតុអ្វី ព្រោះភ័យ រមែងមកអំពីទីដែលធ្លាប់ស្និទ្ធស្នាលបានដល់ ភ័យនោះឯង រមែងមកអំពីការស្និទ្ធស្នាល ទាំងក្នុងមិត្រ ទាំងក្នុង

អមិត្រ សេចក្តីនេះដូចម្តេច ដូចភ័យរបស់រាជសីហ៍ កើតអំពីមេម្រឹគ ដូច្នោះ គឺដូចគ្នានឹងភ័យដែលសីហៈបានជួប អំពីសម្នាក់មេម្រឹគដែលខ្លួនទុកចិត្ត ដោយអំណាចមិត្តសន្ថវៈ ម្យ៉ាងទៀត មានអធិប្បាយថា ដូចមេម្រឹគដែលប្រាថ្នានឹងមករក ចូលជិតសីហៈដោយសេចក្តីវិនាស ដូច្នេះក៏បាន ។

ព្រះពោធិសត្វសម្តែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នា ដោយប្រការដូច្នេះ ធ្វើបុណ្យទាំងឡាយ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា វិស្សាសភោជនជាតក ចប់**

# សុត្តន្តបិដក

## លោមហំសជាតក

[ ៩៤ ] ( អាជីវកពោធិសត្វពោលថា ) អាត្មាអញ ក្តៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់ខ្វាយក្នុងការស្វែងរក ( នូវព្រហ្មចរិយធម៌ ) ប្រតិបត្តិដើម្បីមោនៈ ។

*លោមហំសជាតកទី ៤ ចប់*

# អដ្ឋកថា

## លោមហំសជាតក

[ ៩៤ ] ព្រះសាស្តា ទ្រង់អាស្រ័យនគរវេសាលី គង់នៅក្នុងបាដិការាម ទ្រង់ប្រារព្ធសុនក្ខត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សោតត្តោ សោសីតោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យមួយ សុនក្ខត្តភិក្ខុជាឧបដ្ឋាកព្រះសាស្តាកាន់បាត្រនិងចីវរតាមព្រះសាស្តាទៅ កើតនូវការពេញចិត្តក្នុងធម៌របស់កោរក្ខត្តិយបរិញ្វាជកឲ្យបាត្រនិងចីវរដល់ព្រះទសពល ទៅអាស្រ័យកោរក្ខត្តិយបរិញ្វាជកនោះ ។ ក្នុងកាលកោរក្ខត្តិយបរិញ្វាជកនោះ ទៅកើតក្នុងកំណើតអសុរពួកកាឡកញ្ចិក ទើបសឹកជាគ្រហស្ថ ដើរពោលទោសព្រះសាស្តា តាមកំពែងទាំង ៣ ជាន់ ក្នុងនគរវេសាលីថា ឧត្តរិមនុស្សធម៌ គឺញាណទស្សនៈដ៏វិសេស ដែលល្មមជាព្រះអរិយៈរបស់ព្រះគោតម មិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួនត្រិះរិះឯង ដៅស្មានតាម ការស្ទាបស្ទង់ ដោយអំណាចបដិភាណរបស់ខ្លួន ធម៌ដែលព្រះសមណគោតមសម្តែងនោះសោតក៏មិនបាននាំទៅដើម្បីការអស់ទុក្ខដោយប្រពៃ ដល់អ្នកបដិបត្តិតាម ។ កាលនោះ ព្រះសារីបុត្តត្ថេរត្រាច់បិណ្ឌបាត បានឮសុនក្ខត្តពោលទោសរឿយៗមក ត្រឡប់អំពីបិណ្ឌបាតហើយ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្រ សុនក្ខត្ត ជាអ្នកច្រើនដោយសេចក្តីក្រោធ ជាមោឃបុរស ពោលយ៉ាងនេះ ដោយអំណាចសេចក្តីក្រោធប៉ុណ្ណោះ ពោលថា ធម៌នោះ មិនបាននាំទៅដើម្បីការអស់ទុក្ខដោយប្រពៃ ដល់អ្នក

បដិបត្តិតាមនោះឡើយ ដូច្នេះ ដោយអំណាចនៃសេចក្តីក្រោធច្រើន ព្រោះហេតុដែលខ្លួនមិនដឹងពិត ទើបពោលទោសតថាគតសព្វកាល សុនក្ខត្តជាមោឃបុរស ទើបមិនដឹងគុណរបស់តថាគត ម្នាលសារីបុត្រ គុណវិសេសដែលឈ្មោះថា អភិញ្ញា ៦ របស់តថាគតក៏មាន សេចក្តីនេះជាឧត្តរិមនុស្សធម្មរបស់តថាគតដូចគ្នា ពល ១០ ក៏មាន វេសារជ្ជញ្ញាណ ៤ ក៏មាន ញាណដែលកំណត់ដឹងកំណើត ៤ ក៏មាន ញាណដែលកំណត់ដឹងគតិទាំង ៥ ក៏មាន សេចក្តីនេះ ក៏ជាឧត្តរិមនុស្សធម្មរបស់តថាគតដូចគ្នា បុគ្គលណាពោលថា តថាគត ជាអ្នកដល់ព្រមដោយឧត្តរិមនុស្សធម៌ត្រឹមប៉ុណ្ណេះ យ៉ាងនេះថា ឧត្តរិមនុស្សធម៌របស់ព្រះសមណគោតមមិនមានទេ បុគ្គលនោះ មិនលះបង់នូវពាក្យនោះ មិនលះនូវការគិតនោះ មិនដកការយល់ឃើញនោះ រមែងត្រូវកប់ក្នុងនរក ដូចបុគ្គលចាប់យកមកកប់ ដូច្នោះ កាលត្រាស់គុណនៃឧត្តរិមនុស្សធម៌ ដែលមានក្នុងព្រះអង្គយ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលសារីបុត្រ បានឮថា សុនក្ខត្តជ្រះថ្លាក្នុងមិច្ឆាតបៈ ដោយកិរិយានៃកម្មដែលបុគ្គលធ្វើបានលំបាកនៃកោរក្ខត្តិយៈ កាលកំពុងជ្រះថ្លា ក៏មិនសមគួរជ្រះថ្លាក្នុងតថាគតនោះឯង ពិតហើយ ក្នុងទីបំផុតនៃកប្បទី ៩១ បន្ទាប់អំពីកប្បនេះ តថាគតមើលមិនឃើញមិច្ឆាតបៈរបស់លទ្ធិខាងក្រៅ ដើម្បីនឹងដឹងថា សារៈក្នុងតបៈនោះមានពិតឬទេ បំពេញព្រហ្មចរិយៈ ដែលប្រកបដោយអង្គ ៤ ហើយពោលបានថា ជាអ្នកតបៈ ជាអ្នកតបៈដ៏កំពូល ជាអ្នកសៅហ្មង ជាអ្នកសៅហ្មងដ៏កំពូល ជាអ្នកគួរខ្ពើស ជាអ្នកគួរខ្ពើសដ៏កំពូល ជាអ្នកស្ងាត់

ជាអ្នកស្ងាត់ដ៏កំពូល ដូច្នេះ កាលព្រះថេរៈទូលអារាធនា ទើបទ្រង់នាំអតីត-និទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល រាប់អំពីកប្បនេះទៅ ៩១ កប្ប ព្រះពោធិសត្វត្រិះរិះថា អាត្មាអញនឹងសាកល្បងតបៈរបស់ពួកពាហិរៈមើល ទើបបួសជាអាជីវក មិនស្លៀកសំពត់ប្រឡាក់ដោយធូលី ជាអ្នកស្ងាត់ស្ងៀមនៅតែម្នាក់ឯង ឃើញពួកមនុស្សហើយ ត្រូវរត់គេច ដូចម្រឹគមានមហាវិកត្តិជាភោជន ជាអ្នកបរិភោគអាចម៍នៃកូនគោជាដើម នៅដោយការមិនប្រមាទ ទើបនៅក្នុងព្រៃ-ជាច់ស្រយាលមួយកន្លែងក្នុងដងព្រៃ កាលនៅក្នុងទីនោះ ក្នុងពេលសន្សើមធ្លាក់ក្នុងពេលយប់ដែលរងាខ្លាំង ចេញអំពីដងព្រៃនៅកណ្តាលវាល ក្នុងពេលព្រះអាទិត្យរះឡើង ក៏ត្រឡប់ចូលដងព្រៃធ្វើឲ្យខ្លួនជោកដោយតំណក់ទឹកសន្សើមដែលហូរអំពីដងព្រៃក្នុងវេលាថ្ងៃ ដូចធ្វើខ្លួនឲ្យសើមដោយទឹកសន្សើមក្នុងទីវាលនាពេលរាត្រី ដូច្នោះ សោយទុក្ខអំពីការរងា អស់ពេលថ្ងៃ និងពេលយប់យ៉ាងនោះ ។ ម្យ៉ាងទៀត ខាងចុងនៃរដូវក្តៅ ពេលថ្ងៃនៅទីវាល ពេលយប់ចូលកាន់ដងព្រៃ ជួបនូវកម្តៅក្នុងដងព្រៃ ដែលប្រាសចាកខ្យល់ក្នុងពេលរាត្រី ដូចជួបនូវការក្តៅព្រោះកម្តៅថ្ងៃ ក្នុងកណ្តាលវាល នាពេលថ្ងៃ ដូច្នោះ ។ តំណក់ញើសហូរចេញអំពីសរីរៈ ។ គ្រានោះ គាថាដែលមិនធ្លាប់បានឮមកអំពីមុន បានប្រាកដជាក់ច្បាស់ថា

អាត្មាអញ ក្តៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង
ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់

ខ្វាយក្នុងការស្វែងរក ( នូវព្រហ្មចរិយធម៌ ) ប្រតិបត្តិដើម្បីមោនៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោតត្តោ** សេចក្ដីថា តថាគត ក្ដៅក្រហាយ ដោយការក្ដៅក្រហាយអំពីព្រះអាទិត្យ ។

បទថា **សោសីតោ** សេចក្ដីថា តថាគតត្រជាក់ណាស់ គឺជោកដោយទឹកសន្សើម ។

បទថា **ឯកោ ភឹសនកេ វនេ** នេះ លោកសម្ដែងសេចក្ដីថា តថាគតនៅម្នាក់ឯង មិនមានសម្លាញ់ ក្នុងព្រៃគួរស្បើម ដែលធ្វើឲ្យបុគ្គលចូលទៅហើយ ព្រឺរោម ព្រឺស្បែក ។

បទថា **នគ្គោ ន ចគ្គិមាសីនោ** នេះ លោកសម្ដែងថា តថាគតជាមនុស្សអាក្រាតផង មិនបានអាំងភ្លើងផង សូម្បីត្រូវរងាបៀតបៀន ក៏មិនបានអាស្រ័យសំពត់ដណ្ដប់ជាដើម និងមិនបានអាំងភ្លើងទៀតផង ។

បទថា **ឯសនាបសុតោ** នេះ លោកសម្ដែងថា ក្នុងអព្រហ្មចរិយៈ ក៏សំដៅយកថា ជាព្រហ្មចរិយៈក្នុងការស្វែងរកព្រហ្មចរិយៈនោះ ជាអ្នកខ្វល់ខ្វាយ ព្យាយាម គឺមានការព្យាយាមយ៉ាងតឹងរ៉ឹងយ៉ាងនេះថា សេចក្ដីនេះ ជាព្រហ្មចរិយៈពិត ការស្វះស្វែង និងការស្វែងរកជាឧបាយនៃព្រហ្មលោក ។

បទថា **មុនិ** នេះ លោកសម្ដែងថា បានជាបុគ្គលដែលសត្វលោកសរសើរយ៉ាងនេះថា បុគ្គលនេះបដិបត្តិដើម្បីញាណជាគ្រឿងដឹង ជាមុនី ។

ព្រះពោធិសត្វប្រព្រឹត្តព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ យ៉ាងនេះ សម្រឹងឃើញនិមិត្តនរកប្រាកដច្បាស់ឡើងក្នុងវេលាទៀបក្ស័ ក៏ដឹងថា ការសមាទានវត្តនេះ ឥតប្រយោជន៍ ទើបទម្លាយលទ្ធិនោះចោលក្នុងខណៈនោះឯង ត្រឡប់មកសមាទានសម្មាទិដ្ឋិ កើតក្នុងទេវលោកហើយ ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អាជីវកក្នុងសម័យនោះ គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា លោមហំសជាតក ចប់**

# សុត្តន្តបិដក

## មហាសុទស្សនជាតក

[ ៩៥ ] ( ព្រះពោធិសត្វពោលថា ) សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើង និងសូន្យទៅជាធម្មតា ( ព្រោះ ) កើតឡើងហើយ តែងរលត់ទៅវិញ ការរម្ងាប់សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្ដីសុខ ។

មហាសុទស្សនជាតកទី ៥ ចប់

# អដ្ឋកថា

## មហាសុទស្សនជាតក

[ ៩៥ ] ព្រះសាស្តា កាលផ្ទំលើព្រះទែនបរិនិព្វាន ទ្រង់ប្រារព្ធពាក្យរបស់ព្រះអានន្ទត្ថេរដែលពោលថា សូមព្រះមានព្រះភាគ ទ្រង់កុំបរិនិព្វានក្នុងនគរតូចៗ នេះឡើយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អនិច្ចា វត សង្ខារា** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលព្រះតថាគតគង់នៅក្នុងវត្តជេតពនមហាវិហារ ព្រះសារីបុត្របរិនិព្វានហើយ ក្នុងបន្ទប់ដែលលោកប្រសូត ក្នុងស្រុកនាលកៈ លុះដល់ថ្ងៃពេញបូណ៌មីខែកត្តិក ព្រះមហាមោគ្គល្លានបរិនិព្វានក្នុងថ្ងៃអមាវសី ក្នុងកាឡបក្ខនៃខែកត្តិកនោះឯង ។ ព្រះសាស្តាទ្រង់ត្រិះរិះថា កាលគូអគ្គសាវក បរិនិព្វានហើយយ៉ាងនេះ តថាគតក៏នឹងបរិនិព្វានក្នុងនគរកុសិនារា ដូច្នេះហើយ ទ្រង់ចារិកទៅដោយលំដាប់ក្នុងនគរនោះ ទ្រង់ផ្ទំដោយអនុដ្ឋានសេយ្យា លើព្រះទែន ដាក់ព្រះសីសៈទៅទិសឧត្តរ ចន្លោះដើមរាំងទាំងគូ ។ គ្រានោះ ព្រះអានន្ទត្ថេរទូលអារាធនាព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់កុំបរិ-និព្វានក្នុងនគរកុសិនារានេះ ដែលជានគរតូច នគរទួល ជាសាខានគរឡើយ បពិត្រព្រះអង្គដ៏ចម្រើន នគរធំៗ ឯទៀតក៏មាន ដូចជានគរចម្បា នគររាជគ្រឹះ ជាដើម ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលថា នគរនេះ ជានគរតូច នគរទួល ជាសាខានគរយ៉ាងនេះឡើយ ។ ម្នាលអានន្ទ កាលពីព្រេងនាយមក មានព្រះរាជាព្រះនាមមហាសុទស្សនៈ ជាក្សត្របានមុទ្ធា-ភិសេក ( ឥស្សរលើផែនដី ) មានមហាសមុទ្រទាំង ៤ ជាទីបំផុត ព្រះអង្គ

ជាស្តេចឈ្មោះសង្គ្រាម ទ្រង់មានជនបទដល់នូវការមាំមួន មានកំពែងព័ទ្ធជុំវិញ ១២ យោជន៍ ជាមហានគរ កាលព្រះថេរៈទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈ គឺមហាសុទស្សនសូត្រដូចតទៅ

ក្នុងសម័យនោះ កាលព្រះនាងសុភទ្ទាទេវី ទតឃើញព្រះបាទមហាសុទស្សនៈយាងចុះអំពីប្រាសាទសុធម្មា ទ្រង់ផ្ទំដោយអនុដ្ឋានសេយ្យា ដោយព្រះបង្អៀងស្តាំ លើព្រះទែនដ៏សមគួរ ដែលសម្រេចដោយកែវ ៧ ប្រការ ដែលរាជបុរសរៀបចំក្នុងព្រៃត្នោតមិនឆ្ងាយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព នគរ ៨៤០០០ មានរាជធានីកុសាវតីជាប្រមុខនេះ ជារបស់ព្រះអង្គ សូមទ្រង់ពេញព្រះហឫទ័យក្នុងនគរទាំងនេះចុះ ។ ព្រះបាទសុទស្សនៈត្រាស់ថា នែទេវី នាងកុំត្រាស់យ៉ាងនេះឡើយ ចូរនាងជាស់តឿនយើងយ៉ាងនេះថា សូមព្រះអង្គទ្រង់កម្ចាត់ការពេញចិត្តក្នុងនគរទាំងនេះចុះ ទ្រង់កុំសម្ងំឡើយ ។ ព្រះទេវីទូលសួរថា ព្រោះហេតុអ្វី មហាបពិត្រ ព្រះរាជាត្រាស់ថា យើងនឹងត្រូវសោយទិវង្គតក្នុងថ្ងៃនេះ ។ វេលានោះ ព្រះទេវីទ្រង់ព្រះកន្សែងជូតនូវទឹកភ្នែក ត្រាស់ពាក្យយ៉ាងនោះ នឹងព្រះបាទមហាសុទស្សនៈដោយលំបាក កាលព្រះនាងទ្រង់ព្រះកន្សែង ស្ត្រីទាំងឡាយ ៨៤០០០ ដ៏សេសក៏នាំគ្នាទ្រហោយំ ក្នុងពួកអមាត្យជាដើមសូម្បីតែម្នាក់ ក៏មិនអាចអត់សង្កត់នូវសេចក្តីសោកបាន នាំគ្នាស្រែកយំរំពង ។ ព្រះពោធិសត្វឃាត់មនុស្សទាំងអស់ថា អ្នកទាំងឡាយកុំយំឡើយ ពួកអ្នកកុំធ្វើសំឡេងរំខានយើងឡើយ ។ ទ្រង់ត្រាស់ជាស់តឿនព្រះទេវីថា នែទេវី សូមនាងកុំខ្សឹកខ្សួល កុំសោយសោក

ថ្មីឡើយ ព្រោះសង្ខារដែលឈ្មោះថា ទៀង សូម្បីប៉ុនគ្រាប់ល្ង មិនមានទេ វត្ថុគ្រប់យ៉ាងមិនទៀង មានការរលត់ជាធម្មតា កាលទ្រង់ប្រៀនប្រដៅព្រះទេវី ត្រាស់ព្រះគាថានេះថា

សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើង និងសូន្យទៅជា
ធម្មតា ( ព្រោះ ) កើតឡើងហើយ តែងរលត់ទៅវិញ ការរម្ងាប់
សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនិច្ចា វត សង្ខារា** សេចក្តីថា នែសុភទ្ទាទេវី សង្ខារទាំងឡាយ មានខន្ធ និងអាយតនៈជាដើម ដែលបច្ច័យមានប្រមាណប៉ុនណា ប្រជុំឲ្យកើតឡើង សង្ខារទាំងអស់នោះ ឈ្មោះថា មិនទៀងទាំងអស់ ព្រោះបណ្តាសង្ខារទាំងនេះ រូបមិនទៀង ។បេ។ វិញ្ញាណមិនទៀង ចក្ខុមិនទៀង ។បេ។ ធម៌ទាំងឡាយមិនទៀង សរុបសេចក្តីថា វត្ថុដែលញ៉ាំងសេចក្តីត្រេកអរឲ្យកើត ទាំងដែលមានវិញ្ញាណ និងមិនមានវិញ្ញាណណាមួយ វត្ថុទាំងអស់នោះ មិនទៀងទាំងអស់ ដោយហេតុនេះ ចូរកំណត់យកថា សង្ខារទាំងឡាយមិនទៀងហ្ន៎ ព្រោះហេតុអ្វី ព្រោះកើតឡើង និងកន្លងទៅ គឺព្រោះសង្ខារទាំងអស់ មានការកើតឡើងជាធម្មតាផង មានការវិនាសជាធម្មតាផង សុទ្ធតែមានការកើតឡើង និងការបែកធ្លាយជាសភាវៈទាំងអស់ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ជារបស់មិនទៀង ព្រោះមិនទៀង ទើបកើតហើយ ក៏រលត់ គឺកើតហើយ ដល់នូវការតាំងនៅមិនបាន ក៏ត្រូវរលត់ទាំងអស់ ពិតហើយ សង្ខារទាំងនេះ គ្រប់យ៉ាង កំពុងកើត ឈ្មោះ

ថា រមែងកើតឡើង កំពុងបែកធ្លាយ ឈ្មោះថា រលត់ កាលការកើតឡើងនៃសង្ខារទាំងនោះមាន ឈ្មោះថា ឋិតិក៏មាន កាលឋិតិមាន ភង្គៈក៏មាន ព្រោះកាលសង្ខារមិនកើតឡើង ឋិតិក៏មិនមាន ឋិតិក្ខណៈប្រាកដហើយ ឈ្មោះថា ការមិនបែកធ្លាយក៏មិនមាន ព្រោះដូច្នោះ សង្ខារទាំងអស់ ដល់ខណៈទាំង ៣ ហើយ ក៏រមែងរលត់ទៅ ក្នុងខណៈនោះៗ ឯង ព្រោះហេតុនោះ ទើបសង្ខារទាំងអស់ ជារបស់មិនទៀង ប្រព្រឹត្តទៅមួយជួរខណៈ ជារបស់ផ្លាស់ប្តូរ មិនស្ថិតស្ថេរ ស្អុយរលួយ ញាប់ញ័រ រង្គោះរង្គើ តាំងនៅមិនបានយូរ ប្រែប្រួល ជារបស់មួងម្កាល មិនមានសារៈ ជារបស់បោកបញ្ឆោតដូចថ្ងៃបណ្តើរកូន និងពពុះទឹក ដោយអត្ថថា ជារបស់មួយជួរខណៈ ។

ម្នាលសុភទ្ទាទេវី ព្រោះហេតុអ្វី ទើបនាងញុំាងសុខសញ្ញាឲ្យកើតឡើងក្នុងសង្ខារទាំងឡាយ នាងកុំកាន់យកយ៉ាងនោះឡើយ ។

បទថា **តេសំ វូបសមោ សុខោ** សេចក្តីថា ម្នាលនាងសុភទ្ទាទេវី សភាវៈដែលឈ្មោះថា រម្ងាប់បង់នូវសង្ខារទាំងនោះ ព្រោះរម្ងត់បាននូវវដ្ដៈទាំងមូល បានដល់ ព្រះនិព្វាន ហើយព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា សុខដោយចំណែកមួយ ធម្មជាតដទៃ ដែលឈ្មោះថា ជាសុខមិនមានឡើយ ដូច្នេះ ។

ព្រះបាទមហាសុទស្សនៈ ទ្រង់កាន់យកកំពូលនៃទេសនា ដោយអមតមហានិព្វាន ដោយប្រការដូច្នេះហើយ ទ្រង់ប្រទានឱវាទដល់មហាជនដ៏សេស

ថា ចូរអ្នកទាំងឡាយឲ្យទាន ចូររក្សាសីល ចូរធ្វើឧបោសថកម្ម ដូច្នេះហើយ ជាអ្នកមានទេវលោកជាទីទៅខាងមុខ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សុភទ្ទាទេវីក្នុងកាលនោះ បានមកជារាហុលមាតា ក្នុងកាលឥឡូវនេះ បរិនាយកកែវក្នុងកាលនោះ បានមកជារាហុល បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯព្រះបាទមហាសុទស្សនៈ ក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

**អដ្ឋកថា មហាសុទស្សនជាតក ចប់**

# សុត្តន្តបិដក

## តេលបត្តជាតក

[ ៩៦ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេងដែលពេញត្រឹមកណ្តាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ ( ព្រះយោគាវចរ ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន ( ដោយសតិ ) យ៉ាងនោះដែរ ។

**តេលបត្តជាតកទី ៦ ចប់**

# អដ្ឋកថា

## តេលបត្តជាតក

[ ៩៦ ] ព្រះសាស្តា កាលទ្រង់អាស្រ័យនិគមឈ្មោះសេតកៈ[១] ក្នុងសុម្ភរដ្ឋ គង់នៅក្នុងដងព្រៃមួយកន្លែង ទ្រង់ប្រារព្ធជនបទកល្យាណីសូត្រ ( ទុតិយសេតកសូត្រ ) ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សមតិត្តិកំ អនវសេសកំ** ដូច្នេះជាដើម ។

ពិតហើយ ក្នុងកាលនោះ ព្រះសាស្តាត្រាស់ជនបទកល្យាណីសូត្រ មួយអន្លើដោយអត្ថ និងព្យញ្ជនៈថា ម្នាលភិក្ខុទាំងឡាយ បានឮថា ស្រីស្អាតក្នុងជនបទ ស្រីស្អាតក្នុងជនបទ ដូច្នេះ ពួកមហាជនគប្បីប្រជុំគ្នាក្រៃលែង បានឮថា ស្រីស្អាតក្នុងជនបទនោះ ជាអ្នកជំនាញដ៏កំពូលក្នុងការរាំ ជាអ្នកជំនាញដ៏កំពូលក្នុងការច្រៀង ។ ស្រីស្អាតក្នុងជនបទ រាំ និងច្រៀង ពួកមហាជនប្រជុំគ្នាយ៉ាងណែនណាន់តាន់តាប់ កាលនោះ បុរសអ្នកតាំងជីវិតប្រាថ្នានូវសេចក្ដីសុខ រង្កៀសនូវសេចក្ដីទុក្ខគប្បីមក ។ ព្រះរាជាគប្បីត្រាស់នឹងបុរសនោះ យ៉ាងនេះថា នែបុរសដ៏ចម្រើន ភាជនប្រេងដ៏ពេញនេះ ចូរអ្នកនាំទៅក្នុងរវាងពួកមហាជន និងនាងជនបទកល្យាណី និងមានមនុស្សផ្ទាជាវដើរជាប់ពីក្រោយ បើឯងធ្វើប្រេងនោះឲ្យកំពប់តែបន្តិចក្នុងទីណា អញនឹងឲ្យបុរសនោះកាត់ក្បាលឯង ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់សេចក្ដីនោះដូចម្ដេច បុរសនោះគប្បីមិនយកចិត្តទុកដាក់ក្នុងថាសប្រេង ហើយមកប្រមាទក្នុងអារម្មណ៍ខាងក្រៅបានឬ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ

១- ក្នុងទីខ្លះជាសេទកៈ ។

ដ៏ចម្រើន មិនគប្បីយ៉ាងនោះឡើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះ តថាគតពោលដើម្បីឲ្យពួកអ្នកជ្រាបអត្ថ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះក្នុងរឿងនេះថា ភាជនប្រេងដែលពេញស្មើកណ្តាប់មាត់ ជាឈ្មោះនៃសតិ ដែលប្រព្រឹត្តទៅក្នុងកាយ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ពួកអ្នកគប្បីសិក្សាក្នុងសេចក្តីនោះ យ៉ាងនេះថា សតិទៅហើយក្នុងកាយ ជាបទដែលពួកអ្នកទាំងឡាយ ត្រូវធ្វើឲ្យមាន ឲ្យកើតទាល់តែបាន ផ្តើមហើយដោយល្អ ឲ្យទាល់តែបាន ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីសិក្សាយ៉ាងនេះឯង ។

ក្នុងព្រះសូត្រនោះ មានពាក្យអធិប្បាយសង្ខេបៗ ដូច្នេះ ដែលឈ្មោះថា ជនបទកល្យាណីនោះ បានដល់ ស្រីស្អាតក្នុងជនបទ គឺជាស្រីស្អាតក្រៃលែង ប្រាសចាកទោសនៃសរីរៈ ៦ ប្រការ ដល់ព្រមដោយលម្អ ៥ ព្រោះជនបទកល្យាណីនោះ ជាស្រីមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ពណ៌សម្បុរក្រៃលែងជាងពណ៌សម្បុរមនុស្ស តែមិនដល់ពណ៌សម្បុរទេវតា ដូច្នោះ ទើបបានឈ្មោះថា វៀរចាកទោសនៃសរីរៈ ៦ ប្រការ និងព្រោះប្រកបដោយលម្អ ៥ គឺលម្អស្បែក លម្អសាច់ លម្អសរសៃ លម្អឆ្អឹង និងលម្អវ័យ ដូច្នោះ ទើបឈ្មោះថា ដល់ព្រមហើយដោយលម្អ ៥ ប្រការ ។ ពិតហើយ បញ្ចពិធកល្យាណីនោះ មិនចាំបាច់បន្ថែមនូវពន្លឺដទៃឡើយ រមែងធ្វើឲ្យពន្លឺភ្លឺបានក្នុងទី ១២ ហត្ថ ដោយពន្លឺនៃរាងកាយរបស់ខ្លួន ពណ៌សម្បុរស្មើដោយផ្កាប្រយង្គុ ឬស្មើដោយមាស នេះជាលម្អ

សម្បុរស្បែក ម្យ៉ាងទៀត ដៃ ឬជើងរបស់នាងទាំង ៤ និងបបូរមាត់ ដូចជាជ្រលក់ដោយទឹកល័ខ ដូចគ្នានឹងកែវប្រពាលក្រហម និងសំពត់កម្ពលពណ៌ក្រហម នេះជាលម្អសាច់របស់នាង ។ បន្ទះក្រចកទាំង ២០ ក្នុងទីដែលមិនផុតចាកសាច់ ដូចជ្រលក់ដោយទឹកល័ខ ក្នុងទីដែលផុតចាកសាច់ ដូចគ្នានឹងផ្កាទឹកដោះ នេះជាលម្អសរសៃរបស់នាង ធ្មេញទាំង ៣២ រាប ស្មើជិតល្អដូចជួរនៃពេជ្រដែលច្នៃ ហើយតម្រៀប នេះជាលម្អឆ្អឹងរបស់នាង ម្យ៉ាងទៀតទោះបីនាងមានអាយុ ១២០ ក៏មើលទៅនៅតែស្រស់ស្អាត ដូចអាយុ ១៦ ឆ្នាំ ស្អាមជ្រីវជ្រួញ មិនប្រាកដ សក់មិនស្កូវ នេះជាលម្អវ័យរបស់នាង ។

ក្នុងបទថា **បរមចាសាវិនី** អធិប្បាយថា មានការប៉ិនប្រសប់ ឈ្មោះថា **បសវោ** អធិប្បាយថា ការប្រព្រឹត្តទៅ ។ **ចាសាវោ** គឺ **បសវោ** ។ កាលប្រព្រឹត្តទៅដ៏កំពូល ឈ្មោះថា **បរមចាសាវិនី** ។ ការជំនាញដ៏កំពូល មានដល់ស្រីនោះ ព្រោះហេតុនោះ ទើបស្រីនោះ ឈ្មោះថា **បរមចាសាវិនី** ។ លោកអធិប្បាយថា មានការស្ទាត់ជំនាញដ៏ឧត្តម គឺមានលីលាដ៏ប្រសើរ ក្នុងការរាំ ឬក្នុងការច្រៀង គឺរាំបានយ៉ាងទន់ និងច្រៀងបានយ៉ាងពីរោះ ។

បទថា **អថ បុរិសោ អាគច្ឆេយ្យ** បានដល់ បុរសមិនបានមកដោយការពេញចិត្តរបស់ខ្លួន ។ ក្នុងសេចក្តីនេះ លោកអធិប្បាយថា កាលជនបទកល្យាណីនោះ កំពុងរាំក្នុងកណ្តាលមហាជន នឹងមានសំឡេងសាធុការថា ស្អាតពិត ល្អពិត មួយអន្ទើដោយសំឡេងផ្ទាត់ម្រាមដៃ ទាំងការគ្រវីសំពត់កំពុងប្រព្រឹត្តទៅយ៉ាងកក្រើក ព្រះរាជាទ្រង់ជ្រាបព្រឹត្តិកម្មនោះ ទ្រង់ត្រាស់ឲ្យ

ហៅអ្នកទោសម្នាក់ចេញមកអំពីគុក ដោះឃ្នាងចេញ ប្រទានថាសប្រេង មានប្រេងពេញប្រៀបស្មើកណ្ដាប់មាត់ ដាក់ក្នុងដៃបុរសនោះ ឲ្យកាន់យ៉ាងមាំ ដោយដៃទាំង ២ ទ្រង់បង្គាប់បុរសដែលកាន់ដាវម្នាក់ថា ចូរនាំអ្នកទោសនេះ ទៅកាន់លានមហោស្រពរបស់នាងជនបទកល្យាណី បើបុរសនេះមានសេចក្ដី ប្រមាទ ធ្វើឲ្យកំពប់តំណក់ប្រេងសូម្បីមួយតំណក់ក្នុងទីណា ចូរកាត់ក្បាល របស់បុរសនេះ ក្នុងទីនោះឯង បុរសនោះងាដាវក្ជង់កអ្នកទោស នាំទៅក្នុង ទីនោះ បុរសនោះត្រូវមរណភ័យគំរាមហើយ មិនដាក់ចិត្តដល់នាង ដោយ អំណាចសេចក្ដីប្រមាទឡើយ មិនបើកភ្នែកមើលនាងជនបទកល្យាណីនោះ សូម្បីតែម្ដង ព្រោះត្រូវការជីវិត នេះជារឿងធ្លាប់មានមកហើយយ៉ាងនេះ រឿងនេះគប្បីជ្រាបថា ព្រះសាស្ដាត្រាស់ហើយ ដោយអំណាចនៃគោលក្នុង ព្រះសូត្រ ក្នុងបទថា **ឧបមា ខោ មយ្ហាយំ** នេះ ទ្រង់ធ្វើការឧបមាប្រៀប កាយគតាសតិ និងថាសប្រេង[១] ។

ក្នុងរឿងនេះ កម្ម គប្បីឃើញដូចព្រះរាជា កិលេសគប្បីឃើញដូចដាវ មារគប្បីឃើញដូចបុរសងាដាវ យោគាវចរអ្នកសម្លឹងកាយគតាសតិ ដូច បុរសដែលកាន់ថាសប្រេង ។

ព្រះមានព្រះភាគ ទ្រង់នាំព្រះសូត្រនេះមក ទ្រង់សម្ដែងថា ភិក្ខុប្រាថ្នា ចម្រើនកាយគតាសតិ មិនត្រូវបណ្ដែតបណ្ដោយសតិ ជាអ្នកមិនប្រមាទ

---

១- បទដែលលោកលើកមកពន្យល់ខាងលើនេះ មានក្នុងសំយុត្តនិកាយ មហាវារវគ្គ ឯណោះ ។

ចម្រើនកាយគតាសតិ ដូចបុរសកាន់កាជន៍ប្រេងនោះ ដោយប្រការដូច្នេះ ។ ភិក្ខុទាំងឡាយ កាលស្តាប់ព្រះសូត្រនេះ និងអធិប្បាយហើយ នាំគ្នាក្រាបទូលយ៉ាងនេះថា ការដែលបុរសនោះ មិនមើលនាងជនបទកល្យាណី ផ្គងកាជន៍ប្រេងដើរទៅ ធ្វើកម្ម ដែលធ្វើបានដោយលំបាក ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មដែលបុរសនោះធ្វើហើយ មិនមែនជាកម្មធ្វើបានលំបាកទេ នុ៎ះជាកម្មធ្វើបានដោយងាយពិត ព្រោះហេតុអ្វី ព្រោះមានបុគ្គលងាជាវនៅចាំសម្លុត និងគំរាមរហូតទៅ តែការដែលបណ្ឌិតទាំងឡាយក្នុងកាលមុន មិនបណ្តែតបណ្តោយសតិ ព្រោះសេចក្តីប្រមាទ មិនទម្លាយឥន្ទ្រិយ មិនសម្លឹងមើលនូវរូបជាទិព្វ ដែលកាឡាខ្ជួនល្អហើយ ដើរទៅ រហូតបានគ្រងរាជសម្បត្តិ នេះទើបជាការធ្វើបានលំបាក កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាឱរសពៅបង្អស់ ក្នុងបណ្តាឱរស ១០០ អង្គនៃព្រះរាជានោះ ដល់នូវភាពជាអ្នកដឹងក្តីដោយលំដាប់ ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធច្រើនអង្គ ឆាន់ក្នុងព្រះរាជវាំង ព្រះពោធិសត្វធ្វើនាទីជាវេយ្យាវច្ចៈដល់ព្រះបច្ចេកពុទ្ធទាំងនោះ ថ្ងៃមួយ ទ្រង់ត្រិះរិះថា បងប្រុសរបស់អាត្មាអញមានច្រើន អញនឹងបានរាជសម្បត្តិបន្តវង្ស ក្នុងព្រះនគរនេះឬហ្ន៎ កាលទ្រង់មានបរិវិតក្កថា ត្រូវសួរព្រះបច្ចេកពុទ្ធសាកមើល ទើបដឹងពិត ។ ក្នុងថ្ងៃទី ២ កាលព្រះបច្ចេកពុទ្ធទាំងឡាយ នាំគ្នាមកហើយ ទ្រង់កាន់យកធម្មក្រក

ត្រង់ទឹកសម្រាប់ផឹក លាងជើង លាបប្រេង ក្នុងកាលដែលព្រះបច្ចេកពុទ្ធ ទាំងនោះធាន់របស់ទំពាក្នុងចន្លោះ ទើបថ្វាយបង្គំ ហើយប្រថាប់គង់នាចំណែក ម្ខាង មានព្រះតម្រាស់សួរសេចក្តីនោះ លុះព្រះបច្ចេកពុទ្ធទាំងនោះប្រាប់ថា នៃកុមារ ទ្រង់មិនបានសោយរាជសម្បត្តិក្នុងនគរនេះទេ តែបន្ទាប់អំពីនគរនេះ ទៅ ក្នុងទីបំផុត ១២០ យោជន៍ ក្នុងគន្ធាររដ្ឋ មានព្រះនគរឈ្មោះតក្កសិលា អ្នកអាចទៅក្នុងព្រះនគរនោះ នឹងត្រូវបានរាជសម្បត្តិក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃ នេះ តែក្នុងរវាងផ្លូវ ក្នុងព្រៃធំមានអន្តរាយ កាលបើវាងព្រៃនោះ នឹងឆ្ងាយ ដល់ ១២០ យោជន៍ បើទៅត្រង់ត្រឹមតែ ៥០ យោជន៍ ផ្លូវនោះជាអមនុស្ស-កន្តារ ពួកយក្ខិនីនាំគ្នានិម្មិតស្រុក និងសាលាក្នុងចន្លោះផ្លូវ រៀបចំទីដេកដ៏មាន តម្លៃ នៅលើពិតាន លម្អដោយផ្កាយមាស បាំងវាំងននដែលជ្រលក់ដោយ ពណ៌ផ្សេងៗ តាក់តែងអត្តភាពដោយអលង្ការដែលជាទិព្វ នាំគ្នាអង្គុយក្នុង សាលាទាំងឡាយ ទាក់យកពួកបុរសអ្នកដើរផ្លូវ ដោយពាក្យសម្តីទន់ភ្លន់ នាំ គ្នាអញ្ជើញថា ពួកលោកទាំងឡាយប្រាកដដូចមនុស្សហត់នឿយ សូមមក អង្គុយលើសាលានេះ ផឹកនូវរបស់ដែលគួរផឹក ហើយសឹមទៅចុះ រួចឲ្យនូវ ទីអង្គុយដល់ជនដែលមកហើយ នាំគ្នាលួងលោមដោយអាកប្បកិរិយាទន់ភ្លន់ របស់ខ្លួន ធ្វើឲ្យធ្លាក់នៅក្នុងអំណាចកិលេស កាលបានធ្វើអជ្ឈាចាររួមនឹងខ្លួន ហើយ នាំគ្នាទំពាស៊ីជនទាំងនោះក្នុងទីនោះឯង ធ្វើឲ្យដល់ការអស់ជីវិត ទាំង ដែលឈាមកំពុងហូរ យក្ខិនីចាំចាប់សត្វដែលមានរូបជាអារម្មណ៍ ដោយរូប សម្រស់របស់ខ្លួននោះឯង អ្នកដែលមានសំឡេងជាអារម្មណ៍ ដោយសំឡេង

ប្រៀងល្អងលោមទន់ផ្អែមនោះឯង អ្នកដែលមានក្លិនជាអារម្មណ៍ ដោយក្លិនទិព្វ អ្នកដែលមានរសជាអារម្មណ៍ ដោយភោជនដែលមានរសផ្សេងៗ ដូចរសទិព្វ អ្នកដែលមានផោដ្ឋព្វៈជាអារម្មណ៍ ដោយទីដេកដូចជាទិព្វ មានកម្រាលពណ៌ក្រហមទាំងសងខាង បើព្រះអង្គមិនទម្លាយឥន្ទ្រិយ ៥ មើលនូវយក្ខិនីទាំងនោះទេ គ្រប់គ្រងសតិបាន ដើរទៅ នឹងបានរាជសម្បត្តិក្នុងនគរនោះក្នុងថ្ងៃទី ៧ ព្រះពោធិសត្វត្រាស់ថា បពិត្រលោកម្ចាស់ រឿងនោះ សូមលើកទុក ខ្ញុំទទួលឱវាទរបស់លោកម្ចាស់ទាំងឡាយហើយ នឹងសម្លឹងមើលពួកយក្ខធ្វើអ្វី ដូច្នេះហើយ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យបម្រើនព្រះបរិត្តទទួលខ្សែចាប់ដោយព្រះបរិត្ត និងអំបោះដោយព្រះបរិត្ត ថ្វាយបង្គំលាព្រះបច្ចេកពុទ្ធ និងព្រះរាជមាតាបិតា យាងទៅកាន់ព្រះរាជវាំង ត្រាស់នឹងមនុស្សរបស់ព្រះអង្គថា ខ្ញុំនឹងទៅគ្រងរាជសម្បត្តិ ក្នុងនគរតក្កសិលា ចូរពួកអ្នកនៅក្នុងទីនេះចុះ កាលនោះ មនុស្សទាំង ៥ ក្រាបទូលព្រះពោធិសត្វថា សូម្បីពួកទូលបង្គំនឹងតាមទ្រង់ទៅ ព្រះពោធិសត្វត្រាស់ថា ពួកអ្នកមិនអាចទៅតាមខ្ញុំបានទេ បានឮថា ក្នុងចន្លោះផ្លូវ មានពួកយក្ខិនីឃ្លាំល្អងលោមពួកមនុស្ស ដែលមានរូបជាអារម្មណ៍ជាដើម ដោយកាមារម្មណ៍ មានរូបជាដើមច្រើនយ៉ាង ច្រើនបែប ហើយចាប់ស៊ីជាអាហារ អន្តរាយធំកន្លង ខ្ញុំត្រៀមខ្លួនហើយ ទើបទៅ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលពួកទូលបង្គំទៅជាមួយព្រះអង្គ នឹងសម្លឹងមើលរូបជាទីស្រឡាញ់ដើម្បីខ្លួនធ្វើអ្វី ពួកទូលបង្គំនឹងទៅក្នុងទីនោះបានដូចគ្នា ។ ព្រះពោធិសត្វត្រាស់ថា បើដូច្នោះ

ចូរពួកអ្នកជាអ្នកមិនប្រមាទចុះ ហើយនាំពួកមនុស្សទាំង ៥ នាក់នោះចេញទៅ ។

យក្ខិនីទាំគ្នានិម្មិតស្រុកជាដើម អង្គុយរង់ចាំហើយ ។ ក្នុងមនុស្សទាំងនោះ អ្នកដែលពេញចិត្តរូប សម្លឹងមើលយក្ខិនីនោះហើយ មានចិត្តជាប់ជំពាក់ក្នុងរូបារម្មណ៍ ក៏មានចិត្តរារែកបន្តិច ព្រះពោធិសត្វត្រាស់ថា នែអ្នក ហេតុអ្វីទើបអ្នករារែក ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ជើងរបស់ទូលបង្គំឈឺចាប់ ទូលបង្គំអង្គុយសម្រាកក្នុងសាលាបន្តិចហើយ នឹងទៅតាមព្រះអង្គ ព្រះពោធិសត្វត្រាស់ថា នែអ្នក នុ៎ះជាពួកយក្ខិនី អ្នកកុំប្រាថ្នាឡើយ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទោះជាអ្វីក៏ដោយ ទូលបង្គំមិនញាប់ញ័រ ទើបព្រះពោធិសត្វត្រាស់ថា បើដូច្នោះ ចូរអ្នកដឹងឯងចុះ ហើយនាំបុរស ៤ នាក់ចេញដំណើរទៅ ។ អ្នកដែលគាប់ចិត្តក្នុងរូប បានទៅក្នុងសម្នាក់របស់ពួកយក្ខិនី កាលបានធ្វើអជ្ឈាចារជាមួយខ្ទួនហើយ ក៏ធ្វើឲ្យអស់ជីវិតក្នុងទីនោះឯង ហើយទៅស្កាត់ខាងមុខ និម្មិតសាលាដទៃ អង្គុយលេងតន្ត្រី ច្រៀងនូវចម្រៀងផ្សេងៗ ក្នុងមនុស្សទាំងនោះ បុរសដែលគាប់ចិត្តក្នុងសំឡេងក៏រារែក ត្រូវពួកយក្ខស៊ីដូចគ្នា ។ ហើយនាំគ្នាទៅស្កាត់ខាងមុខ រៀបចំភោជនដូចជាទិព្វ មានរសច្រើនប្រភេទ ពេញភាជនៈ អង្គុយលក់បាយ និងម្ហូប ។ ទៅដល់ទីនោះ ជនដែលជាប់ចិត្តនឹងរស ក៏រារែក ពួកយក្ខិនីក៏ស៊ីជននោះហើយទៅស្កាត់ខាងមុខ រៀបចំទីដេកដូចជាទិព្វ អង្គុយរង់ចាំហើយ ដល់ត្រង់នោះ បុរសដែលគាប់ចិត្តក្នុងផោដ្ឋព្វៈក៏រារែក ត្រូវពួកយក្ខទំពាស៊ីទៀត ។

ព្រះពោធិសត្វសល់ត្រឹមតែមួយអង្គឯងប៉ុណ្ណោះ ។ កាលនោះ យក្ខិនីម្នាក់គិតថា បុរសនោះ មានមន្តពូកែពេក អញនឹងស៊ីឲ្យបាន ហើយសឹមត្រឡប់ ក៏ដើរតាមក្រោយព្រះពោធិសត្វទៅរឿយៗ ដល់មាត់ព្រៃនោះ ពួកជនដែលធ្វើការក្នុងព្រៃជាដើម ក៏សួរយក្ខិនីថា បុរសដែលដើរខាងមុខជាអ្វីនឹងនាង ក៏ឆ្លើយថា ជាប្តីរបស់ខ្ញុំ ពួកមនុស្សទាំងនោះពោលថា នែអ្នកទាំងឡាយ កុមារីនេះទន់ភ្លន់យ៉ាងនេះ គួរតែថ្នមដូចកម្រងផ្កា ពណ៌សម្បុរល្អដូចមាស លះបង់ត្រកូលរបស់ខ្លួនចេញមក ព្រោះសេចក្តីស្រឡាញ់ ដើរតាមមក នែអ្នកហេតុអ្វី ទើបបណ្តោយឲ្យនាងលំបាក មិនដឹកដៃនាងទៅ ព្រះពោធិសត្វត្រាស់ថា នែអ្នកទាំងឡាយ នុ៎ះមិនមែនប្រពន្ធរបស់ខ្ញុំទេ ស្រីនោះ ជាយក្ខិនីមនុស្សរបស់ខ្ញុំ ៥ នាក់ ត្រូវយក្ខិនីនោះស៊ីអស់ហើយ ។ យក្ខិនីពោលថា នែលោកទាំងឡាយ ធម្មតាបុរសក្នុងពេលក្រោធ ក៏ធ្វើប្រពន្ធរបស់ខ្លួនឲ្យជាយក្ខិនីក៏បាន ឲ្យជាប្រេតក៏បាន ។ យក្ខិនីដើរតាមមកការឡាខ្លួនជាស្រីមានគភ៌ជាស្រីកើតកូនម្តង បីបុត្រដើរតាមព្រះពោធិសត្វទៅ មនុស្សដែលឃើញហើយ ក៏នាំគ្នាសួរតាមន័យមុននោះឯង ព្រះពោធិសត្វក៏ត្រាស់យ៉ាងនោះរហូតមក ។ លុះដល់នគរតក្កសិលា យក្ខធ្វើកូនឲ្យអន្តរធាន ដើរតាមព្រះពោធិសត្វតែម្នាក់ឯង ព្រះពោធិសត្វយាងដល់ព្រះនគរហើយ ប្រថាប់អង្គុយក្នុងសាលាមួយកន្លែង សូម្បីយក្ខិនីនោះ មិនអាចចូលទៅបាន ដោយតេជះរបស់ព្រះពោធិសត្វ ក៏និម្មិតរូបស្អាតដូចទេពអប្សរ ឈរត្រង់ទ្វារសាលា ។

សម័យនោះ ព្រះរាជាយាងចេញអំពីនគរតក្កសិលា ទៅកាន់ព្រះរាជ-

ឧទ្យាន ឃើញនាងហើយ ទ្រង់មានចិត្តប្រតិព័ទ្ធត្រាស់ប្រើរាជបុរសថា ទៅសួរមើល ស្រីនេះ មានប្តីហើយឬនៅ ពួករាជបុរសចូលទៅរកនាងយក្ខិនីសួរថា នាងមានប្តីហើយឬ នាងឆ្លើយថា បុរសដែលអង្គុយក្នុងសាលា ជាប្តីរបស់ខ្ញុំ ព្រះពោធិសត្វត្រាស់ថា នាងមិនមែនជាប្រពន្ធរបស់ខ្ញុំទេ ជាយក្ខិនីមនុស្សរបស់ខ្ញុំ ៥ នាក់ ត្រូវយក្ខស៊ីទាំងអស់ ឯយក្ខិនីពោលថា នៃលោកទាំងឡាយ ធម្មតាបុរស ក្នុងពេលខឹង ក៏នឹងពោលតាមគាប់ចិត្តរបស់ខ្លួន ។ រាជបុរសនោះ ក៏ក្រាបទូលពាក្យរបស់មនុស្សទាំង ២ ដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា ធម្មតាភណ្ឌៈមិនមានម្ចាស់ រមែងធ្លាក់ជារបស់ព្រះរាជា ហើយត្រាស់ឲ្យហៅយក្ខិនីមក ឲ្យអង្គុយលើគជធារជាមួយទ្រង់ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ហើយឡើងកាន់ប្រាសាទ ទ្រង់ស្ថាបនាស្រីនោះ ក្នុងតំណែងអគ្គមហេសី ទ្រង់ស្រពស្រង់តែងព្រះកាយរៀបរយ សោយព្រះក្រយាហារពេលល្ងាចហើយ យាងឡើងកាន់ព្រះទែនដ៏មានសិរី យក្ខិនីនោះ បរិភោគអាហារដែលគួរដល់ខ្លួនហើយ តាក់តែងខ្លួនប្រាណ ផ្ទំរួមជាមួយព្រះរាជា លើព្រះទែនដ៏មានសិរី ពេលព្រះរាជាទ្រង់ស្កប់ស្កល់ទៅដោយសេចក្តីសុខ ដោយអំណាចសេចក្តីត្រេកអរ ទ្រង់ផ្ទំហើយ ក៏ប្រែទៅម្ខាង ធ្វើជាយំ កាលព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន ហេតុអ្វី ទើបនាងយំ យក្ខិនីក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ទ្រង់ជួបតាមផ្លូវ ហើយនាំមក ម្យ៉ាងទៀត ក្នុងព្រះរាជវាំងរបស់ព្រះអង្គ មានស្រីជាច្រើន ខ្ញុំម្ចាស់ បើនៅក្នុងក្រុមស្រីដែលរួមបម្រើព្រះបាទ កាលកើតពាក្យពោលឡើងថា អ្នកណាស្គាល់មាតា បិតា កូន ឬ

ជាតិរបស់នាង ព្រះរាជាជួបក្នុងរវាងផ្លូវ ហើយទ្រង់នាំមកដូច្នេះ តើនឹងយកមុខទុកឯណា ត្រូវខ្មាសគេពិត បើទ្រង់ព្រះរាជទានភាពជាធំ និងឲ្យសិទ្ធិក្នុងការបញ្ជាក្នុងដែនទាំងមូលដល់ខ្ញុំម្ចាស់ បុគ្គលណាម្នាក់ មិនអាចមានចិត្តហ៊ានពោលដល់ខ្ញុំម្ចាស់បានទេ ព្រះរាជាទ្រង់ត្រាស់ថា នែនាងដ៏ចម្រើន អ្នកដែនទាំងមូល មិនមែនជាសម្បត្តិរបស់ខ្ញុំឡើយ ខ្ញុំមិនមែនជាម្ចាស់របស់ជនទាំងនោះ តែបើជនណាល្មើសព្រះរាជអាជ្ញា ធ្វើវត្ថុដែលមិនគួរធ្វើ ខ្ញុំជាម្ចាស់របស់អ្នកទាំងនោះប៉ុណ្ណោះ ដោយហេតុនេះ ខ្ញុំមិនអាចឲ្យភាពជាធំ និងអាជ្ញាក្នុងដែនទាំងមូលដល់នាងបានទេ ។ នាងក្រាបទូលថា បើទ្រង់មិនអាចព្រះរាជទានអំណាចក្នុងដែនទាំងមូល ឬក្នុងនគរ សូមទ្រង់ព្រះរាជទានអំណាចលើពួកជនខាងក្នុងព្រះរាជវាំង ដើម្បីឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្ញុំចុះ ។ ព្រះរាជាទ្រង់ជាប់ព្រះហឫទ័យក្នុងផោដ្ឋព្វៈ ដែលដូចជាទិព្វហើយ មិនអាចបដិសេធពាក្យរបស់នាងបាន ទើបត្រាស់ថា នែនាងដ៏ចម្រើន យើងយល់ព្រម យើងប្រគល់អាជ្ញាក្នុងពួកជនខាងក្នុងដល់នាង ចូរនាងគ្រប់គ្រងជនទាំងនោះឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួនចុះ យក្ខិនីទទួលថា សាធុ ព្រះអង្គ ។ លុះព្រះរាជាផ្ទំលក់ស៊ប់ស្ងួន ក៏ទៅកាន់នគរយក្ខ នាំពួកយក្ខមក ញុំាងព្រះរាជារបស់ខ្លួនឲ្យអស់ជីវិត ទំពាស៊ីស្បែក សាច់ និងឈាមរហូតអស់ សល់ត្រឹមតែឆ្អឹង ពួកយក្ខដ៏សេស នាំគ្នាទំពាស៊ីមនុស្ស និងសត្វ ចាប់តាំងអំពីមាន់និងឆ្កែ ដែលនៅខាងក្នុងវាំង តាំងអំពីទ្វារធំ រហូតអស់ សល់តែរាងឆ្អឹង ។ ព្រឹកឡើង មនុស្សទាំងឡាយ ឃើញទ្វារវាំងបិទដូចដើម នាំគ្នាពុះទ្វារដោយ

ពូថៅ ហើយបបួលគ្នាចូលទៅខាងក្នុង ឃើញព្រះរាជវាំងគ្រប់កន្លែងជេរជាស ដោយរាងឆ្អឹង ទើបពោលថា បុរសនោះ និយាយជាពាក្យពិតហ្ន៎ថា ស្រីនេះ មិនមែនជាប្រពន្ធរបស់ខ្ញុំ ជាយក្ខិនី តែព្រះរាជាទ្រង់មិនជ្រាប ទ្រង់នាំនាងមក តែងតាំងជាមហេសី លុះពេលយប់ យក្ខិនីក៏បបួលយក្ខមកស៊ីអស់ ហើយទៅដោយពិត ។

ថ្ងៃនោះ ព្រះពោធិសត្វ ទ្រង់ដាក់ខ្សាច់ព្រះបរិត្តត្រង់សីសៈ រុំដោយអំបោះព្រះបរិត្ត ទ្រង់កាន់ដាវឈរក្នុងសាលានោះ រហូតដល់ថ្ងៃរះ ពួកមនុស្សនាំគ្នាសម្អាតព្រះរាជនិវេសន៍ លាបដោយពណ៌ខៀវ ប្រោះព្រំដោយគ្រឿងក្រអូបរោយដោយផ្កា ចងនូវកម្រងផ្កា អប់ដោយធូមគន្ធៈ ចងកម្រងផ្កាជាថ្មី ហើយប្រឹក្សាគ្នាថា កាលពីម្សិលមិញនេះ បុរសនោះ មិនបានធ្វើត្រឹមតែការទម្លាយឥន្ទ្រិយ សម្លឹងមើលយក្ខិនីដែលកាឡាខ្លួនដូចរូបទិព្វ ដើរមកតាមក្រោយឡើយ បុរសនោះជាសត្វប្រសើរក្រៃពេក ជាអ្នកធ្ងន់ សម្បូរដោយញាណ បើបុរសនោះគ្រប់គ្រងដែនរដ្ឋសីមាមណ្ឌល នឹងមានតែសុខសន្តិភាព ពួកយើងគួរធ្វើបុរសនោះ ឲ្យជាព្រះរាជាចុះ ។ គ្រានោះ ពួកអមាត្យ និងអ្នកស្រុកគ្រប់គ្នារួមគ្នាជាឯកច្ឆន្ទ ចូលទៅគាល់ព្រះពោធិសត្វ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់គ្រងរាជ្យចុះ យាងព្រះពោធិសត្វចូលព្រះនគរ ហើយយាងឲ្យឡើងប្រថាប់លើគំនររតនៈ អភិសេកធ្វើឲ្យជាព្រះរាជា នៃតក្កសិលានគរ ព្រះរាជាទ្រង់វៀរនូវការលុះក្នុងអគតិ ៤ មិនឲ្យទសពិធរាជធម៌កម្រើកគ្រប់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បំពេញកុសល មានឲ្យទានជាដើម ហើយ

ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់ត្រាស់ដឹងក្រៃលែងហើយ កាលទ្រង់នាំយករឿងអតីតមកសាធកៈ ទើបត្រាស់ព្រះគាថានេះថា

បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្តាប់មាត់

មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ ( ព្រះយោគាវចរ ) កាល

ប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្ត

របស់ខ្លួន ( ដោយសតិ ) យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមតិត្តិកំ** សេចក្តីថា ពេញស្មើកណ្តាប់មាត់ គឺស្មើរណ្តាខាងក្នុង ។

បទថា **អនវសេសកំ** សេចក្តីថា ធ្វើឲ្យដាក់ចូលទៅទៀតមិនបាន គឺបន្តក់ចូលទៅទៀតមិនបាន ។

បទថា **តេលបត្តំ** បានដល់ ភាជនៈដែលដាក់ប្រេងល្ង ។

បទថា **បរិហរេយ្យ** សេចក្តីថា គប្បីផ្គងទៅ គឺកាន់យកទៅ ។

បទថា **ឯវំ សចិត្តមនុរក្ខេ** សេចក្តីថា ព្រះយោគាវចរដែលជាបណ្ឌិតគប្បីផ្គងចិត្តរបស់ខ្លួន ដែលដូចជាភាជនៈដែលពេញដោយប្រេងនោះទុក ក្នុងរវាងនៃធម៌ទាំង ២ គឺក្នុងអារម្មណ៍ជាមួយសតិ ដែលប្រកបយ៉ាងល្អ ហើយគប្បីរក្សា គឺគ្រប់គ្រង ដោយកាយគតាសតិ ដោយចិត្តដែលមិនរសាត់ទៅក្នុងអារម្មណ៍ខាងក្រៅ សូម្បីត្រឹមតែមួយរំពេច ព្រោះហេតុអ្វី ព្រោះថា

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាត

រហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណា មួយ រមែងជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្ត ដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ដូច្នេះ ។

ព្រោះហេតុនោះ

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែល ល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអា- រម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែង នាំមកនូវសេចក្តីសុខ ដូច្នេះ ។

ព្រោះថា

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅ តែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យ នៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ដូច្នេះ ។

ឯបុគ្គលក្រៅពីនេះ

ប្រាជ្ញារមែងមិនបរិបូណ៌ដល់បុគ្គល ដែលមានចិត្តមិនខ្ជាប់ខ្ជួន មិន ដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ដូច្នេះ ។

ឯបុគ្គលដែលសេពកម្មដ្ឋានមកអស់កាលដ៏យូរ

ភ័យ រមែងមិនមានដល់បុគ្គល អ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាប លះ បោលហើយ ភ្ញាក់រឭកជានិច្ច ដូច្នេះ ។

ព្រោះហេតុនោះ

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ដូច្នេះ[១] ។

កាលព្រះយោគាវចរ ធ្វើចិត្តឲ្យត្រង់យ៉ាងនេះ ឈ្មោះថា តាមរក្សាចិត្តរបស់ខ្លួន ។

បទថា **បត្ថយានោ ទិសំ អគតបុព្វំ** សេចក្ដីថា ព្រះយោគាវចរ កាលប្រាថ្នាបរិកម្មដោយកាយគតាសតិកម្មដ្ឋាននេះ ប្រាថ្នាទិសដែលមិនធ្លាប់ទៅក្នុងសង្សារ ដែលមិនមានខាងចុង និងខាងដើម គប្បីរក្សាចិត្តរបស់ខ្លួន ដោយន័យដូចពោលហើយ ។ ដែលឈ្មោះថា ទិសនេះ គឺអ្វី ជាបឋម បុត្រ និងភរិយាជាដើម លោកពោលថា ជាទិស ដូចក្នុងគាថា ( ទីឃនិកាយ សិង្គាលកសូត្រ ) ថា

មាតា បិតា ជាទិសខាងកើត អាចារ្យ ជាទិសខាងត្បូង កូនប្រពន្ធ ជាទិសខាងលិច មិត្តអាមាត្យ ជាទិសខាងជើង ទាសៈ និងកម្មករ ជាទិសខាងក្រោម សមណព្រាហ្មណ៍ ជាទិសខាងលើ គ្រហស្ថក្នុងត្រកូល ដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ដូច្នេះ ។

នៅមានទិសដទៃទៀត ដោយប្រភេទ មានទិសខាងកើតជាដើម លោក

---

១- ៥ គាថាខាងលើនេះ មានក្នុងខុទ្ទកនិកាយ ធម្មបទ ។

ហៅថា ទិស ដូចក្នុងគាថា ( ធម្មទ្ធជាតក ) ថា

បណ្ដាទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រីទ្រង់ព្រះសុបិនឃើញដីដ៏ប្រសើរ មានក្លិនក្រអូបមួយ ឋិតនៅក្នុងទិសណា ដូច្នេះ ។

ព្រះនិព្វាន លោកហៅថា ទិស ដូចក្នុងគាថា ( ក្នុងតេលបត្តជាតកនេះ ) ថា

បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្ដាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ ( ព្រះយោគាវចរ ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន ( ដោយសតិ ) យ៉ាងនោះដែរ ដូច្នេះ ។

ក្នុងបាទព្រះគាថានេះថា ទិសដែលខ្លួនមិនធ្លាប់ទៅ ក៏បំណងយកទិសគឺព្រះនិព្វាននោះឯង ព្រោះថា ព្រះនិព្វាននោះ រមែងប្រាកដដោយលក្ខណៈជាដើមថា ការអស់ទៅ ការប្រាសចាកតម្រេក ហេតុនោះ ទើបព្រះសាស្ដាត្រាស់ហៅថា ទិស ។ ចំណែកដែលត្រាស់ថា ឈ្មោះថា ទិសដែលមិនធ្លាប់ទៅ ព្រោះពាលបុថុជ្ជនណាម្នាក់ ក្នុងសង្សារ ដែលមិនមានខាងដើម និង

*ខាងចុងនេះ មិនធ្លាប់ទៅ សូម្បីត្រឹមតែដោយយល់សប្តិ ។ កាលព្រះយោគាវចរប្រាជ្ញាទិសនោះ គប្បីធ្វើសេចក្តីព្យាយាមក្នុងកាយគតាសតិ ។*

*ព្រះបរមសាស្តា ទ្រង់កាន់យកកំពូលនៃទេសនាដោយព្រះនិព្វាន ដោយប្រការដូច្នេះហើយ ទ្រង់ប្រជុំជាតកថា រាជបរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯព្រះរាជកុមារដែលគ្រងរាជសម្បត្តិ ក្នុងកាលនោះ គឺ តថាគតនេះឯង ។*

**អដ្ឋកថា តេលបត្តជាតក ចប់**

# សុត្តន្តបិដក

## នាមសិទ្ធិជាតក

[ ៩៧ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) មាណពឈ្មោះបាបកៈ បានឃើញបុរសរស់ហើយស្លាប់ផង ឃើញទាសីឈ្មោះនាងធនបាលីក្រ ទ្រព្យហើយខ្សត់ទ្រព្យផង ឃើញបុរសអ្នកដើរផ្លូវ ហើយវង្វេងក្នុងព្រៃផង មកវិញហើយ ។

**នាមសិទ្ធិជាតកទី ៧ ចប់**

# អដ្ឋកថា

## នាមសិទ្ធិជាតក

[ ៩៧ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលប្រាថ្នានូវសេចក្តីសម្រេចដោយឈ្មោះមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ជីវកញ្ច មតំ ទិស្វា** *ដូច្នេះជាដើម ។*

*បានឮថា កុលបុត្តម្នាក់ ដោយឈ្មោះ ឈ្មោះថា* **ទាបកះ** *បួសថ្វាយជីវិតក្នុងសាសនា កាលពួកភិក្ខុហៅថា មកអាវុសោបាបកៈ ឈប់ចុះអាវុសោបាបកៈ ក៏គិតថា ក្នុងលោក បុគ្គលដែលមានឈ្មោះថា បាបកៈ ដែលគេសន្មតថា អាក្រក់ ជាកាឡកិណី អញត្រូវឲ្យឧបជ្ឈាយ៍ និងអាចារ្យរកឈ្មោះដែលប្រកបដោយមង្គលដទៃ ។ ភិក្ខុនោះចូលទៅរកឧបជ្ឈាយ៍ និងអាចារ្យប្រាប់ថា បពិត្រលោកម្ចាស់ ឈ្មោះរបស់ខ្ញុំជាអពមង្គល សូមលោកម្ចាស់ដាក់ឈ្មោះដទៃឲ្យខ្ញុំចុះ ។ គ្រានោះ អាចារ្យ និងឧបជ្ឈាយ៍ ក៏ពោលយ៉ាងនេះថា ឈ្មោះគ្រាន់តែជាបញ្ញត្តសម្រាប់ហៅគ្នា ឈ្មោះថា ការសម្រេចប្រយោជន៍ណាមួយ មិនមានព្រោះឈ្មោះឡើយ ចូរអ្នកពេញចិត្តនឹងឈ្មោះរបស់ខ្លួននោះចុះ ។ ភិក្ខុនោះ នៅតែអង្វររឿយៗ ព្រោះលោកប្រាថ្នាការសម្រេចដោយឈ្មោះ ក៏ផ្សាយខ្វះខ្វាយទៅក្នុងសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ភិក្ខុនោះ ប្រាថ្នានូវការសម្រេចដោយឈ្មោះ សូមឲ្យឧបជ្ឈាយ៍រកឈ្មោះដែលជាមង្គលដាក់ឲ្យ ។ ព្រះសាស្តាយាងមកកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យ*

ទ្រង់ជ្រាបហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ប្រាថ្នាការសម្រេចដោយឈ្មោះដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិ ជាអាចារ្យទិសាបាមោក្ខបង្រៀនមន្តមាណព ៥០០ ក្នុងនគរតក្កសិលា មាណពម្នាក់របស់លោកឈ្មោះបាបកៈ ត្រូវគេហៅថា មកចុះបាបកៈ ទៅចុះបាបកៈ គិតថា ឈ្មោះរបស់អញជាអពមង្គល ត្រូវសូមឲ្យអាចារ្យ តាំងឈ្មោះថ្មីដទៃឲ្យ ចូលទៅរកអាចារ្យ ប្រាប់ថា បពិត្រលោកអាចារ្យ ឈ្មោះរបស់ខ្ញុំជាអពមង្គល សូមដាក់ឈ្មោះដទៃឲ្យចុះ កាលនោះ អាចារ្យបានពោលថា ទៅចុះបា ចូរបាត្រាច់ទៅតាមជនបទ ហើយកំណត់យកឈ្មោះដែលជាមង្គលណាមួយ ដែលខ្ទនពេញចិត្តក្រៃលែងហើយ សឹមមក អញនឹងដូរឈ្មោះរបស់បា ជាឈ្មោះដទៃ ។ បុរសនោះទទួលថា សាធុ កាន់យកស្បៀងធ្វើដំណើរទៅ ត្រាច់ទៅតាមនិគមជនបទ ដល់នគរមួយកន្លែង ក្នុងព្រះនគរនោះឯង មានបុរសម្នាក់ ឈ្មោះថាជីវកៈ បានស្លាប់ ពួកញាតិកំពុងសែងចូលទៅកាន់ព្រៃខ្មោច ទើបសួរថាអ្នកនេះឈ្មោះអ្វី ពួកញាតិឆ្លើយថា បុរសនេះឈ្មោះជីវកៈ កុលបុត្តនោះសួរថា បុរសនេះ ឈ្មោះជីវកៈ ក៏ស្លាប់ឬ ពួកញាតិឆ្លើយថា ឈ្មោះថាជីវកៈ ( រស់ ) ក្តី អជីវកៈ ( មិនមានជីវិត ) ក្តី ក៏ស្លាប់ទាំងអស់ ឈ្មោះត្រឹមតែជាបញ្ញត្តសម្រាប់ហៅ ឯងប្រហែលជាល្ងង់ខ្លៅទេដឹង ។ កុលបុត្តនោះ ស្តាប់ពាក្យនោះហើយ ធ្វើព្រងើយៗ ក្នុងរឿងឈ្មោះ ធ្វើដំណើរត្រឡប់

ចូលនគររបស់ខ្លួន ។

គ្រានោះ ពួកអ្នកជំនួញកំពុងចាប់ទាសីម្នាក់ ដែលមិនឲ្យការប្រាក់ ឲ្យអង្គុយត្រង់ទ្វារ ចងដោយខ្សែ ទាសីនោះឈ្មោះថា ធនបាលី ដែលមានន័យថា អ្នកមានទ្រព្យច្រើន ។ បុរសនោះដើរតាមផ្លូវ ឃើញនាងត្រូវគេចង ក៏សួរថា នាងឈ្មោះអ្វី ពួកអ្នកជំនួញឆ្លើយថា នាងឈ្មោះធនបាលី បុរសនោះសួរថា ឈ្មោះធនបាលីហើយ មិនអាចសងការប្រាក់បានឬ ។ ពួកឈ្មួញតបថា ទោះជាឈ្មោះធនបាលីក្តី ឈ្មោះអធនបាលីក្តី ក៏ជាអ្នកក្រីក្របានទាំងអស់ ឈ្មោះត្រឹមតែជាបញ្ញត្តសម្រាប់ហៅគ្នា ឯងនេះល្ងង់ពិត ។ កុលបុត្តនោះធ្វើព្រងើយៗ ក្នុងរឿងឈ្មោះក្រៃលែងឡើង ដើរចេញអំពីក្រុង ក្នុងរវាងផ្លូវ បានជួបមនុស្សវង្វេងផ្លូវម្នាក់ សួរថា អ្នកត្រាច់ធ្វើអ្វី បុរសនោះឆ្លើយថា ខ្ញុំវង្វេងផ្លូវហើយ បាបកៈសួរថា អ្នកឈ្មោះអ្វី បុរសនោះឆ្លើយថា ខ្ញុំឈ្មោះបន្ថកៈ ដែលមានន័យថា ជាអ្នកស្គាល់ផ្លូវ បាបកមាណពសួរថា អ្នកឈ្មោះបន្ថកៈនៅវង្វេងផ្លូវទៀតឬ បុរសអ្នកវង្វេងផ្លូវពោលថា ទោះឈ្មោះបន្ថកៈក្តី អបន្ថកៈក្តី ក៏មានឱកាសវង្វេងផ្លូវបានទាំងអស់ ឈ្មោះគ្រាន់តែជាបញ្ញត្តសម្រាប់ហៅ អ្នកប្រហែលជាបុគ្គលល្ងង់ខ្លៅពិត បាបកៈរឹងរឹតតែទៀយណាយក្នុងរឿងឈ្មោះ ទៅកាន់សម្នាក់របស់ព្រះពោធិសត្វ កាលព្រះពោធិ-សត្វសួរថា នែបា ដូចម្តេចទៅហើយ បាបានឈ្មោះដែលពេញចិត្តមកហើយឬ ក៏ប្រាប់អាចារ្យថា ធម្មតាមនុស្សយើង ទោះឈ្មោះថា ជីវកៈក្តី អជីវកៈក្តី គង់ស្លាប់ទាំងអស់ ឈ្មោះថា ធនបាលីក្តី អធនបាលីក្តី ក៏ជាមនុស្សក្រីក្រ

បានទាំងអស់ ទោះឈ្មោះបន្ទកៈក្តី ឈ្មោះអបន្ទកៈក្តី ក៏ជាអ្នកវង្វេងផ្លូវបានដូចគ្នា ឈ្មោះត្រឹមតែជាបញ្ញត្តសម្រាប់ហៅ ការសម្រេចព្រោះឈ្មោះមិនមានទេ ការសម្រេចមាន ព្រោះការធ្វើប៉ុណ្ណោះ ឈ្មោះរបស់ខ្ញុំគ្រប់គ្រាន់ហើយ ខ្ញុំសុំប្រើឈ្មោះដើមនោះឯង ព្រះពោធិសត្វប្រៀបធៀបរឿងដែលមាណពឃើញ និងកម្មដែលបុគ្គលធ្វើហើយ ពោលគាថានេះថា

មាណពឈ្មោះបាបកៈ បានឃើញបុរសរស់ហើយស្លាប់ផង ឃើញ
ទាសីឈ្មោះនាងរក្សាទ្រព្យ ហើយខ្សត់ទ្រព្យផង ឃើញបុរសអ្នក
ដើរផ្លូវ ហើយវង្វេងក្នុងព្រៃផង មកវិញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុនរាគតោ** សេចក្តីថា ព្រោះឃើញហេតុ ៣ យ៉ាង ទើបវិលត្រឡប់មក ។ រ អក្ខរៈ លោកពោលដោយអំណាចនៃសន្ធិ ។

ព្រះបរមសាស្តា ទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ប្រាថ្នាសេចក្តីសម្រេចព្រោះឈ្មោះមកហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា មាណពដែលត្រូវការសេចក្តីសម្រេចព្រោះឈ្មោះ ក្នុងកាលនោះ បានមកជាភិក្ខុដែលប្រាថ្នាការសម្រេចព្រោះឈ្មោះ ក្នុងកាលឥឡូវនេះ បរិស័ទរបស់អាចារ្យក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។៙

**អដ្ឋកថានាមសិទ្ធិជាតក ចប់**

# សុត្តន្តបិដក

## កូដវាណិជជាតក

[ ៩៨ ] ( បិតារបស់អតិបណ្ឌិតពាណិជពោលថា ) បុគ្គលដែលឈ្មោះថា បណ្ឌិត ជាអ្នកប្រពៃពិត ឯបុគ្គលឈ្មោះថា អតិបណ្ឌិត មិនប្រពៃទេ អាត្មាអញត្រូវភ្លើងរោល ព្រោះតែកូនឈ្មោះអតិបណ្ឌិត ។

**កូដវាណិជជាតកទី ៨ ចប់**

# អដ្ឋកថា

## កូដវាណិជជាតក

[ ៩៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញទុច្ចរិតម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សាធុ ខោ បណ្ឌិតោ នាម** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ជន ២ នាក់ ក្នុងក្រុងសាវត្ថី ដាក់ទុនជុំគ្នា ធ្វើនូវការលក់ដូរដោយរទេះ ទៅកាន់ជនបទ បានរបស់ហើយ នាំគ្នាត្រឡប់ ។ ក្នុងឈ្មួញទាំង ២ នាក់នោះ ឈ្មួញមិនស្មោះត្រង់គិតថា សម្លាញ់របស់អញនេះ យ៉ាប់យ៉ឺនដោយការបរិភោគមិនល្អ ដេកលំបាក មកច្រើនថ្ងៃហើយ ឥឡូវនេះ គេនឹងបរិភោគភោជនល្អៗ ដោយរសដ៏ប្រសើរផ្សេងៗ ក្នុងផ្ទះរបស់គេតាមគាប់ចិត្ត នឹងស្លាប់ដោយរោគអាហារមិនរលួយ បើដូច្នេះ អញនឹងបែងរបស់នេះជា ៣ ចំណែក ឲ្យកូនរបស់គេមួយចំណែក ២ ចំណែកទៀត អញនឹងកាន់យកឯង ហើយពន្យាថ្ងៃថា នឹងចែកក្នុងថ្ងៃនេះ នឹងចែកក្នុងស្អែកនេះ ដូច្នេះហើយ មិនចង់ចែកភណ្ឌៈ ។ ឯឈ្មួញដែលជាបណ្ឌិតក៏ជំទាស់សម្លាញ់ដែលមិនប្រាថ្នានឹងចែក ឲ្យចែកទាល់តែបាន ហើយទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្ដា បានទទួលបដិសណ្ឋារៈដែលទ្រង់ធ្វើ កាលព្រះសាស្ដាត្រាស់សួរថា ហេតុអ្វី ទើបអ្នកយឺតយូរ សូម្បីមកដល់នគរនេះហើយ ទម្រាំចូលគាល់ក៏យូរ ទើបក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគឲ្យទ្រង់ជ្រាប ព្រះបរមសាស្ដាត្រាស់ថា ម្នាលឧបាសក មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលពាណិជនោះជាពាណិជកោង សូម្បីក្នុងកាលមុន ក៏ធ្លាប់ជាពាណិជ

កោងមកហើយដូចគ្នា ក្នុងពេលនេះ ប្រាថ្នានឹងបោកអ្នក តែក្នុងកាលមុន ធ្វើសេចក្តីព្យាយាមបោកបណ្ឌិតហើយ ។ កាលឧបាសកទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឈ្មួញក្នុងនគរពារាណសីនោះ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិបានដាក់ឈ្មោះថា បណ្ឌិត លោកចម្រើនវ័យហើយ ដាក់ហ៊ុនជាមួយឈ្មួញដទៃ ធ្វើនូវការជួញដូរ ។ ឈ្មួញនោះ ឈ្មោះថា អតិ-បណ្ឌិតទាំង ២ នាក់ នាំគ្នាដឹកកណ្ឌៈដោយរទេះ ៥០០ ទៅកាន់ជនបទ ធ្វើការជួញដូរ បានទ្រព្យជាច្រើន នាំគ្នាត្រឡប់មកកាន់នគរពារាណសី លុះដល់ហើយ ក៏ចែកអន្តរគ្នា ។ អតិបណ្ឌិតពោលថា ខ្ញុំគួរបាន ២ ចំណែក ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី ឈ្មួញនោះតបថា អ្នកឈ្មោះបណ្ឌិត ឯខ្ញុំឈ្មោះអតិបណ្ឌិត បណ្ឌិតគួរបានមួយចំណែក អតិបណ្ឌិតគួរបាន ២ ចំណែក ព្រះពោធិសត្វសួរថា ដើមទុនដែលទិញរបស់ក្តី ពាហនៈ មានគោជាដើមក្តី របស់ទាំង ២ ស្មើៗ គ្នាមិនមែនឬ ហេតុអ្វី ទើបអ្នកគួរបាន ២ ចំណែក បុរសនោះឆ្លើយថា ព្រោះខ្ញុំជាអតិបណ្ឌិត ។ ជន ២ នាក់ប្រកែកគ្នាយ៉ាងនេះហើយ ក៏ឈ្លោះគ្នា លំដាប់នោះ អតិបណ្ឌិតគិតបានថា នៅមានឧបាយម្យ៉ាងទៀត ទើបឲ្យឪពុករបស់ខ្លួនចូលទៅពួនក្នុងព្រង់ឈើមួយដើម ប្រាប់ថា ពេលយើងទាំង ២ មកដល់ លោកឪពុកគួរពោលថា អតិបណ្ឌិតគួរបាន ២ ចំណែក ហើយទៅរកព្រះពោធិសត្វពោលថា នែសម្លាញ់ រុក្ខទេវតានោះ រមែងដឹង

ការដែលខ្ញុំគួរបាន ២ ចំណែក ឬមិនគួរ មកយើងនឹងសួររុក្ខទេវតានោះមើល នាំគ្នាទៅត្រង់ដើមឈើនោះឯង ពោលថា បពិត្ររុក្ខទេវតាដែលជាម្ចាស់ព្រៃ សូមលោកកាត់ក្តីរបស់ពួកយើងផងចុះ ។ កាលនោះ ឪពុករបស់បុរសនោះ បំភ្លៃសំឡេងឲ្យជាមនុស្សផ្សេង ពោលថា បើដូច្នោះ ចូរពួកអ្នកប្រាប់រឿងរ៉ាវ អតិបណ្ឌិតក៏ពោលថា បពិត្រម្ចាស់ព្រៃ បុរសនេះឈ្មោះបណ្ឌិត ខ្ញុំឈ្មោះ អតិបណ្ឌិត យើងទាំង ២ ជាក់ទុនរួមគ្នាធ្វើជំនួញ ក្នុងរឿងនោះ បុរសនេះគួរ បានប៉ុនណា បុរសនោះឆ្លើយថា ត្រូវបានមួយចំណែក អតិបណ្ឌិតត្រូវបាន ២ ចំណែក ព្រះពោធិសត្វស្តាប់ក្តីដែលទេវតាវិនិច្ឆ័យហើយយ៉ាងនេះ គិតថា ឥឡូវនេះ នឹងបានដឹងគ្នាជាទេវតា ឬមិនមែនទេវតា ហើយឱបចំបើងមកដាក់ ក្នុងព្រង់ឈើ ដុតភ្លើងមួយរំពេច ឪពុករបស់អតិបណ្ឌិត ពេលអណ្តាតភ្លើង ពាល់ត្រូវខ្លួនក៏ក្តៅ ព្រោះសរីរៈត្រូវឆេះ ទើបប្រវាឡើងលើ តោងមែកឈើ សម្រូតចុះដី ពោលគាថានេះថា

បុគ្គលដែលឈ្មោះថាបណ្ឌិត ជាអ្នកប្រពៃពិត ឯបុគ្គលឈ្មោះថា
អតិបណ្ឌិត មិនប្រពៃទេ អាត្មាអញត្រូវភ្លើងរោល ព្រោះតែកូន
ឈ្មោះអតិបណ្ឌិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ ខោ បណ្ឌិតោ នាម** សេចក្តីថា បុគ្គលប្រកបដោយគុណជាបណ្ឌិត ដឹងហេតុ និងមិនមែនហេតុ ចាត់ជា បុគ្គលល្អក្នុងលោកនេះ ។

បទថា **អតិបណ្ឌិតោ** សេចក្ដីថា បុគ្គលវៀចវេរជាអតិបណ្ឌិត ដោយហេតុត្រឹមតែឈ្មោះ មិនប្រសើរឡើយ ។

បទថា **មជ្ឈម្ហិ ឧបក្កុដ្ឋិតោ** សេចក្ដីថា ខ្ញុំត្រូវភ្លើងឆេះបន្តិចបន្តួច រួចផុតអំពីការឆេះពាក់កណ្ដាលខ្លួនបានយ៉ាងប្រផុតប្រផើយ ។ មនុស្សទាំង ២ នោះក៏ចែកគ្នាម្នាក់ពាក់កណ្ដាល កាន់យកចំណែកស្មើៗ គ្នានោះឯង ហើយទៅតាមយថាកម្ម ។

ព្រះសាស្ដា ទ្រង់នាំយករឿងអំពីអតីតមកសាធកៈថា សូម្បីក្នុងកាលមុន ពាណិជនោះ ក៏ជាពាណិជកោងដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ឈ្មួញកោងក្នុងកាលនោះ បានមកជាឈ្មួញកោងក្នុងកាលឥឡូវនេះឯង ឯឈ្មួញដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា កូដវាណិជជាតក ចប់**

# សុត្តន្តបិដក

## បរោសហស្សជាតក

[ ៩៩ ] ( មហាព្រហ្មពោធិសត្វពោលថា ) ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់មួយរយឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់ នូវអត្ថនៃភាសិត បុរសនោះនៅតែម្នាក់ឯង ប្រសើរជាង ។

បរោសហស្សជាតកទី ៩ ចប់

# អដ្ឋកថា

## បរោសហស្សជាតក

[ ៩៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួក ៥ នៃបញ្ហា មានបញ្ហាក្នុងវិស័យរបស់បុថុជ្ជនជាដើម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បរោសហស្សម្បិ សមាគតានំ** ដូច្នេះជាដើម ។

រឿងនឹងប្រាកដជាក់ច្បាស់ក្នុងសរភង្គជាតក ។ សម័យមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាដល់រឿងគុណរបស់ព្រះថេរៈថា អាវុសោទាំងឡាយ ព្រះធម្មសេនាបតីសារីបុត្រព្យាករបញ្ហា ដែលព្រះទសពលត្រាស់ដោយសង្ខេបបានដោយពិស្តារ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលសារីបុត្រព្យាករបញ្ហា ដែលតថាគតពោលដោយសង្ខេប បានដោយពិស្តារ សូម្បីក្នុងកាលមុនក៏ព្យាករបានហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយរៀនសព្វសិប្បវិជ្ជាក្នុងនគរតក្កសិលា លះកាមទាំងឡាយ បួសជាឥសី ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតបានហើយ នៅក្នុងព្រៃហិមពាន្ត សូម្បីបរិវាររបស់លោក ក៏បានបួសជាតាបស ៥០០ រូប ។ កាលនោះ ជារដូវភ្លៀង អន្តេវាសិកដែលជាច្បងរបស់លោក នាំគណៈឥសីប្រមាណពាក់កណ្តាលមក

កាន់ដែនដីមនុស្ស ដើម្បីរសជួរ និងប្រែ ។ ក្នុងកាលនោះ ជួនជាសម័យដែល ព្រះពោធិសត្វធ្វើកាលកិរិយា អន្តេវាសិកទាំងឡាយ នាំគ្នាសួរការសម្រេច គុណវិសេសជាមួយនឹងលោកថា បពិត្រលោកអាចារ្យ លោកបានគុណវិសេស ប្រភេទណា លោកឆ្លើយថា អ្វីតិចតួចមិនមាន ហើយទៅកើតក្នុងព្រហ្មលោក ជាន់អាភស្សរ ព្រោះព្រះពោធិសត្វទាំងឡាយ ទោះបីបានអរូបសមាបត្តិ ក៏ មិនកើតក្នុងអរូបភព ជាទីដែលមិនគួរ ។ ពួកអន្តេវាសិកគិតគ្នាថា លោក អាចារ្យមិនមានគុណវិសេសឡើយ ដូច្នេះហើយ មិនធ្វើសក្ការៈក្នុងឈាបនដ្ឋាន ។ អន្តេវាសិកធំត្រឡប់មកហើយ សួរថា លោកអាចារ្យទៅឯណា កាលដឹងថា ធ្វើកាលកិរិយាហើយ ទើបពោលថា អើ ពួកអ្នកសួរដល់គុណ វិសេសដែលលោកបានដែរឬ អន្តេវាសិកទាំងឡាយពោលថា ពួកខ្ញុំសួរហើយ សិស្សច្បងពោលថា លោកឆ្លើយដូចម្តេច ជនទាំងនោះប្រាប់ថា លោកអាចារ្យ ពោលថា អ្វីតិចតួចមិនមាន ហេតុនោះ ទើបពួកខ្ញុំមិនធ្វើសក្ការៈដល់លោក ។ អន្តេវាសិកធំពោលថា ពួកអ្នកមិនបានដឹងនូវអត្ថរបស់ពាក្យលោកអាចារ្យ គឺ លោកអាចារ្យបានអាកិញ្ចញ្ញាយតនសមាបត្តិ សូម្បីអន្តេវាសិកធំនោះនិយាយ ហើយនិយាយទៀត ពួកអន្តេវាសិកទាំងនោះក៏មិនព្រមជឿ ព្រះពោធិសត្វ ជ្រាបហេតុនោះ ត្រិះរិះថា ពួកអន្ធពាល មិនជឿពាក្យអន្តេវាសិកច្បងរបស់ អញៗ ត្រូវធ្វើហេតុនេះឲ្យប្រាកដដល់អន្តេវាសិកទាំងនោះ ហើយមកអំពី ព្រហ្មលោក ឈរក្នុងអាកាសដោយអានុភាពធំខាងលើអាស្រមបទ កាល ពណ៌នាអានុភាពរបស់អន្តេវាសិកដែលជាច្បង ទើបពោលគាថានេះថា

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះ ឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់មួយរយឆ្នាំ បុរសណា ប្រកប ដោយប្រាជ្ញា បានដឹងច្បាស់ នូវអត្ថនៃភាសិត បុរសនោះនៅ តែម្នាក់ឯង ប្រសើរជាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរោសហស្សម្បិ** ប្រែថា សូម្បីច្រើនជាង ពាន់ ។

បទថា **សមាគតានំ** សេចក្តីថា ពួកបុគ្គលល្ងង់ខ្លៅ មិនអាចដឹងអត្ថ របស់ពាក្យដែលយើងពោលហើយ មកប្រជុំគ្នាហើយ ។

បទថា **កន្ទេយ្យុំ តេ វស្សសតំ អបញ្ញា** នេះ ព្រះពោធិសត្វសម្តែងថា ជនទាំងនេះដែលមករួមគ្នាយ៉ាងនេះ ឥតបញ្ញា ដូចពួកតាបសល្ងង់ខ្លៅទាំង នេះ នាំគ្នាស្រែកយំកន្ទក់កន្ទេញ អស់ ១០០ ឆ្នាំ ១០០០ ឆ្នាំ ឬ ១ សែន ឆ្នាំ ទោះបីនាំគ្នាយំ ក៏មិនដឹងអត្ថ ឬហេតុបានឡើយ ។

បទថា **ឯកោវ សេយ្យោ បុរិសោ សបញ្ញោ** សេចក្តីថា បុរសដែលជា បណ្ឌិតម្នាក់ប៉ុណ្ណោះល្អជាង ប្រសើរជាងពួកបុគ្គលពាលបែបនោះ សូម្បីរាប់ ពាន់ ។ សួរថា តើមានបញ្ញាដូចម្តេច ។ ឆ្លើយថា មានបញ្ញាដឹងច្បាស់នូវ អត្ថនៃពាក្យដែលយើងពោលហើយ ដូចអន្តេវាសិកធំនេះ ។

ព្រះមហាសត្វឈរក្នុងអាកាសនោះឯង សម្តែងធម៌ ប្រាប់ឲ្យគណៈតាបសដឹង ដោយប្រការដូច្នេះហើយ ក៏ទៅកាន់ព្រហ្មលោកវិញ ។ ពួកតាបសទាំងនោះ កាលអស់ជីវិត ក៏ទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អន្តេវាសិកជំក្នុងកាលនោះ បានមកជាសារីបុត្រ ក្នុងកាលឥឡូវនេះ ចំណែកមហាព្រហ្មក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា បរោសហស្សជាតក ចប់**

# សុត្តន្តបិដក

## អសាតរូបជាតក

[ ១០០ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) របស់មិនឆ្ងាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោសភាពនៃរបស់ដែលគួរស្រឡាញ់ សេចក្តីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្តីសុខ ។

អសាតរូបជាតកទី ១០ ចប់

លិត្តវគ្គទី ១០ ចប់

មជ្ឈិមបណ្ណាសក ចប់

## ឧទ្ទាននៃលិត្តវគ្គនោះ គឺ

និយាយអំពីការលេបកូនស្កា ( ក្នុងលិត្តជាតក ) ១ បុរសមានវាចាមិនពេយពាយ ( ក្នុងមហាសារជាតក ) ១ មេម្រឹគ ( ក្នុងវិស្សាសភោជនជាតក ) ១ ប្រតិបត្តិដើម្បីមោនៈ ( ក្នុងលោមហំសជាតក ) ១ សង្ខារមិនទៀង ( ក្នុងមហាសុទស្សនជាតក ) ១ ភាជន៍ប្រេង ( ក្នុងតេលបត្តជាតក ) ១ ទាសីឈ្មោះនាងរក្សាទ្រព្យ ( ក្នុងនាមសិទ្ធិជាតក ) ១ អតិបណ្ឌិតពាណិជ ( ក្នុងកូដវាណិជជាតក ) ១ ជនជាងពាន់នាក់ ( ក្នុងបរោសហស្សជាតក ) ១ របស់មិនឆ្ងាញ់ ( ក្នុងអសាតរូបជាតក ) ១ ត្រូវជា ១០ ។

# អដ្ឋកថា

## អសាតរូបជាតក

[ ១០០ ] ព្រះសាស្តា ទ្រង់អាស្រ័យកុណ្ឌិយនគរ គង់នៅក្នុងកុណ្ឌធានវ័ន ទ្រង់ប្រារព្ធឧបាសិកា ឈ្មោះសុប្បវាសាកោលិយធីតា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសាតំ សាតរូបេន** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងសម័យនោះ ព្រះនាងសុប្បវាសាទ្រង់បរិហារគភ៌ រហូតដល់ ៧ ឆ្នាំ ដោយសេចក្តីទុក្ខ ហើយឈឺព្រះគភ៌អស់ ៧ ថ្ងៃ វេទនាប្រព្រឹត្តទៅយ៉ាងធ្ងន់ ព្រះនាងសូម្បីត្រូវវេទនាយ៉ាងធ្ងន់ចាក់ដោតយ៉ាងនេះ ក៏អត់សង្កត់នូវទុក្ខបាន ដោយវិតក្ក ៣ ប្រការ គឺព្រះមានព្រះភាគអង្គណា ទ្រង់សម្តែងធម៌ដើម្បីការលះទុក្ខបែបនេះ ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតហ្ន៎ ១ សង្ឃសាវ័ករបស់ព្រះមានព្រះភាគអង្គនោះឯណា លោកបដិបត្តិហើយ ដើម្បីការលះទុក្ខបែបនេះ ពួកសាវ័ករបស់ព្រះសាស្តាអង្គនោះ ជាអ្នកបដិបត្តិល្អពិតហ្ន៎ ១ ទុក្ខបែបនេះ មិនមានក្នុងព្រះនិព្វានណា ព្រះនិព្វាននោះជាសុខពិតហ្ន៎ ១ ។ ព្រះនាងត្រាស់ហៅស្វាមីមកហើយ ឲ្យចូលគាល់ព្រះសាស្តា ដើម្បីក្រាបទូលការប្រព្រឹត្តទៅរបស់នាង និងដំណឹងក្រាបថ្វាយបង្គំ ។ ព្រះសាស្តាជ្រាបដំណឹងការថ្វាយបង្គំហើយ ត្រាស់ថា សុប្បវាសាកោលិយធីតា ចូរមានសេចក្តីសុខចុះ ចូរមានសេចក្តីសុខ មិនមានរោគប្រសូតឱរសដោយមិនមានរោគចុះ ដំណាលគ្នានឹងព្រះតម្រាស់របស់ព្រះសាស្តានោះឯង ព្រះនាងសុប្បវាសាកោលិយធីតា ព្រះនាងទ្រង់ដល់នូវផាសុក ប្រាសចាកព្រះរោគាពាធ ប្រសូតព្រះឱរសមិនមានរោគហើយ ។

កាលស្វាមីរបស់ព្រះនាងយាងដល់និវេសន៍ ទតឃើញព្រះនាងប្រសូតហើយ ទ្រង់កើតអស្ចារ្យចម្លែកក្នុងព្រះហឫទ័យថា គួរអស្ចារ្យពិតហ្ន៎ អានុភាពរបស់ព្រះតថាគត មិនអាចប្រមាណាហ្ន៎ ។ ព្រះនាងសុប្បវាសាប្រសូតព្រះរាជ-កុមារហើយ ក៏ប្រាថ្នានឹងថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ទើបបញ្ជូនស្វាមីត្រឡប់ទៅ ដើម្បីនិមន្តព្រះសាស្តា ។ សម័យនោះ ឧបដ្ឋាករបស់ព្រះមហាមោគ្គល្លាន និមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធអង្គជាប្រធានហើយ ទើបព្រះសាស្តាបញ្ជូនស្វាមីរបស់ព្រះនាងទៅកាន់សម្នាក់របស់ព្រះថេរៈ ឲ្យព្រះថេរៈប្រាប់ឧបដ្ឋាកឲ្យយល់ព្រម ដើម្បីឲ្យឱកាសដល់ទានរបស់ព្រះនាងសុប្បវាសាហើយ ទ្រង់ទទួលទានរបស់ព្រះនាងអស់ ៧ ថ្ងៃ មួយអន្លើដោយភិក្ខុសង្ឃ ។

លុះដល់ថ្ងៃទី ៧ ព្រះនាងសុប្បវាសាតាក់តែងសីវលីកុមារដែលជាឱរសឲ្យថ្វាយបង្គំព្រះសាស្តា និងភិក្ខុសង្ឃ កាលព្រះរាជកុមារនាំចូលទៅកាន់សម្នាក់របស់ព្រះថេរៈដោយលំដាប់ ព្រះថេរៈបានធ្វើបដិសណ្ឋារៈជាមួយនឹងព្រះរាជកុមារថា នែសីវលី អ្នកល្មមអត់ធន់បានដែរឬ សីវលីកុមារត្រាស់ពាក្យបែបនេះជាមួយព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំមានសេចក្តីសុខឯណាបាន ខ្ញុំត្រូវនៅក្នុងលោហកុម្ភី ( គភ៌មាតា ) ដល់ទៅ ៧ ឆ្នាំ ។ ព្រះនាងសុប្បវាសាស្តាប់ពាក្យនោះរបស់ព្រះឱរសហើយ សោមនស្សថា កូនរបស់អញកើតបាន ៧ ថ្ងៃ ចរចាជាមួយព្រះអនុពុទ្ធធម្មសេនាបតីបាន ។ ព្រះសាស្តាត្រាស់ថា ម្នាលនាងសុប្បវាសា នាងប្រាថ្នាបុត្រយ៉ាងនេះទៀតដែរឬទេ ព្រះ

នាងទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំម្ចាស់គប្បីបានឱរសដទៃៗ យ៉ាងនេះ ៧ នាក់ ខ្ញុំម្ចាស់គប្បីប្រាថ្នានោះឯង ។ ព្រះសាស្តាទ្រង់បន្លឺឧទាន ធ្វើអនុ-មោទនាហើយ ចៀសចេញទៅ ឯកុមារសីវលី លុះមានព្រះជន្មបាន ៧ វស្សាប៉ុណ្ណោះ ក៏ទ្រង់ព្រះផ្នួសថ្វាយជីវិតក្នុងសាសនា លុះអាយុគ្រប់ ក៏ឧបសម្បទា លោកជាអ្នកមានបុណ្យ ដល់នូវភាពជាកំពូលដោយលាភ និងយស ល្បីរន្ទឺពេញផ្ទៃប្រឹថពី សម្រេចអរហត្តផលហើយ បានទទួលឋានៈជាឯតទគ្គៈ ក្នុងចំណោមនៃអ្នកមានបុណ្យទាំងឡាយ ។ សម័យថ្ងៃមួយ ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា ផ្តើមសន្ទនាគ្នាថា អាវុសោទាំងឡាយ ព្រះថេរៈមានឈ្មោះថា សីវលី ជាអ្នកមានបុណ្យច្រើន មានសេចក្តីប្រាថ្នាតាំងទុកហើយ ជាសត្វកើតក្នុងភពចុងក្រោយបែបនេះ ត្រូវនៅក្នុងលោហកុម្ភី គឺក្នុងផ្ទៃម្តាយអស់ ៧ ឆ្នាំ ដល់នូវការវង្វេងគភ៌អស់ ៧ ថ្ងៃ គួរករុណាហ្ន៎ ព្រះមាតារបស់លោក សោយទុក្ខធំកន្លង លោកបានធ្វើនូវកម្មអ្វីហ្ន៎ ។ ព្រះសាស្តាយាងទៅក្នុងធម្មសភានោះ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ក្នុងកាលអម្បាញ់មិញនេះ កាលពួកភិក្ខុក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការនៅក្នុងលោហកុម្ភីអស់ ៧ ឆ្នាំ និងការវង្វេងគភ៌អស់ ៧ ថ្ងៃ របស់សីវលីអ្នកមានបុណ្យច្រើន មានកម្មដែលខ្លួនធ្វើជាមូលនោះឯង សេចក្តីទុក្ខក្នុងការថែរក្សាគភ៌ ដោយការពពោះអស់ ៧ ឆ្នាំ និងទុក្ខ ព្រោះវង្វេងគភ៌អស់ ៧ ថ្ងៃ របស់ព្រះនាងសុប្បវាសានោះ ក៏មានកម្ម

ដែលខ្លួនធ្វើជាមូលដូចគ្នា ។ កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល គ្រាព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងព្រះឧទរនៃព្រះមហេសីរបស់ព្រះបាទព្រហ្មទត្តអង្គនោះ ចម្រើនវ័យហើយ សិក្សាសព្វសិប្បវិជ្ជា ក្នុងនគរតក្កសិលា កាលព្រះជនកសោយទិវង្គត ទ្រង់គ្រងរាជ្យដោយធម៌ ។ សម័យនោះ ព្រះបាទកោសលទ្រង់កែនពួកពលជាច្រើន យាងមកដណ្តើម នគរពារាណសី បានសម្រេចទោសព្រះរាជា ។ ទ្រង់ធ្វើអគ្គមហេសីរបស់ព្រះរាជានោះឲ្យជាអគ្គមហេសីរបស់ទ្រង់ ។ ឯព្រះឱរសរបស់ព្រះបាទពារាណសី កាលព្រះរាជបិតាសោយទិវង្គតហើយ ទ្រង់គេចចេញទៅតាមលូទឹក ទ្រង់ប្រមូលកម្លាំងបាន លើកមកកាន់នគរពារាណសី បោះជំរំទ័ពក្នុងទីមិនឆ្ងាយ ទ្រង់បញ្ជូនព្រះរាជសាសន៍ដល់ព្រះរាជានោះថា តើទ្រង់ឲ្យរាជសម្បត្តិមកវិញ ឬមួយក៏ច្បាំងគ្នា ព្រះរាជាទ្រង់តបព្រះរាជសាសន៍ទៅថា យើងនឹងច្បាំង ។ ឯព្រះរាជមាតានៃព្រះរាជកុមារ ទ្រង់ស្តាប់ដំណឹងនោះហើយ លួចបញ្ជូនដំណឹងទៅថា មិនចាំបាច់ធ្វើការច្បាំងទេ ចូរព័ទ្ធនគរពារាណសី ផ្តាច់ការទៅមករបស់អ្នកនគរឲ្យដាច់ ៧ ថ្ងៃ បន្ទាប់អំពីនោះ ក៏ដណ្តើមនគរ កាលពួកមនុស្សលំបាកហើយ ដោយការអត់ឧស ទឹក និងភត្ត ដោយមិនចាំបាច់ច្បាំងឡើយ ព្រះរាជកុមារស្តាប់ដំណឹងរបស់ព្រះរាជមាតាហើយ ក៏ព័ទ្ធនគរ កាត់ផ្តាច់ការទៅមកអស់ ៧ ថ្ងៃ អ្នកនគរមិនបានចេញទៅមក ក៏កាត់ក្បាលរបស់ព្រះរាជា

ថ្វាយព្រះរាជកុមារ ក្នុងថ្ងៃទី ៧ ព្រះរាជកុមារចូលព្រះនគរគ្រងរាជសម្បត្តិ លុះអស់ព្រះជន្មាយុ ក៏ទៅតាមយថាកម្ម ។

ក្នុងកាលឥឡូវនេះ សីវលីនោះ ត្រូវនៅក្នុងលោហកុម្ភីអស់ ៧ ឆ្នាំ ដល់នូវការវេទនាក្រៃលែងអស់ ៧ ថ្ងៃ ដោយកម្មដែលព័ទ្ធនគរ កាត់ផ្តាច់ការទៅមកអស់ ៧ ថ្ងៃ ហើយដណ្តើមយក ។ តែសីវលីបានឲ្យមហាទាន ធ្វើនូវសេចក្តីប្រាថ្នាទៀបបាទមូលនៃព្រះបទុមុត្តរៈថា ខ្ញុំព្រះអង្គគប្បីជាបុគ្គលក្រៃលែងជាងបុគ្គលដែលមានលាភទាំងឡាយ ហើយក្នុងកាលព្រះវិបស្សីសម្ពុទ្ធ បានរួមគ្នាជាមួយអ្នកនគរប្រគេនដុំទឹកដោះរឹង ដែលមានតម្លៃមួយពាន់ ហើយបានធ្វើសេចក្តីប្រាថ្នា ដោយអានុភាពនៃទាននោះ ទើបបានជាកំពូលជាងភិក្ខុដែលមានលាភទាំងឡាយ ចំណែកព្រះនាងសុប្បវាសា ព្រោះបញ្ជូនដំណឹងទៅថា ចូរព័ទ្ធព្រះនគរដណ្តើមយកចុះ ទើបត្រូវរក្សាគភ៌អស់ ៧ ឆ្នាំ ហើយកើតនូវការវេទនាក្រៃលែងអស់ ៧ ថ្ងៃ ដូច្នេះ ។ ព្រះសាស្តាទ្រង់នាំយករឿងក្នុងអតីតមកសាធកៈហើយ ត្រាស់ព្រះគាថានេះ ជាអភិសម្ពុទ្ធគាថាថា

របស់មិនឆ្ងាញ់ រមែងគ្របសង្កត់ នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោសភាពនៃរបស់ដែលគួរស្រឡាញ់ សេចក្តីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្តីសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសាតំ សាតរូបេន** សេចក្តីថា វត្ថុដែលមិនគួរឆ្ងាញ់ គឺមិនមានរសផ្អែមឡើយ រមែងគ្របសង្កត់បុគ្គលអ្នកប្រមាទ

ដោយអាការដូចមានសេចក្ដីស្រឡាញ់ ។

បទថា **បមត្តមតិវត្តតិ** អធិប្បាយថា វត្ថុទាំង ៣ យ៉ាង គឺវត្ថុដែលមិនគួរឆ្ងាញ់ វត្ថុដែលមិនគួរស្រឡាញ់ និងទុក្ខ រមែងសង្កត់សង្កិន គឺគ្របសង្កត់បុគ្គលដែលប្រមាទហើយ ដោយអំណាចនៃការនៅប្រាសចាកសតិ ដោយអាការដែលគួរស្រឡាញ់ជាដើមនោះ រឿងនេះ គប្បីជ្រាបថា មាតា និងបុត្រទាំងនោះ ត្រូវវត្ថុដែលមិនគួរស្រឡាញ់ ពោល គឺការបរិហារគភ៌ និងការនៅក្នុងគភ៌ជាដើមនេះគ្របសង្កត់ហើយ ដោយការប្រៀបធៀបឲ្យឃើញការព័ទ្ធនគរក្នុងកាលមុនជាដើម យ៉ាងណា ឥឡូវនេះ ឧបាសិកានោះ រមែងឲ្យវត្ថុដែលមិនគួរសរសើរ មិនគួរស្រឡាញ់ជាទុក្ខបែបនេះ គ្របសង្កត់ដដែលទៀតដល់ទៅ ៧ ដង ដោយរូបប្រៀបធៀប ដែលដឹកនាំឲ្យយល់ខុសថា គួរស្រឡាញ់ ពោល គឺបុត្រដែលជាទីតាំងនៃសេចក្ដីស្រឡាញ់ជាដើម ទើបក្រាបទូលយ៉ាងនោះឯណាក្តី ព្រះមានព្រះភាគទ្រង់សំដៅយកវត្ថុនោះ ត្រាស់ហើយ ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា រាជកុមារព័ទ្ធព្រះនគរ ហើយបន្តរាជសម្បត្តិក្នុងកាលនោះ បានមកជាសីវលីក្នុងកាលឥឡូវនេះ ព្រះមាតាក្នុងកាលនោះ បានមកជាព្រះនាងសុប្បវាសា ឯព្រះបាទពារាណសី ជាព្រះរាជបិតា ក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

**អដ្ឋកថា អសាតរូបជាតក ចប់**

**លិត្តវគ្គ ចប់**

**មជ្ឈិមបណ្ណាសក ចប់**

# សុត្តន្តបិដក

# បរោសតវគ្គ

## បរោសតជាតក

[ ១០១ ] ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីពិចារណា ( នូវអត្ថនៃភាសិត ) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯង ប្រសើរវិញ ។

*បរោសតជាតកទី ១ ចប់*

# អដ្ឋកថា
# បរោសតវគ្គ

## បរោសតជាតក

[ ១០១ ] ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីពិចារណា ( នូវអត្ថនៃភាសិត ) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯង ប្រសើរវិញ ដូច្នេះ ។

ដូចគ្នានឹងបរោសហស្សជាតកដោយផ្ទៃរឿង ដោយវេយ្យាករណ៍ និងដោយប្រជុំជាតក តែក្នុងជាតកនេះ ប្លែកគ្នាត្រឹមតែបទ **ឈាយេយ្យុំ** មួយបទប៉ុណ្ណោះ ។ គាថានោះមានអធិប្បាយថា ជនទាំងនោះ មិនមានបញ្ញាគប្បីសម្លឹង គប្បីមើល គប្បីពិចារណាអស់ ១០០ ឆ្នាំ សូម្បីពិចារណាមើលយ៉ាងនេះ ក៏រមែងមិនឃើញហេតុ ឬផល ហេតុនោះ បុគ្គលណាដឹងអត្ថនៃពាក្យដែលយើងពោលបាន បុគ្គលនោះម្នាក់ប៉ុណ្ណោះ ជាអ្នកមានបញ្ញាប្រសើរជាង ដូច្នេះឯង ។

**អដ្ឋកថា បរោសតជាតក ចប់**

# សុត្តន្តបិដក

## បណ្ឌិកជាតក

[ ១០២ ] ( កូនស្រីរបស់ឧបាសកពោលថា ) បុគ្គលណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលមានទុក្ខពាល់ត្រូវហើយ បុគ្គលនោះ ឈ្មោះថាជាបិតារបស់ខ្ញុំ នឹងធ្វើនូវការប្រទូស្តក្នុងព្រៃ ខ្ញុំនោះ កន្ទក់កន្ទេញក្នុងកណ្តាលព្រៃ ដើម្បីបុគ្គលដូចម្តេច បុគ្គលណាជាអ្នករក្សា បុគ្គលនោះនឹងធ្វើនូវកម្មដ៏ខ្លាំងក្លា ( មេថុន ) ។

**បណ្ណិកជាតកទី ២ ចប់**

# អដ្ឋកថា

## បណ្ណិកជាតក

[ ១០២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នកលក់បន្លែម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ ទុក្ខ-ផុដ្ឋាយ ភវេយ្យ តាណំ** ដូច្នេះជាដើម ។

បានឮថា ឧបាសកអ្នកក្រុងសាវត្ថីនោះ លក់បន្លែផ្សេងៗ មានបន្លែដែលមានមើមជាដើម និងបន្លែផ្លែ មានឃ្លោក និងត្រឡាចជាដើមចិញ្ចឹមជីវិត ។ ឧបាសកនោះមានកូនស្រីម្នាក់ រូបស្អាតបាត គួរស្រឡាញ់ បរិបូណ៌ដោយមារយាទ និងការប្រព្រឹត្ត ប្រកបដោយហិរិឱត្តប្បៈ ទាស់តែម្យ៉ាង គឺចូលចិត្តសើចជានិច្ច កាលត្រកូលដែលជាគូនាំគ្នាមកដណ្តឹងនាង ឧបាសកគិតថា ការដណ្តឹងនេះកំពុងប្រព្រឹត្តទៅ ចំណែកកូនស្រីអញនេះ សើចជានិច្ច បើកុមារីមិនមានសម្បត្តិជាកូនស្រី ទៅកាន់ត្រកូលប្តី គេរមែងនិន្ទាដល់មាតាបិតាបាន អញត្រូវសាកល្បងកូនស្រីមើលថា តើនាងមានសម្បត្តិជាមនុស្សស្រី ឬមិនមាន ។ ថ្ងៃមួយ ឲ្យធីតាកាន់កំប្រោងទៅព្រៃ ដើម្បីបេះបន្លែ ហើយធ្វើជាត្រូវកិលេសរួបរឹត ដោយប្រាថ្នានឹងសាកល្បង ពោលពាក្យលួងលោម ហើយចាប់ដៃ ។ គ្រាន់តែចាប់ដៃប៉ុណ្ណោះ ក៏ស្រែកយំ ពោលថា ពុកធ្វើរឿងនេះ មិនសមគួរឡើយ ដូចគ្នានឹងការប្រាកដឡើងនៃភ្លើងដែលឆេះអំពីទឹក សូមពុកកុំធ្វើយ៉ាងនេះឡើយ ។ ឪពុកពោលថា កូនជាទីស្រឡាញ់ អញចាប់ដៃនាងដើម្បីនឹងល្បងមើល មិនមែនចាប់ដោយអំណាចកិលេស ចូរប្រាប់ពុកមកចុះថា ឥឡូវនេះ កូនមានសម្បត្តិជាមនុស្សស្រីហើយឬ នាង

ឆ្លើយថា មាន ព្រោះខ្ញុំមិនធ្លាប់សម្លឹងមើលបុរសណាម្នាក់ ដោយអំណាចសេចក្តីស្រឡាញ់ឡើយ ។ ឧបាសកល្ងង់លោមធីតាហើយ ធ្វើនូវអាវាហមង្គល បញ្ជូនខ្លួនទៅកាន់ត្រកូលប្តី គិតថា អញនឹងថ្វាយបង្គំព្រះសាស្តា កាន់គ្រឿងប្រអប់ និងផ្កាជាដើមទៅវត្តជេតពនមហាវិហារ ថ្វាយបង្គំព្រះសាស្តាបូជាហើយ អង្គុយក្នុងចំណែកម្ខាង ។ ព្រះសាស្តាមានព្រះតម្រាស់ថា យូរហើយ ដែលមិនឃើញអ្នកមក ទើបក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក កុមារិកាដល់ព្រមដោយមារយាទ និងសីលមកយូរហើយនោះឯង ម្យ៉ាងទៀត អ្នកមិនមែនទើបតែសាកល្បងនាងយ៉ាងនេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់ពិសោធហើយដូចគ្នា ឧបាសកទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធក: ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតាក្នុងព្រៃ ។ រឿងមានដូច្នេះថា កាលនោះ ក្នុងនគរពារាណសី មានអ្នកលក់បន្លែម្នាក់ ដូច្នេះ ។ រឿងបន្តទៅ ដូចគ្នានឹងរឿងបច្ចុប្បន្ននោះឯង ខុសត្រង់តែកាលនាងត្រូវចាប់ដៃដើម្បីសាកល្បង ក៏យំពោលគាថានេះថា

បុគ្គលណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលមានទុក្ខពាល់ត្រូវហើយ បុគ្គលនោះ ឈ្មោះថាជាបិតារបស់ខ្ញុំ នឹងធ្វើនូវការប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញក្នុងកណ្តាលព្រៃ ដើម្បីបុគ្គលដូចម្តេច បុគ្គលណាជា

អ្នករក្សា បុគ្គលនោះនឹងធ្វើនូវកម្មដ៏ខ្មាំងក្លា ( មេថុន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ ទុក្ខជុដ្ឋាយ ភវេយ្យ តាណំ** សេចក្តីថា ក្នុងកាលទុក្ខផ្លូវកាយ ទុក្ខផ្លូវចិត្ត មកពាល់ត្រូវ បុគ្គលណាជាទីពឹង គឺជាទីពំនាក់ ។

បទថា **សោ មេ បិតា ទុព្ភិ វនេ ករោតិ** សេចក្តីថា បុគ្គលនោះ គឺបិតារបស់ខ្ញុំ ជួយការពារនូវទុក្ខ កំពុងធ្វើកម្មដែលកាត់នូវមេត្រីដែលគួរតិះដៀលបែបនេះក្នុងព្រៃ គឺកំពុងគិតដើម្បីធ្វើនូវការកន្ទងល្មើសក្នុងធីតា ដែលខ្លួនឲ្យកំណើត ។

បទថា **កស្ស កន្ទាមិ** នេះ នាងសម្តែងថា ខ្ញុំនឹងយំរកអ្នកណា គឺអ្នកណានឹងមកជាទីពឹងដល់ខ្ញុំ ។

បទថា **យោ តាយិតា សោ សហសា ករោតិ** សេចក្តីថា បុគ្គលណាដែលគ្រប់គ្រងរក្សាខ្ញុំ គួរជាទីពឹងពំនាក់បាន បុគ្គលនោះ គឺបិតានោះឯងកំពុងធ្វើកម្មដែលគួរតិះដៀល ។

គ្រានោះ ទើបបិតាលួងលោមទារិកា ហើយសួរថា នែនាង នាងរក្សាខ្លួនបានហើយឬ កុមារិកាឆ្លើយថា ខ្ញុំរក្សាខ្លួនឯងបាន បុរសនោះក៏នាំមកផ្ទះប្រដាប់តាក់តែងធ្វើមង្គល ហើយបញ្ជូនទៅកាន់ត្រកូលស្វាមី ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផលហើយ ទ្រង់ប្រជុំជាតកថា បិតាក្នុងកាលនោះ បានមកជាឪពុកក្នុងកាលឥឡូវនេះ ធីតាក្នុងកាលនោះ ក៏បានមកជាកូនស្រី ឯរុក្ខទេវតាដែលឃើញហេតុនោះដោយប្រចក្សក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា បណ្ឌិកជាតក ចប់**

# សុត្តន្តបិដក

## វេរិជាតក

[ ១០៣ ] *( សេដ្ឋីពោធិសត្វពោលថា ) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិនគប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសម្នាក់នៃបុគ្គលមានពៀរអស់មួយរាត្រី ឬ ២ រាត្រី ក៏នាំមកនូវសេចក្ដីទុក្ខ ។*

***វេរិជាតកទី ៣ ចប់***

# អដ្ឋកថា

## វេរិជាតក

[ ១០៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យត្ថ វេរី និវីសតិ** ដូច្នេះជាដើម ។

បានឮថា អនាថបិណ្ឌិកសេដ្ឋីទៅកាន់ស្រុកសួយហើយ កំពុងដើរមកជួបពួកចោរក្នុងរវាងផ្លូវ គិតថា មិនគួរស្នាក់ក្នុងរវាងផ្លូវ ត្រូវទៅឲ្យដល់នគរសាវត្ថីនោះឯង ហើយដេញហ្វូងគោមកដល់នគរសាវត្ថីដោយរហ័ស ។ ស្អែកឡើង ទៅកាន់វិហារ ក្រាបទូលរឿងនោះដល់ព្រះសាស្តាៗ ត្រាស់ថា ម្នាលគហបតី សូម្បីក្នុងកាលមុន បណ្ឌិតជួបចោរក្នុងចន្លោះផ្លូវ មិនស្នាក់នៅក្នុងចន្លោះផ្លូវ ទៅរហូតដល់លំនៅខ្លួននោះឯង អនាថបិណ្ឌិកទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី មានសម្បត្តិច្រើន ទៅកាន់ទីអញ្ជើញក្នុងស្រុក ដើម្បីការបរិភោគ កាលដើរត្រឡប់មក ជួបពួកចោរក្នុងចន្លោះផ្លូវ មិនឈប់ក្នុងចន្លោះផ្លូវឡើយ ប្រញាប់ដេញគោទាំងឡាយមកកាន់ផ្ទះរបស់ខ្លួននោះឯង បរិភោគអាហារដោយរសដ៏ប្រសើរ អង្គុយលើអាសនៈដែលមានតម្លៃច្រើន ត្រិះរិះថា អាត្មាអញរួចផុតពីកណ្តាប់ដៃចោរមកកាន់ផ្ទះដែលជាទីផុតភ័យ ហើយពោលគាថានេះ ដោយអំណាចនៃឧទានថា

បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិនគប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសម្នាក់នៃបុគ្គលមានពៀរអស់ ១ រាត្រី ឬ ២ រាត្រី ក៏នាំមកនូវសេចក្តីទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេរី** បានដល់ បុគ្គលដែលដល់ព្រមដោយចេតនាបង្ករនូវពៀរ ។

បទថា **និវិសតិ** ប្រែថា រមែងស្នាក់នៅ ។

បទថា **ន វសេ តត្ថ បណ្ឌិតោ** សេចក្តីថា បុគ្គលដែលជាពៀរនោះស្នាក់នៅ គឺអាស្រ័យនៅក្នុងទីណា បណ្ឌិត គឺបុគ្គលដែលប្រកបដោយគុណជាគ្រឿងធ្វើនូវភាពជាបណ្ឌិតមិនគួរនៅក្នុងទីនោះ ព្រោះហេតុអ្វី ព្រោះបុគ្គលនៅក្នុងពួកអ្នកមានពៀរមួយយប់ ឬពីរយប់ រមែងជាទុក្ខ ពង្រីកសេចក្តីថា បុគ្គលកាលនៅក្នុងក្រុមរបស់អ្នកមានពៀរ សូម្បីតែ ១ ថ្ងៃ ២ ថ្ងៃ ក៏ឈ្មោះថា នៅជាទុក្ខទាំងអស់ ។

ព្រះពោធិសត្វ បន្លឺឧទានដោយប្រការនេះ ធ្វើកុសល មានទានជាដើម ហើយទៅតាមយថាកម្ម ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ក្នុងកាលនោះ តថាគតនេះឯង ជាសេដ្ឋីក្នុងនគរពារាណសី ដូច្នេះ ។ ល។

**អដ្ឋកថា វេរិជាតក ចប់**

# សុត្តន្តបិដក

## មិត្តវិន្ទជាតក

[ ១០៤ ] *( ទេវបុត្តពោធិសត្វពោលថា )* អ្នក ( ចេញ ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨ ( ចេញ ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ ( ចេញ ) អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ ( ក៏នៅតែមិនស្កប់ស្កល់ ) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នាក្នុងទីនោះៗ ទើបមកដល់កង់ចក្រ កង់ចក្ររមែងវិលលើក្បាលបុគ្គលដែលមានសេចក្តីប្រាថ្នាគ្របសង្កត់ ។

**មិត្តវិន្ទជាតកទី ៤ ចប់**

# អដ្ឋកថា

## មិត្តវិន្ទជាតក

[ ១០៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ចតុព្ភិ អដ្ឋជ្ឈគមា** ដូច្នេះជាដើម ។

រឿងគប្បីឲ្យពិស្តារ តាមន័យដែលពោលហើយ ក្នុងមិត្តវិន្ទជាតកខាងដើម ។ ឯជាតកនេះ ជារឿងដែលកើតក្នុងកាលនៃព្រះពុទ្ធព្រះនាមថាកស្សបៈ ។ ក្នុងកាលនោះ នេរយិកសត្វម្នាក់ទូលចក្រក្នុងនរក សួរព្រះ-ពោធិសត្វថា បពិត្រលោកម្ចាស់ ខ្ញុំបានធ្វើបាបកម្មអ្វីហ្ន៎ ព្រះពោធិសត្វពោលថា ឯងបានធ្វើបាបកម្មនេះៗ ហើយពោលគាថាថា

អ្នក ( ចេញ ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨
( ចេញ ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ ( ចេញ )
អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ ( ក៏នៅតែមិនស្កប់
ស្កល់ ) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នាក្នុងទីនោះៗ
ទើបមកដល់កង់ចក្រ កង់ចក្ររមែងវិលលើក្បាលបុគ្គលដែល
មានសេចក្តីប្រាថ្នាគ្របសង្កត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុព្ភិ អដ្ឋជ្ឈគមា** សេចក្តីថា អ្នកបានវេមានិកប្រេត ៤ នាក់ ក្នុងរវាងសមុទ្រ ក៏មិនស្កប់ស្កល់ដោយស្រីទាំងនោះ ទើបធ្វើដំណើរទៅខាងមុខ ដោយការល្មោភ បានគ្រប់គ្រងវេមានិកប្រេត ៨ រូបទៀត ក្នុងពាក្យដ៏សេសទាំង ២ ក៏មានន័យនេះដូចគ្នា ។

បទថា **អត្រិច្ឆំ ចក្កមាសទោ** សេចក្តីថា អ្នកមិនពេញចិត្តដោយលាភរបស់ខ្លួនយ៉ាងនេះ នៅប្រាថ្នាច្រើន គឺប្រាថ្នាតទៅមិនឈប់ឈរ ទទឹងលាភខាងមុខតទៅ គ្រានេះ ទើបមកទូលខុរចក្ក គឺដល់នូវចក្កនេះ អ្នកដែលការប្រាថ្នាកម្ចាត់ហើយ គឺត្រូវតណ្ហាកម្ចាត់ ចូលទៅកាត់ផ្តាច់ហើយ ទើបចក្ករួចផុតអំពីក្បាលរបស់អ្នក ក្នុងចក្កទាំង ២ គឺចក្កថ្ម និងចក្កដែក ព្រះពោធិសត្វឃើញចក្កដែកមុតដូចកាំបិតកោរ វិលនៅលើក្បាលរបស់មិត្តវិន្ទុកៈ ដោយអំណាចការវិលជាប់តគ្នាទៅ ទើបពោលយ៉ាងនេះ ។

កាលពោលយ៉ាងនេះហើយ ត្រឡប់ទៅកាន់ទេវលោករបស់ខ្លួន ។

នេរយិកសត្វនោះ កាលបាបកម្មរបស់ខ្លួនអស់ហើយ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ឯទេវបុត្រក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា មិត្តវិន្ទុជាតក ចប់**

# សុត្តន្តបិដក

## ទុព្ពលកដ្ឋជាតក

[ ១០៥ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ឈើគ្រាំគ្រាដែលខ្យល់កាច់បំបាក់បានក្នុងព្រៃនោះ មានច្រើន ម្នាលដំរី ប្រសិនបើអ្នកខ្លាចឈើនោះ អ្នកមុខជានឹងស្គមមិនខាន ។

*ទុព្ពលកដ្ឋជាតកទី ៥ ចប់*

# អដ្ឋកថា

## ឧព្វិលកដ្ឋជាតក

[ ១០៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកខ្លាចមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពហុម្បេតំ វនេ កដ្ឋំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាកុលបុត្រមួយរូប អ្នកនគរសាវត្ថី ស្តាប់ធម៌របស់ព្រះសាស្តាហើយ បព្វជ្ជា បានជាអ្នកខ្លាចស្លាប់ក្រៃលែង លោកបានឮសំឡេងខ្យល់បក់ សំឡេងមែកឈើធាប់បាក់ ឬសំឡេងបក្សី សំឡេងសត្វចតុប្បាទក្នុងទីសម្រាកពេលយប់ និងក្នុងទីសម្រាកពេលថ្ងៃ ក៏ភ័យខ្លាចស្លាប់ ស្រែករត់ទៅ ដោយហេតុត្រឹមតែការរឭកថា អញត្រូវស្លាប់ ដូច្នេះ ក៏មិនមានដល់លោកឡើយ បើលោកដឹងថា អញត្រូវស្លាប់ ដូច្នេះ ក៏មិនខ្លាចស្លាប់ តែព្រោះលោកមិនធ្លាប់ចម្រើនមរណស្សតិកម្មដ្ឋាន ទើបខ្លាច ។ ការខ្លាចស្លាប់របស់លោកល្បីទៅក្នុងចំណោមភិក្ខុ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយលើករឿងនេះឡើង និយាយគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុខ្លាចចំពោះសេចក្តីស្លាប់ ខ្លាចស្លាប់ ធម្មតាភិក្ខុ គួរចម្រើនមរណស្សតិកម្មដ្ឋានថា អញត្រូវស្លាប់ពិត ដូច្នេះ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ឲ្យហៅភិក្ខុនោះមកគាល់ សួរថា នែភិក្ខុ អ្នកជាបុគ្គលខ្លាចស្លាប់ ពិតឬ កាលភិក្ខុនោះទូលថា ព្រះករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ពួកអ្នកកុំទោមនស្សចំពោះភិក្ខុនោះឡើយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះខ្លាចស្លាប់ ក្នុងកាលមុន ក៏ជាអ្នកខ្លាចស្លាប់ដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតា ក្នុងព្រៃហិមពាន្ត ។ ក្នុងគ្រានោះ ព្រះបាទពារាណសី ទ្រង់ប្រគល់មង្គលហត្ថីរបស់ព្រះអង្គ ដល់នាយហត្ថាចារ្យ ដើម្បីបង្ហាត់ដល់ហេតុនៃការមិនភ័យខ្លាច ទើបពួកនាយហត្ថាចារ្យ ចងដំរីត្រង់សសរ មិនឲ្យរើបាន ពួកមនុស្សនាំគ្នាកាន់លំពែងជន្លជុំវិញ ធ្វើឲ្យកើតការភ័យខ្លាច ដំរីត្រូវគេបង្ហាត់ ដូច្នោះ មិនអាចអត់ធន់នឹងវេទនាបាន ទម្លាយទន្លីង ដេញព្រេចមនុស្សឲ្យគេចទៅ ហើយចូលកាន់ព្រៃហិមពាន្ត ពួកមនុស្សមិនអាចចាប់ដំរីនោះបាន ក៏នាំគ្នាត្រឡប់ ។ ដំរីនោះបានជាសត្វខ្លាចស្លាប់ព្រោះរឿងនោះ បានឮសំឡេងខ្យល់ជាដើម ក៏មានខ្លួនញ័រចំប្រប់ ខ្លាចស្លាប់ មូរប្រមោយរត់ទៅដោយរហ័ស ដូចកាលដែលត្រូវចងត្រង់សសរកាលបង្ហាត់មិនឲ្យខ្លាច ដូច្នោះ មិនបាននូវការសប្បាយកាយ ឬសប្បាយចិត្ត មានតែការរង្កៀសត្រាច់ទៅ ។ រុក្ខទេវតាឃើញដំរីនោះហើយឈរលើប្រគាបឈើ ពោលគាថានេះថា

ឈើគ្រាំគ្រាដែលខ្យល់កាច់បំបាក់បាន ក្នុងព្រៃនោះ មានច្រើន
ម្នាលដំរី ប្រសិនបើអ្នកខ្លាចឈើនោះ អ្នកមុខជានឹងស្គមមិនខាន
ដូច្នេះ ។

ក្នុងគាថានោះ ប្រមូលអធិប្បាយដូច្នេះថា ខ្យល់ មានខ្យល់ទិសខាង កើតជាដើម រមែងកាច់បំបាក់ដើមឈើដែលទុព្វលណា ដើមឈើនោះមាន ច្រើនក្នុងព្រៃនេះ គឺរកបានងាយ មានក្នុងព្រៃនោះៗ បើអ្នកខ្លាចដើមឈើ នោះ កាលបើយ៉ាងនោះ ចាំបាច់ខ្លាចជានិច្ច នឹងត្រូវដល់នូវការអស់សាច់ និងឈាម អ្នកត្រូវស្ដាំងស្ដមដោយពិត តែក្នុងព្រៃនេះ មិនមានភ័យចំពោះ អ្នក ហេតុនោះ តាំងអំពីនេះតទៅ អ្នកកុំខ្លាចឡើយ ។

ទេវតាឲ្យឱវាទដំរីនោះ ដោយប្រការដូច្នេះ តាំងអំពីនោះមក ដំរីនោះ ក៏ បាត់ខ្លាច ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ ទាំងឡាយ កាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ ប្រជុំជាតកថា ដំរីក្នុងកាលនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ ឯ រុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ទុព្វលកដ្ឋជាតក ចប់**

# សុត្តន្តបិដក

## ឧទញ្ចនីជាតក

[ ១០៦ ] ( កូនតាបសពោធិសត្វពោលថា ) មេចោរជុតចម្អិនល្មោក ស៊ី ដូចជាកាជន៍ជងនូវទឹក រមែងសូមនូវប្រេងផង នូវអំបិលផង នឹងខ្ញុំដែលធ្លាប់រស់នៅជាសុខ ដោយសម្តីហាក់ដូចជាប្រពន្ធ ។

ឧទញ្ចនីជាតកទី ៦ ចប់

# អដ្ឋកថា

## ឧទញ្ចនីជាតក

[ ១០៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារិកា ( ក្រមុំចាស់ ) ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុខំ វត មំ ជីវន្តំ** ដូច្នេះជាដើម ។

រឿងជាក់ច្បាស់ក្នុងចូឡនារទកស្សបជាតក តេរសកនិបាតនោះឯង ។ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់សួរថា ចិត្តរបស់អ្នកប្រតិព័ទ្ធក្នុងអ្វី ទើបលោកទូលថា ក្នុងក្រមុំចាស់ម្នាក់ ។ គ្រានោះ ទើបព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនេះ ធ្វើការវិនាសឲ្យដល់អ្នក ក្នុងកាលមុន អ្នកអាស្រ័យកុមារិកានេះ ដល់នូវការសាបសូន្យចាកសីល ត្រាច់សោយសោក លុះតែអាស្រ័យបណ្ឌិត ទើបបានសេចក្តីសុខ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

រឿងក្នុងអតីត តាំងអំពីពាក្យថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសីជាដើម ក៏ជាក់ច្បាស់ក្នុងចូឡនារទ-កស្សបជាតកដូចគ្នា ។ ក្នុងកាលនោះ ព្រះពោធិសត្វកាន់ផល្លាផលមកក្នុងវេលាល្ងាច បើកទ្វារបណ្ណសាលាចូលទៅ បាននិយាយពាក្យនេះនឹងតាបសតូច ដែលជាកូនថា នែបា ក្នុងថ្ងៃដទៃៗ បាកាច់ឧស ដងទឹកទុក បង្កាត់ភ្លើងទុក តែថ្ងៃនេះ មិនធ្វើអ្វីមួយសោះ ហេតុអ្វី ទើបមានមុខស្រពោន អង្គុយសុបសៅ ។ តាបសតូចឆ្លើយថា បពិត្របិតា កាលបិតាទៅរកផល្លាផល ស្រី

ម្នាក់មកហើយ លួងលោមខ្ញុំឲ្យទៅជាមួយ តែខ្ញុំពន្យាថា លុះណាតែឪពុករបស់ខ្ញុំអនុញ្ញាតហើយ ទើបខ្ញុំទៅ ក៏មិនបានទៅ ខ្ញុំឲ្យនាងអង្គុយចាំក្នុងទីឈ្មោះនោះ ហើយត្រឡប់មក ឥឡូវនេះ ខ្ញុំនឹងទៅ ។ ព្រះពោធិសត្វដឹងថា អាត្មាអញមិនអាចឃាត់បុត្រនេះបាន ទើបអនុញ្ញាត ដោយប្រាប់ថា បើដូច្នោះ ចូរបាទៅចុះ តែបើទៅហើយ កាលណា ស្រីនោះចង់ស៊ីត្រី ស៊ីសាច់ ឬត្រូវការសប្បិ អំបិល និងអង្ករជាដើម កាលនោះ នាងនឹងរំអុកថា ចូរទៅរកវត្ថុនេះៗ មកឲ្យ ក្នុងពេលនោះ ចូរឯងនឹកដល់គុណរបស់ឪពុក ហើយគប្បីរត់មកទីនេះចុះ ។ តាបសបានទៅកាន់ដែនដីមនុស្សជាមួយនាង កាលនោះ នាងក៏ឲ្យតាបសធ្លាក់ក្នុងអំណាចរបស់ខ្លួន ត្រូវការវត្ថុណាមួយ ក៏ប្រើឲ្យទៅរកវត្ថុនោះមក ដូចជាប្រើឲ្យរកសាច់ រកត្រី គ្រានោះ បុរសនោះ បានគិតថា ស្រីនោះរំអុកឲ្យអញ ធ្វើអញឲ្យដូចជាទាសកម្មកររបស់ខ្លួន ហើយរត់មកកាន់សម្នាក់របស់បិតា ថ្វាយបង្គំតាបសហើយ ឈរពោលគាថានេះថា

មេចោរដុតចម្អិន ល្មោកស៊ី ដូចជាភាជន៍ដងនូវទឹក រមែងសូមនូវប្រេងផង នូវអំបិលផង នឹងខ្ញុំដែលធ្លាប់រស់នៅជាសុខ ដោយសម្ដីហាក់ដូចជាប្រពន្ធ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខំ វត មំ ជីវន្តំ** សេចក្ដីថា បពិត្រលោកឪពុក ស្រីនោះធ្វើខ្ញុំដែលធ្លាប់នៅជាសុខក្នុងសម្នាក់ឪពុកឲ្យក្ដៅក្រហាយ ។

បទថា **បចមានា** សេចក្ដីថា ត្រូវស្រីនោះធ្វើឲ្យក្ដៅក្រហាយ ប្រើខ្ញុំដោយត្រូវការបរិភោគវត្ថុណាៗ ក៏ទារយកវត្ថុនោះៗ ស្រី ឈ្មោះថា **ឧឧញ្ញនី**

ព្រោះនាំទៅដោយក្អម ។ បទថា **ឧទញ្ចនី** នេះ ជាឈ្មោះរបស់ស្រីដែលដងទឹកអំពីពាង ឬអំពីអណ្តូង ស្រីប្រភេទឧទញ្ចនីនោះ ត្រូវការរបស់ណាមួយ ក៏ប្រើឲ្យរករបស់នោះៗ ទាល់តែបាន ដូចដងយកទឹកដោយក្អម ។ បទថា **ចោរី ជាយបុវាទេន** សេចក្តីថា ស្រីលួងម្នាក់ ដោយឈ្មោះថាជាភរិយា លួងលោមខ្ញុំ ដោយពាក្យពីរោះ នាំខ្ញុំទៅក្នុងទឹកដីមនុស្ស ស្រីនោះត្រូវការប្រេង ឬអំបិលណាមួយ ក៏រំអុកទាររបស់នោះៗ គ្រប់យ៉ាង ឲ្យនាំមកឲ្យ ដូចជាទាសៈ ដូចកម្មករ ហេតុនោះ ទើបខ្ញុំពោលទោសរបស់នាង ។

គ្រានោះ ព្រះពោធិសត្វក៏លួងលោមតាបសតូចនោះថា ណ្ហើយចុះ បា មក ចូរអ្នកចម្រើនមេត្តា ករុណាចុះ ហើយប្រាប់ព្រហ្មវិហារ៤ ប្រាប់កសិណបរិកម្ម មិនយូរប៉ុន្មាន តាបសតូចនោះ ក៏ញុំាងអភិញ្ញា និងសមាបត្តិឲ្យកើត បានចម្រើនព្រហ្មវិហារ ហើយទៅកើតក្នុងព្រហ្មលោក មួយអន្លើដោយបិតា ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ទ្រង់ប្រជុំជាតកថា ចុល្លកុមារិកាក្នុងកាលនោះ បានមកជាចុល្លកុមារិកា ក្នុងកាលឥឡូវនេះ ចូឡតាបសក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ឯតាបសជាបិតាក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ឧទញ្ចនីជាតក ចប់**

# សុត្តន្តបិដក

## សាលិត្តកជាតក

[ ១០៧ ] ( អាមាត្យពោធិសត្វពោលថា ) ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចប្រយោជន៍ សូមព្រះអង្គទតស្រុកស្លួយទាំង ៤ ទិស ដែលបុរសខ្វិនបានហើយ ដោយការផ្ទាត់ ( អាចម៍ពពែ ) នៃបុរសខ្វិន ។

*សាលិត្តកជាតកទី ៧ ចប់*

# អដ្ឋកថា

## សាលិត្តកជាតក

[ ១០៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុសម្លាប់ហង្ស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សាធុ ខោ សិប្បកំ នាម** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាកុលបុត្រអ្នកក្រុងសាវត្ថី ដល់នូវការសម្រេចក្នុងសាលិត្តកសិប្បៈ ។ ដែលហៅថា **សាលិត្តកសិប្បៈ** បានដល់ វិជ្ជាក្នុងការផ្ទាត់គ្រាប់ក្រួស ។ ថ្ងៃមួយ គាត់ស្ដាប់ធម៌ ហើយបួសថ្វាយជីវិតក្នុងព្រះសាសនា បានឧបសម្បទាហើយ តែជាអ្នកមិនប្រាថ្នាក្នុងការសិក្សា មិនបានជាអ្នកញ៉ាំងកិច្ចបដិបត្តិឲ្យសម្រេច ។ ថ្ងៃមួយ បបួលភិក្ខុកំលោះមួយរូប ទៅកាន់ស្ទឹងអចិរវតី ងូតទឹកហើយ នាំគ្នាសម្រាកត្រង់ឆ្នេរស្ទឹង ។ គ្រានោះ ហង្សស ២ ក្បាល នាំគ្នាហើរមកតាមអាកាស ទើបលោកពោលនឹងភិក្ខុកំលោះនោះថា ខ្ញុំនឹងយកដុំក្រួសប្រហារហង្សខាងក្រោយនោះត្រង់ភ្នែក ឲ្យធ្លាក់ចុះទៀបជើងលោក ភិក្ខុមួយរូបទៀតពោលថា លោកធ្វើឲ្យវាធ្លាក់បានដូចម្ដេច លោកមិនអាចប្រហារវាបានទេ ។ លោកពោលថា រឿងនោះ ទុកមួយអន្លើចុះ ខ្ញុំនឹងប្រហារវាត្រង់ភ្នែកខាងនោះឲ្យធ្លុះទៅភ្នែកខាងនេះ ភិក្ខុនោះប្រកែកថា ពេលនេះ លោកនិយាយមិនពិត ភិក្ខុនោះប្រាប់ថា បើដូច្នោះ លោកចាំមើល ហើយចាប់យកដុំក្រួសមួយដុំ ប្រមៀលដោយម្រាមដៃ ផ្ទាត់ទៅអំពីក្រោយហង្សនោះ ដុំក្រួសនោះ ជ្រែកខ្យល់លាន់សំឡេង ហឺ ហឺ ហង្សគិតថា ប្រហែលជាមានអន្តរាយ ងាកមកបំណងនឹងស្ដាប់សំឡេង ភិក្ខុ

នោះក៏កាន់ដុំក្រួសមួយដុំទៀត ខណៈនោះ កាលហង្សងាកមកមើល ក៏ផ្ទាត់ទៅចំភ្នែកម្ខាងធ្លុះដល់ភ្នែកម្ខាងទៀត ហង្សស្រែកតាមសំឡេងរបស់ខ្លួន ធ្លាក់ចុះមកក្បែរជើងមួយរំពេច ពួកភិក្ខុមកអំពីទីនោះៗ នាំគ្នាតិះដៀល ពោលថា លោកធ្វើមិនសមគួរឡើយ ហើយនាំទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះ ធ្វើកម្មឈ្មោះនេះ ព្រះសាស្តាទ្រង់តិះដៀលភិក្ខុនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះ ឈ្លាសក្នុងសិប្បៈនោះ សូម្បីក្នុងកាលមុន ក៏ជាអ្នកឈ្លាសហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអមាត្យរបស់ព្រះរាជាអង្គនោះ ។ កាលនោះ បុរោហិតរបស់ព្រះរាជា ជាអ្នកមាត់រឹងពន់ពេក ចូលចិត្តនិយាយច្រើន កាលខ្លួននិយាយហើយ អ្នកដទៃមិនមានឱកាសបាននិយាយឡើយ ឯព្រះរាជាទ្រង់ព្រះតម្រិះថា កាលណាហ្ន៎ អញនឹងបានបុគ្គលណាម្នាក់ ផ្តាច់ពាក្យរបស់បុរោហិតនេះបាន ។ តាំងអំពីនោះមក ព្រះរាជាទ្រង់ពិចារណារកមនុស្សយ៉ាងនេះណាម្នាក់ ។ កាលនោះ ក្នុងនគរពារាណសី មានបុរសកង្វិនម្នាក់ ដល់នូវការសម្រេចក្នុងសិប្បៈ គឺការផ្ទាត់ដុំក្រួស ពួកក្មេងអ្នកស្រុកលើកគាត់ឡើងកាន់រទេះ ហើយអូសមកដាក់ត្រង់គល់ជ្រៃធំ សម្បូរដោយប្រគាបមួយដើម ក្បែរទ្វារនគរពារាណសី នាំគ្នាចោមរោមឲ្យប្រាក់ មានកាក-

ណិកជាដើម សំណូមពរថា សូមលោកធ្វើរូបដីរ៍ រូបសេះ គាត់ក៏ផ្ចាត់គ្រាប់ក្រួស ធ្វើជារូបផ្សេងៗ ត្រង់ស្លឹកជ្រៃទាំងឡាយ ក្នុងស្លឹកជ្រៃទាំងអស់សុទ្ធតែមានប្រហោងតូចប្រហោងធំ ។ គ្រានោះ ព្រះបាទពារាណសី យាងមកកាន់ព្រះរាជឧទ្យាន ដល់ទីនោះ ពួកក្មេងទាំងអស់នាំគ្នារត់ទៅ ព្រោះខ្លាចត្រូវបណ្តេញ បុរសខ្វិនដេកក្នុងទីនោះឯង ។ ព្រះរាជាយាងដល់គល់ជ្រៃ ប្រថាប់គង់ក្នុងព្រះរាជរថនោះឯង ទតឃើញស្រមោលផ្សេងៗ ក្នុងស្លឹកឈើទាំងឡាយ ដែលដាច់ជាប្រហោង ក៏ទ្រង់ទតមើល លុះឃើញស្លឹកឈើទាំងពួងធ្លុះទាំងអស់ ក៏ត្រាស់សួរថា ស្លឹកឈើទាំងនេះ អ្នកណាធ្វើឲ្យទៅជាយ៉ាងនេះ ។ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសខ្វិនធ្វើក្រាបទូល ព្រះរាជាទ្រង់ត្រិះរិះថា អាស្រ័យបុរសនេះ អញអាចកាត់ផ្តាច់នូវពាក្យរបស់ព្រាហ្មណ៍បាន ទើបត្រាស់សួរថា នែអ្នក បុរសនោះនៅឯណា ពួករាជបុរសដើររកក៏ឃើញដេកត្រង់គល់ឈើ នាំគ្នានាំខ្លួនមក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នេះបុរសខ្វិន ព្រះរាជាត្រាស់ឲ្យចូលគាល់ ហើយទ្រង់ដេញបរិស័ទទៅអស់ ត្រាស់សួរថា ក្នុងសម្នាក់របស់យើង មានព្រាហ្មណ៍មាត់រឹងម្នាក់ឯងអាចធ្វើឲ្យព្រាហ្មណ៍នោះស្ងាត់សំឡេងបានដែរឬទេ បុរសខ្វិនក្រាបទូលថា បើបានមូលពពែមួយនាឡិ ទូលបង្គំអាចធ្វើបាន ។ ព្រះរាជាប្រាប់ឲ្យរាជបុរសនាំបុរសខ្វិន ចូលទៅកាន់ព្រះរាជវាំង ឲ្យអង្គុយក្នុងវាំងនន ចោះប្រហោងត្រង់វាំងនន ឲ្យរៀបចំទីអង្គុយរបស់ព្រាហ្មណ៍ត្រង់ប្រហោង ហើយឲ្យដាក់អាចម៍ពពែក្រៀមប្រមាណមួយនាឡិក្បែរបុរសខ្វិន ។ កាលព្រាហ្មណ៍មកគាល់

ក៏ឲ្យអង្គុយលើអាសនៈនោះ ទ្រង់ផ្ដើមសន្ទនាឡើង ។ ព្រាហ្មណ៍មិនព្រមឲ្យឱកាសដល់អ្នកដទៃៗ ផ្ដើមក្រាបទូលដល់ព្រះរាជា ។ កាលនោះ បុរសខ្វិនក៏ផ្ទាត់អាចម៍ពពែម្ដងមួយៗ តាមប្រហោងវាំងនន ឲ្យចូលដល់ពិតានរបស់ព្រាហ្មណ៍ ដូចបោះដាក់ក្នុងកំប្រោង ដូច្នោះ ព្រាហ្មណ៍លេបអាចម៍ពពែដែលផ្ទាត់មកហើយ ដូចតម្រងប្រេងដែលចាក់ក្នុងនាឡិ ។ អាចម៍ពពែដល់នូវការអស់ទៅមួយនាឡិ អាចម៍ពពែប្រមាណមួយនាឡិនោះ ចូលក្នុងពោះរបស់ព្រាហ្មណ៍ប្រមាណកន្លះអាឡ្ហក ព្រះរាជាទ្រង់ជ្រាបភាពដែលអាចម៍ពពែអស់ហើយ ទើបត្រាស់ថា លោកអាចារ្យ លោកលេបអាចម៍ពពែអស់ទាំងនាឡិ ព្រោះជាអ្នកសម្ដីច្រើន លោកនៅតែមិនដឹងអ្វីឡើយ ឥឡូវនេះ លោកមិនអាចឲ្យអាចម៍ពពែច្រើនជាងនេះ រលួយបានទេ ទៅចុះ ចូរផឹកទឹកបយង្គុ បញ្ចុះចេញ ធ្វើខ្លួនឲ្យប្រាសចាករោគចុះ ។ តាំងអំពីពេលនោះ ព្រាហ្មណ៍ហាក់ដូចមានមាត់ត្រូវបិទជិត ទោះបីអ្នកណាពោល ក៏មិនសូវនិយាយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បុរសនេះ ធ្វើនូវការសប្បាយត្រចៀកឲ្យដល់អញ ព្រះរាជទានស្រុក ៤ ក្នុងទិសទាំង ៤ មានសួយប្រមាណមួយសែនកហាបណៈ ។ ព្រះពោធិសត្វចូលគាល់ព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព ធម្មតាសិប្បៈក្នុងលោក បណ្ឌិតទាំងឡាយគប្បីរៀន សូម្បីត្រឹមតែផ្ទាត់គ្រាប់ក្រួស ក៏គង់ជួយឲ្យបុរសខ្វិនបានសម្បត្តិនេះ ហើយពោលគាថានេះថា

ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចប្រយោជន៍
សូមព្រះអង្គទតស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបានហើយ

ដោយការផ្ទាត់ ( អាចម៍ពពែ ) នៃបុរសខ្វិន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បស្ស ខញ្ជប្បហារេន** សេចក្ដីថា ព្រះពោធិសត្វពោលសរសើរគុណនៃសិប្បៈថា បពិត្រមហារាជ សូមទ្រង់ទតចុះ បុរសខ្វិននេះបានទទួលព្រះរាជទានស្រុក ៤ ក្នុងទិសទាំង ៤ ដោយការផ្ទាត់អាចម៍ពពែ តើមានអ្វីដែលរាប់រាំងអានិសង្សនៃសិប្បៈដទៃៗ នោះ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រជុំជាតកថា បុរសខ្វិនក្នុងកាលនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯអមាត្យជាបណ្ឌិត គឺតថាគតនេះឯង ។

**អដ្ឋកថា សាលិត្តកជាតក ចប់**

# សុត្តន្តបិដក

## ពាហិយជាតក

[ ១០៨ ] ( អាមាត្យពោធិសត្វពោលថា ) ជនគប្បីសិក្សានូវកិច្ច ដែលត្រូវសិក្សា ពួកជន រមែងមានសេចក្តីពេញចិត្តក្នុងកិច្ចនោះ ចំណែក ស្រីអ្នកស្រុកពាហិយៈ បានញុំាងព្រះរាជាឲ្យត្រេកអរ ដោយការខ្មាសអៀន ( របស់ខ្លួន ) ។

*ពាហិយជាតកទី ៨ ចប់*

# អដ្ឋកថា

## ពាហិយជាតក

[ ១០៨ ] ព្រះសាស្តា កាលទ្រង់អាស្រ័យនគរវេសាលី គង់នៅក្នុងកូដាគារសាលានាព្រៃមហាវ័ន ទ្រង់ប្រារព្ធស្តេចលិច្ឆវីមួយអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សិក្ខេយ្យ សិក្ខិតព្វានិ** ដូច្នេះជាដើម ។

បានឮថា ស្តេចលិច្ឆវីអង្គនោះ ទ្រង់មានសទ្ធាជ្រះថ្លា និមន្តភិក្ខុ មានព្រះសម្ពុទ្ធជាប្រធាន ទ្រង់ញុំាងមហាទានឲ្យប្រព្រឹត្តទៅក្នុងវាំងរបស់ព្រះអង្គ តែទេវីរបស់ទ្រង់ មានអវយវៈធាត់គ្រប់ចំណែក ដូចគ្នានឹងនិមិត្តសាកសពដែលហើមប៉ោង មិនសម្បូរដោយមារយាទ ព្រះសាស្តាទ្រង់ធ្វើអនុមោទនា ក្នុងកាលស្រេចភត្តកិច្ចហើយ យាងទៅព្រះវិហារ ប្រទានឱវាទដល់ភិក្ខុទាំងឡាយ ទ្រង់ចូលព្រះគន្ធកុដិ ភិក្ខុទាំងឡាយនាំគ្នាផ្តើមសន្ទនាក្នុងរោងធម្មសភាថា នែអាវុសោទាំងឡាយ ស្តេចលិច្ឆវីអង្គនោះ មានព្រះរូបល្អបែបនេះ តែមានព្រះទេវីមានលក្ខណៈផ្ទុយគ្នា មានអវយវៈតូច-ធំថ្លោស មិនមានកិរិយាមារយាទ ព្រះរាជាទ្រង់អភិរមជាមួយព្រះទេវីបានដូចម្តេច ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្តេចលិច្ឆវីអង្គនេះ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ទ្រង់អភិរមជាមួយស្រីដែលមានរាងកាយធាត់ដូចគ្នា ហើយទ្រង់បាននាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអមាត្យរបស់ព្រះរាជាអង្គនោះ ។ គ្រានោះ ស្រីជនបទម្នាក់ មានអវយវៈធំ មិនមានកិរិយាមារយាទ ធ្វើការស៊ីឈ្នួល ដើរចូលមិនឆ្ងាយអំពីលានព្រះរាជវាំង ឈឺបន្ទោបង់ឧច្ចារៈ ក៏យកសំពត់ស្លៀកដណ្តប់សរីរៈ អង្គុយបន្ទោបង់ឧច្ចារៈ ហើយប្រញាប់ក្រោកឡើង ខណៈនោះ ព្រះបាទពារាណសីទតត្រង់លានរាជវាំងតាមមាត់បង្អួច ទ្រង់ឃើញហើយ ទ្រង់ត្រិះរិះថា ស្រីនេះបន្ទោបង់ឧច្ចារៈត្រង់លានព្រះរាជវាំងយ៉ាងនេះ មិនបានលះហិរិឱត្តប្បៈ យកសំពត់នោះឯងបិទបាំង បន្ទោបង់ឧច្ចារៈហើយ ប្រញាប់ក្រោកឡើង ប្រហែលនាងជាស្រីមិនមានរោគ វត្ថុរបស់នាងត្រូវបរិសុទ្ធ កូនម្នាក់ដែលបានក្នុងវត្ថុបរិសុទ្ធ នឹងជាសត្វបរិសុទ្ធ ជាសត្វមានបុណ្យ អញគួរតាំងនាងជាអគ្គមហេសី ។ ព្រះរាជាទ្រង់ជ្រាបភាពដែលនាងមិនទាន់មានគូគ្រង ក៏ព្រះរាជទានតំណែងជាអគ្គមហេសី នាងបានជាទីប្រោសប្រាណ គាប់ព្រះហឫទ័យរបស់ព្រះរាជា មិនយូរប៉ុន្មាន ប្រសូតព្រះឱរសមួយអង្គ ហើយឱរសរបស់ព្រះនាង ក៏បានជាស្តេចចក្រពត្តិ ព្រះពោធិសត្វឃើញនូវការដល់ព្រមដោយយសរបស់ព្រះនាង បានឱកាស ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព សិប្បៈ គួរសិក្សា ហេតុអ្វី មិនគួរសិក្សា តែព្រះមហេសីជាអ្នកមានបុណ្យអង្គនេះ មិនលះហិរិឱត្តប្បៈ ព្រះនាងធ្វើឧច្ចារៈដោយអាការបិទបាំង ធ្វើឲ្យទ្រង់ប្រោសប្រាណ ព្រះនាងដល់នូវសម្បត្តិបែបនេះ បានកាលក្រាបទូលគុណនៃសិប្បៈ ដែលគួរសិក្សាទាំងឡាយ ទើប

ពោលគាថានេះថា

ជនគប្បីសិក្សានូវកិច្ច ដែលត្រូវសិក្សា ពួកជន រមែងមានសេចក្តីពេញចិត្តក្នុងកិច្ចនោះ ចំណែកស្រីអ្នកស្រុកពាហិយៈ បានញ៉ាំងព្រះរាជាឲ្យត្រេកអរ ដោយការខ្មាសអៀន ( របស់ខ្លួន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តិ តច្ឆន្ទិនោ** សេចក្តីថា ពពួកជនដែលមានការពេញចិត្តក្នុងសិប្បៈទាំងនោះ គង់មានពិតប្រាកដ ។

បទថា **ពាហិយា** បានដល់ ស្រីដែលកើតធំធាត់ក្នុងជនបទខាងក្រៅ ។

បទថា **សុហន្នេន** សេចក្តីថា មិនលះហិរិឱត្តប្បៈ បន្ទោបង់ដោយអាការដែលបិទបាំង ឈ្មោះថា អាការដែលអៀនខ្មាស បន្ទោបង់ដោយអាការអៀនខ្មាសនោះ ។

បទថា **រាជានំ អភិរាធយិ** សេចក្តីថា គង់ធ្វើឲ្យព្រះសម្មតិទេពទ្រង់ប្រោសប្រាណ ដល់នូវសម្បត្តិនេះបាន ។

ព្រះពោធិសត្វពោលគុណរបស់សិប្បៈទាំងឡាយដែលសមគួរ ដល់គុណរបស់ការសិក្សា ដោយប្រការដូច្នេះ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជា និងអគ្គមហេសីក្នុងកាលនោះ បានមកជាព្រះរាជា និងអគ្គមហេសីក្នុងកាលឥឡូវនេះ ឯអមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ពាហិយជាតក ចប់**

# សុត្តន្តបិដក

## កុណ្ឌកបូវជាតក

[ ១០៩ ] ( *រុក្ខទេវតាពោធិសត្វពោលថា* ) *បុរសស៊ីយ៉ាងណា ទេវតារបស់បុរសនោះ ក៏ស៊ីយ៉ាងនោះដែរ អ្នកចូរនាំយកនូវនំកុណ្ឌកនោះមក អ្នកកុំញុំាងនំកុណ្ឌក ជាចំណែករបស់ខ្ញុំ ឲ្យវិនាសទៅ ។*

***កុណ្ឌកបូវជាតកទី ៩ ចប់***

# អដ្ឋកថា

## កុណ្ឌកបូវជាតក

[ ១០៩ ] ព្រះសាស្ដា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធបុរសទុគ៌តម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យថន្នោ បុរិសោ ហោតិ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងនគរសាវត្ថី ជួនកាល ត្រឹមតែមួយត្រកូលប៉ុណ្ណោះ ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ជួនកាល ៣-៤ ត្រកូលរួមគ្នា ជួនកាល រួមគ្នាជាគណៈ ជួនកាល រួមគ្នាជាវិថី ជួនកាល រួមបុគ្គលដែលមានធនុះទាំងនគរ ថ្វាយទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងកាលនោះ មានភត្ត ដែលឈ្មោះថា វិថីភត្តបានកើតឡើង ។ កាលនោះ ពួកមនុស្សប្រឹបួលគ្នាថា សូមលោកទាំងឡាយថ្វាយបបរ សូមនាំរបស់ទំពាមកថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានចុះ ។ ក្នុងកាលនោះ មានកូនឈ្នួលរបស់អ្នកដទៃម្នាក់ ជាអ្នកក្រីក្រនៅក្នុងវិថីនោះ គិតថា អញមិនអាចថ្វាយបបរបាន របស់ទំពាអាចថ្វាយបាន ហើយពូតកន្ទក់ម៉ដ្ឋ ដែលផ្សើមដោយទឹក ខ្ចប់ដោយស្លឹករាក់ ដុតលើរងើកភ្លើង គិតថា អញនឹងថ្វាយនំនេះដល់ព្រះពុទ្ធ កាន់នំនោះទៅឈរក្នុងសម្នាក់ព្រះសាស្ដាៗ ត្រាស់ថា ចូរពួកអ្នកនាំរបស់ទំពាមកចុះ ក៏ទៅមុនមនុស្សទាំងពួង ដាក់នំនោះក្នុងបាត្ររបស់ព្រះសាស្ដា ហើយឈរ ព្រះសាស្ដាទ្រង់មិនទទួលរបស់ទំពា ដែលអ្នកដទៃថ្វាយ ទ្រង់សោយរបស់ទំពា គឺនំនោះប៉ុណ្ណោះ ។

ក្នុងខណៈនោះ ផ្ទៃនគរទាំងមូល មានសំឡេងលាន់ឮទៅថា បានឮថា

ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនរង្កៀសរបស់ទំពាំដែលធ្វើដោយកន្ទក់របស់មហាទុគ្គតបុរស ទ្រង់សោយដូចសោយអមតភោជន ដូច្នោះ ឥស្សរជន មានព្រះរាជា និងអមាត្យនៃព្រះរាជាជាដើម ដោយហោច សូម្បីអ្នកយាមទ្វារក៏ប្រជុំគ្នាទាំងអស់ ថ្វាយបង្គំព្រះសាស្តាហើយ ចូលទៅរកមហាទុគ្គតបុរស នាំគ្នាពោលថា នែបា ចូរបាយកទ្រព្យមួយរយ ពីររយ ប្រាំរយ ហើយឲ្យចំណែកបុណ្យដល់ពួកយើងចុះ ។ មហាទុគ្គតឆ្លើយថា ចាំខ្ញុំទូលសួរព្រះសាស្តាហើយនឹងដឹង ទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលសេចក្តីនោះ ព្រះសាស្តាត្រាស់ថា ចូរអ្នកទទួលទ្រព្យ ហើយឲ្យចំណែកបុណ្យដល់សព្វសត្វចុះ ។ មហាទុគ្គតទទួលទ្រព្យ ដែលពួកមនុស្សនាំគ្នាឲ្យ ដោយប្រមូលជាទ្វេគុណ ចតុគុណ អដ្ឋគុណជាដើម បានទ្រព្យ ៩ កោដិ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ យាងទៅវិហារ កាលពួកមនុស្សសម្តែងវត្តបដិបត្តិថ្វាយហើយ ប្រទានព្រះសុគតោវាទ ទ្រង់យាងចូលព្រះគន្ធកុដិ វេលាល្ងាចថ្ងៃនោះ ព្រះរាជាត្រាស់ឲ្យហៅមហាទុគ្គតបុរសចូលគាល់ ទ្រង់បូជាដោយតំណែងសេដ្ឋី ។ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មិនរង្កៀសទំកន្ទក់ ដែលមហាទុគ្គតបុរសថ្វាយឡើយ ទ្រង់សោយដូចអមតភោជន ឯមហាទុគ្គតបុរសសោតបានទាំងទ្រព្យជាច្រើន បានទាំងតំណែងសេដ្ឋី ដល់នូវសម្បត្តិដ៏ធំក្រៃលែងហើយ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន

ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតមិនរង្កៀស បរិភោគនំកន្ទក់របស់បុរសនេះ សូម្បីកាលនៅជារុក្ខទេវតា ក៏ធ្លាប់បរិភោគដូចគ្នា ក្នុងកាលនោះ បុរសអ្នកអាស្រ័យតថាគត ក៏បានតំណែងសេដ្ឋីដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាទេវតា អាស្រ័យដើមល្ហុងមួយដើម ។ គ្រានោះ ពួកមនុស្សក្នុងស្រុកនោះ នាំគ្នាគោរពរុក្ខទេវតាជាមង្គលកាលដល់បុណ្យនក្ខត្តឫក្សមួយ ពួកមនុស្សធ្វើពលិកម្មដល់ទេវតារៀងៗ ខ្លួន កាលនោះ មានមនុស្សទុគ៌តម្នាក់ ឃើញមនុស្សទាំងនោះ នាំគ្នាបដិបត្តិរុក្ខ-ទេវតា ក៏បដិបត្តិដើមល្ហុងមួយដើម មនុស្សទាំងឡាយនាំគ្នាកាន់យកផ្កាឈើគ្រឿងក្រអូប គ្រឿងលាប របស់ទំពា របស់បរិភោគជាដើម ច្រើនប្រការទៅដើម្បីបូជាទេវតាទាំងឡាយរបស់ខ្លួន ឯបុរសនោះ មានតែនំកន្ទក់ កាន់ទៅមួយអន្ទើដោយត្រឡោកទឹក ឈរមិនឆ្ងាយអំពីដើមល្ហុង គិតថា ធម្មតាទេវតារមែងសោយតែរបស់ទំពាដែលជាទិព្វ ទេវតាគង់មិនសោយនំកន្ទក់របស់អញឡើយ អញឲ្យនំនេះវិនាសទៅដោយហេតុនេះធ្វើអ្វី អញនឹងស៊ីនំនេះឯងហើយក៏ត្រឡប់ទៅអំពីទីនោះវិញ ព្រះពោធិសត្វស្ថិតនៅលើប្រគាបពោលថា បុរសដ៏ចម្រើន បើអ្នកជាអ្នកធំ ក៏ត្រូវឲ្យរបស់ទំពាដែលឆ្ងាញ់ដល់យើង តែអ្នកជាទុគ្គត បើខ្ញុំមិនបរិភោគរបស់អ្នកហើយ តើនឹងបរិភោគនំដទៃបានដូច

ម្តេច កុំឲ្យចំណែករបស់យើងវិនាសទៅឡើយ ហើយពោលគាថានេះថា

បុរសស៊ីយ៉ាងណា ទេវតារបស់បុរសនោះ ក៏ស៊ីយ៉ាងនោះដែរ អ្នកចូរនាំយកនូវនំកុណ្ឌកនោះមក អ្នកកុំញ៉ាំងនំកុណ្ឌក ជាចំណែករបស់ខ្ញុំ ឲ្យវិនាសទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថន្នោ** សេចក្តីថា មនុស្សបម្រើបរិភោគយ៉ាងណា ។

បទថា **តថន្នា** សេចក្តីថា ទេវតារបស់មនុស្សនោះ ក៏បរិភោគយ៉ាងនោះដូចគ្នា ។

បទថា **អាហរេតំ កណ្ឌបូវំ** សេចក្តីថា ចូរអ្នកនាំយកនំដែលធ្វើដោយកន្ទក់នោះមកចុះ កុំទម្លាយចំណែកដែលបានរបស់យើងចោលឡើយ ។

បុរសនោះ បែរសម្លឹងមើលព្រះពោធិសត្វ ហើយធ្វើពលីកម្ម ព្រះពោធិសត្វក៏បរិភោគឱជាអំពីនំនោះ ហើយពោលថា នែបុរស អ្នកបដិបត្តិយើងត្រូវការអ្វី បុរសនោះពោលថា បពិត្រលោកជាធំ ខ្ញុំជាមនុស្សក្រីក្រមកប្រណិប័តន៍ដោយបំណងថា នឹងអាស្រ័យលោកហើយ ផុតចាកភាពក្រីក្រ ។ ព្រះពោធិសត្វពោលថា នែបុរសដ៏ចម្រើន អ្នកកុំគិតអ្វីឡើយ អ្នកធ្វើការបូជាយើង ដែលជាអ្នកមានកតញ្ញូកតវេទី ក្បែរដើមល្ហុងនេះ មានថ្នាំងកំណប់ទ្រព្យតម្កល់តម្រៀបគ្នាពេញស្មើកណ្តាប់មាត់ ចូរអ្នកទូលព្រះរាជាយករទេះមកដឹកនាំទ្រព្យ គរនៅក្នុងលានព្រះរាជវាំង ព្រះរាជានឹងត្រេកអរប្រទានតំណែងសេដ្ឋីដល់អ្នក ។ លុះប្រាប់ហើយ ព្រះពោធិសត្វក៏អន្តរធាន

ទៅ គាត់ក៏បានធ្វើតាមនោះ សូម្បីព្រះរាជាក៏ប្រទានតំណែងសេដ្ឋីដល់គាត់ ។ បុរសនោះ អាស្រ័យព្រះពោធិសត្វ ដល់នូវសម្បត្តិដ៏ធំ ហើយទៅតាមយថាកម្ម ដោយប្រការដូច្នេះ ។

ព្រះសាស្តា នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ទុគ្គតបុរសក្នុងកាលនោះ បានមកជាទុគ្គតបុរសក្នុងកាលឥឡូវនេះ ដូច្នេះ ឯទេវតាដែលអាស្រ័យត្រង់ដើមល្ហុងក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា កុណ្ឌកបូវជាតក ចប់**

# សុត្តន្តបិដក

## សព្វសំហារកបញ្ហា

[ ១១០ ] គ្រឿងអប់ទាំងពួងគ្មានទេ សុទ្ធតែផ្កាប្រយង្គុទេតើ បក់ផ្សាយទៅ ( នោះ ) ឯស្ត្រីអ្នកលេង រមែងពោលពាក្យមិនពិត ស្ត្រីចាស់ ទើបបានពោលពាក្យពិត ។

សព្វសំហារកបញ្ហាទី ១០ ចប់

បរោសតវគ្គទី ១១ ចប់

### ឧទ្ទាននៃបរោសតវគ្គនោះ គឺ

និយាយអំពីបុគ្គលជាងមួយរយ ១ បុគ្គលជាទីពឹង ១ បុគ្គលមានពៀរ ១ ចក្រវិល ១ ដីរប្រសើរ ១ រស់នៅជាសុខ ១ សិល្បៈ ១ ស្រីអ្នកស្រុកពាហិយៈ ១ នំកុណ្ឌក ១ ស្រីចាស់ ១ ត្រូវជា ១០ ។

# អដ្ឋកថា

## សព្វសំហារកបញ្ហជាតក

[ ១១០ ] *បញ្ហាក្នុងរឿងគ្រឿងប្រដាប់ អប់ដោយក្លិនប្រអូបគ្រប់យ៉ាង មានពាក្យផ្ដើមថា* **សព្វសំហារកោ** **ណត្ថិ** *ដូច្នេះ ជាក់ច្បាស់ដោយអាការទាំងពួង ក្នុងឧម្មង្គជាតក ( មហោសធជាតក ) ។*

**អដ្ឋកថា សព្វសំហារកបញ្ហជាតក ចប់**

**បរោសតវគ្គ ចប់**

# សុត្តន្តបិដក
# ហំសិវគ្គ

## គទ្រភបញ្ហា

[ ១១១ ] បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គរីករាយ រមែងសម្គាល់ថា បិតាប្រសើរជាងកូនយ៉ាងនេះ បើដូច្នោះ មានតែសត្វលារបស់ព្រះអង្គនេះ ប្រសើរជាងសេះអស្សតរ ព្រោះសត្វលាជាបានៃសេះអស្សតរ ។

គទ្រភបញ្ហាទី ១ ចប់

# អដ្ឋកថា

# ហំសិវគ្គ

## គទ្រភបញ្ហជាតក

[ ១១១ ] *គទ្រភបញ្ហានេះ មានពាក្យផ្ដើមថា* **ហំសិ តុវំ ឯវំ មញ្ញសិ** *ដូច្នេះជាដើម ។ នឹងជាក់ច្បាស់ក្នុងឧម្មង្គជាតកដូចគ្នា ។*

**អដ្ឋកថា គទ្រភបញ្ហជាតក ចប់**

# សុត្តន្តបិដក

## អមរាទេវិបញ្ហា

[ ១១២ ] ( បពិត្រអ្នកម្ចាស់ ) រានផ្សារដែលគេលក់សដូវ និងម្ជូរ និងដើមរល្អួសមានស្លឹក ២ ជាន់ មាននៅក្នុងទិសាភាគណា ខ្ញុំកាន់បបរដោយដៃណា ខ្ញុំម្ចាស់ប្រាប់ផ្លូវដោយដៃនោះ ខ្ញុំមិនបានកាន់បបរដោយដៃណា ខ្ញុំមិនប្រាប់ផ្លូវដោយដៃនោះទេ ទិសាភាគនុ៎ះឯងហើយ ជាផ្លូវនៃយាវមជ្ឈគ្រាម អ្នកចូរដឹងផ្លូវដ៏កំបាំងនោះចុះ ។

**អមរាទេវិបញ្ហាទី ២ ចប់**

# អដ្ឋកថា

## អមរាទេវិបញ្ហជាតក

[ ១១២ ] *អមរាទេវិបញ្ហានេះ មានពាក្យផ្ដើមថា* **យេន សត្តុវិលង្គា ច** *ដូច្នេះជាដើម ។ ជាក់ច្បាស់ក្នុងឧម្មង្គជាតកនោះឯង ។*

**អដ្ឋកថា អមរាទេវិបញ្ហជាតក ចប់**

# សុត្តន្តបិដក

## សិគាលជាតក

[ ១១៣ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យចចកដែលផឹកសុរាដូចម្តេចបាន ( សូម្បីសម្បក ) ខ្យងចំនួន ១០០ មិនមានទេ តើកហាបណៈ ២០០ នឹងមានមកអំពីទីណា ។

*សិគាលជាតកទី ៣ ចប់*

# អដ្ឋកថា

## សិង្គាលជាតក

[ ១១៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សទ្ធុហាសិ សិង្គាលស្ស** ដូច្នេះជាដើម ។

ក្នុងសម័យនោះ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាគ្នាដល់ទោសរបស់ទេវទត្តថា អាវុសោទាំងឡាយ ទេវទត្តបបួលភិក្ខុប្រមាណ ៥០០ រូប ទៅកាន់គយាសីសបទេស ឲ្យភិក្ខុទាំងនោះ កាន់យកលទ្ធិរបស់ខ្លួនថា ព្រះសមណគោតមត្រាស់បទណា បទនោះ មិនមែនធម៌ ខ្ញុំពោលបទណា បទនោះ ជាធម៌ ដូច្នេះហើយ ធ្វើមុសាវាទដែលដល់ឋានៈវិបត្តិ បំបែកសង្ឃ ធ្វើឧបោសថ ២ ជង ក្នុងសីមាតែមួយ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះ ប៉ុណ្ណោះទេ ដែលទេវទត្តពោលមុសាវាទ សូម្បីក្នុងកាលមុន ក៏ជាអ្នកមានប្រក្រតីពោលមុសាវាទដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតា នៅក្បែរព្រៃខ្មោច ។ ក្នុងគ្រានោះ ក្នុងនគរពារាណសី មានបុណ្យនក្ខត្តឫក្សគគ្រឹកគគ្រេង ពួក

មនុស្សគិតគ្នាថា ពួកយើងនឹងធ្វើពលីកម្មដល់យក្ខ ហើយរៀបចំត្រី និងសាច់ ជាដើមបន្តបន្ទាប់ បិតស្រាជាច្រើន ដាក់ក្នុងក្រឡទាំងឡាយ ដាក់ក្នុងទីនោះៗ មានច្រក និងផ្លូវបែកជា ៤ ជាដើម ។ ក្នុងកាលនោះ ចចកមួយក្បាល ចូលទៅកាន់នគរតាមលូបង្ហូរទឹកក្នុងពេលយប់ ទំពាស៊ីត្រី និងសាច់ជាដើម ផឹកស្រាហើយ ចូលទៅកាន់រវាងគុម្ពបុន្នាគ ដេកលក់រហូតដល់ថ្ងៃរះ ។ លុះ ចចកភ្ញាក់ឡើង ឃើញថ្ងៃរះហើយ គិតថា អញមិនអាចចេញទៅក្នុងពេល នេះបាន ហើយទៅកាន់ទីជិតផ្លូវ ដេកលាក់ខ្លួន ទោះបីឃើញមនុស្សដទៃៗ ក៏មិនពោលពាក្យណាមួយ លុះឃើញព្រាហ្មណ៍ម្នាក់កំពុងដើរទៅលុបមុខ ក៏គិតថា ឈ្មោះថា ព្រាហ្មណ៍ រមែងជាអ្នកចង់បានទ្រព្យ អញត្រូវយកទ្រព្យ បញ្ឆោតព្រាហ្មណ៍នេះ ឲ្យគាត់ស្ពាយអញចេញអំពីក្រុងឲ្យបាន ចចកនោះ ពោលដោយភាសាមនុស្សថា នែព្រាហ្មណ៍ ព្រាហ្មណ៍បែរមើល ពោលថា នរណាហៅអញ ចចកឆ្លើយថា ខ្ញុំព្រាហ្មណ៍ ។ ព្រាហ្មណ៍សួរថា ហៅអញ ធ្វើអ្វី ចចកឆ្លើយថា នែព្រាហ្មណ៍ ខ្ញុំមានទ្រព្យ ២០០ កហាបណៈ បើ លោកអាចពុនខ្ញុំដែលរុំជិតដោយសំពត់ឆៀងស្មា មិនឲ្យអ្នកណាឃើញ នាំខ្ញុំ ចេញអំពីក្រុងបាន ខ្ញុំនឹងឲ្យកហាបណៈទាំងនោះដល់លោក ។ ដោយការចង់ បានទ្រព្យ ទើបព្រាហ្មណ៍ទទួលពាក្យថា សាធុ ធ្វើតាមពាក្យរបស់ចចក នាំ ចេញអំពីនគរបានបន្តិច ចចកសួរព្រាហ្មណ៍ថា នែព្រាហ្មណ៍ ដល់ណាហើយ ព្រាហ្មណ៍ឆ្លើយថា ដល់ទីនោះហើយ ចចកប្រាប់ថា ទៅបន្តិចទៀតចុះ ចចក ពោលរឿយៗ យ៉ាងនោះ លុះដល់ព្រៃធំ ទើបប្រាប់ថា ដាក់ខ្ញុំចុះត្រង់ទីនេះចុះ

កាលព្រាហ្មណ៍ដាក់ចុះហើយ ចចកប្រាប់ថា នែព្រាហ្មណ៍ បើដូច្នោះ ចូរលោកក្រាលសំពត់ធៀងស្មាចុះ ព្រាហ្មណ៍ក្រាលសំពត់ធៀងស្មារបស់ខ្លួន ដោយចំណង់ក្នុងទ្រព្យ កាលនោះ ចចកក៏ប្រាប់ថា ចូរជីកត្រង់គល់ឈើនេះចុះ ឲ្យព្រាហ្មណ៍ជីក ចចកក៏ឡើងលើសំពត់ធៀងស្មារបស់ព្រាហ្មណ៍ បន្ទោបង់មូត្រលាមកក្នុងទី ៥ កន្លែង គឺត្រង់ជ្រុងទាំង ៤ និងត្រង់កណ្ដាល ១ ជូតផងធ្វើឲ្យសើមផង ហើយរត់ចូលព្រៃខ្មោចទៅ ។ ព្រះពោធិសត្វអាស្រ័យនៅលើប្រគាបឈើ ពោលគាថានេះថា

ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យចចកដែលផឹកសុរា ដូចម្ដេចបាន ( សូម្បីសម្បក ) ខ្យងចំនួន ១០០ មិនមានទេ តើ កហាបណៈ ២០០ នឹងមានមកអំពីទីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទ្ទហាសិ** បានដល់ ដាក់ចិត្តជឿ ម្យ៉ាងទៀត បាឋៈយ៉ាងនេះឯង តែមានសេចក្ដីថា ជឿកាន់យក ។

បទថា **សិប្បិកានំ សតំ នត្ថិ** សេចក្ដីថា ព្រោះថា បៀ ១០០ របស់ចចក ក៏មិនមាន ។

បទថា **កុតោ កំសសតា ទុវេ** សេចក្ដីថា តើចចកនឹងមានប្រាក់ ២០០ កហាបណៈ មកអំពីណា ។

ព្រះពោធិសត្វពោលគាថានេះហើយ ប្រាប់ថា ទៅចុះព្រាហ្មណ៍ ចូរទៅបោកសំពត់របស់អ្នក ងូតទឹក ធ្វើកិច្ចរបស់ខ្លួនចុះ ដូច្នេះហើយ ក៏អន្តរធាន

ទៅ ព្រាហ្មណ៍ធ្វើតាមយ៉ាងនោះ ដល់នូវទោមនស្សថា ឱហ៍! អញត្រូវចចក នេះបោកហើយ ក៏ដើរចៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ថា ចចកក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ រុក្ខទេវតា ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សិង្គាលជាតក ចប់**

# សុត្តន្តបិដក

## មិតចិន្តិជាតក

[ ១១៤ ] *( ព្រះសាស្តាត្រាស់ថា ) ត្រីឈ្មោះពហុចិន្តី និងអប្បចិន្តី ទាំង ២ បានជាប់នៅក្នុងសំណាញ់ ត្រីឈ្មោះមិតចិន្តី បានដោះឲ្យរួចខ្លួន ត្រីទាំង ២ បានជួបគ្នាក្នុងទឹកនោះ ។*

**មិតចិន្តិជាតកទី ៤ ចប់**

# អដ្ឋកថា

## មិតចិន្តិជាតក

[ ១១៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈចាស់ ២ រូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពហុចិន្តី អប្បចិន្តី** ៥ ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈចាស់ ២ រូបនោះ នៅចាំវស្សាក្នុងអរញ្ញាវាសមួយកន្លែង ក្នុងជនបទ គិតគ្នាថា យើងទាំង ២ នឹងទៅគាល់ព្រះសាស្តា ហើយត្រៀមទូវស្បៀង ពន្យាថា ទៅថ្ងៃនេះចុះ ទៅស្អែកនេះចុះ រហូតដល់កន្លងទៅមួយខែហើយមួយខែទៀត ព្រោះខ្លួនជាមនុស្សខ្ជិលច្រអូស និងព្រោះជាអ្នកហួងហែងទីលំនៅ លុះគ្រប់ ៣ ខែកន្លងទៅហើយ ទើបបានចេញអំពីទីនោះទៅកាន់វត្តជេតពន រក្សាបាត្រចីវរ ក្នុងលំនៅរបស់ភិក្ខុដែលពេញចិត្តគ្នា ហើយនាំគ្នាទៅគាល់ព្រះសាស្តា ។ កាលនោះ ពួកភិក្ខុនាំគ្នាសួរព្រះថេរៈចាស់ទាំង ២ រូបថា អាវុសោ យូរហើយហ្ន៎ ដែលលោកទាំង ២ មិនបានគាល់ព្រះមានព្រះភាគ ព្រោះហេតុអ្វី ទើបលោកយឺតយូរយ៉ាងនេះ ព្រះថេរៈចាស់ទាំង ២ នាំគ្នានិយាយរឿងនោះ កាលនោះ ការខ្ជិលច្រអូស ការបង្អែបង្អង់របស់លោកទាំង ២ នោះ ក៏ល្បីទៅក្នុងចំណោមសង្ឃ ។ ក្នុងធម្មសភាពួកភិក្ខុក៏អាស្រ័យភាពជាអ្នកខ្ជិលច្រអូសរបស់លោកទាំង ២ នោះឯង លើកជារឿងឡើង ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបទ្រង់

ត្រាស់ឲ្យហៅភិក្ខុទាំង ២ មកគាល់ ត្រាស់សួរថា បានឮថា ពួកអ្នកជាអ្នកខ្ជិលច្រអូស បង្អែបង្អង់ ពិតឬ កាលលោកទាំង ២ ទទួលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកទាំង ២ ខ្ជិលច្រអូស សូម្បីក្នុងកាលមុន ក៏ជាអ្នកខ្ជិលច្រអូស ជាអ្នកអាឡោះអាល័យ ជាប់ជំពាក់ក្នុងលំនៅ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី មានត្រី ៣ ក្បាល នៅក្នុងនគរពារាណសី ត្រីទាំង ៣ មានឈ្មោះថា ពហុចិន្តី ១ អប្បចិន្តី ១ និងមិតចិន្តី ១ ។ ត្រីទាំង ៣ នាំគ្នាចេញអំពីព្រៃ មកកាន់ដែនដីមនុស្ស ។ ក្នុងត្រីទាំង ៣ នោះ មិតចិន្តីប្រាប់ត្រីទាំង ២ យ៉ាងនេះថា ឈ្មោះថា ដែនដីមនុស្សនេះ ពេញទៅដោយសេចក្តីរង្កៀស មានភ័យតាំងនៅចំពោះមុខ ពួកអ្នកប្រមង់នាំគ្នាដាក់សំណាញ់ និងលបជាដើម មានប្រការផ្សេងៗ ហើយចាប់យកត្រី ពួកយើងនាំគ្នាចូលព្រៃវិញចុះ ។ ត្រីទាំង ២ ពោលបណ្តោះបណ្តៃថា ពួកយើងនឹងទៅក្នុងថ្ងៃនេះ ឬស្អែកនេះ សឹមទៅ ព្រោះជាអ្នកខ្ជិលច្រអូស និងព្រោះជាប់ចិត្តក្នុងចំណីកន្លងទៅរហូត ៣ ខែ កាលនោះ ពួកអ្នកប្រមង់នាំគ្នាបង់សំណាញ់ក្នុងស្ទឹង ត្រីឈ្មោះពហុចិន្តី និងត្រីឈ្មោះអប្បចិន្តី កាលចេញរកអាហារ នាំគ្នាហែលទៅមុន មិនកំណត់ក្លិនសំណាញ់ ព្រោះភាពជាសត្វល្ងង់ ចូលក្នុងសំណាញ់មួយរំពេច ត្រីមិតចិន្តីមកឯក្រោយ កំណត់ក្លិនសំណាញ់បាន និងដឹងថា ត្រី

ទាំង ២ ចូលទៅក្នុងសំណាញ់ហើយ គិតថា យើងនឹងឲ្យទានជីវិតដល់ត្រីអន្ធពាលដែលល្ងង់ខ្លៅនេះ ហើយក៏ហែលទៅខាងលើសំណាញ់ ធ្វើឲ្យទឹកល្អក់កករ ធ្វើហាក់ដូចជាសំណាញ់រហែក ហើយលោតចេញទៅបាន ហើយក៏លោតទៅខាងមុខសំណាញ់ ហែលចូលទៅខាងក្រោមសំណាញ់ទៀត ធ្វើឲ្យទឹកក្រពួញ ហាក់ដូចជាសំណាញ់រហែកលោតចេញទៅបាន ហើយក៏លោតទៅខាងលើខ្នងសំណាញ់ ពួកអ្នកប្រមង់សម្គាល់ថា ត្រីនាំគ្នាហែកសំណាញ់ចេញទៅបាន ក៏នាំគ្នាចាប់សំណាញ់លើកឡើង ត្រីទាំង ២ ក៏រួចអំពីសំណាញ់ធ្លាក់ទៅក្នុងទឹក ។ ត្រីទាំង ២ នោះ អាស្រ័យត្រីមិតចិន្តី ទើបមានជីវិត ។ ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកសាធកៈហើយ ទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទើបត្រាស់ព្រះគាថានេះថា

ត្រីឈ្មោះពហុចិន្តី និងអប្បចិន្តី ទាំង ២ បានជាប់នៅក្នុងសំណាញ់ ត្រីឈ្មោះមិតចិន្តី បានដោះឲ្យរួចខ្លួន ត្រីទាំង ២ បានជួបគ្នាក្នុងទឹកនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុចិន្តី** សេចក្តីថា ត្រីដែលបានឈ្មោះយ៉ាងនេះថា ពហុចិន្តី ព្រោះមានការគិតច្រើន មានការត្រិះរិះច្រើន ក្នុងឈ្មោះទាំង ២ ក្រៅអំពីនេះ ក៏មានន័យនេះឯង ។

បទថា **ឧភោ តត្ថ សមាគតា** សេចក្តីថា ត្រីទាំងគូចូលទៅជាប់សំណាញ់ អាស្រ័យត្រីមិតចិន្តី ទើបរួចជីវិតត្រឡប់មកជាមួយត្រីមិតចិន្តី ក្នុងទឹកនោះទៀត ។

*ព្រះសាស្តាទ្រង់នាំព្រះធម្មទេសនានេះមក ដោយប្រការដូច្នេះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុចាស់ ២ រូប តាំងនៅក្នុងសោតាបត្តិផលហើយ ។ ទ្រង់ប្រជុំជាតកថា ត្រីពហុចិន្តី និងត្រីអប្បចិន្តី ក្នុងកាលនោះ បានមកជាគូភិក្ខុនេះ ក្នុងកាលឥឡូវនេះ ឯត្រីមិតចិន្តី ក្នុងកាលនោះ គឺតថាគតនេះឯង ។*

## អដ្ឋកថា មិតចិន្តិជាតក ចប់

# សុត្តន្តបិដក

## អនុសាសិកជាតក

[ ១១៥ ] ( បក្សីជាធំពោធិសត្វពោលថា ) មេបក្សីណា ប្រៀនប្រដៅនូវបក្សីដទៃ តែជាអ្នកប្រព្រឹត្តលោភដោយខ្លួនឯង មេបក្សីនោះ ដេកបាក់ស្លាប ដូចជាសត្វសាលិកា ដែលកង់កិនហើយ ។

*អនុសាសិកជាតកទី ៥ ចប់*

# អដ្ឋកថា

## អនុសាសិកជាតក

[ ១១៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនី ដែលចូលចិត្តទូន្មានអ្នកដទៃមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យាយញ្ញមនុសាសតិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនីនោះ ជាកុលធីតាមួយរូប ជាអ្នកនគរសាវត្ថី បួសហើយ តាំងពីកាលដែលខ្លួនបួសហើយ មិនបានដាក់ចិត្តក្នុងសមណធម៌ ជាប់ចិត្តក្នុងអាមិស ត្រាច់ទៅបិណ្ឌបាតក្នុងឯកទេសនៃព្រះនគរ ដែលភិក្ខុនីដទៃៗ នាំគ្នាទៅ ក្នុងកាលនោះ ពួកមនុស្សនាំគ្នាប្រគេនបិណ្ឌបាតដ៏ប្រណីតដល់នាងភិក្ខុនីនោះ ត្រូវចំណង់ក្នុងរសេចង គិតថា បើភិក្ខុនីដទៃៗ ត្រាច់បិណ្ឌបាតក្នុងទីនេះ លាភរបស់អញនឹងវិនាស អញគួរធ្វើឲ្យភិក្ខុនីដទៃៗ មិនមកដល់ប្រទេសនេះ ដូច្នេះហើយ ទៅកាន់សម្នាក់របស់ភិក្ខុនីទាំងឡាយ ទូន្មានភិក្ខុនីទាំងឡាយថា អ្នកនាងម្ចាស់ទាំងឡាយ ក្នុងទីឈ្មោះនោះ មានដំរីកាច មានសេះកាច មានឆ្កែកាច កំពុងត្រាច់ទៅ ជាទីដែលមានអន្តរាយដោយជុំវិញ អ្នកនាងម្ចាស់ទាំងឡាយ កុំទៅបិណ្ឌបាតទីនោះឡើយ ស្តាប់ពាក្យរបស់នាងហើយ ភិក្ខុនីសូម្បីត្រឹមតែមួយរូបក៏មិនសម្លឹងមើលទីនោះ ។ ថ្ងៃមួយ ខណៈដែលភិក្ខុនីនោះកំពុងចូលទៅបិណ្ឌបាត ចូលទៅកាន់ផ្ទះមួយដោយរហ័ស ពពែកាចជល់ឆ្អឹងស្មងបាក់ ពួកមនុស្សចូលទៅពិនិត្យមើល ចតឆ្អឹងស្មងដែលបាក់ឲ្យជាប់គ្នា ហើយសែងមកដោយគ្រែ នាំទៅកាន់សម្នាក់ភិក្ខុនី ពួកភិក្ខុនីនាំគ្នាសើចចំអកថា ភិក្ខុនីរូបនេះ ប្រៀនប្រដៅភិក្ខុនីដទៃៗ ខ្លួនឯង បែរជាទៅកាន់

ប្រទេសឈ្មោះនោះ រហូតដល់ស្ទឹងបាក់ត្រឡប់មក ហេតុដែលនាងធ្វើនោះ ក៏ប្រាកដក្នុងពួកភិក្ខុក្នុងកាលមិនយូរឡើយ ។ ថ្ងៃមួយ ពួកភិក្ខុនាំគ្នាពោលទោសរបស់នាងក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុនីដែលចូលចិត្តប្រៀនប្រដៅភិក្ខុនីដទៃៗ ខ្លួនឯង ត្រាច់ទៅក្នុងប្រទេសឈ្មោះនោះ ត្រូវពពែកាចជល់បាក់ឆ្អឹង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនីនោះ គិតតែប្រៀនប្រដៅអ្នកដទៃ តែខ្លួនឯង មិនប្រព្រឹត្ត ត្រូវសោយទុក្ខអស់កាលជានិច្ចនោះឯង ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូច្នេះ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតបក្សីព្រៃ ចម្រើនវ័យហើយ បានជាបក្សីមេហ្វូង មានបក្សីច្រើនរយជាបរិវារ ចូលទៅកាន់ព្រៃហិមពាន្ត ក្នុងកាលដែលព្រះពោធិសត្វនៅក្នុងព្រៃហិមពាន្តនោះ បក្សីចណ្ឌាលញីមួយក្បាលទៅកាន់ផ្លូវក្នុងព្រៃជ្រៅរកស៊ី ។ បក្សីញីបានស្រូវ និងគ្រាប់សណ្តែកជាដើម ដែលជ្រុះត្រង់ផ្លូវរទេះ ក្នុងទីនោះហើយ គិតថា ឥឡូវនេះ អញត្រូវរកវិធីកុំឲ្យពួកបក្សីដទៃៗ ទៅកាន់ប្រទេសនោះ ដូច្នេះហើយ ឲ្យឱវាទដល់ហ្វូងបក្សីថា ឈ្មោះថា ផ្លូវធំក្នុងព្រៃជ្រៅ ជាផ្លូវមានភ័យចំពោះមុខ ហ្វូងសត្វ មានដំរី

*សេះ និងយាន ដែលទឹមដោយគោកាចៗ រមែងធ្លាក់ទៅមក បើមិនអាចលោត ហើរបានរហ័ស ក៏មិនគួរទៅក្នុងទីនោះ ហ្វូងបក្សីដាក់ឈ្មោះឲ្យបក្សីញីនោះថា អនុសាសិកា ។ ថ្ងៃមួយ បក្សីញីកំពុងត្រាច់ទៅក្នុងផ្លូវធំ នាព្រៃជ្រៅនោះ បានឮសំឡេងយានដែលស្ទុះមកដោយសម្ទុះដ៏រហ័ស ក៏ក្រឡេកមើលដោយគិតថា នៅឆ្ងាយ ក៏លោតរឿយៗ ទៅ ។ កាលនោះ យានក៏មកដល់ដោយសម្ទុះដ៏រហ័ស ដូចខ្យល់បក់ បក្សីញីហើរឡើងមិនទាន់ កង់ក៏សង្កត់រាងកាយហើយហួសទៅ ។ បក្សីមេហ្វូង ហៅពួកបក្សីប្រជុំ មិនឃើញក៏ពោលថា អនុសាសិកាមិនប្រាកដ ចូរពួកអ្នកស្វែងរកនាង ហ្វូងបក្សីនាំគ្នាស្វែងរក ឃើញបក្សីញីនោះបែកជា ២ ចម្រៀក ត្រង់ផ្លូវធំ ក៏នាំគ្នាប្រាប់ដល់មេហ្វូងៗ ពោលថា នាងហាមបក្សីដទៃៗ តែខ្លួនឯងត្រាច់ទៅក្នុងទីនោះ ទើបបែកជា ២ ចម្រៀក រួចពោលគាថានេះថា*

*មេបក្សីណា ប្រៀនប្រដៅ នូវបក្សីដទៃ តែជាអ្នកប្រព្រឹត្តលោភ*
*ដោយខ្លួនឯង មេបក្សីនោះ ដេកបាក់ស្លាប ដូចជាសត្វសាលិកា*
*ដែលកង់កិនហើយ[១] ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **យ** *អក្ខរៈ ក្នុងបទថា* **យាយញ្ញ-មនុសាសតិ** *ធ្វើការភ្ជាប់បទ សេចក្តីថា មេបក្សីសាសិកាណាប្រៀនប្រដៅអ្នកដទៃ ។*

---

*១- គួរប្រែថា មេបក្សីសាលិកានោះ ដែលកង់កិនហើយ ដេកបាក់ស្លាប ទើបត្រូវន័យរបស់អដ្ឋកថា ។*

បទថា **សយំ លោលុប្បចារិនី** សេចក្តីថា ជាអ្នកមានប្រក្រតីត្រាច់ទៅដោយខ្លួនឯង ។

បទថា **សាយំ វិបក្ខិកា សេតិ** សេចក្តីថា បក្សីនោះ គឺមេបក្សីសាលិកានេះ មានស្លាបបាក់ខ្ទេច ដេកត្រង់ផ្លូវធំ ។

បទថា **ហតា ចក្កេន សាលិកា** សេចក្តីថា មេសាលិកាត្រូវយានកិនស្លាប់ ។

ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មេសាលិកាដែលប្រៀនប្រដៅអ្នកដទៃក្នុងកាលនោះ បានមកជាភិក្ខុនី ដែលចូលចិត្តប្រៀនប្រដៅអ្នកដទៃ ក្នុងកាលឥឡូវនេះ ឯបក្សីមេហ្វូងក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា អនុសាសិកជាតក ចប់**

# សុត្តន្តបិដក

## ទុព្ភចជាតក

[ ១១៦ ] ( កូនសិស្សពោធិសត្វពោលថា ) បពិត្រលោកអាចារ្យ អំពើដែលធ្វើជ្រុលនេះ មិនគាប់ចិត្តខ្ញុំទេ លោកបានតែផ្លែលំពែងទី ៤ ហើយ ត្រូវលំពែងទី ៥ មុតហើយ ។

ទុព្ភចជាតកទី ៦ ចប់

## អដ្ឋកថា

## ទុព្ពចជាតក

[ ១១៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អតិករមេករាចរិយ** ដូច្នេះជាដើម ។

រឿងរបស់ភិក្ខុនោះ មានជាក់ច្បាស់ក្នុងគិជ្ឈជាតក ក្នុងនវកនិបាតឯណោះ តែក្នុងជាតកនេះ ព្រះសាស្តាត្រាស់ហៅភិក្ខុនោះមក ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាបុគ្គលប្រដៅក្រ សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រដៅក្រដូចគ្នា ព្រោះភាពជាអ្នកប្រដៅក្រ មិនធ្វើតាមឱវាទនៃបណ្ឌិត ទើបត្រូវលំពែងជង់ស្លាប់ ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតអ្នករបាំ ជំនាញខាងលោតចម្រើនវ័យហើយ បានជាអ្នកមានបញ្ញា ឈ្លាសក្នុងឧបាយ សិក្សាសិប្បៈក្នុងការលោតឆ្លងលំពែង ក្នុងសម្នាក់អាចារ្យម្នាក់ ហើយដើរសម្តែងសិប្បៈជាមួយអាចារ្យ តែអាចារ្យនោះ ចេះសិប្បៈក្នុងការលោតឆ្លងលំពែងបានត្រឹម ៤ ដើមប៉ុណ្ណោះ មិនបាន ៥ ដើមទេ ។ ថ្ងៃមួយ អាចារ្យសម្តែងសិប្បៈក្នុងស្រុកមួយ ដោយស្រវឹងស្រា ហើយពោលថា យើងនឹងលោតឆ្លងលំពែង ៥ ដើម ហើយឲ្យដោតលំពែងរៀងគ្នា ។ កាលនោះ ព្រះពោធិសត្វពោលនឹងអាចារ្យថា បពិត្រលោកអាចារ្យ លោកមិនចេះសិប្បៈលោតឆ្លងលំពែង ៥

ដើមទេ សូមយកលំពែង ១ ដើមចេញ បើលោកនៅតែលោត នឹងត្រូវលំពែងទី ៥ មុតស្លាប់ពិត តែព្រោះស្រវឹង ទើបអាចារ្យពោលថា សូម្បីខ្លួនអ្នកក៏មិនដឹងកម្រិតសមត្ថភាពរបស់យើង មិនបានជឿនូវពាក្យរបស់ព្រះពោធិសត្វ លោតឆ្លងទៅបាន ៤ ដើម ត្រូវលំពែងទី ៥ ដោត ដូចផ្កាស្រគំក្នុងឈើអណ្ដាត ដូច្នោះ ដេកសោកសៅ កាលនោះ ព្រះពោធិសត្វពោលនឹងអាចារ្យថា លោកមិនជឿពាក្យរបស់បណ្ឌិត ទើបដល់នូវការវិនាសនោះ ដូច្នេះហើយ ពោលគាថានេះថា

បពិត្រលោកអាចារ្យ អំពើដែលធ្វើជ្រុលនេះ មិនគាប់ចិត្តខ្ញុំទេ លោក
បានតែផ្លែលំពែងទី ៤ ហើយត្រូវលំពែងទី ៥ មុតហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អតិករមករាចរិយ** សេចក្ដីថា បពិត្រលោកអាចារ្យ លោកបានធ្វើការព្រហើន អធិប្បាយថា ធ្វើហួសសមត្ថភាពខ្លួនដែលអាចធ្វើបាន ។

បទថា **មយ្ហម្បេតំ ន រុច្ចតិ** នេះ ព្រះពោធិសត្វសម្ដែងថា ការធ្វើរបស់លោក មិនគាប់ចិត្តដល់ខ្ញុំដែលជាអន្តេវាសិក ព្រោះហេតុនោះ ទើបខ្ញុំប្រាប់លោកអំពីមុននោះឯង ។

បទថា **ចតុត្ថេ លង្ឃយិត្វាន** សេចក្ដីថា លោកមិនធ្លាក់លើលំពែងទី ៤ គឺខ្លួនអាចឆ្លងបាន ។

*បទថា* **បញ្ញាយសិ អាវុសោ** *សេចក្តីថា លោកមិនជឿពាក្យរបស់បណ្ឌិត ឥឡូវនេះ ទើបត្រូវលំពែងទី ៥ ដោតហើយ ។*

*ព្រះពោធិសត្វកាលពោលពាក្យនេះហើយ ក៏នាំអាចារ្យចេញពីលំពែង ធ្វើកិច្ចដែលគួរធ្វើហើយ ព្រះសាស្តាទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថា អាចារ្យក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ចំណែកអន្តេវាសិកក្នុងកាលនោះ គឺតថាគតនេះឯង ៕៚*

**អដ្ឋកថា ឧព្ពចជាតក ចប់**

# សុត្តន្តបិដក

## តិត្តិរជាតក

[ ១១៧ ] ( តាបសពោធិសត្វពោលថា ) វាចាដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា រមែងសម្លាប់បុគ្គលពាល អ្នកឥតបញ្ញាដូចជាវាចាដែលសម្លាប់នូវសត្វទទាដែលរងាវហួស ។

**តិត្តិរជាតកទី ៧ ចប់**

# អដ្ឋកថា

## តិត្តិរជាតក

[ ១១៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនវិហារ ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អច្ចុគ្គតា អតិពលតា** ដូច្នេះជាដើម ។

រឿងរបស់កោកាលិកភិក្ខុនោះ ជាក់ច្បាស់ក្នុងតក្ការិយជាតក ក្នុងតេរសកនិបាត ។ តែក្នុងជាតកនេះ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលកោកាលិកអាស្រ័យមាត់របស់ខ្លួនត្រូវវិនាស សូម្បីក្នុងកាលមុន ក៏ធ្លាប់វិនាសដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយរៀនសិប្ប:គ្រប់យ៉ាង ក្នុងនគរតក្កសិលា លះនូវកាមទាំងឡាយ ចេញបួសជាឥសី ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ គណ:ឥសីទាំងពួងប្រជុំគ្នាក្នុងហិមវន្តប្បទេស តាំងឲ្យធ្វើជាអាចារ្យឲ្យឱវាទ ដាក់ខ្លួនជាបរិវារ លោកបានជាអាចារ្យអ្នកឲ្យឱវាទដល់ឥសី ៥០០ ជាអ្នកលេងឈានក្នុងព្រៃហិមពាន្តនោះ ។ សម័យនោះ តាបសមួយរូប កើតរោគស្គមលឿងក្នុងព្រៃហិមពាន្តនោះ កាន់កាំបិតទៅពុះឧស គ្រានោះ តាបសមាត់រឹងម្នាក់ អង្គុយក្នុងទីជិតតាបសស្គមនោះ ពោលថា ចូរកាប់ក្នុងទីនេះ ចូរកាប់ក្នុងទីនេះ ធ្វើឲ្យតាបសស្គមនោះអាក់អន់ ក្រោធហើយ ពោលថា ឥឡូវនេះ លោកមិនមែនជា

អាចារ្យបង្ហាត់សិប្បៈក្នុងការពុះឧសដល់យើងឡើយ ហើយងាកាំបិតដ៏មុតកាប់ត្រឹមមួយកាំបិតប៉ុណ្ណោះ ធ្វើឲ្យតាបសមាតរឹងដល់នូវការអស់ជីវិត ព្រះពោធិសត្វឲ្យធ្វើសរីរកិច្ចដល់លោកហើយ ។ ក្នុងកាលនោះ ត្រង់ជើងជំបូកកណ្តៀរមួយកន្លែង មិនឆ្ងាយអំពីអាស្រមបទ សត្វទទាមួយនៅអាស្រ័យ ទាំងព្រឹកទាំងល្ងាច មកឈរលើជំបូក រងាវដោយសំឡេងខ្លាំង ។ ស្តាប់សំឡេងនោះហើយ ព្រានម្នាក់គិតថា ប្រហែលជាមានសត្វទទា ទើបដើរតម្រង់ទៅ ដោយមានសំឡេងជាសញ្ញា សម្លាប់ទទាហើយ កាន់យកទៅ ព្រះពោធិសត្វមិនបានឮសំឡេងទទា សួរតាបសទាំងឡាយថា ទីត្រង់នោះ មានទទានៅអាស្រ័យ ព្រោះហេតុអ្វីហ្ន៎ ទើបខានឮសំឡេងទទានោះ ។ តាបសប្រាប់រឿងនោះដល់ព្រះពោធិសត្វៗ ក៏ប្រៀបធៀបហេតុការណ៍ទាំង ២ នោះហើយ ពោលគាថានេះកណ្តាលជំនុំឥសីថា

វាចាដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា រមែង
សម្លាប់បុគ្គលពាល អ្នកឥតបញ្ញា ដូចជាវាចាដែលសម្លាប់នូវ
សត្វទទាដែលរងាវហួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ចុគ្គតា** បានដល់ វាចាដែលខ្ពស់ហួសពេក ។

បទថា **អតិពលតា** បានដល់ វាចាដែលខ្លាំងក្លាពេក ព្រោះពោលដដែលៗ ។

បទថា **អតិវេលំ បភាសិតា** បានដល់ វាចាដែលកន្លងពេលវេលា គឺ ពាក្យពោលដែលហួសប្រមាណ ។

បទថា **តិត្តិរំវាតិវស្សិតំ** សេចក្តីថា សំឡេងរងាវខ្លាំងពេក រមែងកម្ចាត់សត្វទទាបាន យ៉ាងណា វាចាបែបនេះ រមែងកម្ចាត់បុគ្គលល្ងង់ខ្លៅ គឺបុគ្គលពាល ដូច្នោះ ។

ព្រះពោធិសត្វឲ្យឱវាទដល់ពួកឥសី ដោយប្រការដូច្នេះ ចម្រើនព្រហ្មវិហារ ៤ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលកោកាលិកភិក្ខុអាស្រ័យវាចារបស់ខ្លួនវិនាសហើយ សូម្បីក្នុងកាលមុន ក៏ធ្លាប់វិនាសហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសប្រដៅក្រក្នុងកាលនោះ បានមកជាកោកាលិកភិក្ខុក្នុងកាលឥឡូវនេះ គណៈឥសីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯសាស្តានៃគណៈ គឺតថាគតនេះឯង ។

**អដ្ឋកថា តិត្តិរជាតក ចប់**

# សុត្តន្តបិដក

## វដ្តកជាតក

[ ១១៨ ] ( ចាបពោធិសត្វពោលថា ) បុរសកាលមិនបានរិះគិត រមែងមិនបានសម្រេចនូវគុណវិសេសឡើយ អ្នកចូរឃើញផលនៃឧបាយ ដែលខ្ញុំគិតហើយ ព្រោះខ្ញុំរួចអំពីសេចក្ដីស្លាប់នឹងចំណង ។

វដ្តកជាតកទី ៨ ចប់

# អដ្ឋកថា

## វដ្ដកជាតក

[ ១១៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុត្តរបស់ឧត្តរសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **នាចិន្តយិត្វា បុរិសោ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានសេដ្ឋីឈ្មោះឧត្តរ មានសម្បត្តិច្រើន សត្វសម្បូរបុណ្យម្នាក់ចុតិអំពីព្រហ្មលោក បដិសន្ធិក្នុងផ្ទៃនៃភរិយារបស់សេដ្ឋី ចម្រើនវ័យ មានរូបស្អាតផូរផង់ មានពណ៌សម្បុរដូចព្រហ្ម ។ សម័យមួយក្នុងនគរសាវត្ថី មានបុណ្យនក្ខត្តឫក្សប្រចាំខែកត្តិក គេបានប្រកាសទូទៅនូវបុណ្យនក្ខត្តឫក្ស ។ កូនសេដ្ឋីដទៃៗ ដែលជាសម្លាញ់របស់សេដ្ឋីបុត្រនោះ មានភរិយាហើយ តែព្រោះបុត្ររបស់ឧត្តរសេដ្ឋីនៅក្នុងព្រហ្មលោកអស់កាលយូរ ទើបមិនទទឹកដោយកិលេស ។ គ្រានោះ សម្លាញ់របស់សេដ្ឋីបុត្រគិតគ្នាថា ពួកយើងនឹងនាំស្រីម្នាក់មកឲ្យបុត្ររបស់ឧត្តរសេដ្ឋី ហើយបបួលគ្នាលេងនក្ខត្តឫក្ស ចូលទៅរកពោលថា នែសម្លាញ់ ក្នុងនគរមានមហោស្រពប្រចាំខែកត្តិក គេប្រកាសទូទៅហើយ ពួកយើងនាំស្រីម្នាក់មកឲ្យឯង ដើម្បីលេងនក្ខត្តឫក្សទាំងអស់គ្នា កាលមាណពប្រាប់ថា ខ្ញុំមិនត្រូវការស្រីទេ ក៏នាំគ្នាបញ្ចុះបញ្ចូលរឿយៗ រហូតយល់ព្រម ទើបទៅស្អិតស្អាងវណ្ណទាសីម្នាក់ដោយគ្រឿងប្រដាប់សព្វយ៉ាង នាំទៅកាន់ផ្ទះរបស់មាណព ហើយពោលថា ចូរនាងទៅក្នុងសម្នាក់សេដ្ឋីបុត្រចុះ ដូច្នេះហើយ ក៏បញ្ជូនចូលទៅកាន់បន្ទប់ដេក រួចនាំគ្នាចេញទៅ សូម្បីនាងចូលទៅដល់បន្ទប់ដេក សេដ្ឋីបុត្រក៏មិនសម្លឹងមើល

មិនចរចាជាមួយ ស្រីនោះគិតថា បុរសនេះមិនសម្លឹងមើលអញ ដែលជាស្រីស្អាត សម្បូរដោយរូបឆោមដ៏កំពូលបែបនេះ ទាំងមិននិយាយជាមួយផងឥឡូវនេះ អញនឹងឲ្យបុរសនេះមើលអញដោយមាយាកែក្រាយនៃស្ត្រីឲ្យបានដូច្នេះហើយ សម្តែងមាយាស្រី បង្ហាញចុងធ្មេញដោយការញញឹម ធ្វើអៀនប្រៀន សេដ្ឋីបុត្រសម្លឹងមើលត្រង់ធ្មេញ កើតអដ្ឋិកសញ្ញា រូបដែលស្អាតទាំងអស់ ប្រាកដដូចគ្រោងឆ្អឹង ទើបឲ្យរង្វាន់ដល់នាង ហើយបញ្ជូនខ្លួនទៅ ។

ឥស្សរជនម្នាក់ ឃើញនាងចុះអំពីផ្ទះក្នុងចន្លោះផ្លូវ ក៏ឲ្យរង្វាន់ នាំទៅកាន់ផ្ទះរបស់ខ្លួន លុះកន្លងទៅ ៧ ថ្ងៃ បុណ្យនក្ខត្តឫក្សក៏ឈប់ ម្តាយរបស់នាងវណ្ណទាសីមិនឃើញនាងត្រឡប់មក ក៏ទៅរកសេដ្ឋីទាំងឡាយ សួរថា កូនស្រីរបស់ខ្ញុំទៅណា សេដ្ឋីទាំងនោះក៏នាំគ្នាទៅកាន់ផ្ទះឧត្តរសេដ្ឋីបុត្រ សួរថា នាងទៅណា មាណពប្រាប់ថា ខ្ញុំឲ្យរង្វាន់នាង ហើយបញ្ជូននាងទៅក្នុងខណៈនោះឯង ។ មាតារបស់នាងក៏ស្រែកយំ ពោលថា ខ្ញុំមិនឃើញកូនស្រីរបស់ខ្ញុំទេ សូមពួកលោកនាំកូនស្រីរបស់ខ្ញុំមកសង ហើយចាប់ឧត្តរសេដ្ឋីបុត្រទៅកាន់រាជសម្នាក់ ។ ព្រះរាជា កាលទ្រង់ជម្រះក្តី ត្រាស់សួរថា សេដ្ឋីបុត្រទាំងនេះនាំនាងទៅឲ្យអ្នកឬ បុរសនោះក្រាបទូលថា ករុណាថ្លៃវិសេស ។ ព្រះរាជាសួរថា ឥឡូវនេះ នាងទៅឯណា ក៏ក្រាបទូលថា មិនដឹងទេព្រះអង្គ ទូលបង្គំបញ្ជូននាងទៅក្នុងខណៈនោះឯង ។ ព្រះរាជាត្រាស់ថា ឥឡូវនេះ អ្នកអាចនាំនាងមកឲ្យម្តាយវិញបានដែរឬទេ ក៏ទូលថា ទូលបង្គំមិនអាចទេ ព្រះរាជាត្រាស់ថា បើមិនអាចនាំនាងមកវិញបានទេ ចូរពួកអ្នកដាក់អាជ្ញាបុរស

នេះចុះ ។ គ្រានោះ ពួករាជបុរស នាំគ្នាចាប់ចងក្រពាត់ស្លាបសេក នាំខ្លួនទៅ ដោយគិតថា ពួកយើងនឹងដាក់អាជ្ញា ក៏ល្បីពេញព្រះនគរថា បានឮថា ព្រះរាជាបញ្ជាឲ្យដាក់រាជអាជ្ញាដល់សេដ្ឋីបុត្រ ដែលមិនអាចនាំនាងវណ្ណទាសីមកសងដល់ម្ដាយបាន ។ មហាជននាំគ្នាទ្រហោយំថា លោកអើយ ហេតុអ្វីមានរឿងបែបនេះ សេដ្ឋីបុត្របានទូវវត្ថុដែលមិនគួរដល់ខ្លួន នាំគ្នាដើរយំទៅអំពីខាងក្រោយរបស់សេដ្ឋីបុត្រៗ គិតថា ទុក្ខបែបនេះ ដែលអញបានទទួល ព្រោះការនៅគ្រប់គ្រងផ្ទះ បើអញរួចទុក្ខនេះបាន នឹងបួសក្នុងសម្នាក់ព្រះមហាគោតមសម្ពុទ្ធ ។

ឯនាងវណ្ណទាសីនោះ ស្ដាប់សំឡេងកោលាហលនោះហើយ ក៏សួរថា នុ៎ះសំឡេងអ្វី លុះដឹងរឿងហើយ រត់ចុះមកដោយរហ័ស ពោលថា សូមចៀសផ្លូវលោកទាំងឡាយ សូមឲ្យឱកាសខ្ញុំបានជួបរាជបុរសចុះ ហើយបង្ហាញខ្លួន ។ ពួករាជបុរសឃើញនាងហើយ ក៏ឲ្យមាតាមកទទួលយកទៅ ដោះលែងសេដ្ឋីបុត្រហើយ នាំគ្នាទៅ ។ សេដ្ឋីបុត្រត្រូវសម្លាញ់ទាំងឡាយចោមរោមទៅកាន់ស្ទឹងដើម្បីងូតទឹក ស្រេចបាច់ហើយ ទើបទៅផ្ទះបរិភោគអាហារព្រឹក សូមឲ្យមាតាបិតាអនុញ្ញាតឲ្យបព្វជ្ជា កាន់យកសំពត់ចីវរទៅក្នុងសម្នាក់ព្រះសាស្ដា ដោយបរិវារធំ ថ្វាយបង្គំហើយ ទូលសូមបព្វជ្ជា បានសម្រេចឧបសម្បទា មិនបោះបង់កម្មដ្ឋាន ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានតាំងនៅក្នុងអរហត្តផល ។

សម័យមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា ពោលដល់គុណរបស់

លោកថា អាវុសោទាំងឡាយ ឧត្តរសេដ្ឋីបុត្រ កាលភ័យកើតឡើងដល់ខ្លួន ជ្រាបគុណរបស់ព្រះសាស្តា បានគិតថា បើអញផុតចាកទុក្ខនេះ នឹងបួស ដោយការគិតល្អនោះ ទើបរួចផុតចាកមរណភ័យ បួសហើយ តាំងនៅក្នុង អគ្គផល ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់ មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយ ក្រាប ទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើប ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែបុត្ររបស់ឧត្តរសេដ្ឋីប៉ុណ្ណោះដែល ភ័យកើតឡើងហើយ បានគិតថា អញនឹងផុតចាកទុក្ខនេះ ដោយឧបាយនេះ ផុតចាកមរណភ័យហើយ សូម្បីបណ្ឌិតក្នុងអតីតកាល គ្រាមានភ័យកើតដល់ ខ្លួនហើយ ក៏គិតថា អញនឹងផុតចាកទុក្ខនេះ ដូច្នេះហើយ ក៏ផុតចាកទុក្ខ គឺ មរណភ័យបានហើយដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វកាលកម្លាំងកម្មបក់បោកឲ្យវិលវល់ អន្ទោលទៅ មក ដោយអំណាចនៃចុតិ និងបដិសន្ធិ យោនយកកំណើតជាសត្វចាប ។ គ្រានោះឯង ព្រានបក្សីម្នាក់ ចាប់សត្វចាបជាច្រើនមកអំពីព្រៃ បង្ខាំងក្នុងផ្ទះ ចិញ្ចឹមទុកហើយ កាលមនុស្សទាំងឡាយនាំគ្នាមកទិញ ក៏លក់ចាប បញ្ចូនឲ្យ ក្នុងដៃចិញ្ចឹមជីវិត ។ ថ្ងៃមួយ ព្រានបក្សីនោះ បានចាប់ព្រះពោធិសត្វ មួយ អន្លើដោយចាបជាច្រើនមកហើយ ។ ព្រះពោធិសត្វគិតថា បើអញបរិភោគ បាយ ទឹកដែលព្រាននេះឲ្យហើយសោត ព្រាននេះ ក៏គង់ចាប់អញឲ្យដល់អ្នក

ទិញ បើអញមិនបរិភោគ នឹងត្រូវស្គមស្គាំង កាលមនុស្សទាំងឡាយឃើញអញស្គម ក៏មិនព្រមទិញ ការផុតភ័យ នឹងមានដល់អញដោយឧបាយនេះ អញនឹងធ្វើឧបាយ ដូច្នេះ ។ កាលព្រះពោធិសត្វធ្វើយ៉ាងនោះ ក៏ស្គមសល់តែស្បែកដណ្តប់ឆ្អឹង ពួកមនុស្សឃើញព្រះពោធិសត្វហើយ មិនប្រាថ្នាសូម្បីយកដៃប៉ះ ព្រានព្រៃកាលចាប់ចាបដទៃអស់ទៅហើយ ក៏នាំយកព្រះពោធិសត្វអំពីទ្រុង ឈរត្រង់ទ្វារ ដាក់ព្រះពោធិសត្វត្រង់បាតដៃ ប្រារព្ធនឹងពិនិត្យមើលថា ចាបមួយនេះដូចម្តេចហ្ន៎ កាលព្រះពោធិសត្វដឹងថា ព្រានភ្លេចខ្លួនក៏ទទះស្លាបហើរចូលព្រៃ ចាបដទៃឃើញព្រះពោធិសត្វ ទើបនាំគ្នាសួរថា ហេតុអ្វី ទើបអ្នកមិនប្រាកដ អ្នករវល់ទៅណា ព្រះពោធិសត្វប្រាប់ថា ខ្ញុំត្រូវព្រានចាប់ទៅ ក៏សួរដេញដោលថា ចុះហេតុអ្វី ទើបអ្នករួចមកបាន ព្រះពោធិ-សត្វប្រាប់ថា ខ្ញុំមិនបរិភោគអាហារដែលគេឲ្យ មិនផឹកទឹក ទើបរួចមកបានដោយឧបាយ ដូច្នេះហើយ ពោលគាថានេះថា

បុរសកាលមិនបានរិះគិត រមែងមិនបានសម្រេចនូវគុណវិសេស
ឡើយ អ្នកចូរឃើញផលនៃឧបាយ ដែលខ្ញុំគិតហើយ ព្រោះខ្ញុំរួច
អំពីសេចក្តីស្លាប់នឹងចំណង ដូច្នេះ ។

ក្នុងគាថានោះ អធិប្បាយសរុបមានដូច្នេះថា បុគ្គលដល់នូវទុក្ខហើយ កាលមិនគិតថា អញនឹងផុតទុក្ខនេះដោយឧបាយឈ្មោះនេះ ក៏មិនជួបនូវផល

វិសេស គឺការរួចផុតចាកទុក្ខរបស់ខ្លួនបាន ឥឡូវនេះ ចូរមើលផលនៃកម្ម ដែលខ្ញុំគិតហើយ ដោយឧបាយនេះប៉ុណ្ណោះ ដែលខ្ញុំរួចចាកការសម្លាប់ និង ការឃុំខាំង គឺផុតចាកការស្លាប់ អំពីការដាក់ក្នុងទ្រុងផងដែរ ព្រះពោធិសត្វ ប្រាប់ហេតុដែលខ្លួនធ្វើហើយ ដោយប្រការដូច្នេះ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចាបដែលរួចខ្លួនចាកសេចក្តីស្លាប់ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វដ្តកជាតក ចប់**

# សុត្តន្តបិដក

## អកាលរាវិជាតក

[ ១១៩ ] ( *អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា* ) *មាន់នេះ ចម្រើននៅក្នុងសម្នាក់នៃបុគ្គល មិនមែនជាមាតាបិតា កាលនៅក្នុងត្រកូលនៃបុគ្គល មិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួររងាវ ឬកាលមិនគួររងាវ ។*

*អកាលរាវិជាតកទី ៩ ចប់*

# អដ្ឋកថា

## អកាលរាវិជាតក

[ ១១៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុស្វាធ្យាយមិនដឹងកាលមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អមាតាបិតុសំវឌ្ឍោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាកុលបុត្រអ្នកនគរសាវត្ថី បព្វជ្ជាក្នុងសាសនាហើយ មិនរៀនវត្ត ឬសិក្ខា លោកមិនដឹងថា ពេលនេះគួរធ្វើវត្ត ពេលនេះគួរប្រតិបត្តិ ពេលនេះគួររៀន ពេលនេះគួរទន្ទេញ បន្លឺសំឡេងខ្លាំងក្នុងខណៈដែលខ្ទនភ្ញាក់នោះឯង ទាំងក្នុងបឋមយាម មជ្ឈិមយាម និងក្នុងបច្ឆិមយាម ភិក្ខុទាំងឡាយមិនបានសិងលក់ នាំគ្នាពោលទោសរបស់លោកក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុនោះបព្វជ្ជាក្នុងសាសនា គឺរតនៈបែបនេះ មិនស្គាល់វត្ត ឬសិក្ខា កាល ឬមិនមែនកាល ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះបន្លឺសំឡេងមិនដឹងកាល សូម្បីក្នុងកាលមុន ក៏បន្លឺសំឡេងមិនដឹងកាលដូចគ្នា ព្រោះភាពដែលមិនដឹងកាល ឬមិនមែនកាល ត្រូវមួលកអស់ជីវិត ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ដឹងក្តីហើយ សម្រេច

សិប្បវិទ្យាគ្រប់យ៉ាង ជាអាចារ្យទិសាបាមោក្ខ ក្នុងនគរពារាណសី ប្រាប់សិប្បៈដល់មាណពប្រមាណ ៥០០ ។ ពួកមាណពទាំងនោះ មានមាន់រងាវប្រចាំយាមមួយក្បាល ពួកគេនាំគ្នាក្រោកតាមសំឡេងរងាវរបស់មាន់នោះ ដើម្បីសិក្សាសិប្បៈ ក្រោយមក មាន់នោះក៏ស្លាប់ហើយ ទើបពួកជនដើររកមាន់ដទៃ ។ កាលនោះ មាណពម្នាក់កាច់ឧសនៅក្នុងព្រៃខ្មោច ឃើញមាន់មួយក្បាល ក៏ចាប់មកដាក់ទ្រុងចិញ្ចឹម មាន់នោះមិនដឹងថា គួររងាវក្នុងពេលនោះ ព្រោះខ្លួនធំនៅក្នុងព្រៃខ្មោច ជួនកាល ក៏រងាវពីល្ងាចពេក ជួនកាល ក៏រងាវក្នុងពេលអរុណរះ ពួកមាណពនាំគ្នាសិក្សាសិប្បៈ ក្នុងពេលដែលមាន់រងាវល្ងាចពេក មិនអាចសិក្សាបាន រហូតអរុណរះ នាំគ្នាដេកលក់ទៅ សូម្បីបទដែលទន្ទេញចាំហើយ ក៏ភ្លេចទៅ ។ ក្នុងពេលដែលមាន់រងាវភ្លឺពេក ក៏មិនបានទន្ទេញ ។ មាណពនិយាយគ្នាថា ឥឡូវនេះ មាន់រងាវពីយប់ពេក ជួនកាល ក៏រងាវភ្លឺពេក អាស្រ័យមាន់នេះ ពួកយើងនឹងរៀនសិប្បវិទ្យាមិនសម្រេចឡើយ នាំគ្នាចាប់មួលកទាល់តែអស់ជីវិត ហើយប្រាប់អាចារ្យថា មាន់រងាវពុំដូកាល ពួកខ្ញុំសម្លាប់ហើយ អាចារ្យពោលថា មាន់នោះដល់នូវការស្លាប់ ព្រោះចម្រើនដោយមិនបានទទួលការទូន្មាន ដូច្នេះហើយ ពោលគាថានេះថា

មាន់នេះ ចម្រើននៅក្នុងសម្នាក់នៃបុគ្គល មិនមែនជាមាតាបិតា
កាលនៅក្នុងត្រកូលនៃបុគ្គល មិនមែនជាអាចារ្យ រមែងមិនដឹង
ច្បាស់នូវកាលគួររងាវ ឬកាលមិនគួររងាវ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អមាតាបុត្តសំវឌ្ឍោ** សេចក្ដីថា មាន់នេះធំធាត់ដោយមិនបានអាស្រ័យមាតាបិតា ហើយទទួលឱវាទ ។

បទថា **អនាចរិយាកុលេ វសំ** សេចក្ដីថា សូម្បីក្នុងត្រកូលអាចារ្យក៏មិនបាននៅ ព្រោះមិនបានអាស្រ័យបុគ្គលណាមួយ ជាអាចារ្យដែលប្រៀនប្រដៅឡើយ ។

បទថា **ឆាយំ កាលមកាលំ វា** សេចក្ដីថា មាន់នេះមិនដឹងកាលឬមិនមែនកាលដែលខ្លួនគប្បីរងាវយ៉ាងនេះថា គួររងាវក្នុងពេលនេះ មិនគួររងាវក្នុងពេលនេះ ព្រោះហេតុដែលមិនដឹងនោះឯង ទើបត្រូវដល់នូវការអស់ជីវិត ។

ព្រះពោធិសត្វសម្ដែងហេតុនេះហើយ រស់នៅដរាបដល់អាយុក្ខ័យ ទៅតាមយថាកម្ម ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មាន់ដែលរងាវខុសកាល ក្នុងសម័យនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ អន្តេវាសិកក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា អកាលរាវិជាតក ចប់**

# សុត្តន្តបិដក

## ពន្ធនមោក្ខជាតក

[ ១២០ ] ( បុរោហិតពោធិសត្វពោលថា ) ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់ រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ ។

*ពន្ធនមោក្ខជាតកទី ១០ ចប់*

*ហំសិវគ្គទី ១២ ចប់*

## ឧទ្ទាននៃហំសិវគ្គនោះ គឺ

និយាយអំពីគទ្រភបញ្ហា ១ សជូវ ១ រយកហាបណៈ ១ ត្រីឈ្មោះពហុចិន្តិ ១ មេបក្សី ១ អំពើដែលធ្វើជ្រុល ១ ហួសវេលា ១ គុណវិសេស ១ មាន់គ្មានអាចារ្យ ១ អ្នកប្រាជ្ញពោល ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ពន្ធនមោក្ខជាតក

[ ១២០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អពទ្ធា តត្ថ ពជ្ឈន្តិ** ដូច្នេះជាដើម ។

រឿងរបស់នាងជាក់ច្បាស់ក្នុងមហាបទុមជាតក ទ្វាទសកនិបាត ។

ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងចិញ្ចមាណវិកាពោលទោសតថាគតដោយរឿងមិនពិត សូម្បីក្នុងកាលមុន ក៏ធ្លាប់ពោលទោសហើយដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទះរបស់បុរោហិត ចម្រើនវ័យហើយ បានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្ត បន្តវេនជំនួសបិតាដែលស្លាប់ទៅ ព្រះបាទព្រហ្មទត្តបានព្រះរាជទានពរដល់អគ្គមហេសីថា នែនាងដ៏ចម្រើន នាងត្រូវការរបស់ណា គប្បីប្រាប់របស់នោះ ព្រះនាងក្រាបទូលថា ឈ្មោះថាពរដទៃមិនបានជារបស់ដែលខ្ញុំម្ចាស់បានដោយលំបាកឡើយ សូមព្រះរាជទានត្រឹមតែ តាំងអំពីនេះជាដើមទៅ សូមទ្រង់កុំទតស្រីដទៃដោយកិលេស ។ សូម្បីព្រះរាជាទ្រង់ឃាត់ក៏ត្រូវនាងទូលសូមរឿយៗ ទើបមិនអាចបដិសេធនូវពាក្យរបស់នាងបាន ទ្រង់ក៏ទទួល ។ តាំងអំពីកាលនោះ ទ្រង់មិនបានសម្លឹងមើលបណ្ដាអ្នករបាំ ១៦០០០ នាក់ សូម្បីត្រឹមតែម្នាក់ដោយអំណាចកិលេស ។

សម័យក្រោយមក បច្ចន្តជនបទក៏កើតបះបោរ ពួកយោធាដែលបោះជំរំឯជនបទច្បាំងជាមួយពួកចោរ ២-៣ ដង ក៏បញ្ជូនសំបុត្រទូលដល់ព្រះរាជាថា សត្រូវខ្លាំងក្លាក្រៃពេក ពួកខ្ញុំព្រះអង្គមិនអាចតយុទ្ធបានទេ ។ ព្រះរាជាមានព្រះបំណងយាងទៅក្នុងទីនោះ ទ្រង់ត្រួតពលនិកាយ ហើយហៅព្រះនាងមកត្រាស់ថា នែ នាងដ៏ចម្រើន យើងត្រូវទៅកាន់ជនបទ ការប្រយុទ្ធមានច្រើនបែបសណ្ឋាន ឈ្នះ ឬចាញ់ក៏មិនប្រាកដក្នុងទីបែបនោះ មាតុគ្រាមគ្រប់គ្រងបានលំបាក ចូរនាងនៅក្នុងរាជវាំងនេះឯង ដូច្នេះ ។ ឯព្រះនាងក៏ក្រាបទូលថា ព្រះមេខ្ញុំម្ចាស់ ខ្ញុំម្ចាស់មិនអាចនៅខាងក្រោយ ដូចព្រះតម្រាស់បាន កាលព្រះរាជាឃាត់រឿយៗ ក៏ក្រាបទូលថា បើដូច្នោះ ទ្រង់យាងទៅគ្រប់យោជន៍ សូមបញ្ជូនមនុស្សម្នាក់ មកប្រាប់គ្រប់យោជន៍ ដើម្បីជ្រាបសុខទុក្ខរបស់ខ្ញុំម្ចាស់ ។ ព្រះរាជាទទួលពាក្យហើយ ទ្រង់តាំងព្រះពោធិសត្វជាអ្នករក្សាព្រះនគរ ទ្រង់លើកកងទ័ពធំចេញទៅ កាលយាងទៅបានមួយយោជន៍ ក៏បញ្ជូនបុរសម្នាក់មក ដោយព្រះតម្រាស់ថា ចូរប្រាប់ការមិនមានរោគរបស់យើង ហើយដឹងសុខទុក្ខរបស់ព្រះទេវី សឹមមកចុះ ។ ព្រះនាងសាកសួរបុរសដែលមកថា ព្រះរាជាទ្រង់បញ្ជូនមកដើម្បីអ្វី កាលរាជបុរសក្រាបទូលថា ដើម្បីដឹងសុខទុក្ខរបស់ព្រះនាង ក៏មានព្រះសវនីយ៍ថា បើដូច្នោះ ចូរមកនេះ ហើយព្រះនាងសេពអសទ្ធម្មជាមួយបុរសនោះ ។ ព្រះរាជាយាងទៅអស់ចម្ងាយផ្លូវ ៣២ យោជន៍ បញ្ជូនមនុស្សទៅ ៣២ នាក់ ព្រះនាងបានធ្វើជាមួយមនុស្សទាំងនោះគ្រប់គ្នាដោយទំនងនេះឯង ។

ព្រះរាជាទ្រង់បង្ក្រាបបច្ចន្តជនបទរាបទាបហើយ រៀបចំជនបទល្អហើយ កាលយាងត្រឡប់ ក៏បញ្ជូនមនុស្ស ៣២ នាក់ ទៅដោយទំនងដូចគ្នានោះឯង ព្រះនាងក៏បដិបត្តិខុស ជាមួយមនុស្សទាំងនោះយ៉ាងនោះដូចគ្នា ។ ព្រះរាជាយាងមកដល់ទីសម្រាក ដើម្បីធ្វើជ័យជម្នះ ទ្រង់បញ្ជូនសំបុត្រដល់ព្រះពោធិសត្វថា ចូរនាំគ្នាតាក់តែងព្រះនគរចុះ ព្រះពោធិសត្វក៏កែនមនុស្សឲ្យតាក់តែងព្រះនគរ កាលឲ្យមនុស្សតាក់តែងព្រះរាជនិវេសន៍ បានទៅដល់ទីប្រថាប់នៃព្រះទេវី ព្រះនាងទតឃើញសរីរៈរបស់ព្រះពោធិសត្វ ដល់នូវលម្អដ៏លើសដោយរូបសម្បត្តិ ព្រះនាងមិនអាចទប់ព្រះហឫទ័យបាន មានព្រះសវនីយ៍ថា មកនេះព្រាហ្មណ៍ អញ្ជើញឡើងកាន់សយនាចុះ ព្រះពោធិសត្វក្រាបទូលថា កុំមានព្រះសវនីយ៍យ៉ាងនេះឡើយ ព្រះរាជាជាទីគោរពរបស់ទូលបង្គំៗ ខ្លាចចំពោះអកុសល ទូលបង្គំមិនអាចធ្វើយ៉ាងនោះបានទេ ទើបមានព្រះសវនីយ៍ថា ព្រះរាជាមិនជាទីគោរពរបស់រាជបុរស ៦៤ នាក់ មនុស្សទាំងនោះ ក៏មិនខ្លាចអកុសល ឯងម្នាក់គោរពព្រះរាជា ឯងម្នាក់ខ្លាចអកុសលឬ ព្រះពោធិសត្វក្រាបទូលថា បើមនុស្សទាំងនោះជាបុគ្គលយ៉ាងនោះសោត ទូលបង្គំមិនដូច្នោះឡើយ ទូលបង្គំដឹង មិនធ្វើកម្មដ៏អាក្រក់នោះឡើយ ។ ទើបព្រះនាងមានព្រះសវនីយ៍ថា ឯងនិយាយឲ្យច្រើនអ្វី បើមិនធ្វើតាមពាក្យរបស់យើងៗនឹងកាត់ក្បាលអាចោល ទើបក្រាបទូលថា ការកាត់ក្បាលក្នុងអត្តភាពមួយជាការប្រសើរ មិនដូចការកាត់ក្បាលរាប់ពាន់អត្តភាព ទូលបង្គំមិនអាចធ្វើយ៉ាងនេះ ព្រះនាងត្រាស់ថា ណ្ហើយចុះ ឯងនឹងដឹងល្អ និងអាក្រក់ជាមួយគ្នា

ហើយយាងចូលបន្ទប់ សម្តែងនូវស្នាមក្រចកត្រង់រាងកាយ លាបខ្លួនដោយប្រេង ស្លៀកសំពត់ចាស់ ធ្វើពុតជាឈឺ ផ្តាំទាសីទាំងឡាយថា កាលព្រះរាជាយាងមកសួរថា ព្រះទេវីទៅណា ពួកនាងគប្បីទូលថា យើងប្រឈួន ។

ឯព្រះពោធិសត្វ ក៏បានទៅទទួលព្រះរាជាៗ ទ្រង់ធ្វើប្រទក្សិណព្រះនគរហើយ ឡើងកាន់ប្រាសាទត្រាស់សួរថា ព្រះទេវីទៅណា ទាសីទាំងឡាយទូលថា ព្រះទេវីប្រឈួន ព្រះរាជាយាងចូលបន្ទប់ដ៏មានសិរី ទ្រង់អង្អែលខ្នងព្រះទេវីបណ្តើរ ត្រាស់សួរបណ្តើរថា នែនាងដ៏ចម្រើន នាងមិនសប្បាយរឿងអ្វី ព្រះនាងក៏នៅស្ងៀម ក្នុងវារៈទី ៣ ទើបងាកមើលព្រះរាជា ក្រាបទូលថា ទោះបីព្រះអង្គគង់ព្រះជន្មនៅ ស្រីទាំងឡាយដូចខ្ញុំម្ចាស់ ត្រូវជាស្រីមានប្តីមួយដោយពិត ។ ព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន តើមានរឿងអ្វី ក៏ក្រាបទូលថា បុរោហិតដែលទ្រង់តែងតាំងរក្សាព្រះនគរមកក្នុងទីនេះ ប្រាប់ថា នឹងគាស់តែងព្រះរាជនិវេសន៍ ហើយប្រទូស្តខ្ញុំម្ចាស់ដែលមិនធ្វើតាមពាក្យខ្លួន សម្រេចដូចបំណងហើយ ទើបទៅ ។ ព្រះរាជាទ្រង់បញ្ចេញសំឡេងដោយសេចក្តីក្រេវក្រោធ ដូចបោះដុំអំបិលចូលភ្លើង ដូច្នោះ យាងចេញអំពីបន្ទប់ដ៏មានសិរី ត្រាស់ឲ្យហៅអ្នកយាមទ្វារជាដើមថា ចូរពួកអ្នកទៅចាប់បុរោហិតចងដៃទៅក្រោយ ធ្វើវាឲ្យសមជាមនុស្សដែលត្រូវសម្លាប់ នាំចេញទៅក្រៅព្រះនគរ ទៅកាន់ផ្លូវបែកជា ៤ កាត់ក្បាលវា ។ ពួករាជបុរសប្រញាប់ប្រញាល់ទៅចាប់ព្រះពោធិសត្វចងក្រពាត់ស្វាបសេក ហើយត្រាច់វាយស្គរប្រកាស ។ ព្រះពោធិសត្វត្រិះរិះថា ព្រះរាជាត្រូវព្រះទេវីអាក្រក់នោះទូល

ញុះញង់ពិត គ្រានេះ អញត្រូវដោះខ្លួនដោយប្រាជ្ញាខ្លួនឯងក្នុងថ្ងៃនេះឲ្យបាន ទើបពោលនឹងរាជបុរសទាំងនោះថា នែអ្នកទាំងឡាយ ពួកអ្នកកុំអាលសម្លាប់ខ្ញុំឡើយ នាំខ្ញុំចូលគាល់ព្រះរាជាហើយ សឹមសម្លាប់ចុះ ។ ពួករាជបុរសសួរថា ព្រោះហេតុអ្វី ទើបប្រាប់ថា យើងជាខ្ញុំរាជការ ការងារដែលយើងធ្វើមានច្រើន យើងដឹងទីតាំងនៃកំណប់ទ្រព្យច្រើនកន្លែង ឃ្លាំងក៏យើងត្រួតត្រា បើមិននាំយើងចូលគាល់ព្រះរាជា ទ្រព្យជាច្រើននឹងសាបសូន្យ សូមទុកឱកាសល្មមយើងបានប្រាប់សម្បត្តិដល់ព្រះរាជាហើយ សឹមពួកអ្នកធ្វើទោសដែលត្រូវធ្វើខាងក្រោយចុះ ទើបពួករាជបុរសនាំព្រះពោធិសត្វចូលគាល់ព្រះរាជា ។

ព្រះរាជាគ្រាន់តែទតឃើញព្រះពោធិសត្វប៉ុណ្ណោះ ក៏ត្រាស់ថា នែព្រាហ្មណ៍ ហេតុអ្វី ឯងមិនកោតក្រែងយើង ហេតុអ្វី ទើបធ្វើកម្មអាក្រក់សាមាន្យដល់ម៉្លេះ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលបង្គំកើតក្នុងត្រកូលសោត្ថិយព្រាហ្មណ៍ ការសម្លាប់សត្វបំបាត់ជីវិត ត្រឹមតែស្រមោចខ្មៅ ស្រមោចក្រហម ក៏ទូលបង្គំមិនធ្លាប់ធ្វើ ទ្រព្យដែលគេមិនបានឲ្យ សូម្បីតែស្មៅមួយសរសៃ ក៏ទូលបង្គំមិនធ្លាប់កាន់យក ស្រីរបស់អ្នកដទៃ ទូលបង្គំក៏មិនធ្លាប់ត្រឹមតែសម្លឹងមើលដោយអំណាចសេចក្តីប្រាថ្នា ពាក្យកុហក សូម្បីត្រឹមតែសើចលេង ក៏ទូលបង្គំមិនធ្លាប់ពោល ទឹកស្រវឹងត្រឹមតែមួយតំណក់ចុងស្បូវ ក៏ទូលបង្គំមិនធ្លាប់ផឹក ទូលបង្គំប្រាសចាកកំហុសក្នុងព្រះអង្គ តែព្រះនាងជាបុគ្គលពាល ចាប់ដៃទូលបង្គំដោយអំណាចនៃសេចក្តីប្រាថ្នា ទាំងដែលទូលបង្គំហាម បែរជាសម្លុតទូលបង្គំ ដោយបើកនូវអំពើអាក្រក់ដែលខ្លួនធ្វើ ប្រាប់

ដល់ទូលបង្គំ ហើយចូលទៅខាងក្នុងបន្ទប់ ទូលបង្គំប្រាសចាកកំហុស តែជនទាំង ៦៤ នាក់ ដែលកាន់រាជសាសន៍មក មានកំហុស បពិត្រព្រះសម្មតិទេព សូមត្រាស់ហៅអ្នកទាំងនោះមកសាកសួរថា ជនទាំងនោះធ្វើតាមពាក្យរបស់ព្រះនាង ឬមិនបានធ្វើ ។ ព្រះរាជាឲ្យចងជនទាំង ៦៤ ហើយត្រាស់ឲ្យហៅព្រះទេវីចូលគាល់ មានព្រះតម្រាស់ថា នាងធ្វើកម្មអាក្រក់ជាមួយអ្នកនេះ ឬមិនបានធ្វើ ព្រះនាងក្រាបទូលថា ខ្ញុំម្ចាស់ធ្វើ ទើបត្រាស់ឲ្យចងនាងក្រពាត់ស្ពាបសេក ហើយទ្រង់ត្រាស់ថា ចូរពួកឯងកាត់ក្បាលអ្នកទាំង ៦៤ នេះចោល ។ គ្រានោះ ព្រះពោធិសត្វទូលថា បពិត្រមហារាជ អ្នកទាំងនេះមិនមានទោស ព្រះទេវីបង្គាប់ឲ្យធ្វើតាមចិត្តរបស់ខ្លួន អ្នកទាំងនេះមិនមានកំហុស ហេតុនោះ សូមទ្រង់អភ័យទោសដល់មនុស្សទាំងនេះចុះ សូម្បីព្រះទេវីក៏មិនមានទោស ធម្មតាស្រីទាំងឡាយជាអ្នកមិនឆ្អែតដោយមេថុនធម្ម ពិតហើយ ការមិនឆ្អែតដោយមេថុនធម្មនេះ ជាសភាវធម៌ប្រចាំកំណើត វត្ថុដែលគួរមាន ក៏រមែងមានដល់ពួកនាងប៉ុណ្ណោះ ព្រោះហេតុនោះ សូមទ្រង់លើកលែងទោសព្រះនាងផងចុះ ។ ព្រះពោធិសត្វ ទូលឲ្យព្រះរាជាយល់ដោយប្រការផ្សេងៗ រហូតទ្រង់ដោះលែងជនទាំង ៦៤ និងព្រះទេវីពាល ព្រះរាជទានឋានៈតាមតំណែងដើមដល់មនុស្សទាំងពួង ព្រះពោធិសត្វកាលឲ្យព្រះរាជាដោះលែងមនុស្សទាំងអស់ហើយ ទ្រង់ក៏តែងតាំងព្រះពោធិសត្វក្នុងតំណែងដើម ចូល

ទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ពួកបណ្ឌិតមិនគួរចាប់ចង បែរជាចងទៅក្រោយបាន ព្រោះពាក្យដែលមិនពិតប្រាកដរបស់បុគ្គលពាល ពួកបណ្ឌិតរួចផុតបានអំពីការដែលត្រូវចងទៅក្រោយ ដោយវាចាដែលប្រពៃ តាមហេតុ ឈ្មោះថា បុគ្គលពាល បុគ្គលអ្នកដែលមិនគួរចង ក៏ធ្វើឲ្យជាប់ចំណងបាន បណ្ឌិតរមែងដោះស្រាយឲ្យរួចចាកការចងទាំងឡាយបានយ៉ាងនេះ ហើយពោលគាថានេះថា

ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់
រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា
ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អពទ្ធា** បានដល់ បុគ្គលដែលមិនគួរចង ។ បទថា **បភាសរេ** បានដល់ រមែងនិយាយ គឺរមែងប្រាប់ រមែងពោល ។

ព្រះពោធិសត្វសម្ដែងធម៌ដល់ព្រះរាជាដោយគាថានេះ ដោយប្រការដូច្នេះ ហើយ ក្រាបទូលសូមអនុញ្ញាតដើម្បីបព្វជាថា បពិត្រព្រះសម្មតិទេព ទុក្ខទាំងនេះ ទូលបង្គំបានព្រោះការនៅគ្រប់គ្រងផ្ទះ ឥឡូវនេះ ទូលបង្គំមិនមានកិច្ចដោយការគ្រប់គ្រងផ្ទះ សូមទ្រង់អនុញ្ញាតបព្វជ្ជាដល់ទូលបង្គំចុះ ហើយលះបុគ្គលដែលជាញាតិដែលកំពុងមានមុខជោកដោយទឹកភ្នែក និងសម្បត្តិដ៏ច្រើន

បួសជាឥសី ក្នុងព្រៃហិមពាន្ត ញ៉ាំងឈាន និងសមាបត្តិឲ្យកើតហើយ បាន ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ទេវីកំណាចក្នុងកាលនោះ បានមកជាចិញ្ចមាណវិកាក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯបុរោហិតក្នុងកាលនោះ គឺតថាគត នេះឯង ។ល។

**អដ្ឋកថា ពន្ធនមោក្ខជាតក ចប់**

**ហំសិវគ្គទី ១២ ចប់**

# សុត្តន្តបិដក

# កុសនាឡិវគ្គ

## កុសនាឡិជាតក

[ ១២១ ] ( រុក្ខទេវតាពោលថា ) ជនស្មើគ្នាក្តី ទាំងជនប្រសើរជាងក្តី គប្បីធ្វើ ( នូវមិត្តធម៌ ) សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ ( នូវមិត្តធម៌ដែរ ) ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តមក្នុងកាលដែលមានសេចក្តីវិនាស ដូចជាខ្ញុំជាទេវតា ឈ្មោះកុសនាឡិ និងទេវតាឈ្មោះរុចា ធ្វើនូវប្រយោជន៍ដ៏ឧត្តម ( ក្នុងកាលដែលមានសេចក្តីវិនាស ) ។

កុសនាឡិជាតកទី ១ ចប់

# អដ្ឋកថា
# កុសនាឡិវគ្គ

## កុសនាឡិជាតក

[ ១២១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមិត្រ ដែលស្មោះត្រង់ក្នុងការងាររបស់អនាថបិណ្ឌិក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ករេ សរិក្ខោ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ពួកមិត្រស្និទ្ធស្នាល និងញាតិរបស់អនាថបិណ្ឌិករួមគ្នាឃាត់រឿយៗ ថា លោកមហាសេដ្ឋី បុគ្គលនេះ មិនស្មើនឹងលោកដោយជាតិ គោត្រ ទ្រព្យ និងសិរីជាដើម ទាំងមិនដូចលោកឡើយ ហេតុអ្វី ទើបលោកធ្វើនូវការស្និទ្ធស្នាលជាមួយបុគ្គលនេះ កុំធ្វើឡើយ ឯអនាថបិណ្ឌិកបែរជាពោលថា ធម្មតាការស្និទ្ធស្នាលជាមួយមិត្រដែលទាបជាងក្តី ស្មើគ្នាក្តី ដែលខ្ពស់ជាងក្តី គួរធ្វើទាំងអស់ ហើយមិនជឿពាក្យរបស់មនុស្សទាំងនោះ កាលទៅកាន់ស្រុកសួយ ក៏តាំងបុរសនោះឲ្យជាអ្នកមើលថែទ្រព្យសម្បត្តិ ហើយទើបទៅ ។ រឿងទាំងអស់ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងរឿងកាឡកិណ្ណីនោះឯង ប្លែកតែក្នុងរឿងនេះ កាលអនាថបិណ្ឌិកក្រាបទូលរឿងក្នុងផ្ទះរបស់ខ្លួនហើយ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី ធម្មតាមិត្រជាបុគ្គលតូចតាចមិនមាន ឯភាពជាអ្នកអាចរក្សាមិត្តធម៌បាន ជាប្រមាណក្នុងរឿងមិត្រនេះ ធម្មតាមិត្រស្មើខ្លួនក្តី ទាបជាងខ្លួនក្តី ក្រៃលែងជាងខ្លួនក្តី គួរ

សេពគប់ ព្រោះថា មិត្រទាំងអស់នោះ រមែងជួយការៈដែលមកដល់ខ្លួនបាន ទាំងអស់ ឥឡូវនេះ អ្នកអាស្រ័យមិត្តដែលត្រួតត្រាការងាររបស់ខ្លួន ទើបជាម្ចាស់របស់កំណាប់បានតទៅ ឯបុរាណកបណ្ឌិត អាស្រ័យមិត្រដែលត្រួតត្រាការងារ ទើបជាម្ចាស់របស់វិមានបាន ដូច្នេះ កាលអនាថបិណ្ឌិកទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាទេវតា ត្រង់គុម្ពស្បូវភ្លាំង ក្នុងឧទ្យានរបស់ព្រះរាជា ។ ក្នុងឧទ្យាននោះឯង មានដើមរុចាដែលជាឈើមង្គលអាស្រ័យមង្គលសិលា មានដើមត្រង់ល្អ ដល់ព្រមដោយបរិមណ្ឌល មែកនិងប្រគាប បានទទួលការលើកតម្កើងអំពីរាជសម្នាក់ ដែលហៅថា ដើមសមុខកក៏មាន ។ ទេវរាជដែលមានសក្តិមួយរូប កើតត្រង់ដើមឈើនោះ ព្រះពោធិសត្វមានសេចក្តីស្និទ្ធស្នាលជាមួយទេវរាជនោះ កាលនោះ ព្រះរាជាប្រថាប់នៅក្នុងប្រាសាទសសរមួយ សសរប្រាសាទនោះរង្គើ ។ គ្រានោះ ពួករាជបុរសនាំគ្នាក្រាបទូលការញាប់ញ័ររបស់សសរនោះដល់ព្រះរាជាៗ ត្រាស់ឲ្យពួកជាងចូលគាល់ ត្រាស់ថា នែបា សសរនៃមង្គលប្រាសាទញាប់ញ័រហើយ ចូរពួកអ្នកយកសសរខ្លឹមមួយដើម ធ្វើសសរនោះកុំឲ្យរង្គើចុះ ។ ពួកជាងទាំងនោះក្រាបទូលទទួលព្រះតម្រាស់របស់ព្រះរាជាថា សាធុ ហើយនាំគ្នាស្វែងរកដើមឈើដែលសមគួរដល់សសរនោះ ក៏មិនឃើញក្នុងទីដទៃ ទើបចូលទៅកាន់ឧទ្យាន ឃើញដើមសមុខកនោះហើយ នាំគ្នាទៅកាន់សម្នាក់ព្រះ

រាជា កាលព្រះរាជាត្រាស់សួរថា នែបាទាំងឡាយ ដើមឈើដែលសមគួរដល់យើងនោះ ពួកអ្នកឃើញហើយឬ ទើបក្រាបទូលថា ឃើញហើយព្រះអង្គ តែមិនអាចកាប់ដើមឈើនោះបាន ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី នាំគ្នាក្រាបទូលថា ពួកទូលបង្គំមិនឃើញដើមឈើក្នុងទីដទៃ នាំគ្នាចូលកាន់ព្រះរាជឧទ្យាន ក្នុងព្រះឧទ្យាននោះ វៀរដើមមង្គលព្រឹក្សហើយ មិនឃើញឈើដទៃ ដូច្នោះ ដោយទីជាមង្គលព្រឹក្ស ទើបពួកទូលបង្គំមិនហ៊ានកាប់ដើមឈើនោះ ព្រះរាជាត្រាស់ថា ចូរពួកអ្នកកាប់ធ្វើប្រាសាទឲ្យមាំទាំចុះ យើងនឹងតាំងដើមឈើដទៃជាមង្គលព្រឹក្ស ។

ពួកជាងឈើទាំងនោះ ទទួលព្រះតម្រាស់ហើយ នាំគ្នាកាន់គ្រឿងពលីកម្មទៅកាន់ឧទ្យាន បបួលគ្នាថា នឹងកាប់ក្នុងថ្ងៃស្អែក ហើយធ្វើពលីកម្មដល់ដើមឈើ ស្រេចហើយនាំគ្នាចេញទៅ រុក្ខទេវតាដឹងហើយ គិតថា ស្អែកនេះវិមានរបស់យើងនឹងវិនាស យើងនឹងនាំពួកក្មេងទៅទីណាហ្ន៎ កាលមិនឃើញទីដែលគួរទៅ ក៏ឱបកូនតូចៗ យំ ។ ពួករុក្ខទេវតាដែលរាប់អានទេវតានោះនាំគ្នាសាកសួរថា តើមានរឿងអ្វី កាលស្តាប់រឿងនោះហើយ ក៏មិនឃើញឧបាយដែលឃាត់ជាងឈើបាន នាំគ្នាបោះបង់ទេវតានោះ ទ្រហោយំដូចគ្នា ។

ក្នុងសម័យនោះ ព្រះពោធិសត្វត្រិះរិះថា អញនឹងទៅសួរសុខទុក្ខរុក្ខទេវតា ទើបទៅទីនោះ ស្តាប់ហេតុនោះហើយ ក៏លួងលោមទេវតានោះថា ណ្ហើយចុះ កុំទោមនស្សឡើយ ខ្ញុំមិនឲ្យគេកាប់ដើមឈើនោះឡើយ ស្អែកនេះ គ្រាពួកជាងមក ពួកអ្នកចាំមើលហេតុការណ៍របស់ខ្ញុំចុះ ។ ស្អែកឡើង កាលពួក

ជាងឈើនាំគ្នាមក ក៏កាឡាខ្លួនជាបង្គួយ រត់នាំមុខពួកជាងឈើទៅ ចូលទៅកាន់គល់របស់មង្គលព្រឹក្ស ធ្វើហាក់បីដូចជាដើមឈើនោះជាប្រហោង វារឡើងតាមព្រង់ឈើខាងក្នុង ទៅចេញឯចុង ដេកធ្វើក្បាលផ្ងក់ៗ ។ មេជាងធំឃើញបង្គួយនោះហើយ ក៏យកដៃគោះដើមឈើនោះ ហើយតិះដៀលដើមឈើធំដែលមានខ្លឹមថា ដើមឈើនេះមានប្រហោង មិនមានខ្លឹម ម្សិលមិញមិនទាន់បានពិនិត្យមើលសព្វគ្រប់ ជ្រុលធ្វើពលីកម្ម ហើយនាំគ្នាចៀសចេញទៅ រុក្ខ-ទេវតាអាស្រ័យព្រះពោធិសត្វ បានជាម្ចាស់របស់វិមាន ដើម្បីជាការទទួលរុក្ខ-ទេវតានោះ ទេវតាដែលស្និទ្ធស្នាលជាច្រើនប្រជុំគ្នា រុក្ខទេវតាត្រេកអរថា អញបានវិមានហើយ កាលពោលគុណរបស់ព្រះពោធិសត្វ ក្នុងកណ្ដាលទីប្រជុំនៃទេវតាទាំងនោះ ទើបពោលថា នៃទេវតាដ៏ចម្រើនទាំងឡាយ យើងសូម្បីជាទេវតាមានសក្តិធំ ក៏មិនបានដឹងឧបាយនេះ ព្រោះបញ្ញាទន់ខ្សោយ ឯទេវតាកុសនាឡិ បានធ្វើឲ្យយើងជាម្ចាស់របស់វិមានបាន ព្រោះញាណសម្បត្តិរបស់ខ្លួន ធម្មតាមិត្រ មិនមែនជ្រើសរើសទាល់តែស្មើគ្នា ក្រៃលែងជាងគ្នា ឬទាបជាងគ្នា គួររាប់អានបានទាំងអស់ មិត្រគ្រប់គ្នា អាចបំបាត់ទុក្ខដែលកើតដល់មិត្រឲ្យមាំទាំ តាំងនៅក្នុងសេចក្ដីសុខបាន តាមកម្លាំងរបស់ខ្លួននោះឯង កាលពណ៌នាមិត្តធម៌ហើយ ពោលគាថានេះថា

ជនស្មើគ្នាក្ដី ទាំងជនប្រសើរជាងក្ដី គប្បីធ្វើ ( នូវមិត្តធម៌ )
សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ ( នូវមិត្តធម៌ដែរ )
ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តមក្នុងកាលដែលមាន

សេចក្ដីវិនាស ដូចជាខ្ញុំជាទេវតា ឈ្មោះកុសនាឡិ និងទេវតាឈ្មោះរុចា ធ្វើនូវប្រយោជន៍ដ៏ឧត្ដម ( ក្នុងកាលដែលមានសេចក្ដីវិនាស ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ការេ សរិក្ខោ** សេចក្ដីថា ជាបុគ្គលស្មើគ្នាដោយឋានៈ មានជាតិជាដើម ក៏គួរសេពគប់គ្នា ។

បទថា **អថវាបិ សេដ្ឋោ** សេចក្ដីថា សូម្បីជាអ្នកខ្ពស់ជាង គឺក្រៃលែងជាងដោយជាតិជាដើម ក៏គួរសេពគប់ ។

បទថា **និហីនកោ វាបិ ករេយ្យ ឯកោ** សេចក្ដីថា សូម្បីជាបុគ្គលទាបដោយជាតិជាដើមម្នាក់ ក៏គប្បីសេពគប់ ។ លោកសម្ដែងអត្ថថា ព្រោះហេតុនោះ មនុស្សទាំងអស់នេះ គួរធ្វើជាមិត្រទាំងអស់ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិត្រទាំងនោះ កាលការវិនាសកើតឡើង ក៏គប្បីធ្វើប្រយោជន៍ដ៏ឧត្ដមឲ្យបាន ពង្រីកសេចក្ដីថា ព្រោះមនុស្សទាំងអស់នេះ កាលវិបត្តិកើតឡើងដល់សម្លាញ់ហើយ ក៏ជួយសម្រាលភារៈដែលមកដល់ខ្លួន ធ្វើប្រយោជន៍ខ្ពង់ខ្ពស់ឲ្យបាន គឺជួយដោះនូវសម្លាញ់នោះចាកទុក្ខផ្លូវកាយ ទុក្ខផ្លូវចិត្តបាន ព្រោះហេតុនោះ មិត្រសូម្បីទាបជាង ក៏គួររាប់អាននោះឯង នឹងពោលទៅថ្វីដល់មិត្រក្រៅអំពីនេះ ក្នុងអត្ថនោះ មានរឿងនេះជាឧបមា ។

បទថា **យថា អហំ កុសនាឡិ រុចាយំ** សេចក្ដីថា ដូចខ្ញុំជាទេវតាកើតត្រង់ដើមរុចា និងទេវតាដែលកើតត្រង់គុម្ពស្បូវភ្លាំង មានសក្តិតូច ធ្វើនូវការស្និទ្ធស្នាលគ្នា ក្នុងយើងទាំង ២ នោះ ខ្ញុំ សូម្បីមានសក្តិធំ ក៏មិនអាចបំបាត់

ទុក្ខដែលកើតដល់ខ្លួនបាន ព្រោះជាបុគ្គលល្ងង់ខ្លៅ មិនឈ្លាសក្នុងឧបាយ តែអាស្រ័យទេវតានេះ សូម្បីមានសក្តិតូច ក៏ជាបណ្ឌិត ផុតចាកទុក្ខបានដូច្នោះ ។ ព្រោះហេតុនោះ បុគ្គលដទៃ បំណាងនឹងផុតទុក្ខ ក៏មិនចាំបាច់គិតដល់ភាពស្មើគ្នា និងភាពវិសេសជាងគ្នា គប្បីរាប់អានមិត្រទាំងទាប និងទាំងខ្ពស់ ។

រុចាទេវតា សម្តែងធម៌ដល់ពួកទេវតាដោយគាថានេះ តាំងនៅដរាបដល់អស់អាយុក្ខ័យ ទៅតាមយថាកម្ម មួយអន្លើនឹងកុសនាឡិទេវតាផងដែរ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា រុចាទេវតាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ឯកុសនាឡិទេវតា ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា កុសនាឡិជាតក ចប់**

# សុត្តន្តបិដក

## ទុម្មេធជាតក

[ ១២២ ] *( ទម័កដ៏រពោលថា )* *បុគ្គលឥតប្រាជ្ញា បានយសបរិវារ ហើយ តែងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់ខ្លួន ទាំងប្រតិបត្តិដើម្បីបៀតបៀនដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង ។*

**ទុម្មេធជាតកទី ២ ចប់**

# អដ្ឋកថា

## ទុម្មេធជាតក

[ ១២២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យសំ លទ្ធាន ទុម្មេធោ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ភិក្ខុទាំងឡាយ នាំគ្នាពោលទោសរបស់ទេវទត្ត ក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តភិក្ខុសម្លឹងមើលព្រះភក្ត្រដែលទ្រទ្រង់សិរី ដូចព្រះចន្ទពេញវង់ និងអត្តភាពដែលប្រដាប់ដោយអនុព្យញ្ជនៈ ៨០ និងមហាបុរិសលក្ខណៈ ៣២ ប្រការ ចោមរោមដោយព្រះរស្មីប្រមាណមួយព្យាម ដល់នូវលម្អដ៏លើស បញ្ចេញព្រះពុទ្ធរស្មីជាគូៗ ដោយអាការផ្សេងៗ ស្តាប់សំឡេងរបស់ព្រះតថាគតហើយ មិនអាចញុំាងចិត្តឲ្យជ្រះថ្លាបាន មិនមែនតែប៉ុណ្ណោះ ទាំងធ្វើនូវឫស្យាទៀតផង មិនអាចអត់ធន់ ក្នុងកាលដែលមានបុគ្គលពោលថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់ប្រកបដោយសីល សមាធិ បញ្ញា វិមុត្តិ ញាណទស្សនៈបែបនេះ ធ្វើនូវការប្រណែនតែម្យ៉ាង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តធ្វើនូវការប្រណែនក្នុងតថាគត ក្នុងកាលមានអ្នកដទៃពោលដល់គុណរបស់តថាគត សូម្បីក្នុងកាលមុន ក៏ធ្លាប់ធ្វើហើយដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទមគធៈ សោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ព្រះពោធិសត្វកើតក្នុងកំណើតដំរីសសុទ្ធ ដល់ព្រមដោយរូបសម្បត្តិ ដូចពណ៌នាមកហើយខាងដើម ព្រះរាជាអង្គនោះទ្រង់ព្រះតម្រិះថា ដំរីនេះសម្បូរដោយលក្ខណៈ ទើបទ្រង់តែងតាំងជាមង្គលហត្ថី លុះដល់ថ្ងៃមហោស្រពមួយ ទ្រង់ឲ្យប្រដាប់តាក់តែងនគរទាំងមូល ឲ្យស្អាតដូចទេវនគរ ទ្រង់ឡើងកាន់មង្គលហត្ថី ដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយរាជានុភាពធំ មហាជនឈរមើលក្នុងទីនោះៗ ឃើញសរីរៈដ៏ល្អក្រៃលែង ដោយសម្បត្តិរបស់មង្គលហត្ថី ក៏នាំគ្នាពណ៌នាដល់មង្គលហត្ថីប៉ុណ្ណោះថា មានរូបស្អាត ដំណើរល្អ ឫកពាអង់អាច សម្បូរដោយលក្ខណៈពិត ស្តេចដំរីសបែបនេះ សមគួរដល់បុណ្យបារមីរបស់ស្តេចចក្រពត្តិ ។ ព្រះរាជាទ្រង់ស្តាប់នូវសំឡេងសរសើរមង្គលហត្ថី មិនអាចនឹងទប់ព្រះហឫទ័យបាន ទ្រង់កើតការប្រណែន ត្រិះរិះថា ថ្ងៃនេះឯង អញនឹងឲ្យវាដល់នូវការអស់ជីវិតឲ្យបាន ហើយទ្រង់ឲ្យហៅនាយហត្ថាចារ្យមកត្រាស់សួរថា ដំរីនេះធ្វើអ្វីកើតខ្លះ អ្នកឲ្យសិក្សាអ្វីខ្លះ នាយហត្ថាចារ្យទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំឲ្យសិក្សាល្អហើយ ព្រះរាជាត្រាស់សួរថា បង្វឹកបានល្អហើយឬ ទើបក្រាបទូលអះអាងថា បង្វឹកល្អហើយ ព្រះរាជាត្រាស់ថា បើបង្វឹកល្អហើយ ឯងអាចឲ្យវាឡើងកាន់កំពូលភ្នំវេបុលបានឬ ហត្ថាចារ្យក្រាបទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះ សូមយាងមកចុះ ។ ព្រះរាជាទ្រង់ចុះអំពីដំរី ឲ្យហត្ថាចារ្យឡើងអង្គុយលើដំរីទៅដល់ជើងភ្នំ កាលហត្ថាចារ្យអង្គុយលើខ្នងដំរី

ដល់កំពូលភ្នំវេបុលហើយ ទ្រង់ចោមរោមដោយពួកអមាត្យ ឡើងកាន់កំពូលភ្នំ ហើយទ្រង់បង្គាប់ហត្ថាចារ្យឲ្យបញ្ជាដំរីបែរមុខទៅរកជ្រោះ ត្រាស់ថា ឯងប្រាប់ថា ដំរីនេះបង្ហឹកល្អហើយ ចូរឲ្យវាឈរជើង ៣ ប៉ុណ្ណោះ នាយហត្ថាចារ្យអង្គុយលើខ្នង បានឲ្យសញ្ញាដល់ដំរីដោយកែងជើង ឲ្យដំរីដឹងថា នែបាចូរបាឈរជើង ៣ ចុះ ព្រះរាជាត្រាស់ថា ចូរឲ្យវាឈរដោយជើងមុខ ២ ប៉ុណ្ណោះចុះ ដំរីមហាសត្វ ក៏លើកជើងក្រោយទាំង ២ ឡើង ឈរដោយជើងមុខទាំង ២ កាលព្រះរាជាត្រាស់ថា ចូរឲ្យវាឈរជើងក្រោយ ២ ប៉ុណ្ណោះ ក៏លើកជើងមុខទាំង ២ ឡើង ឈរដោយជើងក្រោយ កាលព្រះរាជាបញ្ជាថា ឲ្យឈរជើង ១ ក៏លើកជើងទាំង ៣ ឡើង ឈរដោយជើង ១ ប៉ុណ្ណោះ ព្រះរាជាទ្រង់ជ្រាបភាពដែលស្តេចដំរីនោះមិនធ្លាក់ក្នុងជ្រោះ ក៏ត្រាស់ថា បើអាចពិត ចូរឲ្យវាឈរក្នុងអាកាសចុះ ហត្ថាចារ្យគិតថា ក្នុងជម្ពូទ្វីប ដំរីដែលឈ្មោះថា បង្ហឹកល្អហើយដូចដំរីនេះ មិនមានឡើយ តែព្រះរាជាអង្គនេះ មានបំណងឲ្យដំរីនេះធ្លាក់ជ្រោះស្លាប់ដោយឥតសង្ស័យ គិតហើយ ក៏ខ្សឹបត្រង់ត្រចៀកថា នែបា ព្រះរាជានេះ បំណងឲ្យអ្នកធ្លាក់ជ្រោះស្លាប់ អ្នកមិនគួរដល់ព្រះរាជា បើអ្នកមានកម្លាំង ល្មមទៅក្នុងអាកាសបាន ក៏ចូរនាំយើងដែលអង្គុយលើខ្នង ហោះឡើងកាន់អាកាស ទៅកាន់នគរពារាណសីចុះ ។ ព្រះមហាសត្វដល់ព្រមដោយឫទ្ធិដែលកើតអំពីបុណ្យ បានឈរក្នុងអាកាសក្នុងខណៈនោះឯង ហត្ថាចារ្យទូលថា បពិត្រមហារាជ ដំរីនេះដល់ព្រមដោយបុញ្ញឫទ្ធិ មិនគួរដល់អ្នកមានបុណ្យតិច បញ្ញាថោកថយដូចព្រះអង្គទេ គួរដល់

ព្រះរាជាដែលជាបណ្ឌិត ដល់ព្រមដោយបុណ្យ ឈ្មោះថា បុគ្គលមានបុណ្យតិចដូចព្រះអង្គ ទោះបីបានពាហនៈបែបនេះ ក៏មិនបានដឹងគុណ បំណាន់ញ៉ាំងពាហនៈនេះ និងយសសម្បត្តិដ៏សេសឲ្យវិនាសតែម្យ៉ាង ទាំងដែលអង្គុយលើកដំរី ពោលគាថានេះថា

បុគ្គលឥតប្រាជ្ញា បានយសបរិវារហើយ តែងប្រព្រឹត្តនូវកម្មមិនជា
ប្រយោជន៍ដល់ខ្លួន ទាំងប្រតិបត្តិដើម្បីបៀតបៀនដល់ខ្លួនឯងផង
ដល់ជនទាំងឡាយដទៃផង ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះថា បពិត្រមហារាជ បុគ្គលល្ងង់ខ្លៅ គឺបុគ្គលដែលគ្មានបញ្ញាដូចព្រះអង្គ បាននូវបរិវារសម្បត្តិហើយ រមែងប្រព្រឹត្តនូវសេចក្តីវិនាសដល់ខ្លួន ព្រោះហេតុអ្វី ព្រោះបុគ្គលល្ងង់ទាំងនោះ ស្រវឹងក្នុងយសហើយ មិនបានដឹងនូវការដែលគួរធ្វើ និងមិនគួរធ្វើ រមែងបដិបត្តិដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃៗ ។ ការលំបាក និងកើតឡើងនៃទុក្ខ ហៅថា ការបៀតបៀន ។ រមែងប្រព្រឹត្តទៅយ៉ាងនេះ ដើម្បីសេចក្តីលំបាក និងការកើតឡើងនៃទុក្ខ ។

នាយហត្ថាចារ្យសម្តែងធម៌ដល់ព្រះរាជា ដោយគាថានេះ ដោយប្រការដូច្នេះហើយ ក្រាបទូលថា ពេលនេះ សូមយាងប្រថាប់នៅចុះ ហើយឲ្យដំរីហោះទៅក្នុងអាកាស ឆ្ពោះទៅកាន់នគរពារាណសីនោះឯង ឈប់នៅក្នុងអាកាស ត្រង់លានព្រះរាជវាំង មនុស្សក្នុងនគរគោឡោ ពពាក់ពពូនដោយសំឡេងតែមួយថា ដំរីសរបស់ព្រះរាជានៃយើងមកតាមអាកាស ឈប់ត្រង់

លានព្រះរាជវាំង រាជបុរសទាំងឡាយប្រញាប់ក្រាបទូលព្រះរាជាៗ យាងមកត្រាស់ថា បើអ្នកមកដើម្បីជាឧបភោគដល់យើង សូមចុះមកឈរត្រង់ផែនដីចុះ ព្រះពោធិសត្វក៏ចុះកាន់ផែនដី ហត្ថាចារ្យក៏ចុះមកថ្វាយបង្គំព្រះរាជាៗ ត្រាស់ថា នែបា បាមកអំពីណា ក៏ក្រាបទូលថា បពិត្រព្រះអង្គ មកអំពីនគររាជគ្រឹះ ហើយទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ព្រះរាជាត្រាស់ថា នែបា ការដែលបាមកទីនេះ ធ្វើនូវវត្ថុដែលគួរត្រេកអរពិតៗ ទ្រង់សប្បាយព្រះហឫទ័យ ត្រាស់ឲ្យរៀបចំព្រះនគរ ទ្រង់តាំងស្តេចដំរីក្នុងតំណែងមង្គលហត្ថី ទ្រង់ចែករាជសម្បត្តិទាំងអស់ជា ៣ ចំណែក ១ ចំណែក ប្រទានដល់ព្រះពោធិសត្វ ១ ចំណែក ដល់ហត្ថាចារ្យ ១ ចំណែក ទ្រង់គ្រប់គ្រង ។ តាំងអំពីព្រះពោធិសត្វមកហើយនោះឯង រាជសម្បត្តិក្នុងសកលជម្ពូទ្វីប ក៏ធ្លាក់ក្នុងកណ្តាប់ព្រះហស្តរបស់ព្រះរាជា ទ្រង់ជាព្រះរាជាធំក្នុងជម្ពូទ្វីប ទ្រង់បំពេញកុសលមានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាមគធៈក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះបាទពារាណសី ក្នុងកាលនោះ បានមកជាសារីបុត្រ ហត្ថាចារ្យក្នុងកាលនោះ បានមកជាអានន្ទ ឯដំរីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាទុម្មេធជាតក ចប់**

# សុត្តន្តបិដក

## ឆន្ទលីសជាតកៈ

[ ១២៣ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) បុគ្គលពាលរមែងពោលនូវវាចា ដែលមិនទូទៅក្នុងវត្ថុទាំងពួង ក្នុងទីទាំងពួង មាណពនេះមិនស្គាល់ទឹកដោះជូរ មិនស្គាល់ចន្ទោលនង្គ័លឡើយ ទើបសម្គាល់នូវទឹកដោះជូរ និងទឹកដោះស្រស់ ថាជាចន្ទោលនៃនង្គ័លទៅវិញ ។

**នង្គលីសជាតកទី ៣ ចប់**

# អដ្ឋកថា

## ឆគ្គលីសជាតក

[ ១២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសព្វត្ថគាមឹ វាចំ** ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈនោះ កាលពោលធម៌ មិនបានដឹងបទដែលគួរ និងមិនគួរថា ក្នុងទីនេះ គួរពោលបទនេះ ក្នុងទីនេះ មិនគួរពោលបទនេះ ក្នុងការងារមង្គល ពោលអវមង្គល ពោលអនុមោទនាអវមង្គលថា ប្រេតទាំងឡាយ មកកាន់ផ្ទះរបស់ខ្លួន ឋិតនៅខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ .... ។ កាលការងារអវមង្គល បែរជាពោលអនុមោទនាថា ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារកសួស្តី បានគិតរកមង្គលទាំងឡាយ .... ហើយពោលបញ្ជាក់ថា សូមឲ្យពួកអ្នកអាចធ្វើមង្គលបែបនោះឲ្យបាន ១០០ ដង ១០០០ ដងចុះ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយនាំគ្នាលើករឿងនេះឡើង សន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ លោឡុទាយិភិក្ខុ មិនបានដឹងបទដែលគួរ និងមិនគួរ ពោលវាចាដែលមិនគួរ ពោលទូទៅគ្រប់ទីកន្លែង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលលោឡុទាយីនេះ មានបដិភាណមិនរហ័ស កាលពោល

ក៏មិនដឹងបទដែលគួរ និងមិនគួរ សូម្បីក្នុងកាលមុនក៏យ៉ាងនេះ លោកជាអ្នកខ្ជិលខ្ជាលនោះឯង ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល ចម្រើនវ័យហើយ រៀនសព្វសិប្បវិទ្យាក្នុងនគរតក្កសិលា បានជាអាចារ្យទិសាបាមោក្ខនៅក្នុងនគរពារាណសី បង្រៀនសិប្បវិទ្យាដល់មាណព ៥០០ នាក់ ។ ក្នុងបណ្ដាមាណពទាំងនោះ មានមាណពម្នាក់ មានបដិភាណទន់ខ្សោយ ជាអ្នកខ្ជិលខ្ជាល ជាធម្មន្តេវាសិក រៀនសិប្ប: តែមិនអាចរៀនបាន ព្រោះជាមនុស្សល្ងង់ តែបានជាអ្នកឧបការៈចំពោះព្រះពោធិសត្វ ធ្វើកិច្ចគ្រប់យ៉ាង ឲ្យដូចជាទាស: ។ ថ្ងៃមួយ ព្រះពោធិសត្វបរិភោគអាហារល្ងាចហើយ ដេកលើគ្រែពោលនឹងមាណពនោះ ដែលធ្វើការគក់ប្របាច់ដៃ ជើង និងខ្នងថា នែបា បាជួយកល់ជើងគ្រែសិន ហើយសឹមទៅចុះ មាណពកល់ជើងគ្រែម្ខាងហើយមិនមានអ្វីកល់ម្ខាងទៀត ក៏យកជើងរបស់ខ្លួនកល់អស់មួយយប់ ។ ព្រះពោធិសត្វក្រោកឡើងពេល ព្រឹក ឃើញហើយ សួរថា នែបា បាអង្គុយធ្វើអ្វី មាណពឆ្លើយថា បពិត្រលោកអាចារ្យ ខ្ញុំរកអ្វីកល់ជើងគ្រែមិនបាន ក៏លើកជើងគ្រែដាក់លើជើងរបស់ខ្ញុំ ហើយអង្គុយ ។ ព្រះពោធិសត្វសង្វេគគិតថា មាណពនេះមានឧបការៈច្រើនដល់អញក្រៃពេក ក្នុងបណ្ដាមាណពមានប្រមាណប៉ុណ្ណោះ មាណពនេះល្ងង់ខ្លៅជាងសម្មាញ់ឯទៀត មិនអាចសិក្សាសិប្ប:បាន ធ្វើដូចម្ដេចហ្ន៎ អញគប្បីធ្វើឲ្យឈ្លាសឡើងបាន ហើយក៏បានកើត

គំនិតឡើងថា មានឧបាយមួយ អញត្រូវសួរមាណពនេះ ដែលទៅរកឧស រកបន្លែត្រឡប់មកថា ថ្ងៃនេះឯងឃើញអ្វី ឯងធ្វើអ្វី កាលបើដូច្នេះ គេនឹងត្រូវប្រាប់ថា ថ្ងៃនេះ ខ្ញុំឃើញវត្ថុនេះ ធ្វើកិច្ចឈ្មោះនេះ ហើយអញត្រូវសួរថា អ្នកឃើញអ្នកធ្វើដូចម្ដេច បុរសនេះនឹងប្រាប់ដោយឧបមា និងដោយហេតុថា ដូច្នេះ ដូច្នេះ ដោយវិធីនេះ អញឲ្យមាណពនេះពោលឧបមា និងហេតុហើយ នឹងធ្វើឲ្យមាណពនេះឈ្លាសបានដោយឧបាយនេះ ទើបអាចារ្យហៅមាណពមកប្រាប់ថា បាមាណព តាំងអំពីនេះទៅ ក្នុងទីដែលឯងចូលទៅរកឧស និងបន្លែ ឯងបានឃើញ បានបរិភោគ បានផឹក ឬបានទំពារបស់ណាក្នុងទីនោះ កាលមកហើយ ត្រូវប្រាប់វត្ថុនោះដល់យើង ។

មាណពទទួលថា សាធុ ថ្ងៃមួយ ទៅព្រៃរកឧសជាមួយមាណពទាំងឡាយ ឃើញពស់ក្នុងព្រៃ កាលមកហើយក៏ប្រាប់ថា បពិត្រលោកអាចារ្យ ខ្ញុំឃើញពស់ អាចារ្យសួរថា នែបា ឈ្មោះថា ពស់ មានរូបរាងដូចម្ដេច បុរសនោះឆ្លើយថា ដូចចន្ទោលនង្គ័ល អាចារ្យសរសើរថា សាធុ សាធុ ឧបមានេះ ឯងនាំមកថា ពស់ដូចចន្ទោលនង្គ័លជាទីពេញចិត្ត ។ កាលព្រះពោធិសត្វត្រិះរិះថា ឧបមាគួរពេញចិត្ត មាណពនាំមកបាន អញគង់អាចធ្វើមាណពឲ្យឈ្លាសបាន ថ្ងៃមួយ មាណពឃើញដំរីក្នុងព្រៃ ក៏មកប្រាប់ថា បពិត្រលោកអាចារ្យ ខ្ញុំឃើញដំរី អាចារ្យសួរថា នែបា ដំរីដូចអ្វី មាណពឆ្លើយថា ដូចចន្ទោលនង្គ័លនោះឯង ។ ព្រះពោធិសត្វគិតថា ប្រមោយដំរីក៏ដូចចន្ទោលនង្គ័ល អវយវៈដទៃៗ ដូចជាភ្លុកជាដើម ក៏អាចមានរូបរាងដូច្នោះបាន តែ

មាណពនេះ មិនអាចបែក ហើយពោលបាន ព្រោះខ្លួនល្ងង់ ប្រហែលជាពោលសំដៅយកប្រមោយដំរីទេដឹង ហើយក៏នៅស្ងៀម ។ ថ្ងៃមួយ មាណពបានបរិភោគអំពៅក្នុងទីដែលគេអញ្ជើញ ក៏មកប្រាប់ថា បពិត្រលោកអាចារ្យ ថ្ងៃនេះ ខ្ញុំបានទំពាអំពៅ កាលអាចារ្យសួរថា អំពៅដូចអ្វី ក៏ពោលថា ដូចចន្ទោលនង្គ័លនោះឯង អាចារ្យគិតថា មាណពពោលហេតុផលសមគួរតិចតួច ហើយនៅស្ងៀម ។ ថ្ងៃមួយ ក្នុងទីដែលបានទទួលការអញ្ជើញ មាណពពួកខ្លះ បានបរិភោគទឹកអំពៅជាមួយទឹកដោះជូរ ពួកខ្លះ បរិភោគទឹកអំពៅជាមួយទឹកដោះស្រស់ មាណពនោះមកហើយ ពោលថា បពិត្រលោកអាចារ្យ ថ្ងៃនេះ ខ្ញុំបរិភោគទឹកដោះជូរផង ទឹកដោះស្រស់ផង កាលអាចារ្យសួរថា ទឹកដោះស្រស់ និងទឹកដោះជូរដូចអ្វី ក៏ឆ្លើយថា ដូចចន្ទោលនង្គ័លនោះឯង ។ អាចារ្យពោលថា មាណពនេះ កាលពោលថា ពស់ដូចចន្ទោលនង្គ័ល ជាការពោលត្រឹមត្រូវហើយ សូម្បីពោលថា ដំរីដូចចន្ទោលនង្គ័ល ក៏គង់ពោលបានដោយចំណែក មានប្រមោយជាដើម សូម្បីពោលថា អំពៅដូចចន្ទោលនង្គ័លក៏ត្រឹមត្រូវ តែទឹកដោះជូរ ទឹកដោះស្រស់សជានិច្ច គង់នៅក្នុងភាជនៈ មិនគួរពោលឧបមាក្នុងសេចក្តីនេះបាន ដោយប្រការទាំងពួងឡើយ អញមិនអាចឲ្យមនុស្សឡេះឡោះនេះសិក្សាបានទេ ទើបពោលគាថានេះថា

បុគ្គលពាល រមែងពោលនូវវាចា ដែលមិនទូទៅ ក្នុងវត្ថុទាំងពួង
ក្នុងទីទាំងពួង មាណពនេះ មិនស្គាល់ទឹកដោះជូរ មិនស្គាល់ចន្ទោល
នង្គ័លឡើយ ទើបសម្គាល់នូវទឹកដោះជូរ និងទឹកដោះស្រស់ ថាជា

ចន្ទោលនៃនង្គ័លទៅវិញ ដូច្នេះ ។

ក្នុងគាថានេះ មានសេចក្តីសង្ខេបដូច្នេះថា វាចាណាដែលមិនសម ក្នុងទីគ្រប់កន្លែង ដោយអំណាចនៃឧបមា វាចាដែលមិនសមក្នុងទីគ្រប់អន្លើនោះ បុគ្គលល្ងង់ ពោលបានគ្រប់កន្លែង ដូចជាត្រូវសួរថា ទឹកដោះជូរដូចអ្វី ក៏ឆ្លើយបានថា ដូចចន្ទោលនង្គ័ល កាលពោលយ៉ាងនេះ ជាការមិនស្គាល់ទាំងទឹកដោះជូរ ទាំងចន្ទោលនង្គ័ល ព្រោះហេតុអ្វី ព្រោះថា សូម្បីទឹកដោះជូរ ក៏បុគ្គលនេះសម្គាល់ថា ចន្ទោលនង្គ័លបាន ។ម្យ៉ាងទៀត បទថា **ទធិ** បានដល់ ទឹកដោះជូរ ។ បទថា **បយំ** បានដល់ ទឹកដោះស្រស់ ។ ទឹកដោះជូរនិងទឹកដោះស្រស់ គឺ **ទធិប្បយំ** នោះឯង ។ ព្រោះបុរសនេះ សម្គាល់ទឹកដោះជូរ និងទឹកដោះស្រស់ថា ដូចចន្ទោលនង្គ័ល មាណពនេះល្ងង់យ៉ាងនេះ ព្រះពោធិសត្វគិតថា ប្រយោជន៍អ្វីដោយមាណពនេះ ទើបពោលដល់ពួកអន្តេវាសិកទាំងឡាយ ឲ្យរៀបចំស្បៀងឲ្យ ហើយបញ្ជូនមាណពនោះត្រឡប់ទៅ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មាណពឡេះឡោះក្នុងកាលនោះ បានមកជាលោឡុទាយី ក្នុងកាលឥឡូវនេះ ឯអាចារ្យទិសាបាមោក្ខ ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា នង្គលីសជាតក ចប់**

# សុត្តន្តបិដក

## អម្ពជាតក

[ ១២៤ ] ( តាបសពោធិសត្វពោលថា ) បុរសជាបណ្ឌិតគប្បីប្រឹងប្រែង មិនគប្បីធុញទ្រាន់ឡើយ អ្នកចូរឃើញផលនៃសេចក្តីព្យាយាមដ៏ជាក់ស្តែង ( ព្រោះ ) ផ្លែស្វាយទាំងឡាយជាដើម ដែលពួកឥសីបរិភោគហើយ ។

អម្ពជាតកទី ៤ ចប់

# អដ្ឋកថា

## អម្ពជាតក

[ ១២៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍សម្បូរដោយវត្តម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វាយមេថេវ បុរិសោ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះជាកុលបុត្ត អ្នកនគរសាវត្ថី បួសថ្វាយជីវិតក្នុងសាសនា បានជាអ្នកដល់ព្រមដោយវត្ត ធ្វើអាចរិយវត្ត ឧបជ្ឈាយវត្ត និងវត្តមានការតម្កល់ទឹកផឹក និងទឹកប្រើ ធ្វើវត្តក្នុងរោងឧបោសថ និងវត្តក្នុងរោងភ្លើងជាដើម ជាអ្នកធ្វើវត្តឲ្យបរិបូណ៌ ក្នុងមហាវត្តទាំង ១៤ និងខន្ធកវត្ត ៨០ បោសវិហារ បរិវេណផ្លូវទៅកាន់វិហារ ឲ្យនូវទឹកផឹកដល់ពួកមនុស្សៗ ជ្រះថ្លាក្នុងការសម្បូរដោយវត្តរបស់លោក នាំគ្នាប្រគេននិច្ចភត្តប្រមាណ៥០០សម្រាប់លោក និងសក្ការៈជាច្រើនកើតឡើង ការនៅយ៉ាងផាសុកកើតហើយដល់ភិក្ខុជាច្រើន ព្រោះអាស្រ័យលោក ថ្ងៃមួយ ភិក្ខុទាំងឡាយនាំគ្នាលើករឿងនេះឡើង អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុឈ្មោះនេះញ៉ាំងលាភសក្ការៈយ៉ាងច្រើនឲ្យកើតដល់ខ្លួន ព្រោះដល់ព្រមដោយវត្ត ការនៅយ៉ាងផាសុកកើតដល់ភិក្ខុជាច្រើន ព្រោះអាស្រ័យលោកមួយរូប ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុ

នេះ ក៏ធ្លាប់ជាអ្នកដល់ព្រមដោយវត្ត អាស្រ័យភិក្ខុនេះម្នាក់ ឥសី ៥០០ មិនចាំបាច់ស្វែងរកផ្លែឈើឡើយ ចិញ្ចឹមជីវិតដោយផ្លែឈើដែលភិក្ខុនេះនាំមក ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយបួសជាឥសី មានតាបស ៥០០ ជាបរិវារ អាស្រ័យនៅត្រង់ជើងភ្នំ ។ កាលនោះ ក្នុងព្រៃហិមពាន្ត មានគ្រោះរាំងស្ងួតយ៉ាងខ្លាំងក្លា ទឹកក្នុងទីនោះៗ ក៏រីងស្ងួតទៅ ពួកសត្វតិរច្ឆាន កាលមិនបានទឹកផឹក ក៏ដល់នូវសេចក្តីលំបាក ។ កាលនោះ ក្នុងបណ្តាតាបសទាំងនោះ មានតាបសម្នាក់ ឃើញនូវសេចក្តីទុក្ខដែលកើតអំពីសេចក្តីស្រេកឃ្លានរបស់ពួកតិរច្ឆានទាំងនោះ ទើបកាប់ដើមឈើមួយដើម ធ្វើជាស្នូក ដាក់ទឹកសម្រាប់ផឹកដល់សត្វតិរច្ឆានទាំងនោះ កាលពួកសត្វតិរច្ឆានជាច្រើនមកប្រជុំគ្នាផឹកទឹក តាបសជ្រុលពេល មិនមានឱកាសទៅរកផ្លែឈើ អត់អាហារ ក៏នៅតែដងទឹកចាក់ស្នូកនោះឯង ពួកម្រឹគនាំគ្នាគិតថា តាបសនេះឲ្យទឹកផឹកដល់ពួកយើង ខានទៅរកផ្លែឈើ លំបាកពន់ពេកព្រោះអត់អាហារ ណ្ហើយចុះ ចូរពួកយើងធ្វើកតិកា ទើបសត្វទាំងនោះធ្វើកតិកាថា តាំងពីឥឡូវនេះទៅ សត្វណាមកផឹកទឹក ត្រូវពាំផ្លែឈើតាមសមគួរដល់កម្លាំងរបស់ខ្លួន ។ តាំងពីនោះមក សត្វនីមួយៗ ក៏ពាំផ្លែឈើ មានស្វាយ និងខ្នុរជាដើម ដែលឆ្ងាញ់ៗ នាំមកតាមសមគួរដល់កម្លាំងរបស់ខ្លួនរៀងៗ មក ផលាផលដែលពួកសត្វតិរច្ឆាននាំមកដើម្បីតាបសអង្គនោះ បើ

ដាក់រទេះ មានប្រមាណ ២ រទេះកន្លះ ។ តាបសទាំង ៥០០ ឆាន់ផ្លែឈើនោះរាល់ថ្ងៃ ក៏នៅតែមិនអស់ ។ ព្រះពោធិសត្វឃើញហេតុនោះហើយ ពោលថា អាស្រ័យតាបសដែលដល់ព្រមដោយវត្តតែមួយរូប តាបសមានប្រមាណប៉ុណ្ណេះ គង់ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយមិនចាំបាច់ទៅរកផលាផល ដែលឈ្មោះថា សេចក្ដីព្យាយាមជាកិច្ចដែលគួរធ្វើពិត ហើយពោលគាថានេះថា

បុរសជាបណ្ឌិតគប្បីប្រឹងប្រែង មិនគប្បីធុញទ្រាន់ឡើយ អ្នកចូរឃើញផលនៃសេចក្ដីព្យាយាមដ៏ជាក់ស្ដែង ( ព្រោះ ) ផ្លែស្វាយទាំងឡាយជាដើម ដែលពួកឥសីបរិភោគហើយ ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូចតទៅនេះថា បណ្ឌិតគប្បីព្យាយាមរឿយៗ មិនគួររួញរាក្នុងការងារ មានការបំពេញវត្តជាដើមរបស់ខ្លួន ព្រោះហេតុអ្វី ព្រោះសេចក្ដីព្យាយាមដែលឥតផលមិនមានទេ ដោយហេតុនេះ ព្រះមហាសត្វ កាលដាស់តឿនគណៈឥសីថា ធម្មតាសេចក្ដីព្យាយាម រមែងមានផលរឿយៗ ទើបពោលថា ចូរអ្នកឃើញផលនៃសេចក្ដីព្យាយាមដ៏ជាក់ស្ដែង ដូច្នេះ សួរថា ផលដូចម្ដេច ឆ្លើយថា ដូចផ្លែស្វាយដែលឥសីទាំងឡាយបរិភោគ មិនមែនគ្រាន់តែនិយាយ ។ បណ្ដាបទទាំងនោះ បទថា **អម្ពា** គ្រាន់តែលើកមកជាគំរូ ដោយអត្ថថា ផ្លែឈើដែលសត្វទាំងនោះនាំមក មានប្រការផ្សេងៗ តែពោលដល់ស្វាយជាដើម ដោយអំណាចជាផ្លែឈើ ដែលល្អជាងឬច្រើនជាងផ្លែឈើដទៃ ។ ផ្លែស្វាយទាំងឡាយដែលឥសីទាំង ៥០០ មិនចាំ

បាច់ទៅព្រៃដោយខ្លួនឯង ត្រូវសត្វនាំមកដើម្បីប្រយោជន៍តាបសនោះ ដែលពួកខ្លួន ( គឺឥសីទាំងឡាយ ) បរិភោគហើយ នេះជាផលនៃសេក្តីព្យាយាម ។ ឯផ្លែនោះ មិនមែនគ្រាន់តែពោល គឺមិនមែនកាន់យក ដោយគ្រាន់តែពោលថា គេនិយាយយ៉ាងនេះៗ អញ្ជើញមើលផលដែលប្រចក្សនោះឯង ។ ព្រះមហាសត្វបានឲ្យឱវាទដល់ឥសី ដោយប្រការដូច្នេះ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសដែលដល់ព្រមដោយវត្តក្នុងកាលនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ ឯសាស្តានៃគណៈ ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា អម្ពជាតក ចប់**

# សុត្តន្តបិដក

## កដាហកជាតក

[ ១២៥ ] *( ធីតានៃសេដ្ឋីពោលថា ) ទាសៈឈ្មោះកដាហកៈនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម ( ម្ដងទៀត ) គប្បីប្រទូស្តមិនខាន ម្នាលកដាហកៈ អ្នកចូរបរិភោគនូវភោគៈទាំងឡាយទៅ ។*

*កដាហកជាតកទី ៥ ចប់*

# អដ្ឋកថា

## កដាហកជាតក

[ ១២៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអួតមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពហុម្បិ សោ វិកត្ថេយ្យ** ដូច្នេះជាដើម ។

រឿងរបស់ភិក្ខុនោះ ដូចគ្នានឹងរឿងដែលពោលហើយខាងដើមនោះឯង ។ ប្លែកត្រង់តែថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី មានសម្បត្តិច្រើន ភរិយារបស់គាត់ប្រសូតកុមារ ទាសីក៏សម្រាលកូនក្នុងថ្ងៃជាមួយគ្នា ។ ក្មេងទាំង ២ ចម្រើនវ័យជាមួយគ្នា កាលបុត្តសេដ្ឋីរៀនអក្សរ កូនទាសៈក៏កាន់ក្តារឈ្នួនតាមទៅសិក្សាជាមួយបុត្តសេដ្ឋីនោះដែរ បានសរសេរ ២-៣ ដង កូនទាសៈនោះ ក៏ឈ្លាសក្នុងពាក្យសម្តី ឈ្លាសក្នុងវោហារដោយលំដាប់ ជាកំលោះមានរូបស្អាត ឈ្មោះថា **កដាហកៈ** បានទទួលនាទីជាស្មៀនឃ្លាំងភស្តុក្នុងផ្ទះរបស់សេដ្ឋី ត្រិះរិះថា អ្នកទាំងនេះ គង់មិនប្រើឲ្យអញធ្វើកិច្ចជាស្មៀនឃ្លាំងរហូត លុះឃើញទោសណាមួយតិចតួច គង់នឹងវាយ ចង ធ្វើនូវត្រាជាគ្រឿងចំណាំ ហើយក៏ប្រើប្រាស់ធ្វើជាទាសៈតទៅ នៅឯជាយដែនមានសេដ្ឋីជាសម្លាញ់លោកសេដ្ឋី បើដូច្នោះ អញកាន់យកសំបុត្រ ដោយពាក្យសម្តីរបស់លោកសេដ្ឋីទៅក្នុងទីនោះ ប្រាប់ថា អញជាកូនសេដ្ឋី បញ្ឆោតសេដ្ឋីនោះហើយ សូមធីតារបស់សេដ្ឋីជាគូគាប់ គប្បីនៅយ៉ាងសប្បាយ គេកាន់យកសំបុត្រទៅដោយខ្លួនឯង ចារឹកអក្សរថា ខ្ញុំបញ្ជូនកូនប្រុសរបស់ខ្ញុំឈ្មោះ

នោះ ទៅកាន់សម្នាក់របស់អ្នក ឈ្មោះថា ការសម្ពន្ធដ្ឋានរវាងខ្ញុំ និងអ្នក រវាងអ្នក និងខ្ញុំ ជាការសមគួរ ព្រោះដូច្នោះ សូមអ្នកលើកធីតារបស់អ្នកឲ្យដល់ទារកនេះ ហើយឲ្យនៅក្នុងទីនោះឯង ខ្ញុំមានឱកាសហើយ ទើបមក ដូច្នេះហើយយកត្រារបស់លោកសេដ្ឋីប្រថាប់ កាន់យកស្បៀង គ្រឿងក្រអូប និងសំពត់ជាដើមទៅតាមគាប់ចិត្ត ទៅកាន់ជនបទ ជួបលោកសេដ្ឋី ថ្វាយបង្គំហើយឈរ កាលនោះ លោកសេដ្ឋីសួរថា បាមកអំពីណា ក៏ឆ្លើយថា ខ្ញុំមកអំពីនគរពារាណសី សេដ្ឋីសួរថា ឯងជាកូនចៅអ្នកណា ក៏ឆ្លើយថា ខ្ញុំជាកូនរបស់ពារាណសីសេដ្ឋី សេដ្ឋីសួរថា បាមកត្រូវការអ្វី ខណៈនោះ កដាហកៈក៏ឲ្យសំបុត្រ ព្រមទាំងពោលថា លោកម្ចាស់មើលសំបុត្រនេះហើយនឹងជ្រាប សេដ្ឋីអានសំបុត្រហើយ ត្រេកអរថា ពេលនេះ អញនឹងនៅយ៉ាងសប្បាយ រៀបចំលើកធីតាឲ្យ បរិវាររបស់លោកសេដ្ឋីមានច្រើន កដាហកៈនោះ កាលមានបុគ្គលនាំបបរ និងរបស់ទំពាជាដើមចូលទៅឲ្យ ឬនាំសំពត់ដែលអប់ដោយគ្រឿងក្រអូបថ្មីៗ ចូលទៅឲ្យ ក៏តិះដៀលបបរជាដើមថា ឱហ្ន៎ ! មនុស្សស្រុកក្រៅចម្អិនបបរបែបនេះ របស់ទំពាបែបនេះ បាយបែបនេះឯង តិះដៀលសំពត់ និងកម្មករជាដើមថា ព្រោះជាអ្នកស្រុកក្រៅនោះឯង ទើបពួកមនុស្សទាំងនេះ មិនចេះប្រើសំពត់ថ្មីៗ មិនចេះអប់គ្រឿងក្រអូប មិនចេះក្រងកម្រងផ្កា ។

ព្រះពោធិសត្វ កាលមិនឃើញទាសៈ ក៏សួរថា កដាហកៈ ខ្ញុំមិនជួបមុខសោះ តើគេទៅណា នាំគ្នាតាមរកចុះ ដូច្នេះហើយ ប្រើឲ្យមនុស្សដើររកដោយ

ជុំវិញ បណ្តាមនុស្សទាំងនោះ មនុស្សម្នាក់ទៅក្នុងទីនោះ ឃើញទាសៈនោះ ហើយ ចាំបាន ទៅប្រាប់ដល់ព្រះពោធិសត្វៗ ស្តាប់រឿងនោះហើយ គិតថា ទាសៈនេះធ្វើមិនសមគួរឡើយ ត្រូវតែចាប់មក ក្រាបទូលព្រះរាជា ចេញអំពីស្រុកទៅ ដោយបរិវារច្រើន ដំណឹងក៏ប្រាកដទូទៅថា បានឮថា សេដ្ឋីទៅកាន់បច្ចន្តជនបទ កដាហកៈដឹងដំណឹងថា លោកសេដ្ឋីមក គិតថា មិនមែនមកដោយរឿងដទៃឡើយ មកដោយរឿងអញនេះឯង បើអញគេចទៅមិនអាចត្រឡប់មកវិញបានទេ ឧបាយមាន អញត្រូវទៅជួបលោកសេដ្ឋីជាចៅហ្វាយ ហើយធ្វើកិច្ចរបស់ទាសៈ ធ្វើលោកឲ្យប្រោសប្រាណឲ្យទាល់តែបាន តាំងអំពីនោះ គេពោលយ៉ាងនេះក្នុងកណ្តាលបរិស័ទថា ពួកបុគ្គលពាលដទៃៗ មិនដឹងគុណរបស់មាតាបិតា ព្រោះខ្លួនជាបុគ្គលពាល ក្នុងកាលដែលលោកបរិ-ភោគ ក៏មិនធ្វើការឱនលំទោន បរិភោគរួមជាមួយលោក ឯខ្ញុំ ក្នុងពេលមាតាបិតាបរិភោគ រមែងរង់ចាំ លើកកន្ទោរចូលទៅ លើករបស់បរិភោគចូលទៅជូនកាលក៏រកទឹកឲ្យ ជូនកាលក៏បក់ឲ្យ ចូលទៅឈរក្នុងទីជិត ដូច្នេះហើយប្រកាសកិច្ច ដែលពួកទាសៈត្រូវធ្វើដល់ចៅហ្វាយគ្រប់យ៉ាង រហូតដល់ការកាន់យកក្អមទឹក ទៅកាន់ទីកំបាំងក្នុងពេលដែលចៅហ្វាយបន្ទោបង់ឧច្ចារបស្សាវៈ កាលព្រះពោធិសត្វមកជិតបច្ចន្តជនបទ ក៏ប្រាប់ដល់សេដ្ឋីជាឪពុកក្មេកថា បពិត្រលោកឪពុក បានឮថា បិតារបស់ខ្ញុំមកដើម្បីជួបលោកឪពុក សូមលោកឪពុកឲ្យគេត្រៀមរៀបចំខាទនីយ និងភោជនីយាហារចុះ ខ្ញុំនឹងកាន់យកគ្រឿងបណ្ណាការទៅ ឪពុកក្មេកទទួលពាក្យថា សាធុ ។

កដាហកៈកាន់យកបណ្ណាការទៅជាច្រើន ធ្វើដំណើរទៅ មួយអន្លើដោយបរិវារធំ ថ្វាយបង្គំព្រះពោធិសត្វហើយ ឲ្យបណ្ណាការ ឯព្រះពោធិសត្វទទួលបណ្ណាការ ធ្វើបដិសណ្ឋារៈជាមួយទាសៈនោះ ដល់ពេលបរិភោគអាហារ ក៏ឲ្យតាំងកងទ័ព ហើយចូលទៅកាន់ទីកំបាំងដើម្បីបន្ទោបង់ កដាហកៈឲ្យបរិវាររបស់ខ្លួនត្រឡប់ ហើយកាន់ក្អមទឹកទៅកាន់សម្នាក់ព្រះពោធិសត្វ លុះសម្រេចឧទកកិច្ចហើយ ក៏ក្រាបទៀបជើងទាំង ២ពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងឲ្យទ្រព្យដល់លោកម្ចាស់ តាមដែលលោកប្រាថ្នា សូមកុំឲ្យយសរបស់ខ្ញុំវិនាសឡើយ ព្រះពោធិសត្វជ្រះថ្លាក្នុងភាពសម្បូរដោយវត្តរបស់ទាសៈនោះ លួងលោមថា កុំខ្លាចឡើយ អន្តរាយអំពីសម្នាក់របស់យើងមិនមានដល់ឯងទេ ហើយចូលទៅកាន់បច្ចន្តនគរ សក្ការៈយ៉ាងច្រើន មានហើយ ។ ចំណែកកដាហកៈក៏ធ្វើកិច្ច ដែលទាសៈត្រូវធ្វើដល់សេដ្ឋីគ្រប់កាល ។ ក្នុងពេលមួយ បច្ចន្តសេដ្ឋីពោលនឹងព្រះពោធិសត្វ ដែលអង្គុយយ៉ាងសប្បាយថា បពិត្រលោកសេដ្ឋី ខ្ញុំឃើញសំបុត្ររបស់លោកប៉ុណ្ណោះ ក៏លើកកូនស្រីឲ្យដល់បុត្ររបស់លោកនោះឯង ព្រះពោធិសត្វក៏ធ្វើកដាហកៈឲ្យជាបុត្រដូចគ្នា ពោលនូវពាក្យជាទីស្រឡាញ់ដល់គ្នានិងគ្នា ឲ្យសេដ្ឋីត្រេកអរហើយ តាំងអំពីនោះ ក៏មិនមាននរណាអាចមើលមុខរបស់កដាហកៈបានឡើយ ។ ថ្ងៃមួយ ព្រះពោធិសត្វហៅធីតាសេដ្ឋីមកហើយ ពោលថា មកនេះនាង ជួយរកចៃលើក្បាលរបស់ឪពុកបន្តិច ដូច្នេះហើយ ពោលពាក្យជាទីស្រឡាញ់ជាមួយនាងដែលឈររកចៃឲ្យ សួរថា នែនាង កូនរបស់យើងមិនប្រមាទក្នុងសុខទុក្ខរបស់នាងទេឬ

ឯងទាំង ២ ស្រឡាញ់ស្និទ្ធស្នាលនឹងទេឬ នាងឆ្លើយថា បពិត្រលោកឪពុក កូនរបស់លោក មិនមានពាក្យតិះដៀលដទៃឡើយ គ្រាន់តែរអ៊ូរទាំក្នុងរឿងអាហារប៉ុណ្ណោះ សេដ្ឋីពោលថា អើនាង កូនម្នាក់នេះមានប្រក្រតីស៊ីលំបាកតាំងអំពីដើមមក ណ្ហើយចុះ ឪពុកនឹងឲ្យមន្តសម្រាប់ចងមាត់វាដល់នាង ចូរនាងរៀនមន្តនោះឲ្យល្អ កាលកូនរបស់អញរអ៊ូក្នុងពេលបរិភោគបាយ ចូរនាងឈរពោលចំពោះមុខតាមបទដែលអញបង្រៀន ហើយឲ្យនាងរៀនគាថា ។ ស្នាក់នៅ ២-៣ ថ្ងៃ ក៏ត្រឡប់ទៅនគរពារាណសីវិញ ។ ឯកដាហកៈជញ្ជូនខាទនីយភោជនីយាហារជាច្រើន តាមជូនទៅ ឲ្យទ្រព្យជាច្រើន ហើយលាត្រឡប់ ។ តាំងពីកាលព្រះពោធិសត្វត្រឡប់ទៅហើយ គេរឹងរឹតតែរើសអើងក្រៃលែងឡើង ។ ថ្ងៃមួយ កាលធីតាសេដ្ឋី នាំភោជនមានរសដ៏ប្រសើរផ្សេងៗ ចូលទៅឲ្យ កាន់វែករង់ចាំប្រណិប័តន៍ គាត់ចាប់ផ្ដើមតិះដៀលអាហារ ទើបសេដ្ឋីធីតាពោលគាថា តាមទំនងដែលរៀនហើយ ក្នុងសម្នាក់របស់ព្រះពោធិសត្វថា

*ទាសៈឈ្មោះកដាហកៈនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម ( ម្ដងទៀត ) គប្បីប្រទូស្តមិនខាន ម្នាលកដាហកៈ អ្នកចូរបរិភោគនូវភោគៈទាំងឡាយទៅដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **ពហុម្បិ សោ វិកត្ថេយ្យ អញ្ញំ ជនបទំ គតោ** សេចក្ដីថា បុគ្គលណាទៅកាន់ជនបទដទៃ ចាកជាតិភូមិរបស់ខ្លួន ក្នុង

ទីណាមិនមានបុគ្គលដឹងកំណើតរបស់ខ្លួន បុគ្គលនោះ គប្បីរអ៊ូ គឺពោលពាក្យសង្កត់សង្កិនច្រើនក៏បាន ។

បទថា **អន្នាគន្ត្វាន ទូសេយ្យ** សេចក្ដីថា ព្រោះធ្វើកិច្ចរបស់ទាសៈឲ្យដល់ចៅហ្វាយហើយ ទើបអ្នកផុតការដែលត្រូវវាយដោយផ្ដៅ ឲ្យរបកស្បែកខ្នង និងការវាយត្រាជាគ្រឿងសម្គាល់ទាសៈក្នុងកាលមុន បើអ្នកធ្វើមិនល្អក្នុងពេលក្រោយ គាត់នឹងត្រឡប់មក ចៅហ្វាយរបស់អ្នកគប្បីប្រទូស្តបាន គឺតាមចាប់ដល់ផ្ទះនេះ ហើយប្រទូស្ត ទម្លាយនូវអ្នកបាន ដោយការវាយដោយផ្ដៅ ដោយការបោះត្រាសម្គាល់ថា ជាទាសៈ និងដោយការប្រកាសកំណើតក៏បាន ហេតុនោះ នែកដាហកៈ ចូរអ្នកលះការប្រព្រឹត្តមិនល្អនេះចេញ បរិភោគភោគៈទាំងឡាយចុះ កុំធ្វើភាពដែលខ្លួនជាទាសៈឲ្យប្រាកដ ហើយក្ដៅក្រហាយក្នុងកាលជាខាងក្រោយឡើយ នេះជាអធិប្បាយរបស់លោកសេដ្ឋី ។

ធីតាសេដ្ឋីមិនដឹងសេចក្ដីនោះ ពោលតែព្យញ្ជនៈតាមដែលរៀនមកប៉ុណ្ណោះ កដាហកៈគិតថា សេដ្ឋីប្រាប់រឿងរៀចវេររបស់អញហើយ មុខតែប្រាប់រឿងទាំងអស់ដល់ស្រីនេះដោយពិត តាំងអំពីនោះមក ក៏លែងហ៊ានតិះដៀលកត្តទៀត លះនូវមានះបាន បរិភោគតាមមានតាមបានហើយ ទៅតាមយថាកម្ម ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កដាហកៈក្នុងកាលនោះ បានមកជាភិក្ខុអួតក្នុងកាលឥឡូវនេះ ចំណែកពារាណសីសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថាកដាហកជាតក ចប់**

# សុត្តន្តបិដក

## អសិលក្ខណជាតក

[ ១២៦ ] *( ព្រះរាជាពោធិសត្វពោលថា ) ការកណ្តាស់នោះ របស់បុគ្គលខ្លះល្អ ការកណ្តាស់នោះ របស់បុគ្គលខ្លះអាក្រក់ ហេតុនោះ ការកណ្តាស់ មិនមែនល្អទាំងអស់ មិនមែនអាក្រក់ទាំងអស់ទេ ។*

*អសិលក្ខណជាតកទី ៦ ចប់*

# អដ្ឋកថា

## អសិលក្ខណជាតក

[ ១២៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ចេះមើលលក្ខណៈដាវរបស់ស្តេចកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តថេវេកស្ស កល្យាណំ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះ ក្នុងកាលដែលពួកជាងដែកនាំដាវមកថ្វាយដល់ព្រះរាជា ក៏ហិតក្លិនដាវ ហើយចង្អុលបង្ហាញដល់លក្ខណៈល្អ អាក្រក់នៃដាវ បានលាភអំពីដៃរបស់ជាងដាវពួកណា ក៏ពោលដាវរបស់ជាងនោះថា សម្បូរដោយលក្ខណៈ ប្រកបដោយមង្គល បើមិនបានលាភសក្ការៈអំពីដៃរបស់ពួកជាងណា ក៏តិះដៀលដាវរបស់ពួកជាងនោះថា អប្បលក្ខណ៍ ។ គ្រានោះជាងដាវម្នាក់ ធ្វើដាវហើយ រោយលម្អិតម្ទេសក្នុងស្រោម នាំដាវមកថ្វាយព្រះរាជាៗ ត្រាស់ឲ្យហៅព្រាហ្មណ៍មកត្រាស់ថា ចូរលោកពិចារណាមើលដាវនេះចុះ កាលព្រាហ្មណ៍ដកដាវចេញមកហិត ម្ទេសចូលក្នុងច្រមុះ ធ្វើឲ្យគាត់កណ្តាស់ឡើង កាលព្រាហ្មណ៍កំពុងកណ្តាស់នោះឯង ច្រមុះក៏ត្រូវមុតដាច់ជា ២ ចម្រៀក ព្រាហ្មណ៍នោះ ត្រូវដាវមុតច្រមុះប៉ុណ្ណោះ ក៏ល្បីទូទៅក្នុងជំនុំសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយនាំគ្នាលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ព្រាហ្មណ៍ចេះមើលលក្ខណៈដាវរបស់ព្រះរាជា ហិតលក្ខណៈដាវ ជ្រុលធ្វើឲ្យច្រមុះច្រៀកជា ២ ចម្រៀក ទៅហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី លុះភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបហើយ

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលព្រាហ្មណ៍នោះហិតក្លិនដាវរហូតមុតច្រមុះ សូម្បីក្នុងកាលមុន ក៏ដាច់ច្រមុះមកហើយ ទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ទ្រង់មានព្រាហ្មណ៍ម្នាក់ចេះមើលលក្ខណៈដាវដូចគ្នា ។ រឿងគ្រប់យ៉ាង ដូចគ្នានឹងរឿងបច្ចុប្បន្ននោះឯង ប្លែកតែព្រះរាជាបានព្រះរាជទានគ្រូពេទ្យដល់ព្រាហ្មណ៍ ឲ្យរក្សាច្រមុះ រហូតជាសះស្បើយជាប្រក្រតី ឲ្យធ្វើច្រមុះសិប្បនិមិត្តអំពីក្រមួនជំនួស ។ ហើយទ្រង់តាំងព្រាហ្មណ៍នោះ ឲ្យចូលកាន់តំណែងដើមនោះឯង ។ ព្រះបាទពារាណសីមិនមានឱរស មានតែធីតាមួយអង្គ និងព្រះភាគិនេយ្យមួយអង្គ ទ្រង់ចិញ្ចឹមព្រះរាជធីតា និងក្មួយនោះក្នុងសម្នាក់ព្រះអង្គនោះឯង កាលព្រះរាជធីតា ព្រះរាជភាគិនេយ្យ ទ្រង់ចម្រើនរួមគ្នាមក ជនទាំង ២ ក៏មានចិត្តប្រតិព័ទ្ធដល់គ្នានិងគ្នា ។ ឯព្រះរាជាត្រាស់ហៅអមាត្យទាំងឡាយមកត្រាស់ថា ក្មួយរបស់យើង នឹងបានជាម្ចាស់នៃរាជ-សម្បត្តិនេះតែម្នាក់ យើងនឹងលើកធីតាឲ្យ ធ្វើការអភិសេកនោះឯង ហើយទ្រង់ព្រះតម្រិះជាថ្មីថា ក្មួយរបស់យើង គង់ជាញាតិរបស់យើងដោយប្រការទាំងពួង យើងនឹងនាំរាជធីតាដទៃមកឲ្យក្មួយ ហើយធ្វើការអភិសេក លើកធីតារបស់យើងឲ្យដល់ព្រះរាជាដទៃ ដោយឧបាយនេះ ញាតិរបស់យើងនឹងបានរាជសម្បត្តិទាំង ២ នគរ ។ ព្រះរាជាទ្រង់ប្រឹក្សាជាមួយអមាត្យទាំងឡាយត្រាស់ថា គួរបំបែកអ្នកទាំង ២ នោះចេញ ហើយត្រាស់ឲ្យព្រះរាជភាគិនេយ្យ

ប្រថាប់នៅក្នុងដំណាក់មួយ ព្រះរាជធីតា ប្រថាប់នៅក្នុងដំណាក់មួយ ព្រះរាជភាគិនេយ្យ និងព្រះរាជធីតាទាំងគូនោះ មានព្រះជន្ម ១៦ វស្សា រីឯរិតតែមានព្រះហឫទ័យប្រតិព័ទ្ធគ្នាក្រៃលែង រាជកុមារទ្រង់ព្រះតម្រិះថា ដោយឧបាយដូចម្តេច ទើបយើងអាចនាំធីតារបស់ម្ចាស់អ៊ំចេញអំពីរាជវាំងបាន ឃើញថា មានឧបាយមួយ ទើបត្រាស់ហៅស្រីមេមត់ដែលជាធំចូលមកគាល់ប្រទានរបស់មានតម្លៃ ១០០០ កហាបណៈដល់នាង កាលក្រាបទូលសួរថា ឲ្យខ្ញុំធ្វើអ្វី ទើបត្រាស់ថា បើនាងធ្វើការក្នុងថ្ងៃនេះ រឿងដែលឈ្មោះថា មិនសម្រេចមិនមាន ចូរនាងអាងហេតុណាមួយក៏បាន ធ្វើឲ្យម្ចាស់អ៊ំរបស់ខ្ញុំនាំធីតាចេញអំពីរាជវាំងឲ្យបានក៏ជាការស្រេច ។ ស្រីមេមត់ទទួលពាក្យថា ខ្ញុំនឹងធ្វើបាន ខ្ញុំនឹងចូលគាល់ព្រះរាជា ហើយទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព កាឡកិណីកំពុងគ្របសង្កត់ព្រះធីតាអស់កាលមានប្រមាណប៉ុណ្ណេះ មិនមានផ្លូវដទៃដែលចង្រៃនេះត្រឡប់ទៅ ហើយខ្ញុំម្ចាស់ នឹងនាំព្រះធីតាឡើងរថក្នុងថ្ងៃឈ្មោះនោះ ចាត់បុរសកាន់អាវុធតាមទៅផង ទៅកាន់ព្រៃខ្មោចដោយបរិវារច្រើន ឲ្យមនុស្សដែលស្លាប់ហើយ ដេកលើគ្រែក្នុងព្រៃខ្មោច នៅខាងក្រោមតាំង ដែលជាមណ្ឌលពិធី ឲ្យព្រះរាជធីតាប្រថាប់លើគ្រែខាងលើ ឲ្យព្រះនាងស្រង់ដោយទឹកក្រអូប ប្រមាណ ១០៨ ក្អម ញុំាងកាឡកិណីឲ្យអណ្តែតទៅ កាលខ្ញុំម្ចាស់ទូលយ៉ាងនេះហើយ នឹងនាំព្រះរាជធីតាទៅព្រៃខ្មោចបាន ក្នុងថ្ងៃដែលពួកខ្ញុំទៅព្រៃខ្មោចនោះ សូមទ្រង់កាន់យកម្ទេសម៉ដ្ឋបន្តិច ចោមរោមដោយពួកអ្នកកាន់អាវុធរបស់ព្រះអង្គ ឡើងរថទៅកាន់ព្រៃ

ខ្លាចជាមុន បញ្ឈប់រថនៅត្រង់ទ្វារចូលទៅកាន់ព្រៃខ្លាច ឲ្យពួកអ្នកដែលកាន់អាវុធចូលទៅកាន់ព្រៃខ្លាច ទ្រង់ចូលទៅកាន់ទែនពិធីមណ្ឌលក្នុងព្រៃខ្លាច ដេកផ្ងារហាក់បីដូចជាសាកសព ខ្ញុំម្ចាស់មកដល់ទីនោះ ក៏នឹងដាក់គ្រែព័ទ្ធព្រះអង្គ លើកព្រះរាជធីតាឡើងដាក់ខាងលើ ខណៈនោះ សូមទ្រង់យកម្ជុសដាក់ព្រះនាសិក ទ្រង់នឹងកណ្តាស់ ២-៣ ដង ក្នុងកាលដែលទ្រង់កណ្តាស់ ខ្ញុំម្ចាស់នឹងលះព្រះរាជធីតា ហើយគេចទៅ កាលនោះ ទ្រង់នឹងញ៉ាំងរាជធីតាឲ្យស្រង់ព្រះសិរសៈ ទ្រង់ក៏ស្រង់ព្រះសិរសៈដែរ ហើយនាំព្រះរាជធីតាទៅកាន់ដំណាក់របស់ព្រះអង្គ ។ ព្រះរាជកុមារត្រាស់ថា ឧបាយនេះ សមពិត ល្អពិត ។

ឯស្រីមេមត់ក៏ទៅក្រាបទូលសេចក្តីនោះដល់ព្រះរាជាៗ ក៏ទ្រង់អនុញ្ញាតហើយទៅទូលសេចក្តីនោះឲ្យព្រះរាជធីតាជ្រាប សូម្បីព្រះរាជធីតាក៏ទទួលពាក្យក្នុងថ្ងៃដែលចេញទៅ ស្រីមេមត់ឲ្យសញ្ញាដល់ព្រះរាជកុមារ ហើយទៅកាន់ព្រៃខ្លាចដោយបរិវារច្រើន ពោលបន្ទាចដើម្បីឲ្យកើតការខ្លាចដល់ពួកមនុស្សដែលរក្សាថា ក្នុងកាលដែលយើងដាក់ព្រះធីតាលើគ្រែ មនុស្សស្លាប់ដែលនៅក្រោមគ្រែនឹងកណ្តាស់ ហើយក្រោកចាកគ្រែ ឃើញអ្នកណាមុន នឹងចាប់បុគ្គលនោះទៅ ពួកអ្នកគប្បីប្រយ័ត្នខ្លួនឲ្យល្អ កុំប្រមាទ ។ ព្រះរាជកុមារទៅដល់មុនហើយ ផ្ទំនៅទីនោះដោយន័យដូចពោលហើយ មេមត់ធំ បីព្រះធីតាដើរទៅកាន់ទែនមណ្ឌល ទូលលួងលោមថា សូមព្រះនាងកុំខ្លាចឡើយ ឲ្យសញ្ញាហើយ ដាក់លើគ្រែ ខណៈនោះ ព្រះរាជកុមារក៏យកម្ជុសម៉្ជដាក់ក្នុង

ប្រមុះ កណ្តាស់ឡើង គ្រាន់តែព្រះរាជកុមារកណ្តាស់ប៉ុណ្ណោះ មេមត់ជំស្រែក ដោយសំឡេងខ្លាំង រត់ចោលព្រះធីតា គេចទៅមុនមនុស្សទាំងឡាយ លុះ មេមត់ជំគេចទៅហើយ មិនមាននរណាសូម្បីតែម្នាក់ដែលឈ្មោះថា អាចនៅ បាន គ្រប់គ្នាទម្លាក់អាវុធដែលកាន់មក នាំគ្នាគេចទៅអស់ ព្រះរាជកុមារធ្វើ គ្រប់យ៉ាងតាមដែលប្រឹក្សាគ្នា ហើយនាំរាជធីតាទៅកាន់និវេសន៍របស់ព្រះអង្គ ។

ស្រីមេមត់ទៅក្រាបទូលរឿងនោះដល់ព្រះរាជាៗ ទ្រង់ព្រះតម្រិះថា ដោយ ប្រក្រតី យើងក៏ចិញ្ចឹមនាងដើម្បីលើកឲ្យក្មួយនោះឯង ក៏ហាក់ដូចជាចាក់ សប្បិក្នុងបាយាស ទើបទ្រង់ព្រមទទួល ក្នុងកាលតមក ក៏ទ្រង់ប្រគល់រាជ-សម្បត្តិដល់ព្រះភាគិនេយ្យ ទ្រង់តាំងព្រះរាជធីតាជាមហាទេវី ព្រះភាគិនេយ្យ ក៏បាននៅរួមស្នេហ៍គ្រសង្វាសជាមួយព្រះរាជធីតានោះ គ្រងរាជសម្បត្តិដោយធម៌ ។ ព្រាហ្មណ៍អ្នកត្រួតលក្ខណៈ ក៏បានជាឧបដ្ឋាករបស់ព្រះអង្គ ថ្ងៃមួយ កាល ព្រាហ្មណ៍ចូលគាល់ព្រះរាជា ឈរគាល់ក្រោមកម្តៅព្រះអាទិត្យ ក្រមួនរលាយ ប្រមុះក៏ធ្លាក់ចុះត្រង់ផែនដី ព្រាហ្មណ៍ឱនមុខ ដោយសេចក្តីខ្មាស់ គ្រានោះ ព្រះរាជាទ្រង់សើចព្រាហ្មណ៍ ត្រាស់ថា លោកអាចារ្យ កុំគិតឡើយ ធម្មតា ការកណ្តាស់បានផលល្អដល់បុគ្គលម្នាក់ បានផលអាក្រក់ដល់បុគ្គលម្នាក់ លោកកណ្តាស់ ត្រូវដាច់ប្រមុះ ឯខ្ញុំកណ្តាស់បានធីតាម្ចាស់អ៊ំ ហើយបាន រាជសម្បត្តិ ត្រាស់គាថានេះថា

ការកណ្តាស់នោះ របស់បុគ្គលខ្លះល្អ ការកណ្តាស់នោះ របស់បុគ្គលខ្លះអាក្រក់ ហេតុនោះ ការកណ្តាស់ មិនមែនល្អទាំងអស់ មិនមែនអាក្រក់ទាំងអស់ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តថេវេកស្ស** បានដល់ ដូចគ្នា ។ ម្យ៉ាងទៀត បាលីក៏ពោលយ៉ាងនេះដូចគ្នា សូម្បីបទទី ២ ក៏មានន័យនេះដូចគ្នា ។

ព្រះរាជាទ្រង់នាំហេតុការណ៍នោះមកដោយគាថានេះ ដោយប្រការដូច្នេះ ទ្រង់ធ្វើបុណ្យ មានឲ្យទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់ប្រកាសភាពដែលល្អ និងអាក្រក់ ដែលជាលោកសម្មតិ ជាការមិនពិតប្រាកដដោយព្រះទេសនានេះ ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ដែលមើលលក្ខណៈដាវក្នុងកាលនោះ បានមកជាព្រាហ្មណ៍ដែលមើលលក្ខណៈដាវក្នុងកាលឥឡូវនេះ ឯព្រះរាជាដែលជាភាគិនេយ្យក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា អសិលក្ខណជាតក ចប់

# សុត្តន្តបិដក

## កលណ្ឌុកជាតក

[ ១២៧ ] ( កូនសេកពោលថា ) នុ៎ះជាប្រទេស នុ៎ះជាទឹកទន្លេ ( គឺផ្ទៃនៃទាសី ) សូមឲ្យខ្ញុំជាសត្វគោចរក្នុងព្រៃ ( គង់ដឹងដំណើរនុ៎ះ ម្ចាស់ទាំងឡាយរបស់អ្នក ) រកឃើញហើយចាប់អ្នកមិនខាន ម្នាលកលណ្ឌុក អ្នកចូរផឹកនូវទឹកដោះ ។

*កលណ្ឌុកជាតកទី ៧ ចប់*

# អដ្ឋកថា

## កាលណ្ណកជាតក

[ ១២៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលច្រើនដោយការអួតអាងមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **តេ ទេសា តានិ វត្ថូនិ** ដូច្នេះជាដើម ។

រឿងទាំងពីរ ក្នុងជាតកនោះ ក៏ដូចគ្នានឹងកដាហកជាតកនោះឯង តែក្នុងជាតកនេះ ទាសៈរបស់ពារាណសីសេដ្ឋីនេះ មានឈ្មោះថា កាលណ្ណកៈ ក្នុងកាលដែលបុរសនោះ គេចទៅគ្រប់គ្រងធីតារបស់បច្ចន្តសេដ្ឋី ដោយបរិវារច្រើន ។ ពារាណសីសេដ្ឋីឲ្យមនុស្សត្រាច់ស្វែងរក ក៏មិនដឹងទីដែលបុរសនោះទៅ ទើបបញ្ជូនសេកមួយដែលនៅជាមួយខ្លួនថា ទៅចុះ ទៅស៊ើបមើលកាលណ្ណកៈចុះ កូនសេកត្រាច់ទៅរឿយៗ រហូតដល់នគរនោះ ក្នុងកាលនោះកាលណ្ណកៈបំណាងនឹងលេងទឹក ឲ្យមនុស្សកាន់យកផ្កា គ្រឿងក្រអូប គ្រឿងលាប និងខាទនីយ និងភោជនីយាហារទៅកាន់មាត់ស្ទឹង អង្គុយជាមួយសេដ្ឋីធីតា លេងទឹក ។ ក្នុងទឹកដីនោះ កាលចៅហ្វាយធំលេងកីឡាក្នុងទឹកផឹកទឹកដោះស្រស់ បរិភោគភេសជ្ជៈ ដែលមានរសប្រៃ ព្រោះដូច្នោះ កាលជនទាំងនោះលេងទឹកអស់មួយថ្ងៃ ការរោគក៏បៀតបៀនមិនបាន តែកាលណ្ណកៈនោះ កាន់ពែងទឹកដោះស្រស់ ខ្ពុរមាត់ ហើយស្ដោះទឹកដោះស្រស់នោះចោល តែកាលស្ដោះចោល ក៏មិនស្ដោះក្នុងទឹកទេ ស្ដោះលើក្បាលសេដ្ឋីធីតាទៀតផង ឯកូនសេកហើរដល់ប្រាំងស្ទឹង ក៏ទំត្រង់មែកល្វាមួយមែក សម្លឹងមើលក៏ចាំកាលណ្ណកៈបាន ឃើញកំពុងស្ដោះដាក់ក្បាលសេដ្ឋីធីតា ក៏ពោលថា នែ

អាកលណ្ឌុកៈជាតិថោកទាប ចូរអានឹកដល់ជាតិកំណើតដើមរបស់ខ្លួនផងចុះ កុំយកទឹកដោះស្រស់ខ្ពុរមាត់ ហើយស្ពោះដាក់សីសៈសេដ្ឋីធីតាដែលសម្បូរដោយជាតិ ចម្រើនដោយសុខឡើយ អាមិនដឹងប្រមាណរបស់ខ្លួនឡើយ ហើយពោលគាថានេះថា

*ទ្រុះជាប្រទេស ទ្រុះជាទឹកទន្លេ ( គឺផ្ទៃនៃទាសី ) សូម្បីខ្ញុំជាសត្វគោចរក្នុងព្រៃ ( គង់ដឹងដំណើរទ្រុះ ម្ចាស់ទាំងឡាយរបស់អ្នក ) រកឃើញហើយ ចាប់អ្នកមិនខាន ម្នាលកលណ្ឌុក អ្នកចូរផឹកនូវទឹកដោះ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **តេ ទេសា តានិ វត្ថូនិ** បានដល់ កូនសេកពោលសំដៅដល់ផ្ទៃមាតា ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា ឯងប្រតិស្ឋានហើយក្នុងប្រទេសណា ប្រទេសនោះ មិនមែនជាផ្ទៃរបស់ឥស្សរជនមានផ្ទៃរបស់ខត្តិយកញ្ញាជាដើមឡើយ ដែលពិត ផ្ទៃដែលឯងនៅហើយចម្រើនហើយ ជាផ្ទៃទាសីទេតើ ។

បទថា **អហាញ្ច វនគោចរោ** នេះ សេកសម្តែងថា សូម្បីយើងជាសត្វតិរច្ឆាន ក៏គង់ដឹងសេចក្តីនេះ ។

បទថា **អនុវិច្ច ខោ តំ គណ្ហេយ្យុំ** សេចក្តីថា កាលយើងទៅប្រាប់ដល់ការប្រព្រឹត្តមារយាទដែលអាក្រក់យ៉ាងនេះហើយ ពួកម្ចាស់របស់ឯងពិចារណាដឹងហើយ គប្បីចាប់ទៅ គឺចាប់ខ្លួនទៅវាយ ធ្វើត្រាជាគ្រឿងសម្គាល់ជាទាសៈពិត ព្រោះហេតុនោះ ចូរឯងប្រមាណខ្លួន ផឹកទឹកដោះស្រស់

កុំស្អោះដាក់សីសៈធីតាសេដ្ឋីឡើយ សេកហៅបុរសនោះដោយឈ្មោះថា កលណ្ឌុកៈ ។

ឯកលណ្ឌុកៈក៏ចាំសេកបាន ដោយខ្លាចសេកប្រាប់រឿងរបស់ខ្លួន ទើបនិយាយរាក់ទាក់ថា មកចុះអ្នក អ្នកមកអំពីកាលណា សេកក៏ដឹងថា បុរសនេះ មិនមែនហៅអញដោយបំណងល្អ មានបំណងនឹងមួលកអញឲ្យស្លាប់ ទើបពោលថា អញមិនមានធុរៈទៅជាមួយឯងឡើយ ដូច្នេះហើយ ហើរអំពីទីនោះ ទៅកាន់នគរពារាណសី និយាយរឿងតាមដែលខ្លួនឃើញឲ្យសេដ្ឋីស្តាប់ដោយពិស្តារ សេដ្ឋីគិតថា ទាសៈនេះធ្វើមិនសមគួរឡើយ ទើបទៅដាក់អាជ្ញា នាំខ្លួនមកកាន់នគរពារាណសីវិញ ហើយប្រើជាទាសៈតទៅ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កលណ្ឌុកៈក្នុងកាលនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ ឯពារាណសីសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា កលណ្ឌុកជាតក ចប់**

# សុត្តន្តបិដក

## មូសិកជាតក

[ ១២៨ ] ( កណ្ឌុរពោធិសត្វពោលថា ) បុគ្គលអ្នកបិទបាំងទោសណា ធ្វើនូវធម៌ឲ្យជាទង់ជ័យ ញុំាំងសត្វទាំងឡាយឲ្យទុកចិត្ត ហើយប្រព្រឹត្តនូវអំពើអាក្រក់ វត្តរបស់បុគ្គលនោះ ឈ្មោះថា ពិឡារវត្ត ( វត្តឆ្មា ) ។

**មូសិកជាតកទី ៨ ចប់**

# អដ្ឋកថា

## មូសិកជាតក

[ ១២៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ វេ ធម្មទ្ធជំ កត្វា** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងកាលនោះ កាលភិក្ខុទាំងឡាយក្រាបទូលភាពដែលភិក្ខុនោះ ជាអ្នកកុហកឲ្យទ្រង់ជ្រាបហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏កុហកដូចគ្នា ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតកណ្តុរ អាស្រ័យការចម្រើនធំធាត់ មានរាងកាយដូចកូនជ្រូកដែលទើបកើត មានកណ្តុរច្រើនរយជាបរិវារត្រាច់ទៅក្នុងព្រៃ កាលនោះ មានឆ្កែចចកមួយក្បាល ត្រាច់ទៅតាមទំនើងឃើញហ្វូងកណ្តុរនោះ គិតថា អញនឹងកុហក ស៊ីកណ្តុរទាំងនេះ ហើយងើបមុខសម្លឹងមើលព្រះអាទិត្យ ស្រូបយកខ្យល់ ឈរដោយជើងម្ខាង ក្នុងទីមិនឆ្ងាយអំពីទីអាស្រ័យរបស់ហ្វូងកណ្តុរ ព្រះពោធិសត្វត្រាច់រកស៊ីឃើញហើយគិតថា ចចកនេះ ប្រហែលជាអ្នកមានសីល ទើបចូលទៅកាន់សម្នាក់របស់ចចក សួរថា លោកដ៏ចម្រើន លោកឈ្មោះអ្វី ចចកឆ្លើយថា យើងឈ្មោះធម្មិកៈ កណ្តុរសួរថា លោកមិនឈរលើផែនដីដោយជើងទាំង ៤ ឈរតែជើងមួយ ព្រោះហេតុអ្វី ចចកឆ្លើយថា បើយើងជាន់ផែនដីដោយជើងទាំង ៤

ផែនដី មិនអាចទ្រទ្រង់បាន ហេតុនោះ យើងត្រូវឈរជើង ១ ប៉ុណ្ណោះ កណ្ដុរសួរថា ហេតុអ្វី ចាំបាច់ឈរហាមាត់ ចចកឆ្លើយថា យើងមិនស៊ីអាហារដទៃ ស៊ីខ្យល់តែម្យ៉ាង កណ្ដុរសួរថា បើដូច្នោះ ហេតុអ្វី ចាំសម្លឹងមើលព្រះអាទិត្យ ចចកឆ្លើយថា យើងនមស្ការព្រះអាទិត្យ ព្រះពោធិសត្វស្ដាប់ពាក្យចចកហើយ គិតថា ចចកនេះ គង់មានសីលពិត បន្ទាប់អំពីនោះ ក៏ទៅកាន់ទីបម្រើជាមួយពួកកណ្ដុរ ទាំងពេលល្ងាច ទាំងពេលព្រឹក ។ ក្នុងកាលដែលកណ្ដុរព្រះពោធិសត្វធ្វើការបម្រើហើយ ចចកក៏ចាប់យកកណ្ដុរដែលមកក្រោយគេ ស៊ីសាច់ហើយ ជូតមាត់ឈរ ។ ហ្វូងកណ្ដុររលស់ដោយលំដាប់ កណ្ដុរទាំងឡាយប្រឹក្សាគ្នាថា កាលមុន ពួកយើងត្រូវប្រជ្រៀតគ្នា ឥឡូវនេះ រលស់ទៅទីលំនៅមានប្រមាណប៉ុណ្ណោះ ក៏មិនពេញ មានរឿងអ្វីហ្ន៎ ហើយនាំគ្នាប្រាប់រឿងនោះដល់ព្រះពោធិសត្វៗ គិតថា ហេតុអ្វីហ្ន៎ ទើបពួកកណ្ដុររលស់ទៅ ក៏កំណត់សេចក្ដីសង្ស័យក្នុងឆ្កែចចក ត្រិះរិះថា អញត្រូវសាកល្បងឆ្កែចចកនោះ ក្នុងពេលបម្រើ ឲ្យពួកកណ្ដុរទៅមុន ខ្លួនឯងនៅក្រោយគេ ឆ្កែចចកស្ទុះទៅសង្គ្រុបព្រះពោធិសត្វៗ ឃើញឆ្កែចចកស្ទុះមកចាប់ខ្លួន ក៏ងាកក្រោយ ពោលថា នែចចកមានល្បិច ការបំពេញវត្តរបស់ឯងនេះ មិនមែនប្រព្រឹត្តទៅដើម្បីការប្រព្រឹត្តល្អ បដិបត្តិល្អទេ តែឯងប្រព្រឹត្តយកធម៌បាំងមុខ យកធម៌ជាទង់ ដើម្បីបៀតបៀនសត្វដទៃ ហើយពោលគាថានេះថា

បុគ្គលអ្នកបិទបាំងទោសណា ធ្វើនូវធម៌ឲ្យជាទង់ជ័យ ញ៉ាំងសត្វ
ទាំងឡាយឲ្យទុកចិត្ត ហើយប្រព្រឹត្តនូវអំពើអាក្រក់ វត្តរបស់បុគ្គល

នោះ ឈ្មោះថា ពិឡារវត្ត ( វត្តឆ្មា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ វេ** សេចក្តីថា ក្នុងពួកជន មានក្សត្រជាដើមណាមួយ ។

បទថា **ធម្មធជំ កត្វា** សេចក្តីថា លើកតម្កើងកុសលកម្មបថ ១០ ប្រការជាទង់ គឺធម៌ លើកឡើងសម្តែង ហាក់ដូចជាខ្លួនបដិបត្តិធម៌នោះ ។

បទថា **វិស្សាសយិត្វា** សេចក្តីថា ធ្វើឲ្យហ្វូងសត្វកើតនូវការទុកចិត្ត ដោយសម្គាល់ខុសថា ជាអ្នកមានសីល ។

បទថា **ពិឡារវ្វតំ នាម តំ វតំ** សេចក្តីថា វត្តរបស់បុគ្គលដែលលើកតម្កើងធម៌ ដូចជាទង់យ៉ាងនេះ ហើយបន្តប់នូវអំពើអាក្រក់ក្នុងទីកំបាំងនោះ រមែងឈ្មោះថា ជាវត្តដែលប្រកបដោយការកុហក ។

ស្តេចកណ្តុរពោលបណ្តើរ លោតឡើងតោងត្រង់កខាំបំពង់ក ឲ្យដល់នូវការអស់ជីវិត ហ្វូងកណ្តុរត្រឡប់មកកកេរស៊ីឆ្កែចចកដោយសំឡេងខ្លាំងរួចនាំគ្នាទៅ បានឮថា កណ្តុរដែលមកមុន បានស៊ីសាច់កណ្តុរដែលមកក្រោយក៏មិនបាន តាំងអំពីនោះមក ពួកកណ្តុរក៏អស់ភ័យ បាននូវសេចក្តីសុខ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ឆ្កែចចកក្នុងកាលនោះ បានមកជាភិក្ខុកុហក ក្នុងកាលឥឡូវនេះ ឯស្តេចកណ្តុរក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មូសិកជាតក ចប់**

# សុត្តន្តបិដក

## អគ្គិកជាតក

[ ១២៩ ] ( កណ្ឌុរពោធិសត្វពោលថា ) កំប៉ោយនេះមិនមែនមាន ព្រោះហេតុនៃបុណ្យទេ កំប៉ោយនេះមានព្រោះហេតុតែគ្រឿងបរិភោគ ការរាប់ដោយកន្ទុយ រមែងប្រព្រឹត្តទៅ នៃអគ្គិក ការនៅរួមគ្នាគួរដល់អ្នកហើយ ។

**អគ្គិកជាតកទី ៩ ចប់**

# អដ្ឋកថា

## អគ្គិកភារទ្វាជជាតក

[ ១២៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឆាយំ សិខា បុញ្ញហេតុ** ដូច្នេះជាដើម ។ រឿងបច្ចុប្បន្នដូចគ្នានឹងរឿងដែលពោលហើយខាងដើមនោះឯង ។

សេចក្តីសង្ខេបថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះពោធិសត្វ សោយព្រះជាតិជាស្តេចកណ្តុរក្នុងព្រៃ កាលនោះភ្លើងឆេះព្រៃ ។ ចចកមួយក្បាល មិនអាចរត់រួច ឈរស៊កក្បាលត្រង់រន្ធឈើមួយដើម រោមត្រូវភ្លើងឆេះ សល់តែរោមត្រង់ក្បាលដែលស៊កត្រង់ដើមឈើ ដូចកោរទុកជុក ។ ថ្ងៃមួយ ចចកផឹកទឹកក្នុងត្រពាំង មើលស្រមោលឃើញជុកហើយ គិតថា ឥឡូវនេះ វត្ថុដែលជាឫសគល់នៃកណ្ឌៈកើតដល់អញហើយ កាលអញនៅព្រៃ ឃើញហ្វូងកណ្តុរនោះ គិតថា អញនឹងកុហកស៊ីកណ្តុរទាំងនេះ បានឈរក្នុងទីមិនឆ្ងាយ តាមន័យដែលពោលហើយខាងដើមនោះឯង ។ កាលនោះ ព្រះពោធិសត្វដើររកស៊ី ឃើញចចកនោះហើយ ចូលទៅរក ដោយសម្គាល់ថា បុគ្គលនេះមានសីល ហើយសួរថា អ្នកឈ្មោះដូចម្តេច ចចកឆ្លើយថា ខ្ញុំឈ្មោះអគ្គិកភារទ្វាជៈ កណ្តុរសួរថា លោកមកធ្វើអ្វី ចចកឆ្លើយថា មកដើម្បីជួយគ្រប់គ្រងពួកអ្នក កណ្តុរសួរថា លោកធ្វើដូចម្តេច ទើបរក្សាពួកខ្ញុំបាន ចចកឆ្លើយថា ខ្ញុំចេះវិធីគណនាដែលហៅថា រាប់ដោយកន្ទុយ ក្នុងកាលដែលពួកអ្នកនាំគ្នាចេញទៅរកស៊ីនៅ

ពេលព្រឹក យើងក៏រាប់ថា មានចំនួនប៉ុណ្ណេះ ក្នុងកាលត្រឡប់ក៏ត្រូវរាប់មើល កាលយើងរាប់ទាំងព្រឹក ទាំងល្ងាចយ៉ាងនេះ ក៏នឹងរក្សាពួកអ្នកបាន ព្រះពោធិសត្វពោលថា បើដូច្នោះ សូមអ៊ំរក្សាពួកយើងចុះ ។ ចចកទទួលពាក្យថា សាធុ ក្នុងកាលដែលពួកកណ្ដុរចេញទៅក៏រាប់ ១-២-៣ ជាដើម ក្នុងកាលដែលត្រឡប់មក ក៏រាប់ដោយទំនងដូចគ្នា ហើយសង្គ្រុបកណ្ដុរមួយដែលមកក្រោយគេដើម្បីស៊ី ។ រឿងដ៏សេសដូចគ្នានឹងរឿងមុននោះឯង តែក្នុងជាតកនេះ ស្ដេចកណ្ដុរត្រឡប់មកឈរ ហើយពោលថា នែអគ្គិកការទ្វាជៈ កំហូច ជុកលើក្បាលរបស់ឯងមិនមានដើម្បីសច្ចៈ សុចរិត យុត្តិធម៌ទេ មានព្រោះហេតុនៃមាត់ និងផ្ទៃ ហើយពោលគាថានេះថា

កំប៉ោយនេះមិនមែនមាន ព្រោះហេតុនៃបុណ្យទេ កំប៉ោយនេះ
មានព្រោះហេតុតែគ្រឿងបរិភោគ ការរាប់ដោយកន្ទុយ រមែង
ប្រព្រឹត្តទៅ នែអគ្គិកការនៅរួមគ្នាគួរដល់អ្នកហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នង្គុដ្ឋគណនំ យាតិ** លោកពោលសំដៅដល់ការរាប់ដោយកន្ទុយ អធិប្បាយថា ហ្វូងកណ្ដុរនេះមិនដល់ មិនប្រហាក់ប្រហែល មិនគ្រប់ចំនួន បានដល់ រលស់ទៅ ។

បទថា **អលមេត្ថុ ហោតុ អគ្គិក** សេចក្ដីថា ស្ដេចកណ្ដុរកាលនឹងពោលដល់ឆ្កែចចក ហៅដោយឈ្មោះថា អគ្គិកៈ អធិប្បាយថា អគ្គិកៈល្បិចច្រើន

អើយ សម្រាប់ឯង គ្រប់គ្រាន់ប៉ុណ្ណោះចុះ ខាងមុខអំពីនេះទៅ ឯងខាំកណ្តុរស៊ីទៀតមិនបានទេ អញ និងឯង ឈប់នៅរួមគ្នា អធិប្បាយថា ឥឡូវនេះពួកអញ មិននៅរួមជាមួយឯងតទៅ បទដ៏សេសដូចគ្នានឹងរឿងមុននោះឯង ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ ស្តេចកណ្តុរក្នុងកាលនោះ គឺតថាគតនេះឯង ។l ៚

**អដ្ឋកថា អគ្គិកភារទ្វាជជាតក ចប់**

# សុត្តន្តបិដក

## កោសិយជាតក

[ ១៣០ ] ( ព្រាហ្មណ៍ជាប្តីពោលថា ) នាងចូរបរិភោគឲ្យដូចជាសម្តី ចូរលេប ( ថ្នាំ ) ឲ្យដូចជាបាយដែលនាងស៊ីហើយ ម្នាលព្រាហ្មណី ជាកោសិយគោត្រ ( ព្រោះ ) វាចា និងកត្តដែលនាងបរិភោគហើយ ទាំងពីរ ( នេះ ) មិនស្មើគ្នាទេ ។

កោសិយជាតកទី ១០ ចប់

កុសនាឡិវគ្គទី ១៣ ចប់

### ឧទ្ទាននៃកុសនាឡិវគ្គនោះ គឺ

និយាយអំពីកុសនាឡិជាតក ១ យស ១ ទឹកដោះជូរ ១ ស្វាយ ១ ទាសៈឈ្មោះកដាហកៈជាគម្រប់ប្រាំ ១ ទឹកដោះស្រស់ ១ វិឡារវត្ត ១ ចចកមានកំពៅយ ១ កណ្តាស់អាក្រក់ ១ ព្រាហ្មណីជាកោសិយគោត្រ ១ ត្រូវជា ១០ ។

# អដ្ឋកថា

## កោសិយជាតក

[ ១៣០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតុគ្រាម ក្នុងនគរសាវត្ថីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា វាចា ច កុញ្ចស្ស** ដូច្នេះជាដើម ។

បានឮថា នាងជាព្រាហ្មណីរបស់ព្រាហ្មណឧបាសក ដែលមានបសាទ-សទ្ធាម្នាក់ ជាស្រីប្រព្រឹត្តអាក្រក់យ៉ាងខ្លាំងក្លា ជាបុគ្គលគ្រោតគ្រាត ជាបុគ្គលលាមក ពេលយប់ប្រព្រឹត្តក្រៅចិត្តប្តី ពេលថ្ងៃមិនធ្វើការងារណាមួយ សម្តែងអាកប្បកិរិយាធ្វើជាឈឺ ដេកដកដង្ហើមធំទៅមក កាលនោះ ព្រាហ្មណ៍សួរថា នែនាង នាងមិនសប្បាយរឿងអ្វីឬ ស្រីនោះឆ្លើយថា ខ្យល់សៀតពោះរបស់ខ្ញុំ ព្រាហ្មណ៍សួរថា បើដូច្នោះ បានអ្វី ទើបសមគួរ នាងឆ្លើយថា បានយាគូភត្ត និងប្រេងជាដើមដែលប្រណីតៗ មានរសល្អ ទើបគួរ ។ ព្រាហ្មណ៍ទៅរកវត្ថុដែលនាងត្រូវការមកឲ្យ ធ្វើកិច្ចគ្រប់យ៉ាងដូចជាទាសៈ ឯនាងព្រាហ្មណី ពេលព្រាហ្មណ៍ចូលផ្ទះក៏ដេក ពេលព្រាហ្មណ៍ចេញទៅ ក៏សប្បាយជាមួយសហាយ ព្រាហ្មណ៍ត្រិះរិះថា ខ្យល់ដែលសៀតសរីរៈកិរិយារបស់អញនេះ មើលទៅមិនមានទីបំផុត ។ ថ្ងៃមួយ ទើបកាន់គ្រឿងក្រអូប និងផ្កាជាដើម ទៅកាន់ជេតពនវិហារ បូជាព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាង កាលព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រោះហេតុអ្វី ទើបអ្នកមិនឃើញមក ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា គំនរខ្យល់សៀតនូវសរីរៈព្រាហ្មណីរបស់ខ្ញុំព្រះអង្គៗ ត្រូវស្វែងរកសប្បិ ប្រេងជា

ដើម និងភោជនដែលប្រណីតៗ ឲ្យនាង រាងកាយរបស់នាងមើលទៅដូចជា ធំធាត់ ផូរផង់ មានពណ៌សម្បុរល្អ តែរោគខ្យល់ មើលទៅមិនមានទីបំផុត ឡើយ ខ្ញុំព្រះអង្គត្រូវប្រណិប័តន៍នាងរឿយៗ ទើបមិនបានឱកាសមកវិហារ នេះ ព្រះសាស្តាទ្រង់ជ្រាបភាពអាក្រក់របស់ព្រាហ្មណីហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ កាលមាតុគ្រាមដេកយ៉ាងនេះ រោគក៏មិនស្ងប់ ត្រូវផ្សំថ្នាំយ៉ាង នេះឲ្យ ទើបគួរ ក្នុងកាលមុន បណ្ឌិតប្រាប់អ្នកហើយ តែអ្នកចាំមិនបាន ព្រោះអន្តរភពបិទបាំង ព្រាហ្មណ៍ទូលអារាធនា ទើបទ្រង់នាំយករឿងក្នុង អតីតមកសាធក:តទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល រៀនសិប្បៈ គ្រប់ប្រការ ក្នុងនគរតក្កសិលា ហើយបានជាអាចារ្យទិសាបាមោក្ខ នៅក្នុង នគរពារាណសី ខត្តិយកុមារក្នុងរាជធានីទាំង ១០១ និងព្រាហ្មណកុមារ នាំ គ្នាមករៀនសិប្បៈក្នុងសម្នាក់របស់លោកជាច្រើន កាលនោះ ព្រាហ្មណ៍អ្នក ជនបទម្នាក់រៀនត្រៃវេទ និងវិជ្ជដ្ឋាន ១៨ ប្រការ ក្នុងសម្នាក់របស់ព្រះពោធិ-សត្វ តាំងទីលំនៅក្នុងនគរពារាណសីនោះឯង មកត្រង់សម្នាក់របស់ព្រះពោធិ-សត្វ មួយថ្ងៃ ២-៣ ដង រាល់ថ្ងៃ ។ ព្រាហ្មណីរបស់បុរសនោះ ជាស្រី ប្រព្រឹត្តអាក្រក់គ្រោតគ្រាត លាមក ។ រឿងទាំងពួងតាំងអំពីនេះទៅ ដូចគ្នា នឹងរឿងបច្ចុប្បន្ននោះឯង ឯព្រះពោធិសត្វ កាលព្រាហ្មណ៍នោះប្រាប់ថា ដោយ ហេតុនេះ ទើបខ្ញុំមិនមានឱកាសដើម្បីទទួលឱវាទ ដូច្នេះ ក៏ជ្រាបថា នាង

មាណវិកានេះដេកបោកបញ្ឆោតព្រាហ្មណ៍នេះហើយ គិតថា អញនឹងប្រាប់ថ្នាំសមគួរឲ្យដល់នាង រួចពោលថា នែបា តាំងអំពីនេះទៅ អ្នកកុំឲ្យសប្បិ និងទឹកដោះដល់នាងជាដាច់ខាត តែចូរបេះស្លឹកឈើ ៥ យ៉ាង និងផ្លែឈើ ៣ យ៉ាងជាដើម ដាក់ក្នុងទឹកនោមគោ ហើយត្រាំក្នុងភាជន:ទង់ដែងថ្មីៗ ឲ្យជាប់ក្លិនលោហៈ ហើយកាន់ខ្សែផ្តៅ ឬរំពាត់ ពោលថា ថ្នាំនេះសមគួរដល់រោគរបស់នាង ចូរបរិភោគថ្នាំនេះ បើមិនដូច្នោះទេ ក៏ក្រោកឡើង ធ្វើការងារឲ្យសមគួរដល់កត្តដែលនាងបរិភោគ ហើយត្រូវពោលគាថានេះ បើនាងមិនព្រមផឹកថ្នាំ ក៏ត្រូវយកខ្សែ ឬផ្តៅ ឬរំពាត់វាយនាង ពីរបីកន្ទេង ហើយបោចសក់ អូសមកអុកដោយកែង នាងនឹងក្រោកឡើង ធ្វើការងារក្នុងរំពេចនោះឯង ។ បុរសនោះទទួលពាក្យថា សាធុ ហើយធ្វើថ្នាំតាមដែលប្រាប់ហើយនោះឯង ពោលថា នែនាង ចូរនាងផឹកថ្នាំចុះ នាងសួរថា ថ្នាំនេះអ្នកណាប្រាប់អ្នក បុរសនោះឆ្លើយថា អាចារ្យជាអ្នកប្រាប់ នាងពោលថា យកវាទៅចោលចុះ ខ្ញុំមិនផឹក មាណពពោលថា នាងមិនផឹកតាមចិត្តរបស់ខ្លួនមិនបាន ស្រវាខ្សែ ពោលថា ចូរផឹកថ្នាំសមគួរដល់រោគរបស់ខ្លួន បើមិនដូច្នោះក៏ចូរធ្វើការងារឲ្យសមគួរដល់កត្តដែលបរិភោគ ហើយពោលគាថានេះថា

នាងចូរបរិភោគឲ្យដូចជាសម្តី ចូរលេប ( ថ្នាំ ) ឲ្យដូចជាបាយ
ដែលនាងស៊ីហើយ ម្នាលព្រាហ្មណី ជាកោសិយគោត្រ ( ព្រោះ )
វាចា និងកត្តដែលនាងបរិភោគហើយ ទាំងពីរ ( នេះ ) មិនស្មើ
គ្នាទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យថា វាចា ច ភុញ្ជស្សុ** សេចក្ដីថា ចូរនាងបរិភោគឲ្យសមនឹងវាចាដែលនាងពោល អធិប្បាយថា ចូរបរិភោគឲ្យសមនឹងវាចាដែលនាងពោលថា ខ្យល់សៀតផ្ទៃខ្ញុំ ដូច្នេះ ។ បាឋៈថា **យថា វាចំ វា** ដូច្នេះក៏គួរ អាចារ្យខ្លះពោលថា **យថា វាចាយ** ដូច្នេះក៏មាន គ្រប់បទទាំងអស់ ក៏មានន័យដូចគ្នាយ៉ាងនេះ ។

បទថា **យថា ភុត្តញ្ច ព្យាហរ** សេចក្ដីថា ចូរនិយាយចេញមកឲ្យសមគ្នានឹងអាហារដែលនាងបរិភោគហើយ អធិប្បាយថា ចូរប្រាប់ថា ខ្ញុំមិនឈឺធ្វើការងារដែលត្រូវធ្វើក្នុងផ្ទះ ។

បាឋៈថា **យថា ភុត្វាញ្ច** ដូច្នេះក៏មាន ។

ម្យ៉ាងទៀត មានអធិប្បាយថា ចូរនិយាយតាមពិតថា ខ្ញុំមិនមានរោគទេ ដូច្នេះហើយ ធ្វើការងារចុះ ។

បទថា **ឧភយន្តេ ន សមេតិ វាចា ភុត្តញ្ច កោសិយេ** សេចក្ដីថា វាចារបស់នាងដែលថា គំនរខ្យល់សៀតពោះខ្ញុំ ដូច្នេះ និងភោជនដ៏ប្រណីតដែលនាងបរិភោគ ទាំងពីរយ៉ាងនេះ មិនស៊ីគ្នា ព្រោះហេតុនោះ ចូរក្រោកឡើងធ្វើការងារចុះ ។ ព្រាហ្មណ៍ហៅនាងតាមគោត្តថា កោសិយៈ ។

កាលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ធីតានៃកោសិយព្រាហ្មណ៍គិតថា តាំងអំពីកាលដែលអាចារ្យខ្វល់ខ្វាយហើយ អញមិនអាចបោកបញ្ឆោតព្រាហ្មណ៍នេះតទៅបាន ត្រូវក្រោកឡើងធ្វើការងារ ដូច្នេះហើយ ក៏ក្រោកឡើងប្រកបកិច្ចតាមនាទី ទាំងជាស្រីមានសីល វៀរចាកបាបកម្ម ដោយការគោរពកោតក្រែងក្នុងអាចារ្យថា ភាពដែលអញជាស្រីប្រព្រឹត្តអាក្រក់យ៉ាងខ្លាំងក្លា អាចារ្យដឹងអស់ហើយ បន្តអំពីនេះទៅ អញមិនអាចធ្វើដូច្នេះបានទៀតទេ ។

ព្រាហ្មណីនោះមិនហ៊ានធ្វើអនាចារទៀត ដោយការគោរពក្នុងព្រះសាស្តាថា បានឮថា ព្រះសម្មាសម្ពុទ្ធទ្រង់ដឹងរឿងរបស់អញហើយ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា គូស្វាមីភរិយាក្នុងកាលនោះ បានមកជាប្តីប្រពន្ធក្នុងកាលឥឡូវនេះ ឯអាចារ្យក្នុងកាលនោះ គឺតថាគតដូច្នេះឯង ៕

## អដ្ឋកថា កោសិយជាតក ចប់

## កុសនាឡិវគ្គ ចប់

# សុត្តន្តបិដក

## អសម្បទានវគ្គ

### អសម្បទានជាតក

[ ១៣១ ] ( សេដ្ឋីពោធិសត្វពោលថា ) ការរាប់អានទាំងឡាយ របស់ជនពាល រមែងទៅជាទោស ព្រោះតែមិនទទួលនូវវត្ថុ តាមមាន តាមបាន ព្រោះហេតុនោះ បានជាយើងខ្ញុំនាំយកសំដីស្រូវកន្លះមានះ ( ៤ នាឡិ ) មក កុំឲ្យការមេត្រីរាប់អានរបស់យើង បែកបាក់ទៅឡើយ សូមឲ្យការមេត្រីរាប់អាននេះ នៅទៀងទាត់ ។

*អសម្បទានជាតកទី ១ ចប់*

# អដ្ឋកថា

# អសម្បទានវគ្គ

## អសម្បទានជាតក

[ ១៣១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត-ភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសម្បទានេនិតរីតរស្ស** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាបុគ្គលអកតញ្ញូ មិនដឹងគុណរបស់ព្រះតថាគត ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តជាបុគ្គលអកតញ្ញូ សូម្បីតែក្នុងកាលមុន ក៏អកតញ្ញូដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះរាជាមគធ:មួយអង្គ សោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ដែនមគធ: ព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី ក្នុងរជ្ជកាលរបស់ព្រះរាជាអង្គនោះ មានសម្បត្តិ ៨០ កោដិ ឈ្មោះសង្ខសេដ្ឋី ។ ក្នុងនគរពារាណសីមានសេដ្ឋីម្នាក់ មានសម្បត្តិ ៨០ កោដិ ឈ្មោះបិលិយសេដ្ឋី

សេដ្ឋីទាំង ២ នោះជាសម្លាញ់នឹងគ្នា ។ ក្នុងសេដ្ឋីទាំង ២ នោះ បិលិយសេដ្ឋី ក្នុងនគរពារាណសី ជួបនូវភ័យយ៉ាងមហន្ត ដោយការងារឯណាទីមួយ ខ្លួនមិនរួច រហូតក្លាយជាមនុស្សក្រីក្រ គ្មានទីពឹង បបួលភរិយាធ្វើដំណើរមករកសង្ខសេដ្ឋី ។ ចេញអំពីនគរពារាណសី មកកាន់នគររាជគ្រឹះដោយជើងទទេ រហូតដល់និវេសន៍របស់សង្ខសេដ្ឋី ។ សង្ខសេដ្ឋីឃើញហើយ ពោលថា សម្លាញ់របស់ខ្ញុំមកហើយ ទទួលយ៉ាងរីករាយ សម្តែងសេចក្តីគោរពរាប់អាន ឲ្យស្នាក់អាស្រ័យនៅ ២-៣ ថ្ងៃ ។ ថ្ងៃមួយ សួរថា នែសម្លាញ់ អ្នកមកដោយបំណងអ្វី ។ បិលិយសេដ្ឋីឆ្លើយថា នែសម្លាញ់ ភ័យកើតដល់ខ្ញុំ រហូតដល់ធ្លាក់ខ្លួនក្រ ជួយឧបការៈខ្ញុំផងចុះ ។ ឯសង្ខសេដ្ឋីក៏ពោលថា សាធុ សម្លាញ់ អ្នកកុំគិតថ្វីឡើយ ហើយបើកឃ្លាំង ឲ្យនូវទ្រព្យ ៤០ កោដិ និងសវិញ្ញាណកទ្រព្យ អវិញ្ញាណទ្រព្យ ជារបស់ខ្លួនគ្រប់យ៉ាង ដែលជាបរិវារតាមកំណត់ និងទ្រព្យដ៏សេសហួសរាប់ទៀតផង បិលិយសេដ្ឋីជញ្ជូនសម្បត្តិត្រឡប់ទៅនគរពារាណសី តម្កល់ខ្លួនបាន ។

ក្នុងកាលតមក ភ័យដូចគ្នានោះឯង កើតដល់សង្ខសេដ្ឋីម្តង សង្ខសេដ្ឋីពិចារណាដល់ទីពឹងរបស់ខ្លួន គិតថា អញបានធ្វើឧបការៈយ៉ាងធំដល់សម្លាញ់ ចែកសម្បត្តិឲ្យពាក់កណ្តាល គេឃើញអញហើយ គង់មិនបោះបង់ អញនឹងទៅរកគេ ដូច្នេះហើយ នាំភរិយាធ្វើដំណើរទៅនគរពារាណសីដោយជើងទទេ ពោលថា នែនាង នាងដើរតាមវិថីជាមួយខ្ញុំ មិនគួរឡើយ ចាំឡើងយានដែលខ្ញុំបញ្ជូនមកទទួលជាមួយបរិវារជាខាងក្រោយ ចូរផងចាំនៅទីនេះ ទម្រាំ

ខ្ញុំបញ្ជូនយានមក ដូច្នេះហើយ ឲ្យក្រិយាស្នាក់ត្រង់សាលា ខ្លួនឯងចូលកាន់នគរ ទៅកាន់ផ្ទះសេដ្ឋី ឲ្យមនុស្សប្រាប់សេដ្ឋីថា សម្លាញ់របស់លោកឈ្មោះសន្ធសេដ្ឋី មកអំពីនគររាជគ្រឹះ ។ បិលិយសេដ្ឋីឲ្យមនុស្សទៅអញ្ជើញមក កាលឃើញសន្ធសេដ្ឋីហើយ ក៏មិនបានក្រោកឡើងចាកអាសនៈ មិនធ្វើបដិសណ្ឋារៈឡើយ សួរដោយសោះកក្រោះថា ឯងមកធ្វើអ្វី ។ សន្ធសេដ្ឋីឆ្លើយថា ខ្ញុំមកដើម្បីជួបឯង ។ បិលិយសេដ្ឋីសួរថា ឯងសម្រាកឯណា ។ សន្ធសេដ្ឋីឆ្លើយថា ទីពឹងពំនាក់របស់ខ្ញុំ មិនមានទេ ខ្ញុំឲ្យមេផ្ទះឈប់ត្រង់សាលា ហើយមកមុន បិលិយសេដ្ឋីពោលថា ទីអាស្រ័យរបស់ឯងក្នុងទីនេះ ក៏មិនមាន ចូរឯងទទួលអាហារទៅឲ្យនាងចម្អិនបរិភោគក្នុងទីមួយកន្លែង រួចនាំគ្នាទៅចុះ កុំមកជួបយើងទៀតឡើយ ហើយប្រាប់ទាសៈថា ចូរឯងវាល់សំដីស្រូវ ១ តុម្ពៈ ( ៤ នាឡិ ) វេចដោយជាយសំពត់ ឲ្យសម្លាញ់យើងចុះ ។ បានឮថា ក្នុងថ្ងៃនោះបិលិយសេដ្ឋីឲ្យមនុស្សជញ្ជូនស្រូវសាលីក្រហមប្រមាណមួយពាន់រទេះ ដាក់ពេញជង្រុក ទាំងដែលបានទទួលទ្រព្យ ៤០ កោដិមក គង់រមិលគុណ ដូចមហាចោរ ប្រាប់ឲ្យវាល់សំដីស្រូវ ១ តុម្ពៈ ដល់សម្លាញ់បាន ។ ទាសៈវាល់សំដីស្រូវ ១ តុម្ពៈ ដាក់កញ្ជើ ហើយឲ្យដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា បុគ្គលនេះ ជាអសប្បុរស បានទ្រព្យ ៤០ កោដិ អំពីសម្នាក់របស់អញ ឥឡូវនេះ ឲ្យសំដីស្រូវ ១ តុម្ពៈ អញគួរទទួលឬហ្ន៎ ហើយមានបរិវិតក្កថា បុគ្គលនេះជាមនុស្សរមិលគុណ ជាអ្នកទ្រុស្តមិត្ត ជាអ្នកទម្លាយមិត្តភាពរវាងអញហើយ ដោយភាពជាបុគ្គលកាត់ផ្តាច់នូវឧបការៈ

ដែលអញធ្វើ បើអញមិនទទួលសំដីស្រូវ ១ តុម្ពៈ ដែលគេឲ្យ ព្រោះជារបស់អាក្រក់សោត ក៏ត្រូវទម្លាយមិត្តភាព បុគ្គលអន្ធពាល មិនព្រមទទួលរបស់ដែលខ្លួនបានតិចតួច តែងញ៉ាំងមិត្តភាពឲ្យរវាតទៅ តែអញទទួលសំដីស្រូវដែលគេឲ្យ និងធ្វើមិត្តភាពឲ្យតាំងនៅ ដោយអំណាចរបស់អញ ហើយក៏ខ្ចប់សំដីស្រូវ ១ តុម្ពៈ ត្រង់ជាយសំពត់ ចុះអំពីប្រាសាទទៅកាន់សាលា ។ គ្រានោះ ភរិយាសួរថា នែអ្នក អ្នកបានវត្ថុអ្វីមកខ្លះ ។ សន្ធសេដ្ឋីឆ្លើយថា នែនាងដ៏ចម្រើន បិលិយសេដ្ឋីសម្លាញ់របស់យើង ឲ្យសំដីស្រូវ ១ តុម្ពៈ ហើយបណ្ដេញយើងក្នុងថ្ងៃនេះឯង ។ ភរិយាពោលថា អ្នកទទួលមកធ្វើអ្វី របស់នោះសមគួរដល់ទ្រព្យ ៤០ កោដិឬ ហើយផ្ដើមទ្រហោយំ ព្រះពោធិ-សត្វពោលថា នែនាង នាងកុំយំថ្វីឡើយ ខ្ញុំខ្លាចខូចមេត្រីភាពជាមួយគេ ទើបទទួលមក ដើម្បីតម្កល់នូវមិត្តភាពដោយអំណាចរបស់ខ្ញុំ នាងយំធ្វើអ្វី ដូច្នេះហើយ ពោលគាថានេះថា

ការរាប់អានទាំងឡាយ របស់ជនពាល រមែងទៅជាទោស ព្រោះ
តែមិនទទួលនូវវត្ថុ តាមមាន តាមបាន ព្រោះហេតុនោះ បានជា
យើងខ្ញុំ នាំយកសំដីស្រូវកន្លះមានៈ ( ៤ នាឡិ ) មក កុំឲ្យការ
មេត្រីរាប់អានរបស់យើង បែកបាក់ទៅឡើយ សូមឲ្យការមេត្រី
រាប់អាននេះ នៅទៀងទាត់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសម្បទានេន** សេចក្ដីថា មិនព្រមទទួលរបស់ ចូលសន្និដ្ឋា ដោយលុបស្រះ សេចក្ដីថា ព្រោះមិនកាន់យករបស់ ។

បទថា **ឥតរីតរស្ស** បានដល់ របស់ណាមួយ ទោះអាក្រក់ ឬមិនអាក្រក់ក៏ដោយ ។

បទថា **ពាលស្ស មិត្តានិ កលី ភវន្តិ** សេចក្តីថា មេត្រីរបស់មនុស្សល្ងង់ ឥតបញ្ញា រមែងឈ្មោះថា ជាកលី គឺដូចគ្នានឹងកាឡកិណី អធិប្បាយថា រមែងប្រេះធាបាន ។

បទថា **តស្មា ហរាមិ ភុសំ អឌ្ឍមានំ** នេះ ព្រះពោធិសត្វសម្តែងថា ដោយហេតុនោះ ទើបខ្ញុំ គឺព្រមទទួលកណ្តៀបស្រូវមួយតុម្ពៈ ដែលសម្លាញ់ឲ្យ អធិប្បាយថា ១ មានៈ = ៨ នាឡិ កន្លះមានៈ = ៤ នាឡិ ៤ នាឡិ ឈ្មោះថា ១ តុម្ពៈ ដោយហេតុនោះ ទើបលោកពោលថា **បលាបតុម្ពំ**។

បទថា **មា មេ មិត្តិ ភិជ្ជិត្ថ សស្សតាយំ** សេចក្តីថា មេត្រីភាពរបស់យើង និងសម្លាញ់ កុំបែកគ្នាឡើយ សូមឲ្យមេត្រីនេះស្ថិតស្ថេរទៅចុះ ។

កាលព្រះពោធិសត្វពោលយ៉ាងនេះ ភរិយាក៏នៅតែយំនោះឯង ។ ក្នុងខណៈនោះ ទាសៈអ្នកធ្វើការងារដែលសង្ខសេដ្ឋី ប្រគល់ឲ្យដល់បិលិយសេដ្ឋី ដើរមកកាត់ទ្វារសាលា បានឮសំឡេងភរិយារបស់សេដ្ឋីយំ ទើបចូលទៅកាន់សាលា ឃើញចៅហ្វាយចាស់របស់ខ្លួន ក៏ក្រាបទៀបបាតជើង យំរៀបរាប់ថា បពិត្រលោកម្ចាស់ លោកនាំគ្នាមកទីនេះធ្វើអ្វី លោកសេដ្ឋីក៏និយាយរឿងទាំងអស់ឲ្យស្តាប់ ទើបទាសៈលួងលោមជនទាំង ២ ថា ណ្ហើយចុះ លោកទាំង ២ កុំគិតឡើយ ហើយនាំទៅផ្ទះរបស់ខ្លួន ឲ្យងូតទឹកក្រអូប ឲ្យបរិភោគអាហារហើយ ទាសៈទាំងឡាយដ៏សេសមកប្រជុំគ្នា សម្តែងឲ្យដឹងថា ចៅហ្វាយ

របស់ពួកយើងមកហើយ ស្នាក់នៅ ២-៣ ថ្ងៃ ក៏នាំទាសៈទាំងអស់ទៅកាន់លានព្រះរាជវាំង ហើយស្រែកឡើង ។ ព្រះរាជាត្រាស់ឲ្យហៅមកសួរថា នេះរឿងអ្វី ទាសៈទាំងនោះនាំគ្នាក្រាបទូលរឿងទាំងអស់ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ទាសៈហើយ ត្រាស់ឲ្យហៅសេដ្ឋីទាំង ២ ចូលគាល់ ត្រាស់សួរសន្ខសេដ្ឋីថា មហាសេដ្ឋី បានឮថា លោកឲ្យទ្រព្យ ៤០ ដល់បិលិយសេដ្ឋីពិតឬ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ មិនមែនត្រឹមទ្រព្យតែម៉្យាងប៉ុណ្ណោះទេ ដែលទូលបង្គំឲ្យដល់សម្លាញ់ដែលនឹកដល់ទូលបង្គំ ហើយបែរមុខមកកាន់នគររាជគ្រឹះ ទូលបង្គំចែកសវិញ្ញាណកទ្រព្យ និងអវិញ្ញាណទ្រព្យជាសម្បត្តិគ្រប់យ៉ាងចេញជា ២ ចំណែកហើយ ឲ្យពាក់កណ្តាល ។ ព្រះរាជាត្រាស់សួរបិលិយសេដ្ឋីថា សេចក្តីនោះពិតឬ បិលិយ-សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព ជាការពិត ព្រះរាជាសួរបន្តថា សេដ្ឋីនឹកដល់អ្នកមកដល់ទីនេះហើយ អ្នកបានធ្វើសក្ការៈរាប់អានអ្វីខ្លះ បិលិ-យសេដ្ឋីនៅស្ងៀម ព្រះរាជាត្រាស់ថា នៅមានរឿងមួយទៀត អ្នកបានឲ្យទាសៈវាល់សំដីស្រូវ ១ តុម្ពៈ ដាក់ជាយសំពត់ឲ្យមែនឬ ។ បិលិយសេដ្ឋីសូម្បីស្តាប់ព្រះតម្រាស់នោះ ក៏នៅស្ងៀមនោះឯង ព្រះរាជាទ្រង់ប្រឹក្សាជាមួយអមាត្យថា ពួកយើងគួរធ្វើដូចម្តេច ទ្រង់បរិភាសបិលិយសេដ្ឋី ហើយត្រាស់ថា ទៅចុះ អ្នកទាំងឡាយ ចូរយកសម្បត្តិទាំងអស់ក្នុងផ្ទះរបស់បិលិយសេដ្ឋីឲ្យដល់សន្ខសេដ្ឋីចុះ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមិនត្រូវការទ្រព្យដទៃឡើយ សូមទ្រង់ព្រះរាជទានចំណែកដែលទូលបង្គំ

ឲ្យដល់គេប៉ុណ្ណោះចុះ ។ ព្រះរាជាឲ្យព្រះរាជទានសម្បត្តិដែលជាចំណែកនៃព្រះពោធិសត្វ ។ ព្រះពោធិសត្វបានសម្បត្តិដែលខ្លួនឲ្យទៅទាំងអស់ត្រឡប់មកវិញ ចោមរោមដោយពួកទាសៈ ទៅកាន់នគររាជគ្រឹះនោះឯង តម្កល់ខ្លួនបានហើយ ធ្វើបុណ្យទាំងឡាយ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បិលិយសេដ្ឋីក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ឯសង្ខសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា អសម្បទានជាតក ចប់**

# សុត្តន្តបិដក

## បញ្ចភិរុកជាតក

[ ១៣២ ] ( ព្រះរាជាពោធិសត្វពោលថា ) យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្តីព្យាយាមដ៏មាំក្នុងឧបាយ គ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្របសង្កត់សេចក្តីខ្លាច និងសេចក្តីតក់ស្លុតផង សុវត្ថិភាពចាកភ័យដ៏ធំនោះមានដល់ខ្ញុំ ។

**បញ្ចភិរុកជាតកទី ២ ចប់**

# អដ្ឋកថា

## បញ្ញាភិរុកជាតក

[ ១៣២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសូត្រ ដែលពោលអំពីការលួងលោមរបស់មារធីតា ត្រង់អជបាលនិគ្រោធ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កុសលូបទេសេ ធិតិយា ទឡ្ហាយ ច** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលដែលព្រះសាស្តាត្រាស់ព្រះសូត្រនោះ តាំងអំពីដើមរហូតចប់បរិបូណ៌យ៉ាងនេះ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

នាងតណ្ហា អរតី រាគា ក៏នាំគ្នាដើរមក ដោយសេចក្តីរុងរឿង ព្រះសាស្តាបណ្តេញនូវនាងទាំងនោះពីទីនោះចេញ ដូចជាខ្យល់ ដែលបក់ផាត់នូវប៉ុយ ដែលធ្លាក់ចុះអំពីផ្លែ ដូច្នេះ ។

ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា លើករឿងមកសន្ទនាគ្នាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មិនបើកព្រះនេត្រមើលពួកមារធីតា ដែលនិម្មិតរូបទិព្វរាប់រយយ៉ាង ហើយចូលទៅរកដើម្បីលួងលោម ឱ ! ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធ គួរអស្ចារ្យ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយ ទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលមិនសម្លឹងមើលពួកមារធីតារបស់តថាគតក្នុងកាលដែលតថាគតមានអាសវៈអស់ហើយ ជាសព្វញ្ញូហើយ ក្នុងឥឡូវនេះ មិនគួរអស្ចារ្យឡើយ ពិតហើយ ក្នុងកាលមុន តថាគតកំពុងស្វែង

រកពោធិញ្ញាណ ក្នុងកាលដែលតថាគត នៅមានកិលេស មិនបានទម្លាយឥន្រ្ទិយទាំងឡាយ សម្លឹងមើលរូបដែលជាទិព្វ ដែលពួកយក្ខិនីនាំគ្នានិម្មិតដោយអំណាចនៃកិលេស ប្រព្រឹត្តទៅរហូតសម្រេចដល់ភាពជាព្រះរាជាធំបាន ហើយទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាប្អូនពៅគេបង្អស់ ក្នុងបណ្តាបងប្អូនទាំង ១០០ អង្គ រឿងទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារ ដោយន័យដូចពោលហើយ ក្នុងតក្កសិលាជាតកខាងដើមនោះឯង ប៉ុន្តែក្នុងកាលនោះ កាលអ្នកនគរតក្កសិលាចូលទៅអញ្ជើញព្រះពោធិសត្វ ក្នុងសាលាខាងក្រៅនគរ ប្រគល់រាជសម្បត្តិ ធ្វើនូវការអភិសេកហើយ អ្នកតក្កសិលានគរនាំគ្នាតាក់តែងព្រះនគរ ដូចស្ថានសួគ៌ តាក់តែងព្រះរាជនិវេសន៍ដូចវិមានព្រះឥន្រ្ទ កាលព្រះពោធិសត្វយាងចូលព្រះនគរហើយ យាងឡើងកាន់បល្ល័ង្ករតន៍ ខាងក្រោមស្វេតច្ឆត្រ ក្នុងផ្ទៃប្រាសាទដែលជាព្រះរាជដ្ឋាន ប្រថាប់គង់ដោយលីលា ដូចទេវរាជ ពួកអមាត្យ ព្រាហ្មណ៍ គហបតី និងខត្តិយកុមារ តែងគ្រឿងអលង្ការសព្វគ្រប់ ចោមរោមដោយអ្នករបាំ អ្នកបម្រើប្រមាណ ១៦ ពាន់នាក់ សុទ្ធតែស្រស់ស្អាត ប្រៀបដូចទេពអប្សរ ស្រីទាំងនោះ ឈ្លាសក្នុងការរាំ ច្រៀង និងប្រគំ ដល់ព្រមដោយលីលាដ៏ស្រស់ត្រកាល នាំគ្នារាំច្រៀង និងប្រគំ ព្រះរាជវាំងក៏ឮរងំទូទៅ ដោយសំឡេងច្រៀង និងសំឡេងតន្ត្រី ហាក់បីដូចផ្ទៃមហាសមុទ្រ ដែលរលកបក់បោក ក្នុងកាលដែលភ្លៀងធ្លាក់

ហើយ ព្រះពោធិសត្វទតមើលសិរីសម្បត្តិ ដែលទ្រង់សម្រេចនោះ ទ្រង់ត្រិះរិះថា បើអញជ្រុលសម្ងឹងមើលរូបទិព្វ ដែលយក្ខិនីទាំងនោះនិម្មិតហើយ គង់នឹងអស់ជីវិត គង់មិនបានមើលសិរីសម្បត្តិនេះ តែព្រោះអញតាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបសិរីសម្បត្តិនេះ សម្រេចដល់អញ កាលទ្រង់ត្រិះរិះដូច្នេះហើយ ទ្រង់បន្លឺឧទានដោយព្រះតម្រាស់ថា

យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្តីព្យាយាមដ៏មាំក្នុងឧបាយ គ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគេចសង្កត់សេចក្តីខ្លាច និងសេចក្តីតក់ស្លុតផង សួស្តិភាពចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុសលូបទេសេ** សេចក្តីថា ក្នុងពាក្យបង្អុលបង្ហាញរបស់លោកអ្នកឈ្លាសទាំងឡាយ អធិប្បាយថា ក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។

បទថា **ធិតិយា ទឡ្ហាយ ច** សេចក្តីថា ព្រោះសេចក្តីព្យាយាមដាច់ខាតមាំទាំ អធិប្បាយថា ព្រោះសេចក្តីព្យាយាមដែលជាប់តគ្នាមិនដាច់ យ៉ាងពិតប្រាកដ ។

បទថា **អវត្ថិតត្តា ភយភីរុតាយ ច** សេចក្តីថា ព្រោះការមិនញាប់ញ័រចំពោះការខ្លាច និងការតក់ស្លុត ។ ក្នុងភ័យទាំង ២ យ៉ាងនោះ ភ័យតិចតួចដែលធ្វើឲ្យចិត្តតក់ស្លុត ឈ្មោះថា **ភយៈ** ( ខ្លាច ) ភ័យធំដែលធ្វើឲ្យរាងកាយញ័ររន្ធត់ ឈ្មោះថា **ភីរុតា** ( តក់ស្លុត ) ភ័យទាំង ២ ប្រការនេះ

មិនមានដល់ព្រះពោធិសត្វឡើយ ព្រោះឃើញអារម្មណ៍ដែលគួរខ្លាចថា ឈ្មោះថា យក្ខិនីទាំងនេះ នឹងស៊ីមនុស្សទាំងនោះ ។ ដោយហេតុនោះ ទើបលោកពោលថា **អវត្ថិតត្តា ភយភីរុតាយ ច** ដូច្នេះ អធិប្បាយថា ព្រោះទោះឃើញអារម្មណ៍ដែលគួរខ្លាច ក៏មិនរាថយ ដ្បិតថា មិនមានការខ្លាច និងការតក់ស្លុតឡើយ ។

បទថា **ន រក្ខសីនំ វសមាគមិម្ហ សេ** សេចក្តីថា មិនត្រូវមកកាន់អំណាចនៃស្រីអារក្ខទាំងនោះ ក្នុងផ្លូវកន្តារដោយយក្ខ លោកអធិប្បាយថា ព្រោះយើងមានការតាំងចិត្តដាច់ខាត មាំទាំ ក្នុងពាក្យឱវាទរបស់អ្នកឈ្លាស យើងមានការមិនរាថយជាសភាវៈ ព្រោះមិនមានការខ្លាច និងការតក់ស្លុត ដូច្នោះទើបខ្ញុំមិនមកកាន់អំណាចរបស់អារក្ខ ។ បទថា **ស សោត្ថិភាវោ មហតា ភយេន មេ** សេចក្តីថា សួស្តី គឺការក្សេមចាកភ័យដ៏ធំក្រៃលែង គឺចាកទុក្ខទោមនស្សដែលខ្ញុំត្រូវជួបក្នុងសម្នាក់នៃពួកអារក្ខ បានដល់ មានបីតិសោមនស្សតែម្យ៉ាង ដែលកើតហើយ ដល់ខ្ញុំក្នុងថ្ងៃនេះ ។ ព្រះមហាសត្វទ្រង់សម្តែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ បំពេញបុណ្យ មានទានជាដើម យាងទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជកុមារ ដែលទៅគ្រប់គ្រងរាជសម្បត្តិក្នុងតក្កសិលានគរ ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា បញ្ចភីរុកជាតក ចប់**

# សុត្តន្តបិដក

## ឃតាសនជាតក

[ ១៣៣ ] ( ស្តេចបក្សីពោធិសត្វពោលថា ) សេចក្តីក្សេមក្សាន្តមាននៅលើខ្នងទឹកណា លើខ្នងទឹកនោះ មានសត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់ពាក់កណ្តាលនៃទឹក ទីអាស្រ័យនៅ ( នៃពួកយើង ) លើដើមឈើ ( ដែលដុះ ) លើផែនដីធំ ក្នុងថ្ងៃនេះគ្មានទេ អ្នកទាំងឡាយ ចូរទៅកាន់ទិសឯទៀតទៅ ថ្ងៃនេះ ភ័យកើតឡើងដល់យើងទាំងឡាយ អំពីឈើជាទីពឹងហើយ ។

**ឃតាសនជាតកទី ៣ ចប់**

# អដ្ឋកថា

## យវាសជាតក

[ ១៣៣ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ខេមំ យហឹ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ភិក្ខុនោះរៀនកម្មដ្ឋានអំពីសម្នាក់ព្រះសាស្តា ហើយទៅកាន់ជាយដែន ក្នុងតំបន់មួយ អាស្រ័យស្រុកមួយចាំវស្សា នាសេនាសនៈក្នុងព្រៃ ក្នុងខែដំបូងនោះឯង កាលលោកចូលទៅបិណ្ឌបាត សាលាត្រូវភ្លើងឆេះ លោកលំបាកដោយការមិនមានលំនៅ ទើបប្រាប់ពួកឧបដ្ឋាក ជនទាំងនោះនាំគ្នានិយាយថា មិនជាការអ្វីទេ ពួកខ្ញុំនឹងសាងបណ្ណសាលា ប្រគេនរង់ចាំឲ្យពួកខ្ញុំភ្ជួរ និងសាបព្រោះហើយសិនចុះ ។ ៣ ខែបានកន្លងផុតទៅ លោកមិនអាចបំពេញកម្មដ្ឋានឲ្យដល់ទីបំផុតបាន ព្រោះមិនមានសេនាសនៈដែលជាទីសប្បាយ សូម្បីត្រឹមតែនិម្មិត ក៏ឲ្យកើតឡើងមិនបាន លុះចេញវស្សាទើបទៅកាន់ជេតពនមហាវិហារ ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនៅក្នុងចំណែកម្ខាង ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយលោក ហើយត្រាស់សួរថា ម្នាលភិក្ខុ កម្មដ្ឋានរបស់អ្នកជាសប្បាយឬទេ ទើបក្រាបទូលភាពមិនសប្បាយ តាំងអំពីដើមដល់ចប់ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន សូម្បីតែសត្វតិរច្ឆានទាំងឡាយ ក៏គង់ស្គាល់សប្បាយ និងអសប្បាយរបស់ខ្លួន នាំគ្នានៅអាស្រ័យក្នុងកាលដែលជាសប្បាយ ក្នុងកាលមិនសប្បាយ ក៏នាំគ្នាគេចទៅកាន់ទីដទៃ ចុះហេតុអ្វី ទើបអ្នកមិនដឹងសប្បាយ និងអសប្បាយរបស់ខ្លួន លោកក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមក*

សាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតបក្សី ដល់នូវភាពដឹងក្តីហើយ ជាសត្វមានរូបស្អាតក្រៃលែង បានជាស្តេចបក្សី អាស្រ័យដើមឈើធំ សម្បូរដោយមែក និងស្លឹកសាខា និងប្រគាប មានស្លឹកក្រាស់ ក្បែរជាតស្រះ ក្នុងដងព្រៃមួយកន្លែងនៅជាប្រចាំ មួយអន្លើដោយបរិវារ បក្សីជាច្រើន កាលនៅត្រង់មែក ដែលទោរទន់ទៅលើទឹករបស់ដើមឈើនោះ នាំគ្នាបន្ទោបង់លាមកក្នុងទឹក ហើយក្នុងជាតស្រះនោះ មាននាគរាជកាចនៅអាស្រ័យ នាគរាជនោះមានវិតក្កថា បក្សីទាំងនេះនាំគ្នាជុះក្នុងជាតស្រះ ជាលំនៅរបស់អញ អញត្រូវឲ្យភ្លើងឆេះអំពីទឹកដុតដើមឈើចោល ឲ្យពួកបក្សីទាំងនេះគេចទៅ ស្តេចនាគមានចិត្តក្រោធ លុះពេលយប់ កាលដែលបក្សីទាំងអស់មកប្រជុំគ្នា ដេកត្រង់មែកឈើទាំងឡាយ ក៏ផ្តើមធ្វើឲ្យទឹកក្តៅ ហាក់ដូចជាលើកស្រះឡើងដាក់លើជើងក្រានដូច្នោះជាបឋម បន្ទាប់មក ធ្វើឲ្យផ្សែងហុយឡើង បន្ទាប់មក ធ្វើឲ្យភ្លើងឆេះកម្ពស់មួយជួរត្នោត ។ ព្រះពោធិសត្វឃើញភ្លើងឆេះឡើងអំពីទឹក ក៏ពោលថា ម្នាលគ្នាយើងទាំងឡាយ ធម្មតាភ្លើងកើតឡើង គេក៏នាំគ្នាយកទឹកលត់ តែឥឡូវនេះ ទឹកនោះឯងឆេះជាភ្លើង ពួកយើងមិនអាចនៅក្នុងទីនេះបាន ត្រូវនាំគ្នាទៅទីដទៃ ហើយពោលគាថានេះថា

សេចក្តីក្សេមក្សាន្ត មាននៅលើខ្នងទឹកណា លើខ្នងទឹកនោះ មាន
សត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់ពាក់កណ្តាលនៃទឹក ទីអាស្រ័យ

នៅ ( នៃពួកយើង ) លើដើមឈើ ( ដែលដុះ ) លើផែនដីធំក្នុងថ្ងៃនេះគ្មានទេ អ្នកទាំងឡាយ ចូរទៅកាន់ទិសឯទៀតទៅ ថ្ងៃនេះ ភ័យកើតឡើងដល់យើងទាំងឡាយ អំពីឈើជាទីពឹងហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខេមំ យហឹ តត្ថ អរី ឧទីរិតោ** សេចក្តីថា ការក្រេម គឺការផុតភ័យ មាននៅលើទឹកណា ទឹកនោះ មានសត្រូវប្រឈមមុខហើយ ។

បទថា **ឧកស្ស** ស្មើគ្នានឹង **ឧទកស្ស** បានដល់ នៃទឹក ។

ភ្លើង ឈ្មោះថា **ឃតាសន** អធិប្បាយថា ភ្លើងនោះរមែងស៊ីទធិ ព្រោះហេតុនោះ ទើបលោកហៅថា **ឃតាសន**។

បទថា **ន អជ្ជ វាសោ** សេចក្តីថា ថ្ងៃនេះ លំនៅរបស់ពួកយើងមិនមានឡើយ ។

បទថា **មហិយា មហីរុហោ** នេះ ដើមឈើ លោកហៅថា **មហីរុហោ** អធិប្បាយថា បានដល់ ដើមឈើដែលកើតលើផែនដី ។

បទថា **ទិសា ភជវ្ហោ** សេចក្តីថា ចូរអ្នកទាំងឡាយគប់រក គឺនាំគ្នាហើរទៅតាមទិសផ្សេងៗ ។

បទថា **សរណាជ្ជ នោ ភយំ** សេចក្តីថា ថ្ងៃនេះ ភ័យកើតអំពីទីពឹងនៃពួកយើងហើយ គឺទីពំនាក់របស់ពួកយើងកើតភ័យឡើងហើយ ។

ព្រះពោធិសត្វ កាលពោលយ៉ាងនេះហើយ ក៏នាំហ្វូងបក្សីដែលស្ដាប់នូវដំបូន្មានខ្លួន ហើរទៅក្នុងទីដទៃ ហ្វូងបក្សីដែលមិនជឿពាក្យរបស់ព្រះពោធិសត្វ នាំគ្នាទំនៅ ដល់នូវការអស់ជីវិតហើយ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងអរហត្តផល ហើយទ្រង់ប្រជុំជាតកថា ហ្វូងបក្សីដែលធ្វើតាមពាក្យរបស់ព្រះពោធិសត្វក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯស្ដេចបក្សី ក្នុងកាលនោះ គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា យសាសនជាតក ចប់**

# សុត្តន្តបិដក

## ឈានសោធនជាតក

[ ១៣៤ ] *( មហាព្រហ្មពោធិសត្វពោលថា ) ពួកសត្វណាមានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត ( មិនបានសមាបត្តិ ) ពួកសត្វណាមិនបានសញ្ញា ពួកសត្វនោះក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួល គឺកិលេសឡើយ ។*

***ឈានសោធនជាតកទី ៤ ចប់***

# អដ្ឋកថា

## ឈានសោធនជាតក

[ ១៣៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មសេនាបតី ដែលព្យាករបញ្ហារបស់ទ្រង់ ដោយសង្ខេបបានដោយពិស្តារត្រង់ទ្វារសង្កស្សនគរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យេ សញ្ញិនោ** ដូច្នេះជាដើម ។

បន្តអំពីនេះទៅ ជារឿងអតីតក្នុងព្រះធម្មទេសនានោះ ។ បានឮថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកំពុងធ្វើកាលកិរិយាត្រង់ជាយព្រៃ ត្រូវពួកអន្តេវាសិកសួរ ក៏ពោលថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។បេ។ ( ដូចគ្នានឹងរឿងក្នុងបរោសហស្សជាតក ) ពួកតាបសមិនជឿពាក្យអន្តេវាសិកដែលជាធំ ទើបព្រះពោធិសត្វមកអំពីព្រហ្មលោកជាន់អាភស្សរ ឈរក្នុងអាកាសពោលគាថានេះថា

ពួកសត្វណាមានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត ( មិនបានសមាបត្តិ ) ពួកសត្វណាមិនបានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួល គឺកិលេសឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ សញ្ញិនោ** នេះ លោកសម្ដែងដល់ពួកសត្វដែលមានចិត្តដ៏សេស វៀរបុគ្គលដែលបាននេវសញ្ញានាសញ្ញាយតនជ្ឈាន ។

បទថា **តេបិ ទុគ្គតា** សេចក្ដីថា ព្រោះមិនបានសមាបត្តិនោះ ទើបជនទាំងនោះ ជាបុគ្គលឈ្មោះថា ទុគ្គត ។

បទថា **យេបិ អសញ្ញិនោ** នេះ លោកសម្ដែងដល់អចិត្តកសត្វ ដែលកើតក្នុងអសញ្ញីភព ។

បទថា **តេបិ ទុគ្គតា** សេចក្ដីថា សូម្បីសត្វទាំងនោះ ក៏គង់ជាទុគ្គតដូចគ្នា ព្រោះមិនទាន់បានសមាបត្តិនោះឯង ។

បទថា **ឯតំ ឧភយំ វិវជ្ជយ** សេចក្ដីថា ព្រះពោធិសត្វឲ្យឱវាទដល់អន្តេវាសិកតទៅថា ចូរអ្នកវៀរ គឺលះបង់ទាំង ២ យ៉ាងនោះ គឺសញ្ញីភាវៈនិងអសញ្ញីភាវៈ ។

បទថា **តំ សមាបត្តិ សុខំ អនង្គណំ** សេចក្ដីថា សេចក្ដីសុខក្នុងឈាននោះ គឺដល់នូវការរាប់ថាជាសុខ ដោយជាធម្មជាតស្ងប់រម្ងាប់របស់លោកដែលបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ជាសភាពមិនមានកិលេស ដូចទីទួល គឺប្រាសចាកទោស សេចក្ដីសុខនោះ ឈ្មោះថា ជាសភាវៈមិនមាន

*កិលេសដូចទីទួល ព្រោះភាពដែលចិត្តមានអារម្មណ៍តែមួយ មានកម្លាំងជាសភាវៈ ។*

*ព្រះពោធិសត្វ សម្តែងធម៌សរសើរគុណរបស់អន្តេវាសិក ដោយប្រការដូច្នេះហើយ ក៏ត្រឡប់ទៅកាន់ព្រហ្មលោក គ្រានោះ តាបសដ៏សេសនាំគ្នាស្តាប់អន្តេវាសិកធំ ។*

*ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អន្តេវាសិកធំ ក្នុងកាលនោះ បានមកជាសារីបុត្រ ក្នុងកាលឥឡូវនេះ ឯមហាព្រហ្មក្នុងកាលនោះ គឺតថាគតនេះឯង ។*

**អដ្ឋកថា ឈានសោធនជាតក ចប់**

# សុត្តន្តបិដក

## ចន្ទាភជាតក

[ ១៣៥ ] *( មហាព្រហ្មពោធិសត្វពោលថា ) បុគ្គលណាក្នុងលោកនេះ បាននូវកសិណ មានពន្លឺដូចព្រះចន្ទ្រ ( ឱទាតកសិណ ) មានពន្លឺដូចព្រះអាទិត្យ ( បីតកសិណ ) ដោយបញ្ញា បុគ្គលនោះ រមែងទៅកើតក្នុងអាភស្សរព្រហ្មលោក ដោយឈានមិនមានវិតក្ក ( ទុតិយជ្ឈាន ) ។*

**ចន្ទាភជាតកទី ៥ ចប់**

# អដ្ឋកថា

## ចន្ទាភជាតក

[ ១៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការព្យាករណ៍បញ្ហារបស់ព្រះថេរៈនោះឯង ត្រង់ទ្វារសង្កស្សនគរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ចន្ទាភំ** ដូច្នេះ ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកំពុងធ្វើកាលកិរិយាក្នុងជាយព្រៃ ត្រូវពួកអន្តេវាសិកសាកសួរ ក៏ពោលថា **ចន្ទាភំ សុរិយាភំ** ពន្លឺព្រះចន្ទ ពន្លឺព្រះអាទិត្យ ដូច្នេះហើយ កើតក្នុងអាភស្សរព្រហ្ម ។ ពួកតាបសមិនជឿអន្តេវាសិកធំ ព្រះពោធិសត្វ មកអំពីអាភស្សរព្រហ្ម ស្ថិតក្នុងអាកាស ពោលគាថានេះថា

បុគ្គលណា ក្នុងលោកនេះ បាននូវកសិណ មានពន្លឺដូចព្រះចន្ទ្រ
( ឱទាតកសិណ ) មានពន្លឺដូចព្រះអាទិត្យ ( បីតកសិណ )
ដោយបញ្ញា បុគ្គលនោះ រមែងទៅកើតក្នុងអាភស្សរព្រហ្មលោក
ដោយឈានមិនមានវិតក្ក ( ទុតិយជ្ឈាន ) ដូច្នេះ ។

បណ្ដាពាក្យទាំងនោះ ព្រះពោធិសត្វសម្ដែងឱទាតកសិណ ដោយបទថា **ចន្ទាភំ** សម្ដែងបីតកសិណ ដោយបទថា **សុរិយាភំ**។
បទថា **យោធ បញ្ញាយ គាធតិ** សេចក្ដីថា បុគ្គលណាក្នុងសត្វលោកនេះ ឈមចុះបានដោយបញ្ញានូវកសិណទាំង ២ យ៉ាងនេះ គឺធ្វើឲ្យជាអារម្មណ៍បញ្ជូនចិត្តទៅ ឬតាំងចិត្តទុកបានក្នុងកសិណទាំង ២ យ៉ាងនោះ បរិយាយ

មួយទៀត បទថា **ចន្ទាភំ សុរិយាភញ្ច យោធ បញ្ញាយ គាធតិ** សេចក្តីថា ពន្លឺព្រះចន្ទ និងពន្លឺព្រះអាទិត្យផ្សាយទៅក្នុងទីមានប្រមាណប៉ុនណា បុគ្គល ចម្រើនបដិភាគកសិណក្នុងទីមានប្រមាណប៉ុណ្ណោះ ធ្វើបដិភាគកសិណនោះ ឲ្យជាអារម្មណ៍ ញ៉ាំងឈានឲ្យកើត ក៏រមែងឈ្មោះថា ឈមចុះកាន់ពន្លឺទាំងពីរ នោះបានដោយបញ្ញា ព្រោះហេតុនោះ សេចក្តីនេះ ជាការអធិប្បាយសេចក្តី ក្នុងបទទាំងនោះបានដូចគ្នា ។ បទថា **អវិតក្កេន ឈានេន ហោតិ អាភស្សរូបគោ** សេចក្តីថា បុគ្គលនោះ រមែងចូលដល់អាភស្សរព្រហ្មលោកបាន ដោយឈានទី ២ ដែលខ្លួនបានហើយ ព្រោះធ្វើយ៉ាងនោះ ។

ព្រះពោធិសត្វឲ្យពួកតាបសដឹងច្បាស់ ដោយប្រការដូច្នេះហើយ ពោល សរសើរគុណរបស់អន្តេវាសិកដែលជាធំ ត្រឡប់ទៅកាន់ព្រហ្មលោក មួយ រំពេច ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អន្តេវាសិកធំក្នុងកាលនោះ បានមកជាសារីបុត្រ ក្នុងកាលឥឡូវនេះ ឯ មហាព្រហ្ម ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ចន្ទាភជាតក ចប់**

# សុត្តន្តបិដក

## សុវណ្ណហំសជាតក

[ ១៣៦ ] *( ព្រះសាស្តាត្រាស់ថា ) ទ្រព្យណា ដែលបុគ្គលបានមក ហើយ បុគ្គលគប្បីត្រេកអរដោយទ្រព្យនោះ ព្រោះថា សេចក្តីល្មោភហួស ជារបស់លាមក ( ដូចនាងព្រាហ្មណី ) ក៏សាបសូន្យចាកមាស ព្រោះចាប់ ស្តេចហង្ស ។*

*សុវណ្ណហំសជាតកទី ៦ ចប់*

# អដ្ឋកថា

## សុវណ្ណហំសជាតក

[ ១៣៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីឈ្មោះថុល្លនន្ទា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យំ លទ្ធំ តេន តុដ្ឋព្វំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ឧបាសកម្នាក់ ក្នុងនគរសាវត្ថីបវារណាខ្ទឹមដល់ភិក្ខុនីសង្ឃ និងប្រាប់អ្នកយាមចម្ការថា បើភិក្ខុនីទាំងឡាយនាំគ្នាមកយក ចូរឲ្យមួយរូប ២-៣ មើមចុះ ។ តាំងអំពីនោះ ភិក្ខុនីទាំងឡាយត្រូវការខ្ទឹម ក៏នាំគ្នាទៅកាន់ផ្ទះរបស់បុគ្គលនោះខ្លះ ត្រង់ចម្ការរបស់បុគ្គលនោះខ្លះ ។ កាលដល់ថ្ងៃមហោស្រពមួយ ខ្ទឹមក្នុងផ្ទះរបស់គាត់អស់ ភិក្ខុនីថុល្លនន្ទា មួយអន្លើដោយបរិវារនាំគ្នាទៅត្រង់ផ្ទះ ហើយពោលថា អាវុសោ ខ្ញុំត្រូវការខ្ទឹម អ្នករក្សាចម្ការពោលថា បពិត្រនាងម្ចាស់ ខ្ទឹមមិនមានទេ ខ្ទឹមដែលទុកអស់ហើយ សូមនិមន្តទៅចម្ការចុះ ទើបនាំគ្នាទៅត្រង់ចម្ការ ជញ្ជូនខ្ទឹមទៅដោយមិនដឹងប្រមាណ ទើបអ្នកចាំចម្ការពោលទោសថា ហេតុអ្វី ទើបពួកភិក្ខុនីជញ្ជូនខ្ទឹមទៅមិនស្គាល់ប្រមាណ ពួកភិក្ខុនីដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ស្តាប់ពាក្យរបស់បុគ្គលនោះហើយ នាំគ្នាពោលទោស កាលពួកភិក្ខុបានឮអំពីសម្នាក់ភិក្ខុនីទាំងនោះ ក៏នាំគ្នាពោលទោស ហើយក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ព្រះមានព្រះភាគ តិះដៀលថុល្លនន្ទាភិក្ខុនី ហើយទ្រង់សម្តែងធម៌ដ៏សមគួរដល់រឿងនោះដល់ភិក្ខុនីទាំងឡាយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បុគ្គលមានសេចក្តីប្រាថ្នាច្រើន មិនបានជាទីស្រឡាញ់

ជាទីត្រេកអរ សូម្បីមាតាបិតាបង្កើត ក៏មិនអាចញុាំងបុគ្គលដែលមិនជ្រះថ្លា ឲ្យជ្រះថ្លា មិនអាចញុាំងអ្នកដែលជ្រះថ្លាហើយ ឲ្យជ្រះថ្លាក្រៃលែងឡើងទេ មិនអាចញុាំងលាភដែលមិនទាន់កើត ឲ្យកើតឡើង ឬលាភដែលកើតហើយ ក៏មិនអាចធ្វើឲ្យស្ថិតស្ថេរបាន ផ្ទុយមកវិញ បុគ្គលមានសេចក្តីប្រាថ្នាតិច រមែងញុាំងបុគ្គលដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ញុាំងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង រមែងញុាំងលាភដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយក៏ធ្វើឲ្យស្ថិតស្ថេរបាន ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនីថុល្លនន្ទា មានសេចក្តីប្រាថ្នាច្រើន សូម្បីក្នុងកាលមុន ក៏ធ្លាប់មានសេចក្តីប្រាថ្នាច្រើនដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍មួយ ចម្រើនវ័យហើយ មាតាបិតាបាននាំទារិកាមកអំពីត្រកូលដែលមានជាតិស្មើគ្នាឲ្យជាភរិយា នាងមានធីតា ៣ នាក់ ឈ្មោះនន្ទា នន្ទវតី និងសុនន្ទា កាលធីតាទាំងនោះ បានប្តីហើយគ្រប់គ្នា ព្រះពោធិសត្វធ្វើកាលកិរិយា ទៅកើតក្នុងកំណើតហង្សមាស មានញាណរឭកជាតិបាន ។ ហង្សមាសនោះចម្រើនធំធាត់ហើយ ឃើញអត្តភាពសម្បូរពេញលេញទៅដោយរោមដែលជាមាស ក៏ពិចារណាថា អញច្យុតិអំពីទីណាហ្ន៎ ទើបមកកើតក្នុងទីនេះ ដឹងថា មកអំពីមនុស្សលោក ពិចារណាទៀតថា ព្រាហ្មណី និងធីតារបស់អញនៅមានជីវិតឬហ្ន៎ ក៏បានដឹងថា ភរិយា

និងធីតារបស់អញ ត្រូវនាំគ្នាទៅស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិត ដោយអត្តខាត់ ទើបគិតថា រោមទាំងឡាយក្នុងសរីរៈរបស់អញជាមាស អត់ធន់នឹងការដំ ការគោះ អញនឹងឲ្យរោមអំពីសរីរៈនេះដល់ស្រីទាំងនោះម្តងមួយរោម ដោយហេតុនោះ ប្រពន្ធ និងកូនស្រីទាំង ៣ របស់អញ នឹងនាំគ្នារស់នៅយ៉ាងសុខសប្បាយ ទើបស្តេចហង្សហើរទៅក្នុងទីនោះ ទំត្រង់ចុងត្បាល់ក្បឿង ។ ព្រាហ្មណី និងធីតាឃើញព្រះពោធិសត្វហើយ ក៏នាំគ្នាសួរថា នែបា បាមកអំពីណា សុវណ្ណហង្សឆ្លើយថា ខ្ញុំជាឪពុករបស់អ្នក ស្លាប់ទៅកើតជាហង្សមាសមកដើម្បីជួបពួកអ្នក តាំងអំពីនេះទៅ ពួកអ្នកមិនចាំបាច់ស៊ីឈ្នួលអ្នកដទៃចិញ្ចឹមជីវិតដោយលំបាកទៀតឡើយ ខ្ញុំនឹងឲ្យរោមដល់ពួកអ្នកម្តងមួយ ចូរយកទៅចិញ្ចឹមជីវិតតាមសប្បាយចុះ ហើយក៏ជម្រុះរោមមួយសរសៃឲ្យ ហើយហើរទៅ ហង្សមាសនោះមកជារឿយៗ ជម្រុះរោមម្តងមួយៗ ដោយទំនងនេះ ព្រាហ្មណី និងកូនទាំងឡាយ រីងរឹតតែមានឡើង មានសេចក្តីសុខតាមលំដាប់ ថ្ងៃមួយ ព្រាហ្មណីប្រឹក្សាជាមួយកូនៗ ថា នែនាងទាំងឡាយ ឈ្មោះថាតិរច្ឆាន ដឹងចិត្តបានលំបាក ក្នុងកាលខ្លះ ឪពុករបស់នាងមិនមកទីនេះ ពួកយើងនឹងធ្វើដូចម្តេច គ្រានេះ កាលហង្សនោះមក ពួកយើងជួយគ្នាចាប់ដករោមឲ្យអស់ចុះ ពួកកូនស្រីពោលថា ធ្វើយ៉ាងនោះ ឪពុករបស់យើងនឹងលំបាក អាចខានបានឃើញតទៅ ។ តែនាងព្រាហ្មណីមានសេចក្តីប្រាថ្នាច្រើន ពេលមួយ ស្តេចហង្សមាសមក ក៏ពោលថា មកនេះសិនចុះ លុះស្តេចហង្សចូលទៅជិត ក៏ចាប់ដោយដៃទាំង ២ ដករោមទាល់តែអស់ តែព្រោះចាប់ដក

ដោយបន្ទំ ព្រះពោធិសត្វមិនបានឲ្យដោយស្ម័គ្រចិត្ត ទើបរោមទាំងនោះ ដូចជារោមកុកទាំងអស់ ព្រះពោធិសត្វមិនអាចទទះស្លាបហើរបាន ទើបព្រាហ្មណីចាប់ស្តេចហង្សដាក់ក្នុងពាងធំចិញ្ចឹម រោមដែលដុះសាជាថ្មីរបស់ស្តេចហង្សនោះ ក្លាយជាពណ៌សទាំងអស់ ស្តេចហង្ស កាលរោមដុះស្រួលបួលហើយ ក៏ហោះឡើង ហើរទៅលំនៅរបស់ខ្លួន មិនបានមកទៀតឡើយ ។

ព្រះសាស្តា ទ្រង់នាំយករឿងក្នុងអតីតនេះមកសាធក: ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលថុល្លនន្ទាមានសេចក្តីប្រាថ្នាច្រើន សូម្បីក្នុងកាលមុន ក៏មានសេចក្តីប្រាថ្នាច្រើនដូចគ្នា ព្រោះមានសេចក្តីប្រាថ្នាច្រើន ទើបត្រូវវិនាសចាកហង្សមាស ឥឡូវនេះ ព្រោះខ្លួនមានសេចក្តីប្រាថ្នាច្រើននោះឯង នឹងត្រូវវិនាសចាកខ្ទឹម ព្រោះដូច្នោះ តាំងអំពីឥឡូវនេះទៅ នឹងមិនបានឆាន់ខ្ទឹម សូម្បីដល់ភិក្ខុនីដ៏សេសទាំងឡាយ បុគ្គលអាស្រ័យថុល្លនន្ទានោះ នឹងមិនបានឆាន់ខ្ទឹម ដូចថុល្លនន្ទាដែរ ហេតុនោះ ទោះបីបានច្រើន ក៏ត្រូវស្គាល់ប្រមាណនោះឯង តែបានតិច ក៏ត្រូវពេញចិត្តតាមដែលបានប៉ុណ្ណោះ មិនគួរប្រាថ្នាឲ្យក្រៃលែងឡើង ហើយត្រាស់គាថានេះថា

ទ្រព្យណា ដែលបុគ្គលបានមក ហើយបុគ្គលគប្បីត្រេកអរ ដោយ
ទ្រព្យនោះ ព្រោះថា សេចក្តីល្មោភហួស ជារបស់លាមក ( ដូច
នាងព្រាហ្មណី ) ក៏សាបសូន្យចាកមាស ព្រោះចាប់ស្តេចហង្ស
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តុដ្ឋព្ពំ** បានដល់ គប្បីត្រេកអរ ។

ព្រះសាស្ដា កាលត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់តិះដៀលដោយអនេកបរិយាយ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុនីណាធាន់ខ្ទឹម ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ព្រាហ្មណីក្នុងកាលនោះ បានមកជាភិក្ខុនីថុល្លនន្ទា ក្នុងកាលឥឡូវនេះ ធីតាទាំង ៣ ក្នុងកាលនោះ បានមកជាបងប្អូនស្រីក្នុងកាលឥឡូវនេះ ឯស្ដេចសុវណ្ណហង្ស ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សុវណ្ណហំសជាតក ចប់**

# សុត្តន្តបិដក

## ពត្ថុជាតកៈ

[ ១៣៧ ] ( ព្រះសាស្តាត្រាស់ថា ) ឆ្មាមួយបានកណ្តុរ ក្នុងទីណា ឆ្មាជាគម្រប់ពីរ គម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះ ( ប្រហារ ) នូវរន្ធនេះហើយ ដល់នូវសេចក្តីស្លាប់ ។

ពព្ភុជាតកទី ៧ ចប់

# អដ្ឋកថា

## ៣៧ ជាតក

[ ១៣៧ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសិក្ខាបទដែលទ្រង់បញ្ញត្ត ដោយមានកាណមាតាជាហេតុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យត្ថេកោ លភតេ ពត្ថុ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ក្នុងនគរសាវត្ថី ឧបាសិកាប្រាកដនាមតាមកូនស្រីថា កាណមាតា បានជាអរិយសាវិកាដែលជាសោតាបន្ន នាងបានលើកកូនស្រីឈ្មោះកាណាឲ្យដល់បុរសអ្នកមានជាតិស្មើគ្នា ក្នុងស្រុកមួយ ។ នាងកាណាត្រឡប់មកកាន់ផ្ទះរបស់មាតាដោយករណីយកិច្ចឯណាមួយ បន្ទាប់មក ស្វាមីរបស់នាងកាណាលុះកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនទូតទៅថា ចូរនាងកាណាត្រឡប់មក យើងត្រូវការឲ្យនាងកាណាត្រឡប់ ។ នាងកាណាស្តាប់ពាក្យរបស់ទូតហើយ លាមាតាថា បពិត្រអ្នកម៉ែ ខ្ញុំនឹងទៅ មាតាពោលថា កាណា នាងនៅយូរបែបនេះ នឹងទៅដៃទទេដូចម្តេច ហើយចៀននំ ។ ខណៈនោះឯង ភិក្ខុមួយរូប មានប្រក្រតីត្រាច់បិណ្ឌបាតជាវត្ត បានទៅដល់លំនៅរបស់នាង ឧបាសិកានិមន្តលោកឲ្យគង់ហើយ ប្រគេននំពេញបាត្រ ភិក្ខុនោះចេញទៅហើយ ក៏ប្រាប់ដល់ភិក្ខុដទៃ ឧបាសិកាក៏ប្រគេនដល់ភិក្ខុនោះដោយទំនងនោះឯង ភិក្ខុរូបនោះក៏ត្រឡប់ចេញទៅ ហើយប្រាប់ដល់ភិក្ខុរូបដទៃ ឧបាសិកាក៏ប្រគេនដល់ភិក្ខុនោះទៀត បន្តៗ គ្នា រហូតដល់ ៤ រូប ។ នំដែលបានត្រៀមក៏អស់ទៅ នាងកាណាក៏ខកខានទៅ ។ គ្រានោះប្តីរបស់នាងកាណា ក៏បញ្ជូនទូតទៅអស់វារៈ ២ ដង លុះគ្រាទី ៣ បញ្ជូនទូត*

ទៅ មួយអន្ទើដោយពាក្យថា បើនាងកាណាមិនព្រមមក យើងនឹងនាំស្រីដទៃមកជាភរិយា អស់វារៈទាំង ៣ នាងកាណាក៏មិនទាន់ទៅបាន ដោយរវល់ចាំយកនំនោះឯង ទើបប្តីរបស់នាងនាំស្រីដទៃមកជាភរិយា នាងកាណាបានស្តាប់រឿងនោះហើយ ក៏ទ្រហោយំ ។

ព្រះសាស្តាទ្រង់ជ្រាបរឿងនោះ ព្រឹកឡើង ក៏ទ្រង់ស្លៀកស្បង់ កាន់បាត្រចីវរ ទៅកាន់និវេសន៍របស់កាណមាតា គង់លើអាសនៈដែលគេរៀបចំថ្វាយ ហើយត្រាស់សួរកាណមាតាថា កាណានេះយំព្រោះហេតុអ្វី កាលទ្រង់ស្តាប់ថា ដោយហេតុឈ្មោះនេះ ទើបត្រាស់លួងលោមកាណមាតា សម្តែងធម្មីកថា ក្រោកចាកអាសនៈ ត្រឡប់ទៅកាន់វិហារ ។ សម័យនោះ ភាពដែលភិក្ខុ ៤ រូបនោះទទួលយកនំដែលគេបានត្រៀម រហូតជាការកាត់ផ្តាច់ការទៅរបស់នាងកាណា ក៏ល្បីទៅក្នុងពួកភិក្ខុ ថ្ងៃមួយ ទើបពួកភិក្ខុលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុ ៤ រូប ឆាន់នំដែលកាណមាតាចៀនអស់ ៣ ដង ធ្វើឲ្យនាងកាណាខកខានទៅ ត្រូវប្តីបោះបង់ចោល ព្រោះអាស្រ័យធីតា ទើបធ្វើនូវទោមនស្សឲ្យកើតដល់មហាឧបាសិកា ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូល ឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុទាំង ៤ នោះបរិភោគខាទនីយាហាររបស់កាណមាតា ហើយធ្វើនូវទោមនស្សឲ្យកើតដល់នាង

សូម្បីក្នុងកាលមុន ក៏ធ្លាប់ធ្វើឲ្យទោមនស្សមកហើយដូចគ្នា ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលជាងឆ្លាក់ថ្ម ចម្រើនវ័យហើយសិក្សាសិប្បៈសម្រេចហើយ ។ ក្នុងនិគមមួយកន្លែងនាដែនកាសី មានសេដ្ឋីមានសម្បត្តិច្រើនម្នាក់ សេដ្ឋីនោះកប់ប្រាក់ ៤០ កោដិ ភរិយារបស់គាត់ស្លាប់ទៅហើយ ព្រោះការជាប់ជំពាក់ក្នុងទ្រព្យ ទើបកើតជាសត្វកណ្ដុរ នៅលើគំនរទ្រព្យ ត្រកូលទាំងអស់ដល់នូវការលំបាកដោយលំដាប់ ដោយប្រការដូច្នេះ ខ្សែស្រឡាយក៏ដាច់ ។ សូម្បីផ្ទះនោះ ក៏ក្លាយជាផ្ទះដែលគេបោះបង់បោល ដល់នូវភាពជាផ្ទះមិនមានបញ្ញត្ត ដាច់នូវគ្រឿងសម្គាល់ កាលនោះព្រះពោធិសត្វជីកថ្មក្នុងផ្ទះបុរាណនោះមកឆ្លាក់ ។

ឯកណ្ដុរញីនោះដើររកស៊ី ឃើញព្រះពោធិសត្វរឿយៗ ក៏កើតសេចក្ដីស្រឡាញ់ គិតថា ទ្រព្យរបស់អញមានច្រើន នឹងវិនាសទទេដោយឥតហេតុ អញនឹងសហការជាមួយបុរសនេះចាយវាយទ្រព្យនេះ ។ ថ្ងៃមួយ កណ្ដុរញីពាំ ១ កហាបណៈ ទៅកាន់សម្នាក់ព្រះពោធិសត្វ ។ ព្រះពោធិសត្វឃើញហើយ ក៏ប្រាស្រ័យដោយវាចាជាទីស្រឡាញ់ ពោលថា នែនាង នាងពាំកហាបណៈមកធ្វើអ្វី កណ្ដុរឆ្លើយថា សូមអ្នកទទួលកហាបណៈនេះទៅប្រើជាចំណែកផ្ទាល់ខ្លួនខ្លះ នាំសាច់មកដើម្បីខ្ញុំខ្លះ ព្រះពោធិសត្វទទួលពាក្យហើយយកកហាបណៈទៅកាន់ព្រះនគរ ទិញសាច់មួយមាសក ហើយនាំមកឲ្យកណ្ដុរ

នោះ ។ កណ្តុរនោះទទួលយកសាច់ទៅកាន់ទីលំនៅរបស់ខ្លួន ទំពាស៊ីតាមគាប់ចិត្ត ។ តាំងអំពីនោះមក កណ្តុរក៏ឲ្យកហាបណៈដល់ព្រះពោធិសត្វរាល់ថ្ងៃ ដោយទំនងនេះឯង សូម្បីព្រះពោធិសត្វក៏នាំសាច់មកឲ្យកណ្តុររាល់ថ្ងៃ ។

ថ្ងៃមួយ ឆ្មាចាប់កណ្តុរនោះបាន កណ្តុរញីនិយាយនឹងឆ្មានោះថា នែសម្លាញ់ អ្នកកុំសម្លាប់ខ្ញុំឡើយ ឆ្មាសួរថា រឿងអ្វីដែលយើងមិនសម្លាប់ យើងឃ្លាន យើងចង់ស៊ីសាច់ មិនអាចទុកជីវិតឯងបានទេ កណ្តុរសួរថា អ្នកចង់ស៊ីសាច់ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ឬចង់ស៊ីរហូត ឆ្មាឆ្លើយថា បើបាន យើងចង់ស៊ីរហូត ទើបកណ្តុរពោលថា បើដូច្នោះ ខ្ញុំនឹងឲ្យសាច់អ្នករហូត ចូរលែងខ្ញុំចុះ ។ ពេលនោះ ឆ្មាក៏បញ្ជាក់កណ្តុរថា បើដូច្នោះ ឯងកុំភ្លេច ហើយលែងទៅ តាំងអំពីនោះ កណ្តុរក៏រំលែកសាច់ដែលព្រះពោធិសត្វនាំមកឲ្យខ្លួនជា ២ ចំណែក ឲ្យឆ្មា ១ ចំណែក ខ្លួនឯង ១ ចំណែក ។ ថ្ងៃមួយ កណ្តុរត្រូវឆ្មាដទៃចាប់បានទៀត កណ្តុរញីក៏សំណូមពរឲ្យឆ្មាយល់ព្រមដោយទំនងដូចគ្នានោះឯង ហើយឲ្យដោះលែងខ្លួន តាំងអំពីនោះមក ក៏ត្រូវចែកសាច់ជា ៣ ចំណែក កាលត្រូវឆ្មាដទៃចាប់បានទៀត ក៏សំណូមពរឲ្យដោះលែងខ្លួនដោយវិធីនោះឯង តាំងអំពីនោះ ក៏ត្រូវចែកសាច់ជា ៤ ចំណែក ។ តមក ត្រូវឆ្មាដទៃចាប់បានទៀត ក៏សំណូមពរឲ្យដោះលែងដោយវិធីនោះឯងទៀត តាំងអំពីនោះមក ក៏ត្រូវចែកសាច់ដល់ ៥ ចំណែក កណ្តុរស៊ីចំណែកទី ៥ ព្រោះមានអាហារតិច ទើបលំបាក ស្គាំងស្គម មានសាច់ និងឈាមតិច ។

ព្រះពោធិសត្វឃើញកណ្តុរនោះហើយ ពោលថា នែនាង ហេតុអ្វី ទើប

ស្គាំងស្គមស្មេកស្មាំងយ៉ាងនេះ កាលកណ្តុរញីប្រាប់ហេតុហើយ ក៏ពោលថា ហេតុអ្វីមិនប្រាប់ខ្ញុំ រហូតក្លាយជាបែបនេះ ខ្ញុំនឹងជួយធ្វើកិច្ចក្នុងរឿងនេះឯង ធ្វើឲ្យកណ្តុរធូរចិត្តហើយ ធ្វើរន្ធដោយកែវផលិកថ្លានាំមកប្រគល់ឲ្យ ប្រាប់ថា ចូរនាងចូលទៅដេកក្នុងប្រអប់កែវនេះ ហើយសម្លុតឆ្មាដែលនាំគ្នាមកដោយវាចាគ្រោតគ្រាត កណ្តុរញីចូលប្រអប់កែវដេក កាលឆ្មាមួយមករកកណ្តុរញី ពោលថា ចូរឲ្យសាច់ដល់យើង កណ្តុរក៏សម្លុតថា វ៉ីយ ឆ្មាអាក្រក់ អញជាខ្ញុំបម្រើរកសាច់ឲ្យអាឬ ចូរទៅស៊ីសាច់កូនរបស់អាចុះ ។ ឆ្មាមិនដឹងថា កណ្តុរដេកក្នុងប្រអប់កែវផលិក ដោយអំណាចសេចក្តីក្រោធ ទើបស្ទុះទៅដោយរហ័ស បំណងនឹងចាប់កណ្តុរឲ្យបាន ក៏ជ្រុលយកដើមទ្រូងបុកនឹងប្រអប់កែវផលិក បេះដូងក៏បែក ភ្នែកទាំងគូលៀនមក អស់ជីវិតត្រង់នោះឯង ហើយអូសទៅទុកក្នុងចំណែកម្ខាង ដោយឧបាយនេះ ឆ្មាទាំង ៤ ក៏នាំគ្នាអស់ជីវិតទាំងអស់ តាំងអំពីនោះមក កណ្តុរក៏ផុតភ័យ ឲ្យ ២-៣ កហាបណៈ ដល់ព្រះពោធិសត្វរាល់ៗ ថ្ងៃ តមក បានប្រគល់ទ្រព្យទាំងអស់ឲ្យដល់ព្រះពោធិសត្វតាមលំដាប់ដោយឧបាយយ៉ាងនេះ ជនទាំង ២ មិនបានទម្លាយមេត្រីភាពជរាបដល់អស់ជីវិត ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទើបត្រាស់ព្រះគាថានេះថា

ឆ្មាមួយបានកណ្ដុរ ក្នុងទីណា ឆ្មាជាគម្រប់ពីរ គម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះ ( ប្រហារ ) នូវរន្ធនេះហើយ ដល់នូវសេចក្ដីស្លាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យត្ថ** បានដល់ ក្នុងទីណា ។ បទថា **ពព្ពុ** បានដល់ ឆ្មា ។

បទថា **ទុតិយោ តត្ថ ជាយតិ** សេចក្ដីថា ឆ្មាមួយ បានកណ្ដុរ ឬសាច់ ក្នុងទីណា សូម្បីឆ្មាទី ២ ក៏កើតក្នុងទីនោះបាន ឆ្មាទី ៣ ទី ៤ ក៏កើតតាមៗ គ្នាមកដោយទំនងនោះឯង ដោយអាការយ៉ាងនេះ ទើបឆ្មាទាំងនោះ ក្នុងកាលនោះ ជាឆ្មា ៤ រួមគ្នាហើយ ក៏ស៊ីសាច់រាល់ថ្ងៃ ។ ឆ្មាទាំងនោះយកដើមទ្រូងបុកនឹងប្រអប់កែវផលិក ដល់នូវការអស់ជីវិតទាំងអស់ហើយ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ឆ្មាទាំង ៤ ក្នុងកាលនោះ បានមកជាភិក្ខុទាំង ៤ ក្នុងកាលឥឡូវនេះ កណ្ដុរក្នុងកាលនោះ បានមកជាកាណមាតា ឯជាងច្នាក់ថ្ម ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ពព្ពុជាតក ចប់**

# សុត្តន្តបិដក

## គោធជាតក

[ ១៣៨ ] *( ទេវទ្រង់ពោធិសត្វពោលថា ) ម្នាលតាបស ឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញ៉ាំដោយ ( រាគាទិក្កិលេស ) មានខាងក្នុងរបស់អ្នក អ្នកខំដុសខាត់តែខាងក្រៅទេ ។*

***គោធជាតកទី ៨ ចប់***

# អដ្ឋកថា

## គោធជាតក

[ ១៣៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហក មួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិំ តេ ជដាហិ ទុម្មេធ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន ដូចគ្នានឹងរឿងដែលពោលហើយខាងដើមនោះឯង ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតទន្សង កាលនោះ តាបស មួយរូប បានអភិញ្ញា ៥ មានតបៈខ្លាំងក្លា អាស្រ័យបច្ចន្តគាម ក្នុងតំបន់មួយ ត្រង់បណ្ណសាលាជាយព្រៃ ពួកអ្នកស្រុកនាំគ្នាទំនុកបម្រុងតាបសដោយ សេចក្តីគោរព ព្រះពោធិសត្វក៏បាននៅក្នុងជំបូកមួយកន្លែង ក្នុងទីចង្រ្កម របស់តាបស ។ កាលនៅនោះឯង បានទៅរកតាបសមួយថ្ងៃ ២-៣ ដង រាល់ៗ ថ្ងៃ ស្តាប់ពាក្យប្រកបដោយហេតុ ប្រកបដោយផលហើយ ថ្វាយ បង្គំតាបស ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន តាបសលាពួកអ្នកស្រុក ចៀស ចេញទៅ ។ កាលតាបសដែលសម្បូរដោយសីល និងវត្តចៀសចេញទៅ ហើយ មានតាបសកោងកាចទៃមកស្នាក់នៅត្រង់អាស្រមបទនោះ ។ ព្រះពោធិ-សត្វកំណត់ថា តាបសនេះក៏មានសីល ទើបទៅកាន់សម្នាក់របស់តាបស ដោយន័យមុននោះឯង ។ ថ្ងៃមួយ មេឃពុំជូកាល ញុំាងភ្លៀងឲ្យធ្លាក់ក្នុង រដូវប្រាំង មេភ្លៀងនាំគ្នាចេញអំពីជំបូកទាំងឡាយ ហ្វូងទន្សងក៏នាំគ្នាចេញស៊ី មេភ្លៀងទាំងនោះ ពួកអ្នកស្រុកក៏នាំគ្នាដើរចាប់ទន្សងដែលស៊ីមេភ្លៀងបានជា

ច្រើន ហើយស្ងួររ ចម្អិនដោយគ្រឿងផ្សំដ៏ឆ្ងាញ់ ប្រគេនតាបសៗ ឆាន់សាច់ទន្សងហើយ ជាប់ចិត្តក្នុងរស ក៏សួរថា សាច់នេះឆ្ងាញ់ណាស់ សាច់នេះជាសាច់របស់សត្វប្រភេទណា លុះបានឮគេប្រាប់ថា ជាសាច់ទន្សង ទើបត្រិះរិះថា ទន្សងធំមកកាន់សម្នាក់របស់អញៗ នឹងសម្លាប់វាស៊ីសាច់ ហើយឲ្យមនុស្សជញ្ជូនភាជនៈសម្រាប់ស្ល និងវត្ថុ មានសប្បិ និងអំបិលជាដើម ទុកម្ខាង លាក់ដំបងក្នុងសំពត់ដណ្តប់ រង់ចាំការមករបស់ព្រះពោធិសត្វ នៅត្រង់ទ្វារបណ្ណសាលា អង្គុយធ្វើដូចជាស្ងប់ស្ងៀម ។

ក្នុងវេលាល្ងាច ព្រះពោធិសត្វគិតថា អញនឹងទៅរកតាបស ហើយវារទៅ ខណៈដែលកំពុងចូលទៅជិតនោះឯង បានឃើញអាការចម្លែកនៃឥន្ទ្រិយរបស់តាបស ទើបគិតថា តាបសនេះ មិនអង្គុយដោយអាកប្បកិរិយាដែលធ្លាប់អង្គុយក្នុងថ្ងៃដទៃៗ សម្លឹងមើលអញក្នុងថ្ងៃនេះ ដោយអាការចម្លែកគួរសង្ស័យ អញត្រូវពិនិត្យពិច័យឲ្យល្អ ដូច្នេះ ព្រះពោធិសត្វចូលទៅឈរខាងក្រោមខ្យល់របស់តាបស បានក្លិនទន្សង ទើបគិតថា ថ្ងៃនេះ តាបសនេះពិតជាឆាន់សាច់ទន្សង ជាប់ចិត្តក្នុងរសហើយ ពេលនេះ ប្រាថ្នានឹងវាយអញដែលចូលទៅរកដោយដំបង ហើយយកសាច់ស្លស៊ីពិត ក៏មិនព្រមចូលទៅជិត បកក្រោយរត់ត្រឡប់ទៅ តាបសដឹងភាពដែលព្រះពោធិសត្វមិនព្រមមក ក៏គិតថា ទន្សងនេះ គង់ដឹងខ្លួនថា អញនឹងសម្លាប់វា ហេតុនោះ ទើបមិនចូលមក តែទោះបីវាមិនចូលមក ក៏មិនផុតអំពីដៃអញបានទេ ហើយយកដំបងចេញមកគ្រវែងទៅ ដំបងនោះ ចំចុងកន្ទុយព្រះពោធិសត្វប៉ុណ្ណោះ ព្រះពោធិសត្វចូល

ទៅក្នុងជំបូកដោយរហ័ស អើតក្បាលចេញមកតាមរន្ធដទៃ ពោលថា រុំយ ជដិលបោកប្រាស កាលខ្ញុំចូលទៅរក ក៏ចូលទៅរកដោយសម្គាល់ថា ជាអ្នក មានសីល តែឥឡូវនេះ ល្បិចរបស់អ្នកខ្ញុំដឹងហើយ មហាចោរដូចអ្នក បួស ធ្វើអ្វី កាលទឹងតិះដៀលតាបស ទើបពោលគាថានេះថា

ម្នាលតាបសឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក ប្រយោជន៍ អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញ៉ាំ ដោយ ( រាគា- ទិក្កិលេស ) មានខាងក្នុងរបស់អ្នក អ្នកខំដុសខាត់តែខាងក្រៅទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្តេ ជដាហិ ទុម្មេធ** សេចក្តីថា រុំយជដិល ឥតប្រាជ្ញា មិនមានញាណដឹងដោយជុំវិញ ការបួងផ្នួងសក់នេះ ដែលបុគ្គល វៀរចាកការបៀតបៀន គួរទ្រទ្រង់ អធិប្បាយថា អ្នកប្រាសចាកគុណ គឺការ វៀរចាកការបៀតបៀន ហើយមូរជដានោះធ្វើអ្វី ។

បទថា **កិន្តេ អជិនសាដិយា** សេចក្តីថា ចាប់តាំងអំពីពេលដែលអ្នក មិនមានសំវរគុណដែលសមគួរ អ្នកដណ្តប់ស្បែកខ្លាធ្វើអ្វី ។

បទថា **អព្ភន្តរន្តេ គហនំ** សេចក្តីថា ខាងក្នុង គឺហទយៈរបស់អ្នក សាំញ៉ាំពិតប្រាកដ ក្រាស់ដោយគ្រឿងសាំញ៉ាំ គឺរាគៈ ទោសៈ មោហៈ ។

បទថា **ពាហិរំ បរិមជ្ជសិ** សេចក្តីថា ខាងក្នុងរបស់អ្នកនៅសាំញ៉ាំ អ្នក ដុសខាត់តែខាងក្រៅ ដោយការងូតទឹកជាដើម និងដោយការកាន់យកភេទ កាលរវល់តែដុសខាត់ខាងក្រៅ អ្នកដូចជាសម្បកឃ្លោកដែលពេញដោយស្រកី

និងដូចពាងពេញដោយថ្នាំពិស និងដូចដំបូកពេញដោយពស់ និងដូចក្អមដ៏វិចិត្រពេញដោយលាមក ដែលរលោងតែខាងក្រៅប៉ុណ្ណោះ អ្នកជាចោរ តើនៅទីនេះធ្វើអ្វី ប្រញាប់ទៅដោយរហ័សចុះ បើអ្នកមិនព្រមគេចទៅទេ ខ្ញុំនឹងប្រាប់អ្នកស្រុកឲ្យធ្វើការបណ្ដេញអ្នក ។

ព្រះពោធិសត្វគំរាមតាបសយ៉ាងនេះហើយ ចូលកាន់ដំបូក តាបសអាក្រក់ក៏គេចចេញទៅអំពីទីនោះ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសកោងក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ តាបសអ្នកមានសីលក្នុងកាលនោះ បានមកជាសារីបុត្រ ឯគោធបណ្ឌិត គឺតថាគតនេះឯង ។

## អដ្ឋកថា គោធជាតក ចប់

# សុត្តន្តបិដក

## ឧភតោភដ្ឋជាតក

[ ១៣៩ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ភ្នែកទាំងឡាយបែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះ ក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ។

**ឧភតោភដ្ឋជាតកទី ៩ ចប់**

# អដ្ឋកថា

## ឧភតោភដ្ឋជាតក

[ ១៣៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អក្ខី ភិន្នា បដោ នដ្ឋោ** ដូច្នេះ ជាដើម ។

បានឮថា ក្នុងកាលនោះ ភិក្ខុទាំងឡាយ នាំគ្នាលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ អង្កត់ឧសដុតខ្មោច ភ្លើងឆេះទាំងសងខាង ត្រង់កណ្តាលប្រឡាក់លាមក មិនឲ្យប្រយោជន៍ ជាឈើក្នុងព្រៃ មិនឲ្យប្រយោជន៍ ជាឈើក្នុងស្រុក យ៉ាងណា ទេវទត្តក៏ដូច្នោះដូចគ្នា ហើយបួសក្នុងសាសនា ដែលប្រកបដោយធម៌ជាគ្រឿងនាំសត្វចេញចាកទុក្ខបែបនេះ គង់ក្លាត់ចាកប្រយោជន៍ទាំង ២ បាន គឺវិនាសចាកភោគៈនៃគ្រហស្ថ ទាំងមិនអាចធ្វើប្រយោជន៍នៃភាពជាសមណៈឲ្យបរិបូណ៌បាន ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តក្លាត់ចាកប្រយោជន៍ទាំង ២ សូម្បីក្នុងអតីតក៏ធ្លាប់ឃ្លាតចាកប្រយោជន៍ទាំង ២ មកហើយដូចគ្នា ហើយទ្រង់នាំយករឿងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតា ។ កាលនោះ ព្រាន

សន្ទូចប្រជុំគ្នា រស់នៅក្នុងតំបន់មួយ កាន់សន្ទូចទៅជាមួយកូនប្រុស ទៅដល់បឹងដែលពួកព្រានសន្ទូចនាំគ្នានេសាទដោយប្រក្រតី ហើយដាក់សន្ទូចៗជាប់ជន្លត់ក្នុងទឹក ព្រានមិនអាចទាញឡើងមកបាន ក៏គិតថា សន្ទូចគង់ជាប់ត្រីធំ អញត្រូវបញ្ជូនកូនប្រុសទៅរកម្ដាយវា ឲ្យបង្កជម្លោះនឹងអ្នកជិតខាង កាលបើដូច្នេះ បុគ្គលណាម្នាក់ ក៏មិនទទួលចំណែកដែលចែកអំពីត្រីនេះ រួចប្រាប់កូនប្រុសថា ចូរទៅចុះ ប្រាប់ដល់ម្ដាយរបស់ឯងដល់រឿងដែលអញបានត្រីធំ ឲ្យម៉ែឯងបង្កវិវាទនឹងអ្នកភូមិផងរបងជាមួយ ។ លុះគាត់បញ្ជូនកូនទៅហើយ កាលមិនអាចទាញមកបាន ខ្លាចដាច់ខ្សែ ទើបស្រាតសំពត់ដាក់លើគោក លោតចុះក្នុងទឹក ព្រោះចង់បានត្រី មិនបានពិចារណាថាជាត្រី ឬមិនមែនត្រី ទើបទង្គិចជាមួយជន្លត់បែកភ្នែកទាំង ២ សំពត់ដែលដាក់លើគោកសោត ចោរក៏លួចទៅ គាត់ឈឺចាប់ យកដៃខ្ទប់ភ្នែកទាំងសងខាង ឡើងអំពីទឹក ស្រវារកសំពត់ ។ ឯភរិយារបស់គាត់គិតថា អញនឹងបង្កជម្លោះ ធ្វើឲ្យបុគ្គលដទៃមិនត្រូវការចំណែក ដូច្នេះហើយ យកស្លឹកត្នោតប្រដាប់ត្រចៀកម្ខាងប៉ុណ្ណោះ ភ្នែកម្ខាងក៏លាបដោយធ្យូង ពកូនក្អែដាក់ត្រង់ចង្កេះ ដើរទៅកាន់ផ្ទះខាងចុងគេ កាលនោះ ស្រីជាសម្លាញ់ម្នាក់និយាយលេងយ៉ាងនេះថា ហងយកស្លឹកត្នោតមកប្រដាប់ត្រង់ត្រចៀកម្ខាងប៉ុណ្ណោះ ភ្នែកម្ខាងក៏លាបពណ៌ឲ្យខ្មៅ ពកូនក្អែដាក់ត្រង់ចង្កេះ ហាក់ដូចកូនជាទីស្រឡាញ់ ដើរទៅកាន់ផ្ទះអ្នកស្រុក ហងឆ្កួតទៅហើយឬ ។ ស្រីនោះពោលថា អញមិនបានឆ្កួត ហងមកជេរអញមិនមានហេតុផល ឥឡូវនេះ អញនឹងនាំហងទៅជួបមេស្រុក ឲ្យ

បង់ ៨ កហាបណៈ កាលឈ្លោះគ្នាយ៉ាងនេះហើយ ជនទាំង ២ ក៏នាំគ្នាទៅផ្ទះមេស្រុក កាលមេស្រុកជម្រះក្តីនៃស្រីទាំង ២ ក៏ពិន័យកិរិយានាយព្រានសន្ទូចបន្ថែមទៀត មនុស្សទាំងឡាយក៏ចងនាង តឹងទារថា ចូរឲ្យថ្លៃពិន័យហើយវាយ ។ រុក្ខទេវតាឃើញហេតុការណ៍នោះ របស់នាងក្នុងស្រុក និងការវិនាសរបស់ប្តីនោះក្នុងព្រៃ ក៏ឈរត្រង់ប្រគាបឈើ ពោលថា នែអ្នកថោកថយ ការងាររបស់អ្នកវិនាសអស់ហើយ ទាំងក្នុងទឹក ទាំងលើគោក អ្នកភ្លាត់ហើយចាកប្រយោជន៍ទាំង ២ ទើបពោលគាថានេះថា

ភ្នែកទាំងឡាយបែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សខីគេហេ ច ភណ្ឌនំ** សេចក្តីថា ស្រីជាសម្លាញ់ ឈ្មោះថា **សខី** ពង្រីកសេចក្តីថា ប្រពន្ធរបស់អ្នកធ្វើនូវការរករឿងក្នុងផ្ទះរបស់ស្រីជាសម្លាញ់នោះ ត្រូវចាប់ចងដាក់ទណ្ឌកម្ម ។

បទថា **ឧភតោ បទុដ្ឋា** សេចក្តីថា ការងារក្នុងឋានៈទាំង ២ របស់អ្នកវិនាស រមែងលំបាកយ៉ាងនេះឯង ។

សួរថា ក្នុងឋានៈទាំង ២ យ៉ាង ដូចម្តេចខ្លះ ។

ឆ្លើយថា ទាំងផ្លូវទឹក និងទាំងផ្លូវគោក បានដល់ ការងារក្នុងទឹកវិនាស ព្រោះភ្នែកបែក សំពត់ស្លៀកត្រូវចោរលួច ការងារលើគោកវិនាស ព្រោះប្រពន្ធធ្វើនូវការរករឿងជាមួយសម្លាញ់ជិតខាង ត្រូវចាប់ចងដាក់ទណ្ឌកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រានសន្ទូចក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ឯរុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ឧភតោភដ្ឋជាតក ចប់**

# សុត្តន្តបិដក

## កាកជាតក

[ ១៤០ ] ( ក្អែកពោធិសត្វពោលថា ) ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច ជាសត្វបៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ បានជាខ្លាញ់ភាវនៃពួកក្អែក ជាញាតិរបស់យើងទាំងនោះ មិនចេះមានឡើយ ។

កាកជាតកទី ១០ ចប់

អសម្បទានវគ្គទី ១៤ ចប់

### ឧទ្ទាននៃអសម្បទានវគ្គនោះ គឺ

និយាយអំពីវត្ថុតាមមានតាមបាន ១ យក្ខិនី ១ ទីក្រុម ១ អាកស្សរមហាព្រហ្មដូចក្នុងបរោសតបញ្ហា ១ អាកស្សរមហា-ព្រហ្ម ១ ទៀត ហង្សឧត្តមប្រសើរ ១ ធ្នូ ១ ជជា ១ ព្រានបាត់សំពត់ ១ ក្អែក ១ ត្រូវជា ១០ ។

# អដ្ឋកថា

## កាកជាតក

[ ១៤០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការប្រព្រឹត្តប្រយោជន៍ដល់ពួកញាតិ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **និច្ចំ ឧព្វិគ្គហទយា** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្នមានប្រាកដក្នុងភទ្ទសាលជាតក ក្នុងទ្វាទសកនិបាត ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតក្អែក ។ ថ្ងៃមួយ បុរោហិតរបស់ព្រះរាជា ងូតទឹកក្នុងស្ទឹងក្រៅព្រះនគរ ប្រោះព្រំរាងកាយ ប្រដាប់ដោយផ្កាស្លៀកសំពត់សមសក្តិ កំពុងចូលព្រះនគរ ត្រង់ចុងសសរបន្ទាយក្បែរទ្វារនគរ ក្អែក ២ កំពុងទំ ។ ក្នុងក្អែក ២ នោះ ក្អែកមួយពោលនឹងក្អែកមួយទៀតថា សម្លាញ់ អញនឹងជុះអាចម៍ដាក់ក្បាលព្រាហ្មណ៍នេះ ក្អែកមួយទៀតជំទាស់ថា ឯងកុំគិតសប្បាយយ៉ាងនោះឡើយ ព្រាហ្មណ៍នេះជាអ្នកធំ ឈ្មោះថា ការបង្កនូវពៀរជាមួយឥស្សរជន ធ្ងន់ណាស់ ព្រោះបើគាត់ក្រោធខឹងហើយ នឹងធ្វើក្អែកទាំងអស់ឲ្យវិនាសបាន ក្អែកនោះពោលថា ខ្ញុំមិនអាចប្តូរចិត្តបានទេ ក្អែកមួយទៀតពោលថា បើដូច្នោះ ឯងគង់តែបានដឹង ហើយហើរទៅ ។ ក្អែកនោះ កាលព្រាហ្មណ៍មកដល់ខាងក្រោមសសរបន្ទាយ ក៏ជុះដាក់ក្បាលព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះក្រោធខឹង ចងពៀរក្នុងហ្វូងក្អែក ។

ក្នុងកាលនោះ ស្រីស៊ីឈ្នួលបុកអង្ករម្នាក់ យកស្រូវហាលកម្តៅថ្ងៃត្រង់ទ្វារផ្ទះ អង្គុយយាមនោះឯង ក៏ដេកលក់ទៅ ពពែរោមវែងមួយ ដឹងថា ស្រី

នោះប្រមាទ ក៏មកស៊ីស្រូវ នាងភ្ញាក់ឡើងឃើញ ក៏ដេញទៅ ។ ពពែមក លួចស៊ីស្រូវ ក្នុងពេលដែលនាងដេកលក់យ៉ាងនោះឯង ២-៣ ដង នាងក៏ដេញទៅ លើកទី ៣ គិតថា បើវាស៊ីច្រើនដង នឹងស៊ីស្រូវអស់ពាក់កណ្ដាលចំនួនដែលអញត្រូវបុក ពេលនេះ អញនឹងមិនឲ្យវាមកបានទៀត ទើបពុតធ្វើជាដេកលក់ កាលពពែមកស៊ីស្រូវ ក៏ក្រោកឡើង គ្រវែងពពែដោយអង្កត់ឧសដែលមានភ្លើង រោមពពែក៏ជាប់ភ្លើង កាលរាងកាយត្រូវភ្លើងឆេះ ពពែគិតឲ្យភ្លើងរលត់ ទើបរត់ទៅដោយរហ័ស យកខ្លួនត្រដុសខ្ទមស្បូវមួយក្នុងក្បែររោងដំរី ខ្ទមនោះក៏ឆេះ អណ្ដាតភ្លើងដែលកើតអំពីខ្ទមនោះ រាលទៅឆេះរោងដំរី កាលរោងដំរីឆេះ ខ្នងដំរីក៏ត្រូវភ្លើងឆេះស្បែក ។ ដំរីជាច្រើនមានខ្លួនដំបៅ ពួកគ្រូពេទ្យមិនអាចព្យាបាលឲ្យជាបាន នាំគ្នាក្រាបទូលព្រះរាជា ទើបព្រះរាជាត្រាស់ជាមួយនឹងបុរោហិតថា លោកអាចារ្យ ពេទ្យអស់តម្រិះនឹងព្យាបាលដំរីទាំងឡាយ លោកចេះថ្នាំសង្កូវអ្វីខ្លះដែរឬទេ ។ បុរោហិតក្រាបទូលថា បពិត្រមហារាជ ទូលបង្គំចេះ ព្រះរាជាត្រាស់សួរថា បានអ្វីទើបគួរ បុរោហិតក្រាបទូលថា ថ្នាំនោះ គឺខ្លាញ់ក្អែក ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកឲ្យមនុស្សសម្លាប់ក្អែក យកខ្លាញ់មកចុះ ចាប់ពីនោះមក មនុស្សទាំងឡាយនាំគ្នាសម្លាប់ក្អែក តែមិនបានខ្លាញ់ ក៏បោះចោលជាពំនូកៗ ក្នុងទីនោះៗ ភ័យធំកើតឡើងដល់ហ្វូងក្អែកហើយ ។

គ្រានោះ ព្រះពោធិសត្វមានហ្វូងក្អែក ៨០០០០ ជាបរិវារ អាស្រ័យក្នុងព្រៃស្មសានធំ មានក្អែកមួយ មកប្រាប់ដល់ព្រះពោធិសត្វដល់ភ័យដែលកើត

ឡើងដល់ហ្វូងក្អែក ព្រះពោធិសត្វត្រិះរិះថា វៀរអាត្មាអញចេញហើយ បុគ្គលដទៃដែលអាចបំបាត់ភ័យ ដែលកើតឡើងដល់ពួកញាតិរបស់អញបាន មិនមាន អញត្រូវកម្ចាត់ភ័យនេះ ហើយរម្លឹកដល់បារមី ១០ ធ្វើមេត្តាបារមីឲ្យជាបុរេចារិក ហើរទៅម្នាក់ឯងប៉ុណ្ណោះ ចូលតាមបង្អួចដែលបើក ពួនខាងក្រោមព្រះរាជអាសនៈ ។ សម័យនោះ អមាត្យម្នាក់សម្តែងអាកប្បកិរិយានឹងចាប់ព្រះពោធិសត្វ ព្រះរាជាឃាត់ថា ក្អែកនេះចូលមករកទីពឹង កុំចាប់វាឡើយ ។ ព្រះមហាសត្វសម្រាកបន្តិចហើយ អធិដ្ឋានដល់មេត្តាបារមី ចេញអំពីក្រោមអាសនៈ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាព្រះរាជា មិនលុះអំណាចអគតិ មានឆន្ទាគតិជាដើម ហើយគ្រងរាជ្យ ទើបប្រពៃ កម្មណាមួយដែលត្រូវធ្វើ កម្មនោះៗ ត្រូវពិចារណាឲ្យសព្វគ្រប់ សឹមធ្វើ ទើបប្រពៃម្យ៉ាងទៀត កម្មណាដែលនឹងធ្វើ ត្រូវបានផល កម្មនោះប៉ុណ្ណោះ ទើបគួរធ្វើកម្មក្រៅពីនេះ មិនគួរធ្វើ បើព្រះរាជាទាំងឡាយ ទ្រង់ធ្វើកម្មដែលធ្វើទៅ មិនសម្រេចផលសោត មហាភ័យ មានមរណភ័យជាទីបំផុត រមែងកើតដល់មហាជន បុរោហិតធ្លាក់នៅក្នុងការចងពៀរ បានក្រាបទូលមុសា ឈ្មោះថាខ្លាញ់របស់សត្វក្អែកមិនមានឡើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ មានព្រះហឫទ័យជ្រះថ្លា ឲ្យព្រះពោធិសត្វទំលើតាំងដែលរំលេចដោយមាស ឲ្យមនុស្សលាបស្រឡាបស្លាបដោយប្រេង ដែលចម្រាញ់ហើយរាប់សែនដងឲ្យបរិភោគអាហារដ៏ស្អាត សមគួរជាព្រះក្រយាហារ ឲ្យផឹកនូវទឹក លុះព្រះពោធិសត្វសប្បាយ ប្រាសចាកការនឿយលំបាកហើយ ទើបត្រាស់ពាក្យនេះ

ថា នែបណ្ឌិត អ្នកពោលថា ឈ្មោះថា ខ្ញាញ់របស់ក្អែកទាំងឡាយ មិនមាន ខ្ញាញ់របស់ក្អែកមិនមានដោយហេតុអ្វី ព្រះពោធិសត្វកាលចង្អុលបង្ហាញថា បពិត្រព្រះអង្គ ដោយហេតុឈ្មោះនេះ ធ្វើព្រះរាជវាំងទាំងមូល ឲ្យជាសំឡេង តែមួយសម្តែងធម៌ ទើបពោលគាថានេះថា

ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច ជាសត្វ
បៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ បានជាខ្ញាញ់រាវ
នៃពួកក្អែក ជាញាតិរបស់យើងទាំងនោះ មិនចេះមានឡើយ
ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះថា បពិត្រមហារាជ ធម្មតា ហ្វូងក្អែក មានចិត្តតក់ស្លុត គឺភ័យខ្លាចជានិច្ចនោះឯង ។

បទថា **សព្វលោកវិហេសកា** សេចក្តីថា ក្អែកទាំងឡាយ ចូលចិត្តបៀតបៀន គំរាមកំហែងមនុស្សដែលជាធំ មានក្សត្រជាដើមខ្លះ បុរសស្ត្រីទូទៅខ្លះ ក្មេងប្រុស ក្មេងស្រីជាដើមខ្លះ ហេតុនោះ គឺដោយហេតុ ២ ប្រការនេះ ឈ្មោះថា ខ្ញាញ់របស់ក្អែកដែលជាញាតិរបស់ទូលបង្គំមិនមាន សូម្បីក្នុងអតីតក៏មិនធ្លាប់មាន ក្នុងអនាគត នឹងមិនមាន ។

ព្រះពោធិសត្វបើកផ្សារនូវហេតុនេះ ដោយប្រការដូច្នេះហើយ ទូលដាស់តឿនព្រះរាជាថា បពិត្រមហារាជ ធម្មតាព្រះរាជា មិនបានពិចារណាហើយ មិនគប្បីបដិបត្តិព្រះរាជកិច្ច ព្រះរាជាទ្រង់ពេញព្រះហឫទ័យ បូជាព្រះពោធិសត្វ ដោយរាជសម្បត្តិ ។ ព្រះពោធិសត្វថ្វាយរាជសម្បត្តិសងព្រះរាជាវិញ ឲ្យព្រះ

រាជាតាំងនៅក្នុងបញ្ចសីល ទូលសូមព្រះរាជទានអភ័យដល់សត្វទាំងពួង ព្រះរាជាទ្រង់ស្តាប់ព្រះធម្មទេសនាហើយ ព្រះរាជទានអភ័យដល់សព្វសត្វ ទ្រង់តាំងនិពទ្ធទាន គឺទានដែលឲ្យប្រចាំដល់ហ្វូងក្អែក ឲ្យចម្អិនបាយមួយថ្លៃមួយថាំង លាយដោយរបស់មានរសដ៏ប្រសើរផ្សេងៗ ឲ្យដល់ក្អែករាល់ៗ ថ្ងៃ ឯព្រះមហាសត្វបានទទួលព្រះរាជទានព្រះក្រយាហាររនោះឯង ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទពារាណសី ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ឯស្តេចក្អែក ក្នុងកាលនោះ គឺតថាគតនេះឯង ៕៙

**អដ្ឋកថា កាកជាតក ចប់**

**អសម្បទានវគ្គ ចប់**

# សុត្តន្តបិដក

# កកណ្ដកវគ្គ

## គោធជាតក

[ ១៤១ ] ( ស្ដេចទន្សោងពោធិសត្វពោលថា ) បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់នូវសេចក្ដីសុខពិតទេ ដូចជាត្រកូលទន្សោង មិនបានសេចក្ដីសុខ ព្រោះត្រកួត រមែងញុំាងខ្លួនឲ្យដល់នូវសេចក្ដីវិនាស ។

*គោធជាតកទី ១ ចប់*

# អដ្ឋកថា

# កកណ្ដកវគ្គ

## គោធជាតក

[ ១៤១ ] *ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់មិត្តខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ឆ ចាបជនសំសេវី** *ដូច្នេះជាដើម ។*

*រឿងក្នុងបច្ចុប្បន្ន ដូចគ្នានឹងរឿងដែលពោលហើយក្នុងមហិឡាមុខជាតកនោះឯង ។*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតទន្សង ចម្រើនវ័យហើយ មានទន្សងច្រើនរយជាបរិវារ រស់នៅក្នុងព្រៃឈើធំ ក្បែរច្រាំងស្ទឹង ។ កូនរបស់ព្រះពោធិសត្វ ឈ្មោះគោធបិល្លិកៈ ធ្វើនូវការស្និទ្ធស្នាល ចងមិត្រនឹងសត្វបង្កួយមួយក្បាល ទន្សងប្រឡែងជាមួយបង្កួយ ឡើងសង្កត់លើបង្កួយ ដោយគិតថា អញនឹងឱបបង្កួយ ហ្វូងទន្សងប្រាប់ការស្និទ្ធស្នាលរវាងគោធបិល្លិកៈនិងបង្កួយនោះឲ្យស្ដេចទន្សងជ្រាប ទើបស្ដេចទន្សងហៅកូនមកថា នែកូនអ្នកធ្វើសេចក្ដីស្និទ្ធស្នាលជាមួយបង្កួយ មិនគួរឡើយ ធម្មតាបង្កួយទាំងឡាយមានកំណើតថោកទាប មិនគួរធ្វើសេចក្ដីស្និទ្ធស្នាលជាមួយទេ បើបាធ្វើសេចក្ដីស្និទ្ធស្នាល ត្រកូលទន្សងទាំងអស់នឹងត្រូវវិនាស ព្រោះអាស្រ័យបង្កួយពិត*

ប្រាកដ បន្ទាប់អំពីនេះទៅ បាកុំធ្វើសេចក្តីស្និទ្ធស្នាលជាមួយបក្ខីនោះឡើយ ។ គោធបិល្លិកៈក៏នៅតែធ្វើយ៉ាងនោះ សូម្បីព្រះពោធិសត្វពោលរឿយៗ ក៏មិនអាចឃាត់សេចក្តីស្និទ្ធស្នាលរវាងទន្សង និងបក្ខីនោះបាន ទើបត្រិះរិះថា អាស្រ័យបក្ខីនោះ ភ័យនឹងត្រូវកើតឡើងដល់ពួកយើងពិត គួរត្រៀមរៀបចំផ្លូវដើម្បីគេចឲ្យហើយ ក្នុងកាលភ័យនោះកើតឡើង ហើយធ្វើរូងព័ទ្ធក្នុងចំណែកម្ខាង ។ ឯកូនរបស់ស្តេចទន្សងនោះ មានរាងកាយធំដោយលំដាប់ចំណែកបក្ខីយ មានរាងកាយនៅដដែល គោធបិល្លិកៈគិតថា អញនឹងឱបបក្ខីយក្នុងពេលណា ក៏ឱបរឿយៗ ក្នុងពេលនោះ ពេលដែលគោបិល្លិកៈសង្កត់បក្ខីយ ដូចគ្នានឹងកំពូលភ្នំសង្កត់ ដូច្នោះ បក្ខីយបានទទួលសេចក្តីលំបាកគិតថា បើទន្សងនេះឱបអញយ៉ាងនេះពីរបីថ្ងៃជាប់គ្នា អញនឹងស្លាប់ពិត អញនឹងសហការជាមួយព្រានម្នាក់ គាស់រម្លើងត្រកូលទន្សាងនេះចេញឲ្យបាន ។

ថ្ងៃមួយ ក្នុងរដូវប្រាំង កាលភ្លៀងធ្លាក់ហើយ មេភ្លៀងនាំគ្នាហើរចេញអំពីដំបូក ហ្វូងទន្សងនាំគ្នាចេញអំពីទីនោះៗ ស៊ីមេភ្លៀង ។ ព្រានទន្សងម្នាក់កាន់ចបទៅព្រៃជាមួយឆ្កែទាំងឡាយ ដើម្បីជីករូងទន្សង ។ បក្ខីយឃើញហើយគិតថា ថ្ងៃនេះ សេចក្តីប្រាថ្នារបស់អញសម្រេចពិត ដូច្នេះហើយ ចូលទៅរកក្រាបក្នុងទីមិនឆ្ងាយ សួរថា លោកដ៏ចម្រើន លោកទៅព្រៃធ្វើអ្វី ព្រានឆ្លើយថា ទៅរកទន្សង បក្ខីយពោលថា ខ្ញុំស្គាល់ទីអាស្រ័យរបស់ទន្សងច្រើនរយ សូមលោកយកភ្លើង និងចំបើងមកចុះ ហើយនាំចូលទៅក្នុងទីនោះ ប្រាប់ថា សូមលោកដាក់ភ្លើងត្រង់នេះ ហើយដុតធ្វើឲ្យកើតជាផ្សែង ហើយឲ្យឆ្កែព័ទ្ធ

ជុំវិញ ហើយលោកកាន់ដំបងធំចេញទៅវង់ចាំវាយទន្សោងឲ្យស្លាប់ ហើយគរទុក ។ លុះប្រាប់យ៉ាងនេះហើយ ក៏គិតថា ថ្ងៃនេះ អញនឹងបានឃើញខ្នងសត្រូវ ហើយដេកផ្ទើក្បាលផ្ងក់ៗ ក្នុងទីមួយកន្លែង ព្រានក៏រៀបចំបំពក់ភ្លើងផ្សែងចូលទៅក្នុងរន្ធ ហ្វូងទន្សោងនាំគ្នាឈ្លក់ផ្សែង ត្រូវមរណភ័យគំរាម ក៏ប្រញាប់នាំគ្នាគេចចេញ ព្រានក៏ចាំវាយទន្សោងដែលចេញមកឲ្យស្លាប់ ទន្សោងដែលរួចពីដៃព្រាន ក៏ត្រូវហ្វូងខ្លែខាំ សេចក្តីវិនាសធំក៏កើតដល់ហ្វូងទន្សោង ព្រះពោធិសត្វដឹងថា ព្រោះអាស្រ័យបង្កួយ ទើបភ័យកើតឡើង ពោលថា ឈ្មោះថា ការប្រឡូកប្រឡំជាមួយបុគ្គលអាក្រក់ មិនគប្បីធ្វើ ឈ្មោះថាប្រយោជន៍ រមែងមិនមាន ព្រោះអាស្រ័យបុគ្គលអាក្រក់ ដោយអំណាចបង្កួយអាក្រក់តែមួយ ទើបសេចក្តីវិនាសកើតឡើងដល់ហ្វូងទន្សោង មានប្រមាណប៉ុណ្ណេះ កាលនឹងគេចទៅតាមរូងដែលបានត្រៀម ទើបពោលគាថានេះថា

*បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់នូវសេចក្តីសុខពិតទេ*
*ដូចជាត្រកូលទន្សោង មិនបានសេចក្តីសុខ ព្រោះត្រកួត[១] រមែង*
*ញុំាងខ្លួនឲ្យដល់នូវសេចក្តីវិនាស ដូច្នេះ ។*

---

១- កកណ្តកសត្វ គួរប្រែថា សត្វបង្កួយ ព្រោះក្នុងកកណ្តកបញ្ហា ក្នុងមហោសថជាតក ក៏លោកប្រែថា សត្វបង្កួយដូចគ្នា ។

ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះថា បុគ្គលសេពគប់ជាមួយបុគ្គលអាក្រក់ រមែងមិនសម្រេច គឺមិនជួប មិនបានទទួលសេចក្តីសុខដែលស្ថិតស្ថេរ គឺសេចក្តីសុខ ដែលឈ្មោះថា សុខជានិរន្តរ សេចក្តីនេះដូចម្តេច ដូចត្រកូលទន្សោងមិនបានសេចក្តីសុខព្រោះបច្ច័យ ។ ត្រកូលទន្សោង មិនបានទទួលសេចក្តីសុខព្រោះបច្ច័យ យ៉ាងណា បុគ្គលដែលសេពគប់ជាមួយបុគ្គលអាក្រក់ រមែងមិនបានសេចក្តីសុខក៏ដូច្នោះ មានតែនាំខ្លួនឲ្យដល់នូវការវិករជាមួយបុគ្គលអាក្រក់ រមែងនាំខ្លួន និងអ្នកដទៃៗ ដែលនៅជាមួយខ្លួនឲ្យដល់នូវសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ។ តែក្នុងព្រះបាលី លោកបានរចនាថា **កលិចាបិយ** គប្បីនាំខ្លួនឲ្យដល់នូវការវិករ ។ ព្យញ្ជនៈយ៉ាងនោះ មិនមានក្នុងអដ្ឋកថា ទាំងអត្ថនៃព្យញ្ជនៈនោះ ក៏មិនត្រឹមត្រូវ ហេតុនោះ គប្បីកាន់យកពាក្យតាមដែលពោលហើយនោះឯង ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បច្ច័យក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ កូនរបស់ព្រះពោធិសត្វឈ្មោះគោធបិល្លិកៈ ដែលមិនជឿឪវាទ ក្នុងកាលនោះ បានមកជាភិក្ខុដែលសេពគប់ខុស ឯស្តេចទន្សោង ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា គោធជាតក ចប់**

# សុត្តន្តបិដក

## សិង្គាលជាតក

[ ១៤២ ] ( ស្តេចចចកពោធិសត្វពោលថា ) អ្នកដេកធ្វើពុតជាស្លាប់ ដោយហេតុណា ហេតុរបស់អ្នកនុ៎ះ ដឹងបានដោយក្រ តែដំបងមិនរបូតអំពីដៃរបស់អ្នក កំពុងចាប់កាន់នោះ ។

*សិង្គាលជាតកទី ២ ចប់*

# អដ្ឋកថា

## សិង្គាលជាតក

[ ១៤២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការខ្នះខ្នែង ដើម្បីផ្តាច់ព្រះជន្មរបស់ព្រះអង្គនៃទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯតំ ហិ តេ ទុរាជានំ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយ ក្នុងធម្មសភាហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវប៉ុណ្ណោះនេះទេ ដែលទេវទត្តព្យាយាមដើម្បីសម្លាប់តថាគត សូម្បីក្នុងកាលមុន ក៏ធ្លាប់ប្រឹងប្រែងមកហើយដូចគ្នា តែមិនអាចសម្លាប់តថាគតបាន លំបាកតែខ្លួនប៉ុណ្ណោះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាចចក បានជាស្តេចសិង្គាល ចោមរោមដោយចចក នៅក្នុងព្រៃខ្មោច ។ សម័យនោះ នគររាជគ្រឹះមានមហោស្រព ហ្វូងបុគ្គលពាលនាំគ្នាផឹកស្រាដោយច្រើន បានឮថា មហោស្រពនោះ គឺមហោស្រព ដែលរៀបចំឡើងដើម្បីផឹកស្រានោះឯង កាលនោះ ពួកអ្នកលេងសុរាជាច្រើននាំគ្នារកសុរា និងសាច់មកសន្ទឹកសន្ធាប់ ហើយប្រដាប់តាក់តែងរាងកាយ នាំគ្នាច្រៀង ហើយផឹកស្រាបណ្តើរ ក្លែមបណ្តើរ អស់បឋមយាម សាច់ក្លែមក៏អស់ តែស្រាសល់ច្រើន ។ គ្រានោះ អ្នកលេងសុរាម្នាក់ពោលថា បញ្ជូនដុំសាច់ឲ្យមួយដុំចុះ កាលបានទទួលពាក្យឆ្លើយថា ដុំសាច់អស់ហើយ ក៏ពោលថា កាលអញនៅមិនត្រូវមានពាក្យថា សាច់អស់ ហើយពោលថា អញនឹង

សម្ងាប់ចចកដែលវាមកស៊ីមនុស្សស្លាប់ក្នុងព្រៃខ្មោច យកសាច់វាមក ទាញដំបងចេញពីនគរតាមលូបង្ហូរទឹក ទៅកាន់ព្រៃខ្មោច ដេកផ្ងារ កាន់ដំបងធ្វើជាមនុស្សស្លាប់ ។ ខណៈនោះ ព្រះពោធិសត្វចោមរោមដោយចចកទៅក្នុងទីនោះ ឃើញហើយ ទោះបីដឹងថា នេះមិនមែនមនុស្សស្លាប់ គិតថា ត្រូវពិចារណាមើលឲ្យល្អិតល្អន់ ទើបទៅឈរក្រោមខ្យល់ ហិតក្លិន ក៏ដឹងភាពដែលបុរសនោះមិនទាន់ស្លាប់ដោយពិតប្រាកដ គិតថា ត្រូវឲ្យបុរសនោះខ្មាសហើយសើមឲ្យគេទៅ ទើបដើរទៅខាំចុងដំបងទាញមក អ្នកលេងមិនព្រមលែងដំបង ទោះមិនសម្លឹងមើលស្តេចចចកដែលចូលមកជិត ក៏រឹតតែក្តាប់ដំបងនោះយ៉ាងណែន ព្រះពោធិសត្វត្រឡប់ទៅហើយ ពោលថា នែលោកដ៏ចម្រើន បើលោកជាមនុស្សស្លាប់ហើយពិត កាលខ្ញុំទាញដំបងមក ក៏មិនគួរទាញទុកយ៉ាងមាំ ដោយហេតុនេះ ទោះលោកស្លាប់ ឬមិនស្លាប់ ទើបដឹងច្បាស់បានដោយលំបាក ដូច្នេះហើយ ពោលគាថានេះថា

អ្នកដេកធ្វើពុតជាស្លាប់ ដោយហេតុណា ហេតុរបស់អ្នកនុ៎ះ ដឹងបានដោយក្រ តែដំបងមិនរបូតអំពីដៃរបស់អ្នក កំពុងចាប់កាន់នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតំ ហិ តេ ទុរាជានំ** សេចក្តីថា ហេតុនេះរបស់លោកដឹងបានលំបាកពិត ។

បទថា **យំ សេសិ មតសាយិតំ** សេចក្តីថា ហេតុដែលលោកដេកដូចជាមនុស្សស្លាប់នោះ ដឹងបានលំបាកពិត ។

បទថា **យស្ស តេ កឌ្ឍមានស្ស** សេចក្ដីថា បុគ្គលណា កាលខ្ញុំទាញដំបងអូសមក ដំបងមិនរបូតពីដៃ បុគ្គលនោះ ហៅថា អ្នកស្លាប់ហើយមិនបានពិតប្រាកដ ដូច្នេះ ។

កាលព្រះពោធិសត្វពោលយ៉ាងនេះហើយ អ្នកលេងនោះគិតថា ឆ្កែចចកនេះ ដឹងភាពដែលអញមិនស្លាប់ ក៏ក្រោកឡើងពួយដំបងទៅ ដំបងខុសគោលដៅ អ្នកលេងពោលថា អាទៅចុះ ពេលនេះ អញភ្លាំងភ្លាត់ ព្រះពោធិសត្វបែរមកពោលថា នែបុរសដ៏ចម្រើន ទោះបីអ្នកភ្លាំងភ្លាត់ខ្ញុំ ក៏គង់មិនភ្លាំងភ្លាត់អំពីមហានរក ៨ រណ្ដៅ និងឧស្សទនរក ១៦ រណ្ដៅ ដោយពិត ហើយគេចទៅ អ្នកលេងមិនបានសាច់ ចេញអំពីព្រៃខ្មោច ងូតទឹកក្នុងប្រឡាយចូលកាន់នគរតាមផ្លូវដែលមកនោះឯង ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អ្នកលេងក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ឯស្ដេចសិង្គាលក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សិង្គាលជាតក ចប់**

# សុត្តន្តបិដក

## វិរោចនជាតក

[ ១៤៣ ] *( កេសរសីហពោធិសត្វពោលថា ) ខួរក្បាលរបស់អ្នកធ្លាយចេញផង រលាក្បាលរបស់អ្នកបែកធ្លាយផង ឆ្អឹងជំនីរទាំងអស់របស់អ្នក ដំរីបំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត ។*

***វិរោចនជាតកទី ៣ ចប់***

# អដ្ឋកថា

## វិរោចនជាតក

[ ១៤៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ដែលសម្តែងឫកពាដូចព្រះសុគតក្នុងគយាសីសប្បទេស ត្រាស់ព្រះធម្ម-ទេសនានេះ មានពាក្យផ្តើមថា **លសី ច តេ និប្ផលិតា** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ទេវទត្តមានឈានវិនាសហើយ ក៏វិនាសចាកលាភសក្ការៈទៅដែរ គិតថា មានឧបាយមួយ ដូច្នេះហើយ ក្រាបទូលសូមវត្ថុ ៥ ប្រការនឹងព្រះសាស្តា កាលមិនបាន ក៏បបួលភិក្ខុ ៥០០ រូប ដែលជាសទ្ធិ-វិហារិករបស់អគ្គសាវ័កទាំង ២ ដែលបួសបានមិនយូរ ជាអ្នកមិនឈ្លាសក្នុងធម្មវិន័យ ទៅកាន់គយាសីសប្បទេស បែកពួកធ្វើសង្ឃកម្មមួយផ្នែកក្នុងសីមាតែមួយ ព្រះសាស្តាទ្រង់ជ្រាបកាលដែលប្រាជ្ញារបស់ភិក្ខុទាំងនោះចាស់ក្លា ទ្រង់បញ្ជូនអគ្គសាវ័កទាំង ២ ទៅ ទេវទត្តឃើញអគ្គសាវ័កទាំង ២ ហើយ ក៏ត្រេកអរ គិតថា កាលអញសម្តែងធម៌អស់មួយយប់ ធ្វើអាកប្បកិរិយាដូចព្រះពុទ្ធ ដូច្នេះហើយ កាលនឹងសម្តែងបែបផែនដូចព្រះសុគត ទើបពោលថា អាវុសោសារីបុត្រ ភិក្ខុសង្ឃមិនងោកងុយ ធម្មកថា ចូរអាស្រ័យលោក ជាក់ច្បាស់ដល់ភិក្ខុទាំងឡាយចុះ ខ្ញុំចុកពោយខ្នងណាស់ នឹងសណ្តូកខ្នងបន្តិចហើយចូលសិង អគ្គសាវ័កទាំង ២ សម្តែងធម៌ដល់ភិក្ខុទាំងនោះ ឲ្យត្រាក់រឭកទូទៅដោយមគ្គផលទាំងឡាយ ហើយនាំគ្នាមកកាន់វត្តវេឡុវ័នទាំងអស់នោះឯង កោកាលិកភិក្ខុឃើញវិហារស្ងាត់ ទើបចូលទៅកាន់សម្នាក់ទេវទត្តពោលថា លោកម្ចាស់ទេវទត្ត អគ្គសាវ័កទាំង ២ របស់លោក ទម្លាយបរិស័ទ

របស់លោកហើយ ទៅទាំងអស់ រហូតស្វាត់វិហារ លោកនៅដេកលក់ទៀត ហើយកន្ត្រាក់សំពត់ដណ្តប់ទេវទត្តចេញ យកកែងជើងវែកកណ្តាលដើមទ្រូង ដូចដំដែកគោលត្រង់ជញ្ជាំងផ្ទះ រំពេចនោះឯង ឈាមធ្លាក់ចេញអំពីមាត់របស់ទេវទត្ត ។ បន្ទាប់អំពីនោះ ទេវទត្តក៏ធ្លាក់ខ្លួនឈឺ ។ ព្រះសាស្តាត្រាស់សួរព្រះថេរៈថា ម្នាលសារីបុត្រ ពេលដែលអ្នកនាំគ្នាទៅ ទេវទត្តធ្វើដូចម្តេច ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តឃើញខ្ញុំព្រះអង្គទាំង ២ ហើយ ធ្វើលីលាដូចទ្រង់ សម្តែងអាកប្បកិរិយាតាមបែបព្រះសុគត ដល់នូវការវិនាសធំ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្រ មិនមែនតែក្នុងកាលឥឡូវនេះទេ ដែលទេវទត្តយកតម្រាប់តាមតថាគតដល់នូវសេចក្តីវិនាស សូម្បីក្នុងកាលមុន ក៏ដល់នូវសេចក្តីវិនាសមកហើយដូចគ្នា ។ ព្រះថេរៈទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាកេសរសីហរាជ អាស្រ័យនៅក្នុងគុហាមាសក្នុងហិមវន្តប្បទេស ។ ថ្ងៃមួយ ចេញអំពីគុហា រលាស់កាយ សម្លឹងមើលទិសទាំង ៤ បន្លឺសីហនាទ ហើយចេញរកអាហារ ចាប់ក្របីធំស៊ីសាច់ហើយ ចុះកាន់ស្រះផឹកទឹក ដែលមានពណ៌ដូចកែវមណី ឆ្អែតហើយ ចូលទៅកាន់គុហា គ្រានោះ ចចកមួយ ដើរស្វះស្វែងរកចំណី ជួបនឹងរាជសីហ៍ មិនអាចគេចទាន់ ក៏ក្រាបចុះទៀបជើងខាងមុខរាជសីហ៍ កាលរាជសីហ៍សួរថា នែចចក អ្នកមានការអ្វីឬ ចចកប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបំណង

នឹងបម្រើលោក រាជសីហ៍ពោលថា សាធុ មកចុះ ចូរបម្រើយើងចុះ យើងនឹងឲ្យឯងស៊ីសាច់ល្អៗ ហើយនាំចចកទៅកាន់គុហាមាស ។ តាំងអំពីនោះមក ចចកក៏ស៊ីដែលអំពីរាជសីហ៍ ។ កន្លងមកបាន ២-៣ ថ្ងៃ ចចកនោះក៏មានរាងកាយធាត់ ។ ថ្ងៃមួយ រាជសីហ៍ដេកក្នុងគុហា ប្រាប់ចចកថា នែចចក ចូរអ្នកឡើងទៅឈរលើកំពូលភ្នំ ចង់ស៊ីសត្វណា ក្នុងបណ្ដាដំរី សេះ ក្របីជាដើម ដែលត្រាច់ត្រង់ជើងភ្នំ ចូរសម្លឹងរកសត្វនោះ ហើយមកប្រាប់យើងថា ខ្ញុំចង់ស៊ីសត្វឈ្មោះនោះ ហើយចូរប្រាប់ថា សូមលោកម្ចាស់បន្លឺសំឡេងចុះ ដូច្នេះហើយ យើងនឹងចាប់សត្វនោះ ស៊ីសាច់ល្អៗ ហើយចែកឲ្យឯងដែរ ទើបចចកឡើងកាន់កំពូលភ្នំ សម្លឹងមើលហ្វូងម្រឹគច្រើនប្រភេទ កាលនឹកចង់ស៊ីសាច់របស់សត្វណា ក៏ចូលទៅកាន់គុហាមាស ប្រាប់សត្វនោះដល់រាជសីហ៍ ហើយក្រាបទៀបបាតជើង ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បញ្ចេញសំឡេងចុះ រាជសីហ៍រត់ទៅដោយរហ័ស សូម្បីដំរីចុះប្រេង ក៏សម្លាប់ឲ្យស្លាប់ត្រង់ទីនោះ ខ្លួនឯងស៊ីសាច់ល្អៗ ហើយឲ្យចចកផងដែរ ចចកស៊ីសាច់រហូតពេញពោះហើយ ចូលគុហាដេកលក់ ។

ពេលវេលាចេះតែកន្លងទៅ ឆ្កែចចកមានមានះឡើងថា សូម្បីអញក៏ជាសត្វជើង ៤ ដូចគ្នា ហេតុអ្វី ចាំបាច់ឲ្យអ្នកដទៃជួយចិញ្ចឹមរាល់ៗ ថ្ងៃ ចាប់ពីថ្ងៃនេះទៅ អញនឹងសម្លាប់ដំរីជាដើមស៊ីសាច់ សូម្បីរាជសីហ៍ដែលជាមិគ-រាជ អាស្រ័យពាក្យដែលអញពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បន្លឺសីហនាទចុះ ដូច្នេះប៉ុណ្ណោះ ក៏សម្លាប់ដំរីទាំងឡាយបាន អញត្រូវឲ្យរាជ-

សីហ៍ពោលនឹងអញថា ចចកអើយ អញ្ជើញអ្នកបញ្ចេញសំឡេងចុះ ដូច្នេះ ក៏នឹងសម្លាប់ដំរីមួយស៊ីសាច់បាន ។ ចចកចូលទៅរករាជសីហ៍ហើយ ពោលដូច្នេះថា បពិត្រលោកម្ចាស់ ខ្ញុំស៊ីសាច់ដំរីដែលលោកសម្លាប់មកយូរហើយ ខ្ញុំចង់សម្លាប់ដំរីមួយ ស៊ីសាច់វាម្តង ហេតុនោះ ខ្ញុំត្រូវដេកក្នុងគុហាមាស លើដំណេករបស់លោក សូមលោកជួយមើលដំរីដែលដើរមកត្រង់ជើងភ្នំ ហើយមកកាន់សម្នាក់ខ្ញុំ ប្រាប់ថា ចចកអើយ អញ្ជើញអ្នកបន្លឺសំឡេងចុះ ពាក្យមានប្រមាណប៉ុណ្ណេះ សូមលោកកុំហួងហែងឡើយ ។ កាលនោះ រាជសីហ៍ប្រាប់ថា នែចចក អ្នកមិនអាចសម្លាប់ដំរីបានទេ ឈ្មោះថា ចចក ដែលកើតក្នុងត្រកូលសីហៈ អាចសម្លាប់ដំរីស៊ីសាច់បាន មិនមានឡើយក្នុងលោក អ្នកកុំពេញចិត្តយ៉ាងនេះឡើយ នៅចាំស៊ីសាច់ដំរី ដែលយើងសម្លាប់ហើយ ទៅបន្ទោបង់ចុះ សូម្បីរាជសីហ៍ពោលចង្អុលហេតុយ៉ាងនេះ ចចកក៏មិនដាក់ចុះនូវការតាំងចិត្ត នៅតែរំអុកនោះឯង ។ រាជសីហ៍កាលមិនអាចឃាត់បាន ក៏ទទួលពាក្យ ពោលថា បើដូច្នោះ ចូរអ្នកនៅក្នុងលំនៅរបស់យើង ដេករង់ចាំចុះ ឲ្យចចកដេកក្នុងគុហាមាស ខ្លួនឯងចាំមើលដំរីចុះប្រេង ត្រង់ជើងភ្នំ ហើយទៅកាន់គុហាមាសប្រាប់ថា ចចកអើយ អញ្ជើញអ្នកបន្លឺសំឡេងចុះ ចចកចេញអំពីគុហាមាស រលាស់កាយ សម្លឹងមើលទិសទាំង ៤ លូ ៣ ដង គិតថា អញត្រូវលោតចុះត្រង់ក្បាលដំរី ក៏ភ្លាត់ជើងធ្លាក់ទៅត្រង់ជើងដំរីៗលើកជើងស្តាំឡើងជាន់ក្បាល លលាដ៍ក្បាលបែកជាចម្រៀកតូចធំ ពេលនោះ ដំរីក៏យកជើងប្រមូលសរីរៈរបស់ចចក គរជាគំនរ ជុះអាចម៍ដាក់ពីលើ

ហើយ កន្លួចចូលព្រៃទៅ ។ ព្រះពោធិសត្វឃើញការប្រព្រឹត្តទៅនេះ ពោលថា ចចកអើយ ពេលនេះ អញ្ជើញអ្នកបន្ទឺសំឡេងចុះ ដូច្នេះហើយ ទើបពោលគាថានេះថា

ខួរក្បាលរបស់អ្នក ធ្លាយចេញផង រលាក្បាលរបស់អ្នក បែកធ្លាយផង ឆ្អឹងជំនីរទាំងអស់របស់អ្នក ដីរបំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លសី** បានដល់ ខួរក្បាល ។

បទថា **និប្ផលិតា** បានដល់ ហូរចេញហើយ ព្រះពោធិសត្វពោលគាថានេះហើយ តាំងនៅដរាបដល់អស់អាយុ ហើយទៅតាមយថាកម្ម ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ឯរាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

**អដ្ឋកថា វិរោចនជាតក ចប់**

# សុត្តន្តបិដក

## ឆគ្គុជជាតក

[ ១៤៤ ] *( តាបសពោធិសត្វពោលថា )* *ម្នាលភ្លើង ជាអសប្បុរស យើងនឹងបូជាអ្នកដោយកន្ទុយណា កន្ទុយប៉ុណ្ណោះច្រើនហើយ ក្នុងថ្ងៃនេះ សាច់មិនមានដល់អ្នកដ៏គួរដល់សាច់ទេ អ្នកដ៏ចម្រើន ចូរទទួលយកតែកន្ទុយចុះ ។*

**នង្គុដ្ឋជាតកទី ៤ ចប់**

# អដ្ឋកថា

## ឆន្ទុដ្ឋជាតក

[ ១៤៤ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធតបៈដែលខុសរបស់ពួកអាជីវក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ពហុម្បេតំ អសព្ភិ ជាតវេទ** ដូច្នេះជាដើម ។

បានឮថា ក្នុងគ្រានោះ ពួកអាជីវកនាំគ្នាប្រព្រឹត្តតបៈខុស មានប្រការផ្សេងៗ ខាងក្រោយវត្តជេតពន ភិក្ខុទាំងឡាយជាច្រើនឃើញតបៈដែលខុស ដូចជា **ឧក្កុដិកប្បធាន** គឺការសមាទានអង្គុយប្រហោង **វគ្គុលិវត្ត** គឺធ្វើដូចសត្វប្រចៀវ **កណ្ដកាបស្សយ** គឺដេកលើបន្លា **បញ្ចតបន** គឺអាំងរំដោយភ្លើង ៥ គំនរបស់ជនទាំងនោះ នាំគ្នាទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កុសល ឬសេចក្ដីចម្រើន អាស្រ័យតបៈដែលខុសទាំងនេះ នឹងមានបានឬ កុសល ឬសេចក្ដីចម្រើនអាស្រ័យតបៈដែលខុសទាំងនេះនឹងមានបានឬ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុសល ឬសេចក្ដីចម្រើន អាស្រ័យតបៈដែលខុសយ៉ាងនេះ មានមិនបានឡើយ ក្នុងកាលមុនបណ្ឌិតសម្គាល់ខុសថា អាស្រ័យតបៈយ៉ាងនេះ កុសល ឬសេចក្ដីចម្រើនគង់មាន កាន់យកភ្លើងដែលឪពុកម្ដាយដុតឲ្យតាំងអំពីកំណើតចូលព្រៃ មិនជួបសេចក្ដីចម្រើនណាមួយឡើយ ដោយអំណាចការបូជាភ្លើងជាដើម ទើបយកទឹកលត់ភ្លើងចោល បំពេញកសិណបរិកម្ម ឲ្យអភិញ្ញាសមាបត្តិកើតហើយ បានទៅកាន់ព្រហ្មលោកហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងថ្ងៃដែលលោកកើត មាតាបិតាក៏អុជភ្លើងប្រចាំកំណើតតម្កល់ទុកឲ្យ លុះមានអាយុ ១៦ ឆ្នាំ មាតាបិតាប្រាប់ថា នែកូន ក្នុងថ្ងៃដែលឯងកើត អញដុតភ្លើងទុកឲ្យ បើឯងប្រាថ្នានឹងគ្រប់គ្រងផ្ទះ ចូររៀនវេទទាំង ៣ ឬបើបំណងទៅព្រហ្មលោក ក៏ចូរកាន់ភ្លើងចូលព្រៃ បម្រើភ្លើង ធ្វើឲ្យមហាព្រហ្មត្រេកអរហើយ អ្នកនឹងមានព្រហ្មលោកជាបុរេចារិកបាន ព្រះពោធិសត្វពោលថា ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះ កាន់ភ្លើងចូលព្រៃសាងអាស្រមបទ បម្រើភ្លើងក្នុងព្រៃ ។ ថ្ងៃមួយ បានទទួលរបស់ដែលគេប្រគេន គឺគោក្នុងស្រុកជាយដែន ទើបដឹកគោទៅកាន់អាស្រមបទ គិតថា អញនឹងឲ្យព្រះអគ្គីដ៏មានជោគ សោយនូវសាច់គោ ។ កាលនោះ ព្រះពោធិសត្វមានបរិវិតក្កដូច្នេះថា ក្នុងទីនេះ មិនមានអំបិល ព្រះអគ្គីដ៏មានជោគនឹងមិនអាចសោយសាច់ដែលសាបបានទេ អញនឹងទៅរកអំបិលអំពីស្រុក ឲ្យព្រះអគ្គីដ៏មានជោគសោយសាច់ដែលមានរសប្រៃ ។ ទើបព្រះពោធិសត្វចងគោទុកក្នុងទីនោះឯង បានទៅស្រុកដើម្បីរកអំបិល ។ ខណៈដែលលោកទៅ មានព្រានច្រើននាក់មកដល់ទីនោះ ឃើញគោហើយ សម្លាប់ អាំងសាច់ស៊ី បោលកន្ទុយ ស្មង និងស្បែកក្នុងទីនោះឯង ហើយនាំគ្នាយកសាច់ដែលសល់ទៅផងដែរ ។ ព្រាហ្មណ៍មកហើយ ឃើញគោសល់តែកន្ទុយជាដើម គិតថា ព្រះអគ្គីដ៏មានជោគនេះ សូម្បីតែគោរបស់ខ្លួន ក៏មិនអាចរក្សាបាន នឹងរក្សាអញបានអំពីណា ការបម្រើភ្លើងនេះ ជារបស់ឥតប្រយោជន៍ កុសល

ឬសេចក្ដីចម្រើន មានការបូជាភ្លើងនេះជាហេតុ មិនមានពិត ព្រាហ្មណ៍ក៏អស់នូវការពេញចិត្តក្នុងការបម្រើភ្លើង ពោលថា បពិត្រព្រះអគ្គីដ៏ចម្រើន សូម្បីតែរបស់ខ្លួនឯង លោកមិនអាចរក្សាឲ្យគង់បាន តើនឹងរក្សាខ្ញុំបានដូចម្ដេច សាច់មិនមានហើយ ចូរត្រេកអរត្រឹមរបស់ប៉ុណ្ណេះចុះ កាលបោះកន្ទុយចូលក្នុងគំនរភ្លើងជាដើម ទើបពោលគាថានេះថា

ម្នាលភ្លើងជាអសប្បុរស យើងនឹងបូជាអ្នកដោយកន្ទុយណា កន្ទុយប៉ុណ្ណេះច្រើនហើយ ក្នុងថ្ងៃនេះ សាច់មិនមានដល់អ្នកដ៏គួរដល់សាច់ទេ អ្នកដ៏ចម្រើន ចូរទទួលយកតែកន្ទុយចុះ ។

បណ្ដាបទទាំងនោះ បទថា **ពហុម្បេតំ** សេចក្ដីថា សូម្បីរបស់ត្រឹមប៉ុណ្ណេះ ក៏ឈ្មោះថា ច្រើនពេកផង ។

បទថា **អសព្ភិ** សេចក្ដីថា ភ្លើងមិនមែនសប្បុរស គឺមិនមែនបុគ្គលល្អ ។ ព្រាហ្មណ៍ហៅភ្លើងថា ជាតវេទ អធិប្បាយថា ភ្លើង ត្រឹមតែកើតក៏ដឹងគ្នា គឺប្រាកដឲ្យឃើញទូទៅ ព្រោះដូច្នោះ ទើបហៅថា ជាតវេទ ។

បទថា **យន្តំ វាលធិនាភិបូជយាម** សេចក្ដីថា ការដែលខ្ញុំបូជាលោកដ៏មានជោគ ដែលមិនអាចរក្សានូវរបស់ខ្លួនបាន ក្នុងថ្ងៃនេះ ដោយកន្ទុយត្រឹមតែប៉ុណ្ណេះ ក៏ច្រើនពេកទៅហើយ សម្រាប់អ្នក ។

បទថា **មំសារហស្ស** សេចក្ដីថា ថ្ងៃនេះ សាច់មិនមានសម្រាប់អ្នកដែលចូលចិត្តសាច់ ។

បទថា **ឆឌ្ឌុជ្ជម្បិ ភវំ បដិគ្គហាតុ** សេចក្តីថា កាលអ្នកមិនអាចរក្សារបស់ខ្លួនបាន ក៏អញ្ជើញលោកដ៏ចម្រើន ទទួលត្រឹមតែកន្ទុយ ស្នែង និងស្បែកនេះចុះ ។

ព្រះមហាសត្វកាលពោលយ៉ាងនេះហើយ យកទឹកលត់ភ្លើងចោល បួសជាឥសី ធ្វើអភិញ្ញា និងសមាបត្តិឲ្យកើត ហើយបានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសអ្នកលត់ភ្លើងចោលក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ឆឌ្ឌុដ្ឋជាតក ចប់**

# សុត្តន្តបិដក

## រាធជាតក

[ ១៤៥ ] *( សេចក្តីពោធិសត្វពោលថា ) ម្នាលរាធៈ អ្នករមែងមិនដឹងច្បាស់ថា ពួកមនុស្សប៉ុណ្ណេះ ក្នុងពេលពាក់កណ្តាលអធ្រាត្រ មិនទាន់មកដល់ ពោលចរចានូវពាក្យមិនប្រាកដនឹងនាងព្រាហ្មណី ជាកោសិយគោត្រ អ្នកមិនមានតម្រេក ( នឹងស្វាមីខ្លួន ) ។*

***រាធជាតកទី ៥ ចប់***

# អដ្ឋកថា

## រាធជាតក

[ ១៤៥ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់អតីតកិរិយា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឆ តុំ រាធ វិជានាសិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន នឹងមានជាក់ច្បាស់ក្នុងឥន្ទ្រិយជាតក ប្លែកត្រង់តែព្រះសាស្ដាហៅភិក្ខុនោះមក ត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា មាតុគ្រាម ជាអ្នកដែលបុគ្គលណាម្នាក់រក្សាមិនបាន សូម្បីរវាំងប្រយ័ត្នយ៉ាងតឹងរ៉ឹង ក៏មិនអាចរក្សាបាន ម្នាលភិក្ខុ ក្នុងកាលមុន អ្នកធ្វើការរក្សាការពារមាតុគ្រាម តែមិនអាចរក្សាបាន ឥឡូវនេះ នឹងរក្សាបានដូចម្ដេច ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសេក ព្រាហ្មណ៍ម្នាក់ក្នុងដែនកាសី ចិញ្ចឹមព្រះពោធិសត្វ និងប្អូនប្រុសក្នុងឋានៈជាកូន ក្នុងបក្សីទាំង ២ នោះ ព្រះពោធិ-សត្វបានឈ្មោះថា **ពោដ្ឋបាទ** ប្អូនប្រុសបានឈ្មោះថា **រាធ:** ។ កិរិយារបស់ព្រាហ្មណ៍ជាស្រីមិនមានមារយាទ ទ្រុស្តសីល កាលព្រាហ្មណ៍ធ្វើដំណើរទៅជួញដូរ ក៏បញ្ជាបក្សី ២ នាក់បងប្អូនថា នែបាទាំង ២ បើព្រាហ្មណីម្ដាយរបស់ឯងប្រព្រឹត្តមិនល្អ ចូរបាហាមគាត់ បក្សីពោធិសត្វឆ្លើយថា បាទពុក បើអាចហាមបាន ខ្ញុំក៏នឹងហាម បើហាមមិនបាន ខ្ញុំនឹងនៅស្ងៀម ព្រាហ្មណ៍ប្រគល់នាងព្រាហ្មណីដល់សេកទាំង ២ យ៉ាងនេះហើយ ក៏ធ្វើដំណើរទៅជួញ

ដូរ តាំងអំពីថ្ងៃដែលព្រាហ្មណ៍ចេញទៅ ព្រាហ្មណីក៏ចាប់ផ្ដើមប្រព្រឹត្តក្រៅចិត្ត ទាំងមនុស្សដែលចូលទៅ និងមនុស្សដែលចេញមក មិនមានប្រមាណ ។ រាធៈ ឃើញកិរិយារបស់ម្ចាស់ស្រី ក៏ពោលនឹងព្រះពោធិសត្វថា ឪពុករបស់យើង ប្រាប់ស្រេចថា បើម៉ែរបស់ឯងទាំង ២ ប្រព្រឹត្តមិនល្អ មិនប្រពៃ ចូរឯងហាម ដូច្នេះ ទើបទៅ ឥឡូវនេះ ម៉ែយើងកំពុងប្រព្រឹត្តមិនល្អ មិនប្រពៃ យើងនាំគ្នាហាមគាត់ចុះ ព្រះពោធិសត្វពោលដាស់តឿនថា ប្អូនសម្លាញ់ ឯងនិយាយដោយល្ងង់ ព្រោះមិនឈ្លាសពិតៗ ឈ្មោះថា មាតុគ្រាម សូម្បីបុគ្គលចាប់ដៃរក្សានាំទៅ ក៏មិនអាចរក្សាបានឡើយ យើងមិនគួរធ្វើវត្ថុដែលយើងមិនអាចធ្វើបាន ហើយពោលគាថានេះថា

ម្នាលរាធៈ អ្នករមែងមិនដឹងច្បាស់ថា ពួកមនុស្សប៉ុណ្ណោះ ក្នុង
ពេលពាក់កណ្ដាលអធ្រាត្រ មិនទាន់មកដល់ ពោលចរចានូវពាក្យ
មិនប្រាកដនឹងនាងព្រាហ្មណី ជាកោសិយគោត្រ អ្នកមិនមាន
តម្រេក ( នឹងស្វាមីខ្លួន ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ត្វំ រាធ វិជានាសិ អឌ្ឍរត្តេ អនាគតេ** សេចក្ដីថា នែបារាធៈ ឯងមិនដឹងអ្វី ក្នុងកណ្ដាលយប់ខាងមុខ គឺក្នុងបឋមយាមប៉ុណ្ណោះ មនុស្សដែលមិនទាន់មក មានដល់ប៉ុណ្ណោះ ឥឡូវនេះ អ្នកណានឹងថា មនុស្សដទៃប៉ុនណាទៀត នឹងនាំគ្នាមក ។

បទថា **អព្យាយតំ វិលបសិ** សេចក្ដីថា អ្នកកុំពោលផ្ដេសផ្ដាសព្រោះភាពល្ងង់ខ្លៅ ។

បទថា **ពិរត្តេ កោសិយាយនេ** សេចក្តីថា ព្រាហ្មណីកោសិយៈ ជាមាតារបស់យើង អស់សេចក្តីស្រឡាញ់ហើយ គឺមិនស្រឡាញ់ក្នុងឪពុករបស់យើង បើគាត់មានការប្រតិព័ទ្ធ ឬការស្រឡាញ់ក្នុងឪពុក ក៏មិនគួរប្រព្រឹត្តមិនល្អមិនស្អាតយ៉ាងនេះឡើយ ព្រះពោធិសត្វប្រកាសសេចក្តីដូចពណ៌នាមកនេះ ដោយព្យញ្ជនៈក្នុងគាថាទាំងនេះ ។

កាលព្រះពោធិសត្វប្រកាសយ៉ាងនេះហើយ មិនឲ្យរាធៈប្អូនប្រុសនិយាយនឹងព្រាហ្មណី នាងក៏ប្រព្រឹត្តអាក្រក់តាមគាប់ចិត្ត ដរាបព្រាហ្មណ៍មិនទាន់ត្រឡប់មក ។ ព្រាហ្មណ៍មកហើយ សួរបក្សីបោត្ថបាទថា នែបា ម៉ែរបស់ឯងទាំង ២ យ៉ាងណាដែរ ព្រះពោធិសត្វក៏ប្រាប់រឿងទាំងអស់តាមសេចក្តីពិតដល់ព្រាហ្មណ៍ ហើយពោលបន្តថា បពិត្រលោកឪពុក ស្រីប្រព្រឹត្តអាក្រក់យ៉ាងនេះ លោកឪពុកចិញ្ចឹមធ្វើអ្វី បពិត្រលោកឪពុក ចាប់ពីពេលដែលខ្ញុំទាំង ២ ពោលទោសរបស់អ្នកម៉ែហើយ ក៏មិនអាចនៅទីនេះបាន ក៏ថ្វាយបង្គំទៀបបាតជើងព្រាហ្មណ៍ ហើយនាំបងប្អូនទៅកាន់ព្រៃ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រកាសសច្ចៈ កាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ និងព្រាហ្មណីក្នុងកាលនោះ បានមកជាជនទាំង ២ នាក់ ក្នុងកាលឥឡូវនេះ រាធៈក្នុងកាលនោះ បានមកជាអានន្ទ ឯបោត្ថបាទ ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថារាធជាតក ចប់**

# សុត្តន្តបិដក

## កាកជាតក

[ ១៨៦ ] ( ពួកក្អែកពោលថា ) អើ ចង្កាយើងក៏រោយ ទាំងមាត់ ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល ។

កាកជាតកទី ៦ ចប់

# អដ្ឋកថា

## សមុទ្ទកាកជាតក

[ ១៤៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់ៗ ជាច្រើនរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ នុ ហនុកា សន្តា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុទាំងនោះ កាលជាគ្រហស្ថ ជាកុដុម្ពិកៈក្នុងក្រុងសាវត្ថី ជាអ្នកស្តុកស្តម្ភដោយទ្រព្យ ជាសម្លាញ់នឹងគ្នា ធ្វើបុណ្យរួមគ្នា ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ នាំគ្នាត្រិះរិះថា ពួកយើងជាមនុស្សចាស់ មានប្រយោជន៍អ្វីដល់ពួកយើង ដោយការនៅគ្រប់គ្រងផ្ទះ ពួកយើងនឹងបួសក្នុងព្រះពុទ្ធសាសនា ដែលគួរជាទីត្រេកអរក្នុងសម្នាក់ព្រះសាស្តា នឹងធ្វើទីបំផុតនៃទុក្ខ ដូច្នេះហើយ លើកសម្បត្តិទាំងពួងឲ្យដល់កូនចៅជាដើម លះពួកញាតិដែលមានមុខជោកដោយទឹកភ្នែក ទូលសូមបព្វជ្ជានឹងព្រះសាស្តា កាលបួសហើយ មិនបានបបួលគ្នាធ្វើសមណធម៌ ដែលសមគួរដល់បព្វជ្ជា សូម្បីព្រះធម៌ក៏មិនសិក្សា ព្រោះភាពជាមនុស្សចាស់ សូម្បីបួសហើយ ក៏ដូចកាលនៅជាគ្រហស្ថ ឲ្យមនុស្សសាងបណ្ណសាលាខាងចុងវិហារ នៅរួមគ្នានោះឯង ត្រាច់បិណ្ឌបាត ក៏មិនបានទៅទីដទៃ បបួលគ្នាទៅកាន់ត្រង់ផ្ទះកូនប្រពន្ធរបស់ខ្លួននោះឯង ។ ក្នុងបណ្តាមនុស្សទាំងនោះ ភរិយាចាស់របស់ព្រះថេរៈមួយរូប មានឧបការៈដល់ព្រះថេរៈចាស់ៗ ទាំងពួង ហេតុនោះ សូម្បីព្រះថេរៈដ៏សេសក៏កាន់យកអាហារដែលខ្លួនបាន មកអង្គុយកាន់ក្នុងផ្ទះរបស់នាង ។ ឯនាងក៏ប្រគេនសម្លតាមដែលខ្លួនរៀបចំដល់ព្រះថេរៈទាំងនោះ ។ នាងមានអាពាធ

ឯណាទីមួយ ធ្វើកាលកិរិយាហើយ ។ កាលនោះ ព្រះថេរៈចាស់ៗ ទាំងនោះ នាំគ្នាទៅកាន់វិហារ កៀកកគ្នា ដើរយំខាងចុងវិហារថា ឧបាសិកាដែលមានថ្វីដៃធ្វើសម្លឆ្ងាញ់ ស្លាប់ហើយ ។ ឯភិក្ខុទាំងឡាយ ស្ដាប់សំឡេងរបស់ព្រះថេរៈទាំងនោះហើយ ក៏មកប្រជុំគ្នាអំពីទីផ្សេងៗ សួរថា អាវុសោទាំងឡាយ ហេតុអ្វី ទើបពួកលោកយំ ព្រះថេរៈទាំងនោះឆ្លើយថា អតីតកិរិយាសម្លាញ់របស់ពួកខ្ញុំ មានថ្វីដៃធ្វើម្ហូបឆ្ងាញ់ ស្លាប់ហើយ នាងមានឧបការៈដល់ពួកខ្ញុំក្រៃពេក ក្នុងទីនេះ មិនមានអ្នកណាមានថ្វីដៃដូចនាងឡើយ ហេតុនេះ ទើបពួកខ្ញុំនាំគ្នាយំ ។ ភិក្ខុទាំងឡាយឃើញវិប្បរិតនោះ របស់ព្រះថេរៈទាំងនោះហើយ នាំគ្នាលើករឿងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ដោយហេតុឈ្មោះនេះ ព្រះថេរៈចាស់ៗ ទាំងឡាយ កៀក-កគ្នាដើរយំខាងចុងវិហារ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុទាំងនោះនាំគ្នាយំ ព្រោះស្រីនោះស្លាប់ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះ អាស្រ័យស្រីនេះដែលកើតក្នុងកំណើតក្អែក ហើយស្លាប់ក្នុងសមុទ្រ នាំគ្នាគិតថា ពួកយើងនឹងបាចទឹកសមុទ្រ យកនាងឡើងមកឲ្យបាន ដូច្នេះ នាំគ្នាព្យាយាម ព្រោះបានអាស្រ័យបណ្ឌិត ទើបមានជីវិតរស់នៅបាន ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាទេវតារក្សាសមុទ្រ កាលនោះ ក្អែកមួយ នាំក្អែកញីជាភរិយារបស់ខ្លួនស្វែងរកចំណី បានទៅដល់មាត់សមុទ្រ ។ កាលនោះ ពពួកជននាំគ្នាធ្វើពលីកម្មដល់ស្តេចនាគ ដោយទឹកដោះ បាយាស ត្រី សាច់ និងស្រាជាដើមទ្រង់ធ្នេរ ហើយនាំគ្នាចៀសចេញទៅ ។ កាលនោះ ក្អែកមួយទៅដល់ទីពលីកម្ម ឃើញទឹកដោះជាដើម ក៏នាំក្អែកញីផឹកទឹកដោះ ស៊ីបាយាស ត្រី សាច់ជាដើម ហើយផឹកស្រាជាច្រើន ក្អែកញីឈ្មោល ទាំងគូស្រវឹង គិតនឹងលេងសមុទ្ទកីឡា ទំត្រង់ធ្នេរខ្សាច់ បំណងនឹងងូតទឹក កាលនោះ រលកមួយបក់មក នាំយកក្អែកញីទៅក្នុងសមុទ្រ ត្រីមួយឃើញ ស៊ីក្អែកញីនោះលេបចូលទៅ ។ ក្អែកឈ្មោលយំរៀបរាប់ថា ប្រពន្ធរបស់ខ្ញុំស្លាប់ហើយ កាលក្អែកជាច្រើនមក បានឮសំឡេងយំរបស់ក្អែកនោះ ក៏មកប្រជុំគ្នាសួរថា ឯងយំព្រោះហេតុអ្វី ក្អែកនោះប្រាប់ថា ស្រីសម្លាញ់របស់ពួកអ្នកកំពុងងូតទឹកត្រង់ធ្នេរខ្សាច់ រលកមួយបានក្ដួចទៅហើយ ក្អែកទាំងអស់នោះក៏យំទ្រហឹងដូចគ្នា ។ គ្រានោះ ក្អែកទាំងនោះ មានការគិតដូច្នេះថា ឈ្មោះថា ទឹកក្នុងសមុទ្រនេះ ច្រើនល្មមដល់ពួកយើងឬ ពួកយើងនាំគ្នាបាចទឹកឲ្យរីង យកស្រីសម្លាញ់របស់ពួកយើងមកឲ្យបាន ។ ក្អែកទាំងនោះ នាំគ្នាបៀមទឹកពេញចំពុះនោះឯង យកទៅខ្ជាក់ចោលខាងលើគោក កាលខះកព្រោះទឹកសមុទ្រប្រៃ ក៏នាំគ្នាឡើងលើគោក ពួកក្អែក កាលរោយដើង មាត់ស្ងួក ភ្នែកក្រហម ក៏អស់កម្លាំងទៅតាមគ្នា ទើបហៅគ្នាមកប្រាប់នូវទុក្ខថា

ពួកយើងអើយ យើងនាំគ្នាបៀមទឹកអំពីសមុទ្រទៅចោលលើគោក ទីដែលយើងបៀមទៅហើយ ត្រឡប់ពេញវិញដោយទឹក ពួកយើងប្រហែលមិនអាចឲ្យសមុទ្ររីងពិត ដូច្នេះហើយ ពោលគាថានេះថា

អើ ចង្កាយើងក៏រោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ យើងមិនអាច

បាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញ

ដដែល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ នុ ហនុកា សន្តា** សេចក្តីថា ឱហ្ន៎ ! ចង្ការបស់យើងក៏ចុករោយហើយ ។

បទថា **ឱរមាម ន ចារេម** សេចក្តីថា ពួកយើងនាំគ្នាបៀមទឹកអំពីមហាសមុទ្រ ទៅចោលតាមកម្លាំងរបស់ខ្លួន ក៏មិនអាចធ្វើសមុទ្រឲ្យរីងបាន ព្រោះអន្លង់ទឹកធំ ពេញដូចដើមនោះឯង ។

កាលពោលយ៉ាងនេះហើយ ក្អែកទាំងអស់នោះ ក៏កន្ទក់កន្ទេញជាច្រើនថា ចំពុះរបស់ក្អែកញីនោះ ស្អាតបែបនេះ ក្អែកមូលក្រឡង់យ៉ាងនេះ ពណ៌សម្បុរ ទ្រង់ទ្រាយស្អាតយ៉ាងនេះ សំឡេងពីរោះបែបនេះ ព្រោះអាស្រ័យសមុទ្រដែលជាចោរនេះ ក្អែកញីរបស់ពួកយើងបាត់ទៅហើយ ទេវតារក្សាសមុទ្របង្ហាញរូបគួរខ្លាច ដេញហ្វូងក្អែកដែលកំពុងយំរៀបរាប់យ៉ាងនេះ ឲ្យគេចទៅ សួស្តីមានដល់ក្អែកទាំងនោះ ដោយប្រការដូច្នេះ ។

*ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ក្អែកញីក្នុងកាលនោះ បានមកជាបុរាណទុតិយិកា ក្នុងកាលឥឡូវនេះ ក្អែកឈ្មោលក្នុងកាលនោះ បានមកជាភិក្ខុចាស់ ក្នុងកាលឥឡូវនេះ ហ្វូងក្អែកដ៏សេស ក្នុងកាលនោះ បានមកជាព្រះថេរៈចាស់ៗ ឯទេវតារក្សាសមុទ្រក្នុងកាលនោះ គឺជាតថាគត ដូច្នេះឯង ។ល។*

**អដ្ឋកថា សមុទ្ទកាកជាតក ចប់**

# សុត្តន្តបិដក

## បុប្ផរត្តជាតក

[ ១៤៧ ] *( មនុស្សទុគ៌តពោលថា ) ក្អែកចោះអញ ដោយហេតុណា ហេតុនេះ មិនជាទុក្ខទេ សេចក្តីទុក្ខនោះ ក៏មិនមានដល់យើងឡើយ ទុក្ខមាន ដល់យើងនោះ គ្រង់កិរិយាឈ្មោះសាមា មិនស្លៀកដណ្តប់សំពត់ដែលជ្រលក់ ដោយទឹកដកគាំ ដើរមើលមហោស្រព ក្នុងខែកត្តិក ។*

***បុប្ផរត្តជាតកទី ៧ ចប់***

# អដ្ឋកថា

## បុប្ផរត្តជាតក

[ ១៤៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឆយិទំ ទុក្ខំ អទុំ ទុក្ខំ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ភិក្ខុនោះ កាលព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ក៏ក្រាបទូលថា បពិត្រព្រះអង្គពិតមែន ។ ព្រះសាស្ដាត្រាស់សួរថា តើអ្នកអផ្សុកព្រោះហេតុអ្វី ទើបក្រាបទូលថា ព្រោះបុរាណទុតិយិការបស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គ ស្រីនោះមានថ្វីដៃឆ្ងាញ់ ខ្ញុំព្រះអង្គមិនអាចព្រាត់ប្រាសចាកនាងបាន ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ស្រីនេះ ធ្វើសេចក្ដីវិនាសឲ្យអ្នកក្នុងកាលមុន ព្រោះស្រីនេះជាហេតុ អ្នកត្រូវដោតលំពែង ខ្សឹកខ្សួលដល់នាងប៉ុណ្ណោះ កាលស្លាប់ហើយ ទៅកើតក្នុងនរកឥឡូវនេះ ព្រោះហេតុអ្វី អ្នកនៅតែប្រាថ្នានាងទៀត ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអាកាសដ្ឋកទេវតា ។ កាលនោះ នៅក្នុងនគរពារាណសី មានមហោស្រពពេលយប់ ក្នុងខែកត្តិក មហាជននាំគ្នារៀបចំស្រុកភូមិស្អាតបាត ដូចគ្នានឹងទេវនគរ មនុស្សទាំងពួង បំណងលេងមហោស្រព តែមានមនុស្សក្រីក្រម្នាក់ មានសំពត់សាច់ល្អមួយគូប៉ុណ្ណោះ គាត់យកមកបោកឲ្យស្អាត គាត់បោកជ្រុល ក៏មានស្នាមជ្រីវជ្រួញ រាប់រយ រាប់

ពាន់ ។ គ្រានោះ ភរិយាពោលថា នែអ្នក ខ្ញុំចង់ស្លៀកសំពត់ជ្រលក់ដោយផ្កាដកគាំមួយផ្ទាំង ដណ្តប់មួយផ្ទាំង កៀក-កអ្នកដើរលេងមហោស្រពប្រចាំរាត្រីខែកត្តិក ។ បុរសនោះពោលថា នែនាង យើងក្រីក្រ តើមានសំពត់ជ្រលក់ផ្កាដកគាំមកអំពីណា ចូរនាងស្លៀកសំពត់ស ដើរលេងចុះ ។ ភរិយាពោលថា បើមិនបានសំពត់ជ្រលក់ផ្កាដកគាំ ខ្ញុំមិនលេងកីឡាក្នុងមហោស្រពទេ សូមអ្នកនាំស្រីដទៃដើរលេងចុះ បុរសនោះពោលថា នែនាង នាងរំអុកខ្ញុំពន់ពេក ខ្ញុំនឹងបានសំពត់ជ្រលក់ផ្កាដកគាំមកអំពីណា នាងពោលថា កាលសេចក្តីប្រាថ្នារបស់កូនប្រុសមាន ឈ្មោះថា សេចក្តីមិនសម្រេចមិនមាន ផ្កាដកគាំក្នុងចម្ការរបស់ព្រះរាជាមានច្រើនមិនមែនឬ បុរសនោះពោលថា នែនាង ទីនោះមានការយាមកាមតឹងរ៉ឹង ដូចគ្នានឹងស្រះបោក្ខរណី ដែលមានអារក្សទឹកគ្រប់គ្រង ខ្ញុំមិនអាចចូលទៅជិតបានទេ នាងកុំគាប់ចិត្តក្នុងទីនោះឡើយ ចូរត្រេកអរតាមមានតាមបានចុះ ។ ភរិយាពោលថា នែអ្នក ភាពងងឹតក្នុងរាត្រីកាលមាន ឈ្មោះថា ទីដែលកូនប្រុសទៅមិនបានមិនមាន ។ ទេវតាដែលនៅក្នុងអាកាសមួយរូបឃើញភ័យក្នុងអនាគតរបស់បុរសនោះ ក៏ជួយឃាត់ផងដែរ ។ កាលភរិយាពោលហើយ ពោលទៀតយ៉ាងនេះ បុរសនោះក៏ជឿពាក្យភរិយាដោយអំណាចកិលេស លួងលោមនាងថា នែនាង ចូរនាងនៅស្ងៀមចុះ កុំគិតថ្វីឡើយ ។ លុះដល់ពេលយប់ក៏ប្រថុយជីវិត ចេញអំពីព្រះនគរ ទៅកាន់ចម្ការដកគាំរបស់ព្រះរាជា ឡើងរបងចូលទៅក្នុងចម្ការ អ្នកយាមចម្ការបានឮសំឡេងរបង ស្រែកថា ចោរ ចោរ ហើយព័ទ្ធចាប់បាន នាំ

គ្នាជេរ ចោមរោមវាយតប់ ហើយចង លុះភ្លឺហើយ ក៏នាំទៅថ្វាយព្រះរាជា ។ ព្រះរាជាត្រាស់ថា ចូរពួកអ្នកយកវាជោតដោយលំពែង អ្នកទាំងនោះ ចងបុរសនោះក្រពាត់ស្លាបសេក នាំចេញអំពីនគរដោយមាន មនុស្សវាយស្គរប្រកាសទោសប្រហារទៅជាមួយផង ហើយយកទៅជោតលំពែង ។ បុរសនោះ សោយនូវទុក្ខវេទនាដ៏ខ្លាំងក្លា ហ្វូងក្អែកនាំគ្នាទំត្រង់ក្បាល ចឹកភ្នែកដោយចំពុះដ៏ស្រួច ដូចចុងលំពែង បុរសនោះ មិនបានដាក់ចិត្តដល់ទុក្ខដ៏ពន្លឹកនោះ គិតដល់ស្រីនោះតែម្យ៉ាងថា អញអស់ឱកាសក្នុងមហោស្រពប្រចាំរាត្រីខែកត្តិកជាមួយនាង ដែលស្លៀកសំពត់ជ្រលក់ដោយផ្កាដកគាំ ប្រើដើមដៃទាំង ២ ឱបត្រង់ក ហើយពោលគាថានេះថា

ក្អែកចោះអញ ដោយហេតុណា ហេតុនេះ មិនជាទុក្ខទេ សេចក្តីទុក្ខនោះ ក៏មិនមានដល់យើងឡើយ ទុក្ខមានដល់យើងនោះ ត្រង់ភរិយាឈ្មោះសាមា មិនស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកដកគាំ ដើរមើលមហោស្រព ក្នុងខែកត្តិក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នយិទំ ទុក្ខំ អទុំ ទុក្ខំ យំ មំ តុទតិ វាយសោ** អធិប្បាយថា ទុក្ខតាមកាយ តាមចិត្តដែលត្រូវលំពែងជោតជាបច្ច័យក្តី ទុក្ខដែលក្អែកចឹកដោយចំពុះដ៏មុត ហាក់ដូចជាធ្វើដោយលោហៈក្តី ទាំងអស់នេះ មិនមែនជាទុក្ខរបស់ខ្ញុំឡើយ ទុក្ខដទៃឯណោះទេ ដែលជាទុក្ខរបស់ខ្ញុំ ។ សួរថា តើទុក្ខប្រភេទណា ។ ឆ្លើយថា គឺទុក្ខដែលស្រីពណ៌សម្បុរដូចមាស មិនបានស្លៀកសំពត់ជ្រលក់ដោយផ្កាដកគាំ ដើរលេង

មហាស្រពខែកត្ដិក អធិប្បាយថា ការដែលទាងបយន្ដសាមា ដែលជាកិរិយារបស់ខ្ញុំនោះ មិនបានស្លៀកសំពត់ជ្រលក់ដោយផ្កាដកគាំមួយផ្ទាំង ជណ្ដប់មួយផ្ទាំង បិទបាំងរាងកាយដោយគូនៃសំពត់ជ្រលក់ដោយផ្កាឈើសាច់ល្អិត ហើយកៀកក-ខ្ញុំដើរលេងនក្ខត្តឫក្ស ខែកត្ដិកនេះឯណោះទេ ដែលជាទុក្ខរបស់ខ្ញុំ ទុក្ខនេះប៉ុណ្ណោះ ដែលបៀតបៀនខ្ញុំពន់ពេក ។

បុរសនោះគិតតែខ្សឹកខ្សួល ដល់មាតុគ្រាមនោះយ៉ាងនេះប៉ុណ្ណោះ រហូតស្លាប់ទៅកើតក្នុងនរក ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ស្វាមីកិរិយាក្នុងកាលនោះ បានមកជាប្ដីប្រពន្ធក្នុងកាលឥឡូវនេះ ឯអាកាសដ្ឋកទេវតា ដែលឈរប្រកាសធ្វើហេតុនោះឲ្យប្រចក្សក្នុងកាលនោះ គឺតថាគតនេះឯង ។l

## អដ្ឋកថា បុប្ផរត្តជាតក ចប់

# សុត្តន្តបិដក

## សិង្គាលជាតក

[ ១៤៨ ] *( ចចកពោធិសត្វពោលថា ) យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីញយៗ ទេ ព្រោះយើងត្រូវភ័យគំរាមហើយ ដូច្នោះ ។*

***សិង្គាលជាតកទី ៨ ចប់***

# អដ្ឋកថា

## សិង្គាលជាតក

[ ១៤៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់សង្កិនកិលេស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **នាហំ បុនំ ន ច បុនំ** ដូច្នេះជាដើម ។

បានឮថា កូនសេដ្ឋីក្នុងក្រុងសាវត្ថី ប្រមាណ ៥០០ នាក់ ជាសម្លាញ់នឹងគ្នា មានសម្បត្តិសន្ធឹកសន្ធាប់ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ នាំគ្នាបួសថ្វាយជីវិតក្នុងព្រះសាសនា នៅក្នុងកុដិខាងចុងវិហារវត្តជេតពន ។ ថ្ងៃមួយ ក្នុងពេលកណ្ដាលយប់ ការត្រិះរិះអាស្រ័យកិលេសជាម្ចាស់ផ្ទះ បានកើតឡើងដល់ពួកភិក្ខុទាំងនោះ ពួកលោកក៏អផ្សុក កើតចិត្តប្បាទ ដើម្បីវិលត្រឡប់ទៅរកកិលេសដែលខ្លួនលះបង់ហើយម្ដងទៀត ។ កាលនោះ ព្រះសាស្ដាទ្រង់ទ្រោលប្រទីប ដែលមានសព្វញ្ញុតញ្ញាណជាជង ក្នុងកណ្ដាលរត្តិកាល ទ្រង់ប្រមើលមើលអជ្ឈាស្រ័យរបស់ភិក្ខុទាំងឡាយថា ពួកភិក្ខុនាំគ្នាស្នាក់នៅខាងចុងវិហារវត្តជេតពន មានសេចក្ដីត្រិះរិះ ដោយសេចក្ដីត្រេកអរដូចម្ដេចហ្ន៎ ។ ទ្រង់បានជ្រាបភាពដែលភិក្ខុទាំងនោះ មានសេចក្ដីត្រិះរិះក្នុងកាមរាគៈ កើតឡើងក្នុងខាងក្នុង ។ ធម្មតាព្រះសាស្ដា រមែងរក្សាសាវករបស់ព្រះអង្គ ដូចស្រីមានបុត្រតែមួយ ថ្នាក់ថ្នមបុត្ររបស់ខ្លួន ឬដូចបុគ្គលមានភ្នែកតែម្ខាង រក្សាភ្នែករបស់ខ្លួន ។ ក្នុងសម័យណា មានពេលព្រឹកជាដើម កិលេសទាំងឡាយកើតដល់ពួកសាវកនោះ ទ្រង់ក៏មិនព្រមឲ្យកិលេសទាំងនោះរបស់សាវកទាំងនោះ ចម្រើនជាងនោះ ទ្រង់សង្កត់សង្កិន

ក្នុងសម័យនោះៗ ឯង ដោយហេតុនោះ ទើបទ្រង់មានព្រះបរិវិតក្កថា កាលនេះ ដូចគ្នានឹងកាលដែលពួកចោរកើតឡើង ខាងក្នុងព្រះនគររបស់ស្តេចចក្រពត្តិ ដូច្នោះ ។ តថាគតត្រូវតែសម្តែងធម្មទេសនាសង្កត់សង្កិនទូវគំនរកិលេស ហើយឲ្យអរហត្តផលដល់ភិក្ខុទាំងនេះ ក្នុងកាលឥឡូវនេះឯង ទើបទ្រង់ចេញអំពីព្រះគន្ធកុដិ ត្រាស់ព្រះសូរសៀងដ៏ពីរោះ ហៅព្រះអានន្ទដែលជាឃ្លាំងធម៌ថា ម្នាលអានន្ទ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា ករុណាព្រះអង្គមកថ្វាយបង្គំ រួចឈរ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ភិក្ខុមានប្រមាណប៉ុនណា ដែលនៅក្នុងកុដិខាងចុង ចូរអ្នកឲ្យភិក្ខុទាំងនោះប្រជុំគ្នាក្នុងបរិវេណគន្ធកុដិទាំងអស់នោះឯង ។ បានឮថា ទ្រង់មានព្រះតម្រិះដូច្នេះថា កាលតថាគតឲ្យហៅភិក្ខុទាំង ៥០០ នោះ ប៉ុណ្ណោះមកប្រជុំ ភិក្ខុទាំងនោះនឹងសង្ស័យថា ព្រះសាស្តាទ្រង់ជ្រាបភាពដែលកិលេសកើតឡើងខាងក្នុងរបស់ពួកយើងហើយ នឹងមិនអាចទទួលធម្មទេសនាបាន ហេតុនោះ ទើបត្រាស់ថា ឲ្យភិក្ខុទាំងអស់ប្រជុំ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា សាធុ ហើយកាន់យកកូនសោ ត្រាច់ទៅក្នុងបរិវេណ ប្រាប់ឲ្យភិក្ខុទាំងអស់ប្រជុំគ្នា ក្នុងបរិវេណព្រះគន្ធកុដិ ហើយរៀបចំក្រាលពុទ្ធាសនៈ ។

ព្រះសាស្តាទ្រង់ពត់ព្រះភ្នែន មានព្រះកាយត្រង់ ប្រថាប់លើពុទ្ធាសនៈដែលរៀបចំ ដូចស្តេចភ្នំសិនេរុតាំងនៅលើបឋវីសិលា ទ្រង់បញ្ចេញឆព្វណ្ណ-រង្សី ធ្លៀលធ្លាត់ជាគូៗ ព្រះរស្មីទាំងនោះមានប្រមាណប៉ុនថាស ប៉ុនឆត្រ ប៉ុនគោមមាសនៃផ្ទះកំពូល ដាច់ជារយៈៗ ធ្វើលជុំវិញព្រះកាយ ដូចផ្គេកបន្ទោរ

ក្នុងនភាកាស ។ កាលនោះ ហាក់បីដូចជាព្រះអាទិត្យកំពុងជះរស្មីស្រទន់ ធ្វើឲ្យផ្ទៃសមុទ្រចាំងរស្មីព្រិចៗ ដូច្នោះ ។ ភិក្ខុសង្ឃសោត ក៏បន្ទន់កាយថ្វាយបង្គំព្រះសាស្តា តាំងចិត្តគោរពយ៉ាងមាំទាំ ចោមរោមព្រះសាស្តាដោយជុំវិញបីដូចព័ទ្ធដោយវាំងននសំពត់កម្ពលក្រហម ។ ព្រះសាស្តាទ្រង់បន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ទ្រង់ដាស់តឿនភិក្ខុទាំងឡាយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយធម្មតាភិក្ខុ មិនគួរត្រិះរិះអកុសលវិតក្កទាំង ៣ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ ឈ្មោះថា កិលេសដូចនឹងបច្ចាមិត្រ ឈ្មោះថា បច្ចាមិត្រមិនមែនជារបស់តូចតាចឡើយ បើបានឱកាសហើយ រមែងធ្វើឲ្យដល់សេចក្តីវិនាសដោយចំណែកមួយ ។ កិលេសដែលមានប្រមាណតិចកើតឡើងហើយបានឱកាស ក៏ចម្រើនឡើង រមែងញ៉ាំងសេចក្តីវិនាសយ៉ាងធំឲ្យកើតឡើងបានដូច្នោះឯង ។ ឈ្មោះថា កិលេសនេះ ប្រៀបដូចថ្នាំពិសដ៏ពន្លឹក ដូចគ្នានឹងបូសដែលមានស្បែករបកហើយ ដូចគ្នានឹងអាសិរពិស ដូចគ្នានឹងភ្លើងដែលកើតអំពីអសនីបាត មិនគួរត្រេកអរឡើយ គួរតែលះបង់ចោល ដោយកម្លាំងនៃការពិចារណា ដោយកម្លាំងនៃភាវនា ក្នុងខណៈដែលកើតនោះឯង គួរលះបង់ចោល ដោយការដែលគំនរកិលេសទាំងនោះ នឹងប្រាសទៅ មិនទាន់តាំងនៅក្នុងហទយៈ សូម្បីត្រឹមមួយរំពេច ដូចតំណក់ទឹករមៀលធ្លាក់ទៅអំពីស្លឹកឈូក ក៏ដូច្នោះ សូម្បីបណ្ឌិតទាំងឡាយក្នុងកាលមុន ក៏តិះដៀលកិលេសសូម្បីមានប្រមាណតិចតួច សង្កត់សង្កិនកិលេសមិនឲ្យកើតឡើងខាងក្នុងទៀតបានដូច្នោះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាចចក ស្នាក់នៅត្រង់ឆ្នេរស្ទឹង ក្បែរព្រៃ ។ គ្រានោះ ដំរីចាស់មួយក្បាល ដួលត្រង់ច្រាំងស្ទឹងគង្គា ចចកចេញរកចំណី ជួបសាកសពដំរីនោះ គិតថា ចំណីធំកើតដល់អញហើយ ទើបទៅត្រង់សាកសពនោះ ខាំត្រង់ប្រមោយ ក៏ដូចជាខាំយាមទង្គ័ល ចចកគិតថា ត្រង់នេះមិនគួរស៊ី ទើបខាំត្រង់ភ្លុកទាំងគូ ក៏ដូចជាខាំសសរ កាលខាំត្រចៀកសោត ក៏ដូចជាខាំកណ្តាប់ចង្អេរ ខាំត្រង់ពោះ ដូចជាខាំជង្រុកស្រូវ ខាំត្រង់ជើង ដូចជាខាំត្បាល់ ខាំត្រង់កន្ទុយ ដូចជាខាំអង្រែ ក៏ត្រិះរិះថា ក្នុងទីនេះមិនគួរស៊ី ។ លុះមិនបានទទួលការពេញចិត្តក្នុងអវយវៈទាំងពួង ក៏ខាំត្រង់វច្ចមគ្គ ក៏ហាក់ដូចជាខាំនំដែលទន់ ចចកត្រិះរិះថា ពេលនេះ អញបានទីដែលគួរបរិភោគដ៏ទន់ក្នុងសរីរៈនេះហើយ ទើបខាំត្រង់វច្ចមគ្គនោះ ចូលទៅខាងក្នុងផ្ទៃ ស៊ីថ្លើម និងបេះដូងជាដើម ពេលស្រេកទឹក ក៏ផឹកឈាម ពេលចង់ដេក ក៏យកផ្ទៃពោះ ( ដំរី ) ធ្វើជាដំណេក ។ គ្រានោះ ចចកមានបរិវិតក្កថា សាកសពដំរីនេះជាផ្ទះនៃអញជាទីនៅសប្បាយ កាលចង់ស៊ី ក៏មានសាច់គ្រប់គ្រាន់ អញនឹងទៅទីដទៃធ្វើអ្វី ទើបមិនព្រមទៅក្នុងទីដទៃទៀត នៅស៊ីសាច់ក្នុងពោះដំរីនោះឯង ។

ក្នុងកាលកន្លងទៅដល់រដូវប្រាំង សាកសពដំរីនោះ ក៏ក្រៀម ព្រោះត្រូវខ្យល់ និងកម្តៅព្រះអាទិត្យ រន្ធដែលចចកចូលទៅក៏បិទ ខាងក្នុងក៏ងងឹតប្រាកដដល់ចចក ដូចនៅក្នុងលោកន្តរនរក កាលសាកសពក្រៀមស្ងួត

*សាច់ក៏ក្រៀមទៅដែរ ឈាមក៏ខះអស់ ចចកមិនមានផ្លូវចេញ កើតនូវការភ័យខ្លាច ច្រេឆ្ឆាទៅមក ក្រវល់ក្រវាយរកផ្លូវចេញ កាលចចកជាប់នៅក្នុងពោះដំរីយ៉ាងនេះ ក៏ដូចគ្នានឹងដុំម្សៅនៅក្នុងឆ្នាំងបាយ ។ កន្លងមក ២-៣ ថ្ងៃ ភ្លៀងមួយមេធំក៏ធ្លាក់ កាលសាកសពនោះសើមដោយទឹកភ្លៀង ក៏រីកឡើងមានសណ្ឋានជាប្រក្រតី វច្ចមគ្គក៏បើក ប្រាកដដូចផ្កាយ ចចកឃើញប្រហោងនោះ គិតថា ពេលនេះ អញនឹងរួចបានពិត ដើរថយក្រោយរហូតដល់ក្បាលដំរី ស្ទុះទៅដោយរហ័ស យកក្បាលជល់វច្ចមគ្គចេញទៅបាន ព្រោះរាងកាយចចកស្គមស្គាំង រោមទាំងអស់ ក៏ជាប់ត្រង់វច្ចមគ្គនោះឯង ចចកមានចិត្តតក់ស្លុតដោយសរីរៈដែលមិនមានរោម ដូចដើមត្នោត រត់ទៅមួយសន្ទុះ អង្គុយមើលសរីរៈ សង្វេគថា ទុក្ខរបស់អញនេះ វត្ថុដទៃមិនបានធ្វើឡើយ តែព្រោះសេចក្ដីលោភជាហេតុ ព្រោះសេចក្ដីលោភជាការណៈ អញអាស្រ័យសេចក្ដីលោភ ញុំាងទុក្ខនេះឲ្យកើតឡើង ឥឡូវនេះ ចាប់អំពីនេះទៅ អញមិនព្រមធ្លាក់នៅក្នុងអំណាចនៃសេចក្ដីលោភ ឈ្មោះថា សាកសពដំរី ក៏អញមិនចូលទៅទៀតឡើយ ដូច្នេះហើយ ពោលគាថានេះថា*

*យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីញយៗ ទេ ព្រោះយើងត្រូវភ័យគំរាមហើយ ដូច្នោះ ។*

*ក្នុងគាថានោះ* **អ** *អក្ខរៈ ក្នុងបាទគាថាថា* **ឩ ចាបិ អបុនប្បុនំ** *ត្រឹមតែជានិបាត ក្នុងគាថាទាំងអស់នោះ មានអធិប្បាយដូច្នេះថា បន្ទាប់អំពីនេះទៅ*

អញមិនចូលទៅទៀតឡើយ បានដល់ អញមិនចូលទៅកាន់សរីរៈដ៏រី ក្រោយអំពីពោលថា មិនមានទៀតឡើយ ដូច្នេះ ព្រោះហេតុអ្វី ព្រោះពេលដែលនៅក្នុងពោះដ៏រី ត្រូវភ័យគំរាមស្ទើរស្លាប់ អធិប្បាយថា ព្រោះត្រូវភ័យក្នុងការចូលទៅទីនោះឯងគំរាមស្ទើរស្លាប់ គឺត្រូវដល់នូវការតក់ស្លុត ការភ័យខ្លាចព្រោះសេចក្តីស្លាប់ ។

ចចកនោះ កាលពោលយ៉ាងនេះហើយ ក៏គេចទៅមួយរំពេច ឈ្មោះថាសរីរៈដ៏រីនោះក្តី ( សរីរៈ ) ដទៃក្តី ចចកមិនបែរមើលទៀតឡើយ បន្ទាប់អំពីនោះ ចចកនោះ ក៏មិនធ្លាក់នៅក្នុងអំណាចនៃសេចក្តីលោភ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ត្រាស់ថាម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិលេសដែលកើតឡើងខាងក្នុង មិនត្រូវឲ្យចម្រើនឡើង គួរសង្កត់សង្កិនមួយរំពេចនោះឯង ហើយត្រាស់ប្រកាសសច្ចៈទាំងឡាយ ទ្រង់ប្រជុំជាតក ក្នុងកាលចប់សច្ចៈ ភិក្ខុទាំង ៥០០ រូប ក៏តាំងនៅក្នុងអរហត្តផល ក្នុងបណ្តាភិក្ខុដ៏សេសរូបខ្លះ ក៏បានជាព្រះសោតាបន្នរូបខ្លះបានជាព្រះសកទាគាមី រូបខ្លះបានជាព្រះអនាគាមី ហើយទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា សិង្គាលជាតកទី ៨ ចប់**

# សុត្តន្តបិដក

## ឯកបណ្ណជាតក

[ ១៤៩ ] *( ឥសីពោធិសត្វពោលថា ) ឈើនេះ ទើបតែនឹងមានស្លឹកតែមួយៗ ដុះអំពីផែនដី មិនទាន់ដល់ ៤ ធ្នាប់ មានផ្លែដូចជាថ្នាំពិសទៅហើយ ចំណាង់ឈើនេះធំឡើង នឹងដូចម្តេចទៅទៀត ។*

**ឯកបណ្ណជាតកទី ៩ ចប់**

# អដ្ឋកថា

## ឯកបណ្ណជាតក

[ ១៤៩ ] ព្រះសាស្ដា កាលទ្រង់អាស្រ័យនគរវេសាលី គង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទ្រង់ប្រារព្ធទុដ្ឋលិច្ឆវីកុមារ អ្នកនគរវេសាលី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឯកបណ្ណោ អយំ រុក្ខោ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងកាលនោះ នគរវេសាលី មានកំពែង ៣ ជាន់ ចម្ងាយមួយគាវុត ១ ប្រកបដោយបន្ទាយ និងប៉មក្នុងទីទាំង ៣ ដល់នូវភាពជានគរស្អាតក្រៃលែង ចំនួនព្រះរាជាសោយរាជសម្បត្តិជានិច្ចកាល ក្នុងព្រះនគរនោះសោត មានដល់ទៅ ៧៧០៧ អង្គ ឧបរាជក៏ប៉ុណ្ណោះដូចគ្នា សេនាបតី និងនាយឃ្លាំងមានចំនួនប៉ុណ្ណោះដែរ ក្នុងបណ្ដាឱរសរបស់ព្រះរាជាទាំងនោះ មានរាជកុមារមួយអង្គ ព្រះនាមទុដ្ឋលិច្ឆវី ជាអ្នកច្រើនដោយសេចក្ដីក្រោធ កាចគ្រោតគ្រាត ដូចពស់ដែលគេវាយដោយដំបង ឆេវឆាវជាប្រចាំ បុគ្គលដែលហ៊ានពោលពាក្យ ២-៣ ម៉ាត់ចំពោះ មុខរាជកុមារដោយអំណាចសេចក្ដីក្រោធ មិនមានទេ មាតាបិតា ព្រះញាតិ និងសម្លាញ់ ក៏មិនអាចអប់រំរាជកុមារនោះបាន ។

សម័យនោះ ព្រះមាតាបិតារបស់កុមារ មានបរិវិតក្កថា កុមារនេះគ្រោតគ្រាតក្រៃលែង ជាអ្នកឃោរឃៅ វៀរព្រះសម្មាសម្ពុទ្ធហើយ អ្នកដទៃដែលឈ្មោះថា អាចអប់រំបាន មិនមានឡើយ កុមារនេះប្រហែលជាពុទ្ធវេនេយ្យ ដូច្នេះហើយ ទើបនាំកុមារទៅកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំហើយ

ក្រាបទូលថា បពិត្រព្រះអង្គ កុមារនេះកាច គ្រោតគ្រាត ឆាបឆេះដោយសេចក្តីក្រោធ សូមទ្រង់ប្រទានឱវាទដល់កុមារនេះផងចុះ ព្រះសាស្តាទ្រង់ទូន្មានកុមារថា ម្នាលកុមារ អ្នកមិនគួរជាបុគ្គលកាច គ្រោតគ្រាត ឃោរឃៅគាប់ចិត្តក្នុងការគំរាម កំហែង ក្នុងពួកសត្វទាំងនេះឡើយ ឈ្មោះថា បុគ្គលមានវាចាគ្រោតគ្រាត តែងមិនជាទីស្រឡាញ់ ជាទីគាប់ចិត្តសូម្បីម្តាយបង្កើតបិតាបង្កើត បុត្រ ភរិយា ប្អូនប្រុស ប្អូនស្រី បងប្រុស បងស្រី ញាតិសាលោហិតឡើយ ជាទីតាំងនៃការតក់ស្លុត ដូចពស់ដែលលូនមកចឹក ដូចចោរដែលស្ទាក់ផ្លូវក្នុងព្រៃ ដូចយក្ខដែលកំពុងដើរមកចាប់ស៊ី ក្នុងវារៈចិត្តទី ២ រមែងកើតក្នុងនរកជាដើមបាន ក្នុងបច្ចុប្បន្ននោះសោត បុគ្គលក្រោធ ទោះបីប្រដាប់តាក់តែងស្អាតបាត ក៏មានពណ៌សម្បុរសៅហ្មងនោះឯង មុខមាត់សូម្បីមានសិរីដូចព្រះចន្ទពេញវង់ ក៏ដូចគ្នានឹងផ្កាឈូកដែលរោលដោយភ្លើង ដូចកញ្ចក់មាសដែលធូលីរុំព័ទ្ធ តែងខុសប្រក្រតី មិនគួរមើល ព្រោះថា សត្វទាំងឡាយអាស្រ័យសេចក្តីក្រោធ រមែងចាប់សស្ត្រាសម្លាប់ខ្លួនឯងខ្លះ ផឹកថ្នាំពិសខ្លះ ចង-កខ្លះ លោតពីលើភ្នំខ្លះ បើស្លាប់ដោយសេចក្តីក្រោធយ៉ាងនេះ ក៏រមែងកើតក្នុងអបាយភូមិ មាននរកជាដើម ទោះបីខ្លួនចូលចិត្តគំរាមកំហែងអ្នកដទៃសោត ក៏ត្រូវតិះដៀលក្នុងបច្ចុប្បន្ន កាលបែកធ្លាយទម្លាយខន្ធក៏ទៅកើតក្នុងនរកជាដើម ទោះបីវិលមកកើតជាមនុស្ស ក៏រមែងជាអ្នកមានរោគច្រើន តាំងអំពីកើតមកនោះឯង បណ្តារោគទាំងឡាយ មានរោគភ្នែករោគត្រចៀកជាដើម ចោមរោមបុគ្គលប្រភេទនេះ បុគ្គលនោះ មិនផុតអំពី

រោគសាហាវៗ នឹងត្រូវមានទុក្ខជាប្រចាំ ព្រោះហេតុនោះ គប្បីជាបុគ្គលមានចិត្តមេត្តា មានចិត្តទន់ភ្លន់ក្នុងសព្វសត្វ ព្រោះបុគ្គលបែបនេះ តែងរួចផុតចាកភ័យ មាននរកជាដើមបាន ដូច្នេះ ។ កុមារនោះស្តាប់ឱវាទរបស់ព្រះសាស្តាហើយ លះបង់មានះបានដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ជាអ្នកទូន្មានខ្លួនបានអស់នូវព្យសន៍កំណាច ជាអ្នកមានចិត្តមេត្តា មានចិត្តទន់ភ្លន់នោះឯង ទោះបីបុគ្គលដទៃជេរក្តី វាយក្តី មិនបានបែរមើល ដូចពស់ដែលត្រូវដកចង្កូម ដូចក្តាមដែលកាច់ដង្កៀប និងដូចគោដែលត្រូវកាត់ស្នែង ដូច្នោះ ។

ភិក្ខុទាំងឡាយ ជ្រាបព្រឹត្តិការណ៍របស់កុមារនោះហើយ ទើបលើករឿងឡើងអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ មាតា បិតា ញាតិ និងសម្លាញ់ជាដើម មិនអាចទូន្មានលិច្ឆវីកុមារដែលកាចអស់កាលដ៏យូរ តែព្រះសម្មាសម្ពុទ្ធ ទ្រង់ទូន្មានដោយឱវាទម្តងប៉ុណ្ណោះ ក៏ទ្រង់ធ្វើហេតុ គឺការឲ្យនៅក្នុងព្រំដែនដែលត្រឹមត្រូវបាន ដូចហត្ថាចារ្យទូន្មានដំរីដែលចុះប្រេង ឲ្យអស់ព្យសន៍កំណាច ដូច្នោះ សមដូចពុទ្ធភាសិត ( ក្នុងមជ្ឈិមនិកាយ ឧបរិ-បណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មាន ដែលទម័កដំរីបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ សេះគួរទូន្មាន ។បេ។ គោគួរទូន្មាន ។បេ។ ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសគួរទូន្មាន ដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ បាន គឺបុគ្គលបាននូវរូបជ្ឈានតែងមើលឃើញនូវរូបទាំងឡាយ នេះជាទិស

ទី ១ ។បេ។ ពាក្យណាថា បុគ្គលនោះ តថាគតហៅថាជាសារថី អ្នកទូន្មាននូវបុរស ជាអាចារ្យប្រសើរជាងអាចារ្យអ្នកទូន្មាននូវវាហនៈ មានដំរីជាដើម ដូច្នេះ ។ អាវុសោទាំងឡាយ ឈ្មោះថា បុគ្គលទូន្មាននូវបុរសដែលគួរទូន្មាន ស្មើដូចព្រះសម្មាសម្ពុទ្ធ មិនមានដោយពិត ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នា ដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតទូន្មានកុមារនេះបាន ដោយឱវាទត្រឹមតែម្ដងសូម្បីក្នុងកាលមុន តថាគតក៏បានទូន្មានកុមារនេះ ដោយឱវាទម្ដងដូចគ្នា ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ រៀនត្រៃវេទ និងសិប្បវិទ្យាសព្វយ៉ាង ក្នុងនគរតក្កសិលា នៅគ្រប់គ្រងផ្ទះអស់កាលបន្តិចបន្តួច កាលមាតាបិតាអនិច្ចកម្មទៅ ក៏បួសជាឥសី ធ្វើអភិញ្ញា និងសមាបត្តិឲ្យកើតហើយ នៅអាស្រ័យក្នុងព្រៃហិមពាន្ត កាលនៅក្នុងព្រៃនោះយូរ ក៏ទៅកាន់ជនបទដើម្បីបរិភោគរសជូរប្រៃ ក៏ដល់នគរពារាណសី អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ។ ពេលព្រឹក ស្លៀកដណ្ដប់រៀបរយហើយ សម្បូរដោយមារយាទរបស់តាបស ចូលកាន់នគរដើម្បីភិក្ខារ ដើរទៅកាន់លានព្រះរាជវាំង ។

ព្រះរាជាកំពុងទតតាមបង្អួច ឃើញតាបសហើយ ទ្រង់ជ្រះថ្លាក្នុងឥរិយា-

បថ ទ្រង់ត្រិះរិះថា តាបសនេះមានឥន្ទ្រិយល្អ មានចិត្តស្ងប់ មានភ្នែកដាក់ចុះត្រឹមមួយជួរទឹម ដើរមក ដោយលីលាអង់អាចដូចរាជសីហ៍ ហាក់បីដូចដាក់បន្ទិចទ្រព្យ ១០០០ គ្រប់ជំហាន បើមានសភាវៈដែលឈ្មោះថា សន្តធម៌ណាមួយ សន្តធម៌នោះ ត្រូវមានក្នុងតាបសនេះ ហើយទ្រង់ទតមើលអមាត្យម្នាក់ អមាត្យនោះក្រាបទូលថា ទូលបង្គំត្រូវធ្វើដូចម្តេច ព្រះរាជាត្រាស់ថា ចូរឯងនិមន្តតាបសនោះមក ។ អមាត្យទទួលព្រះតម្រាស់ថា សាធុ ចូលទៅរកព្រះពោធិសត្វ ថ្វាយបង្គំហើយ ទទួលភាជនៈដាក់កិច្ចាអំពីដៃព្រះពោធិសត្វ កាលព្រះពោធិសត្វពោលថា នែអ្នកមានបុណ្យច្រើន មានរឿងអ្វីឬ ក៏ពិតថា បពិត្រលោកម្ចាស់ ព្រះរាជាត្រាស់ឲ្យនិមន្តលោកម្ចាស់ ព្រះពោធិសត្វពោលថា អាត្មាមិនមែនអ្នកបួសប្រចាំរាជសម្នាក់ ជាអ្នកបួសនៅព្រៃហិមពាន្ត អមាត្យទៅក្រាបទូលសេចក្តីនោះដល់ព្រះរាជាៗ ត្រាស់ថា តាបសដទៃដែលជិតស្និទ្ធរបស់យើង មិនមានទេ ចូរនិមន្តលោកមកចុះ អមាត្យក៏ទៅថ្វាយបង្គំព្រះពោធិសត្វ និមន្តឲ្យចូលកាន់ព្រះរាជវាំង ។ ព្រះរាជាថ្វាយបង្គំព្រះពោធិសត្វ និមន្តឲ្យគង់លើបល្ល័ង្កមាស ខាងក្រោមស្វេតច្ឆត្រ ឲ្យឆាន់ភោជនមានរសដ៏ប្រសើរផ្សេងៗ ដែលគេរៀបចំដើម្បីព្រះអង្គ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ៗ នៅឯណា ព្រះពោធិសត្វថ្វាយព្រះពរថា មហាបពិត្រ អាត្មានៅព្រៃហិមពាន្ត ព្រះរាជាត្រាស់ថា ឥឡូវនេះ លោកម្ចាស់នៅឯណា តាបសថ្វាយព្រះពរថា មហាបពិត្រ អាត្មាកំពុងសម្លឹងក្នុងសេនាសនៈ ដែលសមគួរដល់រដូវភ្លៀង ក៏ត្រាស់ថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់

នៅក្នុងឧទ្យានរបស់ញោមចុះ ព្រះរាជាឲ្យតាបសកាន់យកពាក្យប្តេជ្ញាហើយ ទ្រង់ក៏សោយស្រេច ទ្រង់នាំព្រះពោធិសត្វទៅកាន់ឧទ្យាន ឲ្យសាងបណ្ណ-សាលា ឲ្យធ្វើទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ទ្រង់ថ្វាយបរិក្ខារ សម្រាប់បព្វជិត ទ្រង់ចាត់ចែងឲ្យអ្នកយាមឧទ្យានឃ្លាំមើលថែរក្សា ហើយ យាងចូលព្រះនគរ ។

តាំងអំពីពេលនោះ ព្រះពោធិសត្វក៏នៅក្នុងឧទ្យាន សូម្បីព្រះរាជាក៏យាង ទៅរកមួយថ្ងៃពីរបីដង រាល់ៗ ថ្ងៃ ។ ព្រះរាជាទ្រង់មានឱរសព្រះនាមទុដ្ឋកុមារ ជាអ្នកមាននិស្ស័យកាច គ្រោតគ្រាត ព្រះរាជា និងញាតិទាំងឡាយ ក៏មិន អាចទូន្មានអប់រំបាន ពួកអមាត្យក្តី ពួកព្រាហ្មណ៍ និងគហបតីក្តី សូម្បីរួមគ្នា ពោលជំទាស់ថា បពិត្រព្រះរាជកុមារ សូមទ្រង់កុំធ្វើយ៉ាងនេះ ទ្រង់មិនគួរធ្វើ យ៉ាងនេះ ក៏មិនអាចឲ្យព្រះរាជកុមារស្តាប់ពាក្យបានឡើយ ។ ព្រះរាជាទ្រង់ ព្រះតម្រិះថា វៀរតាបសដែលទ្រទ្រង់សីលរបស់អញចេញហើយ អ្នកដទៃ ឈ្មោះថា អាចទូន្មានកុមារនេះបាន មិនមានទេ លោកម្ចាស់ប៉ុណ្ណោះ នឹង ទូន្មានកុមារនេះបាន ។ ព្រះរាជាទ្រង់នាំព្រះរាជកុមារទៅកាន់សម្នាក់ព្រះពោធិ-សត្វ ត្រាស់ថា បពិត្រលោកម្ចាស់ កុមារនេះកាច រឹងត្អឹង ពួកខ្ញុំមិនអាចអប់រំ ទូន្មានបានទេ សូមលោកម្ចាស់រកឧបាយណាមួយ អប់រំផងចុះ ដូច្នេះហើយ ទ្រង់ប្រគល់កុមារដល់ព្រះពោធិសត្វ ហើយចៀសចេញទៅ ព្រះពោធិសត្វ បបួលព្រះរាជកុមារត្រាច់ទៅក្នុងឧទ្យាន ឃើញពន្លកស្តៅមួយដើម ទើបតែ មានស្លឹក ២ ប៉ុណ្ណោះ គឺម្ខាងមួយសន្លឹក ទើបពោលនឹងព្រះរាជកុមារថា

បពិត្រព្រះរាជកុមារ សូមទ្រង់ទំពាស្លឹកស្ដៅនេះ ហើយចងចាំរសទុកចុះ ។ ព្រះរាជកុមារទ្រង់ទំពាស្លឹកស្ដៅមួយសន្លឹក ដឹងរសហើយ ត្រាស់ថា ថ្វីយ ថ្វីយ ស្ដោះចោលត្រង់ផែនដី មួយអន្លើដោយទឹកមាត់ កាលតាបសពោលថា នែកុមារ តើដូចម្ដេចដែរ ក៏ប្រាប់តាបសថា បពិត្រលោកម្ចាស់ ដើមឈើនេះ ប្រៀបដូចថ្នាំពិសដ៏ខ្លាំងក្លា ឥឡូវនេះ បើធំឡើង គង់នឹងសម្លាប់មនុស្សជាច្រើន ពោលបណ្ដើរ ទ្រង់ដកពន្លកស្ដៅនោះបណ្ដើរ ហើយញីរហូតខ្ទេចខ្ទី ដោយព្រះហស្ដ ត្រាស់គាថានេះថា

ឈើនេះ ទើបតែនឹងមានស្លឹកតែមួយៗ ដុះអំពីផែនដី មិនទាន់ដល់ ៤ ធ្នាប់ មានផ្លែដូចជាថ្នាំពិសទៅហើយ ចំណង់ឈើនេះធំឡើង នឹងដូចម្ដេចទៅទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកបណ្ណោ** សេចក្ដីថា មានស្លឹកម្ខាងមួយសន្លឹក ។

បទថា **ន ភូម្យា ចតុរង្គុលោ** សេចក្ដីថា ដើមឈើនេះ ដុះចេញអំពីផែនដីមិនដល់ ៤ ធ្នាប់ ។

បទថា **ផលេន** បានដល់ រសដែលកើតអំពីផ្លែ ។

បទថា **វិសកប្បេន** បានដល់ មានរសជាតិដូចថ្នាំពិសដ៏ខ្លាំងក្លា អធិប្បាយថា ស្ដៅដើមតូចយ៉ាងនេះ ក៏ប្រកបដោយស្លឹក មានរសល្វីងយ៉ាងនេះ ។

បទថា **មហាយំ កឹ ភវិស្សតិ** សេចក្ដីថា ដើមឈើនេះដល់នូវសេចក្ដី

ចម្រើន គឺចម្រើនឡើងកាលណា កាលនោះ តើនឹងទៅជាយ៉ាងណា ដើមឈើនេះ នឹងត្រូវសម្លាប់មនុស្សបានពិត ព្រះរាជកុមារដកដើមឈើនោះ ហើយត្រាស់ថា អញនឹងត្រូវឈ្លីចោល ។

លំដាប់នោះ ទើបព្រះពោធិសត្វពោលពាក្យនេះ នឹងព្រះរាជកុមារថា បពិត្រព្រះរាជកុមារ ទ្រង់ពោលដល់ពន្លកស្ដៅនេះថា ឥឡូវនេះ ដើមឈើនេះ គង់ល្វីងដល់ម្ល៉េះ បើវាធំ នឹងទៅជាយ៉ាងណា អាស្រ័យវាហើយ នឹងមានសេចក្ដីចម្រើនមកអំពីណា ដូច្នេះហើយ ដកប្របាច់ចោល ទ្រង់បដិបត្តិក្នុងពន្លកស្ដៅនេះ យ៉ាងណា សូម្បីអ្នកនគររបស់ទ្រង់ ក៏គង់ធ្វើដូច្នោះ នឹងនាំគ្នាពោលថា ព្រះរាជកុមារនេះ នៅតូចសោះ គង់កាចរឹងត្អឹងយ៉ាងនេះ កាលចម្រើនធំធាត់ គ្រងរាជសម្បត្តិ នឹងទៅជាយ៉ាងណា ពួកយើងអាស្រ័យទ្រង់ នឹងចម្រើនបានដូចម្ដេច ហើយមិនថ្វាយរាជសម្បត្តិ ដែលជារបស់ត្រកូលនៃទ្រង់ នឹងដកទ្រង់ចោលដូចពន្លកស្ដៅ រួចធ្វើការបណ្ដេញចេញអំពីដែន ព្រោះដូច្នោះ សូមទ្រង់វៀរនូវការធ្វើខ្លួនឲ្យដូចជាដើមស្ដៅចេញ សូមទ្រង់ដល់នូវការអត់ធន់ មេត្តា និងការអើពើ តាំងអំពីឥឡូវនេះចុះ ។ តាំងពីកាលនោះមក ព្រះរាជកុមារក៏អស់មានះ អស់ព្យសន៍ សម្បូរដោយខន្តីមេត្តា និងការអើពើ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ កាលព្រះជនកសោយទិវង្គតហើយ ក៏បានគ្រងរាជសម្បត្តិ ទ្រង់បំពេញបុណ្យ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតទូន្មានទុដ្ឋលិច្ឆវីកុមារនេះបាន សូម្បីក្នុងកាលមុន តថាគតក៏ធ្លាប់ទូន្មានដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ទុដ្ឋកុមារក្នុងកាលនោះ បានមកជាទុដ្ឋលិច្ឆវីកុមារក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ តាបសអ្នកឲ្យឱវាទក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឯកបណ្ណជាតក ចប់**

# សុត្តន្តបិដក

## សញ្ជីវជាតក

[ ១៥០ ] ( អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា ) បុគ្គលណា លើកតម្កើងនូវជន ជាអសប្បុរសផង ចូលទៅសេពគប់នូវជន ជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវបុគ្គលនោះឯង ឲ្យទៅជាអាហារ ដូចខ្លា និងសញ្ជីវមាណព ។

សញ្ជីវជាតកទី ១០ ចប់

កកណ្តកវគ្គទី ១៥ ចប់

### ឧទ្ទាននៃកកណ្តកវគ្គនោះ គឺ

និយាយអំពីបុគ្គលដល់នូវសេចក្តីសុខ ១ ដំបងប្រសើរ ១ ខ្នូរក្បាល ១ កន្ទុយ ១ សេកឈ្មោះរាធៈដ៏ប្រសើរជាគម្រប់ប្រាំ ១ សមុទ្រ ១ មហោស្រពខែកត្តិក ១ ពោះដំរី ១ ឈើដុះ ៤ ធ្នាប់ ១ ខ្លាដ៏ប្រសើរ ១ ត្រូវជា ១០ ។

### ឧទ្ទាននៃវគ្គមានក្នុងឯកនិបាតនោះ គឺ

អបណ្ណកវគ្គ ១ សីលវគ្គ ១ កុរុង្គវគ្គ ១ កុលាវកវគ្គ ១ អត្ថកាមវគ្គជាគម្រប់ប្រាំ ១ អសីសវគ្គ ១ ឥត្ថីវគ្គ ១ វរុណវគ្គ ១ អបាយិម្ហវគ្គ ១ លិត្តវគ្គ ១ ត្រូវជា ១០ បរោសតវគ្គ ១ ហំសិវគ្គ ១ កុសនាឡិវគ្គ ១ អសម្បទានវគ្គ ១ កកណ្តកវគ្គ ១ ក្នុងឯកនិបាតប្រជាប់ ( ដោយវគ្គដូច្នេះឯង ) ។

ឯកនិបាត ចប់

# អដ្ឋកថា

## សញ្ជីវជាតក

[ ១៥០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលើកតម្កើងអសប្បុរសរបស់ព្រះបាទអជាតសត្រូវ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសន្តំ យោ បគ្គណ្ហាតិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះបាទអជាតសត្តុនោះ ទ្រង់ជ្រះថ្លាក្នុងទេវទត្តដែលជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជាចម្រូងចំពោះព្រះពុទ្ធអង្គ និងពុទ្ធសាវក ទ្រង់លើកតម្កើងទេវទត្តនោះ ដែលជាអ្នកមិនស្ងប់រម្ងាប់ ជាអសប្បុរស ទ្រង់ព្រះតម្រិះថា នឹងធ្វើសក្ការៈដល់ទេវទត្ត ដូច្នេះហើយ ទ្រង់បរិច្ចាគទ្រព្យជាច្រើនឲ្យសាងវិហារ ត្រង់គាយាសីសបទេស ទ្រង់ស្តាប់ពាក្យរបស់ទេវទត្ត សម្រេចទោស ( ផ្តាច់ព្រះជន្ម ) ព្រះបិតា ដែលជាព្រះរាជាតាំងនៅក្នុងធម៌ ជាព្រះអរិយសាវកថ្នាក់សោតាបន្ន កាត់ផ្តាច់នូវឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ខ្លួន ដល់នូវសេចក្តីវិនាសធំ ។ កាលទ្រង់ឮថា ទេវទត្តត្រូវផែនដីស្រូប ក៏រន្ធត់ព្រះហឫទ័យថា អញត្រូវផែនដីស្រូបដែរឬទេហ្ន៎ មិនបាននូវសេចក្តីសុខក្នុងរាជសម្បត្តិ មិនបានជួបនូវសេចក្តីត្រេកអរលើទែនបន្ទំ ទ្រង់តក់ស្លុតត្រាច់ទៅ ដូចប្រេតដែលត្រូវទារុណកម្មដ៏ខ្លាំងក្លា ។ ព្រះរាជានឹកឃើញហាក់ដូចកំពុងត្រូវផែនដីស្រូប ដូចអណ្តាតភ្លើងក្នុងអវីចីកំពុងលៀនចេញមក និងដូចទ្រង់កំពុងផ្ទំផ្ងារលើផែនដីដែកដែលក្តៅ ហើយត្រូវចាក់ដោយលំពែងដែកដូច្នោះ ដោយហេតុនោះ ឈ្មោះថា ការស្ងប់ព្រះហឫទ័យ សូម្បីត្រឹមមួយរំពេច ក៏មិនមានដល់ទ្រង់ជាអ្នកតក់ស្លុត ដូចមាន់ដែលត្រូវអារ-ក ។ ព្រះ

រាជាមានព្រះបំណងនឹងគាល់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបំណងឲ្យព្រះសម្ពុទ្ធទ្រង់អត់ទោស និងមានបំណងទូលសួរបញ្ហា ព្រោះទ្រង់មានកំហុសយ៉ាងធំ ទើបមិនអាចចូលគាល់បាន ។

កាលនោះ នគររាជគ្រឹះ មានបុណ្យនក្ខត្តឫក្សប្រចាំខែកត្តិក មហាជននាំគ្នារៀបចំនគរ ហាក់ដូចទេវនគរ ព្រះបាទអជាតសត្រូវចោមរោមដោយពួកអមាត្យ ប្រថាប់គង់លើព្រះរាជអាសនៈមាសត្រង់ផ្ទៃប្រាសាទ ទតឃើញជីវកកោមារភច្ច អង្គុយគាល់មិនឆ្ងាយ ទ្រង់មានបរិវិតក្កថា អញនឹងបបួលពេទ្យជីវកទៅគាល់ព្រះសម្មាសម្ពុទ្ធ តែអញមិនអាចបបួលត្រង់ៗ បានថា ជីវកសម្លាញ់ យើងមិនអាចទៅតាមទំនើងចិត្តបាន សូមអ្នកជួយនាំយើងទៅគាល់ព្រះសាស្ដាផងចុះ ដូច្នេះ ត្រូវពណ៌នាដល់លម្អនៃរាត្រីដល់ជីវកកោមារភច្ចដោយបរិយាយដ៏ច្រើន ហើយសឹមពោលថា ធ្វើម្ដេចហ្ន៎ ថ្ងៃនេះ ពួកយើងនឹងចូលទៅរកសមណៈ ឬព្រាហ្មណ៍ កាលយើងចូលទៅរកលោក គប្បីបាននូវចិត្តជ្រះថ្លា ស្ដាប់ពាក្យនោះហើយ ពួកអមាត្យនឹងនាំគ្នាពណ៌នាគុណគ្រូទាំង-ឡាយរបស់ខ្លួន សូម្បីពេទ្យជីវកក៏គង់ពណ៌នាគុណរបស់ព្រះសម្មាសម្ពុទ្ធ កាលបើដូច្នោះ អញនឹងបបួលពេទ្យជីវកទៅកាន់សម្នាក់ព្រះសាស្ដា ដូច្នេះ ទើបព្រះរាជាពណ៌នារាត្រីកាលដោយបទទាំង ៥ ( ដែលមាននៅក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ដូច្នេះថា

រាត្រីប្រាសចាកទោស ( ស្ងាត់រុងរឿង ) គួរជាទីត្រេកអរអ្វីម្ល៉េះហ្ន៎
រាត្រីប្រាសចាកទោស មានភាពល្អអ្វីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស

គួរជាទីរមិលមើលអ្វីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស ជាទីនាំមកនូវសេចក្តីជ្រះថ្លាអ្វីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស គួរជាទីកំណត់ដឹងអ្វីម្ល៉េះហ្ន៎ ក្នុងថ្ងៃនេះ តើយើងគប្បីចូលទៅរកសមណៈ ឬព្រាហ្មណ៍ណាហ្ន៎ យើងចូលទៅអង្គុយជិតបុគ្គលណា ទើបនឹងមានចិត្តជ្រះថ្លាបាន ដូច្នេះ ។

កាលនោះ អមាត្យម្នាក់ពោលដល់គុណរបស់បូរណកស្សបៈ អមាត្យម្នាក់ពោលដល់គុណរបស់មក្ខលិគោសាល អមាត្យម្នាក់ពោលដល់គុណនៃអជិតកេសកម្ពល អមាត្យម្នាក់ពោលដល់គុណបកុទ្ធកច្ចាយនៈ អមាត្យម្នាក់ពោលដល់គុណសញ្ជយវេលដ្ឋបុត្រ អមាត្យម្នាក់ពោលដល់គុណរបស់និគ្គណ្ឋនាដបុត្រ ។ ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់អមាត្យទាំងនោះហើយ ទ្រង់តុណ្ហីភាព ព្រោះទ្រង់ប្រាថ្នានូវពាក្យរបស់ពេទ្យជីវកប៉ុណ្ណោះ ។ ឯពេទ្យជីវកត្រិះរិះថា បើព្រះរាជាត្រាស់សួរអញនោះឯង អញនឹងក្រាបទូល ហើយក៏អង្គុយក្នុងទីមិនឆ្ងាយ ។ គ្រានោះ ព្រះរាជាត្រាស់ថា ជីវកសម្លាញ់ ហេតុអ្វីទើបអ្នកនៅស្ងៀម ខណៈនោះ ជីវកក៏ក្រោកចាកអាសនៈ ផ្គងអញ្ជលីទៅកាន់ទិសដែលព្រះសាស្តាគង់នៅ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងចម្ការស្វាយរបស់ទូលបង្គំ ជាមួយនឹងភិក្ខុ ១២៥០ រូប កិត្តិសព្ទដ៏រុងរឿងនេះរបស់ព្រះមានព្រះភាគអង្គនោះ ល្បីខ្ទរខ្ទារទៅហើយ ទ្រង់ប្រកាសបាដិហារ្យ ៩០០ ប្រការ អានុភាពរបស់ព្រះសាស្តា មានបុព្វនិមិត្ត តាំងអំពីប្រសូតជាដើមរៀងមក រួច

ក្រាបទូលថា សូមទ្រង់យាងចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ស្ដាប់ធម៌ សួរបញ្ហាចុះ ។ ព្រះរាជាទ្រង់មានមនោរថពេញបរិបូណ៌ ត្រាស់ថា ជីវក សម្លាញ់ បើដូច្នោះ ចូរអ្នករៀបចំដំរីចុះ ។ កាលត្រាស់ឲ្យរៀបចំពាហនៈដំរី ហើយ ស្ដេចយាងទៅកាន់ជីវកម្ពវ័ន ដោយរាជានុភាពធំ ទតឃើញព្រះតថាគត ចោមរោមដោយពួកភិក្ខុត្រង់រោងមូល ក្នុងជីវកម្ពវ័ននោះ ទ្រង់ទតមើលពួក ភិក្ខុ ដែលប្រាសចាកការកម្រើក ហាក់បីដូចមហានាវាកណ្ដាលសមុទ្រ ដែល មានរលកស្ងប់ហើយ ដូច្នោះ ព្រះរាជាជ្រះថ្លាក្នុងឥរិយាបថនោះឯង ទ្រង់ ត្រិះរិះថា បរិស័ទដល់ម្ល៉េះ អញមិនធ្លាប់ឃើញឡើយ ទ្រង់ផ្គងអញ្ជលីដល់ ព្រះសង្ឃ ទ្រង់ត្រាស់សរសើរ ថ្វាយបង្គំព្រះមានព្រះភាគ ប្រថាប់គង់ក្នុងទី សមគួរ នាចំណែកម្ខាង ទូលសួរបញ្ហាក្នុងសាមញ្ញផល ។ គ្រានោះ ព្រះ មានព្រះភាគ ទ្រង់សម្ដែងសាមញ្ញផលសូត្រ ប្រដាប់ដោយភាណវារ ២ ភាណវារដល់ព្រះរាជា ក្នុងកាលចប់ព្រះសូត្រ ព្រះរាជាសប្បាយព្រះហឫទ័យ ទូលសូមឲ្យព្រះសាស្ដាអត់ទោស ទ្រង់ក្រោកអំពីអាសនៈ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។

កាលព្រះរាជាយាងទៅហើយមិនយូរ ព្រះសាស្ដា ត្រាស់ហៅភិក្ខុទាំង- ឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះជីកឫសគល់ហើយ បើទ្រង់មិនផ្ដាច់ព្រះជន្មព្រះរាជបិតា ដែលប្រកបដោយធម៌ ជាធម្មរាជា ព្រោះ ប្រាថ្នាភាពជាធំសោត ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិល នឹងកើត ក្នុងខណៈប្រថាប់គង់នេះឯង តែទ្រង់អាស្រ័យទេវទត្ត លើកតម្កើងអសប្បុរស

ទើបវិនាសចាកសោតាបត្តិផល ។ ស្អែកឡើង ភិក្ខុទាំងឡាយលើករឿងឡើង អង្គុយសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ព្រះបាទអជាតសត្តុ សាបសូន្យចាកសោតាបត្តិផល ព្រោះធ្វើការលើកតម្កើងអសប្បុរស អាស្រ័យទេវទត្តដែលជាអ្នកទ្រុស្តសីល មានបាបធម៌ ទ្រង់ធ្វើបិតុឃាតកម្ម ជាព្រះរាជាដែលទេវទត្តធ្វើឲ្យវិនាសហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលព្រះបាទអជាតសត្តុលើកតម្កើងអសប្បុរស ដល់នូវការវិនាសធំ សូម្បីក្នុងកាលមុន ទ្រង់ក៏បំផ្លាញខ្លួនឯង ដោយការលើកតម្កើងអសប្បុរសដូចគ្នា ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិច្រើន ចម្រើនវ័យហើយ ទៅកាន់នគរតក្កសិលា រៀនសិប្បវិទ្យាសព្វយ៉ាង បានជាអាចារ្យទិសាបាមោក្ខ ក្នុងនគរពារាណសី បង្រៀនសិប្បៈដល់មាណព ៥០០ នាក់ ក្នុងមាណពទាំងនោះ មានមាណពម្នាក់ឈ្មោះសញ្ជីវៈ ព្រះពោធិសត្វបានឲ្យមន្ត ធ្វើមនុស្សស្លាប់ ឲ្យជីងខ្លួនមួយស្របក់ដល់មាណព ។ មាណពរៀនមន្តធ្វើមនុស្សស្លាប់ឲ្យជីងខ្លួនមួយស្របក់តែម្យ៉ាង មិនបានរៀនមន្តសម្រាប់ការពារ ។ ថ្ងៃមួយ ទៅព្រៃរកឧសជាមួយសម្លាញ់ ឃើញខ្លាមួយស្លាប់ ក៏ពោលនឹងពួក

មាណពថា អ្នកទាំងឡាយ ខ្ញុំនឹងធ្វើខ្លាស្លាប់នេះ ឲ្យដឹងខ្លួនឡើង មាណពទាំងឡាយពោលជំទាស់ថា អ្នកមិនអាចទេ បុរសនោះពោលថា ខ្ញុំនឹងធ្វើឲ្យវាដឹងខ្លួនឡើង ឲ្យពួកអ្នកឃើញគ្រប់គ្នា ពួកមាណពទាំងនោះពោលថា បើអ្នកអាច ក៏ចូរប្រោសវាឲ្យដឹងខ្លួនចុះ កាលពោលហើយ ក៏រូតរះឡើងដើមឈើ សញ្ជីវមាណពរាយមន្តហើយ គ្រវែងខ្លាដោយដុំក្រួស ខ្លាក្រោកឡើង លោតខាំសញ្ជីវមាណព ត្រង់បំពង់ក ធ្វើឲ្យអស់ជីវិត ដួលចុះត្រង់ទីនោះឯង ជនទាំង ២ ដេកស្លាប់ក្នុងទីតែមួយ ពួកមាណពនាំគ្នាជញ្ជូនឧសទៅហើយ ប្រាប់ការប្រព្រឹត្តទៅនោះដល់អាចារ្យៗ ក៏ហៅមាណពទាំងឡាយមក ពោលថា បាទាំងឡាយ ឈ្មោះថា បុគ្គលដែលលើកតម្កើងអសប្បុរស ធ្វើសក្ការៈ និងសេចក្តីស្និទ្ធស្នាលក្នុងទីដែលមិនសមគួរ រមែងបានទទួលទុក្ខបែបនេះ ហើយពោលគាថានេះថា

បុគ្គលណា លើកតម្កើងនូវជនជាអសប្បុរសផង ចូលទៅសេព
គប់នូវជនជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវ
បុគ្គលនោះឯង ឲ្យទៅជាអាហារ ដូចខ្លា និងសញ្ជីវមាណព ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសន្តំ** បានដល់ បុគ្គលទ្រុស្តសីល មានបាបធម៌ ប្រកបដោយទុច្ចរិតទាំង ៣ ប្រការ ។

បទថា **យោ បគ្គណ្ហាតិ** សេចក្តីថា បណ្តាជន មានក្សត្រជាដើម ជនណាម្នាក់លើកតម្កើង គឺធ្វើសក្ការៈ សេចក្តីស្និទ្ធស្នាល អសប្បុរសដែលទ្រុស្តសីលបែបនេះ ដែលជាបព្វជិត ដោយការប្រគេនបច្ច័យ មានចីវរជាដើម

ដែលជាគ្រហស្ថ ដោយការឲ្យគ្រប់គ្រងតំណែងឧបរាជ និងសេនាបតីជាដើម ។

បទថា **អសន្តំ ចូបសេវតិ** សេចក្តីថា ម្យ៉ាងទៀត បុគ្គលណា រមែងចូលទៅសេព ចូលទៅគប់រក ចូលទៅស្និទ្ធស្នាលអសប្បុរសដែលទ្រុស្តសីលបែបនេះ ។

បទថា **តមេវ ឃាសំ កុរុតេ** សេចក្តីថា បុគ្គលអាក្រក់ ទ្រុស្តសីលនោះរមែងខាំ គឺរមែងទំពាស៊ី បានដល់ រមែងធ្វើអសប្បុរសនោះឯង ឲ្យដល់នូវសេចក្តីវិនាស ។ សួរថា វិនាសដូចម្តេច ឆ្លើយថា ដូចខ្លាដែលមានជីវិតព្រោះមាណពព្រោសឡើង អធិប្បាយថា ខ្លាដែលស្លាប់ មានជីវិតដោយសញ្ជីវ-មាណពរាយមន្ត លើកតម្កើងដោយការប្រគល់ជីវិតឲ្យ បែរជាផ្តាច់ជីវិតសញ្ជីវមាណពដែលឲ្យជីវិតដល់ខ្លួន ឲ្យដួលចុះក្នុងទីនោះឯង យ៉ាងណាបុគ្គលដទៃក៏ដូច្នោះ បុគ្គលណា ធ្វើនូវការលើកតម្កើងអសប្បុរសៗ ទ្រុស្ត-សីលនោះ រមែងបំផ្លាញបុគ្គលដែលលើកតម្កើងខ្លួននោះឯង ពួកជនដែលលើកតម្កើងអសប្បុរស រមែងដល់នូវសេចក្តីវិនាស ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វ សម្ដែងធម៌ដល់មាណពទាំងឡាយដោយគាថានេះ ធ្វើនូវបុណ្យ មានទានជាដើម ហើយទៅតាមយថាកម្ម ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មាណពដែលធ្វើខ្លាស្លាប់ ឲ្យដឹងខ្លួនមួយស្របក់ក្នុងកាលនោះ បានមកជាព្រះបាទ អជាតសត្តុក្នុងកាលឥឡូវនេះ ឯអាចារ្យទិសាបាមោក្ខ ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សញ្ជីវជាតក ចប់**

**កកណ្ដកវគ្គ ចប់**

**ឯកនិបាត ចប់**

# ក្បាលទី ៤៥

# សុត្តន្តបិដក ចាលីប្រែ –៥៨

សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

## អបណ្ណកវគ្គ


អបណ្ណកជាតក ...... ...... ...... ...... ២

ទូរេនិទាន ...... ...... ...... ..... ៣

អវិទូរេនិទាន ...... ...... ...... ...... ១០០

សន្តិកេនិទាន ...... ...... ...... ...... ១៥៧

អដ្ឋកថាអបណ្ណកជាតក ...... ...... ...... ...... ១៩៧

វណ្ណុបថជាតក ...... ...... ...... ...... ២២១

អដ្ឋកថាវណ្ណុបថជាតក ...... ...... ...... ...... ២២២

សេរិវវាណិជជាតក ...... ...... ...... ...... ២៣១

អដ្ឋកថាសេរិវវាណិជជាតក ...... ...... ...... ...... ២៣២

ចុល្លកសេដ្ឋិជាតក ...... ...... ...... ...... ២៣៨

អដ្ឋកថា ចុល្លកសេដ្ឋិជាតក ...... ...... ...... ...... ២៣៩

តណ្ឌុលនាឡិជាតក ...... ...... ...... ...... ២៥៦

អដ្ឋកថាតណ្ឌុលនាឡិជាតក ...... ...... ...... ...... ២៥៧

ទេវធម្មជាតក ...... ...... ...... ...... ២៦៣

អដ្ឋកថាទេវធម្មជាតក ...... ...... ...... ...... ២៦៤

កដ្ឋហារិជាតក ...... ...... ...... ...... ២៨០

អដ្ឋកថាកដ្ឋហារិជាតក ...... ...... ...... ...... ២៨១

គាមណិជាតក ...... ...... ...... ...... ២៨៧

អដ្ឋកថាគាមណិជាតក ...... ...... ...... ...... ២៨៨
មឃទេវជាតក ...... ...... ...... ...... ២៩១
អដ្ឋកថាមឃទេវជាតក ...... ...... ...... ...... ២៩២
សុខវិហារិជាតក ...... ...... ...... ...... ២៩៧
អដ្ឋកថាសុខវិហារិជាតក ...... ...... ...... ...... ២៩៨

សីលវគ្គ

លក្ខណជាតក ...... ...... ...... ...... ៣០២
អដ្ឋកថាលក្ខណមិគជាតក ...... ...... ...... ...... ៣០៣
និគ្រោធមិគជាតក ...... ...... ...... ...... ៣០៩
អដ្ឋកថានិគ្រោធមិគជាតក ...... ...... ...... ...... ៣១០
កណ្ឌិនជាតក ...... ...... ...... ...... ៣២៦
អដ្ឋកថាកណ្ឌិនជាតក ...... ...... ...... ...... ៣២៧
វាតមិគជាតក ...... ...... ...... ...... ៣៣២
អដ្ឋកថាវាតមិគជាតក ...... ...... ...... ..... ៣៣៣
ខរាទិយជាតក ...... ...... ...... ...... ៣៤០
អដ្ឋកថាខរាទិយជាតក ...... ...... ...... ...... ៣៤១
តិបល្លត្ថមិគជាតក ...... ...... ...... ...... ៣៤៤
អដ្ឋកថាតិបល្លត្ថមិគជាតក ...... ...... ...... ...... ៣៤៥
មាលុតជាតក ...... ...... ...... ...... ៣៥៣
អដ្ឋកថាមាលុតជាតក ...... ...... ...... ...... ៣៥៤
មតកភត្តជាតក ...... ...... ...... ...... ៣៥៧
អដ្ឋកថាមតកភត្តជាតក ...... ...... ...... ...... ៣៥៨
អាយាចិតភត្តជាតក ...... ...... ...... ...... ៣៦៣
អដ្ឋកថាអាយាចិតភត្តជាតក ...... ...... ...... ...... ៣៦៤

នឡបានជាតក ...... ...... ...... ...... ៣៦៦

អដ្ឋកថានឡបានជាតក ...... ...... ...... ...... ៣៦៧

### កុរុង្គវគ្គ

កុរុង្គមិគជាតក ...... ...... ...... ...... ៣៧២

អដ្ឋកថាកុរុង្គមិគជាតក ...... ...... ...... ...... ៣៧៣

កុក្កុរជាតក ...... ...... ...... ...... ៣៧៧

អដ្ឋកថាកុក្កុរជាតក ...... ...... ...... ...... ៣៧៨

ភោជាជានីយជាតក ...... ...... ...... ...... ៣៨៥

អដ្ឋកថាភោជាជានីយជាតក ...... ...... ...... ...... ៣៨៦

អាជញ្ញជាតក ...... ...... ...... ..... ៣៩១

អដ្ឋកថាអាជញ្ញជាតក ...... ...... ...... ..... ៣៩២

តិត្ថជាតក ...... ...... ...... ..... ៣៩៥

អដ្ឋកថាតិត្ថជាតក ...... ...... ...... ...... ៣៩៦

មហិឡាមុខជាតក ...... ...... ...... ...... ៤០៣

អដ្ឋកថាមហិឡាមុខជាតក ...... ...... ...... ...... ៤០៤

អភិណ្ហជាតក ...... ...... ...... ...... ៤១០

អដ្ឋកថាអភិណ្ហជាតក ...... ...... ...... ...... ៤១១

នន្ទិវិសាលជាតក ...... ...... ...... ...... ៤១៥

អដ្ឋកថានន្ទិវិសាលជាតក ...... ...... ...... ...... ៤១៦

កណ្ហជាតក ...... ...... ...... ...... ៤២១

អដ្ឋកថាកណ្ហជាតក ...... ...... ...... ...... ៤២២

មុណិកជាតក ...... ...... ...... ...... ៤២៨

អដ្ឋកថា មុណិកជាតក ...... ...... ...... ...... ៤២៩

## កុលាវកវគ្គ


កុលាវកជាតក ...... ...... ...... ...... ៤៣៣

អដ្ឋកថាកុលាវកជាតក ...... ...... ...... ...... ៤៣៤

នច្ចជាតក ...... ...... ...... ...... ៤៤៩

អដ្ឋកថានច្ចជាតក ...... ...... ...... ...... ៤៥០

សម្មោទមានជាតក ...... ...... ...... ...... ៤៥៤

អដ្ឋកថាសម្មោទមានជាតក ...... ...... ...... ...... ៤៥៥

មច្ឆជាតក ...... ...... ...... ...... ៤៥៩

អដ្ឋកថាមច្ឆជាតក ...... ...... ...... ...... ៤៦០

វដ្ដកជាតក ...... ...... ...... ...... ៤៦៤

អដ្ឋកថាវដ្ដកជាតក ...... ...... ...... ...... ៤៦៥

សកុណជាតក ...... ...... ...... ...... ៤៧២

អដ្ឋកថាសកុណជាតក ...... ...... ...... ...... ៤៧៣

តិត្តិរជាតក ...... ...... ...... ...... ៤៧៧

អដ្ឋកថាតិត្តិរជាតក ...... ...... ...... ...... ៤៧៨

ពកជាតក ...... ...... ...... ...... ៤៨៥

អដ្ឋកថាពកជាតក ...... ...... ...... ...... ៤៨៦

នន្ទជាតក ...... ...... ...... ...... ៤៩៤

អដ្ឋកថានន្ទជាតក ...... ...... ...... ...... ៤៩៥

ខទិរង្គារជាតក ...... ...... ...... ...... ៥០០

អដ្ឋកថាខទិរង្គារជាតក ...... ...... ...... ...... ៥០១


## អត្ថកាមវគ្គ


លោសកជាតក ...... ...... ...... ...... ៥១៦

អដ្ឋកថាលោសកជាតក ...... ...... ...... ...... ៥១៧

កបោតកជាតក ...... ...... ...... ...... ៥៣១

អដ្ឋកថាកបោតជាតក ...... ...... ...... ...... ៥៣២

វេឡុកជាតក ...... ...... ...... ...... ៥៣៧

អដ្ឋកថាវេឡុកជាតក ...... ...... ...... ...... ៥៣៨

មកសជាតក ...... ...... ...... ...... ៥៤១

អដ្ឋកថាមកសជាតក ...... ...... ...... ...... ៥៤២

រោហិណីជាតក ...... ...... ...... ...... ៥៤៦

អដ្ឋកថារោហិណិជាតក ...... ...... ...... ...... ៥៤៧

អារាមទូសកជាតក ...... ...... ...... ...... ៥៥០

អដ្ឋកថាអារាមទូសកជាតក ...... ...... ...... ...... ៥៥១

វារុណិទូសកជាតក ...... ...... ...... ...... ៥៥៥

អដ្ឋកថាវារុណិទូសកជាតក ...... ...... ...... ...... ៥៥៦

វេទព្វជាតក ...... ...... ...... ...... ៥៥៩

អដ្ឋកថាវេទព្វជាតក ...... ...... ...... ...... ៥៦០

នក្ខត្តជាតក ...... ...... ...... ...... ៥៦៧

អដ្ឋកថានក្ខត្តជាតក ...... ...... ...... ...... ៥៦៨

ទុម្មេធជាតក ...... ...... ...... ...... ៥៧២

អដ្ឋកថាទុម្មេធជាតក ...... ...... ...... ...... ៥៧៣

**អាសឹសវគ្គ**

អាសឹសវគ្គ ...... ...... ...... ...... ៥៧៨

អដ្ឋកថាអាសឹសវគ្គ ...... ...... ...... ...... ៥៧៩

ចូឡជនកជាតក ...... ...... ...... ...... ៥៩២

អដ្ឋកថាចូឡជនកជាតក ...... ...... ...... ...... ៥៩៣

បុណ្ណបាតិជាតក ...... ...... ...... ..... ៥៩៤

អដ្ឋកថាបុណ្ណបាតិជាតក ...... ...... ...... ...... ៥៩៥

ផលជាតក ...... ...... ...... ...... ៥៩៩

អដ្ឋកថា ផលជាតក ...... ...... ...... ...... ៦០០

បញ្ចាវុធជាតក ...... ...... ...... ...... ៦០៤

អដ្ឋកថាបញ្ចាវុធជាតក ...... ...... ...... ...... ៦០៥

កញ្ចនក្ខន្ធជាតក ...... ...... ...... ...... ៦១២

អដ្ឋកថាកញ្ចនក្ខន្ធជាតក ...... ...... ...... ...... ៦១៣

វានរិន្ទជាតក ...... ...... ...... ...... ៦១៨

អដ្ឋកថាវានរិន្ទជាតក ...... ...... ...... ...... ៦១៩

តយោធម្មជាតក ...... ...... ...... ...... ៦២៤

អដ្ឋកថាតយោធម្មជាតក ...... ...... ...... ...... ៦២៥

ភេរិវាទជាតក ...... ...... ...... ...... ៦២៩

អដ្ឋកថាភេរិវាទកជាតក ...... ...... ...... ...... ៦៣០

សង្ខធមនជាតក ...... ...... ...... ...... ៦៣៣

អដ្ឋកថាសង្ខធមនជាតក ...... ...... ...... ...... ៦៣៤


### ឥត្ថីវគ្គ


អសាតមន្តជាតក ...... ...... ...... ...... ៦៣៦

អដ្ឋកថាអសាតមន្តជាតក ...... ...... ...... ...... ៦៣៧

អណ្ឌភូតជាតក ...... ...... ...... ...... ៦៤៦

អដ្ឋកថាអណ្ឌភូតជាក ...... ...... ...... ...... ៦៤៧

តក្កជាតក ...... ...... ...... ...... ៦៥៨

អដ្ឋកថាតក្កបណ្ឌិតជាតក ...... ...... ...... ...... ៦៥៩

ទុរាជានជាតក ...... ...... ...... ...... ៦៦៦

អដ្ឋកថាទុភជានជាតក ...... ...... ...... ...... ៦៦៧
អនភិរតិជាតក ...... ...... ...... ...... ៦៧១
អដ្ឋកថាអនភិរតិជាតក ...... ...... ...... ...... ៦៧២
មុទុលក្ខណជាតក ...... ...... ...... ...... ៦៧៥
អដ្ឋកថាមុទុលក្ខណជាតក ...... ...... ...... ...... ៦៧៦
ឧច្ឆង្គជាតក ...... ...... ...... ...... ៦៨៤
អដ្ឋកថាឧច្ឆង្គជាតក ...... ...... ...... ...... ៦៨៥
សាកេតជាតក ...... ...... ...... ...... ៦៩០
អដ្ឋកថាសាកេតជាតក ...... ...... ...... ...... ៦៩១
វិសវន្តជាតក ...... ...... ...... ...... ៦៩៤
អដ្ឋកថាវិសវន្តជាតក ...... ...... ...... ...... ៦៩៥
កុទ្ទាលជាតក ...... ...... ...... ...... ៦៩៨
អដ្ឋកថាកុទ្ទាលជាតក ...... ...... ...... ...... ៦៩៩

## វរុណវគ្គ

វរុណជាតក ...... ...... ...... ...... ៧០៧
អដ្ឋកថាវរុណជាតក ...... ...... ...... ...... ៧០៨
សីលវនាគជាតក ...... ...... ...... ..... ៧១៥
អដ្ឋកថាសីលវនាគជាតក ...... ...... ...... ...... ៧១៦
សច្ចង្កិរជាតក ...... ...... ...... ...... ៧២២
អដ្ឋកថាសច្ចង្កិរជាតក ...... ...... ...... ...... ៧២៣
រុក្ខធម្មជាតក ...... ...... ...... ...... ៧៣២
អដ្ឋកថារុក្ខធម្មជាតក ...... ...... ...... ...... ៧៣៣
មច្ឆជាតក ...... ...... ...... ...... ៧៣៧
អដ្ឋកថាមច្ឆជាតក ...... ...... ...... ...... ៧៣៨

អសន្ទិយជាតក ...... ...... ...... ...... ៧៤៤

អដ្ឋកថាអសន្ទិយជាតក ...... ...... ...... ...... ៧៤៥

មហាសុបិនជាតក ...... ...... ...... ...... ៧៤៩

អដ្ឋកថាមហាសុបិនជាតក ...... ...... ...... ..... ៧៥០

ឥល្លិសជាតក ...... ...... ...... ...... ៧៧៤

អដ្ឋកថាឥល្លិសជាតក ...... ...... ...... ...... ៧៧៥

ខរស្សរជាតក ...... ...... ...... ...... ៧៩២

អដ្ឋកថាខរស្សរជាតក ...... ...... ...... ...... ៧៩៣

ភីមសេនជាតក ...... ...... ...... ...... ៧៩៦

អដ្ឋកថាភីមសេនជាតក ...... ...... ...... ...... ៧៩៧

## អបាយិម្ហវគ្គ

សុរាបានជាតក ...... ...... ...... ...... ៨០៥

អដ្ឋកថាសុរាបានជាតក ...... ...... ...... ...... ៨០៦

មិត្តវិន្ទជាតក ...... ...... ...... ...... ៨១៣

អដ្ឋកថា មិត្តវិន្ទជាតក ...... ...... ...... ...... ៨១៤

កាឡកណ្ណិជាតក ...... ...... ...... ...... ៨១៦

អដ្ឋកថាកាឡកណ្ណិជាតក ...... ...... ...... ...... ៨១៧

អត្ថស្សទ្វារជាតក ...... ...... ...... ...... ៨២២

អដ្ឋកថាអត្ថស្សទ្វារជាតក ...... ...... ...... ...... ៨២៣

កិម្បកជាតក ...... ...... ...... ...... ៨២៧

អដ្ឋកថាកឹម្បកជាតក ...... ...... ...... ...... ៨២៨

សីលវីមំសនជាតក ...... ...... ...... ...... ៨៣១

អដ្ឋកថាសីលវីមំសនជាតក ...... ...... ...... ...... ៨៣២

មង្គលជាតក ...... ...... ...... ...... ៨៣៨

អដ្ឋកថាមន្តលជាតក ...... ...... ...... ...... ៨៣៩

សារម្ភជាតក ...... ...... ...... ..... ៨៤៥

អដ្ឋកថាសារម្ភជាតក ...... ...... ...... ...... ៨៤៦

កុហកជាតក ...... ...... ...... ...... ៨៤៨

អដ្ឋកថាកុហកជាតក ...... ...... ...... ...... ៨៤៩

អកតញ្ញូជាតក ...... ...... ...... ...... ៨៥៣

អដ្ឋកថាអកតញ្ញូជាតក ...... ...... ...... ...... ៨៥៤

## លិត្តវគ្គ

លិត្តជាតក ...... ...... ...... ...... ៨៥៨

អដ្ឋកថាលិត្តជាតក ...... ...... ...... ..... ៨៥៩

មហាសារជាតក ...... ...... ...... ...... ៨៦៣

អដ្ឋកថាមហាសារជាតក ...... ...... ...... ...... ៨៦៤

វិស្សាសភោជនជាតក ...... ...... ...... ...... ៨៧៨

អដ្ឋកថាវិស្សាសភោជនជាតក ...... ...... ...... ...... ៨៧៩

លោមហំសជាតក ...... ...... ...... ...... ៨៨៣

អដ្ឋកថាលោមហំសជាតក ...... ...... ...... ...... ៨៨៤

មហាសុទស្សនជាតក ...... ...... ...... ...... ៨៨៩

អដ្ឋកថាមហាសុទស្សនជាតក ...... ...... ...... ...... ៨៩០

តេលបត្តជាតក ...... ...... ...... ...... ៨៩៥

អដ្ឋកថាតេលបត្តជាតក ...... ...... ...... ...... ៨៩៦

នាមសិទ្ធិជាតក ...... ...... ...... ...... ៩១៣

អដ្ឋកថានាមសិទ្ធិជាតក ...... ...... ...... ...... ៩១៤

កូដវាណិជជាតក ...... ...... ...... ...... ៩១៨

អដ្ឋកថាកូដវាណិជជាតក ...... ...... ...... ...... ៩១៩

បរោសហស្សជាតក ...... ...... ...... ...... ៩២៣
អដ្ឋកថាបរោសហស្សជាតក ...... ...... ...... ...... ៩២៤
អសាតរូបជាតក ...... ...... ...... ...... ៩២៨
អដ្ឋកថាអសាតរូបជាតក ...... ...... ...... ...... ៩២៩

### បរោសតវគ្គ

បរោសតជាតក ...... ...... ...... ...... ៩៣៥
អដ្ឋកថាបរោសតជាតក ...... ...... ...... ...... ៩៣៦
បណ្ណិកជាតក ...... ...... ...... ...... ៩៣៧
អដ្ឋកថាបណ្ណិកជាតក ...... ...... ...... ...... ៩៣៨
វេរិជាតក ...... ...... ...... ...... ៩៤២
អដ្ឋកថាវេរិជាតក ...... ...... ...... ...... ៩៤៣
មិត្តវិន្ទជាតក ...... ...... ...... ...... ៩៤៥
អដ្ឋកថាមិត្តវិន្ទជាតក ...... ...... ...... ...... ៩៤៦
ទុព្វលកដ្ឋជាតក ...... ...... ...... ...... ៩៤៨
អដ្ឋកថាទុព្វលកដ្ឋជាតក ...... ...... ...... ...... ៩៤៩
ឧទញ្ចនីជាតក ...... ...... ...... ...... ៩៥២
អដ្ឋកថាឧទញ្ចនីជាតក ...... ...... ...... ...... ៩៥៣
សាលិត្តកជាតក ...... ...... ...... ...... ៩៥៦
អដ្ឋកថាសាលិត្តកជាតក ...... ...... ...... ...... ៩៥៧
ពាហិយជាតក ...... ...... ...... ...... ៩៦២
អដ្ឋកថាពាហិយជាតក ...... ...... ...... ...... ៩៦៣
កណ្ឌកបូវជាតក ...... ...... ...... ...... ៩៦៦
អដ្ឋកថាកណ្ឌកបូវជាតក ...... ...... ...... ...... ៩៦៧
សព្វសំហារកបញ្ហា ...... ...... ...... ...... ៩៧២

អដ្ឋកថាសព្វសំហារកបញ្ហជាតក ...... ...... ...... ..... ៩៧៣

## ហំសិវគ្គ

គទ្រភបញ្ហា ...... ...... ...... ...... ៩៧៤
អដ្ឋកថាគទ្រភបញ្ហជាតក ...... ...... ...... ...... ៩៧៥
អមរាទេវិបញ្ហា ...... ...... ...... ...... ៩៧៦
អដ្ឋកថាអមរាទេវិបញ្ហជាតក ...... ...... ...... ...... ៩៧៧
សិគាលជាតក ...... ...... ...... ...... ៩៧៨
អដ្ឋកថាសិគាលជាតក ...... ...... ...... ...... ៩៧៩
មិតចិន្តិជាតក ...... ...... ...... ...... ៩៨៣
អដ្ឋកថាមិតចិន្តិជាតក ...... ...... ...... ...... ៩៨៤
អនុសាសិកជាតក ...... ...... ...... ...... ៩៨៨
អដ្ឋកថាអនុសាសិកជាតក ...... ...... ...... ...... ៩៨៩
ទុព្វចជាតក ...... ...... ...... ...... ៩៩៣
អដ្ឋកថាទុព្វចជាតក ...... ...... ...... ...... ៩៩៤
តិត្តិរជាតក ...... ...... ...... ...... ៩៩៧
អដ្ឋកថាតិត្តិរជាតក ...... ...... ...... ...... ៩៩៨
វដ្ដកជាតក ...... ...... ...... ...... ១០០១
អដ្ឋកថា វដ្ដកជាតក ...... ...... ...... ...... ១០០២
អកាលរាវិជាតក ...... ...... ...... ...... ១០០៨
អដ្ឋកថាអកាលរាវិជាតក ...... ...... ...... ...... ១០០៩
ពន្ធនមោក្ខជាតក ...... ...... ...... ...... ១០១២
អដ្ឋកថាពន្ធនមោក្ខជាតក ...... ...... ...... ...... ១០១៣

## កុសនាឡិវគ្គ

កុសនាឡិជាតក ...... ...... ...... ...... ១០២១

អដ្ឋកថាកុសនាឡិជាតក ...... ...... ...... ...... ១០២២

ទុម្មេធជាតក ...... ...... ...... ...... ១០២៨

អដ្ឋកថាទុម្មេធជាតក ...... ...... ...... ...... ១០២៩

នន្ទិវិសជាតក ...... ...... ...... ...... ១០៣៤

អដ្ឋកថានន្ទិវិសជាតក ...... ...... ...... ...... ១០៣៥

អម្ពជាតក ...... ...... ...... ...... ១០៤០

អដ្ឋកថាអម្ពជាតក ...... ...... ...... ...... ១០៤១

កដាហកជាតក ...... ...... ...... ...... ១០៤៥

អដ្ឋកថាកដាហកជាតក ...... ...... ...... ...... ១០៤៦

អសិលក្ខណជាតក ...... ...... ...... ...... ១០៥២

អដ្ឋកថាអសិលក្ខណជាតក ...... ...... ...... ...... ១០៥៣

កលណ្ឌុកជាតក ...... ...... ...... ...... ១០៥៩

អដ្ឋកថាកលណ្ឌុកជាតក ...... ...... ...... ...... ១០៦០

មូសិកជាតក ...... ...... ...... ...... ១០៦៣

អដ្ឋកថា មូសិកជាតក ..... ...... ...... ...... ១០៦៤

អគ្គិកជាតក ...... ...... ...... ...... ១០៦៧

អដ្ឋកថាអគ្គិកការទ្វាជជាតក ...... ...... ...... ...... ១០៦៨

កោសិយជាតក ...... ...... ...... ...... ១០៧១

អដ្ឋកថា កោសិយជាតក ...... ...... ...... ...... ១០៧២


## អសម្បទានវគ្គ


អសម្បទានជាតក ...... ...... ...... ...... ១០៧៧

អដ្ឋកថាអសម្បទានជាតក ...... ...... ...... ...... ១០៧៨

បញ្ចភិរុកជាតក ...... ...... ...... ...... ១០៨៥

អដ្ឋកថា បញ្ចភិរុកជាតក ...... ...... ...... ...... ១០៨៦

យតាសនជាតក ...... ...... ...... ...... ១០៩០

អដ្ឋកថាយតាសនជាតក ...... ...... ...... ...... ១០៩១

ឈានសោធនជាតក ...... ...... ...... ...... ១០៩៥

អដ្ឋកថាឈានសោធនជាតក ...... ...... ...... ...... ១០៩៦

ចន្ទាភជាតក ...... ...... ...... ...... ១០៩៩

អដ្ឋកថាចន្ទាភជាតក ...... ...... ...... ...... ១១០០

សុវណ្ណហំសជាតក ...... ...... ...... ...... ១១០២

អដ្ឋកថាសុវណ្ណហំសជាតក ...... ...... ...... ...... ១១០៣

ពព្ពុជាតក ...... ...... ...... ...... ១១០៨

អដ្ឋកថាពព្ពុជាតក ...... ...... ...... ...... ១១០៩

គោធជាតក ...... ...... ...... ...... ១១១៥

អដ្ឋកថា គោធជាតក ...... ...... ...... ...... ១១១៦

ឧភតោភដ្ឋជាតក ...... ...... ...... ...... ១១២០

អដ្ឋកថាឧភតោភដ្ឋជាតក ...... ...... ...... ...... ១១២១

កាកជាតក ...... ...... ...... ...... ១១២៥

អដ្ឋកថាកាកជាតក ...... ...... ...... ...... ១១២៦

ককណ្ឌកវគ្គ

គោធជាតក ...... ...... ...... ...... ១១៣១

អដ្ឋកថា គោធជាតក ...... ...... ...... ...... ១១៣២

សិង្គាលជាតក ...... ...... ...... ...... ១១៣៦

អដ្ឋកថាសិង្គាលជាតក ...... ...... ...... ...... ១១៣៧

វិរោចនជាតក ...... ...... ...... ...... ១១៤០

អដ្ឋកថាវិរោចនជាតក ...... ...... ...... ...... ១១៤១

នង្គុដ្ឋជាតក ...... ...... ...... ...... ១១៤៦

អដ្ឋកថានន្ទិជាតក ...... ...... ...... ...... ១១៤៧

ភេជាតក ...... ...... ...... ...... ១១៥១

អដ្ឋកថាភេជាតក ...... ...... ...... ...... ១១៥២

កាកជាតក ...... ...... ...... ...... ១១៥៥

អដ្ឋកថាសមុទ្ទកាកជាតក ...... ...... ...... ...... ១១៥៦

បុប្ផរត្តជាតក ...... ...... ...... ...... ១១៦១

អដ្ឋកថាបុប្ផរត្តជាតក ...... ...... ...... ...... ១១៦២

សិង្គាលជាតក ...... ...... ...... ...... ១១៦៦

អដ្ឋកថាសិង្គាលជាតក ...... ...... ...... ...... ១១៦៧

ឯកបណ្ណជាតក ...... ...... ...... ...... ១១៧៣

អដ្ឋកថាឯកបណ្ណជាតក ...... ...... ...... ...... ១១៧៤

សញ្ជីវជាតក ...... ...... ...... ...... ១១៨៣

អដ្ឋកថាសញ្ជីវជាតក ...... ...... ...... ...... ១១៨៤